# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ១៤

បាលីប្រែ ២០ - ២១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ
# សុត្តន្តបិដក
## និង
# បបញ្ចសូទនី អដ្ឋកថា
## សេចក្តីប្រែជាភាសាខ្មែរ
# មជ្ឈិមនិកាយ មូលបណ្ណាសក
# សីហនាទវគ្គ បឋមភាគ
# ឱបម្មវគ្គ ទុតិយភាគ

# ១៤
# បាលីប្រែ ២០-២១

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ១៤

# សីហនាទវគ្គ បឋមភាគ

## ចូឡសីហនាទសូត្រទី ១

[ ១៥៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ។ ភិក្ខុទាំងឡាយនោះ បានទទួលភាសិតរបស់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ១៥៤ ] ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) ( គឺ សោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈ ទី ២ ( គឺ សកទាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ( គឺ អនាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ( គឺអរហន្ត ) ក៏មានតែក្នុងសាសនានេះ វាទៈ ( គឺ ទិដ្ឋិ ៦២ ) របស់សាសនាដទៃសូន្យចាក សមណៈទាំងឡាយ ( ដែលស្ថិតនៅក្នុងផលទាំង ៤ ពួក ) និងសមណៈ ទាំងឡាយដទៃ ( ដែលស្ថិតនៅក្នុងមគ្គទាំង ៤ ពួកជាដើម ) ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយចូរបន្លឺនូវសីហនាទដោយប្រពៃយ៉ាងនេះឯងចុះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះរមែងមាន គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ[១]

[១]- តិរ្ថ ប្រែថា កំពង់ សំដៅយកទិដ្ឋិ ៦២ ព្រោះពួកសត្វ តែងឆ្លង តែងជាប់ជំពាក់ក្នុងលទ្ធិទាំងនេះ ។ ពួកអ្នកបួសដែលប្រកាន់លទ្ធិទាំងនេះ ហៅថា តិត្ថិយ ។ តិត្ថិយដទៃ គឺផ្សេងពីពុទ្ធសាសនា ហៅថា អន្យតិត្ថិយ ។

ក្នុងលោកនេះ សមជានិយាយយ៉ាងនេះថា លោកមានអាយុទាំងឡាយបានអ្វីជាគ្រឿងអាង បានអ្វីជាកម្លាំង ដែលជាហេតុឲ្យលោកមានអាយុទាំងឡាយពិចារណាឃើញច្បាស់ក្នុងខ្លួន ហើយពោលយ៉ាងនេះថា សមណៈ ( ទី ១ ) មានតែក្នុងសាសនានេះ សមណៈទី ២ មានតែក្នុងសាសនានេះ សមណៈទី ៣ មានតែក្នុងសាសនានេះ សមណៈទី ៤ មានតែក្នុងសាសនានេះ វាទៈរបស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយ និងសមណៈទាំងឡាយដទៃ ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ មានធម៌ ៤ យ៉ាងដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់បានសម្តែងហើយដល់យើងទាំងឡាយ ជាធម៌នាំយើងទាំងឡាយពិចារណាឃើញច្បាស់ក្នុងខ្លួន ហើយនិយាយយ៉ាងនេះថា សមណៈ ( ទី ១ ) មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី៣ ក៏មានតែក្នុងសាសនានេះ សមណៈទី៤ ក៏មានតែក្នុងសាសនានេះ វាទៈរបស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយ និងសមណៈទាំងឡាយដទៃ ធម៌ទាំង ៤ ប្រការ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ គឺ យើងទាំងឡាយមានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ១ មានសេចក្តីជ្រះថ្លាក្នុងព្រះធម៌ ១ មានការៈជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ១ ពួកសហធម្មិកដែលជាគ្រហស្ថក្តី ជាបព្វជិតក្តី ក៏ជាទីស្រឡាញ់ជាទីពេញចិត្ត ១ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៤ ប្រការ នេះឯងដែលព្រះមានព្រះភាគ

ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់បានសម្តែងហើយដល់យើងទាំងឡាយ ជាធម៌នាំឲ្យយើងទាំងឡាយ ពិចារណាឃើញច្បាស់ក្នុងខ្លួនហើយ និយាយយ៉ាងនេះថា សមណៈ ( ទី ១ ) មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ វាទៈរបស់សាសនាដទៃ សូន្យចាកសមណៈទាំងឡាយ និងសមណៈទាំងឡាយដទៃ ។ ម្នាលភិក្ខុទាំងឡាយ គង់មានហេតុជាទំនងយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយគប្បីនិយាយយ៉ាងនេះថា យើងទាំងឡាយ មានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ដែលជាសាស្តារបស់ពួកយើងដែរ យើងទាំងឡាយមានសេចក្តីជ្រះថ្លាក្នុងព្រះធម៌ ដែលជាធម៌របស់ពួកយើងដែរ យើងទាំងឡាយបានធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ដែលជាសីលរបស់ពួកយើងដែរ ពួកសហធម្មិក គឺ គ្រហស្ថ និងបព្វជិតក៏ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើងទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើយ៉ាងនេះ ពួកលោកនិងពួកយើងមានសេចក្តីប្លែកគ្នាត្រង់ណា មានអធិប្បាយដូចម្តេច មានការធ្វើឲ្យផ្សេងគ្នាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ គង់និយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំង-ឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លាមានតែមួយ ឬមានច្រើន ។ ម្នាលភិក្ខុទាំង-ឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយកាលដែលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ឯទីបំផុតនៃសេចក្តីជ្រះថ្លាមានតែមួយ មិន

មានច្រើនទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះជារបស់បុគ្គលប្រកបដោយរាគៈ ឬជារបស់បុគ្គលប្រាសចាករាគៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិញ្វជក អន្យតិ្ថយ កាលដែលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយទីបំផុតនៃសេចក្ដីជ្រះថ្លានោះ ជារបស់បុគ្គលប្រាសចាករាគៈ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលដែលប្រកបដោយរាគៈទេ ។ អ្នកទាំងឡាយត្រូវសួរថា ទីបំផុតនៃសេចក្ដីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយទោសៈ ឬជារបស់បុគ្គលប្រាសចាកទោសៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិញ្វជកជាអន្យតិ្ថយ កាលដែលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះជារបស់បុគ្គលប្រាសចាកទោសៈ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយទោសៈទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះជារបស់បុគ្គលប្រកបដោយមោហៈ ឬជារបស់បុគ្គលប្រាសចាកមោហៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិញ្វាកជកជាអន្យតិ្ថយ កាលព្យាករឲ្យត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះជារបស់បុគ្គលប្រាសចាកមោហៈ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយមោហៈទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្ដីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយតណ្ហា ឬជារបស់បុគ្គលប្រាសចាកតណ្ហា ។ ម្នាលភិក្ខុទាំងឡាយ ពួក

បរិព្វាជកជាអន្យតិ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រាសចាកតណ្ហា ទីបំផុតនៃសេចក្តីជ្រះថ្លានោះមិនមែនជារបស់បុគ្គលប្រកបដោយតណ្ហាទេ ។ អ្នកទាំង-ឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលប្រកបដោយឧបាទាន ឬជារបស់បុគ្គលមិនមានឧបាទាន ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះជារបស់បុគ្គលមិនមានឧបាទាន ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលប្រកបដោយឧបាទានទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះជារបស់បណ្ឌិត ឬជារបស់បុគ្គលមិនមែនជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យារកយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះជារបស់បណ្ឌិត ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលដែលមិនមែនជាបណ្ឌិតទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលដែលនៅមានត្រេកអរ នៅមានក្រោធ ឬជារបស់បុគ្គលដែលមិនមានត្រេកអរ និងមិនមានក្រោធ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិ្ថិយកាលដែលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមិនមានត្រេកអរ មិនមានក្រោធ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ

មិនមែនជារបស់បុគ្គលនៅមានត្រេកអរ នៅមានក្រោធទេ ។ អ្នកទាំងឡាយត្រូវសួរថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមានបបញ្ចធម៌ ជាទីត្រេកអរ មានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ឬជារបស់បុគ្គលមិនមានបបញ្ចធម៌ ជាទីត្រេកអរ មិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិញ្វាជកជាអន្យតិរ្ថិយ កាលព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ ជារបស់បុគ្គលមិនមានបបញ្ចធម៌ ជាទីត្រេកអរ មិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ទីបំផុតនៃសេចក្តីជ្រះថ្លានោះ មិនមែនជារបស់បុគ្គលមានបបញ្ចធម៌ជាទីត្រេកអរ មានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ទេ ។

[ ១៥៥ ] ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិនេះមាន ២ ប្រការ គឺភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ក៏ពួកសមណៈ ឬព្រាហ្មណ៍ណាមួយជាអ្នកតោងជាប់នឹងភវទិដ្ឋិ ចូលទៅកាន់ភវទិដ្ឋិ ចុះស៊ប់កាន់ភវទិដ្ឋិ ពួកសមណៈ ឬព្រាហ្មណ៍នោះ ក៏ស្អប់ខ្ពើមវិភវទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ជាអ្នកតោងជាប់នៅនឹងវិភវទិដ្ឋិចូលទៅកាន់វិភវទិដ្ឋិ ចុះស៊ប់កាន់វិភវទិដ្ឋិ ពួកសមណៈ ឬព្រាហ្មណ៍នោះ ក៏ស្អប់ខ្ពើមភវទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយមិនដឹងច្បាស់នូវសេចក្តីកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នៃទិដ្ឋិទាំង ២ នេះ នូវសេចក្តីរលាស់ចេញ នូវទិដ្ឋិទាំង ២ នោះផង តាមសេចក្តីពិតទេ តថាគតពោលថា ពួកសមណៈ ឬព្រាហ្មណ៍ទាំង

នោះ ជាអ្នកប្រកបដោយរាគៈ ជាអ្នកប្រកបដោយទោសៈ ជាអ្នកប្រកបដោយមោហៈ ជាអ្នកប្រកបដោយតណ្ហា ជាអ្នកប្រកបដោយឧបាទាន ជាអ្នកល្ងង់ខ្លៅ ជាអ្នកនៅមានត្រេកអរ នៅមានក្រេវក្រោធ ជាអ្នកមានបបញ្ចធម៌ជាទីត្រេកអរ មានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ពួកសមណៈ ឬព្រាហ្មណ៍ទាំងនោះ មិនរួចស្រឡះចាកជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនរួចស្រឡះចាកវដ្តទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក៏ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់នូវសេចក្តីកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផងនៃទិដ្ឋិទាំង ២ នេះ នូវសេចក្តីរលាស់ចេញ ( នូវទិដ្ឋិទាំង ២ នោះ ) ផងតាមសេចក្តីពិត តថាគតពោលថា ពួកសមណៈ ឬព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រាសចាករាគៈ ជាអ្នកប្រាសចាកទោសៈ ជាអ្នកប្រាសចាកមោហៈ ជាអ្នកប្រាសចាកតណ្ហា ជាអ្នកមិនមានឧបាទាន ជាអ្នកចេះដឹង ជាអ្នកមិនមានសេចក្តីត្រេកអរ និងសេចក្តីក្រោធ ជាអ្នកមិនមានបបញ្ចធម៌ជាទីត្រេកអរ មិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ពួកសមណៈ ឬព្រាហ្មណ៍ទាំងនោះ រមែងរួចស្រឡះចាកជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងរួចស្រឡះចាកវដ្តទុក្ខ ។

[ ១៥៦ ] ម្នាលភិក្ខុទាំងឡាយ ឧបាទាន ( សេចក្តីប្រកាន់មាំ ) នេះមាន ៤ ប្រការ ឧបាទាន ៤ តើដូចម្តេច គឺកាមុបាទាន ( សេចក្តីប្រកាន់មាំក្នុងកាម ) ១ ទិដ្ឋុបាទាន ( សេចក្តីប្រកាន់មាំក្នុងទិដ្ឋិ ) ១ សីលព្វតុបាទាន

( សេចក្ដីប្រកាន់មាំក្នុងសីល និងវត្ត ) ១ អត្តវាទុបាទាន ( សេចក្ដីប្រកាន់មាំក្នុងពាក្យពោលថាខ្លួនប្រាណ ) ១ ។ ម្នាលភិក្ខុទាំងឡាយ មានសមណៈព្រាហ្មណ៍ពួកមួយ ប្ដេជ្ញាថា ជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែសមណព្រាហ្មណ៍ទាំងនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន ( ប៉ុណ្ណោះ ) មិនបញ្ញត្តនូវការកំណត់ដឹងនូវទិដ្ឋុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវសីលព្វតុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនបានដឹងច្បាស់នូវហេតុទាំង ៣ ប្រការនេះ តាមសេចក្ដីពិតឡើយ ព្រោះហេតុនោះបានជាពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ ប្ដេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេទាំងនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវទិដ្ឋុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវសីលព្វតុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ប្ដេជ្ញាថា ជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែសមណព្រាហ្មណ៍ទាំងនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវសីលព្វតុបាទាន មិនបញ្ញត្តនូវការកំណត់ដឹងនូវ

អត្តវាទុបាទានទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថាពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ មិនដឹងច្បាស់នូវហេតុទាំង ២ ប្រការនេះតាមពិតទេ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ ប្តេជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទាន បញ្ញត្តតែការកំណត់ដឹងនូវសីលព្វតុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ប្តេជ្ញាថា ជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេទាំងនោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ដោយប្រពៃទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទាន បញ្ញត្តតែការកំណត់ដឹងនូវសីលព្វតុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា ពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ មិនដឹងច្បាស់នូវហេតុមួយប្រការនេះ តាមពិតទេ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ ប្តេជ្ញាថា ជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែពួកគេនោះមិនបញ្ញត្តនូវការកំណត់ដឹងនូវឧបាទានទាំងអស់ទេ បញ្ញត្តតែការកំណត់ដឹងនូវកាមុបាទាន បញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទាន បញ្ញត្តតែការកំណត់ដឹងនូវសីលព្វតុបាទានប៉ុណ្ណោះ មិនបញ្ញត្តនូវការកំណត់ដឹងនូវអត្តវាទុបាទានទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាណាក្នុងសាស្តា

ក្នុងធម្មវិន័យបែបនេះឯង សេចក្តីជ្រះថ្លានោះ មិនហៅថាប្រព្រឹត្តទៅដោយប្រពៃទេ សេចក្តីជ្រះថ្លាក្នុងធម៌ ក៏មិនហៅថា ប្រព្រឹត្តទៅដោយប្រពៃទេ ការធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ក៏មិនហៅថា ប្រព្រឹត្តទៅដោយប្រពៃទេ សេចក្តីស្រឡាញ់ និងសេចក្តីគាប់ចិត្ត ក្នុងសហធម្មិកទាំងឡាយ ក៏មិនហៅថា ប្រព្រឹត្តទៅដោយប្រពៃទេ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ បានជាយ៉ាងនុ៎ះ ព្រោះហេតុតែធម្មវិន័យ ដែលគេពោលហើយមិនត្រឹមត្រូវ ប្រកាសទុកមិនល្អ មិនមែនជាធម៌ស្រោចស្រង់សត្វ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ទុក្ខ ជាជាធម៌ដែលគ្រូមិនមែនជាសម្មាសម្ពុទ្ធសម្តែងទុកដោយពិត ។

[ ១៥៧ ] ម្នាលភិក្ខុទាំងឡាយ ចំណែកព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធប្រាជ្ញាថាជាអ្នកពោលនូវការកំណត់ដឹងនូវឧបាទានទាំងអស់ តែងបញ្ញត្តនូវការកំណត់នូវឧបាទានទាំងអស់ដោយប្រពៃ គឺបញ្ញត្តនូវការកំណត់ដឹងកាមុបាទាន បញ្ញត្តនូវការកំណត់ដឹងទិដ្ឋុបាទាន បញ្ញត្តនូវការកំណត់ដឹងសីលព្វតុបាទាន បញ្ញត្តនូវការកំណត់ដឹងអត្តវាទុបាទាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាណាក្នុងសាស្តា ក្នុងធម្មវិន័យបែបនេះឯង សេចក្តីជ្រះថ្លានោះ ហៅថា ប្រព្រឹត្តទៅដោយប្រពៃ សេចក្តីជ្រះថ្លាក្នុងធម៌ ក៏ហៅថាប្រព្រឹត្តទៅដោយប្រពៃ ការធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ក៏ហៅថាប្រព្រឹត្តទៅដោយប្រពៃ សេចក្តីស្រឡាញ់ពេញចិត្ត ក្នុងសហធម្មិកទាំងឡាយក៏ហៅថា ប្រព្រឹត្តទៅដោយប្រពៃ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុ

ទាំងឡាយ បានជាយ៉ាងនេះ ព្រោះហេតុតែធម្មវិន័យដែលព្រះតថាគតសម្តែង ល្អហើយ ប្រកាសទុកល្អហើយ ជាធម៌ស្រោចស្រង់សត្វ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ទុក្ខ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធសម្តែងទុកហើយដោយពិត ។

[ ១៥៨ ] ម្នាលភិក្ខុទាំងឡាយ ឧបាទានទាំង ៤ នេះឯង មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ ឧបាទានទាំង ៤ នេះ មានតណ្ហាជាហេតុ មានតណ្ហាជាទីកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតណ្ហានេះ មានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ តណ្ហាមានវេទនាជាហេតុ មានវេទនាជាទីកើត មានវេទនាជាកំណើត មានវេទនាជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ ឯវេទនានោះ មានអ្វីជាហេតុ មានអ្វីជាទីកីត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ វេទនា មានផស្សៈជាហេតុ មានផស្សៈជាទីកើត មានផស្សៈជាកំណើត មានផស្សៈ ជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈនេះ តើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ ផស្សៈមានសឡាយតនៈជាហេតុ មានសឡាយតនៈជាទីកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ សឡាយតនៈនេះ តើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ សឡាយតនៈ មាននាមរូបជាហេតុ មាននាមរូបជាទីកើត មាននាមរូបជាកំណើត មាននាមរូបជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ

នាមរូបនេះ តើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ នាមរូបមានវិញ្ញាណជាហេតុ មានវិញ្ញាណជាទីកើត មានវិញ្ញាណជាកំណើត មានវិញ្ញាណជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណនេះ តើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ វិញ្ញាណមានសង្ខារជាហេតុ មានសង្ខារជាទីកើត មានសង្ខារជាកំណើត មានសង្ខារជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយនេះ តើមានអ្វីជាហេតុ មានអ្វីជាទីកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ។ សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ មានអវិជ្ជាជាទីកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើតមុន ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុលះបង់អវិជ្ជាបានហើយ វិជ្ជាក៏កើតឡើង ភិក្ខុនោះលែងប្រកាន់មាំនូវកាមុបាទាន លែងប្រកាន់មាំនូវទិដ្ឋុបាទាន លែងប្រកាន់មាំនូវសីលព្វតុបាទាន លែងប្រកាន់មាំនូវអត្តវាទុបាទាន កាលបើលែងប្រកាន់មាំហើយ ក៏នឹងមិនបានតក់ស្លុត ( ដោយតណ្ហា ) កាលបើមិនតក់ស្លុតហើយ ក៏នឹងរំលត់ ( កិលេស ) ចំពោះខ្លួនឯង ព្រោះអស់ទៅនៃអវិជ្ជា ព្រោះវិជ្ជាកើតឡើងហើយ ដឹងច្បាស់ដូច្នេះថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញនៅចប់ស្រេចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ កិច្ចក្រៅអំពីនេះទៅទៀតមិនមានឡើយ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចូឡសីហនាទសូត្រទី ១ ចប់

# អដ្ឋកថា
# ចូឡសីហនាទសូត្រ

[ ១៥៣ ] ចូឡសីហនាទសូត្រមានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់មកយ៉ាងនេះ ។

ព្រោះចូឡសីហនាទសូត្រនោះ មានការសរុបដល់ការកើតឡើងនៃរឿង ព្រោះដូច្នោះ ខ្ញុំសម្ដែងការសរុបនោះហើយ នឹងពណ៌នាបទ ដោយមិនតាម លំដាប់នៃចូឡសីហនាទសូត្រនោះ ។ រឿងនេះ បានលើកឡើងពោលក្នុងការ កើតឡើងនៃរឿងអ្វី ។

ក្នុងរឿងតិត្ថិយសុបសៅ ព្រោះលាភសក្ការៈជាបច្ច័យ ។ បានឮថា លាភ សក្ការៈធំ បានកើតឡើងដល់ព្រះមានព្រះភាគ ដោយន័យដែលពោលហើយ ក្នុងធម្មទាយាទសូត្រ ។

លោកសន្និវាសនេះ មានប្រមាណ ៤ តាំងនៅហើយ ដោយ ៤ យ៉ាង ដោយអំណាចនៃបុគ្គលទាំងនេះ គឺបុគ្គលមានប្រមាណក្នុងរូប ជ្រះថ្លាក្នុងរូប ១ មានប្រមាណក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេង ១ មានប្រមាណក្នុងការ សៅហ្មង ជ្រះថ្លាក្នុងការសៅហ្មង ១ មានប្រមាណក្នុងធម៌ ជ្រះថ្លាក្នុងធម៌ ១ ។ ការដែលធ្វើឲ្យផ្សេងគ្នានៃបុគ្គលទាំងនោះ ដូច្នេះ ។ បុគ្គលដែលមានប្រមាណ ក្នុងរូប ជ្រះថ្លាក្នុងរូបដូចម្ដេច បុគ្គលពួកខ្លះក្នុងលោកនេះ ឃើញការចម្រើន ឡើង ឬឃើញការចម្រើនក្រៃលែង ឃើញការចម្រើនបរិបូណ៌ ឬឃើញទ្រង់ ទ្រាយ កាន់យកប្រមាណក្នុងរូបនោះហើយ ញុំាងសេចក្ដីជ្រះថ្លាឲ្យកើតឡើង

នេះហៅថា បុគ្គលដែលមានប្រមាណក្នុងរូប ជ្រះថ្លាក្នុងរូប ។ បុគ្គលដែលមានប្រមាណក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេងដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ កាន់យកប្រមាណក្នុងសំឡេងនោះ ដោយពណ៌នារបស់អ្នកដទៃ ដោយការលើកតម្កើងរបស់អ្នកដទៃ ដោយការសរសើររបស់អ្នកដទៃ ដោយបុគ្គលដែលនាំគុណរបស់អ្នកដទៃ ហើយញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង នេះហៅថា បុគ្គលមានប្រមាណក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេង ។ បុគ្គលមានប្រមាណក្នុងការសៅហ្មង ជ្រះថ្លាក្នុងការសៅហ្មងដូចម្តេច បុគ្គលពួកខ្លះក្នុងលោកនេះ ឃើញការសៅហ្មងក្នុងចីវរក្តី ឃើញការសៅហ្មងក្នុងបាត្រក្តី ឃើញការសៅហ្មងក្នុងសេនាសនៈក្តី ឃើញការបំពេញទុក្ករកិរិយាផ្សេងៗ ក្តី ហើយកាន់យកប្រមាណក្នុងការសៅហ្មងនោះ ញុំាងការជ្រះថ្លាឲ្យកើតឡើង នេះហៅថា បុគ្គល ជាអ្នកមានប្រមាណក្នុងការសៅហ្មង ជ្រះថ្លាក្នុងការសៅហ្មង ។ បុគ្គលមានប្រមាណក្នុងធម៌ ជ្រះថ្លាក្នុងធម៌ដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ ឃើញសីល ឬឃើញសមាធិ ឬឃើញបញ្ញាហើយ កាន់យកប្រមាណក្នុងធម៌នោះ ញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង នេះហៅថា បុគ្គលមានប្រមាណក្នុងធម៌ ជ្រះថ្លាក្នុងធម៌ ។

ក្នុងបុគ្គល ៤ ពួកនេះ ចំណែកបុគ្គលមានប្រមាណក្នុងរូប ឃើញការចម្រើនឡើង និងការចម្រើនក្រៃលែង ទ្រង់ទ្រាយ ការបរិបូណ៌របស់ព្រះមានព្រះភាគ ទ្រង់មានព្រះឆវីវណ្ណស្រស់ល្អ ដូចវិចិត្រដោយរតនៈផ្សេងៗ ព្រោះលម្អដោយអនុព្យញ្ជនៈ ៨០ ដូចដំបារមាស ដ៏រុងរឿងដោយពួកផ្កាយ ព្រោះ

ដេរដាសដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងដូចផ្ទៃមេឃដែលភ្លឺច្បាស់ដោយប្រការទាំងពួង ដូច្នោះ មានព្រះសរីរៈមិនមានអ្វីប្រៀបបាន ដូចបារិច្ឆត្តកម្ពស់ ១០០ យោជន៍ មានព្រះសិរីហែហមដោយព្រះរស្មីមានប្រមាណមួយព្យាម កម្ពស់ ១៨ហត្ថ ហើយជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។

ឯបុគ្គលមានប្រមាណក្នុងសំឡេង បានស្តាប់សំឡេង ដែលប្រព្រឹត្តទៅហើយនៃព្រះមានព្រះភាគ ដោយន័យជាដើមថា អស់កាល ៤ អសង្ខេយ្យ និងមួយសែនកប្ប ព្រះមានព្រះភាគទ្រង់បំពេញបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់ធ្វើអង្គបរិច្ចាគ បុត្តទារបរិច្ចាគ រជ្ជបរិច្ចាគ ធនបរិច្ចាគ និងនយនបរិច្ចាគ គឺបរិច្ចាគភ្នែក ហើយជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។

ឯបុគ្គលមានប្រមាណក្នុងការសៅហ្មង ឃើញការសៅហ្មងក្នុងចីវររបស់ព្រះមានព្រះភាគហើយ គិតថា បើព្រះមានព្រះភាគ នៅគ្រប់គ្រងសម្បត្តិ ក៏នឹងទ្រទ្រង់តែសំពត់ដែលធ្វើក្នុងក្រុងកាសី តែព្រះអង្គកាលទ្រង់ផ្នួសហើយ ទ្រង់ត្រេកអរដោយចីវរបង្សុកូល ដែលធ្វើពីសម្បកឈើ ទ្រង់ធ្វើការធ្ងន់ដូច្នេះ រមែងធ្វើការជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។ សូម្បីឃើញការសៅហ្មងក្នុងបាត្រ ហើយគិតថា ព្រះមានព្រះភាគអង្គនេះ កាលទ្រង់គ្រប់គ្រងផ្ទះ បានសោយភោជននៃស្រូវសាលី ដែលមានក្លិនក្រអូប សមគួរដល់ភោជនរបស់ស្តេចចក្រពត្តិ ដោយភាជនៈមាសពណ៌ក្រហមដ៏ប្រសើរ តែកាលទ្រង់ព្រះផ្នួសហើយ ទ្រង់កាន់បាត្រថ្ម បិណ្ឌបាតតាមប្រេក ក្នុងទ្វាររបស់ត្រកូលខ្ពស់ ទ្រង់ត្រេកអរក្នុងដុំបាយដែលបាន ហើយធ្វើការៈធ្ងន់ ដូច្នេះ

រមែងជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។ សូម្បីបានឃើញការសៅហ្មងក្នុងសេនាសនៈហើយ គិតថា ព្រះមានព្រះភាគអង្គនេះ កាលទ្រង់គ្រប់គ្រងផ្ទះមានអ្នកបម្រើ ៣ ពួក ជាបរិវារ សោយរាជ្យសិរីដូចសម្បត្តិទិព្វក្នុងប្រាសាទទាំង ៣ ដែលសមគួរដល់រដូវទាំង ៣ ឥឡូវនេះ ទ្រង់ព្រះផ្នួសហើយ ទ្រង់ត្រេកអរដោយវត្ថុ មានបន្ទះក្តារ ផ្ទាំងថ្ម និងគ្រែឫស្សីជាដើម ក្នុងរុក្ខមូលនិងសេនាសនៈជាដើម ទ្រង់ធ្វើការៈចូន ដូច្នេះ រមែងជ្រះថ្លាក្នុងព្រះសម្មា-សម្ពុទ្ធ ដូច្នេះ ។ បានឃើញការបំពេញទុក្ករកិរិយារបស់ព្រះមានព្រះភាគអង្គនោះហើយ គិតថា ព្រះមានព្រះភាគ ទ្រង់ញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយវត្ថុមានទឹកសណ្តែកបាយស្ងោរ ទឹកសណ្តែកកជមាស និងទឹកហរេណុជាដើមត្រឹមមួយទូកដៃ ក៏ចម្រើនឈានដែលមិនមានប្រមាណ ទ្រង់មិនជាប់ជំពាក់ក្នុងសរីរៈ និងជីវិត អស់កាល ៦ ឆ្នាំ ឱ ព្រះមានព្រះភាគ ទ្រង់ធ្វើកិច្ចដែលធ្វើបានលំបាក ដូច្នេះ រមែងជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។

ឯបុគ្គលមានប្រមាណក្នុងធម៌ ឃើញសីលគុណ សមាធិគុណ បញ្ញាគុណ ឈាន វិមោក្ខ សមាធិសម្បត្តិ សម្បទា ការបរិបូណ៌នៃអភិញ្ញាយមកប្បាដិហារ្យ ទេវោរោហនៈ និងការអស្ចារ្យច្រើនប្រការ មានការទូន្មានបាដិកបុត្រជាដើមរបស់ព្រះមានព្រះភាគហើយ រមែងជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។

បុគ្គលទាំងនោះ កាលជ្រះថ្លាយ៉ាងនេះហើយ រមែងនាំលាភសក្ការៈធំថ្វាយដល់ព្រះមានព្រះភាគ តែលាភសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏សាប

សូន្យទៅ ដូចក្អែកក្នុងពាវេរុជាតក ។ ដូចលោកពោលថា

ជនទាំងឡាយ បានយកសាច់ និងផ្លែឈើបូជាក្អែក ក្នុងដែននោះ ព្រោះ មិនទាន់ឃើញសត្វក្ងោក ជាសត្វមានសិរី មានសំឡេងពីរោះ ។ ក្ងោកជាសត្វបរិបូណ៌ ដោយសំឡេងពីរោះ បានមកដល់ដែនពាវេរុ ក្នុងកាលណា លាភ និងសក្ការៈរបស់ក្អែក ក៏សាបសូន្យក្នុងកាលនោះ ។ ព្រះពុទ្ធជាធម្មរាជ ទ្រង់ធ្វើនូវពន្លឺ មិនទាន់កើតឡើងដរាបណា ពួកជនឯទៀត បានបូជាសមណព្រាហ្មណ៍ដ៏ច្រើនដរាបនោះ ។ ព្រះពុទ្ធព្រះអង្គបរិបូណ៌ដោយសំឡេង បានសម្តែងនូវព្រះធម៌ ក្នុងកាលណា លាភ និងសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏សាបសូន្យអស់ក្នុងកាលនោះ ។

តិរ្ថិយទាំងនោះ សាបសូន្យចាកលាភសក្ការៈយ៉ាងនេះហើយ សូម្បីញុំាងរាត្រីឲ្យភ្លឺត្រឹមតែមួយផ្ទាប់ ឬពីរផ្ទាប់មិនមាន ជាអ្នកសាបសូន្យចាករស្មី ដូចអំពិលអំពែកទាំងឡាយក្នុងវេលាព្រះអាទិត្យរះឡើង ដូច្នោះ ។

អំពិលអំពែកទាំងឡាយ រមែងសម្តែងចេញនូវរស្មី ក្នុងរាត្រីខាងរនោចព្រោះនោះជាវិស័យរបស់អំពិលអំពែកទាំងនោះ ក្នុងវេលាណា ព្រះអាទិត្យដែលដល់ព្រមដោយរស្មីមានឡើង ក្នុងវេលានោះ ពន្លឺរបស់អំពិលអំពែកទាំងឡាយ ក៏សាបសូន្យទៅ យ៉ាងណា សូម្បីតិរ្ថិយទាំងឡាយក្នុងលោកនេះដោយច្រើន ដូចគ្នានឹងអំពិលអំពែក ដូច្នោះ រមែងសម្តែងគុណខុនក្នុងលោកប្រៀបដូចខាងរនោច តែក្នុងវេលាណា ព្រះពុទ្ធមានរស្មី មិនមានបុគ្គលប្រៀប

កើតឡើងក្នុងលោក ក្នុងវេលានោះ តិត្ថិយទាំងឡាយ ក៏អស់រស្មី ដូចអំពិលអំពែកទាំងឡាយ ក្នុងវេលាព្រះអាទិត្យរះឡើង ដូច្នោះ ។

តិត្ថិយទាំងនោះ ជាអ្នកប្រាសចាករស្មីយ៉ាងនេះ សរីរៈដេរដាសដោយរោគរមាស់ និងពកតូចៗ ជាដើម ដល់នូវការសោបសូន្យយ៉ាងក្រៃលែង ទៅរកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងទីប្រជុំរបស់មហាជន ហើយឈរកន្ទក់កន្ទេញក្នុងរវាងផ្លូវខ្លះ ក្នុងច្រកខ្លះ ក្នុងផ្លូវបែកជា ៤ ខ្លះ ក្នុងសាលាប្រជុំខ្លះ ស្រែកប្រកាសផ្សេងៗ យ៉ាងនេះថា នែអ្នកដ៏ចម្រើន សមណគោតមប៉ុណ្ណោះឬជាសមណៈ ពួកយើងមិនមែនជាសមណៈទេឬ សាវ័ករបស់សមណគោតមប៉ុណ្ណោះឬជាសមណៈ សាវ័ករបស់ពួកយើងមិនមែនជាសមណៈទេឬ ទានដែលឲ្យសមណគោតម និងសាវ័ករបស់សមណគោតមនោះ ទើបមានផលច្រើនឬ ទានដែលឲ្យដល់ពួកយើង មិនមានផលច្រើនឬ សមណគោតមក៏ជាសមណៈ ពួកយើងក៏ជាសមណៈ សាវ័ករបស់សមណគោតម ក៏ជាសមណៈ សាវ័ករបស់ពួកយើង ក៏ជាសមណៈ ទានដែលឲ្យដល់សមណ-គោតម និងដល់សាវ័ករបស់សមណគោតមនោះ ក៏មានផលច្រើន ទានដែលឲ្យដល់ពួកយើង និងដល់សាវ័ករបស់ពួកយើង ក៏មានផលច្រើនដែរ មិនមែនឬ អ្នកទាំងឡាយចូរឲ្យ ចូរធ្វើដល់សមណគោតម ដល់សាវ័ករបស់សមណគោតមនោះផង ចូរឲ្យ ចូរធ្វើដល់ពួកយើង និងដល់សាវ័ករបស់ពួកយើងផង សមណគោតមកើតឡើងហើយអស់ថ្ងៃមុនៗ មិនមែនឬ តែពួកយើងកាលកើតឡើងក្នុងលោក ក៏បានកើតហើយ ដូច្នេះ ។ លំដាប់នោះ

បរិស័ទ ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា បានស្តាប់សំឡេងរបស់តិរ្ថិយ ទាំងនោះហើយ ក្រាបទូលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន តិរ្ថិយទាំងឡាយពោលពាក្យនេះ និងពាក្យនេះ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំសម្គាល់ ថា សមណៈមានក្នុងទីដទៃ តាមពាក្យពួកតិរ្ថិយ កាលទ្រង់បដិសេធភាព ជាសមណៈក្នុងអន្យតិរ្ថិយទាំងឡាយ និងកាលទ្រង់អនុញ្ញាតភាពជាសមណៈ ក្នុងសាសនានេះប៉ុណ្ណោះ ទើបត្រាស់ព្រះសូត្រនៃការកើតឡើងរបស់រឿងនេះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សមណៈមានតែក្នុងសាសនានេះប៉ុណ្ណោះ ។

[ ១៥៤ ] ក្នុងបទទាំងនោះ បទថា **ឥធេវ** គឺក្នុងសាសនានេះប៉ុណ្ណោះ ។ ឯការកំណត់នេះ គប្បីជ្រាបក្នុងបទដ៏សេស ។ សមណៈទាំងឡាយ មាន សមណៈទី ២ ជាដើម ក៏មានក្នុងសាសនានេះប៉ុណ្ណោះ មិនមានក្នុងទីដទៃ ឡើយ ។ បទថា **សមណោ** បានដល់ ព្រះសោតាបន្ន ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈដូចម្តេច ម្នាល ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់ទៅនៃសំយោជនៈ ៣ ជា សោតាបន្ន មានការមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានការត្រាស់ ដឹងជាទីទៅខាងមុខ ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈ ។ សកទាគាមី ឈ្មោះថា សមណៈទី ២ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ២ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ជាសកទាគាមី ព្រោះសំយោជនៈ ៣ អស់ទៅ ព្រោះភាព

ដែលរាគៈ ទោសៈ និងមោហៈស្រាលស្តើង ត្រឡប់មកកាន់លោកនេះម្តងប៉ុណ្ណោះ នឹងធ្វើទីបំផុតនៃទុក្ខបាន ម្នាលភិក្ខុទាំងឡាយ នេះសមណៈទី ២ ដូច្នេះ ។ ព្រះអនាគាមី ឈ្មោះថា សមណៈទី ៣ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ៣ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះការអស់ទៅនៃសំយោជនៈខាងក្រោម ៥ ជាឱបបាតិកៈ បរិនិព្វានក្នុងភពនោះ មិនវិលត្រឡប់មកអំពីលោកនោះ ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈទី ៣ ។ ព្រះអរហន្តឈ្មោះថា សមណៈទី ៤ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ៤ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយអភិញ្ញារបស់ខ្លួនឯង ចូលដល់ក្នុងទិដ្ឋធម៌ ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈទី ៤ ។ លោកបំណងយកសមណៈដែលតាំងនៅក្នុងផល ៤ ក្នុងទីនេះឯង ដោយប្រការដូច្នេះ ។ បទថា **សុញ្ញា** បានដល់ ទំនេរ គឺទទេ ។ បទថា **បរប្បវាទា** សេចក្តីថា វាទៈថា ទៀង ៤ វាទៈថា ទៀងដោយចំណែកខ្លះ ៤ វាទៈថា មានទីបំផុតនិងមិនមានទីបំផុត ៤ វាទៈដែលហាមការមិនស្លាប់ ៤ វាទៈដែលកើតឡើងចំពោះ ២ សញ្ញីវាទ ១៦ អសញ្ញីវាទ ៨ នេវសញ្ញីនាសញ្ញីវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ ទាំងអស់ដូចពោលមកនេះ មកហើយក្នុងព្រហ្មជាលសូត្រ វាទៈរបស់ពាហិរៈដទៃក្រៅអំពីនេះ ៦២ ឈ្មោះថា បរប្បវាទ ។

វាទៈទាំងអស់នោះ សោះសូន្យទទេចាកសមណៈដែលតាំងនៅក្នុងផលទាំង ៤ នេះ ។ វាទៈទាំងនោះ មិនមានក្នុងសមណៈនោះ វាទៈទាំងនោះមិនមានតែម្យ៉ាងក៏ទេ តែសូន្យចាកសមណៈទាំងនោះឯង ។ ម្យ៉ាងទៀត សូន្យចាកសមណៈ ១២ នោះឯង គឺសមណៈដែលតាំងនៅក្នុងមគ្គ ៤ ខ្វះ សមណៈដែលជាវិបស្សកៈ ដែលប្រារព្ធដើម្បីប្រយោជន៍ដល់មគ្គ ៤ ខ្វះ ។

ព្រះមានព្រះភាគ ទ្រង់សំដៅដល់សេចក្តីនេះឯង ទើបត្រាស់ក្នុងមហាបរិនិព្វានសូត្រថា

ម្នាលសុភទ្ទ កាលតថាគតមានវ័យ ២៩ ឆ្នាំ បានបួសហើយ ជាអ្នកស្វែងរកនូវកុសល ( សព្វញ្ញុតញ្ញាណ ) ម្នាលសុភទ្ទ កាលណាបើតថាគតបួសបានជាង ៥០ ឆ្នាំហើយ ញ៉ាំងប្រទេស គឺវិបស្សនា មគ្គ ឲ្យប្រព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹង គឺអរិយមគ្គ ព្រោះហេតុនោះ សមណៈខាងក្រៅអំពីសាសនានៃតថាគតនេះ មិនមានឡើយ ។

សមណៈទី ២ ក៏មិនមាន សមណៈទី ៤ ក៏មិនមាន លទ្ធិរបស់សាស្តាដទៃទទេចាកសមណៈដែលដឹងទូទៅ ។ លោកបំណងយកអ្នកប្រារព្ធវិបស្សនាថា បទេសវត្តី ក្នុងមហាបរិនិព្វានសូត្រនោះ ព្រោះដូច្នោះ ទ្រង់ធ្វើបុគ្គលអ្នកប្រារព្ធវិបស្សនាដើម្បីសោតាបត្តិមគ្គ ដែលតាំងនៅក្នុងមគ្គ តាំងនៅក្នុងផលទាំង ៣ ដូចពោលចូលគ្នា ហើយត្រាស់ថា សូម្បីសមណៈក៏មិនមានដូច្នេះ ទ្រង់ធ្វើបុគ្គលអ្នកប្រារព្ធវិបស្សនា ដើម្បីសកទាគាមិមគ្គដែលតាំងនៅក្នុងមគ្គ តាំងនៅក្នុងផលទាំង ៣ ដូចពោលចូលជាមួយគ្នា ត្រាស់ថា សមណៈ

ទី ២ ក៏មិនមាន ។ ក្នុងបទទាំង ២ នេះ ក៏មានន័យនេះដូចគ្នា ។ សមណៈទាំងនោះ មិនមានក្នុងលទ្ធិដទៃ ព្រោះហេតុអ្វី ព្រោះលទ្ធិដទៃនោះ មិនមានខេត្ត ។ គ្រាប់ស្ពៃរមែងមិនតាំងនៅលើចុងដែកស្រួច ភ្លើងមិនឆេះលើទឹក ពូជទាំងឡាយមិនដុះលើថ្ម យ៉ាងណា សមណៈទាំងនេះ រមែងមិនកើតក្នុងលទ្ធិតិរ្ថិយ ខាងក្រៅយ៉ាងនោះដូចគ្នា ។ ក្នុងសាសនានេះប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រោះសាសនានេះមានខេត្តល្អ ។ លទ្ធិតិរ្ថិយមិនមានខេត្ត សាសនានេះមានខេត្ត នេះគប្បីជ្រាបដោយការមិនមាន និងការមានអរិយមគ្គ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលសុភទ្ទ មគ្គមានអង្គ ៨ ដ៏ប្រសើរ ដែលបុគ្គលមិនបានក្នុងធម្មវិន័យណា សូម្បីសមណៈក៏មិនបានក្នុងធម្មវិន័យនោះ សមណៈទី ២ ក៏មិនបានក្នុងធម្មវិន័យនោះ សមណៈទី ៣ ក៏មិនបានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក៏មិនបានក្នុងធម្មវិន័យនោះ ម្នាលសុភទ្ទ មគ្គមានអង្គ ៨ ដ៏ប្រសើរ រមែងបានក្នុងធម្មវិន័យណា សមណៈ ( ទី ១ ) រមែងបានក្នុងធម្មវិន័យនោះ សមណៈទី ២ ក៏រមែងបានក្នុងធម្មវិន័យនោះ ។បេ។ សមណៈទី ៤ ក៏រមែងបានក្នុងធម្មវិន័យនោះ ម្នាលសុភទ្ទ អរិយមគ្គមានអង្គ ៨ មិនមានក្នុងធម្មវិន័យណា សមណៈទី ១ ក្តី មិនមានក្នុងធម្មវិន័យនោះ ... សមណៈទី ៤ ក្តី ក៏មិនមានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈទី ១ ក៏មានតែក្នុងសាសនានេះ ... សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ ( វាទៈនៃគ្រូដទៃ ) អំពីសម្នាក់នៃបុគ្គលដទៃ រមែង

សូន្យចាកពួកសមណៈ ( នេះ ) ដូច្នេះ ។ ព្រោះលទ្ធិតិរ្ថិយមិនមានខេត្ត សាសនាមានខេត្តយ៉ាងនេះ ព្រោះដូច្នោះ កេសរសីហៈ មានពន្លឺធៀបធ្មាត់ ជាស្តេចម្រឹគ មានជើងមុខ និងជើងក្រោយក្រហមចាស់ រមែងមិនអាស្រ័យ នៅក្នុងព្រៃខ្មោច ឬគំនរសំរាម តែងចូលទៅកាន់ហិមពាន្ត ដែលមានទំហំ ៣០០០ យោជន៍ នៅក្នុងគុហាកែវមណី យ៉ាងណា ។ ស្តេចដំរីឆទ្ទន្ត រមែងមិនកើតក្នុងត្រកូលដំរី ៩ មានត្រកូលដំរីឈ្មោះគោចរិយៈជាដើម តែ កើតក្នុងត្រកូលដំរីឆទ្ទន្តប៉ុណ្ណោះ យ៉ាងណា ។ ស្តេចសេះវលាហកៈ មិន កើតក្នុងត្រកូលលា ឬក្នុងត្រកូលអូដ្ឋ តែកើតក្នុងត្រកូលសេះសិន្ធព ត្រង់ ច្រាំងស្ទឹងសិន្ធុប៉ុណ្ណោះ យ៉ាងណា ។ មណីរតន៍ដែលនាំការពេញចិត្ត ឲ្យ ទ្រព្យដែលបំណងគ្រប់យ៉ាង រមែងមិនកើតក្នុងគំនរសំរាម ឬក្នុងភ្នំ មានភ្នំដី ជាដើមឡើយ រមែងកើតក្នុងចន្លោះភ្នំវិបុលបព៌តប៉ុណ្ណោះ យ៉ាងណា ។ ស្តេច ត្រីឈ្មោះតិមិរមិង្គល រមែងមិនកើតក្នុងអណ្តូង និងស្រះបោក្ខរណីតូចៗ រមែង កើតក្នុងមហាសមុទ្រ ដែលមានជម្រៅ ៨ ម៉ឺន ៤ ពាន់យោជន៍ប៉ុណ្ណោះ យ៉ាងណា ។ ស្តេចគ្រុឌ ទំហំ ១៥០ យោជន៍ រមែងមិនអាស្រ័យនៅក្នុង ព្រៃ មានព្រៃល្ហុងខ្វងជាដើម ត្រង់ទីជិតទ្វារស្រុក តែហើរឆ្លងមហាសមុទ្រ ហើយ អាស្រ័យនៅក្នុងសិម្ពលិទហវនប៉ុណ្ណោះ យ៉ាងណា ។ ស្តេចហង្ស មាសធតរដ្ឋ មិនអាស្រ័យនៅក្នុងទីទាំងឡាយ មានអណ្តូងជាដើម ត្រង់ទីជិត ទ្វារស្រុក តែងមានហង្ស ៩ ម៉ឺនជាបរិវារ អាស្រ័យនៅក្នុងភ្នំចិត្តកូដបព៌ត ប៉ុណ្ណោះ យ៉ាងណា ។ ស្តេចចក្រពត្តិដ៏ជាធំក្នុងទ្វីប ៤ រមែងមិនកើតក្នុងត្រកូល

ទាប តែរមែងកើតក្នុងត្រកូលក្សត្រ ដែលមិនលាយឡំប៉ុណ្ណោះ យ៉ាងណា ក្នុងសមណៈទាំងនេះ សូម្បីសមណៈទី ១ ក៏មិនកើតក្នុងលទ្ធិរបស់អន្យ-តិរ្ថិយ តែរមែងកើតក្នុងព្រះពុទ្ធសាសនាដែលហែហមដោយអរិយមគ្គប៉ុណ្ណោះ ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ សមណៈមានក្នុងសាសនានេះប៉ុណ្ណោះ ។បេ។ លទ្ធិរបស់សាស្តាដទៃ សោះសូន្យទទេចាកសមណៈទាំងឡាយ ដែលដឹងទូទៅ ដូច្នេះ ។

បទថា **សម្មា** ក្នុងបទថា **សម្មា សីហនាទំ នទថ** នោះ បានដល់ ដោយហេតុ ដោយន័យ ដោយការណ៍ ។ បទថា **សីហនាទំ** គឺការបន្លឺដ៏ប្រសើរបំផុត គឺបន្លឺមិនគួរខ្លាច ការបន្លឺដែលមិនជាប់ជំពាក់ ។ ក៏ព្រោះភាពដែលសមណៈទាំង ៤ នេះ មាននៅក្នុងសាសនានេះប៉ុណ្ណោះ ការបន្លឺនេះ ជាការបន្លឺដ៏ឧត្តម ឈ្មោះថា ការបន្លឺដ៏ប្រសើរបំផុត ។ ការបន្លឺរបស់ភិក្ខុដែលពោលថា សមណៈទាំងនេះ មានក្នុងសាសនានេះប៉ុណ្ណោះ ឈ្មោះថា បន្លឺដែលមិនគួរខ្លាច ព្រោះភ័យ ឬការស្រៀវខ្លាចអំពីទីដទៃមិនមាន ។ ការបន្លឺថាសមណៈទាំងនេះ មាននៅក្នុងសាសនារបស់ពួកយើង ឈ្មោះថា ការបន្លឺមិនជាប់ជំពាក់ ព្រោះភាពដែលបណ្តាមេលទ្ធិទាំងឡាយ មានបូរណៈជាដើម សូម្បីតែម្នាក់ ក៏មិនអាចដើម្បីនឹងក្រោកឡើងពោលបាន ។ ដោយហេតុនោះ ទើបលោកពោលថា បទថា **សីហនាទំ** គឺការបន្លឺដែលប្រសើរបំផុត គឺការបន្លឺដែលមិនគួរខ្លាច ការបន្លឺដែលមិនជាប់ជំពាក់ ដូច្នេះ ។ បទថា **ឋានំ ខោ បនេតំ វិជ្ជតិ** សេចក្តីថា ការណ៍នេះឯងមាន ។ បទថា **យំ អញ្ញតិត្ថិយា**

*គឺពួកអន្យតិរ្ថិយដោយការណ៍ណា ។ ម្យ៉ាងទៀត គប្បីជ្រាបតិត្ថ គប្បីជ្រាប តិត្ថករ គប្បីជ្រាបតិរ្ថិយ គប្បីជ្រាបតិរ្ថិយសាវកក្នុងទីនេះ ។ ទិដ្ឋិ ៦២ យ៉ាង ឈ្មោះថា តិត្ថ ។ សត្វទាំងឡាយរមែងឆ្លង រមែងអណ្តែតទៅ រមែងធ្វើការ ផុសឡើង លិចចុះ ក្នុងកំពង់នោះ ព្រោះដូច្នោះ ទើបហៅថា* **តិត្ថ** *ប្រែថា ជាទីឆ្លងរបស់សត្វទាំងឡាយ ។ ការដែលឲ្យទិដ្ឋិទាំងនោះកើតឡើង ឈ្មោះ ថា* **តិត្ថករ** *ប្រែថា មេលទ្ធិ ។ បុគ្គលកាន់លទ្ធិរបស់មេលទ្ធិនោះ ហើយ បួស ឈ្មោះថា* **តិត្ថិយ** ។ *បុគ្គលឲ្យបច្ច័យដល់តិរ្ថិយទាំងនោះ គប្បីជ្រាបថា* **តិត្ថិយសាវក** *ប្រែថា សាវករបស់តិរ្ថិយ ។ បុគ្គលលះការជាប់ជំពាក់ក្នុង ឃរាវាស ហើយដល់នូវការបួស ឈ្មោះថា* **បរិព្វាជក** ។ *ទីពឹង ទីតាំងនៅ ការទំនុកបម្រុង ឈ្មោះថា* **អស្សាស** ។ *កម្លាំង ឈ្មោះថា* **ពល** ។ *បទថា* **យេន តុម្ហេ** *សេចក្តីថា ពួកអ្នកចូរពោលយ៉ាងនេះ ដោយអស្សាសៈ ឬពល ណា ។ ក្នុងពាក្យនេះថា លោកដ៏មានអាយុទាំងឡាយ ធម៌ ៤ ប្រការ ដែលព្រះមានព្រះភាគអង្គនោះ ដឹង ឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធត្រាស់ ហើយ នៅមាន ដូច្នេះ ។*

*មានអត្ថដោយសង្ខេប ដូច្នេះ ។ ព្រះមានព្រះភាគអង្គនោះ បំពេញបារមី ៣០ កម្ចាត់កិលេសទាំងពួង ត្រាស់ដឹងដោយប្រពៃក្រៃលែង នូវសម្មាសម្ពោធិ ដ៏កំពូល ព្រះមានព្រះភាគអង្គនោះ ដឹងអាសយានុសយរបស់សត្វនោះៗ ឃើញធម៌ដែលគួរដឹងទាំងអស់ ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃ ដូច្នោះ ។ ម្យ៉ាងទៀត ទ្រង់ដឹងដោយញាណទាំងឡាយ មានបុព្វេនិវាសញ្ញាណជាដើម*

ទ្រង់ឃើញដោយទិព្វចក្ខុ ។ ម្យ៉ាងទៀត ទ្រង់ដឹងដោយវិជ្ជា ៣ ឬអភិញ្ញា ៦ ទ្រង់ឃើញដោយសមន្តចក្ខុ ដែលមិនទើសទាក់ក្នុងទីទាំងពួង ទ្រង់ដឹងដោយបញ្ញាដែលអាចដឹងធម៌ទាំងពួង ទ្រង់ឃើញរូបទាំងឡាយ កន្លងចក្ខុវិស័យរបស់សត្វទាំងពួង ដែលនៅក្នុងកំពែងជាដើម ដោយមំសចក្ខុដ៏បរិសុទ្ធក្រៃលែង ទ្រង់ដឹងដោយបដិវេធប្បញ្ញា ដែលជាបទដ្ឋាននៃសមាធិ ដែលញុំាងប្រយោជន៍ខ្លួនឲ្យសម្រេច ទ្រង់ឃើញដោយទេសនាបញ្ញា ដែលជាបទដ្ឋាននៃករុណា ដែលញុំាងប្រយោជន៍អ្នកដទៃឲ្យសម្រេច ។ ឈ្មោះថា ជាព្រះអរហន្ត ព្រោះភាពដែលកិលេសជាសត្រូវទាំងឡាយ ទ្រង់លះបានហើយ និងព្រោះភាវៈដែលព្រះអង្គ ជាអ្នកសមគួរដល់បច្ច័យជាដើម ។ ឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះសច្ចៈទាំងឡាយ ក៏ព្រះអង្គត្រាស់ដឹងហើយ ដោយប្រពៃ និងដោយព្រះអង្គឯង ។ ម្យ៉ាងទៀត ទ្រង់ដឹងធម៌ដែលប្រកបដោយអន្តរាយទាំងឡាយ ទ្រង់ឃើញធម៌ដែលជាគ្រឿងនាំសត្វចេញចាកទុក្ខទាំងឡាយ ឈ្មោះថាជា **ព្រះអរហន្ត** ព្រោះសត្រូវ គឺកិលេសទាំងឡាយ ព្រះអង្គលះបានហើយ ។ ឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះធម៌ទាំងពួងព្រះអង្គត្រាស់ដឹងហើយដោយព្រះអង្គឯង ដែលមហាជនលើកតម្កើងហើយដោយអាការ ៤ ដោយអំណាចនៃវេសារជ្ជៈ ៤ បានត្រាស់ធម៌ ៤ ដោយប្រការដូច្នេះ ។ ពួកយើងឃើញធម៌ទាំងនេះក្នុងខ្លួន ចូរពោលយ៉ាងនេះ ចូរកុំពោលដល់ការទំនុកបម្រុងការជួយស្រោចស្រង់ ឬកម្លាំងកាយរបស់ព្រះរាជា និងរាជមហាមាត្យជាដើម ។ បទថា **សត្ថរិ បសាទោ** បានដល់ សេចក្ដីជ្រះថ្លាដែលកើតដល់បុគ្គលវពុក

*ដល់ពុទ្ធគុណ ដោយន័យថា* **ឥតិបិ សោ ភគវា អរហំ** *ជាដើម ។ បទថា* **ធម្មេ បសាទោ** *បានដល់ ការជ្រះថ្លាដែលកើតឡើងដល់បុគ្គលរឭកដល់ធម្មគុណ ដោយន័យថា* **ស្វាក្ខាតោ ភគវតា ធម្មោ** *ជាដើម ។ បទថា* **សីលេសុ បរិបូរការិតា** *គឺភាពជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយដែលព្រះអរិយៈប្រាថ្នាហើយ ។ សីល ៥ ឈ្មោះថា* **អរិយកន្តសីល** *ពិតហើយ អរិយសាវកសូម្បីនៅក្នុងអន្តរភព កាលមិនដឹងការដែលខ្លួនជាព្រះអរិយៈ ក៏មិនកន្លងសីលទាំង ៥ នោះ បើមានបុគ្គលណា គប្បីពោលនឹងព្រះអរិយសាវកនោះថា អ្នកចូរទទួលយករាជសម្បត្តិរបស់ស្តេចចក្រពត្តិទាំងអស់នេះ ហើយចូរផ្តាច់ជីវិតរុយតូច ដូច្នេះ ។ ព្រះអរិយសាវកគប្បីធ្វើតាមពាក្យរបស់បុគ្គលនោះ មិនមែនជាឋានៈឡើយ ។ សីលទាំងឡាយជាទីប្រាថ្នា គឺជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ព្រះអរិយៈទាំងឡាយដោយប្រការដូច្នេះ ទ្រង់សំដៅដល់សីលទាំងនោះ ទើបត្រាស់ថា ភាពជាអ្នកបរិបូណ៌ក្នុងសីលទាំងឡាយ ដូច្នេះ ។ បទថា* **សហធម្មិកា ខោ បន** *បានដល់ បុគ្គលមានប្រក្រតីប្រព្រឹត្តធម៌រួមគ្នា ៧ ពួកនោះ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកា ។ ពិតហើយ ក្នុងសហធម្មចារីទាំងនោះ ភិក្ខុ ឈ្មោះថា ប្រព្រឹត្តធម៌រួមជាមួយភិក្ខុទាំងឡាយព្រោះជាអ្នកមានសិក្ខាស្មើគ្នា ។ ភិក្ខុនីក៏ប្រព្រឹត្តធម៌រួមជាមួយភិក្ខុនីទាំងឡាយតែមួយដូចគ្នា ។បេ។ ឧបាសិកា ក៏ប្រព្រឹត្តធម៌រួមជាមួយឧបាសិកាទាំងឡាយព្រះសោតាបន្ន ក៏ប្រព្រឹត្តធម៌រួមជាមួយព្រះសោតាបន្នទាំងឡាយ ព្រះសក-*

ទាគាមី ។បេ។ ព្រះអនាគាមី ក៏ប្រព្រឹត្តធម៌រួមជាមួយព្រះអនាគាមីទាំងឡាយ ព្រោះដូច្នោះ សហធម្មចារីទាំងអស់នោះ ហៅថា **សហធម្មិក** ។ ម្យ៉ាងទៀត ក្នុងទីនេះ លោកបំណងយកព្រះអរិយសាវកតែម្យ៉ាង ។ ព្រោះព្រះអរិយ-សាវកទាំងនោះ មិនមានវិវាទក្នុងការឃើញមគ្គសូម្បីក្នុងចន្លោះនៃភព ព្រោះដូច្នោះ ទើបអរិយសាវកទាំងនោះ ឈ្មោះថា **សហធម្មិក** ព្រោះមានប្រក្រតីប្រព្រឹត្តធម៌តែមួយដូចគ្នាដោយពិត ។ លោកសម្តែងការជ្រះថ្លា ដែលកើតដល់អ្នករឭកដល់ព្រះសង្ឃ ដោយន័យថា **សុបដិបន្នោ ភគវតោ សាវក-សង្ឃោ** ដោយបទនេះជាដើម ។ អង្គទាំង ៤ នៃព្រះសោតាបន្ន ឈ្មោះថា លោកសម្តែងហើយ ដោយប្រការមានប្រមាណប៉ុណ្ណេះ ។ បទថា **ឥមេ ខោ នោ អាវុសោ** សេចក្តីថា នៃអ្នកដ៏មានអាយុ ធម៌ទាំង ៤ នេះ ព្រះមានព្រះភាគអង្គនោះត្រាស់ថា ជាការជូនចិត្ត និងជាកម្លាំងរបស់ពួកយើង ។ ពួកយើងសម្លឹងឃើញធម៌ទាំងនេះក្នុងខ្លួន ចូរពោលយ៉ាងនេះ ។ បរិព្វាជកសម្តែងអាងសាស្តាទាំង ៦ មានបូរណកស្សបជាដើម ដោយបទនេះថា បុគ្គលណាជាសាស្តារបស់ពួកយើង ។ ឥឡូវនេះ មានការស្រឡាញ់ដែលអាស្រ័យផ្ទះថា អាចារ្យរបស់ពួកយើង ឧបជ្ឈាយ៍របស់ពួកយើង ក្នុងបុគ្គលទាំងឡាយ មានអាចារ្យ និងឧបជ្ឈាយ៍ជាដើមក្នុងសាសនា ដោយប្រការណា បរិព្វាជកពោលថា ការជ្រះថ្លាក្នុងសាស្តា សំដៅដល់ការស្រឡាញ់ដែលមានសភាពបែបនោះ ព្រះថេរៈពោលថា ព្រោះព្រះសាស្តា មិនមែនជារបស់បុគ្គលណាម្នាក់ មិនមែនជារបស់បុគ្គលពីរនាក់ តែជាព្រះសាស្តាមួយព្រះអង្គ

ប៉ុណ្ណោះរបស់សត្វលោក ព្រមទាំងទេវលោក ព្រោះដូច្នោះ តិរ្ថិយទាំងឡាយ បានចែកសាស្តាចេញជាផ្នែក ដោយបទមួយប៉ុណ្ណោះថា សាស្តារបស់ពួកយើង ឈ្មោះថា ក្លាំងក្លាត់ហើយ ចាញ់ហើយដោយបទនេះឯង ដូច្នេះ ។ ក្នុងបទថា **ធម្មេ បសាទោ** នេះ បរិព្វាជកទាំងឡាយសម្គាល់ថា ទីឃនិកាយរបស់ពួកយើង មជ្ឈិមនិកាយរបស់ពួកយើង ក្នុងសាសនា ក្នុងឥឡូវនេះ យ៉ាងណា រមែងពោលសំដៅដល់សេចក្តីស្រឡាញ់ ដែលអាស្រ័យផ្ទះ ក្នុងបរិយត្តិធម៌រៀងៗខ្លួន ដូច្នោះ ។ បទថា **សីលេសុ** គឺក្នុងសីលទាំងឡាយ មានសីលពពែ សីលគោ សីលចៀម និងសីលឆ្កែជាដើម ។ បរិព្វាជកទាំង-ឡាយពោលសំដៅដល់ការជ្រះថ្លាថា **៩ធ** ក្នុងបទនេះថា **៩ធ នោ អាវុសោ** ដូច្នេះ ។ បទថា **កោ អធិប្បាយោ** បានដល់ ការប្រកបគោលបំណងអ្វី ។ បទថា **យទិទំ** សេចក្តីថា បរិព្វាជកទាំងឡាយ ជាអ្នកមានធុរៈស្មើគ្នា តាំងនៅដោយពាក្យថា លោកគប្បីពោលការដែលធ្វើឲ្យផ្សេងគ្នា រវាងរបស់ពួកលោក និងរបស់ពួកយើងណា សេចក្តីនោះជាការជ្រះថ្លាក្នុងឋានៈ ៤ របស់ពួកលោកមិនមែនឬ ក៏ជាការជ្រះថ្លាក្នុងឋានៈដូចគ្នារបស់ពួកយើងផង មិនមែនឬ ពួកលោក និងពួកយើង ដូចជាពួកតែមួយ ដូចមាសដែលបែកចេញជា ២ ចំណែកហើយ ដូច្នោះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ទម្លាយភាពជាបុគ្គលមានធុរៈស្មើគ្នានោះរបស់បរិព្វាជកទាំងនោះ ទើបត្រាស់ថា **ឯវំ វាទិនោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ឯកា និដ្ឋា** សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកចូរសួរយ៉ាងនេះថា ការសម្រេច

ដែលជាទីបំផុតនៃការជ្រះថ្លានោះ ការសម្រេចនោះមានតែម្យ៉ាង ឬមានច្រើនយ៉ាង ។ ព្រោះឈ្មោះអ្នកបញ្ញត្តការសម្រេចក្នុងលទ្ធិនោះៗ មិនមាន ទើបអសញ្ញីភព ត្រូវកំណត់យ៉ាងនេះថា ព្រហ្មលោកជារបស់ពួកព្រាហ្មណ៍ ការសម្រេច គឺការរលត់មានតែម្យ៉ាង អាភស្សរជារបស់ពួកតាបស សុភកិណ្ហជារបស់ពួកបរិព្វាជក ដោយទីបំផុតជារបស់ពួកអាជីវក ។ ឯអរហត្ត គឺការសម្រេចក្នុងសាសនានេះ ។ ពួកបរិព្វាជកទាំងអស់នោះ រមែងពោលថា អរហត្តប៉ុណ្ណោះ គឺការសម្រេច ។ ម្យ៉ាងទៀត រមែងបញ្ញត្តក្នុងលោកទាំង-ឡាយ មានព្រហ្មលោកជាដើម ដោយអំណាចទិដ្ឋិ ព្រោះដូច្នោះ ទើបបញ្ញត្តការសម្រេច មានតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃលទ្ធិរៀងៗ ខ្លួន ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីសម្រេចនោះ ទើបត្រាស់ថា កាលព្យាករដោយប្រពៃ ដូច្នេះជាដើម ។

ឥឡូវនេះ កាលការសម្រេច ២ យ៉ាង គឺការសម្រេចមានម្យ៉ាងក្នុងសាសនានេះ សម្រាប់ភិក្ខុទាំងឡាយផង ការសម្រេចមានម្យ៉ាងសម្រាប់តិរ្ថិយទាំងឡាយផង តាំងនៅដូចកូនក្តីទាំងឡាយ ដូច្នោះ កាលព្រះមានព្រះភាគទ្រង់សម្តែងវត្តនៃការប្រកបរឿយៗ ទើបត្រាស់ថា ម្នាលអាវុសោទាំងឡាយ ឯការសម្រេចនោះ ជារបស់បុគ្គលមានរាគៈក្តី របស់អ្នកប្រាសចាករាគៈក្តី ដូច្នេះជាដើម ។ ក្នុងទីនេះ ព្រោះធម្មតាការសម្រេចរបស់អ្នកមានកិលេសទាំងឡាយ មានបុគ្គលដែលជោកជាំដោយរាគៈជាដើមមិនមាន ព្រោះដូច្នោះ ទើបទ្រង់សម្តែងព្យាករដោយន័យជាដើមថា ម្នាលអាវុសោទាំងឡាយ ការ

សម្រេចនោះ ជារបស់អ្នកប្រាសចាករាគៈដល់តិរ្ថិយទាំងឡាយ ដែលឃើញទោសនេះថា ប្រៀបដូចផ្ទៃស្រុក និងចចកជាដើម គប្បីមានសោត ក៏គប្បីមានដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វិទ្ទសុនោ** បានដល់ បណ្ឌិត ។ បទថា **អនុរុទ្ធប្បដិវិរុទ្ធស្ស** បានដល់ បុគ្គលត្រេកអរដោយរាគៈ បុគ្គលត្រេកអរដោយកោធៈ ។ ក្នុងបទថា **បបញ្ចារាមស្ស បបញ្ចរតិនោ** នោះ សត្វទាំងឡាយ រមែងត្រេកអរក្នុងបបញ្ចធម៌នោះ ព្រោះដូច្នោះ ទើបបបញ្ចធម៌នោះ ឈ្មោះថា **អារាមោ** ជាទីត្រេកអរ ។ បបញ្ចធម៌ ជាទីត្រេកអររបស់បុគ្គលនោះ ព្រោះដូច្នោះ ទើបបុគ្គលឈ្មោះថា **បបញ្ចារាមោ** ប្រែថា បុគ្គលមានបបញ្ចធម៌ ជាទីត្រេកអរ ។ ការត្រេកអរក្នុងបបញ្ចធម៌ របស់បុគ្គលនោះ ព្រោះដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា **បបញ្ចរតី** បុគ្គលត្រេកអរក្នុងការយឺតយូរ ។ បទថា **បបញ្ចោ** នោះ ជាឈ្មោះរបស់តណ្ហា ទិដ្ឋិ និងមានះ ដែលប្រព្រឹត្តទៅហើយ ដោយភាពជាអាការរបស់បុគ្គលស្រវឹង និងបុគ្គលប្រមាទហើយ ។ ក្នុងទីនេះ លោកបំណងចំពោះតណ្ហា និងទិដ្ឋិ ប៉ុណ្ណោះ ។ កិលេសតែម្យ៉ាងប៉ុណ្ណោះ មកហើយក្នុងឋានៈ ៥ របស់បុគ្គលមានរាគៈជាដើម គប្បីជ្រាបអាការ និងការផ្សេងគ្នានៃកិលេសនោះ ។ លោកកាន់យកកិលេសដោយអំណាចរាគៈ ដែលលាយឡំដោយកាមគុណ ៥ ក្នុងទីដែលលោកពោលថា **សរាគស្ស** ។ កាន់យកកិលេសដោយអំណាចភវតណ្ហា ក្នុងបទថា **សតណ្ហស្ស** ។ កាន់យកកិលេសដោយអំណាចការប្រកាន់ ក្នុងបទថា **សឧបាទានស្ស** ។ កាន់យកកិលេសដោយអំណាចគូ ក្នុងបទថា

**អន្តរុទ្ធប្បដិវិរុទ្ធស្ស** ។ កាន់យកកិលេសដោយអំណាចការសម្តែងការកើតឡើងនៃកិលេសជាគ្រឿងយឺតយូរ ក្នុងបទថា **បបញ្ចរាមស្ស** ។ ម្យ៉ាងទៀត កាន់យកកិលេស ដោយអំណាចអកុសលមូល ក្នុងបទនេះថា **សរាគស្ស** ។ កាន់យកកិលេស ដោយអំណាចឧបាទាន ព្រោះតណ្ហាជាបច្ច័យក្នុងបទនេះថា **សតណ្ហស្ស** ។ បទដ៏សេស ដូចគ្នានឹងបទមុននោះឯង ។ ព្រះថេរៈពោលថា លោកចូរកម្ចាត់យ៉ាងនេះ ព្រោះហេតុអ្វី ព្រោះលោកៈតែមួយប៉ុណ្ណោះ ពោលថា **រាគ** ដោយអំណាចនៃការត្រេកអរ ឈ្មោះថា **តណ្ហា** ដោយអំណាចការធ្វើនូវសេចក្តីប្រាថ្នា ឈ្មោះថា **ឧបាទាន** ដោយអត្ថថា ប្រកាន់ ឈ្មោះថា ការត្រេកអរ និងការមិនត្រេកអរ ដោយអំណាចគូ ឈ្មោះថា **បបញ្ច** ដោយអត្ថថា កើតឡើងនៃកិលេសជាគ្រឿងយឺតយូរ ។

[ ១៥៥ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងទិដ្ឋិវាទដែលជាឫសគល់របស់កិលេសទាំងនេះ ទើបត្រាស់ថា **ទ្វេមា ភិក្ខវេ ទិដ្ឋិយោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ភវទិដ្ឋិ** បានដល់ ការឃើញថាទៀង ។ បទថា **វិភវទិដ្ឋិ** បានដល់ ការឃើញថា ដាច់សូន្យ ។ បទថា **ភវទិដ្ឋិំ អល្លីនា** សេចក្តីថា បុគ្គលអាស្រ័យការឃើញថា ទៀង ដោយអំណាចតណ្ហាទិដ្ឋិ ។ បទថា **ឧបគតា** សេចក្តីថា ចូលដល់ដោយអំណាចតណ្ហាទិដ្ឋិនោះឯង ។ បទថា **អជ្ឈោសិតា** សេចក្តីថា តោងចូលទៅដោយអំណាចតណ្ហាទិដ្ឋិនោះឯង ។ បទថា **វិភវទិដ្ឋិយា តេ បដិវិរុទ្ធា** សេចក្តីថា សមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកមិនត្រេកអរថា ពួកលោកល្ងង់ខ្លៅ

ព្រមទាំងជាអ្នកពោលថាដាច់សូន្យ មិនដឹងថា លោកនេះទៀង លោកនេះមិនដាច់សូន្យ ខ្វល់ខ្វាយក្នុងការឈ្លោះប្រកែកជានិច្ច ។ ក្នុងវារៈទី ២ ក៏មានន័យនេះដូចគ្នា ។ ក្នុងបទមានបទថា **សមុទយញ្ច** ជាដើម ដែនកើតរបស់ទិដ្ឋិទាំងឡាយ មាន ២ យ៉ាង គឺខណិកសមុទយៈ ១ បច្ចយសមុទយៈ ១ ។ ការកើតនៃទិដ្ឋិទាំងឡាយ ឈ្មោះថា **ខណិកសមុទយ** ។ ឋានៈដែលតាំងនៅមិនបាននៃទិដ្ឋិទាំងឡាយ ឈ្មោះថា **បច្ចយសមុទយ** ។ សេចក្ដីនេះដូចម្ដេច គឺខន្ធក្ដី អវិជ្ជាក្ដី ផស្សៈក្ដី សញ្ញាក្ដី វិតក្កក្ដី អយោនិសោមនិការក្ដី បាបមិត្តក្ដី បរតោឃោសក្ដី ចាត់ជាទិដ្ឋិឋានៈ ។ ខន្ធទាំងឡាយជាហេតុ ខន្ធទាំងឡាយជាបច្ច័យនៃការកើតឡើងរបស់ទិដ្ឋិទាំងឡាយ ព្រោះអត្ថថា តាំងឡើងព្រម ។ ខន្ធទាំងឡាយ ឈ្មោះថា **ទិដ្ឋិឋាន** ដោយប្រការដូច្នេះ ។ អវិជ្ជា ផស្សៈ សញ្ញា វិតក្ក អយោនិសោមនសិការ បាបមិត្ត បរតោឃោស ជាបច្ច័យនៃការកើតឡើងរបស់ទិដ្ឋិទាំងឡាយ ព្រោះអត្ថថា តាំងឡើងព្រម ។ បរតោឃោស ឈ្មោះថា **ទិដ្ឋិឋាន** ដោយប្រការដូច្នេះ ។ ការតាំងនៅមិនបាន មាន ២ យ៉ាងប៉ុណ្ណោះ គឺខណិកត្ថង្គម ១ បច្ចយត្ថង្គម ១ ។ ការអស់ទៅ ការវិនាស ការបែក ការបែកធ្លាយ ការមិនទៀង ការសូន្យទៅ ឈ្មោះថា **ខណិកត្ថង្គម** ។ សោតាបត្តិមគ្គ លោកពោលថា ទម្លាយព្រមនូវទិដ្ឋិទាំងឡាយ ។ បទថា **អស្សាទំ** គឺពោលដល់អានិសង្សដែលមានទិដ្ឋិជាមូល អធិប្បាយថា ព្រះសាស្ដាទ្រង់មានទិដ្ឋិណា សាវកទាំងឡាយ ក៏ជាអ្នកមានទិដ្ឋិនោះ សាវកទាំងឡាយ រមែងសក្ការៈ គោរព រាប់អាន បូជា

រមែងបានព្រះសាស្តាទ្រង់មានទិដ្ឋិណា ទិដ្ឋិនោះជាដើមហេតុនៃចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជៈ និងបរិក្ខារទាំងឡាយ ម្នាលភិក្ខុទាំង-ឡាយ នេះជាអានិសង្សដែលប្រកបដោយទិដ្ឋិធម៌នៃទិដ្ឋិ ។ បទថា **អាទីនវំ** បានដល់ ឧបទ្រព ដែលមានការប្រកាន់ដោយទិដ្ឋិជាមូល ។ អាទីនវៈ គឺ ទោសនោះ គប្បីជ្រាបដោយអំណាចនៃវត្តទាំងឡាយ មានវគ្គុលិវត្ត ឧក្កុដិក-បធាន កណ្តកាបស្សយតា បញ្ចាតបតប្បន មរុប្បបាតបតន កេសមស្សុ-លោចន អប្បាណកជ្ឈានជាដើម ។ បទថា **និស្សរណំ** បានដល់ និព្វាន ឈ្មោះថា រលាស់ចោលនូវទិដ្ឋិទាំងឡាយ ។ បទថា **យថាភូតំ នប្បជានន្តិ** សេចក្តីថា សមណៈ ឬព្រាហ្មណ៍ពួកណា មិនដឹងសមុទយៈជាដើមទាំងអស់ នោះតាមសភាវៈ ។ បទថា **ន បរិមុច្ចន្តិ ទុក្ខស្មា** សេចក្តីថា មិនរួចផុត អំពីវដ្តទុក្ខទាំងមូល ។ ដោយបទនេះ ទ្រង់សម្តែងថា ឈ្មោះថា ការ សម្រេចរបស់សមណៈ ឬព្រាហ្មណ៍ទាំងនោះមិនមាន ។ បទថា **បរិមុច្ចន្តិ ទុក្ខស្មា** សេចក្តីថា រមែងរួចផុតចាកវដ្តទុក្ខទាំងមូល ។ ដោយបទនេះ ទ្រង់ តាំងទុកនូវការសម្រេច មានក្នុងសាសនាប៉ុណ្ណោះ ដូចទ្រង់សម្រេចក្តីរបស់ គូវិវាទទាំង ២ ការសម្រេចរបស់សមណៈ ឬព្រាហ្មណ៍ទាំងនោះមាន ដូច្នេះ ។

[ ១៥៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការកាត់នូវទិដ្ឋិ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាទានមាន ៤ ប្រការជាដើម ។ កថា ពោលដោយពិស្តារនៃឧបាទានទាំងនោះ បានពោលហើយ ក្នុងវិសុទ្ធិមគ្គនោះ ឯង ។ បទថា **សព្វុបាទានបរិញ្ញាវាទា បដិជានមានា** សេចក្តីថា ប្តេជ្ញា

យ៉ាងនេះថា យើងទាំងឡាយ រមែងពោលនូវការដឹងសុខ គឺការឈានកន្លងឧបាទានគ្រប់យ៉ាង ។ បទថា **ន សម្មា សព្វុបាទានស្ស បរិញ្ញំ បញ្ញាបេន្តិ** សេចក្តីថា រមែងមិនបញ្ញត្តការឈានកន្លងឧបាទានគ្រប់យ៉ាងដោយជុំវិញ ។ ជនពួកខ្លះ បញ្ញត្តការដឹងសព្វ ត្រឹមតែកាមុបាទាន ជនពួកខ្លះ បញ្ញត្តការដឹងសព្វ ត្រឹមតែទិដ្ឋុបាទាន ជនពួកខ្លះ បញ្ញត្តការដឹងត្រឹមតែសីលព្វតុបាទានប៉ុណ្ណោះ ។ តែបុគ្គលឈ្មោះថា បញ្ញត្តការដឹងសព្វនូវអត្តវាទុបាទានមិនមាន ។ កាលទ្រង់សម្តែងការចែកឧបាទានទាំងនោះ ទើបត្រាស់ថា បញ្ញត្តការដឹងសព្វកាមុបាទាន ដូច្នេះជាដើម ។ ក្នុងឧបាទានទាំងនោះ សមណព្រាហ្មណ៍ទាំងអស់បញ្ញត្តការដឹងកាមុបាទានប៉ុណ្ណោះ ។ សូម្បីការឃើញក្រៅគន្លង ៩៦ ប្រការ គឺ កាមដែលបព្វជិតមិនគប្បីសេព ព្រោះដូច្នោះ ទើបសមណ-ព្រាហ្មណ៍មិនបញ្ញត្តថា បុគ្គលសេពវត្ថុ រមែងគួរធ្វើឲ្យជាកប្បិយប៉ុណ្ណោះហើយ ទើបបញ្ញត្ត ។ បុគ្គលពួកណាសេព បុគ្គលទាំងនោះសេពដោយថេយ្យចិត្ត ។ ព្រោះដូច្នោះ ទើបត្រាស់ថា រមែងបញ្ញត្តថា ការដឹងសព្វនូវកាមុបាទាន ដូច្នេះ ។ ព្រោះសមណព្រាហ្មណ៍ប្រកាន់ថា ទានដែលឲ្យហើយមិនមានផល ដូច្នេះជាដើម រមែងប្រកាន់ថា ការបរិសុទ្ធិដោយសីល ការបរិសុទ្ធិដោយវត្ត មិនមែនបរិសុទ្ធដោយភាវនា ឈ្មោះថា មិនលះបង់អត្តូ-បលទ្ធិ ព្រោះដូច្នោះ ទើបមិនបញ្ញត្តការដឹងសព្វនូវទិដ្ឋុបាទាន អត្តវាទុបាទាន ។ បទថា **តំ កិស្ស ហេតុ** សេចក្តីថា ការមិនបញ្ញត្តនោះ ជាហេតុដូចម្តេចនៃឧបាទានទាំងនោះ គឺព្រោះហេតុអ្វី ។ បទថា **ឋានានិ ហិ តេ ភោន្តោ**

សេចក្តីថា ព្រោះសមណព្រាហ្មណ៍ទាំងនោះ មិនដឹងហេតុ ៣ យ៉ាងនេះ តាមសភាវៈ ។ សមណព្រាហ្មណ៍ពួកណា រមែងដឹងតាមសភាវៈក្នុងបទនោះ ថា ហេតុនៃការបញ្ញត្តការដឹងសព្វ ២ យ៉ាង គឺទិដ្ឋិ និងសីលព្វតនោះគប្បី លះ ទ្រង់សំដៅដល់សមណព្រាហ្មណ៍ទាំងនោះ ទើបត្រាស់ ២ វារៈយ៉ាង ខាងមុខ ។ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកណា ប្រកាន់ថា ទានដែលឲ្យហើយ មានផលដូច្នេះជាដើម សមណព្រាហ្មណ៍ ទាំងនោះ រមែងបញ្ញត្តការដឹងសព្វក្នុងទិដ្ឋុបាទាន ។ ឯជនពួកណាប្រកាន់ថា ការបរិសុទ្ធិដោយសីល ការបរិសុទ្ធិដោយវត្ត ការបរិសុទ្ធដោយការនាទាំង នោះ រមែងបញ្ញត្តការដឹងសព្វ សូម្បីសីលព្វតុបាទាន តែសូម្បីបុគ្គលម្នាក់ មិនអាចដើម្បីបញ្ញត្តការដឹងសព្វ នូវអត្តវាទុបាទានខាងមុខ តិរ្ថិយទាំងឡាយ ដែលបានសមាបត្តិ ៨ ក្តី ជាអ្នកយកដៃស្ទាបព្រះចន្ទ និងព្រះអាទិត្យក្តី រមែងបញ្ញត្តការដឹងសព្វ ៣ យ៉ាង ។ តែមិនអាចដើម្បីដោះនូវអត្តវាទបាន ព្រោះដូច្នោះ ទើបធ្លាក់នៅក្នុងវដ្តៈរឿយៗ នោះឯង ។ តិរ្ថិយទាំងនោះ ដូចគ្នា នឹងទន្សាយរន្ធៀសនឹងផែនដី ។ ឧបមាទាក់ទងនឹងការសន្ទនាអត្តក្នុងទីនេះ ដូច្នេះ ។

បានឮថា ផែនដីពោលនឹងទន្សាយថា នែទន្សាយ ។ ទន្សាយពោលថា នរណាហ្នឹ ។ ផែនដីពោលថា អ្នកសម្រេចឥរិយាបថទាំងអស់ បន្ទោបង់ ឧច្ចារៈ និងបស្សាវៈលើខ្ញុំនោះឯង ហេតុអ្វី ទើបមិនស្គាល់ខ្ញុំ ។ ទន្សាយ ពោលថា អ្នកឃើញខ្ញុំដោយល្អ ការដែលខ្ញុំជាន់ ហាក់ដូចជាពាល់ត្រូវដោយ

ចុងម្រាម ទឹកមូត្រដែលបញ្ចេញមក ក៏មានប្រមាណតិច ករីស គឺលាមក ក៏ត្រឹមតែគ្រាប់ល្មៀង តែដីរ និងសេះជាដើមជាន់ហើយ ក្លាយទៅជាទីជំបស្សាវៈរបស់សត្វទាំងនោះ ក៏មានប្រមាណពេញថ្នាំង ឧច្ចារៈក៏ប្រមាណពេញកំប្រោង ខ្ញុំនឹងលះបង់លោក ទើបលោតទៅកាន់ទីដទៃ ។ តែផែនដីពោលនឹងទន្សាយនោះថា ឱ ទោះអ្នកទៅឆ្ងាយ អ្នកក៏នៅលើខ្ញុំហើយ មិនមែនឬ ។ ទន្សាយនោះស្អប់ផែនដីនោះទៀត ទើបលោតទៅនៅទីដទៃ ។ ទន្សាយលោតហើយលោតទៀត សូម្បីមួយពាន់ឆ្នាំយ៉ាងនេះ ក៏មិនអាចផុតផែនដីបាន តិរ្ថិយទាំងឡាយក៏ដូចគ្នាយ៉ាងនោះ សូម្បីបញ្ញត្តការដឹងសព្វនូវឧបាទានគ្រប់យ៉ាង ក៏រមែងបញ្ញត្តការឈានកន្លងឧបាទាន ៣ យ៉ាង មានកាមុបាទានជាដើមប៉ុណ្ណោះ តែមិនអាចផុតអត្តវាទបាន កាលមិនអាច ទើបធ្លាក់នៅក្នុងវដ្តៈរឿយៗ នោះឯង ។ ដោយប្រការយ៉ាងនេះ តិរ្ថិយទាំងឡាយមិនអាចឈានកន្លងឧបាទានណា ព្រះមានព្រះភាគត្រាស់ដល់វាទៈដែលកាត់ផ្តាច់ទិដ្ឋិ ដោយអំណាចនៃឧបាទាននោះហើយ ឥឡូវនេះ កាលទ្រង់សម្តែងវាទៈកាត់នូវសេចក្តីជ្រះថ្លា ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យបែបនេះឯង ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ធម្មវិនយេ** បានដល់ក្នុងធម៌ និងវិន័យ ។ ទ្រង់សម្តែងសាសនាដែលមិនជាគ្រឿងនាំសត្វចេញចាកទុក្ខដោយបទទាំង ២ ។ បទថា **យោ សត្ថរិ បសាទោ សោ ន សម្មគ្គតោ** សេចក្តីថា សាស្តាក្នុងសាសនាដែលមិនមែនជាគ្រឿងនាំសត្វចេញចាកទុក្ខ ធ្វើកាលកិរិយាហើយ កើតជាសីហៈខ្លះ ខ្លាធំខ្លះ ខ្លាដំបងខ្លះ

ខ្លាឃ្មុំខ្លះ ខ្លារខិនខ្លះ ។ ឯសាវ័កទាំងឡាយរបស់សាស្តានោះ ជាម្រឹគខ្លះ ជ្រូកខ្លះ ទន្សាយខ្លះ ។ សត្វទាំងនោះ មិនធ្វើការអត់ធន់ ឬបំណាងល្អ ឬការអាណិតអាសូរថា សត្វទាំងនេះធ្លាប់ជាឧបដ្ឋាក ជាអ្នកឲ្យបច្ច័យដល់អញសម្លាប់សត្វទាំងនោះហើយ បីតឈាមខ្លះ ស៊ីសាច់ទាំងឡាយខ្លះ មួយប្រការទៀត សាស្តាកើតជាឆ្មា សាវ័កទាំងឡាយកើតជាមាន់ ឬកណ្តុរ លំដាប់នោះឆ្មាក៏មិនធ្វើការអនុគ្រោះ រមែងស៊ីមាន់ ឬកណ្តុរទាំងនោះ ដោយន័យដូចពោលហើយនោះឯង ។ ម្យ៉ាងទៀត សាស្តាជានាយនិរយបាល សាវ័កទាំងឡាយជាសត្វនរក ។ នាយនិរយបាលនោះ មិនធ្វើសេចក្តីអនុគ្រោះថា សត្វទាំងនេះធ្លាប់ឲ្យបច្ច័យដល់អញ រមែងធ្វើកម្មករណៈផ្សេងៗ ដាក់ក្នុងរថដែលក្តៅខ្លាំងខ្លះ ឲ្យឡើងភ្នំភ្លើងខ្លះ ជ្រលក់ក្បាលចូលក្នុងឆ្នាំងលោហៈខ្លះ ប្រកបដោយទុក្ខធម៌ច្រើនយ៉ាង ។ ឬសាវ័កទាំងឡាយស្លាប់ទៅកើតជាសត្វ មានសីហៈជាដើម សាស្តាជាសត្វឯណាមួយ មានម្រឹគជាដើម សត្វទាំងនោះមិនធ្វើការអត់ធន់ បំណាងល្អ ឬអាណិតអាសូរសត្វនោះថា អញធ្លាប់ឧបដ្ឋាកសត្វនេះដោយបច្ច័យ ៤ សត្វនេះធ្លាប់ជាសាស្តារបស់ពួកអញ ដូច្នេះ រមែងឲ្យដល់សេចក្តីវិនាស ដោយន័យដូចពោលហើយនោះឯង ។ ក្នុងសាសនាដែលមិនជាគ្រឿងនាំសត្វចេញចាកទុក្ខ ដោយប្រការដូច្នេះ ។ ការជ្រះថ្លាក្នុងសាស្តាណា ការជ្រះថ្លានោះ មិនទៅហើយដោយប្រពៃ សូម្បីទៅកាន់កាលយ៉ាងណាហើយ នឹងវិនាសខាងក្រោយនោះឯង ។ បទថា **យោ ធម្មេ បសាទោ** សេចក្តីថា ធម្មតាការជ្រះថ្លាក្នុងធម៌ ក្នុងសាសនាដែលមិនជាគ្រឿង

នាំសត្វចេញចាកទុក្ខ ជាការជ្រះថ្លាក្នុងតន្តិធម៌ត្រឹមតែរៀនទន្ទេញ ទ្រទ្រង់ទុក និងប្រាប់ហើយ តែការផុតចាកវដ្ដៈ មិនមានក្នុងការជ្រះថ្លានោះ ព្រោះដូច្នោះ ការជ្រះថ្លាក្នុងធម៌ណា ការជ្រះថ្លានោះ រឹងរឹតតែធ្វើវដ្ដៈឲ្យវែងឆ្ងាយរឿយៗ ព្រោះដូច្នោះ តថាគតពោលថា មិនទៅហើយដោយប្រពៃ គឺមិនទៅហើយដោយសការៈ ។ បទថា **យា សីលេសុ បរិបូរការិតា** សេចក្ដីថា កាលធ្វើឲ្យបរិបូណ៌ដោយអំណាចនៃសីលទាំងឡាយ មានសីលពពៃជាដើម ក្នុងសាស្ដាដែលមិននាំសត្វចេញចាកទុក្ខណា ការធ្វើឲ្យបរិបូណ៌នោះ មិននាំឲ្យដល់នូវការផុតចាកវដ្ដៈ គឺការរលាស់ចេញចាកភពបាន តែកាលដល់ព្រមរមែងនាំមកកាន់កំណើតតិរច្ឆាន ការឲ្យផលរមែងនាំមកកាន់នរក ព្រោះដូច្នោះ តថាគតមិនពោលថា ទៅហើយដោយប្រពៃ ។ បទថា **យា សហធម្មិកេសុ** សេចក្ដីថា ក្នុងសាសនាដែលមិនជាគ្រឿងនាំសត្វចេញចាកទុក្ខ ពួកសហ-ធម្មិកខ្លះ ធ្វើកាលកិរិយាហើយ កើតជាសត្វ មានសីហៈជាដើម ពួកខ្លះជាសត្វមានម្រឹគជាដើមនោះ ក្នុងសត្វទាំងនោះ ពួកសត្វមានសីហៈជាដើមមិនធ្វើកិច្ច មានការអត់ធន់ជាដើមក្នុងសត្វទាំងឡាយ ដែលកើតជាម្រឹគជាដើមថា សត្វទាំងនេះជាសហធម្មិករបស់ពួកយើង ដូច្នេះហើយ ញុំាងមហាទុក្ខឲ្យកើតឡើងដល់សត្វទាំងឡាយ មានម្រឹគទាំងឡាយជាដើមនោះ ដោយន័យដូចពោលហើយពីមុននោះឯង ព្រោះដូច្នោះ ទើបភាពជាទីស្រឡាញ់ និងគួរពេញចិត្តក្នុងពួកសហធម្មិកនោះ តថាគតពោលថា មិនប្រព្រឹត្តទៅហើយ ដោយប្រពៃ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងប្រភេទនៃហេតុទាំងអស់នេះរួម

គ្នា ទើបត្រាស់ថា សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសេចក្តីនោះ ដូច្នេះជាដើម ។ ការសន្ធែបក្នុងបទនោះ ដូច្នេះ ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតពោលថា ការជ្រះថ្លាក្នុងសាស្តាណា មិនទៅហើយដោយប្រពៃនោះ រមែងយ៉ាងនេះ ដូច្នេះជាដើមនោះ រមែងយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះការជ្រះថ្លាជាដើមនោះ ក្នុងធម្មវិន័យដែលសាស្តាពោលអាក្រក់ហើយ ។បេ។ មិនមែនជាអ្នកដឹងឯង ដោយប្រពៃប្រកាស ។ ក្នុងបទនោះ បទថា **យថាតំ** ជានិបាត ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ បណ្តាបទទាំងនោះ បទថា **ទុរក្ខាតេ** បានដល់ ពោលមិនល្អ ឈ្មោះថា ប្រកាសមិនល្អហើយ ព្រោះភាពដែលធម្មវិន័យនោះពោលមិនល្អនោះឯង ។ ធម្មវិន័យនោះ រមែងមិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់មគ្គ និងផល ព្រោះដូច្នោះ ទើបឈ្មោះថា **អនិយ្យានិកោ** ប្រែថា មិនជាគ្រឿងនាំចេញចាកទុក្ខ ។ ឈ្មោះថា មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ ព្រោះមិនប្រព្រឹត្តទៅដើម្បីស្ងប់កិលេសទាំងឡាយ មានរាគៈជាដើម ។ ឈ្មោះថា មិនមែនជាអ្នកដឹងឯងដោយប្រពៃប្រកាស ព្រោះអ្នកដឹងឯងដោយប្រពៃ គឺសព្វញ្ញូមិនប្រកាស ។ ក្នុងធម្មវិន័យនោះ មិនមែនសភាពនាំចេញចាកទុក្ខ មិនប្រព្រឹត្តទៅដើម្បីការស្ងប់ មិនមែនជាអ្នកដឹងឯងដោយប្រពៃប្រកាស ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ការជ្រះថ្លាក្នុងតិរ្ថិយទាំងឡាយឥតប្រយោជន៍ ដូចការជ្រះថ្លាក្នុងចចកផឹកស្រា ដូច្នោះ ដោយប្រការដូច្នេះ ។

បានឮថា ចចកមួយភ្នែកខ្វាក់ម្ខាង ចូលកាន់នគរក្នុងរាត្រី ស៊ីបាយស្រា

ហើយ ដេកលក់ក្នុងព្រៃបុន្នាគ ភ្ញាក់ឡើងក្នុងកាលព្រះអាទិត្យរះហើយ គិតថា អញមិនអាចទៅក្នុងវេលានេះបាន សត្វដែលជាពៀទនឹងអញមានច្រើន សមគួរបោកមនុស្សម្នាក់ ដូច្នេះ ។ ចចកនោះឃើញព្រាហ្មណ៍ម្នាក់ ដើរទៅ ទើបគិតថា អញនឹងបោកព្រាហ្មណ៍នេះ ហើយពោលថា នែលោកព្រាហ្មណ៍ ព្រាហ្មណ៍ពោលថា នរណាហៅព្រាហ្មណ៍ ចចកឆ្លើយថា ខ្ញុំណាលោក សូមលោកមកណេះសិន ព្រាហ្មណ៍ពោលថា មានរឿងអ្វី ចចកប្រាប់ថា សូមលោកនាំខ្ញុំទៅក្រៅស្រុក ខ្ញុំនឹងឲ្យកហាបណៈ ២០០ ដល់លោក ព្រាហ្មណ៍នោះពោលថា យើងនឹងនាំទៅ ហើយចាប់ត្រង់ជើងទាំងឡាយ ចចកពោលថា នែព្រាហ្មណ៍ល្ងង់ ខ្ញុំមិនមានកហាបណៈបោះចោលទេ កហាបណៈជារបស់រកបានលំបាក សូមលោកចាប់ខ្ញុំឲ្យមាំៗ ព្រាហ្មណ៍ពោលថា យើងនឹងធ្វើដូចម្តេច ចចកប្រាប់ថា សូមលោកយកសំពត់ដណ្តប់ ស្តាយខ្ញុំ ហើយចាប់ ។ ព្រាហ្មណ៍ចាប់ចចកយ៉ាងនោះហើយ ទៅកាន់ទីជិតត្រង់ទ្វារទិសខាងត្បូង ហើយសួរថា យើងនឹងលែងក្នុងទីនេះ ចចកសួរថា នេះជាទីណា ព្រាហ្មណ៍ប្រាប់ថា នេះជាទ្វារធំ ចចកប្រាប់ថា ឱ ព្រាហ្មណ៍ល្ងង់ ញាតិរបស់លោកកប់កហាបណៈខាងក្នុងទ្វារឬ សូមនាំខ្ញុំទៅទីដទៃ ។ ព្រាហ្មណ៍នោះដើរបណ្តើរ សួរបណ្តើរថា យើងនឹងលែងក្នុងទីនេះៗ ត្រូវចចកគំរាម ហើយប្រាប់ថា សូមលោកទៅឲ្យផុតភ័យ ហើយលែងក្នុងទីនោះ ដូច្នេះហើយ លែងទៅកាន់សំពត់សាដក ។ កាណសិង្គាលពោលថា ខ្ញុំបានពោលថា ខ្ញុំនឹងឲ្យកហាបណៈ ២០០ ដល់លោក តែខ្ញុំមានកហាបណៈច្រើន មិនមែន

មានត្រឹមតែ ២០០ កហាបណៈប៉ុណ្ណោះទេ សូមលោកឈរមើលព្រះអាទិត្យ ទម្រាំខ្ញុំនាំកហាបណៈទាំងឡាយមកឲ្យលោក ហើយសឹមទៅ ត្រឡប់មក ពោលនឹងព្រាហ្មណ៍ទៀតថា លោកព្រាហ្មណ៍ លោកកុំសម្លឹងមើលទីនេះ សូមឈរមើលព្រះអាទិត្យតែម្យ៉ាង ។ ឯចចកកាលពោលយ៉ាងនេះហើយ ក៏ចូលទៅកាន់ព្រៃរំចេក គេចទៅតាមសប្បាយ ។ ឯព្រាហ្មណ៍សម្លឹងមើលព្រះអាទិត្យនោះឯង រហូតញើសហូរចេញអំពីថ្ងាស និងក្លៀក ។ លំដាប់នោះ រុក្ខទេវតាបានពោលនឹងព្រាហ្មណ៍នោះថា

ម្នាលព្រាហ្មណ៍ អ្នកជឿពាក្យចចកផឹកសុរាដូចម្ដេចបាន ( សូម្បីសម្បក ) ខ្យងចំនួនមួយរយ មិនមានទេ តើកហាបណៈ ២០០ នឹងមានមកអំពីទីណា ។

ដោយប្រការដូច្នេះ ការជ្រះថ្លាក្នុងកាណសង្គាល គឺចចកខ្វាក់ មិនមានប្រយោជន៍ យ៉ាងណា ការត្រេកអរក្នុងតិរិយ ក៏ឥតប្រយោជន៍ ដូច្នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការដែលជ្រះថ្លាក្នុងសាសនា ដែលមិនមែនជាគ្រឿងនាំចេញចាកទុក្ខ ជាវត្ថុឥតប្រយោជន៍ហើយ ដើម្បីទ្រង់សម្ដែងភាពដែលជ្រះថ្លានោះ ក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខថា ជាវត្ថុមានប្រយោជន៍ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនេះឯង ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **កាមុបាទានស្ស បរិញ្ញំ បញ្ញាបេតិ** សេចក្ដីថា ទ្រង់បញ្ញត្តការដឹងសព្វក្នុងការលះ គឺការឈានកន្លងកាមុបាទានដោយអរហត្តមគ្គ ទ្រង់បញ្ញត្តការដឹងសព្វនូវឧបាទាន ៣ យ៉ាងក្រៅអំពីនេះ

ដោយសោតាបត្តិមគ្គ ។ បទថា **ឯវរូបេ ខោ ភិក្ខវេ ធម្មវិនយេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ និងវិន័យដែលមានសភាពបែបនេះ ទ្រង់សម្តែងសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខដោយបទទាំង ២ ។ បទថា **សត្ថរិ បសាទោ** សេចក្តីថា ក្នុងសាសនាបែបនេះ ការជ្រះថ្លាក្នុងសាស្តាណា ការជ្រះថ្លានោះ តថាគតពោលថា ទៅហើយដោយប្រពៃ គឺរមែងប្រព្រឹត្តទៅដើម្បីរលាស់ចេញចាកទុក្ខក្នុងភព ។ ក្នុងសេចក្តីនោះ មានរឿងដូច្នេះថា

បានឮថា ព្រះមានព្រះភាគ ទ្រង់អាស្រ័យនៅក្នុងគុហាឥន្ទសាល ក្នុងវេទិស្សកបព៌ត ។ កាលនោះ ទីទុយមួយ កាលព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ក៏ហើរតាមបានពាក់កណ្តាលផ្លូវ កាលព្រះមានព្រះភាគយាងមក ក៏ធ្វើការទទួលពាក់កណ្តាលផ្លូវ ។ ថ្ងៃមួយ ទីទុយនោះចុះអំពីភ្នំ ថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ដែលមានភិក្ខុសង្ឃចោមរោម ប្រថាប់គង់ក្នុងវេលាល្ងាច ដោយលើកស្លាបផ្គងអញ្ជលី ធ្វើក្បាលឲ្យទាបចុះ ឈរនមស្ការព្រះទសពល ។ ព្រះមានព្រះភាគទ្រង់ទតទីទុយនោះហើយ ទ្រង់ធ្វើការញញឹម ។ ព្រះអានន្ទត្ថេរទូលថា បពិត្រព្រះអង្គ អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យនៃការទ្រង់ញញឹមឲ្យប្រាកដ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើលទីទុយនេះ ទីទុយនេះញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគត និងក្នុងភិក្ខុសង្ឃ អន្ទោលក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយសែនកប្ប នឹងបានជាព្រះបច្ចេកពុទ្ធ ឈ្មោះថា សោមនស្ស ដូច្នេះហើយ ទើបត្រាស់ព្រះគាថាថា

ម្នាលទីទុយ អ្នកមានក្អែកមូល រស់នៅអស់វេលាដ៏យូរ ក្នុងភ្នំវេទិស្សកៈ

នៃទីទុយ អ្នកមានសេចក្ដីសុខហើយ អ្នកបានឃើញព្រះពុទ្ធដ៏ប្រសើរ ក្រោកឡើងតាមកាល ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងតថាគត និងក្នុងភិក្ខុសង្ឃដ៏កំពូល អ្នកនឹងមិនទៅកាន់ទុគ្គតិអស់សែននៃកប្ប កាលឃ្លាតចាកទេវលោកហើយ ត្រូវកុសលមូលដាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធ មានបញ្ញា មិនមានបុគ្គលណាប្រៀបស្មើ ប្រាកដឈ្មោះថា សោមនស្ស ។

រឿងទាំងឡាយ មានរឿងសុមនមាលាការ ក្នុងនគររាជគ្រឹះ រឿងមហាភេរិវាទក រឿងមោរជាតក រឿងវីណាវាទ រឿងសន្ធមក ដូច្នេះជាដើម និងរឿងដទៃៗ ទៀត គប្បីឲ្យពិស្ដារក្នុងរឿងនោះ ។ ការជ្រះថ្លាក្នុងព្រះសាស្ដាក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ ឈ្មោះថា ទៅហើយដោយប្រពៃដោយប្រការដូច្នេះ ។

បទថា **ធម្មេ បសាទោ** សេចក្ដីថា ការជ្រះថ្លាក្នុងធម៌ក្នុងសាសនានេះជាគ្រឿងនាំចេញចាកទុក្ខ ឈ្មោះថា ទៅហើយដោយប្រពៃ ការជ្រះថ្លានោះរមែងឲ្យសម្បត្តិ សូម្បីដល់តិរច្ឆានទាំងឡាយ ដែលកាន់យកនូវនិមិត្ត ដោយគ្រាន់តែសំឡេង ហើយស្លាប់ ។ អត្ថនេះ គប្បីជ្រាបដោយអំណាចនៃរឿងមណ្ឌូកទេវបុត្រជាដើម ។ បទថា **សីលេសុ បរិបូរការិតា** សេចក្ដីថា សូម្បីការធ្វើឲ្យបរិបូណ៌ក្នុងសីលក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ ឈ្មោះថា ប្រព្រឹត្តទៅហើយដោយប្រពៃ គឺរមែងនាំមកនូវសគ្គសម្បត្តិ និងមោក្ខសម្បត្តិ ។ ក្នុងទីនេះ គប្បីសម្ដែងរឿងទាំងឡាយ មានរឿងឆត្តមាណវក និងរឿងសាមណេរជាដើម ។ បទថា **សហធម្មិកេសុ** សេចក្ដីថា ភាពជាទី

ស្រឡាញ់ និងគួរពេញចិត្តក្នុងពួកសហធម្មិក ក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ ឈ្មោះថា ប្រព្រឹត្តទៅហើយដោយប្រពៃ គឺរមែងនាំមកនូវមហាសម្បត្តិ ។ អត្ថនេះគប្បីសម្តែងដោយរឿងវិមានប្រេតទាំងឡាយ លោកបានពោលពាក្យនេះថា ខ្ញុំបានឲ្យទឹកដោះដល់ភិក្ខុដែលត្រាច់បិណ្ឌបាត ខ្ញុំឲ្យទឹកអំពៅ ។បេ។ ដើមអំពៅ ទន្ទាប់ ត្រសក់ ល្ពៅ វល្លិបក្ក ហត្ថបតាក បន្លែមួយក្តាប់ អំបុក ត្រាវ ស្តៅមួយក្តាប់ ទឹកជ្រក់ នំចៀន វត្ថពន្ធចង្កេះ សំពត់អង្សក សំពត់សម្រាប់ធ្វើសេចក្តីព្យាយាម ការបក់ផ្លិត ផ្លិតស្លឹកត្នោត ផ្លិតកន្ទុយក្ងោក ឆត្រ ស្បែកជើង នំ នំកុម្មាស គ្រឿងចងដល់ភិក្ខុដែលត្រាច់បិណ្ឌបាត លោកចូរមើលវិមានរបស់ខ្ញុំនោះ ខ្ញុំមានទេពអប្សរដែលមានពណ៌សម្បុរគួរស្រឡាញ់ ដូច្នេះ ពាក្យថា **តំ កិស្ស ហេតុ** ជាដើម គប្បីប្រកបដោយគន្លងរបស់ន័យដែលពោលហើយចុះ ។

[ ១៥៨ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបច្ច័យនៃឧបាទានទាំងឡាយ ដែលតិត្ថិយទាំងឡាយមិនបញ្ញត្តការដឹងសព្វដោយប្រពៃ តថាគតទ្រង់បញ្ញត្ត ទើបត្រាស់ថា **ឥមេ ច ភិក្ខវេ** ជាដើម ។ ពាក្យទាំង-ឡាយ មាននិទានជាដើម ក្នុងបទទាំងឡាយ មានបទថា **កឹ និទានា** ក្នុងបទនោះជាដើម ។ ទាំងអស់នេះឯង ជាវេវចនៈនៃហេតុ ពិតហើយ ហេតុរមែងប្រគល់ឲ្យនូវផល ដូចបញ្ជូនឲ្យថា ណ្ហើយចុះ លោកទាំងឡាយ ចូរកាន់យកផលនេះ ព្រោះដូច្នោះ ទើបហៅថា **និទាន** ។ ព្រោះនិទាននោះ រមែងកើត តាំងឡើង ផលិតចេញអំពីហេតុនោះ ព្រោះដូច្នោះ ទើបហៅថា សមុទយៈ

ជាតិ បករ ។ អត្ថនៃបទក្នុងទីនេះ ដូច្នេះ ។ អ្វីជាដើមហេតុនៃឧបាទានទាំងនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះ មានអ្វីជាដើមហេតុ ។ អ្វីជាហេតុកើតនៃឧបាទានទាំងនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះ មានអ្វីជាហេតុកើត ។ អ្វីជាកំណើតរបស់ឧបាទាន ដូច្នោះ ព្រោះដូច្នោះ ឧបាទានទាំងនោះមានអ្វីជាកំណើត អ្វីជាដែនកើតនៃឧបាទានទាំងនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះមានអ្វីជាដែនកើត ។ ព្រោះតណ្ហាជាដើមហេតុ ជាហេតុកើត ជាកំណើត និងជាដែនកើតនៃឧបាទានទាំងនោះ ដោយអត្ថតាមដែលពោលហើយ ព្រោះដូច្នោះ ទើបត្រាស់ថា មានតណ្ហាជាដើមហេតុ ដូច្នេះជាដើម ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងយ៉ាងនេះឯង ។ ព្រោះព្រះមានព្រះភាគ ទ្រង់ដឹងបច្ច័យនៃឧបាទានតែម្យ៉ាងប៉ុណ្ណោះក៏ទេ ទ្រង់រមែងដឹងដល់បច្ច័យរបស់តណ្ហា ដែលជាបច្ច័យនៃឧបាទានផង របស់ធម៌ទាំងឡាយ មានវេទនាជាដើម ដែលមានតណ្ហាជាដើមជាបច្ច័យផង ព្រោះដូច្នោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហានេះដូច្នេះជាដើម ។ បទថា **យតោ ច ខោ** បានដល់ ក្នុងកាលណា ។ បទថា **អវិជ្ជា បហីនា ហោតិ** សេចក្តីថា អវិជ្ជាដែលជាឫសគល់នៃវដ្តៈ ឈ្មោះថាលះហើយ ដោយអនុប្បាទនិរោធ ។ បទថា **វិជ្ជា ឧប្បន្នា** បានដល់ វិជ្ជាគឺអរហត្តមគ្គកើតឡើងហើយ ។ បទថា **សោ អវិជ្ជាវិរាគា វិជ្ជុប្បាទា** សេចក្តីថា ភិក្ខុនោះ ព្រោះលះអវិជ្ជាបានហើយ និងព្រោះវិជ្ជាកើតឡើងហើយ រមែងមិនប្រកាន់មាំក្នុងកាមុបាទាន បទថា **នេវ កាមុបាទានំ ឧបាទិយតិ** សេចក្តីថា រមែងមិនប្រកាន់មាំ គឺមិនចូលកាន់កាមុបាទាន រមែងមិនប្រកាន់

មាំ រមែងមិនចូលកាន់ឧបាទានទាំងឡាយដ៏សេស ។ បទថា **អនុបាទិយំ ន បរិតស្សតិ** សេចក្តីថា កាលមិនប្រកាន់មាំ ក្នុងឧបាទានណាមួយយ៉ាងនេះ ឈ្មោះថា មិនភ័យខ្លាយ ដោយការភ័យខ្លាច គឺតណ្ហា ។ បទថា **អបរិតស្សំ** បានដល់ កាលមិនភ័យខ្លាច គឺមិនញុំាងតណ្ហាឲ្យកើតឡើង ។ បទថា **បច្ចត្តំ យេវ បរិនិព្វាយតិ** សេចក្តីថា រមែងបរិនិព្វានដោយការរំលត់កិលេស ចំពោះខ្លួននោះឯង ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការអស់ទៅនៃអាសវៈដល់ភិក្ខុនោះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងបច្ចវេក្ខណញ្ញាណដល់ភិក្ខុដែលមានអាសវៈអស់ហើយ ទើបត្រាស់ថា ជាតិអស់ហើយ ដូច្នេះជាដើម ។ បទដ៏សេស មានអត្ថដូចពោលហើយនោះឯង ។ល។

**ចូឡសីហនាទ ចប់**

**សូត្រទី ១ ចប់**

# សុត្តន្តបិដក

## មហាសីហនាទសូត្រទី ២

[ ១៥៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងដងព្រៃក្រៅនគរ ជាខាងលិចក្រុងវេសាលី ។ សម័យនោះឯង សុនក្ខត្តលិច្ឆវិបុត្ត ទើបនឹងសឹកចេញចាកធម្មវិន័យនេះទៅមិនយូរប៉ុន្មាន ។ តែងពោលវាចាក្នុងកណ្តាលបរិសទ្យ ក្នុងក្រុងវេសាលីយ៉ាងនេះថា គុណវិសេសគឺញាណទស្សនៈ ជាគុណអាចដើម្បីធ្វើខ្លួនឲ្យជាព្រះអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ដែលខ្លួនស្រាវជ្រាវដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯង តែធម៌ដែលព្រះអង្គសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីអស់ទៅនៃវដ្តទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ ។

[ ១៦០ ] លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាត ។ ព្រះសារីបុត្តមានអាយុ បានឮសុនក្ខត្តលិច្ឆវិបុត្តកំពុងពោលវាចាក្នុងកណ្តាលបរិសទ្យ ក្នុងក្រុងវេសាលីយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈដែលអាចដើម្បីធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ ដែលខ្លួនស្រាវជ្រាវដោយសេចក្តី

ត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃខ្លួនឯង តែធម៌ ដែលព្រះអង្គសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ រមែងប្រព្រឹត្តទៅដើម្បីឲ្យអស់ទៅ នៃវដ្តទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ លុះព្រះសារីបុត្តមានអាយុត្រាច់ទៅក្រុងវេសាលី ដើម្បីបិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តមានអាយុអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សុនក្ខត្តលិច្ឆវិបុត្ត ទើបនឹងសឹកចេញចាកធម្មវិន័យនេះមិនយូរប៉ុន្មាន តែងពោលវាចាក្នុងកណ្តាលបរិសទ្យ ក្នុងក្រុងវេសាលីយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈ ជាគុណអាចធ្វើខ្លួនឲ្យជាព្រះអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ ដែលខ្លួនស្រាវជ្រាវដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណាជាការឈ្លាសវៃដោយខ្លួនឯង តែធម៌ដែលព្រះអង្គសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីអស់ទៅនៃវដ្តទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ ។

[ ១៦១ ] ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត សុនក្ខត្ត ជាមនុស្សក្រោធជាមោឃបុរស ព្រោះវាចានោះ គាត់ពោលដោយសេចក្តីក្រេវក្រោធ ម្នាលសារីបុត្ត សុនក្ខត្ត ជាមោឃបុរសនោះគិតថា អាត្មាអញនឹងតិះដៀលហើយ

ត្រឡប់ជាសរសើរតថាគតវិញ ម្នាលសារីបុត្ត ព្រោះការនិយាយយ៉ាងនេះថា ធម៌ដែលព្រះសមណគោតមសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីអស់ទៅនៃវដ្តទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះ នេះឯងជាគុណរបស់តថាគត ។

[ ១៦២ ] ម្នាលសារីបុត្ត សុនក្ខត្ត ជាមោឃបុរស មិនបានយល់ធម៌ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធបរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគតជ្រាបច្បាស់នូវលោក ជាសារថី ទូន្មាននូវបុរសមិនមានអ្នកណាប្រសើរជាង ជាសាស្តានៃទេវតា និងមនុស្ស ជាបុគ្គលភ្ញាក់រឭក ទ្រង់មានជោគ ។

[ ១៦៣ ] ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរស នឹងមិនបានត្រាស់ដឹងនូវធម៌ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ តែងសម្តែងនូវឫទ្ធិបានច្រើនប្រការ គឺសូម្បីតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន សូម្បីច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ទៅកាន់ទីវាល ជាទីខាងក្រៅ ខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំវិញ ឥតមានទើសដូចជាគេដើរលើអាកាស ។ ងើបមុជក្នុងផែនដី ដូចជាគេងើបមុជក្នុងទឹកក៏បាន ។ ដើរលើទឹកក៏បាន ឥតមានបែកធ្លាយ ដូចជាគេដើរលើផែនដី ។ អង្គុយពែនភ្នែនទៅទាំងភ្នែនក្នុងអាកាសក៏បានដូចជាសត្វសកុណជាតិ ដែលមានស្លាប ។ យកដៃស្ទាបអង្អែលព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ឬញុំាងអំណាចកាយឲ្យអណ្តែតរហូតដល់ព្រហ្មលោកក៏បាន ។

[ ១៦៤ ] ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរសនឹងមិនបានត្រាស់ដឹងធម៌ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ មានសោតធាតុជាទិព្វ ដ៏បរិសុទ្ធកន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮសំឡេង ២ ប្រការ គឺសំឡេងទិព្វ និងសំឡេងមនុស្សក្នុងទីឆ្ងាយក៏បាន ទីជិតក៏បាន ។

[ ១៦៥ ] ម្នាលសារីបុត្ត សុនក្ខត្តជាមោឃបុរស នឹងមិនបានត្រាស់ដឹងធម៌ ក្នុងតថាគតនេះថា ព្រះមានព្រះភាគអង្គនោះ អាចកំណត់នូវចិត្តរបស់សត្វដទៃ បុគ្គលដទៃ ហើយជ្រាបច្បាស់ដោយព្រះទ័យបាន ។ ចិត្តដែលប្រកបដោយរាគៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រាសចាករាគៈ ។ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រាសចាកទោសៈ ។ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ជ្រាបច្បាស់ថា ចិត្តប្រាសចាកមោហៈ ។ ចិត្តរួញរាក្តី ក៏ជ្រាបច្បាស់ថា ចិត្តរួញរា ចិត្តរាយមាយក្តី ក៏ជ្រាបច្បាស់ថា ចិត្តរាយមាយ ។ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរ និងអរូបាវចរក្តី ... ចិត្តដែលមិនមែនជាមហគ្គតៈក្តី ... ។ ចិត្តដែលជាសឧត្តរៈ គឺលោកិយចិត្តក្តី ... ចិត្តដែលជាអនុត្តរៈ គឺលោកុត្តរចិត្តក្តី ... ។ ចិត្តដែលតាំងមាំក្តី ... ចិត្តដែលមិនបានតាំងមាំក្តី ... ។ ចិត្តដែលផុតស្រឡះចាកអាសវៈក្តី ក៏ជ្រាបច្បាស់ថាចិត្តផុតស្រឡះចាកអាសវៈ ចិត្តដែលមិនទាន់ផុតចាកអាសវៈក្តី ក៏ជ្រាបច្បាស់ថាចិត្ត

មិនទាន់ផុតចាកអាសវៈ ។

[ ១៦៦ ] ម្នាលសារីបុត្ត តថាគតពលញ្ញាណរបស់តថាគតនេះមាន ១០ ប្រការ គឺជាពលញ្ញាណ ដែលតថាគតបានប្រកបហើយ ទើបដឹងច្បាស់នូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញ៉ាំងព្រហ្មចក្រ ( ចក្រដ៏ប្រសើរ ) ឲ្យប្រព្រឹត្តទៅ ។ ឯតថាគតពលញ្ញាណ ១០ តើដូចម្តេច ។ ម្នាលសារីបុត្ត ព្រះតថាគតក្នុងលោកនេះ រមែងដឹងច្បាស់នូវហេតុតាមហេតុផង ដឹងច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផងតាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវហេតុតាមហេតុផង ដឹងច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង តាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់តថាគតទី ១ ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិសទ្យញ៉ាំងព្រហ្មចក្រ ( ចក្រដ៏ប្រសើរ ) ឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតរមែងដឹងច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្មដែលសត្វបានធ្វើហើយទាំងអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ដោយសេចក្តីពិតមែន ។ ម្នាលសារីបុត្ត ត្រង់ដែលតថាគតដឹងច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយទាំងអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ដោយសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់តថាគត ( ទី ២ ) ជាពលញ្ញាណដែលតថាគតតែងអាស្រ័យ

ទើបបានដល់នូវថ្នាក់ប្រសើរ បន្លឺឡើងនូវសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សុគតិ និងទុគ្គតិក្នុងទីទាំងពួង តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវបដិបទាដំណើរទៅកាន់សុគតិ និងទុគ្គតិក្នុងទីទាំងពួង ម្នាលសារីបុត្ត នេះឯង ជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៣ ) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបដល់នូវថ្នាក់ដ៏ប្រសើរបន្លឺសីហនាទ ក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវលោកដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេងៗគ្នាតាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលតថាគតដឹងច្បាស់នូវលោក ដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេងៗ គ្នាតាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណ ( ទី ៤ ) ជាពលញ្ញាណដែលព្រះតថាគតបានដល់នូវថ្នាក់ដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតដឹងច្បាស់នូវអធ្យាស្រ័យផ្សេងៗ គ្នារបស់សត្វទាំងឡាយ តាមសេចក្តីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវអធ្យាស្រ័យផ្សេងៗ គ្នារបស់សត្វទាំងឡាយ តាមសេចក្តីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់តថាគត ( ទី ៥ ) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្ម-

ចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត តថាគតដឹងច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់របស់ពួកសត្វដទៃ របស់បុគ្គលដទៃតាមសេចក្ដីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលថាព្រះតថាគតដឹងច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់របស់ពួកសត្វដទៃ ពួកបុគ្គលដទៃតាមសេចក្ដីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៦ ) ជាពលញ្ញាណ ដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតដឹងច្បាស់នូវសេចក្ដីសៅហ្មង សេចក្ដីផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយតាមសេចក្ដីពិត ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតដឹងច្បាស់នូវសេចក្ដីសៅហ្មង សេចក្ដីផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ តាមសេចក្ដីពិត ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៧ ) ជាពលញ្ញាណ ដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតរឭកជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ គឺរឭកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រឭកបានច្រើនសំវដ្ដកប្ប ច្រើនវិវដ្ដកប្ប ច្រើនសំវដ្ដវិវដ្ដកប្បក៏បានថា ក្នុងភពឯណោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មាន

គោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ អាត្មាអញនោះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពឯណោះទៀត អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ ទើបមកកើតក្នុងភពនេះឯង ។ ព្រះតថាគតរឭកជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស យ៉ាងនេះឯង ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតរឭកជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ គឺរឭកបាន ១ ជាតិ ២ ជាតិ ។បេ។ រឭកជាតិដែលបាននៅអាស្រ័យក្នុងកាលមុនជាអនេកជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៨ ) ជាពលញ្ញាណ ដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា តែងឃើញនូវសត្វទាំងឡាយកំពុងច្យុត កំពុងកើត ជាសត្វទាបថោកខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម ( របស់ខ្លួន ) ថា អើហ្ន៎ សត្វទាំងអម្បាលនេះ ។បេ។ រមែងដឹង

ច្បាស់ ( យ៉ាងនេះឯង ) ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា តែងឃើញនូវសត្វទាំងឡាយដែលច្យុត ដែលកើត ជាសត្វទាបថោកខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម ( របស់ខ្លួន ) ថាអើហ្ន៎ សត្វទាំងអម្បាលនេះ ។បេ។ រមែងដឹងច្បាស់ ( យ៉ាងនេះ ) ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ៩ ) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត មួយទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញារបស់ខ្លួនក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលសារីបុត្ត ត្រង់ដែលព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ម្នាលសារីបុត្ត នេះឯងជាតថាគតពលញ្ញាណរបស់ព្រះតថាគត ( ទី ១០ ) ជាពលញ្ញាណដែលព្រះតថាគតតែងអាស្រ័យហើយ ទើបបានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត តថាគតពលញ្ញាណទាំង ១០ ប្រការរបស់ព្រះតថាគតនេះឯង ជា

ពលញ្ញាណដែលតថាគតបានប្រកបហើយ ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះ ចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះ ជាគុណវិសេស គឺញាណទស្សនៈ ជាគុណអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ដែលខ្លួនស្រាវជ្រាវបានមក ដោយសេចក្តីត្រិះរិះដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯងដូច្នេះ ម្នាលសារីបុត្ត បុគ្គលនោះឯង បើមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនលះបង់ទិដ្ឋិនោះទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុ ( នៃការមិនលះបង់នូវវាចាជាដើមរបស់បុគ្គលនោះ ) ថាមានឧបមេយ្យប្រហែលគ្នាយ៉ាងនោះដែរ ។ បុគ្គលនោះបើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះឯង ។

[ ១៦៧ ] ម្នាលសារីបុត្ត ព្រះតថាគតប្រកបហើយ ដោយវេសារជ្ជញ្ញាណទាំងឡាយណា ទើបបានដល់នូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ វេសារជ្ជញ្ញាណរបស់ព្រះ

តថាគតនេះ មាន ៤ យ៉ាង ។ វេសារជ្ជញ្ញាណទាំង ៤ ដូចម្តេច ។ ម្នាល សារីបុត្ត ព្រះតថាគតពិចារណាមិនឃើញនូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬនរណាមួយក្នុងលោកនេះ នឹងចោទ តថាគតប្រកបដោយហេតុក្នុងធម៌ទាំងឡាយនោះថា ព្រះអង្គគ្រាន់តែប្តេជ្ញាខ្លួន ថា ជាអ្នកត្រាស់ដឹងដោយប្រពៃ តែធម៌ទាំងនេះ ព្រះអង្គឥតបានត្រាស់ដឹង ឡើយ ម្នាលសារីបុត្ត តថាគត កាលពិចារណាមិនឃើញនូវនិមិត្តនោះហើយ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត មិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬនរណាមួយក្នុងលោកនេះ នឹងចោទ តថាគតប្រកបដោយហេតុក្នុងធម៌ទាំងឡាយនោះថា ព្រះអង្គគ្រាន់តែប្តេជ្ញាខ្លួន ថា ជាអ្នកអស់អាសវៈ តែព្រះអង្គមិនទាន់អស់អាសវៈទាំងនេះទេ ម្នាល សារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះហើយ ក៏បានដល់នូវ សេចក្តីក្សេមក្សាន្តមិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាល សារីបុត្ត តថាគតពិចារណាមិនឃើញ នូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬនរណាមួយក្នុងលោកនេះនឹងចោទ តថាគតប្រកបដោយហេតុក្នុងធម៌ទាំងឡាយនោះថា ធម៌ទាំងឡាយណាដែល ព្រះអង្គពោលថា ជាធម៌ធ្វើនូវសេចក្តីអន្តរាយ ឯធម៌ទាំងឡាយនោះ មិនគួរ ដល់នូវសេចក្តីអន្តរាយចំពោះបុគ្គលណាមួយដែលសេពឡើយ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនោះ ក៏បានដល់នូវសេចក្តីក្សេម

ក្សាន្ត មិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនេះឡើយថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬនរណាមួយក្នុងលោកនេះនឹងចោទតថាគតប្រកបដោយហេតុក្នុងនិយ្យានិកធម៌នោះថា ធម៌ដែលព្រះអង្គសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះ មិនប្រព្រឹត្តទៅដើម្បីអស់ទៅនៃទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកធ្វើតាមធម៌នោះទេ ។ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ក៏បានដល់នូវសេចក្តីក្សេមក្សាន្ត មិនដល់នូវភ័យ ដល់នូវភាវៈជាអ្នកក្លៀវក្លា ១ ។ ម្នាលសារីបុត្ត តថាគតប្រកបដោយវេសារជ្ជញាណទាំងឡាយណាហើយ បានដល់នូវថ្នាក់ដ៏ប្រសើរ បន្លឺសីហនាទក្នុងបរិសទ្យទាំងឡាយ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ វេសារជ្ជញាណរបស់ព្រះតថាគតមាន ៤ នេះឯង ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះ ចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈ ជាគុណអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌នៃព្រះសមណគោតមមិនមាន ព្រះសមណគោតមសម្តែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាសេចក្តីឈ្លាសវៃដោយខ្លួនឯងដូច្នេះ ម្នាលសារីបុត្ត បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរកដូចជាគេនាំយកទៅទម្លាក់ យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិ

ហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ន នេះឯង យ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះ ជាគ្រឿង ផ្តល់នូវពាក្យឧបមេយ្យក៏យ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចា នោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅរង ទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ យ៉ាងនោះដែរ ។

[ ១៦៨ ] ម្នាលសារីបុត្ត បរិសទ្យនេះមាន ៨ ពួក បរិសទ្យទាំង ៨ ពួក តើដូចម្តេច គឺខត្តិយបរិសទ្យ ១ ព្រាហ្មណបរិសទ្យ ១ គហបតិ- បរិសទ្យ ១ សមណបរិសទ្យ ១ ចាតុម្មហារាជិកបរិសទ្យ ១ តាវត្តឹស- បរិសទ្យ ១ មារបរិសទ្យ ១ ព្រហ្មបរិសទ្យ ១ ម្នាលសារីបុត្ត បរិសទ្យ មាន ៨ ពួកនេះឯង ។ ម្នាលសារីបុត្ត ព្រះតថាគតប្រកបព្រមដោយវេសា- រជ្ជញាណ ៤ យ៉ាងនេះឯង តែងចូលទៅរក តែងចូលទៅជិតនូវពួកបរិសទ្យ ទាំង ៨ នេះ ។ ម្នាលសារីបុត្ត តថាគតធ្លាប់ចូលទៅរកខត្តិយបរិសទ្យជា ច្រើនរយនាក់ តថាគតធ្លាប់អង្គុយប្រជុំផង ធ្លាប់ចរចាផង ធ្លាប់ជួបប្រទះ សាកច្ឆាផង ក្នុងពួកខត្តិយបរិសទ្យទាំងនោះ ម្នាលសារីបុត្ត តថាគតពិចា- រណាមិនឃើញនូវនិមិត្តនេះថាភ័យ ឬសេចក្តីកត់ស្លុតនឹងគ្របសង្កត់តថាគត ក្នុងពួកខត្តិយបរិសទ្យនោះដូច្នេះឡើយ ម្នាលសារីបុត្ត តថាគតកាលពិចា- រណាមិនឃើញនូវនិមិត្តនោះ ។បេ។ ម្នាលសារីបុត្ត តថាគតធ្លាប់ចូលទៅ រកព្រាហ្មណបរិសទ្យ គហបតិបរិសទ្យ សមណបរិសទ្យ ចាតុម្មហារាជិក- បរិសទ្យ តាវត្តឹសបរិសទ្យ មារបរិសទ្យ និងព្រហ្មបរិសទ្យជាច្រើនរយនាក់

តថាគតធ្លាប់អង្គុយប្រជុំផង ធ្លាប់ចរចាផង ធ្លាប់ជួបប្រទះសាកច្ឆាផង ក្នុងពួកបរិសទ្យទាំងនោះ ម្នាលសារីបុត្ត តថាគតពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ជាភ័យ ឬសេចក្តីតក់ស្លុត នឹងគ្របសង្កត់តថាគត ក្នុងពួកបរិសទ្យនោះដូច្នេះឡើយ ម្នាលសារីបុត្ត តថាគតកាលពិចារណាមិនឃើញនូវនិមិត្តនុ៎ះ ក៏បានដល់នូវសេចក្តីក្សេមក្សាន្ត ។បេ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈ ដែលអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយខ្លួនឯងដូច្នេះ ម្នាលសារីបុត្ត បុគ្គលនោះ បើមិនលះបង់វាចានោះទេ មិនលះបង់ចិត្តនោះទេ មិនលះបង់ទិដ្ឋិនោះទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរកដូចជា គេនាំយកទៅទម្លាក់ យ៉ាងនោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផល ក្នុងបច្ចុប្បន្ននេះបាន យ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះ ជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យក៏យ៉ាងនោះដែរ ។ បុគ្គលនោះបើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ យ៉ាងនោះឯង ។

[ ១៦៩ ] ម្នាលសារីបុត្ត កំណើត ( របស់សត្វ ) នេះមាន ៤ កំណើត

ទាំង ៤ តើដូចម្តេច គឺកំណើតដែលកើតអំពីស៊ុត ១ កំណើតដែលកើតអំពីទឹក ១ កំណើតដែលកើតអំពីញើស ១ កំណើតហាក់ដូចជាអណ្តែតទៅកើត ១ ។ ម្នាលសារីបុត្ត ចុះកំណើតដែលកើតអំពីស៊ុតនោះដូចម្តេច ម្នាលសារីបុត្ត សត្វដែលទម្លាយនូវសម្បកស៊ុតហើយកើតចេញមក ម្នាលសារីបុត្ត នេះតថាគត ហៅថា កំណើតដែលកើតអំពីស៊ុត ។ ម្នាលសារីបុត្ត ចុះកំណើតដែលកើតអំពីទឹក តើដូចម្តេច ម្នាលសារីបុត្ត សត្វទាំងឡាយដែលទម្លាយនូវស្រោមទឹកភ្លោះហើយកើត ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតដែលកើតអំពីទឹក ។ ម្នាលសារីបុត្ត កំណើតដែលកើតអំពីញើស តើដូចម្តេច ម្នាលសារីបុត្ត សត្វដែលទាំងឡាយដែលកើតក្នុងត្រីស្អុយក្តី ក្នុងសាកសពស្អុយក្តី ក្នុងនំស្អូមក្តី ក្នុងរណ្តៅជ្រាំក្តី ក្នុងប្រឡាយទឹកស្អុយក្តី ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតដែលកើតអំពីញើសក្អែល ។ ម្នាលសារីបុត្ត ចុះកំណើតហាក់ដូចជាអណ្តែតទៅកើត តើដូចម្តេច ពួកទេវតា ពួកសត្វនរក មនុស្សពួកខ្លះ និងវិនិបាតពួកខ្លះ ម្នាលសារីបុត្ត នេះតថាគតហៅថា កំណើតហាក់ដូចជាអណ្តែតទៅកើត ។ ម្នាលសារីបុត្ត កំណើត ( របស់សត្វ ) មាន ៤ នេះឯង ។ ម្នាលសារីបុត្ត បុគ្គលណាពោលយ៉ាងនេះចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈដែលអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ នៃព្រះសមណគោតម មិនមានទេ ព្រះសមណគោតមសម្តែងធម៌ ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាការឈ្លាសវៃដោយ

ខ្ទួនឯង ដូច្នេះ ម្នាលសារីបុត្ត បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរកដូចជាគេនាំយកទៅទម្លាក់ យ៉ាងនោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ តថាគតពោលនូវហេតុនេះ ជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យក៏យ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះចេញទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរកដូចជាគេនាំយកទៅទម្លាក់ យ៉ាងនោះឯង ។

[ ១៧០ ] ម្នាលសារីបុត្ត គតិនេះមាន ៥ ប្រការ គតិ ៥ ប្រការ តើដូចម្តេច គឺនរក ១ កំណើតតិរច្ឆាន ១ បិត្តិវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។ ម្នាលសារីបុត្ត តថាគតស្គាល់នរកផង ស្គាល់ផ្លូវជាទីទៅកាន់នរកផង ស្គាល់សេចក្តីប្រត្រិបត្តិជាទីទៅកាន់នរកផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក តថាគតស្គាល់ច្បាស់នូវការប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវកំណើតតិរច្ឆានផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់កំណើតតិរច្ឆានផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិជាទីទៅកាន់កំណើតតិរច្ឆានផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយទៅខាងមុខអំពីមរណៈ ទៅកើតក្នុងកំណើតតិរច្ឆាន តថាគតស្គាល់ច្បាស់

នូវសេចក្តីប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវបិត្តិ-វិស័យផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់បិត្តិវិស័យផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាទីទៅកាន់បិត្តិវិស័យផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងបិត្តិវិស័យ តថាគតក៏ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវមនុស្សទាំងឡាយផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់មនុស្សលោកផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិជាទីទៅកាន់មនុស្សលោកផង ឯបុគ្គលប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងមនុស្សលោក តថាគតស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះ ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវទេវតាទាំងឡាយផង ស្គាល់ច្បាស់នូវផ្លូវជាទីទៅកាន់ទេវលោកផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិជាទីទៅកាន់ទេវលោកផង ឯបុគ្គលប្រតិបត្តិយ៉ាងណា លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក តថាគតស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះផង ។ ម្នាលសារីបុត្ត តថាគតស្គាល់ច្បាស់នូវព្រះនិព្វានផង ស្គាល់ច្បាស់នូវផ្លូវទៅកាន់ព្រះនិព្វានផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាទីទៅកាន់ព្រះនិព្វានផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ ធ្វើឲ្យជាក់ច្បាស់នូវចេតោ-វិមុត្តិ នូវបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ តថាគតក៏ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះផង ។

[ ១៧១ ] ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួក ១ ក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈមុខជានឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិនខាន លុះសម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះឯង បែកធ្លាយរាងកាយខាងមុខអំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក រងទុក្ខវេទនាដ៏ក្លៀវក្លាខ្លោចផ្សាឥតស្រាក ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត រណ្តៅរងើកភ្លើង មានជម្រៅជាងមួយជួរបុរស[១] ពេញដោយរងើកភ្លើងដែលឥតមានអណ្តាត ឥតមានផ្សែង គ្រានោះមានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកម្តៅថ្ងៃ មានកម្តៅគ្របសង្កត់ មានខ្លួនលំបាក ជង្ហាក់ស្រេកទឹក ដើរមកតាមផ្លូវដែលទៅបានតែម្នាក់ សំដៅទៅត្រង់រងើកភ្លើងនោះឯង បុរសអ្នកមានភ្នែក បានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះ ដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់រណ្តៅរងើកភ្លើងនេះពុំខាន លុះសម័យខាងក្រោយមក ( បុរសមានភ្នែកនោះ ) ក៏ឃើញនូវបុរសនោះ ធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនោះ រងទុក្ខវេទនាដ៏ក្លៀវក្លាខ្លោចផ្សាឥតស្រាក សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួក ១ ក្នុងលោកនេះ យ៉ាងនេះថា

---

១- ជាង ៥ ហត្ថនៃបុរស ( ជាងមួយទទូងបុរស ) ។

បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក រងទុក្ខវេទនាដ៏ក្លៀវក្លាខ្លាំងក្លាឥតស្រាក ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតាដូច្នោះឯង ។

[ ១៧២ ] ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយ ក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងកើតក្នុងកំណើតតិរច្ឆានមិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈទៅកើតក្នុងកំណើតតិរច្ឆាន រងទុក្ខវេទនាដ៏ក្លៀវក្លាខ្លាំងក្លា ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត រណ្តៅលាមកមានជម្រៅជាងមួយជួរបុរស ពេញដោយលាមក គ្រានោះ មានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកម្តៅថ្ងៃ ដែលកម្តៅថ្ងៃគ្រប់សង្កត់ លំបាក ដង្ហាក់ស្រេកទឹក ដើរមកតាមផ្លូវដែលទៅបានតែម្នាក់ សំដៅទៅត្រង់រណ្តៅលាមកនោះឯង បុរសមានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះ ដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់រណ្តៅលាមកនេះពុំខាន លុះសម័យខាងក្រោយមក ( បុរស

មានចក្ខុនោះ ) ក៏ឃើញបុរសនោះធ្លាក់ទៅក្នុងរណ្តៅលាមកនោះ រងទុក្ខវេទនាដ៏ក្លៀវក្លាខ្លោចផ្សា សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងកំណើតតិរច្ឆានមិនខាន លុះសម័យខាងក្រោយ មកតថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ទៅកើតក្នុងកំណើតនៃតិរច្ឆាន រងទុក្ខវេទនាដ៏ក្លៀវក្លាខ្លោចផ្សា ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតាដូច្នោះឯង ។

[ ១៧៣ ] ម្នាលសារីបុត្ត តថាគតកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួក ១ ក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុនអំពីមរណៈ មុខជានឹងទៅកើតក្នុងបិត្តិវិស័យ លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ ទៅកើតក្នុងបិត្តិ-វិស័យ រងទុក្ខវេទនាជាច្រើន ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត ដើមឈើដែលដុះលើផែនដីមិនរាបស្មើ មានស្រទាប់ស្លឹកដ៏ស្តើង មានម្លប់ប៉ើងរ៉ើង គ្រានោះ មានបុរសម្នាក់ ក្តៅក្រហល់ក្រហាយដោយកម្តៅថ្ងៃ ដែលកម្តៅថ្ងៃគ្របសង្កត់ លំបាក ជង្ហាក់ស្រេកទឹក ដើរមកតាមផ្លូវដែលត្រាច់ទៅបានតែម្នាក់ សំដៅទៅរកដើមឈើ

នោះឯង បុរសអ្នកមានភ្នែក បានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់ដើមឈើនេះពុំខាន លុះសម័យខាងក្រោយមក ( បុរសមានចក្ខុនោះ ) ក៏ឃើញបុរសនោះអង្គុយ ឬដេក ទទួលទុក្ខវេទនាជាច្រើន ក្រោមម្លប់ដើមឈើនោះ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងបិត្តិវិស័យមិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ បែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ ទៅកើតក្នុងបិត្តិ-វិស័យ រងទុក្ខវេទនាជាច្រើន ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតាដូច្នោះឯង ។

[ ១៧៤ ] ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះ យ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងពួកមនុស្ស លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ ទៅកើតក្នុងពួកមនុស្ស សោយសុខវេទនាជាច្រើន ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត ដើមឈើដែលដុះលើផែនដី

រាបស្មើល្អ មានស្រទាប់ស្លឹកដ៏ក្រាស់ មានម្លប់ត្រឈៃ គ្រានោះ មានបុរស ក្តៅក្រហល់ក្រហាយដោយកម្តៅថ្ងៃ ដែលកម្តៅថ្ងៃគ្របសង្កត់ លំបាក ជង្ឃាក់ ស្រេកទឹក ដើរមកតាមផ្លូវដែលត្រាច់ទៅបានតែម្នាក់ សំដៅទៅរកដើមឈើ នោះឯង បុរសសម្អកមានចក្ខុ បានឃើញបុរសនោះ និយាយយ៉ាងនេះថា បុរសនេះដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជា នឹងមកកាន់ដើមឈើនេះពុំខាន លុះសម័យខាងក្រោយមក ( បុរសមានចក្ខុ នោះ ) ក៏ឃើញបុរសនោះឯង អង្គុយ ឬដេកសោយសុខទេវនាជាច្រើន ក្រោមម្លប់នៃដើមឈើនោះ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់នូវចិត្តដោយចិត្ត ដឹងនូវចិត្តនៃបុគ្គល ពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះ ផង ឡើងកាន់ផ្លូវនោះផង ។បេ។ ទៅកើតក្នុងពួកមនុស្ស សោយសុខវេទនា ជាច្រើនដូច្នោះឯង ។

[ ១៧៥ ] ម្នាលសារីបុត្ត តថាគតកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គល ពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះ ផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ មុខ ជានឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោកមិនខាន លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបែកធ្លាយរាងកាយ ខាងមុខអំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក សោយសេចក្តីសុខជានិច្ច ដោយចក្ខុដូច ជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។ ម្នាលសារីបុត្ត ប្រាសាទ

មានកូដាគារ ( ផ្ទះមានកំពូល ) ដែលលាបទាំងខាងក្នុង ទាំងខាងក្រៅ ជិតខ្យល់ មានទ្វារជិត មានបង្អួចបើកបិទបាន ក្នុងកូដាគារនោះ មានបល្ល័ង្ក ដែលក្រាលដោយព្រំមានរោមវែងៗ ជាង ៤ ធ្នាប់ ក្រាលដោយកម្រាលមានពណ៌សធ្វើដោយរោមសត្វ ជាផ្កាចង្កោម មានកម្រាលដ៏ឧត្តម ដែលគេធ្វើដោយស្បែកសត្វឈ្លូស មានខ្នើយពណ៌ក្រហមទាំង ២ ខាង គឺខ្នើយក្បាល និងខ្នើយជើង ព្រមទាំងពិតានដែលមានពណ៌ក្រហម គ្រានោះ មានបុរសម្នាក់ ក្តៅក្រហល់ក្រហាយដោយកម្តៅថ្ងៃ ដែលកម្តៅថ្ងៃគ្របសង្កត់ លំបាកជង្ហាក់ ស្រេកទឹក ដើរមកតាមផ្លូវដែលត្រាច់ទៅបានតែម្នាក់ សំដៅទៅត្រង់ប្រាសាទនោះឯង បុរសអ្នកមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់ប្រាសាទនេះដោយពិត លុះសម័យខាងក្រោយមក ( បុរសមានចក្ខុនោះ ) ក៏ឃើញនូវបុរសនោះ កំពុងអង្គុយ ឬដេកសោយសុខវេទនាជានិច្ច លើបល្ល័ង្កក្នុងកូដាគារប្រាសាទនោះ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ មុខជានឹងទៅកើតក្នុងសុគតិ សួគ៌ទេវលោក លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះដែលបែកធ្លាយរាងកាយខាងមុខអំពីមរណៈទៅកើតក្នុងសុគតិ សួគ៌ ទេវលោក សោយ

សុខ វេទនាជានិច្ច ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្ស ធម្មតាដូច្នោះឯង ។

[ ១៧៦ ] ម្នាលសារីបុត្ត តថាគតកំណត់ដឹងនូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ សោយសុខវេទនាជានិច្ច ។ ម្នាលសារីបុត្ត ស្រះបោក្ខរណីមានទឹកថ្លា មានទឹកឆ្ងាញ់ មានទឹកត្រជាក់ មានទឹករងថ្លា មានកំពង់រាបទាបល្អ គួរជាទីរីករាយ មានជងព្រៃស្រោងស្រាង មិនឆ្ងាយអំពីស្រះបោក្ខរណីនោះ គ្រានោះ មានបុរសម្នាក់ក្តៅក្រហល់ក្រហាយដោយកម្តៅថ្ងៃ ដែលកម្តៅថ្ងៃគ្របសង្កត់ លំបាក ដង្ហាក់ ស្រេកទឹក ដើរមកតាមផ្លូវដែលត្រាច់ទៅបានតែម្នាក់ សំដៅទៅរកស្រះបោក្ខរណីនោះ បុរសអ្នកមានចក្ខុបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះ ដើរទៅដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងកាន់ផ្លូវនោះផង មុខជានឹងមកកាន់ស្រះបោក្ខរណីនេះដោយពិត លុះសម័យខាងក្រោយមក ( បុរសមានចក្ខុនោះ )

ក៏ឃើញបុរសនោះ ចុះទៅក្នុងស្រះបោក្ខរណីនោះ ងូតផង ផឹកផង បំបាត់បង់នូវសេចក្តីក្រវល់ក្រវាយ នឿយហត់ និងសេចក្តីក្តៅក្រហល់ក្រហាយគ្រប់យ៉ាងហើយ ឡើងមកអង្គុយ ឬដេកសោយសុខទ្ទែសុខវេទនា ក្នុងដងព្រៃនោះ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចតថាគតដែលកំណត់នូវចិត្តដោយចិត្ត ដឹងនូវបុគ្គលពួកមួយក្នុងលោកនេះយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះផង ប្រព្រឹត្តដូច្នោះផង ឡើងទៅកាន់ផ្លូវនោះផង មុខជានឹងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ លុះសម័យខាងក្រោយមក តថាគតក៏ឃើញបុគ្គលនោះ ដែលបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្ត ដោយឥរិយាបថទាំង ៤ សោយសុខទ្ទែសុខវេទនាដូច្នោះឯង ។ ម្នាលសារីបុត្ត គតិនេះឯងមាន ៥ យ៉ាង ។ ម្នាលសារីបុត្ត អ្នកណាពោលយ៉ាងនេះចំពោះតថាគតដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះថា គុណវិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ របស់ព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ដែលខ្លួនស្រាវជ្រាវ បានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមានដោយប្រាជ្ញារបស់ខ្លួនដូច្នេះ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្ត

នោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅវេទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ដូច្នោះឯង ។ ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ សម្រេចអរហត្តផលក្នុងបច្ចុប្បន្ននេះឯង មានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យយ៉ាងនោះដែរ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅវេទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ដូច្នោះឯង ។

[ ១៧៧ ] ម្នាលសារីបុត្ត មួយទៀត តថាគតធ្លាប់ប្រព្រឹត្តព្រហ្មចរិយៈដែលប្រកបដោយអង្គ ៤ ។ គឺបើនិយាយពីអ្នកមានតបៈ តថាគតជាអ្នកមានតបៈដ៏ក្រៃលែង បើនិយាយពីអ្នកសៅហ្មង តថាគតជាអ្នកសៅហ្មងដ៏ក្រៃលែង បើនិយាយពីអ្នកមានសេចក្តីខ្ពើមបាប តថាគតជាអ្នកមានសេចក្តីខ្ពើមបាបដ៏ក្រៃលែង បើនិយាយពីអ្នកស្ងប់ស្ងាត់ តថាគតជាអ្នកស្ងប់ស្ងាត់ដ៏ក្រៃលែង ។

[ ១៧៨ ] ម្នាលសារីបុត្ត ការមានតបៈរបស់តថាគតក្នុងព្រហ្មចរិយៈប្រកបដោយអង្គ ៤ នោះដូច្នេះ គឺតថាគតជាអ្នកអាក្រាត លះបង់មារយាទល្អ ប្រព្រឹត្តហត្ថាវលេខនបដិបត្តិ ជាអ្នកកាន់វត្តមិនចូលមក ( ទទួលភត្ត ) ដែលគេនិមន្តថា លោកដ៏ចម្រើនចូរចូលមក មិនរង់ចាំតាមគេនិមន្តថា លោកដ៏ចម្រើនសូមរង់ចាំសិន មិនត្រេកអរនឹងចង្ហាន់ដែលកាន់យកមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេប្រាប់ថាធ្វើចំពោះខ្លួន មិនត្រេកអរនឹងចង្ហាន់ដែលគេ

និមន្ត ។ តថាគតនោះមិនទទួលចង្ហាន់ ដែលគេកំពុងដោះដួសអំពីឆ្នាំង មិនទទួលចង្ហាន់អំពីមាត់កញ្ជើ មិនទទួលចង្ហាន់ដែលគេឲ្យគ្រង់ចន្លោះធរណី មិនទទួលចង្ហាន់ដែលគេឲ្យគ្រង់ចន្លោះត្បាល់ មិនទទួលចង្ហាន់ដែលគេឲ្យគ្រង់ចន្លោះអង្រែ មិនទទួលចង្ហាន់របស់មនុស្សដែលកំពុងបរិភោគពីរនាក់ មិនទទួលចង្ហាន់របស់ស្ត្រីមានគភ៌ មិនទទួលចង្ហាន់របស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលចង្ហាន់របស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលចង្ហាន់ដែលគេអង្គាសគ្នាធ្វើ មិនទទួលចង្ហាន់ក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលចង្ហាន់ដែលមានរុយហោមរោម មិនបរិភោគត្រី មិនបរិភោគសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំដោយស្រូវទាំងពួង ។ តថាគតនោះទទួលចង្ហាន់តែក្នុងផ្ទះមួយ ឬបរិភោគភោជនតែមួយពំនូត ទទួលចង្ហាន់ក្នុងផ្ទះពីរ ឬបរិភោគភោជនតែពីរពំនូត ។បេ។ ទទួលចង្ហាន់ក្នុងផ្ទះ ៧ ឬបរិភោគតែ ៧ ពំនូត ។ តថាគតចិញ្ចឹមអត្តភាពដោយចង្ហាន់ ១ ភាជន៍តូចខ្លះ ចិញ្ចឹមអត្តភាពដោយចង្ហាន់ ២ ភាជន៍តូចខ្លះ ។បេ។ ចិញ្ចឹមអត្តភាពដោយចង្ហាន់ ៧ ភាជន៍តូចខ្លះ ឆាន់អាហាររំលងមួយថ្ងៃខ្លះ ឆាន់អាហាររំលងពីរថ្ងៃខ្លះ ។បេ។ ឆាន់អាហាររំលង ៧ ថ្ងៃខ្លះ តថាគតប្រកបរឿយៗ នូវការបរិភោគភត្តតាមលំដាប់ថ្ងៃយ៉ាងនេះ រហូតដល់រំលងកន្លះខែខ្លះ ដូចសម្តែងមកនេះឯង ។ តថាគតមានបន្លែជាអាហារខ្លះ មានស្រងែជាអាហារខ្លះ មានស្មៅគែលលកជាអាហារខ្លះ មានចំនៀរស្បែកដែលគេជៀរចោលជាអាហារខ្លះ មានសារាយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ

មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើម និងផ្លែឈើជាអាហារចិញ្ចឹមជីវិតខ្លះ តែងបរិភោគផ្លែឈើ ដែលជ្រុះឯងចិញ្ចឹមជីវិតខ្លះ ។ តថាគតប្រើប្រាស់សំពត់ ដែលត្បាញដោយសម្បកធ្មៃខ្លះ ប្រើប្រាស់សំពត់ដែលត្បាញលាយចម្រុះគ្នាខ្លះ ប្រើប្រាស់សំពត់ដែលគេរុំសាកសពខ្លះ ប្រើប្រាស់សំពត់បង្សុកូលខ្លះ ប្រើប្រាស់សំពត់សម្បកឈើខ្លះ ប្រើប្រាស់ស្បែកខ្លាខ្លះ ប្រើប្រាស់ស្បែកខ្លាទាំងក្រចកខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយស្បូវខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយសម្បកក្រចៅខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយសម្បកផ្លែឈើខ្លះ ប្រើប្រាស់សំពត់កម្ពល ដែលត្បាញដោយសក់មនុស្សខ្លះ ប្រើប្រាស់សំពត់ដែលត្បាញដោយរោមកន្ទុយសត្វខ្លះ ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ជាអ្នកទុកសក់ និងពុកមាត់ពុកចង្កា ប្រកបរឿយៗ នូវសេចក្តីព្យាយាមទុកសក់ និងពុកមាត់ពុកចង្កាខ្លះ ជាអ្នកប្រព្រឹត្តតែឈរ មិនអង្គុយខ្លះ ជាអ្នកអង្គុយច្រហោង ប្រកបរឿយៗ នូវសេចក្តីព្យាយាមអង្គុយច្រហោងខ្លះ ជាអ្នកដេកលើបន្លា សម្រេចការដេកលើបន្លាខ្លះ ប្រកបរឿយៗ នូវសេចក្តីព្យាយាមចុះត្រាំក្នុងទឹក ( ដើម្បីបន្សាត់បាប ) ក្នុងមួយថ្ងៃ ៣ ដង ប្រកបរឿយៗ នូវសេចក្តីព្យាយាមដុតកម្តៅរោលរាលនូវកាយច្រើនប្រការមានសភាពយ៉ាងនេះ ដូច្នេះឯង ។ ម្នាលសារីបុត្ត នេះឯងជាភាពនៃអ្នកមានតបៈរបស់តថាគត ។

[ ១៧៩ ] ម្នាលសារីបុត្ត សេចក្តីសៅហ្មងរបស់តថាគតក្នុងព្រហ្មចរិយធម៌ប្រកបដោយអង្គ ៤ នេះដូច្នេះ ។ មន្ទិល គឺធូលីរាប់ដោយឆ្នាំដ៏ច្រើន ដែល

ជាប់នៅនឹងកាយ ក៏ក្លាយទៅជាក្រមរស្រទាប់ ។ ម្នាលសារីបុត្ត ដង្គត់ដើមដង្កោដែលតាំងនៅរាប់ដោយឆ្នាំដ៏ច្រើន ក៏កើតជាក្រមរ មានឧបមាដូចម្តេចមិញ ម្នាលសារីបុត្ត មានឧបមេយ្យដូចមន្ទិល គឺធូលីរាប់ដោយឆ្នាំដ៏ច្រើនដែលជាប់នៅនឹងកាយតថាគត ក៏ក្លាយទៅជាក្រមរដូច្នោះឯង ។ ម្នាលសារីបុត្តតថាគតនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីយកបាតដៃដុសមន្ទិល គឺធូលីនេះចេញដូច្នេះឡើយ ។ ម្នាលសារីបុត្ត សូម្បីតែគំនិតយ៉ាងនេះថា ជនទាំងឡាយដទៃគប្បីយកបាតដៃដុសក្អែលរបស់តថាគតនេះដូច្នេះ ក៏មិនមានដល់តថាគតឡើយ ។ ម្នាលសារីបុត្ត នេះជាវត្តខាងសេចក្តីសៅហ្មងរបស់តថាគត ។

[ ១៨០ ] ម្នាលសារីបុត្ត វត្តខាងសេចក្តីខ្ពើមបាបរបស់តថាគតក្នុងព្រហ្មចរិយធម៌ប្រកបដោយអង្គ ៤ នោះដូច្នេះ ។ ម្នាលសារីបុត្ត តថាគតនោះឯង ឈានទៅមុខក៏មានស្មារតី ថយក្រោយក៏មានស្មារតី ។ តថាគតតម្កល់នូវសេចក្តីអាណិតចំពោះដំណក់ទឹកដរាបមកថា តថាគតមិនបានញុំាងពួកសត្វតូចៗ គឺដំណក់ទឹកដែលដក់ជាប់នៅក្នុងទីផ្សេងៗ ឲ្យដល់នូវសេចក្តីវិនាសឡើយ ។ ម្នាលសារីបុត្ត នេះឯងជាវត្តខាងការខ្ពើមបាបរបស់តថាគត ។

[ ១៨១ ] ម្នាលសារីបុត្ត វត្តខាងការស្ងប់ស្ងាត់ របស់តថាគតក្នុងព្រហ្មចរិយធម៌ប្រកបដោយអង្គ ៤ នោះដូចម្តេច ។ ម្នាលសារីបុត្ត តថាគតនោះឯង តែងចូលសំដៅទៅនៅអាស្រ័យក្នុងព្រៃរលឹងណាមួយ ។ កាលណាបើតថាគតឃើញអ្នកគង្វាលគោក្តី អ្នកគង្វាលសត្វចិញ្ចឹមក្តី អ្នករកស្មៅក្តី អ្នក

រកឧសក្តី អ្នករករបរក្នុងព្រៃក្តី តថាគតក៏ចេញអំពីព្រៃទៅកាន់ព្រៃ ចេញអំពីព្រៃស្បាតទៅកាន់ព្រៃស្បាត ចេញអំពីទីទាបទៅកាន់ទីទាប ចេញអំពីទីទួលទៅកាន់ទីទួល ដំណើរនោះតើព្រោះហេតុអ្វី ព្រោះតថាគតបានអធិដ្ឋានថា សូមកុំឲ្យជនទាំងឡាយ នោះបានឃើញតថាគតទាំងតថាគតសោត ក៏កុំបានឃើញជនទាំងឡាយនោះឡើយ ។ ម្នាលសារីបុត្ត ម្រឹគព្រៃឃើញមនុស្សទាំងឡាយតែងរត់ចេញអំពីព្រៃចូលទៅកាន់ព្រៃ ចេញអំពីព្រៃស្បាតចូលទៅកាន់ព្រៃស្បាត ចេញអំពីទីទាបចូលទៅកាន់ទីទាប ចេញអំពីទីទួលចូលទៅកាន់ទីទួលយ៉ាងណាមិញ ម្នាលសារីបុត្ត កាលណាបើតថាគតឃើញអ្នកគង្វាលគោក្តី អ្នកគង្វាលសត្វចិញ្ចឹមក្តី អ្នករកស្មៅក្តី អ្នករកឧសក្តី អ្នករករបរក្នុងព្រៃក្តី តថាគតក៏ចេញអំពីព្រៃទៅកាន់ព្រៃ ចេញអំពីព្រៃស្បាតទៅកាន់ព្រៃស្បាត ចេញអំពីទីទាបទៅកាន់ទីទាប ចេញអំពីទីទួលទៅកាន់ទីទួលក៏យ៉ាងនោះដែរ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតថាគតបានអធិដ្ឋានថាសូមកុំឲ្យជនទាំងឡាយនោះបានឃើញតថាគត ទាំងតថាគតសោត ក៏កុំបានឃើញជនទាំងឡាយនោះឡើយ ។ ម្នាលសារីបុត្ត នេះឯងជាវត្តខាងសេចក្តីស្ងប់ស្ងាត់របស់តថាគត ។

[ ១៨២ ] ម្នាលសារីបុត្ត តថាគតជាអ្នកវារដោយជង្គង់ ៤ ចូលទៅរកក្រោលគោដែលមានគោចេញហើយ មានអ្នកគង្វាលគោចៀសចេញទៅហើយ ហើយស៊ីអាចម៍របស់កូនគោជំទន់ដែលនៅបៅមេ ។ ម្នាលសារីបុត្ត មូត្រ និងករីសខ្លួនឯង របស់តថាគតមិនទាន់អស់ដរាបណា តថាគតក៏ស៊ីនូវមូត្រ និង

កិរិសរបស់ខ្លួនឯងដរាបនោះ ។ ម្នាលសារីបុត្ត នេះឯងជាវត្តខាងកោជន យ៉ាងចម្លែកធំរបស់តថាគត ។

[ ១៨៣ ] ម្នាលសារីបុត្ត តថាគតចូលទៅអាស្រ័យនៅក្នុងដងព្រៃមួយ ដែលគួរស្បើម ។ ម្នាលសារីបុត្ត សេចក្តីតក់ស្លុតនឹងដងព្រៃ ដែលគួរស្បើម នោះតែងមាន ។ បុគ្គលណានីមួយ មិនទាន់ប្រាសចាករាគៈទេ ចូលទៅកាន់ ដងព្រៃនោះ ច្រើនតែព្រឺព្រួចរោម ។ ម្នាលសារីបុត្ត រាត្រីទាំង ៨ ជាចន្លោះ ខែមាឃ និងខែផល្គុន ក្នុងហេមន្តរដូវជាសម័យធ្លាក់ទឹកសន្សើមដ៏ត្រជាក់ក្នុង រាត្រីទាំងឡាយមានសភាពដូច្នោះ តថាគតនៅទីវាលក្នុងវេលាយប់ នៅក្នុង ដងព្រៃវេលាថ្ងៃ ខែជាខាងចុងគិម្ហរដូវ តថាគតនៅទីវាលក្នុងវេលាថ្ងៃ នៅ ក្នុងដងព្រៃវេលាយប់ ។ ម្នាលសារីបុត្ត អើក៏គាថាដែលគួរអស្ចារ្យនេះដែល តថាគតមិនធ្លាប់បានស្តាប់ក្នុងកាលពីមុនមកទេ ស្រាប់តែភ្លឺច្បាស់ប្រាកដលំ តថាគតថា

> អ្នកប្រាជ្ញដែលខ្វល់ខ្វាយក្នុងកិរិយាស្វែងរក ( នូវសេចក្តី
> បរិសុទ្ធិ ) អ្នកប្រាជ្ញនោះត្រូវតែក្តៅ អ្នកប្រាជ្ញនោះត្រូវតែ
> ត្រជាក់ម្នាក់ឯង ជាអ្នកត្រូវតែនៅក្នុងព្រៃ គួរស្បើមតែម្នាក់
> ឯង អាក្រាតមិនចូលទៅរកភ្លើងឡើយ ។

[ ១៨៤ ] ម្នាលសារីបុត្ត តថាគតនោះ សម្រេចនូវឥរិយាបថដេកក្នុង ព្រៃស្មសានកើយលើឆ្អឹងសាកសពទាំងឡាយ ។ ម្នាលសារីបុត្ត ចំណែក ពួកក្មេងឃ្វាលគោនាំគ្នាចូលទៅជិតតថាគតហើយ ស្តោះដាក់ខ្លះ នោមដាក់ខ្លះ

យកដីពោយដាក់ខ្លះ យករំកាច់ឈើមករុកក្នុងរន្ធត្រចៀកខ្លះ ។ ម្នាលសារីបុត្ត តថាគតមិនដែលឲ្យចិត្តអាក្រក់កើតឡើង ចំពោះពួកក្មេងឃ្វាលគោទាំងនោះឡើយ ។ ម្នាលសារីបុត្ត នេះឯងឈ្មោះថា ជាវត្តខាងការនៅប្រកបដោយឧបេក្ខារបស់តថាគត ។

[ ១៨៥ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះអាហារ ។ ពួកសមណព្រាហ្មណ៍ទាំងនោះពោលយ៉ាងនេះថា យើងទាំងឡាយនឹងចិញ្ចឹមអត្តភាពដោយផ្លែពុទ្រាទាំងឡាយ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏ស៊ីផ្លែពុទ្រាខ្លះ ស៊ីលម្អិតនៃផ្លែពុទ្រាខ្លះ ផឹកទឹកដែលប្រឡាក់លាយដោយផ្លែពុទ្រាខ្លះ បរិភោគនំដែលធ្វើដោយផ្លែពុទ្រាយ៉ាងច្រើនខ្លះ ។ ម្នាលសារីបុត្ត តថាគតធ្លាប់យកផ្លែពុទ្រាតែមួយប៉ុណ្ណោះ មកធ្វើជាអាហារ ។ ម្នាលសារីបុត្ត សមជាអ្នកមានសេចក្តីយល់យ៉ាងនេះថា ផ្លែពុទ្រាក្នុងសម័យនោះជាផ្លែធំៗ ណាស់ ។ ម្នាលសារីបុត្ត ដំណើរនុ៎ះអ្នកមិនគួរយល់យ៉ាងនោះឡើយ ។ ព្រោះថា ផ្លែពុទ្រាក្នុងកាលឥឡូវនេះមានទំហំប៉ុនណា ក្នុងកាលពីដើមក៏មានទំហំប៉ុណ្ណោះដែរ ។ ម្នាលសារីបុត្ត កាលដែលតថាគតនោះ យកផ្លែពុទ្រាតែមួយប៉ុណ្ណោះមកធ្វើជាអាហារ កាយក៏ដល់នូវភាវៈស្គាំងស្គមហួសប្រមាណ ។ ព្រោះតែអាហារតិចនោះឯង អវយវៈតូចធំរបស់តថាគតក៏ដូចជាថ្នាំងវល្លិឈ្មោះអសីតិ ( ដកគន់ ឬលែនពែន ) ឬដូចជាថ្នាំងវល្លិកាលា ( វល្លិអណ្តាតត្រកួត ) ។ ព្រោះអាហារតិចនោះឯង ត្រគាករបស់តថាគតក៏ដូចជាជើងសត្វអូដ្ឋ ។ ព្រោះ

តែអាហារតិចនោះឯង ឆ្អឹងខ្នងរបស់តថាគតរតីមរគោមដូចជាខ្សែដែលគេវេញ ។ ព្រោះតែអាហារតិចនោះឯង ឆ្អឹងជំនីរទាំងឡាយរបស់តថាគត ក៏រតីមរគោម ដូចបង្កង់សាលាចាស់ ដែលរវេករវាក ។ ព្រោះតែអាហារតិចនោះឯង ប្រស្រីភ្នែក ឬកែវភ្នែករបស់តថាគត ក៏ខូងជ្រៅទៅក្នុងរណ្ដៅភ្នែក ដូចជាក្រពេញទឹកដែលជ្រៅខូងទៅក្នុងអណ្ដូងទឹកដ៏ជ្រៅ ។ ព្រោះតែអាហារតិចនោះឯង ស្បែកក្បាលរបស់តថាគតក៏រួញរីត ស្វិតស្រពោន ដូចជាផ្លែននោងព្រៃដែលគេកាប់ទាំងខ្ចី តែងរួញរីតស្វិតស្រពោនដោយខ្យល់ និងកម្ដៅថ្ងៃ ។ ម្នាលសារីបុត្ត តថាគតនោះគិតថា នឹងស្ទាបស្បែកពោះ ហើយចាប់ទៅត្រូវទ្រនុងឆ្អឹងខ្នងវិញ តថាគតគិតថា នឹងស្ទាបទ្រនុងឆ្អឹងខ្នង ហើយចាប់ទៅត្រូវស្បែកពោះវិញ ម្នាលសារីបុត្ត ស្បែកពោះរបស់តថាគត ក៏ជាប់គ្នានឹងទ្រនុងឆ្អឹងខ្នងដោយពិត ព្រោះតែអាហារតិចនោះឯង ។ ម្នាលសារីបុត្ត តថាគតនោះគិតថា នឹងបន្ទោបង់វច្ចៈ ឬទឹកមូត្រ ក៏ដួលផ្កាប់មុខទៅលើផែនដី ព្រោះតែអាហារតិចនោះឯង ។ ម្នាលសារីបុត្ត តថាគតនោះ កាលធ្វើកាយនោះឯងឲ្យបានស្រួល ក៏យកដៃស្ទាបខ្លួន ។ ម្នាលសារីបុត្ត កាលតថាគតនោះយកដៃស្ទាបខ្លួន រោមទាំងឡាយដែលមានគល់ស្អុយ ក៏ជ្រុះចេញចាកកាយ ព្រោះតែអាហារតិចនោះឯង ។

[ ១៨៦ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្ដីបរិសុទ្ធិកើតមានព្រោះអាហារ ( តិច ) ។ ពួកសមណព្រាហ្មណ៍ទាំងនោះ បាននិយាយយ៉ាងនេះថា យើង

ទាំងឡាយនឹងចិញ្ចឹមអត្តភាពដោយសណ្តែកបាយទាំងឡាយ ។បេ។ ចិញ្ចឹមអត្តភាពដោយល្ងទាំងឡាយ ។បេ។ ចិញ្ចឹមអត្តភាពដោយអង្ករទាំងឡាយ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ ទំពាស៊ីអង្ករខ្លះ ទំពាស៊ីចុងអង្ករខ្លះ ផឹកទឹកអង្ករខ្លះ បរិភោគនំដែលធ្វើពីអង្ករច្រើនយ៉ាងខ្លះ ។ ម្នាលសារីបុត្ត ចំណែកតថាគតធ្លាប់អាស្រ័យអាហារ ចំពោះអង្ករតែមួយគ្រាប់ប៉ុណ្ណោះ ។ ម្នាលសារីបុត្ត អ្នកប្រហែលជាមានសេចក្តីយល់ឃើញយ៉ាងនេះថា អង្ករក្នុងសម័យនោះជាអង្ករធំៗ ទេដឹង ។ ម្នាលសារីបុត្ត ជំណើរនុ៎ះ អ្នកមិនគួរយល់ឃើញយ៉ាងនេះឡើយ ។ ព្រោះថា អង្ករក្នុងកាលឥឡូវនេះ មានទំហំប៉ុនណា ក្នុងកាលនោះក៏មានទំហំប៉ុណ្ណោះដែរ ។ ម្នាលសារីបុត្ត កាលដែលតថាគតនោះអាស្រ័យអាហារចំពោះអង្ករតែមួយគ្រាប់ កាយក៏ដល់នូវភាវៈស្គាំងស្គមហួសប្រមាណ ។ ព្រោះតែអាហារតិចនោះឯង អវយវៈតូចធំ របស់តថាគតក៏ដូចជាថ្នាំងវល្លិឈ្មោះអសីតិកៈ ឬថ្នាំងវល្លិកាលា ។ ព្រោះតែអាហារតិចនោះឯងត្រគាករបស់តថាគត ។បេ។ ដូចជាជើងសត្វអូដ្ឋ ។ ព្រោះតែអាហារតិចនោះឯង ឆ្អឹងខ្នងរបស់តថាគត ។បេ។ ដូចជាខ្សែដែលគេវេញ ។ ដូចជាបង្កង់នៃសាលាចាស់ ។បេ។ ដូចជាក្រពេញទឹកដែលជ្រៅខូងចុះទៅ ។បេ។ ដូចជាផ្លែននោងព្រៃ ។បេ។ ម្នាលសារីបុត្ត តថាគតនោះគិតថានឹងស្ទាបស្បែកពោះ ។បេ។ ម្នាលសារីបុត្ត តថាគតនោះគិតថានឹងបន្ទោបង់នូវវច្ចៈក្តី ។បេ។ ម្នាលសារីបុត្ត តថាគតនោះកាលធ្វើកាយនោះឯងឲ្យបានស្រួល ។បេ។ ឯរោមទាំងឡាយមានគល់ស្អុយ ក៏ជ្រុះចេញចាកកាយ ព្រោះហេតុតថាគតមាន

អាហារតិចនោះឯង ។ ម្នាលសារីបុត្ត តថាគតមិនបានត្រាស់ដឹងគុណវិសេស គឺញាណទស្សនៈ ជាគុណធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ ដោយសេចក្តីប្រតិបត្តិដ៏ប្រសើរ ជាអំពើដែលគេធ្វើតាមបានដោយកម្រនោះទេ ដំណើរនោះព្រោះហេតុអ្វី ព្រោះហេតុ ( តថាគត ) មិនទាន់បានត្រាស់ដឹងនូវបញ្ញាដ៏ប្រសើរនេះឯង អរហត្តមគ្គបញ្ញាណា ដែលតថាគតបានត្រាស់ដឹងហើយ អរហត្តមគ្គបញ្ញានោះ ជាបញ្ញាដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ រមែងដឹកនាំសត្វអ្នកធ្វើតាមនោះ ឲ្យអស់ទៅនៃវដ្តទុក្ខ ដោយប្រពៃបាន ។

[ ១៨៧ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធកើតមាន ព្រោះសង្សារ គឺការអន្ទោលទៅ ( ច្រើនជាតិ ) ។ ម្នាលសារីបុត្ត សង្សារណា ដែលតថាគតមិនធ្លាប់អន្ទោលទៅដោយកាលវែងនោះ វៀរលែងតែទេវលោក ឈ្មោះសុទ្ធាវាសទាំងឡាយចេញ សង្សារនុ៎ះឯង បុគ្គលមិនងាយរកបានឡើយ ម្នាលសារីបុត្ត ព្រោះថា បើតថាគតអន្ទោលទៅកាន់ទេវលោក ឈ្មោះសុទ្ធាវាស តថាគតមិនបានមកកាន់កាមលោកនេះទៀតទេ ។

[ ១៨៨ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះការកើតឡើង ( ច្រើនជាតិ ) ។ ម្នាលសារីបុត្ត ការកើតឡើងណាដែលតថាគតមិនធ្លាប់កើតដោយកាលវែងនេះ វៀរលែងតែទេវលោកឈ្មោះសុទ្ធាវាសទាំងឡាយចេញ ការកើតឡើងនុ៎ះឯង បុគ្គលមិនងាយរកបានទេ ម្នាលសារីបុត្ត ព្រោះ

ថា បើតថាគតទៅកើតក្នុងទេវលោកឈ្មោះសុទ្ធាវាស តថាគតមិនបានមកកាន់កាមលោកនេះទៀតទេ ។

[ ១៨៩ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះអាវាស គឺការនៅ ( ច្រើនកន្លែង ) ។ ម្នាលសារីបុត្ត អាវាសណាដែលតថាគតមិនធ្លាប់នៅហើយ ដោយកាលវែងនេះ វៀរលែងតែសុទ្ធាវាសទេវលោកទាំង-ឡាយចេញ អាវាសនុ៎ះឯង បុគ្គលមិនងាយរកបានទេ ម្នាលសារីបុត្ត ព្រោះថា បើតថាគតនៅក្នុងសុទ្ធាវាសទេវលោក តថាគតមិនបានមកកាន់កាម-លោកនេះទៀតទេ ។

[ ១៩០ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះការបូជាយញ្ញ ( ច្រើនយ៉ាង ) ។ ម្នាលសារីបុត្ត យញ្ញណាដែលតថាគតកើតជាស្តេចបានមុទ្ធាភិសេកជាក្សត្រក្តី កើតជាព្រាហ្មណ៍មហាសាលក្តី ដោយកាលដ៏វែងនេះហើយ មិនដែលបានបូជាយញ្ញនុ៎ះឯង បុគ្គលមិនងាយរកបានទេ ។

[ ១៩១ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា សេចក្តីបរិសុទ្ធិកើតមានព្រោះបម្រើភ្លើង ។ ម្នាលសារីបុត្ត ភ្លើងណាដែលតថាគតកើតជាស្តេច បានមុទ្ធាភិសេកជាក្សត្រក្តី កើតជាព្រាហ្មណ៍មហាសាលក្តី ដោយកាលដ៏វែងនេះ ហើយមិនដែលបានបូជាភ្លើងនោះឯង បុគ្គលមិនងាយរកបានទេ ។

[ ១៩២ ] ម្នាលសារីបុត្ត មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា បុរសដ៏ចម្រើននេះ នៅក្មេងកំលោះ មានសក់ខ្មៅល្អ មានវ័យដ៏ចម្រើនដោយបឋមវ័យ ដរាបណា បុរសនេះជាអ្នកប្រកបដោយបញ្ញា ដ៏ឈ្លាសវៃយ៉ាងសំខាន់ ដរាបនោះ តែថា កាលណាបុរសដ៏ចម្រើននេះ គ្រាំគ្រា ចម្រើនវ័យ ចាស់ ដល់ហើយនូវសេចក្តីថមថយ ដោយលំដាប់ មានអាយុ ៨០ ឬ ៩០ ឆ្នាំ ឬ ១០០ ឆ្នាំ រាប់អំពីកំណើតមក ក្នុងកាលនោះ បុរសនេះក៏សាបសូន្យចាកបញ្ញា ដ៏ឈ្លាសវៃ ។ ម្នាលសារីបុត្ត សេចក្តីនុ៎ះអ្នកមិនត្រូវយល់យ៉ាងនេះឡើយ ។ ម្នាលសារីបុត្ត ឥឡូវនេះ តថាគតគ្រាំគ្រា ចម្រើនវ័យ ចាស់ ដល់ហើយនូវសេចក្តីថមថយដោយលំដាប់ មានអាយុ ៨០ ឆ្នាំហើយ វ័យរបស់តថាគត ក៏នៅតែប្រព្រឹត្តទៅបាន ។ ម្នាលសារីបុត្ត ក្នុងទីនេះ សាវ័ករបស់តថាគតទាំង ៤ រូប សុទ្ធតែមានអាយុ ១០០ ឆ្នាំ រស់នៅអស់ ១០០ ឆ្នាំ ជាអ្នកប្រកបដោយសតិនិងគតិ និងសេចក្តីព្យាយាមដ៏ក្រៃលែងផង ដោយបញ្ញាដ៏ឈ្លាសវៃក្រៃលែងផង ម្នាលសារីបុត្ត អ្នកកាន់ធ្នូដ៏មាំបានសិក្សាសិប្បៈរួចហើយ មានថ្វីដៃស្ទាត់ក្នុងការបាញ់ បានយកព្រួញដ៏ស្រាល ( បាញ់ ) ឲ្យឆ្លងរំលងប្រមាណដើមត្នោតទទឹងដោយមិនលំបាកឡើយ យ៉ាងណាមិញ សាវ័កទាំង ៤ មានស្មារតីដ៏ក្រៃលែងក៏យ៉ាងនោះ មានគតិដ៏ក្រៃលែងក៏យ៉ាងនោះ មានព្យាយាមដ៏ក្រៃលែងក៏យ៉ាងនោះ ប្រកបដោយបញ្ញាដ៏ឈ្លាសវៃក្រៃលែង ក៏យ៉ាងនោះ ពួកសាវ័កទាំង ៤ នោះតែងសួរប្រស្នា ប្រៀបដោយសតិប្បដ្ឋានទាំង ៤ នឹង

តថាគត ចំណែកតថាគតដែលសាវកទាំងនោះសួរហើយៗ ក៏ដោះស្រាយនូវប្រស្នានោះដល់ពួកសាវកទាំងនោះ សាវកទាំងនោះក៏ចាំទុកនូវប្រស្នា ដែលតថាគតដោះស្រាយហើយ ថាជាប្រស្នាដែលតថាគតដោះស្រាយហើយ មិនបាច់សួរតថាគតឲ្យជាគម្រប់ពីរដងតទៅទៀតឡើយ វៀរលែងតែការស៊ីផឹកទំពាស៊ី និងជញ្ជាប់ជញ្ជក់ភោជន វៀរលែងតែការបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ វៀរលែងតែការដេកលក់ និងការសម្រាកសេចក្ដីលំបាក ម្នាលសារីបុត្ត ធម៌ទេសនារបស់តថាគតមិនចេះអស់បទ និងព្យញ្ជនៈនៃធម៌របស់តថាគតមិនចេះអស់បញ្ហា ព្យាកររបស់តថាគតក៏មិនចេះអស់ឡើយ ។ ចំណែកខាងពួកសាវកទាំង ៤ របស់តថាគតនោះមានអាយុ ១០០ ឆ្នាំ រស់នៅបាន ១០០ ឆ្នាំ នឹងធ្វើមរណកាលដោយកាលកន្លងនៃឆ្នាំ ១០០ ។ ម្នាលសារីបុត្ត បើទុកណាជាអ្នកទាំងឡាយនាំយកតថាគតដោយគ្រែតូច ប្រាជ្ញា និងសេចក្ដីឈ្លាសវៃរបស់តថាគត ក៏មិនក្លាយទៅជាដទៃឡើយ ។ ម្នាលសារីបុត្ត អ្នកផងកាលពោលដោយប្រពៃ តែងពោលចំពោះបុគ្គលណាថា សត្វមានធម៌មិនវង្វេងទេ រមែងកើតក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្ស ។ អ្នកផងកាលពោលដោយប្រពៃចំពោះបុគ្គលនោះ គួរពោលចំពោះតថាគតនឹងឯងថា សត្វមានធម៌មិនវង្វេងទេ កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន

ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

[ ១៩៣ ] សម័យនោះឯង ព្រះនាគសមាលៈ ដ៏មានអាយុ កំពុងព័ត ( បក់ ) ថ្វាយព្រះមានព្រះភាគអំពីខាងក្រោយព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះនាគសមាលៈដ៏មានអាយុ បានក្រាបបង្គំទូលចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះមិនដែលមានសោះ បពិត្រព្រះអង្គដ៏ចម្រើន មិនតែប៉ុណ្ណោះ ខ្ញុំព្រះអង្គស្ដាប់ធម្មបរិយាយនេះហើយ ក៏ព្រឺព្រួចរោម បពិត្រព្រះអង្គដ៏ចម្រើន ធម្ម-បរិយាយនេះ ឈ្មោះដូចម្ដេច ។ ព្រះអង្គត្រាស់ថា ម្នាលនាគសមាលៈ បើដូច្នោះ អ្នកចូរចាំទុកនូវធម្មបរិយាយនេះចុះ ឈ្មោះថា លោមហំសនបរិយាយ ។ លុះព្រះមានព្រះមានព្រះភាគ ត្រាស់ព្រះសូត្រនេះចប់ហើយ នាគសមាលៈដ៏មានអាយុក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## មហាសីហនាទសូត្រទី ២ ចប់

# អដ្ឋកថា
# មហាសីហនាទសូត្រ

[ ១៥៩ ] មហាសីហនាទសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់ដូច្នេះ ។

ក្នុងមហាសីហនាទសូត្រនោះ បទថា **វេសាលិយំ** សេចក្ដីថា ជិតនគរ ដែលមានឈ្មោះយ៉ាងនោះ បានឮថា នគរនោះ ដល់នូវការរាប់ថា **វេសាលី** ព្រោះជានគរបម្រើនវិសាលរឿយៗ ។ ក្នុងមហាសីហនាទសូត្រនេះ មានការ ពោលតាមលំដាប់ដូច្នេះ ។

បានឮថា ព្រះអគ្គមហេសីរបស់ព្រះបាទពារាណសីទ្រង់ព្រះគភ៌ ។ ព្រះ នាងទ្រង់ជ្រាបហើយ ទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាបានព្រះរាជទាន គ្រឿងរក្សាគភ៌ ។ ព្រះនាងកាលទ្រង់បានទទួលការបរិហារដោយប្រពៃ ក៏ យាងចូលកាន់ផ្ទះសម្រាប់ទ្រង់ប្រសូត ក្នុងកាលព្រះនាងមានព្រះគភ៌ចាស់ ។ ក្នុងសម័យជិតភ្លឺ អ្នកមានបុណ្យទាំងឡាយ បានប្រសូតចាកព្រះគភ៌ ។ ឯ អគ្គមហេសីខុសអំពីព្រះទេវីដទៃ ព្រះនាងបានប្រសូតដុំសាច់ដូចគ្នានឹងត្របក ផ្កាចប្បា ដែលមិនទាន់ក្រៀម ក្នុងសម័យជិតភ្លឺនោះ ។ ព្រះទេវីពួកដទៃក្រៅ អំពីអគ្គមហេសីនោះ ទ្រង់ប្រសូតព្រះឱរសទាំងឡាយ ដូចគ្នានឹងពុម្ពមាស អគ្គមហេសី ព្រះនាងដឹងថា ជាដុំសាច់ ទើបត្រិះរិះថា ការអប្បយសរបស់ អញ គប្បីកើតឡើងចំពោះមុខរបស់ព្រះរាជា ដូច្នេះ ព្រោះព្រះនាងខ្លាចចំពោះ ការអប្បយសនោះ ទើបដាក់ដុំសាច់នោះក្នុងភាជនៈមួយ បិទជិត ប្រថាប់

ត្រាព្រះលញ្ចករ ព្រះនាងឲ្យដាក់ចុះក្នុងក្រសែស្ទឹងគង្គា ។ កាលភាជនៈនោះគ្រាន់តែមនុស្សបោលហើយ ទេវតាទាំងឡាយក៏ត្រៀមការរក្សា ។ ឯមនុស្សទាំងឡាយបានចារឹកផែនមាស ដោយជាតិពណ៌ក្រហម ចងទុកក្នុងភាជនៈនោះថា រាជឱរសរបស់ព្រះអគ្គមហេសីនៃព្រះបាទពារាណសី ។ បន្ទាប់អំពីនោះ ភាជនៈនោះ មិនត្រូវភ័យទាំងឡាយ មានភ័យអំពីរលកជាដើម បៀតបៀនឡើយ បានអណ្តែតទៅតាមក្រសែទឹកគង្គា ។ សម័យនោះ មានតាបសម្នាក់អាស្រ័យត្រកូលអ្នកចិញ្ចឹមគោ នៅត្រង់ច្រាំងស្ទឹងគង្គា ។ តាបសនោះចុះកាន់ស្ទឹងគង្គាអំពីព្រលឹម បានឃើញភាជនៈនោះអណ្តែតមក ទើបចាប់លើកឡើង ដោយសម្គាល់ថា ជារបស់បង្សុកូល ។ លំដាប់នោះ បានឃើញបន្ទះអក្សរ និងស្នាមព្រះរាជលញ្ចករនោះក្នុងភាជនៈនោះហើយ ស្រាយមើលឃើញដុំសាច់នោះ ។ តាបសនោះ កាលឃើញហើយ ទើបគិតថា គប្បីជាគភ៌ តែហេតុអ្វី ទើបគភ៌នោះមិនស្អុយ មិនរលួយហ្ន៎ ទើបនាំមកកាន់អាស្រមតាំងទុកក្នុងឱកាសដែលបរិសុទ្ធ លំដាប់នោះ កន្លងទៅកន្លះខែ ដុំសាច់ក៏បែកជា ២ ចំណែក ។ តាបសឃើញហើយ ក៏តាំងទុកក្នុងទីដែលល្អជាងមុន ដោយកន្លងទៅទៀតកន្លះខែអំពីនោះ ដុំសាច់នីមួយៗ ក៏ដុះជាពកប្រាំៗ ដើម្បីប្រយោជន៍ដល់ដៃ ជើង និងក្បាល ។ លំដាប់នោះ ដោយកន្លងទៅកន្លះខែបន្ទាប់អំពីនោះ ដុំសាច់មួយ ជាទារកដូចគ្នានឹងពុម្ពមាស ដុំសាច់មួយ ជាទារិកា ។ តាបសបានកើតសេចក្តីស្រឡាញ់ ដូចជាកូនក្នុងទារកទាំងនោះ ។ ទឹកដោះបានកើតអំពីមេដៃរបស់តាបសនោះ ចាប់តាំងអំពីនោះ បានទឹកដោះ

នោះជាភត្ត ។ តាបសនោះ បរិភោគភត្តហើយ ដាក់ទឹកដោះក្នុងមាត់ទារក ទាំងឡាយ ។ ទីដែលតាបសចូលទៅទាំងអស់ ប្រាកដដល់ទារកទាំងនោះ ដូច នៅក្នុងកាជនៈកែវមណី ។ ទារកទាំង ២ ប្រាសចាកឆវីយ៉ាងនេះ ។ អាចារ្យ មួយពួកពោលថា ទារកទាំងនោះ មានឆវីកំបាំងគ្នានិងគ្នា ដូចជេរ ហើយ តាំងទុក ដោយប្រការដូច្នេះ ទើបទារកនោះប្រាកដថា **លិច្ឆវី** ព្រោះការដែល ទារកទាំងនោះប្រាសចាកសម្បុរថ្ងៃ មានសម្បុរថ្ងៃកំបាំង ។ តាបសចិញ្ចឹម ទារកទាំងឡាយ ចូលទៅកាន់ស្រុកក្នុងពេលថ្ងៃដើម្បីកិច្ចា ត្រឡប់មកក្នុង កាលយឺតយូរពេក ។ អ្នកចិញ្ចឹមគោទាំងឡាយដឹងការកង្វល់នោះ របស់ តាបសនោះ ទើបពោលថា បពិត្រលោកម្ចាស់ ការចិញ្ចឹមទារក រមែងជា កង្វល់ដល់អ្នកបួស សូមលោកម្ចាស់ឲ្យទារកនោះដល់ពួកខ្ញុំចុះ ពួកខ្ញុំនឹង ចិញ្ចឹម សូមលោកម្ចាស់ធ្វើការងាររបស់ខ្លួនចុះ ។ តាបសទទួលថា សាធុ ។ ក្នុងថ្ងៃទី ២ នាយគោបាលទាំងឡាយ ធ្វើផ្លូវឲ្យរាបស្មើ រោយផ្កាទាំងឡាយ លើកទង់ជ្វាលា មានតូរ្យតន្ត្រីបន្លឺមកកាន់ផ្លូវដែលមិនរាបស្មើ ។ តាបសពោល ថា ទារកជាអ្នកមានបុណ្យច្រើន អ្នកទាំងឡាយ ចូរឲ្យចម្រើនដោយការមិន ប្រមាទ កាលឲ្យចម្រើនហើយ ចូរធ្វើអាវាហវិវាហៈជាមួយគ្នា អ្នកទាំងឡាយ ត្រូវឲ្យព្រះរាជាពេញព្រះទ័យដោយបញ្ចគោរស រៀបចំដីសាងនគរអភិសេក កុមារក្នុងនគរនោះ ដូច្នេះហើយ បានឲ្យទារកទាំងឡាយ ។ នាយគោបាល ទាំងនោះទទួលថា សាធុ នាំទារកទាំងឡាយទៅចិញ្ចឹមរក្សា ។ ទារកទាំង នោះអាស្រ័យការចម្រើន លេងជាមួយកុមារ ក៏វាយកូននាយគោបាលដទៃ

ដោយដៃខ្លះ ដោយជើងខ្លះ ក្នុងទីដែលឈ្លោះគ្នា ។ កូនរបស់នាយគោបាលទាំងនោះក៏យំ កាលមាតាបិតាសួរថា ពួកឯងយំរឿងអ្វី ទើបប្រាប់ថា កូនដែលមិនមានមាតាបិតា ដែលតាបសចិញ្ចឹមនេះវាយពួកខ្ញុំពន់ពេក ។ បន្ទាប់អំពីនោះ ទើបមាតាបិតារបស់កុមារទាំងនោះពោលថា ក្មេង ២ នាក់នេះញ៉ាំងកុមារពួកដទៃឲ្យវិនាស ឲ្យដល់សេចក្តីទុក្ខ ពួកយើងមិនគប្បីសង្គ្រោះក្មេងទាំងនេះ គួរបណ្តេញក្មេងទាំងនេះចេញទៅ ដូច្នេះ ។ បានឮថា ចាប់តាំងអំពីកាលនោះ ទើបបទេសនោះ ហៅថា **វជ្ជី** ។ លំដាប់នោះ នាយគោបាលទាំងឡាយ ញ៉ាំងព្រះរាជាឲ្យទ្រង់ពេញព្រះទ័យហើយ បានទទួលបទេសនោះ ដោយបរិមាណ ១០០ យោជន៍ ។ ហើយបានសាងនគរក្នុងបទេសនោះ ហើយអភិសេកកុមារដែលមានអាយុបាន ១៦ ឆ្នាំ ឲ្យជាព្រះរាជា ។ បានឲ្យព្រះរាជានោះ ទ្រង់ធ្វើវិវាហៈជាមួយទារិកានោះ ហើយធ្វើកតិកាថា ពួកយើងមិនគប្បីនាំក្មេងស្រីមកអំពីខាងក្រៅ មិនគប្បីឲ្យក្មេងប្រុសអំពីត្រកូលនេះដល់បុគ្គលណាមួយឡើយ ដូច្នេះ ។ ដោយការនៅរួមគ្នា គ្រាដំបូង ជនទាំងពីរនោះ មានកូនភ្លោះ ២ នាក់ គឺធីតា ១ បុត្រ ១ ដោយប្រការដូច្នេះ ។ ទើបមានបុត្រភ្លោះដល់ទៅ ១៦ ដង ។ បន្ទាប់អំពីនោះទារកទាំងនោះចម្រើនឡើងតាមលំដាប់ ទើបពង្រីកនគរដែលមិនគ្រប់គ្រាន់ដើម្បីយកជាអារាម ឧទ្យាន ទីលំនៅ និងបរិវារសម្បត្តិដល់ទៅ ៣ ដងដោយឆ្ងាយអំពីគ្នាម្តងមួយគាវុត ។ ទើបនគរនោះមានឈ្មោះថា **វេសាលី** ព្រោះជានគរដែលមានការចម្រើនទូលំទូលាយឡើងរឿយៗ ។ ដោយហេតុ

នោះ ទើបលោកពោលថា **វេសាលិយំ** សេចក្ដីថា ជិតព្រះនគរមានឈ្មោះយ៉ាងនោះ ។

បទថា **ពហិនគរេ** សេចក្ដីថា ខាងក្រៅនៃព្រះនគរ គឺមិនមែនខាងក្នុងព្រះនគរ ដូចអម្ពបាលីវ័ន ។ នេះ គឺដងព្រៃខាងក្រៅនគរ ដូចជីវកម្ពវ័ន ។ ដោយហេតុនោះ ទើបលោកពោលថា ខាងក្រៅព្រះនគរ ។ បទថា **អបរ-បុរេ** សេចក្ដីថា ផ្ទុយគ្នានឹងទិសខាងកើត គឺក្នុងទិសខាងលិច ។ បទថា **វនសណ្ឌេ** សេចក្ដីថា បានឮថា ដងព្រៃនោះ នៅក្នុងទីប្រមាណមួយគាវុតក្នុងទិសខាងលិចនៃព្រះនគរ ។ ក្នុងដងព្រៃនោះ មនុស្សទាំងឡាយធ្វើព្រះ-គន្ធកុដិថ្វាយដល់ព្រះមានព្រះភាគ ព័ទ្ធព្រះគន្ធកុដិនោះ ទាំងទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ ទីចង្ក្រម ទីសម្ងំ កុដិ មណ្ឌបជាដើម ថ្វាយដល់ភិក្ខុសង្ឃទាំងឡាយ ។ ព្រះមានព្រះភាគ ប្រថាប់នៅក្នុងដងព្រៃនោះ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងដងព្រៃដែលផ្ទុយគ្នានឹងទិសខាងកើត ។ ពាក្យថា **សុនក្ខត្តោ** នោះ ជាឈ្មោះរបស់បុគ្គលនោះ សុនក្ខត្តនោះ ហៅថាលិច្ឆវីបុត្រ ព្រោះបុគ្គលនោះ ជាបុត្ររបស់លិច្ឆវីទាំងឡាយ ។ បទថា **អចិរបក្កន្តោ** សេចក្ដីថា សឹកមកជាគ្រហស្ថ ចៀសចេញទៅមិនយូរ ។ បទថា **បរិសតិ** បានដល់ ត្រង់កណ្ដាលបរិស័ទ ។ កុសលកម្មបថ ១០ ឈ្មោះថា **មនុស្សធម៌** ក្នុងបទនេះថា **ឧត្តរិមនុស្សធម្មា** សុនក្ខត្តមិនអាចនឹងបដិសេធកុសលកម្មបថទាំង ១០ នោះ ព្រោះហេតុអ្វី ។ ព្រោះភ័យអំពីពាក្យតិះដៀល ។ ព្រោះថា ក្នុងក្រុងវេសាលី មនុស្សជាច្រើនជ្រះថ្លាហើយ

ក្នុងព្រះរតនត្រ័យ រាប់អានព្រះពុទ្ធ រាប់អានព្រះធម៌ រាប់អានព្រះសង្ឃ មនុស្សទាំងនោះ កាលសុនក្ខត្តពោលថា ដោយគ្រាន់តែកុសលកម្មបថ ១០ របស់ព្រះសមណគោតមមិនមាន ដូច្នេះ ក៏នឹងពោលពាក្យជាដើមថា លោកបានឃើញ ព្រះមានព្រះភាគសម្លាប់សត្វក្នុងទីណា ព្រះមានព្រះភាគទ្រង់កាន់យករបស់ដែលគេមិនបានឲ្យក្នុងទីណា ហើយគប្បីពោលថា លោកមិនស្គាល់ប្រមាណខ្លួនឯង លោកស៊ីថ្ម និងដុំក្រួស ដោយគិតថា ធ្មេញទាំង-ឡាយរបស់អញមានឬ លោកព្យាយាមដើម្បីចាប់កន្ទុយពស់ លោកប្រាថ្នាដើម្បីលេងកម្រងផ្កាក្នុងធ្មេញរណារ ពួកយើងនឹងញ៉ាំងធ្មេញទាំងឡាយរបស់លោកឲ្យជ្រុះអំពីមាត់ ដូច្នេះ ។ សុនក្ខត្តមិនអាចពោលយ៉ាងនេះ ព្រោះភ័យអំពីការតិះដៀលនោះ ។ សុនក្ខត្តកាលនឹងបដិសេធការសម្រេចគុណវិសេសក្រៅអំពីឧត្តរិមនុស្សធម្មនោះ ទើបពោលថា ញាណទស្សនវិសេសដែលគួរជាព្រះអរិយៈ ក្រៅអំពីមនុស្សធម៌ ដូច្នេះ ។ ក្នុងបទនោះ ឈ្មោះថា **អល-មរិយ** ព្រោះគួរដើម្បីដឹងអរិយៈ អធិប្បាយថា ដែលអាចដើម្បីភាពជាអរិយៈ ។ ញាណទស្សនៈនោះឯង ឈ្មោះថា **ញាណទស្សនវិសេស** ញាណទស្សនវិសេសនោះផង គួរដល់ព្រះអរិយៈផង ព្រោះដូច្នោះ ទើបឈ្មោះថា **អលមរិយញ្ញាណទស្សនវិសេស** ទិព្វចក្ខុក្តី វិបស្សនាក្តី មគ្គក្តី ផលក្តី បច្ចវេក្ខណញ្ញាណក្តី សព្វញ្ញុតញ្ញាណក្តី ហៅថា **ញាណទស្សន** ។ ពិតហើយ **ទិព្វចក្ខុ** ឈ្មោះថា **ញាណទស្សន** ក្នុងពាក្យនេះថា ជាអ្នកមិនប្រមាទហើយ រមែងសម្រេចញាណទស្សនៈ ។ **វិបស្សនាញាណ** ឈ្មោះថា

**ញាណទស្សន** *ក្នុងពាក្យនេះថា នាំទៅចំពោះ បង្អោនទៅចំពោះនូវចិត្តដើម្បីញាណទស្សនៈ ។* **មគ្គ** *ឈ្មោះថា* **ញាណទស្សន** *ក្នុងពាក្យនេះថា បុគ្គលទាំងនោះមិនគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹងដ៏កំពូល ។* **ផលញ្ញាណ** *ឈ្មោះថា* **ញាណទស្សន** *ក្នុងពាក្យនេះថា ញាណទស្សនវិសេសដែលគួរដល់ព្រះអរិយៈក្រៅអំពីឧត្តរិមនុស្សធម៌នេះ ជាការនៅជាផាសុក បានសម្រេចហើយទេដឹង ។* **បច្ចវេក្ខណញ្ញាណ** *ឈ្មោះថា* **ញាណទស្សន** *ក្នុងពាក្យនេះថា ញាណទស្សនៈបានកើតឡើងដល់តថាគតហើយ វិមុត្តិរបស់អញមិនកម្រើក ជាតិនេះជាជាតិចុងក្រោយ ឥឡូវនេះ ភពថ្មីមិនមាន ។* **សព្វញ្ញុតញ្ញាណ** *ឈ្មោះថា* **ញាណទស្សន** *ក្នុងពាក្យនេះថា ញាណទស្សនៈរបស់តថាគតបានកើតឡើងហើយ អាឡារតាបសកាឡាមគោត្រ បានដល់កម្ម គឺស្លាប់ហើយ ៧ ថ្ងៃ ។ ឯលោកុត្តរមគ្គ លោកបំណងយកក្នុងទីនេះ ។ សុនក្ខត្តនោះ បដិសេធលោកុត្តរមគ្គរបស់ព្រះមានព្រះភាគនោះ ។ ហាមអាចារ្យដោយបទនេះថា* **តក្កបរិយាហតំ ។** *បានឮថា សុនក្ខត្តមានបរិវិតក្កយ៉ាងនេះថា ធម្មតាព្រះគោតម ទ្រង់មិនចូលរកអាចារ្យទាំងឡាយ ហើយកាន់យកលំដាប់ធម៌ដ៏ល្អិតឡើយ ព្រះសមណគោតម ទ្រង់សម្តែងធម៌ទាញនូវការត្រិះរិះ គឺទ្រង់ពិចារណា ទ្រង់ត្រិះរិះហើយ សម្តែងធម៌តាមការត្រិះរិះ ថាជាយ៉ាងនេះ និងមានយ៉ាងនេះ ដូច្នេះ ។ រមែងដឹងលោកិយប្បញ្ញារបស់ព្រះសមណគោតមនោះ ដោយបទនេះថា* **វីមំសានុចរិតំ ។** *ព្រះសមណគោតមទ្រង់មានព្រះបញ្ញា ។ ព្រះសមណគោតមនោះ ទ្រង់ញុាំងព្រះវិមង្សា*

ដែលប្រៀបដូចផ្លូវជិត ពោល គឺបញ្ញានោះ ឲ្យត្រាច់ទៅខាងនោះ និងខាងនេះថា នឹងប្រព្រឹត្តទៅយ៉ាងនោះ នឹងប្រព្រឹត្តទៅយ៉ាងនេះ ទ្រង់រមែងសម្តែងធម៌ ស្របតាមព្រះវិមង្សា ។ ហាមភាពដែលព្រះសមណគោតមនោះ ទ្រង់ប្រចក្សក្នុងធម៌ទាំងឡាយ ដោយបទនេះថា **សយំ បដិភានំ ។** សុនក្ខត្តនោះ មានការគិតយ៉ាងនេះថា វិបស្សនាក្តី មគ្គក្តី ផលក្តី ដែលជាលំដាប់នៃធម៌ល្អិតរបស់ព្រះគោតមនោះ ឈ្មោះថា ប្រចក្សរមែងមិនមាន ឯសមណគោតមនេះ ទ្រង់បានបរិស័ទវណ្ណៈ ៤ រមែងចោមរោមព្រះអង្គ ដូចស្តេចចក្រពត្តិ ឯជួរព្រះទន្តរបស់ព្រះអង្គរាបស្មើល្អ ព្រះជិវ្ហាទន់ ព្រះសូរសៀងពីរោះ ព្រះវាចាមិនមានទោស ព្រះអង្គទ្រង់កាន់យកវត្ថុដែលប្រាកដដល់ទេវតាហើយ ត្រាស់ព្រះតម្រាស់តាមបដិភាណរបស់ព្រះអង្គ ទ្រង់ញ៉ាំងមហាជនឲ្យត្រេកអរ ។ បទថា **យស្ស ច ខ្វស្សត្ថាយ ធម្មោ ទេសិតោ** សេចក្តីថា ធម៌នេះព្រះអង្គទ្រង់សម្តែងដើម្បីប្រយោជន៍ដល់បុគ្គលណា ។ សេចក្តីនេះដូចម្តេច ។ គឺអសុភកម្មដ្ឋាន ដើម្បីប្រយោជន៍ដល់ការកម្ចាត់រាគៈ មេត្តាភាវនាដើម្បីប្រយោជន៍ការកម្ចាត់ទោសៈ ធម៌ ៥ ប្រការ ដើម្បីប្រយោជន៍ដល់ការកម្ចាត់មោហៈ អានាបានស្សតិ ដើម្បីកម្ចាត់វិតក្ក ។ បទថា **សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ** សេចក្តីថា សុនក្ខត្តសម្តែងថា ធម៌នោះនាំចេញ គឺប្រព្រឹត្តទៅ ដើម្បីការអស់ទៅនៃវដ្តទុក្ខដោយប្រពៃ គឺដោយហេតុដោយន័យ ដោយការណ៍ ដល់អ្នកបដិបត្តិតាមធម៌ដែលទ្រង់សម្តែងនោះ គឺញ៉ាំងប្រយោជន៍នោះឲ្យសម្រេច ។ តែសុនក្ខត្តមិនពោលដល់អត្ថនោះ ដោយ

អធ្យាស្រ័យរបស់ខ្លួន ទើបពោលយ៉ាងនេះថា ធម៌របស់ព្រះពុទ្ធទាំងឡាយ មិនជាគ្រឿងនាំចេញចាកទុក្ខ ដូច្នេះ ។ តែមិនអាចនឹងពោលបាន ព្រោះហេតុអ្វី ព្រោះភ័យអំពីការតិះដៀល ពិតហើយ ក្នុងក្រុងវេសាលី មានឧបាសកជាសោតាបន្ន សកទាគាមី និងអនាគាមីជាច្រើន ។ ឧបាសកទាំងនោះ គប្បីពោលយ៉ាងនេះថា នែសុនក្ខត្ត អ្នកពោលថា ធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ មិនជាគ្រឿងនាំចេញចាកទុក្ខបាន ដូច្នេះ ឧបមាថា ធម៌នេះមិនជាគ្រឿងនាំចេញចាកទុក្ខបានសោត ចុះហេតុអ្វីក្នុងនគរនេះ ឧបាសកទាំងនេះជាសោតាបន្នប្រមាណប៉ុណ្ណេះ ជាសកទាគាមីប្រមាណប៉ុណ្ណេះ ជាអនាគាមីប្រមាណប៉ុណ្ណេះ ។ ឧបាសកទាំងនោះ គប្បីធ្វើការជំទាស់ ដោយន័យដូចពោលហើយក្នុងបទមុន ។ សុនក្ខត្តនោះ កាលមិនអាចពោលថា ធម៌នេះមិនជាគ្រឿងនាំចេញចាកទុក្ខបាន ព្រោះភ័យអំពីការតិះដៀលនេះ ទើបពោលថា ធម៌របស់សមណគោតមនោះ មិនជាមោឃៈ រមែងនាំចេញចាកទុក្ខបាន ដូចកំណាត់ឈើដែលគេទុកដោយមិនត្រូវដុត តែព្រះសមណគោតមនោះ មិនមានអ្វីខាងក្នុងឡើយ ដូច្នេះ ។

[ ១៦០ ] បទថា **អស្សោសិ ខោ** សេចក្ដីថា កាលសុនក្ខត្តពោលយ៉ាងនេះ ក្នុងកណ្ដាលបរិស័ទនោះៗ ក្នុងត្រកូលទាំងឡាយ មានត្រកូលព្រាហ្មណ៍ និងត្រកូលសេដ្ឋីជាដើម ក្នុងនគរវេសាលី ព្រះសារីបុត្របានស្ដាប់ពាក្យនោះហើយ មិនជំទាស់ ។ ព្រោះហេតុអ្វី ។ ព្រោះលោកមានសេចក្ដីករុណា ។ បានឮថា ព្រះសារីបុត្រនោះ មានការត្រិះរិះយ៉ាងនេះថា សុនក្ខត្ត

នេះ ប្រទូស្តដោយអំណាចនៃសេចក្តីក្រោធ ដូចឫស្សីដែលត្រូវដុត និងដូចអំបិលដែលដាក់ក្នុងចង្ក្រាន សុនក្ខត្ត កាលអាត្មាអញជំទាស់ហើយ នឹងចងអាឃាតក្នុងអាត្មាអញ កាលបើយ៉ាងនេះ សុនក្ខត្តនោះ ក៏នឹងចងអាឃាតជាការៈយ៉ាងក្រៃលែងក្នុងជនទាំង ២ គឺក្នុងព្រះតថាគត និងអាត្មាអញ ព្រោះដូច្នោះ ទើបមិនជំទាស់ ព្រោះលោកមានសេចក្តីករុណា ម្យ៉ាងទៀត ព្រះសារីបុត្រនោះ មានការត្រិះរិះយ៉ាងនេះថា ធម្មតាការពោលពាក្យតិះដៀលព្រះពុទ្ធទាំងឡាយ ក៏ដូចគ្នានឹងការបាចសាចទោសក្នុងព្រះចន្ទពេញវង់ ដូច្នោះបុគ្គលណានឹងកាន់យកពាក្យរបស់សុនក្ខត្តនេះ សុនក្ខត្តនោះឯង កាលអស់ទឹកមាត់ មាត់ស្ងួតហើយ នឹងឈប់ពោលពាក្យតិះដៀល ព្រោះដូច្នោះ ទើបព្រះសារីបុត្រមិនជំទាស់ ព្រោះសេចក្តីករុណានេះ ។ បទថា **បិណ្ឌបាត-បដិក្កន្តោ** សេចក្តីថា ត្រឡប់អំពីស្វែងរកបិណ្ឌបាតហើយ ។

[ ១៦១ ] បទថា **កោធនោ** គឺជាអ្នកប្រទូស្ត គឺជាបុគ្គលគ្រោតគ្រាត ។ បទថា **មោឃបុរិសោ** សេចក្តីថា បុរសទទេ ពិតហើយ ព្រះពុទ្ធទាំងឡាយហៅបុរសដែលមិនមានឧបនិស្ស័យនៃមគ្គ និងផល ក្នុងអត្តភាពនោះថា មោឃបុរស ។ កាលឧបនិស្ស័យមាន តែមគ្គ និងផល មិនមានក្នុងខណៈនោះ ក៏ហៅថា មោឃបុរសដូចគ្នា ។ តែសុនក្ខត្តនេះ បានកាត់ផ្តាច់ឧប-និស្ស័យនៃមគ្គ និងផលទាំងឡាយហើយក្នុងអត្តភាពនោះ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ហៅសុនក្ខត្តនោះថា មោឃបុរស ។ បទថា **កោធា ច បនស្ស ឯសា វាចា ភាសិតា** សេចក្តីថា ឯវាចារបស់សុនក្ខត្តនោះឯង

បានពោលហើយដោយសេចក្តីក្រោធ ។

ព្រោះហេតុអ្វី ទើបសុនក្ខត្តនោះ ខឹងនឹងព្រះមានព្រះភាគ ។ ព្រោះក្នុងកាលមុនសុនក្ខត្តនេះ ចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរដល់ការបរិកម្មទិព្វចក្ខុ ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ដល់សុនក្ខត្តនោះហើយ ។ សុនក្ខត្តនោះ ញុំាងទិព្វចក្ខុឲ្យកើតឡើង ចម្រើនអាលោកសញ្ញា កាលសម្លឹងមើលទេវលោក ក៏បានឃើញទេវបុត្រទាំងឡាយ និងទេពធីតាទាំងឡាយដែលកំពុងសោយទិព្វសម្បត្តិ ក្នុងនន្ទវ័ន ចិត្តលតាវ័ន បារុស្សកវ័ន និងមិស្សកវ័ន ជាអ្នកបំណងនឹងស្តាប់សំឡេងរបស់ទេវបុត្រ និងទេពធីតាទាំងនោះ ដែលតាំងនៅក្នុងអត្តភាពសម្បត្តិបែបនេះថា នឹងមានសំឡេងពីរោះដូចម្តេចហ្ន៎ ទើបចូលទៅគាល់ព្រះទសពល ហើយទូលសួរការបរិកម្មទិព្វសោតធាតុ ។ តែព្រះមានព្រះភាគទ្រង់ដឹងថា សុនក្ខត្តនោះ មិនមានឧបនិស្ស័យដល់ទិព្វសោតធាតុ ទើបមិនត្រាស់ប្រាប់ការបរិកម្មដល់សុនក្ខត្តនោះ ព្រោះព្រះពុទ្ធទាំងឡាយ រមែងមិនត្រាស់បរិកម្មដល់បុគ្គលដែលមិនមានឧបនិស្ស័យ ។ សុនក្ខត្តបានចងអាឃាតក្នុងព្រះមានព្រះភាគ ហើយគិតថា អញបានទូលសួរបរិកម្មដល់ទិព្វចក្ខុកាលពីដំបូង នឹងព្រះសមណគោតម ព្រះអង្គបានប្រាប់ដល់អញថា ទិព្វចក្ខុបរិកម្មនោះ ចូរសម្រេច ឬថា ចូរកុំសម្រេច តែអញញុំាងទិព្វចក្ខុបរិកម្មនោះ កើតឡើងដោយការធ្វើរបស់បុរសចំពោះខ្លួនហើយ ទើបសួរដល់បរិកម្មទិព្វសោតធាតុ ព្រះអង្គមិនត្រាស់ប្រាប់ការបរិកម្មទិព្វសោតធាតុនោះដល់អញ ប្រហែលព្រះអង្គមានព្រះតម្រិះយ៉ាងនេះថា

សុនក្ខត្តនេះ បួសអំពីរាជត្រកូល ញ៉ាំងទិព្វចក្ខុញ្ញាណឲ្យកើតឡើងហើយ ញ៉ាំងទិព្វសោតធាតុញ្ញាណឲ្យកើត ញ៉ាំងចេតោបរិយញ្ញាណឲ្យកើត ញ៉ាំងញាណក្នុងការអស់ទៅនៃអាសវៈទាំងឡាយ ឲ្យកើតហើយ នឹងប្រហាក់ប្រហែលជាមួយអញពិត ទើបព្រះអង្គមិនត្រាស់ប្រាប់ដល់អញ ដោយអំណាចនៃការច្រណែន និងការកំណាញ់ ដូច្នេះ ។ សុនក្ខត្តចងអាឃាតដោយប្រមាណក្រៃលែងហើយ បោលសំពត់កាសាយៈទាំងឡាយហើយ ដល់នូវភាពជាគ្រហស្ថ ក៏មិនស្ងៀម ត្រាច់ទៅ ។ សុនក្ខត្តពោលទោសព្រះទសពលដោយភាពទទេ មិនពិត ត្រាច់ទៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា វាចានេះ សុនក្ខត្តពោលព្រោះសេចក្តីក្រោធ ដូច្នេះ ។ បទថា **វណ្ណោ ហេសោ សារីបុត្ត** សេចក្តីថា ម្នាលសារីបុត្រ តថាគតបំពេញបារមីទាំងឡាយអស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប បានធ្វើសេចក្តីព្យាយាមដើម្បីប្រយោជន៍នៃបារមីទាំងនោះ ធម្មទេសនារបស់តថាគត នឹងជាគ្រឿងនាំសត្វចេញចាកទុក្ខបាន ព្រោះដូច្នោះ បុគ្គលណាពោលយ៉ាងនេះ បុគ្គលនោះ ឈ្មោះថា ពោលសរសើរតថាគតនោះឯង ។ ទ្រង់សម្តែងថា ម្នាលសារីបុត្រ ការសរសើរនោះជាគុណរបស់តថាគត ទ្រង់សម្តែងអ្វីដោយថា **អយំបិ ហិ ឆាម សារីបុត្ត** ដូច្នេះបទដើម ។ ទ្រង់សម្តែងឧត្តរិមនុស្សធម្ម ដែលសុនក្ខត្តបដិសេធ មាននៅក្នុងព្រះអង្គ ។

[ ១៦២-១៦៦ ] បានឮថា ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះដោយន័យថា **អយំបិ ហិ ឆាម សារីបុត្ត** ជាដើម ដើម្បីទ្រង់សម្តែងអត្ត

នោះថា ម្នាលសារីបុត្រ សុនក្ខត្តនេះ ជាមោឃបុរស រមែងពោលថា ឧត្តរិ-មនុស្សធម៌របស់ព្រះតថាគតមិនមាន ដូច្នេះ ឯតថាគតមានសព្វញ្ញុតញ្ញាណ មានឥទ្ធិវិធញ្ញាណ មានទិព្វសោតធាតុញ្ញាណ មានចេតោបរិយញ្ញាណ មានទសពលញ្ញាណ មានចតុវេសារជ្ជញ្ញាណ មានញាណដែលមិនតក់ស្លុត ក្នុងបរិស័ទ ៨ មានញាណកំណត់កំណើត ៤ មានញាណកំណត់គតិ ៥ ធម៌ទាំងអស់នោះ ក៏គឺឧត្តរិមនុស្សធម្មនោះឯង ធម្មតាគ្រាន់តែការអនុលោមតាមធម៌ ដែលអាចដឹងឧត្តរិមនុស្សធម្ម ១ ក្នុងបណ្តាឧត្តរិមនុស្សធម្មបែបនេះ នឹងមិនមានដល់មោឃបុរសនោះ ដូច្នេះ ។ ក្នុងបទទាំងនោះ ឈ្មោះថា **អន្វយ** ព្រោះអត្ថថា អនុលោមតាម អធិប្បាយថា ដឹង គឺដឹងតាម ។ ការអនុលោមតាមធម៌ ឈ្មោះថា **ធម្មន្វយ** ។ នុ៎ះជាឈ្មោះរបស់បញ្ញាដែលជាគ្រឿងដឹងធម៌មានសព្វញ្ញុតញ្ញាណជាដើមនោះ ។ ទ្រង់សម្តែងថា សូម្បី **ធម្មន្វយ** ក៏មិនមានដល់មោឃបុរសនោះ ដើម្បីឲ្យដឹងឧត្តរិមនុស្សធម្ម ពោល គឺសព្វញ្ញុ-តញ្ញាណបែបនេះរបស់តថាគតកំពុងមាននោះឯងថា មាន ដោយបទថា **ឥតិបិ សោ ភគវា** ជាដើម ។ គប្បីជ្រាបការប្រកបយ៉ាងនេះ ក្នុងញាណទាំងឡាយមានឥទ្ធិវិធញ្ញាណជាដើម ។ ម្យ៉ាងទៀត គប្បីពោលវិជ្ជា ៣ ក្នុងលំដាប់នៃចេតោបរិយញ្ញាណ ក្នុងបទនោះដោយពិត ។

សូម្បីយ៉ាងនោះ កាលវិជ្ជាទាំង ៣ នោះ ពោលហើយ ធម្មតាទសព-លញ្ញាណខាងលើ រមែងបរិបូណ៌ ព្រោះដូច្នោះ ទើបមិនត្រាស់វិជ្ជា ៣ នោះ ទ្រង់សម្តែងធ្វើឲ្យបរិបូណ៌ដោយទសពលញ្ញាណរបស់តថាគត ទើបត្រាស់ថា

**ឧស ខោ បនិមានិ សារីបុត្ត** ជាដើម ។

[ ១៦៦ ] បណ្ដាបទទាំងនោះ បទថា **តថាគតពលានិ** បានដល់ កម្លាំងរបស់តថាគតប៉ុណ្ណោះ មិនទូទៅដល់បុគ្គលដទៃ គឺពលដែលមកហើយ ដោយប្រការដែលពលរបស់ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ដែលមកដោយ បុញ្ញសម្បត្តិ និងឥស្សរិយសម្បត្តិ ។ ក្នុងពលទាំងនោះ ពលរបស់តថាគត មាន ២ យ៉ាង គឺ កាយពល ១ ញាណពល ១ ។ ក្នុងពលទាំងនោះ កាយពល គប្បីជ្រាបដោយទំនងនៃត្រកូលដំរី ។ សមដូចគាថាព័ន្ធ ដែល បុរាណាចារ្យទាំងឡាយពោលយ៉ាងនេះថា

ត្រកូលដំរី ១០ គឺកាឡាវកៈ ១ គង្គេយ្យៈ ១ បណ្ឌរៈ ១
តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១ ហេមៈ ១
ឧបោសថ ១ ឆទ្ទន្ត ១ ។

ត្រកូលនៃដំរី ១០ នេះ ។ ក្នុងត្រកូលដំរីទាំងនោះ គប្បីឃើញត្រកូល ដំរីធម្មតាថា កាឡាវកៈ ។ កម្លាំងកាយរបស់បុរស ១០ នាក់ ស្មើគ្នានឹង កម្លាំងដំរីកាឡាវកៈ ១ ។ កម្លាំងរបស់ដំរីកាឡាវកៈ ១០ ស្មើកម្លាំងដំរី គង្គេយ្យៈ ១ កម្លាំងដំរីគង្គេយ្យៈ ១០ ប៉ុននឹងកម្លាំងដំរីបណ្ឌរៈ ១ កម្លាំងដំរី បណ្ឌរៈ ១០ ស្មើនឹងកម្លាំងដំរីតម្ពៈ ១ កម្លាំងដំរីតម្ពៈ ១០ ស្មើនឹងកម្លាំងដំរី បិង្គលៈ ១ កម្លាំងដំរីបិង្គលៈ ១០ ស្មើនឹងកម្លាំងដំរីគន្ធៈ ១ ។ កម្លាំងដំរីគន្ធៈ ១០ ស្មើកម្លាំងដំរីមង្គលៈ ១ កម្លាំងដំរីមង្គលៈ ១០ ស្មើកម្លាំងដំរីហេមវតៈ ១ កម្លាំងដំរីហេមវតៈ ១០ ស្មើគ្នានឹងកម្លាំងដំរីឧបោសថ ១ ។ កម្លាំងដំរី

*ឧបោសថ ១០ ស្មើគ្នានឹងកម្លាំងដំរីឆទ្ទន្ត ១ ។ កម្លាំងដំរីឆទ្ទន្ត ១០ ស្មើគ្នានឹងកម្លាំងព្រះតថាគតមួយព្រះអង្គ ។ តថាគតពលនេះ ហៅថា កម្លាំងរូបរបស់ព្រះនារាយន៍ក៏មាន ។ កម្លាំងនេះ ជាកម្លាំងដំរីធម្មតា ១០០០ កោដិ ជាកម្លាំងបុរស ១០ ពាន់កោដិ ។ នេះជាកម្លាំងទី ១ គឺកម្លាំងកាយរបស់ព្រះតថាគត ។ ឯព្រះពលមកហើយក្នុងបាលីមុននោះឯង ។ ញាណច្រើនពាន់ដទៃយ៉ាងនេះ គឺទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ ញាណដែលមិនតក់ស្លុតក្នុងបរិស័ទ ៨ ញាណកំណត់កំណើត ៤ ញាណកំណត់គតិ ៥ ញាណ ៧៣ ញាណ ៧៧ ដែលមកក្នុងសំយុត្តនិកាយនោះ ឈ្មោះថា* **ញាណពល** *។ ញាណពលនោះឯង លោកបំណងយកហើយក្នុងទីនេះ ។ ញាណលោកពោលថា* **ពល** *ដោយអត្ថថា មិនញាប់ញ័រ និងអត្ថថា ឧបការៈ ។ បទថា* **យេហិ ពលេហិ សមន្នាគតោ** *សេចក្តីថា ទ្រង់ដល់ គឺទ្រង់ដល់ព្រមដោយញាណពល ១០ ប្រការ ទាំងឡាយណា ។ បទថា* **អាសភណ្ឋានំ** *គឺឋានៈដ៏ប្រសើរបំផុត គឺឋានៈឧត្តម ។ អធិប្បាយថា ឋានៈព្រះពុទ្ធក្នុងកាលមុន ដែលជាអ្នកនាំទាំងនោះ ។ ម្យ៉ាងទៀត មេនៃហ្វូងគោក្នុងគោ ១០០ ឈ្មោះថា* **ឧសភ** *មេនៃគោហ្វូងក្នុងគោ ១០០០ ឈ្មោះថា* **វសភ** *ម្យ៉ាងទៀត មេហ្វូងក្នុងគោ ១០០ ក្រោល ឈ្មោះថា* **ឧសភ** *មេហ្វូងក្នុងគោ ១០០០ ក្រោល ឈ្មោះថា* **វសភ** *គោដែលជាមេនៃហ្វូងក្នុងគោទាំងពួង ជាអ្នកនាំហ្វូងគោទាំងអស់ សសុទ្ធ គួរជ្រះថ្លា នាំការៈច្រើន មិនញាប់ញ័រដោយសំឡេងរន្ទះ ១០០ ជាន់ ឈ្មោះថា* **និសភ** និសភៈនោះ *លោក*

បំណាំងយកឧសភៈក្នុងទីនេះ ។ ពិតហើយ ពាក្យនេះ ជាពាក្យដោយអម របស់ឧសភៈនោះ ។ ឈ្មោះថា **អាសភ** ព្រោះអត្ថថា នេះជារបស់ឧសភៈ ។ បទថា **ឋានំ** សេចក្តីថា ឋានៈដែលទម្លាយផែនដីដោយជើងទាំង ៤ ហើយមិនញាប់ញ័រ នេះហាក់បីដូចគោឧសភៈ ព្រោះដូច្នោះ ទើបឈ្មោះថា **អាសភ** ។ គោឧសភៈ ពោល គឺ និសភៈ ដល់ព្រមដោយកម្លាំងនៃគោឧសភៈ ទម្លាយផែនដីដោយជើងទាំង ៤ ហើយឈរមិនញាប់ញ័រ យ៉ាងណា សូម្បីព្រះតថាគតក៏ដូច្នោះដូចគ្នា ទ្រង់ដល់ព្រមដោយកម្លាំងរបស់ព្រះតថាគត ១០ ប្រការ ទ្រង់ទម្លាយផែនដី គឺបរិស័ទ ៨ ដោយព្រះបាទ គឺវេសារជ្ជៈ ៤ ប្រការ ហើយមិនតក់ស្លុតចំពោះសត្រូវ គឺបច្ចាមិត្រណាមួយក្នុងលោក ព្រមទាំងទេវលោក ទ្រង់តាំងនៅដោយមិនញាប់ញ័រ ។ កាលទ្រង់តាំងនៅយ៉ាងនោះ ឈ្មោះថា ទ្រង់ប្រកាស គឺទ្រង់ចូលដល់ឋានៈនៃភាពជាអ្នកនាំនោះ គឺទ្រង់លើកក្នុងព្រះអង្គដោយមិនប្រែប្រួល ។ ព្រោះហេតុនោះ ទើបត្រាស់ថា **អាសភណ្ឋានំ បដិជានាតិ** ។ បទថា **បរិសាសុ** គឺក្នុងបរិស័ទ ៨ ។ បទថា **សីហនាទំ នទតិ** សេចក្តីថា ទ្រង់បន្លឺដល់ការបន្លឺដ៏ប្រសើរបំផុត គឺមិនមានខ្លាចក្រែង ឬទ្រង់បន្លឺដល់ការបន្លឺដែលដូចគ្នានឹងការបន្លឺរបស់សីហៈ ។ អត្ថនេះគប្បីសម្តែងដោយសីហនាទសូត្រ ។ មួយប្រការទៀត រាជសីហ៍ ហៅថា **សីហ** ព្រោះគ្របសង្កត់ និងព្រោះសម្លាប់ យ៉ាងណា ព្រះតថាគត ហៅថា **សីហ** ព្រោះគ្របសង្កត់លោកធម៌ទាំងឡាយ និងព្រោះកម្ចាត់លទ្ធិរបស់សាស្តាដទៃៗ ដូច្នោះ ។ ការបន្លឺរបស់សីហៈតាមដែលពោលហើយយ៉ាងនេះ

*ឈ្មោះថា* **សីហនាទ** ។ *ក្នុងបទនោះ មានអធិប្បាយថា សីហៈ ដល់ព្រម ដោយកម្លាំងរបស់សីហៈ ហើយក្លៀវក្លាប្រាសចាកការព្រឺរោមព្រឺស្បែក រមែង បន្លឺសីហនាទក្នុងទីទាំងពួង យ៉ាងណា សូម្បីសីហៈ គឺព្រះតថាគត ដល់ព្រម ដោយកម្លាំងរបស់ព្រះតថាគតទាំងឡាយ ហើយក្លៀវក្លាប្រាសចាកការព្រឺរោម ព្រឺស្បែក ទ្រង់បន្លឺសីហនាទដែលដល់ព្រមដោយការទូលំទូលាយ នៃព្រះ ទេសនា មានវិធីផ្សេងៗ ដោយន័យជាដើមថា រូប ដោយប្រការដូច្នេះ ក្នុង បរិស័ទ ៨ ដូច្នេះ ព្រោះហេតុនោះ ទើបត្រាស់ថា ទ្រង់បន្លឺសីហនាទក្នុង បរិស័ទទាំងឡាយ ដូច្នេះ ។*

*ក្នុងបទថា* **ព្រហ្មចក្កំ បវត្តេតិ** *នេះ បទថា* **ព្រហ្មំ** *បានដល់ ប្រសើរ បំផុត គឺឧត្តមខ្ពង់ខ្ពស់ ។*

*សព្ទនៃ* **ចក្ក** *នេះ រមែងប្រាកដក្នុងសម្បត្តិ លក្ខណៈ អង្គនៃរថ ឥរិយាបថ ទាន រតនៈ និងក្នុងចក្រទាំងឡាយ មានធម្មចក្រជាដើម លោក បំណងយកក្នុងធម្មចក្រនេះ ឯធម្មចក្រនោះ ចែកចេញជា ២ យ៉ាង ។*

*ពិតហើយ* **ចក្ក** *សព្ទនេះ រមែងប្រាកដក្នុងសម្បត្តិ ក្នុងប្រយោគទាំង-ឡាយថា* **ចត្តារីមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ** *ម្នាលភិក្ខុទាំងឡាយ ចក្រនេះមាន ៤ យ៉ាង ចក្រនេះតែងប្រព្រឹត្តទៅដល់ពួក ទេវតា និងមនុស្សដែលប្រកបព្រម ចក្រ ... ។ ក្នុងលក្ខណៈ ដូចក្នុង ប្រយោគជាដើមថា* **បាទតលេសុ ចក្កានិ ជាតានិ** *ចក្រទាំងឡាយកើតមាន*

*ត្រង់ផ្ទៃព្រះបាទានៃព្រះរាជកុមារនេះ ។ ក្នុងអង្គនៃរថ ក្នុងប្រយោគជាដើមថា* **ចក្កំវ វហតោ បទំ** *ដូចកង់រទេះវិលតាមជានជើងគោ ដែលកំពុងអូសទៅ ។ ក្នុងឥរិយាបថ ដូចក្នុងប្រយោគជាដើមថា* **ចតុចក្កំ នវទ្វារំ** *សរីរៈមានចក្រ ៤ មានទ្វារ ៩ ។ ក្នុងទាន ដូចក្នុងប្រយោគជាដើមថា* **ទទំ ភុញ្ជ ច មា ច បមាទោ ចក្កំ បវត្តយ សព្វបាណិនំ** *សូមព្រះអង្គទ្រង់ឲ្យទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គញ៉ាំងចក្កធម៌ឲ្យប្រព្រឹត្តទៅ ។ ក្នុងរតនចក្រ ដូចក្នុងប្រយោគជាដើមថា* **ទិព្វំ ចក្ករតនំ បាតុរហោសិ** *ចក្ករតន៍ជាទិព្វមានកាំ ១០០០ ព្រមទាំងខ្នង និងដុំបរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដហើយ ។ ក្នុងធម្មចក្រ ដូចក្នុងប្រយោគជាដើមថា* **មយា បវត្តិតំ ចក្កំ** *ញ៉ាំងធម្មចក្រជាចក្រដ៏ប្រសើរដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងឧរចក្រ ដូចក្នុងប្រយោគជាដើមថា* **ឥច្ឆាហតស្ស បោសស្ស ចក្កំ មតិ មត្ថកេ** *ចក្រវិលកិនអំបែងក្បាលបុគ្គលដែលឥស្សាគ្របសង្កត់ហើយ ។ ក្នុងបហរចក្រ ដូចក្នុងបទនេះថា* **ខុរបរិយន្តេន ចេបិ ចក្កេន** *ដោយគ្រឿងចក្រ មានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ។ ក្នុងអសនិមណ្ឌល ដូចក្នុងប្រយោគជាដើមថា* **អសនិវិចក្កំ** *( ម្នាលភិក្ខុទាំងឡាយ ) កាំរន្ទះធ្លាក់ចំលើបុគ្គលណា ។ ឯសព្វ* **ចក្ក** *នេះលោកបំណងក្នុងធម្មចក្រ ។ ធម្មចក្រនោះ មាន ២ យ៉ាង គឺបដិវេធញ្ញាណ ១ ទេសនាញាណ ១ ក្នុងធម្មចក្រ ២ យ៉ាងនោះ ធម្មចក្រដែលបញ្ញាអប់រំហើយ នាំមកនូវអរិយផលដល់ខ្លួន ឈ្មោះថា* **បដិវេធញ្ញាណ** *។ ធម្មចក្រ*

ដែលករុណាអប់រំហើយ នាំមកនូវអរិយផលដល់សាវកទាំងឡាយ ឈ្មោះថា **ទេសនាញាណ** ។ ក្នុងញាណទាំង ២ នោះ បដិវេធញ្ញាណ មាន ២ យ៉ាង គឺកំពុងកើត ១ កើតឡើងហើយ ១ ។ ឯបដិវេធញ្ញាណនោះ តាំងអំពីទ្រង់ចេញអភិនេស្រ្កមណ៍ដល់អរហត្តមគ្គ ឈ្មោះថា កំពុងកើត ។ បដិវេធញ្ញាណ ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ ម្យ៉ាងទៀត បដិវេធញ្ញាណ តាំងអំពីជាន់តុសិត រហូតដល់អរហត្តមគ្គ ក្នុងមហាពោធិបល្ល័ង្ក ឈ្មោះថា កំពុងកើត ។ បដិវេធញ្ញាណ ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ បដិវេធញ្ញាណ តាំងអំពីព្រះពុទ្ធទីបង្ករ រហូតដល់អរហត្តមគ្គ ឈ្មោះថា កំពុងកើត ។ ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ ឯទេសនាញាណ ក៏មាន ២ យ៉ាង គឺកំពុងប្រព្រឹត្តទៅ ១ ប្រព្រឹត្តទៅហើយ ១ ។ ពិតហើយ ទេសនាញាណនោះ តាំងអំពីព្រះអញ្ញាកោណ្ឌញ្ញៈសម្រេចសោតាបត្តិមគ្គ ឈ្មោះថា កំពុងប្រព្រឹត្តទៅ ។ ក្នុងខណៈនៃផល ឈ្មោះថា ប្រព្រឹត្តទៅហើយ ។ ក្នុងញាណទាំង ២ យ៉ាងនោះ បដិវេធញ្ញាណ ជាលោកុត្តរ ទេសនាញាណ ជាលោកិយ ។ ញាណទាំង ២ នោះ មិនទូទៅដល់បុគ្គលដទៃ ជាញាណរបស់ឱរសនៃព្រះពុទ្ធទាំងឡាយតែម្យ៉ាង ។

ព្រះតថាគត ទ្រង់ដល់ព្រមដោយពលៈទាំងឡាយណា ទ្រង់ប្រកាសឋានៈនៃភាពជាអ្នកនាំ និងពលៈទាំងឡាយណា ដែលលើកឡើងខាងដើមថា ម្នាលសារីបុត្រ តថាគតពលញ្ញាណរបស់តថាគត ១០ យ៉ាងនេះឯង ឥឡូវ

នេះ ដើម្បីទ្រង់សម្តែងពលៈទាំងនោះដោយពិស្តារ ទើបត្រាស់ថា **ករតមានិ ធស ឥធ សារីបុត្ត តថាគតោ ឋានញ្ច ឋានតោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឋានញ្ច ឋានតោ** សេចក្តីថា នូវឋានៈដោយឋានៈ ។ ពិតហើយ **ការណៈ** លោកហៅថា **ឋាន** ព្រោះជាទីតាំងនៃផល ព្រោះជាទីកើតនិងជាទីប្រព្រឹត្តទៅនៃផល ព្រោះភាពដែលផលប្រព្រឹត្តទៅទាក់ទងនឹងការណៈនោះ ។ ព្រះមានព្រះភាគ កាលទ្រង់ដឹងច្បាស់ឋានៈនោះថា ធម៌ទាំងឡាយណាជាហេតុប្បច្ច័យដល់ធម៌ទាំងឡាយណា ព្រោះអាស្រ័យធម៌នោះៗ ទើបឈ្មោះថា **ឋាន** ធម៌ទាំងឡាយណា មិនជាហេតុប្បច្ច័យដល់ធម៌ទាំងឡាយណា ព្រោះអាស្រ័យធម៌នោះៗ ទើបឈ្មោះថា **អឋាន** ឈ្មោះថា ទ្រង់ដឹងច្បាស់ឋានៈដោយឋានៈ និងអឋានៈដោយអឋានៈតាមសេចក្តីពិត ។ ឯហេតុនោះបានឲ្យពិស្តារហើយក្នុងអភិធម្ម ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង នូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង តើដូចម្តេច ដូច្នេះ ។ បទថា **យំបិ** សេចក្តីថា ដោយញាណណា ។ បទថា **ឥទំបិ សារីបុត្ត តថាគតស្ស** សេចក្តីថា ឋានាឋានញ្ញាណនេះ ឈ្មោះថា ជាកម្លាំងរបស់តថាគត ។ គប្បីជ្រាបយោជន៍ក្នុងបទទាំងពួងយ៉ាងនេះ ។ បទថា **កម្មសមាទានានំ** សេចក្តីថា នៃកុសលកម្ម និងអកុសលកម្ម ដែលសមាទាន ហើយធ្វើ ឬកម្មនោះឯង ជាកម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ** បានដល់ដោយបច្ច័យ និងដោយហេតុ ។ ក្នុងបទនោះ គតិ ឧបធិ កាល និងបយោគ

ជាឋានៈ គឺជាកម្ម ជាហេតុរបស់វិបាក ។ កថាដោយពិស្ដារនៃញាណនេះ មកហើយក្នុងអភិធម្ម ដោយន័យជាដើមថា កម្មសមាទានដ៏លាមកពួកខ្លះ មានគតិសម្បត្តិរាំង មិនឲ្យផលក៏មាន ដូច្នេះ ។ បទថា **សព្វត្ថគាមិនី** សេចក្ដីថា ដែលឲ្យទៅកាន់គតិក្នុងទីទាំងពួង និងដែលមិនឲ្យទៅកាន់គតិ ។ បទថា **បដិបទំ** បានដល់ មគ្គ ។ បទថា **យថាភូតំ បជានាតិ** សេចក្ដីថា ទ្រង់ដឹងសភាវៈដោយមិនខុសក្លាំងក្លាត់នៃបដិបត្តិទាំងឡាយ ពោលគឺ កុសលចេតនា និងអកុសលចេតនាក្នុងវត្ថុមួយ ដោយន័យនេះថា កាលមនុស្សទាំងឡាយមកសម្លាប់សត្វមួយ ចេតនារបស់ជននេះ នឹងញ៉ាំងឲ្យទៅកាន់នរក ចេតនារបស់បុគ្គលនេះ នឹងញ៉ាំងឲ្យទៅកាន់កំណើតតិរច្ឆាន ។ កថាដោយពិស្ដារនៃញាណនេះ មកហើយក្នុងអភិធម្មនោះឯង ដោយន័យជាដើមថា បណ្ដាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិត នូវបដិបទាជាដំណើរទៅក្នុងទីទាំងពួង តើដូចម្ដេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់នរក ។ បទថា **អនេកធាតុំ** សេចក្ដីថា ធាតុច្រើន ដោយធាតុទាំងឡាយ មានចក្ខុធាតុជាដើម ឬកាមធាតុជាដើម ។ បទថា **នានាធាតុំ** សេចក្ដីថា ធាតុមានប្រការផ្សេងៗ ព្រោះធាតុទាំងនោះមានលក្ខណៈពិសេស ។ បទថា **លោកំ** គឺលោក បានដល់ ខន្ធ អាតយនៈ និងធាតុ ។ បទថា **យថាភូតំ បជានាតិ** សេចក្ដីថា ទ្រង់ចាក់ធ្លុះសភាវៈ ដោយមិនខុសក្លាំងក្លាត់នៃធាតុទាំងឡាយនោះៗ ។ ញាណនេះឲ្យពិស្ដារហើយ ក្នុងអភិធម្មនោះឯង ដោយន័យជាដើម

ថា បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិតនូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ គ្នា តើដូចម្តេច ព្រះតថាគតក្នុងលោក នេះ ទ្រង់ជ្រាបច្បាស់នូវសេចក្តីផ្សេងគ្នានៃខន្ធ ... ។ បទថា **នានាធិ-មុត្តិកតំ** បានដល់ ការមានអធ្យាស្រ័យផ្សេងៗ ដោយអធ្យាស្រ័យទាំង-ឡាយ មានថោកទាបជាដើម ។ ញាណនេះក៏ឲ្យពិស្តារក្នុងអភិធម្មនោះ ឯង ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់ តាមពិត នូវអធ្យាស្រ័យផ្សេងៗ គ្នា នៃពួកសត្វ តើដូចម្តេច ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា ពួកសត្វមានអធ្យាស្រ័យថោកទាបក៏មាន ដូច្នេះ ។ បទថា **បរសត្តានំ** បានដល់ សត្វជាប្រធានទាំងឡាយ ។ បទថា **បរបុគ្គលានំ** គឺសត្វថោកទាបទាំងឡាយ ដទៃអំពីសត្វជាប្រធាននោះ ។ ម្យ៉ាងទៀត ពីរបទនេះ មានអត្ថដូចគ្នា តែពោលទុកជា ២ យ៉ាង ដោយ អំណាចវេនេយ្យសត្វ ។ បទថា **ឥន្ទ្រិយបរោបរិយត្តំ** បានដល់ ឥន្ទ្រិយ ទាំងឡាយ មានសទ្ធាជាដើមក្រៃលែង និងទន់ខ្សោយ បានដល់ ការចម្រើន និងការវិនាស ។ កថាពិស្តារនៃញាណនេះ មកហើយក្នុងអភិធម្មនោះឯង ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់ តាមពិត នូវឥន្ទ្រិយចាស់ក្លា និងទន់របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ តើដូចម្តេច ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវអាសយៈ ( ធម៌ ជាទីនៅអាស្រ័យរបស់ពួកសត្វ ) ទ្រង់ជ្រាបច្បាស់នូវអនុសយៈ ( កិលេស ដែលដេកត្រាំនៅក្នុងសន្តានរបស់ពួកសត្វ ) ដូច្នេះ ។ បទថា **ឈានវិមោក្ខ-**

**សមាធិសមាបត្តីនំ** *សេចក្តីថា ឈាន ៤ មាន បឋមជ្ឈានជាដើម វិមោក្ខ ៨ មានពាក្យថា បុគ្គលមានរូប រមែងឃើញរូបទាំងឡាយជាដើម សមាធិ ៣ ដែលមានវិតក្ក និងវិចារៈជាដើម និងអនុបុព្វសមាបត្តិ មានបឋមជ្ឈានសមាបត្តិជាដើម ។ បទថា* **សង្កិលេសំ** *បានដល់ ធម៌ដែលជាចំណែកសៅហ្មង ។ បទថា* **វោទានំ** *បានដល់ ធម៌ដែលជាចំណែកផូរផង់ ។ បទថា* **វុដ្ឋានំ** *សេចក្តីថា ឈានដែលស្ទាត់ជំនាញ និងភវង្គផលសមាបត្តិ ដែលពោលហើយយ៉ាងនេះថា សូម្បីការផូរផង់ គឺការចេញ សូម្បីការចេញអំពីសមាធិនោះៗ ក៏ជាការចេញ ។ ពិតហើយ ឈានដែលស្ទាត់ជំនាញហើយដែលជាចំណែកខាងដើម រមែងជាបទដ្ឋានរបស់ឈានខ្ពស់ៗ សូម្បីការផូរផង់អំពីឈាននោះ ហៅថា ការចេញ ។ ការចេញអំពីឈានទាំងពួងរមែងមានដោយភវង្គ ។ ការចេញអំពីនិរោធសមាបត្តិ រមែងមានដោយផលសមាបត្តិ ។ លោកសំដៅដល់ការចេញនោះ ទើបពោលថា ការចេញចាកសមាធិនោះៗ ថាជាការចេញ ។ ញាណនេះ គប្បីធ្វើឲ្យពិស្តារក្នុងអភិធម្មដោយន័យជាដើមថា បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិត នូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញនៃឈាន វិមោក្ខសមាធិ និងសមាបត្តិ តើដូចម្តេច ពាក្យថា បុគ្គលមានឈាន បានដល់បុគ្គលមានឈាន ៤ ពួក គឺបុគ្គលមានឈាន ១ ពួក សម្គាល់នូវសម្បត្តិថាជាវិបត្តិក៏មាន ... ដូច្នេះ ។ ការវិនិច្ឆ័យដល់សព្វញ្ញុតញ្ញាណ ដោយការពោលដោយពិស្តារ បានពោលហើយ ក្នុងវិភង្គអដ្ឋកថា ឈ្មោះសម្មោហ-*

វិនោទនី ។ កថាពោលដោយបុព្វេនិវាសានុស្សតិ និងទិព្វចក្ខុញ្ញាណ មានពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ កថាពោលដោយការអស់ទៅនៃអាសវៈ មានពិស្តារហើយ ក្នុងភយភេរវសូត្រ ។ បទថា **ឥមានិ ខោ សារីបុត្ត** សេចក្តីថា រមែងធ្វើអប្បនាថា តថាគតបានពោលថា ម្នាលសារីបុត្រ តថាគតពលៈរបស់តថាគត ១០ ក្នុងកាលមុនឯណា តថាគតពលៈទាំងនេះឯង ។

ក្នុងបទនោះ មានបរវាទិកថាដូច្នេះ ។ ឈ្មោះថា ទសពលញ្ញាណ មិនមានការចែកចេញជាចំណែកមួយ សព្វញ្ញុតញ្ញាណប៉ុណ្ណោះ មានការចែកប្រភេទយ៉ាងនេះ ។ សេចក្តីនោះ មិនគប្បីឃើញយ៉ាងនោះ ។ ពិតហើយទសពលញ្ញាណមួយបែប សព្វញ្ញុតញ្ញាណមួយបែប ។ ទសពលញ្ញាណរមែងដឹងចំពោះកិច្ចរបស់ខ្លួនប៉ុណ្ណោះ សព្វញ្ញុតញ្ញាណរមែងដឹងកិច្ចរបស់ខ្លួនខ្លះ កិច្ចដ៏សេសអំពីកិច្ចរបស់ខ្លួនខ្លះ ។ ក្នុងទសពលញ្ញាណទាំងឡាយ ញាណទី ១ រមែងដឹងចំពោះហេតុ និងមិនមែនហេតុប៉ុណ្ណោះ ។ ញាណទី ២ រមែងដឹងលំដាប់នៃកម្ម និងលំដាប់នៃវិបាកប៉ុណ្ណោះ ។ ញាណទី ៣ រមែងដឹងការកំណត់កម្មប៉ុណ្ណោះ ។ ញាណទី ៤ រមែងដឹងហេតុនៃភាពដែលធាតុផ្សេងៗគ្នាប៉ុណ្ណោះ ។ ញាណទី ៥ រមែងដឹងអជ្ឈាស្រ័យ និងអធិមុត្តិរបស់សត្វទាំងឡាយប៉ុណ្ណោះ ។ ញាណទី ៦ រមែងដឹងភាពដែលឥន្ទ្រិយទាំងឡាយចាស់ក្លា និងទន់ខ្សោយប៉ុណ្ណោះ ។ ញាណទី ៧ រមែងដឹងកិច្ច មានការសៅហ្មងជាដើមនៃឥន្ទ្រិយប៉ុណ្ណោះ ព្រមទាំងឈានជាដើមប៉ុណ្ណោះ ។ ញាណទី ៨ រមែងដឹងការបន្តនៃខន្ធ ដែលធ្លាប់នៅអាស្រ័យក្នុងជាតិមុនប៉ុណ្ណោះ ។ ញាណ

ទី ៩ រមែងដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយប៉ុណ្ណោះ ។ ញាណទី ១០ រមែងដឹងការកំណត់សច្ចៈប៉ុណ្ណោះ ។ ឯសព្វញ្ញុតញ្ញាណ រមែងដឹងច្បាស់នូវកិច្ចដែលគួរដឹងដោយញាណទាំងនោះ និងវត្ថុដែលក្រៅលែងជាងកិច្ចនោះ ។ ឯកិច្ចនៃញាណទាំងនោះ រមែងមិនធ្វើកិច្ចគ្រប់យ៉ាង ។ ព្រោះញាណនោះជាឈានហើយ រមែងមិនអាចដើម្បីជាអប្បនា ជាឥទ្ធិហើយ រមែងមិនអាចដើម្បីសម្តែងឫទ្ធិបាន ជាមគ្គ ក៏មិនអាចដើម្បីញុំាងកិលេសទាំងឡាយឲ្យអស់ទៅបាន ។ម្យ៉ាងទៀត បរវាទីគប្បីត្រូវសួរយ៉ាងនេះថា ដែលឈ្មោះថាទសពលញ្ញាណនោះ មានវិតក្ក ឬមានវិចារៈ គ្រាន់តែមិនមានវិតក្ក មានតែវិចារៈ មិនមានវិតក្ក មិនមានវិចារៈ ជាកាមាវចរ ជារូបាវចរ ជាលោកិយជាលោកុត្តរ ដូច្នេះ ។ កាលដឹងក៏នឹងឆ្លើយថា ញាណ ៧ តាមលំដាប់ មានវិតក្ក មានវិចារៈ ។ និងឆ្លើយថា ញាណ ២ ដទៃអំពីញាណ ៧ នោះ មិនមានវិតក្ក មិនមានវិចារៈ ។ និងឆ្លើយថា អាសវក្ខយញ្ញាណ គប្បីមានវិតក្កមានវិចារៈ គប្បីគ្រាន់តែមិនមានវិតក្ក មានវិចារៈ ។ និងឆ្លើយថា ញាណ ៧ តាមលំដាប់យ៉ាងនោះ ជាកាមាវចរ ញាណ ២ ក្រៅអំពីនោះ ជារូបាវចរ ញាណ ១ ចុងក្រោយ ជាលោកុត្តរ ។ និងឆ្លើយថា ឯសព្វញ្ញុតញ្ញាណមានវិតក្ក មានវិចារៈផង ជាកាមាវចរផង ជាលោកិយផង ។ បណ្ឌិតដឹងការពណ៌នាតាមលំដាប់បទក្នុងទីនេះ ដោយប្រការដូច្នេះហើយ ឥឡូវនេះ គប្បីជ្រាបទសពលយ៉ាងនេះថា បានពោលហើយតាមលំដាប់នេះ ព្រោះព្រះតថាគតទ្រង់ឃើញភាវៈមានកិលេសជាគ្រឿងរាំង ដែលជាឋានៈ និងអឋានៈនៃការ

សម្រេចការអស់ទៅនៃអាសវៈ និងការមិនសម្រេចរបស់វេនេយ្យសត្វដោយឋានាឋានញ្ញាណមុននោះឯង ព្រោះទ្រង់ឃើញឋានៈនៃការឃើញប្រពៃ ជាលោកិយ និងទ្រង់ឃើញជាឋានៈនៃការឃើញខុសក្លាំងក្លាត់ទៅ លំដាប់នោះទ្រង់ឃើញភាវៈមានវិបាកជាគ្រឿងរារាំងរបស់វេនេយ្យសត្វទាំងនោះ ដោយកម្មវិបាកញ្ញាណ ព្រោះទ្រង់ឃើញហេតុបដិសន្ធិ ៣ ទ្រង់ឃើញភាវៈមានកម្មជាគ្រឿងរារាំងដោយសព្វត្ថគាមិនីបដិបទាញាណ ព្រោះទ្រង់ឃើញការមិនមាននៃអនន្តរិយកម្ម ទ្រង់ឃើញចរិយាពិសេស ដើម្បីទ្រង់សម្តែងធម៌ ដែលសមគួរដល់វេនេយ្យសត្វទាំងឡាយ ដែលមិនមានសេចក្តីអាល័យយ៉ាងនេះ ដោយអនេកធាតុនានាធាតុញ្ញាណ ព្រោះទ្រង់ឃើញការប្រព្រឹត្តទៅផ្សេងៗ នៃធាតុលំដាប់នោះ ទ្រង់ឃើញអធិមុត្តិរបស់វេនេយ្យសត្វទាំងនោះ ដោយនានាធិមុត្តិកតាញាណ ដើម្បីទ្រង់មិនប្រកបសេចក្តីព្យាយាម ក៏ទ្រង់សម្តែងព្រះធម៌ដោយអំណាចនៃអធិមុត្តិ លំដាប់នោះ ដើម្បីទ្រង់សម្តែងធម៌តាមសតិ តាមកម្លាំងដល់វេនេយ្យសត្វទាំងឡាយ ដែលមានអធិមុត្តិ បានឃើញហើយយ៉ាងនេះ ទ្រង់រមែងឃើញភាពដែលសត្វ មានឥន្ទ្រិយទន់ខ្សោយ និងចាស់ក្លាដោយឥន្ទ្រិយបរោបរិយត្តិញ្ញាណ ព្រោះទ្រង់ឃើញភាពដែលឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើម ជាធម្មជាតចាស់ក្លា និងទន់ខ្សោយ បើវេនេយ្យសត្វទាំងនោះ មានឥន្ទ្រិយដែលកំណត់ដឹងហើយយ៉ាងនេះទន់ខ្សោយ និងចាស់ក្លា រមែងនៅក្នុងទីឆ្ងាយ ព្រោះវេនេយ្យសត្វជាអ្នកជំនាញក្នុងឈានទាំងឡាយ មានបឋមជ្ឈានជាដើម តែចូលដល់បានរហ័ស ដោយឥទ្ធិពិសេស

*នោះឯង កាលចូលដល់ហើយ ក៏ចូលដល់ថ្នាក់បុព្វជាតិរបស់សត្វទាំងនោះ ដោយបុព្វេនិវាសានុស្សតិញ្ញាណ កាលទ្រង់ឃើញសម្បត្តិចិត្តពិសេសដោយចេតោបរិយញ្ញាណ ដែលទ្រង់សម្រេចដោយអានុភាពទិព្វចក្ខុ ឈ្មោះថាទ្រង់សម្តែងធម៌ដើម្បីការអស់ទៅនៃអាសវៈ ព្រោះការដែលព្រះអង្គទ្រង់ប្រាសចាកការវង្វេងដោយបដិបទា ដែលញុំាងសត្វឲ្យដល់ការអស់ទៅនៃអាសវៈដោយអានុភាពនៃអាសវក្ខយញ្ញាណ ។*

*ក្នុងបទថា* **តំ សារីបុត្ត វាចំ អប្បហាយ** *ដូច្នេះជាដើម បុគ្គលពោលថា អញនឹងមិនពោលវាចាបែបនេះ ឈ្មោះថា លះវាចានោះ ។ កាលគិតថា អញនឹងមិនញុំាងការគិតបែបនេះកើតឡើងទៀត ឈ្មោះថា លះការគិត ។ កាលលះបង់ថា អញនឹងមិនប្រកាន់ការឃើញបែបនេះទៀត ឈ្មោះថា រលាស់នូវការឃើញ ។ កាលមិនធ្វើយ៉ាងនោះ ឈ្មោះថា មិនលះបង់ មិនរលាស់ ។ បុគ្គលនោះក៏ទៀងពិតដែលនឹងធ្លាក់នរក ព្រោះដូច្នោះ គប្បីជ្រាបថា តាំងនៅក្នុងនរកនោះឯង ដូចត្រូវនាយនិរយបាលទាំងឡាយនាំមកដាក់នៅក្នុងនរក ។ ឥឡូវនេះ កាលទ្រង់សម្តែងឧបមាដែលឲ្យសម្រេចប្រយោជន៍ដល់បុគ្គលនោះ ទើបត្រាស់ថា* **សេយ្យថាបិ** *ជាដើម ។ ក្នុងបទទាំងនោះ គប្បីជ្រាបសីល សមាធិ បញ្ញាដែលជាលោកិយ និងលោកុត្តរ ក្នុងបទថា* **សីលសម្បន្នោ** *ដូច្នេះជាដើម ។ ភិក្ខុរមែងគួរឲ្យរិលត្រឡប់ដោយអំណាចនៃលោកុត្តរនោះឯង ។ ភិក្ខុនេះដល់ព្រមដោយសីល ដោយវាចាប្រពៃ ការងារប្រពៃ និងការចិញ្ចឹមជីវិតប្រពៃ ។ ដល់ព្រមដោយសមាធិ ដោយសេចក្តីព្យាយាមប្រពៃ រឭក*

ប្រពៃ និងតាំងចិត្តប្រពៃ ។ ដល់ព្រមដោយបញ្ញា ដោយការឃើញប្រពៃ និងការត្រិះរិះប្រពៃ ។ កិច្ចដែលដល់ព្រមដោយសីលជាដើមយ៉ាងនេះ រមែងសង្ឃឹមអរហត្ត គឺរមែងសម្រេចអរហត្តក្នុងទិដ្ឋធម៌នោះឯង គឺក្នុងអត្តភាពនេះឯង យ៉ាងណា ម្នាលសារីបុត្រ តថាគតរមែងពោលឧបមេយ្យនេះ គឺការណ៍នេះ បែបនេះ ដូច្នោះ ។ ទ្រង់សម្តែងថា ផលមិនប្រែប្រួលក្នុងលំដាប់នៃមគ្គរមែងកើតឡើង យ៉ាងណា បដិសន្ធិក្នុងនរកមិនប្រែប្រួលក្នុងលំដាប់នៃចុតិរបស់បុគ្គលនេះ ក៏រមែងមានដូច្នោះដូចគ្នា ។ ដែលឈ្មោះថា ឧបមា ដែលត្រាស់ឲ្យជួន់ក្រៃលែងឡើងដោយឧបមានេះ រមែងមិនមានក្នុងពុទ្ធវចនៈទាំងមូល ។ ក្នុងបទថា **វេសារជ្ជានិ** នេះ ជាបដិបក្ខចំពោះការភ័យខ្លាច ឈ្មោះថា **វេសារជ្ជ** នេះជាឈ្មោះរបស់ញាណដែលសម្រេចអំពីសោមនស្ស ដែលកើតឡើងដល់បុគ្គលពិចារណាដល់ការភ័យខ្លាចក្នុងឋាន: ៤ ។ បទថា **សម្មា-សម្ពុទ្ធស្ស តេ បដិជានតោ** សេចក្តីថា ទ្រង់ប្តេជ្ញាយ៉ាងនេះថា ជាព្រះអរហន្តសម្មាសម្ពុទ្ធ ធម៌ទាំងអស់តថាគតបានត្រាស់ដឹងក្រៃលែងហើយ ។ បទថា **អនភិសម្ពុទ្ធា** សេចក្តីថា ធម៌ទាំងនេះ ទ្រង់មិនទាន់បានត្រាស់ដឹងហើយ ។ បទថា **តត្រ វត** សេចក្តីថា ក្នុងធម៌ដែលសម្តែងយ៉ាងនេះថាមិនទាន់បានត្រាស់ដឹងហើយទាំងនោះហ្ន៎ ។ បទថា **សហ ធម្មេន** សេចក្តីថា ដោយពាក្យដែលមានហេតុមានការណ៍ ដូចសុនក្ខត្តរើរវាយ មិនមានប្រមាណដូច្នេះ ។ បុគ្គលក្តី ធម៌ក្តី លោកសំដៅយកនិមិត្ត ក្នុងបទថា **និមិត្តមេតំ** នេះ ។ ក្នុងបទនោះ មានអធិប្បាយយ៉ាងនេះថា តថាគតមិនឃើញបុគ្គល

ដែលចោទថា តថាគតមិនឃើញធម៌ដែលសម្តែងហើយ នឹងចោទតថាគតថា ធម៌ឈ្មោះនេះ ទ្រង់មិនទាន់បានត្រាស់ដឹងឡើយ ។ បទថា **ខេមប្បត្តោ** បាន ដល់ សេចក្តីក្សេម ។ ពីរបទដ៏សេសជាវេវចនៈរបស់បទនេះឯង ។ ឯបទ ទាំងអស់នោះ ត្រាស់សំដៅដល់វេសារជ្ជញាណប៉ុណ្ណោះ ។ កាលព្រះទស- ពលមិនឃើញបុគ្គលដែលចោទ ឬធម៌ដែលជាហេតុចោទ ដែលមិនទាន់បាន ត្រាស់ដឹងហើយ ថាធម៌ឈ្មោះនេះ ទ្រង់មិនទាន់បានត្រាស់ដឹងហើយ ដូច្នេះ ឬកាលពិចារណាថា តថាគតជាព្រះពុទ្ធ ដោយសភាពនោះឯង ពោលថា តថាគតជាព្រះពុទ្ធ ដូច្នេះ សោមនស្សដ៏មានកម្លាំងក្រៃលែងរមែងកើតឡើង ។ ញាណដែលសម្បយុត្តដោយសោមនស្សនោះ ឈ្មោះថា **វេសារជ្ជ** ។ ទ្រង់ សំដៅដល់វេសារជ្ជៈនោះ ទើបត្រាស់ពាក្យថា **ខេមប្បត្តោ** ដូច្នេះជាដើម ។ គប្បីជ្រាបអធិប្បាយក្នុងបទទាំងពួង ដូច្នេះ ។ ធម៌ទាំងឡាយ ឈ្មោះថា **អន្តរាយិក** ព្រោះអត្ថថា ធ្វើអន្តរាយ ក្នុងបទនេះថា **អន្តរាយិកាធម្មា** ដូច្នេះ ។ ធម៌ទាំងនោះ ដោយអត្ថក៏បានដល់ អាបត្តិ ៧ កង ដែលក្លែងកន្លង ល្មើស ។ ពិតហើយ កងអាបត្តិដែលក្លែងល្មើសហើយ ដោយហោចសូម្បី ទុក្កដ និងទុព្ភាសិតក៏ធ្វើអន្តរាយដល់មគ្គ និងផលទាំងឡាយបាន ។ តែក្នុង ទីនេះលោកបំណងយកមេថុនធម្ម ។ ការប្រាសចាកសេចក្តីសង្ស័យតែម្យ៉ាង របស់ភិក្ខុរូបណាមួយដែលសេពមេថុន រមែងជាអន្តរាយដល់មគ្គ និងផល ទាំងឡាយបាន។ បទថា **យស្ស ខោ បន តេសុ អត្ថាយ** សេចក្តីថា ដើម្បី ប្រយោជន៍ណា ក្នុងប្រយោជន៍ទាំងឡាយ មានការអស់ទៅនៃរាគៈជាដើម ។

បទថា **ធម្មោ ទេសិតោ** សេចក្តីថា ធម៌ មានការចម្រើនអសុភជាដើម ដែលលោកសម្តែងហើយ ។ បទថា **តត្រ វត មំ** បានដល់ ការចោទ ចំពោះតថាគតក្នុងធម៌ជាគ្រឿងនាំចេញចាកទុក្ខនោះ ។ បទដ៏សេស គប្បី ជ្រាបដោយន័យដែលពោលហើយនោះឯង ។

[ ១៦៨ ] បទថា **អដ្ឋ ខោ ឥមា សារីបុត្ត** នេះ ទ្រង់ប្រារព្ធព្រោះ ហេតុអ្វី ។ ព្រោះដើម្បីទ្រង់សម្តែងកម្លាំងនៃវេសារជ្ជញ្ញាណ ។ ដូចព្រះធម្ម- កថិកឈមចុះកាន់បុរសអ្នកឈ្លាសហើយ រមែងប្រាកដជាអ្នកឈ្លាស ដោយ ពាក្យដែលអាចញុំាងចិត្តរបស់វិញ្ញូជនទាំងឡាយឲ្យត្រេកអរ យ៉ាងណា ភាព ដែលវេសារជ្ជញ្ញាណឲ្យក្លៀវក្លា ដែលបរិស័ទទាំង ៨ នេះ អាចដឹងបាន ដូច្នោះ ព្រោះដូច្នោះ ដើម្បីទ្រង់សម្តែងកម្លាំងនៃវេសារជ្ជញ្ញាណ ទើបត្រាស់ ថា **អដ្ឋ ខោ ឥមា សារីបុត្ត** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ខត្តិយបរិសា** បានដល់ ទីអង្គុយប្រជុំរបស់ក្សត្រទាំងឡាយ ។ បទទាំងពួង មានន័យដូចគ្នា ។ ទីកន្លែងដែលពួកមារទាំងឡាយអង្គុយប្រជុំ គប្បីជ្រាបថា មារបរិស័ទ ម្យ៉ាងទៀត បរិស័ទរបស់មារទាំងអស់នោះ មិនបានកាន់យក ដោយអំណាចនៃការឃើញទីកន្លែងដ៏លើស ។ ព្រោះមនុស្សទាំងឡាយ រមែង មិនអាចដើម្បីនឹងពោលពាក្យប្រក្រតីថា ព្រះរាជាប្រថាប់គង់ក្នុងទីនេះ ញើស ទាំងឡាយ រមែងហូរចេញអំពីក្លៀក ។ ខត្តិយបរិស័ទប្រសើរយ៉ាងនេះ ។ ព្រាហ្មណ៍ទាំងឡាយ រមែងជាអ្នកឈ្លាសក្នុងវេទ ៣ ។ គហបតីទាំងឡាយ រមែងជាអ្នកឈ្លាសក្នុងវោហារផ្សេងៗ និងក្នុងការគិតអក្ខរៈ ។ សមណៈទាំង-

ឡាយរមែងជាអ្នកឈ្លាសក្នុងវាទៈរបស់ខ្លួន និងវាទៈរបស់អ្នកដទៃ ។ ឈ្មោះថា ការពោលធម្មកថា ក្នុងកណ្តាលបរិស័ទទាំងនោះ ជាការៈធ្ងន់ក្រៃលែង ។ សូម្បីអមនុស្សទាំងឡាយក៏ជាបុគ្គលប្រសើរ ។ ព្រោះកាលគ្រាន់តែពោលថា អមនុស្ស សរីរៈទាំងមូលរមែងញ័រ ។ សត្វទាំងឡាយបានឃើញរូប ឬស្តាប់សំឡេងរបស់អមនុស្សនោះ រមែងប្រាសចាកសញ្ញាបាន បរិស័ទរបស់អមនុស្សជាបុគ្គលប្រសើរយ៉ាងនេះ ។ ឈ្មោះថា ការសម្តែងធម្មកថាក្នុងអមនុស្សបរិស័ទទាំងនោះ រមែងជាការៈធ្ងន់ក្រៃលែង ។ អមនុស្សបរិស័ទទាំងនោះ គប្បីជ្រាបថា លោកកាន់យកហើយ ដោយអំណាចនៃការឃើញឋានៈដ៏ប្រសើរ ដោយប្រការដូច្នេះ ។ បទថា **អជ្ឈោគាហាមិ** គឺតាមចូលទៅ ។ បទថា **អនេកសតំ ខត្តិយបរិសំ** គឺដូចជាសមាគមព្រះបាទពិម្ពិសារ សមាគមព្រះញាតិ និងសមាគមលិច្ឆវី ។ រមែងបានសូម្បីក្នុងចក្កវាឡដទៃ ។ សួរថា ព្រះមានព្រះភាគទ្រង់ទៅកាន់ចក្កវាឡដទៃឬ ឆ្លើយថា អើ ទ្រង់យាងទៅ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា បុគ្គលទាំងនោះយ៉ាងណា ព្រះអង្គក៏យ៉ាងនោះឯង ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ចំណែកតថាគត ចូលទៅកាន់ខត្តិយបរិស័ទជាច្រើនរយ រមែងស្គាល់ច្បាស់ក្នុងខត្តិយបរិស័ទនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ចូលទៅសាកច្ឆាជាមួយផង សម្បុររបស់ជនទាំងនោះ ក្នុងពួកបរិស័ទនោះ យ៉ាងណា សម្បុររបស់តថាគត យ៉ាងនោះដែរ សំឡេងរបស់ជនទាំងនោះ យ៉ាងណា សំឡេងរបស់តថាគតយ៉ាងនោះដែរ មួយទៀត

តថាគតបានញ៉ាំងជនទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ជនទាំងនោះ មិនស្គាល់តថាគតថា ជនដែលកំពុងនិយាយនេះ តើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ តថាគតលុះញ៉ាំងជនទាំងនាះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បាត់រូបទៅ កាលដែលតថាគតបាត់រូបទៅហើយ ឯជនទាំងនោះ នៅតែមិនស្គាល់តថាគតថា ជនដែលបាត់ទៅហើយនេះ តើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ពួកក្សត្រទ្រង់ប្រដាប់ តាក់តែងដោយសង្វារមាលា និងគ្រឿងក្រអូបជាដើម ទ្រទ្រង់សំពត់ច្រើនពណ៌ ទ្រង់ពាក់កុណ្ឌលកែវមណី ទ្រទ្រង់មូលី គឺផ្នួងសក់ ឯព្រះមានព្រះភាគ ទ្រង់តាក់តែងព្រះអង្គដូច្នោះឬ ក្សត្រទាំងនោះមានសម្បុរសខ្វះ ខ្មៅខ្វះ សណ្តែកបាយខ្វះ ព្រះសាស្តាទ្រង់ក៏ដូច្នោះឬ ។ ព្រះសាស្តាយាងទៅដោយភេទបព្វជិតរបស់ព្រះអង្គនោះឯង តែទ្រង់ប្រាកដដូចគ្នានឹងសត្វទាំងនោះ កាលយាងទៅហើយ ទ្រង់បង្ហាញព្រះអង្គ ប្រថាប់លើរាជាសនៈ រមែងដូចគ្នានឹងក្សត្រទាំងនោះថា ក្នុងថ្ងៃនេះ ព្រះរាជារបស់ពួកយើងរុងរឿងក្រៃលែងដូច្នេះ ។ បើក្សត្រទាំងនោះមានសំឡេងបែក ឬសំឡេងជ្រៅ ឬសំឡេងក្អក ព្រះសាស្តាក៏ទ្រង់សម្តែងធម៌ដោយសំឡេងព្រហ្មនោះឯង បទនេះថា តថាគតក៏មានសំឡេងដូច្នោះ ត្រាស់សំដៅដល់លំដាប់ភាសា មនុស្សទាំងឡាយបានស្តាប់សំឡេងនោះហើយ រមែងគិតថា ថ្ងៃនេះ ព្រះរាជាត្រាស់ដោយសំឡេងពីរោះ ។ កាលព្រះមានព្រះភាគត្រាស់ហើយ ទ្រង់ចៀសចេញ

ទៅ ឃើញព្រះរាជាយានមកទៀត ក៏កើតការពិចារណា បុគ្គលនេះជានរណាហ្ន៎ ។ ទើបព្រះអង្គត្រាស់ព្រះតម្រាស់នេះថា បុគ្គលនេះជានរណាហ្ន៎ នៅក្នុងទីនេះ ឥឡូវនេះ សម្តែងដោយសំឡេងពីរោះ ដោយភាសាមគធៈ ដោយភាសាសីហឡ បាត់ទៅ ជាទេវតា ឬមនុស្ស ដូច្នេះ ។ សួរថា ទ្រង់សម្តែងធម៌ដល់បុគ្គលទាំងឡាយ ដែលមិនស្គាល់យ៉ាងនេះដើម្បីអ្វី ឆ្លើយថា ដើម្បីប្រយោជន៍ដល់វាសនា ។ ព្រះអង្គទ្រង់សម្តែងដើម្បីអនាគតថា ធម៌បានស្តាប់យ៉ាងនេះ រមែងជាបច្ច័យក្នុងអនាគតនោះឯង ។ បទថា **សន្និសិន្នបុព្វំ** បានដល់ ធ្លាប់រួមអង្គុយប្រជុំ ។ បទថា **សល្លបិតបុព្វំ** គឺធ្លាប់ធ្វើការសន្ទនា ។ បទថា **សាកច្ឆា** សេចក្តីថា ធ្លាប់ចូលសន្ទនាធម៌ ។ គប្បីជ្រាបការចូលរួមប្រជុំ ដោយអំណាចសមាគម មានសមាគមសោណទណ្ឌព្រាហ្មណ៍ និងដោយអំណាចនៃចក្កវាឡដទៃ ដោយបទថា **អនេកសតំ ព្រាហ្មណបរិសំ** ជាដើម ។

[ ១៦៩ ] បទថា **យោនិ** ក្នុងបទនេះថា **ចតស្សោ ខោ ឥមា សារីបុត្ត យោនិយោ** ជាឈ្មោះនៃចំណែកខន្ធខ្លះ ជាឈ្មោះនៃការណៈខ្លះ ជាឈ្មោះនៃអង្គកំណើតខ្លះ ។ ចំណែករបស់ខន្ធ បទថា **យោនិ** ដូចក្នុងប្រយោគថា **ចតស្សោ នាគយោនិយោ ចតស្សោ សុបណ្ណយោនិយោ** ម្នាលភិក្ខុទាំងឡាយ កំណើតរបស់នាគនេះមាន ៤ យ៉ាង ម្នាលភិក្ខុទាំងឡាយ កំណើតគ្រុឌនេះមាន ៤ យ៉ាង ។ ការណៈ ឈ្មោះថា **យោនិ** ដូចក្នុងប្រយោគជាដើមថា **យោនិ ហេសា ភូមិជ ផលស្ស អធិគមាយ** ម្នាលភូមិជៈ ព្រោះ

មានហេតុដែលនាំឲ្យត្រាស់ដឹងនូវផលបាន ។ អង្គកំណើត ឈ្មោះថា **យោនិ** ដូចក្នុងប្រយោគជាដើមថា **ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ** តថាគតនឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ក៏ទេ ។ **យោនិ** ក្នុងទីនេះ លោកបំណងយកចំណែករបស់ខន្ធ ។ ក្នុងកំណើតទាំងនោះ សត្វដែលកើតក្នុងស៊ុត ឈ្មោះថា **អណ្ឌជៈ** ។ សត្វដែលកើតក្នុងគភ៌ ឈ្មោះថា **ជលាពុជៈ** ។ សត្វដែលកើតក្នុងញើសក្អែល ហៅថា **សំសេទជៈ** ។ សត្វដែលកើតឡើងចំពោះ វៀរហេតុទាំងនោះ កើតដូចផុសឡើង ឈ្មោះថា **ឱបបាតិកៈ** ។ បទថា **អភិនិព្ពជ្ជ ជាយន្តិ** គឺរមែងកើតដោយអំណាចនៃការទម្លាយចេញមក ។ លោកសម្តែងឋានៈដែលមិនគួរប្រាថ្នាទាំងឡាយ ដោយបទថា **បូតិកុណបេ** ជាដើម ។ សត្វទាំងឡាយរមែងកើតក្នុងឋានៈដែលគួរប្រាថ្នា មានសប្បិ ស្ករ ទឹកឃ្មុំ និងទឹកអំពៅជាដើមដូចគ្នា ។ ទេវតាជាន់ខ្ពស់ តាំងអំពីចាតុម្មហារាជិកា ក្នុងបទថា **ទេវា** ជាដើម ចាត់ជាឱបបាតិកៈដូចគ្នា ។ ឯភុម្មទេវតាទាំងឡាយមានកំណើត ៤ ។ បទថា **ឯកច្ចេ ច មនុស្សា** សេចក្តីថា ក្នុងមនុស្សទាំងឡាយ មនុស្សពួកខ្លះជាឱបបាតិកៈដូចទេវតាដែរ ។ តែមនុស្សពួកនោះ ដោយច្រើនកើតអំពីគភ៌ ។ ក្នុងទីនេះ សូម្បីកើតអំពីស៊ុត ដូចព្រះថេរៈពីររូប ឈ្មោះភាតិយៈ ជាកូនរបស់កោន្តៈ ។ ដែលកើតអំពីញើសក្អែល មានបោក្ខរសាតិព្រាហ្មណ៍ និងព្រះនាងបទុមវតីទេវី ដែលកើតក្នុងត្របកឈូកជាដើម ។ ក្នុងវិនិបាតិកទាំង-ឡាយ និជ្ឈាមប្រេត និងតណ្ហិកប្រេត ជាឱបបាតិកៈដូចគ្នា ដូចគ្នានឹងសត្វ

នរកទាំងឡាយដែរ ប្រេតដ៏សេសមានកំណើត ៤ ។ យក្ខទាំងឡាយក្តី សត្វទាំងឡាយ មានសត្វជើង ៤ បក្សី និងពស់ទាំងពួងជាដើមក្តី ទាំងអស់មានកំណើត ៤ ដូចវិនិបាតិកៈទាំងនោះ ។

គតិទាំងឡាយ គប្បីទៅដោយអំណាចនៃកម្មដែលធ្វើល្អ និងធ្វើអាក្រក់ ក្នុងពាក្យនេះថា ម្នាលសារីបុត្រ គតិ ៤ យ៉ាងនេះឯង ។ មួយប្រការទៀត ឈ្មោះថា **គតិ** មានច្រើនយ៉ាង គឺគតិគតិ និព្វត្តិគតិ អជ្ឈាយគតិ វិភវគតិ និងនិប្ផត្តិគតិ ។ ក្នុងគតិទាំងនោះ គតិថា អញស្គាល់ទៅកាន់គតិណា និងគតិថា ទេវតា គន្ធព្វ និងមនុស្ស រមែងមិនដឹងគតិរបស់បុគ្គលណា ដូច្នេះ ឈ្មោះថា **គតិគតិ** ។ គតិថា ខ្ញុំមិនដឹងគតិ ឬអគតិរបស់ភិក្ខុទាំងឡាយ ដែលជាអ្នកមានសីលទាំងនេះ ដូច្នេះ ឈ្មោះថា **និព្វត្តិគតិ** ។ គតិនេះថា ម្នាលព្រហ្ម តថាគត ដឹងច្បាស់គតិ និងដឹងច្បាស់ចុតិរបស់អ្នកយ៉ាងនេះឯង ឈ្មោះថា **អជ្ឈាសយគតិ** ។ គតិនេះថា **វិភវ** ជាគតិធម៌ទាំងឡាយ និព្វាន ជាគតិរបស់ព្រះអរហន្ត ឈ្មោះថា **វិភវគតិ** ។ គតិនេះថា គតិមាន ២ យ៉ាង ប៉ុណ្ណោះ មិនដទៃឡើយ ឈ្មោះថា **និប្ផត្តិគតិ** ។ ក្នុងគតិទាំងនោះ លោកបំណងយកគតិគតិក្នុងទីនេះ ។

[ ១៧០ ] ឈ្មោះថា **និរយ** ដោយអត្ថថា ប្រាសចាកការត្រេកអរ ដោយអត្ថថា មិនមានការសប្បាយចិត្ត ក្នុងបទថា **និរយោ** ជាដើម ។ ឈ្មោះថា **តិរច្ឆាន** ព្រោះអត្ថថា ដើរទទឹង ។ កំណើតរបស់តិរច្ឆានទាំងនោះ ឈ្មោះថា **តិរច្ឆានយោនិ** ។ ឈ្មោះថា **បេតវិស័យ** ព្រោះអត្ថថា ជាវិស័យនៃសត្វ

ទាំងឡាយដែលដល់នូវការស្លាប់ទៅហើយ ។ ឈ្មោះថា **មនុស្ស** ព្រោះអត្ថថា ជាអ្នកមានចិត្តខ្ពស់ហើយ ។ ឈ្មោះថា **ទេវ:** ព្រោះវិគ្គហៈថា លេងនឹងកាមគុណ ៥ និងអានុភាពរៀងៗ ខ្លួន ។ ខន្ធទាំងឡាយព្រមជាមួយឱកាសឈ្មោះថា **និរយ** ក្នុងបទថា **និរយំ ចាហំ សារីបុត្ត** ជាដើម ។ ក្នុងបទថា **តិរច្ឆានយោនឹ ច** ជាដើមក៏ន័យនេះដូចគ្នា ។ ទ្រង់សម្តែងកម្មដែលប្រព្រឹត្តទៅកាន់គតិប៉ុណ្ណោះ ដែលត្រាស់ដោយបទទាំង ២ ថា **មគ្គំ បដិបទំ។** បទថា **យថា ច បដិបន្នោ** សេចក្តីថា ប្រព្រឹត្តទៅដោយផ្លូវណា ដោយបដិបទាណា ព្រោះដូច្នោះ ទាំង ២ បទរួមចូលគ្នា រមែងប្រាកដឈ្មោះថា **អបាយ** ព្រោះប្រាសចាកការលូតលាស់ ពោលគឺ សេចក្តីចម្រើន ឬសេចក្តីសុខ ក្នុងបទថា **អបាយំ** ដូច្នេះជាដើម ។ ឈ្មោះថា **ទុគ្គតិ** ព្រោះអត្ថថា ជាគតិគឺជាទីតាំងនៃទុក្ខ ។ ឈ្មោះថា **វិនិបាត** ព្រោះជាទីធ្លាក់ទៅនៃសត្វទាំងឡាយដែលធ្វើសេចក្តីអាក្រក់ ។ ព្រះមានព្រះភាគត្រាស់បទនេះថា **និព្វានញ្ចាហំ** ដើម្បីទ្រង់សម្តែងថា តថាគតមិនមែនដឹងគតិតែម្យ៉ាងនោះឡើយ តថាគតរមែងដឹងនិព្វានដែលជាគ្រឿងរលាស់ចេញចាកគតិផងដែរ ។ លោកពោលអរិយមគ្គ ដោយបទទាំង ២ គឺមគ្គ និងបដិបទាក្នុងទីនេះ ។

[ ១៧១ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអាការដែលប្រព្រឹត្តទៅហើយ ដោយញាណរបស់ព្រះអង្គ ក្នុងឋានៈទាំងឡាយតាមដែលពោលហើយ ទើបត្រាស់ថា **ឥធាហំ សារីបុត្ត** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ឯកន្តទុក្ខា** គឺមានទុក្ខជានិច្ច បានដល់ មានទុក្ខជានិរន្តរ ។ បទថា

**តិប្បា** គឺក្តៅក្លា ។ បទថា **កដុកា** បានដល់ ខ្លោចផ្សាឥតស្រាក ។ បទថា **សេយ្យថាបិ** ជាដើម ទ្រង់ត្រាស់ហើយ ដើម្បីសម្តែងការប្រៀបធៀប ។ រណ្តៅក្តី គំនរក្តី ហៅថា **កាសុ** ក្នុងបទនោះ ។ រណ្តៅ ឈ្មោះថា **កាសុ** ដូចក្នុងគាថានេះថា

នៃនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្តៅ តើព្រោះហេតុអ្វី ម្នាលសម្លាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅ ។

គំនរ ឈ្មោះថា **កាសុ** ដូចក្នុងគាថានេះថា

ពួកសត្វនរកដទៃ មានខ្លួនឆេះជុំវិញ កំពុងទួញយំ ( ធ្លាក់ទៅ ) កាន់គំនររងើកភ្លើង ហើយថ្ងូរ ។

តែក្នុងទីនេះ លោកបំណងយករណ្តៅ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សាធិកបោរិសំ** ជ្រៅជាងមួយជួរបុរស ។ ក្នុងបទនោះ រណ្តៅនោះ ជ្រៅជាងមួយជួរបុរសជាប្រមាណ ព្រោះដូច្នោះ ទើបឈ្មោះថា ជ្រៅជាងមួយជួរបុរស អធិប្បាយថា ជ្រៅជាង ៥ ហត្ថ ។ ពាក្យថា ប្រាសចាកអណ្តាត ប្រាសចាកផ្សែងនោះ ទ្រង់ត្រាស់ដើម្បីសម្តែងកម្តៅជាធម្មជាតិមានកម្លាំង ។ កាលអណ្តាតមាន ឬផ្សែងមាន ខ្យល់រមែងតាំងឡើង ព្រោះហេតុនោះ ទើបកម្តៅមិនមានកម្លាំង ។ បទថា **ឃម្មបរេតោ** បានដល់ ដល់នូវការដុតរោល ។ បទថា **តសិតោ** សេចក្តីថា កើតនូវការចង់បាន ។ បទថា **បិបាសិតោ** បានដល់ បំណងនឹងផឹកទឹក ។ បទថា

**ឯកាយនេន មគ្គេន** សេចក្តីថា ដោយផ្លូវមួយដែលមានបន្ទា ដើមឈើស្លុក លំបាកនិវន្ត ទាំងសងខាងដែលគប្បីដើរតាម ។ បទថា **បណិធាយ** សេចក្តីថា ឈ្មោះថា ការប្រាថ្នាក្នុងរណ្តៅរងើកភ្លើងមិនមាន ទ្រង់ប្រារព្ធដល់រណ្តៅរងើកភ្លើង ទើបត្រាស់យ៉ាងនោះ ព្រោះឥរិយាបថតាំងហើយ ។ ការសម្តែងឧបមាក្នុងបទថា **ឯវមេវ ខោ** នេះ មានដូច្នេះ ។ គប្បីឃើញនរកដូចរណ្តៅរងើកភ្លើង ។ គប្បីឃើញកម្មដែលជាហេតុឲ្យដល់នូវនរក ដូចផ្លូវទៅកាន់រណ្តៅរងើកភ្លើង ។ គប្បីឃើញបុគ្គលដែលដេរដាសដោយកម្ម ដូចមនុស្សឡើងកាន់ផ្លូវ ។ គប្បីឃើញព្រះមានព្រះភាគជាអ្នកមានទិព្វចក្ខុ ដូចបុរសមានចក្ខុ ។ បុរសនោះឃើញបុគ្គលឡើងកាន់ផ្លូវនោះឯង រមែងដឹងថា បុគ្គលនេះទៅដោយផ្លូវនេះ នឹងធ្លាក់ក្នុងរណ្តៅរងើកភ្លើង យ៉ាងណា ព្រះមានព្រះភាគទ្រង់ដឹងកម្មឯណាមួយ មានផ្តើជីវិតសត្វឲ្យធ្លាក់ចុះ គឺការសម្លាប់សត្វជាដើម យ៉ាងនេះថា បុគ្គលនេះ ធ្វើកម្មនេះហើយ នឹងធ្លាក់នរកដូច្នោះដូចគ្នា ។ ក្នុងកាលចំណែកដទៃ បុរសនោះឃើញបុគ្គលនោះ ធ្លាក់ក្នុងរណ្តៅរងើកភ្លើង យ៉ាងណា ក្នុងកាលចំណែកដទៃ ព្រះមានព្រះភាគ ទ្រង់ញុំាងពន្លឺឲ្យចម្រើនហើយថា បុរសនោះធ្វើកម្មនោះហើយ កើតហើយក្នុងទីណា ទ្រង់សម្លឹងមើលដោយទិព្វចក្ខុ រមែងឃើញបុរសដែលកើតហើយក្នុងនរក សោយមហាទុក្ខមានគ្រឿងចង ៥ ប្រការ ជាដើមយ៉ាងនោះដូចគ្នា ។ កាលទ្រង់សម្លឹងមើលថា ក្នុងនរកនោះ សត្វនោះមានវណ្ណៈដទៃ ក្នុងវេលាសន្សំកម្ម សត្វដែលកើតក្នុងនរកមានវណ្ណៈដទៃក៏ពិត សូម្បីយ៉ាងនោះ សត្វទាំងនោះធ្វើកម្មនោះ

ហើយ កើតហើយក្នុងនរកនោះ សត្វនេះតាំងនៅក្នុងកណ្តាលសត្វជាច្រើន សែន ព្រោះដូច្នោះ សត្វនោះរមែងមកកាន់គន្លង ព្រោះដូច្នោះ ទើបអាចារ្យទាំងឡាយពោលថា នុ៎ះ ឈ្មោះថា កម្លាំងនៃទិព្វចក្ខុ ។

[ ១៧២ ] គប្បីជ្រាបអធិប្បាយក្នុងឧបមាទី ២ ព្រោះការក្តៅក្រហាយក្នុងរណ្តៅលាមក ដូចក្នុងរណ្តៅភ្លើងមិនមាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគមិនត្រាស់ **ឯកន្តទុក្ខា** ត្រាស់បទថា **ទុក្ខា** ជាដើម ។ គប្បីជ្រាបការប្រៀបធៀបឧបមាដោយន័យមុននោះឯងក្នុងបទនោះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលនេះកើតក្នុងកំណើតមួយ ក្នុងបណ្តាកំណើតទាំងឡាយ មានកំណើតដំរីជាដើម សោយទុក្ខច្រើនដោយការសម្លាប់ ការចង ការទាញមក និងការទាញទៅជាដើម ។

[ ១៧៣ ] គប្បីជ្រាបអធិប្បាយក្នុងឧបមាទី ៣ ថា បទថា **តនុបត្ត-បលាសោ** បានដល់ ស្លឹកទន់ មិនដូចដុំពពក តែបទនេះ ត្រាស់សំដៅដល់មានស្លឹកប៉ុនរ៉ុង ។ បទថា **កពរច្ឆាយោ** បានដល់ មានម្លប់តិចតួច ។ បទថា **ទុក្ខពហុលំ** សេចក្តីថា ទុក្ខក្នុងបេតវិស័យមានច្រើន តែគប្បីសោយសុខបន្តិចបន្តួចក្នុងពេលខ្លះ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ គប្បីជ្រាបការប្រៀបធៀបការឧបមាដោយន័យមុន ក្នុងទីនេះចុះ ។

[ ១៧៤ ] គប្បីជ្រាបអធិប្បាយក្នុងឧបមាទី ៤ ថា បទថា **ពហល-បត្តបលាសោ** បានដល់ មានស្លឹកជានិច្ច គឺគ្របដណ្តប់ដោយស្លឹក ។ បទថា **សណ្ឌច្ឆាយោ** សេចក្តីថា មានម្លប់ក្រាស់ដូចឆត្រថ្ម ។ បទថា **សុខ-**

**ពហុលា វេទនា** សេចក្តីថា វេទនាក្នុងត្រកូលទាំងឡាយ មានខត្តិយត្រកូលជាដើម ក្នុងមនុស្សលោក គប្បីជ្រាបថា វេទនាច្រើនដោយសេចក្តីសុខ ទ្រង់សម្តែងថា តថាគតឃើញបុគ្គលដេក ឬអង្គុយ សោយវេទនានោះ ។ គប្បីជ្រាបការប្រៀបធៀបឧបមានេះដោយន័យមុននោះឯង ។

[ ១៧៥ ] គប្បីជ្រាបអធិប្បាយក្នុងឧបមាទី ៥ ថា បទថា **បាសាទោ** បានដល់ ប្រាសាទវែង បទថា **ឧល្លិត្តាវលិត្តំ** សេចក្តីថា បូកលាបខាងក្នុង និងខាងក្រៅ ។ បទថា **ផុសិតគ្គឡំ** បានដល់ បន្ទះទ្វារ បន្ទះបង្អួចបិទជិតល្អ ព្រមដោយក្របជុំវិញ ។ បទថា **គោនកត្ថតោ** សេចក្តីថា ក្រាលដោយសំពត់កោជវៈពណ៌ខ្មៅ រោមវែងជាង ៤ ធ្នាប់ ។ បទថា **បដិកត្ថតោ** បានដល់ ក្រាលដោយកម្រាលពណ៌សដែលសម្រេចអំពីរោមសត្វ ។ បទថា **បដលិកត្ថតោ** គឺក្រាលដោយកម្រាលដែលសម្រេចដោយរោមដ៏ក្រាស់ ។ បទថា **កទលិមិគបវរបច្ចត្ថរណោ** សេចក្តីថា ក្រាលដោយកម្រាលដ៏ឧត្តមដែលសម្រេចដោយស្បែកឈ្លូស ។ បានឮថា ជនទាំងឡាយក្រាលស្បែកឈ្លូសលើសំពត់សហើយ ដេរធ្វើគ្រឿងកម្រាលនោះ ។ បទថា **សឧត្តរច្ឆទោ** សេចក្តីថា មានពិតានបាំងខាងលើ គឺមានពិតានពណ៌ក្រហមបាំងខាងលើ ។ បទថា **ឧភតោ លោហិតកូបធានោ** បានដល់ មានខ្នើយក្រហមទាំងសងខាងរបស់បល្ល័ង្ក គឺខ្នើយកើយក្បាល និងខ្នើយកើយជើង គប្បីជ្រាបការប្រៀបធៀប ឧបមាដោយន័យមុនក្នុងទីនេះ ។

យោជនាចំណែកដទៃ ក្នុងបទនេះមានដូច្នេះ ។ បុរសនោះ រមែងដឹង

បុគ្គលដែលឡើងកាន់ផ្លូវនោះឯងថា បុគ្គលនេះទៅដោយផ្លូវនោះ ឡើងកាន់ប្រាសាទ ចូលទៅកាន់កូដាគារ អង្គុយក្តី ដេកក្តី លើបល្ល័ង្ក យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលដែលសន្សំកុសលកម្មឯណាមួយ ក្នុងបណ្តាបុញ្ញកិរិយាវត្ថុ មានទានជាដើម ទ្រង់រមែងដឹងថា បុគ្គលនេះធ្វើកម្មនេះហើយនឹងកើតក្នុងទេវតាយ៉ាងនោះដូចគ្នា ។ ក្នុងសម័យក្រោយមក បុរសនោះឃើញបុគ្គលនោះឡើងកាន់ប្រាសាទនោះហើយ ចូលទៅកាន់កូដាគារ អង្គុយក្តី ដេកក្តី លើបល្ល័ង្ក សោយសុខវេទនាដោយចំណែកមួយ យ៉ាងណា ក្នុងសម័យក្រោយមក ព្រះមានព្រះភាគ ទ្រង់ចម្រើនអាលោកសញ្ញាថា បុគ្គលនោះធ្វើកម្មល្អនោះហើយ កើតក្នុងទីណាហ្ន៎ កាលទ្រង់មើលដោយទិព្វចក្ខុ ទ្រង់រមែងឃើញបុគ្គលនោះកើតក្នុងទេវលោក ដែលពួកនាងទេពអប្សរចោមរោមក្នុងឧទ្យានទាំងឡាយ មានឧទ្យាននន្ទវ័ន សោយទិព្វសម្បត្តិ ក៏ដូច្នោះដូចគ្នា ។

[ ១៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាសវក្ខយវារៈថា បើមានពាក្យសួរថា សេចក្តីនោះ ព្រះមានព្រះភាគមិនត្រាស់ថា ដោយទិព្វចក្ខុ តែត្រាស់ថា តថាគតឃើញបុគ្គលនោះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានការកំណត់ ។ ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលនោះដោយទិព្វចក្ខុខ្លះ ទ្រង់ដឹងដោយចេតោបរិយញ្ញាណខ្លះ ទ្រង់ដឹងដោយសព្វញ្ញុតញ្ញាណខ្លះ ។ ពាក្យថា **ឯកន្ត-សុខា វេទនា** នេះ ដោយព្យញ្ជនៈ ជាសុខតែម្យ៉ាង ដូចគ្នានឹងទេវសុខក៏ពិតសូម្បីយ៉ាងនោះ ដោយអត្ថ ជាសុខផ្សេងគ្នា ព្រោះសុខក្នុងទេវលោក មិនជា

ឯកន្តសុខដោយចំណែកមួយឡើយ ព្រោះនៅមានការក្តៅក្រហាយព្រោះរាគៈជាដើម ។ តែសុខក្នុងនិព្វានជាឯកន្តសុខ ដោយអាការទាំងពួង ព្រោះចូលទៅស្ងប់ការក្តៅក្រហាយទាំងអស់ ។ សុខណាដែលពោលក្នុងការឧបមាថា សុខដោយចំណែកមួយក្នុងប្រាសាទ សុខនោះ ឈ្មោះថា សុខដោយចំណែកមួយដូចគ្នា ព្រោះការក្តៅក្រហាយក្នុងផ្លូវមិនទាន់ស្ងប់ ព្រោះនៅមានការស្រេកឃ្លានដុតរោល ព្រោះនៅមានការស្រេកគ្របសង្កត់ ។ តែក្នុងដងព្រៃ ក៏ឈ្មោះថា ជាសុខដោយចំណែកមួយ ដោយអាការទាំងពួង ព្រោះមន្ទិល គឺធូលី ដែលបុគ្គលនោះ ចុះកាន់ស្រះបោក្ខរណីបណ្តែតអស់ហើយ ព្រោះការហត់នឿយក្នុងផ្លូវស្ងប់រម្ងាប់ហើយ ព្រោះការដែលស្រេកឃ្លានទាំងឡាយត្រូវកម្ចាត់ហើយ ដោយការបរិភោគក្រអៅឈូក និងដោយការផឹកទឹកឆ្ងាញ់ និងព្រោះបុគ្គលនោះផ្លាស់សំពត់ងូតទឹក ហើយស្លៀកសំពត់សាច់ម៉ដ្ឋ ដេកកើយទៃអង្ករ ដាក់សំពត់ងូតទឹកត្រង់ដើមទ្រូង ត្រូវខ្យល់ល្ហៀកៗ បក់មក ដេកលក់ទៅ ។ ក្នុងបទនេះថា **ឯវមេវ ខោ** មានការប្រៀបធៀបឧបមាដូច្នេះ ។ គប្បីឃើញអរិយមគ្គដូចស្រះបោក្ខរណី គប្បីឃើញបដិបត្តិក្នុងចំណែកខាងដើម ដូចផ្លូវទៅកាន់ស្រះបោក្ខរណី ។ គប្បីឃើញបុគ្គលដែលដល់ព្រមដោយបដិបត្តិ ដូចបុគ្គលឡើងកាន់ផ្លូវ គប្បីឃើញព្រះមានព្រះភាគដ៏មានទិព្វចក្ខុ ដូចបុរសមានចក្ខុ គប្បីឃើញព្រះនិព្វានដូចដងព្រៃ បុរសនោះឃើញបុគ្គលឡើងកាន់ផ្លូវ រមែងដឹងថា បុគ្គលនេះទៅដោយផ្លូវនេះ ងូតទឹកក្នុងស្រះបោក្ខ-រណីហើយ អង្គុយក្តី ដេកក្តី ត្រង់គល់ឈើក្នុងដងព្រៃ គួរជាទីរីករាយ យ៉ាង

ណា ព្រះមានព្រះភាគ ក៏ដូច្នោះដូចគ្នា ទ្រង់ដឹងបុគ្គលដែលបំពេញបដិបទា កំណត់នាមរូប ធ្វើការកំណត់បច្ច័យ ធ្វើការផ្សារដោយវិបស្សនា ដែលមានលក្ខណៈជាអារម្មណ៍ថា បុគ្គលនេះបំពេញបដិបទានេះហើយ ញ៉ាំងអាសវៈទាំងពួងឲ្យអស់ទៅ ចូលដល់ផលសមាបត្តិ ដែលពោលហើយយ៉ាងនេះថា ចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ។ ក្នុងសម័យក្រោយមក បុរសនោះឃើញបុគ្គលនោះងូតទឹកក្នុងស្រះបោក្ខរណីនោះហើយ ចូលទៅកាន់ដងព្រៃហើយ អង្គុយ ឬដេក សោយវេទនាដែលមានសេចក្ដីសុខ ដោយចំណែកមួយ យ៉ាងណា ក្នុងកាលចំណែកដទៃ ព្រះមានព្រះភាគទ្រង់ឃើញបុគ្គលនោះបំពេញបដិបទា ចម្រើនមគ្គ ធ្វើឲ្យជាក់ច្បាស់នូវផល សម្រេចផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ដល់នូវការដេកដ៏ប្រសើរ គឺនិរោធ សោយសុខវេទនា ដោយចំណែកមួយដូច្នោះដូចគ្នា ។

[ ១៧៧ ] ពាក្យនេះថា ម្នាលសារីបុត្រ មួយទៀត តថាគតធ្លាប់ប្រព្រឹត្តព្រហ្មចរិយៈ ប្រកបដោយអង្គ ៤ ដូច្នេះ ទ្រង់ប្រារព្ធព្រោះហេតុអ្វី ។ ទ្រង់ប្រារព្ធដោយអំណាចការជាប់គ្នាជាលំដាប់ ។ បានឮថា សុនក្ខត្តនេះមានលទ្ធិយ៉ាងនេះថា ការបរិសុទ្ធិ រមែងមានដោយការបំពេញទុក្ករកិរិយា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្ដែងដល់សុនក្ខត្តនោះថា តថាគតតាំងនៅក្នុងអត្តភាពមួយ បានធ្វើទុក្ករកិរិយាដែលប្រកបដោយអង្គ ៤ ហើយបុគ្គលដែលឈ្មោះថា ធ្វើទុក្ករកិរិយាដូចគ្នានឹងតថាគតមិនមាន បើបរិសុទ្ធមាន ដោយការធ្វើទុក្ករកិរិយា តថាគតនេះឯង

គប្បីជាព្រះពុទ្ធដូច្នេះ ។ ម្យ៉ាងទៀត សុនក្ខត្តនេះ ជ្រះថ្លាក្នុងការធ្វើទុក្ករកិរិយា ការដែលសុនក្ខត្តជាបុគ្គលជ្រះថ្លានោះ គប្បីជ្រាបដោយន័យដែលមកហើយក្នុងបាដិកសូត្រ មានពាក្យថា ឯសុនក្ខត្តលិច្ឆវីបុត្រ បានឃើញអចេលកោ-រក្ខិតិយៈសមាទានកុក្កុរវត្ត ដើរវារជើង ៤ កំពុងយកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ លុះសុនក្ខត្តលិច្ឆវីបុត្រនោះបានឃើញហើយ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អើហ្ន៎ សមណៈជាព្រះអរហន្តល្អពេកណាស់ ដើរវារជើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ដូច្នេះជាដើម ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា សុនក្ខត្តជ្រះថ្លាក្នុងទុក្ករកិរិយា តថាគតតាំងនៅក្នុងអត្តភាពមួយ បានធ្វើទុក្ករកិរិយាដែលប្រកបដោយអង្គ ៤ ហើយ សុនក្ខត្តនេះ កាលជ្រះថ្លាក្នុងការធ្វើទុក្ករកិរិយា ក៏គួរជ្រះថ្លាក្នុងតថាគត សុនក្ខត្តមិនមានការជ្រះថ្លាក្នុងតថាគតនោះឡើយ ដូច្នេះទ្រង់បានប្រារព្ធទេសនានេះ ។ ទានក្ដី វេយ្យាវច្ចៈក្ដី សិក្ខាបទក្ដី ព្រហ្មវិហារក្ដី ទេសនាក្ដី មេថុនវិរតិក្ដី សទារសន្តោសក្ដី វីរិយៈក្ដី ឧបោសថក្ដី អរិយមគ្គក្ដី សាសនាទាំងមូលក្ដី អជ្ឈាស័យៈក្ដី ហៅថា ព្រហ្មចរិយៈក្នុងទីនេះ ។

ទាន លោកហៅថា ព្រហ្មចរិយៈ ក្នុងបុណ្ណកជាតក ( វិធុរជាតក ) ថា

អ្វីជាវត្តរបស់ព្រះអង្គ អ្វីព្រហ្មចរិយៈរបស់ព្រះអង្គ បពិត្រនាគ ឫទ្ធិសេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាម និងការកើត ( ក្នុងភពនាគ ) ទាំងវិមានធំរបស់ព្រះអង្គនេះ នេះជាផលនៃកម្មដែលព្រះអង្គសន្សំល្អហើយ

ដូចម្តេច ។

ខ្ញុំ និងភរិយាទាំង ២ នាក់ ( កាលនៅ ) ក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំដូចជាអណ្តូង ( នៃមហាជន ) ទាំងពួកសមណៈ និងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ខ្ញុំ ( កាលនៅ ) ក្នុងកាលចម្ប៉ានគរនោះ បានឲ្យទានដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសម្នាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ ដូច្នេះ ។

វេយ្យាវច្ចៈ ហៅថា ព្រហ្មចរិយៈ ក្នុងអង្កុរបេតវត្ថុថា

ខ្ញុំបានលើកដើមដៃខាងស្តាំ ( បង្ហាញលំនៅនៃអសយ្ហមហាសេដ្ឋីដល់ជនទាំងនោះ ) ថា សេចក្តីចម្រើន ចូរមានដល់អ្នកទាំងឡាយចុះ អ្នកទាំង-ឡាយ ចូរនាំគ្នាទៅក្នុងទីនោះចុះ អសយ្ហមហាសេដ្ឋី តែងឲ្យទានក្នុងទីនុ៎ះ ដៃរបស់ខ្ញុំអាចឲ្យសម្រេចសេចក្តីប្រាថ្នាបាន ដោយហេតុនោះ ដៃរបស់ខ្ញុំទើបបញ្ចេញនូវរសផ្អែមបាន ដោយហេតុនោះ បុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយព្រហ្មចរិយៈនោះ ។

សិក្ខាបទ ៥ ហៅថា ព្រហ្មចរិយៈ ក្នុងតិត្តិរជាតកនេះថា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនុ៎ះឯង ឈ្មោះតិត្តិរិយព្រហ្មចរិយៈ ដូច្នេះ ។ ព្រហ្ម-វិហារ ហៅថា ព្រហ្មចរិយៈ ក្នុងមហាគោវិន្ទសូត្រនេះថា ម្នាលបញ្ចសិខៈ ឯព្រហ្មចរិយធម៌នោះឯង មិនមែនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាស

ចាកភគៈ ដើម្បីរំលត់ ( កិលេស ) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានបានទេ ( គ្រាន់តែឲ្យបានទៅ ) កើតក្នុងព្រហ្មលោកប៉ុណ្ណោះ ។ ធម្មទេសនា ហៅថា ព្រហ្មចរិយៈ ក្នុងបទថា ក្នុងព្រហ្មចរិយៈ គឺធម្មទេសនាមួង បានពួកលោកដែលលះបង់នូវមច្ចុបាន ១០០០ ។ មេថុនវិរតិ ហៅថា ព្រហ្មចរិយៈ ក្នុងសល្លេខសូត្រថា ពួកអ្នកត្រូវធ្វើសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រព្រឹត្តនូវអព្រហ្មចរិយធម៌ក្នុងវត្ថុណា ពួកយើងនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងវត្ថុនោះ ។ សទារសន្តោស ហៅថា ព្រហ្មចរិយៈ ក្នុងមហាធម្មបាលជាតកថា

ពួកយើងមិនប្រព្រឹត្តក្រៅចិត្តភរិយាទេ ទាំងពួងភរិយាក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើងមិនស្លាប់ ។

ឧបោសថដែលប្រកបដោយអង្គ ៨ ដែលរក្សាហើយដោយអំណាចការទូន្មានខ្លួន ហៅថា ព្រហ្មចរិយៈ ក្នុងនេមិជាតក យ៉ាងនេះថា

បុគ្គលកើតក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈថោកទាប ដល់នូវភាពទេវតា ដោយព្រហ្មចរិយៈជាកណ្តាល បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់ ។

អរិយមគ្គ ហៅថា ព្រហ្មចរិយៈ ក្នុងមហាគោវិន្ទសូត្រនោះឯងថា ម្នាលបញ្ចសិខៈ ព្រហ្មចរិយធម៌របស់តថាគតនេះឯង ទើបរមែងប្រព្រឹត្តទៅដើម្បី

នឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ ( កិលេស ) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែមួយយ៉ាង ។បេ។ គឺផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ។ សាសនាទាំងមូល ដែលសង្គ្រោះចូលជាមួយសិក្ខា ៣ យ៉ាង ហៅថា ព្រហ្មចរិយៈ ក្នុងបាសាទិកសូត្រថា ( ម្នាលចុន្ទ ឥឡូវនេះ ) ព្រហ្មចរិយធម៌របស់តថាគតក៏មាំមួនផ្សាយទូលាយទៅ មានគេចេះដឹងច្រើនក្រាស់ក្រែល ទាំងពួកទេវតា និងមនុស្សក៏សម្តែងបានដោយប្រពៃហើយ ។ អធ្យាស្រ័យ ហៅថា ព្រហ្មចរិយៈ ដូចក្នុងបទនេះថា ម្យ៉ាងទៀត ការប្រាថ្នានូវផល តែងសម្រេចព្រមដល់ពួកជនអ្នកមិនរួសរាន់ អញជាអ្នកមានព្រហ្មចារ្យចាស់ក្លាហើយ ម្នាលគាមណិ អ្នកចូរដឹងយ៉ាងនេះចុះ ។

ក្នុងសូត្រនេះ ព្រហ្មចរិយៈ លោកបំណងយកសេចក្តីព្យាយាម ។ សូត្រនេះឯង ជាសូត្រនៃព្រហ្មចរិយៈ គឺសេចក្តីព្យាយាម សេចក្តីព្យាយាមនេះ លោកពោលថា ប្រកបដោយអង្គ ៤ ព្រោះទុក្ករកិរិយា ៤ យ៉ាង ដែលព្រះមានព្រះភាគ ទ្រង់បំពេញហើយក្នុងអត្តភាពមួយ ។

បទថា **សុទំ** ក្នុងបទថា **តបស្សី សុទំ ហោមិ** គ្រាន់តែជានិបាតប៉ុណ្ណោះ អធិប្បាយថា តថាគតជាអ្នកអាស្រ័យនូវសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។ បទថា **បរមតបស្សី** សេចក្តីថា មានសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេសដ៏ក្រៃលែង គឺដ៏ឧត្តមរបស់បុគ្គលទាំងឡាយ ដែលអាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ។ បទថា **លូខោ សុទំ**

**ហោមិ** សេចក្ដីថា តថាគតជាអ្នកសៅហ្មង ។ បទថា **ជេគុច្ឆិ** បានដល់ ជាអ្នកស្អប់ខ្ពើមបាប ។ បទថា **បវិវិត្តោ សុទំ ហោមិ** សេចក្ដីថា តថាគតជាអ្នកស្ងាត់ ។

[ ១៧៨ ] បទថា **តត្រស្សុ មេ ឥទំ សារីបុត្ត** សេចក្ដីថា ព្រហ្មចរិយៈមានអង្គ ៤ នោះ ព្រហ្មចរិយៈនេះ ជាវត្តក្នុងការដែលមានសេចក្ដីព្យាយាមជាគ្រឿងដុតកម្ដៅកិលេសរបស់តថាគត ទ្រង់សំដែងថា ព្រហ្មចរិយៈនេះ ដែលតថាគតធ្វើហើយ ក្នុងការមានសេចក្ដីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស មានវត្តរបស់អ្នកបួសអាក្រាតជាដើម ក្នុងការដែលព្រះអង្គទ្រង់អាស្រ័យសេចក្ដីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ។ ក្នុងបទទាំងនោះ បទថា **អចេលកោ** បានដល់ បុគ្គលប្រាសចាកសំពត់ គឺបុគ្គលអាក្រាត ។ បទថា **មុត្តាចារោ** បានដល់ តថាគតមានមារយាទលះបង់ហើយ គឺវៀរចាកមារយាទរបស់កុលបុត្រក្នុងលោក ក្នុងកម្មទាំងឡាយ មានការបន្ទោបង់ឧច្ចារៈជាដើម ជាអ្នកឈរបន្ទោបង់ឧច្ចារៈ បន្ទោបង់បស្សាវៈ ទំពា បរិភោគ ។ បទថា **ហត្ថាវលេខនោ** សេចក្ដីថា ទ្រង់សំដែងថា កាលដុំបាយនៅក្នុងដៃ តថាគតក៏ប្រើអណ្ដាតលិទ្ធដៃ កាលបន្ទោបង់ឧច្ចារៈ តថាគតក៏ជាអ្នកមានការសម្គាល់ក្នុងដៃនោះឯងថា ជាកំណាត់ឈើ ប្រើដៃដើម្បីជូត ដូច្នេះ ។ បានឮថា ពួកជនទាំងនោះ បញ្ញត្តកំណាត់ឈើថាជាសត្វ ព្រោះដូច្នោះ ព្រះអង្គទ្រង់បំពេញបដិបទារបស់ពួកបុគ្គលនោះ ទើបទ្រង់ធ្វើយ៉ាងនោះ ទ្រង់សំដែងថា កាលគេពោលដើម្បីឲ្យទទួលភិក្ខាថា មកចុះ លោកក៏មិនមក ព្រោះដូច្នោះ ទើប

ឈ្មោះថា ជាអ្នកកាន់វត្តមិនចូលមក ( ទទួលភត្ត ) ដែលគេនិមន្តថា លោកដ៏ចម្រើន ចូរចូលមក សូម្បីអ្នកដែលគេពោលថា លោកដ៏ចម្រើនសូមរង់ចាំសិន ក៏មិនរង់ចាំ ទើបឈ្មោះថា គេនិមន្តឲ្យរង់ចាំ ក៏មិនរង់ចាំ តិរ្ថិយទាំង-ឡាយ រមែងមិនធ្វើការទាំង ២ យ៉ាងនោះ ដោយយល់ថា ពាក្យរបស់បុគ្គលនោះនឹងធ្វើហើយ សូម្បីអញក៏បានធ្វើយ៉ាងនេះ ។ បទថា **អភិហតំ** បានដល់ ភត្តដែលគេបែងទុកមុន ហើយនាំមកឲ្យ ។ បទថា **ឧទ្ទិស្ស កតំ** គឺកិច្ចដែលគេប្រាប់យ៉ាងនេះថា បានធ្វើចំពោះលោកនោះឯង ។ បទថា **និមន្តនំ** សេចក្តីថា តថាគតមិនត្រេកអរ មិនកាន់យកកិច្ចដែលគេនិមន្តយ៉ាងនេះថា លោកគប្បីចូលទៅកាន់ត្រកូល ផ្លូវ ឬស្រុកឈ្មោះនោះ ។ បទថា **ន កុម្ភិមុខា** គឺតថាគតមិនទទួល ភិក្ខាដែលគេដួសអំពីឆ្នាំងឲ្យ ។ បទថា **ន កឡោបិមុខា** សេចក្តីថា ឆ្នាំងបាយ ឬកញ្ជើ ឈ្មោះថា **កឡោបិ** តថាគតមិនទទួលភិក្ខាអំពីឆ្នាំងបាយនោះ ព្រោះហេតុអ្វី ព្រោះថា ម្ចាស់របស់ឆ្នាំងបាយអាស្រ័យតថាគត នឹងបានការប្រហារដោយវែក ។ បទថា **ន ឯឡកមន្តរំ** សេចក្តីថា តថាគតមិនទទួលភិក្ខាដែលគេឈរត្រង់ចន្លោះធរណីទ្វារឲ្យ ព្រោះហេតុអ្វី ព្រោះថា បុគ្គលដែលអាស្រ័យតថាគតហើយ រមែងបានធ្វើក្នុងចន្លោះ ។ សូម្បីក្នុងកំណាត់ឈើ និងអង្រែទាំងឡាយ ក៏ន័យនេះដូចគ្នា ។ បទថា **ន ទ្វិន្នំ** សេចក្តីថា កាលមនុស្ស ២ នាក់កំពុងបរិភោគ មនុស្សម្នាក់ក្រោកឡើងឲ្យ តថាគតក៏មិនទទួល ព្រោះហេតុអ្វី ព្រោះថា នឹងមានអន្តរាយអំពីការឈ្លោះ ។ ក្នុងបទទាំងឡាយ មានបទថា **ន គព្ភិនិយា**

ជាដើម ទារកក្នុងផ្ទៃរបស់ស្រីមានគភ៌នឹងលំបាក កាលស្រីឲ្យបៅដោះ ទារកក៏នឹងមានអន្តរាយអំពីទឹកដោះ ។ បទថា **បុរិសន្តរគតាយ** សេចក្តីថា តថាគតមិនទទួលដោយគិតថា នឹងមានអន្តរាយអំពីការត្រេកអរ ។ បទថា **ន សង្កិត្តីសុ** សេចក្តីថា មិនទទួលភិក្ខា ដែលណាត់គ្នានឹងគ្នាធ្វើ បានឮថា ក្នុងវេលាស្រូវអន្តរឡើងថ្លៃ សាវកនៃអចេលក៍ទាំងឡាយ ក៏នឹងបបួលគ្នាប្រមូលអង្ករជាដើមអំពីទីនោះៗ ចម្អិនភត្ត ដើម្បីប្រយោជន៍ដល់អចេលក៍ទាំងឡាយ អចេលក៍ដែលជាអ្នកប្រព្រឹត្តតឹងតែង ទៅហើយ មិនទទួល ។ បទថា **ន យត្ថ សា** សេចក្តីថា ក្នុងទីណា ឆ្កែបានទទួលការចិញ្ចឹម តថាគតទោះបានដុំបាយ ក៏មិនទទួលភិក្ខាដែលគេមិនឲ្យដល់ឆ្កែ ក្នុងទីនោះហើយនាំមក ព្រោះហេតុអ្វី ព្រោះថា ឆ្កែនោះនឹងមានអន្តរាយអំពីដុំបាយ ។ បទថា **សណ្ឌសណ្ឌចារិនី** សេចក្តីថា មានរុយចោមរោមជាក្រុមៗ បើមនុស្សទាំង-ឡាយឃើញអចេលក៍ហើយ គិតថា អញនឹងឲ្យភិក្ខាដល់អចេលក៍នេះ ចូលទៅកាន់រោងភត្ត កាលពួកបុគ្គលចូលរោងភត្ត រុយទាំងឡាយនឹងទំត្រង់មាត់ឆ្នាំងជាដើម ក៏នឹងហើរឆ្វេលរោមជាក្រុមៗ តថាគតមិនទទួលភិក្ខា ដែលគេនាំមកអំពីឆ្នាំងបាយនោះ ព្រោះហេតុអ្វី ព្រោះថា រុយទាំងឡាយនឹងមានអន្តរាយអំពីអាហារ ព្រោះអាស្រ័យតថាគត សូម្បីតថាគតក៏បានធ្វើយ៉ាងនោះហើយ ។ បទថា **ន ថុសោទកំ** សេចក្តីថា ទឹកដាក់អំបិលដែលគេធ្វើដោយស្រូវត្រាំទាំងអស់ក្នុងទីនេះ ការផឹកសុរានោះឯងមានទោស ឯបុគ្គលនេះមានសេចក្តីសម្គាល់ថា មានទោស ។ បុគ្គលណា បានភិក្ខាក្នុងផ្ទះមួយ

*ប៉ុណ្ណោះ ហើយត្រឡប់ ឈ្មោះថា* **ឯកាគារិក ។** *បុគ្គលចិញ្ចឹមជីវិតដោយភិក្ខាមួយ ពំនូតប៉ុណ្ណោះ ឈ្មោះថា* **ឯកាលោបិក។** *ក្នុងបទទាំងឡាយ មានទ្វាគារិកាជាដើម ក៏ន័យនេះដូចគ្នា ។ បទថា* **ឯកិស្សាបិ ទត្តិយា** *សេចក្តីថា ដោយថាសតូចមួយ ថាសតូចៗ ដែលគេដាក់ភិក្ខាដ៏ប្រសើរទុក ឈ្មោះថា* **ទត្តិ ។** *បទថា* **ឯកាហិកំ** *បានដល់ ភិក្ខាដែលរំលងមួយថ្ងៃ ។ បទថា* **អឌ្ឍមាសិកំ** *បានដល់ ភិក្ខាដែលរំលងក្នុងរវាងកន្លះខែ ។ បទថា* **បរិ-យាយភត្តភោជនំ** *សេចក្តីថា បរិភោគភត្តវារៈ គឺបរិភោគភត្តដែលរំលងមកតាមវារៈនៃថ្ងៃយ៉ាងនេះ គឺវារៈ ១ ថ្ងៃ វារៈ ២ ថ្ងៃ វារៈ ៧ ថ្ងៃ វារៈកន្លះខែ ។ បទថា* **សាកភក្ខោ** *បានដល់ បន្លែស្រស់ត្រាំជាភិក្ខា ។ បទថា* **សមាកភក្ខោ** *បានដល់ មានអង្ករនៃស្រងែជាភិក្ខា ។ ស្រូវដំណើបដែលកើតឯងក្នុងព្រៃ ឈ្មោះថា ស្កួយ ក្នុងបទទាំងឡាយ មានបទថា* **នីវារា** *ជាដើម ។ បទថា* **ទទ្ទុលំ** *បានដល់ ចំនៀរស្បែកដែលគេចៀរហើយចោល ។ សម្បកឈើក្តី សារាយក្តី ជ័រកណិការជាដើមក្តី ហៅថា* **ហដ ។** *បទថា* **កណំ** *បានដល់ កុណ្ឌក ។ បទថា* **អាចាមោ** *បានដល់ បាយដែលជាប់នឹងឆ្នាំង កាន់យកបាយក្តាំងនោះក្នុងទីដែលគេចោលហើយបរិភោគ ។ អាចារ្យទាំងឡាយពោលថា ទឹកបាយដូច្នេះក៏មាន ។ វត្ថុទាំងឡាយ មានម្សៅជាដើមប្រាកដហើយ ។ បទថា* **បវត្តផលភោជី** *បានដល់ បរិភោគផ្លែឈើដែលជ្រុះឯង ។ បទថា* **សាណានិ** *បានដល់ សំពត់សម្បកធ្មៃ ។ បទថា* **មសាណានិ** *សំពត់ដែលត្បាញលាយចម្រុះគ្នា ។ បទថា* **ឆវទុស្សានិ** *បាន*

ដល់ សំពត់ដែលគេរុំសព ។ ឬសំពត់ដែលគេត្បាញ វត្ថុមានវល្លិ៍ទឹកជាដើម ធ្វើជាសំពត់ស្លៀក ។ បទថា **បំសុកូលានិ** បានដល់ សំពត់ប្រឡាក់ធូលី ដែលគេចោលលើផែនដី ។ បទថា **តិរីដានិ** បានដល់ សំពត់សម្បកឈើ ។ បទថា **អជិនំ** គឺស្បែកខ្លា ។ បទថា **អជិនក្ខិបំ** គឺស្បែកខ្លានោះឯង ដែលមានធ្នូតត្រង់កណ្តាល អាចារ្យខ្លះពោលថា មានក្រចកដូច្នេះក៏មាន ។ បទថា **កុសចីរំ** គឺសំពត់ដែលក្រងដោយស្បូវក្លាំង ធ្វើជាសំពត់ ។ សូម្បីក្នុងសំពត់សម្បកក្រចៅ និងសំពត់ដែលធ្វើអំពីសម្បកផ្លែឈើទាំងឡាយក៏មានន័យដូចគ្នា ។ បទថា **កេសកម្ពលំ** បានដល់ សំពត់កម្ពលដែលធ្វើដោយសក់មនុស្សទាំងឡាយ ។ ដែលព្រះមានព្រះភាគត្រាស់ដល់ថា ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុតជាងសំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្សត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ ។ បទថា **វាលកម្ពលំ** គឺសំពត់កម្ពលដែលធ្វើដោយរោមសេះជាដើម ។ បទថា **ឧលូកបក្ខំ** បានដល់ សំពត់ដែលត្បាញអំពីស្លាបមៀមធ្វើជាសំពត់ស្លៀក ។ បទថា **ឧព្ភដ្ឋកោ** បានដល់ ជាអ្នកប្រព្រឹត្តឈរ ។ បទថា **ឧក្កុដិកប្បធានមនុយុត្តោ** គឺតាមប្រកបសេចក្តីព្យាយាមអង្គុយច្រហោង កាលដើរ ក៏ជាអ្នកច្រហោង ជាន់ផែនដីមិនពេញជើងដើរទៅ ។ បទថា **កណ្ដកាបស្សយិកោ** សេចក្តីថា ទ្រង់សម្តែងថា តបាគតបោះបន្លាដែក ឬបន្លាប្រក្រតីក្នុងផែនដីហើយ ក្រាលស្បែកលើបន្លានោះហើយ

*ធ្វើកិច្ច មានការឈរ និងការបង្រ្កមជាដើម ។ បទថា* **សេយ្យំ** *សេចក្តីថា តថាគតកាលនឹងដេក ក៏សម្រេចការដេកលើបន្ទានោះឯង ។ បទថា* **សាយ-តតិយកំ** *គឺមួយថ្ងៃ ៣ ដង ទ្រង់សម្តែងថា តថាគតខ្នះខ្នែងប្រកបរឿយៗ នូវការចុះត្រាំទឹក ដោយគិតថា អញនឹងបន្សាត់បាបមួយថ្ងៃ ៣ ដង គឺពេលព្រឹក ថ្ងៃត្រង់ វេលាល្ងាច ។*

*[ ១៧៩ ] បទថា* **នេកវស្សគណិកំ** *បានដល់ សន្សំក្នុងការរាប់ដោយឆ្នាំមិនមែនតិច ។ បទថា* **រជោជល្លំ** *បានដល់ មន្ទិល គឺធូលី ព្រះមានព្រះភាគ ទ្រង់សំដៅដល់កាលនៃការសមាទានរជោជល្លកវត្តរបស់ព្រះអង្គ ទើបត្រាស់ដល់មន្ទិល គឺធូលីនេះ ។*

*[ ១៨០ ] បទថា* **ជេគុច្ឆិស្មឹ** *គឺក្នុងភាវៈទ្រង់ខ្ពើមបាប ។ បទថា* **យាវ ឧទកពិន្ទុម្ហិបិ** *សេចក្តីថា តថាគតបានតាំងការអាណិតអាសូរសូម្បីក្នុងតំណក់ទឹក ក៏នឹងពោលទៅថ្វីដល់ដុំក្រួស ដុំដី កំណាត់ឈើ និងខ្សាច់ជាដើមដទៃនោះ បានឮថា ពួកជនទាំងនោះបញ្ញត្តតំណក់ទឹក និងវត្ថុទាំងឡាយ មានដុំក្រួស និងដុំដីជាដើមទាំងនោះថា ជាសត្វតូចៗ ។ ដោយហេតុនោះ ទើបត្រាស់ថា តថាគតបានតាំងសេចក្តីអាណិតអាសូរគ្រាន់តែក្នុងតំណក់ទឹក ដូច្នេះ ។ តថាគតមិនបំផ្លាញសូម្បីតំណក់ទឹក ព្រោះហេតុអ្វី ព្រោះតថាគតកុំបានបំផ្លាញសត្វតូចៗ ដែលនៅក្នុងទីដែលមិនស្មើឡើយ ព្រោះហេតុនោះ ទើបតថាគតមិនបំផ្លាញ គឺសម្លាប់សត្វតូចៗ ពោល គឺតំណក់ទឹកដែលនៅក្នុងទីស្មើ ក៏ដូចក្នុងទីទួលលើគោក ចុងស្មៅ និងស្លឹកឈើជាដើម ព្រោះដូច្នោះ*

ទើបទ្រង់សម្ដែងអត្ថនោះថា តថាគតមានសតិឈានទៅខាងមុខ ដូច្នេះ ។ បានឮថា ក្នុងអចេលក៍ទាំងឡាយ អចេលក៍ឈ្មោះថា ជាអ្នកមានសីល ចាប់តាំងអំពីកាលនៃខ្លួនជាន់ផែនដីមិនមាន អចេលក៍ទាំងឡាយ សូម្បីទៅកាន់ភិក្ខាចារ ក៏ជាអ្នកទៅដោយទ្រុស្តសីល សូម្បីបរិភោគក្នុងផ្ទះឧបដ្ឋាកទាំង-ឡាយ ក៏ជាអ្នកបរិភោគទាំងទ្រុស្តសីល សូម្បីត្រឡប់មក ក៏ត្រឡប់មកក្នុងភាពជាអ្នកទ្រុស្តសីល ។ តែក្នុងកាលអចេលក៍ទាំងឡាយចូលកាន់ក្តារ ដែលមានរាងដូចជាកន្ទុយក្ងោក អធិដ្ឋានសីលអង្គុយ ក្នុងវេលានោះ ទើបឈ្មោះថា ជាអ្នកមានសីល ។

[ ១៨១ ] បទថា **វនកម្មិកំ** បានដល់ ជាអ្នកត្រាច់ទៅក្នុងព្រៃដើម្បីប្រយោជន៍ដល់ឫសឈើ មើមឈើ និងផ្លៃឈើជាដើម ។ បទថា **វនេន វនំ** គឺអំពីព្រៃទៅកាន់ព្រៃ ។ ក្នុងបទទាំងពួង ក៏មានន័យនេះ ។ បទថា **បបតាមិ** គឺតថាគតទៅ ។ បទថា **អារញ្ញកោ** គឺម្រឹគដែលនៅជាប្រចាំក្នុងព្រៃ ទ្រង់សំដៅដល់កាលនៃអាជីវករបស់ព្រះអង្គ ទើបត្រាស់ពាក្យនេះ ។ បានឮថា ព្រះពោធិសត្វបួសជាអាជីវកនោះ ដើម្បីប្រយោជន៍ដល់ទ្រង់សមាទានការនៅព្រៃជាវត្ត សូម្បីទ្រង់ដឹងដល់បព្វជ្ជានោះថា មិនមានប្រយោជន៍ តែក៏មិនសឹក ព្រោះព្រះពោធិសត្វទាំងឡាយ មិនវិលត្រឡប់ចាកឋានៈដែលចូលដល់ជាធម្មតា តែកាលបួសហើយ ក៏ទ្រង់គិតថា បុគ្គលណាមួយ កុំបានឃើញតថាគត បន្ទាប់អំពីនោះ ទើបយាងចូលទៅកាន់ព្រៃ ព្រោះហេតុនោះឯង ទើបត្រាស់ថា ជនទាំងនោះកុំឃើញអាត្មាអញឡើយ ទាំងអាត្មាអញក៏កុំ

ឃើញជនទាំងនោះឡើយ ដូច្នេះ ។

[ ១៨២ ] បទថា **គោដ្ឋា** បានដល់ ក្រោលគោ ។ បទថា **បដ្ឋិតគាវោ** គឺពួកគោចេញទៅហើយ ។ ក្នុងបទទាំងនោះ បទថា **ចតុក្កុណ្ឌិកោ** សេចក្តីថា ត្រាច់ទៅ ឈរសម្លឹងឃើញអ្នកចិញ្ចឹមគោចេញទៅ ព្រមទាំងគោទាំងឡាយហើយ ដាក់ដៃទាំងពីរ និងជង្គង់ទាំងពីរលើផែនដី លូនទៅយ៉ាងនេះ ។ បទថា **តានិ សុទំ អាហារេមិ** សេចក្តីថា អាចម៍របស់កូនគោធំ រមែងមិនមានឱជារស ព្រោះដូច្នោះ វៀរអាចម៍គោទាំងនោះ ទើបបរិភោគអាចម៍គោដែលមានឱជារសរបស់កូនគោតូច ដែលបៅដោះពេញពោះហើយ ចូលកាន់ដងព្រៃជិតនោះឯង ។ ទ្រង់សំដៅដល់ពាក្យនេះ ទើបត្រាស់ថា តថាគតបរិភោគអាចម៍គោទាំងនោះ ដូច្នេះ ។ បទថា **យាវ កីវញ្ច មេ** សេចក្តីថា ទឹកមូត្រ និងករីសរបស់តថាគតមិនទាន់អស់ទៅកាលណា ស្នាមជើងត្រង់ទ្វាររបស់តថាគត នៅប្រព្រឹត្តទៅដរាបណា តថាគតក៏បរិភោគមូត្រ និងករីសនោះឯង អស់កាលដរាបនោះ ។ កាលកន្ទួយយូរទៅ សាច់ និងឈាមអស់ទៅ ស្នាមជើងក្នុងទ្វារអស់ទៅ តថាគតក៏បរិភោគអាចម៍របស់កូនគោខ្ចី ។ បទថា **មហាវិកដភោជនស្មឹ** បានដល់ ភោជនធំ អធិប្បាយថា ក្នុងភោជនខុសប្រក្រតី ។

[ ១៨៣ ] បទថា **តត្រ** ក្នុងបទថា **តត្រ សុទំ សារីបុត្ត ភឹសនកស្ស វនសណ្ឌស្ស ភឹសនកស្មឹ ហោតិ** ជាពាក្យសំដៅដល់ពាក្យដើម ។ សព្ទថា **សុទំ** ជានិបាត ក្នុងពាក្យគ្រាន់តែធ្វើបទឲ្យពេញ ។ បទថា **សារីបុត្ត** ជា

ពាក្យហៅ ។ អត្ថយោជនាក្នុងបទនោះមានដូច្នេះ បទថា **តត្រ** សេចក្ដីថា ជាសេចក្ដីគួរខ្លាចនៃដងព្រៃដែលគួរខ្លាច ត្រាស់ទុកក្នុងពាក្យថា ក្នុងដងព្រៃដែលគួរខ្លាចឯណាមួយ អធិប្បាយថា ជាការធ្វើដែលគួរខ្លាច ។ សេចក្ដីនេះដូចម្ដេច សេចក្ដីនេះ យ៉ាងនេះថា បុគ្គលណាម្នាក់ មិនទាន់ប្រាសចាករាគៈ ចូលទៅកាន់ព្រៃនោះ ដោយច្រើន ព្រឺរោម ព្រឺស្បែក ដូច្នេះ ។ ម្យ៉ាងទៀត បទថា **តត្រ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។ ពាក្យថា **សុ** ជានិបាត ដូចក្នុងពាក្យថា **កឹសុ នាម ភោន្តោ សមណព្រាហ្មណា** ជាដើម ។ បទថា **ឥទំ** ជាពាក្យសម្ដែងធ្វើអត្ថដែលបំណងហើយ ដូចឲ្យប្រចក្ស ។ បទថា **សុឥទំ** ជា **សុទំ** គប្បីជ្រាបការលុប **ឥ** អក្ខរៈ ដោយអំណាចសន្ធិ ដូចក្នុងពាក្យថា **ចក្ខុន្ទ្រិយំ ឥត្ថិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ កឹសូធ វិត្តំ** ដូច្នេះជាដើម ។ ឯយោជនាក្នុងបទនោះ ដូច្នេះ ម្នាលសារីបុត្រ នេះឯងជាការគួរខ្លាចនៃដងព្រៃដែលគួរខ្លាចនោះ ។ បទថា **ភីសនកត្តស្មឹ** សេចក្ដីថា ក្នុងភាវៈដែលគួរខ្លាច ។ គប្បីឃើញការលុប **ត** អក្ខរៈមួយតួចេញ ។ បាលីថា **ភីសនកតស្មឹយេវ** ដូច្នេះក៏មាន ។ ម្យ៉ាងទៀត កាលពោលថា **ភីសនកតាយ** ឈ្មោះថា ធ្វើការខុសឃ្លៀងឃ្លាតក្នុងលិង្គ ។ ក្នុងបទនេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា គ្រឿងសម្គាល់ ។ ព្រោះដូច្នោះ គប្បីជ្រាបការសម្ពន្ធយ៉ាងនេះ ។ នេះឯងជាការខ្លាច គឺការគួរខ្លាចជានិមិត្ត មានការគួរខ្លាចជាហេតុ មានការគួរខ្លាចជាបច្ច័យ បុគ្គលណាម្នាក់ មិនទាន់ប្រាសចាករាគៈ ចូលទៅកាន់ព្រៃនោះ ដោយច្រើន ព្រឺរោម គឺរោមបះឡើង រមែងព្រឺ មានចុងតាំង

*ឡើងដូចគ្មានឹងម្ជុល ឬដូចគ្មានឹងបន្លា តាំងនៅ ដែលមិនព្រឺរោមមានតិច ឬរោមរបស់សត្វទាំងឡាយច្រើនជាង រមែងព្រឺ ។ រោមរបស់បុរសអ្នកក្លាហានមានតិច រមែងមិនព្រឺ ដូច្នេះ ។ បទថា* **អន្តរដ្ឋកា** *សេចក្តីថា ៨ រាត្រី ក្នុងរវាង ២ ខែយ៉ាងនេះ គឺខាងចុងខែមាឃ ៤ រាត្រី ខាងដើមខែផល្គុណ ៤ រាត្រី ។ បទថា* **អព្ភោកាសេ** *សេចក្តីថា ព្រះមហាសត្វប្រថាប់នៅក្នុងទីវាលអស់រាត្រីក្នុងសម័យសន្សើមធ្លាក់ ។ លំដាប់នោះ តំណក់សន្សើមទាំងឡាយគ្របដណ្តប់រណ្តៅព្រះលោមាគ្រប់រោមរបស់ព្រះមហាសត្វនោះ ដូចកែវមុក្តាសរីរៈទាំងមូល ដូចដណ្តប់ដោយសំពត់គ្រោតគ្រាតពណ៌ស ដូច្នោះ ។ បទថា* **ទិវា វនសណ្ឌេ** *សេចក្តីថា កាលសន្សើមទាំងឡាយទៅប្រាសហើយព្រោះសម្ផស្សពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃ សូម្បីខ្យល់ដង្ហើមគប្បីមាន តែព្រះមហាសត្វកាលព្រះអាទិត្យរះ ក៏ចូលទៅកាន់ព្រៃ ។ ក្នុងដងព្រៃនោះ សន្សើមរលាយ ព្រោះពន្លឺព្រះអាទិត្យធ្លាក់ចុះក្នុងព្រះសរីរៈ របស់ព្រះពោធិសត្វនោះឯង ។ បទថា* **ទិវា អព្ភោកាសេ វិហារាមិ រត្តឹ វនសណ្ឌេ** *សេចក្តីថា បានឮថា ព្រះពោធិសត្វប្រថាប់នៅក្នុងទីវាលអស់ថ្ងៃក្នុងគិម្ហកាល ។ ដោយហេតុនោះ ទើបញើសហូរចេញអំពីព្រះកច្ឆៈ គឺក្លៀកទាំង ២ របស់ព្រះពោធិសត្វនោះ គប្បីមានព្រះអស្សាសៈអស់រាត្រី ព្រះពោធិសត្វកាលព្រះអាទិត្យអស្តង្គត ក៏យាងចូលទៅកាន់ដងព្រៃ ។ លំដាប់នោះ ក្នុងដងព្រៃដែលមានចំហាយក្តៅក្នុងពេលថ្ងៃ អត្តភាពរបស់ព្រះពោធិសត្វ ក៏ក្តៅដូចត្រូវទម្លាក់ក្នុងរណ្តៅរងើកភ្លើង ដូច្នោះ ។ បទថា* **អនច្ឆរិយា** *បានដល់ អស្ចារ្យ*

តិចតួច ។ បទថា **បដិភាសិ** បានដល់ ប្រាកដហើយ ។ បទថា **សោតត្តោ** សេចក្តីថា កម្តៅដុតរោល ដោយពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃ ដោយចំហាយក្តៅក្នុងព្រៃធំនាពេលយប់ ។ បទថា **សោ សិនោ** សេចក្តីថា សើមដោយល្អ ដោយសន្សើមក្នុងពេលយប់ ដោយទឹកសន្សើមក្នុងពេលថ្ងៃ ។ បទថា **ភឹសនកេ** បានដល់ ដែលគួរឲ្យ កើតសេចក្តីខ្លាច ។ បទថា **នគ្គោ** បានដល់ ប្រាសចាកសំពត់ លោកសម្តែងថា ការមានសំពត់ស្បៀក និងសំពត់ដណ្តប់ រងា ឬក្តៅ មិនគប្បីបៀតបៀនក្រៃលែង សំពត់ស្បៀក និងសំពត់ដណ្តប់នោះរបស់តថាគតក៏មិនមាន ។ បទថា **នចគ្គិមាសិនោ** គឺមិនបានអាំងភ្លើង ។ បទថា **ឯសនាបសុតោ** បានដល់ ខ្វល់ខ្វាយ គឺប្រកបដើម្បីប្រយោជន៍ ដើម្បីស្វែងរកសេចក្តីបរិសុទ្ធិ ។ បទថា **មុនិ** សេចក្តីថា ក្នុងកាលនោះ ព្រះអង្គទ្រង់ធ្វើព្រះអង្គឲ្យជាមុនី ហើយត្រាស់ ។

[ ១៨៤ ] បទថា **ឆវដ្ឋិកានិ** បានដល់ ឆ្អឹងទាំងឡាយ ដែលបោះបោលរាត់រាយ ។ បទថា **អបណាធាយ** គឺទ្រង់សម្តែងថា ខ្នើយកើយសីសៈ និងខ្នើយកើយជើងរមែងប្រាកដ យ៉ាងណា ព្រះអង្គទ្រង់ក្រាលហើយសម្រេចការផ្ទំលើគំនរឆ្អឹងនោះ ដូច្នោះ ។ បទថា **គោមណ្ឌលា** បានដល់ ពួកក្មេងឃ្វាលគោ បានឮថា ក្មេងទាំងនោះទៅកាន់សម្នាក់ព្រះពោធិសត្វហើយ ពោលថា បពិត្រសុមេធ លោកអង្គុយពោលនៅក្នុងទីនេះ ព្រោះហេតុអ្វី ព្រះពោធិសត្វទ្រង់អង្គុយឱនមុខ មិនឆ្លើយ ។ លំដាប់នោះ ក្មេងឃ្វាលគោទាំងនោះ ចោមរោមព្រះពោធិសត្វនោះហើយ ស្រែកខ្លាំងៗ ថា ពួក

*យើងនឹងធ្វើឲ្យឆ្លើយ ទើបស្តោះទឹកមាត់ដាក់ព្រះសរីរៈ ។ ទោះបីពួកក្មេងធ្វើយ៉ាងនោះ ព្រះពោធិសត្វក៏មិនត្រាស់ដូចមុន ។ លំដាប់នោះ ពួកក្មេងឃ្វាលគោក្រោធខឹងព្រះពោធិសត្វថា លោកមិនព្រមពោល ទើបបន្ទោបង់បស្សាវៈស្រោចលើព្រះពោធិសត្វនោះ ។ សូម្បីយ៉ាងនោះ ព្រះពោធិសត្វក៏មិនត្រាស់ឡើយ ។ បន្ទាប់អំពីនោះ ទើបបាចធូលីលើព្រះពោធិសត្វនោះថា សូមលោកនិយាយ សូមលោកពោល ដូច្នេះ ។ ទោះបីយ៉ាងនេះ ព្រះពោធិសត្វក៏មិនឆ្លើយនោះឯង ។ លំដាប់នោះ ទើបពោលថា លោកមិននិយាយ ទើបយកផ្កាស្មៅត្បារត្រង់ព្រះកាណ៌ទាំង ២ របស់ព្រះពោធិសត្វនោះ ។ ព្រះ-ពោធិសត្វទ្រង់អត់សង្កត់នូវទុក្ខវេទនាដ៏ខ្លាំងក្លា ក្តៅរោលរាល រមែងស្ថិតនៅដូចមនុស្សស្លាប់ថា អញនឹងមិនពោលពាក្យណា ដល់បុគ្គលណាឡើយ ដោយហេតុនោះ ទើបត្រាស់ថា ម្នាលសារីបុត្រ តថាគតមិនដែលឲ្យចិត្តអាក្រក់កើតឡើងចំពោះពួកក្មេងឃ្វាលគោទាំងនោះឡើយ ដូច្នេះ អធិប្បាយថា ចិត្តអាក្រក់ក៏តថាគតមិនឲ្យកើតហើយ ក្នុងកុមារទាំងនោះ ។ បទថា* **ឧបេក្ខាវិហារស្មឹ ហោតិ** *គឺជាអ្នកនៅដោយឧបេក្ខា ។ វិហារនោះឯង ហៅថា* **វិហារស្មឹ** *ដោយបទនោះឯង គប្បីជ្រាបអត្ថយ៉ាងនេះថា* **អយំសុ មេ** *ក្នុងបទនេះ* **ឥធំសុ មេ** *ក្នុងទីនេះ ។ គប្បីជ្រាបបទដទៃបែបនេះ ដោយន័យនេះ ។ ទ្រង់សម្តែងឧបេក្ខាវិហារដែលទ្រង់បំពេញហើយ អស់ ៩១ កប្បអំពីនេះ ដោយបទនេះ ។ ទ្រង់សំដៅដល់ឧបេក្ខាវិហារ ទើបត្រាស់ថា*

*កាលជួបនឹងសេចក្តីសុខ តថាគតក៏មិនត្រេកអរ កាលជួបនឹងសេចក្តីទុក្ខ*

តថាគតក៏មិនទោមនស្ស តថាគតមិនជាប់ក្នុងសុខ និងទុក្ខទាំងពួង នុ៎ះជាឧបេក្ខាបារមីរបស់តថាគត ។

[ ១៨៥ ] បទថា **អាហារេន សុទ្ធិ** គឺជាអ្នកមានការឃើញយ៉ាងនេះថា សត្វទាំងឡាយអាចបរិសុទ្ធដោយអាហារបន្តិចបន្តួចខ្លះ ដូចជាពុទ្រាជាដើម ។ បទថា **ឯវំមាហំសុ** បានដល់ ពោលយ៉ាងនេះ ។ បទថា **កោលេហិ** បានដល់ ពុទ្រាទាំងឡាយ ។ បទថា **កោលោទកំ** គឺទឹកដែលគេច្របាច់ផ្លែពុទ្រាទាំងឡាយ ហើយធ្វើ ។ បទថា **កោលវិកតឹ** បានដល់ ប្រភេទនៃពុទ្រាដូចជាតំណាប់ពុទ្រា នំពុទ្រា និងដុំពុទ្រាជាដើម ។ បទថា **ឯតបរមោ** សេចក្តីថា នុ៎ះជាប្រមាណយ៉ាងក្រៃលែងរបស់ពុទ្រានោះ ព្រោះដូច្នោះ ទើបពុទ្រានោះ ឈ្មោះថា **ឯតបរមោ** មានផ្លែធំ អធិប្បាយថា ក្នុងកាលនោះក្នុងទីបំផុត ៩១ កប្ប ពុទ្រាមិនធំប៉ុនផ្លែព្នៅ និងផ្លែត្នោត តែធំប៉ុនផ្លែពុទ្រាក្នុងឥឡូវនេះប៉ុណ្ណោះ ។ បទថា **អធិមត្តកសិមានំ** សេចក្តីថា ទ្រង់ស្គមយ៉ាងក្រៃលែង ។ បទថា **អសីតិកបព្វានិ វា កាលបព្វានិ វា** គឺទ្រង់សម្តែងថា វល្លិមានថ្នាំងច្រើន ឬវល្លិមានថ្នាំងខ្មៅ ដែលស្ងួតក្នុងទី-ត រមែងប៉ោងឡើង និងផតចុះត្រង់កណ្តាល យ៉ាងណា អវយវៈតូចធំរបស់តថាគតក៏ដូច្នោះ ។ បទថា **ឱដ្ឋបទំ** សេចក្តីថា ជើងអូដ្ឋ ជាធម្មជាតិជ្រៅត្រង់កណ្តាល យ៉ាងណា កាលសាច់ និងឈាមរីងស្ងួត ត្រគាករបស់ព្រះពោធិ-សត្វក៏ជ្រៅត្រង់កណ្តាល ព្រោះការដែលវច្ចទ្វារចូលទៅខាងក្នុងយ៉ាងនោះដូចគ្នា ។ ពេលនោះ ទឹកខ្នែងអង្គុយត្រង់ផែនដីរបស់ព្រះពោធិសត្វនោះ ក៏នឹង

ប៉ោងឡើងត្រង់កណ្ដាល ដូចប្រថាប់ដោយបំពង់ព្រួញ ។ បទថា **វដ្ដនាវឡី** សេចក្ដីថា វល្លិដកគន់ដែលគេវេញធ្វើជាខ្សែ ក៏នឹងប៉ោងក្នុងចន្លោះៗ នៃដកគន់ដែលគេវេញ យ៉ាងណា ឆ្អឹងខ្នងក៏ប៉ោងជាពក ដូច្នោះ ។ បទថា **ជរសាលាយ គោបាណសិយោ** បានដល់ បង្កង់នៃសាលាចាស់ ។ បង្កង់ទាំងនោះជ្រុះចាកគ្រឿង ហើយតាំងនៅក្នុងបរិវេណ បង្កង់ដែលនៅក្នុងបរិវេណក៏ជ្រុះនៅក្នុងផែនដី ព្រោះដូច្នោះ ក៏បះឡើង និងសំយុងចុះ គឺមួយនៅខាងលើ មួយនៅខាងក្រោម ។ ឆ្អឹងជំនីរបស់ព្រះពោធិសត្វ មិនជាយ៉ាងនោះឡើយ ព្រោះកាលឈាមស្ងួត សាច់ស្វិត ព្រះពោធិសត្វនោះក៏មានព្រះចម្ពះ គឺស្បែកក្នុងចន្លោះៗ ឆ្អឹងជំនីរស្រុតចុះ ទ្រង់សំដៅដល់ឆ្អឹងជំនីរនោះ ទើបត្រាស់បទនេះ ។ បទថា **ឱក្ខាយិកា** បានដល់ ជ្រៅទៅក្នុងចំណែកខាងក្រោម ។ បានឮថា កាលឈាមរីងស្ងួត សាច់ក្រៀមស្វិត រណ្ដៅភ្នែកព្រះពោធិសត្វក៏ជ្រៅទៅទល់គ្នានឹងខួរ ព្រោះហេតុនោះ ទើបភ្នែករបស់ព្រះពោធិ-សត្វ យ៉ាងនោះ ។ បទថា **អាមកច្ឆិន្នោ** បានដល់ កាត់ហើយក្នុងវេលានៅទន់ ។ ននោងខ្ចីនោះប៉ះខ្យល់ និងកម្ដៅថ្ងៃ រមែងស្ងួត ។ បទថា **យាវស្សុ មេ សារិបុត្ត** សេចក្ដីថា ម្នាលសារីបុត្រ ស្បែកពោះរបស់តថាគតស្វិតជាប់នឹងឆ្អឹងខ្នង មួយប្រការទៀត គប្បីជ្រាបការសម្ពន្ធក្នុងបទនោះយ៉ាងនេះថា ម្នាលសារីបុត្រ ការបំពេញទុក្ករកិរិយារបស់តថាគតនៅជាការៈធ្ងន់ដរាបណា ស្បែកពោះរបស់តថាគតស្វិតជាប់នឹងឆ្អឹងខ្នងដរាបនោះ ។ បទថា **បិដ្ឋិ-កណ្ដកាំយេវ បរិគ្គណ្ហាមិ** សេចក្ដីថា តថាគតគិតថា នឹងចាប់ស្បែកពោះ

ស្អាបអង្កែលស្បែកពោះតែម្យ៉ាង ក៏ស្អាបត្រូវឆ្អឹងខ្នងនោះឯង ។ បទថា **អវក្កុជ្ជា បបតាមិ** សេចក្ដីថា កាលព្រះអង្គគង់ដើម្បីអង្គុយប្រយោជន៍ដល់ការបន្ទោបង់ឧច្ចារបស្សាវៈ បស្សាវៈមិនចេញឡើយ តែវច្ចៈមានត្រឹមតែប៉ុនគ្រាប់ល្មៀង ២-៣ ដុំ ក៏ញុំាងទុក្ខដែលមានកម្លាំងឲ្យកើតឡើង ញើសទាំងឡាយក៏ហូរចេញចាកសរីរៈ ។ ព្រះអង្គក៏ដួលចុះត្រង់ផែនដីក្នុងទីនោះឯង ។ ដោយហេតុនោះ ទើបត្រាស់ថា តថាគតដួលចុះ ដូច្នេះ ។ បទថា **តមេវ កាយំ** បានដល់ កាយទីបំផុតក្នុង ៩១ កប្ប ។ ទ្រង់សំដៅដល់កាយក្នុងកពចុងក្រោយ ក្នុងមហាសច្ចកសូត្រ ទើបត្រាស់ថា **ឥមមេវ កាយំ** ដូច្នេះ ។ បទថា **បូតិមូលានិ** សេចក្ដីថា កាលព្រះមំសៈ ឬព្រះលោហិតនៅមាន រោមទាំងឡាយក៏តាំងនៅបាន តែព្រោះមិនមានសាច់ និងឈាមនោះ រោមទាំងឡាយ ដូចជាជាប់ក្នុងបន្ទះស្បែក ក៏ជ្រុះជាប់ដៃផងដែរ ទ្រង់សំដៅដល់អាការនោះ ទើបត្រាស់ថា រោមទាំងឡាយមានគល់ស្អុយ ក៏ជ្រុះចាកកាយ ដូច្នេះ ។

[ ១៨៦ ] បទថា **អលមរិយ ញាណទស្សន វិសេសំ** បានដល់ លោកុត្តរមគ្គដែលអាចនឹងធ្វើភាពជាអរិយៈបាន ។ បទថា **ឥមិស្សាយេវ អរិយាយ បញ្ញាយ** សេចក្ដីថា ព្រោះមិនសម្រេចវិបស្សនាបញ្ញា ។ បទថា **យាយំ អរិយា** បានដល់ សម្រេចមគ្គប្បញ្ញានេះ ។ លោកពោលដូច្នេះថា ឈ្មោះថា **សម្រេចមគ្គប្បញ្ញា** ព្រោះវិបស្សនាញាណបានសម្រេចហើយ ក្នុងឥឡូវនេះ យ៉ាងណា តថាគតមិនសម្រេចលោកុត្តរមគ្គប្បញ្ញា ព្រោះ

វិបស្សនាញាណមិនបានសម្រេចហើយ ក្នុងទីបំផុត ៩១ កប្ប ដូច្នោះ ។ ឯមជ្ឈិមភាណកត្ថេរពោលថា បញ្ញាដែលពោលថា **ឥមិស្សាយេវ** ក្តី បញ្ញាដែលពោលថា **យាយំ អរិយា** ក្តី គឺមគ្គប្បញ្ញានោះឯង ។ លំដាប់នោះ ភិក្ខុទាំងឡាយបានពោលនឹងមជ្ឈិមភាណកត្ថេរនោះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលបើដូច្នោះ ពាក្យថា ខ្ញុំមិនបានសម្រេចមគ្គ ព្រោះមគ្គបានសម្រេចហើយនេះ លោកបានពោលហើយ ។ ព្រះថេរៈឆ្លើយថា នែអាវុសោ ខ្ញុំមិនអាចសម្តែងក៏ពិត តែបញ្ញា ២ យ៉ាងនោះ គឺមគ្គប្បញ្ញានោះឯង ។ ពាក្យនោះឯង សមគួរហើយក្នុងទីនេះ ។ ដោយប្រការនេះ និទ្ទេសថា **យា អយំ** ក៏មិនសមគួរ ។

[ ១៨៧ ] បទថា **សំសារេន សុទ្ធិ** គឺពោលថា សត្វទាំងឡាយអន្ទោលទៅមកច្រើនជាតិ រមែងបរិសុទ្ធ ។

[ ១៨៨ ] បទថា **ឧបបត្តិយា សុទ្ធិ** បានដល់ ពោលថា កើតឡើងច្រើនជាតិ រមែងបរិសុទ្ធ ។

[ ១៨៩ ] បទថា **អាវាសេនសុទ្ធិ** គឺពោលថា នៅក្នុងទី ទាំងឡាយច្រើនកន្លែង រមែងបរិសុទ្ធ ។ លោកពោលដល់ខន្ធទាំងឡាយនោះឯង ក្នុងឋានៈ ៣ ថា សង្សារ ដោយអំណាចអ្នកអន្ទោលទៅ ឧប្បត្តិ ដោយអំណាចអ្នកកើត អាវាស ដោយអំណាចអ្នកនៅ ។ បទថា **យញ្ញេន** បានដល់ពោលថា បូជាយញ្ញច្រើន រមែងបរិសុទ្ធ ។

[ ១៩០ ] បទថា **មុទ្ធាវសិត្តេន** សេចក្តីថា អភិសេក ជាក្សត្រដោយ

ស័ន្ធ ៣ ។

[ ១៩១ ] បទថា **អគ្គិចារិចរិយាយ** បានដល់ ពោលថា រមែង បរិសុទ្ធដោយការបម្រើភ្លើងច្រើន ។

[ ១៩២ ] បទថា **ទហរោ** គឺកំលោះ ។ បទថា **យុវា** បានដល់ ដល់ព្រមដោយភាពជាកំលោះ ។ បទថា **សុសុកាឡកេសោ** គឺមានសក់ខ្មៅស្រិល ។ បទថា **បញ្ញាវេយ្យត្តិយេន** បានដល់ ភាពជាអ្នកមានបញ្ញាមុតស្រួច ។ បទថា **ជិណ្ណោ** គឺដែលជរាគ្របសង្កត់ ។ បទថា **វុឌ្ឍោ** បានដល់ មានអវយវៈតូចធំចម្រើនបរិបូណ៌ហើយ ។ បទថា **មហល្លកោ** គឺធំដោយជាតិ ។ បទថា **អទ្ធគតោ** បានដល់ អស់កាលច្រើន គឺកន្លងកាលយូរ ។ បទថា **វយោ អនុប្បត្តោ** សេចក្តីថា កន្លងបច្ឆិមវ័យ ដែលជាចំណែកទី ៣ នៃ ១០០ ឆ្នាំ ។ បទថា **អសីតិកោ មេ វយោ វត្តតិ** សេចក្តីថា បានឮថា ព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះ ក្នុងឆ្នាំនៃបរិនិព្វាន ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **បរមាយ** គឺឧត្តម ។ រមែងពោលដល់ ១០០ បទខ្លះ ១០០០ បទខ្លះ ក្នុងបទថា **សតិយា** ជាដើម ភាពជាអ្នកអាចរៀនឈ្មោះថា **សតិ** ភាពជាអ្នកអាចទ្រទ្រង់ និង ចាំ ឈ្មោះថា **គតិ** សេចក្តីព្យាយាមដែលអាចធ្វើការស្វាធ្យាយ ដែលរៀនហើយ ចងចាំហើយយ៉ាងនេះឈ្មោះថា **ធិតិ** ។ ភាពជាអ្នកអាចឃើញ អត្ថ និងហេតុនៃធិតិនោះ ឈ្មោះថា **បញ្ញាវេយ្យត្តិយ** ។ បទថា **ទឡ្ហធម្មោ ធនុគ្គហោ** សេចក្តីថា ខ្មាន់ធ្នូឈរចាប់ធ្នូមាំទាំ ។ កម្លាំង ២០០០ ហៅថា **ទឡ្ហធនូ** ធ្នូណាដែលលើក

*ឡើងហើយ មានខ្សែចង មានទម្ងន់ដូចគ្នានឹងដុំដែកជាដើម ចាប់ជងលើកឡើងផុតអំពីដីប្រមាណស្មើក ធ្នូនោះ ឈ្មោះថា មានកម្លាំង ២០០០ ។ បទថា* **សិក្ខិតោ** *សេចក្តីថា មានសិប្បៈដែលរៀនហើយ ក្នុងត្រកូលអាចារ្យដល់ទៅ ១២ ឆ្នាំ ។ បទថា* **កតហត្ថោ** *សេចក្តីថា បុគ្គលខ្លះរៀនត្រឹមតែសិប្បៈប៉ុណ្ណោះ មិនបានទទួលការហ្វឹកហាត់ តែខ្មាន់ធ្នូនេះ បានទទួលការហ្វឹកហាត់ ហើយជំនាញ ស្ទាត់ ធ្លាប់សម្តែងប្ញីដែមកហើយ គឺមានសិប្បៈដែលបានសម្តែងហើយក្នុងទីទាំងឡាយ មានរាជត្រកូលជាដើម ។ បទថា* **លហុ-កេន អសនេន** *សេចក្តីថា ដោយព្រួញដែលស្រាល ដែលធ្វើបរិកម្មដោយជ័រ ដែលធ្វើទម្រទុកខាងក្នុង ធ្វើឲ្យពេញខ្សែជាដើម ព្រួញដែលធ្វើយ៉ាងនេះ ទម្លុះគោឧសភៈមួយ ទម្លុះគោឧសភៈ ២ ក្បាលបាន ព្រួញដែលទម្លុះគោឧសភៈ ៨ ក្បាល ទម្លុះគោឧសភៈ ១៦ ក្បាលបាន ។ បទថា* **អប្បក-សិរេន** *បានដល់ ដោយមិនលំបាក ។ បទថា* **អតិបាតេយ្យ** *គឺគប្បីឲ្យធ្លុះ ។ បទថា* **ឯវំ អធិមត្តសតិមន្តោ** *សេចក្តីថា ខ្មាន់ធ្នូនោះ រមែងបាញ់ស្រមោល ១ ចំអាម ៤ ធ្លាប់បានរហ័ស យ៉ាងណា អាចដើម្បីរៀន ដើម្បីទ្រទ្រង់ចាំ ដើម្បីស្វាធ្យាយ ១០០ បទខ្លះ ១០០០ បទខ្លះ និងដើម្បីពិចារណាអត្ថ និងហេតុទាំងឡាយបាន ដូច្នោះ ។ បទថា* **អញ្ញត្រ អសិតបីតខាយិត-សាយិតា** *សេចក្តីថា កិច្ចទាំងឡាយ មានការបរិភោគ និងការផឹកជាដើម ជាកិច្ចដែលព្រះមានព្រះភាគក្តី ភិក្ខុទាំងឡាយក្តី គប្បីធ្វើ ព្រោះដូច្នោះ ទើបទ្រង់សម្តែងថា វៀរវេលាដែលធ្វើកិច្ចទាំងឡាយ មានការបរិភោគ និងការផឹក*

ជាដើមនោះ ។ បទថា **អបរិយាទិន្នាយេវ** សេចក្តីថា ដែលមិនចប់ ។ បើភិក្ខុមួយរូបសួរកាយានុបស្សនា មួយរូបសួរវេទនានុបស្សនា មួយរូបសួរចិត្តានុបស្សនា មួយរូបសួរធម្មានុបស្សនា ភិក្ខុតែមួយរូប រមែងមិនសម្គឹងគ្នាថា អញត្រូវភិក្ខុនេះសួរហើយក៏នឹងសួរ ។ កាលបើដូច្នោះ វារៈនៃភិក្ខុទាំងនោះ រមែងប្រាកដ ។ តែវារៈនៃព្រះពុទ្ធទាំងឡាយ រមែងមិនប្រាកដយ៉ាងនេះ ។ ព្រះមានព្រះភាគត្រាស់កាយានុបស្សនា ១៤ វិធី វេទនានុបស្សនា ៩ វិធី ចិត្តានុបស្សនា ១៦ វិធី ធម្មានុបស្សនា ៥ វិធី លឿនជាងការបាញ់ស្រមោល ១ ចំអាម ៤ ធ្នាប់ យ៉ាងរហ័សទៅទៀត ។ សតិប្បដ្ឋាន ៤ នោះ ចូរលើកទុកសិន បើភិក្ខុ ៤ រូបដទៃគប្បីសួរបញ្ហាក្នុងសម្មប្បធានទាំងឡាយ មួយពួកទៀតសួរបញ្ហាក្នុងឥទ្ធិបាទ មួយពួកទៀតសួរបញ្ហាក្នុងឥន្ទ្រិយ ៥ មួយពួកទៀតសួរបញ្ហាក្នុងពល ៥ មួយពួកទៀតគប្បីសួរបញ្ហាក្នុងពោជ្ឈង្គ ៧ មួយពួកទៀតគប្បីសួរបញ្ហាក្នុងអង្គមគ្គ ៨ សោត ព្រះមានព្រះភាគ គប្បីត្រាស់បញ្ហានោះបាន ។ម្យ៉ាងទៀត អង្គមគ្គ ៨ នោះចូរលើកទុកសិន ។ បើជន ៣៧ នាក់ដទៃគប្បីសួរបញ្ហាក្នុងពោធិបក្ខិយធម៌ទាំងឡាយសោត ព្រះមានព្រះភាគគប្បីត្រាស់បញ្ហានោះបានមុននោះឯង ។ ព្រោះហេតុអ្វី ព្រោះមហាជនក្នុងលោក រមែងពោលបានបទមួយដោយប្រមាណប៉ុនណា ព្រះអានន្ទត្ថេររមែងពោលបាន ៨ បទ ដោយប្រមាណប៉ុណ្ណោះ ។ កាលព្រះអានន្ទត្ថេរពោលបានមួយបទប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់បាន ១៦ បទ ។ ព្រោះហេតុអ្វី ព្រោះជិវ្ហារបស់ព្រះមានព្រះភាគទន់ ជួរព្រះទន្តរាបស្មើ ព្រះវចនៈមិន

*ជាប់ កវង្គបរិវាសស្រោល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ធម្មទេសនារបស់តថាគតនោះ ទើបមិនអស់ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **ធម្មទេសនា** *បានដល់ ដាក់របៀបបែបផែន ។ បទថា* **ធម្មបទព្យញ្ជនំ** *សេចក្តីថា បទព្យញ្ជនៈនៃបាលី គឺអក្ខរៈដែលជាតួព្យញ្ជនៈនៃអត្ថនោះៗ ។ បទថា* **បញ្ហាបដិភាណំ** *បានដល់ បញ្ហាព្យាករ ។ ទ្រង់សម្តែងអ្វីដោយបទនោះ ទ្រង់សម្តែងយ៉ាងនេះថា ក្នុងកាលមុនវេលានៅជាកំលោះ តថាគតអាចប្រមូលអក្ខរៈទាំងឡាយ ពោលជាបទបាន អាចប្រមូលបទទាំងឡាយ ពោលជាគាថាបាន អាចពោលអត្ថដោយគាថាដែលប្រកបដោយបទ មាន ៤ អក្ខរៈខ្វះ មាន ១៦ អក្ខរៈខ្វះ តែក្នុងវេលាចាស់ឥឡូវនេះ មិនអាចដើម្បីប្រមូលអក្ខរៈទាំងឡាយពោលជាបទ ឬប្រមូលបទទាំងឡាយពោលជាគាថា ឬពោលអត្ថដោយគាថាបាន ដូចពោលមកនេះ រមែងមិនមានក្នុងវេលាកំលោះ និងក្នុងវេលាចាស់ ធម្មទេសនាជាដើមទាំងអស់នោះរបស់តថាគត មិនមានពេលអស់ ។ បទថា* **មញ្ចកេន ចេ មំ** *សេចក្តីថា ទ្រង់កំណត់បទនេះ ហើយត្រាស់សម្តែងកម្លាំងរបស់ព្រះពុទ្ធនោះឯង ។ ឈ្មោះថា កាលក្នុងការលើកព្រះទសពលឡើងកាន់គ្រែតូច ហើយបរិហារពេញគាមនិគម និងរាជធានីមិនមាន ។ ព្រះតថាគតទាំងឡាយដែលជាអ្នកមានលក្ខណៈ មានធ្មេញបាក់ជាដើមមិនគ្របសង្កត់ហើយ ក្នុងចំណែកនៃអាយុទី ៥ កាលការផ្លាស់ប្តូរនៃពណ៌សម្បុរសរីរៈ មានពណ៌ដូចមាសមិនកើតឡើងហើយ រមែងបរិនិព្វានក្នុងកាលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតា និងមនុស្សទាំងឡាយនោះឯង ។*

[ ១៩៣ ] បទថា **នាគសមាលោ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ក្នុងបឋមពោធិកាលខាងក្នុង ២០ ឆ្នាំ ព្រះនាគសមាលៈនេះជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ដូចព្រះឧបវាណត្ថេរ ព្រះនាគិតត្ថេរ និងព្រះមេឃិយត្ថេរ ។ បទថា **វីជយមានោ** គឺញុំាងសេចក្ដីសុខក្នុងរដូវឲ្យតាំងឡើងដល់ព្រះមានព្រះភាគដោយខ្យល់អំពីផ្ចិតស្លឹកត្នោតដ៏ទន់ ។ បទថា **ឯតទវោច** សេចក្ដីថា ព្រះថេរៈស្ដាប់ព្រះសូត្រពីដើមដល់ចប់ហើយ អាស្រ័យការបំពេញទុក្ករកិរិយាដែលធ្លាប់បំពេញមកហើយក្នុងកាលមុនរបស់ព្រះមានព្រះភាគ ជ្រះថ្លាហើយ ទើបក្រាបទូលពាក្យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីនុ៎ះអស្ចារ្យពេកណាស់ ដូច្នេះ ។ ក្នុងបទនោះ ឈ្មោះថា **អច្ឆរិយ** ព្រោះគួរហើយដើម្បីទះដៃ ។ ឈ្មោះថា **អព្ភុត** ព្រោះមិនធ្លាប់មាន ក៏មានឡើង ។ ព្រះថេរៈសម្ដែងការចម្លែកក្នុងចិត្តរបស់ខ្លួនដោយបទទាំង ២ ។ ក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះឈ្មោះអ្វី ដោយបំណងថា ធម្មបរិយាយនេះល្អហ្ន៎ ណ្ហើយចុះ អញនឹងទូលសូមព្រះមានព្រះភាគ ឲ្យកំណត់ឈ្មោះធម្មបរិយាយនេះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រារព្ធឈ្មោះធម្មបរិយាយនោះ ទើបត្រាស់ថា **តស្មា តិហ ត្វំ** ជាដើម ។ អត្ថនៃធម្មបរិយាយនោះថា រោមទាំងឡាយព្រឺឡើង ព្រោះស្ដាប់សូត្រនេះ ព្រោះហេតុនោះឯង នាគសមាលៈ អ្នកចូរចាំទុកនូវធម្មបរិយាយនេះថា **លោមហំសនបរិយាយ** ដូច្នេះឯង ។៚

**មហាសីហនាទសូត្រទី ២ ចប់**

# សុត្តន្តបិដក

## មហាទុក្ខក្ខន្ធសូត្រទី ៣

[ ១៩៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាតក្នុងពេលព្រឹកព្រហាម ។ លំដាប់នោះ ភិក្ខុទាំងនោះបានគិតគ្នាយ៉ាងនេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ( នេះ ) ក៏នៅព្រឹកពេកណាស់ បើដូច្នេះ គួរតែពួកយើងចៀងចូលទៅឯអារាមរបស់ពួកបរិព្វាជកអន្យតិរ្ថិយសិន ។ គ្រានោះឯង ភិក្ខុទាំងនោះ ក៏ចូលទៅឯអារាមរបស់បរិព្វាជកអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅរកពួកបរិព្វាជកអន្យតិរ្ថិយនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបពួកបរិព្វាជកអន្យតិរ្ថិយបានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម បញ្ញត្តការកំណត់ដឹងនូវកាមារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវកាមារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតមបញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម តែងបញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយ

ចំណែកខាងពួកយើងក៏បញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយដែរ ។ ម្នាល អាវុសោទាំងឡាយ ចុះក្នុងការបញ្ញត្តនេះ ( បើប្រៀបធៀប ) នូវធម៌ទេសនា ដោយធម៌ទេសនា ឬ ( ប្រៀបធៀប ) នូវពាក្យប្រៀនប្រដៅ ដោយពាក្យប្រៀនប្រដៅរបស់ព្រះសមណគោតមក្តី របស់ពួកយើង តើណាមានសេចក្តីវិសេសជាងណា មានអធិប្បាយដូចម្តេច មានហេតុផ្សេងៗ គ្នាដូចម្តេច ។ លំដាប់នោះ ភិក្ខុទាំងនោះ មិនបានត្រេកអរ មិនបានហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជកអន្យតិរ្ថិយនោះឡើយ លុះមិនបានត្រេកអរ មិនបានហាមឃាត់ហើយ ក៏នាំគ្នាក្រោកចាកអាសនៈចៀសចេញទៅដោយគិតថា ពួកយើងគង់នឹងដឹងច្បាស់នូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគមិនខាន ។

[ ១៩៥ ] គ្រានោះឯង ភិក្ខុទាំងនោះ ក៏ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ហើយចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រហាមនេះ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គបានគិតគ្នាយ៉ាងនេះថា ការត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី ( នេះ ) ក៏នៅព្រឹកពេកណាស់ បើដូច្នោះ ពួក

យើងគួរចៀនចូលទៅឯអារាមរបស់ពួកបរិព្វាជកអន្យតិ្ថិយសិនចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ខ្ញុំព្រះអង្គទាំងឡាយ ក៏ចូលទៅឯអារាមរបស់ពួកបរិព្វាជកអន្យតិ្ថិយ លុះចូលទៅដល់ហើយក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលទៅរកពួកបរិព្វាជកអន្យតិ្ថិយនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះពួកខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ពួកបរិព្វាជកអន្យតិ្ថិយនោះ បានពោលសេចក្តីនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតមបញ្ញត្តការកំណត់ដឹងនូវចំណែកកាមារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើងក៏បញ្ញត្តការកំណត់ដឹងនូវកាមារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំង-ឡាយ ព្រះសមណគោតម បញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវរូបារម្មណ៍ទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម បញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយ ចំណែកខាងពួកយើង ក៏បញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយដែរ ។ ម្នាលអាវុសោទាំងឡាយ ចុះការបញ្ញត្តនេះ ( បើប្រៀបធៀប ) ធម៌ទេសនាដោយធម៌ទេសនា ( ប្រៀបធៀប ) ពាក្យប្រៀនប្រដៅដោយពាក្យប្រៀនប្រដៅរបស់ព្រះសមណគោតមក្តី របស់ពួកយើងក្តី តើណាមានសេចក្តីវិសេសជាងណា មានសេចក្តីអធិប្បាយដូចម្តេច មានហេតុផ្សេងគ្នាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គទាំងឡាយមិនបានត្រេកអរ មិនបានហាមឃាត់ភាសិត របស់ពួកបរិព្វាជកអន្យតិ្ថិយនោះ

ឡើយ លុះមិនបានត្រេកអរ មិនបានហាមឃាត់ហើយ ក៏នាំគ្នាក្រោកចាកអាសនៈ ចៀសចេញមកដោយគិតគ្នាថា ពួកយើងគង់នឹងដឹងច្បាស់នូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគមិនខាន ។

[ ១៩៦ ] ព្រះមានជោគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិព្វាជកអន្យតិរ្ថិយសួរយ៉ាងនេះ ពួកអ្នកត្រូវសួរយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាតម្រេករបស់កាមទាំងឡាយ អ្វីជាទោសរបស់កាមទាំងឡាយ អ្វីជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ អ្វីជាតម្រេករបស់រូបទាំងឡាយ អ្វីជាទោសរបស់រូបទាំងឡាយ អ្វីជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ អ្វីជាតម្រេករបស់វេទនាទាំងឡាយ អ្វីជាទោសរបស់វេទនាទាំងឡាយ អ្វីជាគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ពួកបរិព្វាជកអន្យតិរ្ថិយ កាលបើអ្នកទាំងឡាយ សួរយ៉ាងនេះហើយ មុខជាមិនអាចនឹងដោះស្រាយរួចផង នឹងដល់នូវសេចក្តីចង្អៀតចង្អល់ចិត្តជាយ៉ាងក្រៃពេកផង ។ ចុះដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុថា ( ប្រស្នានោះ ) មិនមែនជាវិស័យ ( របស់ខ្លួន ) ម្នាលភិក្ខុទាំងឡាយ បុគ្គលណានឹងញ៉ាំងចិត្តឲ្យត្រេកអរ ដោយវេយ្យាករណ៍នៃបញ្ហានេះបាន តថាគតពិចារណារកបុគ្គលនោះក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសមិនឃើញមានឡើយ វៀរលែងតែតថាគត ឬសាវ័ករបស់តថាគត ឬក៏បុគ្គលដែលបានស្តាប់អំពីសាសនានេះ ។

[ ១៩៧ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេករបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាមគុណ ( ចំណងកាម ) នេះមាន ៥ ប្រការ កាមគុណ ៥ ប្រការ តើអ្វីខ្លះ គឺរូបទាំងឡាយដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ សំឡេងទាំងឡាយដែលគប្បីដឹងបានដោយត្រចៀក ... ១ ក្លិនទាំងឡាយដែលគប្បីដឹងបានដោយច្រមុះ ... ១ រសទាំងឡាយដែលគប្បីដឹងបានដោយអណ្ដាត ... ១ ផ្សព្វទាំងឡាយដែលគប្បីដឹងបានដោយកាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា កាមគុណ ៥ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណ ៥ ប្រការនេះ នេះឯងជាតម្រេករបស់កាមទាំងឡាយ ។

[ ១៩៨ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្ដីប្រឹងប្រែង ដោយសិល្បសាស្ត្រណាមួយ ទោះបីដោយការរាប់ម្រាមដៃទទេក្ដី ដោយការរាប់លេខនព្វន្តក្ដី ដោយការរាប់ប្រមូលក្ដី ដោយកសិកម្មក្ដី ដោយពាណិជ្ជកម្មក្ដី ដោយគោរក្ខកម្មក្ដី ដោយភាវៈនៃខ្លួនជាអ្នកកាន់អាវុធក្ដី ដោយភាវៈនៃខ្លួនជារាជបុរសក្ដី ដោយសិល្បសាស្ត្រណាមួយក្ដី កុលបុត្រដែលអាស្រ័យនូវការចិញ្ចឹមជីវិត ដោយការរាប់ម្រាមដៃទទេជាដើមនោះ តែងមានត្រជាក់បៀតបៀន មានក្ដៅបៀតបៀន ប៉ះពាល់ដោយសម្ផស្សនៃរបោម មូស

ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំ ស្លាប់ខ្លួនព្រោះសេចក្តីស្រេកឃ្លាន ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើកុលបុត្តនោះ ប្រឹងប្រែងខ្នះខ្នែង ព្យាយាមយ៉ាងនេះហើយ ភោគៈទាំងឡាយនោះ ក៏មិនបានសម្រេច កុលបុត្តនោះតែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ឱ សេចក្តីប្រឹងប្រែងរបស់អញឥតអំពើសោះ ឱ សេចក្តីព្យាយាមរបស់អញឥតផលសោះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើមជាបច្ច័យនៃកាមទាំង-ឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើកុលបុត្តនោះ ប្រឹងប្រែងខ្នះខ្នែងព្យាយាមយ៉ាងនេះហើយ ភោគៈទាំងឡាយនោះក៏សម្រេច កុលបុត្តនោះតែងទទួលនូវសេចក្តីទុក្ខទោមនស្ស ព្រោះហេតុនៃការរក្សានូវភោគៈទាំង-ឡាយនោះថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យព្រះរាជទាំងឡាយនាំយកភោគៈទាំងឡាយនោះទៅបាន កុំឲ្យចោរទាំងឡាយលួចយកបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យអ្នកទទួកមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់នាំយកទៅបាន ។ កាលកុលបុត្តនោះខំរក្សាគ្រប់គ្រងយ៉ាងនេះ ក៏ស្រាប់តែព្រះរាជាទាំងឡាយរឹបយកនូវភោគៈទាំងឡាយនោះទៅក្តី ចោរទាំងឡាយលួចយក

ទៅក្តី ភ្លើងឆេះទៅក្តី ទឹកបន្សាត់ទៅក្តី អ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់នាំយកទៅក្តី កុលបុត្តនោះ តែងក្រៀមក្រំចិត្ត លំបាកខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ទ្រព្យណាបានកើតមានហើយដល់អាត្មាអញ ឥឡូវនេះ ទ្រព្យនោះឯង ត្រឡប់ជាមិនមានដល់អាត្មាអញវិញឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាព្រះរាជាទាំងឡាយទាស់ទែងគ្នានឹងព្រះរាជាទាំងឡាយខ្លះ ក្សត្រទាំងឡាយទាស់ទែងគ្នានឹងក្សត្រទាំងឡាយខ្លះ ព្រាហ្មណ៍ទាំងឡាយ ទាស់ទែងគ្នានឹងព្រាហ្មណ៍ទាំងឡាយខ្លះ គហបតីទាំង-ឡាយ ទាស់ទែងគ្នានឹងគហបតីទាំងឡាយខ្លះ មាតាទាស់ទែងនឹងបុត្តខ្លះ បុត្តទាស់ទែងនឹងមាតាខ្លះ បិតាទាស់ទែងនឹងបុត្តខ្លះ បុត្តទាស់ទែងនឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសខ្លះ បងប្អូនប្រុស ទាស់ទែងនឹងបងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសខ្លះ សម្លាញ់ទាស់ទែងនឹងសម្លាញ់ខ្លះ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីឈ្លោះប្រកែក ប្រកាន់ខុសទាស់ទែងគ្នាក្នុងទីនោះហើយ ប្រហារគ្នាទៅវិញទៅមកដោយដៃខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយគ្រឿងសស្ត្រាខ្លះ

ជនទាំងនោះក៏ដល់នូវសេចក្តីស្លាប់ក្នុងទីនោះខ្លះ ដល់នូវសេចក្តីទុក្ខ ស្មើរនឹងស្លាប់ខ្លះ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំង-ឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ បានជាមនុស្សទាំងឡាយកាន់នូវដាវ និងខែល កាន់ធ្នូសៀតបំពង់ព្រួញ ចូលទៅកាន់សង្គ្រាម ដែលកើតជាក្បួនទ័ព មកទាំងសងខាង កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេឆ្វាដាវឡើងក្តី មនុស្សទាំងឡាយនោះបាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ កាត់ក្បាលគ្នាដោយដាវខ្លះ ក្នុងសង្គ្រាមនោះ មនុស្សទាំងឡាយនោះក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខ ស្មើរនឹងស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំង-ឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាមនុស្សទាំងឡាយនោះកាន់ដាវ និងខែល កាន់ធ្នូសៀតបំពង់ព្រួញចូលទៅកាន់បន្ទាយ ដែលលាបបូកដោយបាយអ កាល

ដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេងា ដាវឡើងក្តី មនុស្សទាំងនោះ ក៏បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ បាចសាចដាក់គ្នាដោយអាចម៍គោជ្រាយខ្លះ ញាំញីគ្នាដោយរនាស់ដែកខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងបន្ទាយនោះ មនុស្សទាំងនោះដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរនឹងស្លាប់ខ្លះ ក្នុងបន្ទាយនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចំពោះខ្លួនឯង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត មនុស្សទាំងឡាយក៏កាត់នូវជញ្ជាំងផ្ទះខ្លះ ប្លន់ខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយៗ ខ្លះ ឈរស្កាត់ប្រកផ្លូវខ្លះ គប់រកកិរិយារបស់អ្នកដទៃខ្លះ ។ ព្រះរាជាទាំងឡាយចាប់មនុស្សទាំងនោះបានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ទាំងឡាយ មានប្រការផ្សេងៗ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ប្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងប្រមុះខ្លះ ធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ធ្វើនូវសង្ខមុណ្ឌកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ធ្វើនូវជោតិមាលិកកម្ម គឺអំពើ

ដែលធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើនូវឯរកវត្តិកកម្ម គឺអំពីដែលធ្វើដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូច ជាស្លៀកសំពត់សម្បកឈើខ្លះ ធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យ ដូចជាជើងសត្វទ្រាយខ្លះ ធ្វើនូវពសិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬសន្ទូចខ្លះ ធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈ ប្រមាណប៉ុនកហាបណៈមួយៗ ខ្លះ ធ្វើនូវខារាបជិច្ឆកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ មនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះ ក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ ម្នាលភិក្ខុទាំងឡាយមួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ បានជាជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះជនទាំងឡាយនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា

ប្រព្រឹត្តទុច្ចរិតដោយចិត្ត ហើយដល់បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបរលោក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

[ ១៩៩ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឧបាយជាទីកម្ចាត់បង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈ ក្នុងកាមទាំងឡាយណា នេះឯងឈ្មោះថា ជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ។

[ ២០០ ] ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយពួកខ្លះ មិនដឹងនូវតម្រេករបស់កាមទាំងឡាយ ថាជាគ្រឿងត្រេកអរផង មិនដឹងនូវទោសរបស់កាមទាំងឡាយ ថាជាទោសផល មិនដឹងនូវគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង យ៉ាងនេះដោយពិត សមណៈ ឬព្រាហ្មណ៍ទាំងនោះឯង នឹងកំណត់ដឹងនូវកាមទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវកាមទាំងឡាយបាន នឹងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះមិនមែនជាឋានៈទេ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយណាមួយ ដឹងនូវតម្រេករបស់កាមទាំងឡាយ ថាជាគ្រឿងត្រេកផង ដឹងនូវទោសរបស់កាមទាំងឡាយ ថាជាទោសផង ដឹងនូវគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ថាជា

គ្រឿងរលាស់ចេញផង ដោយពិត សមណៈ ឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវកាមទាំងឡាយ ដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណាទើបនឹងកំណត់ដឹងនូវកាមទាំងឡាយបាន ទាំងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះទើបជាឋានៈ ។

[ ២០១ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេករបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងខត្តិយកញ្ញា ឬព្រាហ្មណកញ្ញា គហបតិកញ្ញា ដែលមានវ័យ ១៥ ឆ្នាំ ឬ ១៦ ឆ្នាំ ជាស្រ្តីមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក ម្នាលភិក្ខុទាំងឡាយ ចុះស្រ្តីនោះមានសម្បុរល្អស្អាតសមរម្យ ក្នុងសម័យនោះឬទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រង់សេចក្តីសុខ សោមនស្សកើតឡើង ព្រោះអាស្រ័យសម្បុរល្អស្អាត នេះឯងជាតម្រេករបស់រូបទាំងឡាយ ។

[ ២០២ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីមើលនូវបងប្អូនស្រីនោះឯងក្នុងសម័យខាងក្រោយមក ដែលមានអាយុ ៨០ ឆ្នាំ ឬមានអាយុ ៩០ ឆ្នាំ មានអាយុ ១០០ ឆ្នាំ ជាស្រ្តីចាស់ជរាហើយដោយជាតិ មានឆ្អឹងជំនីរកោងដូចបង្កង់ផ្ទះ មានកាយកោង កាន់ឈើច្រត់ កាលដើរទៅញ័ររន្ធត់ រសាប់រសល់ដោយជរា មានវ័យកន្លងហើយ មានធ្មេញបាក់ សក់ស្កូវ ក្បាលធកក្បាលតម្ពែក ស្បែកជ្រួញជ្រីវ ខ្លួនរទុះដោយអាចម៍រុយ ។ ម្នាលភិក្ខុទាំង-

ឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនុ៎ះ ថាដូចម្ដេច សម្បុរល្អសមរម្យណា ក្នុងសម័យពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានបុណ្យត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលមានអាពាធដល់នូវសេចក្ដីទុក្ខ ឈឺចាប់ជាទម្ងន់ ដួលដេកត្រាំក្នុងមូត្រ និងលាមករបស់ខ្លួន លុះតែមានជនឯទៀតគ្រាហ៍ឡើង ទើបបានក្រោករួច លុះតែមានជនឯងទៀតនាំឲ្យចូលទៅ ទើបចូលទៅបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនុ៎ះដូចម្ដេច សម្បុរល្អសមរម្យណា ក្នុងកាលពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហ្នឹងហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលគេយកសរីរៈទៅចោលក្នុងព្រៃស្មសាន ទោះស្លាប់អស់មួយថ្ងៃក្ដី ស្លាប់អស់ ២ ថ្ងៃក្ដី ស្លាប់អស់ ៣ ថ្ងៃក្ដី ដែលកំពុងហើមប៉ោងឡើង មានសម្បុរខៀវ មានខ្ទុះហូរចេញ ( តាមទ្វារផ្សេងៗ ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះថាដូចម្ដេច សម្បុរល្អសមរម្យណា ក្នុងកាលពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ព្រះករុណាព្រះ

អង្គ ។ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហ្នឹងហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលគេយកសរីរៈទៅចោលក្នុងព្រៃស្មសាន ក្អែកទាំងឡាយកំពុងតែចឹកស៊ីក្តី ពួកត្មាតកំពុងចឹកស៊ីក្តី ត្រដក់ទាំងឡាយកំពុងចឹកស៊ីក្តី ស្វានទាំងឡាយកំពុងកកេរស៊ីក្តី ចចកទាំងឡាយកំពុងកកេរស៊ីក្តី បាណកជាតិទាំងឡាយផ្សេងៗ កំពុងរុកជញ្ជក់ស៊ីក្តី ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច សម្បុរល្អសមរម្យណាក្នុងកាលពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯង ដែលគេយកសរីរៈទៅចោលក្នុងព្រៃស្មសាន សល់នៅតែរាងឆ្អឹង ប្រកបដោយសាច់ឈាម មានសរសៃជាគ្រឿងចង ។បេ។ សល់នៅតែរាងឆ្អឹង ឥតមានសាច់ តែនៅប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។បេ។ សល់នៅតែរាងឆ្អឹង មិនមានសាច់ និងឈាម មានសរសៃជាគ្រឿងចង ។បេ។ សល់នៅតែរាងឆ្អឹងទទេ មិនមានសរសៃជាគ្រឿងចងរួបរឹត ខ្ចាត់ខ្ចាយរាត់រាយទៅក្នុងទិសតូច និងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅ

ដោយឡែក ឆ្អឹងដើមដៃទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ឆ្អឹងធ្មេញទៅដោយឡែក លលាដ៍ក្បាលទៅដោយឡែក ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនុ៎ះថាដូចម្តេច សម្បុរល្អសមរម្យណា ក្នុងកាលពីមុន សម្បុរល្អសមរម្យនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតឡើងប្រាកដមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះសយម្ភូញាណ ទ្រង់មានព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុគប្បីមើលបងប្អូនស្រីនោះឯងដែលគេយកសរីរៈទៅចោលក្នុងព្រៃស្មសាន សល់នៅតែឆ្អឹងទទេ មានសម្បុរស ប្រៀបដូចពណ៌នៃស័ង្ខ ។បេ។ សល់នៅតែឆ្អឹងទទេ រោយរាយ នៅជាពំនូកៗកន្លងទៅយូរឆ្នាំហើយ ។បេ។ សល់នៅតែឆ្អឹងទទេ ពុកផុយ ខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេងៗ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច សម្បុរល្អសមរម្យណា ក្នុងកាលពីមុន សម្បុរល្អនោះ ក៏អន្តរធានបាត់ទៅ ទោសក៏កើតប្រាកដឡើងមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា ទោសរបស់រូបទាំងឡាយ ។

[ ២០៣ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឧបាយដែលជាគ្រឿងកម្ចាត់នូវឆន្ទរាគៈ កាលលះបង់នូវឆន្ទរាគៈ ក្នុងរូបទាំងឡាយណា នេះឯងជាគ្រឿងរលាស់ចេញនូវ

រូបទាំងឡាយ ។

[ ២០៤ ] ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយឯណានីមួយ មិនដឹងនូវតម្រេករបស់រូបទាំងឡាយ ថាជាគ្រឿងត្រេកផង មិនបានដឹងនូវទោសរបស់រូបទាំងឡាយ ថាជាទោសផង មិនបានដឹងនូវគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង តាមពិតយ៉ាងនេះ សមណៈ ឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវរូបទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវរូបទាំងឡាយបាន នឹងបបួលបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ ហេតុនេះ មិនជាឋានៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ណាមួយ ដឹងនូវតម្រេករបស់រូបទាំងឡាយ ថាជាគ្រឿងត្រេកផង ដឹងនូវទោសរបស់រូបទាំង-ឡាយ ថាជាទោសផង ដឹងនូវគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ នឹងកំណត់ដឹងនូវរូបទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវរូបទាំងឡាយបាន នឹងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះទើបជាឋានៈ ។

[ ២០៥ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេករបស់វេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ក៏ចូលកាន់បឋមជ្ឈាន ប្រកប ដោយវិតក្កវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអា- រម្មណ៍ក្នុងសម័យនោះ ( ភិក្ខុនោះឯង ) មិនបានគិតដើម្បីបៀតបៀនខ្លួនផង មិនបានគិតដើម្បីបៀតបៀនបុគ្គលដទៃផង មិនបានគិតដើម្បីបៀតបៀតបុគ្គល ទាំង ២ ពួក គឺខ្លួន និងបុគ្គលដទៃផង ក្នុងសម័យនោះ ( ភិក្ខុនោះ ) ឈ្មោះ ថា ទទួលនូវវេទនា មិនមានសេចក្ដីព្យាបាទ ( ឥតទុក្ខ ) តែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា តម្រេករបស់ទេវនាទាំងឡាយ បំផុត ត្រឹមសេចក្ដីមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុចូល កាន់ទុតិយជ្ឈានជាទីផូរផង់ ក្នុងសន្ដាន មានភាវៈនៃចិត្តដ៏ប្រសើរ មិនមាន វិតក្ក មិនមានវិចារៈទេ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ព្រោះ រម្ងាប់នូវវិតក្ក និងវិចារៈ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាដែលភិក្ខុ ។បេ។ ព្រោះរម្ងាប់វិតក្ក និងវិចារៈ ក្នុងសម័យនោះ ( ភិក្ខុនោះឯង ) មិន បានគិតដើម្បីបៀតបៀនខ្លួនឯង ។បេ។ ទើបឈ្មោះថា ទទួលនូវវេទនា មិន មានសេចក្ដីព្យាបាទតែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សេចក្ដីត្រេកអររបស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្ដីមិនព្យាបាទ ។ ម្នាល ភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុជាអ្នកមានចិត្តព្រងើយផង មានស្មារតី តាំងមាំផង មានប្រាជ្ញាដឹងសព្វផង ទទួលនូវសេចក្ដីសុខដោយនាមកាយផង ព្រោះអស់ទៅនៃបីតិ ក៏បានចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ

តែងសម្តែងថា បុគ្គលដែលបានចូលកាន់តតិយជ្ឈាន រមែងជាអ្នកមានចិត្តព្រងើយ មានស្មារតីនៅជាសុខ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុ ។បេ។ ព្រោះអស់ទៅនៃបីតិ ក្នុងសម័យនោះ ភិក្ខុនោះឯងមិនគិត ។បេ។ ទើបឈ្មោះថា ទទួលនូវវេទនាមិនមានសេចក្តីព្យាបាទតែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សេចក្តីត្រេកអរបស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្តីមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយយ៉ាងទៀត ភិក្ខុចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានតែសតិដ៏បរិសុទ្ធ ព្រោះឧបេក្ខា ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះរលត់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុ ។បេ។ ព្រោះលះបង់នូវសុខផង ក្នុងសម័យនោះ ភិក្ខុនោះឯង មិនបានគិតដើម្បីបៀតបៀនខ្លួនផង មិនបានគិតដើម្បីបៀតបៀនបុគ្គលដទៃផង មិនបានគិតដើម្បីបៀតបៀនបុគ្គលទាំង ២ ពួក គឺខ្លួន និងបុគ្គលដទៃផង ក្នុងសម័យនោះ ភិក្ខុនោះ ឈ្មោះថា ទទួលនូវវេទនា ដែលមិនមានសេចក្តីព្យាបាទតែមួយយ៉ាង ម្នាលភិក្ខុទាំងឡាយ តថាគតតែងពោលថា សេចក្តីត្រេកអរបស់វេទនាទាំងឡាយ បំផុតត្រឹមសេចក្តីមិនព្យាបាទ ។

[ ២០៦ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់វេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលវេទនាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលទៅជាធម្មតា នេះឯងជាទោសរបស់វេទនាទាំងឡាយ ។

[ ២០៧ ] ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឧបាយជាគ្រឿងកម្ចាត់បង់នូវឆន្ទរាគៈ ការ

លះបង់នូវឆន្ទរាគៈ ក្នុងវេទនាទាំងឡាយណា នេះឯងជាគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ។

[ ២០៨ ] ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយពួកខ្លះ មិនបានដឹងនូវតម្រេករបស់វេទនាទាំងឡាយ ថាជាគ្រឿងត្រេកផង មិនបានដឹងនូវទោសរបស់វេទនាទាំងឡាយ ថាជាទោសផង មិនបានដឹងនូវគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង យ៉ាងនេះតាមពិត សមណព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវវេទនាទាំងឡាយដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបនឹងកំណត់ដឹងនូវវេទនាទាំង-ឡាយបាន ទាំងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះមិនមែនជាឋានៈទេ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬ ព្រាហ្មណ៍ទាំងឡាយណាមួយ ដឹងនូវតម្រេករបស់វេទនាទាំងឡាយ ថាជាគ្រឿងត្រេកផង ដឹងនូវទោសរបស់វេទនាទាំងឡាយ ថាជាទោសផង ដឹងនូវគ្រឿងរលាស់ចេញនូវវេទនាទាំងឡាយ ថាជាគ្រឿងរលាស់ចេញផង យ៉ាងនេះតាមពិត ទើបសមណៈ ឬព្រាហ្មណ៍ទាំងនោះ នឹងកំណត់ដឹងនូវវេទនាដោយខ្លួនឯងឬ ឬក៏បុគ្គលប្រតិបត្តិយ៉ាងណា ទើបកំណត់ដឹងនូវវេទនាទាំងឡាយបាន ទាំងបបួលនូវបុគ្គលដទៃ ដើម្បីសេចក្តីប្រតិបត្តិយ៉ាងនោះ នេះទើបជាឋានៈ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយចំពោះភាសិតនៃព្រះមានព្រះភាគ ។

**មហាទុក្ខក្ខន្ធសូត្រទី ៣ ចប់**

# អដ្ឋកថា

## មហាទុក្ខក្ខន្ធសូត្រ

[ ១៩៤ ] មហាទុក្ខក្ខន្ធសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់មកហើយ ដូច្នេះ ។

ក្នុងមហាទុក្ខក្ខន្ធសូត្រនោះ ក្នុងវិនយបរិយាយ ជន ៣ នាក់ ហៅថា **សម្ពហុលា** ច្រើនជាងនោះ ហៅថា **សង្ឃ** ។ ក្នុងសុត្តន្តបរិយាយ ជន ៣ នាក់ គង់ជា ៣ នាក់នោះឯង ។ លើសជាង ៣ នោះ ហៅថា **សម្ពហុលា** ។ គប្បីជ្រាបសម្ពហុលា ដោយសុត្តន្តបរិយាយក្នុងសូត្រនេះ ។ បទថា **បិណ្ឌាយ បាវិសឹសុ** បានដល់ ចូលទៅហើយ ។ ភិក្ខុទាំងនោះ មិនបានចូលទៅហើយ ដោយគិតថា ព្រោះអញនឹងចូលទៅ តែកាលចេញមក ទើបពោលថា **បាវិសឹសុ** ។ សេចក្ដីនេះដូចម្ដេច ដូចបុរសអ្នកចេញទៅថា អញនឹងទៅកាន់ស្រុក សូម្បីមិនដល់ស្រុកនោះ កាលគេពោលថា បុរសឈ្មោះនេះទៅណា ក៏ហៅថា ទៅកាន់ស្រុកហើយ យ៉ាងណា ភិក្ខុទាំងឡាយក៏ដូច្នោះ ។ បទថា **បរិព្វាជកានំ អារាមោ** សេចក្ដីថា មានអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជក ក្នុងទីមិនឆ្ងាយអំពីវត្តជេតពន សំដៅដល់អារាមនោះ ទើបពោលយ៉ាងនោះ ។ បទថា **សមណោអាវុសោ** សេចក្ដីថា នៃអ្នកមានអាយុ ព្រះសមណគោតម ជាសាស្ដារបស់ពួកលោក ។ បទថា **កាមានំ បរិញ្ញំ** សេចក្ដីថា ព្រះសមណគោតមទ្រង់បញ្ញត្តការលះ គឺការឈានកន្លងកាមទាំងឡាយ ក្នុងរូប វេទនាជាដើមក៏ន័យនេះដូចគ្នា ។ ក្នុងសេចក្ដីនោះ ពួកតិរ្ថិយ

ដឹងលទ្ធិរបស់ខ្លួន គប្បីបញ្ញត្តការដឹងដោយជុំវិញនូវកាមទាំងឡាយ កាលពោលដល់បឋមជ្ឈាន គប្បីបញ្ញត្តការដឹងដោយជុំវិញនូវរូបទាំងឡាយ កាលពោលដល់អរូបភព គប្បីបញ្ញត្តការដឹងដោយជុំវិញនូវវេទនា កាលពោលដល់អសញ្ញីភព ក៏គប្បីបញ្ញត្តការដឹងដោយជុំវិញនូវវេទនាទាំងឡាយ ។ តែតិរ្ថិយទាំងនោះរមែងមិនដឹងថា នេះបឋមជ្ឈាន នេះរូបភព នេះអរូបភព កាលមិនអាចបញ្ញត្ត ទើបពោលថា ពួកយើងនឹងបញ្ញត្ត ពួកយើងនឹងបញ្ញត្តតែម្យ៉ាង ។ ព្រះតថាគតទ្រង់បញ្ញត្តការដឹងជុំវិញនូវកាមទាំងឡាយ ដោយអនាគាមិមគ្គ ទ្រង់បញ្ញត្តការដឹងដោយជុំវិញនូវរូប និងវេទនាទាំងឡាយដោយអរហត្តមគ្គ ។ តិរ្ថិយទាំងនោះ កាលមានការប្លែកគ្នាយ៉ាងនេះ ទើបពោលថា **តត្រ កោ អាវុសោ កោ វិសេសោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **តត្រ** គឺក្នុងការបញ្ញត្តនេះ ឬក្នុងការសម្តែងធម៌នេះ ។ បទថា **ធម្មទេសនំ** សេចក្តីថា តិរ្ថិយទាំងឡាយពោលថា ពួកលោកពោលការធ្វើឲ្យផ្សេងគ្នា ប្រារព្ធធម្មទេសនារបស់ពួកយើង និងធម្មទេសនារបស់ព្រះសមណគោតម ឬប្រារព្ធធម្មទេសនារបស់ព្រះសមណគោតម និងធម្មទេសនារបស់ពួកយើងនេះ មានហេតុផ្សេងគ្នាដូចម្តេច ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា តិរ្ថិយទាំងនោះតាំងធុរៈស្មើគ្នា ដោយហេតុគ្រាន់តែពោលលទ្ធិរបស់ខ្លួន និងសាសនា ដូចមាសបាក់ត្រង់កណ្តាល ដោយប្រការដូច្នេះ ។ បទថា **នេវ អភិនន្ទឹសុ** គឺមិនព្រមទទួលថា ពាក្យនោះយ៉ាងនោះឯង ។ បទថា **នប្បដិក្កោសឹសុ** បានដល់មិនបដិសេធថា ពាក្យនោះមិនមែនយ៉ាងនេះ ព្រោះហេតុអ្វី បានឮថា ធម្មតា

តិរ្ថិយទាំងនោះដូចជាមនុស្សក្មេកខ្វាក់ ដឹងហើយក៏ដោយ មិនដឹងក៏ដោយ ក៏គប្បីពោល ព្រោះដូច្នោះ ទើបភិក្ខុទាំងឡាយមិនត្រេកអរ មិនជំទាស់ថា ក្លិនរបស់សាសនាមានបន្តិចបន្តួច ដោយពាក្យថា **បរិញ្ញំ** ។ បានធ្វើទាំង ២ យ៉ាង ដោយគិតថា តិរ្ថិយទាំងនោះជាអ្នកជនបទ មិនឈ្លាស គ្រប់គ្រាន់ក្នុងលទ្ធិរបស់ខ្លួន និងលទ្ធិដទៃ ។

[ ១៩៥ ] បទថា **ន ចេវ សម្បាយិស្សន្តិ** សេចក្តីថា មិនអាចឲ្យពេញចិត្តបាន ។

[ ១៩៦ ] បទថា **ឧត្តរិញ្ច វិឃាតំ** សេចក្តីថា នឹងដល់នូវទុក្ខក្រៃលែងជាងការមិនពេញចិត្ត ។ សេចក្តីទុក្ខ រមែងកើតឡើងដល់តិរ្ថិយទាំងឡាយដែលមិនអាចឲ្យពេញចិត្តពោល ។ បទថា **តំ** ក្នុងបទនេះថា **យថាតំ ភិក្ខវេ អវិសយស្មឹ** ត្រឹមតែជានិបាត ពាក្យថា **យថា** ជាតតិយាវិភត្តិ អធិប្បាយថា ព្រោះជាអ្នកត្រូវសួរហើយ ក្នុងបញ្ហាដែលមិនមែនវិស័យ ។ បទថា **សទេវកេ** បានដល់ ប្រព្រឹត្តទៅជាមួយដោយទេវលោក ។ ក្នុងបទថា **សមារកេ** ជាដើមក៏មានន័យនេះដូចគ្នា ។ ព្រះមានព្រះភាគ ទ្រង់បន្ថែមឋានៈ ៣ ចូលជាមួយលោកយ៉ាងនេះហើយ ទ្រង់កំណត់សត្វលោកនោះឯងថា សត្វ ២ ពួក រួមជា ៥ ហើយ ទ្រង់សម្តែងថា តថាគតមិនឃើញទេវតា ឬមនុស្សណាមួយក្នុងលោក មានទេវលោកជាដើមនោះ ។ បទថា **ឥតោ វា បន សុត្វា** សេចក្តីថា ស្តាប់អំពីនេះក្តី គឺអំពីសាសនារបស់តថាគត ។ ទ្រង់សម្តែងថា បុគ្គលមិនមែនជាតថាគតក្តី សាវករបស់បុគ្គល

ដែលមិនមែនជាតថាគតក្តី ស្តាប់អំពីនេះហើយ គប្បីត្រេកអរ គឺគប្បីពេញចិត្ត ឈ្មោះថា ការត្រេកអរដោយប្រការដទៃមិនមាន ។

[ ១៩៧ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការញុំាងចិត្តឲ្យត្រេកអរ ដោយការព្យាករណ៍ទាំងនោះរបស់ព្រះអង្គ ទើបត្រាស់ថា **កោច ភិក្ខវេ** ដូច្នេះជាដើម ។ បទថា **កាមគុណា** សេចក្តីថា ឈ្មោះថា **កាម** ព្រោះអត្ថថា ដែលបុគ្គលគប្បីត្រេកអរ ឈ្មោះថា **គុណា** ព្រោះអត្ថថា ស្រទាប់ ឬជាន់ ១ គ្រា ជំនាន់ ១ អានិសង្ស ១ ចំណង ១ ប្រើក្នុងអត្ថថា ស្រទាប់ ឬជាន់ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ តិចីវរំ ទ្វិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរ ៣ គឺ សង្ឃាដី ២ ជាន់ ឧត្តរាសង្គ ( ចីពរ ) ១ ជាន់ ស្បង់ ១ ជាន់ ដូច្នេះ ។ ប្រើក្នុងអត្ថថា គ្រា ជំនាន់ ដូចក្នុងប្រយោគជាដើមថា **អច្ចេន្តិ កាលា តរយន្តិ រត្តិយោ វយោគុណា អនុបព្វំ ជហន្តិ** កាលទាំងឡាយតែងកន្លងផុតទៅ រាត្រីទាំងឡាយ តែងធ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ ។ ប្រើក្នុងអត្ថថា អានិសង្ស ដូចក្នុងប្រយោគជាដើមថា **សតគុណា ទក្ខិណា ចាដិកង្ខិតព្វា** ទក្ខិណាមានគុណ ១០០ ដែលបុគ្គលត្រូវបាន ( ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន )។ ប្រើក្នុងអត្ថថា ចំណង ដូចក្នុងប្រយោគជាដើមថា **អន្តំ អន្តគុណំ** ពោះវៀនធំ ពោះវៀនតូច និងប្រយោគមួយទៀតថា **កយិរា មាលាគុណេ**[១]

---

១- បិដកខ្មែរថា គុឡេ ។

**ពហុំ** មាលាការបេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កាឲ្យច្រើនបាន ។ ក្នុងបទនេះ លោកបំណងយកអត្ថថា ចំណង នោះតែម្យ៉ាង ព្រោះដូច្នោះ ទើបលោកពោលថា ឈ្មោះថា **គុណា** ព្រោះអត្ថថា **ចំណង** ដូច្នេះ ។ បទថា **ចក្ខុវិញ្ញេយ្យា** សេចក្ដីថា គប្បីឃើញដោយចក្ខុវិញ្ញាណ ។ គប្បីជ្រាបអត្ថក្នុង **សោតវិញ្ញេយ្យ** ដោយទំនងនេះជាដើម ។ បទថា **ឥដ្ឋា** សេចក្ដីថា ចូរត្រេកអរក្ដី មិនត្រេកអរក្ដី ក៏ជាឥដ្ឋារម្មណ៍ ។ បទថា **កន្តា** បានដល់ គប្បីឲ្យត្រេកអរ ។ បទថា **មនាបា** គឺឲ្យគាប់ចិត្ត ។ បទថា **បិយរូបា** គឺកើតសេចក្ដីស្រឡាញ់ ។ បទថា **កាមូបសញ្ហិតា** សេចក្ដីថា ប្រកបហើយដោយកាម ដែលធ្វើអារម្មណ៍កើតឡើង ។ បទថា **រជនីយា** បានដល់ គប្បីតម្រេក អធិប្បាយថា ជាហេតុកើតឡើងនៃរាគៈ ។

[ ១៩៨ ] ក្នុងបទទាំងឡាយ មានបទថា **យទិ មុទ្ទាយ** ជាដើម ។ បទថា **មុទ្ទាយ** បានដល់ ដោយការតាំងសញ្ញាក្នុងសេចក្ដីទាំងឡាយ នេះហើយរាប់ដៃ ។ បទថា **គណនាយ** បានដល់ ដោយការគណនាមិនខុស ។ បទថា **សង្ខា** សេចក្ដីថា ជនទាំងឡាយសម្លឹងមើលស្រែដោយការរាប់ស្រូវថា ក្នុងស្រែនេះមានស្រូវប្រមាណប៉ុណ្ណោះ សម្លឹងមើលដើមឈើ ក៏ដឹងថា ក្នុងដើមឈើនេះមានផ្លែប៉ុណ្ណោះ សម្លឹងមើលអាកាសក្នុងអាកាស មានបក្សីប្រមាណប៉ុណ្ណោះ ។ បទថា **កសិ** បានដល់ កសិកម្ម ។ បទថា **វណិជ្ជា** បានដល់ គន្លងនៃការលក់ដូរ មានការលក់ដូរផ្លូវទឹក និងលក់ដូរផ្លូវគោក ជាដើម ។ បទថា **គោរក្ខំ** បានដល់ ការរក្សាគោរបស់ខ្លួន ឬរបស់អ្នកដទៃ

ធ្វើការចិញ្ចឹមជីវិត ដោយការលក់បញ្ចូគោរស ។ ការកាន់អាវុធ ហើយធ្វើការបដិបត្តិ ហៅថា ការបាញ់ធ្នូ ។ បទថា **រាជបោរិសំ** បានដល់ ធ្វើរាជការដោយអាវុធឲ្យប្រាកដ ។ បទថា **សិប្បញ្ញតរំ** បានដល់ សិប្បៈ មានសិប្បៈដំរី ឬសិប្បៈសេះជាដើមដ៏សេស ក្រៅអំពីប្រារព្ធទុកហើយ ។ បទថា **សីតស្ស បុរក្ខតោ** សេចក្តីថា ជួបនូវត្រជាក់ ដូចក្តារប៉ាយជួបនឹងព្រួញ ដូច្នោះ អធិប្បាយថា បុគ្គលត្រូវត្រជាក់បៀតបៀន ។ សូម្បីក្នុងការក្តៅ ក៏មានន័យនេះដូចគ្នា ។ ក្នុងបទថា **ឌំសា** ជាដើម បទថា **ឌំសា** បានដល់របោម ។ បទថា **មក្កសា** បានដល់ សត្វល្អិតគ្រប់ប្រភេទ ។ បទថា **សិរិំសបា** បានដល់ សត្វពួកណាមួយដែលលូនទៅ ។ បទថា **រិស្សមានោ** បានដល់ ញាប់ញ័រ រសាប់រសល់ ។ បទថា **មិយ្យមានោ** បានដល់ ស្លាប់ ។ បទថា **អយំ ភិក្ខវេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីលំបាកដែលអាស្រ័យការចិញ្ចឹមជីវិតដោយសិប្បៈ មានការរាប់គណនាជាដើម មានការរងាជាដើមជាបច្ច័យ ។ បទថា **កាមានំ អាទីនវោ** គឺជាអន្តរាយ សេចក្តីថា ជាឧបសគ្គក្នុងកាមទាំងឡាយ ។ បទថា **សន្ទិដ្ឋិកោ** គឺប្រចក្ស បានដល់ គប្បីឃើញឯង ។ បទថា **ទុក្ខក្ខន្ធោ** បានដល់ ជាកងទុក្ខ ។ ក្នុងបទទាំងឡាយ មានបទថា **កាមហេតុ** ជាដើម កាមទាំងឡាយ ឈ្មោះថាជាហេតុនៃទោសនោះ ព្រោះអត្ថថា ជាបច្ច័យ ព្រោះដូច្នោះ ទោសនោះទើបឈ្មោះថា **កាមហេតុ** ប្រែថា មានកាមជាហេតុ ។ កាមទាំងឡាយឈ្មោះថា ជាមូលរបស់ទោសនោះ ព្រោះអត្ថថា ជាឫសគល់ ព្រោះដូច្នោះ

ទើបទោសនោះ ឈ្មោះថា **កាមនិទាន** ប្រែថា មានកាមជាដើមហេតុ ។ តែលោកពោលថា **កាមនិទានំ** ព្រោះភ្ជាំងភ្ជាត់ក្នុងលិង្គ ។ កាមទាំងឡាយ ឈ្មោះថា ជាហេតុនៃទោសនោះ ព្រោះអត្ថថា ការណ៍ ព្រោះដូច្នោះ ទើបទោសនោះឈ្មោះថា **កាមាធិករណ** ប្រែថា មានកាមជាហេតុបន្ទាប់ ។ តែលោកពោលថា **កាមាធិករណំ** ព្រោះការភ្ជាំងភ្ជាត់នៃលិង្គ ។ បទថា **កាមានមេវ ហេតុ** នេះជាពាក្យកំណត់ អធិប្បាយថា ទោសកើតឡើងព្រោះកាមជាបច្ច័យនោះឯង ។ បទថា **ឧដ្ឋហតោ** គឺប្រឹងប្រែងដោយសេចក្ដីព្យាយាម ជាហេតុឲ្យមានអាជីវៈជាគោល ។ បទថា **ឃដតោ** បានដល់បន្តសេចក្ដីព្យាយាមនោះឲ្យច្រើនឡើងជាងក្នុងថ្ងៃមុនៗ ។ បទថា **វាយមតោ** សេចក្ដីថា ធ្វើសេចក្ដីព្យាយាម ការប្រឹងប្រែង ការប្រកបរឿយៗ ។ បទថា **នាភិនិប្ផជ្ជន្តិ** សេចក្ដីថា ភោគៈនោះ រមែងមិនសម្រេច គឺមិនឡើងកាន់កណ្ដាប់ដៃ ។ បទថា **សោចតិ** គឺរមែងសោយសោក ដោយការសោយសោកដ៏ខ្លាំងក្លាកើតឡើងក្នុងចិត្ត ។ បទថា **កិលមតិ** បានដល់ រមែងលំបាកដោយទុក្ខដែលកើតឡើងក្នុងកាយ ។ បទថា **បរិទេវតិ** បានដល់ រមែងយំរៀបរាប់ដោយវាចា ។ បទថា **ឧរត្តាឡឹ** គឺគក់ទ្រូង ។ បទថា **កន្ទតិ** បានដល់ រមែងយំ ។ បទថា **សម្មោហំ អាបជ្ជតិ** សេចក្ដីថា ជាអ្នកដល់នូវសេចក្ដីវង្វេង ដូចជាអ្នកបាត់បង់ស្មារតី ។ បទថា **មោឃំ** ប្រែថា ទទេ ។ បទថា **អផលោ** បានដល់ ឥតផល ។ បទថា **អារក្ខាធិករណំ** គឺមានការគ្រប់គ្រងជាហេតុ ។ បទថា **កិន្តិ មេ** គឺដោយឧបាយដូចម្ដេចហ្ន៎ ។

បទថា **យំបិ មេ** សេចក្តីថា ទ្រព្យដែលអញធ្វើការងារ មានកសិកម្មជាដើម ឲ្យកើតហើយ ។ បទថា **តំបិ នោ ឆត្តិ** សេចក្តីថា ឥឡូវនេះ ទ្រព្យនោះ របស់អញក៏មិនមាន ។ ព្រះមានព្រះភាគ ទ្រង់សម្តែងការណ៍ ដោយបទ ថា **បុន ច បរំ ភិក្ខវេ ហេតុ** ដូច្នេះជាដើមហើយ ទ្រង់សម្តែងទោស ។

ក្នុងបទទាំងនោះ បទថា **កាមហេតុ** សេចក្តីថា ពួកក្សត្រវិវាទនឹងពួក ក្សត្រ ព្រោះកាមជាបច្ច័យ ។ បទថា **កាមនិទានំ** ជាការនៃបុំសកលិង្គ អធិប្បាយថា ធ្វើកាមទាំងឡាយឲ្យជាមូល ហើយវិវាទគ្នា ។ បទថា **កាមា-ធិករណំ** ក៏ជាការនៃបុំសកលិង្គដូចគ្នា អធិប្បាយថា ធ្វើកាមទាំងឡាយឲ្យ ជាមូល ហើយវិវាទគ្នា ។ បទថា **កាមានមេវ ហេតុ** សេចក្តីថា វិវាទគ្នា ព្រោះហេតុនៃស្រុក និគម សេនាបតី បុរោហិត និងឋានន្តរជាដើម ។ បទ ថា **ឧបក្កមន្តិ** គឺប្រហារ ។ បទថា **អសិចម្មំ** បានដល់ ដាវ និងវត្ថុ មាន ខែលជាដើម ។ បទថា **ធនុកលាបំ សន្នយ្ហិត្វា** សេចក្តីថា កាន់ធ្នូហើយ សៀតនូវបំពង់ព្រួញ ។ បទថា **ឧភតោព្យូឡ្ហំ** បានដល់ ច្បាំងគ្នាទាំង ២ ចំណែក ។ បទថា **បក្ខន្ទន្តិ** គឺចូលទៅ ។ បទថា **ឧសូសុ** គឺកាលព្រួញ ទាំងឡាយ ។ បទថា **វិជ្ជោតលន្តេសុ** គឺពួយទៅ ។ បទថា **តេ តថ** គឺ ពពួកជនទាំងនោះ ក្នុងសង្គ្រាមនោះ ។ បទថា **អទ្ទាវលេបនា ឧបការិយោ** នោះ មនុស្សទាំងឡាយ រៀបជើងកំពែងដោយឥដ្ឋទាំងឡាយ មានសណ្ឋាន ដូចក្រចកជើងសេះ ហើយបូកលាបបាយអខាងលើ ជើងកំពែងទាំងឡាយ ដែលធ្វើយ៉ាងនេះ ហៅថា **ឧបការិយោ** ជើងកំពែងទាំងនោះ បូកលាបដោយ

កក់ក្តៅ ទើបឈ្មោះថា **អង្គារលេបនា** ។ បទថា **បក្ខន្ទន្តិ** សេចក្តីថា ជនទាំងនោះ កាលត្រូវបាញ់ដោយអាវុធ មានព្រួញដែកដ៏មុតជាដើមខាងក្រោមជើងកំពែងនោះខ្លះ កាលមិនអាចគេចបាន ព្រោះកំពែងជារបស់មាំទាំខ្លះ ទើបរត់ស្ទុះស្ទាទៅមក ។ បទថា **ឆកណាដិយា** គឺដោយអាចម៍គោដ៏ក្តៅ ។ បទថា **អភិវគ្គេន** សេចក្តីថា ជនទាំងឡាយឈរត្រង់ទ្វារជាន់លើដែលមកដល់ថា ពួកយើងនឹងធ្វើការរស់នោះ ព្រមទាំងជ្រៀកឲ្យជាអាការ ៨ ចម្រៀកទម្លាយទ្វារនគរចូលទៅហើយ កាត់គ្រឿងចង និងខ្សែនៃរនាស់នោះ ហើយរាស់ដោយរនាស់នោះ ។ បទថា **សន្ធិម្បិ ឆិន្ទន្តិ** គឺកាត់ទីតនៃផ្ទះខ្លះ ។ បទថា **និល្លោបំ** សេចក្តីថា ចោមរោមស្រុកជាដើម ហើយធ្វើការប្លន់ធំ ។ បទថា **ឯកាគារិកំ** សេចក្តីថា ហ៊ុងជនប្រមាណ ៥០ នាក់ខ្លះ ប្រមាណ ៦០ នាក់ខ្លះ ចោមរោមវាយ ហើយចាប់នាំមក ។ បទថា **បរិបន្ថេ តិដ្ឋន្តិ** សេចក្តីថា ធ្វើការវាយក្នុងចន្លោះផ្លូវ ។ បទថា **អឌ្ឍទណ្ឌកេហិ** សេចក្តីថា ដោយដំបងទាំងឡាយ ឬដោយកំណាត់ឈើដែលគេកាត់ប្រមាណ ៤ ហត្ថ ដើម្បីឲ្យសម្រេចការប្រហារឲ្យជា ២ ចំណែក ។ បទថា **ពិលង្គថាលិកំ** បានដល់ កម្មករណ៍ គឺស្លោរដោយឆ្នាំង ។ ព្រះរាជាទាំងឡាយ កាលទ្រង់ធ្វើកម្មករណ៍នោះ ក៏បកលលាដ៍ក្បាលចេញ យកដង្កាប់ចំពុះសត្វចាប់ដុំដែកក្តៅ ដាក់លើលលាដ៍ក្បាលនោះ យកដង្កាប់ដែកនោះ ចាប់ខួរលើកឡើងខាងលើ ។ បទថា **សង្ខមុណ្ឌកំ** បានដល់ កម្មករណ៍ គឺខាត់ស័ង្ខ ។ កាលធ្វើកម្មករណ៍នោះ បកស្បែកដោយការកំណាត់សៀតផ្កា និងគល់កទាំងសង

ខាងឲ្យតាំងនៅខាងលើ ប្រមូលសក់ឲ្យនៅមួយកន្លែង រួចនឹងកំណាត់ឈើ លើកឡើង ស្បែកក្បាល ព្រមទាំងសក់ ទាំងឡាយក៏ជ្រុះចេញ បន្ទាប់អំពីនោះ ក៏ខាត់លលាដ៍ដោយដុំថ្មក្រាស់ លាងឲ្យមានពណ៌ដូចជាស័ង្ខ ។ បទថា **រាហុមុខំ** បានដល់ កម្មករណ៍ គឺមាត់រាហូ ។ កាលធ្វើកម្មករណ៍នោះ ក៏បើកមាត់ដោយកង្វេរដែក ដាក់ប្រទីបចូលក្នុងមាត់ ឬបោះមាត់ដោយពន្លាក រហូតដល់គុម្ពត្រចៀកទាំងសងខាង ឈាមហូរចេញពេញមាត់ ។ បទថា **ជោតិមាលិកំ** បានដល់ រុំសរីរៈទាំងមូលដោយសំពត់ ហើយចាក់ប្រេង ដុតដោយភ្លើង ។ បទថា **ហត្ថបជ្ជោតិកំ** បានដល់ រុំដៃទាំងសងខាងដោយសំពត់ដែលសើមដោយប្រេង ហើយដុតឲ្យឆេះឡើង ។ បទថា **ឯរកវត្តិកំ** បានដល់ កម្មករណ៍ គឺស្លៀកស្បែកជ័រ ។ កាលធ្វើកម្មករណ៍នោះ ធូតស្បែកតាំងអំពីកឡើងទៅ ទុកត្រង់ជើងសក់ លំដាប់នោះ ក៏ចងស្បែកដែលសល់ដោយខ្សែទាំងឡាយ ហើយទាញទៅក្រោម ឲ្យបុគ្គលនោះជាន់ហើយជាន់ទៀតនូវស្បែករបស់ខ្លួន ក៏ដួលចុះ ។ បទថា **ចីរកវាសិកំ** បានដល់ កម្មករណ៍ គឺស្លៀកសំពត់សារាយ ។ កាលធ្វើកម្មករណ៍នោះ ក៏បកស្បែកដូចគ្នា មកដល់ត្រឹមចង្កេះ ពន្លាត់តាំងអំពីចង្កេះរហូត ដល់កជើងទាំងសងខាង សរីរៈខាងក្រោម និងខាងលើ ដូចស្លៀកសំពត់ ដែលធ្វើដោយសម្បកធ្មៃ ។ បទថា **ឯណេយ្យកំ** បានដល់ កម្មករណ៍ គឺក្តាន់ឈរ ។ កាលធ្វើកម្មករណ៍នោះ ក៏ចងលួសដែកត្រង់កែងដៃ និងក្បាលជង្គង់ទាំង ២ ហើយបោះដែកស្រួចទាំងឡាយ បុគ្គលនោះឈរលើផែនដី ដោយដែកស្រួច ៤

កំណាត់ លំដាប់នោះ ក៏ចោមរោមបុគ្គលនោះ ដុតភ្លើង ដូចជាក្អាន់ចោមរោមភ្លើង សមដូចលោកពោលមកហើយយ៉ាងនេះថា គេបោះដែកស្រួចតាមវេលាដែលសមគួរនោះ បោះជាមួយឆ្អឹងចង្កេះ ៤ កន្លែងនោះឯង ដែលឈ្មោះថា ការធ្វើបែបនេះមិនមាន ។ បទថា **ពឡិសមំសិកំ** វាយដោយកន្ទេរ មានផ្លៀងទាំងសងខាង ហើយកន្ត្រាក់ស្បែក សាច់ និងសរសៃ ។ បទថា **កហាបណកំ** បានដល់ ឆ្កៀលសរីរៈទាំងមូលឲ្យមានស្នាមប្រមាណប៉ុនកហាបណៈមួយ តាំងអំពីចង្កេះ ដោយកាំបិតដ៏មុត ។ បទថា **ខារាបដិច្ឆកំ** បានដល់ វាយសរីរៈក្នុងទីនោះ ដោយអាវុធទាំងឡាយ ស្រោចដោយទឹកផ្សារូសដោយច្រាស់ ស្បែក សាច់ និងសរសៃក៏ជ្រុះចេញ នៅសល់តែគ្រោងឆ្អឹងប៉ុណ្ណោះ ។ បទថា **បលិឃបរិវត្តកំ** បានដល់ ឲ្យដេកផ្អៀង ហើយបោះដែកស្រួចក្នុងរន្ធត្រចៀកឲ្យជាប់នឹងផែនដី លំដាប់នោះ ទើបចាប់ជើងរបស់អ្នកទោសនោះ ហើយបង្វិល ។ បទថា **បលាលបីឋកំ** បានដល់ កម្មករណ៍ដែលកាត់ស្បែកចេញ វាយឆ្អឹងទាំងឡាយដោយថ្មសំលៀង ហើយចាប់សក់ទាំងឡាយលើកឡើង នៅសល់តែដុំសាច់ប៉ុណ្ណោះ លំដាប់នោះ ក៏ចាប់សក់របស់បុគ្គលនោះប៉ុណ្ណោះ ចាប់គ្រវីគ្រវាត់ឲ្យជ្រុះឆ្អឹង ដូចបាច់ចំបើង ។ បទថា **សុនខេហិ** បានដល់ ញ៉ាំងឆ្កែទាំងឡាយដែលឃ្លានខ្លាំង ព្រោះមិនឲ្យអាហារ ២-៣ ថ្ងៃ ឲ្យដេញខាំស៊ី ឆ្កែទាំងនោះធ្វើឲ្យសល់ តែគ្រោងឆ្អឹងមួយសន្ទុះប៉ុណ្ណោះ ។ បទថា **សម្បរាយិកោ** សេចក្តីថា ជាវិបាកក្នុងសម្បរាយិកភព ក្នុងអត្តភាពទី ២ ។

[ ១៩៩ ] ការកម្ចាត់ឆន្ទរាគៈ ការលះឆន្ទរាគៈ គឺនិព្វាន ។ ពិតហើយ ឆន្ទរាគៈក្នុងកាមទាំងឡាយ រមែងត្រូវកម្ចាត់ និងត្រូវលះបាន ព្រោះអាស្រ័យនិព្វាន ព្រោះដូច្នោះ ទើបលោកពោលថា ការកម្ចាត់ឆន្ទរាគៈ ការលះឆន្ទ-រាគៈ គឺនិព្វាន ។

[ ២០០ ] បទថា **សាមំ វា កាមេ បរិជានិស្សន្តិ** សេចក្តីថា ព្រាហ្មណ៍ពួកនោះឬ កំណត់ដឹងសព្វនូវកាមទាំងឡាយដោយខ្លួនឯង ដោយបរិញ្ញា ៣ ។ បទថា **តថត្តាយ** បានដល់ ដើម្បីភាពជាអ្នកបដិបត្តិ ។ បទថា **យថា-បដិបន្នោ** សេចក្តីថា បដិបត្តិហើយ ដោយបដិបទាណា ។

[ ២០១ ] បទថា **ខត្តិយកញ្ញា វា** ជាដើម ត្រាស់ហើយដើម្បីទ្រង់សម្តែងស្ត្រីដែលកើតហើយ ក្នុងឋានៈដែលបានវត្ថុទាំងឡាយ មានសំពត់និងគ្រឿងប្រដាប់ជាដើម ដែលមានបដិសន្ធិ ដែលកុសលមិនមែនតិច គឺច្រើនឲ្យទទួលហើយ ។ បទថា **បណ្ណរសវស្សុទ្ទេសិកា** គឺមានវ័យ ១៥ ឆ្នាំ ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូចគ្នា ។ សួរថា ហេតុអ្វី ទើបទ្រង់កាន់យករយៈវ័យ ឆ្លើយថា ដើម្បីទ្រង់សម្តែងសម្បត្តិ គឺពណ៌សម្បុរ ព្រោះអាយតនៈ គឺពណ៌សម្បុររបស់ស្ត្រី សូម្បីកើតក្នុងត្រកូលក្រីក្រ រមែងស្រស់ស្អាតសន្សឹមៗ ឡើងក្នុងកាលមួយ ចំណែកអាយតនៈ គឺពណ៌សម្បុររបស់បុរសទាំងឡាយ រមែងស្អាតស្រស់ថ្លា ក្នុងវេលាមានអាយុបាន ២០-២៥ ឆ្នាំ ទ្រង់សម្តែងសម្បត្តិ គឺសរីរៈដែលប្រាសចាកទោស ៦ ប្រការ ដោយបទទាំងឡាយថា មិនខ្ពស់ពេកជាដើម ។ បទថា **វណ្ណនិភា** គឺមានពណ៌សម្បុរ

នោះឯង ។

[ ២០២ ] បទថា **ជិណ្ណំ** គឺចាស់ព្រោះជរា ។ បទថា **គោបានសិរំកំ** បានដល់ មានឆ្អឹងជំនីរកោងដូចបង្កង់ផ្ទះ ។ បទថា **ភោគ្គំ** បានដល់ សរីរៈដែលកោង ។ ទ្រង់សម្តែងភាពដែលរាងកាយនោះកោង ដោយបទនេះឯង ។ បទថា **ទណ្ឌបរាយនំ** គឺអាស្រ័យឈើច្រត់ បានដល់ មានឈើច្រត់ជាគម្រប់ ២ ។ បទថា **បវេធមានំ** បានដល់ មានខ្លួនញ័រទទ្រើក ។ បទថា **អាតុរំ** បានដល់ ក្តៅក្រហាយព្រោះជរា ។ បទថា **ខណ្ឌទន្តំ** គឺមានធ្មេញបាក់ ព្រោះភាពជាមនុស្សចាស់ ។ បទថា **បលិតកេសំ** បានដល់ មានសក់ស្កូវ ។ បទថា **វិលូនំ** បានដល់ សក់រង្គោះ ដូចសក់ ដែលត្រូវដកទៅដូច្នោះ ។ បទថា **ខលិតសិរំ** គឺក្បាលតម្លែកច្រើន ។ បទថា **វលីនំ** បានដល់ ស្បែកស្អួតកើតឡើងព្រមហើយ ។ បទថា **តិលកាហតគត្តំ** គឺមានរាងកាយដេរដាសដោយអាចម៍រុយពណ៌ស និងពណ៌ខ្មៅ ។ បទថា **អាពាធិកំ** បានដល់ មានព្យាធិ ។ បទថា **ទុក្ខិតំ** គឺដល់ហើយនូវទុក្ខ ។ បទថា **ពាឡ្ហគិលានំ** បានដល់ មានជំងឺតម្កាត់មានប្រមាណក្រៃលែង ។ បទថា **សីវថិកាយឆឌ្ឌិតំ** គឺធ្លាក់ហើយក្នុងឈាបនដ្ឋាន ។ បទដ៏សេសបានពោលហើយ ក្នុងសតិប្បដ្ឋាននោះឯង ។ និព្វាននោះឯង ឈ្មោះថា **ឆន្ទរាគវិនយ** ក្នុងទីនេះ ។

[ ២០៥ ] បទថា **នេវតស្មឹ សមយេ អត្តព្យាពាធាយ** សេចក្តីថា ក្នុងសម័យនោះ រមែងមិនគិតដើម្បីប្រយោជន៍នៃទុក្ខរបស់ខ្លួន ។ បទថា **អព្យា-**

**បជ្ជាំយេវ** *បានដល់ មិនមានសេចក្ដីទុក្ខនោះឯង ។*

[ ២០៦ ] *បទថា* **យំ ភិក្ខវេ វេទនា អនិច្ចា** *សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រោះវេទនាមិនទៀង ព្រោះដូច្នោះ អាការមានការមិនទៀងជាដើមនេះ ជាទោសនៃវេទនា ។ ការរលាស់ចេញទៅ មានប្រការដូចពោលហើយនោះឯង ។*

**មហាទុក្ខក្ខន្ធសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ចូឡទុក្ខក្ខន្ធសូត្រទី ៤

[ ២០៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងសក្កជនបទ ។ លំដាប់នោះឯង សក្យរាជទ្រង់ព្រះនាមមហានាម ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រកាគ ទ្រង់សម្តែងអស់កាលជាយូរហើយយ៉ាងនេះថា លោភៈជាគ្រឿងសៅហ្មងរបស់ចិត្ត ទោសៈជាគ្រឿងសៅហ្មងរបស់ចិត្ត មោហៈជាគ្រឿងសៅហ្មងរបស់ចិត្ត ប៉ុន្តែ ជួនកាល ធម៌ គឺលោភៈគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ ជួនកាល ធម៌ គឺទោសៈគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ ជួនកាល ធម៌ គឺ មោហៈ គ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ទើបមានសេចក្តីត្រិះរិះយ៉ាងនេះថា ចុះធម៌អ្វីហ្ន៎ នៅខាងក្នុងសន្តានដែលអាត្មាអញមិនទាន់លះបង់អស់ បានជាជួនកាល ធម៌ គឺលោភៈគ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ជួនកាល ធម៌ គឺទោសៈគ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ជួនកាល ធម៌ គឺមោហៈគ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ។

[ ២១០ ] ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហានាម ធម៌ គឺ

លោភៈ ទោសៈ មោហៈ ក្នុងសន្តាននោះឯង ដែលមហាបពិត្រមិនទាន់លះបង់អស់ បានជាជួនកាល ធម៌ គឺលោភៈគ្របសង្កត់ចិត្តរបស់មហាបពិត្រខ្លះ ជួនកាល ធម៌ គឺទោសៈគ្របសង្កត់ចិត្តរបស់មហាបពិត្រខ្លះ ជួនកាល ធម៌ គឺមោហៈគ្របសង្កត់ចិត្តរបស់មហាបពិត្រខ្លះ ។ បពិត្រមហានាម បើធម៌ក្នុងសន្តាននោះ មហាបពិត្របានលះបង់អស់ហើយ ។ មហាបពិត្រ នឹងគប្បីលែងនៅគ្រប់គ្រងផ្ទះ នឹងគប្បីលែងបរិភោគកាមទាំងឡាយ ។ បពិត្រមហានាម ធម៌ខាងក្នុងសន្តាននោះឯង មហាបពិត្រលះបង់មិនទាន់បាន ព្រោះហេតុនោះ បានជាមហាបពិត្រនៅគ្រប់គ្រងផ្ទះ បរិភោគនូវកាមទាំងឡាយ ។

[ ២១១ ] ថ្វាយព្រះពរមហានាម បើអរិយសាវកបានឃើញច្បាស់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើនពេក ។ អរិយសាវកនោះឯងបានវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយហើយ តែមិនទាន់បាននូវបីតិ និងសុខ ឬគុណ-ជាតិដទៃដែលល្អិត លើសជាងបីតិ និងសុខនោះទេ កាលបើដូច្នេះ អរិយ-សាវកនោះ នឹងឈ្មោះថា មិនវិលត្រឡប់មករកកាមទាំងឡាយវិញនោះ មិនមែនឡើយ ។ បពិត្រមហានាម កាលណាបើអរិយសាវក បានឃើញច្បាស់តាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំង-ឡាយនុ៎ះ មានច្រើនក្រៃពេក ។ អរិយសាវកនោះឯង បានវៀរចាកកាម

ទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយ ហើយបាននូវបីតិ និងសុខ ឬ
គុណជាតិដទៃដែលល្អិត លើសជាងបីតិ និងសុខនោះ កាលបើដូច្នេះ អរិយ-
សាវកនោះទើបឈ្មោះថា មិនវិលត្រឡប់មករកកាមទាំងឡាយទៀតឡើយ ។
បពិត្រមហានាម ប៉ុនអម្បាលតថាគត កាលនៅជាពោធិសត្វ មិនទាន់បាន
ត្រាស់ដឹង ក្នុងកាលមុនអំពីកាលត្រាស់នៅឡើយ បានឃើញច្បាស់តាមពិត
ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសុខតិច មានទុក្ខច្រើន
មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះ មានច្រើន
ក្រៃពេក ។ តថាគតនោះវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំង-
ឡាយហើយ តែមិនទាន់បាននូវបីតិ និងសុខ ឬគុណជាតិដទៃ ដែលល្អិត
លើសជាងបីតិ និងសុខនោះ កាលបើដូច្នេះ តថាគតនោះក៏ដឹងប្រាកដថា
អាត្មាអញត្រឡប់មករកកាមទាំងឡាយវិញដោយពិត ។ បពិត្រមហានាម
លុះកាលណាតថាគតបានឃើញច្បាស់តាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះ
ថា កាមទាំងឡាយមានសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់
ច្រើន ទោសក្នុងកាមទាំងឡាយនោះ មានច្រើនក្រៃពេក ។ តថាគតនោះឯង
បានវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយ ហើយបាននូវ
បីតិ និងសុខផង ឬគុណជាតិដទៃ ដែលល្អិតលើសជាងបីតិ និងសុខនោះ
ផង កាលបើដូច្នេះ តថាគតដឹងច្បាស់ថា មិនវិលត្រឡប់មករកកាមទាំង-
ឡាយវិញឡើយ ។

[២១២] ថ្វាយព្រះពរមហានាម ចុះអ្វីជាតម្រេករបស់កាមទាំងឡាយ ។

បពិត្រមហានាម កាមគុណទាំងនេះមាន ៥ ប្រការ ចុះកាមគុណ ៥ ប្រការ តើអ្វីខ្លះ គឺរូបទាំងឡាយដែលគប្បីដឹងច្បាស់បានដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ សំឡេងទាំងឡាយ ដែលគប្បីដឹងច្បាស់បានដោយត្រចៀក ... ១ ក្លិនទាំងឡាយដែលគប្បីដឹងច្បាស់បានដោយច្រមុះ ... ១ រសទាំងឡាយ ដែលគប្បីដឹងច្បាស់បានដោយអណ្តាត ... ១ ផស្សព្វទាំងឡាយដែលគប្បីដឹងច្បាស់បានដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ បពិត្រមហានាម នេះឯងឈ្មោះថាកាមគុណ ៥ ប្រការ ។ បពិត្រមហានាម ត្រង់ដែលសេចក្តីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ នេះឯង ជាតម្រេករបស់កាមទាំងឡាយ ។

[២១៣] ថ្វាយព្រះពរមហានាម ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ បពិត្រមហានាម កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែងដោយសិល្បសាស្រ្តណាទីមួយ ទោះបីដោយការរាប់ម្រាមដៃទទេក្តី ដោយការរាប់លេខនព្វន្តក្តី ដោយការរាប់ប្រមូលក្តី ដោយកសិកម្មក្តី ដោយពាណិជ្ជកម្មក្តី ដោយគោរក្ខកម្មក្តី ដោយការៈនៃខ្លួនជាខ្មាន់ធ្នូក្តី ដោយការៈខ្លួនជារាជបុរសក្តី ដោយសិល្បសាស្រ្តឯណាទីមួយក្តី កុលបុត្តដែលអាស្រ័យនូវការចិញ្ចឹមជីវិត ដោយការរាប់ម្រាមដៃទទេជាដើមនោះ តែងមានត្រជាក់បៀតបៀន មានក្តៅបៀតបៀន ប៉ះពាល់ដោយសម្ផស្សនៃរបោមមូស

ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំ ស្លាប់ខ្លួនដោយសេចក្តីស្រេកឃ្លាន បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ បពិត្រមហានាម កាលបើកុលបុត្តនោះប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាតយ៉ាងនេះហើយ ភោគៈទាំងនោះក៏មិនបានសម្រេច កុលបុត្រនោះតែងក្រៀមក្រំចិត្ត លំបាកខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ឱ សេចក្តីប្រឹងប្រែងរបស់អាត្មាអញ អាសារឥតការសោះ ឱ សេចក្តីព្យាយាមរបស់អាត្មាអញ ឥតផលប្រយោជន៍សោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។ បពិត្រមហានាម កាលបើកុលបុត្តនោះខំប្រឹងប្រែង ខ្នះខ្នែង ព្យាយាមយ៉ាងនេះហើយ ភោគៈនោះក៏បានសម្រេច កុលបុត្តនោះតែងរងទុក្ខទោមនស្ស ព្រោះហេតុនៃការរក្សានូវភោគៈទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយ នាំយកភោគៈទាំងឡាយរបស់អាត្មាអញទៅបាន កុំឲ្យចោរទាំងឡាយលួចយកទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកនាំយកទៅបាន កុំឲ្យអ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់ នាំយកទៅបាន ។ កាលកុលបុត្តនោះ ខំរក្សាគ្រប់គ្រងយ៉ាងនេះហើយ ក៏គង់តែព្រះរាជាទាំងឡាយ រឹបយកនូវភោគៈទាំងនោះទៅក្តី ចោរ

ទាំងឡាយលួចយកទៅក្តី ភ្លើងឆេះអស់ក្តី ទឹកបន្សាត់ទៅក្តី អ្នកទទួលមត៌ក ទាំងឡាយមិនជាទីស្រឡាញ់ ទាមទៀរចំណែកក្តី កុលបុត្តនោះតែងក្រៀមក្រំ ចិត្ត លំបាកខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ទ្រព្យ ណាបានកើតមានហើយដល់អាត្មាអញ ឥឡូវនេះ ទ្រព្យនោះឯង ត្រឡប់ជា មិនមានដល់អាត្មាអញវិញឡើយ ។ បពិត្រមហានាម នេះឯងជាទោសរបស់ កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជា ហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជា បច្ច័យនៃកាមទាំងឡាយមែនពិត ។

[ ២១៤ ] ថ្វាយព្រះពរមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃ កាមទាំងឡាយមែនពិត បានជាព្រះរាជាទាំងឡាយទាស់ទែងគ្នានឹងព្រះរាជា ទាំងឡាយខ្លះ ក្សត្រទាំងឡាយទាស់ទែងគ្នានឹងក្សត្រទាំងឡាយខ្លះ ព្រាហ្មណ៍ ទាំងឡាយទាស់ទែងគ្នានឹងព្រាហ្មណ៍ទាំងឡាយខ្លះ គហបតីទាំងឡាយ ទាស់ ទែងគ្នានឹងគហបតីទាំងឡាយខ្លះ មាតាទាស់ទែងគ្នានឹងបុត្តខ្លះ បុត្រទាស់ទែង គ្នានឹងមាតាខ្លះ បិតាទាស់ទែងគ្នានឹងបុត្រខ្លះ បុត្រទាស់ទែងគ្នានឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងគ្នានឹងបងប្អូនប្រុសខ្លះ បងប្អូនប្រុសទាស់ទែងគ្នានឹង បងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងគ្នានឹងបងប្អូនប្រុសខ្លះ សម្លាញ់ទាស់ ទែងគ្នានឹងសម្លាញ់ខ្លះ ។ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីឈ្លោះ ប្រកែក ប្រកាន់ខុស ទាស់ទែងគ្នាក្នុងទីនោះ ហើយប្រហារគ្នានិងគ្នាដោយដៃ

ខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយគ្រឿងសស្ត្រាវុធខ្លះ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះក្នុងទីនោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

[ ២១៥ ] ថ្វាយព្រះពរមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាមនុស្សទាំងឡាយកាន់យកនូវដាវ និងខែល កាន់យកនូវធ្នូ សៀតបំពង់ព្រួញ ចូលទៅកាន់សង្គ្រាម ដែលលើកជាក្បួនទ័ពមកទាំងសងខាង កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេងារដាវឡើងក្តី ពួកមនុស្សទាំងនោះ ក៏បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងសង្គ្រាមនោះ ពួកមនុស្សទាំងនោះដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

[២១៦] ថ្វាយព្រះពរមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ

មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាពួកមនុស្សទាំងនោះ កាន់យកនូវដាវ និងខែល កាន់ធ្នូ សៀតបំពង់ព្រួញ ចូលទៅកាន់បន្ទាយ ដែលលាបបូកដោយបាយអ កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេឆាដាវឡើងក្តី ពួកមនុស្សទាំងនោះ ក៏បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ បាចសាចដាក់គ្នាដោយអាចម៍គោជ្រាយខ្លះ ញាំញីគ្នាដោយនាសំដែកខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងបន្ទាយនោះ ពួកមនុស្សទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះ ក្នុងបន្ទាយនោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំង-ឡាយមែនពិត ។

[ ២១៧ ] ថ្វាយព្រះពរមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត មនុស្សទាំងឡាយ ក៏កាត់នូវជញ្ជាំងផ្ទះខ្លះ ប្លន់ខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយៗ ខ្លះ ឈរស្ទាក់ប្រកផ្លូវខ្លះ គប់រកនូវភរិយារបស់អ្នកដទៃខ្លះ ព្រះរាជាទាំងឡាយចាប់មនុស្សទាំងនោះបានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ទាំងឡាយ មានប្រការផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ។បេ។ ធ្វើជាតិមាលិកកម្ម

គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាគេស្លៀកសំពត់សម្បកឈើខ្លះ ធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្លក់មាត់ដោយកាំង ឬសន្ទូចខ្លះ ធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈប្រមាណប៉ុនកហាបណៈខ្លះ ធ្វើនូវខារាបដិច្ឆកកម្ម គឺអំពើដែលគេយកទឹកផ្សារស្រោចខ្លះ ធ្វើបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាគេបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ មនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះ ក្នុងទីនោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

[២១៨] បពិត្រមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ជនទាំងឡាយនោះ លុះប្រព្រឹត្ត

ទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងសម្បរាយិកភព ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

[ ២១៩ ] បពិត្រមហានាម មានកាលសម័យថ្ងៃមួយ តថាគតនៅឰដ៏ភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកនិគ្រន្ថជាច្រើន ជាអ្នកឈរងើយលើផ្ទៃកាឡសិលា ទៀបភ្នំឥសិគិលិ ជាអ្នកឃាត់អាសនៈ តែងទទួលនូវវេទនា ជាទុក្ខដ៏ខ្លាំងក្លា ក្រហល់ក្រហាយ ដែលកើតអំពីសេចក្ដីព្យាយាម ។ បពិត្រមហានាម គ្រានោះឯង តថាគតក្រោកអំពីទីសម្ងំ ក្នុងវេលាល្ងាច ហើយចូលទៅឯកាឡសិលា ខាងភ្នំឥសិគិលិ សំដៅទៅត្រង់ទីដែលពួកនិគ្រន្ថនៅ លុះចូលទៅដល់ហើយ បានសួរពួកនិគ្រន្ថទាំងនោះដូច្នេះថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះព្រោះហេតុអ្វី បានជាអ្នកទាំងឡាយនាំគ្នាឈរងើយ ឃាត់អាសនៈ ទទួលនូវវេទនាជាទុក្ខដ៏ខ្លាំងក្លា ក្រហល់ក្រហាយ ដែលកើតអំពីសេចក្ដីព្យាយាមដូច្នេះ ។ បពិត្រមហានាម កាលតថាគតសួរយ៉ាងនេះហើយ និគ្រន្ថទាំងនោះ បាននិយាយតបពាក្យនេះ នឹងតថាគតថា ម្នាលអាវុសោ និគ្រន្ថនាដបុត្រ ( ជាគ្រូយើង ) ជាអ្នកដឹងសព្វ ឃើញសព្វ ប្តេជ្ញានូវញាណទស្សនៈ គឺការដឹង និងការឃើញ មិនមានសេស

សល់ថា អាត្មាអញ កាលដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ក៏មានញាណទស្សនៈតាំងស៊ប់ជានិច្ច មិនដែលដាច់ និគ្រន្ថនាដបុត្រនោះ ពោលយ៉ាងនេះថា ម្នាលនិគ្រន្ថទាំងឡាយដ៏ចម្រើន បាបកម្មដែលអ្នកទាំងឡាយបានធ្វើហើយ ក្នុងកាលមុនក៏មានដែរ អ្នកទាំងឡាយចូរញ៉ាំងបាបកម្មនោះឲ្យសាបសូន្យទៅ ដោយអំពើកម្រដ៏ជាទុក្ខនេះ ក៏ការដែលអ្នកទាំងឡាយសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត ក្នុងអំពើដ៏កម្រនោះ ក្នុងកាលឥឡូវនេះ នោះឈ្មោះថាមិនធ្វើនូវបាបកម្មតទៅ ព្រោះហេតុនោះ កម្មចាស់ទាំងឡាយដែលវិនាសទៅ ដោយសារសេចក្តីព្យាយាម ទាំងកម្មថ្មីទាំងឡាយដែលមិនបានធ្វើ ឈ្មោះថា នឹងមិនមានការជាប់តាមតទៅ ព្រោះមិនមានការជាប់តាមតទៅ ឈ្មោះថានឹងអស់ទៅនៃកម្ម ព្រោះអស់ទៅនៃកម្ម ឈ្មោះថានឹងអស់ទៅនៃទុក្ខ ព្រោះអស់ទៅនៃទុក្ខ ឈ្មោះថា នឹងអស់ទៅនៃវេទនា ព្រោះអស់ទៅនៃវេទនា ឈ្មោះថាទុក្ខទាំងពួង នឹងសាបសូន្យទៅ ក៏ពាក្យនោះឯងតែងគាប់ចិត្តផង គួរផង ដល់យើងទាំងឡាយ យើងទាំងឡាយជាអ្នកមានចិត្តរីករាយដោយពាក្យនោះ ។

[ ២២០ ] បពិត្រមហានាម កាលនិគ្រន្ថទាំងឡាយ ពោលយ៉ាងនេះហើយ តថាគតក៏បានសួរពួកនិគ្រន្ថទាំងនោះ ដូច្នេះថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថា យើងទាំងឡាយធ្លាប់កើត ក្នុងកាលមុន ឬមិនដឹងថា មិនធ្លាប់កើត ក្នុងកាលមុនទេ ។ និគ្រន្ថទាំងឡាយឆ្លើយតបថា ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំង-

ឡាយ ចុះអ្នកទាំងឡាយ ដឹងថាយើងទាំងឡាយ បានធ្វើនូវបាបកម្មក្នុងកាល មុន ឬមិនដឹងថា មិនបានធ្វើនូវបាបកម្មក្នុងកាលទេ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថា យើងទាំងឡាយបានធ្វើនូវបាបកម្មមានសភាពយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ដូច្នេះដែរឬ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថា ទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយឬ ទុក្ខមានប្រមាណប៉ុណ្ណេះ គប្បីសាបសូន្យទៅឬ កាលបើទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយ ទុក្ខទាំងអស់នឹងសាបសូន្យទៅដូច្នេះដែរឬ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថា ក្នុងសាសនារបស់ពួកអ្នកមានការលះបង់ នូវធម៌ទាំងឡាយជាអកុសល ញុំាងធម៌ទាំងឡាយជាកុសលឲ្យកើតឡើង ក្នុងបច្ចុប្បន្ននេះដូច្នេះដែរឬ ។ ម្នាលអាវុសោ ដំណើរនេះ យើងមិនបានដឹងច្បាស់ទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ បានឮថា អ្នកទាំងឡាយមិនដឹងថា យើងទាំងឡាយធ្លាប់កើតក្នុងកាលមុន មិនមែនថា មិនធ្លាប់កើតដូច្នេះទេ មិនដឹងថា យើងទាំងឡាយបានធ្វើនូវបាបកម្មក្នុងកាលមុន មិនមែនថា មិនបានធ្វើដូច្នេះទេ មិនដឹងថា យើងទាំងឡាយបានធ្វើបាបកម្មមានសភាពយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ដូច្នេះទេ មិនបានដឹងថា ទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយ ឬទុក្ខមានប្រមាណប៉ុណ្ណេះ គប្បីសាបសូន្យទៅ ឬក៏កាលបើទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យ

ទៅហើយ ទុក្ខទាំងអស់ក៏នឹងសាបសូន្យទៅដូច្នេះទេ មិនបានដឹងថា ក្នុងសាសនារបស់ពួកអ្នកមានការលះបង់នូវធម៌ទាំងឡាយជាអកុសល ញុំាងធម៌ទាំងឡាយជាកុសលឲ្យកើតឡើង ក្នុងបច្ចុប្បន្ននេះដូច្នេះទេ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ កាលបើយ៉ាងនេះ មានតែជនទាំងឡាយណា ក្នុងលោកដែលជាអ្នកមានមារយាទអាក្រក់ មានដៃប្រឡាក់ដោយឈាម មានការងារអាក្រក់ ជនទាំងនោះ លុះបានកើតមកជាមនុស្ស ក្នុងកាលជាខាងក្រោយ ក៏បួសក្នុងពួកនិគ្រន្ថទៀតឬអ្វី ។ ពួកនិគ្រន្ថឆ្លើយតបថា អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខតែម្យ៉ាងក៏ទេ អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីទុក្ខក៏មាន អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខក៏មាន ដូចព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់សោយនូវសេចក្តីសុខ ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់គង់នៅជាសុខលើសលប់ជាងព្រះគោតមដ៏មានអាយុ ។ តថាគតតបថា ពួកនិគ្រន្ថដ៏មានអាយុ មិនបានពិចារណា ហើយស្រាប់តែពោលវាចាដោយរហ័សថា អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខតែម្យ៉ាងក៏ទេ បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីទុក្ខក៏មាន អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខក៏មាន ដូចព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់សោយនូវសេចក្តីសុខ ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់គង់នៅជាសុខលើសលប់ជាងព្រះគោតមដ៏មានអាយុ ដូច្នេះ

ចំណែកខាងតថាគតឯង គង់មានគេសាកសួរក្នុងដំណើរនុ៎ះថា បណ្តាអ្នកដ៏មានអាយុទាំងឡាយ ចុះព្រះបាទមាគធសេនិយពិម្ពិសាររាជ និងព្រះគោតមដ៏មានអាយុ នរណានៅជាសុខជាង ។ ពួកនិគ្រន្ថឆ្លើយតបថា អាវុសោគោតម ពួកយើងខ្ញុំពិតជាមិនបានពិចារណាហើយ ស្រាប់តែពោលវាចាដោយរហ័សថា អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខតែម្យ៉ាងក៏ទេ បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីទុក្ខក៏មាន អាវុសោគោតម បុគ្គលនឹងត្រូវបាននូវសេចក្តីសុខ ដោយសារសេចក្តីសុខក៏មាន ដូចព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់សោយនូវសេចក្តីសុខ ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់គង់នៅជាសុខលើសលប់ ជាងព្រះគោតមដ៏មានអាយុដូច្នេះមែនហើយ តែថាដំណើរនុ៎ះចូរលើកទុកសិនចុះ ឥឡូវនេះ ពួកខ្ញុំនឹងសូមសួរព្រះគោតមដ៏មានអាយុថា បណ្តាអ្នកដ៏មានអាយុទាំងឡាយ ចុះព្រះបាទមាគធសេនិយពិម្ពិសាររាជ និងព្រះគោតមដ៏មានអាយុ នរណានៅជាសុខជាង តថាគតឆ្លើយថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ បើដូច្នោះ តថាគតនឹងត្រឡប់សួរអ្នកទាំងឡាយ ក្នុងរឿងនោះវិញ អ្នកទាំងឡាយចូលចិត្តយ៉ាងណា គប្បីព្យាកររឿងនោះ យ៉ាងនោះចុះ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់អាចមិនកម្រើកព្រះកាយ មិនពោលព្រះវាចា ប្រថាប់នៅសោយសេចក្តីសុខតែម្យ៉ាង អស់ ៧ យប់ ៧ ថ្ងៃបានឬទេ ។ ពួកនិគ្រន្ថតបថា ម្នាលអាវុសោ មិនបានទេ ។ តថាគត

សួរថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះ ជាដូចម្តេច ព្រះបាទមាគធសេនិយពិម្ពិសាររាជ ទ្រង់មិនអាចកម្រើកព្រះកាយ មិនពោលព្រះវាចា ប្រថាប់នៅ សោយចំពោះនូវសេចក្តីសុខតែម្យ៉ាងអស់ ៦ យប់ ៦ ថ្ងៃ... អស់ ៥ យប់ ៥ ថ្ងៃ... អស់ ៤ យប់ ៤ ថ្ងៃ... អស់ ៣ យប់ ៣ ថ្ងៃ... អស់ ២ យប់ ២ ថ្ងៃ... អស់ ១ យប់ ១ ថ្ងៃបានឬទេ ។ ពួកនិគ្រន្ថឆ្លើយថា ម្នាលអាវុសោមិនបានទេ ។ តថាគតពោលថា ម្នាល អាវុសោនិគ្រន្ថទាំងឡាយ តថាគតហ្នឹងឯង ទើបអាចមិនកម្រើនកាយ មិន ពោលវាចា សោយចំពោះនូវសេចក្តីសុខអស់ ១ យប់ ១ ថ្ងៃបាន ។ ម្នាល អាវុសោនិគ្រន្ថទាំងឡាយ តថាគតហ្នឹងឯង ទើបអាចមិនកម្រើកកាយ មិន ពោលវាចា សោយចំពោះនូវសេចក្តីសុខអស់ ២ យប់ ២ ថ្ងៃ ... អស់ ៣ យប់ ៣ ថ្ងៃ ... អស់ ៤ យប់ ៤ ថ្ងៃ ... អស់ ៥ យប់ ៥ ថ្ងៃ ... អស់ ៦ យប់ ៦ ថ្ងៃ ... អស់ ៧ យប់ ៧ ថ្ងៃបាន ។ ម្នាលអាវុសោនិគ្រន្ថទាំង-ឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាង នេះមានហើយ ព្រះបាទមាគសេនិយពិម្ពិសាររាជ និងតថាគត នរណានៅ ជាសុខជាង ។ ពួកនិគ្រន្ថទាំងឡាយឆ្លើយតបថា កាលបើហេតុយ៉ាងនេះមាន ហើយ ព្រះគោតមដ៏មានអាយុ ព្រះអង្គតែងគង់នៅជាសុខ លើសលប់ជាង ព្រះបាទមាគធសេនិយពិម្ពិសាររាជ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់នូវ ព្រះសូត្រនេះចប់ហើយ មហានាមសក្យរាជ ក៏មានព្រះហឫទ័យទទួលអំណរ ត្រេកអរចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចូឡទុក្ខក្ខន្ធសូត្រទី ៤ ចប់តែប៉ុណ្ណេះ

# អដ្ឋកថា

# ចូឡទុក្ខក្ខន្ធសូត្រ

[ ២០៩ ] ចូឡទុក្ខក្ខន្ធសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់មកដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សក្កេសុ** បានដល់ ក្នុងជនបទ មានឈ្មោះ យ៉ាងនោះ ។ ជនបទនោះ ដល់នូវការរាប់ថា **សក្យា** ព្រោះជាទីលំនៅរបស់ រាជកុមារអ្នកសក្យៈទាំងឡាយ ។ ការកើតឡើងនៃសក្យៈទាំងឡាយ មក ហើយក្នុងអម្ពដ្ឋសូត្រនោះឯង ។ បទថា **កបិលវត្ថុស្មឹ** គឺក្នុងនគរមានឈ្មោះ យ៉ាងនោះ ។ ពិតហើយ នគរនោះ ហៅថា កបិលពស្ដុ ព្រោះជានគរដែល សាងឡើងក្នុងទីនៅរបស់ឥសី ឈ្មោះកបិល ។ ធ្វើនគរនោះជាទីគោចរគាម ។ បទថា **និគ្រោធារាមេ** សេចក្ដីថា ស្ដេចសក្យៈព្រះនាមថា និគ្រោធ កាល ព្រះមានព្រះភាគ ទ្រង់យាងមកក្រុងកបិលពស្ដុ ក្នុងញាតិសមាគម ព្រះ អង្គម្ចាស់និគ្រោធសាងវត្តក្នុងឧទ្យានរបស់ព្រះអង្គ វេរថ្វាយដល់ព្រះមានព្រះ ភាគ ព្រះមានព្រះភាគប្រថាប់នៅក្នុងនិគ្រោធារាមនោះ ។ បទថា **មហា-នាមោ** បានដល់ ព្រះជេដ្ឋា គឺបងរបស់ព្រះអនុរុទ្ធ ទ្រង់ជាឱរសរបស់ព្រះ ចូឡបិតុលានៃព្រះមានព្រះភាគ ។ ស្ដេច ៥ អង្គ គឺព្រះបាទសុទ្ធោទនៈ ព្រះ បាទសុក្កោទនៈ ព្រះបាទសក្កោទនៈ ព្រះបាទធោតោទនៈ ព្រះបាទអមិតោទនៈ ទ្រង់ជាបងប្អូននឹងគ្នា ព្រះទេវីឈ្មោះថា អមិតា ទ្រង់ជាព្រះភគិនី គឺប្អូនស្រី របស់ស្ដេចទាំងនោះ ព្រះតិស្សត្ថេរជាបុត្ររបស់ព្រះនាងអមិតានោះ ព្រះ

តថាគត និងព្រះនន្ទត្ថេរជាព្រះឱរសរបស់ព្រះបាទសុទ្ធោទនៈ ព្រះមហានាម និងព្រះអនុរុទ្ធ ជាឱរសរបស់ព្រះបាទសុក្កោទនៈ ព្រះអានន្ទត្ថេរ ជាព្រះឱរសរបស់ព្រះបាទអមិតោទនៈ ព្រះអានន្ទជាព្រះកនិដ្ឋរបស់ព្រះមានព្រះភាគ ព្រះបាទមហានាម ទ្រង់ចាស់ជាង ជាព្រះសកទាគាមីអរិយសាវក ។ បទថា **ទីឃរត្តំ** សេចក្តីថា ទ្រង់សម្តែងថា ខ្ញុំព្រះអង្គដឹង ចាប់តាំងអំពីខ្ញុំព្រះអង្គសម្រេចសកទាគាមិផល អស់កាលយូរ ។ បទថា **លោភធម្មា** បានដល់ធម៌ ពោល គឺលោភៈ ។ ទ្រង់ពោលសំដៅដល់លោភៈប៉ុណ្ណោះមានប្រការផ្សេងៗ ។ ក្នុង ២ បទក្រៅ អំពីនេះ ក៏មានន័យដូចគ្នា ។ បទថា **បរិយាទាយ តិដ្ឋន្តិ** សេចក្តីថា នៅគ្របសង្កត់នៅឡើយ ។ ធម្មតាបរិយាទាន គឺការគ្របសង្កត់នេះ មានអត្ថ ២ យ៉ាង គឺដោយអត្ថថា គ្របសង្កត់ ១ ដោយអត្ថថា ការលះបង់ ១ ។ មកក្នុងអត្ថថា គ្របសង្កត់ ដូចក្នុងប្រយោគជាដើមថា **សព្វំ ហត្ថិកាយំ បរិយាទិយិត្វា សព្វំ អស្សកាយំ បរិយាទិយិត្វា សព្វំ រថកាយំ បរិយាទិយិត្វា សព្វំ បត្តិកាយំ បរិយាទិយិត្វា ជីវន្តមេវ នំ ឱស្សជ្ជិ** ( ព្របាទបសេនទិកោសល ) បានរឹបយកពលដំរីទាំងអស់ រឹបយកពលសេះទាំងអស់ រឹបយកពលរថទាំងអស់ រឹបយកពលថ្មើរជើងទាំងអស់ របស់ព្រះបាទអជាតសត្តុវេទេហិបុត្រ ជាឥស្សរៈក្នុងដែនមគធៈ ហើយលែងព្រះបាទអជាតសត្តុនោះឲ្យរួចទៅទាំងរស់វិញ ។ មកក្នុងអត្ថថា លះបង់ ដូចក្នុងប្រយោគជាដើមថា **អនិច្ចសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា សព្វំ កាមរាគំ បរិយាទិយតិ** ម្នាលភិក្ខុទាំងឡាយ អនិច្ច-

សញ្ញា ដែលបុគ្គលបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងលះបង់នូវកាមរាគៈទាំងអស់ ដូច្នេះ ។ ក្នុងទីនេះ លោកបំណងយកអត្ថថា លះបង់ ។ ដោយហេតុនោះ ទើបពោលថា បទថា **បរិយាទិយិត្វា** បានដល់ លះបង់ហើយ ។ បទថា **យេន មេ ឯកទា លោភធម្មាបិ** សេចក្តីថា ទ្រង់ទូលសួរថា លោភៈទាំងឡាយនៅគ្របសង្កត់ចិត្តរបស់ខ្ញុំបានក្នុងកាលខ្លះ ព្រោះហេតុអ្វី បានឮថា ព្រះរាជានេះ ទ្រង់មានសេចក្តីសម្គាល់ថា លោភៈ ទោសៈ និងមោហៈ បានលះអស់មិនមានសេសសល់ ដោយសកទាគាមិមគ្គ ។ ព្រះរាជានេះទ្រង់ដឹងថា វត្ថុដែលមិនទាន់លះបានរបស់អញមាននៅឡើយ ទ្រង់កាន់យកវត្ថុដែលមិនទាន់លះបាន ជាអ្នកមានសេចក្តីសម្គាល់ថា វត្ថុដែលលះបានហើយ រមែងប្រព្រឹត្តទៅខាងក្រោយ ដូច្នេះ ។ ព្រះអរិយសាវកកើតសេចក្តីសង្ស័យនេះឬ អើ សង្ស័យរមែងកើតឡើង ។ ព្រោះហេតុអ្វី ព្រោះភាពជាអ្នកមិនឈ្លាសក្នុងបញ្ញត្ត ។ ពិតហើយ អរិសាវកដែលមិនឈ្លាសក្នុងបញ្ញត្តនេះថា កិលេសនេះត្រូវសម្លាប់ដោយមគ្គនោះ រមែងមានសេចក្តីសង្ស័យយ៉ាងនេះ ។ អរិយសាវកនោះ មិនមានការពិចារណាឬ មាន តែការពិចារណានោះ មិនបរិបូណ៌ដល់អរិយសាវកទាំងពួង ។ ព្រោះថា បុគ្គលខ្លះពិចារណាចំពោះកិលេសដែលលះបានហើយប៉ុណ្ណោះ បុគ្គលខ្លះពិចារណាកិលេសដែលមិនទាន់បានប៉ុណ្ណោះ បុគ្គលខ្លះពិចារណាចំពោះមគ្គ បុគ្គលខ្លះពិចារណាចំពោះផល បុគ្គលខ្លះពិចារណាចំពោះនិព្វាន ក្នុងការពិចារណា ៥ ប្រការនេះ ការពិចារណា ១-២ ប្រការ មិនគួរដើម្បីនឹងបានក៏ទេ ដោយ

ប្រការដូច្នេះ អរិយសាវកណាពិចារណាមិនបរិបូណ៌ អរិយសាវកនោះ រមែងមានសេចក្ដីសង្ស័យយ៉ាងនេះ ព្រោះជាអ្នកមិនឈ្លាសក្នុងកិលេសបញ្ញត្តិដែលគប្បីសម្លាប់ដោយមគ្គ ។

[ ២១០ ] បទថា **សោ ឣ ខោ តេ** សេចក្ដីថា ទ្រង់សម្ដែងថា លោភៈ ទោសៈ និងមោហៈនោះឯង មិនទាន់លះបានក្នុងសន្ដានរបស់មហាបពិត្រ តែមហាបពិត្រជាអ្នកមានសេចក្ដីសម្គាល់ថា លះបានហើយ ។ បទថា **សោ ច ហិ តេ** សេចក្ដីថា ធម៌ គឺលោភៈ ទោសៈ និងមោហៈរបស់មហាបពិត្រនោះ ។ បទថា **កាមេ** បានដល់ កាម ២ យ៉ាង ។ បទថា **ន បរិភុញ្ជេយ្យាសិ** គឺទ្រង់សម្ដែងថា មហាបពិត្រក៏គប្បីបួសដូចតថាគត ។

[ ២១១ ] បទថា **អប្បស្សាទា** បានដល់ មានសុខតិចតួច ។ បទថា **ពហុទុក្ខា** បានដល់ ទុក្ខដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងក្នុងសម្បរាយិកភពនោះឯងច្រើន ក្នុងទីនេះ ។ បទថា **ពហូបាយាសា** បានដល់ កិលេស គឺឧបាយាសៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយកភពនោះឯង ជារបស់ច្រើន ក្នុងទីនេះ ។ បទថា **អាទីនវោ** គឺឧបទ្រវដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយកភព ។ បទថា **ឯត្ថ ភិយ្យោ** សេចក្ដីថា ក្នុងកាមទាំងនោះមានទោសច្រើនយ៉ាងនេះឯង តែឲ្យនូវការត្រេកអរតិច គឺតិចតួច ដូចគ្រាប់ស្ពៃអាស្រ័យក្នុំហិមពាន្ត ឲ្យផលតិច ដូច្នោះ ។ បទថា **ឥតិ ចេបិ មហានាម** សេចក្ដីថា ថ្វាយព្រះពរមហានាម បើអរិយសាវកយ៉ាងនេះ ។ បទថា **យថាភូតំ** បានដល់ ទ្រង់សម្ដែងថា សម្លឹងឃើញដោយល្អ ដោយបញ្ញា ដោយ

ប្រពៃតាមសេចក្ដីពិត គឺដោយន័យ ដោយការណ៍ ។ បណ្ដាបទទាំងនោះ បទថា **បញ្ញាយ** បានដល់ ដោយវិបស្សនាបញ្ញា អធិប្បាយថា ដោយញាណ គឺមគ្គ ២ យ៉ាងខាងក្រោម ។ បទថា **សោ ច** គឺអរិយសាវកជាអ្នកឃើញទោសរបស់កាមដោយមគ្គ ២ យ៉ាងនោះឯង ។ ទ្រង់សម្ដែងញាណ ២ យ៉ាង ដែលមានបីតិ ដោយបទនេះថា **បីតិសុខំ** ។ បទថា **អញ្ញំ វា តតោ សន្តតរំ** បានដល់ ឈាន ២ យ៉ាង និងមគ្គ ២ យ៉ាងជាន់លើដទៃដែលស្ងប់ជាងឈាន ២ យ៉ាងនោះ ។ បទថា **នេវ តាវ អនាវដ្ដី កាមេសុ ហោតិ** សេចក្ដីថា អរិយសាវកសូម្បីចាក់ធ្លុះមគ្គទាំង ២ តាំងនៅនោះ ជាអ្នកមិនវិលមកក្នុងកាមទាំងឡាយមិនមានដោយពិតនោះឯង ព្រោះមិនទាន់បានសម្រេចឈាន ឬមគ្គខាងលើ រមែងមិនជាអាភោគ គឺការចងចិត្តដល់បុគ្គលមិនវិលមកក៏ទេ តែមានអាភោគដល់បុគ្គលវិលមកប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រោះមិនមានវិក្ខម្ភនប្បហានដោយឈាន ៤ មិនមានសមុច្ឆេទ-ប្បហានដោយមគ្គ ២ ។ បទថា **មយ្ហម្បិ ខោ** សេចក្ដីថា មិនមែនមហាបពិត្រមួយអង្គប៉ុណ្ណោះទេ ដោយពិត សូម្បីតថាគតក៏ដូច្នោះ ។ បទថា **បុព្វេ សម្ពោធា** បានដល់ មុនត្រាស់ដឹងដោយមគ្គនោះឯង ។ លោកបំណាងយក **ឱឡារិកកាមប្បហានបញ្ញា** គឺបញ្ញាក្នុងការលះបង់ស្រីស្នំនិងស្រីបាំ ក្នុងបទនេះថា **បញ្ញាយ សុទិដ្ឋំ អហោសិ** ដូច្នេះ ។ បទថា **បីតិសុខំ នាជ្ឈគមឹ** បានដល់ តថាគតមិនបានឈាន ២ យ៉ាង ដែលមានបីតិ ។ លោកបំណាងយកឈានខ្ពស់ ២ យ៉ាង និងមគ្គ ៤ ក្នុងបទនេះ

ថា **អញ្ញំ វា តតោ សន្តតរំ** ដូច្នេះ ។ បទថា **បច្ចញ្ញាសឹ** បានដល់ ប្តេជ្ញាហើយ ។

[ ២១៩ ] ព្រោះហេតុអ្វី ទើបទ្រង់ប្រារព្ធថា បពិត្រមហានាម ក្នុងសម័យមួយ តថាគត ដូច្នេះ ។ ព្រោះមានអនុសន្ធិជាផ្នែក ដូច្នេះ ។ ទ្រង់សម្តែងសេចក្តីត្រេកអរខ្លះ ទោសខ្លះនៃកាមទាំងឡាយខាងក្រោម មិនបានត្រាស់ដល់ការរលាស់ចេញ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងដល់ការរលាស់ចេញនោះ ព្រោះការប្រកបខ្លួនឲ្យជាប់ជំពាក់នឹងសុខក្នុងកាម ជាអន្តធម៌ ១ ការប្រកបខ្លួនឲ្យលំបាកជាអន្តធម៌ ១ សាសនារបស់តថាគតផុតចាកអន្តធម៌ទាំង ២ នេះ ព្រោះដូច្នោះ ទើបទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងសាសនាទាំងមូល ដោយមាតិកានៃផលសមាបត្តិជាន់ខ្ពស់ ។ បទថា **គិជ្ឈកូដេ បព្វតេ** សេចក្តីថា ភ្នំនោះមានកំពូលស្រដៀងសត្វត្មាត ព្រោះដូច្នោះ ទើបហៅថា **គិជ្ឈកូដ** ឬមានត្មាតទាំងឡាយ អាស្រ័យនៅក្នុងកំពូលទាំងឡាយរបស់ភ្នំនោះក៏មាន ព្រោះដូច្នោះ ទើបហៅថា **គិជ្ឈកូដ** ។ បទថា **ឥសិគិលិបស្សេ** បានដល់ ក្បែរភ្នំឥសិគិលិ ។ បទថា **កាឡសិលាយំ** បានដល់ ផ្ទាំងថ្មដែលមានពណ៌ខ្មៅ ។ បទថា **ឧព្ភដ្ឋកា ហោន្តិ** សេចក្តីថា ជាបុគ្គលកាន់យកការឈរជាវត្ត មិនអង្គុយ ។ បទថា **ឱបក្កមិកា** សេចក្តីថា ដែលកើតអំពីសេចក្តីព្យាយាមរបស់ខ្លួន មានការឈរជាវត្តជាដើម ។ បទថា **និគណ្ឋោ អាវុសោ** សេចក្តីថា កាលមិនអាចដើម្បីនឹងពោលហេតុដទៃ ទើបបោះឲ្យពួកនិគ្រន្ថ ។ បទថា **សព្វញ្ញូ សព្វទស្សាវី** សេចក្តីថា និគ្រន្ថទាំង-

ឡាយសម្តែងថា សាស្តារបស់ពួកយើងនោះដឹងគ្រប់យ៉ាង ឃើញគ្រប់យ៉ាង ទាំងអតីត អនាគត និងបច្ចុប្បន្ន ។ បទថា **អបរិសេសំ ញាណទស្សនំ បដិជានាតិ** សេចក្តីថា សាស្តារបស់ពួកយើងនោះរមែងដឹងច្បាស់នូវញាណ-ទស្សនៈ ពោល គឺដឹងគ្រប់ចំណែក ព្រោះដឹងធម៌ដោយប្រការទាំងពួង និង កាលបញ្ជាក់ ក៏បញ្ជាក់យ៉ាងនេះថា កាលអាត្មាអញដើរទៅក្តី ឈរក្តី ។បេ។ ញាណទស្សនៈប្រាកដ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សតតំ** បាន ដល់ ជានិច្ច ។ បទថា **សមិតំ** ជាវេវចនៈនៃបទនោះឯង ។

[ ២២០ ] ពាក្យនេះថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំង-ឡាយដឹងថា ទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយឬ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ធម្មតាបុរសរមែងដឹងកិច្ច ដែលជំពាក់បំណុល ២០ កហាបណៈ សងហើយ ១០ កហាបណៈ ក៏ដឹងថា អញសងហើយ ១០ កហាបណៈ នៅសល់ ១០ កហាបណៈ កាលសងកហាបណៈទាំងនោះអស់ហើយ រមែង ដឹងកិច្ចទាំងពួងថា បំណុលទាំងអស់របស់អញជម្រះហើយ ។ ច្រូតចំណែក ទី ៣ នៃស្រែ ក៏ដឹងថា ចំណែកមួយច្រូតហើយ នៅសល់ ២ ចំណែក កាលច្រូតមួយចំណែកទៀត ក៏ដឹងថា មួយចំណែកនៅសល់ កាលស្រែនោះ ច្រូតហើយ ក៏ដឹងថា កិច្ចគ្រប់យ៉ាង សម្រេចហើយ រមែងដឹងកិច្ចដែលធ្វើ ហើយ និងមិនទាន់បានធ្វើក្នុងកិច្ចទាំងពួងយ៉ាងនេះ សូម្បីពួកអ្នកក៏គប្បីដឹង យ៉ាងនោះ ។ ដោយពាក្យថា ការលះអកុសលធម៌ទាំងឡាយ ត្រាស់សួរថា ឈ្មោះថា និគ្រន្ថដែលលះអកុសល ចម្រើនកុសល ដល់នូវភាពជាអ្នកបរិសុទ្ធ

ហើយ មាននៅក្នុងសាសនារបស់ពួកអ្នកឬ ។ បទថា **ឯវំ សន្តេ** សេចក្តីថា កាលពួកអ្នកដឹងយ៉ាងនេះមាន ។ បទថា **លុទ្ទា** បានដល់ មានមារយាទអាក្រក់ ។ បទថា **លោហិតបាណិនោ** បានដល់ បុគ្គលអ្នកញ៉ាំងជីវិតសត្វឲ្យធ្លាក់ចុះ ឈ្មោះថា មានបាតដៃប្រឡាក់ដោយឈាម ។ ធម្មតាដៃរបស់អ្នកសម្លាប់សត្វ រមែងប្រឡាក់ដោយឈាម បុគ្គលនោះ ហៅថា មានបាតដៃប្រឡាក់ដោយឈាមដូចគ្នា ។ បទថា **ក្សួរកម្មន្តា** បានដល់ ទារុណកម្ម គឺការធ្វើខុសក្នុងមាតា បិតា និងសមណព្រាហ្មណ៍ដែលជាអ្នកមានធម៌ជាដើម ឬកម្មដែលគ្រោតគ្រាត មានព្រានម្រឹគជាដើម ។ និគ្រន្ថទាំងឡាយសម្គាល់ថា សមណគោតមនេះឲ្យទោសក្នុងវាទៈរបស់ពួកយើង ចាំមើលពួកយើងនឹងលើកទោសដល់សមណគោតមនោះ ទើបប្រារព្ធពាក្យនេះថា នៃសមណ-គោតមដ៏មានអាយុ ដូច្នេះ ។ បទនេះមានអត្ថថា នៃអាវុសោគោតម ព្រះអង្គទ្រទ្រង់ចីវរដ៏ប្រណីត សោយសុទ្ធតែស្រូវសាលី សាច់ និងទឹក ប្រថាប់នៅក្នុងព្រះគន្ធកុដិ មានពណ៌ដូចទេវវិមាន ប្រកបសេចក្តីសុខបានដោយសេចក្តីសុខ យ៉ាងណា បុគ្គលមិនគប្បីជួបសេចក្តីសុខ ដោយសេចក្តីសុខយ៉ាងនោះ ។ ម្យ៉ាងទៀត ពួកខ្ញុំសោយសេចក្តីទុក្ខច្រើនប្រការ ដោយសេចក្តីព្យាយាមទាំងឡាយ មានសេចក្តីព្យាយាមក្នុងការអង្គុយប្រហោងជាដើមយ៉ាងណា បុគ្គលគប្បីជួបសេចក្តីសុខបាន ដោយសេចក្តីទុក្ខ ដូច្នោះ យ៉ាងនេះ ។ បទថា **សុខេន ច អាវុសោ** នេះ ពោលហើយ ដើម្បីសម្តែងថា បើបុគ្គលគប្បីប្រកបសេចក្តីសុខបានដោយសេចក្តីសុខសោត ព្រះរាជាក៏គប្បី

ជួប ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **មាគធោ** បានដល់ ទ្រង់មានឥស្សរៈនៃដែនមគធៈ ។ បទថា **សេនិយោ** គឺព្រះនាមស្តេចផែនដី មគធៈនោះ ។ បទថា **ពិម្ពិ** បានដល់ ព្រះនាមអត្តភាព ។ ព្រះអង្គជាសារៈនៃដែនមគធៈនោះ ទ្រង់គួរមើល គួរជាទីជ្រះថ្លា ទើបថ្វាយព្រះនាមថា **ពិម្ពិសារ** ព្រោះការសម្រេចក្នុងអត្តភាព ។ ពួកនិគ្រន្ថនោះ សំដៅដល់ការសោយសម្បត្តិ មួយអន្លើដោយអ្នករបាំទាំងឡាយ ដែលមានវ័យទាំង ៣ ក្នុងប្រាសាទទាំង ៣ របស់ព្រះរាជា ទើបពោលពាក្យនេះថា ទ្រង់នៅជាសុខល្អជាង ដូច្នេះ ។ បទថា **អទ្ធា** បានដល់ ដោយចំណែកមួយ ។ បទថា **សហសា អប្បដិសង្ខា** បានដល់ ទ្រង់សម្តែងថា ពួកនិគ្រន្ថប្រញាប់ប្រញាល់មិនទាន់ពិចារណា ទើបពោលវាចាយ៉ាងនោះ ដូចបុគ្គលតម្រេកពោលដោយអំណាចរាគៈ បុគ្គលក្រោធហើយ ពោលដោយអំណាចទោសៈ បុគ្គលវង្វេងហើយ ពោលអំណាចមោហៈ ដូច្នោះ ។ បណ្តាបទទាំងនោះ បទថា **បដិបុច្ឆិស្សាមិ** សេចក្តីថា តថាគតនឹងសួរក្នុងអត្ថនោះ ។ បទថា **យថា វោ ខមេយ្យ** សេចក្តីថា ពួកអ្នកគប្បីពេញចិត្តយ៉ាងណា ។ បទថា **បហោតិ** បានដល់ រមែងអាច ។ បទថា **អនិញ្ជមានោ** បានដល់ មិនញាប់ញ័រ ។ បទថា **ឯកន្តសុខបដិសំវេទី** បានដល់ សោយសុខជានិរន្តរ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីសុខក្នុងផលសមាបត្តិរបស់ព្រះអង្គ ទើបត្រាស់ពាក្យនេះថា ម្នាលអាវុសោនិគ្រន្ថ តថាគតហ្នឹងឯង ។បេ។ សោយចំពោះនូវសេចក្តីសុខ មួយយប់មួយថ្ងៃបាន ដូច្នេះ ។ ទ្រង់ធ្វើវារៈនៃ

ព្រះរាជាឲ្យជាដើម រហូតដល់ ៧ វារៈ ហើយទ្រង់ធ្វើសំណួរដើម្បីឲ្យចប់ពាក្យក្នុងទីនេះ ។ កាលពោលថា មិនអាចដល់ ៧ យប់ ៧ ថ្ងៃបាន ទើបមានពាក្យសួរសេចក្តីសុខ ៦ យប់ ៦ ថ្ងៃ ៥ យប់ ៥ ថ្ងៃ ៤ យប់ ៤ ថ្ងៃ ដូច្នេះ ។ តែក្នុងពុទ្ធវារៈ កាលត្រាស់ដល់ ៧ យប់ ៧ ថ្ងៃ និងត្រាស់ទៀតថា ៦ យប់ ៦ ថ្ងៃ ៥ យប់ ៥ ថ្ងៃ ៤ យប់ ៤ ថ្ងៃ ក៏មិនជាទីអស្ចារ្យ ព្រោះដូច្នោះ ទើបត្រាស់រួមតែមួយចូលគ្នា ហើយទ្រង់ធ្វើទេសនា ។ បទដ៏សេសក្នុងបទទាំងអស់ មានអត្ថងាយយល់ហើយ ។៚

## ចូឡទុក្ខក្ខន្ធសូត្រ ចប់
## សូត្រទី ៤ ចប់

# សុត្តន្តបិដក

## អនុមានសូត្រទី ៥

[ ២២១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាមោគ្គល្លាន ដ៏មានអាយុ នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ពួកសត្វម្រឹគ ជិត ក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ លំដាប់នោះឯង ព្រះមហាមោគ្គល្លានដ៏ មានអាយុ ហៅភិក្ខុទាំងឡាយដែលនៅក្នុងទីនោះឯងថា ម្នាលអាវុសោ ទាំងឡាយ ដ៏មានអាយុ ។ ភិក្ខុទាំងនោះ បានទទួលតបពាក្យព្រះមហា មោគ្គល្លានដ៏មានអាយុថា ព្រះករុណា ។

[ ២២២ ] ព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បើភិក្ខុបវារណាថា សូមលោកដ៏មានអាយុទាំង-ឡាយប្រៀនប្រដៅខ្ញុំចុះ ខ្ញុំជាបុគ្គលដែលលោកដ៏មានអាយុទាំងឡាយគួរស្តីថា បានដូច្នេះ តែភិក្ខុនោះទៅជាអ្នកដែលគេប្រដៅបានដោយក្រ ប្រកបដោយធម៌ ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ ជាអ្នកមិនកាន់យកនូវពាក្យ ប្រដៅដោយចំណែកខាងស្តាំ កាលបើដូច្នេះ សព្រហ្មចារីបុគ្គលទាំងឡាយ តែងសម្គាល់នូវភិក្ខុនោះថា ជាអ្នកមិនគួរស្តីថាផង សម្គាល់ថា មិនគួរប្រៀន ប្រដៅផង សម្គាល់ថា មិនគួរដល់នូវសេចក្តីស្និទ្ធស្នាលក្នុងបុគ្គលនោះផង ។ ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ( ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រនោះ មាន ១៦ យ៉ាង គឺ ) ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុង

អំណាចនៃសេចក្តីប្រាថ្នាលាមក ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលើកខ្លួនឯងបន្តុះបង្អាប់អ្នកដទៃ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំង-ឡាយ ត្រង់ដែលភិក្ខុជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្តីក្រោធជាហេតុ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នកជេរប្រទេច ព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកក្រោធ ជាអ្នកជេរប្រទេច ព្រោះសេចក្តីក្រោធជាហេតុ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចាជិតសេចក្តីក្រោធ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចាជិតសេចក្តីក្រោធ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទ

ហើយ ក៏ទឹងតបតនឹងភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ត្រង់ដែល ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏ទឹងតបតនឹងភិក្ខុអ្នកចោទវិញ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏បណ្តោញភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏បណ្តោញភិក្ខុអ្នកចោទវិញ នេះឯង ជាធម៌ធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទៗ ហើយ និយាយគ្របសង្កត់ភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទៗ ហើយ ក៏និយាយគ្របសង្កត់ភិក្ខុអ្នកចោទវិញ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទៗ ហើយ ក៏និយាយបង្វែរបង្វាន់នូវភិក្ខុអ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ និយាយគេចកែដោយសម្តីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវអ្នកចោទៗហើយ ក៏និយាយបង្វែរបង្វាន់នូវភិក្ខុអ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ និយាយគេចកែដោយសម្តីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទៗ ហើយ មិនឆ្លើយក្នុងដំណើររបស់ខ្លួន ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទៗ ហើយ

ក៏មិនធ្វើយក្នុងដំណើររបស់ខ្លួន នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រឡងវាសនា ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រឡងវាសនា នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រណែន ជាអ្នកកំណាញ់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកប្រណែន ជាអ្នកកំណាញ់ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកអួតអាង ជាអ្នកមានពុតមាយា ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកអួតអាង ជាអ្នកមានពុតមាយា នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នករឹងរូស ជាអ្នកមើលងាយគេ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នករឹងរូស ជាអ្នកមើលងាយគេ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ ម្នាលអាវុសោទាំង-ឡាយ ត្រង់ដែលភិក្ខុជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង (១៦) នេះ ព្រះមានព្រះភាគត្រាស់ហៅថា ទោវចស្សករណធម៌ គឺធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ។

[២២៣] ម្នាលអាវុសោទាំងឡាយ បើភិក្ខុមិនបានបវារណាថា សូម

លោកដ៏មានអាយុទាំងឡាយ ប្រៀនប្រដៅខ្ញុំចុះ ខ្ញុំជាបុគ្គលគួរលោកដ៏មានអាយុទាំងឡាយស្តីថាបានដូច្នេះទេ តែភិក្ខុនោះឯងជាអ្នកប្រដៅងាយ ជាអ្នកប្រកបដោយធម៌ ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ កាន់យកនូវពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ កាលបើដូច្នេះ សព្រហ្មចារីបុគ្គលទាំងឡាយ តែងសម្គាល់ភិក្ខុនោះថា ជាអ្នកគួរស្តីថាផង សម្គាល់ថាគួរប្រៀនប្រដៅផង សម្គាល់ថា គួរដល់នូវសេចក្តីស្និទ្ធស្នាលក្នុងបុគ្គលនោះផង ។ ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ( ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយមាន ១៦ ) គឺភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រាថ្នាលាមក មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនមានសេចក្តីប្រាថ្នាលាមក មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនលើកខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនលើកខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនមានសេចក្តីក្រោធគ្របសង្កត់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនមានសេចក្តីក្រោធគ្របសង្កត់ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនចងគំនុំ

ទុក ព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនចងគំនុំទុកព្រោះសេចក្តីក្រោធជាហេតុ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនជេរប្រទេចព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនជេរប្រទេចព្រោះសេចក្តីក្រោធជាហេតុ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនបញ្ចេញវាចាជិតសេចក្តីក្រោធ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនក្រោធ មិនបញ្ចេញវាចាជិតសេចក្តីក្រោធ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏មិនទីងតបទីងភិក្ខុអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ តែមិនទីងតបតទីងអ្នកចោទវិញ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏មិនបណ្តេញភិក្ខុអ្នកចោទ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ តែមិនបណ្តេញភិក្ខុអ្នកចោទ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏មិននិយាយគ្របសង្កត់ដល់ភិក្ខុអ្នកចោទ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ តែមិននិយាយគ្របសង្កត់ភិក្ខុអ្នកចោទ

នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏មិននិយាយបន្ទែបន្ទប់នូវភិក្ខុអ្នកចោទ ដោយហេតុដទៃ ឬហេតុផ្សេងៗ មិននិយាយគេចកែដោយសម្តីខាងក្រៅ មិនធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ តែមិននិយាយបន្ទែបន្ទប់នូវភិក្ខុអ្នកចោទដោយហេតុដទៃ ឬពាក្យផ្សេងៗ មិននិយាយគេចកែដោយសម្តីខាងក្រៅ មិនធ្វើនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏ឆ្លើយមិនទាល់ក្នុងដំណើររបស់ខ្លួន ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុត្រូវភិក្ខុអ្នកចោទ ចោទហើយ ក៏ឆ្លើយមិនទាល់ក្នុងដំណើររបស់ខ្លួន នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនលុបគុណគេ មិនប្រឡងវាសនា ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនលុបគុណគេ មិនប្រឡងវាសនា នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនច្រណែន មិនកំណាញ់ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនច្រណែន មិនកំណាញ់ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនអួតអាង មិនមានពុតមាយា ម្នាលអាវុសោទាំងឡាយ

ត្រង់ដែលភិក្ខុជាអ្នកមិនអួតអាង មិនមានពុតមាយា នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនរឹងរូស មិនមើលងាយគេ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនរឹងរូស មិនមើលងាយគេ នេះឯង ជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនប្រកាន់យកតាមតែសេចក្តីឃើញរបស់ខ្លួន មិនប្រកាន់មាំ លះបង់ទិដ្ឋិបានដោយងាយ ម្នាលអាវុសោទាំងឡាយ ត្រង់ដែលភិក្ខុជាអ្នកមិនប្រកាន់យកតាមតែសេចក្តីយល់ឃើញរបស់ខ្លួន មិនប្រកាន់មាំ លះបង់ទិដ្ឋិបានដោយងាយ នេះឯងជាធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ( ១៦ ) ប្រការនេះ ព្រះមានព្រះភាគត្រាស់ហៅថា សោវចស្សករណធម៌ គឺធម៌ជាទីធ្វើឲ្យជាអ្នកប្រដៅងាយ ។

[ ២២៤ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុគួរពិចារណាខ្លួនដោយខ្លួនឯង ក្នុងធម៌ទាំងឡាយ ១៦ នោះយ៉ាងនេះថា បុគ្គលណាជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមកវិញ អាត្មាអញហ្នឹងឯងក៏មុខជាមិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកមានសេចក្តីប្រាថ្នាលាមក មិនត្រូវលុះក្នុងអំណាច

នៃសេចក្តីប្រាថ្នាលាមកឡើយ ។ បុគ្គលណាជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកលើកខ្លួនឯង មិនត្រូវបន្តុះបង្អាប់អ្នកដទៃឡើយ ។ បុគ្គលណា ជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់វិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវជាអ្នកមានសេចក្តីក្រោធគ្របសង្កត់បានឡើយ ។ បុគ្គលណាជាអ្នកក្រោធ ជាអ្នកចងគំនុំ ព្រោះសេចក្តីក្រោធជាហេតុ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្តីក្រោធជាហេតុវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវចងគំនុំព្រោះសេចក្តីក្រោធជាហេតុឡើយ ។ បុគ្គលណា

ជាអ្នកក្រោធ ជាអ្នកជេរប្រទេច ព្រោះសេចក្តីក្រោធជាហេតុ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកក្រោធ ជាអ្នកជេរប្រទេច ព្រោះសេចក្តីក្រោធជាហេតុវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវជាអ្នកជេរប្រទេច ព្រោះសេចក្តីក្រោធជាហេតុឡើយ ។ បុគ្គលណាជាអ្នកក្រោធ បញ្ចេញវាចាជិតសេចក្តីក្រោធ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកក្រោធ បញ្ចេញវាចាជិតសេចក្តីក្រោធវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ គប្បីញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកក្រោធ មិនត្រូវជាអ្នកបញ្ចេញវាចាជិតសេចក្តីក្រោធឡើយ ។ បុគ្គលណា ដែលត្រូវអ្នកចោទចោទហើយ ក៏ទឹងតបតទៅនឹងអ្នកចោទវិញ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញត្រូវអ្នកចោទ ចោទហើយ ក៏ទឹងតបតទៅនឹងអ្នកចោទវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកចោទៗ ហើយ នឹងមិនទឹងតបតទៅនឹងអ្នកចោទវិញឡើយ ។ បុគ្គល

ណាដែលត្រូវអ្នកចោទ ចោទហើយ ក៏បណ្ដោញអ្នកចោទ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនអាត្មាអញដែលត្រូវអ្នកចោទ ចោទហើយ នឹងបណ្ដោញអ្នកចោទវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកចោទ ចោទហើយ នឹងមិនបណ្ដោញអ្នកចោទវិញឡើយ ។ បុគ្គលណាដែលត្រូវអ្នកចោទ ចោទហើយ ក៏និយាយគ្របសង្កត់ដល់អ្នកចោទវិញ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ដែលត្រូវអ្នកចោទ ចោទហើយ នឹងនិយាយគ្របសង្កត់ដល់អ្នកចោទវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកចោទ ចោទហើយ នឹងមិននិយាយគ្របសង្កត់ ដល់អ្នកចោទវិញឡើយ ។ បុគ្គលណា ដែលត្រូវអ្នកចោទ ចោទហើយ ក៏និយាយបន្ទែបន្ទប់នូវអ្នកចោទដោយហេតុដទៃ ឬពាក្យផ្សេងៗ និយាយគេចកែដោយសម្ដីខាងក្រៅ ធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ត និងសេចក្ដីអាក់អន់ចិត្តឲ្យប្រាកដឡើង បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ដែលត្រូវអ្នកចោទៗ ហើយ នឹងនិយាយបន្ទែបន្ទប់នូវអ្នកចោទដោយហេតុដទៃ ឬពាក្យផ្សេងៗ នឹងនិយាយគេចកែដោយសំដីខាងក្រៅ នឹង

ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត ឲ្យប្រាដកឡើង អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងឡើងថា អាត្មាអញបើត្រូវអ្នកចោទៗ ហើយ នឹងមិននិយាយបន្ទែបន្ទប់នូវអ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ នឹងមិននិយាយគេចកែដោយសម្តីខាងក្រៅ នឹងមិនធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើងឡើយ ។ បុគ្គលណាដែលត្រូវអ្នកចោទៗ ហើយ ក៏មិនឆ្លើយក្នុងដំណើររបស់ខ្លួន បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ដែលត្រូវអ្នកចោទៗ ហើយ នឹងមិនឆ្លើយក្នុងដំណើររបស់ខ្លួន អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញបើត្រូវអ្នកចោទៗ ហើយ នឹងត្រូវតែឆ្លើយក្នុងដំណើររបស់ខ្លួន ។ បុគ្គលណាជាអ្នកលុបគុណគេ ជាអ្នកប្រឡងវាសនា បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកលុបគុណគេជាអ្នកប្រឡងវាសនា អាត្មាអញហ្នឹងឯងក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញ៉ាំងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកលុបគុណគេ មិនត្រូវជាអ្នកប្រឡងវាសនាឡើយ ។ បុគ្គលណា ជាអ្នកច្រណែន

មានសេចក្ដីកំណាញ់ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញ ជាអ្នកប្រណែន មានសេចក្ដីកំណាញ់ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកប្រណែន មិនត្រូវមានសេចក្ដីកំណាញ់ឡើយ ។ បុគ្គលណាជាអ្នកអួតអាង ជាអ្នកមានពុតមាយា បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នកអួតអាង ជាអ្នកមានពុតមាយា អាត្មាអញហ្នឹងឯងមុខជានឹងមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកអួតអាង មិនត្រូវជាអ្នកមានពុតមាយាឡើយ ។ បុគ្គលណាជាអ្នករឹងរូស ជាអ្នកមើលងាយគេ បុគ្គលនេះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជាអាត្មាអញជាអ្នករឹងរូស ជាអ្នកមើលងាយគេ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នករឹងរូស មិនត្រូវជាអ្នកមើលងាយគេឡើយ ។ បុគ្គលណា ជាអ្នកប្រកាន់តាមតែសេចក្ដីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ បុគ្គលនេះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញទេ បើប្រសិនជា

អាត្មាអញជាអ្នកប្រកាន់តាមតែសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រវិញ អាត្មាអញហ្នឹងឯង ក៏មុខជាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អ្នកដទៃដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុដឹងយ៉ាងនេះហើយ ត្រូវញុំាងចិត្តឲ្យកើតឡើងថា អាត្មាអញនឹងមិនត្រូវជាអ្នកប្រកាន់តាមតែសេចក្តីឃើញរបស់ខ្លួនឯងឡើយ មិនត្រូវជាអ្នកប្រកាន់មាំ ត្រូវជាអ្នកលះបង់ទិដ្ឋិបានដោយងាយវិញ ។

[ ២២៥ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងក្នុងធម៌ទាំង ១៦ នោះយ៉ាងនោះថា អាត្មាអញជាអ្នកមានសេចក្តីប្រាថ្នាលាមកលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមកឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកមានសេចក្តីប្រាថ្នាលាមក មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមកទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះ

ថា អាត្មាអញជាអ្នកលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញ អាត្មាអញមិនជាអ្នកលើកខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃទេ ។ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញជាអ្នកក្រោធ ជាអ្នកមិនមានសេចក្តីក្រោធគ្របសង្កត់ទេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជតែម្យ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចា-រណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្តីក្រោធជាហេតុឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្តីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់

នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញជាអ្នកមិនក្រោធ ជាអ្នកមិនចងគំនុំព្រោះសេចក្ដីក្រោធជាហេតុទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិនិងបាមោជ្ជតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកជេរប្រទេចព្រោះសេចក្ដីក្រោធជាហេតុឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកជេរប្រទេចព្រោះសេចក្ដីក្រោធជាហេតុ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញជាអ្នកមិនក្រោធ ជាអ្នកមិនជេរប្រទេច ព្រោះសេចក្ដីក្រោធជាហេតុទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុគួរពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកបញ្ឆេញវាចាជិតសេចក្ដីក្រោធឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចាជិតសេចក្ដីក្រោធ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ ត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាល

អាវុសោទាំងឡាយ តែបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញជាអ្នកមិនក្រោធ ជាអ្នកមិនបញ្ចេញវាចាជិតសេចក្តីក្រោធទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយហើយ នៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងទទឹងតបតនឹងអ្នកចោទវិញឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងទទឹងតបតនឹងអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ ត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងមិនទទឹងតបតនឹងអ្នកចោទវិញទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងបណ្តេញអ្នកចោទវិញឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចា-រណាហើយដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងបណ្តេញអ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះត្រូវព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ

តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងមិនបណ្ដោញអ្នកចោទវិញទេ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយ បីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងនិយាយគ្របសង្កត់អ្នកចោទវិញឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងនិយាយគ្របសង្កត់អ្នកចោទវិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គប្បីព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចា-រណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ មិននិយាយគ្របសង្កត់អ្នកចោទវិញទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គប្បីសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួន ដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងនិយាយបន្ទែបន្ទប់អ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ និយាយគេចកែដោយសម្ដីខាងក្រៅ ធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ត និងសេចក្ដីអាក់អន់ចិត្ត ឲ្យប្រាកដឡើងដែរឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ

គេចោទហើយ តែងនិយាយបន្ទែបន្ទប់ ដោយហេតុដទៃឬពាក្យផ្សេងៗ និយាយគេចកែដោយសម្តីខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើងដូច្នេះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គប្បីព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងមិននិយាយបន្ទែបន្ទប់អ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ មិននិយាយគេចកែដោយសម្តីខាងក្រៅ មិនធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើងទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទ ចោទហើយ តែងមិនឆ្លើយក្នុងដំណើររបស់ខ្លួនឬទេ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញដែលត្រូវអ្នកចោទគេចោទហើយ តែងមិនឆ្លើយក្នុងដំណើររបស់ខ្លួនទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គប្បីព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញដែលត្រូវអ្នកចោទ គេចោទហើយ តែងតែឆ្លើយក្នុងដំណើររបស់ខ្លួន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និង

បាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកលុបគុណគេ ជាអ្នកប្រឡូងវាសនាឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកលុបគុណទេ ជាអ្នកប្រឡូងវាសនា ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកលុបគុណគេ ជាអ្នកមិនប្រឡូងវាសនាទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀតភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកប្រណែន ជាអ្នកមានសេចក្តីកំណាញ់ឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកប្រណែន ជាអ្នកមានសេចក្តីកំណាញ់ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកប្រណែន មិនជាអ្នកមានសេចក្តីកំណាញ់ទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សា ក្នុងកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មា

អញ ជាអ្នកអួតអាង ជាអ្នកមានពុតមាយាឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកអួតអាង ជាអ្នកមានពុតមាយា ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាម លះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នកអួតអាង មិនជាអ្នកមានពុតមាយាទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជៈនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នករឹងរូស ជាអ្នកមើលងាយគេឬទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នករឹងរូស ជាអ្នកមើលងាយគេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញមិនជាអ្នករឹងរូស មិនជាអ្នកមើលងាយគេទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរសិក្សា ក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះថា អាត្មាអញជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រឬទេ ។ ម្នាលអាវុសោទាំងឡាយ កាល

*បើភិក្ខុពិចារណាហើយដឹងយ៉ាងនេះថា អាត្មាអញជាអ្នកកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះវិញថា អាត្មាអញ មិនជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនឯង មិនជាអ្នកប្រកាន់មាំ ជាអ្នកលះបង់ទិដ្ឋិបានដោយងាយ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំង-ឡាយ បើភិក្ខុពិចារណាហើយ ឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះក្នុងខ្លួន ដែលខ្លួនមិនទាន់លះបង់បាន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះចេញ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាហើយ ឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះក្នុងខ្លួន ដែលខ្លួនលះបង់បានហើយ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះគួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្រី ឬប្រុសដែលនៅក្មេងជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលឆ្លុះមើលស្រមោលមុខរបស់ខ្លួន ក្នុងកញ្ចក់ដ៏ស្អាតផូរផង់ ឬក្នុងភាជន៍ទឹកដ៏ថ្លា បើឃើញធូលី ឬមុនត្រង់មុខនោះ តែងព្យាយាមជម្រះធូលី ឬមុននោះចេញ បើមិនឃើញធូលី ឬមុនត្រង់មុខនោះទេ រមែងជាអ្នកមានចិត្តត្រេកអរ*

*ដោយហេតុនោះថា អើហ្ន៎ អញមានលាភហើយតើ អើហ្ន៎ អញស្អាតណាស់តើ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាហើយ ឃើញច្បាស់នូវអកុសលធម៌លាមកទាំងអស់នេះ ក្នុងខ្លួនដែលខ្លួនមិនទាន់លះបង់បាន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរព្យាយាមលះបង់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះចេញ ។ ម្នាលអាវុសោទាំងឡាយ តែកាលបើភិក្ខុពិចារណាហើយ ឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងអស់នេះក្នុងខ្លួន ដែលខ្លួនបានលះបង់អស់ហើយ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរសិក្សាក្នុងកុសលធម៌ទាំងឡាយ អស់យប់ និងថ្ងៃ ហើយនៅដោយបីតិ និងបាមោជ្ជនោះតែមួយយ៉ាង ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ បានសម្តែងនូវព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានអំណរត្រេកអរ ចំពោះភាសិតនៃព្រះមហាមោគ្គល្លានដ៏មានអាយុ ។*

***អនុមានសូត្រទី ៥ ចប់***

# អដ្ឋកថា

# អនុមានសូត្រ

[ ២២១ ] *អនុមានសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។*

*បណ្តាបទទាំងនោះ បទថា* **ភគ្គេសុ** *បានដល់ ជនបទមានឈ្មោះយ៉ាងនោះ ។ អត្ថនៃពាក្យគប្បីជ្រាបដោយទំនង ដែលពោលហើយក្នុងទីនេះ ។ បទថា* **សុំសុមារគិរេ** *បានដល់ ក្នុងនគរមានឈ្មោះយ៉ាងនោះ ។ បានឮថា ក្នុងថ្ងៃដែលកំណត់ទីលានសាងនគរនោះ ក្រពើក្នុងស្រះដែលមិនឆ្ងាយអំពីទីនោះ បានស្រែកថ្លូចជាសំឡេង* **គិរៈ គិរៈ** *កាលសាងនគរនោះស្រេចហើយ ទើបមហាជនតាំងឈ្មោះនគរនោះថា* **សុំសុមារគិរៈ** ។ *បទថា* **ភេសក-ឡាវនេ** *បានដល់ ក្នុងព្រៃដែលមានឈ្មោះថា* **ភេសកឡា** ។ *បាលីថា* **ភេសកាវន** *ដូច្នេះក៏មាន ។ បទថា* **មិគទាយេ** *សេចក្តីថា ព្រៃនោះបានកើតក្នុងទីជាទីឲ្យអភ័យដល់ម្រឹគ និងបក្សីទាំងឡាយ ព្រោះដូច្នោះ ទើបហៅថា* **មិគទាយ** ។

[ ២២២ ] *បទថា* **បវារេតិ** *បានដល់ រមែងប្រាថ្នា ។ បទថា* **វទន្តុ** *សេចក្តីថា ចូរស្តីប្រដៅ គឺចូរឲ្យឱវាទ ចូរប្រៀនប្រដៅ ដោយអំណាចនៃឱវាទ និងអនុសាសនី ។ បទថា* **វចនីយោម្ហិ** *សេចក្តីថា ខ្ញុំដែលលោកគប្បីស្តីថា គឺគប្បីប្រៀនប្រដៅ គប្បីឲ្យឱវាទ ។ បទថា* **សោ ច ហោតិ ទុព្វចោ** *សេចក្តីថា ភិក្ខុនោះ ជាអ្នកប្រដៅក្រ គឺទូន្មានហើយមិនអត់ធន់ ។ បទថា*

**ទោវចស្សករណេហិ** *សេចក្តីថា ដោយធម៌ ១៦ ប្រការ ដែលមកហើយខាងមុខ ដែលជាធម៌ធ្វើឲ្យជាអ្នកប្រដៅក្រ ។ បទថា* **អប្បទក្ខិណគ្គាហី អនុសាសនឹ** *សេចក្តីថា ភិក្ខុណា កាលត្រូវទូន្មាន ទើបពោលថា លោកទាំងឡាយទូន្មានខ្ញុំ ព្រោះហេតុអ្វី ខ្ញុំរមែងដឹងវត្ថុដែលគួរ និងមិនគួរ ទោស និងមិនមែនទោស ប្រយោជន៍ និងមិនមែនប្រយោជន៍របស់ខ្លួន ភិក្ខុនេះឈ្មោះថា មិនទទួលពាក្យប្រៀនប្រដៅដោយខាងស្តាំ រមែងទទួលដោយខាងឆ្វេង ព្រោះហេតុនោះ ទើបហៅថា មិនទទួលពាក្យប្រៀនប្រដៅដោយគោរព ។ បទថា* **ចាបកានំ ឥច្ឆានំ** *គឺសេចក្តីប្រាថ្នាដែលញុំាងឲ្យកើតការមិនស្ងប់បាប ។ បទថា* **បដិប្ផរតិ** *គឺរមែងតាំងខ្លួនជាបុគ្គលលើកវាទៈជាសត្រូវ ។ បទថា* **អបសាទេតិ** *សេចក្តីថា រមែងព្យាយាមយ៉ាងនេះថា ខ្ញុំបានពោលហើយដល់លោកថាជាពាល មិនឈ្លាស ធម្មតាលោកនឹងសម្គាល់ពាក្យដែលគប្បីពោល មិនមែនឬ ។ បទថា* **បច្ចារោបេតិ** *សេចក្តីថា ត្រឡប់ជាពោលយ៉ាងនេះថា លោកក៏ត្រូវអាបត្តិ ចូរលោកសម្តែងអាបត្តិនោះចេញ ។ បទថា* **អញ្ញេនញ្ញំ បដិចរតិ** *គឺបិទបាំងដោយរឿងដទៃដោយពាក្យដទៃ ឬបន្ទប់រឿងដទៃដោយពាក្យដទៃ ។ កាលនោះភិក្ខុដទៃពោលថា លោកម្ចាស់ត្រូវអាបត្តិ ក៏ពោលថា អ្នកណាត្រូវ ត្រូវអាបត្តិអ្វី ត្រូវក្នុងទីណា លោកម្ចាស់និយាយជាមួយអ្នកណា លោកម្ចាស់ពោលអ្វី ដូច្នោះ កាលភិក្ខុដទៃពោលថា លោកម្ចាស់បានឃើញអ្វីបែបនេះ ក៏ពោលថា ខ្ញុំនឹងមិនស្តាប់ ដូច្នេះ ។ បទថា* **ពហិទ្ធា កថំ អបនាមេតិ** *សេចក្តីថា ភិក្ខុនោះត្រូវភិក្ខុដែលជាអ្នកចោទសួរថា លោក*

ត្រូវអាបត្តិឈ្មោះនេះ ក៏ពោលថា ខ្ញុំទៅកាន់ក្រុងបាតលិបុត្រ កាលនោះអ្នកចោទ ក៏ពោលទៀតថា ពួកខ្ញុំមិនបានសួរដល់ការទៅក្រុងបាតលិបុត្ររបស់លោកទេ ពួកខ្ញុំសួរដល់អាបត្តិ បន្ទាប់អំពីនោះ ក៏ពោលពាក្យជាដើមថា ខ្ញុំទៅកាន់ក្រុងរាជគ្រឹះ សូមលោកទៅកាន់ក្រុងរាជគ្រឹះ ឬលោកត្រូវអាបត្តិក្នុងស្រុកព្រាហ្មណ៍ លោកបានសាច់ជ្រូកក្នុងស្រុកព្រាហ្មណ៍នោះ ដូច្នេះ ឈ្មោះថា និយាយគេចកែដោយសម្ដីខាងក្រៅ ។ បទថា **អបទានេ** គឺក្នុងការប្រព្រឹត្តរបស់ខ្លួន ។ បទថា **ន សម្បាយតិ** សេចក្ដីថា ភិក្ខុត្រូវភិក្ខុដែលជាអ្នកចោទសួរដល់ការប្រព្រឹត្តដោយន័យជាដើមថា អាវុសោ លោកនៅទីណា លោកអាស្រ័យបុគ្គលណា ឬថា លោកពោលនឹងបុគ្គលណា បុគ្គលនោះត្រូវអាបត្តិដែលខ្ញុំឃើញហើយ ឬក្នុងសម័យនោះ លោកធ្វើអ្វី ខ្ញុំធ្វើអ្វី ឬលោកនៅទីណា ខ្ញុំនៅទីណា ដូច្នេះ ក៏មិនអាចដើម្បីឲ្យពេញចិត្តទូន្មាន ។

[ ២២៤ ] បទថា **តត្រាវុសោ** សេចក្ដីថា នៃអាវុសោ ក្នុងធម៌ ១៦ ប្រការនោះ ។ បទថា **អត្តនាវ អត្តានំ ឯវំ អនុមានិតព្វំ** សេចក្ដីថា គប្បីពិចារណាខ្លួនដោយខ្លួនឯងយ៉ាងនេះ ។

[ ២២៥ ] បទថា **អហោរត្តានុសិក្ខិនា** សេចក្ដីថា ភិក្ខុកាលសិក្សាអស់ថ្ងៃ និងយប់ គប្បីសិក្សាកុសលធម៌ទាំងឡាយអស់យប់ និងថ្ងៃ ញុំាងបីតិ និងបាមោជ្ជនោះឯងឲ្យកើតឡើង ។ បទថា **អជ្ឈេ វា ឧទកបត្តេ** គឺក្នុងភាជន៍ទឹកដ៏ថ្លា ។ បទថា **មុខនិមិត្តំ** បានដល់ ស្រមោលមុខ ។ បទថា **រជំ** បានដល់ ធូលីដែលហុយមក ។ បទថា **អង្គណំ** បានដល់ អាចម៍រុយ ឬពក

ដែលកើតលើផ្ទៃមុខនោះ ។ ព្រះថេរៈសម្ដែងការលះទាំងអស់ ដោយបទនេះថា ដែលអកុសលធម៌ដ៏លាមកទាំងអស់នោះមិនទាន់លះបាន ។ សេចក្ដីនេះដូចម្ដេច សេចក្ដីនេះយ៉ាងនេះ គឺព្រះថេរៈសម្ដែងបដិសង្ខានប្បហានដល់ភិក្ខុដែលញុំាងការពិចារណាឲ្យកើតឡើងថា អកុសលធម៌ប្រមាណប៉ុណ្ណោះ មិនសមគួរដល់បព្វជិត សម្ដែងវិក្ខម្ភនប្បហានដល់ភិក្ខុដែលធ្វើសីលឲ្យជាបទដ្ឋាន ហើយប្រារព្ធកសិណបរិកម្ម ញុំាងសមាបត្តិ ៨ ឲ្យកើតឡើង សម្ដែងតទង្គ-ប្បហានដល់ភិក្ខុដែលធ្វើសមាបត្តិឲ្យជាបទដ្ឋាន ហើយចម្រើនវិបស្សនា សម្ដែងសមុច្ឆេទប្បហានដល់ភិក្ខុអ្នកចម្រើនវិបស្សនា ហើយអប់រំមគ្គ សម្ដែងបដិប្បស្សទ្ធិប្បហាន កាលផលមកហើយ សម្ដែងនិស្សរណប្បហាន កាលនិព្វានមកហើយ ព្រោះដូច្នោះ បហានទាំងអស់ ឈ្មោះថា ព្រះថេរៈសម្ដែងហើយនោះឯងក្នុងសូត្រនេះ ដោយប្រការដូច្នេះ ។ បុរាណាចារ្យទាំងឡាយពោលថា សូត្រនេះ ឈ្មោះថា ភិក្ខុប្បាតិមោក្ខ ។

បុរាណាចារ្យទាំងឡាយពោលថា ភិក្ខុគប្បីពិចារណាមួយថ្ងៃ ៣ ដង ដោយប្រការដូច្នេះ ភិក្ខុចូលទៅកាន់ទីលំនៅអំពីព្រលឹម ហើយអង្គុយពិចា-រណាថា កិលេសមានប្រមាណប៉ុណ្ណោះរបស់អញនៅមានឬហ្ន៎ បើឃើញថាមាន ក៏ត្រូវព្យាយាមលះកិលេសទាំងនោះ បើឃើញថាមិនមាន គប្បីជាអ្នកមានចិត្តរបស់ខ្លួនថា អញបួសល្អហើយ ធ្វើកត្តកិច្ច អង្គុយក្នុងទីសម្រាកពេលយប់ ឬក្នុងទីសម្រាកក្នុងពេលថ្ងៃហើយ គប្បីពិចារណាក្ដី អង្គុយនៅក្នុងលំនៅក្នុងវេលាល្ងាច គប្បីពិចារណាក្ដី កាលមិនអាចពិចារណាដល់ទៅ

មួយថ្ងៃ ៣ ដង ក៏គប្បីពិចារណាមួយថ្ងៃត្រឹមតែ ២ ដង តែបើមិនអាច ពិចារណាបាន ២ ដង ក៏គប្បីពិចារណាត្រឹមតែម្តង បើមិនពិចារណាសោះ មិនសមគួរ ដូច្នេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយ ៕៚

**អនុមានសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ចេតោខិលសូត្រទី ៦

[ ២២៦ ] ខ្ញុំបានស្តាប់យកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ២២៧ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មិនបានលះបង់នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការ និងមិនបានផ្តាច់បង់នូវចំណងរបស់ចិត្តទាំង ៥ ប្រការហើយ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចម្រើនលូតលាស់ ដុះដាលក្នុងធម្មវិន័យនេះដូច្នេះ នេះមិនមែនជាឋានៈទេ ។

[ ២២៨ ] បង្គោលរបស់ចិត្តទាំង ៥ ប្រការដែលភិក្ខុនោះមិនបានលះបង់តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យមិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្តាហើយ ចិត្តរបស់ភិក្ខុនោះមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមឡើយ ។ ចិត្តរបស់ភិក្ខុណាមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់

ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថា ជាបង្គោលរបស់ចិត្តទី ១ ដែល ភិក្ខុនោះមិនបានលះបង់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុសង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងធម៌ ។បេ។ សង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងសង្ឃ ។បេ។ សង្ស័យមិនដាច់ ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា សង្ស័យ មិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងសិក្ខា ចិត្តរបស់ភិក្ខុនោះ មិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាម រឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ ។ ចិត្ត របស់ភិក្ខុណាមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បី ប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវ ព្យាយាមទេ នេះឈ្មោះថា ជាបង្គោលរបស់ចិត្តទី ៤ ដែលភិក្ខុនោះមិនបាន លះបង់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាមនុស្សខឹង ញ័រ មានចិត្តអាក់អន់ ។ មានចិត្តដែលទោសគ្របសង្កត់ហើយ មានចិត្តរឹង រូសក្នុងពួកសព្រហ្មចារី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាមនុស្សខឹងញ័រ មាន ចិត្តអាក់អន់ មានចិត្តដែលទោសគ្របសង្កត់ហើយ មានចិត្តរឹងរូសក្នុងពួក សព្រហ្មចារីហើយ ចិត្តរបស់ភិក្ខុនោះមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿង ដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ ។ ចិត្តរបស់ភិក្ខុណាមិនឱនទៅ ដើម្បីធ្វើព្យា- យាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្ត

ព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថា ជាបង្គោលរបស់ចិត្តទី ៥ ដែលភិក្ខុនោះមិនលះបង់ហើយយ៉ាងនេះ ។ បង្គោលរបស់ចិត្តទាំង ៥ ប្រការនេះ ឈ្មោះថា ភិក្ខុនោះមិនបានលះបង់ហើយ ។

[ ២២៩ ] ចំណងរបស់ចិត្តទាំង ៥ ប្រការ ដែលភិក្ខុនោះមិនបានផ្តាច់បង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ចិត្តរបស់ភិក្ខុនោះមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមឡើយ ។ ចិត្តរបស់ភិក្ខុណា ។បេ។ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថា ជាចំណងរបស់ចិត្តទី ១ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មានភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ( របស់ខ្លួន ) ។បេ។ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់

ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងរូប ( ខាងក្រៅ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកមិនទាន់ប្រាសចាកតម្រេកក្នុងរូប ( ខាងក្រៅទេ ) ។បេ។ នេះឈ្មោះថា ចំណងរបស់ចិត្តទី ៣ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុបរិភោគនូវភោជនជរាបដល់ឆ្អែតពេញផ្ទៃ ហើយប្រកបរឿយៗ នូវទីដេកស្រួល នូវទីផ្អែកស្រួល នូវសេចក្តីលក់ស្រួល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាបរិភោគនូវភោជនជរាបដល់ឆ្អែតពេញផ្ទៃ ហើយប្រកបរឿយៗ នូវទីដេកស្រួល នូវទីផ្អែកស្រួល នូវសេចក្តីលក់ស្រួល ចិត្តរបស់ភិក្ខុនោះ មិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមឡើយ ។ ចិត្តរបស់ភិក្ខុណាមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថា ជាចំណងរបស់ចិត្តទី ៤ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុប្រព្រឹត្តនូវព្រហ្មចរិយធម៌ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬទេវតាមានសក្តិតូចណាមួយដោយសីល ឬវត្ត តបៈ ឬព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តនូវព្រហ្មចរិយធម៌ ប្រាថ្នានូវទេវនិកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬជាទេវតាមានសក្តិតូចណាមួយ ដោយសីល ឬវត្ត តបៈ

ឬព្រហ្មចរិយៈនេះដូច្នេះ ចិត្តរបស់ភិក្ខុនោះមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ ។ ចិត្តរបស់ភិក្ខុណាមិនឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមទេ នេះឈ្មោះថា ជាចំណងរបស់ចិត្តទី ៥ ដែលភិក្ខុនោះមិនបានកាត់ផ្តាច់ហើយយ៉ាងនេះ ។ ចំណងរបស់ចិត្តទាំង ៥ ប្រការនេះ ឈ្មោះថា ភិក្ខុនោះមិនបានកាត់ផ្តាច់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមិនបានលះបង់ នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការនេះ មិនកាត់ផ្តាច់នូវចំណងរបស់ចិត្តទាំង ៥ ប្រការនេះទេ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចម្រើន លូតលាស់ ដុះដាល ក្នុងធម្មវិន័យនេះដូច្នេះ នេះមិនមែនជាឋានៈទេ ។

[ ២៣០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយបានលះបង់នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការ កាត់ផ្តាច់នូវចំណងរបស់ចិត្តទាំង ៥ ប្រការ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចម្រើន លូតលាស់ ដុះដាល ក្នុងធម្មវិន័យនេះដូច្នេះ នេះទើបជាឋានៈ ។

[ ២៣១ ] បង្គោលរបស់ចិត្តទាំង ៥ ប្រការ ដែលភិក្ខុនោះលះបង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លាក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនសង្ស័យ មិនស្នាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លាក្នុងព្រះសាស្តា

ចិត្តរបស់ភិក្ខុនោះឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណាឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមហើយ នេះឈ្មោះថា ជាបង្គោលរបស់ចិត្តទី ១ ដែលភិក្ខុនោះលះបង់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនសង្ស័យ មិនស្ទាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លាក្នុងធម៌ ។បេ។ មិនសង្ស័យ មិនស្ទាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លា ក្នុងសង្ឃ ។បេ។ មិនសង្ស័យ មិនស្ទាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លាក្នុងសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនសង្ស័យ មិនស្ទាក់ស្ទើរ ជឿស៊ប់ ជ្រះថ្លាក្នុងសិក្ខា ចិត្តរបស់ភិក្ខុនោះរមែងឱនទៅ ។បេ។ នេះឈ្មោះជាបង្គោលនៃចិត្តទី ៤ ដែលភិក្ខុនោះលះបង់ហើយយ៉ាងនេះ ម្នាលភិក្ខុទាំង-ឡាយ មួយវិញទៀត ភិក្ខុជាមនុស្សមិនខឹងញ័រ មិនមានចិត្តអាក់អន់ មិនមានចិត្តដែលទោសគ្របសង្កត់ មិនមានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាមនុស្សមិនខឹងញ័រ មិនមានចិត្តអាក់អន់ មិនមានចិត្តដែលទោសគ្របសង្កត់ មិនមានចិត្តរឹងរូស ក្នុងពួកសព្រហ្មចារី ចិត្តរបស់ភិក្ខុនោះរមែងឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណាឱនទៅ ដើម្បីធ្វើព្យាយាម ជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បី

តាំងទុកនូវព្យាយាមហើយ នេះឈ្មោះថា ជាបង្កោលរបស់ចិត្តទី ៥ ដែលភិក្ខុនោះលះបង់ហើយយ៉ាងនេះ ។ បង្កោលរបស់ចិត្តទាំង ៥ ប្រការនេះ ឈ្មោះថា ភិក្ខុនោះលះបង់ហើយ ។

[ ២៣២ ] ចំណងរបស់ចិត្តទាំង ៥ ប្រការ ដែលភិក្ខុនោះកាត់ផ្តាច់ហើយដោយល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ចិត្តរបស់ភិក្ខុនោះរមែងឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ចិត្តរបស់ភិក្ខុណាឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាមហើយ នេះឈ្មោះថា ជាចំណងរបស់ចិត្តទី ១ ដែលភិក្ខុនោះកាត់ផ្តាច់ហើយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាសចាកតម្រេកក្នុងកាយ ( របស់ខ្លួន ) ។បេ។ ប្រាសចាកតម្រេកក្នុងរូប ( ខាងក្រៅ ) ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមិនបរិភោគភោជនដរាបដល់ឆ្អែតពេញផ្ទៃ មិនប្រកបរឿយៗ នូវទីដេកស្រួល នូវទីផ្អែក

ស្រួល និងសេចក្ដីលក់ស្រួល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនបរិភោគ ភោជនដរាបដល់ឆ្អែតពេញផ្ទៃ មិនប្រកបរឿយៗ នូវទីដេកស្រួល នូវទីផ្អែក ស្រួល និងសេចក្ដីលក់ស្រួល ចិត្តរបស់ភិក្ខុនោះ រមែងឱនទៅ ដើម្បីព្យា- យាម ជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្ត ព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ចិត្តរបស់ភិក្ខុណារមែងឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បី ប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម នេះឈ្មោះថាជាចំណង របស់ចិត្តទី ៤ ដែលភិក្ខុនោះកាត់ផ្ដាច់ហើយដោយល្អយ៉ាងនេះ ។ ម្នាលភិក្ខុ ទាំងឡាយ មួយវិញទៀត ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ មិនប្រាថ្នានូវទេវ- និកាយណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតា មានសក្តិធំ ឬ ទេវតាមានសក្តិតូចណាមួយដោយសីល ឬវត្ត តបៈ ឬព្រហ្មចរិយៈនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចរិយធម៌ មិនប្រាថ្នានូវទេវនិកាយ ណាមួយ ដោយគិតថា អាត្មាអញនឹងបានជាទេវតាមានសក្តិធំ ឬទេវតាមាន សក្តិតូចណាមួយ ដោយសីល ឬវត្ត តបៈ ឬព្រហ្មចរិយៈនេះទេ ចិត្តរបស់ ភិក្ខុនោះរមែងឱនទៅ ដើម្បីធ្វើព្យាយាមជាគ្រឿងដុតនូវកិលេស ដើម្បីប្រកប ព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ចិត្តរបស់ភិក្ខុណាតែងឱនទៅ ដើម្បីធ្វើព្យាយាម ជាគ្រឿងដុតនូវកិលេស ដើម្បីប្រកបព្យាយាមរឿយៗ ដើម្បីប្រព្រឹត្តព្យាយាមមិនដាច់ ដើម្បីតាំងទុក នូវព្យាយាម នេះឈ្មោះថា ជាចំណងរបស់ចិត្តទី ៥ ដែលភិក្ខុនោះកាត់ផ្ដាច់

ហើយដោយល្អយ៉ាងនេះ ។ ចំណងរបស់ចិត្តទាំង ៥ ប្រការនេះឯង ឈ្មោះថា ភិក្ខុនោះកាត់ផ្តាច់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយបានលះបង់នូវបង្គោលរបស់ចិត្តទាំង ៥ ប្រការនេះ បានកាត់ផ្តាច់នូវចំណងរបស់ចិត្តទាំង ៥ ប្រការនេះ ។ ភិក្ខុនោះឯងនឹងដល់នូវសេចក្តីចម្រើន លូតលាស់ដុះដាល ក្នុងសាសនានេះដូច្នេះ នេះទើបជាឋានៈ ។

[២៣៣] ភិក្ខុនោះចម្រើននូវឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយវីរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ មានសេចក្តីព្យាយាមជាគម្រប់ ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង ប្រកបដោយអង្គ ១៥ មួយអន្លើដោយសេចក្តីព្យាយាមមាំយ៉ាងនេះហើយ ភិក្ខុនោះ គួរដើម្បីទម្លាយនូវកិលេស គួរដើម្បីត្រាស់ដឹង គួរដើម្បីបាននូវអរហត្តជាអនុត្តរធម៌ដ៏ក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស៊ុតមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ស៊ុតមាន់ទាំងនោះដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ ឲ្យបាប់ក្លិនជាតិមាន់ដោយប្រពៃហើយ ។ មេមាន់នោះ មិនបាច់មានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ កូនមាន់ទាំងនេះ គួរទម្លាយនូវសម្បកស៊ុតដោយចុងក្រចក ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីដូច្នេះ ក៏ពិតមែនហើយ ប៉ុន្តែកូនមាន់ទាំងនោះ គង់ទម្លាយសម្បកស៊ុតដោយចុងក្រចក ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង ១៥ មួយអន្លើ

ដោយសេចក្តីព្យាយាមមាំយ៉ាងនេះហើយ ជាអ្នកគួរដើម្បីទម្លាយ ( នូវកិលេស ) គួរដើម្បីត្រាស់ដឹង គួរដើម្បីបាននូវអរហត្តជាអនុត្តរធម៌ដ៏ក្សេមចាកយោគៈក៏ដូច្នោះដែរ ។ លុះព្រះមានព្រះភាគ បានសម្តែងចេតោខីលសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះ ភាសិតរបស់ព្រះមានព្រះភាគ ។

## ចេតោខីលសូត្រទី ៦ ចប់

## អដ្ឋកថា

## ចេតោខិលសូត្រ

[ ២២៦ ] *ចេតោខិលសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ខ្ញុំបាន ស្ដាប់មកដូច្នេះ ។*

[ ២២៧ ] *ក្នុងចេតោខិលសូត្រនោះ ការដែលចិត្តជាធម្មជាតរឹងត្អឹង ការដែលចិត្តជាចំណាង ការដែលចិត្តជាបង្គោល ឈ្មោះថា* **ចេតោខិលា** *។ បទថា* **ចេតសោ វិនិពន្ធា** *សេចក្ដីថា កិលេសជាគ្រឿងជាប់ស្អិតនៃចិត្ត ព្រោះអត្ថថា ចងចិត្ត ដូចធ្វើទុកក្នុងកណ្ដាប់ដៃ ។ សេចក្ដីចម្រើនដោយសីល ការដុះដាលដោយមគ្គ ការធំទូលាយដោយព្រះនិព្វាន ឬសេចក្ដីចម្រើនដោយសីល សមាធិ ការដុះដាលដោយវិបស្សនាមគ្គ ការបរិបូណ៌ដោយផល និងព្រះនិព្វាន ក្នុងបទជាដើមថា* **វុឌ្ឍឹ** *។*

[ ២២៨ ] *បទថា* **សត្ថរិ កង្ខតិ** *សេចក្ដីថា ភិក្ខុសង្ស័យ ក្នុងព្រះសរីរៈ ឬព្រះគុណរបស់ព្រះសាស្ដា ។ កាលភិក្ខុសង្ស័យក្នុងព្រះសរីរៈ ក៏រមែងសង្ស័យថា ព្រះសរីរៈដែលប្រដាប់ដោយព្រះលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មាន ឬមិនមានហ្ន៎ កាលសង្ស័យក្នុងព្រះគុណ រមែងសង្ស័យថា ព្រះសព្វញ្ញុតញ្ញាណដែលអាចដឹងអតីត អនាគត និងបច្ចុប្បន្ន មាន ឬមិនមានហ្ន៎ ។ បទថា* **វិចិកិច្ឆតិ** *សេចក្ដីថា កាលពិចារណា រមែងសង្ស័យ គឺរមែងដល់នូវសេចក្ដីទុក្ខ រមែងមិនអាចវិនិច្ឆ័យ ។ បទថា* **នាធិមុច្ចតិ** *សេចក្ដីថា រមែងមិនបានទទួលនូវការបង្អោនចិត្តទៅថា ន៎ុះពិតជាដូច្នោះ ។ បទថា*

**ន សម្បសីទតិ** សេចក្តីថា រមែងមិនអាចដើម្បីឈមចុះក្នុងព្រះគុណទាំង-ឡាយ ហើយជ្រះថ្លា ដោយភាពជាអ្នកប្រាសចាកការសន្ទិះសង្ស័យ គឺដើម្បីជាអ្នកអស់សង្ស័យ ។ បទថា **អាតប្បាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការធ្វើសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ។ បទថា **អនុយោ-គាយ** សេចក្តីថា ដើម្បីសេចក្តីព្យាយាមរឿយៗ ។ បទថា **សាតច្ចាយ** សេចក្តីថា ដើម្បីធ្វើបន្តរឿយៗ ។ បទថា **បធានាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការតាំងមាំ ។ បទថា **អយំ បឋមោ ចេតោខិលោ** សេចក្តីថា ការដែលចិត្តជាធម្មជាតិរឹងត្អឹង ពោល គឺការសន្ទិះសង្ស័យក្នុងព្រះសាស្តាប្រការទី ១ នេះ ។ ភិក្ខុនោះរមែងឈ្មោះថា មិនទាន់លះបានហើយដោយហេតុយ៉ាងនេះ ។ បទថា **ធម្មេ** គឺក្នុងព្រះបរិយត្តិធម៌ បដិបត្តិធម៌ និងបដិវេធធម៌ ។ កាលសង្ស័យក្នុងបរិយត្តិធម៌ រមែងសង្ស័យថា បណ្ឌិតទាំងឡាយពោលថា ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក មាន ៨៤០០០ ព្រះធម្មក្ខន្ធនោះនៅមាន ឬមិនមានហ្ន៎ ។ កាលសង្ស័យក្នុងបដិវេធធម៌ រមែងសង្ស័យថា បណ្ឌិតទាំងឡាយពោលថា ការហូរចេញនៃវិបស្សនា ឈ្មោះថា មគ្គ ការហូរចេញនៃមគ្គ ឈ្មោះថា ផល ការរលាស់ចេញនូវសង្ខារទាំងពួង ឈ្មោះថា និព្វាន ដូច្នេះ នុ៎ះនៅមាន ឬមិនមានហ្ន៎ ។ បទថា **សង្ឃេ កង្ខតិ** សេចក្តីថា រមែងសង្ស័យថា ឈ្មោះថា ព្រះសង្ឃដែលជាពួកនៃបុគ្គល ៨ គឺបុគ្គលដែលតាំងនៅក្នុងមគ្គ ៤ តាំងនៅក្នុងផល ៤ ដែលបដិបត្តិបដិបទាបែបនេះដោយអំណាចបទទាំងឡាយ មានបទថា **សុបដិបន្នោ** ជាដើម នៅមាន ឬ

មិនមានហ្ន៎ ។ កាលសង្ស័យក្នុងសិក្ខា ក៏រមែងសង្ស័យថា បណ្ឌិតទាំងឡាយពោលថា ឈ្មោះថា អធិសីលសិក្ខា ឈ្មោះថា អធិចិត្តសិក្ខា ឈ្មោះថា អធិប្បញ្ញាសិក្ខា ដូច្នេះ សិក្ខានោះនៅមាន ឬមិនមានហ្ន៎ ។ បទថា **អយំ បញ្ចមោ** សេចក្តីថា ចិត្តជាធម្មជាតរឹងត្អឹង ដូចក្រោះ ដូចបង្គោល ពោលគឺការរឹងរូសក្នុងសព្រហ្មចារីជាគម្រប់ ៥ ។

[ ២២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកិលេស ជាគ្រឿងហួងហែងទាំង-ឡាយ ។ បទថា **កាមេ** បានដល់ វត្ថុកាមខ្លះ កិលេសកាមខ្លះ ។ បទថា **កាយេ** សេចក្តីថា ក្នុងកាយរបស់ខ្លួន ។ បទថា **រូបេ** សេចក្តីថា ក្នុងរូបខាងក្រៅ ។ បទថា **យាវទត្ថំ** សេចក្តីថា មានប្រមាណតាមដែលត្រូវការ ។ បទថា **ឧទរាវទេហកំ** បានដល់ ពេញពោះ ។ ពិតហើយ ពោះនោះ ហៅថា **ឧទរាវទេហកំ** ព្រោះមិនរលួយ ។ បទថា **សេយ្យសុខំ** សេចក្តីថា សេចក្តីសុខលើគ្រែ និងលើតាំង ឬសេចក្តីសុខក្នុងឧតុ ។ បទថា **បស្សសុខំ** សេចក្តីថា សេចក្តីសុខដែលកើតឡើង ដូចសេចក្តីសុខផ្អៀងខាងស្តាំ ផ្អៀងខាងឆ្វេងរបស់អ្នកដេក បម្រះទៅមក ដូច្នោះ ។ បទថា **មិទ្ធសុខំ** បានដល់ សេចក្តីសុខក្នុងការដេកលក់ ។ បទថា **អនុយុត្តោ** សេចក្តីថា ជាអ្នកប្រកបសេចក្តីព្យាយាម ។ បទថា **បណិធាយ** សេចក្តីថា ប្រាថ្នាហើយ ។ ពិតហើយ ចតុប្បារិសុទ្ធិសីល ឈ្មោះថា **សីល** ក្នុងបទជាដើមថា **សីលេន** ដូច្នេះ ។ ការសមាទានវត្ត ឈ្មោះថា **វត** ។ ការប្រព្រឹត្តសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ឈ្មោះថា **តប** ។ ការវៀរមេថុន ឈ្មោះថា

ព្រហ្មចរិយៈ ។ បទថា **ទេវោ វា ភវិស្សាមិ** សេចក្ដីថា អាត្មាអញនឹងជាទេវតាដែលមានសក្តិធំ ។ បទថា **ទេវញ្ញតរោ វា** សេចក្ដីថា ឬជាទេវតាអង្គណាមួយ ក្នុងបណ្ដាទេវតាមានសក្តិតូច ។

[ ២៣៣ ] សមាធិដែលដល់ហើយ ព្រោះអាស្រ័យការពេញចិត្តក្នុងឥទ្ធិបាទទាំងឡាយ ឈ្មោះថា **ឆន្ទសមាធិ** ។ សង្ខារទាំងឡាយដែលជាប្រធាន ឈ្មោះថា **បធានសង្ខារ** ។ បទថា **សមន្នាគតំ** សេចក្ដីថា ប្រកបដោយធម៌ទាំងនោះ ។ បាទនៃឫទ្ធិ ឬបាទដែលជាឫទ្ធិ ព្រោះដូច្នោះ ទើបឈ្មោះថា **ឥទ្ធិបាទ** ។ ក្នុងបទទាំងឡាយដ៏សេស ក៏មានន័យដូច្នោះឯង ។ សេចក្ដីសង្ខេបក្នុងព្រះសូត្រនេះ មានប្រមាណប៉ុណ្ណោះ ។ ឯសេចក្ដីពិស្ដារមកហើយ ក្នុងឥទ្ធិបាទវិភង្គនោះឯង ។ ឯអត្ថនៃឥទ្ធិបាទនោះបានសម្ដែងហើយក្នុងវិសុទ្ធិមគ្គ ។ បានពោលការលះដោយការសង្កត់ទុកដោយឥទ្ធិបាទ ៤ នេះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីព្យាយាម ដែលគប្បីធ្វើក្នុងទីទាំងពួងថា **ឧស្សោឡ្ហិ** ក្នុងបទនេះថា **ឧស្សោឡ្ហិយេវ បញ្ចមី** ដូច្នេះ ។ បទថា **ឧស្សោឡ្ហិបណ្ណរសង្គសមន្នាគតោ** សេចក្ដីថា បុគ្គលប្រកបដោយអង្គ ១៥ ប្រការ ព្រមទាំងសេចក្ដីព្យាយាមយ៉ាងនេះ គឺការលះបង្គោលរបស់ចិត្ត ៥ ការលះកិលេសជាចំណងចិត្ត ៥ ឥទ្ធិបាទ ៤ សេចក្ដីព្យាយាម ១ ។ បទថា **ភព្វោ** សេចក្ដីថា អនុរូប គឺសមគួរ ។ បទថា **អភិនិព្ពិទាយ** សេចក្ដីថា ដើម្បីទម្លាយកិលេសដោយញាណ ។ បទថា **សម្ពោធាយ** សេចក្ដីថា

ដើម្បីត្រាស់ដឹងនូវមគ្គ ៤ ។ បទថា **អនុត្តរស្ស** សេចក្ដីថា ប្រសើរបំផុត ។ បទថា **យោគក្ខេមស្ស** សេចក្ដីថា ការក្សេមចាកយោគៈ ៤ គឺព្រះអរហត្ត ។ បទថា **អធិគមាយ** សេចក្ដីថា ដើម្បីបានទទួល ។ សព្ទថា **សេយ្យថា** ជានិបាត ចុះក្នុងអត្ថថា ប្រៀបធៀប ។ សព្ទថា **បិ** ជានិបាត ចុះក្នុងអត្ថថា លើកតម្កើង ។ ព្រះមានព្រះភាគទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះដូចម្ដេច ដូច្នេះ ដោយបទទាំង ២ ។ ក្នុងបទនេះថា ស៊ុតរបស់មេមាន់មាន ៨ ខ្ទះ ១០ ខ្ទះ ១២ ខ្ទះ ដូច្នេះ ទោះជាស៊ុតរបស់មេមាន់តិចជាង ឬច្រើនជាងអំពីប្រការដែលពោលហើយក៏ដោយ តែពាក្យនោះ លោកពោលដោយការពីរោះរណ្ដំនៃពាក្យ ។ ពិតហើយ ពាក្យដែលពីរោះរណ្ដំ រមែងមានក្នុងលោកយ៉ាងនេះ ។ បទថា **តានស្សុ** កាត់បទជា **តានិ អស្សុ** សេចក្ដីថា ស៊ុតទាំងនោះគប្បីមាន ។ បទថា **កុក្កុដិយា សម្មា អធិសយិតានិ** សេចក្ដីថា សូម្បីមេមាន់នោះ បើកស្លាបទាំង ២ ក្រាបពងទាំងនោះ ស៊ុតទាំងនោះ ឈ្មោះថា មេមាន់ក្រាបល្អហើយ ។ បទថា **សម្មា បរិសេទិតានិ** សេចក្ដីថា ដែលមេមាន់ឲ្យនូវកម្ដៅអស់កាលដ៏សមគួរ ឈ្មោះថា ឲ្យនូវកម្ដៅដោយល្អ គឺដោយប្រពៃ បានដល់ ធ្វើឲ្យមានកម្ដៅ ។ បទថា **សម្មា បរិភាវិតានិ** សេចក្ដីថា ឈ្មោះថា ក្រាបដោយល្អ គឺដោយប្រពៃអស់កាលដ៏សមគួរ អធិប្បាយថា ឲ្យបានទទួលក្លិនរបស់មេមាន់ ។ បទថា **កិញ្ចាបិ តស្សា កុក្កុដិយា** សេចក្ដីថា មេមាន់នោះធ្វើការមិនប្រមាទ ដោយការធ្វើកិរិយា ៣ យ៉ាងនេះ មិនគប្បីកើតសេចក្ដីប្រាថ្នាយ៉ាងនេះដោយពិត ។ បទថា

**អថខោ ភព្វាវ តេ** *សេចក្តីថា កូនមាន់ទាំងនោះគួរពិតដើម្បីចេញមកដោយសួស្តី ដោយន័យដែលពោលហើយ ។ ពិតហើយ ព្រោះស៊ុតទាំងឡាយដែលមេមាន់នោះព្យាយាមក្រាបដោយអាការ ៣ យ៉ាងនេះ រមែងមិនស្អុយ ក្អាសរបស់ស៊ុតមាន់ទាំងនោះ ក៏នឹងដល់នូវការចាស់ឡើង សម្បកស៊ុតក៏ស្តើង ចុងក្រចកជើង និងចំពុះក៏រឹង ស៊ុតទាំងឡាយក៏នឹងចាស់ដោយជុំវិញ ពន្លឺខាងក្រៅក៏ប្រាកដខាងក្នុង ព្រោះសម្បកស្តើង ព្រោះដូច្នោះ ទើបកូនមាន់ទាំងឡាយប្រាថ្នានឹងចេញ ដោយគិតថា អញបត់ស្លាប បត់ជើងនៅក្នុងទីចង្អៀតយូរហើយហ្ន៎ ឥឡូវនេះ ពន្លឺខាងក្រៅក៏ប្រាកដ ពួកយើងនឹងនៅជាសុខក្នុងទី ដែលមានពន្លឺនោះ ដូច្នេះ ។ ហើយក៏ទធាក់សម្បកដោយជើង អើតកចេញ បន្ទាប់អំពីនោះ សម្បកនោះក៏បែកចេញជា ២ ចំណែក តមក កូនមាន់ទាំងឡាយ ក៏ទទះស្លាបស្រែកយំ ចេញមកតាមសមគួរដល់ខណៈនោះឯង កាលចេញមកហើយ ក៏នឹងត្រាច់រកស៊ីតាមគាមខេត្ត ។ បទថា* **ឯវមេវ ខោ** *នេះ មានអត្ថថា ប្រៀបធៀបអ្នកប្រាជ្ញ ប្រៀបធៀបដោយអត្ថនេះហើយ គប្បីជ្រាប ។ គប្បីជ្រាបភាពដែលភិក្ខុនេះ ជាអ្នកដល់ព្រមដោយអង្គ ១៥ រួមសេចក្តីឧស្សាហ៍ ដូចមេមាន់នោះធ្វើកិរិយា ៣ យ៉ាង ក្នុងស៊ុតទាំងឡាយ ដូច្នោះ ការមិនវិនាសនៃវិបស្សនាញាណ ព្រោះដល់ព្រមដោយអនុបស្សនា ៣ យ៉ាង របស់ភិក្ខុដែលប្រកបដោយអង្គ ១៥ ដូចភាពដែលស៊ុតទាំងឡាយមិនស្អុយ ព្រោះការដល់ព្រមដោយកិរិយា ៣ យ៉ាង របស់មេមាន់ ដូច្នោះ ការកាន់យកក្អាស គឺការប្រាថ្នាដែលប្រព្រឹត្តទៅក្នុងភព ៣*

*ដោយការដល់ព្រមដោយអនុបស្សនា ៣ យ៉ាងរបស់ភិក្ខុនោះ ដូចការចាស់ដោយជុំវិញនៃក្តាសរបស់ស៊ុតទាំងឡាយ ដោយការធ្វើកិរិយា ៣ យ៉ាងរបស់មេមាន់ ដូច្នោះ ការដែលសម្បកពង គឺអវិជ្ជារបស់ភិក្ខុជាធម្មជាតស្រាលស្តើង ដូចការដែលសម្បកពងជាធម្មជាតស្តើង ដូច្នោះ ការដែលវិបស្សនាញាណរបស់ភិក្ខុជាធម្មជាតមុតរឹង ផូរផង់ និងខ្លាំងក្លា ដូចចុងក្រចកជើង និងចំពុះរបស់កូនមាន់ទាំងឡាយជាធម្មជាតរឹងមាំ ដូច្នោះ កាលផ្លាស់ប្តូរ កាលចម្រើនហើយ កាលនៃការកាន់បន្ទប់នៃវិបស្សនាញាណរបស់ភិក្ខុ ដូចការប្រែប្រួលទៅនៃកូនមាន់ ដូច្នោះ កាលដែលភិក្ខុនោះឲ្យកាន់បន្ទប់គឺវិបស្សនាញាណត្រាច់ទៅ បានឧតុសប្បាយ ភោជនសប្បាយ បុគ្គលសប្បាយ ឬធម៌ចំណែកសប្បាយ ដែលកើតអំពីវិបស្សនាញាណនោះ អង្គុយលើអាសនៈ ១ ចម្រើនវិបស្សនា ទម្លាយសម្បក គឺអវិជ្ជាដោយអរហត្តមគ្គសម្រេចហើយដោយលំដាប់ ទទះស្លាប គឺអភិញ្ញា ហើយសម្រេចអរហត្តដោយសួស្តី ដូចកូនមាន់ទាំងឡាយទជាក់សម្បកពងដោយចុងក្រចក ឬដោយចំពុះ ហើយទទះស្លាបចេញមកដោយសួស្តី ដូច្នោះ ។ ឯមេមាន់ដឹងកូនមាន់ទាំងឡាយចាស់ហើយ ទម្លាយសម្បក យ៉ាងណា ព្រះសាស្តាក៏ដូច្នោះដូចគ្នា ទ្រង់ដឹងការចាស់នៃញាណរបស់ភិក្ខុបែបនោះហើយ ទ្រង់ផ្សាយឱភាសហើយទ្រង់ទម្លាយសម្បក គឺអវិជ្ជាដោយគាថាជាដើមថា*

*អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន*

ព្រះសុគតសម្តែងទុកហើយ ។

ភិក្ខុនោះទម្លាយសម្បក គឺអវិជ្ជា ហើយសម្រេចអរហត្តក្នុងវេលាចប់ព្រះគាថា ។ ចាប់ពីពេលនោះ កូនមាន់ទាំងនោះ ញុាំងគាមខេត្តឲ្យស្រស់ស្អាត ត្រាច់ទៅក្នុងគាមខេត្តនោះ យ៉ាងណា ភិក្ខុនេះជាព្រះមហាខីណាស្រព សម្រេចផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ហើយញុាំងសង្ឃារាមឲ្យស្អាត ត្រាច់ទៅ ដូច្នោះ ។ លោកសម្តែងបហាន ៤ យ៉ាង ក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។ សេចក្តីនេះដូចម្តេច លោកសម្តែងបដិសង្ខានប្បហាន ដោយការលះបង្គោលដោតចិត្តទាំងឡាយ លះកិលេសជាចំណងចិត្តទាំងឡាយ សម្តែងវិក្ខម្ភនប្បហាន ដោយឥទ្ធិបាទទាំងឡាយ សម្តែងសមុច្ឆេទប្បហាន កាលមគ្គមកហើយ សម្តែងបស្សទ្ធិប្បហាន កាលផលមកហើយ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយដូច្នេះ ។៚

## ចេតោខីលសូត្រ ចប់

## សូត្រទី ៦ ចប់

# សុត្តន្តបិដក

## វនបត្ថសូត្រទី ៧

[ ២៣៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវហេតុនៃការនៅក្នុងព្រៃដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់ ធ្វើទុកក្នុងចិត្តនូវហេតុនោះដោយប្រពៃចុះ តថាគតនឹងសម្តែងឥឡូវនេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ២៣៥ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលខ្លួនមិនទាន់បានដល់ ក៏នៅតែមិនទាន់បានដល់ដដែល គ្រឿងបម្រុងជីវិត គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារណាមួយនេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលអាត្មាអញមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់ដដែល គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារឯណា ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចៀសចេញចាកដងព្រៃនោះ ក្នុងចំណែកនៃរាត្រី ឬក្នុងចំណែកនៃថ្ងៃ មិនត្រូវនៅក្នុងដងព្រៃនោះឡើយ ។

[ ២៣៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលនៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់ដដែល គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំង

នោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលទៅអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលទៅអាស្រ័យនូវដងព្រៃនេះ ចិត្តដែលមិនតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់ដដែល គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ចយភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដូចអាត្មាអញចូលទៅអាស្រ័យនូវដងព្រៃនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលអាត្មាអញមិនទាន់បានដល់ ក៏នៅតែមិនទាន់បានដល់ដដែល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបើដឹង ( នូវកិរិយាមិនដល់នូវសមណធម៌យ៉ាងនេះហើយ ) ត្រូវចេញចាកដងព្រៃនោះ មិនត្រូវនៅ ( ក្នុងដងព្រៃនោះឡើយ ) ។

[ ២៣៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏បានដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្ត ជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនទាន់បានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនទាន់បានខ្ជាប់ខ្ជួន ក៏ខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុតដែលមិនទាន់ដល់ អាត្មាអញក៏បានដល់ដោយលំដាប់ផង ។ គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ច័យ-

ភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដូចអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនទាន់បានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនទាន់ខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ អាត្មាអញក៏បានដល់ដោយលំដាប់ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ បើពិចារណាឃើញ ( យ៉ាងនេះ ) ហើយ គប្បីនៅក្នុងដងព្រៃនោះមិនត្រូវចៀសចេញទេ ។

[ ២៣៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវដងព្រៃណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវដងព្រៃនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏ខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ កាលអាត្មាអញចូលមកអាស្រ័យនូវដងព្រៃនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួនក៏ខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅ

ផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បាន ដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌ-បាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីនៅក្នុងដងព្រៃនោះ ដរាបដល់អស់ជីវិត មិនត្រូវចៀសចេញទេ ។

[ ២៣៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនៅស្រុកណាមួយ ។បេ។ ចូលទៅអាស្រ័យនូវនិគមណាមួយ ។បេ។ ចូលទៅអាស្រ័យនូវក្រុងណាមួយ ។បេ។ ចូលទៅអាស្រ័យនូវជនបទណាមួយ ។បេ។ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនដល់ដដែល គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែ

មិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់អាត្មាអញ ក៏នៅតែមិនដល់ដដែល គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារឯណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនបាច់លាបុគ្គលនោះទេ គប្បីចៀសចេញទៅក្នុងចំណែកនៃរាត្រី ឬក្នុងចំណែកនៃថ្ងៃ មិនគប្បីដើរតាម ( បុគ្គលនោះ ) ឡើយ ។

[ ២៨០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះ ចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនទាន់ខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ ក៏នៅតែមិនទាន់ដល់តាមលំដាប់ គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញ

ចូលមកអាស្រ័យបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈដែលមិនទាន់អស់ទៅ ក៏នៅតែមិនទាន់ដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់ដល់ អាត្មាអញក៏នៅតែមិនទាន់បានដល់តាមលំដាប់ គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើងដោយមិនលំបាក អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ចយភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដួចអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏នៅតែមិនបានតាំងមាំដដែល ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏នៅតែមិនខ្ជាប់ខ្ជួនដដែល អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏នៅតែមិនដល់នូវកិរិយាអស់ទៅដដែល ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ អាត្មាអញក៏នៅតែមិនទាន់បានដល់តាមលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះពិចារណាឃើញ ( យ៉ាងនេះ ) ហើយមិនបាច់លាបុគ្គលនោះទេ គប្បីចៀសចេញទៅ មិនត្រូវដើរតាមទេ ។

[ ២៤១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែល

មិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនបានខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វ-ជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះក៏កើតឡើងដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ អាត្មាអញក៏បានដល់តាមលំដាប់ផង គ្រឿងបម្រុងជីវិតទាំង-ឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះក៏កើតឡើងដោយលំបាក អាត្មាអញចេញចាកផ្ទះមកបួសនេះសោត ព្រោះហេតុតែចីវរក៏ទេ អាត្មាអញចេញចាកផ្ទះមកបួស ព្រោះហេតុតែបិណ្ឌបាតក៏ទេដែរ ព្រោះហេតុតែសេនាសនៈក៏ទេដែរ ព្រោះហេតុតែគិលានប្បច្ច័យភេសជ្ជបរិក្ខារក៏ទេដែរ តាំងពីដួចអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនបានខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើង

ផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តដ៏ជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ អាត្មាអញក៏បានដល់តាមលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបើពិចារណាឃើញ ( យ៉ាងនេះ ) ហើយ ត្រូវដើរតាមបុគ្គលនោះ មិនត្រូវចៀសចេញទេ ។

[ ២៤២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវបុគ្គលណាមួយ កាលភិក្ខុនោះចូលទៅអាស្រ័យនូវបុគ្គលនោះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ ក៏បានដល់តាមលំដាប់ផង គ្រឿងបរិក្ខារជីវិតទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារណានេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបរិក្ខារជីវិតទាំងនោះក៏កើតឡើងដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ កាលអាត្មាអញចូលមកអាស្រ័យនូវបុគ្គលនេះ សតិដែលមិនបានតាំងមាំ ក៏បានតាំងមាំឡើងផង ចិត្តដែលមិនបានខ្ជាប់ខ្ជួន ក៏បានខ្ជាប់ខ្ជួនឡើងផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវកិរិយាអស់ទៅផង ធម៌ដ៏ក្សេមចាកយោគៈ គឺអរហត្តជាធម៌ប្រសើរបំផុត ដែលមិនទាន់បានដល់ អាត្មាអញក៏បានដល់តាមលំដាប់ផង គ្រឿងបរិក្ខារជីវិតទាំង-

ឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារណា នេះ ដែលបព្វជិតគប្បីប្រមូលមក គ្រឿងបម្រុងជីវិតទាំងនោះ ក៏កើតឡើង ដោយមិនលំបាក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះទោះបីបុគ្គលនោះបណ្ដេញ ចេញក៏ដោយ ត្រូវតែដើរតាម មិនត្រូវចៀសចេញចាកបុគ្គលនោះដរាបដល់ អស់ជីវិត ។ លុះព្រះមានព្រះភាគ បានសម្ដែងវនបត្ថសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានសេចក្ដីពេញចិត្ត ត្រេកអរនឹងភាសិតរបស់ព្រះមាន ព្រះភាគ ។

**វនបត្ថសូត្រទី ៧ ចប់**

## អដ្ឋកថា

## វនបត្ថបរិយាយសូត្រ

[ ២៣៤ ] វនបត្ថបរិយាយសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្តាប់មកដូច្នេះ ។

បទថា **វនបត្ថបរិយាយំ** បានដល់ ហេតុនៃការនៅក្នុងព្រៃជ្រៅ ឬការ សម្តែងការនៅក្នុងព្រៃជ្រៅ ។

[ ២៣៥ ] បទថា **វនបត្ថំ ឧបនិស្សាយ វិហរតិ** សេចក្តីថា ភិក្ខុ អាស្រ័យសេនាសនៈក្នុងដងព្រៃ ដែលផុតចាកវត្ថុចោមរោមរបស់មនុស្ស ហើយប្រព្រឹត្តសមណធម៌ ។ ក្នុងបទថា **អនុបដ្ឋិតា** ជាដើម មានអធិប្បាយ ថា កាលលោកចូលទៅអាស្រ័យព្រៃជ្រៅនោះ សតិដែលមិនទាន់ប្រាកដក្នុង កាលមុន ក៏មិនប្រាកដ ចិត្តដែលមិនដែលតាំងមាំក្នុងកាលមុន ក៏មិនតាំងមាំ អាសវៈទាំងឡាយដែលមិនទាន់អស់ទៅក្នុងកាលមុន ក៏មិនដល់នូវការអស់ ទៅ ភិក្ខុនោះ មិនបានសម្រេចអរហត្ត ពោល គឺមានឱកាសទូលាយចាក យោគៈដ៏ខ្ពស់ ដែលមិនបានសម្រេចក្នុងកាលមុន ។ បទថា **ជីវិតបរិក្ខារា** គឺគ្រឿងបម្រុងជីវិត ។ បទថា **សមុទានេតព្វា** បានដល់ គប្បីនាំមកព្រម ។ បទថា **កសិរេន សមុទាគច្ឆន្តិ** គឺកើតឡើងដោយលំបាក ។ បទថា **រត្តិភាគំ វា ទិវសភាគំ វា** បានដល់ ក្នុងចំណែកពេលយប់ ឬក្នុងចំណែក ពេលថ្ងៃ ។ ក្នុងទីនោះ ភិក្ខុពិចារណានៅក្នុងចំណែកពេលយប់ ដឹងហើយ គួរចៀសចេញទៅក្នុងរាត្រីនោះឯង កាលផ្លូវរារាំងដោយសត្វសាហាវជាដើម

ក្នុងពេលរាត្រីមាន គួរវង់ចាំអរុណរះឡើង ដឹងក្នុងចំណែកពេលថ្ងៃ គួរចៀស ទៅក្នុងចំណែកពេលថ្ងៃនោះឯង កាលបើផ្លូវមានឧបសគ្គក្នុងពេលថ្ងៃ គួរវង់ចាំព្រះអាទិត្យលិច ។

[ ២៣៦ ] បទថា **សង្ខាបិ** សេចក្តីថា ដឹងភាពដែលសមណធម៌មិនសម្រេចយ៉ាងនេះ ។ បទថា **អនន្តរវារេ បន សង្ខាបិ** សេចក្តីថា ដឹងភាពដែលសមណធម៌សម្រេចយ៉ាងនេះ ។

[ ២៣៨ ] បទថា **យាវជីវំ** សេចក្តីថា ជីវិតនៅប្រព្រឹត្តទៅដរាបណា គួរដរាបនោះឯង ។

[ ២៣៩-២៤១ ] បទថា **សោ បុគ្គលោ** ភ្ជាប់ជាមួយបទនេះថា **ឆានុពន្ធិតព្វោ** ។ ក្នុងបទថា **អនាបុច្ឆា** អធិប្បាយថា ភិក្ខុនោះ មិនត្រូវប្រាប់បុគ្គលនោះ គួរចៀសចេញទៅ ។ បទថា **សង្ខាបិ** សេចក្តីថា ភិក្ខុដឹងការដែលសមណធម៌មិនសម្រេចយ៉ាងនេះ មិនគួរជាប់ជំពាក់នឹងបុគ្គលនោះ គួរប្រាប់បុគ្គលនោះ ចៀសចេញទៅ ។ បទថា **អបិ សមុជ្ជមានេនបិ** បានដល់ សូម្បីត្រូវបណ្តេញក៏ដោយ ។ បុគ្គលបែបនេះ បើឲ្យនាំឈើ ១០០ ខ្សាច់ ទឹក ១០០ ក្អម ឬខ្សាច់ ១០០ ថង់ ឬបណ្តេញចេញដោយពាក្យថា លោកកុំនៅក្នុងទីនេះ ក៏គួរសូមអភ័យទោសអំពីបុគ្គលនោះ គប្បីនៅរហូតអស់ជីវិតនោះឯង ។៚

**វនបត្ថបរិយាយសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## មធុបិណ្ឌិកសូត្រទី ៨

[ ២៤៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលកាន់ក្រុងកបិលវត្ថុ ដើម្បីបិណ្ឌបាត ។ កាលព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅបិណ្ឌបាត ក្នុងក្រុងកបិលវត្ថុ លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ទ្រង់ស្តេចសំដៅទៅកាន់ព្រៃមហាវ័ន លុះដល់ហើយ ក៏ស្តេចចូលទៅកាន់ព្រៃមហាវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ ទើបគង់នៅក្នុងវេលាថ្ងៃ ទៀបគល់ផ្ចៅសាវ ។ មានសក្យៈមួយរូបឈ្មោះទណ្ឌបាណិ ដើរទៅដើរមកឲ្យស្រួលជើង ក៏ដើរសំដៅទៅព្រៃមហាវ័ន លុះទៅដល់ហើយក៏ចូលទៅកាន់ព្រៃមហាវ័ន ហើយសំដៅទៅរកព្រះមានព្រះភាគ ដែលគង់ទៀបគល់ផ្ចៅសាវនោះ លុះចូលទៅដល់ហើយក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយ ក៏ច្រត់ចុះនូវដំបងឈរ ( ស្ងប់ចង្កា ) នៅក្នុងទីដ៏សមគួរ ។ លុះទណ្ឌបាណិសក្យៈឈរនៅក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា សមណៈអ្នកប្រកាន់នូវទិដ្ឋិដូចម្តេច តែងពោលនូវទិដ្ឋិដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអាវុសោ ក្នុងលោក ( នេះ ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រម

ទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានបុគ្គលអ្នកប្រកាន់ទិដ្ឋិយ៉ាងណា ដែលមិនមានជម្លោះ ទាស់ទែងដោយបុគ្គលណាមួយក្នុងលោក មួយទៀត កិលេសសញ្ញាទាំងឡាយ មិនបានជាប់តាមនូវខីណាសវព្រាហ្មណ៍នោះ ដែលជាអ្នកប្រាសចាកកាមទាំងឡាយ មិនមានសេចក្ដីងឿងឆ្ងល់ ផ្ដាច់បង់នូវសេចក្ដីស្ដាយក្រោយ និងការរពិសដៃជើង ប្រាសចាកសេចក្ដីប្រាថ្នា ក្នុងភពតូច និងភពធំយ៉ាងណា ម្នាលអាវុសោ តថាគតក៏ប្រកាន់ទិដ្ឋិយ៉ាងនោះ ពោលទិដ្ឋិយ៉ាងនោះដែរ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ទើបទណ្ឌបាណិសក្យៈងក់ក្បាល លៀនអណ្ដាត ហើយដាក់ម្រាមដៃលើថ្ងាសដែលមានផ្នត់ ៣ ក្រោកឡើងកាន់ឈើច្រត់ចៀសចេញទៅ ។

[ ២៤៤ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ទ្រង់ពុទ្ធដំណើរទៅកាន់និគ្រោធារាម លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលាបុព្វណ្ហសម័យនេះ ចូលទៅក្រុងកបិលវត្ថុ ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងកបិលវត្ថុហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាបច្ឆាភត្តក៏សំដៅទៅព្រៃមហាវ័ន ចូលទៅកាន់ព្រៃមហាវ័ន ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃទៀបគល់នៃឈើព្នៅសាវ ។ ម្នាលភិក្ខុទាំងឡាយ ទណ្ឌបាណិសក្យៈ

ដើរទៅដើរមកឲ្យស្រួលជើង ក៏ដើរសំដៅមកព្រៃមហាវ័ន លុះចូលមកកាន់ព្រៃមហាវ័នហើយ ក៏បានចូលមករកតថាគត ដែលអង្គុយទៀបដើមព្នៅសាវ លុះចូលមកដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលមួយអន្លើដោយតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏ច្រត់ចុះនូវដំបង ឈរ ( ស្ងប់ចង្កា ) នៅក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទណ្ឌបាណិសក្យៈឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា សមណៈប្រកាន់ទិដ្ឋិដូចម្តេច ពោលទិដ្ឋិដូចម្តេច កាលបើទណ្ឌបាណិសក្យៈសួរយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ តថាគតក៏ពោលពាក្យនេះនឹងទណ្ឌបាណិសក្យៈថា ម្នាលអាវុសោ ក្នុងលោក ( នេះ ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានបុគ្គលប្រកាន់យ៉ាងណា ដែលមិនមានជម្លោះ ទាស់ទែងដោយបុគ្គលណាមួយក្នុងលោក មួយទៀត កិលេសសញ្ញាទាំងឡាយ មិនបានជាប់តាមនូវខីណាសវព្រាហ្មណ៍នោះ ដែលប្រាសចាកកាមទាំងឡាយ មិនមានសេចក្តីងឿងឆ្ងល់ ផ្តាច់បង់នូវសេចក្តីស្តាយក្រោយ និងការរពឹសដៃជើង ប្រាសចាកសេចក្តីប្រាថ្នាក្នុងភពតូច និងភពធំ យ៉ាងណា ម្នាលអាវុសោ តថាគតក៏ប្រកាន់ទិដ្ឋិយ៉ាងនោះ ពោលទិដ្ឋិយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតពោលយ៉ាងនេះហើយ ទណ្ឌបាណិសក្យៈងក់ក្បាល លៀនអណ្តាត ហើយដាក់ម្រាមដៃលើថ្ងាសដែលមានផ្នត់ ៣ ហើយក្រោកឡើងកាន់ដំបង

ចេញទៅ ។

[ ២៤៥ ] កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងលោក ( នេះ ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រះមានព្រះភាគប្រកាន់ទិដ្ឋិដូចម្តេច ដែលមិនមានជម្លោះទាស់ទែងដោយបុគ្គលណាមួយក្នុងលោក បពិត្រព្រះអង្គដ៏ចម្រើន កិលេសសញ្ញាទាំងឡាយ មិនបានជាប់តាមនូវខីណាសវព្រាហ្មណ៍នោះ ដែលប្រាសចាកកាមទាំងឡាយ មិនមានសេចក្តីងឿងឆ្ងល់ ផ្តាច់បង់នូវសេចក្តីស្តាយក្រោយ និងការរពឹសដៃជើង ប្រាសចាកសេចក្តីប្រាថ្នាក្នុងភពតូច និងភពធំយ៉ាងណា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សេចក្តីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បីប្រកាន់ ( ថាអញ ថាយើង ) បើមិនមានក្នុងសភាវៈនោះទេ សេចក្តីមិនត្រេកអរជាដើមនោះឯង ហៅថា ទីបំផុតនៃរាគានុស័យ ហៅថា ទីបំផុតនៃបដិឃានុស័យ ហៅថា ទីបំផុតនៃទិដ្ឋានុស័យ ហៅថា ទីបំផុតនៃវិចិកិច្ឆានុស័យ ហៅថា ទីបំផុតនៃមានានុស័យ ហៅថា ទីបំផុតនៃភវរាគានុស័យ ហៅថា ទីបំផុតនៃអវិជ្ជានុស័យ ហៅថា ទីបំផុតនៃការកាន់ដំបង កាន់សស្ត្រា ជម្លោះ បង្កហេតុ ទាស់ទែង ពោលពាក្យស៊កសៀត ថាឯង ថាមឹង និងពាក្យមុសាវាទ អកុសលធម៌ទាំងឡាយដ៏លាមក

នេះ រមែងរលត់ទៅវិញ ដោយមិនសេសសល់ក្នុងសភាវៈ ១២ នុ៎ះ ។ លុះព្រះសុគតទ្រង់ត្រាស់ដូច្នេះហើយ ក៏ក្រោកចាកអាសនៈហើយទ្រង់ស្តេចចូលទៅកាន់វិហារ ។

[ ២៤៦ ] កាលដែលព្រះមានព្រះភាគស្តេចចេញទៅមិនយូរប៉ុន្មាន ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគរបស់យើងទាំងឡាយ សម្តែងឧទ្ទេសនេះ ដោយបង្រួញ មិនបានចែកអត្ថដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សេចក្តីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បីប្រកាន់ ( ថាអញ ថាយើង ) បើមិនមានក្នុងសភាវៈនោះទេ សេចក្តីមិនត្រេកអរជាដើមនោះឯង ហៅថា ទីបំផុតនៃរាគានុស័យ ហៅថា ទីបំផុតនៃបដិឃានុស័យ ហៅថា ទីបំផុតនៃវិចិកិច្ឆានុស័យ ហៅថា ទីបំផុតនៃមានានុស័យ ហៅថា ទីបំផុតនៃភវរាគានុស័យ ហៅថា ទីបំផុតនៃអវិជ្ជា-នុស័យ ហៅថា ទីបំផុតនៃការកាន់ដំបង កាន់សស្ត្រា ជម្លោះ បង្កហេតុទាស់ទែង ពោលពាក្យសិកសៀត ថាឯង ថាមឹង និងពាក្យមុសា អកុ-សលធម៌ទាំងឡាយដ៏លាមកនេះ រមែងរលត់ទៅមិនសេសសល់ ក្នុងសភាវៈនុ៎ះ ដូច្នេះហើយ ក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈ ចូលទៅកាន់វិហារទៅ ភិក្ខុណាហ្ន៎ គប្បីចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែងដោយបង្រួញ មិនចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន ។ ទើបភិក្ខុទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា មហាកច្ចានៈដ៏មានអាយុនេះឯង ព្រះ

សាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញក៏សរសើរដែរ មានតែព្រះកច្ចានៈដ៏មានអាយុនេះ ទើបអាចនឹងចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែងដោយបង្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន បើដូច្នោះ គួរយើងទាំងឡាយ ចូលទៅរកមហាកច្ចានៈដ៏មានអាយុនោះ លុះចូលទៅដល់ ហើយគប្បីសាកសួរនូវសេចក្តីនេះ នឹងមហាកច្ចានៈដ៏មានអាយុ ។ ទើបភិក្ខុទាំងនោះ នាំគ្នាចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងមហាកច្ចានៈដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះ នឹងមហាកច្ចានៈដ៏មានអាយុថា ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគរបស់យើងទាំងឡាយ សម្តែងឧទ្ទេសនេះ ដោយសេចក្តីបង្រួញ មិនទាន់បានចែកសេចក្តីដោយពិស្តារថា ម្នាលភិក្ខុចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្តីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។បេ។ អកុសលធម៌ទាំងឡាយដ៏លាមកនេះ តែងរលត់ទៅវិញដោយមិនសេសសល់ក្នុងសភាវៈនោះ ដូច្នេះហើយ ក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ម្នាលអាវុសោកច្ចានៈ កាលបើព្រះមានព្រះភាគរបស់យើងទាំងឡាយ ស្តេចចេញទៅមិនយូរប៉ុន្មាន យើងទាំងនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះមានព្រះភាគរបស់យើង សម្តែងឧទ្ទេស

នេះដោយសេចក្ដីបង្រួញ មិនទាន់បានចែកសេចក្ដីដោយពិស្ដារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញា រមែងប្រព្រឹត្តទៅតាមបុរសព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្ដីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។បេ។ អកុសលធម៌ទាំងឡាយដ៏លាមកនេះ រមែងរលត់ទៅវិញដោយមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយ ក៏ស្រាប់តែស្ដេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ភិក្ខុណាហ្ន៎គប្បីចែកសេចក្ដីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយបង្រួញ មិនទាន់ចែកអត្ថឲ្យពិស្ដារនេះ ឲ្យពិស្ដារទៅបាន ។ ម្នាលអាវុសោកច្ចានៈ យើងទាំងអស់គ្នានេះមានសេចក្ដីត្រិះរិះដូច្នេះទៀតថា ម្នាលអាវុសោទាំងឡាយ មហាកច្ចានៈដ៏មានអាយុនេះ ព្រះសាស្ដាទ្រង់សរសើរ ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញក៏សរសើរដែរ មានតែមហាកច្ចានៈដ៏មានអាយុនេះ ទើបអាចនឹងចែកសេចក្ដីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយសេចក្ដីបង្រួញ មិនទាន់បានចែកសេចក្ដីឲ្យពិស្ដារទៅបាន បើដូច្នោះ គួរតែយើងទាំងឡាយចូលទៅរកមហាកច្ចានៈដ៏មានអាយុនោះ លុះចូលទៅដល់ហើយ គប្បីសាកសួរនូវសេចក្ដីនេះនឹងមហាកច្ចានៈដ៏មានអាយុថា សូមមហាកច្ចានៈដ៏មានអាយុចែក ( សេចក្ដីនេះឲ្យទាន ) ។

[២៤៧] មហាកច្ចានៈដ៏មានអាយុឆ្លើយថា ម្នាលអាវុសោ ដូចបុរសជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ដើរទៅកាន់ទីស្វែងរកខ្លឹមឈើ ហើយដើរហួសខ្លឹមឈើធំ ដែលនៅក្នុងទីនោះ ដើរហួសគល់ និងដើម ហើយ

សម្គាល់ថា គួរស្វែងរកខ្លឹមត្រង់មែក និងសន្លឹកទៅវិញ មានឧបមាយ៉ាងណា សេចក្តីឧបមេយ្យនេះក៏យ៉ាងនោះដែរ កាលបើព្រះសាស្តាគង់ក្នុងទីចំពោះមុខនៃលោកដ៏មានអាយុទាំងឡាយ លោកទាំងឡាយ ដើរហួសព្រះមានព្រះភាគនោះ ហើយសម្គាល់ថា គប្បីសួរសេចក្តីនេះនឹងខ្ញុំវិញ ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគនោះ តែងទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌មិនវិបរិតកើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ អ្នកប្រាប់នូវធម៌ អ្នកបង្អោននូវប្រយោជន៍ អ្នកឲ្យនូវសេចក្តីប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះអមតៈ ជាម្ចាស់នៃធម៌ កាលនេះជាកាលគួរដល់ព្រះតថាគតនុ៎ះហើយ លោកទាំងឡាយគប្បីសាកសួរនូវសេចក្តីនៃឧទ្ទេសនេះនឹងព្រះមានព្រះភាគចុះ ( បើ ) ព្រះមានព្រះភាគនៃយើង ទ្រង់សំដែងយ៉ាងណា អ្នកទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះដូច្នោះ ។ ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញដោយពិតណាស់ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌មិនវិបរិតកើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ ជាអ្នកប្រាប់នូវធម៌ អ្នកបង្អោនមកនូវប្រយោជន៍ អ្នកឲ្យនូវសេចក្តីប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានឈ្មោះអមតៈ ជាម្ចាស់នៃធម៌ កាលនេះជាកាលគួរដល់ព្រះតថាគតនោះហើយ យើងទាំងឡាយគប្បីសាកសួរនូវសេចក្តីនៃឧទ្ទេសនេះនឹងព្រះមាន

ព្រះភាគចុះ ( បើ ) ព្រះមានព្រះភាគនៃយើង ទ្រង់សម្តែងយ៉ាងណា យើង ទាំងឡាយគប្បីចាំទុកនូវឧទ្ទេសនោះដូច្នោះ ក៏មែនពិតហើយ ប៉ុន្តែមហាកច្ចានៈ ដ៏មានអាយុ ព្រះសាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរដែរ មហាកច្ចានៈដ៏មានអាយុនេះ អាចចែកសេចក្តីនៃឧទ្ទេសដែល ព្រះមានព្រះភាគសម្តែងដោយបង្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ឲ្យ ពិស្តារទៅបាន សូមមហាកច្ចានៈដ៏មានអាយុ កុំបង្អែបង្អង់ មេត្តាចែក ( នូវ សេចក្តីឲ្យទាន ) ។

[ ២៤៨ ] ព្រះមហាកច្ចានៈឆ្លើយថា ម្នាលអាវុសោ បើដូច្នោះអ្នកទាំង-ឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសម្តែង ( ឥឡូវនេះ ) ។ ភិក្ខុទាំងនោះ ក៏ឆ្លើយតបព្រះមហាកច្ចានៈដ៏មានអាយុថា ព្រះករុណាអាវុសោ ។ ព្រះមហាកច្ចានៈដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំង-ឡាយ ព្រះមានព្រះភាគរបស់យើង សម្តែងនូវឧទ្ទេសណា ដោយសេចក្តី បង្រួញ មិនទាន់បានចែកអត្ថដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ច-សញ្ញាតែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្តី ដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។បេ។ អកុសលធម៌ ទាំងឡាយដ៏លាមកនេះ រមែងរលត់ទៅដោយមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយ ក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈ ចូលទៅកាន់វិហារទៅ ម្នាលអាវុសោ ខ្ញុំដឹងច្បាស់នូវសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់ សម្តែងដោយបង្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ដោយពិស្តារយ៉ាងនេះថា

ម្នាលអាវុសោ ចក្ខុវិញ្ញាណកើតឡើងព្រោះអាស្រ័យចក្ខុប្បសាទ និងរូបា-រម្មណ៍ ការប្រជុំធម៌ ៣ យ៉ាង ( ចក្ខុ ១ រូប ១ ចក្ខុវិញ្ញាណ ១ ) ឈ្មោះថា ផស្សៈ វេទនាកើតឡើងព្រោះមានផស្សៈជាបច្ច័យ វេទនាទទួលនូវអា-រម្មណ៍ណា សញ្ញាក៏ស្គាល់ច្បាស់នូវអារម្មណ៍នោះ សញ្ញាស្គាល់ច្បាស់នូវអារម្មណ៍ណា វិតក្កក៏ត្រិះរិះនូវអារម្មណ៍នោះ វិតក្កត្រិះរិះនូវអារម្មណ៍ណា បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអារម្មណ៍នោះ បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអា-រម្មណ៍ណា ចំណែកនៃបបញ្ចសញ្ញារមែងគ្របសង្កត់នូវបុរស ព្រោះមានចក្ខុនិងរូបជាដើមនោះជាហេតុ ( សហជាតធម៌ទាំងឡាយ ) ក្នុងរូបដែលគេគប្បីដឹងដោយចក្ខុជាអតីត អនាគត និងបច្ចុប្បន្ន ( បណ្ឌិតគប្បីយល់តាមន័យនេះចុះ ) ។ ម្នាលអាវុសោ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យសោត-ប្បសាទ និងសទ្ទារម្មណ៍ ។បេ។ ម្នាលអាវុសោ ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យឃានប្បសាទ និងគន្ធារម្មណ៍ ... ។ ម្នាលអាវុសោ ជិវ្ហា-វិញ្ញាណកើតឡើង ព្រោះអាស្រ័យជិវ្ហាប្បសាទ និងរសារម្មណ៍ ... ។ ម្នាលអាវុសោ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយប្បសាទ និងផោដ្ឋព្វា-រម្មណ៍ ... ។ ម្នាលអាវុសោ មនោវិញ្ញាណ គឺអាវជ្ជនចិត្ត ឬជវនចិត្តកើតឡើង ព្រោះអាស្រ័យភវង្គចិត្ត និងធម្មារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ការប្រជុំនៃភវង្គចិត្ត ធម្មារម្មណ៍ និងមនោវិញ្ញាណទាំង ៣ ( នេះ ) ឈ្មោះថា ផស្សៈ វេទនាកើតឡើងព្រោះមានផស្សៈជាបច្ច័យ វេទនាទទួលនូវអា-រម្មណ៍ណា សញ្ញាក៏ស្គាល់ច្បាស់នូវអារម្មណ៍នោះ សញ្ញាស្គាល់ច្បាស់នូវ

អារម្មណ៍ណា វិតក្កក៏ត្រិះរិះនូវអារម្មណ៍នោះ វិតក្កត្រិះរិះនូវអារម្មណ៍ណា បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអារម្មណ៍នោះ បបញ្ចធម៌ធ្វើឲ្យយឺតយូរនូវអារម្មណ៍ណា ចំណែកនៃបបញ្ចសញ្ញាតែងគ្របសង្កត់នូវបុរស ព្រោះមានអារម្មណ៍នោះជាហេតុ ( សហជាតធម៌ទាំងឡាយ ) ក្នុងអារម្មណ៍ដែលគេគប្បីដឹងដោយចិត្តជាអតីត អនាគត បច្ចុប្បន្ន បណ្ឌិតគប្បីយល់តាមន័យនេះចុះ ។ ម្នាលអាវុសោ កាលបើចក្ខុប្បសាទ រូបារម្មណ៍ និងចក្ខុវិញ្ញាណមានហើយ បុរសនោះឯង នឹងធ្វើឲ្យប្រាកដនូវផស្សប្បញ្ញត្តិបាន ហេតុនេះមានមែន កាលបើផស្សប្បញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើវេទនាបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើសញ្ញាបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវវិតក្កប្បញ្ញត្តិបាន ហេតុនេះមានមែន កាលបើវិតក្កប្បញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណប្បញ្ញត្តិ គឺសម្តែងនូវការគ្របសង្កត់ នូវចំណែកនៃបបញ្ចសញ្ញាបាន ហេតុនេះមានមែន ។ ម្នាលអាវុសោ កាលបើសោតប្បសាទ និងសទ្ទារម្មណ៍មានហើយ បុរសនោះឯង ... ។ កាលបើឃានប្បសាទ និងគន្ធារម្មណ៍មានហើយ ... ។ បើជិវ្ហាប្បសាទ និងរសារម្មណ៍មានហើយ ... ។ កាលបើកាយប្បសាទ និងផោដ្ឋព្វារម្មណ៍មានហើយ ... ។ កាលបើភវង្គចិត្ត ធម្មារម្មណ៍ និងមនោវិញ្ញាណមានហើយ បុរសនោះឯងនឹងធ្វើឲ្យប្រាកដនូវផស្សប្បញ្ញត្តិបាន ហេតុនេះមានមែន កាលបើផស្សប្បញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវវេទនា-

បញ្ញត្តិបាន ហេតុនេះមានមែន កាលបើវេទនាបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមានមែន កាលបើសញ្ញាបញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវវិតក្កប្បញ្ញត្តិបាន ហេតុនេះមានមែន កាលបើវិតក្កប្បញ្ញត្តិមានហើយ នឹងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណ-ប្បញ្ញត្តិបាន ហេតុនេះមានមែន ។ ម្នាលអាវុសោ កាលបើចក្ខុប្រសាទមិនមាន រូបារម្មណ៍មិនមាន និងចក្ខុវិញ្ញាណមិនមានហើយ បុរសនោះឯងនឹងធ្វើឲ្យប្រាកដនូវផស្សប្បញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើផស្សបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវេទនាបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវសញ្ញាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើសញ្ញាបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវវិតក្កប្បញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវិតក្កប្បញ្ញត្តិមិនមាន នឹងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណប្បញ្ញត្តិបាន ហេតុនេះមិនមានឡើយ ។ ម្នាលអាវុសោ កាលបើសោតប្រសាទ និងសទ្ទារម្មណ៍មិនមានហើយ បុរសនោះឯង ។បេ។ កាលបើឃានប្រសាទ និងគន្ធារម្មណ៍មិនមានហើយ ... ។ កាលបើជិវ្ហាប្រសាទ និងរសារម្មណ៍មិនមានហើយ ... ។ កាលបើកាយប្រសាទ និងផោដ្ឋព្វារម្មណ៍មិនមានហើយ ... ។ កាលបើភវង្គចិត្តមិនមាន ធម្មារម្មណ៍មិនមាន និងមនោវិញ្ញាណមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវផស្សប្បញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើផស្សប្បញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវវេទនាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ

កាលបើវេទនាបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដ នូវសញ្ញាបញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើសញ្ញាបញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវវិតក្កប្បញ្ញត្តិបាន ហេតុនេះមិនមានឡើយ កាលបើវិតក្កប្បញ្ញត្តិមិនមានហើយ នឹងធ្វើឲ្យប្រាកដនូវបបញ្ចសញ្ញាសង្ខាសមុទាចរណប្បញ្ញត្តិបាន ហេតុនេះមិនមានឡើយ ។ ម្នាលអាវុសោ ព្រះមានព្រះភាគរបស់យើងទាំងឡាយ ទ្រង់សំដែងនូវឧទ្ទេសណា ដោយសេចក្តីបង្រួញ មិនទាន់ចែកសេចក្តីដោយពិស្តារថា ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញារមែងគ្របសង្កត់នូវបុរស ព្រោះមានសភាវៈណាជាហេតុ សេចក្តីដែលបុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។បេ។ អកុសលធម៌ដ៏លាមកទាំងឡាយនេះ រមែងរលត់ទៅដោយមិនសេសសល់ ក្នុង ( សភាវៈនុ៎ះ ) ដូច្នេះហើយ ក៏ស្រាប់តែស្តេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ម្នាលអាវុសោ ខ្ញុំដឹងច្បាស់នូវសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែងដោយសេចក្តីបង្រួញ មិនទាន់ចែកសេចក្តីឲ្យពិស្តារនេះ ដោយពិស្តារយ៉ាងនេះឯង ។ តែថាបើលោកដ៏មានអាយុទាំងឡាយចង់ដឹង ( សេចក្តីនេះឲ្យច្បាស់លាស់ ) គប្បីនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ ហើយសាកសួរសេចក្តីនេះចុះ ( បើ ) ព្រះមានព្រះភាគនៃយើងទាំងឡាយ ទ្រង់ព្យាករយ៉ាងណា លោកទាំងឡាយគប្បីចាំសេចក្តីនោះយ៉ាងនោះចុះ ។

[ ២៤៩ ] ភិក្ខុទាំងនោះ ក៏ត្រេកអរអនុមោទនានូវភាសិតរបស់ព្រះមហាកច្ចានៈដ៏មានអាយុ ហើយក្រោកអំពីអាសនៈ នាំគ្នាចូលទៅគាល់ព្រះមាន

ព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបអភិវាទចំពោះព្រះមានព្រះភាគ រួច ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលដែលភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សម គួរហើយ បានក្រាបបង្គំទូលព្រះមានជោគដូច្នេះថា បពិត្រព្រះមានព្រះភាគ ដ៏ចម្រើន ព្រះអង្គទ្រង់សម្ដែងនូវឧទ្ទេសណា ដោយសេចក្ដីបង្រួញ មិនទាន់ ចែកសេចក្ដីដោយពិស្ដារ ដល់ពួកខ្ញុំព្រះអង្គថា ម្នាលភិក្ខុ ចំណែកនៃបបញ្ច-សញ្ញារមែងគ្របសង្កត់នូវបុរស ព្រោះមានសភាវៈណាជាហេតុ សេចក្ដីដែល បុគ្គលគប្បីត្រេកអរ បើមិនមានក្នុងសភាវៈនុ៎ះទេ ។បេ។ អកុសលធម៌ដ៏ លាមកទាំងឡាយនេះ រមែងរលត់ទៅ ដោយមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយ ក៏ស្រាប់តែស្ដេចក្រោកអំពីអាសនៈ ចូលកាន់វិហារទៅ ។ បពិត្រព្រះមានព្រះភាគដ៏ចម្រើន កាលព្រះមានព្រះភាគស្ដេចចេញទៅមិន យូរប៉ុន្មាន ខ្ញុំព្រះអង្គទាំងនោះ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ទាំងឡាយ ព្រះមានព្រះភាគរបស់យើង ទ្រង់សម្ដែងនូវឧទ្ទេសនេះ ដោយ សេចក្ដីបង្រួញណាស់ មិនទាន់ចែកសេចក្ដីដោយពិស្ដារថា ម្នាលភិក្ខុ ចំណែក នៃបបញ្ចសញ្ញា រមែងគ្របសង្កត់នូវបុរស ព្រោះមានសភាវៈណាជាហេតុ សូម្បីសេចក្ដីដែលបុគ្គលគប្បីត្រេកអរ គប្បីពោល គប្បីប្រកាន់ ( ថាអញ ថាយើង ) បើមិនមានក្នុងសភាវៈនុ៎ះទេ សេចក្ដីមិនត្រេកអរជាដើមនុ៎ះឯង ហៅថា ទីបំផុតនៃរាគានុស័យ ហៅថា ទីបំផុតនៃបដិឃានុស័យ ហៅថា ទី បំផុតនៃទិដ្ឋានុស័យ ហៅថា ទីបំផុតនៃវិចិកិច្ឆានុស័យ ហៅថា ទីបំផុតនៃ មានានុស័យ ហៅថា ទីបំផុតនៃភវរាគានុស័យ ហៅថា ទីបំផុតនៃអវិជ្ជា-

នុស័យ ហៅថា ទីបំផុតនៃការកាន់ដំបង កាន់សស្ត្រា បង្កហេតុ ជម្លោះ ទាស់ទែង ពោលពាក្យចាក់ដោត ថាឯង ថាមឹង និងពាក្យមុសាវាទ អកុសលធម៌ដ៏លាមកទាំងឡាយនេះ រមែងរលត់ទៅដោយមិនសេសសល់ក្នុងសភាវៈនុ៎ះ ដូច្នេះហើយ ក៏ស្រោប់តែស្តេចក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ភិក្ខុណាហ្ន៎ នឹងគប្បីចែកសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយបង្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារនេះ ឲ្យពិស្តារទៅបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា មហាកច្ចានៈដ៏មានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរ ទាំងពួកសព្រហ្មចារីជាអ្នកប្រាជ្ញក៏សរសើរដែរ មានតែមហាកច្ចានៈដ៏មានអាយុនេះ ទើបនឹងអាចចែកសេចក្តីនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងបង្រួញ មិនទាន់ចែកអត្ថឲ្យពិស្តារ ឲ្យពិស្តារទៅបាន បើដូច្នោះ គួរយើងទាំងឡាយចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរសេចក្តីនេះ នឹងមហាកច្ចានៈដ៏មានអាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន ទើបខ្ញុំព្រះអង្គទាំងនោះ នាំគ្នាចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ បានសាកសួរសេចក្តីនេះ នឹងមហាកច្ចានៈដ៏មានអាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាកច្ចានៈដ៏មានអាយុ បានចែកសេចក្តីដោយអាការទាំងនេះដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះ ដល់យើងទាំងឡាយនោះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរថា ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ( នេះ ) ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ( នេះ ) ជាអ្នកមានប្រាជ្ញា

ច្រើន ម្នាលភិក្ខុទាំងឡាយ ទុកជាអ្នកទាំងឡាយ សាកសួរសេចក្តីនេះនឹងតថាគត តថាគតក៏គង់តែព្យាករសេចក្តីនោះយ៉ាងហ្នឹងដែរ មហាកច្ចានៈព្យាករសេចក្តីនៃឧទ្ទេសនោះយ៉ាងណា សេចក្តីនៃឧទ្ទេសនេះយ៉ាងហ្នឹងហើយ អ្នកទាំងឡាយចូរចាំនូវសេចក្តីនោះចុះ ។

[ ២៥០ ] កាលបើព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដូចបុរសដែលសេចក្តីស្រេកឃ្លានគ្របសង្កត់ ឲ្យមានកម្លាំងថយហើយ ស្រាប់តែបាននំផ្អែម បុរសនោះបានទទួលរសក្នុងកាលណា ក៏បាននូវសេចក្តីឆ្ងាញ់ដែលមិនលាយដោយទឹកធម្មតា ក្នុងកាលណោះ សេចក្តីនេះយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលមានជាតិជាអ្នករិះរំពឹង មានសភាពជាបណ្ឌិត គប្បីកំណត់នូវសេចក្តីនៃធម្មបរិយាយនេះ ដោយបញ្ញាក្នុងកាលណា ក៏បាននូវភាវៈជាអ្នកមានចិត្តរីករាយផង បាននូវសេចក្តីជ្រះថ្លានៃចិត្តផង ( ក្នុងកាលណោះ ) ដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះឈ្មោះដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកចាំទុកនូវសេចក្តីនោះថា ធម្មបរិយាយនេះ ឈ្មោះមធុបិណ្ឌិកបរិយាយដូច្នេះចុះ ។ ព្រះមានព្រះភាគបានត្រាស់សម្តែងសូត្រនេះចប់ហើយ ព្រះអានន្ទដ៏មានអាយុ ក៏ពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## មធុបិណ្ឌិកសូត្រទី ៨ ចប់

# អដ្ឋកថា

## មធុបិណ្ឌិកសូត្រ

[ ២៤៣ ] មធុបិណ្ឌិកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់មកយ៉ាងនេះ ។

បណ្ដាបទទាំងនោះ បទថា **មហាវនំ** បានដល់ ព្រៃដែលកើតឯង ដោយមិនមានអ្នកណាដាំ ជាប់គ្នាតែមួយជាមួយនឹងព្រៃហិមពាន្ត មិនដូចព្រៃ ដែលជាប់នឹងព្រៃដែលដាំហើយ និងមិនទាន់បានដាំក្នុងក្រុងវេសាលី ។ បទ ថា **ទិវាវិហារាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការសម្រាកក្នុងពេល ថ្ងៃ ។ បទថា **វេលុវលដ្ឋិកាយ** បានដល់ ដើមញៀជំទង់ ។ បទថា **ទណ្ឌ-បាណិ** គឺទ្រង់កាន់ឈើច្រត់ ព្រោះជាអ្នកទុព្វលដោយជរាក៏មិនមែន ។ ទណ្ឌបាណិសក្យៈនេះនៅក្មេងនោះឯង តាំងនៅក្នុងបឋមវ័យ តែទ្រង់កាន់ ឈើច្រត់មាស ព្រោះមានចិត្តក្នុងឈើច្រត់គ្រាប់ទៅ ព្រោះដូច្នោះ ទើបហៅថា **ទណ្ឌបាណិ** ។ បទថា **ជង្ឃាវិហារំ** បានដល់ ដើរលេងដើម្បីបន្ទោបង់ការ នឿយហត់របស់ស្មង ។ បទថា **អនុចង្កមមានោ** គឺកំពុងយាងមើលខាង នោះខាងនេះ ដើម្បីប្រយោជន៍ដល់ការក្រសាលឧទ្យាន ក្រសាលព្រៃ និង ក្រសាលភ្នំជាដើម ។ បានឮថា ទណ្ឌបាណិសក្យៈនោះ កាលយាងចេញទៅ ក៏ទ្រង់ចេញក្នុងពេលខ្វះប៉ុណ្ណោះ គ្រាប់ទៅ ។ បទថា **ទណ្ឌមោលុព្ភា** សេចក្ដីថា ទ្រង់គ្រវីឈើច្រត់ គឺដាក់ឈើច្រត់ទៅខាងមុខ ដូចក្មេងឃ្វាលគោ ដាក់ព្រះហស្តលើចុងឈើច្រត់ ទ្រង់ដាក់ព្រះហនុ ( ចង្កា ) លើខ្នងព្រះហស្ត

ហើយប្រថាប់ឈរ នាចំណែកម្ខាង ។ បទថា **កឹវាទី** បានដល់ ទ្រង់មានវាទៈដូចម្តេច ។ បទថា **កិមក្ខាយិ** គឺត្រាស់ប្រាប់ដូចម្តេច ។ ព្រះរាជានេះទ្រង់មិនថ្វាយបង្គំព្រះមានព្រះភាគ ទ្រង់គ្រាន់តែធ្វើបដិសណ្ឋារៈប៉ុណ្ណោះ ហើយទូលសួរបញ្ហា តែក៏ទូលសួរដោយមិនអើពើ ព្រោះជាអ្នកមិនមានបំណងនឹងដឹង ។ បានឮថា ព្រះរាជានេះ ទ្រង់ជាបក្ខពួករបស់ទេវទត្ត ព្រោះហេតុអ្វី ព្រោះទេវទត្តបែកអំពីព្រះតថាគត មកកាន់សម្នាក់របស់ព្រះរាជាអង្គនេះ បានឮថា ទេវទត្តនោះពោលយ៉ាងនេះថា ព្រះសមណគោតមមានពៀរជាមួយត្រកូលពួកយើង មិនបំណងសេចក្តីចម្រើនដល់ត្រកូលពួកយើង ព្រោះប្អូនស្រីរបស់យើងសមគួរសោយសម្បត្តិស្តេចចក្រពត្តិ ព្រះនាងលះសម្បត្តិនោះ រមែងសាបសូន្យបង់ ព្រោះដូច្នោះ ទើបសមណគោតមយាងចេញបួស ទ្រង់ដឹងថា ក្មួយរបស់យើងជាពន្ធុកស្តេចចក្រពត្តិ ក៏ទ្រង់មិនត្រេកអរនឹងការចម្រើនរបស់ត្រកូលពួកយើង ទ្រង់គិតថា នុ៎ះរមែងវិនាស ទើបទ្រង់ឲ្យក្មួយយើងនោះបួសក្នុងវេលានៅជាកុមារនោះឯង ឯយើងវៀរចាកក្មួយនោះ ក៏មិនអាចប្រព្រឹត្តទៅ ទើបបានបួសតាម តាំងអំពីថ្ងៃបួសមកទ្រង់ក៏មិនសម្លឹងមើលយើងដែលបួសយ៉ាងនេះ ដោយព្រះនេត្រត្រង់ៗ កាលត្រាស់ក្នុងកណ្តាលបរិស័ទ ក៏ហាក់ដូចជាប្រហារដោយពាក្យមិនពិតច្រើនយ៉ាង ដូចជាត្រាស់ថា ទេវទត្តជាសត្វមិនចម្រើនដូច្នេះជាដើម ។ ព្រះរាជានេះត្រូវទេវទត្តញុះញង់យ៉ាងនេះ ព្រោះដូច្នោះ ទើបទ្រង់ធ្វើដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់ពាក្យដែលសមគួរដល់ព្រះរាជានោះដោយ

*ព្រះតម្រិះថា តថាគតនឹងត្រាស់ប្រាប់ដល់ព្រះរាជានេះ ដោយប្រការដែលព្រះរាជានោះមិនអាចដើម្បីត្រាស់ថា ព្រះសមណគោតម មិនត្រាស់ប្រាប់បញ្ហាដែលអញទូលសួរ ដោយប្រការដែលមិនដឹងអត្ថនៃភាសិត ទើបត្រាស់ថា* **យថាវាទី ខោ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ន កេនចិ លោកេ វិគ្គយ្ហ តិដ្ឋតិ** *សេចក្តីថា មិនធ្វើពាក្យជំទាស់ គឺឈ្លោះជាមួយបុគ្គលណាមួយក្នុងលោក ពិតហើយ ព្រះតថាគតទ្រង់មិនឈ្លោះជាមួយសត្វលោក តែសត្វលោក កាលទ្រង់ត្រាស់ថា មិនទៀង ក៏ពោលថា ទៀង កាលត្រាស់ថា ទុក្ខ អនត្តា មិនស្អាត ក៏ពោលថា ស្អាត ឈ្មោះថា ឈ្លោះជាមួយតថាគតដូច្នេះ ។ ដោយហេតុនោះឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនឈ្លោះនឹងសត្វលោក តែសត្វលោកឈ្លោះនឹងតថាគត ធម្មវាទីរមែងមិនឈ្លោះជាមួយបុគ្គលណាម្នាក់ដូចគ្នា តែអធម្មវាទីរមែងឈ្លោះ ដូច្នេះ ។ បទថា* **យថា** *បានដល់ ដោយហេតុណា ។ បទថា* **កាមេហិ** *គឺវត្ថុកាមក្តី កិលេសកាមក្តី ។ បទថា* **តំ ព្រាហ្មណំ** *បានដល់ ព្រាហ្មណ៍ដ៏ជាខីណាស្រពនោះ ។ បទថា* **អកថំកថី** *បានដល់ ប្រាសចាកសេចក្តីសង្ស័យ ។ បទថា* **ឆិន្នកុក្កុច្ចំ** *គឺឈ្មោះថា កាត់នូវការឃ្នើសឃ្នងបានហើយ ព្រោះការឃ្នើសឃ្នងទាក់នឹងការក្តៅក្រហាយ និងការឃ្នើសឃ្នងដៃ និងជើង កាត់ផ្តាច់ហើយ ។ បទថា* **ភវាភវេ** *បានដល់ ក្នុងភពហើយក្នុងភពទៀត ឬភពថោកទាប និងភពប្រណីត ។ ពិតហើយ ភពដែលប្រណីតដល់ហើយនូវការចម្រើន ហៅថា អភព ។ បទថា* **សញ្ញា** *បានដល់ កិលេសសញ្ញា ។*

កិលេសទាំងឡាយនោះឯង លោកពោលហើយ ដោយឈ្មោះថា សញ្ញាក្នុងទីនេះ ព្រោះដូច្នោះ ទើបមានអធិប្បាយក្នុងបទយ៉ាងនេះថា កិលេសសញ្ញាទាំងឡាយ មិនគ្របសង្កត់ព្រាហ្មណ៍ ដែលប្រាសចាកាមទាំងឡាយនោះ មានប្រក្រតីពោលនូវការរំលត់ចាកលោកទាំងឡាយ ដោយហេតុណា តថាគតរមែងពោលហេតុនោះ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងកាពដែលព្រះអង្គជាព្រះខីណាស្រព ដោយប្រការដូច្នេះ ។ បទថា **និល្លាលេត្វា** គឺលៀនអណ្តាតលេង ។ បទថា **តិវិសាខំ** បានដល់ ៣ ផ្នត់ ។ បទថា **ណលាដិកំ** សេចក្តីថា ថ្ងាស ទ្រង់សម្តែង ៣ ផ្នត់ក្នុងថ្ងាស ធ្វើថ្ងាសជ្រួញ ។ បទថា **ឧណ្ហមោលុព្ភា** បានដល់ គ្រវីឈើច្រត់ ។ បទថា **ឧណ្ហមាលុព្ភ** ដូច្នេះក៏មាន អធិប្បាយថា កាន់ហើយចៀសចេញទៅ ។

[ ២៤៥ ] បទថា **អញ្ញតរោ** បានដល់ ភិក្ខុមួយរូបមិនប្រាកដឈ្មោះ ។

បានឮថា ភិក្ខុនោះ ឈ្លាសក្នុងការបន្តអនុសន្ធិ កាលព្រះមានព្រះភាគត្រាស់ថា ព្រះបាទទណ្ឌបាណិ ទ្រង់មិនដឹងដោយប្រការណា តថាគតនឹងសម្តែងដោយប្រការនោះ ទើបកាន់យកអនុសន្ធិថា ព្រះមានព្រះភាគត្រាស់បញ្ហាដែលមិនគប្បីដឹងថា ដូចម្តេចហ្ន៎ ទើបទូលសូមព្រះទសពល ដោយគិតថា អញនឹងធ្វើបញ្ហានេះឲ្យប្រាកដដល់ព្រះភិក្ខុសង្ឃ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ផ្គងអញ្ជលីដ៏រុងរឿងដោយម្រាមទាំង ១០ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគមានប្រក្រតីប្រកាន់ទិដ្ឋិដូចម្តេចជាដើម ។ បទថា **យតោនិទានំ** ទុ៎ះជាការនៃបុំសកលិង្គ អធិប្បាយថា

កាលការណ៍ណាមានដោយការណ៍ណា ។ បទថា **សង្ខា** ក្នុងបទថា **បបញ្ច-សញ្ញាសង្ខា** នោះ បានដល់ ចំណែក ។ បទថា **បបញ្ចសញ្ញា** បានដល់ សញ្ញាដែលប្រកបដោយគ្រឿងយឺតយូរ គឺតណ្ហា មានះ និងទិដ្ឋិ ។ ម្យ៉ាង ទៀត ធម៌ជាគ្រឿងយឺតយូរនោះឯង ត្រាស់ដោយឈ្មោះថា **សញ្ញា** ព្រោះ ដូច្នោះ ទើបក្នុងបទនេះ មានអធិប្បាយយ៉ាងនេះថា ចំណែកនៃគ្រឿងយឺត យូរ ។ បទថា **សមុទាចរន្តិ** គឺរមែងប្រព្រឹត្តទៅ ។ បទថា **ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ** សេចក្ដីថា កាលហេតុ ពោល គឺអាយតនៈ ១២ ណាមាន ចំណែកនៃសញ្ញាជាគ្រឿងយឺតយូរ រមែងគ្របសង្កត់ បើអាយតនៈ ១ ដែល បុគ្គលគប្បីត្រេកអរ គប្បីប្រកាន់ គប្បីគ្របសង្កត់ មិនមានក្នុងអារម្មណ៍ នោះ ។ បណ្ដាបទទាំងនោះ បទថា **អភិនន្ទិតព្វំ** សេចក្ដីថា គប្បីត្រេកអរ ថាជាអញ របស់អញ ។ បទថា **អភិវទិតព្វំ** បានដល់ គប្បីពោលថា អញ របស់អញ ។ បទថា **អជ្ឈោសិតព្វំ** បានដល់ ប្រកបការដែលគ្របសង្កត់ សង្កត់ហើយ ឲ្យចប់ហើយ គប្បីកាន់យក ។ ទ្រង់សម្ដែងការមិនប្រព្រឹត្តទៅ នៃតណ្ហាជាដើមនោះឯងក្នុងទីនេះ ដោយបទនោះ ។ បទថា **ឯសេវន្តោ** គឺការ ដែលត្រេកអររីករាយជាដើមមិនមាននេះឯង ជាទីបំផុតនៃអនុស័យទាំងឡាយ មានរាគានុស័យជាដើម ។ ក្នុងបទទាំងពួង ក៏មានន័យនេះដូចគ្នា ។ ក្នុង ទណ្ឌាទានជាដើម បុគ្គលចាប់កំណាត់ឈើ ដោយចេតនាណា ចេតនានោះ ឈ្មោះថា **ទណ្ឌាទានំ** ប្រែថា ការចាប់កំណាត់ឈើ បុគ្គលចាប់សស្ត្រា ដោយចេតនាណា ចេតនានោះឈ្មោះថា **សត្ថាទានំ** ប្រែថា ចេតនាកាន់យក

នូវសស្ត្រា ការកាន់យកខុស ការឈ្លោះដែលដល់ទីបំផុត ការឈ្លោះប្រកែកដែលដល់នូវការប្រកាន់ផ្សេងៗ ការវិវាទដែលដល់នូវវាទៈផ្សេងៗ ។ បទថា **តុវំតុវំ** បានដល់ វាចាដែលពោលថា ឯង មឹង អា ហង ដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ។ ការធ្វើការញុះញង់ ឈ្មោះថា **បេសុញ្ញំ** ប្រែថា ការញុះញង់ ។ វាចាដែលធ្វើការនិយាយកុហក មានភាវៈមិនពិតនោះ គប្បីជ្រាបថា មុសាវាទ ។ បទថា **ឯត្ថេតេ** សេចក្ដីថា អកុសលធម៌ដ៏លាមកទាំងនេះព្រោះអាយតនៈ ១២ នោះ ។ ពិតហើយ កិលេសទាំងឡាយ កាលកើតឡើង រមែងកើតព្រោះអាយតនៈ ១២ កាលរលត់ ក៏រមែងរលត់ ព្រោះអាយតនៈ ១២ ដូចគ្នា ។ កិលេសទាំងឡាយកើតឡើងក្នុងទីណា ក៏រមែងរលត់ក្នុងទីនោះ ដោយប្រការដូច្នេះ ។ អត្ថនេះគប្បីសម្ដែងដោយសមុទយ-សច្ចប្បញ្ហា ។ ពិតហើយ លោកពោលថា តណ្ហានោះឯង កាលកើត រមែងកើតក្នុងទីណា កាលរលត់ រមែងរលត់ក្នុងទីណា ដូច្នេះហើយ ទើបពោលការកើតឡើង និងការរលត់នៃតណ្ហានោះ ព្រោះអាយតនៈ ១២ ដោយន័យជាដើមថា **បិយរូប សាតរូប** ក្នុងលោកណា តណ្ហានោះ កាលកើត រមែងកើតក្នុងបិយរូប សាតរូបនោះ កាលរលត់ រមែងរលត់ក្នុងបិយរូប សាតរូបនោះ បិយរូប សាតរូបក្នុងលោក គឺអ្វី គឺចក្ខុជាបិយរូប សាតរូបក្នុងលោក ដូច្នេះ ។ តណ្ហាកើតឡើងហើយក្នុងអាយតនៈ ១២ អាស្រ័យនិព្វានក៏រលត់ទៅ តែព្រោះមិនមានការគ្រប់សង្កត់ក្នុងអាយតនៈទាំងឡាយ លោកពោលថា រលត់ហើយ ព្រោះអាយតនៈទាំងឡាយនោះឯង យ៉ាងណា អកុសលធម៌ដ៏

*លាមកទាំងនេះ គប្បីជ្រាបថា រមែងរលត់ ព្រោះអាយតនៈទាំងឡាយយ៉ាង នោះ ម្យ៉ាងទៀត ការមិនមាននៃការត្រេកអរជាដើមឯណា លោកពោលថា ជាទីបំផុតនៃអនុស័យទាំងឡាយ មានរាគានុស័យជាដើម អកុសលធម៌ដ៏ លាមកទាំងឡាយ រមែងរលត់ដោយមិនមានសេសសល់ក្នុងនិព្វាន ដែលមាន វោហារហើយថា* **ឯត្ថេតេ រាគានុសយាទីនំ អន្តោ** *វត្ថុណាមិនមានក្នុង និព្វានណា វត្ថុនោះ ឈ្មោះថា រលត់ហើយក្នុងនិព្វាននោះ ។ សេចក្តីនោះ គប្បីសម្តែងដោយនិរោធប្បញ្ញា ។ សមដូចពាក្យលោកពោលហើយថា វិតក្ក វិចារៈ វចីសង្ខាររបស់ភិក្ខុនោះ ដែលចូលដល់ទុតិយជ្ឈាន រមែងរម្ងាប់ ជាដើម ។*

[ ២៤៦ ] *បទថា* **សត្ថុចេវ សំវណ្ណិតោ** *គឺបុគ្គលដែលព្រះសាស្តាទ្រង់ សរសើរហើយ ។ សូម្បីពាក្យថា* **វិញ្ញូនំ** *ជាសត្តមីវិភត្តិ ចុះក្នុងអត្ថតតិយា- វិភត្តិ អធិប្បាយថា បុគ្គលដែលសព្រហ្មចារីទាំងឡាយ ដែលជាបណ្ឌិត សរសើរហើយ ។ បទថា* **បហោតិ** *គឺរមែងអាច ។*

[ ២៤៧ ] *បទថា* **អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ** *សេចក្តីថា ធម្មតា ខ្លឹមឈើ គប្បីមានក្នុងដើម ឬគល់ កន្លងគល់ និងដើមនោះ ។ បទថា* **ឯវំ សម្បទំ** *សេចក្តីថា សេចក្តីឧបមានេះក៏ដូច្នោះ អធិប្បាយថា ដូច្នេះ ។ បទ ថា* **អតិសិត្វា** *បានដល់ ឈានកន្លងហើយ ។ បទថា* **ជានំ ជានាតិ** *បានដល់ ដឹងវត្ថុដែលគប្បីដឹងនោះឯង ។ បទថា* **បស្សំ បស្សតិ** *បានដល់ ឃើញវត្ថុដែលគួរឃើញនោះឯង ។ ម្យ៉ាងទៀត បុគ្គលពួកខ្លះកាន់យកវិបរិត*

កាលដឹង ក៏ថាមិនដឹង កាលឃើញក៏ថាមិនឃើញ យ៉ាងណា ឯព្រះមានព្រះភាគ មិនដូច្នោះឡើយ កាលទ្រង់ដឹង ក៏ថាដឹង កាលទ្រង់ឃើញ ក៏ថាឃើញតែម្យ៉ាង ។ ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា ជាអ្នកមានចក្ខុ ព្រោះអត្ថថា ជាអ្នកនាំក្នុងទស្សនៈ ឈ្មោះថា ជាអ្នកមានញាណ ព្រោះអត្ថថា ធ្វើវត្ថុដែលទ្រង់ដឹងហើយ ឈ្មោះថា មានធម៌ ព្រោះអត្ថថា មានសភាវៈដែលមិនវិបរិត ឬព្រោះទ្រង់មានព្រះធម្មវិន័យ ដែលទ្រង់គិតដោយព្រះហឫទ័យ ទ្រង់បន្លឺដោយព្រះវាចា ព្រោះប្រព្រឹត្តទៅក្នុងបរិយត្តិធម៌ ឈ្មោះថា ជាព្រហ្ម ព្រោះអត្ថថា ប្រសើរបំផុត ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានចក្ខុ ព្រោះជាអ្នកមានចក្ខុ ក្នុងបទទាំងនោះ ក៏មានអត្ថយ៉ាងនេះ ព្រះមានព្រះភាគនោះ ជាអ្នកបើកផ្សារ ព្រោះបើកផ្សារនូវព្រះធម៌ ជាអ្នកប្រកាស ព្រោះទ្រង់ប្រកាសព្រះធម៌ ជាអ្នកពង្រីកអត្ថ ព្រោះព្រះអង្គទ្រង់អាចក្នុងការនាំហើយនាំទៀតនូវអត្ថមកសម្តែង ជាអ្នកឲ្យអមតធម៌ ព្រោះព្រះអង្គទ្រង់សម្រេចអមតធម៌ហើយទ្រង់ឲ្យបដិបត្តិ ។ បទថា **អគរុករិត្វា** អធិប្បាយថា ព្រះមហាកច្ចានៈជាអ្នកសូមរឿយៗ ឈ្មោះថា ជាអ្នកមានចិត្តធ្ងន់តាំងនៅក្នុងសាវកបារមីញាណរបស់ខ្លួន សម្តែងធ្វើឲ្យដឹងបានលំបាក ដូចគ្រាប់ខ្សាច់ត្រង់ជើងភ្នំសិនេរុ ឈ្មោះថា ការធ្ងន់ចិត្តដូចគ្នា សូមលោកម្ចាស់កុំធ្វើឲ្យពួកខ្ញុំសំណូមពររឿយៗឡើយ ហើយសម្តែងធម៌ឲ្យដឹងបានដោយងាយដល់ពួកខ្ញុំចុះ ។

[ ២៤៨ ] ក្នុងបទនេះថា **យំ ខោ ណោ អាវុសោ** ព្រះមហាកច្ចានៈគួរពោលថា **យំ ខោ នោ** ក៏ពិត សូម្បីដូច្នោះ កាលសង្គ្រោះភិក្ខុទាំងនោះ មួយ

អន្ទើដោយខ្លួន ទើបពោលថា **យំ ខោ នោ** ដូច្នេះ ។ ឬព្រោះឧទ្ទេសបាន សម្ដែងហើយដល់ភិក្ខុទាំងនោះ តែព្រះមានព្រះភាគ ក៏ទ្រង់សម្ដែងដល់ព្រះ ថេរៈខ្លះ ដល់ភិក្ខុនោះៗ ខ្លះ ព្រោះដូច្នោះ លោកសំដៅដល់បទនេះថា **ភគវា** ទើបពោលយ៉ាងនោះ អធិប្បាយថា ព្រះមានព្រះភាគរបស់ពួកយើង ទ្រង់ សម្ដែងឧទ្ទេសដោយសង្ខេបណាដល់ពួកលោក ដូច្នេះ ។ ក្នុងបទថា **ចក្ខុ-ញ្ចាវុសោ** ជាដើម មានអធិប្បាយយ៉ាងនេះ នៃអាវុសោទាំងឡាយ ធម្មតា ចក្ខុវិញ្ញាណ រមែងកើតឡើងព្រោះអាស្រ័យចក្ខុបសាទ ដោយភាពជាវិស័យ និងរូបដែលប្រកបដោយសមុដ្ឋាន ៤ យ៉ាង ដោយភាពជាអារម្មណ៍ ។ បទ ថា **តិណ្ណំ សង្គតិ ផស្សោ** សេចក្ដីថា ព្រោះប្រជុំធម៌ ៣ ប្រការនោះ ទើប កើតផស្សៈ ព្រោះផស្សៈជាបច្ច័យដោយអំណាចកើតឡើងព្រមជាដើម ព្រោះ អាស្រ័យផស្សៈនោះ ទើបកើតវេទនា និងដោយវេទនានោះ បុគ្គលសោយ អារម្មណ៍ណា សញ្ញាក៏ចាំអារម្មណ៍នោះ សញ្ញាចាំអារម្មណ៍ណា វិតក្កក៏ ត្រិះរិះនូវអារម្មណ៍នោះ វិតក្កត្រិះរិះនូវអារម្មណ៍ណា ក៏គ្រឿងយឺតយូរដល់ អារម្មណ៍នោះឯង ។ បទថា **តតោនិទានំ** បានដល់ ព្រោះហេតុ មាន ចក្ខុរូបជាដើមនោះ ។ បទថា **បុរិសំ បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ** សេចក្ដីថា ចំណែកនៃគ្រឿងយឺតយូររមែងគ្របសង្កត់បុរស ដែលមិនដឹង ហេតុនោះ អធិប្បាយរមែងប្រព្រឹត្តទៅដល់បុរសនោះ ។ ក្នុងសេចក្ដីនោះ ផស្សៈ វេទនា និងសញ្ញា ឈ្មោះថា កើតឡើងព្រមជាមួយចក្ខុវិញ្ញាណ គប្បី ឃើញវិតក្កក្នុងចិត្តដែលមានវិតក្ក មានក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ។

សួរថា ចំណែកនៃគ្រឿងយឺតយូរ កើតព្រមនឹងជវន បើដូច្នោះ ព្រោះហេតុអ្វី ទើបធ្វើការកាន់យកអតីត និងអនាគតទៅវិញ ឆ្លើយថា ព្រោះកើតឡើងយ៉ាងនោះ ដូចជាគ្រឿងយឺតយូរដែលប្រព្រឹត្តទៅតាមចក្ខុទ្វារកើតឡើងហើយក្នុងឥឡូវនេះ ព្រោះអាស្រ័យចក្ខុ រូប និងសម្ផស្ស វេទនា សញ្ញា វិតក្កយ៉ាងណា ព្រះមហាកច្ចានៈ កាលនឹងសម្តែងការកើតឡើងនៃគ្រឿងយឺតយូរនោះ ក្នុងរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ ដែលជាអតីត និងអនាគតទើបពោលយ៉ាងនោះដូច្នោះដូចគ្នា ។ ក្នុងបទថា **សោតញ្ចាវុសោ** ជាដើមមានន័យដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងឆដ្ឋទ្វារ បទថា **មនំ** បានដល់ភវង្គចិត្ត ។ បទថា **ធម្មេ** បានដល់ ធម្មារម្មណ៍ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **មនោវិញ្ញាណំ** បានដល់ អាវជ្ជនៈ ឬជវន ។ កាលអាវជ្ជនៈកាន់យកហើយ ផស្សៈ វេទនា សញ្ញា និងវិតក្ក រមែងកើតព្រមនឹងអាវជ្ជនៈ គ្រឿងយឺតយូរ កើតព្រមនឹងជវន កាលជវនកាន់យកហើយ ភវង្គចិត្តដែលមានព្រមនឹងអាវជ្ជនៈ ឈ្មោះថា ជាមនោ បន្ទាប់អំពីនោះ ផស្សៈជាដើមទាំងអស់ក៏កើតព្រមនឹងជវន ឯក្នុងមនោទ្វារ អារម្មណ៍ទាំងអស់ មានអតីតជាដើម ក៏រមែងមាន ព្រោះដូច្នោះ ពាក្យថា ដែលជាអតីត អនាគត និងបច្ចុប្បន្ន ឈ្មោះថា សមគួរហើយ ។

ឥឡូវនេះ ព្រះថេរៈកាលនឹងសម្តែងវដ្តៈ ទើបប្រារព្ធទេសនាថា **សោ វតាវុសោ** ដូច្នេះ ។ បទថា **ផស្សបញ្ញត្តឹ បញ្ញបេស្សតិ** សេចក្តីថា នឹងបញ្ញត្តសម្តែងផស្សបញ្ញត្តិ យ៉ាងនេះថា ធម៌ណាមួយ ឈ្មោះថា ផស្សៈ

រមែងកើតឡើង ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។ ព្រះថេរៈកាល សម្តែងវដ្តៈទាំងមូល ដោយអំណាចអាយតនៈ ១២ ថា កាលអាយតនៈនេះ មាន អាយតនៈនេះក៏មាន ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលនឹង សម្តែងវិវដ្តៈ ដោយអំណាចបដិសេធអាយតនៈ ១២ ទើបប្រារព្ធទេសនាថា **សោ វតាវុសោ ចក្ខុស្មឹ អសតិ** ដូច្នេះ ។ គប្បីជ្រាបអត្ថដោយន័យដែល ពោលហើយ ក្នុងបទនោះឯង ។

ព្រះថេរៈកាលវិសជ្ជនាបញ្ហាយ៉ាងនេះហើយ ឥឡូវនេះ ទើបពោលថា បញ្ហាដែលសាវកពោលហើយ ព្រោះដូច្នោះ អ្នកទាំងឡាយកុំជាអ្នកសង្ស័យ ព្រះមានព្រះភាគអង្គនេះ ទ្រង់កាន់យកការប្រៀបធៀបដោយសព្វញ្ញុតញ្ញាណ ប្រថាប់គង់ហើយ លោកទាំងឡាយបើមានប្រាថ្នា សូមចូលទៅគាល់ព្រះមាន ព្រះភាគអង្គនោះ ក៏នឹងអស់សេចក្តីសង្ស័យបាន ដូច្នេះ ទើបពោលពាក្យថា **អាកង្ខមានា ច បន** ដូច្នេះជាដើម ។

[ ២៤៩ ] បទថា **ឥមេហិ អាការេហិ** សេចក្តីថា ដោយហេតុទាំងនេះ គឺដោយហេតុចំពោះនៃការកើតឡើងឯង គ្រឿងយឹតយូរ និងហេតុដែលទាក់ ទងនឹងវដ្តៈ និងវិវដ្តៈ ។ បទថា **ឥមេហិ បទេហិ** គឺដោយប្រមូលអក្ខរៈទាំង នេះ ។ បទថា **ព្យញ្ជនេហិ** បានដល់ ដោយអក្ខរៈ ដោយចំពោះ ។ បទថា **បណ្ឌិតោ** សេចក្តីថា ប្រកបព្រមដោយភាពជាបណ្ឌិត ឬជាបណ្ឌិតដោយ ហេតុ ៤ យ៉ាង គឺឈ្លាសក្នុងធាតុ ឈ្លាសក្នុងអាយតនៈ ឈ្លាសក្នុងបច្ចយាការ ឈ្លាសក្នុងហេតុ និងអហេតុ ។ បទថា **មហាបញ្ញោ** សេចក្តីថា ដល់ព្រម

ដោយបញ្ញាច្រើន ដែលអាចកំណត់អត្ថច្រើន ធម៌ច្រើន និរុត្តិច្រើន បដិ-ភាណច្រើន ។ បទថា **យថា តំ មហាកច្ចានេន** សេចក្ដីថា ព្រះកច្ចានៈព្យាករដោយប្រការណា ទ្រង់សំដៅដល់ព្យាករនោះ ទើបត្រាស់ថា **តំ** ។ សេចក្ដីថា ព្យាករនោះ ព្រះមហាកច្ចានៈព្យាករហើយ ដោយប្រការណា សូម្បីតថាគតក៏ព្យាករយ៉ាងនោះដូចគ្នា ។

[ ២៥០ ] បទថា **មធុបិណ្ឌិកំ** បានដល់ ផ្អែមក្រៃលែង ឬសដូវដែលផ្សំហើយ ។ បទថា **អសេចនកំ** បានដល់ ដែលគប្បីជាទីត្រេកអរនៃចិត្ត គឺរសដែលផ្សំល្អ ដែលមិនគួរពោលថា ក្នុងបណ្ដាសប្បិ ទឹកអំពៅ ទឹកឃ្មុំ និងស្ករជាដើម នេះតិច វត្ថុនេះច្រើន ។ បទថា **ចេតសោ** បានដល់ មានជាតិជាអ្នកគិត ។ បទថា **ទព្វជាតិកោ** គឺមានសភាពជាបណ្ឌិត ។ ព្រះថេរៈដែលធូន់ក្នុងហេតុផល យ៉ាងក្រៃលែង ទើបគិតថា នេះជាធម្មបរិយាយអញនឹងទូលឲ្យទ្រង់ តាំងឈ្មោះ ធម្មបរិយាយនេះ ដោយសព្វញ្ញុតញ្ញាណរបស់ព្រះទសពលនោះឯង ទើបទូលពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះ ឈ្មោះដូចម្ដេច ។ បទថា **តស្មា** សេចក្ដីថា ព្រោះធម្ម-បរិយាយដ៏ផ្អែម ដូចនំផ្អែម ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកចូរចាំធម្មបរិយាយនេះថា **មធុបិណ្ឌិកបរិយាយ** ដូច្នេះចុះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយ ៕

**មធុបិណ្ឌិកសូត្រ ទី ៨ ចប់**

# សុត្តន្តបិដក

## ទ្វេធាវិតក្កសូត្រទី ៩

[ ២៥១ ] ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ២៥២ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ ក្នុងកាលមុនអំពីការត្រាស់ដឹង មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញត្រូវធ្វើវិតក្កឲ្យជាចំណែកពីរៗ ម្នាលភិក្ខុទាំងឡាយ ( លុះត្រិះរិះដូច្នេះហើយ ) តថាគតនោះឯង ក៏ធ្វើនូវកាមវិតក្ក ព្យាបាទវិតក្ក និងវិហិង្សាវិតក្កនេះឲ្យជាចំណែកទី ១ ធ្វើនូវនេក្ខម្មវិតក្ក អព្យាបាទវិតក្ក និងអវិហិង្សាវិតក្កនេះឲ្យជាចំណែកទី ២ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតនូវកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ កាមវិតក្កនោះកើតឡើង តថាគតដឹងច្បាស់យ៉ាងនេះថា កាមវិតក្កនេះ កើតឡើងដល់តថាគតហើយ កាមវិតក្កនោះឯង តែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាង គឺខ្លួនឯង និងបុគ្គលដទៃផង ( កាម-

វិតក្កនេះ ) ជាធម៌ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញថា កាមវិតក្កនេះតែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនដូច្នេះ ក៏កាមវិតក្កនោះដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតទើបតែពិចារណាឃើញថា កាមវិតក្កនេះ តែងប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃដូច្នេះ ក៏កាមវិតក្កនោះ ដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតទើបតែពិចារណាឃើញកាមវិតក្កនេះ តែងប្រព្រឹត្តដើម្បីបៀតបៀនទាំងពីរខាង គឺ ខ្លួនឯង និងបុគ្គលដទៃដូច្នេះ ក៏កាមវិតក្កនោះដល់នូវសេចក្តីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញថា កាមវិតក្កនេះជាធម៌ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានដូច្នេះ កាមវិតក្កនោះដល់នូវសេចក្តីវិនាសទៅ ។ ម្នាលភិក្ខុទាំងឡាយ ទើបតថាគតនោះលះបង់ គឺបន្ទោបង់នូវកាមវិតក្កដែលកើតឡើងហើយៗ ធ្វើកាមវិតក្កនោះមិនឲ្យសេសសល់នៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ ព្យាបាទវិតក្កនោះក៏កើតឡើង ។បេ។ វិហិង្សាវិតក្កនោះក៏កើតឡើង តថាគតដឹងច្បាស់យ៉ាងនេះថា វិហិង្សាវិតក្កនេះកើតឡើងដល់អាត្មាអញហើយ ក៏ឯវិហិង្សាវិតក្កនោះឯងតែងប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនឯងផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាង គឺ ខ្លួនឯង និងបុគ្គលដទៃផង ជាធម៌ធ្វើបញ្ញាឲ្យ

រលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ កាលតថាគតទើបតែនឹងពិចារណាថា វិហិង្សាវិតក្កនេះ តែងប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនដូច្នេះ ក៏វិហិង្សាវិតក្កនោះដល់នូវសេចក្ដីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាថា វិហិង្សាវិតក្កនេះ តែងប្រព្រឹត្តទៅ ដើម្បីបៀតបៀននូវបុគ្គលដទៃដូច្នេះ វិហិង្សាវិតក្កនោះក៏ដល់នូវសេចក្ដីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញថា វិហិង្សាវិតក្កនេះ តែងប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាង គឺ ខ្លួនឯង និង បុគ្គលដទៃដូច្នេះ វិហិង្សាវិតក្កនោះ ក៏ដល់នូវសេចក្ដីវិនាសទៅ ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញថា វិហិង្សាវិតក្កនេះ ជាធម៌ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានដូច្នេះ វិហិង្សាវិតក្កនោះ ក៏ដល់នូវសេចក្ដីវិនាសទៅ ។ ម្នាលភិក្ខុទាំងឡាយ ទើបតថាគតនោះឯងលះបង់ គឺបន្ទោបង់នូវវិហិង្សាវិតក្ក ដែលកើតឡើងហើយៗ ធ្វើវិហិង្សាវិតក្កនោះមិនឲ្យសេសសល់នៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ នូវអារម្មណ៍ដ៏ចម្រើន ដោយអាការណាៗ ចិត្តក៏បង្អោនទៅកាន់អារម្មណ៍នោះដោយអាការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ នូវកាមវិតក្កឲ្យច្រើនហើយ ក៏ឈ្មោះថា លះបង់នូវនេក្ខម្មវិតក្ក បើធ្វើនូវកាមវិតក្កឲ្យច្រើនហើយ ចិត្តរបស់ភិក្ខុនោះនឹងឱនទៅ ដើម្បីកាមវិតក្ក ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ ( ត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ) នូវព្យាបាទវិតក្ក ... ។ ម្នាលភិក្ខុ

ទាំងឡាយ បើភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ នូវវិហិង្សាវិតក្កឲ្យច្រើន ហើយ ឈ្មោះថា លះបង់នូវវិហិង្សាវិតក្ក បើធ្វើនូវវិហិង្សាវិតក្កឲ្យច្រើនហើយ ចិត្តរបស់ភិក្ខុនោះនឹងឱនទៅដើម្បីវិហិង្សាវិតក្ក ។ ម្នាលភិក្ខុទាំងឡាយ ដូចជា គង្វាលគោ រក្សាគោទាំងឡាយ ក្នុងទីចង្អៀតដោយសំណាប ក្នុងសរទសម័យ គឺ ខែជាខាងចុងនៃវស្សានរដូវ គង្វាលគោនោះ វាយគោ កៀងប្រមូលនូវគោទាំងឡាយ អំពីទីចង្អៀតនោះៗ ដោយដំបង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា គង្វាលគោនោះ ឃើញនូវទោស គឺការសម្លាប់ ការចាប់ចង សេចក្តីវិនាស និងពាក្យតិះដៀល ព្រោះតែគោស៊ីស្រូវរបស់បុគ្គលដទៃនោះជាហេតុ យ៉ាងណាមិញ ម្នាលភិក្ខុទាំង-ឡាយ តថាគតបានឃើញនូវទោសដ៏ថោកទាបសៅហ្មង របស់អកុសលធម៌ទាំងឡាយ និងអានិសង្សខាងសេចក្តីផូរផង់ក្នុងនេក្ខម្ម របស់កុសលធម៌ទាំង-ឡាយយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនោះជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតនូវកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ នេក្ខម្មវិតក្កកើតឡើង តថាគតតែងដឹងច្បាស់យ៉ាងនេះថា នេក្ខម្ម-វិតក្កនេះកើតឡើងដល់អាត្មាអញហើយ នេក្ខម្មវិតក្កនោះឯង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាង គឺខ្លួនឯង និងបុគ្គលដទៃទេ ជាវិតក្កធ្វើបញ្ញាឲ្យចម្រើន ជាចំណែកនៃសេចក្តីមិនចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយៗ ពិចារណា

រឿយៗ នូវនេក្ខម្មវិតក្កនោះអស់មួយរាត្រី តថាគតក៏មិនបានឃើញភ័យ ព្រោះមាននេក្ខម្មវិតក្កនោះជាហេតុទេ ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយៗ ពិចារណារឿយៗ នូវនេក្ខម្មវិតក្កនោះអស់មួយថ្ងៃ ក៏តថាគតមិនបានឃើញនូវភ័យ ព្រោះមាននេក្ខម្មវិតក្កនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយៗ ពិចារណារឿយៗ នូវនេក្ខម្មវិតក្កនោះអស់យប់ និងថ្ងៃ ក៏តថាគតមិនបានឃើញភ័យ ព្រោះមាននេក្ខម្មវិតក្កនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតនោះឯងគិតថា កាលតថាគតកំពុងត្រិះរិះរឿយៗ ពិចារណារឿយៗ យូរពេកទៅ កាយក៏លំបាក កាលបើកាយលំបាកហើយ ចិត្តក៏រួញរា កាលបើចិត្តរួញរាហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ទើបតម្កល់ចិត្ត ឲ្យនឹងនៅតែខាងក្នុង ធ្វើចិត្តឲ្យស្ងប់ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ តាំងចិត្តឲ្យមាំ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះតថាគតឃាត់ចិត្តថា ចិត្តរបស់តថាគតកុំរវើរវាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកិលេស មានចិត្តបញ្ជូនទៅយ៉ាងនេះហើយ អព្យាបាទវិតក្កក៏កើតឡើង ។បេ។ អវិហិង្សាវិតក្កក៏កើតឡើង តថាគតនោះដឹងច្បាស់យ៉ាងនេះថា អវិហិង្សាវិតក្កនេះកើតឡើងដល់អាត្មាអញហើយ ក៏ឯអវិហិង្សាវិតក្កនោះឯង មិនបានប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃទេ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនទាំងពីរខាង គឺខ្លួនឯង និងបុគ្គលដទៃទេ ជាវិតក្កធ្វើបញ្ញាឲ្យចម្រើន ជាចំណែកនៃសេចក្តីមិនចង្អៀតចង្អល់ ប្រព្រឹត្តទៅ

ដើម្បីព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយៗ ពិចា-
រណារឿយៗ នូវអវិហិង្សាវិតក្កនោះ អស់មួយរាត្រីហើយ ក៏តថាគតមិនបាន
ឃើញនូវភ័យព្រោះមានអវិហិង្សាវិតក្កនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំង-
ឡាយ បើទុកជាតថាគតត្រិះរិះរឿយៗ ពិចារណារឿយៗ នូវអវិហិង្សាវិតក្ក
នោះអស់មួយថ្ងៃ ក៏តថាគតមិនបានឃើញនូវភ័យ ព្រោះមានអវិហិង្សាវិតក្ក
នោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាតថាគតត្រិះរិះរឿយៗ
ពិចារណារឿយៗ នូវអវិហិង្សាវិតក្កនោះ អស់យប់ និងថ្ងៃ ក៏តថាគតមិន
បានឃើញនូវភ័យ ព្រោះមានអវិហិង្សាវិតក្កនោះជាហេតុឡើយ ។ ម្នាលភិក្ខុ
ទាំងឡាយ មួយទៀត តថាគតនោះឯងគិតថា កាលអាត្មាអញត្រិះរិះរឿយៗ
ពិចារណារឿយៗ យូរពេកទៅ កាយក៏លំបាក កាលបើកាយលំបាកហើយ
ចិត្តក៏រួញរា កាលបើចិត្តរួញរាហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ទើបតម្កល់ចិត្ត
ឲ្យនឹងនៅតែខាងក្នុង ធ្វើចិត្តឲ្យស្ងប់ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ តាំងចិត្ត
ឲ្យមាំ ដំណើរនោះព្រោះហេតុអ្វី ព្រោះតថាគតឃាត់ចិត្តថា ចិត្តរបស់តថាគត
កុំរួញរាឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ
នូវអារម្មណ៍ដ៏ច្រើនដោយអាការណាៗ ចិត្តក៏ឱនទៅកាន់អារម្មណ៍នោះ ដោយ
អាការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ
នូវនេក្ខម្មវិតក្កដោយច្រើនហើយ ឈ្មោះថា លះបង់នូវកាមវិតក្ក ហើយធ្វើ
នេក្ខម្មវិតក្កឲ្យចម្រើន ចិត្តរបស់ភិក្ខុនោះ រមែងឱនទៅដើម្បីនេក្ខម្មវិតក្ក ។
ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះរឿយៗ នូវអព្យាបាទវិតក្ក ... ។ ម្នាលភិក្ខុ

ទាំងឡាយ បើភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ នូវអវិហិង្សាវិតក្កឲ្យច្រើនហើយ ឈ្មោះថា លះបង់នូវវិហិង្សាវិតក្ក ធ្វើអវិហិង្សាវិតក្កឲ្យចម្រើន ចិត្តរបស់ភិក្ខុនោះ រមែងឱនទៅដើម្បីអវិហិង្សាវិតក្ក ។ ម្នាលភិក្ខុទាំងឡាយ ដូចគង្វាលគោរក្សាគោទាំងឡាយ ក្នុងទីទាំងពួងដែលមាននៅក្នុងស្រុក ក្នុងខែជាខាងចុងនៃគិម្ហរដូវ គង្វាលគោនោះ ទោះចូលទៅកាន់ទីជិតឈើ ឬចូលទៅនៅក្នុងទីវាល គួរធ្វើសតិថា គោទាំងឡាយមានប្រមាណប៉ុណ្ណេះ សេចក្តីនោះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរធ្វើសតិថា ធម៌ទាំងឡាយមានប្រមាណប៉ុណ្ណេះ សេចក្តីនេះក៏យ៉ាងនោះដែរ ។

[ ២៥៣ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមដែលតថាគតបានផ្តើមហើយ មិនបន្ធូរបន្ថយឡើយ ទាំងស្មារតី ក៏តថាគតប្រុង មិនឲ្យមានភ្លាត់ កាយសោត ក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ម្នាលភិក្ខុទាំងឡាយ លុះតថាគតឯង ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ បីតិ សុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ។ លុះតថាគតបានដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន ចិត្តប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កមិនមានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ព្រោះរម្ងាប់បង់នូវវិតក្ក និងវិចារៈ ។បេ។ ចូលតតិយជ្ឈាន ... ។ ចូលចតុត្ថជ្ឈាន ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជា

ចិត្តទន់ គួរដល់កម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រយ៉ាងនេះហើយ តថាគត នោះក៏បង្អោនចិត្តទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ តថាគតនោះរឭកនូវជាតិដែលអាស្រ័យនៅពីមុនមកបានច្រើនប្រការ គឺ រឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកនូវជាតិដែលអាស្រ័យនៅពីមុនមកបានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បឋមវិជ្ជានេះឯងហើយ ដែលតថាគតបានត្រាស់ដឹងក្នុងបឋមយាមនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លាត់បាត់ទៅ សេចក្តីចេះដឹងក៏កើតប្រាកដឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងអង្គុយប្រុងស្មារតីមិនប្រហែសធ្វេស ទំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លុង ( ឥតមាននឹកនាដល់កាយ និងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយដែលបាននូវបឋមវិជ្ជានោះដូច្នោះដែរ ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់កម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រយ៉ាងនេះហើយ ទើបតថាគតបង្អោនចិត្តទៅក្នុងចុតូបបាតញ្ញាណ ( ប្រាជ្ញាដែលរឭកឃើញនូវចុតិ និងបដិសន្ធិ ) នៃសត្វទាំងឡាយ តថាគតនោះពិចារណាមើលនូវពួកសត្វ ដែលច្យុតទៅ កើតឡើង ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុនៃមនុស្ស ។បេ។ ថា អើហ្ន៎ សត្វទាំងឡាយអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ។បេ។ តថាគតពិចារណាមើល នូវពួកសត្វដែលច្យុតទៅ និងកើតឡើង ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ និងអាក្រក់ទៅកាន់សុគតិ និងទុគ្គតិ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្ស ក៏

ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ វិជ្ជាទី ២ នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងហើយក្នុងមជ្ឈិមយាមនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅបាត់ទៅ សេចក្តីចេះដឹងប្រាកដក៏កើតឡើង ងងឹតខ្វាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ទុង ( ឥតមាននឹកនាដល់កាយ និងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី ២ នោះដូច្នោះដែរ ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រយ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ( ប្រាជ្ញាដែលជ្រាបច្បាស់ នូវកិរិយាអស់ទៅនៃអាសវធម៌ទាំងឡាយ ) តថាគតនោះដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាជកតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាជកតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យដល់នូវសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តតថាគតក៏ផុតស្រឡះ ចាកកាមាសវៈ ( គ្រឿងត្រាំ គឺ កាម ) ផង ផុតស្រឡះចាកភវាសវៈ ( គ្រឿងត្រាំ គឺ ភព ) ផង ផុតស្រឡះចាកអវិជ្ជាសវៈ

( គ្រឿងត្រាំគឺអវិជ្ជា )ផង កាលបើចិត្តតថាគតផុតស្រឡះ( ចាកអាសវធម៌ ) ហើយ ប្រាជ្ញាក៏កើតប្រាកដថា អាត្មាអញផុតស្រឡះ ( ចាកអាសវធម៌ ) ហើយ តថាគតដឹងច្បាស់ថា កំណើត ( របស់អាត្មាអញ ) អស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានឃើញស្រេចហើយ កិច្ចដទៃក្រៅពីសោឡសកិច្ចនេះ ទៅទៀតមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ វិជ្ជាទី ៣ នេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងបច្ឆិមយាមនៃរាត្រី លុះដល់អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់តថាគតដែលកំពុងប្រុងស្មារតីមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ទុង ( ឥតមានទឹកនាដល់កាយ និងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយ ដែលបានទូវវិជ្ជាទី ៣ នោះដូច្នោះដែរ ។

[២៥៤] ម្នាលភិក្ខុទាំងឡាយ ដូចជាត្រពាំងទំនាបធំ ក្នុងដងព្រៃធំ មានពួកម្រឹគច្រើន ចូលទៅអាស្រ័យនៅនឹងត្រពាំងនោះ បុរសណាមួយដែលប្រាថ្នានូវសេចក្តីវិនាស មិនប្រាថ្នានូវប្រយោជន៍ មិនប្រាថ្នានូវសេចក្តីក្សេមដល់ពួកម្រឹគនោះ បុរសនោះក៏បិទផ្លូវដែលក្សេមដែលប្រកបដោយសួស្តី និងគួរដល់សេចក្តីត្រេកអរ ដល់ពួកម្រឹគនោះ ហើយបើកផ្លូវខុស ស្រះសម្រាស់ចងទុកនៅមេម្រឹគធ្លាក់ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ លុះសម័យខាងក្រោយមក ពួកម្រឹគច្រើននោះឯង ក៏ដល់នូវសេចក្តីវិនាស ស្តួចស្តើងទៅដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុរសណាមួយដែលប្រាថ្នា

នូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីក្សេម ដល់ពួកម្រឹគច្រើននោះ បុរសនោះក៏បើកនូវផ្លូវដែលក្សេមក្សាន្ត ដែលប្រកបដោយសួស្តី ទាំងគួរដល់សេចក្តីត្រេកអរដល់ពួកម្រឹគនោះ ហើយបើកនូវផ្លូវនោះ បិទនូវផ្លូវខុស រើយកសម្រាស់ចេញ ធ្វើមេម្រឹគផ្ទាក់ឲ្យវិនាស ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ លុះសម័យខាងក្រោយមក ពួកម្រឹគច្រើននោះ ក៏ដល់នូវសេចក្តីចម្រើនកុះករ បរិបូណ៌ឡើងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះ តថាគតធ្វើដើម្បីបញ្ជាក់នូវសេចក្តីនេះប៉ុណ្ណោះ ។ សេចក្តីអធិប្បាយក្នុងពាក្យឧបមានេះ ដូចសម្តែងតទៅ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ត្រពាំងទំនាបធំនោះ គឺជាឈ្មោះរបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ពួកម្រឹគច្រើននោះ ជាឈ្មោះរបស់ពួកសត្វច្រើន ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា បុរសមិនប្រាថ្នានូវសេចក្តីចម្រើន មិនប្រាថ្នានូវប្រយោជន៍ មិនប្រាថ្នានូវសេចក្តីក្សេមនោះ ជាឈ្មោះនៃមារដែលមានធម៌ដ៏លាមក ។ ត្រង់ពាក្យថា ផ្លូវខុសនោះ ជាឈ្មោះមិច្ឆាមគ្គ ( ផ្លូវខុស ) ប្រកបដោយអង្គ ៨ ប្រការ គឺមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆា-វាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា សម្រាស់នុ៎ះ ជាឈ្មោះនៃនន្ទិរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មេម្រឹគផ្ទាក់នោះ ជាឈ្មោះនៃអវិជ្ជា ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា បុរសប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីក្សេមក្សាន្តនុ៎ះ ជាឈ្មោះនៃតថាគត ជាអរហន្ត-

សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ផ្លូវក្សេមក្សាន្តដែលប្រកបដោយសួស្តី គួរដល់សេចក្តីត្រេកអរនោះ ជាឈ្មោះនៃអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

[២៥៥] ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលក្សេមប្រកបដោយសួស្តី ជាផ្លូវគួរដល់សេចក្តីត្រេកអរ តថាគតបានបើកហើយ ផ្លូវខុសក៏តថាគតបិទហើយ សម្រាស់ក៏តថាគតរើចោលហើយ មេម្រឹគឈ្នាក់ក៏តថាគតធ្វើឲ្យវិនាសហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចណាដែលតថាគតជាសាស្តា ជាអ្នកស្វែងរកប្រយោជន៍ មានសេចក្តីអនុគ្រោះ ត្រូវធ្វើដល់អ្នកទាំងឡាយជាសាវ័ក ព្រោះអាស្រ័យសេចក្តីអនុគ្រោះ កិច្ចនោះតថាគតបានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្លឹងមើលនូវគល់ឈើទាំងនុ៎ះ នូវសុញ្ញាគារទាំងនុ៎ះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយកុំប្រមាទ កុំមានសេចក្តីក្តៅក្រហាយស្តាយក្រោយឡើយ ។ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ក៏ភិក្ខុទាំងនោះ មានសេចក្តីពេញចិត្តត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគជាម្ចាស់ ។

ទ្វេធាវិតក្កសូត្រទី ៩ ចប់

## អដ្ឋកថា

## ទ្វេធាវិតក្កសូត្រ

[ ២៥១ ] ទ្វេធាវិតក្កសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។

[ ២៥២ ] ក្នុងបទទាំងនោះ បទថា **ទ្វេធា កត្វា ទ្វេធា កត្វា** សេចក្ដីថា ធ្វើឲ្យជា ២ ភាគ ។ វិតក្កដែលប្រកបដោយកាម ឈ្មោះថា **កាមវិតក្ក** ។ វិតក្កដែលប្រកបដោយការប្រទូស្ត ឈ្មោះថា **ព្យាបាទវិតក្ក** ។ វិតក្កដែលប្រកបដោយការបៀតបៀន ឈ្មោះថា **វិហិង្សាវិតក្ក** ។ បទថា **ឯកំ ភាគំ** សេចក្ដីថា វិតក្កទាំងអស់នេះ ទាំងខាងក្នុង និងខាងក្រៅ គ្រោតគ្រាត ឬល្អិត ក៏ជាចំណែកនៃអកុសលនោះឯង ព្រោះដូច្នោះ ទើបតថាគតធ្វើកាមវិតក្ក ព្យាបាទវិតក្ក និងវិហិង្សាវិតក្កទាំង ៣ ឲ្យជាចំណែកទី ១ ។ វិតក្កដែលរលាស់ចេញចាកកាមទាំងឡាយ ហើយប្រកបព្រមដោយនេក្ខម្មៈ ឈ្មោះថា **នេក្ខម្មវិតក្ក** ។ នេក្ខម្មវិតក្កនោះ រមែងគួរដល់បឋមជ្ឈាន ។ វិតក្កដែលប្រកបព្រមដោយការមិនបំណងអាក្រក់ ឈ្មោះថា **អព្យាបាទវិតក្ក** ។ អព្យាបាទវិតក្កនោះ រមែងគួរតាំងអំពីមេត្តាបុព្វភាគ រហូតដល់បឋមជ្ឈាន ។ វិតក្កដែលប្រកបព្រមដោយការមិនបៀតបៀន ឈ្មោះថា **អវិហិង្សាវិតក្ក** ។ អវិហិង្សាវិតក្កនោះ រមែងគួរតាំងអំពីករុណាបុព្វភាគ រហូតដល់បឋមជ្ឈាន ។ បទថា **ទុតិយភាគំ** សេចក្ដីថា លោកសម្ដែងកាលវេលាក្នុងការសង្កត់វិតក្ករបស់ព្រះពោធិសត្វ ដោយបទនេះថា វិតក្កទាំងអស់នេះ ជាចំណែកកុសល

ទាំងនោះ ព្រោះដូច្នោះ ទើបតថាគតធ្វើឲ្យជាចំណែកទី ២ ។ កាលព្រះពោធិសត្វទ្រង់ផ្តើមប្រារព្ធព្យាយាមអស់ ៦ ឆ្នាំ វិតក្កទាំងឡាយ មាននេក្ខម្ម-វិតក្កជាដើម បានប្រព្រឹត្តទៅហើយ ដូចជំនន់ទឹកជំពេញប្រាំង ដូច្នោះ វិតក្កទាំងឡាយ មានកាមវិតក្កជាដើម កើតឡើងរហ័ស ព្រោះការភ្លេចស្មារតីកាត់វារៈនៃកុសល ក្លាយជាវារៈស្មុះទៅនៃអកុសល តាំងនៅ បន្ទាប់អំពីនោះព្រះពោធិសត្វទ្រង់ត្រិះរិះថា វិតក្កទាំងឡាយ មានកាមវិតក្កជាដើមរបស់អញនេះ បានកាត់ផ្តាច់វារៈនៃកុសល តាំងនៅ ណ្ហើយចុះ អញនឹងធ្វើវិតក្កទាំងនេះឲ្យជា ២ ចំណែក ព្រោះដូច្នោះ ទើបតថាគតធ្វើចំណែក ១ ថា វិតក្កមានកាមវិតក្កជាដើម ជាចំណែកអកុសល ធ្វើចំណែក ១ ទៀត នេក្ខម្ម-វិតក្កជាដើមជាចំណែកកុសល លំដាប់នោះ តថាគតនឹងសង្កត់វិតក្កដែលជាចំណែកអកុសល ដោយការដឹង ដូចសង្កត់ពស់វែក ហើយចាប់ និងដូចសង្កត់កសត្រូវ ដូច្នោះ តថាគតមិនឲ្យអកុសលវិតក្កនោះចម្រើន តថាគតនឹងញុំាងវិតក្កដែលជាចំណែកកុសលឲ្យចម្រើនរហ័ស ដូចពពកក្នុងសម័យភ្លៀង និងដូចស្រែល្អ ដែលមានពូជដុះ ដូច្នោះ ព្រះពោធិសត្វនោះ ទ្រង់ធ្វើដូច្នោះហើយ សង្កត់អកុសលវិតក្កទាំងឡាយ ញុំាងកុសលវិតក្កទាំងឡាយឲ្យចម្រើន ។ ក្នុងកាលសង្កត់វិតក្ករបស់ព្រះពោធិសត្វ គប្បីជ្រាបថា លោកសម្តែងហើយដោយបទនេះ ដោយប្រការដូច្នេះ ។ វិតក្កទាំងនោះ កើតឡើងដល់ព្រះពោធិសត្វនោះដោយប្រការណា ព្រះពោធិសត្វទ្រង់សង្កត់វិតក្កទាំងនោះ ដោយប្រការណា ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រការ

នោះ ទើបត្រាស់ថា **តស្ស មយ្ហំ ភិក្ខវេ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អប្បមត្តស្ស** សេចក្ដីថា តាំងនៅក្នុងការមិននៅប្រាសចាកសតិ ។ បទថា **អាតាបិនោ** សេចក្ដីថា មានសេចក្ដីព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ។ បទថា **បហិតស្ស** សេចក្ដីថា មានចិត្តបញ្ជូនទៅហើយ ។ បទថា **ឧប្បជ្ជតិ កាមវិតក្កោ** សេចក្ដីថា កាលព្រះពោធិសត្វ ទ្រង់ផ្ដើមសេចក្ដីព្យាយាមអស់ ៦ ឆ្នាំ កាមវិតក្កដែលប្រារព្ធសេចក្ដីសុខក្នុងការគ្រងរាជ-សម្បត្តិ ប្រាសាទ ស្រីរបាំ ដំណាក់ស្រីស្នំ ឬប្រារព្ធសម្បត្តិណាមួយ ធ្លាប់កើតឡើងហើយ ។ ព្រះពោធិសត្វនោះ ទ្រង់ដល់នូវការសមាទានដ៏កំពូលដោយទ្រង់អត់ព្រះក្រយាហារ ក្នុងការបំពេញទុក្ករកិរិយា ទ្រង់មានព្រះតម្រិះថា បុគ្គលអត់អាហារ មិនអាចញុំាងគុណវិសេសឲ្យកើតឡើងបានឡើយណ្ហើយចុះ អញគប្បីនាំអាហារគ្រោតគ្រាតមកសោយ ដូច្នេះ ។ ព្រះពោធិ-សត្វនោះ យាងចូលឧរុវេលានិគមដើម្បីដុំបាយ ។ មនុស្សទាំងឡាយគិតថា ក្នុងកាលមុនមហាបុរស ទ្រង់មិនទទួលអាហារសូម្បីនាំមកប្រគេន ឥឡូវនេះប្រហែលមនោរថរបស់ព្រះអង្គដល់ទីបំផុតហើយ ព្រោះដូច្នោះ ទើបស្ដេចមកឯង ឥឡូវនេះ ទើបនាំគ្នាយកអាហារប្រណីតៗ ទៅប្រគេន អត្តភាពរបស់ព្រះពោធិសត្វក៏ត្រឡប់ដូចប្រក្រតី ក្នុងកាលមិនយូរឡើយ ។ ពិតហើយ អត្តភាពដែលគ្រាំគ្រាព្រោះជរា សូម្បីបានភោជនជាទីសប្បាយ ក៏មិនត្រឡប់ទៅជាប្រក្រតីបាន ។ តែព្រះពោធិសត្វនៅក្មេង ព្រោះហេតុនោះ កាលព្រះពោធិសត្វនោះសោយព្រះក្រយាហារជាទីសប្បាយ ទើបអត្តភាពត្រឡប់ទៅ

ជាប្រក្រតី ដោយមិនយូរឡើយ ។ ឥន្ទ្រិយទាំងឡាយក៏ផូរផង់ ព្រះឆវីវណ្ណក៏បរិសុទ្ធ ព្រះសរីរៈដែលលម្អដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ក៏បរិបូណ៌ ដូចហ្វូងផ្កាយចរកាត់លម្ហមេឃ ដូច្នោះ ។ ព្រះពោធិសត្វនោះ ទ្រង់សម្លឹងមើលអត្តភាពនោះហើយ ត្រិះរិះថា អត្តភាពដែលលំបាកដល់ម៉្លោះ ត្រឡប់ជាប្រក្រតីយ៉ាងនេះ ទ្រង់កាន់យកវិតក្កតិចតួចយ៉ាងនេះ ព្រោះទ្រង់មានបញ្ញាច្រើន ទើបទ្រង់ធ្វើដោយព្រះតម្រិះថា កាមវិតក្ក ។ ព្រះអង្គប្រថាប់គង់ខាងមុខសាលាស្លឹក ទ្រង់ឃើញពួកម្រឹគ មានទ្រាយ ក្តាន់ ប្រើស គោ រមាំងជាដើម ពួកបក្សី មានក្ងោក មាន់ព្រៃជាដើម ដែលបន្លឺសំឡេងពីរោះ គួរទាក់ទាញចិត្ត បឹងទាំងឡាយដ៏ដេរដាស ដោយឧប្បលខៀវ កុមុទ និងកមលជាដើម ដងព្រៃស្វាត់ជ្រងំ ដេរដាសដោយផ្កាច្រើនប្រភេទ ស្ទឹងនេរញ្ជរាដែលហូរក្តួចទឹកល្អក់ នៅសល់តែទឹកថ្លាឆ្វេង ដូចកែវមណី ។ ព្រះពោធិសត្វនោះ ទ្រង់មានព្រះតម្រិះថា ហ្វូងម្រឹគ ពពួកបក្សី បឹង ដងព្រៃ ស្ទឹងនេរញ្ជរាទាំងនេះ ស្រស់ស្អាតហ្ន៎ ដូច្នេះ ។ ព្រះអង្គទ្រង់កាន់យកវិតក្កបន្តិចបន្តួចយ៉ាងនេះ ទ្រង់ធ្វើកាមវិតក្ក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កាមវិតក្ករមែងកើតឡើង ដូច្នេះ ។ បទថា **អត្តព្យាពាធាយបិ** សេចក្តីថា ដើម្បីសេចក្តីទុក្ខដល់ខ្លួនខ្លះ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នា ។ សួរថា ឈ្មោះថា វិតក្កដែលប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខដល់ចំណែកទាំង ២ នៃព្រះមហាសត្វមានឬ ឆ្លើយថា មិនមាន ។ កាលព្រះមហាសត្វតាំងនៅក្នុងការមិនកំណត់ដឹង វិតក្ករមែងប្រព្រឹត្តទៅរហូតដល់ការ

បៀតបៀនទាំង ២ ចំណែក ព្រោះដូច្នោះ ទើបបានឈ្មោះ ៣ យ៉ាងនោះ យ៉ាងនេះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ បទថា **បញ្ញានិរោធិកោ** សេចក្ដីថា រមែងមិនឲ្យបញ្ញាជាលោកិយក្ដី លោកុត្តរក្ដី កើតឡើង ។ វិតក្កកាត់លោកិយប្បញ្ញាដែលកើតឡើងហើយ ដោយអំណាចនៃសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យអស់ទៅ ព្រោះដូច្នោះ ទើបធ្វើឲ្យបញ្ញាវលត់ ។ បទថា **វិឃាតបក្ខិកោ** សេចក្ដីថា ជាចំណែកនៃទុក្ខ ។ ឈ្មោះថា មិនប្រព្រឹត្តទៅដើម្បីនិព្វាន ព្រោះវិតក្កនោះមិនធ្វើព្រះនូវនិព្វាន ដែលមិនមានបច្ច័យតាក់តែងនោះឲ្យប្រចក្ស ។ បទថា **អព្ភត្ថំ គច្ឆតិ** សេចក្ដីថា ដល់នូវការអស់ទៅ គឺការមិនមាន គឺរលត់ទៅ ដូចដុំពពុះទឹក ដូច្នោះ ។ បទថា **បជហមេវ** គឺចោលហើយនោះឯង ។ បទថា **វិនោទនមេវ** គឺនាំចេញទៅហើយនោះឯង ។ បទថា **ព្យន្តមេវនំ អកាសឹ** សេចក្ដីថា តថាគតធ្វើវិតក្កនោះឲ្យទៅប្រាស មិនមានសេសសល់វិលត្រឡប់ បិទបាំងនោះឯង ។ បទថា **ព្យាបាទវិតក្កោ** សេចក្ដីថា វិតក្កដែលឈ្មោះថា ប្រកបព្រមដោយការបៀតបៀនអ្នកដទៃ រមែងមិនកើតក្នុងព្រះហឫទ័យរបស់ព្រះពោធិសត្វ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដៅដល់កាលដែលព្រះពោធិសត្វនោះទ្រង់បង្អោនចិត្តទៅ ព្រោះអាស្រ័យហេតុទាំងឡាយ មានភ្លៀងខ្លាំង ក្ដៅខ្លាំង និងរងាខ្លាំងជាដើមនោះ ទើបត្រាស់ថា ព្យាបាទវិតក្ក ដូច្នេះ ។ បទថា **វិហិង្សាវិតក្កោ** សេចក្ដីថា វិតក្កដែលប្រកបព្រមដោយការញុំាងទុក្ខ ឲ្យកើតឡើងដល់អ្នកដទៃ រមែងមិនកើតឡើងដល់ព្រះពោធិសត្វ ។ តែអាការ

នៃការរាយមាយក្នុងព្រះហឫទ័យ ជាអាការនៃអារម្មណ៍ច្រើនប្រការ ព្រះពោធិសត្វទ្រង់កាន់យកអាការនោះ ធ្វើវិហិង្សាវិតក្ក ។ ព្រោះព្រះអង្គប្រថាប់គង់ក្នុងទ្វារនៃបណ្ណសាលា ទ្រង់ឃើញសត្វសាហាវ មានសីហៈ និងខ្លាធំជាដើមកំពុងបៀតបៀនម្រឹគតូចៗ មានជ្រូកជាដើម ។ លំដាប់នោះ ព្រះពោធិសត្វទ្រង់ត្រិះរិះថា សត្រូវទាំងឡាយរមែងកើតឡើងដល់តិរច្ឆានទាំងនេះ ក្នុងព្រៃដែលមិនមានភ័យនេះ ពួកសត្វមានកម្លាំងខ្លាំង ស៊ីសត្វមានកម្លាំងតិច ពួកសត្វស៊ីសត្វមានកម្លាំងតិច រមែងប្រព្រឹត្តទៅបាន ដូច្នេះ ទ្រង់ញ៉ាំងករុណាឲ្យកើតឡើង ទ្រង់ឃើញសត្វដទៃ មានឆ្មាជាដើមកំពុងស៊ីសត្វ មានមាន់ និងកណ្ដុរជាដើម ។ ទ្រង់ចូលស្រុកដើម្បីបិណ្ឌបាត ទ្រង់ញ៉ាំងព្រះករុណាឲ្យកើតឡើងថា មនុស្សទាំងឡាយត្រូវរាជការបៀតបៀន សោយទុក្ខមានការសម្លាប់ និងការចងជាដើម រមែងមិនបានធ្វើការងាររបស់ខ្លួន មានធ្វើស្រែ និងលក់ដូរចិញ្ចឹមជីវិតជាដើម ។ ទ្រង់សំដៅដល់ករុណានោះ ទើបត្រាស់ថា វិហិង្សាវិតក្ករមែងកើតឡើង ។ បទថា **តថា តថា** សេចក្ដីថា ដោយហេតុនោះៗ ។ លោកអធិប្បាយយ៉ាងនេះថា ទ្រង់ត្រិះរិះដោយវិតក្កណាមួយ ក្នុងកាមវិតក្កជាដើម ហើយទ្រង់ញ៉ាំងវិតក្កណាមួយឲ្យប្រព្រឹត្តទៅព្រះពោធិសត្វនោះ មិនមានព្រះហឫទ័យដោយកាមវិតក្កជាដើមនោះឡើយដោយប្រការនោះៗ ។ បទថា **បហាសិ នេក្ខម្មវិតក្កំ** សេចក្ដីថា លះនេក្ខម្មវិតក្ក ។ បទថា **ពហុលមកាសិ** សេចក្ដីថា បានធ្វើឲ្យច្រើន ។ បទថា **តស្ស តំ កាមវិតក្កាយ ចិត្តំ** សេចក្ដីថា ព្រះហឫទ័យរបស់ព្រះពោធិសត្វ

នោះ រមែងបង្អោនទៅដើម្បីប្រយោជន៍ដល់កាមវិតក្ក ដោយប្រការដែលប្រកបព្រមដោយកាមវិតក្កនោះឯង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។

ឥឡូវនេះ កាលទ្រង់សម្តែងឧបមាដែលសម្តែងដល់អត្ថ ទើបត្រាស់ថា **សេយ្យថាបិ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **កិដ្ឋសម្ពាធេ** សេចក្តីថា ក្នុងទីចង្អៀតដោយសន្ទូង ។ បទថា **អាកោដេយ្យ** សេចក្តីថា វាយគោត្រង់ខ្នង ។ បទថា **បដិកោដេយ្យ** សេចក្តីថា វាយឆ្អឹងជំនីរ គឺវាយសងខាង ។ បទថា **សន្និរុម្ភេយ្យ** សេចក្តីថា ហាមហើយ គឺឲ្យឈប់ ។ បទថា **សន្និវារេយ្យ** សេចក្តីថា មិនគប្បីឲ្យទៅក្នុងផ្លូវនោះ និងផ្លូវនេះ ។ បទថា **តតោ និទានំ** សេចក្តីថា ដោយហេតុនោះ គឺដោយហេតុដែលគោទាំងឡាយមិនបានរក្សាយ៉ាងនោះ ស៊ីសន្ទូងរបស់មនុស្សដទៃ ។ នាយគោបាលល្ងង់ កាលមិនរក្សាគោទាំងឡាយ រមែងដល់នូវសេចក្តីទុក្ខ មានការសម្លាប់ជាដើមអំពីសម្នាក់នៃម្ចាស់គោទាំងឡាយថា អាឃ្វាលគោស៊ីបាយ និងថ្លៃឈ្នួលរបស់អញ មិនអាចរក្សាគោទាំងឡាយដោយត្រង់ បែរជាឲ្យមានពៀរនឹងត្រកូលទាំងឡាយខ្លះ អំពីម្ចាស់របស់សន្ទូងខ្លះ ។ តែនាយគោបាលដែលឈ្លាស កាលឃើញភ័យ ៤ យ៉ាងនេះ រមែងរក្សាគោទាំងឡាយឲ្យផាសុក ។ បទនោះលោកពោលសំដៅដល់ហេតុនោះ ។ បទថា **អាទីនវំ** បានដល់ ឧបទ្រព ។ បទថា **ឱការំ** គឺអាក្រក់លាមក គឺការថោកទាបក្នុងខន្ធទាំងឡាយ ។ បទថា **សង្កិលេសំ** បានដល់ ភាពជារបស់សៅហ្មង ។

បទថា **នេក្ខម្មេ** សេចក្តីថា ក្នុងនេក្ខម្មៈ ។ បទថា **អានិសំសំ** បានដល់ដែលជាចំណែកនៃសេចក្តីបរិសុទ្ធិ ។ បទថា **វោទានបក្ខំ** នេះ ជាវេវចនៈរបស់អានិសង្សនោះ អធិប្បាយថា តថាគតបានឃើញនេក្ខម្មៈជាចំណែកបរិសុទ្ធនៃកុសលធម៌ទាំងឡាយ ។ ម្យ៉ាងទៀត ពាក្យថា **នេក្ខម្ម** គឺព្រះ-និព្វាននោះឯង កាលសង្គ្រោះកុសលធម៌ទាំងអស់ ដែលរលាស់ចេញហើយអំពីកាមទាំងឡាយក្នុងធម្មបទមួយ ។ ក្នុងបទនោះ មានការប្រៀបធៀប ដូច្នេះអារម្មណ៍ មានរូបជាដើម ដូចទីចង្អៀតដោយសន្ទូង ចិត្តកោងដូចគោកាចព្រះពោធិសត្វ ដូចនាយគោបាលអ្នកឈ្លាស វិតក្កដែលប្រព្រឹត្តទៅដើម្បីការបៀតបៀនខ្លួនឯង អ្នកដទៃ និងចំណែកទាំង ២ ប្រៀបដូចភ័យ ៤ យ៉ាងការដែលព្រះពោធិសត្វទ្រង់តាំងសេចក្តីព្យាយាម អស់កាល ៦ ឆ្នាំ ទ្រង់ឃើញភ័យនៃការបៀតបៀនខ្លួន ហើយរក្សាព្រះហឫទ័យក្នុងអារម្មណ៍ទាំង-ឡាយ មានរូបជាដើម ដោយប្រការដែលវិតក្កទាំងឡាយ មានកាមវិតក្កជាដើម មិនកើតឡើង ប្រៀបដូចនាយគោបាលអ្នកឈ្លាសឃើញភ័យ ៤ យ៉ាងហើយរក្សាគោដោយការមិនប្រមាទ ក្នុងទីចង្អៀតដោយសន្ទូង ដូច្នោះ ។ ក្នុងបទថា **បញ្ញានិរោធិកោ** ជាដើម ឈ្មោះថា **បញ្ញានិរោធិក** ព្រោះប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបញ្ញា ទាំងដែលជាលោកិយ និងលោកុត្តរ ដែលមិនទាន់កើតឡើង និងដើម្បីការចម្រើននៃបញ្ញា ជាលោកិយផង លោកុត្តរផងដែលកើតឡើងហើយ ។ ឈ្មោះថា **វិឃាតបក្ខិក** ព្រោះមិនប្រព្រឹត្តទៅដើម្បីចំណែកនៃសេចក្តីទុក្ខ ។ ឈ្មោះថា **និព្វានសំវត្តនិក** ព្រោះប្រព្រឹត្តទៅ

ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វានធាតុ ។ បទថា **រត្តិញ្ចេបិ តំ ភិក្ខវេ អនុវិតក្កេយ្យំ** សេចក្ដីថា បើតថាគតញ៉ាំងវិតក្កនោះឲ្យប្រព្រឹត្តទៅអស់ទាំងរាត្រី ។ បទថា **តតោ និទានំ** បានដល់ មានវិតក្កនោះជាមូល ។ បទថា **ឱហញ្ញេយ្យ** សេចក្ដីថា គប្បីរាយមាយ គឺប្រព្រឹត្តទៅដើម្បីការរាយមាយ ។ បទថា **អារា** គឺក្នុងទីឆ្ងាយ ។ បទថា **សមាធិម្ហា** គឺចាកឧបចារសមាធិខ្លះ ចាកអប្បនាសមាធិខ្លះ ។ បទថា **សោ ខោ អហំ ភិក្ខវេ អជ្ឈត្តមេវ ចិត្តំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ តថាគតនោះតម្កល់នូវចិត្តដែលប្រព្រឹត្តទៅខាងក្នុងថា ចិត្តរបស់អញ កុំនៅក្នុងទីឆ្ងាយអំពីសមាធិនោះឡើយ គឺតម្កល់ចិត្តទុកក្នុងអារម្មណ៍នោះឯង ។ បទថា **សន្និសិទេមិ** សេចក្ដីថា អញញ៉ាំងចិត្តនោះឲ្យស្ងប់នៅក្នុងអារម្មណ៍នោះឯង ។ បទថា **ឯកោទឹ ករោមិ** គឺធ្វើឲ្យមានអារម្មណ៍ ១ ។ បទថា **សមាទហាមិ** សេចក្ដីថា តាំងមាំដោយប្រពៃ គឺលើកឡើងដោយល្អ ។ បទថា **មា មេ ចិត្តំ ឧគ្ឃាដិ** សេចក្ដីថា ចិត្តរបស់តថាគតកុំរាយមាយ គឺកុំប្រព្រឹត្តទៅដើម្បីការរាយមាយឡើយ ក្នុងបទថា **ឧប្បជ្ជតិ អព្យាបាទវិតក្កោ អវិហិង្សាវិតក្កោ** នោះ វិតក្កដែលកើតឡើងព្រមនឹងតរុណវិបស្សនា ដែលបានពោលហើយខាងដើមនោះឯណា លោកពោលថា ជានេក្ខម្មវិតក្ក ព្រោះអត្ថថា ជាសត្រូវចំពោះកាមវិតក្កនោះឯង លោកពោលថា ជាអព្យាទវិតក្ក ព្រោះអត្ថថា ជាសត្រូវចំពោះការប្រទូស្ដ និងជាអវិហិង្សាវិតក្ក ព្រោះអត្ថថា ជាសត្រូវចំពោះការបៀតបៀន ។ លោកសម្ដែងកាលនៃការតាំងវិបស្សនា អាស្រ័យសមាបត្តិរបស់ព្រះពោធិ-

សត្វ ដោយប្រមាណប៉ុណ្ណោះ ។

ព្រះពោធិសត្វនោះ មានសមាធិផង តរុណវិបស្សនាផង កាលព្រះពោធិសត្វនោះតាំងវិបស្សនា ប្រថាប់គង់យូរពេក ព្រះវរកាយរមែងលំបាក រមែងក្តៅដូចភ្លើងក្នុងខាងក្នុង ញើសទាំងឡាយរមែងហូរចេញអំពីព្រះកច្ឆៈ គឺក្លៀក កម្តៅអំពីព្រះសីសៈ ដូចជាវេញ តាំងឡើង ព្រះហឫទ័យរមែងក្តៅក្រហាយសោប់សេល់ ជាចិត្តរាយមាយ ។ តែព្រះពោធិសត្វ ទ្រង់ចូលសមាបត្តិ ហើយបរិកម្មសមាបត្តិនោះ ធ្វើឲ្យទន់ ទ្រង់ស្រាលព្រះទ័យ ទ្រង់តាំងវិបស្សនាទៀត កាលព្រះពោធិសត្វនោះប្រថាប់គង់យូរពេក ព្រះវរកាយក៏ដូច្នោះទៀត ។ ព្រះពោធិសត្វទ្រង់ចូលសមាបត្តិហើយ ទ្រង់ធ្វើយ៉ាងនោះ ព្រោះសមាបត្តិ មានឧបការៈច្រើនដល់វិបស្សនា ។ ប្រៀបដូចជម្ពូតាខែល មានឧបការៈច្រើនដល់ទាហាន ទាហាននោះអាស្រ័យខែលនោះ ចូលសង្គ្រាម កាលអាវុធទាំងឡាយដែលប្រើក្នុងការច្បាំងរួមទាំងពួកដំរី ពួកសេះ និងពួកទាហានក្នុងសង្គ្រាមនោះ គង់មានតែភាពជាអ្នកប្រាថ្នា នឹងបរិភោគជាដើមប៉ុណ្ណោះ ត្រឡប់ហើយ ចូលទៅកាន់បន្ទាយហើយ ចាប់អាវុធទាំងឡាយខ្លះ សាកល្បងខ្លះ បរិភោគខ្លះ ផឹកខ្លះ ចងអាវក្រោះខ្លះ ធ្វើកិច្ចនោះៗ ហើយចូលសង្គ្រាមទៀត ឬធ្វើការច្បាំងក្នុងសង្គ្រាមនោះ កើតឈឺបន្ទោបង់ឧច្ចារៈជាដើម ចូលទៅកាន់បន្ទាយ ដោយកិច្ចដែលគួរធ្វើខ្លះទៀត កាលធ្វើធុរៈស្រេចក្នុងបន្ទាយនោះហើយ ក៏ចូលសង្គ្រាមទៀត ។ សមាបត្តិ មានឧបការៈច្រើនដល់វិបស្សនា ដូចបន្ទាយសម្រាក មានឧបការៈច្រើនដល់ទាហាន

ដូច្នោះ ។ម្យ៉ាងទៀត វិបស្សនាមានឧបការៈដល់សមាបត្តិច្រើនជាង បន្ទាយ របស់ទាហាន ដែលបំណងនឹងរម្ងាប់សង្គ្រាម ។ ពិតហើយ ព្រះពោធិសត្វ ទ្រង់អាស្រ័យសមាបត្តិ ចម្រើនវិបស្សនាក៏ពិត តែវិបស្សនាមានកម្លាំងរមែង រក្សាសមាបត្តិ ធ្វើសមាបត្តិឲ្យមានកម្លាំង ។ ជនទាំងឡាយ កាលជួញដូរ តាមផ្លូវគោក រមែងធ្វើទូក ទំនិញក្នុងទូក ឲ្យជាភារៈរបស់រទេះ តែដល់ ទឹកហើយ រមែងធ្វើរទេះខ្លះ ទំនិញក្នុងរទេះខ្លះ គោខ្លះ ឲ្យជាភារៈរបស់ទូក ទូកកាត់ក្រសែទឹកស្ទុះទៅកាន់កំពង់ ដោយសួស្តី យ៉ាងណា វិបស្សនា អាស្រ័យសមាបត្តិ រមែងប្រព្រឹត្តទៅដោយពិត តែវិបស្សនាមានកម្លាំងរមែង រក្សាសមាបត្តិ រមែងធ្វើសមាបត្តិឲ្យមានកម្លាំងដូច្នោះដូចគ្នា ។ សមាបត្តិ ប្រៀបដូចរទេះដល់គោក វិបស្សនាប្រៀបដូចទូកដល់ទឹក ។ កាលព្រះ ពោធិសត្វអាស្រ័យសមាបត្តិ ហើយតាំងវិបស្សនា លោកសម្តែងហើយ ដោយប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះ ។ បទថា **យញ្ញទេវ** ជាដើម គប្បីជ្រាបតាមគន្លងដែលពោលហើយ ក្នុងចំណែកកាឡបក្ខនោះឯង ។ ព្រះ មានព្រះភាគត្រាស់ថា **សេយ្យថាបិ** ជាដើម ដើម្បីទ្រង់សម្តែងឧបមាដែល សម្តែងអត្ថក្នុងព្រះសូត្រនេះ ។ ក្នុងបទទាំងនោះ បទថា **គាមន្តសម្ភវេសុ** បានដល់ នាំមកជិតស្រុក ។ បទថា **សតិករណីយមេវ ហោតិ** សេចក្តីថា កិច្ចគ្រាន់តែញុំាងសតិឲ្យកើតឡើងថា ទាំងនោះគោ ដូច្នេះហើយ គប្បីធ្វើ គឺ ធ្វើកិច្ច មានការទៅខាងនោះ និងខាងនេះ កិច្ចដោយការវាយមិនមាន ។ កិច្ច គ្រាន់តែញុំាងសតិឲ្យកើតឡើងថា នេះធម៌ នេះសមថវិបស្សនាធម៌នោះឯង

ជាកិច្ចគប្បីធ្វើ ។ កាលនៃសមថៈ និងវិបស្សនារបស់ព្រះពោធិសត្វមានកម្លាំង បានសម្តែងហើយដោយបទនេះ ។ បានឮថា ក្នុងកាលនោះ កាលព្រះពោធិសត្វប្រថាប់គង់ ដើម្បីប្រយោជន៍ដល់សមាបត្តិ និងអប្បនាសមាបត្តិ ៨ ក៏មកកាន់គន្ធងដោយការរពួកតែម្យ៉ាង ។ ទ្រង់តាំងវិបស្សនាប្រថាប់គង់ហើយ ទ្រង់ឡើងកាន់អនុបស្សនាទាំង ៧ ដោយឋានៈជាមួយគ្នានោះឯង ទ្រង់សម្តែងអ្វីក្នុងបទនេះថា **សេយ្យថាបិ** ។

[ ២៥៤ ] អនុសន្ធិចំពោះយ៉ាងនេះ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបការៈដែលអនុគ្រោះដល់សត្វទាំងឡាយ និងសម្បទា គឺការដែលទ្រង់ជាព្រះសាស្តា ទើបទ្រង់ប្រារព្ធទេសនានេះ ។ ក្នុងបទទាំងនោះ បទថា **អរញ្ញេ** បានដល់ ក្នុងព្រៃ ។ បទថា **បវនេ** បានដល់ ដងព្រៃ ។ ២ បទនេះ ក្នុងអត្ថក៏ជាវេវចនៈតែមួយដូចគ្នា ។ បទថា **អយោគក្ខេមកាមោ** សេចក្តីថា ជាអ្នកមិនប្រាថ្នាការក្សេមចាកយោគៈ ៤ គឺទីដែលផុតភ័យនោះឯង ។ បទថា **សោវត្ថិកោ** បានដល់ ដែលនាំមកនូវសួស្តី ។ បទថា **បិតិគមនីយោ** គឺគួរទៅកាន់សេចក្តីត្រេកអរ ។ មួយប្រការទៀត បាលីថា **បីតិគមនីយោ** ។ បទថា **បិធយេយ្យ** គឺស្រះដោយវត្ថុទាំងឡាយ មានមែកឈើជាដើម ។ បទថា **វិវរេយ្យ** សេចក្តីថា គប្បីធ្វើមាត់ផ្លូវឲ្យស្រួលហើយធ្វើផ្លូវបើកទុក ។ បទថា **កុម្មគ្គំ** គឺមិនមែនផ្លូវដែលបិទការពារដោយទឹក ព្រៃ និងភ្នំជាដើម ។ បទថា **ឱធយេយ្យ ឱកចរំ** សេចក្តីថា ដាក់ម្រឹគផ្ទាក់មួយ ហាក់បីដូចត្រាច់ទៅក្នុងលំនៅរបស់ម្រឹគហ្វូងនោះក្នុងទីជា

មួយគ្នា ។ បទថា **ឱកចារិកំ** សេចក្តីថា សូម្បីម្រឹគដែលលាមខ្សែវែង ។ ពិតហើយ នាយព្រានទៅកាន់ព្រៃ គឺទីកន្លែងដែលជាលំនៅរបស់ម្រឹគទាំង-ឡាយ ឃ្មាំសង្កេតថា ហ្វូងម្រឹគដែលនៅក្នុងទីនេះ ចេញទៅតាមផ្លូវនេះ ត្រាច់ទៅក្នុងទីនោះ ផឹកក្នុងទីនោះ ចូលទៅផ្លូវនេះ ដូច្នេះហើយ បិទផ្លូវ បើកផ្លូវជន្លួ តាំងម្រឹគឈ្មោល និងម្រឹគញីបញ្ឆោត កាន់លំពែងលាក់ខ្លួនក្នុងទីកំបាំង ។ លំដាប់នោះ ក្នុងវេលាល្ងាច ម្រឹគទាំងឡាយដែលត្រាច់នៅក្នុងព្រៃដែលផុតភ័យ ផឹកទឹក ប្រឡែងនឹងកូនម្រឹគទាំងឡាយ មកដល់ទឹកដីដែលជាលំនៅ ឃើញម្រឹគញី ឈ្មោល ដែលជាធ្នាក់ ក៏គិតថា សម្លាញ់របស់ពួកយើង មកហើយ មិនសង្ស័យ ចូលទៅ ។ ម្រឹគទាំងនោះឃើញផ្លូវដែលបិទហើយ ក៏គិតថា នេះមិនមែនផ្លូវ នេះទើបជាផ្លូវ ហើយដើរទៅក្នុងផ្លូវគ្រោះថ្នាក់ ។ ជាដំបូង នាយព្រានមិនធ្វើអ្វីឡើយ តែកាលម្រឹគទាំងនោះចូលទៅហើយ ទើបលបៗ វាយ ម្រឹគចុងក្រោយ ម្រឹគនោះភ័យជាខ្លាំង បន្ទាប់អំពីនោះ ម្រឹគទាំងអស់ក៏ផ្អើលឡើង សម្លឹងមើលខាងមុខថា ភ័យកើតឡើងហើយ ជាផ្លូវដែលបិទដោយទឹក ឬព្រៃ ឬភ្នំ មិនអាចចូលទៅកាន់ព្រៃស្តុកដូចម្រាមដៃទាំងពីរខាងបាន ក៏រត់ត្រឡប់ប្រារព្ធនឹងចេញតាមផ្លូវដែលចូលហើយ ។ បន្ទាប់អំពីនោះ នាយព្រានដឹងថា ម្រឹគទាំងនោះត្រឡប់មកហើយ ទើបសម្លាប់ ៣០ ក្បាលខ្លះ ៤០ ក្បាលខ្លះ ។

ម្នាលភិក្ខុទាំងឡាយ លុះសម័យខាងក្រោយមក ពួកម្រឹគច្រើននោះឯងក៏ដល់នូវសេចក្តីវិនាសសួចស្តើងទៅដូច្នេះឯង ព្រះសាស្តាត្រាស់ហើយ ក្នុង

បទនេះថា ទុំះជាឈ្មោះរបស់នន្ទិរាគៈ ជាឈ្មោះនៃអវិជ្ជានោះឯង ព្រោះសត្វទាំងនេះ ជាបុគ្គលមិនមានញាណ ព្រោះអវិជ្ជាចងឆ្វាក់ដោយនន្ទិរាគៈ នាំចូលទៅកាន់អារម្មណ៍ជាដើម រមែងត្រូវសម្លាប់ដោយលំពែង គឺវដ្តទុក្ខ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងធ្វើម្រឹគ ដែលជាផ្អាក់ឈ្មោលដូចនន្ទិរាគៈ ម្រឹគផ្អាក់មេដូចអវិជ្ជា ។ ពិតហើយ ក្នុងវេលាមួយ នាយព្រានបិទបាំងសរីរៈដោយមែកឈើ ដើម្បីមិនឲ្យម្រឹគទាំងនោះធុំក្លិនមនុស្ស ដាក់ម្រឹគផ្អាក់ឈ្មោលក្នុងទីមួយ លែងម្រឹគផ្អាក់ញី មួយអន្ទើដោយខ្សែ លាក់ខ្លួនកាន់លំពែង ឈរនៅត្រង់ទីជិតម្រឹគផ្អាក់ឈ្មោល ។ ម្រឹគផ្អាក់ញីក៏បែរមុខទៅកាន់ទីត្រាច់ទៅនៃហ្វូងម្រឹគ ។ ម្រឹគទាំងឡាយ ឃើញម្រឹគផ្អាក់ញីនោះហើយ ក៏ឈរអើតក្បាល ។ ចំណែកម្រឹគផ្អាក់ញីនោះក៏ឈរអើតក្បាល ម្រឹគទាំងនោះក៏គិតថា សូម្បីម្រឹគនេះ ក៏ជាពួកតែមួយនឹងពួកយើង ទើបស៊ីស្មៅ ឯម្រឹគផ្អាក់ញីនោះ ក៏ធ្វើជាស៊ីស្មៅ ដើរសន្សឹមៗ ចូលទៅរក ។ ម្រឹគមេហ្វូងដែលនៅក្នុងព្រៃបានក្លិនម្រឹគផ្អាក់ញីនោះ ក៏លះបង់ហ្វូងរបស់ខ្លួន បែរមុខឆ្ពោះទៅកាន់ម្រឹគផ្អាក់ញីនោះ ។ ពិតហើយ របស់ថ្មីៗ នោះឯង រមែងជាទីស្រឡាញ់របស់សត្វទាំងឡាយ ម្រឹគផ្អាក់ញីក៏បែរមុខចំពោះម្រឹគព្រៃនោះ ក៏មិនឲ្យម្រឹគព្រៃចូលជិត បែរខ្នងត្រឡប់ទៅកាន់លំនៅរបស់ម្រឹគផ្អាក់ឈ្មោល កាយដោយក្រចកក្នុងទីដែលមានខ្សែពាក់ ឲ្យគេចទៅ ។ ម្រឹគព្រៃឃើញម្រឹគផ្អាក់ឈ្មោលហើយ ក៏ឈ្លក់វង្វេងនឹងម្រឹគផ្អាក់ញី ធ្វើការប្រចណ្ឌនឹងម្រឹគផ្អាក់ឈ្មោលចំកោងខ្នង គ្រវីក្បាល ។ ក្នុងខណៈនោះ សូម្បីលិទ្ធ

*លំពែង ក៏មិនដឹងថា នេះអ្វី ។ ឯម្រឹគព្រៃ បើម្រឹគធ្លាក់នោះស្រួលវែងខាងលើ ក៏ចំកោងខ្នង បើស្រួលវែងក្នុងចំណែកខាងក្រោម ក៏ពើងទ្រូង ។ លំដាប់នោះ ព្រានក៏យកលំពែងចាក់ម្រឹគព្រៃស្លាប់ក្នុងទីនោះឯង ហើយកាន់យកជុំសាច់ទៅ ។ ដោយប្រការដូច្នេះ ម្រឹគនោះស្រវឹងនឹងម្រឹគធ្លាក់ញី ធ្វើការប្រចណ្ឌនឹងម្រឹគធ្លាក់ឈ្មោល សូម្បីលិទ្ធលំពែង ក៏មិនដឹងថា ជាអ្វីយ៉ាងណា សត្វលោកនេះក៏ដូច្នោះ ជាអ្នកស្រវឹង ងងឹតព្រោះអវិជ្ជា កាលមិនដឹងអ្វី អាស្រ័យតម្រេក ដោយការត្រេកអរក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម រមែងបានការសម្លាប់ដោយលំពែង គឺទុក្ខក្នុងវដ្តៈ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងធ្វើម្រឹគធ្លាក់ឈ្មោលជានន្ទិរាគៈ ទ្រង់ធ្វើម្រឹគធ្លាក់ញីជាអវិជ្ជា ។*

[ ២៥៥ ] *បទថា* **ឥតិ ខោ ភិក្ខវេ វិវដោ មយា ខេមោ មគ្គោ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលប្រកបដោយអង្គ ៨ ដ៏ក្សេម គឺប្រសើរ ដែលតថាគតត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ដោយការប្រព្រឹត្តប្រយោជន៍ដល់សត្វទាំងនេះ មិនបានជាអ្នកអន្ធយស្មៀម ដោយការគិតថា តថាគតជាព្រះពុទ្ធសម្តែងធម៌តាំងអំពីធម្មចក្រឲ្យប្រព្រឹត្តទៅ បានបើកហើយ ផ្លូវអាក្រក់បានបិទហើយ ដោយប្រការដូច្នេះឯង ម្រឹគធ្លាក់ឈ្មោល គឺនន្ទិរាគៈ ដែលកព្វបុគ្គលទាំងឡាយ មានព្រះអញ្ញាកោណ្ឌញ្ញៈលះបានហើយ ម្រឹគធ្លាក់ញី គឺអវិជ្ជា ត្រូវកាត់ជាពីរចំណែក ឲ្យវិនាសហើយ ចាកបុគ្គលដែលមានបាបទាំងអស់ត្រូវដកអស់ហើយ ព្រោះដូច្នោះ ទើបព្រះមានព្រះ*

ភាគ ទ្រង់សម្តែងឧបចារៈ ដែលឧបការៈដល់ព្រះអង្គ ។ ពាក្យដ៏សេស ក្នុងបទទាំងពួង ងាយយល់ហើយ ៕

**ទ្វេធាវិតក្កសូត្រ**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## វិតក្កសណ្ឋានសូត្រទី ១០

[ ២៥៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ២៥៧ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គឺសមាបត្តិ ៨ ហើយគប្បីធ្វើទុកក្នុងចិត្តនូវហេតុទាំង ៥ ប្រការសព្វៗ កាល ។ ហេតុទាំង ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អាស្រ័យនូវហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណា អកុសលវិតក្កដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈ គឺលោភៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិតក្កវិញ កាលបើភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិតក្ក អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះនឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុ-

សលវិតក្កទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាជាងឈើ ឬកូនសិស្សជាងឈើដែលប្រសប់ គប្បីវាយបញ្ចូន នាំចេញ ដកចេញ នូវកន្លាស់ធំដោយកន្លាស់តូចដូចម្តេចមិញ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុអាស្រ័យហេតុណា ធ្វើទុកក្នុងចិត្តនូវហេតុណា អកុសលវិតក្កដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កវិញ កាលភិក្ខុនោះចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិតក្ក អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ទោសៈខ្លះ មោហៈខ្លះ អកុសលវិតក្កទាំងនោះ នឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ដូច្នោះឯង ។

[ ២៥៨ ] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះចេញចាកហេតុនោះហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិតក្កវិញ អកុសល-វិតក្កដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ លុះ

ភិក្ខុនោះកំណត់នូវទោសនៃវិតក្កទាំងនោះថា វិតក្កទាំងនេះជាអកុសល វិតក្កទាំងនេះប្រកបដោយទោស វិតក្កទាំងនេះឲ្យផលជាទុក្ខ ។ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយណាដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះ នឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុង ក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រី ឬបុរសកំលោះ ឬក្រមុំ ប្រកបដោយជាតិជាអ្នកប្រដាប់តាក់តែងកាយ គប្បីនឿយណាយធុញទ្រាន់ ខ្ពើមរអើមសាកសពពស់ សាកសពឆ្កែ សាកសពមនុស្ស ដែលជាប់នៅត្រង់ក យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះចេញចាកហេតុនោះ ហើយធ្វើទុកក្នុងចិត្តនូវហេតុដទៃ ដែលប្រកបដោយកុសលវិតក្កវិញ អកុសលវិតក្កដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីកំណត់នូវទោសនៃវិតក្កទាំងនោះថា វិតក្កទាំងនេះជាអកុសល វិតក្កទាំងនេះប្រកបដោយទោស វិតក្កទាំងនេះឲ្យផលជាទុក្ខ ។ កាលភិក្ខុនោះកំណត់នូវទោសនៃវិតក្កទាំងនោះ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលទាំងនោះ នឹងសាបសូន្យ

ទៅ នឹងដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសល-វិតក្កទាំងនោះចេញបាន ទើបចិត្តខាងក្នុងតាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។

[ ២៥៩ ] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះកំណត់នូវទោសនៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនគប្បីរឭក មិនគប្បីធ្វើទុកក្នុងចិត្តចំពោះវិតក្កទាំងនោះឡើយ កាលភិក្ខុនោះ មិនរឭក មិនធ្វើទុកក្នុងចិត្តចំពោះវិតក្កទាំងនោះទេ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះ នឹងសាបសូន្យទៅ នឹងដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះ ចេញបានហើយ ទើបចិត្តខាងក្នុងតាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដែលមានចក្ខុ មិនចង់ឃើញរូបទាំងឡាយ ដែលមកប្រាកដដល់ចក្ខុ បុរសនោះគប្បីធ្មេចភ្នែក ឬមិនគប្បីក្រឡេកមើល ដោយហេតុដទៃយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះកំណត់នូវទោសនៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈតែងកើតឡើង ។បេ។ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។

[ ២៦០ ] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមិនរឭក មិនធ្វើទុកក្នុងចិត្តចំពោះវិតក្កទាំងនោះទេ អកុសលវិតក្កដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាន គឺហេតុទីតាំងនៃវិតក្កទាំងនោះ កាលភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាន នៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះ នឹងសាបសូន្យទៅ នឹងដល់នូវសេចក្តីវិនាសបាត់បង់ទៅ ព្រោះលះបង់នូវអកុសលវិតក្កនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដើរលឿន បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញដើរលឿនម៉្លេះ បើដូច្នោះមានតែអាត្មាអញដើរទៅសន្សឹមៗ ( លុះគិតដូច្នេះហើយ ) បុរសនោះក៏ដើរទៅសន្សឹមៗ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញដើរសន្សឹមៗ ម៉្លេះ បើដូច្នោះ មានតែអាត្មាអញឈរ ហើយបុរសនោះក៏ឈរ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ក៏អាត្មាអញឈរ បើដូច្នោះ មានតែអាត្មាអញអង្គុយ ហើយបុរសនោះក៏អង្គុយ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ហេតុអ្វីហ្ន៎ ក៏អាត្មាអញអង្គុយ បើដូច្នោះមានតែអាត្មាអញដេក ហើយបុរសនោះក៏ដេក ។ ម្នាលភិក្ខុ

ទាំងឡាយ បុរសនោះលះបង់ឥរិយាបថដ៏គ្រោតគ្រាតៗ យ៉ាងនេះហើយ គប្បីសម្រេចឥរិយាបថដ៏ល្អិតសុខុមវិញ សេចក្តីនេះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវវិតក្កសង្ខារសណ្ឋាននៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយ ប្រកបដោយឆន្ទៈខ្លះ តែងកើតឡើងដល់ភិក្ខុនោះ ។បេ។ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តនឹងនៅក្នុងអារម្មណ៍ សេចក្តីនេះដូច្នោះឯង ។

[ ២៦១ ] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ក្របដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ នៅតែកើតឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាបកម្តៅនូវអកុសលចិត្តដោយកុសលចិត្ត កាលភិក្ខុនោះកំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាបកម្តៅនូវអកុសលចិត្តដោយកុសលចិត្ត អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាង

ត្រង់ក្បាលក្តី ត្រង់កក្តី ត្រង់ខ្លួនក្តី ហើយសង្កត់សង្កិន គាបកម្តៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវវិតក្កសង្ខារសណ្ឋាននៃវិតក្កទាំងឡាយហើយ អកុសលវិតក្កដ៏លាមកទាំងឡាយដែលប្រកបដោយឆន្ទៈខ្លះ ក្របដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ នៅតែកើតឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវសង្កត់ធ្មេញខាងលើ នឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតានសង្កត់សង្កិន គាបកម្តៅនូវអកុសលចិត្តដោយកុសលចិត្ត កាលភិក្ខុនោះកំពុងសង្កត់ធ្មេញខាងលើ នឹងធ្មេញខាងក្រោម យកអណ្តាតទល់ពិតាន សង្កត់ គាបកម្តៅនូវអកុសលចិត្តដោយកុសលចិត្តហើយ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។

[ ២៥៦ ] ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុអាស្រ័យហេតុណាធ្វើទុកក្នុងចិត្តនូវហេតុណាហើយ អកុសលវិតក្កដ៏លាមកទាំងឡាយ ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ រមែងកើតឡើង ភិក្ខុនោះចេញចាកហេតុនោះហើយ ធ្វើទុកក្នុងចិត្តនូវហេតុដទៃដែលប្រកបដោយកុសលវិញ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសល

វិតក្កទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ កាលភិក្ខុកំណត់នូវទោសនៃវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះចេញបាន ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ កាលភិក្ខុមិនបាននឹកនា មិនបានយកចិត្តទុកដាក់ចំពោះវិតក្កទាំងនោះហើយ អកុសលវិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះ ក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់អកុសលវិតក្កទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ កាលភិក្ខុធ្វើទុកក្នុងចិត្តនូវវិតក្កសង្ខារសណ្ឋាននៃវិតក្កទាំងនោះហើយ អកុសលវិតក្កទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្ដីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់នូវអកុសលវិតក្កទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុង ក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។

(កាលភិក្ខុនោះ) កំពុងសង្កត់ធ្មេញខាងលើនឹងធ្មេញខាងក្រោម អណ្តាតទល់ពិតាន សង្កិន គាបកម្តៅនូវអកុសលចិត្តដោយកុសលចិត្តហើយ អកុសល-វិតក្កដ៏លាមកទាំងឡាយណា ដែលប្រកបដោយឆន្ទៈខ្លះ ប្រកបដោយទោសៈខ្លះ ប្រកបដោយមោហៈខ្លះ អកុសលវិតក្កទាំងនោះក៏សាបសូន្យទៅ ដល់នូវសេចក្តីវិនាសបាត់បង់ទៅពុំខាន ព្រោះលះបង់អកុសលវិតក្កទាំងនោះចេញបានហើយ ទើបចិត្តខាងក្នុងក៏តាំងនៅស្ងួតស្ងប់ស៊ប់ស្ងួន មានអារម្មណ៍តែមួយ នឹងនៅក្នុងអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថាជាអ្នកស្ទាត់ក្នុងគន្លងនៃវិតក្កបរិយាយទាំងឡាយ ភិក្ខុនោះ (បើ) ប្រាថ្នានូវវិតក្កណា នឹងត្រិះរិះនូវវិតក្កនោះ (បើ) មិនប្រាថ្នានូវវិតក្កណា នឹងមិនត្រិះរិះនូវវិតក្កនោះ ហើយផ្តាច់បង់នូវតណ្ហា លះបង់នូវសំយោជនធម៌ ធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងដោយចិត្តដ៏ប្រពៃ ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

**វិតក្កសណ្ឋានសូត្រទី ១០ ចប់**

**សីហនាទវគ្គទី ២ ចប់**

**ឧទ្ទាន គឺបញ្ជីរឿងនៃសីហនាទវគ្គនោះ គឺ**

ចូឡសីហនាទសូត្រទី ១ មហាសីហនាទសូត្រទី ២ មហាទុក្ខក្ខន្ធសូត្រទី ៣ ចូឡទុក្ខក្ខន្ធសូត្រទី ៤ អនុមានសូត្រទី ៥ ចេតោខិលសូត្រទី ៦ វនបត្ថសូត្រទី ៧ មធុបិណ្ឌិកសូត្រទី ៨ ទ្វេធាវិតក្កសូត្រទី ៩ វិតក្កសណ្ឋានសូត្រទី ១០ ។

*ព្រមទាំងកថាដែលនិយាយពីហេតុ ៥ ប្រការ*
*សីហនាទវគ្គទី ២ ចប់តែប៉ុណ្ណោះ*

# អដ្ឋកថា

## វិតក្កសណ្ឋានសូត្រ

[ ២៥៦ ] វិតក្កសណ្ឋានសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់មកយ៉ាងនេះ ។

[ ២៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អធិចិត្តមនុយុត្តេន** សេចក្ដីថា ចិត្តដែលកើតឡើងដោយកុសលកម្មបថ ១០ យ៉ាង ជាចិត្តប៉ុណ្ណោះ ចិត្តក្នុងសមាបត្តិ ៨ មានវិបស្សនាជាបាទ ជាចិត្តក្រៃលែងជាងចិត្តនោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅចិត្តនោះថា **អធិចិត្ត ។**

បទថា **អនុយុត្តេន** បានដល់ ព្យាយាមប្រកបអធិចិត្តនោះ អធិប្បាយថា ប្រកបហើយ ខ្វល់ខ្វាយហើយក្នុងអធិចិត្ត ។ ក្នុងសេចក្ដីនោះ ភិក្ខុត្រាច់ទៅបិណ្ឌបាតក្នុងវេលាបុរេភត្ត ត្រឡប់ពីបិណ្ឌបាតក្នុងវេលាបច្ឆាភត្ត ហើយកាន់យកសំពត់នីសីទនៈចេញទៅ ដោយគិតថា អញនឹងធ្វើសមណធម៌ត្រង់គល់ឈើនោះក្ដី ត្រង់ដងព្រៃ ត្រង់ជើងភ្នំក្ដី ត្រង់ញកភ្នំក្ដី ដូច្នេះ ។ ហើយក៏នាំស្មៅ ស្លឹកឈើ ចេញអំពីទីសម្រាប់ប្រកបអធិចិត្ត កាលលាងដៃ និងជើងហើយ ក៏មកអង្គុយពត់ភ្នែន កាន់យកមូលកម្មដ្ឋាន ប្រកបរឿយៗ នូវអធិចិត្តនោះឯង ។ បទថា **និមិត្ត** បានដល់ ការណ៍ គឺហេតុ ។

បទថា **កាលេនកាលំ** បានដល់ តាមសម័យដែលសមគួរ ។

សួរថា ធម្មតាកម្មដ្ឋាននោះ ព្រះយោគីមិនបានបោះបង់ត្រឹមតែមួយសន្ទុះ គឺមានសិការជាប់តគ្នាទៅ មិនមែនឬ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ

ត្រាស់ថា តាមកាលវេលាដ៏សមគួរ ដូច្នេះ ។

ឆ្លើយថា ព្រោះព្រះបាលីចែកកម្មដ្ឋានទុក ៣៨ ក្នុងកម្មដ្ឋានទាំងនោះ ភិក្ខុដែលអន្តុយបដិបត្តិកម្មដ្ឋាន ចាប់តាំងអំពីឧបក្កិលេសណាមួយ មិនទាន់បានកើតឡើង កិច្ចដែលត្រូវមនសិការដោយនិមិត្តដទៃៗ មិនមាន តែកាលកិលេសកើតឡើង លោកក៏គប្បីកាន់យកនិមិត្តទាំងឡាយ នាំកិលេសដែលកើតឡើងក្នុងចិត្តចេញទៅ ព្រះមានព្រះភាគ ទ្រង់ឃើញហេតុនោះ ទើបត្រាស់យ៉ាងនេះ ។

គប្បីជ្រាបខេត្តដែន និងអារម្មណ៍របស់វិតក្កទាំងនេះ គឺវិតក្កដែលប្រកបដោយឆន្ទៈ វិតក្កដែលសហគតៈដោយឆន្ទៈ វិតក្កដែលសម្បយុត្តដោយរាគៈ។

ក្នុង ៣ បទនេះ ចិត្តដែលសហគតៈដោយលោភៈ ៨ ដួង ជាខេត្តដែនរបស់វិតក្កដែលប្រកបដោយឆន្ទៈ ចិត្តដែលសហគតៈដោយទោសៈ ២ ដួង ជាខេត្តដែនរបស់វិតក្កដែលប្រកបដោយទោសៈ អកុសលចិត្ត ១២ ដួង ជាខេត្តដែនរបស់វិតក្កដែលប្រកបដោយមោហៈ តែចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ជាខេត្តដែនចំពោះបុគ្គលដែលមានវិតក្ក ដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈប៉ុណ្ណោះ ។ សត្វទាំងឡាយ និងសង្ខារទាំងឡាយទាំងអស់ ក៏ជាអារម្មណ៍របស់វិតក្កបាន ព្រោះថា កាលភិក្ខុមិនសម្លឹងមើលអនិដ្ឋារម្មណ៍ និងឥដ្ឋារម្មណ៍ហើយ វិតក្កក្នុងសត្វ និងសង្ខារទាំងនោះ ក៏មិនកើតឡើង ។

# អំពីមនសិការនិមិត្តដទៃ។

បទថា **អញ្ញំ និមិត្តំ មនសិការោតព្វំ កុសលូបសញ្ហិតំ** ភិក្ខុនោះ គួរមនសិការនិមិត្តដទៃ ដែលប្រកបដោយកុសល បានដល់ គួរមនសិការនិមិត្តដែលអាស្រ័យកុសលដទៃ ដោយវៀរចាកអកុសលនិមិត្តនោះ ។

ក្នុងសេចក្តីនោះ ឈ្មោះថា និមិត្តដទៃ គឺកាលវិតក្កប្រកបដោយឆន្ទៈកើតឡើងក្នុងសត្វទាំងឡាយ ការចម្រើនអសុភ ( អសុភសញ្ញា ) ឈ្មោះថា និមិត្តដទៃ កាលវិតក្កកើតឡើង ពេញចិត្តក្នុងសង្ខារទាំងឡាយ មានចីវរជាដើម មនសិការដល់ភាពជារបស់មិនទៀង គឺអនិច្ចសញ្ញា ឈ្មោះថា និមិត្តដទៃ ។ កាលវិតក្កប្រកបដោយទោសៈ ក្នុងសត្វទាំងឡាយកើតឡើង ការចម្រើនមេត្តា ឈ្មោះថា និមិត្តដទៃ ។ កាលវិតក្កក្នុងសង្ខារទាំងឡាយកើតឡើង មនសិការដល់ធាតុ ឈ្មោះថា និមិត្តដទៃ ។ កាលវិតក្កប្រកបដោយមោហៈកើតឡើងក្នុងធម៌ណា ភិក្ខុអាស្រ័យធម៌ ៥ យ៉ាង ឈ្មោះថា និមិត្តដទៃ ។

អធិប្បាយថា កាលលោភៈកើតឡើងក្នុងសត្វទាំងឡាយ ដោយន័យមានពាក្យថា ដៃ ឬជើងរបស់បុគ្គលនេះស្អាត ដូច្នេះជាដើម លោកក៏នាំមកពិចារណាដោយអសុភ គឺវត្ថុដែលមិនស្អាតថា អ្នកត្រេកអរក្នុងអ្វី ក្នុងសក់ទាំងឡាយឬ ក្នុងរោមទាំងឡាយឬ ។បេ។ ក្នុងទឹកមូត្រឬ ធម្មតាអត្តភាពនេះ ប្រកបឡើងដោយឆ្អឹង ៣០០ កំណាត់ ចងដោយសរសៃ ៩០០ បូកលាបដោយដុំសាច់ ៩០០ ខ្ទប់ដោយស្បែកស្រស់ ដែលការត្រេកអរពេញចិត្តក្នុងសម្បុរថ្ងៃបិទបាំងហើយ ម្យ៉ាងទៀត របស់មិនស្អាតទាំងឡាយ រមែង

ហូរចេញពីមុខដំបៅទាំង ៩ និងរណ្តៅរោមប្រមាណ ៩៩០០០ រណ្តៅ មានក្លិនស្អុយ ពេញទៅដោយសាកសព ជាវត្ថុដែលគួរខ្ពើម ជារបស់បដិកូលដែលផ្ទុកនូវវត្ថុបដិកូល ៣២ ប្រការ មិនមានវត្ថុដែលជាខ្លឹមសារ ឬវត្ថុដែលប្រសើរក្នុងកាយនេះឡើយ កាលព្រះយោគីនាំការស្អាតចេញ ដោយអសុភយ៉ាងនេះ ដោយប្រការដូច្នេះហើយ រមែងលះលោភៈដែលកើតក្នុងសត្វទាំង-ឡាយបាន ព្រោះហេតុនោះ ការនាំសេចក្តីស្អាតចេញដោយអសុភនេះ ទើបឈ្មោះថា និមិត្តដទៃ ។ កាលលោភៈកើតឡើងក្នុងបរិក្ខារទាំងឡាយ មានបាត្រ និងចីវរជាដើម ក៏មនសិការដោយអំណាចនៃការពិចារណាដល់ភាពជាវត្ថុដែលមិនមានម្ចាស់ និងជាវត្ថុមួយជួរខណៈ ដោយន័យដែលពោលទុកក្នុងសតិប្បដ្ឋានវណ្ណនាថា ភិក្ខុរមែងព្រងើយក្នុងសង្ខារទាំងឡាយ មានបាត្រ និងចីវរជាដើម ដោយអាការ ២ យ៉ាង គឺដោយភាពជាវត្ថុដែលមិនមានម្ចាស់ដោយពិត និងជាវត្ថុមួយជួរខណៈ លោកក៏រមែងលះលោភៈនោះបាន ។ ព្រោះហេតុនោះ ការធ្វើមនសិការដោយអាការ ២ យ៉ាង ក្នុងសង្ខារនោះ ទើបឈ្មោះថា និមិត្តដទៃ ។ កាលទោសៈ កើតឡើងក្នុងសត្វទាំងឡាយ ព្រះយោគីគប្បីចម្រើនមេត្តា ដោយអំណាចនៃសូត្រទាំងឡាយ ដែលនាំអាឃាតចេញ មានកកចូបមសូត្រជាដើម កាលចម្រើនមេត្តា ក៏រមែងលះទោសៈនោះបាន ដោយហេតុនោះ ទើបការចម្រើនមេត្តានោះ ឈ្មោះថា និមិត្តដទៃ ។ កាលទោសៈកើតឡើង ព្រោះវត្ថុទាំងឡាយ មានការជំពប់ជង្គត់ ជាន់បន្លា ស្ទឹកឈើដែលមុតស្រួចជាដើម លោកក៏គប្បីមនសិការដល់

ធាតុ ដោយន័យជាដើមថា លោកក្រោធបុគ្គលណា ក្រោធបឋវីធាតុឬ ឬក្រោធអាបោធាតុជាដើម កាលមនសិការដល់ធាតុយ៉ាងនេះ លោករមែងលះទោសៈបាន ព្រោះហេតុនោះ ទើបការធ្វើមនសិការដល់ធាតុ ឈ្មោះថានិមិត្តដទៃ ។

កាលមោហៈកើតឡើងក្នុងធម៌ណា លោកអាស្រ័យធម៌ទាំង ៥ នេះ គឺ ការនៅរួមជាមួយអាចារ្យ ១ ការរៀនធម៌ គឺឧទ្ទេស ១ ការសាកសួរធម៌ ១ ការស្តាប់ធម៌តាមកាលដ៏គួរ ១ ការវិនិច្ឆ័យធម៌ដែលជាឋានៈ និងអឋានៈ ១ រមែងលះមោហៈបាន ព្រោះដូច្នោះ ភិក្ខុគួរអាស្រ័យធម៌ ៥ យ៉ាងនេះ ។ ព្រោះថា កាលលោកអាស្រ័យអាចារ្យដែលគួរដល់ការគោរព អាចារ្យរមែងដាក់ទណ្ឌកម្មដល់លោក មានការដងទឹក ១០០ ក្អម ព្រោះមិនសួរដល់ការចូលស្រុក ឬមិនធ្វើវត្តក្នុងកាលដែលគួរជាដើម ភិក្ខុនោះឈ្មោះថា ជាបុគ្គលដែលអាចារ្យព្យាយាមគាក់តែងហើយ កាលបើដូច្នោះ លោកក៏រមែងលះមោហៈក្នុងធម៌នោះបាន ។

កាលផ្តើមធម៌ គឺឧទ្ទេស អាចារ្យរមែងដាក់ទណ្ឌកម្មដល់លោកដែលមិនរៀនក្នុងវេលាដែលសមគួរ ឬស្វាធ្យាយមិនល្អ ឬមិនស្វាធ្យាយជាដើម លោករមែងជាបុគ្គលដែលអាចារ្យព្យាយាមអប់រំហើយ ដូច្នេះ លោកក៏រមែងលះមោហៈបាន ។

ភិក្ខុចូលទៅរកភិក្ខុដែលគួរគោរពហើយ សាកសួរថា បពិត្រលោកម្ចាស់ សេចក្តីនេះដូចម្តេច អត្ថរបស់ធម៌នេះដូចម្តេចជាដើម លោករមែងកម្ចាត់ការ

សន្ស័យបាន ដោយអាការយ៉ាងនេះ លោករមែងលះមោហៈក្នុងធម៌នោះបាន ។

កាលភិក្ខុទៅកាន់ទីដែលស្តាប់ធម៌ តាមកាលវេលាដ៏សមគួរ ស្តាប់ដោយគោរព អត្ថធម៌ក្នុងទីនោះៗ រមែងជាក់ច្បាស់ដល់លោក ដោយអាការយ៉ាងនេះ លោកក៏រមែងលះមោហៈក្នុងធម៌នោះបាន ។

បុគ្គលអ្នកឈ្លាសក្នុងការវិនិច្ឆ័យ ក្នុងវត្ថុដែលជាឋានៈ គឺវត្ថុដែលប្រព្រឹត្តទៅបាន និងអឋានៈ គឺវត្ថុដែលប្រព្រឹត្តទៅមិនបានថា នេះជាហេតុរបស់វត្ថុនេះ នេះមិនមែនហេតុរបស់វត្ថុនេះ ដូច្នេះជាដើម ដោយអាការយ៉ាងនេះ លោកក៏រមែងលះមោហៈក្នុងធម៌នោះបាន ព្រោះហេតុនោះ ទើបការអាស្រ័យធម៌ ៥ របស់លោកនោះ ឈ្មោះថា ជានិមិត្តដទៃ ។

ម្យ៉ាងទៀត កាលភិក្ខុចម្រើនកម្មដ្ឋានឯណាមួយ ក្នុងកម្មដ្ឋាន ៣៨ លោករមែងលះអកុសលវិតក្កទាំងនេះបាន ព្រោះនិមិត្ត ៥ ដែលមានលក្ខណៈយ៉ាងនេះ ជាសត្រូវ និងបដិបក្ខដោយត្រង់ចំពោះកិលេសទាំងឡាយ មានរាគៈជាដើម កិលេសមានរាគៈជាដើម ដែលលះបានដោយនិមិត្តទាំង ៥ នេះហើយ ឈ្មោះថា លះយ៉ាងល្អ សេចក្តីថា ដូចបុគ្គលរំលត់ភ្លើង ដោយប្រើឈើស្រស់វាយរំលត់ខ្លះ ធូលីខ្លះ មែកឈើដទៃៗ ខ្លះ រមែងធ្វើឲ្យភ្លើងរលត់តែទឹកដែលជាសត្រូវដោយត្រង់របស់ភ្លើង កាលបុគ្គលនោះពន្លត់ភ្លើងដោយទឹក ដែលជាសត្រូវដោយត្រង់ ឈ្មោះថា រំលត់ល្អហើយ យ៉ាងណា កិលេសទាំងឡាយ មានរាគៈជាដើមដែលលះបានដោយនិមិត្តទាំង ៥ នេះ ឈ្មោះថាជាការលះយ៉ាងល្អ ដូច្នោះ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបពាក្យទាំងនេះ

តាមដែលព្រះមានព្រះភាគត្រាស់ទុកហើយ ។ បទថា **កុសលូបសញ្ហិតំ** គឺ អាស្រ័យកុសលជាបច្ច័យដល់កុសល ។ បទថា **អជ្ឈត្តមេវ** គឺជាអារម្មណ៍ខាងក្នុងនោះឯង ។ បទថា **បលគណ្ឌោ** ប្រែថា នាយជាងឈើ ។ បទថា **សុខុមាយ អាណិយា** សេចក្តីថា មេជាងឈើ ឬកូនសិស្សរបស់ជាងឈើដែលឈ្លាស ត្រូវការនាំកន្ទាស់ឯណាចេញ ក៏ដំដោយកន្ទាស់ដែលរឹងជាងកន្ទាស់នោះចូលទៅ ។ បទថា **ឱឡារិកំ អាណឹ** បានដល់ កន្ទាស់ដែលមិនស្មើគ្នា ដែលមេជាងដំចូលទៅក្នុងបន្ទះក្តារដើមចន្ទន៍ ឬក្តារឈើសាច់រឹង ។

បទថា **អភិហានេយ្យ** គឺកាលដំដោយអន្លូងហើយ ក៏នាំចេញមក ។

បទថា **អភិនីហរេយ្យ** គឺកាលរង្កៀកយ៉ាងនោះ ក៏នាំកន្ទាស់ចេញអំពីបន្ទះក្តារបាន ។ បទថា **អភិនិវត្តេយ្យ** សេចក្តីថា ឥឡូវនេះ កាលមេជាងដឹងថា កន្ទាស់ជាច្រើនទាំងនេះសណ្តកចេញហើយ ទើបយកដៃចាប់រង្កៀកទៅមក ហើយទាញចេញ ។

បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីនេះថា ចិត្តដូចបន្ទះក្តារ អកុសលវិតក្កប្រៀបដូចកន្ទាស់ ដែលធ្វើឲ្យបន្ទះក្តារមិនស្មើគ្នា ។ កុសលនិមិត្ត មានការចម្រើនអសុភ គឺការមិនស្អាតជាដើម ប្រៀបដូចកន្ទាស់តូច ។ ការនាំអកុសលវិតក្កទាំងនោះចេញ ដោយកុសលនិមិត្តទាំងឡាយ មានការចម្រើនអសុភទាំងឡាយ ប្រៀបដូចការដំដកកន្ទាស់ធំចេញបានដោយកន្ទាស់តូចដែលរឹងជាង ដូច្នោះ ។

[ ២៥៨ ] បទថា **អហិកុណបេន** ជាដើម ប្រែថា សាកសពពស់ជា

ដើមនេះ ព្រះមានព្រះភាគត្រាស់ ដើម្បីសម្ដែងដល់សាកសពទាំងឡាយ ដែលជាចំណែកនៃបដិកូល គួរខ្ពើមក្រៃលែង ។ បទថា **កណ្ឋេ អាសត្តេន** គឺនាំយកសាកសពទីណាមួយ ដែលមិនមានប្រយោជន៍មកចង គឺមកពាក់ត្រង់ក ។ បទថា **អដ្ដិយេយ្យ** បានដល់ ការខ្មាស ។ បទថា **ជិគុច្ឆេយ្យ** គឺគប្បីខ្ពើមកើតឡើងឯង ។

បទថា **បហេយ្យន្តិ** សេចក្ដីថា កាលលោករង្កៀសដោយវត្ថុនេះហើយ ប្រាថ្នាដោយកម្លាំងបញ្ញារបស់ខ្លួនថា អកុសលធម៌ទាំងនេះមានទោស មានទុក្ខជាវិបាក ក៏នឹងលះបង់បាន ប្រៀបដូចស្រីក្រមុំ ឬប្រុសកំលោះ មិនពេញចិត្តសាកសពពស់ ដូច្នោះ ។ កាលភិក្ខុណា មិនអាចពិចារណាដោយកម្លាំងបញ្ញារបស់ខ្លួនបាន លោកគប្បីចូលទៅរកអាចារ្យក្ដី ឧបជ្ឈាយ៍ក្ដី សព្រហ្មចារីក្ដី ដែលគួរដល់ការគោរព ឬព្រះសង្ឃត្ថេរអង្គណាមួយអង្គ ហើយវាយជួង ឲ្យភិក្ខុមកប្រជុំគ្នា ប្រាប់ឲ្យជ្រាបដល់ហេតុនោះ ព្រោះថា មនុស្សដែលជាបណ្ឌិតណាម្នាក់ នឹងមានក្នុងទីប្រជុំនោះ បណ្ឌិតនោះនឹងប្រាប់ថា លោកគប្បីឃើញទោសក្នុងអកុសលវិតក្កយ៉ាងនេះៗ ឬថា នឹងសង្កត់អកុសលវិតក្កទាំងនោះ ដោយកថាទាំងឡាយ មានកាយវិច្ឆិន្ទនិយកថាជាដើម ។

[ ២៥៩ ] បទថា **អសតិមនសិការោ អាបជ្ជិតព្វោ** បានដល់ ភិក្ខុនោះមិនគប្បីនឹក មិនគប្បីដាក់ចិត្តដល់អកុសលវិតក្កទាំងនោះ គប្បីជាអ្នកដាក់ចិត្តទៅក្នុងអារម្មណ៍ដទៃៗ ដូចបុគ្គលដែលមិនបំណងនឹងឃើញរូប គប្បីបិទភ្នែកទាំង ២ យ៉ាងណា ភិក្ខុដែលកាន់យកមូលកម្មដ្ឋាន មកអង្គុយហើយ

កាលវិតក្កកើតក្នុងចិត្ត គប្បីជាអ្នកបញ្ចូនចិត្តទៅក្នុងអារម្មណ៍ដទៃ ដូច្នោះ ។ ភិក្ខុនោះរមែងលះអកុសលវិតក្កបានដោយអាការយ៉ាងនេះ កាលលោកបំណងនឹងលះ ក៏គប្បីកាន់យកកម្មដ្ឋានមកហើយនោះ អង្គុយចុះ ។ បើលោកមិនទាន់លះបាន ក៏គួរស្វាធ្យាយព្រះបាលី ធម្មកថា ដែលរៀនមកដោយសំឡេងដ៏ខ្លាំង ។ បើលោកដាក់ចិត្តទៅក្នុងអារម្មណ៍ដទៃយ៉ាងនេះ ក៏នៅតែលះមិនទាន់បាន ក៏ចូរចាប់យកសាស្ត្រាទទេចេញអំពីថង់យាម ចារពណ៌នាសេចក្ដីល្អគឺគុណរបស់ព្រះពុទ្ធណាមួយ លោកគប្បីនាំអកុសលវិតក្កចេញដោយការបញ្ចូនចិត្តក្នុងអារម្មណ៍ដទៃយ៉ាងនេះ ។

បើធ្វើដោយអាការយ៉ាងនេះហើយ ក៏នៅតែលះអកុសលវិតក្កនោះមិនបាន ក៏គប្បីដកយកឈើក្ដួតភ្លើងចេញមកអំពីថង់យាម ហើយពិចារណាឬបញ្ចូនចិត្តទៅក្នុងអារម្មណ៍ដទៃថា នេះឈើក្ដួតភ្លើង ដែលជាចំណែកខាងលើ នេះឈើក្ដួតភ្លើងដែលជាចំណែកខាងក្រោម ដូច្នេះ ។ បើធ្វើយ៉ាងនេះហើយ នៅតែលះអកុសលវិតក្កមិនបាន គប្បីយកប្រអប់តូចចេញមក ប្រមូលបរិក្ខារទុក ឬបញ្ចូនចិត្តទៅក្នុងអារម្មណ៍ដទៃថា នេះបំពង់ម្ជុល នេះកាំបិតតូច នេះគ្រឿងកាត់ក្រចក នេះម្ជុលជាដើម លោកក៏គប្បីលះអកុសលវិតក្កបាន ។ បើធ្វើយ៉ាងនេះហើយ ក៏នៅតែលះអកុសលវិតក្កនោះមិនបាន គប្បីទាញយកម្ជុលដេរចីវរដែលរហែក ដើម្បីបញ្ចូនចិត្តទៅក្នុងអារម្មណ៍ដទៃ ដរាបណាដែលលោកមិនទាន់លះអកុសលវិតក្កបាន ក៏គប្បីបញ្ចូនចិត្តទៅក្នុងអារម្មណ៍ដទៃ ដោយការធ្វើកុសលកម្មនោះៗ កាលលោកលះអកុសលវិតក្កបានហើយ

ក៏គប្បីកាន់យកមូលកម្មដ្ឋាន មកអន្ទុយចុះ មិនគប្បីជាអ្នកផ្ដើមនវកម្ម គឺការកសាងឡើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា លោកទម្លាយអកុសលវិតក្កមិនទាន់បាន ក៏មិនមានឱកាសមនសិការកម្មដ្ឋាន ។ បណ្ឌិតក្នុងកាលមុនធ្វើនវកម្ម ក៏ត្រូវទម្លាយអកុសលចិត្តជាមុនសិន ។ ក្នុងសេចក្ដីនេះ មានរឿងជាឧទាហរណ៍ដូចតទៅនេះ

## រឿង តិស្សសាមណេរ

បានឮថា ព្រះឧបជ្ឈាយ៍របស់សាមណេរ អាស្រ័យនៅក្នុងមហាវិហារឈ្មោះថា **តិស្សៈ** សាមណេរពោលនឹងឧបជ្ឈាយ៍ថា បពិត្រលោកម្ចាស់ ខ្ញុំក្រវល់ក្រវាយ ចង់លាសិក្ខា ។ កាលនោះព្រះថេរៈបានពោលនឹងសាមណេរថា ក្នុងវិហារនេះរកទឹកងូតបានលំបាក លោកចូរនាំខ្ញុំទៅត្រង់ចិត្តលបព៌ត ។ សាមណេរបានធ្វើយ៉ាងនោះ ។ ព្រះថេរៈបានពោលនឹងសាមណេរក្នុងទីនោះថា វិហារនេះ ជារបស់ចំពោះសង្ឃ លោកចូរធ្វើ គឺសាងទីលំនៅថ្មីឲ្យជាទីអាស្រ័យនៅចំពោះបុគ្គលម្នាក់ ។ សាមណេរទទួលពាក្យថា សាធុ លោកម្ចាស់ ហើយសាមណេរក៏ផ្ដើមវត្ថុទាំង ៣ ព្រមគ្នា គឺការរៀនគម្ពីរសំយុត្តនិកាយ តាំងអំពីដើម ការជម្រះដីត្រង់ញកភ្នំ និងការបរិកម្មតេជោកសិណ និងបានញ៉ាំងកម្មដ្ឋាននោះឲ្យដល់អប្បនា ញ៉ាំងការរៀនសំយុត្តនិកាយឲ្យចប់ ហើយផ្ដើមធ្វើនវកម្មក្នុងវិហារ លោកបានធ្វើនវកម្មទាំងពួងឲ្យសម្រេចហើយ ទើបប្រាប់ឲ្យឧបជ្ឈាយ៍ជ្រាប ។ ព្រះឧបជ្ឈាយ៍ពោលថា សាមណេរ ទីលំនៅ

ចំពោះបុគ្គលម្នាក់ លោកធ្វើសម្រេចក្នុងថ្ងៃនេះបានដោយលំបាក លោកនោះឯងចូរនៅ ដូច្នេះ ។ សាមណេរនោះ កាលនៅក្នុងគុហាអស់រាត្រី បានឧតុសប្បាយ ទើបញុំាងវិបស្សនាឲ្យចម្រើន ហើយសម្រេចអរហត្ត បរិនិព្វានហើយក្នុងវិហារនោះឯង ។ ជនទាំងឡាយ កាន់យកធាតុរបស់សាមណេរកសាងព្រះចេតិយ ។ ចេតិយរបស់តិស្សត្ថេរ បានប្រាកដមករហូតដល់សព្វថ្ងៃនេះឯង ។ បទ្វះនេះ ឈ្មោះថា **អសតិបទ្វ** ប្រែថា ការកំណត់ ដោយការរឭកមិនបាន ។

[ ២៦០ ] ព្រះមានព្រះភាគ កាលសម្ដែងការទម្លាយឫសគល់របស់អកុសលវិតក្កថា កាលភិក្ខុតាំងនៅក្នុងសេចក្ដីនេះ គឺអសតិបទ្វះហើយ នៅតែមិនអាចសង្កត់អកុសលវិតក្កបាន ក៏ត្រូវតាំងនៅក្នុងប្រការដែលទម្លាយឫសគល់របស់អកុសលវិតក្កនេះ ដូច្នេះហើយ ត្រាស់ពាក្យថា **តស្ស ចេ ភិក្ខវេ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះដល់នូវការមិននឹក មិនដាក់ចិត្តក្នុងវិតក្កទាំងនោះជាដើម ។

ក្នុងសេចក្ដីនេះ គប្បីជ្រាបវិគ្គហៈពាក្យថា **សង្ខារ** ក្នុងពាក្យថា គប្បីមនសិការសង្ខារសណ្ឋានរបស់ខ្លួននោះថា សភាវៈណារមែងតាក់តែង ហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **សង្ខារ** អធិប្បាយថា ជាបច្ច័យ គឺហេតុជាគ្រឿងអាស្រ័យ ជាការណ៍ គឺហេតុធ្វើ ជាមូល គឺឫសគល់ ។

ឈ្មោះថា **សណ្ឋាន** ព្រោះអត្ថវិគ្គហៈថា ជាទីតាំងនៅល្អ ។ សណ្ឋានរបស់វិតក្កសង្ខារ ឈ្មោះថា **វិតក្កសង្ខារសណ្ឋាន** ។ ភិក្ខុគប្បីមនសិការ

សណ្ឋាននោះ ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់អធិប្បាយថា ភិក្ខុគប្បី មនសិការដល់ហេតុ និងមិនមែនហេតុនៃវិតក្កទាំងឡាយថា វិតក្កនេះ មានអ្វីជាហេតុ មានអ្វីជាបច្ច័យ ព្រោះហេតុអ្វី ទើបកើតឡើង ដូច្នេះ ។

បទថា **កឹ នុ ខោ អហំ សីឃំ គច្ឆាមិ** សេចក្ដីថា បុរសដើរលឿននោះ រមែងគិតថា ប្រយោជន៍អ្វី ដោយការដើរលឿនរបស់អញនេះ អញនឹងដើរសន្សឹមៗ ដូច្នេះ ។

បទថា **សោ សណិកំ គច្ឆេយ្យ** គឺកាលបុរសនោះគិតយ៉ាងនោះហើយ ទើបដើរសន្សឹមៗ ។ ពាក្យទាំងពួងក៏មានន័យនេះឯង ។

បណ្ឌិតគប្បីជ្រាបក្នុងសេចក្ដីនេះថា វេលាកើតឡើងនៃវិតក្ករបស់ភិក្ខុនេះ ប្រៀបដូចការដើរលឿនរបស់បុរស ។ វេលាកំណត់ការត្រាច់ទៅនៃវិតក្ករបស់ភិក្ខុនេះ ប្រៀបដូចការដើរសន្សឹមៗ ទៅក្នុងទីនោះ ។ កាលភិក្ខុនោះកំណត់ការត្រាច់ទៅរបស់វិតក្កបានហើយ នាំចិត្តមកកាន់មូលកម្មដ្ឋាន ប្រៀបដូចការត្រិះរិះរបស់បុរសនោះ ។ កាលភិក្ខុនេះ ញុំាងវិបស្សនាឲ្យចម្រើន ហើយសម្រេចអរហត្ត ប្រៀបដូចកាលបុរសនោះអង្គុយចុះហើយ ។ កាលដែលភិក្ខុនេះឲ្យវេលាកន្លងទៅអស់ថ្ងៃ ដោយផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ប្រៀបដូចបុរសនោះដេកហើយ ។

ក្នុងពាក្យថា វិតក្កទាំងនេះ មានអ្វីជាហេតុ មានអ្វីជាបច្ច័យ សេចក្ដីថា ការត្រាច់ទៅនៃវិតក្ក រមែងជារបស់ស្រាលស្ដើងហើយ ដល់បុគ្គលដឹងហេតុ និងមិនមែនហេតុនៃវិតក្កទាំងឡាយ កាលវិតក្កនោះជារបស់ស្រាលស្ដើងដល់

ទីបំផុតហើយ ក៏រមែងរលត់ទៅ ដោយប្រការទាំងពួង ។ បណ្ឌិតគប្បីសម្តែងសេចក្តីនេះដោយទុទ្ទុភជាតក គឺរឿងទន្សាយផ្អើលផ្លែព្នៅ ។

# រឿង ទន្សាយផ្អើលផ្លែព្នៅ

បានឮថា ទន្សាយមួយ ដេកលក់នៅក្បែរដើមព្នៅ ផ្លែព្នៅទុំជ្រុះអំពីទងធ្លាក់មកក្បែរត្រចៀកទន្សាយ ។ ទន្សាយនោះក៏ភ្ញាក់ក្រោកឡើង រត់ទៅដោយរហ័ស ដោយសម្គាល់ថា ផែនដីស្រុត ព្រោះសំឡេងខ្លាំងនៃផ្លែព្នៅនោះ ។ សត្វចតុប្បាទដទៃៗ ខាងមុខឃើញទន្សាយរត់មកដោយរហ័ស ក៏នាំគ្នារត់ទៅដែរ ។ កាលនោះ ព្រះពោធិសត្វនៃយើង កើតជារាជសីហ៍ ។ រាជសីហ៍នោះគិតថា ធម្មតាផែនដីនេះ ស្រុតវិនាសទៅ ក៏ព្រោះកប្បវិនាសឈ្មោះថា ការដែលផែនដីនេះ បែកធ្លាយទៅត្រង់កណ្តាលទីមិនមាន អញត្រូវទៅពិនិត្យមើលហេតុឲ្យបានដឹង ដូច្នេះ ។ ទើបរាជសីហ៍ផ្តើមសាកសួរសត្វទាំងឡាយតាំងអំពីដំរីទៅ រហូតដល់ទន្សាយនោះថា អ្នកឃើញដីស្រុតឬដូច្នេះ ទន្សាយពោលថា បពិត្រលោកម្ចាស់ដ៏ជាធំ ខ្ញុំឃើញ ។ រាជសីហ៍ពោលថា អ្នកចូរនាំយើងទៅមើល ទន្សាយពោលថា ខ្ញុំមិនអាច ។ ទើបរាជសីហ៍សម្តុតថា នែទន្សាយ ចូរនាំយើងទៅ ឯងកុំខ្លាចឡើយ ហើយក៏លួងលោមចិត្តទន្សាយ ដោយពាក្យសុភាពរាបសា ហើយនាំទន្សាយទៅ ។ ទន្សាយឈរក្នុងទីមិនឆ្ងាយអំពីដើមព្នៅ ហើយបានពោលជាគាថាថា

សូមសេចក្តីចម្រើនមានដល់លោកចុះ ខ្ញុំនៅក្នុងប្រទេសណា ប្រទេសនោះធ្វើសំឡេងឮទុទ្ទុភ តែខ្ញុំមិនដឹងនូវប្រទេសនុ៎ះថា នេះអ្វី ធ្វើសំឡេងឮ

ទុទ្ទុភ ។

ព្រះពោធិសត្វ ពោលនឹងទន្សាយថា អ្នកចូរឈរក្នុងទីនេះឯង ហើយក៏ទៅត្រង់គល់ព្នៅ បានឃើញទីដេករបស់ទន្សាយ និងបានឃើញផ្លែព្នៅទុំ ទើបក្រឡេកមើលខាងលើ បានឃើញទងរបស់ព្នៅ កាលឃើញហើយ ក៏ដឹងថា ទន្សាយនេះ ដេកទីនេះ កំពុងលក់ កាលត្រូវព្នៅទុំនេះជ្រុះមកក្បែរត្រចៀក ទើបមានការសម្គាល់ថា សំឡេងផែនដីស្រុត ទើបប្រញាប់រត់ទៅដោយរហ័ស ដូច្នេះហើយ ទើបសួរដល់ហេតុនោះ ។ ទន្សាយទទួលពាក្យថា ត្រូវហើយលោកម្ចាស់ ។ ទើបព្រះពោធិសត្វពោលពាក្យជាគាថាថា

**វេលុវំ បតិតំ សុត្វា ទុទ្ទុភន្តិ សសោ ជវិ**
**សសស្ស វចនំ សុត្វា សន្តត្តា មិគវាហនី ។**

ទន្សាយឮសូរផ្លែព្នៅជ្រុះថា ទុទ្ទុភ ដូច្នេះ ក៏ស្ទុះបោលប្រូច ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយ ក៏ភ័យតក់ស្លុត ។

លំដាប់នោះ ទើបព្រះពោធិសត្វលួងលោមពួកម្រឹគទាំងឡាយថា ពួកអ្នកកុំខ្លាចឡើយ ដូច្នេះ ។

[ ២៦១ ] កាលភិក្ខុពិនិត្យរកហេតុ របស់អកុសលវិតក្កទាំងឡាយដោយអាការយ៉ាងនេះ ក៏រមែងលះបាន ។ ព្រះមានព្រះភាគ កាលសម្តែងការណ៍ គឺហេតុនេះថា ភិក្ខុអ្នកតាំងនៅក្នុងការទម្លាយមូលហេតុរបស់អកុ-សលវិតក្កនេះហើយ ក៏នៅមិនអាចដើម្បីលះវិតក្កនោះបាន ក៏គប្បីសង្កត់យ៉ាងនេះ ដោយត្រាស់ថា **តស្ស ចេ ភិក្ខវេ** ជាដើម ប្រែថា ម្នាលភិក្ខុ

ទាំងឡាយ បើកាលភិក្ខុនោះមនសិការដល់កម្មដ្ឋាននៃវិតក្ក ដូច្នេះជាដើម ។

បទថា **ទន្តេភិ ទន្តមាធាយ** បានដល់ គប្បីសង្កត់ធ្មេញលើនឹងធ្មេញក្រោម ។ បទថា **ចេតសា ចិត្តំ** បានដល់ គប្បីរាំងអកុសលចិត្ត ដោយកុសលចិត្ត ។

បទថា **ពលវា បុរិសោ** ជាដើម សេចក្ដីថា ប្រៀបដូចបុរសដែលជាអ្នកសម្បូរដោយកម្លាំង មានកម្លាំងច្រើន ចាប់បុរសដែលមានកម្លាំងខ្សោយជាង ហើយសង្កត់ឈ្ងប គ្រញិចត្រង់ក្បាល ឬច្បាមត្រង់កឲ្យណែន គប្បីធ្វើបុរសនោះឲ្យក្ដៅក្រហាយ ឲ្យលំបាក ឲ្យស្រុបសៅ មានការស្លាប់ជាទីបំផុត យ៉ាងណា ភិក្ខុក៏ដូច្នោះឯង គប្បីជាអ្នកកីឡា ដែលជាគូប្រយុទ្ធជាមួយអកុសលវិតក្កទាំងឡាយថា ពួកឯងជាអ្វី យើងជាអ្វី ដូច្នេះ កាលគ្របសង្កត់ហើយ គប្បីផ្គងសេចក្ដីព្យាយាមធំ យ៉ាងនេះថា

**កាមំ តចោ ន្ហារុ ច អដ្ឋិ ច អវសុស្សតុ**
**អវសិស្សតុ មេ សរីរេ សព្វន្តំ មំសលោហិតំ។**

សាច់ និងឈាមទាំងអស់ ក្នុងសរីរៈរបស់អញនេះ ចូររីងស្ងួតទៅ សល់នៅតែស្បែក សរសៃ ឆ្អឹងក៏ដោយចុះ ។

[ ២៦២ ] លោកក៏គប្បីសង្កត់អកុសលវិតក្កទាំងឡាយបាន ។ កាលនឹងសម្ដែងយ៉ាងនេះ ទើបត្រាស់ពាក្យឧបមាដែលសម្ដែងអត្ថនេះថា **យតោ ច ខោ ភិក្ខវេ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនិមិត្តណាហើយ មនសិការនិមិត្តណាជាដើម ។ សេចក្ដីនេះ ឈ្មោះថា **មរិយាទ-**

**ភាជនី** គឺពាក្យចែកខេត្តដែន ។ ពាក្យនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។ គប្បីជ្រាបឧបមាដូចតទៅនេះ

ឧបមាថា អាចារ្យដែលឲ្យពាក្យណែនាំប្រៀនប្រដៅព្រះរាជកុមារ ដែលមកអំពីដែនខាងក្រៅ ឲ្យរៀនយកនូវសិប្បៈ ពោលដោយអាវុធ ៥ ហើយសម្តែងវត្ថុដែលគួរធ្វើ ដោយអាវុធទាំង ៥ យ៉ាងនេះថា អ្នកចូរត្រឡប់ទៅគ្រប់គ្រងរាជសម្បត្តិក្នុងដែនរបស់ខ្លួន បើពួកចោរប្រាកដក្នុងរវាងផ្លូវដល់អ្នក អ្នកចូរប្រើធ្នូនេះ ហើយក៏ចូរទៅ បើធ្នូរបស់អ្នកបាត់ ឬបាក់ ចូរប្រើលំពែង បើលំពែងបាក់ ចូរប្រើដាវ ដូច្នេះជាដើម ហើយឲ្យត្រឡប់ទៅ ។ ព្រះរាជ-កុមារនោះបានធ្វើយ៉ាងនោះ កាលទៅដល់ដែនរបស់ខ្លួនហើយ បានគ្រងរាជ-សម្បត្តិ យ៉ាងណា សេចក្តីនេះក៏ដូច្នោះឯង ព្រះមានព្រះភាគ កាលទ្រង់បញ្ជូនភិក្ខុអ្នកប្រកបដោយអធិចិត្ត ដើម្បីកាន់យកនូវអរហត្ត ទ្រង់សម្តែងបព្វៈទាំង ៥ នេះថា

បើអកុសលចិត្តកើតដល់អ្នកក្នុងចន្លោះ ក៏គួរតាំងនៅក្នុងបព្វៈពោលដោយនិមិត្តដទៃ ( អញ្ញនិមិត្តបព្វៈ ) កាលអ្នកសង្កត់អកុសលវិតក្កបានហើយ ក៏នឹងញ៉ាំងវិបស្សនាឲ្យចម្រើន ហើយនឹងសម្រេចអរហត្ត កាលមិនអាចក្នុងបព្វៈនោះ ក៏នឹងតាំងនៅក្នុងអាទីនវបព្វៈ កាលមិនអាចក្នុងអាទីនវបព្វៈនោះ នឹងតាំងនៅក្នុងអសតិបព្វៈ កាលមិនអាចក្នុងអសតិបព្វៈ ក៏គួរតាំងនៅក្នុងវិតក្កមូលកភេទបព្វៈ គឺការទម្លាយមូលនៃអកុសលវិតក្ក កាលមិនអាចតាំងនៅក្នុងវិតក្កមូលកភេទបព្វៈ ក៏គួរតាំងនៅក្នុងអភិនិគ្គហនបព្វៈ គឺការសង្កត់

វិតក្ក កាលសង្កត់វិតក្កទាំងឡាយនោះបានហើយ នឹងញ៉ាំងវិបស្សនាឲ្យចម្រើន ហើយសម្រេចអរហត្ត ដូច្នេះ ។

បទថា **វសី វិតក្កបរិយាយបថេសុ** ប្រែថា ជាអ្នកជំនាញក្នុងផ្លូវដើរនៃវិតក្ក បានដល់ ជាអ្នកជំនាញតាមដែលខ្លួនសន្សំមកហើយ គឺជាអ្នកជំនាញស្ទាត់ជំនាញក្នុងផ្លូវប្រព្រឹត្តទៅនៃការត្រិះរិះ ។

បទថា **យំ វិតក្កំ អាកង្ខិស្សតិ** ប្រែថា បើអ្នកប្រាថ្នាក្នុងវិតក្កណា នេះព្រះមានព្រះភាគ ត្រាស់ដើម្បីសម្តែងដល់លក្ខណៈនៃភាពជាអ្នកជំនាញ ។ ព្រោះថា បុគ្គលនេះ កាលមុនប្រាថ្នានឹងត្រិះរិះវិតក្កណា រមែងត្រិះរិះវិតក្កនោះមិនបាន មិនបំណងត្រិះរិះវិតក្កណា រមែងត្រិះរិះវិតក្កនោះបាន តែឥឡូវនេះ ព្រោះជាអ្នកជំនាញហើយ ជាអ្នកដែលប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា រមែងត្រិះរិះនូវវិតក្កនោះបាន មិនត្រិះរិះវិតក្កណា ក៏មិនត្រិះរិះវិតក្កនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកប្រាថ្នាវិតក្កណា ក៏ត្រិះរិះវិតក្កនោះបាន បើមិនប្រាថ្នាវិតក្កណា មិនត្រិះរិះវិតក្កនោះបាន ដូច្នេះ ។

បទថា **អច្ឆេច្ឆិ តណ្ហំ** ប្រែថា កាត់តណ្ហាបានហើយជាដើមនេះ បានពោលហើយក្នុងសព្វាសវសំវរសូត្រហើយ ដូច្នេះឯង ។

**វិតក្កសណ្ឋានសូត្រទី ១០ ចប់**

**សីហនាទវគ្គទី ២ ចប់**

# សុត្តន្តបិដក

## ឱបម្មវគ្គ ទុតិយភាគ

## កកចូបមសូត្រទី ១

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏សម័យនោះឯង ព្រះមោលិយផគ្គុនមានអាយុ នៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីហួសវេលា ។ ព្រះមោលិយផគ្គុនមានអាយុ តែងនៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីយ៉ាងនេះ ។ បើមានភិក្ខុណាមួយ ពោលទោសពួកភិក្ខុនីទាំងនោះក្នុងទីចំពោះមុខព្រះមោលិយផគ្គុនមានអាយុ មោលិយផគ្គុនមានអាយុ ក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង ។ បើមានភិក្ខុណាមួយពោលទោសព្រះមោលិយផគ្គុនមានអាយុ ក្នុងទីចំពោះមុខពួកភិក្ខុនីទាំងនោះ ពួកភិក្ខុនីក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង ។ ព្រះមោលិយផគ្គុនមានអាយុ តែងនៅប្រឡូកប្រឡំដោយពួកភិក្ខុនីយ៉ាងនេះ ។ គ្រានោះ មានភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានបុណ្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុនមានអាយុ នៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីហួសវេលា បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុនមានអាយុ តែងនៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីយ៉ាងនេះ បើមានភិក្ខុណាមួយ ពោល

ទោសភិក្ខុនីទាំងនោះ ក្នុងទីចំពោះមុខមោលិយផគ្គុនមានអាយុ មោលិយ-ផគ្គុនមានអាយុ ក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង បើមានភិក្ខុណាមួយ ពោលទោសមោលិយផគ្គុនមានអាយុ ក្នុងទីចំពោះមុខភិក្ខុនីទាំងនោះ ភិក្ខុនីទាំងអម្បាលនោះ ក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិ-ករណ៍ដោយហេតុនោះផង បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុនមានអាយុតែងនៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនី យ៉ាងនេះឯង ។

[ ២ ] គ្រានោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ ចូរអ្នកមកអាយ អ្នកចូរទៅហៅមោលិយផគ្គុនភិក្ខុតាមពាក្យតថាគតថា ម្នាលអាវុសោមោលិយផគ្គុន ព្រះសាស្តា ទ្រង់ត្រាស់ហៅអ្នក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកមោលិយផគ្គុនមានអាយុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងព្រះមោលិយផគ្គុនមានអាយុថា ម្នាលអាវុសោមោលិយផគ្គុនព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ព្រះមោលិយផគ្គុនមានអាយុ ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមោលិយផគ្គុនមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគមានពុទ្ធតម្រាស់នេះថា ម្នាលផគ្គុន បានឮថា អ្នកនៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីហួសវេលា ពិតមែនឬ ម្នាលផគ្គុន អ្នកនៅប្រឡូកប្រឡំជាមួយនឹងពួកភិក្ខុនីយ៉ាងនេះ បើមានភិក្ខុណាមួយពោលទោសពួកភិក្ខុនីនោះក្នុង

ទីចំពោះមុខអ្នកៗ ក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ដោយហេតុនោះផង ពុំនោះសោត បើមានភិក្ខុណាមួយ ពោលទោសអ្នកក្នុងទីចំពោះមុខពួកភិក្ខុនីៗ នោះ ក៏ខឹងអាក់អន់ចិត្ត ថែមទាំងធ្វើអធិករណ៍ ដោយហេតុនោះផង ម្នាលផគ្គុន បានឮថា អ្នកតែងនៅច្រឡូកច្រឡំជាមួយនឹងពួកភិក្ខុនីយ៉ាងនេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលផគ្គុន ចុះក្រែងអ្នកជាកុលបុត្រចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធាឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលផគ្គុន អ្នកនៅច្រឡូកច្រឡំជាមួយនឹងពួកភិក្ខុនីហួសវេលា ដោយអំពើណា អំពើនុ៎ះ មិនសមគួរដល់អ្នក ដែលជាកុលបុត្រចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធាឡើយ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានភិក្ខុណាមួយ ពោលទោសពួកភិក្ខុនីនោះចំពោះមុខអ្នក ម្នាលផគ្គុន ឆន្ទៈណា ដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ វិតក្កណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ អ្នកគប្បីលះបង់ឆន្ទៈ និងវិតក្កទាំងនោះ ក្នុងការពោលទោសនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការពោលទោសនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញ នឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង អាត្មាអញនឹងជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានភិក្ខុណាមួយ ឲ្យនូវការប្រហារដោយដៃ ឲ្យនូវការប្រហារដោយដុំដី ឲ្យនូវការប្រហារដោយដំបង ឲ្យនូវការប្រហារដោយគ្រឿងសស្ត្រាដល់ពួកភិក្ខុនីនោះ ក្នុងទីចំពោះមុខអ្នក ម្នាលផគ្គុន

ឆន្ទៈណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ វិតក្កណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ អ្នកគប្បីលះបង់នូវឆន្ទៈ និងវិតក្កទាំងនោះ ក្នុងការឲ្យនូវប្រហារនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការឲ្យនូវប្រហារនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញនឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង អាត្មាអញនឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានកិច្ចណាមួយពោលទោសចំពោះមុខអ្នក ម្នាលផគ្គុន ឆន្ទៈណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាម-គុណ វិតក្កណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ អ្នកគប្បីលះបង់នូវឆន្ទៈ និងវិតក្កទាំងនោះ ក្នុងការពោលទោសនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការពោលទោសនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញនឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង អាត្មាអញនឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកមានចិត្តមេត្តា មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលផគ្គុន ព្រោះហេតុនោះ បើប្រសិនជាមានកិច្ចណាមួយឲ្យនូវការប្រហារដោយដៃ ឲ្យនូវការប្រហារដោយដុំដី ឲ្យនូវការប្រហារដោយដំបង ឲ្យនូវការប្រហារដោយគ្រឿងសស្ត្រាចំពោះអ្នក ម្នាលផគ្គុន ឆន្ទៈណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ វិតក្កណាដែលអាស្រ័យនូវផ្ទះ គឺបញ្ចកាមគុណ អ្នកគប្បីលះបង់ឆន្ទៈ និងវិតក្កទាំងនោះ ក្នុងការឲ្យនូវប្រហារនោះចេញ ម្នាលផគ្គុន មួយទៀត ក្នុងការឲ្យនូវប្រហារ

នោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញនឹងមិនប្រែប្រួលផង អាត្មាអញនឹងមិនបញ្ចេញវាចាអាក្រក់ផង ជាអ្នកអនុគ្រោះដោយប្រយោជន៍ មានចិត្តមេត្តា មិនមានទោសចិត្តផង ម្នាលផគ្គុន អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ៣ ] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៅនឹងភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបានញុំាងចិត្តតថាគតឲ្យត្រេកអរ ក្នុងសម័យមួយហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រាប់ភិក្ខុទាំងឡាយក្នុងទីនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតឆាន់ភោជនតែក្នុងអាសនៈមួយ ម្នាលភិក្ខុទាំងឡាយ កាលតថាគតឆាន់ភោជនតែក្នុងអាសនៈមួយ តថាគតក៏បានប្រសព្វនូវការមិនមានអាពាធផង មិនមានរោគផង ក្រោកទៅមកបានរហ័សរហួនផង កម្លាំងកាយផង ការនៅជាសុខសប្បាយផង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមកអាយ អ្នកទាំងឡាយចូរបរិភោគភោជនតែក្នុងអាសនៈមួយ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បរិភោគភោជនក្នុងអាសនៈមួយ អ្នកទាំងឡាយនឹងបានប្រសព្វនូវការមិនមានអាពាធផង មិនមានរោគផង ក្រោកទៅមកបានរហ័សរហួនផង កម្លាំងកាយផង ការនៅជាសុខសប្បាយផងមិនខាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានធ្វើនូវការប្រៀនប្រដៅភិក្ខុទាំងនោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតគ្រាន់តែដាស់ស្មារតីភិក្ខុទាំងឡាយនោះប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ដូចជារថទឹមសេះអាជានេយ្យ មានទាំងសេះដែលគេបង្ហឹកល្អហើយ មានជន្លួញប្រុងប្រៀបទីមបញ្ឈរទុកត្រង់ផ្លូវធំបែកជា ៤ មានផែនដីដ៏រាបស្មើ បង្ហឹកទូន្មាន គ្រូអ្នក

បង្ហាត់បានឡើងជិះរថនោះ កាន់ខ្សែបរដោយដៃឆ្វេង កាន់ជន្លួញដោយដៃស្តាំ បរទៅមុខខ្លះ បរវិលត្រឡប់ថយក្រោយខ្លះ តម្រង់ទៅរកផ្លូវដែលខ្លួនប្រាថ្នា និងដំណើរដែលខ្លួនប្រាថ្នា សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតមិនគួរធ្វើនូវការប្រៀនប្រដៅភិក្ខុទាំងឡាយនោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតគួរធ្វើត្រឹមតែការដាស់ស្មារតីភិក្ខុទាំងឡាយនោះប៉ុណ្ណោះ មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំង-ឡាយចូរលះអកុសលចេញ ចូរធ្វើនូវសេចក្តីព្យាយាមក្នុងកុសលធម៌ទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយបានធ្វើយ៉ាងនេះ នឹងបានដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាព្រៃឈើធំនៅជិតស្រុក ឬនិគម ព្រៃឈើនោះ សឹងតែដេរដាសដោយវល្លិឯលណ្ឌ: បុរសណាមួយប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីក្សេមក្សាន្ត ចាកគ្រឿងរួបរឹតដល់ព្រៃឈើនោះ បុរសនោះគ្នារកូនឈើដែលវៀចៗ មានឱជារសផែនដីជ្រួតជ្រាបទៅដល់ ហើយនាំយកចេញទៅខាងក្រៅ ជម្រះទីខាងក្នុងព្រៃឲ្យស្អាតបាត រួចថែរក្សាកូនឈើដែលដុះឡើងត្រង់ៗ ម្នាលភិក្ខុទាំងឡាយ ក៏កាលបើបុរសនោះ បានធ្វើយ៉ាងនេះ ព្រៃឈើនោះឯង មុខជានឹងដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយ ក្នុងសម័យខាងក្រោយមកពុំខាន សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់អកុសលចេញ ចូរធ្វើនូវសេចក្តីព្យាយាមក្នុងកុសលធម៌ទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយធ្វើយ៉ាង

នេះ នឹងដល់នូវសេចក្តីចម្រើន ដុះដាល ធំទូលាយ ក្នុងធម្មវិន័យនេះពុំខាន មានឧបមេយ្យយ៉ាងនោះឯង ។

[ ៤ ] ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា មានគហបតានីម្នាក់ឈ្មោះនាងវេទេហិកា នៅក្នុងក្រុងសាវត្ថីនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិត្តិសព្ទដ៏ពីរោះ របស់នាងវេទេហិកាគហបតានី ល្បីខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា នាងវេទេហិកាគហបតានី ជាស្ត្រីស្លូត នាងវេទេហិកាគហបតានី ជាស្ត្រីសុភាពរាបទាប នាងវេទេហិកាគហបតានី ជាស្ត្រីស្រគត់ស្រគំ ។ ម្នាលភិក្ខុទាំងឡាយ ឯនាងវេទេហិកាគហបតានី មានទាសី ១ នាក់ ឈ្មោះកាឡី ជាស្ត្រីឈ្លាសវៃ មិនខ្ជិលច្រអូស ជាអ្នកចាត់ចែងការងារល្អ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង នាងកាឡីទាសីមានសេចក្តីត្រិះរិះដូច្នេះថា នាងម្ចាស់របស់អាត្មាអញ មានកិត្តិសព្ទដ៏ពីរោះល្បីខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា នាងវេទេហិកាគហបតានី ជាស្ត្រីស្លូត នាងវេទេហិកាគហបតានី ជាស្ត្រីសុភាពរាបទាប នាងវេទេហិកាគហបតានី ជាស្ត្រីស្រគត់ស្រគំដូច្នេះ ចុះអ្នកស្រីជាម្ចាស់អញ មានកំហឹងខាងក្នុងដែរ តែមិនធ្វើឲ្យប្រាកដឬ ឬមិនមានកំហឹងខាងក្នុងទេ ឬក៏ដោយសារការងារទាំងនុ៎ះ ដែលអញបានចាត់ចែងត្រឹមត្រូវ បានជាអ្នកស្រីជាម្ចាស់អញមិនបញ្ចេញកំហឹងខាងក្នុងដែលមានដែរ មិនមែនជាមិនមានទេ បើដូច្នោះ មានតែអញល្បងអ្នកស្ត្រីជាម្ចាស់លមើល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ នាងកាឡីទាសីក្រោកឡើង ( ពីដំណេក ) ក្នុងវេលាថ្ងៃពេក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពេលនោះ នាងវេទេហិកាគហបតានី

បាននិយាយនឹងនាងកាឡីទាសីដូច្នេះថា នែមេកាឡី ។ នាងកាឡីទាសីឆ្លើយតបថា អ្នកស្រីមានប្រសាសន៍ថាម៉េច ។ ចុះហេតុម្តេចក៏ក្រោកទាល់តែថ្ងៃម៉្លេះ ។ គ្មានអ្វីទេអ្នកស្រី ។ នាងវេទេហិកាគហបតានី ក៏ខឹងអាក់អន់ចិត្ត ធ្វើមុខក្រញូវស្រដីថា យើមេចោរទាសីគម្រក់ បើមិនមានអ្វីទេ ម្តេចក៏ហេតុឯងក្រោកទាល់តែថ្ងៃម៉្លេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ កាឡីទាសីមានសេចក្តីត្រិះរិះដូច្នេះថា អ្នកស្រីជាម្ចាស់អញមានកំហឹងខាងក្នុងដែរ តែមិនធ្វើឲ្យប្រាកដ មិនមែនជាមិនមានទេ ដោយសារការងារទាំងនុ៎ះ អាត្មាអញបានចាត់ចែងត្រឹមត្រូវ បានជាអ្នកស្រីជាម្ចាស់អញ មិនបញ្ចេញកំហឹងខាងក្នុងដែលមានដែរ មិនមែនជាមិនមានទេ បើដូច្នោះ គួរតែអញល្បងមើលម្ចាស់អញ ឲ្យលើសជាងនេះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ នាងកាឡីទាសីក្រោកឡើង ( ពីដំណេក ) រឹងរឹតតែទាល់ថ្ងៃជាងមុនទៅទៀត ។ ម្នាលភិក្ខុទាំង-ឡាយ វេលានោះ នាងវេទេហិកាគហបតានី បាននិយាយនឹងនាងកាឡីទាសីដូច្នេះថា នែមេកាឡី ។ កាឡីទាសីឆ្លើយតបថា អ្នកស្រីមានប្រសាសន៍ថាម៉េច ។ ចុះហេតុ ម្តេចក៏ក្រោកទាល់ថ្ងៃម៉្លេះ ។ គ្មានអ្វីទេ អ្នកស្រី ។ នាងវេទេហិកាគហបតានី ខឹងអាក់អន់ចិត្ត ក៏បញ្ចេញវាចា ដោយសេចក្តីអាក់អន់ចិត្តថា យើមេចោរទាសីគម្រក់ បើមិនមានអ្វីទេ ម្តេចក៏ហេតុក្រោកទាល់ថ្ងៃម៉្លេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ កាឡីទាសីមានសេចក្តីត្រិះរិះដូច្នេះថា អ្នកស្រីជាម្ចាស់អញមានកំហឹងខាងក្នុងដែរ តែមិនធ្វើឲ្យប្រាកដ មិនមែនជាមិនមានទេ ដោយសារការងារទាំងនុ៎ះ ដែលអញបានចាត់ចែងត្រឹមត្រូវ បាន

ជាអ្នកស្រីជាម្ចាស់អញ មិនបញ្ចេញកំហឹងខាងក្នុង មិនមែនជាមិនមានទេ បើដូច្នោះ គួរតែអញល្បងមើលអ្នកស្រីជាម្ចាស់ឲ្យលើសជាងនេះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ កាឡីទាសីក្រោកឡើង ( ពីដំណេក ) រឹងរឹតតែទាល់ថ្ងៃជាងមុនទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ នាងវេទេហិកាគហបតានី បាននិយាយនឹងកាឡីទាសីដូច្នេះថា នែមេកាឡី ។ កាឡីទាសីឆ្លើយតបថា អ្នកស្រីមានប្រសាសន៍ថាម៉េច ។ ចុះហេតុម្តេចក៏ក្រោកទាល់ថ្ងៃម្ល៉េះ ។ គ្មានអ្វីទេអ្នកស្រី ។ នាងវេទេហិកាគហបតានី ខឹងអាក់អន់ចិត្តនិយាយថា យើមេចោរទាសីគម្រក់ បើមិនមានអ្វីទេ ម្តេចក៏ហេងក្រោកទាល់ថ្ងៃម្ល៉េះ ថាហើយ ក៏ចាប់រនុកទ្វារយោរសំពងចំក្បាលថា អញនឹងវាយបំបែកក្បាលហេង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង នាងកាឡីទាសី បែកក្បាលហូរឈាមរហាម ក៏ពោលទោសប្រាប់ស្ត្រីអ្នកស្និទ្ធស្នាលជិតខាងថា អ្នកស្រីជាម្ចាស់ ចូរមើលអំពើរបស់ស្ត្រីដែលស្លូតចុះ អ្នកស្រីជាម្ចាស់ ចូរមើលអំពើរបស់ស្ត្រីដែលសុភាពរាបទាបចុះ អ្នកស្រីជាម្ចាស់ ចូរមើលអំពើរបស់ស្ត្រីស្រគត់ស្រគំចុះ មិនសមបើអ្នកស្រីជាម្ចាស់ ( នៃខ្ញុំ ) ខឹងអាក់អន់ចិត្តនឹងទាសីម្នាក់ថា ហេងឯងក្រោក ( ពីដំណេក ) ទាល់ថ្ងៃ ហើយចាប់រនុកទ្វារយោរសំពងចំក្បាលថា អញនឹងវាយបំបែកក្បាលហេងដូច្នេះសោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ នាងវេទេហិកាគហបតានី ក៏មានកិត្តិសព្ទដ៏អាក្រក់ល្បីខ្ចរខ្ចាយសុសសាយក្នុងសម័យខាងក្រោយមកយ៉ាងនេះថា នាងវេទេហិកាគហបតានី ជាស្ត្រីកាច នាងវេទេហិកាគហបតានី ជាស្ត្រីមិនសុភាពរាបទាប

នាងវេទេហិកាគហបតានី ជាស្ត្រីមិនស្រគត់ស្រគំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះក្នុងសាសនានេះ ក៏យ៉ាងនោះដែរ ជាអ្នកស្លូតណាស់ ជាអ្នកសុភាពរាបទាបណាស់ ជាអ្នកស្រគត់ស្រគំណាស់ ត្រាតែគន្លងពាក្យ មិនជាទីគាប់ចិត្តមិនទាន់មកប៉ះពាល់ ម្នាលភិក្ខុទាំងឡាយ កាលណាបើគន្លងពាក្យមិនគាប់ចិត្តមកប៉ះពាល់ភិក្ខុហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបគេដឹងថាជាអ្នកស្លូត ថាជាអ្នកសុភាពរាបទាប ថាជាអ្នកស្រគត់ស្រគំ ក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកប្រដៅងាយ ដល់នូវភាពជាអ្នកប្រដៅងាយ ព្រោះតែចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តថាគតមិនបានហៅភិក្ខុនោះថា ជាអ្នកប្រដៅងាយឡើយ ព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ កាលបើមិនបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ក៏មិនមែនជាអ្នកប្រដៅងាយ មិនដល់នូវភាពជាអ្នកប្រដៅងាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែភិក្ខុណាមួយ ធ្វើសក្ការៈចំពោះធម៌ ធ្វើសេចក្តីគោរពធម៌ ប្រព្រឹត្តកោតក្រែងធម៌មែន ទើបពេញជាអ្នកប្រដៅងាយ ដល់នូវភាពជាអ្នកប្រដៅងាយ តថាគតហៅភិក្ខុនោះថា ជាអ្នកប្រដៅងាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកភិក្ខុក្នុងសាសនានេះ ត្រូវគិតគ្នាថា យើងទាំងឡាយ កាលធ្វើសក្ការៈចំពោះធម៌ ធ្វើសេចក្តីគោរពធម៌ ប្រព្រឹត្តកោតក្រែងធម៌ នឹងជាអ្នកប្រដៅងាយ ដល់នូវភាពជាអ្នកប្រដៅងាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[ ៥ ] ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះមាន ៥ ប្រការ គឺនិយាយក្នុងកាលគួរ ឬមិនគួរ ១ និយាយដោយពាក្យពិត ឬមិនពិត ១ និយាយដោយពាក្យល្អ ឬអាក្រក់ ១ និយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ ១ និយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬទោសចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃកាលនិយាយ គប្បីនិយាយក្នុងកាលគួរ ឬមិនគួរខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យពិត ឬពាក្យមិនពិតខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃកាលនិយាយ គប្បីនិយាយដោយពាក្យល្អ ឬពាក្យអាក្រក់ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្តខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងគន្លងនៃពាក្យនោះយ៉ាងនេះថា ចិត្តរបស់យើងនឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជា

អារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[ ៦ ] ម្នាលភិក្ខុទាំងឡាយ ដូចបុរសកាន់ចប និងល្អីដើរមក បុរសនោះ និយាយយ៉ាងនេះថា អញនឹងធ្វើផែនដីធំនេះ ឲ្យមិនមែនជាផែនដី ។ បុរសនោះ ជីកដីត្រង់ទីនោះៗ បាចសាចទៅក្នុងទីនោះៗ ស្តោះទឹកមាត់ទៅក្នុងទីនោះៗ បន្ទោបង់នូវមូត្រក្នុងទីនោះៗ ដោយគិតថា ទីនេះមិនមែនជាផែនដី ទីនេះមិនមែនជាផែនដី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះអាចនឹងធ្វើផែនដីធំនេះ ឲ្យមិនមែនជាផែនដីបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះធ្វើមិនបានទេ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ផែនដីធំនេះ ជ្រាលជ្រៅរកប្រមាណមិនបាន ផែនដីធំនោះ មិនងាយនឹងធ្វើឲ្យទៅជាមិនមែនផែនដីបានឡើយ ក៏ឯបុរសនោះ គ្រាន់តែបានចំណែកសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯងហើយ ដំណើរនោះដូចគ្នានឹងពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះ មាន ៥ ប្រការ គឺ និយាយក្នុងកាលគួរ ឬមិនគួរ ១ និយាយដោយពាក្យពិតឬមិនពិត ១ និយាយដោយពាក្យល្អ ឬពាក្យអាក្រក់ ១ និយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ ១ និយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ

កាលនិយាយ គប្បីនិយាយក្នុងកាលគួរ ឬកាលមិនគួរខ្លះ ម្នាលភិក្ខុទាំង-ឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យពិត ឬពាក្យមិនពិតខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃកាលនិយាយ គប្បីនិយាយដោយពាក្យល្អ ឬពាក្យអាក្រក់ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្តខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងគន្លងនៃពាក្យទាំងនោះយ៉ាងនេះថា ចិត្តរបស់យើងនឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញវាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តាចិត្ត មិនមានទោសចិត្តផង នឹងមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តស្មើដោយផែនដី ជាចិត្តធំទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ហើយផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[ ៧ ] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកទឹកល័ក្តក្តី ទឹករមៀតក្តី វត្ថុមានពណ៌ខៀវក្តី ពណ៌ហង្សបាទក្តី ដើរមក បុរសនោះនិយាយយ៉ាងនេះថា អាត្មាអញនឹងគូររូបទាំងឡាយ ធ្វើឲ្យមានរូបភាពប្រាកដឡើងក្នុងអាកាសនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះ

អាចគូររូបទាំងឡាយ ធ្វើឲ្យមានរូបភាព ប្រាកដឡើងក្នុងអាកាសនេះ បានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះធ្វើមិនបានទេ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាអាកាសនេះមិនមានរូប មិនជាទីឃើញរូប មិនងាយនឹងគូររូប មិនងាយនឹងធ្វើរូបភាពឲ្យមានប្រាកដ ក្នុងអាកាសនេះបានឡើយ ក៏ឯបុរសនោះ គ្រាន់តែបានចំណែកសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះមែនហើយ សេចក្តីនោះដូចគ្នានឹងពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះ មាន ៥ ប្រការ គឺនិយាយក្នុងកាលគួរ ឬកាលមិនគួរ ១ ។បេ។ ជាអ្នកមានចិត្តស្មើដោយអាកាស ជាចិត្តធំទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសកាន់គប់ភ្លើង ដែលឆេះរន្ទាលដើរមក បុរសនោះនិយាយយ៉ាងនេះថា អាត្មាអញនឹងកម្តៅទន្លេគង្គាឲ្យក្តៅសព្វដោយគប់ស្មៅដែលឆេះរន្ទាលនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះអាចកម្តៅទន្លេគង្គាឲ្យក្តៅសព្វដោយគប់ស្មៅដែលឆេះរន្ទាលបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះធ្វើមិនបានទេ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាទន្លេគង្គាមាន

ជម្រៅរាប់មិនបាន ទន្ទេគង្គានោះ បុគ្គលមិនងាយនឹងកម្តៅឲ្យក្តៅសព្វដោយ គប់ស្មៅដែលឆេះរន្ទាលបានឡើយ ក៏ឯបុរសនោះគ្រាន់តែបានចំណែកសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមាដូចម្តេច មានឧបមេយ្យដូចពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះមាន ៥ ប្រការ គឺនិយាយក្នុងកាលគួរ ឬកាលមិនគួរ ១ ។បេ។ នឹងជាអ្នកមានចិត្តស្មើដោយទន្ទេគង្គា ជាចិត្តធំទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ដូចជាសំពៀតស្បែកខ្លាត្រី ដែលបុគ្គលជំប្រចបាច់ សម្ងាប់ឲ្យទន់ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងណែន បើបុរសកាន់យកឈើ ឬអំបែងក្បឿងដើរមក បុរសនោះនិយាយយ៉ាងនេះថា អាត្មាអញនឹងយកឈើ ឬអំបែងក្បឿង ( នេះ ) ទៅគោះសំពៀតស្បែកខ្លាត្រី ដែលបុគ្គលជំប្រចបាច់ សម្ងាប់ឲ្យទន់ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងណែននេះ ធ្វើឲ្យមានសំឡេងស្រួយ ឲ្យមានសំឡេងណែនឡើងវិញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះអាចយកកំណាត់ឈើ ឬអំបែងក្បឿង ទៅគោះសម្ពៀតស្បែកខ្លាត្រី ដែលបុគ្គលជំប្រចបាច់សម្ងាប់ឲ្យទន់ដូចជាសំឡី មិនមានសំឡេង

ស្រួយ មិនមានសំឡេងណែននេះ ធ្វើឲ្យមានសំឡេងស្រួយ ឲ្យមានសំឡេងណែន ឡើងវិញបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះធ្វើមិនបានទេ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាសម្លៀកស្បែកខ្លាត្រីនេះដែលបុគ្គលជំប្រេបាច់ សម្លាប់ឲ្យទន់ដូចជាសំឡី មិនមានសំឡេងស្រួយ មិនមានសំឡេងណែន សម្លៀកស្បែកខ្លាត្រីនោះ បុគ្គលមិនងាយនឹងគោះឲ្យមានសំឡេងស្រួយ ឲ្យមានសំឡេងណែនដោយឈើ ឬអំបែងក្បឿងបានឡើយ ក៏ឯបុរសនោះ គ្រាន់តែបានចំណែកសេចក្តីលំបាកកាយ និងសេចក្តីចង្អៀតចង្អល់ចិត្តប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមានឧបមាដូចម្តេច មានឧបមេយ្យដូចពួកជនដទៃ កាលនិយាយចំពោះអ្នកទាំងឡាយ គប្បីនិយាយដោយគន្លងនៃពាក្យទាំងឡាយណា គន្លងនៃពាក្យទាំងឡាយនេះ មាន ៥ ប្រការ គឺនិយាយក្នុងកាលគួរ ឬកាលមិនគួរ ១ និយាយដោយពាក្យពិត ឬពាក្យមិនពិត ១ និយាយដោយពាក្យល្អ ឬពាក្យអាក្រក់ ១ និយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ ១ និយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយក្នុងកាលគួរ ឬកាលមិនគួរខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យពិត ឬពាក្យមិនពិតខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យល្អ ឬពាក្យអាក្រក់ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយប្រយោជន៍ ឬមិន

ប្រកបដោយប្រយោជន៍ខ្លះ ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ កាលនិយាយ គប្បីនិយាយដោយពាក្យប្រកបដោយមេត្តាចិត្ត ឬប្រកបដោយទោសចិត្តខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាក្នុងគន្លងនៃពាក្យទាំងឡាយ នោះយ៉ាងនេះថា ចិត្តរបស់យើងនឹងមិនបានប្រែប្រួលផង យើងនឹងមិនបញ្ចេញ វាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកប្រកបដោយ មេត្តាចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយ ទៅកាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តស្មើដោយសម្លៀតស្បែកខ្លាត្រី ជា ចិត្តធំទូលាយ ដល់នូវសភាពធំ មិនមានប្រមាណ មិនមានពៀរ មិនមាន ព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តា ចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[ ១០ ] ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់នាំគ្នា អាអវយវៈតូចធំរបស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញ៉ាំងចិត្តឲ្យប្រទូស្តចំពោះចោរទាំងអម្បាលនោះ ភិក្ខុនោះមិន ឈ្មោះថា ជាអ្នកធ្វើតាមសាសនារបស់តថាគត ដោយការមិនអត់សង្កត់នោះ ឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា ក្នុងការបៀតបៀន របស់ចោរនោះថា ចិត្តរបស់យើង នឹងមិនប្រែប្រួលផង យើងនឹងមិនបញ្ចេញ វាចាអាក្រក់ផង នឹងជាអ្នកអនុគ្រោះដោយប្រយោជន៍ នឹងជាអ្នកមានមេត្តា ចិត្ត មិនមានទោសចិត្តផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយទៅ កាន់បុគ្គលនោះផង នឹងជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ

ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះផង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[ ១១ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីធ្វើទុកក្នុងចិត្តចំពោះឱវាទដែលប្រៀបដោយរណារនេះឯង ឲ្យរឿយៗ ចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនឃើញគន្លងនៃពាក្យតូច ឬធំនោះ ដែលនាំឲ្យអ្នកទាំងឡាយអត់សង្កត់ មិនបានទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនឃើញគន្លងពាក្យនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើទុកក្នុងចិត្ត ចំពោះឱវាទដែលប្រៀបដោយរណារនេះឯង ឲ្យរឿយៗ ចុះ ការធ្វើទុកក្នុងចិត្តនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។ លុះព្រះមានព្រះភាគ ត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានបុណ្យ ។

**កកចូបមសូត្រទី ១ ចប់**

## អដ្ឋកថា

## កកចូបមសូត្រ

[ ១ ] កកចូបមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងកកចូបមសូត្រនោះដូចតទៅនេះ បទថា **មោលិយផគ្គុនោ** នេះ ផ្នួងសក់ លោកហៅថា **មោលិ** ដូចលោកពោលថា

**ឆេត្វាន មោលឹ វរគន្ធវាសិតំ វេហាសយំ ឧក្ខិបិ សក្យបុង្គវោ**
**រតនចង្កោដវរេន វាសវោ សហស្សនេត្តោ សិរសា បដិគ្គហិ។**

ព្រះសក្យៈដ៏ប្រសើរ ទ្រង់កាត់ព្រះមោលី ដែលអប់ដោយគ្រឿងប្រអប់ដ៏ប្រសើរហើយ បោះឡើងទៅក្នុងអាកាស ស្ដេចវាសវសហស្សនេត្រទ្រង់យកប្រអប់កែវដ៏ប្រសើរដាក់លើសិរសាទទួលទុក ដូច្នេះ ។

ក្នុងកាលដែលលោកនៅជាគ្រហស្ថ មានផ្នួងសក់ធំ ។ ព្រោះហេតុនោះ ទើបគេហៅលោកថា មោលិយផគ្គុន ។ សូម្បីបួសហើយ ជនទាំងឡាយក៏នៅចាំឈ្មោះនោះបាន ។ បទថា **អតិវេលំ** ប្រែថា ហួសព្រំដែន ។ ក្នុងបទថា **អតិវេលំ** នោះ វេលាមាន ៣ គឺកាលវេលា ១ សីមវេលា ១ សីលវេលា ១ ។

ពិតហើយ ក្នុងពាក្យថា **តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ** ប្រែថា បន្លឺនូវឧទានគាថានេះក្នុងវេលានោះ ដូច្នេះ ឈ្មោះថា **កាលវេលា** ។ ក្នុងពាក្យថា **ឋិតធម្មោ វេលំ នាតិវត្តតិ** កិក្ខុមានធម៌ដែលតាំងនៅហើយ មិនបានឈានកន្លងដែន ដូច្នេះ វេលានេះ ឈ្មោះថា **សីមវេលា** ។ ក្នុងពាក្យថា

**វេលា អនតិក្កមោ សេតុឃាតោ** ការមិនកន្លងវេលា ឈ្មោះថា សេតុឃាត-វិរតិ អរិយមគ្គជាអ្នកសម្លាប់នូវបាបធម៌ដែលទាក់ទងហើយក្នុងអរិយមគ្គ ឈ្មោះថា **សេតុ** និងក្នុងប្រយោគមួយទៀតថា **វេលាវេសា អវីតិក្កម្មដ្ឋេន** វេលាព្រោះអត្ថថា មិនកន្លងល្មើសនេះ ដូច្នេះ វេលានេះ ឈ្មោះថា **សីលវេលា** ។

ព្រះមោលិយផគ្គុនទនោះ រមែងឈានកន្លងព្រំដែន តាមដែលពោលហើយ ទាំង ៣ នោះឯង ។ ពិតហើយ កាលវេលាសម្រាប់ការឲ្យឱវាទដល់ភិក្ខុនីទាំងឡាយមាន ។ កាលព្រះអាទិត្យអស្តង្គតហើយ ព្រះមោលិយផគ្គុននោះក៏នៅតែប្រៀនប្រដៅ ទើបឈ្មោះថា កន្លងវេលានោះ ។ ឈ្មោះថា ប្រមាណ ( ការកំណត់ ) ក្នុងការទូន្មានភិក្ខុនីទាំងឡាយមាន ឈ្មោះថា **សីមមរិយាទា** ប្រែថា ព្រំដែន ព្រះមោលិយផគ្គុននោះទូន្មានលើស ៥ ឬ ៦ មាត់ឡើងទៅ ទើបឈ្មោះថា ហួសសីមវេលានោះ ។ ព្រះមោលិយផគ្គុនកាលពោលធម៌ ក៏ធ្វើជាលេង ( មានការពោលកំប្លែងជាដើម ) រមែងពោលពាក្យច្រើនគ្រប់គ្រាន់ដែលនឹងជាអាបត្តិគ្រោតគ្រាតបាន ។ ដោយប្រការយ៉ាងនេះ ឈ្មោះថា ហួសសីលវេលា ។

បទថា **សំសដ្ឋោ** គឺជាអ្នកប្រឡូកប្រឡូំរួមសុខទុក្ខគ្នា ។ បទថា **សម្មុខា** គឺខាងមុខ ។ បទថា **អវណ្ណំ ភាសតិ** សេចក្តីថា ភិក្ខុអង្គណាមួយ ឃើញពួកភិក្ខុនីទាំងនោះធ្វើកិច្ច មានបុកអង្ករជាដើម និងពោលវត្ថុដែលមិនមែនជាគុណថា ភិក្ខុនីពួកនេះប្រព្រឹត្តមិនល្អ ប្រដៅក្រ ជាអ្នករពឹស គង់នឹងមិនត្រូវអាបត្តិ ដូច្នេះ ។ បទថា **អធិករណម្បិ ករោតិ** សេចក្តីថា ព្រះមោលិយផគ្គុន

រមែងធ្វើអធិករណ៍ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ចាប់តាំងពីឃើញភិក្ខុនីទាំងឡាយហើយ ទាស់ក្អែក ការបូជាដោយផ្កាក្នុងវិហារនេះ ឬការធ្វើផ្សេងៗ មានការលាងជម្រះអាសនៈ និងការប្រោះព្រំជាដើម រមែងប្រព្រឹត្តទៅដោយភិក្ខុនីទាំងនេះ ភិក្ខុនីទាំងនេះជាកុលធីតា ជាអ្នកមានការខ្មាស ពួកលោកពោលយ៉ាងនេះៗ ដល់ភិក្ខុនីទាំងនោះ ពួកលោកត្រូវអាបត្តិឈ្មោះនេះ ពួកលោកចូរមកសម្មាក់ព្រះវិនយធរ ហើយឲ្យវិនិច្ឆ័យដល់ខ្ញុំ ។ បទថា **មោលិយផគ្គុ-ណស្ស អវណ្ណំ ភាសតិ** សេចក្តីថា ភិក្ខុណាមួយ រមែងពោលវត្ថុដែលមិនមែនគុណថា ឈ្មោះថា អាបត្តិ រមែងមិនមានដល់ភិក្ខុនី ក្នុងបរិវេណរបស់ព្រះមោលិយផគ្គុននេះ មិនស្ងាត់ចាកភិក្ខុនីអស់កាលជានិច្ច ដូច្នេះ ។ បទថា **អធិករណម្បិ ករោន្តិ** សេចក្តីថា រមែងធ្វើអធិករណ៍ដល់ភិក្ខុទាំងឡាយថា ចាប់តាំងអំពីយើងឃើញព្រះមោលិយផគ្គុនត្ថេរហើយ រមែងទាក់ក្អែក អ្នកណាម្នាក់ក៏មិនចង់មើលទីនៅរបស់ភិក្ខុដទៃក្នុងវិហារនេះ ពួកភិក្ខុនីដែលមកកាន់វិហារនេះ បានអាស្រ័យព្រះថេរៈ គឺព្រះមោលិយផគ្គុនមួយរូបពិតៗ ទើបបានឱវាទខ្លះ បដិសណ្ឋារៈខ្លះ បទឧទ្ទេសខ្លះ លោកជាបុត្ររបស់អ្នកមានត្រកូល មានសេចក្តីខ្មាស មានសេចក្តីរង្កៀស ពួកលោកពោលពាក្យយ៉ាងនេះៗ បែបនេះ ពួកលោកចូរមកឲ្យព្រះវិនយធរវិនិច្ឆ័យដល់ខ្ញុំ ដូច្នេះ ។ បទថា **សោ ភិក្ខុ ភគវន្តំ ឯតទវោច** សេចក្តីថា បានក្រាបទូលដើម្បីឲ្យជាទីស្រឡាញ់ក៏ទេ ឬដោយបំណង ដើម្បីឲ្យបែកគ្នាក៏ទេ ដោយពិត ដើម្បីប្រាថ្នាប្រយោជន៍ប៉ុណ្ណោះ ។

បានឮថា ភិក្ខុនោះគិតថា កាលភិក្ខុ គឺមោលិយផល្គុននេះប្រឡូកប្រឡំ យ៉ាងនេះ ការវិនាសយសនឹងកើតឡើង វត្ថុដែលមិនមែនយសនោះជាទោស ដល់ព្រះសាសនា ព្រះមោលិយផល្គុននេះត្រូវភិក្ខុដទៃជាស់តឿនហើយ ក៏មិន ព្រមលះបង់ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ឲ្យឱវាទហើយ ក៏នឹងលះបង់ ដូច្នេះ ។ ព្រោះភិក្ខុនោះជាអ្នកប្រាថ្នាប្រយោជន៍ ទើបបានក្រាបទូលព្រះមាន ព្រះភាគថា **អាយស្មា ភន្តេ** ជាដើម ប្រែថា បពិត្រព្រះអង្គដ៏ចម្រើន មោលិយផគ្គុនមានអាយុ នៅប្រឡូកប្រឡំ ជាមួយនឹងពួកភិក្ខុនីហួសវេលា ជាដើម ។

[ ២ ] បទថា **អាមន្តេហិ** គឺចូរឲ្យជ្រាប ។ បទថា **អាមន្តេតិ** ប្រែថា ត្រាស់ហៅ ។ បទថា **សទ្ធា** ប្រែថា ដោយសទ្ធា ។ បទថា **តស្មា** សេចក្តី ថា ព្រោះលោកជាកូនអ្នកមានត្រកូល ជាអ្នកបួសដោយសទ្ធា ឬព្រោះលោក ប្រឡូកប្រឡំនឹងភិក្ខុនីទាំងនោះ មនុស្សពួកណាជេរភិក្ខុនី ឬប្រហារភិក្ខុនី កើត សេចក្តីទោមនស្សអាក់អន់ចិត្ត ក្នុងមនុស្សទាំងនោះ កាលលោកលះការ ប្រឡូកប្រឡំបានហើយ ទោមនស្សក៏មិនកើត ដូច្នេះ ។ បទថា **តត្រ** គឺក្នុង ការនិន្ទានោះ ។ បទថា **គេហសិតា** គឺអាស្រ័យបញ្ចកាមគុណ ។ បទថា **ឆន្ទា** គឺពេញចិត្តដោយតណ្ហាខ្លះ ពេញចិត្តដោយបដិឃៈខ្លះ ។ បទថា **វិបរិណតំ** សេចក្តីថា ចិត្តត្រេកអរដោយអំណាចតណ្ហា ក៏ប្រែប្រួល ទាំង ចិត្តដែលក្រោធ ទាំងចិត្តដែលវង្វេងក៏ប្រែប្រួលទៅជាដទៃ តែក្នុងទីនេះ ចិត្ត ដែលត្រេកអរដោយការពេញចិត្ត ដោយអំណាចតណ្ហាក៏គួរ សូម្បីចិត្តដែល

ក្រោធដោយការពេញចិត្ត ដោយអំណាចបដិឃៈក៏គួរ ។ បទថា **ហិតានុ-**
**កម្បិ** បានដល់ អនុគ្រោះដោយប្រយោជន៍ គឺ ផ្សាយចេញទៅដោយ
ប្រយោជន៍ ។ បទថា **ន ទោសន្តរោ** គឺអញមិនជាបុគ្គលមានទោសចិត្ត ។

[ ៣ ] ព្រោះហេតុអ្វី ទើបលោកផ្តើមពាក្យថា **អថ ខោ ភគវា** ជា
ដើម បានឮថា សូម្បីការគិតថា តថាគតឲ្យឱវាទមានប្រមាណប៉ុណ្ណេះហើយ
នឹងវៀរចាកការប្រឡូកប្រឡំជាមួយភិក្ខុនីទាំងឡាយ ដូច្នេះ របស់មោលិយ-
ផគ្គុនមិនបានកើតឡើងឡើយ ។ ព្រះមោលិយផគ្គុននោះ ជាអ្នកជំទាស់នឹង
ព្រះមានព្រះភាគ ប្រៀបដូចស្នៀតបោះខ្ទាស់សំពត់ស្តើង ។ ក្នុងគ្រានោះ
ព្រោះទ្រង់ឃើញភិក្ខុអ្នកប្រដៅក្របនេះ ភាវៈនៃពួកភិក្ខុដែលប្រដៅងាយ ក្នុង
បឋមពោធិកាល ក៏មកប្រាកដដល់ព្រះមានព្រះភាគ ដូចបុរសអ្នកឃ្លានប្រាថ្នា
អាហារ អ្នកស្រេកទឹក ប្រាថ្នាទឹកផឹក អ្នករងាប្រាថ្នាកម្តៅ អ្នកជួបទុក្ខ ប្រាថ្នា
សុខ ដូច្នោះ ។ លំដាប់នោះ ទ្រង់មានបំណងនឹងសរសើរពួកភិក្ខុដែលប្រដៅ
ងាយទាំងនោះ ទើបផ្តើមទេសនានេះ ។ បណ្តាបទទាំងនោះ បទថា **អារាធ-**
**យឹសុ** ប្រែថា ឲ្យត្រេកអរ គឺឲ្យកាន់យក ។ បទថា **ឯកំ សមយំ** ប្រែថា
សម័យមួយ ។ បទថា **ឯកាសនភោជនំ** បានដល់ ការឆាន់អាហារម្តងក្នុង
វេលាបុរេភត្ត ។ ពិតហើយ តាំងអំពីព្រះអាទិត្យរះឡើង រហូតដល់វេលាថ្ងៃ
ត្រង់ ភិក្ខុទោះឆាន់អាហារ ១០ ដង លោកបំណងយកក្នុងពាក្យថា ឆាន់
អាហារម្តង ។ បទថា **អប្បាពាធតំ** គឺប្រាសចាកអាពាធ ។ បទថា **អប្បា-**
**តង្កតំ** គឺប្រាសចាកទុក្ខ ។ បទថា **លហុដ្ឋានំ** បានដល់ មានកាយរហ័ស

រហួន ។ បទថា **ពលំ** ប្រែថា មានកម្លាំងកាយ ។ បទថា **ផាសុវិហារំ** គឺកាយនៅជាសុខ ។ សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ដោយសូត្រនេះ ឆ្លើយថា ព្រះមានព្រះភាគត្រាស់ដល់កាលឲ្យលះការឆាន់អាហារក្នុងវេលាវិកាល ក្នុងវេលាថ្ងៃ ក្នុងសូត្រនេះ តែក្នុងកទ្ទាលិសូត្រ ត្រាស់ដល់កាលឲ្យលះការឆាន់អាហារក្នុងវេលាវិកាល ក្នុងវេលាយប់ ។ ព្រះមានព្រះភាគ ទ្រង់មិនបានឲ្យភិក្ខុលះការឆាន់អាហារក្នុងវេលាវិកាលទាំង ២ នេះព្រមគ្នាឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអាហារក្នុងវេលាវិកាលទាំង ២ នេះ សត្វទាំងឡាយប្រព្រឹត្តមក រហូតជាទម្លាប់ក្នុងវដ្តៈហើយ កុលបុត្រដែលជាសុខុមាលជាតិមានប្រាកដ កុលបុត្រទាំងនោះ បើលះអាហារក្នុងវេលាវិកាលទាំង ២ ព្រមគ្នា រមែងលំបាក ព្រោះដូច្នោះ ទើបទ្រង់មិនឲ្យលះព្រមគ្នា គឺឲ្យលះការឆាន់អាហារនោះមួយដង គឺឲ្យលះអាហារក្នុងវេលាវិកាលក្នុងពេលថ្ងៃម្តង និងឲ្យលះអាហារក្នុងវេលាវិកាល ក្នុងពេលយប់ម្តង ។

ក្នុង ២ ដងនោះ ក្នុងសូត្រនេះ ត្រាស់ឲ្យលះការឆាន់អាហារក្នុងវេលាវិកាលក្នុងពេលថ្ងៃ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនមែនចង្អុលភ័យឲ្យការលះការឆាន់អាហារក្នុងវេលាវិកាលប៉ុណ្ណោះទេ តែទ្រង់សម្តែងអានិសង្ស ហើយទើបឲ្យលះ ដោយហេតុនោះឯង ទើបសត្វទាំងឡាយ លះបានដោយងាយ ព្រោះដូច្នោះ កាលសម្តែងអានិសង្ស ទើបត្រាស់គុណប្រយោជន៍ទាំង ៥ នេះ គឺមានអាពាធតិច លំបាកតិចជាដើម ។

បទថា **អនុសាសនី ករណីយា** សេចក្តីថា ត្រូវប្រៀនប្រដៅរឿយៗ ថា

ពួកអ្នកចូរធ្វើវត្ថុនេះ កុំធ្វើវត្ថុនេះ គឺមានតែកិច្ចធ្វើឲ្យកើតសតិប៉ុណ្ណោះ និង ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបឋមពោធិកាល ដោយហេតុមាន ប្រមាណប៉ុណ្ណោះ ភិក្ខុទាំងនោះបានធ្វើវត្ថុដែលគួរធ្វើ បានលះវត្ថុដែលគួរលះ ភិក្ខុទាំងឡាយជាអ្នកប្រដៅងាយ ជឿស្តាប់ ទទួលយកឱវាទ ។

ឥឡូវនេះ កាលទ្រង់នាំឧបមា ដែលទូន្មានដល់កាពដែលភិក្ខុទាំងនោះជា អ្នកប្រដៅងាយ ទើបត្រាស់ពាក្យថា **សេយ្យថាបិ** ជាដើម ។ បណ្តាបទទាំង នោះ បទថា **សុភូមិយំ** បានដល់ ដីដែលរាបស្មើ ដូចក្នុងប្រយោគថា បុគ្គល គប្បីសាបព្រោះពូជក្នុងដីដែលល្អ ក្នុងស្រែដែលប្រាសចាកជង្គត់ឈើជាដើម និងពាក្យដែលមកក្នុងប្រយោគថា ដីដែលស្អាត ជាដីដែលល្អជាដើម ។ បទ ថា **ចតុម្មហាបថេ** បានដល់ ក្នុងផ្លូវធំ ២ ខ្វែង ខ្វែងគ្នាទៅ ។ បទថា **អាជញ្ញរថោ** បានដល់ រថទឹមដោយសេះដែលបង្ហឹកល្អហើយ ។ បទថា **ឱធស្តបតោទោ** សេចក្តីថា នាយសារថីដែលឈ្លាស ឡើងកាន់រថហើយ អាចកាន់យកជន្ទញ ដែលដាក់ខាងស្តាំ ហើយសំយុងចុះ ។ បទថា **យោគ្គា-ចរិយោ** បានដល់ នាយសារថី ។ បុគ្គលណាទូន្មានសេះ បុគ្គលនោះ ឈ្មោះ ថា **អស្សទម្មសារថិ** ។ បទថា **យេនិច្ឆកំ** គឺរមែងប្រាថ្នាទៅផ្លូវណា ។ បទ ថា **យទិច្ឆកំ** គឺរមែងត្រូវចេញទៅទីណា ។ បទថា **សារេយ្យ** គឺគប្បីទៅផ្លូវ ត្រង់ខាងមុខ ។ បទថា **បច្ចា សារេយ្យ** គឺឲ្យត្រឡប់ ។ បទថា **ឯវមេវ ខោ** សេចក្តីថា ដូចនាយសារថីនោះ រមែងប្រាថ្នាទៅផ្លូវណាមួយ សេះក៏ឡើង កាន់ផ្លូវនោះ រមែងប្រាថ្នាដោយគតិណាមួយ ក៏កាន់យកគតិនោះឯងទៅ សេះ

ទាញរថទៅ ក៏មិនហាម មិនវាយ តែសេះដាក់ក្រចកដើរ ទៅក្នុងដីដែលរាប យ៉ាងល្អប៉ុណ្ណោះ ។ ពាក្យដែលយើងគប្បីពោលដដែលក្នុងភិក្ខុទាំងឡាយនោះ មិនមានដោយអាការយ៉ាងនេះថា ចូរធ្វើការនេះ កុំធ្វើការនេះ មានកិច្ចដែល គួរធ្វើ ក៏ត្រឹមតែដាស់តឿនសតិប៉ុណ្ណោះ ដូច្នេះ កិច្ចដែលគួរធ្វើ ក៏ឈ្មោះថា ភិក្ខុទាំងឡាយធ្វើមកមុនហើយទាំងអស់ កិច្ចមិនគួរធ្វើ លោកក៏លះបង់បាន ហើយ ។ បទថា **តស្មា** សេចក្តីថា ពួកភិក្ខុដែលជាអ្នកប្រដៅងាយ ប្រៀប ដូចយានដែលទឹមដោយសេះអាជានេយ្យ លះអកុសលធម៌បានដោយត្រឹមតែ ឲ្យកើតសតិប៉ុណ្ណោះ ព្រោះដូច្នោះ ពួកអ្នកចូរលះអកុសលធម៌ចេញ ។ បទ ថា **ឯឡណ្ឌេហិ** សេចក្តីថា បានឮថា ដើមល្ហុងខ្វងទាំងឡាយ រមែងប្រទូស្ត ដើមសាលៈ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហើយយ៉ាងនោះ ។ បទ ថា **វិសោធេយ្យ** គឺគប្បីកាត់ដើមល្ហុងខ្វងទាំងឡាយ និងវល្លិ៍ដទៃចេញហើយ ក៏ធ្វើការសម្អាតដោយនាំទៅចោលខាងក្រៅ ។ បទថា **សុជាតា** បានដល់ តាំងនៅដោយល្អ ។ បទថា **សម្មា បរិហរេយ្យ** គឺគប្បីការពារខេត្ត ធ្វើឲ្យ ចម្រើន មើលថែឲ្យត្រឹមត្រូវ ដោយការស្រោចទឹកក្តី ជ្រួយដីត្រង់ទីជិតគល់ តាមវេលាដែលគួរក្តី កាត់វល្លិ៍ និងគុម្ពឈើជាដើមក្តី នាំសម្បុកស្រមោចខ្មៅ ចេញទៅក្តី យកសរសៃពីងពាង និងកំណាត់ឈើស្ងួតចេញទៅក្តី ។ ការ ចម្រើនជាដើម មានអត្ថដូចពោលហើយនោះឯង ។

[ ៤ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងទោសនៃការ មិនអត់ធន់ ទើបត្រាស់ថា ភូតបុព្វំ ជាដើម ។ បណ្តាបទទាំងនោះ បទថា

**វេទេហិកា** នេះ ជាឈ្មោះកុលធីតា ដែលអាស្រ័យនៅក្នុងវេទេហរដ្ឋ ។ ម្យ៉ាងទៀត លោកហៅបញ្ញាថា **វេទ** ។ បុគ្គលណាវមែងទៅ វមែងប្រព្រឹត្តទៅដោយបញ្ញា ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **វេទេហិកា** អធិប្បាយថា បណ្ឌិត ។ បទថា **គហបតានី** គឺស្រីមេផ្ទះ ។ បទថា **កិត្តិសទ្ទោ** គឺកិត្តិសព្ទ ។ បទថា **សោរតា** បានដល់ ដែលប្រកបដោយការស្ងប់ស្ងៀម ។ បទថា **និវាតា** គឺប្រព្រឹត្តបន្ទាបខ្លួន ។ បទថា **ឧបសន្តា** គឺជាអ្នកស្ងប់ត្រជាក់ ។ បទថា **ទក្ខា** បានដល់ ជាអ្នកឈ្លាសវៃក្នុងការងារទាំងឡាយមានការចម្អិនបាយ ក្រាលទីដេក និងដុតប្រទីបជាដើម ។ បទថា **អនលសា** ជាអ្នកក្រោកឡើង គឺឧស្សាហ៍ ។ បទថា **សុសំវិហិតកម្មន្តា** គឺមានការងារចាត់ចែងហើយយ៉ាងល្អ ។ លោកសម្តែងថា ទាសីម្នាក់មិនខ្វិលប្រអូស តែចាប់កាជនៈណា ធ្វើឲ្យកាជនៈនោះបែក ឬស្រាំ ទាសីនេះ មិនដូច្នោះឡើយ ។ បទថា **ទិវា ឧដ្ឋាសិ** សេចក្តីថា ក្រោកឡើងក្នុងវេលាដែលព្រះអាទិត្យរះខ្ពស់ហើយ មិនធ្វើការងារ មានការរឹតទឹកដោះគោជាដើម ដែលគួរធ្វើអំពីព្រហាម ។ បទថា **ហេ ជេ កាឡិ** សេចក្តីថា នែនាងកាឡី ព្រោះហេតុអ្វី ទើបហានក្រោកយឺតយូរ ហានមានជំងឺ ឬដូចម្តេច ។ បទថា **នោ វត រេ កិញ្ចិ** សេចក្តីថា កាលមិនផាសុកណាមួយ មានការឈឺក្បាល ឈឺខ្នងជាដើម មិនមានកាលបើដូច្នោះ ទើបនាងនោះបានពោលថា នែនាងជាតិអាក្រក់ ហេតុអ្វី ទើបហានក្រោកយឺតដូច្នេះ ហើយក្រោធអាក់អន់ ធ្វើមុខក្រញូវ ។ បទថា **ទិវាតរំ ឧដ្ឋាសិ** គឺក្នុងថ្ងៃស្អែកឡើង ក៏ក្រោកឡើងយឺតជាងមុន ។ បទថា **អនត្ត-**

**មនំ វាចំ** សេចក្ដីថា មេផ្ទះនោះពោលថា នៃនាងមានជាតិអាក្រក់ ហាងមិនស្គាល់ប្រមាណខ្លួនឯង សម្គាល់ថាត្រជាក់ពេកឬ ដូច្នេះ កាលនឹងឲ្យនាងកាឡីទាសីនោះដឹងខ្លួន ទើបបន្លឺសំឡេងរបស់ខ្លួនដែលក្រោធ ។ បទថា **បដិ-វិស្សកានំ** ប្រែថា ជាអ្នកនៅផ្ទះជិតខាង ។ បទថា **ឧជ្ឈាបេសិ** គឺត្រាច់ពោលទោសឲ្យគេមើលងាយ ។ បទថា **ចណ្ឌី** គឺមិនស្ងប់ស្ងៀម ជាបុគ្គលអាក្រក់ អធិប្បាយថា គុណទាំងឡាយមានប្រមាណប៉ុណ្ណេះ ដោយអាការយ៉ាងនេះ តែទោសកើតឡើងជាទ្វេគុណ ច្រើនជាងគុណនោះ ។ ធម្មតាគុណទាំងឡាយ រមែងមកសន្សឹមៗ ។ តែទោសនោះត្រឹមតែមួយថ្ងៃ ក៏ផ្សាយខ្ចរ-ខ្ចាយទៅ ។ បទថា **សោរតសោរតោ** ប្រែថា ជាមនុស្សស្ងប់ស្ងៀមយ៉ាងក្រៃលែង ។ សូម្បីបុគ្គលនោះពោលថា ជាព្រះសោតាបន្នឬហ្ន៎ សកទាគាមី អនាគាមី អរហន្តឬហ្ន៎ ។ បទថា **ផុសន្តិ** បានដល់ វាចាដែលប្រាកដមកត្រូវប៉ះខ្ទប់ពេលនោះ ទើបដឹងបានថា ភិក្ខុនោះ ជាអ្នកស្ងប់ស្ងាត់ ។ មួយ៉ាងទៀតភិក្ខុតាំងនៅក្នុងអធិវាសនខន្តិ គប្បីជ្រាបថា ជាភិក្ខុដែលស្ងប់ស្ងាត់ ។ បទថា **យោ ចីវរ ។បេ។ បរិក្ខារហេតុ** សេចក្ដីថា ភិក្ខុរូបណា កាលបានបច្ច័យទាំងឡាយ មានចីវរជាដើមដែលប្រណីតៗ ទាំងនោះ រមែងធ្វើការប្រចាប់ជើង ប្រចាប់ខ្នងជាដើម ដោយពោលពាក្យមួយម៉ាត់ប៉ុណ្ណោះ ។ បទថា **អលភមានោ** គឺកាលមិនបានដូចដែលធ្លាប់បានមកអំពីមុន ។ បទថា **ធម្មំយេវ សក្ករោន្តោ** គឺកាលធ្វើសក្ការៈ គឺការដែលធ្វើឲ្យល្អចំពោះធម៌នោះឯង ។ បទថា **គរុករោន្តោ** គឺធ្វើសេចក្ដីគោរពឲ្យជាភារៈ ។ បទថា **មានេន្តោ** គឺធ្វើឲ្យ

ជាទីស្រឡាញ់ ដោយការឱនលំទោន ។ បទថា **ប្វូជោន្តោ** បានដល់ បូជា ដោយបច្ច័យ ។ បទថា **អបចាយមានោ** បានដល់ គោរព សម្តែងការ កោតក្រែង បន្ទាបខ្លួនចំពោះធម៌នោះឯង ។

[ ៥ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងទោសនៃការមិនអត់អន់ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងគន្លងនៃវាទៈ ៥ ប្រការ ដោយព្រះតម្រាស់ថា ពួកជនរមែងអត់ធន់យ៉ាងនេះហើយ ត្រាស់ពាក្យថា **បញ្ចិមេ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កាលេន** ប្រែថា ដោយកាលវេលាដែលសមគួរ ។ បទថា **ភូតេន** ប្រែថា ដោយពាក្យដែលពិត ។ បទថា **សណ្ហេន** គឺដោយពាក្យដែលសុភាព ។ បទថា **អត្ថសញ្ហិតេន** ដោយពាក្យដែលអាស្រ័យប្រយោជន៍ អាស្រ័យហេតុ ។ បទថា **អកាលេន** ជាដើម ប្រែថា ដោយកាលដែលមិនសមគួរជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃធម៌ដែលជាបដិបក្ខចំពោះធម៌ទាំងនោះឯង ។ បទថា **មេត្តចិត្តា** គឺកើតមេត្តាចិត្ត ។ បទថា **ទោសន្តរា** គឺចិត្តដែលទោសៈប្រទូស្តហើយ គឺកើតទោសៈឡើងហើយខាងក្នុង ។ បទថា **តត្រាបិ** គឺក្នុងគន្លងនៃពាក្យទាំងនោះ ។ បទថា **ផរិត្វា** គឺបង្ក្រានទៅ ។ បទថា **តទារម្មណាញ្ច** គឺធ្វើវាចាឲ្យជាអារម្មណ៍នៃចិត្តនោះទូទៅក្នុងលោក ភិក្ខុធ្វើបុគ្គលដែលកាន់យកគន្លងនៃវាចា ៥ មកហើយ ឲ្យជាអារម្មណ៍របស់មេត្តាចិត្ត កាលធ្វើសត្វដ៏សេស ឲ្យជាអារម្មណ៍នៃមេត្តាចិត្តនោះឯងទៀត ទើបឈ្មោះថា ធ្វើឲ្យជាអារម្មណ៍នៃចិត្តនោះទូទៅក្នុងលោក ។ សេចក្តីនោះ គប្បីជ្រាបអត្ថនៃវាចាដូច្នេះ ។ បទថា

**តទារម្មណញ្ច** បានដល់ ធ្វើឲ្យជាអារម្មណ៍នៃមេត្តាចិត្តនោះឯង ។ បទថា **សព្វាវន្តំ** បានដល់ សត្វទាំងអស់ ។ បទថា **លោកំ** បានដល់ សត្វលោក ។ បទថា **វិបុលេន** បានដល់ មានសត្វមិនមែនតិចជាអារម្មណ៍ ។ បទថា **មហគ្គតេន** គឺប្រកបដោយចិត្តមហគ្គតភូមិ ។ បទថា **អប្បមាណេន** គឺ ចម្រើនល្អហើយ ។ បទថា **អវេរេន** គឺមិនមានទោស ។ បទថា **អព្យា-បជ្ឈេន** គឺមិនមានទុក្ខ ។ បទថា **ផរិត្វា វិហរិស្សាម** សេចក្តីថា ពួកយើង បង្អោនទឹកដល់បុគ្គលនោះ និងសត្វលោកទាំងអស់ ធ្វើឲ្យជាអារម្មណ៍របស់ចិត្តនោះ ដោយចិត្តដែលសហគតៈដោយមេត្តាបែបនេះហើយ ។

[ ៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់នាំឧបមា ដែលចង្អុលបង្ហាញដល់អត្ថនោះ ទើបត្រាស់បទថា **សេយ្យថាបិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អបថវឹ** បានដល់ ធ្វើឲ្យមិនមានផែនដី អធិប្បាយថា ឲ្យដល់នូវភាពមិនមានផែនដី ។ បទថា **តត្រ តត្រ** ប្រែថា ទីនោះ ។ បទថា **វិកិរេយ្យ** គឺកាន់យកបន្តិលើកដីឡើងរោយ ដូចគ្រាប់ពូជទាំងឡាយ ។ បទថា **ឱដ្ឋុភេយ្យ** គឺស្តោះទឹកមាត់ ។ បទថា **អបថវឹ ករេយ្យ** សេចក្តីថា បុគ្គលណា ធ្វើសេចក្តីព្យាយាមដោយកាយ និងវាចាយ៉ាងនេះ ក៏មិនអាចធ្វើផែនដីធំមិនឲ្យជាផែនដីបានឡើយ ។

បទថា **គម្ភីរា** ប្រែថា ជ្រៅ គឺជ្រៅដោយកម្រាស់ ២៤០០០០ យោជន៍ ។ បទថា **អប្បមេយ្យា** ប្រែថា ប្រមាណមិនបាន គឺកំណត់មិនបានផ្នែកទទឹង ។ បទថា **ឯវមេវ ខោ** នេះ ជាការប្រៀបធៀបដោយឧបមាក្នុងទីនេះ មេត្តាចិត្ត

គប្បីឃើញដូចផែនដី ។ បុគ្គលដែលកាន់យកគន្លងនៃវាចា ៥ យ៉ាងមកហើយ ដូចបុរសកាន់យកចប និងបង្គីមកហើយ ។ បុរសនោះ មិនអាចធ្វើផែនដីធំមិនឲ្យជាផែនដីបាន ដោយចប និងបង្គី យ៉ាងណា បុគ្គលដែលកាន់យកគន្លងនៃវាទៈ ៥ យ៉ាងមកហើយ ក៏មិនអាចធ្វើមេត្តាចិត្តនៃអ្នកទាំងឡាយឲ្យប្រែប្រួលបាន ដូច្នោះ ។

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាទី ២ ដូចតទៅនេះ បទថា **ហលិទ្ទឹ** បានដល់ ពណ៌លឿងណាមួយ ។ បទថា **នីលំ** បានដល់ ពណ៌ខៀវ ពណ៌សិរីទ្ធ ឬពណ៌បៃតង ។ បទថា **អរូបី** ប្រែថា មិនមានរូប ។ សួរថា បរិច្ឆិន្នាកាសក្នុងរវាងនៃពួកឈើទាំង ២ ក្តី ដើមឈើក្តី ទីដេកក្តី សិលាក្តី ក៏ប្រាកដជាា រូបមិនមែនឬ ព្រោះហេតុអ្វី ទើបក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ថា អាកាសជារបស់មិនមានរូប ដូច្នេះ ឆ្លើយថា ព្រោះបដិសេធការឃើញរូប ដោយហេតុនោះឯង ទើបត្រាស់បទថា **អនិទស្សនោ** ប្រែថា ចង្អុលឲ្យឃើញមិនបាន ។ ពិតហើយ បុគ្គលណាម្នាក់ មិនអាចគូររូបសម្តែងរូបឲ្យប្រាកដក្នុងអាកាសនោះបាន ដូច្នោះ ទើបត្រាស់ថា **អរូបី** ប្រែថា មិនមានរូប ដូច្នេះ ។ បទថា **អនិទស្សនោ** គឺមិនមែនវិថីនៃចក្ខុវិញ្ញាណដែលធ្វើកិច្ចឃើញ ។ ក្នុងការប្រៀបធៀបឧបមាទី ២ នេះ មេត្តាចិត្តប្រៀបដូចអាកាស គន្លងនៃវាទៈ ៥ យ៉ាង ប្រៀបដូចគ្រឿងគូរ ៤ យ៉ាង មានប៉ុយសំឡីជាគម្រប់ ៥ ។ បុគ្គលកាន់យកគន្លងនៃពាក្យ ៥ យ៉ាង មកហើយ ប្រៀបដូចបុរសដែលកាន់យកគ្រឿងគូរទាំងឡាយ មានប៉ុយសំឡីជាគម្រប់ ៥

មកហើយ ។ បុរសនោះរមែងមិនអាចធ្វើរូបភាពឲ្យប្រាកដក្នុងអាកាស ដោយគ្រឿងគូរទាំងឡាយ ដែលមានប៉ុយសំឡីជាគម្រប់ ៥ យ៉ាងណា បុគ្គលដែលកាន់យកគន្លងនៃពាក្យទាំង ៥ មកហើយ ក៏មិនអាចធ្វើមេត្តាចិត្តរបស់អ្នកទាំងឡាយឲ្យប្រែប្រួល គឺឲ្យមានទោសៈកើតឡើងបានឡើយ ដូច្នោះ ។

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាទី ៣ ដូចតទៅនេះ បទថា **អាទិត្តំ** គឺភ្លើងឆេះឡើងសន្ធោសន្ធៅហើយ ។ បទថា **គម្ភីរា អប្បមេយ្យា** សេចក្ដីថា ចំណែកដែលជ្រៅនៃស្ទឹងគង្គា ដែលមានមួយគាវុត គឺ ១០០ សិន ក៏មាន កន្លះយោជន៍ក៏មាន មួយយោជន៍ក៏មាន ឯទទឹងនៃស្ទឹងគង្គានេះ ក៏យ៉ាងនោះដូចគ្នា ។ តែដោយចំណែកបណ្ដោយប្រមាណ ៥០០ យោជន៍ ។ សួរថា ជម្រៅនោះប្រមាណមិនបានព្រោះហេតុអ្វី ឆ្លើយថា ព្រោះផ្លាស់ប្ដូរដោយការព្យាយាមនោះ មិនអាចធ្វើស្ទឹងនោះឲ្យក្ដៅបាន ដូចទឹកដែលយកទៅដាក់លើចង្ក្រាននោះឡើយ ។ ទឹកប្រមាណ ១ ធ្លាប់ ឬ ៨ ធ្លាប់ បុគ្គលអាចធ្វើវាឲ្យក្ដៅបាន ដោយឧបាយណាមួយ តែស្ទឹងគង្គានេះ បុគ្គលមិនអាចធ្វើឲ្យក្ដៅបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ ការប្រៀបធៀបឧបមាក្នុងសេចក្ដីនេះ ដូច្នេះថា មេត្តាចិត្តប្រៀបដូចស្ទឹងគង្គា បុគ្គលដែលកាន់យកគន្លងនៃវាចា ៥ យ៉ាងមកហើយ ប្រៀបដូចបុរសដែលកាន់គប់ស្មៅមកហើយ ។ បុរសនោះ មិនអាចធ្វើស្ទឹងគង្គា ឲ្យក្ដៅដោយគប់ស្មៅយ៉ាងណា បុគ្គលដែលកាន់យកគន្លងនៃវាចា ៥ យ៉ាងមកហើយ ក៏នឹងមិនអាចធ្វើមេត្តាចិត្តឲ្យប្រែប្រួលបាន ដូច្នោះ ។

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាទី ៤ ដូចតទៅនេះ បទថា **វិឡារ-ភស្តា** ប្រែថា សំពៀតស្បែកខ្លាត្រី ។ បទថា **សុមទ្ទិតា** ប្រែថា សម្ងាប់ល្អហើយ ។ បទថា **សុបរិមទ្ទិតា** គឺសម្ងាប់ល្អហើយដោយជុំវិញទាំងខាងក្នុងនិងខាងក្រៅ ។ បទថា **តោលិនី** គឺជារបស់ស្មើគ្នានឹងសម្លីរកាសម្លីវល្លិ ។ បទថា **ឆិន្នសស្សរា** ប្រែថា មិនមានសំឡេងស្រួយ ។ បទថា **ឆិន្នបព្ភរា** ប្រែថា មិនមានសំឡេងណែន ។ ក្នុងការប្រៀបធៀបឧបមាក្នុងសេចក្តីនេះមានដូច្នេះ មេត្តាចិត្ត ប្រៀបដូចសម្លៀតស្បែកខ្លាត្រី ។ បុគ្គលដែលកាន់យកគន្លងនៃវាទៈ ៥ យ៉ាង មកហើយ ប្រៀបដូចបុរសកាន់យកឈើ ឬអំបែងក្បឿងមកហើយ ។ បុរសនោះ មិនអាចយកឈើ ឬអំបែងក្បឿងវាយសម្លៀតស្បែកខ្លាត្រីឲ្យមានសំឡេងស្រួយ យ៉ាងណា បុគ្គលកាន់យកគន្លងនៃវាទៈ ៥ យ៉ាង មកហើយ ក៏មិនអាចធ្វើមេត្តាចិត្តឲ្យប្រែប្រួល គឺឲ្យប្រព្រឹត្តទៅតាមទោសៈបាន ដូច្នោះ ។

[ ១០ ] បទថា **ឱចរកា** គឺប្រព្រឹត្តថោកទាប អធិប្បាយថា អ្នកធ្វើកម្មដ៏អាក្រក់ ។ បទថា **យោ មនោ បទូសេយ្យ** សេចក្តីថា បុគ្គលណា ទោះភិក្ខុក្តី ភិក្ខុនីក្តី អាក់អន់ អត់ធន់នឹងការអារដោយរណារនោះមិនបាន ។ បទថា **ន មេ សោ តេន សាសនករោ** សេចក្តីថា បុគ្គលនោះ ឈ្មោះថាមិនជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅរបស់តថាគត ព្រោះហេតុអត់ធន់មិនបាននោះឯង តែអាបត្តិរមែងមិនមានដល់លោក ព្រោះអត់ធន់មិនបាននោះ ។

[ ១១ ] បទថា **អណុំ វា ថូលំ វា** ប្រែថា មានទោសតិច ឬមានទោស

ច្រើន ។ បទថា **យំ តុម្ហេ ឆាធិវាសេយ្យាថ** សេចក្ដីថា បុគ្គលណាដែលគប្បី ជាបុគ្គលដែលពួកអ្នកអត់ធន់មិនបាន ។ បទថា **នោ ហេតំ ភន្តេ** អធិប្បាយ ថា ពួកខ្ញុំព្រះអង្គមិនឃើញគន្លងនៃពាក្យ ដែលខ្ញុំព្រះអង្គអត់ធន់មិនបានក៏ទេ ។

ព្រះមានព្រះភាគ ទ្រង់កាន់យកកំពូលដោយអរហត្ត ទើបឲ្យទេសនា ចប់តាមលំដាប់អនុសន្ធិថា សេចក្ដីនោះ ជាប្រយោជន៍ និងសេចក្ដីសុខ ដល់ ពួកអ្នកអស់កាលដ៏យូរអង្វែង ដោយប្រការដូច្នេះឯង ។៚

**អដ្ឋកថាកកចូបមសូត្រ ចប់**

**សូត្រទី ១ ចប់**

# សុត្តន្តបិដក

## អលគទ្ទូបមសូត្រទី ២

[ ១២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុឈ្មោះអរិដ្ឋ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ ពួកភិក្ខុច្រើនរូប បានឮដំណឹងថា អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ គ្រានោះឯង ភិក្ខុទាំងនោះ ក៏ចូលទៅរកអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតនោះ លុះចូលទៅដល់ហើយ បានសួរដំណើរនុ៎ះនឹងអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋ បានឮថា អ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនគួរ

ធ្វើនូវសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ មែនឬ ។ ម្នាលអាវុសោទាំង-ឡាយ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា តែងធ្វើនូវសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនគួរធ្វើនូវសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ យ៉ាងហ្នឹងមែន ។ គ្រានោះឯង ភិក្ខុទាំងនោះមានប្រាថ្នាដើម្បីធ្វើអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ឲ្យបែរចាកទិដ្ឋិអាក្រក់នោះ ក៏សាកសួរដេញដោល សួររកហេតុថា នែអាវុសោអរិដ្ឋ អ្នកកុំពោលយ៉ាងហ្នឹងឡើយ អ្នកកុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ការពោលបង្កាច់ព្រះមានព្រះភាគមិនល្អទេ ព្រោះថា ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងហ្នឹងឡើយ នែអាវុសោអរិដ្ឋ ធម៌ទាំងឡាយតែងធ្វើនូវសេចក្ដីអន្តរាយ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្ដីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើន ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដូចរាងឆ្អឹង មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃលែង ព្រះមានព្រះភាគទ្រង់សំដែងថា កាមទាំងឡាយ មានឧបមាដូចដុំសាច់ ... ។ ព្រះមានព្រះភាគទ្រង់សំដែងថា កាមទាំងឡាយ មានឧបមាដូចគប់ស្មៅ ... ។ ព្រះមានព្រះភាគទ្រង់សំដែងថា កាមទាំងឡាយ មានឧបមាដូច

រណ្តៅរងើកភ្លើង ... ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កាមទាំងឡាយមានឧបមាដូចការយល់សប្តិ ... ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កាមទាំង-ឡាយ មានឧបមាដូចរបស់ខ្ចីគេ ... ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កាមទាំងឡាយមានឧបមាដូចផ្លែឈើ ... ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កាមទាំងឡាយមានឧបមាដូចកាំបិត និងជ្រញ់ ... ។ ព្រះមានព្រះភាគ ទ្រង់សម្តែងថា កាមទាំងឡាយមានឧបមាដូចលំពែង និងដែកស្រួច ... ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កាមទាំងឡាយមានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ចិត្តច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើនក្រៃលែង ។ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត ទុកជាភិក្ខុទាំងឡាយនោះសាកសួរដេញដោល សួររកហេតុយ៉ាងនេះហើយ ក៏នៅតែនិយាយប្រកាន់រឹង ព្រោះកម្លាំងនៃទិដ្ឋិ ព្រោះការស្ទាបអង្អែលដោយទិដ្ឋិថា ម្នាលអាវុសោ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់ សម្តែងហើយយ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។

[ ១៣ ] ភិក្ខុទាំងឡាយនោះ មិនអាចធ្វើភិក្ខុឈ្មោះអរិដ្ឋ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ឲ្យបែរចាកទិដ្ឋិអាក្រក់នុ៎ះបាន ក្នុងកាលណា ភិក្ខុទាំងឡាយនោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងកាលនោះ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ភិក្ខុទាំងឡាយ

នោះលុះអន្ទាយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះអរិដ្ឋ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ បានឮដំណឹងថា ភិក្ខុឈ្មោះអរិដ្ឋ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង យើងខ្ញុំទាំងឡាយក៏ចូលទៅរកអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត លុះចូលទៅដល់ហើយ ក៏បានសួរដំណើរនោះនឹងអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋ បានឮថាអ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ មែនឬ កាលដែលយើងខ្ញុំទាំងឡាយ សួរយ៉ាងនេះហើយ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត

ក៏និយាយមកនឹងយើងខ្ញុំទាំងឡាយវិញដូច្នេះថា នែអាវុសោទាំងឡាយ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយយ៉ាងនេះឯង ធម៌ទាំង-ឡាយណា ដែលព្រះមានព្រះភាគទ្រង់សំដែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង យើងខ្ញុំទាំងឡាយមានប្រាថ្នានឹងធ្វើអរិដ្ឋ-ភិក្ខុឲ្យបែរចាកទិដ្ឋិអាក្រក់នុ៎ះ ទើបយើងខ្ញុំទាំងឡាយសាកសួរដេញដោល សួររកហេតុថា ម្នាលអាវុសោអរិដ្ឋ អ្នកកុំពោលយ៉ាងហ្នឹង អ្នកកុំពោលបង្កាច់នូវព្រះមានព្រះភាគឡើយ ការពោលបង្កាច់ព្រះមានព្រះភាគមិនល្អទេ ព្រោះថា ព្រះមានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ នែអាវុសោអរិដ្ឋ ធម៌ទាំង-ឡាយ តែងធ្វើនូវសេចក្តីអន្តរាយ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំង-ឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដូចរាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ។បេ។ ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក បពិត្រព្រះអង្គដ៏ចម្រើន អរិដ្ឋភិក្ខុមាន

បុព្វបុរសជាអ្នកសម្លាប់ត្មាត ទុកជាយើងខ្ញុំទាំងឡាយសាកសួរដេញដោលសួររកហេតុ ក៏នៅតែនិយាយប្រកាន់រឹងព្រោះកម្លាំងនៃទិដ្ឋិ ព្រោះការស្ទាបអង្អែលដោយទិដ្ឋិថា ម្នាលអាវុសោទាំងឡាយ ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយយ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះតែយើងខ្ញុំទាំងឡាយ មិនអាចធ្វើភិក្ខុឈ្មោះអរិដ្ឋ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ឲ្យបែរចាកទិដ្ឋិអាក្រក់នុ៎ះ បានជាយើងខ្ញុំទាំងឡាយ សូមក្រាបបង្គំទូលហេតុនុ៎ះ ចំពោះព្រះមានព្រះភាគ ។

[ ១៤ ] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបថា ម្នាលភិក្ខុ ចូរអ្នកមកអាយ អ្នកចូរទៅហៅអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត តាមពាក្យតថាគតថា ម្នាលអាវុសោអរិដ្ឋ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត លុះចូលទៅដល់ហើយ ក៏និយាយនឹងអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាតដូច្នេះថា ម្នាលអាវុសោអរិដ្ឋ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត ក៏ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះអរិដ្ឋភិក្ខុមានបុព្វបុរស ជាអ្នក

សម្ងាប់ត្មាត អន្ទុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអរិដ្ឋ បានឮថាអ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងថា អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចនឹងធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ដូច្នេះមែនឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយយ៉ាងនេះឯង ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់សម្តែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ នៃមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសម្តែងហើយយ៉ាងនេះ អំពីសំណាក់អ្នកណា ។ ម្នាលមោឃបុរស ធម៌ធ្វើនូវសេចក្តីអន្តរាយ តថាគតសម្តែងហើយ ដោយអនេកបរិយាយ ក៏ឯធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពដោយពិត តថាគតសម្តែងហើយថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក តថាគតសម្តែងហើយថា កាមទាំងឡាយមានឧបមាដូចរាងឆ្អឹង ... ។ តថាគតសម្តែងហើយថា កាមទាំងឡាយមានឧបមាដូចដុំសាច់ ... ។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចគប់ស្មៅ ... ។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ... ។ តថាគតសម្តែងហើយថា កាម

ទាំងឡាយ មានឧបមាដូចការយល់សប្តិ ...។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចរបស់ដែលខ្ចីគេ ...។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចផ្លែឈើ ... ។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចកាំបិត និងជ្រញ់ ... ។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចលំពែង និងដែកស្រួច ... ។ តថាគតសម្តែងហើយថា កាមទាំងឡាយ មានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក នែមោឃបុរស កាលបើហេតុមានទំនងយ៉ាងនេះ អ្នកឈ្មោះថាពោលបង្កាច់តថាគតផង ឈ្មោះថា គាស់រម្លើងនូវខ្លួនឯងផង ឈ្មោះថា ទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនប្រកាន់អាក្រក់ ម្នាលមោឃបុរស ព្រោះថាអំពើអាក្រក់នោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់អ្នកអស់កាលយូរអង្វែង ។ គ្រានោះឯង ព្រះមានព្រះភាគត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះថាដូចម្តេច អរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ ឈ្មោះថាមានចំហាយកម្តៅភ្លើង គឺញាណក្នុងធម្មវិន័យនេះបានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ចំហាយកម្តៅភ្លើងនោះនឹងមានដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចំហាយកម្តៅភ្លើងនោះមិនមានឡើយ ។ កាលដែលពួកភិក្ខុក្រាបទូលព្រះមានព្រះភាគយ៉ាងនេះហើយ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត ក៏អង្គុយនៅស្ងៀមអៀនខ្មាស ជាក់កសំយុងចុះ ឱនមុខចុះ សញ្ជប់សញ្ជឹង មិនក្លៀវក្លា ។

[ ១៥ ] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបថា អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាត អង្គុយនៅស្ងៀម អៀនខ្មាស ដាក់កសំយុងចុះឱនមុខចុះ សញ្ជប់សញ្ជឹងមិនឆ្លៀវឆ្លាហើយ មានព្រះបន្ទូលទៅនឹងអរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតដូច្នេះថា ម្នាលមោឃបុរស អ្នកនឹងប្រាកដដោយទិដ្ឋិអាក្រក់ជារបស់ខ្លួននេះ តែតថាគតនឹងសាកសួរភិក្ខុទាំងឡាយក្នុងសេចក្តីនេះ ។ គ្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ ពោលបង្កាច់តថាគតផង ជីកគាស់រម្លើងនូវខ្លួនឯងផង ទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនកាន់យកអាក្រក់ ដោយប្រការណា ព្រោះអ្នកទាំងឡាយ ដឹងច្បាស់នូវធម៌ ដែលតថាគតសម្តែងហើយ ដោយប្រការដូច្នោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយមិនបានដឹងច្បាស់នូវធម៌ទុំះទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ធម៌ធ្វើនូវសេចក្តីអន្តរាយ ព្រះមានព្រះភាគទ្រង់សម្តែងហើយដល់យើងខ្ញុំទាំងឡាយ ដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពពិតមែន ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយមានឧបមាដូចរាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនក្រៃពេក ។បេ។ ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ

មានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃពេក ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយ យ៉ាងនេះប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ ព្រោះថាធម៌ធ្វើនូវសេចក្តីអន្តរាយ តថាគតសំដែងហើយដល់អ្នកទាំងឡាយដោយអនេកបរិយាយ ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពពិតមែន តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃពេក តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដូចរាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃពេក ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដូចក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើនក្រៃពេក កាលបើហេតុមានទំនងយ៉ាងនេះ អរិដ្ឋភិក្ខុមានបុព្វបុរសជាអ្នកសម្លាប់ត្មាតនេះ ឈ្មោះថាពោលបង្កាច់តថាគតផង ឈ្មោះថា គាស់រំលើងនូវខ្លួនឯងផង តែងទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនប្រកាន់អាក្រក់ ព្រោះថាអំពើនោះ នឹងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ជាទុក្ខដល់មោឃបុរសនោះ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ អរិដ្ឋភិក្ខុនោះ វៀរលែងចាកកាមទាំងឡាយ វៀរលែងចាកសេចក្តីសម្គាល់ ក្នុងកាមទាំងឡាយ វៀរលែងចាកកាមវិតក្កទាំងឡាយហើយ ត្រឡប់សេពនូវកាមទាំងឡាយវិញ នេះមិនមែនជាឋានៈ

ឡើយ ។

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានមោឃបុរសពួកខ្លះ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ លុះមោឃបុរសទាំងនោះ បានរៀនធម៌នោះហើយ ក៏មិនបានពិចារណានូវសេចក្តីនៃធម៌ទាំងឡាយនោះដោយប្រាជ្ញា ធម៌ទាំងនោះដែលមោឃបុរសទាំងនោះ មិនបានពិចារណានូវសេចក្តីដោយប្រាជ្ញាហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្ត មោឃបុរសទាំងនោះ រៀនធម៌ដោយមានបំណងតែខាងលើកទោសគេផង ដោយមានបំណងតែខាងដោះស្រាយវាទៈដូច្នេះដូច្នោះផង កុលបុត្រទាំងឡាយ រៀនធម៌ដើម្បីប្រយោជន៍ណា ពួកមោឃបុរសនោះ មិនបាននូវប្រយោជន៍នោះ របស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះដែលមោឃ-បុរសទាំងនោះ រៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរអង្វែង ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំង-ឡាយ ព្រោះថាធម៌ទាំងឡាយ មោឃបុរសទាំងនោះរៀនមិនល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ក៏ត្រាច់ ទៅស្វែងរកពស់វែក បុរសនោះបានឃើញពស់វែក ១ យ៉ាងធំហើយ ក៏ចាប់ពស់វែកនោះត្រង់ខ្លួន ឬកន្ទុយ ពស់វែកនោះ ក៏ងាកមកចឹកបុរសនោះត្រង់ដៃ ឬដើមដៃ ឬអវយវៈតូចធំណាមួយ បុរសនោះក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខជិតតែនឹងស្លាប់ មានពស់វែកនោះជាហេតុ ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពស់វែក បុរសនោះចាប់មិន

ស្រួល ម្នាលភិក្ខុទាំងឡាយ មានមោឃបុរសពួកខ្លះ ក្នុងសាសនានេះ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ លុះមោឃបុរសទាំងនោះ រៀនធម៌នោះហើយ មិនបានពិចារណានូវសេចក្តីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះ មិនបានពិចារណានូវសេចក្តីដោយប្រាជ្ញាហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្ត មោឃបុរសទាំងនោះ រៀនធម៌ដោយមានបំណងតែខាងលើកទោសគេផង ដោយមានបំណងតែខាងដោះស្រាយនូវវាទៈដូច្នេះ ដូច្នោះផង កុលបុត្រទាំងឡាយ រៀនធម៌ដើម្បីប្រយោជន៍ណា ពួកមោឃបុរសនោះ ក៏មិនបាននូវប្រយោជន៍នោះ របស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះ រៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ធម៌ទាំងឡាយ ដែលមោឃបុរស រៀនមិនល្អហើយ យ៉ាងនេះឯង ។

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ កុលបុត្រទាំងនោះ លុះរៀនធម៌នោះហើយ ក៏ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយនោះដោយប្រាជ្ញា ធម៌ទាំងនោះ លុះកុលបុត្រទាំងនោះពិចារណានូវសេចក្តីដោយប្រាជ្ញាហើយ ក៏ប្រាកដច្បាស់ក្នុងចិត្ត កុលបុត្រទាំងនោះមិនមែនរៀនធម៌ ដោយមានបំណងតែខាងលើកទោសគេផង មិន

មែនរៀនធម៌ដោយមានបំណងតែខាងដោះស្រាយវាទៈដូច្នេះដូច្នោះផង កុល-បុត្រឯទៀតរៀនធម៌ ដើម្បីប្រយោជន៍ណា កុលបុត្រទាំងនោះ ក៏បាននូវប្រយោជន៍នោះ របស់ធម៌នោះ ធម៌ទាំងនោះដែលកុលបុត្រពួកនោះរៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ទាំង-ឡាយដែលកុលបុត្រទាំងនោះ បានរៀនដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ត្រាច់ទៅស្វែងរកពស់វែក បុរសនោះបានឃើញពស់វែក ១ យ៉ាងធំ ក៏សង្កត់ពស់វែកនោះដោយដំបងដូចជាជើងពពែ ដោយស្រួលបួល លុះសង្កត់ដោយដំបងដូចជាជើងពពែយ៉ាងស្រួលហើយ ក៏ចាប់ត្រង់កយ៉ាងមាំ ម្នាលភិក្ខុទាំងឡាយ ពស់វែកនោះរុំព័ទ្ធដៃ ឬដើមដៃ ឬអវយវៈតូចធំណាមួយនៃបុរសនោះ ដោយរំពត់ទាំង-ឡាយ ក៏មែនហើយ តែបើទុកជាដូច្នោះ បុរសនោះក៏មិនដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ មានពស់វែកនោះជាហេតុទេ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាពស់វែក បុរសនោះចាប់ត្រូវទំនង ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះ រៀនធម៌ គឺសុត្តៈគេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ កុលបុត្រទាំងនោះ លុះបានរៀនធម៌នោះហើយ ក៏ពិចារណានូវសេចក្តីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងនោះលុះកុលបុត្រពួកនោះបានពិចារណា នូវសេចក្តីដោយប្រាជ្ញា ក៏ប្រាកដច្បាស់ក្នុងចិត្ត កុលបុត្រទាំងនោះមិនមែនរៀនធម៌

ដោយមានបំណងតែខាងលើកទោសគេផង មិនមែនរៀនធម៌ដោយមានបំណងតែខាងដោះស្រាយវាទៈដូច្នេះ ដូច្នោះផង កុលបុត្រឯទៀត រៀនធម៌ ដើម្បីប្រយោជន៍ណា កុលបុត្រទាំងនោះ ក៏បាននូវប្រយោជន៍នោះ របស់ធម៌នោះ ធម៌ទាំងឡាយនោះ ដែលកុលបុត្រទាំងនោះរៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ទាំងឡាយដែលកុលបុត្រទាំងនោះរៀនដោយល្អ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយអាចដឹងច្បាស់នូវសេចក្តីនៃភាសិតណា របស់តថាគត គប្បីចាំទុកនូវសេចក្តីនៃភាសិតនោះយ៉ាងនោះចុះ មួយវិញទៀត អ្នកទាំងឡាយមិនអាចដឹងច្បាស់នូវសេចក្តីនៃភាសិតណា របស់តថាគត អ្នកទាំងឡាយគប្បីសាកសួរតថាគតក្នុងអត្ថនៃភាសិតនោះចុះ ឬក៏គប្បីសួរចំពោះភិក្ខុណាដែលឈ្លាសវៃចុះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ មានឧបមាដូចក្បូនដល់អ្នកទាំងឡាយ ដើម្បីរលាស់ខ្លួនចេញ មិនមែនដើម្បីឲ្យនៅប្រកាន់ឡើយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវសេចក្តីនោះ ចូរខំយកចិត្តទុកដាក់ឲ្យប្រពៃ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ១៨ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកដើរផ្លូវឆ្ងាយ បុរសនោះឃើញនូវអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យ មានត្រើយខាងនាយដ៏ក្សេម

ប្រាសចាកភ័យ តែថា ទូក ក្បូន ឬស្ពានសម្រាប់ឆ្លងពីត្រើយអាយទៅត្រើយនាយ នៃបុរសនោះមិនមានឡើយ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អន្លង់ទឹកដ៏ធំនេះ មានត្រើយខាងអាយប្រកបដោយសេចក្តីរង្កៀស និងភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ ទូក ក្បូន ឬស្ពានសម្រាប់ឆ្លងពីត្រើយខាងអាយទៅត្រើយខាងនាយក៏គ្មាន បើដូច្នោះ មានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើ មែកឈើ និងចំបើង យកមកចងធ្វើជាក្បូន ហើយអាស្រ័យនូវក្បូននោះ ព្យាយាមដោយដៃ និងជើង ឆ្លងទៅកាន់ត្រើយខាងនាយ ដោយសួស្តីបាន ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះក៏ប្រមូលស្មៅ កំណាត់ឈើ មែកឈើ និងចំបើង មកចងជាក្បូន ហើយបានអាស្រ័យក្បូននោះ ព្យាយាមដោយដៃ និងជើង ឆ្លងទៅកាន់ត្រើយខាងនាយបានដោយសួស្តី កាលបុរសនោះឆ្លងទៅដល់ត្រើយខាងនាយហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញៗបានអាស្រ័យក្បូននេះ ព្យាយាមដោយដៃ និងជើង ឆ្លងមកដល់ត្រើយដោយសួស្តីបាន បើដូច្នោះ មានតែអាត្មាអញលើកក្បូននេះ ទូលលើក្បាល ឬលីនឹងក ដើរចេញទៅកាន់ទីគួរតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះធ្វើយ៉ាងនេះ បានឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនមែនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសនោះធ្វើដូចម្តេច ទើបបានឈ្មោះថា ធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះ

ឆ្លងដល់ត្រើយនាយក្នុងទីឯនោះ គួរតែត្រិះរិះយ៉ាងនេះថា ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញៗ បានអាស្រ័យនូវក្បូននេះហើយ ព្យាយាមដោយដៃ និងជើង ឆ្លងមកដល់ត្រើយនាយបានដោយសួស្តី បើដូច្នោះមានតែអាត្មាអញលើកក្បូននេះ ដាក់លើគោក ឬពន្លិចក្នុងទឹក ហើយដើរចេញទៅកាន់ទីគួរតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះ ដែលធ្វើយ៉ាងនេះបាន ឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មានឧបមាដូចជាក្បូន ដែលតថាគតសំដែងហើយ ដើម្បីឲ្យរលាស់ខ្លួនចេញ មិនមែនដើម្បីឲ្យនៅប្រកាន់ឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ដឹងច្បាស់នូវធម៌ មានឧបមាដូចក្បូន ដែលតថាគតសំដែងហើយ គប្បីលះបង់ធម៌ទាំងឡាយចេញ នឹងចាំបាច់ពោលទៅថ្វីដល់អកុសលធម៌ ។

[១៩] ម្នាលភិក្ខុទាំងឡាយ ហេតុជាទីតាំងនៃទិដ្ឋិទាំងឡាយនេះ មាន៦។ ហេតុជាទីតាំងនៃទិដ្ឋិទាំង ៦ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនឃើញនូវពួកអរិយបុគ្គល មិនឈ្លាសក្នុងអរិយធម៌ មិនសិក្សាក្នុងអរិយធម៌ មិនឃើញនូវពួកសប្បុរស មិនឈ្លាសក្នុងសប្បុរិសធម៌ មិនសិក្សាក្នុងសប្បុរិសធម៌ ពិចារណាឃើញនូវរូបថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ពិចា-រណាឃើញនូវវេទនាថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ពិចារណាឃើញនូវសញ្ញាថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ពិចារណាឃើញនូវសង្ខារទាំង-

ឡាយថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ អារម្មណ៍ណាដែលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ មកដល់ បានស្វែងរក បានពិចារណារឿយៗ ក៏ពិចារណាឃើញអារម្មណ៍នោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ហេតុជាទីតាំងនៃទិដ្ឋិណាថា នុ៎ះជាសត្វលោក នុ៎ះជាខ្លួនអាត្មាអញ អាត្មាអញនោះទៅកាន់បរលោក នឹងជាអ្នកទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតិវត្ថុដូច្នោះឯង ក៏ពិចារណាឃើញហេតុជាទីតាំងនៃទិដ្ឋិនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដូច្នេះ ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលចេះដឹង បានឃើញពួកអរិយៈជាអ្នកឈ្លាសក្នុងអរិយធម៌ បានសិក្សាដោយប្រពៃក្នុងអរិយធម៌ បានឃើញពួកសប្បុរស ជាអ្នកឈ្លាសក្នុងសប្បុរិសធម៌ បានសិក្សាដោយប្រពៃក្នុងសប្បុរិសធម៌ ពិចារណាឃើញនូវរូបថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ពិចារណាឃើញនូវវេទនាថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ពិចារណាឃើញនូវសញ្ញាថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ពិចារណាឃើញនូវសង្ខារទាំងឡាយថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ អារម្មណ៍ណាដែលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ បានដល់ បានស្វែងរក បានពិចារណារឿយៗ ដោយចិត្ត ក៏

ពិចារណាឃើញនូវអារម្មណ៍នោះថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ហេតុជាទីតាំងនៃទិដ្ឋិណាថា នុ៎ះជាសត្វលោក នុ៎ះជាខ្លួន អាត្មាអញនោះទៅក្នុងបរលោក នឹងជាបុគ្គលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតិវត្ថុដូច្នោះឯង ក៏ពិចារណាឃើញនូវហេតុជាទីតាំងនៃទិដ្ឋិនោះថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ អរិយសាវកនោះកាលពិចារណាឃើញច្បាស់យ៉ាងនេះ កាលបើវត្ថុនោះមិនមាន គឺថាវិនាសទៅ ក៏មិនតក់ស្លុតឡើយ ។

[ ២០ ] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុ ១ រូប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បើបរិក្ខារខាងក្រៅមិនមាន គឺថាវិនាសទៅ សេចក្តីតក់ស្លុតមានឬទេ ។ ព្រះមានព្រះភាគទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយក្នុងលោកនេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ទ្រព្យរបស់អាត្មាអញមានហើយ តែឥឡូវ ទ្រព្យរបស់អាត្មាអញនោះ ត្រឡប់ទៅជាគ្មានវិញ ទ្រព្យណា ដែលអាត្មាអញគួរបាន ឥឡូវអាត្មាអញ មិនបានទ្រព្យនោះឡើយ បុគ្គលនោះ ក៏សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងភ្លេច ម្នាលភិក្ខុ កាលបើបរិក្ខារខាងក្រៅមិនមានហើយ សេចក្តីតក់ស្លុត រមែងមាន យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបើបរិក្ខារខាងក្រៅ មិនមានហើយ សេចក្តីមិនតក់ស្លុតមានដែរឬទេ ។ ព្រះមានព្រះភាគ

ទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយ ក្នុងលោកនេះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា ទ្រព្យរបស់អាត្មាអញមានហើយ តែឥឡូវ ទ្រព្យរបស់អាត្មាអញនោះ ត្រឡប់ទៅជាគ្មានវិញ ទ្រព្យណា ដែលអាត្មាអញគួរបាន ឥឡូវ អាត្មាអញមិនបានទ្រព្យនោះឡើយ បុគ្គលនោះមិនសោកសៅ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងភ្លេច ម្នាលភិក្ខុ កាលបើបរិក្ខារខាងក្រៅមិនមានហើយ សេចក្តីមិនតក់ស្លុត រមែងមានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្តីតក់ស្លុត មានឬទេ ។ ព្រះមានព្រះភាគទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយ ក្នុងលោកនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា នុ៎ះជាសត្វលោក នុ៎ះជាខ្លួន អាត្មាអញនោះទៅក្នុងបរលោក នឹងជាបុគ្គលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅបីដូចជាសស្សតិវត្ថុដូច្នោះឯង បុគ្គលនោះ រមែងស្តាប់ពាក្យរបស់តថាគតក្តី របស់សាវកនៃតថាគតក្តី ដែលសម្តែងធម៌ដើម្បីគាស់រម្លើងនូវទិដ្ឋិ និងហេតុនៃទិដ្ឋិ និងទីតាំងអាស្រ័យនៃទិដ្ឋិ និងសេចក្តីគ្របសង្កត់នៃទិដ្ឋិ និងអនុស័យដែលតាំងនៅមាំក្នុងសន្តាន ដើម្បីរម្ងាប់នូវសង្ខារទាំងពួង ដើម្បីលះបង់នូវឧបធិទាំងពួង ដើម្បីអស់ទៅនៃតណ្ហា ដើម្បីប្រាសចាករាគៈ ដើម្បីរលត់នៃកងទុក្ខ ដើម្បីព្រះនិព្វាន ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងសូន្យទៅ មិនកើតទៀតឡើយ អាត្មាអញនឹងវិនាសទៅ មិនកើតទៀតឡើយ អាត្មាអញមុខជានឹងមិនកើតទៀតឡើយ បុគ្គលនោះ ក៏

សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេងភ្លេច ម្នាលភិក្ខុ កាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្ដីតក់ស្លុត រមែងមានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្ដីមិនតក់ស្លុត គប្បីមានដែរឬទេ ។ ព្រះមានព្រះភាគទ្រង់តបថា ម្នាលភិក្ខុ មាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកមួយ ក្នុងលោកនេះ មិនមានសេចក្ដីយល់ឃើញយ៉ាងនេះថា នុ៎ះជាសត្វលោក នុ៎ះជាខ្លួន អាត្មាអញនោះទៅក្នុងបរលោក នឹងជាបុគ្គលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅបីដូចជាសស្សតិវត្ថុដូច្នោះឯង បុគ្គលនោះ រមែងស្ដាប់ពាក្យរបស់តថាគតក្ដី សាវកនៃតថាគតក្ដី ដែលសម្ដែងធម៌ ដើម្បីគាស់រម្លើងនូវទិដ្ឋិ និងហេតុនៃទិដ្ឋិ និងទីតាំងអាស្រ័យនៃទិដ្ឋិ និងសេចក្ដីគ្របសង្កត់នៃទិដ្ឋិ និងអនុស័យដែលតាំងនៅមាំក្នុងសន្ដាន ដើម្បីរម្ងាប់នូវសង្ខារទាំងពួង ដើម្បីលះបង់នូវឧបធិទាំងពួង ដើម្បីអស់ទៅនៃតណ្ហា ដើម្បីប្រាសចាករាគៈ ដើម្បីរលត់នៃកងទុក្ខ ដើម្បីព្រះនិព្វាន ។ បុគ្គលនោះមិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងសូន្យទៅ មិនកើតទៀតឡើយ អាត្មាអញនឹងវិនាសទៅ មិនកើតទៀតឡើយ អាត្មាអញមុខជានឹងមិនកើតទៀតឡើយ បុគ្គលនោះមិនសោកសៅ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេងភ្លេច ម្នាលភិក្ខុ កាលបើវត្ថុខាងក្នុងមិនមានហើយ សេចក្ដីមិនតក់ស្លុត រមែងមានយ៉ាងនេះ ។

[ ២១ ] ម្នាលភិក្ខុទាំងឡាយ ទ្រព្យរបស់ណា ដែលទៀងទាត់ ឋិតថេរ

មិនប្រែប្រួល ឋិតនៅដូចជាសស្សតិវត្ថុដូច្នោះឯង អ្នកទាំងឡាយគប្បីគន់មើល នូវទ្រព្យរបស់នោះចុះ ម្នាលភិក្ខុទាំងឡាយ ទ្រព្យរបស់ណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតិវត្ថុដូច្នោះឯង តើអ្នកទាំងឡាយ ឃើញនូវទ្រព្យរបស់នោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនឃើញ ទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទ្រព្យរបស់ណា ដែលទៀងទាត់ ឋិតថេរ មិនប្រែប្រួល ឋិតនៅដូចជាសស្សតិវត្ថុ ដូច្នោះឯង សូម្បីតថាគត ក៏មិនឃើញនូវទ្រព្យរបស់នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បី កើតដល់បុគ្គលអ្នកប្រកាន់នូវអត្តវាទុបាទានណា អ្នកទាំងឡាយប្រកាន់នូវអត្ត-វាទុបាទាននោះ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើង ដល់បុគ្គលអ្នកប្រកាន់នូវអត្ត-វាទុបាទានណា អ្នកទាំងឡាយបានឃើញនូវអត្តវាទុបាទាននោះឬទេ ។ បពិត្រ ព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនឃើញនូវអត្តវាទុបាទាននុ៎ះទេ ។ ម្នាលភិក្ខុ ទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់បុគ្គលអ្នកប្រកាន់ នូវអត្តវាទុបាទានណា សូម្បីតថាគតក៏មិនឃើញនូវអត្តវាទុបាទាននោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តី ចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើង ដល់បុគ្គលអាស្រ័យនូវទិដ្ឋិនិស្ស័យណា អ្នកទាំងឡាយអាស្រ័យនូវទិដ្ឋិនិស្ស័យនោះ ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក

ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើង ដល់បុគ្គលអាស្រ័យនូវទិដ្ឋិនិស្ស័យណា អ្នកទាំងឡាយឃើញនូវទិដ្ឋិនិស្ស័យ នោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនឃើញនូវទិដ្ឋិនិស្ស័យ នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ សេចក្ដី សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្ត មិនគប្បីកើត ឡើង ដល់បុគ្គលអាស្រ័យនូវទិដ្ឋិនិស្ស័យណា សូម្បីតថាគតក៏មិនឃើញនូវ ទិដ្ឋិនិស្ស័យនោះដែរ ។

[ ២២ ] ម្នាលភិក្ខុទាំងឡាយ កាលបើខ្លួនមានហើយ សេចក្ដីត្រិះរិះថា នេះជាបរិក្ខាររបស់ខ្លួនអញដូច្នេះ មានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាល ភិក្ខុទាំងឡាយ កាលបើបរិក្ខាររបស់ខ្លួនមានហើយ សេចក្ដីត្រិះរិះថា នេះជា ខ្លួនរបស់អញដូច្នេះ មានដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើខ្លួនក្ដី បរិក្ខាររបស់ខ្លួនក្ដី ដែលបុគ្គលមិនបានដោយពិត ដោយ ឋិតថេរ ហេតុជាទីតាំងនៃទិដ្ឋិណាថា នុ៎ះជាសត្វលោក នុ៎ះជាខ្លួន អាត្មាអញ នោះទៅក្នុងបរលោក នឹងជាបុគ្គលទៀងទាត់ ឋិតថេរ មិនប្រែប្រួល នឹងឋិត នៅដូចជាសស្សតវត្ថុដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ នេះជាពាលធម៌បរិបូណ៌ ទាំងអស់ មានពិតឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ថ្វីក៏មិនមាន បពិត្រព្រះ អង្គដ៏ចម្រើន ពាលធម៌មានបរិបូណ៌ទាំងអស់ ពិតមែន ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះថាដូចម្ដេច រូបជាធម្មជាតទៀង ឬ មិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ របស់ណាដែលមិនទៀង

របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសភាពប្រែប្រួលជាធម្មតា គួរនឹងពិចារណាឃើញនូវរបស់នោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនគួរនឹងយល់ឃើញដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច វេទនា ។បេ។ សញ្ញា ... សង្ខារទាំងឡាយ វិញ្ញាណ ជារបស់ទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសភាពប្រែប្រួលជាធម្មតា គួរនឹងពិចារណាឃើញនូវរបស់នោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនគួរនឹងយល់ឃើញ ដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបណានីមួយ ជាអតីត ជាអនាគត ជាបច្ចុប្បន្ន ខាងក្នុង ឬខាងក្រៅ គ្រោតគ្រាតឬល្អិត ថោកទាប ឬឧត្តម រូបណាដែលមានក្នុងទីឆ្ងាយ ឬក្នុងទីជិត អ្នកទាំងឡាយ គប្បីឃើញរូបទាំងអស់នោះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ វេទនាណានីមួយ ។បេ។ សញ្ញាណានីមួយ ... សង្ខារទាំងឡាយណានីមួយ ... វិញ្ញាណណានីមួយ ជាអតីត ជាអនាគត ជាបច្ចុប្បន្ន ខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ថោកទាប ឬឧត្តម វិញ្ញាណ

ណាដែលមានក្នុងទីឆ្ងាយ ឬក្នុងទីជិត អ្នកទាំងឡាយ គប្បីឃើញនូវវិញ្ញាណទាំងអស់នោះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលបើឃើញយ៉ាងនេះហើយ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយហើយ ក៏លែងត្រេកអរ កាលបើលែងត្រេកអរហើយ ចិត្តក៏ផុតស្រឡះ កាលបើចិត្តផុតស្រឡះហើយ សេចក្តីដឹងថា អាត្មាអញផុតស្រឡះហើយដូច្នេះ ក៏កើតមានឡើង ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អាត្មាអញបានធ្វើហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា អ្នកមានសន្ទះទ្វារកន់លើកឡើងហើយផង មានគូរម្ហូបរម្ហាយហើយផង មានសសរគោលជកឡើងហើយផង មិនមានសន្ទះទ្វារផង ជាអរិយៈមានទង់ជ័យដាក់ចុះហើយមានភារៈដាក់ចុះហើយ ប្រាសចាកមានះផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសន្ទះទ្វារកន់លើកឡើង តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអវិជ្ជា ទាំងបានកាត់ផ្តាច់ឫសគល់ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព ឲ្យលែងកើតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសន្ទះទ្វារកន់ លើក

ឡើងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានគូរម្មបរម្ម៉ាយនោះ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវជាតិសង្សារ ជាសភាវៈឲ្យនូវភពថ្មី ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព ឲ្យលែងកើតតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានគូរម្មបរម្ម៉ាយហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសសរគោលដកឡើងហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវតណ្ហា ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព ឲ្យលែងកើតតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសសរគោលដកឡើងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានសន្ទះទ្វារ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវសញ្ញោជនៈជាចំណែកខាងក្រោម ៥ ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុតក លែងមានបែបភាព ឲ្យលែងកើតតទៅខាងមុខទៀត ជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានសន្ទះទ្វារ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអរិយៈមានទង់ជ័យដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកមានះ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអស្មិមានះ ទាំងបានកាត់ផ្តាច់ឫសគល់ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ឲ្យលែងមានបែបភាព ឲ្យ

លែងកើតតទៅខាងមុខទៀតជាធម្មតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអរិយៈមាន ទង់ជ័យដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកមានះ ដោយប្រការ ដូច្នេះឯង ។

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ ពួកទេវតា ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម និងបជាបតិទេវរាជ នាំគ្នាតាមស្វែងរកភិក្ខុ ដែលមានចិត្តរួចស្រឡះយ៉ាងនេះ ក៏មិនបានប្រទះថា វិញ្ញាណរបស់សត្វអាស្រ័យហើយនូវអារម្មណ៍នេះ សេចក្តី នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសត្វថាមិនមានក្នុង បច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ តែមានសមណព្រាហ្មណ៍មួយពួក បាន ពោលបង្កាច់តថាគតដែលមានវាទៈយ៉ាងនេះ ដែលបានពោលយ៉ាងនេះ ដោយ ពាក្យមិនទៀង ដោយពាក្យទទេ ដោយពាក្យកុហក ដោយពាក្យមិនពិត ដូច្នេះថា ព្រះសមណគោតមជាអ្នកបំផ្លាញសត្វ តែងបញ្ញត្តនូវសេចក្តីដាច់ សូន្យ សេចក្តីវិនាស សេចក្តីមិនកើតទៀត របស់សត្វដែលមាននៅ ។ ម្នាល ភិក្ខុទាំងឡាយ តថាគតមិនបានពោលដោយប្រការណាផង ដោយប្រការ ណាផង សមណព្រាហ្មណ៍ដ៏ចម្រើននោះ ពោលបង្កាច់តថាគតដោយប្រការ ដូច្នោះៗ ដោយពាក្យមិនទៀង ដោយពាក្យទទេ ដោយពាក្យកុហក ដោយ ពាក្យមិនពិត ដូច្នេះថា ព្រះសមណគោតម ជាអ្នកបំផ្លាញសត្វ តែងបញ្ញត្ត នូវសេចក្តីដាច់សូន្យ សេចក្តីវិនាស សេចក្តីមិនកើតទៀត របស់សត្វដែល មាននៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវក្តី តថាគត តែងបញ្ញត្តនូវទុក្ខផង នូវសេចក្តីរលត់នៃទុក្ខផង ។ ម្នាលភិក្ខុទាំងឡាយ បើ

ពួកជនដទៃ ជេរ គំរាម ប្រទូស្ត បៀតបៀន ធ្វើបាបតថាគតក្នុងការប្រកាសសច្ចៈទាំង ៤ នោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនមានសេចក្តីក្រោធ មិនមានសេចក្តីមិនត្រេកអរ គឺទោមនស្ស មិនមានសេចក្តីមិនរីករាយនៃចិត្ត ក្នុងហេតុមានជេរជាដើមនោះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃ ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតក្នុងការប្រកាសសច្ចៈនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនមានសេចក្តីត្រេកអរ មិនមានសេចក្តីសោមនស្ស មិនមានសេចក្តីបានចិត្តក្នុងសក្ការៈជាដើមនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃ ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតក្នុងការប្រកាសសច្ចៈនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្តីត្រិះរិះក្នុងសក្ការៈជាដើមនោះយ៉ាងនេះថា ខន្ធបញ្ចកៈណា ដែលតថាគតបានកំណត់ដឹងក្នុងកាលមុនរួចហើយ សក្ការៈមានសភាពយ៉ាងនេះ គឺពួកជនដទៃធ្វើដល់តថាគត ក៏ចំពោះខន្ធបញ្ចកៈនោះ ។

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បើពួកជនដទៃជេរ គំរាម ប្រទូស្ត បៀតបៀន ធ្វើបាបអ្នកទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើសេចក្តីក្រោធ មិនត្រូវធ្វើសេចក្តីមិនត្រេកអរ គឺទោមនស្ស មិនត្រូវធ្វើសេចក្តីមិនរីករាយនៃចិត្ត ក្នុងពាក្យជេរជាដើមនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បើពួកជនដទៃធ្វើសក្ការៈ គោរព រាប់អាន បូជាអ្នកទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើសេចក្តីត្រេកអរ មិនត្រូវធ្វើសេចក្តីសោមនស្ស មិនត្រូវធ្វើសេចក្តីបានចិត្ត ក្នុងសក្ការៈជាដើមនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ បើពួកជនដទៃធ្វើសក្ការៈ គោរព រាប់អាន បូជាអ្នកទាំងឡាយ

អ្នកទាំងឡាយ ត្រូវត្រិះរិះក្នុងសក្ការៈជាដើមនោះយ៉ាងនេះថា ខន្ធបញ្ចកៈណា ដែលអាត្មាអញបានកំណត់ដឹងរួចហើយក្នុងកាលមុន សក្ការៈមានសភាពបែបនេះ គឺពួកជនដទៃធ្វើដល់យើងទាំងឡាយ ក៏ចំពោះខន្ធបញ្ចកៈនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ វត្ថុណា ដែលមិនមែនរបស់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយលះបង់វត្ថុនោះចេញ វត្ថុដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ទោះអ្វីៗ មិនមែនរបស់អ្នកទាំងឡាយដែរ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់រូបនោះចេញ រូបដែលអ្នកទាំងឡាយលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ វេទនាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នូវវេទនានោះចេញ វេទនាដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវសញ្ញានោះចេញ សញ្ញាដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវសង្ខារទាំងឡាយនោះចេញ សង្ខារទាំងឡាយដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។

ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នូវវិញ្ញាណនោះចេញ វិញ្ញាណដែលអ្នកទាំងឡាយបានលះបង់ហើយ នោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះថាដូចម្តេច ស្មៅ កំណាត់ឈើ មែកឈើ និងស្លឹកឈើណា ដែលមានក្នុងវត្តជេតពននេះ បើ អ្នកផងនាំយកទៅក្តី ដុតចោលក្តី ធ្វើឲ្យសមគួរតាមបច្ច័យក្តី នូវវត្ថុមានស្មៅ ជាដើមនោះ តើអ្នកទាំងឡាយគួរមានសេចក្តីត្រិះរិះយ៉ាងនេះថា អ្នកផងនាំយក ទៅក្តី ដុតចោលក្តី ធ្វើឲ្យសមគួរតាមបច្ច័យក្តី នូវយើងទាំងឡាយ ដូច្នេះដែរ ឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរគិតយ៉ាងនេះទេ ដំណើរនោះតើព្រោះ ហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាវត្ថុមានស្មៅជាដើមនុ៎ះ មិនមែនជា ខ្លួន ឬមិនមែនជាទ្រព្យរបស់ខ្លួននៃយើងខ្ញុំទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងហើយ វត្ថុណា ដែលមិនមែនរបស់អ្នកទាំងឡាយទេ ចូរអ្នកទាំង-ឡាយលះបង់នូវវត្ថុនោះចេញ វត្ថុដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាល ភិក្ខុទាំងឡាយ ទោះអ្វីៗ ក៏មិនមែនរបស់អ្នកទាំងឡាយដែរ ម្នាលភិក្ខុទាំង-ឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ ចូរអ្នកទាំងឡាយលះបង់នូវរូបនោះ ចេញ រូបដែលអ្នកទាំងឡាយលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ វេទនា ។បេ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ។បេ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ

។បេ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមិនមែនរបស់អ្នកទាំងឡាយទេ ចូរអ្នកទាំងឡាយលះបង់វិញ្ញាណនោះចេញ វិញ្ញាណដែលអ្នកទាំងឡាយបានលះបង់ហើយនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរអង្វែង ។

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្សាយហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្សាយហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណាជាព្រះអរហន្តខីណាស្រេព មានព្រហ្មចារ្យនៅចប់ហើយ មានកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ វដ្តៈរបស់ភិក្ខុទាំងនោះ មិនមាននាមបញ្ញត្តិ គឺថា វិនាសសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្សាយហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយ យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្សាយហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា បានលះបង់នូវសំយោជនៈជាចំណែកខាងក្រោម ៥ យ៉ាង ភិក្ខុទាំងអស់នោះជាឱបបាតិកទេវតា នឹងបរិនិព្វានក្នុងលោកនោះ មានសភាវៈមិនត្រឡប់ចាកលោកនោះឡើយ ។ ម្នាល

ភិក្ខុទាំងឡាយ ធម៌ដែលផ្សារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំង-ឡាយ កាលបើធម៌ដែលផ្សារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ភិក្ខុទាំង-ឡាយណា បានលះបង់នូវសំយោជនៈទាំង ៣ យ៉ាង ស្រឡះហើយ តែនៅមានរាគៈ ទោសៈ មោហៈ ដែលស្រាលស្តើង ភិក្ខុទាំងអស់នោះ ជាសកទាគាមិបុគ្គល នឹងត្រឡប់មកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្សារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្សារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ភិក្ខុទាំង-ឡាយណាបានលះបង់នូវសំយោជនៈ ៣ យ៉ាងស្រឡះហើយ ភិក្ខុទាំងអស់នោះ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាអ្នកទៀងតែនឹងបានត្រាស់ដឹងក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលផ្សារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្សារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា ជាធម្មានុសារីបុគ្គល នឹងជាសទ្ធានុសារីបុគ្គល ភិក្ខុទាំងអស់នោះនឹងបានត្រាស់ដឹងក្នុងខាងមុខ ។ ម្នាល

ភិក្ខុទាំងឡាយ ធម៌ដែលផ្ចារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌ដែលផ្ចារហើយ របើកហើយ ភ្លឺច្បាស់ហើយ ដូចជាសំពត់ចាស់ដែលដាច់ដាច តថាគតបានសម្តែងល្អហើយយ៉ាងនេះ ភិក្ខុទាំងឡាយណា គ្រាន់តែមានសទ្ធា គ្រាន់តែមានសេចក្តីស្រឡាញ់ចំពោះតថាគត ភិក្ខុទាំងពួងនោះ ទៅខាងមុខ នឹងបានស្ថានសួគ៌ ។ ព្រះមានព្រះភាគ ទ្រង់បានសម្តែងនូវសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរ រីករាយហើយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

## អលគទ្ទូបមសូត្រទី ២ ចប់

# អដ្ឋកថា

# អលគទ្ទូបមសូត្រ

# អន្តរាយិកធម៌ ៥

[ ១២ ] *អលគទ្ទូបមសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអលគទ្ទូបមសូត្រនោះ ដូចតទៅនេះ*

*ជនទាំងឡាយណា បៀតបៀនត្មាត ហេតុនោះ ជនទាំងនោះ ឈ្មោះថាជាអ្នកបៀតបៀនត្មាត បុព្វបុរសបៀតបៀនត្មាតរបស់បុគ្គលនោះមាន ហេតុនោះបុគ្គលនោះ ឈ្មោះថា មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ។ កូននៃត្រកូលអ្នកធ្លាប់សម្លាប់ត្មាតនោះ អធិប្បាយថា ជាអ្នកខ្វល់ខ្វាយនៃត្រកូលអ្នកសម្លាប់ត្មាត ។ ឈ្មោះថា អន្តរាយិកធម៌ ព្រោះធ្វើអន្តរាយចំពោះសួគ៌ និងនិព្វាន ។ អន្តរាយិកធម៌ទាំងនោះ មាន ៥ យ៉ាង គឺកម្ម កិលេស វិបាក អរិយុបវាទ និងអនាវីតិក្កម ។ ក្នុងអន្តរាយិកធម៌ទាំងនោះ អនន្តរិយកម្ម ៥ ឈ្មោះថា កម្មន្តរាយិកធម៌ ។ ភិក្ខុនីទូសកកម្មក៏ដូចគ្នា ។ តែភិក្ខុនីទូសកកម្មនោះ ធ្វើអន្តរាយចំពោះព្រះនិព្វានតែម្យ៉ាង មិនធ្វើអន្តរាយចំពោះស្ថានសួគ៌ឡើយ ។ ធម៌ គឺនិយតមិច្ឆាទិដ្ឋិ ឈ្មោះថា កិលេសន្តរាយិកធម៌ ។ បដិសន្ធិធម៌របស់ខ្ទើយ សត្វតិរច្ឆាន និងឧភតោព្យញ្ជនកៈ ឈ្មោះថា វិបាកន្តរាយិកធម៌ ។ ធម៌ គឺការចូលទៅតិះដៀលព្រះអរិយៈ ឈ្មោះថា ឧបវាទន្តរាយិកធម៌ ។ តែឧប-វាទន្តរាយិកធម៌ទាំងនោះ រមែងធ្វើអន្តរាយអស់កាលដែលមិនទាន់ឲ្យព្រះអរិយៈទាំងឡាយអត់ទោស ខាងមុខអំពីនោះ ឲ្យព្រះអរិយៈអត់ទោសហើយ មិនជា*

អន្តរាយឡើយ ។ អាបត្តិ ៧ កង ដែលភិក្ខុក្លែងកន្លងល្មើសហើយ ឈ្មោះថា អនាវីតិក្កមន្តរាយិកធម៌ ។ សូម្បីអនាវីតិក្កមន្តរាយិកធម៌ទាំងនោះ រមែងធ្វើអន្តរាយដរាបណា ភិក្ខុត្រូវអាបត្តិហើយ នៅតែប្តេជ្ញាខ្លួនថា ជាភិក្ខុក្តី មិននៅបរិវាសកម្មក្តី មិនសម្តែងក្តី ខាងមុខអំពីនោះ ( គឺបានសម្តែងក្តី ) មិនជាអន្តរាយឡើយ ។

ក្នុងរឿងអន្តរាយិកធម៌នេះ អរិដ្ឋភិក្ខុជាពហូសូត ជាព្រះធម្មកថិក តែងដឹងអន្តរាយិកធម៌ដ៏សេស តែព្រោះជាបុគ្គលមិនឈ្លាសក្នុងព្រះវិន័យ ទើបមិនដឹងអន្តរាយិកធម៌ គឺការកន្លងល្មើសព្រះបញ្ញត្តិ ព្រោះដូច្នោះ ទើបអរិដ្ឋភិក្ខុកាលនៅក្នុងទីស្ងាត់គិតយ៉ាងនេះថា គ្រហស្ថទាំងនេះបរិភោគកាមគុណ ៥ ជាព្រះសោតាបន្នក៏មាន ព្រះសកទាគាមីក៏មាន ព្រះអនាគាមីក៏មាន ឯពួកភិក្ខុពិចារណាឃើញរូបដែលគួរពេញចិត្ត ដែលគប្បីដឹងដោយចក្ខុ ពាល់ត្រូវផោដ្ឋព្វារម្មណ៍ ដែលគប្បីដឹងដោយកាយ រមែងប្រើប្រាស់នូវគ្រឿងកម្រាលនិងគ្រឿងស្លៀកដណ្តប់ដ៏ទន់ សេចក្តីទាំងនោះ គួរ ព្រោះហេតុអ្វី រូប សំឡេង ក្លិន រស ផោដ្ឋព្វៈរបស់ស្រីប៉ុណ្ណោះមិនគួរ ឯរូបទាំងនេះជាដើម ទើបគួរ អរិដ្ឋភិក្ខុប្រៀបធៀបរសនិងរសយ៉ាងនេះហើយ រួមការបរិភោគដោយអំណាចរាគៈ ដែលមានឆន្ទៈ និងការបរិភោគដោយអំណាចរាគៈ ដែលមិនមានឆន្ទៈហើយ កើតទិដ្ឋិលាមក ដូចប្រៀបធៀបដោយសំពត់ដែលល្អិតក្រៃលែង នឹងធ្មៃដែលគ្រោតគ្រាត បីដូចប្រៀបធៀបក្អំព្រះសិនេរុនឹងគ្រាប់ស្ពៃ ជំទាស់នឹងព្រះសព្វញ្ញុតញ្ញាណថា ហេតុអ្វី ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបឋមបារាជិក

ដោយព្រះឧស្សាហៈយ៉ាងធំ បីដូចរាំងមហាសមុទ្រ ទោសក្នុងព្រះបញ្ញត្តិនោះមិនមាន ជំទាស់នឹងព្រះវេសារជ្ជញ្ញាណ ដាក់ជង្គត់ និងបន្ទាជាដើមចូលក្នុងអរិយមគ្គ ប្រហារអាណាចក្ររបស់ព្រះជិនៈថា ទោសក្នុងមេថុនធម្មមិនមាន ។ ដោយហេតុនោះ ទើបអរិដ្ឋភិក្ខុពោលថា **តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ** អាត្មាអញដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ យ៉ាងនោះជាដើម ។ បទថា **ឯវំ ព្យាខោ** ស្មើគ្នានឹង **ឯវំ វិយខោ** ។ ក្នុងបទថា **សមនុយុញ្ជន្តិ** ជាដើម ភិក្ខុទាំងឡាយសួរថា លោកមានលទ្ធិអ្វី ទើបពោលលទ្ធិ ឈ្មោះថា សាកសួរ ។ លើកទិដ្ឋិឡើង ឈ្មោះថា ប្រកាន់នូវទិដ្ឋិ ។ សាកសួរហេតុថា ព្រោះហេតុអ្វី ទើបលោកពោលយ៉ាងនេះ ឈ្មោះថា **សមនុភាសន** ។ ក្នុងបទថា **អដ្ឋិកង្កលូបមា** ជាដើម ឧបមាដោយរាងឆ្អឹង ព្រោះអត្ថថា មានអស្សាទ គឺសេចក្ដីត្រេកអរតិច ឧបមាដោយដុំសាច់ ព្រោះអត្ថថា ជារបស់ដែលទូទៅដល់មនុស្សដ៏ច្រើន ឧបមាដោយគប់ភ្លើង ព្រោះអត្ថថា តាមដុត ឧបមាដោយរណ្ដៅរងើកភ្លើង ព្រោះអត្ថថា ធ្វើឲ្យក្ដៅខ្លាំង ឧបមាដោយការយល់សប្ដិ ព្រោះអត្ថថា ប្រាកដតិចតួច ឧបមាដោយរបស់ដែលខ្ចីគេមក ព្រោះអត្ថថា ប្រព្រឹត្តទៅមួយជួរខណៈ ឧបមាដោយផ្លែឈើពុល ព្រោះអត្ថថា ទម្លាយទូទៅសព្វសព៌ាង្គ ឧបមាដោយមុខកាំបិត ព្រោះអត្ថថា កាត់ផ្ដាច់ ឧបមាដោយមុខលំពែង និងចម្រូង ព្រោះអត្ថថា មុតទម្លុះ ឧបមាដោយក្បាលពស់ ព្រោះអត្ថថា គួរខ្លាច និងមានភ័យចំពោះមុខ ។ បទថា **ថាមសា** បានដល់ ដោយកម្លាំងនៃទិដ្ឋិ ។ បទថា

**បរាមាសា** បានដល់ ស្ទាបអង្អែលដោយទិដ្ឋិ ។ បទថា **អភិនិវិស្ស វោហរតិ** បានដល់ ក៏នៅតែពោល ឬសម្ដែង ។

[ ១៣ ] បទថា **យតោ ខោ តេ ភិក្ខូ** បានដល់ កាលណាភិក្ខុទាំងនោះ ។ អរិដ្ឋភិក្ខុនេះ បុគ្គលណាពោលថា មិនមានដូច្នេះ តាមអធ្យាស្រ័យរបស់ខ្លួន ក៏រមែងទទួលពាក្យនេះថា **ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា** ដោយអានុភាពរបស់ព្រះមានព្រះភាគ បានឮថា ឈ្មោះថា អ្នកអាចពោលពាក្យ ២ ម៉ាត់ ចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគមិនមាន ។

[ ១៤ ] បទថា **កស្ស ខោ ឆាម ត្វំ មោឃបុរិស** សេចក្ដីថា ម្នាលមោឃបុរស អ្នកដឹងទូទៅដល់ធម៌ដែលតថាគតសម្ដែងយ៉ាងនេះ ពីអ្នកណា ក្សត្រ ឬព្រាហ្មណ៍ វេស្សៈ ឬសូទ្រៈ គ្រហស្ថ ឬបព្វជិត ទេវតា ឬមនុស្ស ។

បទថា **អថ ខោ ភគវា ភិក្ខូ អាមន្តេសិ** នេះ ជាអនុសន្ធិមួយផ្នែកដោយចំពោះ ។ បានឮថា អរិដ្ឋភិក្ខុគិតថា ព្រះមានព្រះភាគត្រាស់ហៅអញថា មោឃបុរស តែលោកមិនមានធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផលដោយហេតុត្រឹមតែត្រាស់ថា មោឃបុរសក៏មិនមែន ពិតហើយ ព្រះមានព្រះភាគត្រាស់ហៅឧបសេនវង្គន្តបុត្រ ដោយពាក្យថា មោឃបុរស ថា ម្នាលមោឃបុរស អ្នកជាអ្នកវិលមក ដើម្បីសេចក្ដីប្រាថ្នាច្រើនរហ័សពេក ខាងក្រោយមក ព្រះថេរៈព្យាយាមធ្វើឲ្យច្បាស់នូវអភិញ្ញា ៦ ដោយគិតថា សូម្បីអញក៏នឹងផ្គងព្យាយាមបែបនោះ ធ្វើមគ្គផលឲ្យកើត ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងការដែលអរិដ្ឋភិក្ខុជាអ្នកមិនលូតលាស់ ដូចស្ទឹកឈើទុំ

ដែលជ្រុះចាកទង ទើបផ្តើមសម្តែងព្រះធម្មទេសនានេះ ។ បទថា **ឩស្មិ-ករតោបិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អរិដ្ឋភិក្ខុ មានលទ្ធិយ៉ាងនេះ ជំទាស់នឹងសព្វញ្ញុតញ្ញាណ បដិសេធវេសា-រជ្ជញ្ញាណ ប្រហារអាណាចក្ររបស់ព្រះតថាគត សូម្បីអ្នកក៏អប់រំញាណក្នុងធម្មវិន័យនេះបានខ្លះ អ្នកអាស្រ័យការអប់រំញាណ មានប្រមាណតិច កំពុងព្យាយាម គប្បីធ្វើមគ្គផលឲ្យកើតឡើងបានក៏មាន ដូចគំនរភ្លើងធំដែលគប្បីមាន ព្រោះអាស្រ័យភ្លើង ដែលមានប្រមាណប៉ុនអំពិលអំពែកក្នុងគំនរភ្លើងធំដែលរលត់ទៅហើយ ដូច្នោះ ។ បទថា **នោ ហេតំ ភន្តេ** សេចក្តីថា ភិក្ខុទាំងឡាយ ពោលជំទាស់ការដែលអរិដ្ឋភិក្ខុអប់រំញាណ ដើម្បីប្រយោជន៍ដល់មគ្គផល ដែលមានបច្ច័យស្មើគ្នាថា បពិត្រព្រះអង្គដ៏ចម្រើន អរិដ្ឋភិក្ខុដែលមានលទ្ធិយ៉ាងនេះ នឹងអប់រំញាណដូច្នោះបានអំពីណា ។ បទថា **មង្កុភូតោ** បានដល់ ជាអ្នកគ្មានអំណាច ។ បទថា **បត្តក្ខន្ធោ** បានដល់ មានកសំយុងចុះ ។ បទថា **អប្បដិភាណោ** បានដល់ មិនឃើញវត្ថុណាមួយជាក់ច្បាស់ គឺអស់បដិភាណ ។ អរិដ្ឋភិក្ខុពិចារណាភាពដែលខ្លួនជាអភព្វបុគ្គលថា បានឮថា អញបានទូវពាក្យប្រៀនប្រដៅដែលនាំចេញចាកទុក្ខយ៉ាងនេះហើយ នៅតែមិនដុះដាល អញមានបច្ច័យត្រូវដកចេញហើយ ដូច្នេះ ក៏អង្គុយយកចុងម្រាមជើងឆ្កឹះដី ។

[ ១៥ ] បទថា **បញ្ញាយិស្សសិ ខោ** នេះ ជាអនុសន្ធិមួយផ្នែក ដោយចំពោះ ។ បានឮថា អរិដ្ឋភិក្ខុគិតថា ព្រះមានព្រះភាគត្រាស់ថា អញជាបុគ្គល

ជាច់ធម៌ ដែលជាឧបនិស្ស័យនៃមគ្គ និងផល ព្រះពុទ្ធទាំងឡាយទ្រង់មិនមែនសម្តែងធម៌ចំពោះអ្នកមានឧបនិស្ស័យប៉ុណ្ណោះទេ ទ្រង់សម្តែងធម៌ដល់បុគ្គលមិនមានឧបនិស្ស័យផងដែរ អញបានសុគតោវាទអំពីសម្នាក់ព្រះសាស្តាហើយនឹងធ្វើកុសល ដែលចូលដល់សម្បត្តិរបស់ខ្លួន ។ គ្រានោះ ព្រះមានព្រះភាគកាលនឹងរម្ងាប់ព្រះឱវាទ ទើបត្រាស់ថា **បញ្ញាយិស្សសិ** ជាដើម ។ ពាក្យនោះ មានសេចក្តីថា ម្នាលមោឃបុរស អ្នកនោះឯង នឹងប្រាកដក្នុងនរកជាដើម ដោយទិដ្ឋិដ៏អាក្រក់នេះ ដែលឈ្មោះថា សុគតោវាទរបស់អ្នក រមែងមិនមានអំពីសម្នាក់របស់តថាគត អ្នកមិនមានប្រយោជន៍សម្រាប់តថាគត តថាគតនឹងសាកសួរភិក្ខុទាំងឡាយក្នុងទីនេះ ។

បទថា **អថ ខោ ភគវា** នេះ ជាអនុសន្ធិមួយផ្នែក ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ជម្រះបរិស័ទក្នុងទីនេះ ទើបទ្រង់បណ្តេញអរិដ្ឋភិក្ខុចេញចាកក្រុម បើបណ្តាបរិស័ទទាំងឡាយ ភិក្ខុរបខ្លះ គប្បីគិតយ៉ាងនេះថា អរិដ្ឋនេះឬ នឹងអាចពោលពាក្យ ដែលព្រះមានព្រះភាគមិនបានត្រាស់ កាលព្រះមានព្រះភាគទ្រង់ផ្តើមកថា ក៏ប្រញាប់ត្រាស់ក្នុងចំណោមសង្ឃ ឬពាក្យដែលត្រាស់យ៉ាងនេះ អរិដ្ឋប៉ុណ្ណោះមិនស្តាប់ តែនឹងជាព្រះតម្រាស់ដែលភិក្ខុដទៃស្តាប់ហើយ ដូច្នោះ ភិក្ខុរបខ្លះនោះ គប្បីគិតថា ព្រះសាស្តាទ្រង់បណ្តេញអរិដ្ឋភិក្ខុ យ៉ាងណា ទ្រង់គប្បីបណ្តេញអញ ដូច្នោះ សូម្បីស្តាប់ហើយ ក៏នៅស្ងៀម នឹងមិនធ្វើការទាំងអស់នោះ ពាក្យដែលតថាគតមិនពោល ពាក្យដែលអ្នកដទៃស្តាប់ក៏មិនមាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ជម្រះ

លទ្ធិក្នុងបរិស័ទ ដោយព្រះតម្រាស់ថា **តុម្ហេបិ មេ ភិក្ខវេ** ជាដើម អរិដ្ឋភិក្ខុ ឈ្មោះថា ព្រះមានព្រះភាគទ្រង់បណ្តេញចាកគណៈ ដោយការជម្រះលទ្ធិក្នុង បរិស័ទនោះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសលទ្ធិរបស់អរិដ្ឋភិក្ខុ ទើប ត្រាស់ពាក្យថា **សោ វត ភិក្ខវេ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុង បទ ថា **អញ្ញត្រេវ កាមេហិ** ជាដើម ក្នុងបាលីនោះ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មានលទ្ធិយ៉ាងនេះថា ធម៌ទាំងនោះ មិនអាចធ្វើអន្តរាយដល់អ្នក សេពបានពិត ភិក្ខុនោះ នឹងសេពវត្ថុកាមទាំងឡាយ គឺនឹងប្រព្រឹត្តមេថុន- សមាចារ វៀរកិលេសកាម និងសញ្ញាវិតក្កដែលប្រកបដោយកិលេសកាម លះធម៌ទាំងនោះ គឺវៀរចាកធម៌ទាំងនោះ ។ បទថា **នេតំ ឋានំ វិជ្ជតិ** សេចក្តីថា ឈ្មោះថា ដោយហេតុនេះមិនមាន គឺហេតុនេះមិនមែនជាឋានៈ មិនមែនជាឱកាស ។

ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់ប្រកាសលទ្ធិរបស់អរិដ្ឋភិក្ខុថា អរិដ្ឋនេះ ប្រៀបដូចជាងជ្រលក់ កាន់យកសំពត់ក្រអូបខ្លះ ស្អុយខ្លះ ចាស់ខ្លះ ថ្មីខ្លះ ស្អាតខ្លះ មិនស្អាតខ្លះ មកខ្ចប់រួមជាបង្វិចតែមួយ យ៉ាងណា អរិដ្ឋក៏ធ្វើ ការបរិភោគចីវរប្រណីតជាដើម ដែលមិនមានឆន្ទរាគៈសម្រាប់ភិក្ខុ ធ្វើការ បរិភោគដែលមានឆន្ទរាគៈដែលធ្វើអន្តរាយ សម្រាប់គ្រហស្ថដែលមានសីល មិនប្រចាំ និងធ្វើការបរិភោគ ដែលមានឆន្ទរាគៈ ដែលធ្វើការការពារ សម្រាប់ ភិក្ខុដែលមានសីលប្រចាំ រួមជាមួយគ្នាទាំងអស់ ឥឡូវនេះ កាលទ្រង់សម្តែង

ទោសនៃបរិយត្តិរៀនមកមិនល្អ ទើបត្រាស់ថា **ឥធ ភិក្ខវេ ឯកច្ចេ** ជាដើម ។

[ ១៦ ] បណ្តាបទទាំងនោះ បទថា **បរិយាបុណន្តិ** ប្រែថា រៀនសូត្រ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សុត្តំ** ជាដើមដូច្នេះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និងបរិវារ មង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដ្ដកសូត្រ ក្នុងសុត្តនិបាត និងតថាគតវចនៈដទៃដែលមានឈ្មោះថា សូត្រ គប្បីជ្រាបថា សូត្រ ។ សូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា គេយ្យៈ ។ ដោយចំពោះយ៉ាងក្រៃលែង សគាថវគ្គទាំងអស់ ក្នុងសំយុត្តនិកាយ គប្បីជ្រាបថា គេយ្យៈ ។ អភិធម្មបិដកទាំងអស់ សូត្រដែលមិនមានគាថា និងពុទ្ធវចនៈដទៃ ដែលសង្គ្រោះដោយអង្គ ៨ គប្បីជ្រាបថា វេយ្យាករណ៍ ។ ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ដែលមិនឈ្មោះថា សូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា ជាគាថា ។ ព្រះសូត្រ ៨២ ដែលទាក់ទងដោយគាថា ដែលសម្រេចមកអំពីសោមនស្សញ្ញាណ គប្បីជ្រាបថា ឧទាន ។ ព្រះសូត្រ ១១០ ដែលប្រព្រឹត្តទៅជាដើមថា **វុត្តមិទំ ភគវតា** គប្បីជ្រាបថា ឥតិវុត្តកៈ ។ ជាតក ៥៥០ មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា ជាតក ។ ព្រះសូត្រដែលទាក់ទងដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ** គប្បីជ្រាបថា អព្ភុតធម៌ ។ ព្រះសូត្រដែលត្រាស់សួរហើយ បានទូវការដឹង បានទូវការត្រេកអរទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ មហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថា វេទល្ល។

បទថា **អត្ថំ ន ឧបបរិក្ខន្តិ** បានដល់ មិនឃើញ និងកំណត់មិនបានទូវអត្ថនៃសូត្រ នូវអត្ថនៃហេតុ ។ បទថា **អនុបបរិក្ខតំ** បានដល់ កំណត់មិនបាន ។ បទថា **ន និជ្ឈានំ ខមន្តិ** បានដល់ មិនប្រាកដ គឺមិនមកប្រាកដ អធិប្បាយថា បុគ្គលណាម្នាក់ មិនអាចដឹងយ៉ាងនេះថា សីល សមាធិ បញ្ញា មគ្គ ផល វដ្តៈ ឬវិវដ្តៈ ទ្រង់ត្រាស់ហើយក្នុងទីនេះ ។ បទថា **តេ ឧបា-រម្ភានិសំសា ចេវ** សេចក្តីថា កុលបុត្រទាំងនោះ ជាអ្នកមិនលើកទោសក្នុងវាទៈរបស់អ្នកដទៃ ជាអានិសង្សនៃការរៀនសូត្រ ។ បទថា **ឥតិវាទប្ប-មោក្ខានិសំសា ច** បានដល់ មានការដោះនូវវាទៈយ៉ាងនេះ ជាអានិសង្សនៃបរិយត្តិ អធិប្បាយថា មិនរៀនដោយហេតុនេះថា កាលអ្នកដទៃលើកទោសវាទៈរបស់ខ្លួន អញនឹងដោះទោសនោះយ៉ាងនេះ ។ បទថា **តញ្ចស្ស អត្ថំ នានុភោន្តិ** សេចក្តីថា កុលបុត្រទាំងឡាយ រៀនធម៌ដើម្បីប្រយោជន៍ដល់មគ្គ ឬផលឯណា រៀនមិនល្អ រមែងមិនបានទទួលប្រយោជន៍នោះរបស់ធម៌នោះ ម្យ៉ាងទៀត កាលមិនអាចលើកទោសក្នុងវាទៈនៃអ្នកដទៃ និងដោះវាទៈរបស់ខ្លួន រមែងមិនបានទទួលប្រយោជន៍នោះដូចគ្នា ។ បទថា **អលគទ្ទត្ថិកោ** បានដល់ បុគ្គលត្រូវការអាសិរពិស ។ បទថា **គទ្ទោ** ជាឈ្មោះនៃពិស ។ ពិសនៃពស់នោះ មានល្មម គឺបរិបូណ៌ ហេតុនោះ អាសិរពិសនោះ ឈ្មោះថា **អលគទ្ទ** មានពិសល្មមប្រមាណនឹងខ្លួន ។ បទថា **ភោគេ** បានដល់ ខ្លួន ។

[ ១៧ ] បទថា **ឥធ បន ភិក្ខវេ ឯកច្ចេ កុលបុត្តា ធម្មំ បរិយាបុណំ** បានដល់ រៀនដោយអំណាចនិស្សរណបរិយត្តិ ។

ពិតហើយ បរិយត្តិមាន ៣ គឺអលគទ្ទូបរិយត្តិ ១ និស្សរណបរិយត្តិ ១ ភណ្ឌាគារិកបរិយត្តិ ១ ។ បណ្ដាបរិយត្តិទាំង ៣ នោះ ភិក្ខុណារៀនពុទ្ធវចនៈ ព្រោះប្រារព្ធលាភសក្ការៈថា អញនឹងបានចីវរជាដើម ឬមនុស្សទាំងឡាយនឹងស្គាល់អញក្នុងកណ្ដាលបរិស័ទ ៤ យ៉ាងនេះ បរិយត្តិរបស់ភិក្ខុនោះ ឈ្មោះថា អលគទ្ទូបរិយត្តិ ។ ពិតហើយ ការមិនរៀនពុទ្ធវចនៈ ហើយដេកលក់ល្អជាងរៀនយ៉ាងនេះ ។ ឯភិក្ខុណារៀនដោយគិតថា រៀនពុទ្ធវចនៈ បំពេញសីលក្នុងឋានៈដែលសីលមកដល់ ឲ្យកាន់យកគព្ភសមាធិ ក្នុងឋានៈដែលសមាធិមកដល់ ផ្ដើមតាំងវិបស្សនាក្នុងឋានៈដែលវិបស្សនាមកដល់ ធ្វើមគ្គឲ្យកើត ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងឋានៈដែលមគ្គផលមកដល់ហើយ បរិយត្តិរបស់ភិក្ខុនោះ ឈ្មោះថា និស្សរណបរិយត្តិ ។ បរិយត្តិរបស់ព្រះខីណាស្រព ឈ្មោះថា ភណ្ឌាគារិកបរិយត្តិ ។ ពិតហើយ ទុក្ខសច្ចដែលមិនទាន់កំណត់ដឹង សមុទយសច្ចដែលមិនទាន់លះបាន មគ្គសច្ចដែលមិនទាន់បានចម្រើន ឬនិរោធសច្ចដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ រមែងមិនមានដល់ព្រះខីណាស្រពនោះ ព្រោះថា ព្រះខីណាស្រពនោះ កំណត់ដឹងខន្ធហើយ លះកិលេសបានហើយ ចម្រើនមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវផលហើយ ព្រោះដូច្នោះ ទើបលោករៀនពុទ្ធវចនៈ ដើម្បីជាអ្នកទ្រទ្រង់បែបផែន រក្សាប្រពៃណី អនុរក្សវង្ស ដូច្នោះ ទើបបរិយត្តិរបស់លោក ឈ្មោះថា ភណ្ឌាគារិកបរិយត្តិ ។ សួរថា កាលពួកគន្ធធុរៈ មិនអាចនឹងនៅក្នុងទីកន្លែងមួយ ព្រោះឆាតកភ័យជាដើម បុថុជ្ជនណា កាលមិនលំបាកដោយភិក្ខាចារ រៀនដោយគិតថា សូម

ព្រះពុទ្ធវចនៈដ៏ពីរោះក្រៃលែង កុំសាបសូន្យទៅឡើយ អញនឹងតម្រង់បែប ផែន នឹងរក្សាប្រពៃណីទុក បរិយត្តិរបស់បុថុជ្ជននោះ ជាភណ្ឌាគារិកបរិយត្តិ ឬទេ ឆ្លើយថា មិនជាភណ្ឌាគារិកបរិយត្តិឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះខ្លួនមិនបានតាំងនៅក្នុងឋានៈរៀន ពិតហើយ ឈ្មោះថា បរិយត្តិ នៃបុថុជ្ជន ជាអលគទ្ទូៈខ្លះ ជានិស្សរណៈខ្លះ ។ បរិយត្តិរបស់ព្រះសេក្ខៈទាំង ៧ ជានិស្សរណៈតែម្យ៉ាង បរិយត្តិរបស់ព្រះខីណាស្រព ជាភណ្ឌាគារិក-បរិយត្តិប៉ុណ្ណោះ តែក្នុងទីនេះ លោកសំដៅយកនិស្សរណបរិយត្តិ ។

បទថា **និជ្ឈានំ ខមន្តិ** សេចក្តីថា ធម៌ទាំងឡាយ រមែងមកប្រាកដក្នុង អាណាគតដ្ឋាននៃធម៌ មានសីលជាដើមថា សីលត្រាស់ក្នុងទីនេះ សមាធិក្នុង ទីនេះ វិបស្សនាក្នុងទីនេះ មគ្គក្នុងទីនេះ ផលក្នុងទីនេះ វដ្តៈក្នុងទីនេះ វិវដ្តៈ ក្នុងទីនេះ ។ បទថា **តញ្ចស្ស អត្ថំ អនុភោន្តិ** សេចក្តីថា កុលបុត្រទាំង-ឡាយ រមែងរៀនដើម្បីមគ្គផលឯណា កុលបុត្រទាំងនោះ អាស្រ័យបរិយត្តិ ដែលរៀនល្អហើយ ធ្វើមគ្គឲ្យកើត ធ្វើផលឲ្យជាក់ច្បាស់ នឹងសោយនូវ ប្រយោជន៍របស់ធម៌នោះ ។ សូម្បីមិនអាចនឹងលើកទោសក្នុងវាទៈរបស់អ្នក ដទៃក្តី ក៏មិនអាចនឹងកាន់យកឋានៈដែលខ្លួនប្រាថ្នាហើយ ប្រាថ្នាទៀត ដោះ នូវទោសដែលគេលើកក្នុងវាទៈរបស់ខ្លួនក្តី ឈ្មោះថា សោយប្រយោជន៍ដូច គ្នា ។ បទថា **ទីឃរត្តំ ហិតាយ សុខាយ សំវត្តន្តិ** សេចក្តីថា កាល បំពេញសីលជាដើម ក្នុងឋានៈនៃសីលជាដើមមកហើយក្តី លើកទោសក្នុង វាទៈរបស់អ្នកដទៃ ដោយប្រពៃតាមធម៌ក្តី ដោះទោសចាកវាទៈរបស់ខ្លួនក្តី

*សម្រេចអរហត្ត ហើយសម្តែងធម៌ក្នុងកណ្តាលបរិស័ទ បរិភោគបច្ច័យ ៤ ដែលបុគ្គលជ្រះថ្លាក្នុងព្រះទេសនា បង្អោនចូលទៅប្រគេនក្តី ធម៌ទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ អស់កាលយូរ ។ កាលទ្រង់សម្តែងអានិសង្សក្នុងព្រះពុទ្ធវចនៈ ដែលរៀនល្អយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកបបរិស័ទទុកក្នុងព្រះពុទ្ធវចនៈនោះឯង ទើបត្រាស់ពាក្យថា* **តស្មា តិហ ភិក្ខវេ** *ជាដើមដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **តស្មា** *សេចក្តីថា ព្រោះហេតុដែលបរិយត្តិរៀនមកមិនល្អ រមែងប្រព្រឹត្តទៅដើម្បីវត្ថុមិនមែនប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលដ៏យូរ ដូចចាប់ពស់ពិសមិនល្អដូច្នោះ ចំណែកបរិយត្តិដែលរៀនមកល្អ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ ដូចចាប់ពស់ពិសទុកល្អ ដូច្នោះ ។ បទថា* **តថា នំ ធារេយ្យាថ** *សេចក្តីថា គប្បីទ្រទ្រង់បរិយត្តិនោះទុកយ៉ាងនោះឯង គឺទ្រទ្រង់ទុកដោយអត្ថនោះឯង ។ បទថា* **យេ វា បនស្ស វិយត្តា ភិក្ខូ** *សេចក្តីថា ឬគប្បីសាកសួរពួកភិក្ខុដែលជាអ្នកឈ្លាស ជាបណ្ឌិត មានព្រះសារីបុត្រ ព្រះមោគ្គល្លាន ព្រះមហាកស្សប និងព្រះមហាកច្ចានៈជាដើម តែភិក្ខុមិនគប្បីដូចជាអរិដ្ឋភិក្ខុ ដាក់កក់ ឬសំរាមចុះក្នុងសាសនារបស់តថាគត ។ បទថា* **កុល្លូបមំ** *ប្រែថា ឧបមាដូចក្បូន ។ បទថា* **និត្ថរណត្ថាយ** *បានដល់ ដើម្បីប្រយោជន៍ដល់ការឆ្លងឱឃៈ ៤ ។*

*[ ១៨ ] បទថា* **ឧទកណ្ណវំ** *សេចក្តីថា ទឹកណាជ្រៅ តែមិនធំ ឬធំតែមិនជ្រៅ ទឹកនោះមិនហៅថា* **អណ្ណវ** *ឡើយ តែទឹកណាជ្រៅផង ធំផង*

ទឹកនោះលោកហៅថា **អណ្ណវំ** ព្រោះដូច្នោះ អត្ថក្នុងបទថា **មហន្តំ ឧទកណ្ណវំ** នេះ ទើបមានអត្ថដូច្នេះថា អន្លង់ទឹកធំ ទាំងទទឹង និងជម្រៅ ។ ទីណាមានឱកាសដែលចោរឈរ អង្គុយ ដេក នៅប្រាកដ ទីនោះឈ្មោះថា **សាសង្កំ** ប្រែថា គួររង្កៀស ។ ទីណាមានពួកមនុស្សត្រូវពួកចោរមកប្លន់វាយសម្លាប់ នៅប្រាកដ ទីនោះឈ្មោះថា **សប្បដិភយំ** មានភ័យចំពោះមុខ ។ ស្ពានដែលគេចងលើអន្លង់ទឹក ឈ្មោះថា **ឧត្តរសេតុ** ប្រែថា ស្ពានឆ្លង ។ បទថា **កុល្លំ ពន្ធិត្វា** សេចក្តីថា គុម្ពឈើជាដើម ដែលគេចងជាបាច់ដើម្បីប្រយោជន៍ដល់ការឆ្លងទឹក ឈ្មោះថា ក្បូន ឯគុម្ពឈើជាដើមដែលគេចងជាបន្ទះៗ លោកហៅថា ផែរ ។ បទថា **ឧស្សាបេត្វា** ប្រែថា តាំងទុក ។ បទថា **កិច្ចការី** សេចក្តីថា ធ្វើកិច្ចដែលដល់ហើយ ធ្វើកិច្ចដែលគួរ ធ្វើកិច្ចដែលសម ។ ក្នុងបទថា **ធម្មាបិ វោ បហាតព្វា** នេះ ធម៌ទាំងឡាយ ឈ្មោះថា សមថៈ និងវិបស្សនា ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ឲ្យលះឆន្ទរាគៈ ទាំងក្នុងសមថៈ ទាំងក្នុងវិបស្សនា ទ្រង់ឲ្យលះឆន្ទរាគៈក្នុងសមថៈទុកក្នុងទីណា ។ ទ្រង់ឲ្យលះឆន្ទរាគៈក្នុងសមថៈ ក្នុងទីនេះថា ម្នាលឧទាយី តថាគតពោលនូវការលះនូវនេវសញ្ញានាសញ្ញាយតនៈដូច្នេះឯង ម្នាលឧទាយី តថាគតពោលនូវការលះសំយោជនៈណា អ្នកឃើញនូវសំយោជនៈទាំងតូចទាំងធំនោះឬទេ ។ ទ្រង់ឲ្យលះឆន្ទរាគៈក្នុងវិបស្សនា ក្នុងទីនេះថា ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនជាប់ជំពាក់ មិនរីករាយ មិនកួចកាន់ មិនរាប់អានទិដ្ឋិនេះថា បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ។ តែក្នុងទីនេះ ព្រះមានព្រះភាគ កាលទ្រង់ឲ្យ

លះឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាទាំង ២ ទើបត្រាស់ថា គប្បីលះធម៌ទាំងឡាយចេញ នឹងពោលទៅថ្វីដល់អកុសលធម៌ ។ ក្នុងសេចក្តីនោះ មានអធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលការលះឆន្ទរាគៈក្នុងធម៌ទាំងឡាយដែលស្ងប់ និងប្រណីតបែបនេះ នឹងពោលថ្វី ក្នុងអសទ្ធម្មនេះ ដែលជាធម៌របស់អ្នកស្រុក ជារបស់ថោកថយ ជាធម៌គ្រោតគ្រាត ជាធម៌រាវហូរទៅ ដែលអរិដ្ឋមោឃបុរសនេះសម្គាល់ថា មិនមានទោស ពោលឆន្ទរាគៈក្នុងកាមគុណទាំង ៥ ថាជាធម៌មិនអាចធ្វើអន្តរាយបាន ពួកអ្នកមិនគប្បីដូចអរិដ្ឋភិក្ខុដែលជាក់កក់ ឬសំរាមចូលក្នុងសាសនារបស់តថាគត ។

[ ១៩ ] ព្រះមានព្រះភាគ ទ្រង់បណ្តេញអរិដ្ឋភិក្ខុតែមួយ ដោយឱវាទនេះ ដោយប្រការដូច្នេះ ឥឡូវនេះ កាលទ្រង់សម្តែងថា បុគ្គលណាប្រកាន់ថា អញ របស់អញ ដោយអំណាចការប្រកាន់ ៣ យ៉ាង ក្នុងខន្ធ ៥ បុគ្គលនោះ ឈ្មោះថា ជាក់កក់ ឬសំរាមចូលក្នុងសាសនារបស់តថាគត ដូចអរិដ្ឋ-ភិក្ខុនេះ ទើបត្រាស់ថា **ឆយិមានិ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះបទថា **ទិដ្ឋិដ្ឋានានិ** សេចក្តីថា សូម្បីទិដ្ឋិក៏ឈ្មោះថា ទីតាំងនៃទិដ្ឋិ ទាំងអារម្មណ៍របស់ទិដ្ឋិ ទាំងបច្ច័យរបស់ទិដ្ឋិ ឈ្មោះថា ទីតាំងរបស់ទិដ្ឋិ ក្នុងបទថា **រូបំ ឯតំ មម** ជាដើម ការប្រកាន់ថា នុ៎ះជារបស់អញ ជាតណ្ហាគាហៈ ការប្រកាន់ថា នុ៎ះជាអាត្មាអញ ជាមានគាហៈ ការប្រកាន់ថា នុ៎ះជាខ្លួនរបស់អាត្មាអញ ជាទិដ្ឋិគាហៈ ជាការត្រាស់តណ្ហា មានះ និងទិដ្ឋិ ដែលមានរូបជាអារម្មណ៍ ដោយប្រការដូច្នេះ ឯរូបមិនគួរពោលថា ជាអត្តា ។ ក្នុងវេទនា

ជាដើម ក៏មានន័យដូចគ្នា ។ រូបាយតនៈ ឈ្មោះថា ទិដ្ឋៈ សទ្ទាយតនៈ ឈ្មោះថា សុតៈ គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ ឈ្មោះថា មុតៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈនោះ លោកពោលថា មុតៈ ព្រោះជួបហើយប្រកាន់ ។ អាយតនៈ ៧ ដ៏សេស ឈ្មោះថា វិញ្ញាតៈ ។ បទថា **បត្តំ** បានដល់ ដែលស្វែងរកក្តី មិនស្វែងរកក្តី ជួបហើយ ។ បទថា **បរិយេសិតំ** បានដល់ ដែលជួប ឬមិនជួប ក៏ស្វែងរកហើយ ។ បទថា **អនុវិចរិតំ មនសា** បានដល់ ជាប់តាមដល់ចិត្ត ។ ពិតហើយ ក្នុងលោក របស់ដែលស្វែងរកហើយជួបក៏មាន ស្វែងរកហើយមិនជួបក៏មាន មិនស្វែងរកហើយជួបក៏មាន មិនស្វែងរកហើយមិនជួបក៏មាន ។ ក្នុងទីតាំងនៃការឃើញនោះ របស់ដែលស្វែងរកហើយជួប ឈ្មោះថា **បត្ត** របស់ដែលស្វែងរកហើយមិនជួប ឈ្មោះថា **បរិយេសិត** របស់ដែលមិនស្វែងរកហើយជួប និងរបស់ដែលមិនស្វែងរកហើយមិនជួប ឈ្មោះថា **មនសានុចរិត** ។ ម្យ៉ាងទៀត របស់ដែលស្វែងរកហើយជួបក្តី របស់ដែលមិនស្វែងរកមិនជួបក្តី ឈ្មោះថា **បត្ត** ព្រោះអត្ថថា ជួបហើយ ។ របស់ដែលស្វែងរកមិនជួបតែម្យ៉ាង ឈ្មោះថា **បរិយេសិត** ។ របស់ដែលមិនស្វែងរកហើយជួប និងរបស់ដែលមិនស្វែងរកហើយមិនជួប ឈ្មោះថា **មនសានុចរិត** ។ ឬរបស់ទាំងអស់នោះ ឈ្មោះថា **មនសានុចរិត** ព្រោះជារបស់ជាប់តាមដោយចិត្ត តណ្ហា មានះ ទិដ្ឋិ ដែលមានវិញ្ញាណជាអារម្មណ៍ ត្រាស់ដោយបទនេះ វិញ្ញាណ ត្រាស់ដោយអំណាចទិដ្ឋិជាដើមជាអារម្មណ៍ក្នុងខាងដើម ដោយអំណាចការ

ផ្លាស់ប្តូរនៃវេទនា ។

បទថា **យំបិ តំ ទិដ្ឋិដ្ឋានំ** បានដល់ ទីតាំងនៃទិដ្ឋិដែលប្រព្រឹត្តទៅដោយន័យជាដើមថា **យំបិ ឯតំ សោ លោកោ** ។ បទថា **សោ លោកោ សោ អត្តា** សេចក្តីថា ទិដ្ឋិ ប្រព្រឹត្តទៅដោយន័យជាដើមថា បុគ្គលនោះឃើញរូបដោយភាពជាអត្តា រមែងប្រកាន់ថា ជាលោក ជាអត្តា លោកសំដៅយកទិដ្ឋិនោះ ទើបពោលដូច្នេះ ។ បទថា **សោ បេច្ច ភវិស្សាមិ** សេចក្តីថា អញទៅបរលោកហើយ នឹងនៅជានិច្ច ស្ថិតស្ថេរ ទៀង មានការមិនប្រែប្រួលជាធម្មតា នឹងតាំងនៅជានិច្ចដោយការស្ថិតស្ថេរ ដូចភ្នំសិនេរុ មហាប្រឹថពី និងមហាសមុទ្រជាដើមដូច្នោះដូចគ្នា ។ បទថា **តម្បិ ឯតំ មម** សេចក្តីថា ការតាមឃើញទស្សនៈនោះថា នុ៎ះរបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ តណ្ហា មានះ ទិដ្ឋិ ដែលមានទិដ្ឋិជាអារម្មណ៍ ត្រាស់ដោយបទនេះ ។ វេលាប្រកាន់ដោយទិដ្ឋិក្នុងដំបូង រមែងមានដោយទិដ្ឋិខាងក្រោយយ៉ាងនេះ ដូចវេលាឃើញច្បាស់ដោយវិបស្សនា ។ ក្នុងសុក្កបក្ខគឺចំណែកស ទ្រង់ជំទាស់ការប្រកាន់ដោយតណ្ហា មានះ និងទិដ្ឋិក្នុងរូបថាពិចារណានូវរូបថា នុ៎ះមិនមែនជារបស់អញជាដើម ។ ក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ បទនេះថា **សមនុបស្សតិ** សេចក្តីថា សមនុបស្សនាមាន ៤ គឺតណ្ហាសមនុបស្សនា ១ មានសមនុបស្សនា ១ ទិដ្ឋិសមនុបស្សនា ១ ញាណសមនុបស្សនា ១ ។ អត្ថនៃសមនុបស្សនាទាំងនោះ គប្បីជ្រាបដោយអំណាចសមនុបស្សនា ៣ នៅក្នុងកណ្ហបក្ខ ញាណសមនុបស្សនានៅក្នុង

សុក្កបក្ខ ។ បទថា **អសតិ ន បរិតស្សតិ** សេចក្តីថា កាលការប្រកាន់មិនមាន លោករមែងមិនតក់ស្លុតដោយភ័យ ឬតក់ស្លុតដោយតណ្ហា ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ព្រះខីណាស្រពដែលមិនតក់ស្លុត ព្រោះការវិនាសនៃខន្ធខាងក្នុង ទើបទ្រង់បញ្ចប់ទេសនាដោយបទនេះ ។

[ ២០ ] បទថា **ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ** សេចក្តីថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ភិក្ខុអ្នកឈ្លាសក្នុងអនុសន្ធិមួយរូបគិតថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ព្រះខីណាស្រព ជាអ្នកមិនតក់ស្លុតព្រោះការវិនាសនៃខន្ធខាងក្នុង ទ្រង់បញ្ចប់ទេសនា កាលព្រះខីណាស្រពមិនតក់ស្លុតខាងក្នុង ភិក្ខុអ្នកតក់ស្លុងខាងក្នុង ភិក្ខុដែលតក់ស្លុតខាងក្រៅ ភិក្ខុតក់ស្លុតព្រោះការវិនាសបរិក្ខារ និងជាអ្នកមិនតក់ស្លុត គប្បីមាន អញនឹងសួរបញ្ហានេះ ដោយហេតុ ៤ ប្រការ ដូចពោលមកហើយ ទើបធ្វើចីវរឆៀងស្មាម្ខាង ផ្គងអញ្ជលីក្រាបទូលព្រះមានព្រះភាគ ដូច្នេះ ។ បទថា **ពហិទ្ធា អសតិ** បានដល់ ខាងក្រៅ គឺព្រោះការវិនាសនៃបរិក្ខារ ។ បទថា **អហុ វត មេ** សេចក្តីថា ទ្រព្យ យាន ពាហនៈ ប្រាក់ មាសរបស់អញ មានហើយហ្ន៎ ។ បទថា **តំ វត មេ នត្ថិ** សេចក្តីថា ឥឡូវនេះ ទ្រព្យនោះរបស់អញមិនមាន គឺត្រូវព្រះរាជារឹបអូសខ្លះ ពួកចោរលួចទៅខ្លះ ភ្លើងឆេះខ្លះ ត្រូវទឹកកួចយកទៅខ្លះ បាក់បែកព្រោះប្រើប្រាស់ខ្លះ ។ បទថា **សិយា វត មេ** សេចក្តីថា យាន ពាហនៈ ប្រាក់ មាស ស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើបស្រែរបស់អញមានហ្ន៎ ។ បទថា **តំ វតាហំ ន លភាមិ** សេចក្តីថា សោយ

សោកថា អញកាលមិនបានរបស់នោះ ឥឡូវនេះ អញក៏មិនបាន ព្រោះមិនធ្វើការផាររដែលសមគួរដល់ទ្រព្យនោះឯង នេះឈ្មោះថា ការសោយសោករបស់អ្នកគ្រប់គ្រងផ្ទះ ។ សេចក្ដីសោករបស់អ្នកមិនគ្រប់គ្រងផ្ទះ គឺបព្វជិតគប្បីជ្រាបដោយអំណាចបាត្រ និងចីវរជាដើម ។

គប្បីជ្រាបក្នុងអបរិតស្សនាវារៈដូច្នេះ បទថា **ន ឯវំ ហោតិ** សេចក្ដីថា ការតក់ស្លុតគប្បីមានយ៉ាងនេះ ព្រោះកិលេសណារមែងមិនមានយ៉ាងនេះ ព្រោះកិលេសទាំងនោះលះបានហើយ ។ បទថា **ទិដ្ឋិដ្ឋានាធិដ្ឋានបរិយុដ្ឋានាភិនិវេសានុសយានំ** សេចក្ដីថា នូវទិដ្ឋិ ទីតាំងទិដ្ឋិ ទីតាំងមាំនៃទិដ្ឋិ ទីបោមរោមនៃទិដ្ឋិ និងទីដេកត្រាំនៃការប្រកាន់មាំ ។ បទថា **សព្វសង្ខារសមថាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការរម្ងត់ ។ ពិតហើយ ការកម្រើក ការញាប់ញ័រ ការប្រែប្រួលនៃសង្ខារទាំងពួង មកដល់ព្រះនិព្វាន រមែងរម្ងាប់ទៅ ព្រោះដូច្នោះ ទើបព្រះនិព្វាននោះ លោកហៅថា ជាទីរម្ងាប់សង្ខារទាំងពួង ។ម្យ៉ាងទៀត ឧបធិទាំងនេះ គឺខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ កាមូបធិ មកដល់ព្រះនិព្វាននោះ ក៏រលត់ទៅ តណ្ហាក៏អស់ ក៏រលាយ ក៏រលត់ ព្រោះដូច្នោះ ទើបព្រះនិព្វាននោះ លោកហៅថា **សព្វូបធិប្បដិនិស្សគ្គ** ជាទីរលាស់ចោលនូវឧបធិទាំងពួង **តណ្ហាក្ខយ** ជាទីអស់តណ្ហា **វិរាគ** ខ្ចាក់ចោលរាគៈ **និរោធ** គឺរលត់ ។ សព្ទថា **និព្វានាយ** នេះ ជានិទ្ទេសសរុបនៃព្រះនិព្វាននោះ ។ លោកសម្ដែងសេចក្ដីនេះថា កាលទ្រង់សម្ដែងធម៌ដើម្បីជាប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយបទទាំងអស់នេះឯង។

បទថា **តស្សេវំ ហោតិ** សេចក្តីថា ភិក្ខុដែលមានទិដ្ឋិនោះ រមែងមានគំនិតយ៉ាងនេះថា អញនឹងដាច់សូន្យ អញនឹងវិនាស អញនឹងមិនមាន ។ ពិតហើយភិក្ខុដែលមានទិដ្ឋិស្តាប់ធម៌ ដែលទ្រង់លើកឡើងកាន់ត្រៃលក្ខណ៍ សម្តែងឲ្យទាក់ទងដោយសុញ្ញតា កើតការភ័យខ្លាច ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ព្រោះថា ភិក្ខុជាបុថុជ្ជន ជាអ្នកមិនចេះដឹង តែងមានសេចក្តីតក់ស្លុតថា បើអាត្មាអញនឹងមិនមាន ( បរិក្ខារ ) របស់អាត្មាអញក៏មិនមាន ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ត្រាស់សុញ្ញតាមាន ៤ ចំណុច ដោយអំណាចនៃភិក្ខុទាំងនោះ គឺភិក្ខុដែលតក់ស្លុត និងមិនតក់ស្លុត ព្រោះការវិនាសនៃបរិក្ខារខាងក្រៅ ១ គូ និងភិក្ខុដែលតក់ស្លុត និងមិនតក់ស្លុត ព្រោះការវិនាសនៃខន្ធខាងក្នុង ១ គូ ។

[ ២១ ] ឥឡូវនេះ ដើម្បីទ្រង់សម្តែងសុញ្ញតា ៣ គឺចាត់បរិក្ខារខាងក្រៅ ឲ្យឈ្មោះថា **ទិដ្ឋិបរិគ្គហ** ចាត់សក្កាយទិដ្ឋិដែលមានវត្ថុ ២០ ឲ្យឈ្មោះថា **អត្តវាទុបាទាន** ចាត់ទិដ្ឋិ ៦២ ដែលមានសក្កាយទិដ្ឋិជាប្រធាន ឲ្យឈ្មោះថា **ទិដ្ឋិនិស្សយ** ទើបត្រាស់ថា **ភិក្ខវេ បរិគ្គហំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បរិគ្គហំ** បានដល់ បរិក្ខារខាងក្រៅ ។ បទថា **បរិគ្គ-ណ្ហេយ្យ** សេចក្តីថា មនុស្សវិញ្ញូជនគប្បីកំណត់កាន់យក ។ ដោយបទថា **អហំបិ ខោ តំ ភិក្ខវេ** ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកក៏មិនឃើញ តថាគតក៏មិនឃើញ ដូច្នេះ ការកំណត់បែបនោះក៏មិនមាន ។ គប្បី

ជ្រាបសេចក្តីក្នុងបទទាំងពួង ដោយប្រការដូច្នេះ ។

[ ២២ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងសុញ្ញតា ៣ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែង ២ ចំណុច គឺអត្តាក្នុងខន្ធខាងក្នុង និងទាក់ទងដោយខ្លួនក្នុងបរិក្ខារខាងក្រៅ ទើបត្រាស់ពាក្យថា **អត្តនិ វា ភិក្ខវេ សតិ** ជាដើម ។ ក្នុងពាក្យនោះ មានសេចក្តីសង្ខេបដូច្នេះថា កាលខ្លួនមានបរិក្ខាររបស់អញនេះ ក៏ទាក់ទងក្នុងខ្លួន ឬថា បរិក្ខារដែលទាក់ទងនឹងខ្លួនមានអត្តា របស់អញនេះក៏ជាម្ចាស់បរិក្ខារនេះ អញក៏ដូចគ្នា គប្បីប្រកបពាក្យថា កាលវត្ថុមាន របស់អញក៏មាន អញក៏មាន ដូច្នេះ ។ បទថា **សច្ចតោ** ប្រែថា ដោយសេចក្តីពិត ។ បទថា **ថេតតោ** ប្រែថា ដោយពិត ឬមាំទាំ ។

ឥឡូវនេះ កាលទ្រង់មិនប្រកាន់បញ្ចក្ខន្ធ ដោយបរិវដ្ដៈ ៣ យ៉ាង គឺ **អនិច្ចំ ទុក្ខំ អនត្តា** កាលទ្រង់សម្តែងថា ភិក្ខុនេះក៏ដូចអរិដ្ឋភិក្ខុជាក់កក់ និងសំរាមចូលក្នុងសាសនារបស់តថាគត ទើបត្រាស់ថា **តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា** ជាដើម ។ បទថា **អនិច្ចំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គ ព្រោះហេតុដែលរូបមានហើយត្រឡប់ជាមិនមាន ដូច្នោះ ទើបរូបមិនទៀង ដែលឈ្មោះថា មិនទៀង ព្រោះហេតុ ៤ ប្រការ គឺព្រោះកើតហើយ ក៏វិនាសទៅ ឬព្រោះអត្ថថា ប្រែប្រួល ប្រព្រឹត្តទៅមួយជួរខណៈ និងបដិសេធការទៀង ។ បទថា **ទុក្ខំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គ រូបឈ្មោះថា ទុក្ខ ដោយអាការ គឺបៀតបៀន ឈ្មោះថា ជាទុក្ខដោយហេតុ ៤ យ៉ាង គឺព្រោះអត្ថថា ធ្វើឲ្យក្តៅក្រហាយ អត់ធន់បានដោយលំបាក ជាទីតាំងនៃទុក្ខ និងបដិសេធ

សេចក្តីសុខ ។ បទថា **វិបរិណាមធម្មំ** សេចក្តីថា មានការឈានចុះ និងចូលដល់កពជាសភាវៈ គឺមានការលះភាពជាប្រក្រតីជាសភាវៈ ។ បទថា **កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តា** សេចក្តីថា សមគួរ ឬដែលមកប្រកាន់រូបយ៉ាងនេះថា អញ របស់អញ ដោយអំណាចនៃការប្រកាន់នៃតណ្ហា មានះ និងទិដ្ឋិទាំង ៣ នេះ ។ ដោយបទនេះថា **នោ ហេតំ ភន្តេ** ភិក្ខុទាំងនោះ រមែងប្តេជ្ញាថា បពិត្រព្រះអង្គ រូបជាអនត្តា ដោយការមិនប្រព្រឹត្តទៅក្នុងអំណាច រូបឈ្មោះថា ជាអនត្តា ដោយហេតុ ៤ គឺ ដោយអត្ថថា ជារបស់សូន្យ មិនមានម្ចាស់ មិនជាធំ និងបដិសេធអត្តា ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សម្តែងភាពជាអនត្តា ដោយអំណាចជារបស់មិនទៀងទុកក្នុងទីណា ដោយអំណាចភាពជាទុក្ខក្នុងទីណា ដោយអំណាចភាពជារបស់មិនទៀង និងភាពជាទុក្ខក្នុងទីណា ។ ពិតហើយ ទ្រង់សម្តែងភាពជាអនត្តា ដោយអំណាចការមិនទៀងក្នុងឆក្កសូត្រនេះថា បុគ្គលណានិយាយយ៉ាងនេះថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) ភ្នែករបស់គេ តែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួនឡើយ ។ ទ្រង់សម្តែងភាពជាអនត្តាដោយអំណាច

ភាពជាទុក្ខក្នុងអនត្តលក្ខណសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ រូប គឺរាងកាយ ជាអនត្តា មិនមែនជារបស់ខ្លួនឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ រូប នេះជារបស់ខ្លួនពិតមែន រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជំងឺ តម្កាត់ឡើយ ម្យ៉ាងទៀត បុគ្គលគប្បីបាន ( នូវអំណាច ) ក្នុងរូបថា សូម ឲ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឲ្យរូបរបស់អញយ៉ាងនេះឡើយ ដូច្នេះ ។ ទ្រង់សម្ដែងភាពជាអនត្តា ដោយអំណាចការមិនទៀង និងជាទុក្ខទាំង ២ ក្នុង អរហន្តសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញតាមសេចក្ដីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ ថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ គប្បីឃើញរូបនោះដោយប្រពៃតាមសេចក្ដីពិត ដូចពោលមកនេះ ។ ព្រោះ ហេតុអ្វី ព្រោះអនិច្ចំ និងទុក្ខំប្រាកដហើយ អនត្តាមិនទាន់ប្រាកដ ។ ពិត ហើយ កាលភាជនៈដាក់របស់បរិភោគជាដើមបែកទៅ មនុស្សទាំងឡាយ ក៏ពោលថា **អហោ អនិច្ចំ** ឱ ! មិនទៀងហ្ន៎ មិនមានបុគ្គលពោលថា អនត្តា ។ កាលបបូស បូសទាំងឡាយ កើតឡើងត្រង់រាងកាយ ឬត្រូវបន្លា មុត ក៏ពោលថា **អហោ ទុក្ខំ** ឱ ! ទុក្ខហ្ន៎ មិនមានបុគ្គលណា ពោលថា **អហោ អនត្តា** ឱ ! មិនមែនអត្តាហ្ន៎ ព្រោះហេតុអ្វី ព្រោះឈ្មោះថា អនត្ត- លក្ខណៈនេះមិនច្បាស់ ឃើញលំបាក ដឹងលំបាក ដោយហេតុនោះ ទើបព្រះ មានព្រះភាគ ទ្រង់សម្ដែងភាពជាអនត្តានោះ ដោយអំណាចមិនទៀងខ្លះ ទុក្ខ

ខ្លះ មិនទៀងផង ទុក្ខផងទាំង ២ ខ្លះ ។ រូបនោះ ទ្រង់សម្តែងដោយអំណាចការមិនទៀង ជាទុក្ខប៉ុណ្ណោះក្នុងបរិវដ្ដ: ៣ ។ ក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

បទថា **តស្មា តិហ ភិក្ខវេ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រោះរូបមិនទៀង ជាទុក្ខ ជាអនត្តា ទាំងក្នុងឥឡូវនេះ ទាំងក្នុងកាលដទៃៗ ។ បទថា **យង្កិញ្ចិ រូបំ** ជាដើម ពោលពិស្តារហើយ ក្នុងខន្ធនិទ្ទេសនៃគម្ពីរវិសុទ្ធិមគ្គ ។

[ ២៣ ] បទថា **និព្វិន្ទតិ** ប្រែថា នឿយណាយ ។ ក្នុងបទថា **និព្វិន្ទតិ** ក្នុងបាលីនេះ លោកបំណងយកវុដ្ឋានគាមិនីវិបស្សនា គឺវិបស្សនាដែលឲ្យដល់នូវការចេញចាកការប្រកាន់ដោយតណ្ហា ។ ពិតហើយ វុដ្ឋានគាមិនី-វិបស្សនាមានច្រើនឈ្មោះ ទីខ្លះហៅថា **សញ្ញគ្គ** ទីខ្លះហៅថា **ធម្មដ្ឋិតិញ្ញាណ** ទីខ្លះហៅថា **បារិសុទ្ធិបធានិយង្គ** ទីខ្លះហៅថា **បដិបទាញាណទស្សនវិសុទ្ធិ** ទីខ្លះហៅថា **តម្បបរិយាទាន** ទីខ្លះក៏មាន ៣ ឈ្មោះ ទីខ្លះក៏មាន ២ ឈ្មោះ ។ បណ្ដាអាគតដ្ឋានទាំងនោះ ក្នុងបោដ្ឋបាទសូត្រ ត្រាស់ហៅថា **សញ្ញគ្គ** យ៉ាងនេះថា ម្នាលបោដ្ឋបាទ សញ្ញាកើតឡើងមុន ទើបខាងក្រោយញាណកើតឡើង ដូច្នេះ ។ ក្នុងសុសិមសូត្រ ត្រាស់ហៅថា **ធម្មដ្ឋិតិញ្ញាណ** យ៉ាងនេះថា ម្នាលសុសិម: ធម្មដ្ឋិតិញ្ញាណ គឺវិបស្សនាញាណ តែងកើតឡើងមុន ការដឹងក្នុងព្រះនិព្វាន គឺមគ្គញ្ញាណ តែងកើតឡើងក្រោយ ដូច្នេះ ។ ក្នុងទសុត្តរសូត្រ ត្រាស់ហៅថា **បារិសុទ្ធិបធានិយង្គ** យ៉ាងនេះថា បដិបទា-ញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធិ ដូច្នេះ ។

ក្នុងរថវិនីតសូត្រ លោកហៅថា **បដិបទាញាណទស្សនវិសុទ្ធិ** យ៉ាងនេះថា ម្នាលអាវុសោ លោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ ដូច្នេះ ។ ក្នុងសឡាយតនវិភង្គសូត្រ លោកហៅថា **តម្បរិយាទាន** យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរអាស្រ័យនឹងតណ្ហា ពឹងផ្អែកនឹងតណ្ហា ហើយលះបង់ កន្លងឲ្យផុតនូវឧបេក្ខាជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាចេញ ការលះបង់ឧបេក្ខានុ៎ះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ។ ក្នុងបដិសម្ភិទាមគ្គ លោកប្រារព្ធ ៣ ឈ្មោះយ៉ាងនេះថា ធម៌ទាំងនេះ គឺ **មុញ្ចិតុកម្យតា បដិសង្ខានុបស្សនា** និង **សង្ខារុបេក្ខា** មានអត្ថតែមួយដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ ក្នុងគម្ពីរបដ្ឋាន លោកប្រារព្ធ ២ ឈ្មោះយ៉ាងនេះ គឺ **អនុលោមញ្ញាណ** ជាបច្ច័យដល់ **គោត្រភូញាណ** ដោយអនន្តរប្បច្ច័យ អនុលោមញ្ញាណជាបច្ច័យនៃវោទាន គឺមគ្គចិត្ត និងផលចិត្ត ដោយអនន្តរប្បច្ច័យ ។ ឯក្នុងអលគទ្ទូបមសូត្រនេះ វុដ្ឋានគាមិនីវិបស្សនា មកដោយឈ្មោះថា **និព្វិទា** ក្នុងបទថា **និព្វិន្ទតិ** ។ មគ្គឈ្មោះថា វិរាគៈ ក្នុងបទនេះថា **និព្វិន្ទំ វិរជ្ជតិ** ។ ក្នុងបទថា **វិរាគា វិមុច្ចតិ** នេះ លោកពោលផលថា រមែងរួចផុត ព្រោះវិរាគៈ គឺមគ្គ ។ ក្នុងទីនេះ លោកពោលបច្ចវេក្ខណញ្ញាណថា កាលរួចផុត ក៏មានញាណដឹងថា អញរួចផុតហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះមហាខីណាស្រព ដែលជាអ្នកមានចិត្តរួចផុតយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រារព្ធឈ្មោះរបស់ព្រះ-

មហាទីណាស្រពនោះដោយហេតុ ៥ ប្រការតាមសេចក្តីពិត ទើបត្រាស់ថា **អយំ វុច្ចតិ ភិក្ខវេ** ជាដើម ។ បទថា **អវិជ្ជា** បានដល់ អវិជ្ជា មានវដ្តៈជាមូល ។ ពិតហើយ **អវិជ្ជា** នេះ លោកហៅថា **បលិឃ** ព្រោះអត្ថថា លើកឡើងបានលំបាក ដោយហេតុនោះ ទើបភិក្ខុនេះ លោកហៅថា **ឧក្ខិត្តបលិឃ** ព្រោះអវិជ្ជានោះត្រូវលើកឡើង ។ បទថា **តាលាវត្ថុកតា** បានដល់ ធ្វើឲ្យដូចជាត្នោតកំបុតចុង អធិប្បាយថា ដកត្នោតព្រមទាំងឫស ធ្វើឲ្យលែងមានបែបភាព គឺនាំទៅឲ្យដល់នូវការមិនមានបញ្ញត្តិទៀត ដូចដើមត្នោតនោះ មិនប្រាកដទីតាំង ។ បទថា **បោនោព្ភវិកោ** បានដល់ ឲ្យនូវភពថ្មី ។ បទថា **ជាតិសង្ខារោ** បានដល់ អភិសង្ខារ គឺកម្ម ដែលជាបច្ច័យនៃខន្ធក្នុងភពថ្មី ដែលបានឈ្មោះយ៉ាងនេះ ដោយការកើត និងអន្ទោលទៅក្នុងជាតិទាំងឡាយ ។ ពិតហើយ អភិសង្ខារ គឺកម្មនេះ លោកហៅថា **បរិក្ខា** ព្រោះចោមរោម ដោយការធ្វើឲ្យកើតរឿយៗ ដោយហេតុនោះ ភិក្ខុនោះ ហៅថា **សង្កិណ្ណបរិក្ខ** ព្រោះដេរជាសដោយអវិជ្ជានោះ ។ បទថា **តណ្ហា** បានដល់ តណ្ហាដែលមានវដ្តៈជាមូល ។ ពិតហើយ តណ្ហានេះ លោកហៅថា **ឯសិកា** ព្រោះអត្ថថា តាមទៅដោយជ្រាលជ្រៅ ។ ដោយហេតុនោះ ភិក្ខុនោះ លោកហៅថា **អព្វុឡ្ហេសិក** ព្រោះតណ្ហានោះ បុគ្គលនោះលើកឡើង គឺព្រោះបុគ្គលនោះកាត់ផ្តាច់ ។ បទថា **ឱរម្ភាគិយានិ** បានដល់ ឲ្យកើតខាងក្រោម គឺជាបច្ច័យឲ្យកើតក្នុងកាមភព ។ ពិតហើយ សំយោជនៈទាំងនេះ លោកហៅថា **អគ្គឡ** ព្រោះបិទបាំងចិត្ត ដូចសន្ទះទ្វារនគរបិទ ។ ដោយហេតុនោះ ភិក្ខុនោះ លោក

ហៅថា **និរគ្គឡ** ព្រោះសំយោជនៈទាំងនោះ ដែលលោកធ្វើឲ្យមិនមាន គឺបំផ្លាញទៅ ។ បទថា **អរិយោ** បានដល់ បុគ្គលមិនមានកិលេស គឺបរិសុទ្ធ ។ បទថា **បន្នទ្ធជោ** បានដល់ មានទង់ គឺមានះដាក់ចុះហើយ ។ បទថា **បន្នភារោ** មានវិគ្គហៈថា ឈ្មោះថា បន្នភារៈ ព្រោះភិក្ខុនោះមានភារៈ គឺខន្ធ កិលេស អភិសង្ខារ និងកាមគុណ ៥ ដាក់ចុះហើយ គឺលើកចុះហើយ ។ម៉្យាងទៀត ក្នុងទីនេះលោកបំណងយកបន្នភារៈ ព្រោះដាក់ភារៈ គឺមានះប៉ុណ្ណោះ ។ បទថា **វិសំយុត្តោ** បានដល់ ប្រាសហើយចាកយោគៈ ៤ និងកិលេសទាំងអស់ ។ តែក្នុងទីនេះលោកបំណងយកវិសំយុត្ត ព្រោះប្រាសចាកសំយោជនៈ គឺមានះតែម៉្យាង ។ បទថា **អស្មិមានោ** បានដល់ មានមានះថា អញមានក្នុងរូប មានមានះថា អញមានក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងកាលរបស់ព្រះខីណាស្រព ដែលធ្វើកិលេសឲ្យអស់ទៅដោយមគ្គ ជាអ្នកដេកនៅលើដំណេក គឺនិរោធដ៏ប្រសើរ ជាអ្នកចូលផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ប្រៀបដូចនគរ ២ គឺ នគរចោរ ១ នគរក្សេម ១ ។ កាលបើដូច្នោះ អ្នកចម្បាំងជំម្នាក់ គប្បីគិតយ៉ាងនេះថា នគរចោរនេះតាំងនៅដរាបណា នគរក្សេមក៏មិនរួចអំពីអន្តរាយនោះ អញនឹងធ្វើនគរចោរ មិនឲ្យជានគរ ហើយទើបពាក់អាវក្រោះ កាន់យកដាវ ចូលទៅកាន់នគរចោរ យកដាវកាត់បង្គោលរបង លើកឡើងក្បែរទ្វារនគរ ទម្លាយសន្ទះទ្វារ និងក្របទ្វារ ហើយដកគន្លឹះឡើង ទម្លាយកំពែងរើបន្ទាយ រម្ងំទង់ដែលលើកឡើង ដើម្បីលម្អនគរ យកភ្លើងដុតនគរហើយ

ចូលនគរក្សេម ឡើងប្រាសាទ ហែហមដោយពួកញាតិ បរិភោគភោជនមានរសឆ្ងាញ់ យ៉ាងណា សេចក្ដីនេះក៏ដូច្នោះ សក្កាយដូចនគរចោរ និព្វានដូចនគរក្សេម ព្រះយោគាវចរដូចអ្នកចម្បាំងធំ ព្រះយោគាវចរនោះ មានការគិតយ៉ាងនេះថា ការវិលចុះឡើងនៃសក្កាយ ប្រព្រឹត្តទៅជរាបណា ការរួចផុតពីកម្មករណៈ ៣២ រោគ ៩៨ មហាភ័យ ២៥ ក៏មិនមានដរាបនោះ ព្រះយោគាវចរប្រៀបដូចអ្នកចម្បាំងធំនោះ ពាក់អាវក្រោះ គឺសីល ចាប់ដាវ គឺបញ្ញា យកអរហត្តមគ្គកាត់បង្គោលរបង គឺតណ្ហា ដូចយកដាវកាត់បង្គោលរបង ព្រះយោគាវចរនោះដកគន្លឹះ គឺសំយោជនៈខាងក្រោម ៥ ដូចអ្នកចម្បាំងលើកសន្ទះទ្វារនគរ ព្រមទាំងក្របទ្វារ ព្រះយោគាវចរនោះដកគន្លឹះ គឺអវិជ្ជា ដូចអ្នកចម្បាំងដកគន្លឹះ ព្រះយោគាវចរទម្លាយអភិសង្ខារ គឺកម្ម រើបន្ទាយ គឺជាតិសង្សារ ដូចអ្នកចម្បាំងទម្លាយកំពែង រើបន្ទាយ ព្រះយោគាវចររម្ងំទង់ គឺមានះ ផុតនគរ គឺសក្កាយ ដូចអ្នកចម្បាំងរម្ងំទង់ដែលលើកឡើងដើម្បីលម្អនគរ ព្រះយោគវចរចូលនគរ គឺកិលេសនិព្វាន សោយសុខដែលកើតអំពីផលសមាបត្តិ ដែលមានអមតនិរោធជាអារម្មណ៍ ញុំាងកាលឲ្យកន្លងទៅ ដូចអ្នកចម្បាំងបរិភោគភោជន ដែលមានរសល្អ ក្នុងប្រាសាទជាន់លើ ក្នុងនគរក្សេម ដូច្នោះ ។

[ ២៤ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងភាពដែលព្រះខីណាស្រព ជាអ្នកមានចិត្តរួចផុតយ៉ាងនេះ ជាបុគ្គលមានវិញ្ញាណ ដែលអ្នកដទៃជួបមិនបាន ទើបត្រាស់ថា **ឯវំ វិមុត្តចិត្តំ ខោ** ជាដើម ។ បណ្ដាបទទាំង

នោះ បទថា **អន្វេសន្តា** បានដល់ ស្វែងរក ។ បទថា **ឥទំ និស្សិតំ** បាន ដល់ អាស្រ័យវត្ថុនេះ ។ សូម្បីសត្វលោកក៏បំណងយកថា តថាគតក្នុង ពាក្យថា **តថាគតស្ស** នេះ សូម្បីព្រះខីណាស្រពក៏ជាបុគ្គលឧត្តម ។ បទថា **អននុវេជ្ជោ** ប្រែថា អ្នកមិនមាន ឬដែលបុគ្គលមិនជួប ។ ពិតហើយ កាល ប្រកាន់ថាសត្វ ជាតថាគត ក៏គួរមានសេចក្ដីថា មិនមាន ។ កាលប្រកាន់ថា ព្រះខីណាស្រព ក៏គួរនឹងមានសេចក្ដីថា បុគ្គលជួបមិនបាន ក្នុងន័យទាំង ២ នោះ ន័យដំបូងមានអធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិន បញ្ញត្តព្រះខីណាស្រព ដែលនៅមានជីវិតក្នុងបច្ចុប្បន្នប៉ុណ្ណោះថា តថាគត សត្វ បុគ្គល តើតថាគតបញ្ញត្តព្រះខីណាស្រព ដែលបរិនិព្វានហើយ មិនមានបដិ- សន្ធិថា សត្វ ឬបុគ្គលបានដូចម្ដេច អធិប្បាយថា តថាគតមិនមាន ពិតហើយ ពោលដោយបរមត្ថ ឈ្មោះថា សត្វណាមួយ មិនមាន កាលសត្វមិនមាន ទេវតាទាំងឡាយ ទោះស្វែងរកថា វិញ្ញាណអាស្រ័យអ្វី ដូច្នេះ នឹងជួបបាន ដូចម្ដេច គឺនឹងជួបបានយ៉ាងណា ។ ក្នុងន័យទី ២ អធិប្បាយដូច្នេះថា ម្នាល ភិក្ខុទាំងឡាយ តថាគតពោលថា ព្រះខីណាស្រពដែលកំពុងមានជីវិតនៅក្នុង បច្ចុប្បន្ននេះប៉ុណ្ណោះ ដែលទេវតាទាំងឡាយ មានព្រះឥន្ទ្រជាដើម ជួបមិន បានដោយវិញ្ញាណ ពិតហើយ ទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះបជាបតី ទោះបីស្វែងរកក៏មិនអាចដឹងវិបស្សនាចិត្ត មគ្គចិត្ត ឬផលចិត្ត នៃព្រះខីណាស្រពថា អាស្រ័យអារម្មណ៍ឈ្មោះនេះប្រព្រឹត្តទៅ ទេវតាទាំង នោះនឹងដឹងអ្វីរបស់ព្រះខីណាស្រព ដែលបរិនិព្វានហើយ មិនមានបដិសន្ធិ ។

បទថា **អសតា** ប្រែថា មិនមាន ។ បទថា **តុច្ឆា** ប្រែថា ទទេ ។ បទថា **មុសា** ប្រែថា និយាយកុហក ។ បទថា **អភូតេន** ប្រែថា ដោយរឿងដែលមិនមាន ។ បទថា **អព្ភាចិក្ខន្តិ** បានដល់ មួលបង្កាច់ ។ បទថា **វេនយិកោ** សេចក្តីថា ឈ្មោះថា វិន័យ ព្រោះកម្ចាត់ ធ្វើឲ្យវិនាស វិន័យនោះឯង ឈ្មោះថា **វេនយិក** អធិប្បាយថា ធ្វើសត្វឲ្យវិនាស ។ បទថា **យថា ចាហំ ភិក្ខវេ ន** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនជាអ្នកធ្វើសត្វឲ្យវិនាសដោយហេតុណា ។ បទថា **យថា ចាហំ ន វទាមិ** សេចក្តីថា តថាគតមិនបញ្ញត្តការធ្វើសត្វឲ្យវិនាសដោយហេតុណា ។ លោកអធិប្បាយថា តថាគតមិនធ្វើសត្វឲ្យវិនាសដោយប្រការណា និងមិនបញ្ញត្តការធ្វើសត្វឲ្យវិនាសដោយប្រការណា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពោលទោសតថាគតថា ព្រះសមណគោតមជាអ្នកកម្ចាត់ និងពោលទោសថា ព្រះសមណគោតមធ្វើសត្វឲ្យវិនាស ថាតថាគតបញ្ញត្តការដាច់សូន្យ ការវិនាស ការមិនមាននៃសត្វដែលមានផង ពោលបង្កាច់ដោយរឿងដែលមិនមាន ទទេ កុហក និងមិនពិតថា តថាគតបញ្ញត្តសេចក្តីវិនាសនៃសត្វផង ។ បទថា **បុព្វេ ច** បានដល់ ក្នុងកាលមុន គឺកាលត្រាស់ដឹងក្នុងមហាពោធិមណ្ឌលដ្ឋាន ។ បទថា **ឯតរហិ ច** បានដល់ ក្នុងឥឡូវនេះ គឺក្នុងវេលាសម្តែងធម៌ ។ បទថា **ទុក្ខំ ចេវ បញ្ញាបេមិ ទុក្ខស្ស ច និរោធំ** សេចក្តីថា តថាគតនៅត្រង់ពោធិមណ្ឌលដ្ឋាន មិនទាន់ប្រកាសធម្មចក្រក្តី សម្តែងធម៌តាំងអំពីប្រកាសធម្មចក្រក្តី រមែងបញ្ញត្តសច្ចៈ ៤ ប៉ុណ្ណោះ ។ ពិតហើយ ក្នុងសច្ចៈ ៤ នោះ សមុទយៈដែលជាមូលនៃទុក្ខ

នោះ គប្បីជ្រាបថា ទ្រង់កាន់យកដោយ **ទុក្ខ** សច្ច ឯមគ្គដែលឲ្យដល់និរោធនោះ គប្បីជ្រាបថា ទ្រង់កាន់យកដោយ **និរោធ** សច្ច ។ បទថា **តត្រ ចេ** បានដល់ ក្នុងការប្រកាសសច្ចៈ ៤ នោះ ។ បទថា **បរេ** បានដល់ បុគ្គលមិនអាចដឹងច្បាស់ ចាក់ធ្លុះសច្ចៈទាំងឡាយ ។ បទថា **អក្កោសន្តិ** បានដល់ ជេរដោយអក្កោសវត្ថុ ១០ ។ បទថា **បរិភាសន្តិ** បានដល់ បរិភាសដោយវាចា ។ បទថា **រោសេន្តិ វិហេសេន្តិ** បានដល់ បំណងថា អញនឹងក្រោធខឹង នឹងបៀតបៀន ។ បទថា **ឃដ្ដេន្តិ** បានដល់ ឲ្យជួបនូវទុក្ខ ។ បទថា **តត្រ** បានដល់ ក្នុងការជេរជាដើមនោះ ឬក្នុងបុគ្គលដទៃនោះ ។ បទថា **អាឃាតោ** បានដល់ សេចក្ដីក្រោធ ។ បទថា **អប្បច្ចយោ** បានដល់ ការខូចចិត្ត ។ បទថា **អនភិរទ្ធិ** បានដល់ មិនត្រេកអរ ។ បទថា **តត្រ ចេ** បានដល់ ក្នុងការប្រកាសសច្ចៈ ៤ នោះឯង ។ បទថា **បរេ** បានដល់ បុគ្គលដែលដឹងច្បាស់ ចាក់ធ្លុះសច្ចៈ ៤ ។ បទថា **អានន្ទោ** បានដល់ ដោកជាំដោយបីតិ ។ បទថា **ឧប្បិលាវិតត្តំ** បានដល់ ដោកជាំដោយអំណាចនៃបីតិ ។ បទថា **តត្រ ចេ** បានដល់ ក្នុងការប្រកាសសច្ចៈ ៤ នោះឯង ។ បទថា **តត្រ** បានដល់ ក្នុងសក្ការៈជាដើម ។ បទថា **យំ ខោ ឥទំ បុព្វេ បរិញ្ញាតំ** សេចក្ដីថា ខន្ធបញ្ចកៈនេះ ព្រះមានព្រះភាគ ទ្រង់កំណត់ដឹងហើយ ដោយបរិញ្ញា ៣ ត្រង់ពោធិមណ្ឌលដ្ឋានម៉្លេះ ។ បទថា **តត្ថ មេ** ប្រែថា សក្ការៈទាំងនេះដែលគេធ្វើក្នុងខន្ធបញ្ចកៈនោះ ។ លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា ការគិតថា សក្ការៈទាំងនេះ នឹងមានក្នុងអញ ឬថា អញនឹង

សោយសក្ការៈទាំងនេះមិនមាន ក្នុងខន្ធបញ្ចកៈនោះ និងមានការត្រិះរិះប៉ុណ្ណេះថា តថាគតរមែងសោយសក្ការៈរបស់ខន្ធបញ្ចកៈ ដែលកំណត់ដឹងហើយអំពីមុននោះ និងខន្ធបញ្ចកៈ រមែងសោយសក្ការៈទាំងនេះ ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលសមណព្រាហ្មណ៍ដទៃ ដែលមិនអាចចាក់ធ្លុះសច្ចៈទាំងឡាយ ទើបនាំគ្នាជេរនូវព្រះតថាគត ដូច្នោះ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលមកហើយនោះឯង ។

[ ២៥ ] បទថា **តស្មា តិហ ភិក្ខវេ យំ ន តុម្ហាកំ** សេចក្តីថា ការលះឆន្ទរាគៈ ក្នុងវត្ថុដែលមិនទាក់ទងនឹងខ្លួន ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ ព្រោះដូច្នោះ ពួកអ្នកចូរលះវត្ថុដែលមិនមែនរបស់ពួកអ្នកចេញ ។ បទថា **យថាបច្ចយំ វា ករេយ្យ** សេចក្តីថា អ្នកប្រាថ្នាដោយប្រការណាមួយ គប្បីធ្វើដោយប្រការនោះ ។ បទថា **ន ហិ នោ ឯតំ ភន្តេ អត្តា វា** សេចក្តីថា បពិត្រព្រះអង្គ សមណព្រាហ្មណ៍ទាំង-ឡាយ ពោលស្មៅ ឈើ មែកឈើ និងស្លឹកឈើនោះថា មិនមែនខ្លួនរបស់យើង មិនមែនរូបរបស់យើង មិនមែនវិញ្ញាណរបស់យើង ។ បទថា **អត្តនិយំ វា** សេចក្តីថា សូម្បីបរិក្ខារ មានចីវរជាដើម មិនមែនរបស់យើង ។ បទថា **ឯវមេវ ខោ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងខន្ធបញ្ចកៈនោះឯងថា មិនមែនរបស់អ្នក ទើបទ្រង់ឲ្យលះបង់ តែមិនមែនឲ្យកើបកន្ត្រាក់ ឬកាត់ខន្ធបញ្ចកៈ តែឲ្យលះបង់ចេញ ដោយកម្ចាត់ឆន្ទរាគៈ ។

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯវំ ស្វាក្ខាតោ** នេះ ដូច្នេះថា សូម្បីនាំមកនូវបរិវដ្ដៈ ៣ ទើបដល់ឋានៈនេះក៏គួរ ដោយបដិលោម និង ត្រឡប់មកតាំងអំពី **បេមមត្តសគ្គបរាយណ** រហូតដល់ឋានៈនេះក៏គួរ ។ បទ ថា **ស្វាក្ខាតោ** សេចក្ដីថា ត្រាស់ល្អហើយ គឺងាយ បើកផ្ចារ ប្រកាសហើយ ព្រោះជាធម៌ដែលត្រាស់ល្អហើយ ។ សំពត់រហែក សំពត់ធ្លុះដែលដេរធ្វើជា បំណះទុកក្នុងទីនោះៗ សំពត់គ្រាំគ្រា លោកហៅថា សំពត់ចាស់ ក្នុងបទថា **ឆិន្នបិលោតិកោ** បុគ្គលណាមិនមានសំពត់ចាស់នោះ បុគ្គលនោះ ស្លៀកសំពត់ ថ្មី ៨ ហត្ថខ្លះ ៩ ហត្ថខ្លះ ឈ្មោះថា បុគ្គលមិនមានសំពត់ចាស់ ។ សូម្បី ធម៌នេះក៏ដូច្នេះ ក្នុងពាក្យនេះមិនមានភាវៈដូចសំពត់ដែលធ្លុះ ដែលរហែក ដែលដេរជាបំណះ ដោយការបញ្ឆោតជាដើម ។ ម្យ៉ាងទៀត សំរាម លោក ក៏ហៅថា **បិលោតិក** តែដែលឈ្មោះថា សមណៈសំរាមនៅក្នុងសាសនានេះ មិនបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

អ្នករាល់គ្នា គប្បីជាអ្នកព្រមព្រៀងគ្នា បៀសវៀងនូវបុគ្គលនោះចេញ ចូរបោះបង់ចោល ដូចជាគេបោសសំរាមចោល ចូរទាញចេញនូវបុគ្គល អ្នក ប្រព្រឹត្តកខ្វក់ តអំពីនោះទៅ គប្បីបណ្ដេញនូវសមណៈដែលដូចជាអង្កាម មិនមែនជាសមណៈ គ្រាន់តែថា ខ្លួនជាសមណៈចេញ ។ លុះអ្នកទាំងឡាយ បណ្ដេញបុគ្គលអ្នកប្រាថ្នាអាក្រក់ មានអាចារៈ និងគោចរអាក្រក់បានហើយ ជាអ្នកបរិសុទ្ធ សម្រេចការនៅជាមួយនឹងបុគ្គលបរិសុទ្ធ អ្នកមានសេចក្ដី គោរព កោតក្រែងគ្នា តទៅនឹងជាអ្នកព្រមព្រៀងគ្នា មានប្រាជ្ញាចាស់ក្លា ធ្វើ

នូវទីបំផុតនៃទុក្ខបាន ។ ធម៌នេះ រមែងឈ្មោះថា សំពត់ដាច់ដាច ព្រោះដាច់សមណៈសំរាម ដោយប្រការដូច្នេះ ។

បទថា **វដ្ដន្តេសំ នត្ថិ បញ្ញាបនាយ** សេចក្ដីថា វដ្ដៈនៃភិក្ខុទាំងនោះដល់នូវការមិនមានបញ្ញត្ត រកបញ្ញត្តិមិនបាន ។ ព្រះមហាខីណាស្រពបែបនោះរមែងកើតឡើងក្នុងសាសនា ដែលព្រះមានព្រះភាគត្រាស់ល្អហើយយ៉ាងនេះប៉ុណ្ណោះ ។ ព្រះខីណាស្រពយ៉ាងណា ព្រះអរិយបុគ្គល មានអនាគាមីជាដើមក៏យ៉ាងនោះ ។ បណ្ដាព្រះអរិយបុគ្គលទាំងនោះ ព្រះអរិយបុគ្គល ២ នេះគឺធម្មានុសារី សទ្ធានុសារី រមែងជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ។ ដូចដែលលោកពោលថា បុគ្គលជាធម្មានុសារី តើដូចម្ដេច ។ បុគ្គលណាកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតបត្តិផល មានឥន្ទ្រិយគឺបញ្ញាដ៏ក្រៃលែងចម្រើនអរិយមគ្គ មានបញ្ញាជាគ្រឿងនាំ មានបញ្ញាជាប្រធាន នេះហៅថាបុគ្គលជាធម្មានុសារី ។ បុគ្គលកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតា-បត្តិផល ឈ្មោះថាធម្មានុសារី ។ ឯបុគ្គលឋិតនៅក្នុងផល ឈ្មោះថាទិដ្ឋិប្បត្តៈ ។ បុគ្គលជាសទ្ធានុសារី តើដូចម្ដេច ។ បុគ្គលណាប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឥន្ទ្រិយ គឺសទ្ធាដ៏ក្រៃលែង ចម្រើនអរិយមគ្គមានសទ្ធាជាគ្រឿងនាំ មានសទ្ធាជាប្រធាន នេះហៅថាបុគ្គលជាសទ្ធានុសារី ។ បុគ្គលកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថាសទ្ធា-នុសារី ។ ឯបុគ្គលឋិតនៅក្នុងផល ឈ្មោះថាសទ្ធាវិមុត្តិ ។ ដោយបទថា **យេសំ មយិ សទ្ធាមត្តំ បេមមត្តំ** នេះ លោកបំណាងយកពួកបុគ្គលដែល

ចម្រើនវិបស្សនា ដែលមិនមានអរិយធម៌ដទៃ មានត្រឹមតែការជឿ ត្រឹមតែការស្រឡាញ់ក្នុងព្រះតថាគតប៉ុណ្ណោះ ។ ពិតហើយ ពួកភិក្ខុអង្គុយផ្ដើមវិបស្សនា កើតការជឿ ១ សេចក្ដីស្រឡាញ់ ១ ក្នុងព្រះទសពល បុគ្គលដែលមានការជឿនោះ ការស្រឡាញ់នោះ ដូចចាប់ដៃទៅដាក់ក្នុងស្ថានសួគ៌ ។ បានឮថា ភិក្ខុទាំងនោះមានគតិទៀង ។ ឯព្រះថេរៈចាស់ៗ ហៅភិក្ខុទាំងនោះថា ព្រះចូឡសោតាបន្ន ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើងាយយល់ហើយ ៕

**អលគទ្ទូបមសូត្រ ចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## វម្មិកសូត្រទី ៣

[ ២៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះកុមារកស្សបមានអាយុ នៅក្នុងអន្ធវ័ន ( ព្រៃជាទីនៅនៃពួកចោរខ្វាក់ភ្នែក ) ។ គ្រានោះឯង ទេវតាមួយអង្គ មានសម្បុរល្អ ( មក ) ក្នុងវេលារាត្រី គឺមជ្ឈិមយាមកន្លងទៅហើយ បញ្ចេញរស្មីឲ្យភ្លឺក្នុងអន្ធវ័នទាំងអស់ ក៏ចូលទៅរកព្រះកុមារកស្សបមានអាយុ លុះចូលទៅដល់ហើយ ទើបឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះកុមារកស្សបមានអាយុថា ភិក្ខុ ភិក្ខុ ដំបូកនេះហុយផ្សែងក្នុងពេលយប់ ឆេះក្នុងពេលថ្ងៃ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ ចូរអ្នកយកសស្ត្រាមកជីកដំបូកនេះមើល ។ សុមេធ យកសស្ត្រាមកជីក ជីកទៅក៏បានឃើញសន្ទះទ្វារកង់ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សន្ទះទ្វារកង់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ ចូរអ្នកលើកសន្ទះទ្វារកង់ចេញហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញសត្វហ៊ឺង ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សត្វហ៊ឺង ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកសត្វហ៊ឺងចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញផ្លូវបែកជា ២ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន ផ្លូវបែកជា ២ ។ ព្រាហ្មណ៍បានពោល

យ៉ាងនេះថា ម្នាលសុមេធ ចូរអ្នកលើកផ្លូវបែកជា ២ ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញសំពត់តម្រងក្បុង ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សំពត់តម្រងក្បុង ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកសំពត់តម្រងក្បុងចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញអណ្តើក ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន អណ្តើក ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកអណ្តើកចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញកាំបិត និងជ្រញ់ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន កាំបិត និងជ្រញ់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកកាំបិត និងជ្រញ់ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញដុំសាច់ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន ដុំសាច់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកដុំសាច់ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញនាគ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន នាគ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា នាគទុកឲ្យនៅចុះ អ្នកកុំបៀតបៀននាគឡើយ អ្នកចូរថ្វាយបង្គំនាគចុះ ។ ម្នាលភិក្ខុ លោកចូរនាំយកប្រស្នាទាំង ១៥ នេះ ទៅក្រាបទូលសួរព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ព្យាករប្រាប់លោក យ៉ាងណា លោកត្រូវកំណត់ចាំទុកនូវសេចក្តីនោះយ៉ាងនោះ ។ ម្នាលភិក្ខុ ក្នុងលោក ព្រមទាំងទេវតា ព្រមទាំងមារ ព្រមទាំង

ព្រហ្ម ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិ-ទេព និងមនុស្សដ៏សេស យើងមិនដែលឃើញអ្នកណាមួយ ឆ្លើយប្រស្នាទាំងនេះត្រូវចិត្តបានឡើយ វៀរលែងតែព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ឬក៏អ្នកដែលស្តាប់អំពីសំណាក់នៃព្រះតថាគតនេះ ។ ទេវតានោះបានពោលនូវពាក្យនេះ លុះពោលនូវពាក្យនេះហើយ ក៏បាត់អំពីទីនោះទៅ ។

[ ២៨ ] លុះរាត្រីនោះកន្លងហើយ គ្រានោះឯង ព្រះកុមារកស្សបមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះកុមារកស្សបមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យប់មិញនេះ មានទេវតាមួយអង្គ មានសម្បុរល្អ ( មក ) ក្នុងវេលារាត្រី គឺមជ្ឈិមយាមកន្លងទៅហើយ បញ្ចេញរស្មីឲ្យភ្លឺក្នុងអន្ធវ័នទាំងអស់ ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ឋិតនៅក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ បាននិយាយពាក្យនេះនឹងខ្ញុំព្រះអង្គដូច្នេះថា ភិក្ខុ ភិក្ខុ ដំបូកនេះហុយផ្សែងក្នុងពេលយប់ ឆេះក្នុងពេលថ្ងៃ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរយកសស្ត្រាមកជីក ។ សុមេធយកសស្ត្រាជីកទៅ ក៏បានឃើញសន្ទះទ្វារកង់ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សន្ទះទ្វារកង់ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា ម្នាលសុមេធ អ្នកចូរលើកសន្ទះទ្វារកង់ចេញ ហើយយកសស្ត្រាជីកទៀត ។ សុមេធយកសស្ត្រាជីកទៅ ក៏ឃើញ

សត្វហ៊ីង ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន សត្វហ៊ីង ។បេ។ បានឃើញនាគ ហើយប្រាប់ថា បពិត្រអ្នកដ៏ចម្រើន នាគ ។ ព្រាហ្មណ៍បានពោលយ៉ាងនេះថា នាគទុកឲ្យនៅចុះ អ្នកកុំបៀតបៀននាគឡើយ ចូរធ្វើការនមស្ការនាគចុះ ។ នែភិក្ខុ លោកគប្បីចូលទៅរកព្រះមានព្រះភាគ ហើយសួរប្រស្នាទាំង ១៥ នេះឯង ព្រះមានព្រះភាគ ទ្រង់ព្យាករប្រាប់លោកយ៉ាងណា លោកគប្បីចាំទុកនូវប្រស្នានោះយ៉ាងនោះចុះ ។ នែភិក្ខុ ក្នុងលោក ព្រមទាំងទេវតា ព្រមទាំងមារ ព្រមទាំងព្រហ្ម ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស យើងមិនដែលឃើញអ្នកណាមួយឆ្លើយប្រស្នាទាំងនេះឲ្យត្រូវចិត្តបានឡើយ វៀរលែងតែព្រះតថាគត ឬសាវករបស់ព្រះតថាគត ឬក៏អ្នកដែលបានស្តាប់អំពីសំណាក់នៃព្រះតថាគតនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ទេវតានោះបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏បាត់អំពីទីនោះទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ហៅថា ដំបូក អ្វីហុយផ្សែងក្នុងពេលយប់ អ្វីឆេះក្នុងពេលថ្ងៃ អ្នកណាជាព្រាហ្មណ៍ អ្នកណាជាសុមេធ អ្វីជាសស្ត្រា អ្វីជាការជីក អ្វីជាសន្ទះទ្វារកង់ អ្វីជាសត្វហ៊ីង អ្វីជាផ្លូវបែកជាពីរ អ្វីជាសំពត់តម្រងក្បុង អ្វីជាអណ្តើក អ្វីជាកាំបិត និងជ្រញ់ អ្វីជាដុំសាច់ អ្វីជានាគ ។

[ ២៩ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា ដំបូកនេះជាឈ្មោះរបស់កាយនេះ ដែលប្រកបដោយមហាភូតរូប ៤ កើតព្រមព្រោះទឹកសុក្កៈរបស់មាតា និងបិតា ចម្រើនដោយសារបាយ និងនំ មានសភាវៈមិន

ទៀង មានការជុសខាត់បំបាត់ក្លិនអាក្រក់ និងគក់ប្របាច់ និងកិរិយាបែកធ្លាយ ខ្ចាត់ខ្ចាយជាធម្មតា ។ ម្នាលភិក្ខុ ត្រង់ប្រស្នាថា អ្វីហុយផ្សែងក្នុងពេលយប់ សេចក្តីថា បុគ្គលប្រារព្ធការងារក្នុងពេលថ្ងៃ ហើយដល់ពេលយប់ ត្រិះរិះពិចារណារឿយៗ ដោយហេតុណា ហេតុនេះហៅថា ហុយផ្សែងក្នុងពេលយប់ ។ ម្នាលភិក្ខុ ត្រង់ប្រស្នាថា អ្វីឆេះក្នុងពេលថ្ងៃ សេចក្តីថា បុគ្គលត្រិះរិះពិចារណារឿយៗ ក្នុងវេលាយប់ ហើយដល់វេលាថ្ងៃ ក៏ប្រកបការងារដោយកាយវាចា ដោយហេតុណា ហេតុនេះហៅថា ឆេះក្នុងវេលាថ្ងៃ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ព្រាហ្មណ៍នេះ ជាឈ្មោះរបស់ព្រះតថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សុមេធ នេះជាឈ្មោះរបស់ភិក្ខុជាសេក្ខបុគ្គល ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សស្ត្រា នេះជាឈ្មោះរបស់ប្រាជ្ញាដ៏ប្រសើរ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ជីក នេះជាឈ្មោះរបស់ការប្រារព្ធព្យាយាម ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សន្ទះទ្វារកង់ នេះជាឈ្មោះរបស់អវិជ្ជា ។ ម្នាលសុមេធ អ្នកចូរលើកសន្ទះទ្វារកង់ចេញ គឺថាអ្នកចូរលះបង់អវិជ្ជាចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សត្វហ៊ឹង នេះជាឈ្មោះរបស់សេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត ។ ម្នាលសុមេធ អ្នកចូរលើកហ៊ឹងចេញ គឺថាអ្នកចូរលះបង់សេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្តចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ផ្លូវបែកជាពីរ នេះជាឈ្មោះរបស់វិចិកិច្ឆា ។ ម្នាលសុមេធ អ្នកចូរលើកនូវផ្លូវបែកជាពីរចេញ

គឺថាអ្នកចូរលះបង់វិចិកិច្ឆាចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា សំពត់តម្រងក្បុង នេះជាឈ្មោះរបស់នីវរណធម៌ទាំង ៥ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ម្នាលសុមេធ អ្នកចូរលើកសំពត់តម្រងក្បុងចេញ គឺថាអ្នកចូរលះបង់នីវរណធម៌ទាំង ៥ ចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា អណ្តើក នេះជាឈ្មោះរបស់ឧបាទានក្ខន្ធទាំង ៥ ឧបាទានក្ខន្ធទាំង ៥ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូ-បាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលសុមេធ អ្នកចូរលើកអណ្តើកចេញ គឺថា អ្នកចូរលះបង់ឧបាទានក្ខន្ធទាំង ៥ ចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា កាំបិត និងជ្រញ់ នេះជាឈ្មោះរបស់កាមគុណទាំង ៥ គឺរូបដែលបុគ្គលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាមជាទីតាំងនៃតម្រេក ១ សំឡេងដែលបុគ្គលគប្បីដឹងដោយត្រចៀក ... ១ ក្លិនដែលបុគ្គលគប្បីដឹងដោយច្រមុះ ... ១ រសដែលបុគ្គលគប្បីដឹងដោយអណ្តាត ... ១ ផ្សព្វដែលបុគ្គលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃតម្រេក ១ ។ ម្នាលសុមេធ អ្នកចូរលើកកាំបិត និងជ្រញ់ចេញ គឺថា អ្នកចូរលះបង់កាមគុណទាំង ៥ ចេញ ហើយយកសស្ត្រា

ជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា ជុំសាច់ នេះជាឈ្មោះរបស់នន្ទិរាគៈ ( សេចក្តីត្រេកត្រអាល ) ។ ម្នាលសុមេធ អ្នកចូរលើកជុំសាច់ចេញ គឺថាអ្នកចូរលះបង់នន្ទិរាគៈចេញ ហើយយកសស្ត្រាជីកទៀត នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ម្នាលភិក្ខុ ត្រង់ពាក្យថា នាគ នេះជាឈ្មោះរបស់ភិក្ខុដែលជាព្រះខីណាស្រព ។ នាគចូរឋិតនៅចុះ អ្នកកុំបៀតបៀននាគឡើយ អ្នកចូរធ្វើនូវការនមស្ការនាគចុះ នេះជាសេចក្តីអធិប្បាយនៃពាក្យនុ៎ះ ។ ព្រះមានព្រះភាគ ទ្រង់បានសម្តែងនូវសូត្រនេះចប់ហើយ ព្រះកុមារកស្សបមានអាយុ ក៏មានចិត្តត្រេកអរ រីករាយហើយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

## វម្មិកសូត្រទី ៣ ចប់

# អដ្ឋកថា

## វម្មិកសូត្រទី ៣

[ ២៧ ] វម្មិកសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ។ គប្បីជ្រាបវិនិច្ឆ័យក្នុងវម្មិកសូត្រនោះដូច្នេះ បទថា **អាយស្មា** នេះ ជាពាក្យសម្តែងដល់សេចក្តីស្រឡាញ់ ។ បទថា **កុមារកស្សបោ** ជាឈ្មោះរបស់លោក ។ តែព្រោះលោកបួសក្នុងគ្រានៅក្មេង កាលព្រះមានព្រះភាគត្រាស់ថា ចូរហៅកស្សបមក ចូរឲ្យផ្លែឈើ ឬរបស់ទំពានេះដល់កស្សប ភិក្ខុទាំងឡាយក៏សង្ស័យថា កស្សបណាហ្ន៎ ទើបថ្វាយនាមលោកយ៉ាងនេះថា កុមារកស្សប តាំងអំពីនោះមក ក្នុងវេលាដែលលោកចាស់ជរា ក៏នៅតែហៅថា កុមារ-កស្សបនោះឯង ។ មួយវិញទៀត មនុស្សទាំងឡាយសម្គាល់លោកថា កុមារ-កស្សប ព្រោះជាកូនចិញ្ចឹមរបស់ព្រះរាជា ។ នឹងពោលឲ្យជាក់ច្បាស់តាំងអំពីបុព្វយោគរបស់លោកដូចតទៅនេះ

បានឮមកថា ព្រះថេរៈជាបុត្រសេដ្ឋី កាលព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ ថ្ងៃមួយ ព្រះថេរៈឃើញព្រះមានព្រះភាគ ទ្រង់ស្ថាបនាសាវករបស់ព្រះអង្គមួយរូប ដែលជាអ្នកពោលធម៌បានវិចិត្រ ទុកក្នុងឋានន្តរ បានថ្វាយទាន ៧ ថ្ងៃដល់ព្រះមានព្រះភាគ ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គគប្បីជាសាវក អ្នកពោលធម៌ដ៏វិចិត្រដូចព្រះថេរៈអង្គនេះរបស់ព្រះពុទ្ធមួយអង្គក្នុងអនាគតកាល ដូច្នេះហើយ ធ្វើបុណ្យទាំងឡាយ បួសក្នុងព្រះសាសនានៃព្រះមានព្រះភាគកស្សប មិនអាចធ្វើគុណវិសេសឲ្យកើតឡើងបាន ។ បាន

ព្ធថា ក្នុងកាលសាសនានៃព្រះមានព្រះភាគបរិនិព្វានហើយ សាសនាព្រះជិនស្រីក៏សាបសូន្យថយចុះ ភិក្ខុ ៥ រូប ចងជណ្ដើរឡើងភ្នំ ធ្វើសមណធម៌ ។ ព្រះសង្ឃត្ថេរសម្រេចអរហត្តក្នុងថ្ងៃទី ៣ ។ ព្រះអនុថេរៈ ជាព្រះអនាគាមីក្នុងថ្ងៃទី ៤ ។ ឯព្រះថេរៈ ៣ រូប មិនអាចធ្វើគុណវិសេសឲ្យកើត ក៏ទៅកើតក្នុងទេវលោក ។ កាលទេវតាទាំងនោះ សោយសម្បត្តិក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ទេវបុត្រមួយអង្គទៅកើតក្នុងរាជត្រកូល ក្រុងតក្កសិលា ជាព្រះរាជា ឈ្មោះថា បុក្កុសាតិ បួសឧទ្ទិសចំពោះព្រះមានព្រះភាគមកកាន់ក្រុងរាជគ្រឹះ ស្ដាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ត្រង់រោងស្មូនឆ្នាំង សម្រេចអនាគាមិផល ។ មួយអង្គទៀត កើតក្នុងត្រកូលមួយជិតកំពង់ទូក ឈ្មោះ សុប្បារកៈ ឡើងសំពៅ សំពៅក៏បែកធ្លាយ ស្លៀកកំណាត់ឈើជំនួសសំពត់ លាភសម្បត្តិក៏កើតឡើង លោកគិតថា អញជាព្រះអរហន្ត ត្រូវទេវតាដែលជាអ្នកមានបំណងល្អជាស់តឿនថា លោកមិនមែនជាព្រះអរហន្តទេ ទៅទូលសួរបញ្ហានឹងព្រះសាស្ដាចុះ ក៏បានធ្វើយ៉ាងនោះសម្រេចអរហត្តផល ។ មួយអង្គទៀត កើតក្នុងផ្ទៃរបស់ស្ត្រីមានត្រកូលម្នាក់ក្នុងក្រុងរាជគ្រឹះ ។ នាងបានអង្វរមាតាបិតា កាលមិនបានបួសក៏រៀបការ មិនដឹងថាខ្លួនមានគភ៌ អង្វរប្ដី ប្ដីអនុញ្ញាត ក៏បួសក្នុងសម្នាក់ភិក្ខុនី ។ ភិក្ខុនីទាំងឡាយឃើញនាងមានគភ៌ ទើបសួរទេវទត្តភិក្ខុ ។ ទេវទត្តឆ្លើយថា នាងមិនមែនជាសមណីទេ ។ ទើបពួកភិក្ខុនីទៅសួរព្រះទសពល ។ ព្រះសាស្ដាឲ្យព្រះឧបាលីទទួលវិនិច្ឆ័យ ព្រះថេរៈឲ្យអញ្ជើញត្រកូល អ្នកនគរសាវត្ថី និង

នាងវិសាខាឧបាសិកា ឲ្យជួយជម្រះ ឲ្យដឹងការពិតហើយ ទើបពោលថា នាងមានគភ៌មកអំពីមុន ទើបមិនខូចបព្វជ្ជា ។ ព្រះសាស្តា ប្រទានសាធុការដល់ព្រះថេរៈថា ឧបាលីវិនិច្ឆ័យអធិករណ៍ប្រពៃហើយ ។ ភិក្ខុនីនោះប្រសូតបុត្រមានពណ៌ដូចមាស ។ ព្រះបាទបសេនទិកោសល ទ្រង់ទទួលកុមារនោះមកចិញ្ចឹម ។ ប្រទាននាមកុមារនោះថា កស្សប ក្រោយមក ទ្រង់ចិញ្ចឹមចម្រើនវ័យនាំទៅកាន់សម្នាក់ព្រះសាស្តា បានបព្វជ្ជា ។ ដូច្នោះ ទើបមនុស្សទាំងឡាយសម្គាល់ឈ្មោះក្មេងនោះថា កុមារកស្សប ព្រោះជាកូនចិញ្ចឹមរបស់ព្រះរាជា ដូច្នេះ ។

បទថា **អន្ធវនេ** បានដល់ ព្រៃមានឈ្មោះយ៉ាងនេះ ។ បានឮថា ព្រៃនោះ មានឈ្មោះយ៉ាងនេះ ក្នុងពុទ្ធុប្បាទ ២ ព្រះអង្គ ប្រាកដឈ្មោះថា អន្ធវននោះឯង ។ ក្នុងព្រៃអន្ធវននោះ នឹងធ្វើរឿងរ៉ាវឲ្យជាក់ច្បាស់ដូចតទៅនេះ

ពិតហើយ សរីរធាតុរបស់ព្រះពុទ្ធដែលមានព្រះជន្មាយុតិច មិនជាដុំតែមួយ រមែងបែកខ្ចាត់ខ្ចាយទៅ ដោយអានុភាពនៃអធិដ្ឋាន ។ ដោយហេតុនោះឯង ព្រះមានព្រះភាគនៃយើងទាំងឡាយ អធិដ្ឋានថា តថាគតតាំងនៅមិនបានយឺនយូរ ពួកសត្វមានចំនួនតិចដែលឃើញតថាគត ដែលមិនឃើញតថាគតមានចំនួនច្រើនជាង សត្វទាំងនោះកាន់យកធាតុរបស់តថាគត បូជាក្នុងទីនោះ នឹងមានស្ថានសួគ៌ជាទីទៅខាងមុខ ព្រោះដូច្នោះ កាលបរិនិព្វានសរីរធាតុរបស់តថាគត ចូរបែកតូចៗ ទៅ ។ ចំណែកព្រះពុទ្ធដែលមានព្រះជន្មយឺនយូរ ព្រះសរីរធាតុតាំងនៅទាំងមូលដូចដុំមាស ។ ព្រះសរីរធាតុនៃ

ព្រះមានព្រះភាគព្រះនាមថា កស្សប ក៏តាំងនៅយ៉ាងនោះដូចគ្នា ។ បន្ទាប់ពីនោះ មហាជនក៏ប្រជុំប្រឹក្សាគ្នាថា យើងមិនអាចចែកព្រះធាតុដែលនៅជុំទាំងមូលបាន ពួកយើងនឹងធ្វើដូចម្តេច ទើបព្រមព្រៀងគ្នាថា យើងនឹងធ្វើព្រះធាតុដែលនៅទាំងមូលនោះឯង ឲ្យជាព្រះចេតិយ នឹងមានទំហំប៉ុនណា ។ បុគ្គលមួយពួកប្រាប់ថា ៧ យោជន៍ តែក៏ព្រមព្រៀងគ្នាថា ទំហំនោះធំពេក មិនមានអ្នកណាថែទាំបានក្នុងអនាគតកាល ក៏សម្រេចយក ៦ យោជន៍ ៥ យោជន៍ ៤ យោជន៍ ៣ យោជន៍ ២ យោជន៍ ១ យោជន៍ ពិគ្រោះគ្នាថា ប្រើឥដ្ឋទំហំប៉ុនណា ក៏ព្រមព្រៀងគ្នាថា ខាងក្រៅជាឥដ្ឋមួយដុំៗ ធ្វើដោយមាស មានតម្លៃមួយសែន ខាងក្នុងមានតម្លៃ៥ ម៉ឺន បូកលាបដោយហរតាលនិងមនោសីលាជំនួសដី លាយដោយប្រេងជំនួសទឹក បែងចែកមុខទាំង ៤ តាមទិសទាំង ៤ ។ ព្រះរាជាទ្រង់ទទួលមុខមួយ បថវិន្ធរកុមាររាជបុត្រទទួលមុខមួយ សេនាបតីដែលជាប្រធាននៃអមាត្យទទួលមុខមួយ សេដ្ឋីដែលជាប្រមុខនៃមហាជនទទួលមុខមួយ ។ បណ្តាជនទាំងនោះ ព្រោះជាអ្នកសម្បូរដោយទ្រព្យ សូម្បីព្រះរាជាឲ្យជញ្ជូនមាសមក ទ្រង់ផ្តើមធ្វើត្រង់មុខដែលព្រះអង្គទទួល ឧបរាជក្តី សេនាបតីក្តីក៏ដូចគ្នា ។ ចំណែកការៈត្រង់មុខដែលសេដ្ឋីទទួលក៏ស្បើយ ។ កាលនោះឧបាសកម្នាក់ ឈ្មោះយសោធរៈ ជាអរិយ-សាវកថ្នាក់អនាគាមី ទ្រទ្រង់ព្រះត្រៃបិដក ដឹងថា សេដ្ឋីនោះស្បើយថវិកាទើបឲ្យទឹមរទេះ ៥០០ ទៅក្នុងជនបទ បបួលមនុស្សទាំងឡាយថា ព្រះ-កស្សបសម្មាសម្ពុទ្ធ ទ្រង់ព្រះជន្ម ២ ម៉ឺនឆ្នាំ បរិនិព្វានយូរហើយ ពួកយើង

នឹងធ្វើវតនចេតិយមួយយោជន៍របស់ព្រះអង្គ បុគ្គលណាអាចឲ្យវត្ថុណា ទោះជាមាស ឬប្រាក់ កែវ ៧ ប្រការ ហរតាល ឬមនោសិលាក៏ដោយ បុគ្គលនោះចូរឲ្យវត្ថុនោះ ។ ជនទាំងឡាយបានឲ្យប្រាក់ និងមាសជាដើមតាមកម្លាំងរៀងៗ ខ្លួន កាលមិនមានសមត្ថភាព ក៏ឲ្យប្រេង និងអង្ករជាដើមប៉ុណ្ណោះ ។ ឧបាសកបញ្ជូនប្រេង និងអង្ករជាដើម ដើម្បីជាអាហារប្រចាំថ្ងៃ ដល់កម្មករទាំងឡាយ ពួកមនុស្សដ៏សេសឲ្យត្រាច់ទៅប្រកាសពេញជម្ពូទ្វីបដោយអាការយ៉ាងនេះ ។ ការងារព្រះចេតិយស្រេចហើយ ព្រោះដូច្នោះ ពួកជនទាំងនោះបញ្ជូនសំបុត្រទៅអំពីចេតិយដ្ឋានថា ការងារស្រេចហើយ សូមអាចារ្យអញ្ជើញមកថ្វាយបង្គំព្រះចេតិយ សូម្បីអាចារ្យក៏បញ្ជូនសំបុត្រទៅថា ខ្ញុំនឹងបបួលអ្នកជម្ពូទ្វីបទាំងអស់ វត្ថុណាដែលមាន ចូរយកវត្ថុនោះធ្វើការងារឲ្យសម្រេច ។ សំបុត្រទាំងពីរមកជួបគ្នាត្រង់ចន្លោះផ្លូវ តែសំបុត្រខាងចេតិយ-ដ្ឋានមកដល់ដៃរបស់អាចារ្យមុនសំបុត្ររបស់អាចារ្យ ។ អាចារ្យនោះ អានសំបុត្រហើយ គិតថា នឹងថ្វាយបង្គំព្រះចេតិយ ក៏ចេញទៅតាមគាប់ចិត្ត ។ ក្នុងចន្លោះផ្លូវ ចោរ ៥០០ ក៏ប្រាកដឡើងត្រង់ព្រៃជ្រៅ ។ បណ្តាចោរទាំងនោះ ពួកខ្លះឃើញអាចារ្យនោះ គិតថា អាចារ្យនេះប្រមូលមាស និងប្រាក់អំពីជម្ពូទ្វីបទាំងមូល មនុស្សទាំងឡាយដែលរក្សាទ្រព្យគង់មកជាមួយ ទើបប្រាប់ដល់ចោរដ៏សេស ហើយចាប់អាចារ្យនោះ ។ អាចារ្យសួរថា បាអើយហេតុអ្វី ទើបពួកអ្នកចាប់ខ្ញុំ ពួកចោរឆ្លើយថា លោកប្រមូលមាស និងប្រាក់ទាំងអស់អំពីជម្ពូទ្វីប ចូរឲ្យទ្រព្យបន្តិចបន្តួចដល់ពួកខ្ញុំចុះ ។ អាចារ្យសួរថា

ពួកអ្នកមិនដឹងទេឬថា ព្រះពុទ្ធព្រះនាមកស្សបបរិនិព្វានហើយ ពួកខ្ញុំកំពុងសាងរតនចេតិយមួយយោជន៍សម្រាប់ព្រះអង្គ ឯខ្ញុំបបួលគេដើម្បីប្រយោជន៍នោះ មិនមែនដើម្បីប្រយោជន៍របស់ខ្លួន ដូច្នោះ ខ្ញុំបញ្ជូនរបស់ដែលរក្សាទុកហើយ ទៅក្នុងទីនោះឯង ឯទ្រព្យក្រៅអំពីសំពត់ដែលស្លៀកមក ក៏មិនមានអ្វីដទៃ សូម្បីតែមួយកាកណិក ។ ចោរម្នាក់ពោលថា សេចក្តីពិតយ៉ាងនោះ ក៏សូមលែងអាចារ្យនោះទៅ ។ ចោរម្នាក់ពោលថា អាចារ្យនេះ ព្រះរាជាក៏បូជា អមាត្យក៏បូជា ឃើញបុគ្គលខ្លះក្នុងចំណោមពួកយើងត្រង់ផ្លូវព្រះនគរ គប្បីប្រាប់ព្រះរាជា និងអមាត្យរបស់ព្រះរាជាជាដើម នឹងធ្វើឲ្យពួកយើងដល់នូវការលំបាកបាន ។ ឧបាសកពោលថា បាអើយ ខ្ញុំមិនធ្វើយ៉ាងនោះទេ ការពោលនេះមានដោយសេចក្តីករុណាក្នុងចោរទាំងនោះ មិនមែនមានដោយការស្រឡាញ់ក្នុងជីវិតរបស់ខ្លួនឡើយ ។ កាលបើដូច្នោះ បណ្តាចោរទាំងនោះ ដែលកំពុងជជែកគ្នាថា គួរចាប់ គួរដោះលែងទៅ ពួកចោរដែលមានការយល់ឃើញថា គួរចាប់មានចំនួនច្រើនជាង ក៏សម្លាប់អាចារ្យនោះ ។ ភ្នែករបស់ពួកចោរទាំងនោះ ក៏អន្តរធានទៅ ដូចប្រទីបដែលរលត់ ព្រោះធ្វើខុសក្នុងព្រះអរិយសាវ័ក ដែលប្រកបដោយពលគុណ ។ ចោរទាំងនោះកន្ទក់កន្ទេញថា ភ្នែកខ្ញុំនៅឯណា ភ្នែកខ្ញុំនៅឯណា ពួកខ្លះ ញាតិក៏នាំត្រឡប់ទៅស្រុក ពួកចោរដែលមិនមានញាតិ ក៏ក្លាយជាមនុស្សអនាថា ព្រោះដូច្នោះទើបអាស្រ័យនៅត្រង់បណ្ណសាលា ត្រង់គល់ឈើក្នុងព្រៃនោះឯង ។ ពួកមនុស្សដែលមកក្នុងព្រៃ ក៏ឲ្យអង្ករខ្លះ កញ្ចប់បាយខ្លះ ស្បៀងខ្លះ ដល់ចោរ

ទាំងនោះ ដោយសេចក្ដីករុណា ។ ពួកមនុស្សដែលទៅស្វែងរកឈើ និងស្លឹកឈើជាដើម ត្រឡប់មកហើយ កាលមានគេសួរថា ពួកអ្នកទៅណាហ្ន៎ ក៏ឆ្លើយថា ទៅព្រៃមនុស្សខ្វាក់ ។ ព្រៃនោះក៏ប្រាកដឈ្មោះថា អន្ធវន ក្នុងពុទ្ធុប្បាទនៃព្រះពុទ្ធ ២ អង្គ ដោយប្រការដូច្នេះ ។

ព្រៃនោះ កាលព្រះពុទ្ធព្រះនាមថា កស្សប បានក្លាយជាព្រៃស្អុក ក្នុងជនបទដែលគេបោះបង់ចោល ។ តែកាលព្រះមានព្រះភាគនៃយើង បានក្លាយជាទីកន្លែងសម្រាប់ធ្វើសេចក្ដីព្យាយាម ជាទីលំនៅរបស់ពួកកុលបុត្រដែលត្រូវការស្ងប់ស្ងាត់ នៅខាងក្រោយវត្តជេតពន មិនឆ្ងាយអំពីក្រុងសាវត្ថី ។ សម័យនោះ ព្រះកុមារកស្សបក៏បំពេញសេក្ខប្បដិបទា ត្រង់អន្ធវននោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អន្ធវនេ វិហរតិ** ។

បទថា **អញ្ញតរា ទេវតា** បានដល់ ទេវតាមួយអង្គមានឈ្មោះ និងគោត្រមិនប្រាកដ ។ សូម្បីសក្កទេវរាជ ដែលយើងស្គាល់ច្បាស់ លោកក៏ហៅថា **អញ្ញតរោ** ក្នុងបាលីថា បពិត្រព្រះអង្គដ៏ចម្រើនព្រះមានព្រះភាគធ្លាប់បានសម្ដែងនូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហាដោយសង្ខេប ជាគ្រឿងតង្វាយដល់ទេវតា ដែលមានសក្តិធំមួយរូបឬទេ ។ សូម្បីពាក្យថា ទេវតានេះ ក៏ជាពាក្យហៅទូទៅ សម្រាប់ទេវតាទាំងឡាយ ។ តែក្នុងទីនេះ លោកបំណងយកពួកទេព ក្នុងពាក្យថា ទេវតានោះ ។ **អភិក្កន្ត** សព្ទ ក្នុងបទថា **អភិក្កន្តាយ រត្តិយា** ប្រាកដក្នុងអត្ថទាំងឡាយមានអស់ទៅ ល្អ ស្អាត និងការត្រេកអរក្រៃលែងជាដើម ។ ក្នុងអត្ថទាំង

នោះ **អភិក្កន្ត** សព្ទ ដែលប្រាកដក្នុងអត្ថថាអស់ទៅ ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ** បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីបឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ ។ ប្រាកដក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថា ល្អជាងផង ប្រសើរជាងផង ។ ប្រាកដក្នុងអត្ថថា ស្អាត ដូចក្នុងប្រយោគជាដើមថា **កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា** អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ និងយស មានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។ ប្រាកដក្នុងអត្ថថា ត្រេកអរក្រៃលែង ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តំ ភន្តេ** បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ ។ តែក្នុងទីនេះ **អភិក្កន្ត** សព្ទ ប្រាកដក្នុងអត្ថថា អស់ទៅ ។ ព្រោះហេតុនោះ បទថា **អភិក្កន្តាយ រត្តិយា** ទើបលោកអធិប្បាយថា កាលរាត្រីអស់ទៅហើយ ។ ក្នុងសេចក្តីនោះគប្បីជ្រាបថា ទេវបុត្រនេះមកក្នុងចន្លោះមជ្ឈិមយាម ។

**អភិក្កន្ត** សព្ទ ក្នុងបទថា **អភិក្កន្តវណ្ណា** នេះ ប្រាកដក្នុងអត្ថថា ស្អាត ឯ **វណ្ណ** សព្ទ ប្រាកដក្នុងអត្ថ មានជាដើមថា ពណ៌សម្បុរ គួរសរសើរ ពួកត្រកូល ហេតុ សណ្ឋាន ប្រមាណ និងរូបាយតនៈ ។ ក្នុងអត្ថទាំងនោះ **វណ្ណ** សព្ទ ប្រាកដក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងប្រយោគជាដើមយ៉ាងនេះ

ថា **សុវណ្ណវណ្ណោសិ ភគវា** បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានពណ៌សម្បុរដូចមាស ។ ប្រាកដក្នុងអត្ថថា គួរសរសើរ ដូចក្នុងប្រយោគជាដើមនេះថា **កទា សញ្ញូឡ្ហា បន តេ គហបតិ សមណស្ស គោតមស្ស វណ្ណា** នៃគហបតី ក្នុងកាលណាពណ៌សម្បុររបស់ព្រះសមណគោតម ដែលលោកគួរសរសើរ ។ ប្រាកដក្នុងអត្ថថា ពួកត្រកូល ដូចក្នុងប្រយោគជាដើមថា **ចត្តារោ មេ ភោ គោតម វណ្ណា** បពិត្រព្រះគោតមដ៏ចម្រើន ត្រកូលទាំង ៤ នេះ ។ ប្រាកដក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **អថ កេន នុ វណ្ណេន គន្ធថេនោតិ វុច្ចតិ** កាលបើដូច្នេះ ព្រោះហេតុអ្វីហ្ន៎ ទើបអ្នកពោលថា លួចក្លិន ។ ប្រាកដក្នុងអត្ថថា សណ្ឋាន ដូចក្នុងប្រយោគជាដើមថា **មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិនិត្វា** និម្មិតសណ្ឋានជាស្តេចដំរីធំ ។ ប្រាកដក្នុងអត្ថថា ប្រមាណ ដូចក្នុងប្រយោគជាដើមថា **តយោ បត្តស្ស វណ្ណា** បាត្រ ៣ ខ្នាត ។ ប្រាកដក្នុងរូបាយតនៈ ដូចក្នុងប្រយោគជាដើមថា **វណ្ណោ គន្ធោ រសោ ឱជា** រូបាយតនៈ គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ ។ **វណ្ណ** សព្ទនោះ គប្បីឃើញថា ចុះក្នុងអត្ថថា ពណ៌សម្បុរក្នុងទីនេះ ។ ដោយហេតុនោះ បទថា **អភិក្កន្តវណ្ណា** លោកអធិប្បាយថា មានពណ៌សម្បុរស្អាត មានពណ៌សម្បុរគួរប្រាថ្នា គួរពេញចិត្ត ។ ពិតហើយ ទេវតាទាំងឡាយ កាលមកកាន់មនុស្សលោក លះពណ៌សម្បុរប្រក្រតី ឫទ្ធិប្រក្រតី ធ្វើអត្តភាពឲ្យគ្រោតគ្រាត និម្មិតពណ៌សម្បុរលើសប្រក្រតី ឫទ្ធិលើសប្រក្រតី មកដោយកាយដែលតាក់តែងហើយ ដូចមនុស្សទៅកាន់ទីប្រជុំ

គុណគ្រប់គ្រាន់ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ដូច្នេះ ។ មានអត្ថថា មិនប្រកប ដូចក្នុងពាក្យជាដើមថា **កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ** តថាគតពោលថា ជាបុរសឧត្តម មានកិច្ចបានធ្វើអស់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ ។ តែក្នុងទីនេះ លោកបំណងយកអត្ថថា មិនមានចំណែកសេសសល់ ។

ម្យ៉ាងវិញទៀត **កប្ប** សព្ទនេះ មានអត្ថច្រើនយ៉ាង ដូចជាការជឿយ៉ាងស៊ប់លែង វោហារ កាល បញ្ញត្តិ ការកាត់ វិកប្ប លេស ដោយជុំវិញ ។ មានអធិប្បាយថា **កប្ប** សព្ទ មកក្នុងអត្ថថា ការជឿយ៉ាងស៊ប់លែង ដូចក្នុងប្រយោគជាដើមថា **ឱកប្បំ និយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** ពាក្យរបស់ព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនោះ ជាពាក្យគួរជឿពិតហើយ ។ មកក្នុងអត្ថថា វោហារ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្ប ៥ យ៉ាង ។ មកក្នុងអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហរាមិ** តថាគតនោះឯង តែងនៅអស់កាលជានិច្ច ។ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **ឥច្ចាយស្មា កប្បោ** កប្បមាណពដ៏មានអាយុទូលសួរថា ។ មកក្នុងអត្ថថា កាត់ ដូចក្នុងប្រយោគជាដើមថា **អលង្កតោ មាល្យធរោ សុវត្ថោ សុកុណ្ឌលី កប្បិតកេសមស្សុ** អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្តប់ល្អ មានប្រដាប់ត្រចៀកល្អ មានសក់ និងពុកចង្កាកាត់ហើយ ។ មកក្នុងអត្ថថា វិកប្ប

ដូចក្នុងប្រយោគជាដើមថា **កប្បតិ ទុន្ទុលកប្បា** កំណត់ដោយស្រមោលព្រះអាទិត្យថ្ងៃទៅ ប្រមាណពីរធ្នាប់ធ្នូរ ។ មកក្នុងអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និបជ្ជិតុំ** បើដូច្នោះ អាត្មាអញដេកសិន ។ មកក្នុងអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ តិជ្ឈក្ខុដំ ឱភាសេត្វា** ញ៉ាំងកំពឹសក្លួដឲ្យភ្លឺស្វាងដោយជុំវិញ ។ តែក្នុងទីនេះ លោកបំណងយកអត្ថថា ដោយជុំវិញ ព្រោះដូច្នោះ ក្នុងពាក្យថា **កេវលកប្បំ អន្ធវនំ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា ជុំវិញព្រៃអន្ធវ័ន មិនមានចំណែកសេសសល់ ។

បទថា **ឱភាសេត្វា** សេចក្តីថា ផ្សាយទៅដោយរស្មី ដែលកើតឡើងអំពីសរីរៈដែលប្រដាប់ដោយសំពត់ ធ្វើឲ្យមានឱកាស ដូចគ្នានឹងព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **ឯកមន្តំ អដ្ឋាសិ** បានដល់ ឈរក្នុងចំណែកម្ខាង គឺក្នុងឱកាសមួយ ។ បទថា **ឯតទវោច** បានដល់ ត្រាស់នឹងភិក្ខុនោះថា ភិក្ខុ ភិក្ខុ ដូច្នេះជាដើម ។

សួរថា ព្រោះហេតុអ្វី ទេវតានេះមិនថ្វាយបង្គំ ពោលដោយសមណ-វោហារតែម្យ៉ាង ឆ្លើយថា ដោយការហៅដោយសមណសញ្ញា ។ បានឮថា ទេវបុត្រមានការគិតយ៉ាងនេះថា បុគ្គលនេះនៅក្នុងវាងកាមាវចរភូមិ ចំណែកអញជាព្រហ្មចារី តាំងអំពីកាលនោះ ក្នុងវេលានោះ ។ សមណសញ្ញារបស់ទេវបុត្រនោះ នៅប្រាកដនៅឡើយ ព្រោះដូច្នោះ ទើបទេវបុត្រនោះមិនថ្វាយបង្គំ ពោលដោយសមណវោហារតែម្យ៉ាង ។

សួរថា បានឮថា ទេវបុត្រនោះ ជាសម្លាញ់អំពីមុនរបស់ព្រះថេរៈ តាំង

ពីអង្កាល់ណា ឆ្លើយថា តាំងអំពីកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ។ ម្យ៉ាងទៀត បណ្តាសម្លាញ់ទាំង ៥ ដែលមកក្នុងកាលមុន សម្លាញ់ណាដែលលោកពោលថា ព្រះអនុថេរៈបានជាព្រះអនាគាមីក្នុងថ្ងៃទី ៤ សម្លាញ់នោះ គឺទេវតានេះ ។ បានឮថា កាលនោះ បណ្តាព្រះថេរៈទាំងនោះ អភិញ្ញា និងអរហត្តនោះឯង បានមកដល់សង្ឃត្ថេរ ។ ព្រះសង្ឃត្ថេរនោះគិតថា កិច្ចរបស់អញដល់ទីបំផុតហើយ ទើបហោះទៅកាន់នភាកាស ខ្វរមាត់ត្រង់អនោតត្តស្រះទទួលបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ត្រឡប់មកហើយ ពោលថា អ្នកមានអាយុ ចូរឆាន់បិណ្ឌបាតនេះ កុំប្រមាទ ធ្វើសមណធម៌ចុះ ។ ភិក្ខុក្រៅអំពីនេះពោលថា អាវុសោ ពួកយើងមិនមានកតិកាយ៉ាងនេះថា អ្នកណាសម្រេចគុណវិសេសមុន នាំបិណ្ឌបាតមក អ្នកដែលនៅសល់ ឆាន់បិណ្ឌបាតដែលបុគ្គលនោះនាំមក ហើយធ្វើសមណធម៌ លោកម្ចាស់សម្រេចទីបំផុតកិច្ចដោយឧបនិស្ស័យរបស់ខ្លួន បើពួកយើងមានឧបនិស្ស័យ ក៏នឹងសម្រេចទីបំផុតកិច្ចនោះមិនយឺតយូរឡើយ របស់ពួកយើងឯង សូមពួកលោកម្ចាស់ទៅចុះ ។ សង្ឃត្ថេរនោះទៅតាមផាសុក បរិនិព្វានក្នុងកាលដែលអស់អាយុ ។ ស្អែកឡើង ព្រះអនុថេរៈធ្វើឲ្យជាក់ច្បាស់នូវព្រះអនាគាមិផល អភិញ្ញាទាំងឡាយក៏មកដល់លោក ។ លោកក៏នាំបិណ្ឌបាតមកដូចគ្នា ត្រូវភិក្ខុទាំងនោះបដិសេធ ក៏ទៅតាមផាសុក កាលអស់អាយុក៏ទៅកើតក្នុងជាន់សុទ្ធាវាស ។ ព្រះអនុ-ថេរៈនោះ កាលតាំងនៅក្នុងជាន់សុទ្ធាវាសហើយ រំពឹងមើលសម្លាញ់ទាំងនោះឃើញថា សម្លាញ់ម្នាក់បរិនិព្វានក្នុងគ្រានោះឯង សម្លាញ់ម្នាក់សម្រេចអរិយភូមិ

ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ក្នុងកាលមិនយឺតយូរឡើយ ម្នាក់ទៀត អាស្រ័យលាភសក្ការៈ កើតគំនិតឡើងថា អញជាព្រះអរហន្ត នៅត្រង់កំពង់ឈ្មោះសុប្បារកៈនោះឯង ហើយចូលទៅរក បញ្ជូនសម្លាញ់នោះទៅ ដោយពោលថា អ្នកមិនមែនជាព្រះអរហន្តទេ មិនទាន់បដិបត្តិដល់អរហត្តមគ្គទេ សូមទៅគាល់ព្រះមានព្រះភាគស្តាប់ធម៌ចុះ ។ សម្លាញ់នោះទូលសូមឱវាទនឹងព្រះមានព្រះភាគក្នុងចន្លោះស្រុក ព្រះមានព្រះភាគទ្រង់ឲ្យឱវាទដោយសង្ខេបថា ម្នាលពាហិយៈ ព្រោះដូច្នោះឯង អ្នកគប្បីសិក្សាក្នុងវត្ថុដែលអ្នកឃើញហើយថា ត្រឹមតែការឃើញ ក៏សម្រេចអរិយភូមិ ។ សម្លាញ់ម្នាក់ក្រៅអំពីនោះនៅមាន ក៏រំពឹងមើលថា នៅក្នុងទីណាហ្ន៎ ក៏ឃើញថា កំពុងបំពេញសេក្ខប្បដិបទានៅក្នុងអន្តរវ័ន ទើបគិតថា អញនឹងទៅកាន់សម្នាក់របស់សម្លាញ់ តែកាលទៅ មិនទៅដៃទទេ គួរកាន់យកគ្រឿងបណ្ណាការណាមួយទៅផង តែសម្លាញ់របស់អញ មិនមានអាមិសនៅលើកំពូលភ្នំ តែសម្លាញ់នោះនឹងមិនធាន់សូម្បីបិណ្ឌបាត ដែលអញឈរនៅលើអាកាសប្រគេន បានធ្វើសមណធម៌ ឥឡូវនេះ លោកនឹងទទួលអាមិសបណ្ណាការឬ ចាំអាត្មាអញកាន់យកធម្មបណ្ណាការទៅ ហើយតាំងនៅក្នុងព្រហ្មលោកនោះឯង ចែកប្រស្នា ១៥ ចំណុច ដូចដោតរតនវលីកម្រងកែវ កាន់ធម្មបណ្ណាការនោះមកឈរក្នុងទីមិនឆ្ងាយអំពីសម្លាញ់ មិនធ្វើអភិវាទព្រះថេរៈនោះ ពោលដោយសមណ-សញ្ញាថា ភិក្ខុ ភិក្ខុ ទើបពោលថា **អយំ វម្មិកោ** ជាដើម ។ ក្នុងពាក្យនោះគប្បីជ្រាបពាក្យដែលលោកពោលដដែលៗ ថា ភិក្ខុ ភិក្ខុ ដោយរហ័សៗ ។

ថាសរមែនមិនស្អាត ដោយការចុចមួយប៉ុណ្ណោះ លុះបន្ថែមចំណុចដទៃជុំវិញចំណុចនោះ ទើបស្អាត ហាក់ដូចប្រដាប់ដោយកម្រងផ្កាដែលរីក យ៉ាងណា ពាក្យសម្ដីមិនស្អាតដោយបទមួយៗ ប៉ុណ្ណោះ លុះតែប្រកបដោយបទដែលជាបរិវារ ទើបមានលម្អ ដូចការរចនាដោយផ្កាដែលរីក ដូច្នោះ ព្រោះហេតុនោះ ទេវបុត្រនោះធ្វើពាក្យដោយបទបរិវារនោះ ធ្វើឲ្យដូចជាក្រងផ្កាដែលរីក ទើបពោលយ៉ាងនោះ ។

ដែលឈ្មោះថា ដំបូក ដែលតាំងនៅចំពោះមុខមិនមាន តែទេវបុត្រហាក់ដូចជាបង្ហាញដំបូកដែលតាំងនៅចំពោះមុខ ដោយអំណាចទេសនាវិធី ទើបពោលថា **អយំ** ក្នុងបទថា **អយំ វម្មិកោ** ។ បទថា **បលង្គិ** សេចក្ដីថា កាន់សស្ត្រាជីក ជួបសន្ទះទ្វារកង់ ។ បទថា **ឧក្ខិប បលិង្គិ អភិក្ខណ សុមេធ** បានដល់ បណ្ឌិត ។ ឈ្មោះថា សន្ទះទ្វារកង់ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះជាភ្លើង កាលលើកសន្ទះទ្វារកង់ឡើង ជីកបន្ត គប្បីឃើញក្នុងបទទាំងពួងដូចដែលពោលមកនេះ ។ បទថា **ឧទ្ធុមាយិកំ** បានដល់ សត្វហ៊ឹង ។ បទថា **បង្គវារំ** បានដល់ តម្រងក្បុង ។ បទថា **កុម្មំ** បានដល់ អណ្ដើក ។ បទថា **អសិសូនំ** បានដល់ ជ្រញ់ហាន់សាច់ ។ បទថា **មំសបេសី** បានដល់ ដុំសាច់ទំហំប៉ុនថ្មកិន ។ បទថា **នាគំ** បានដល់ ឃើញស្ដេចនាគ ដែលលម្អដោយផ្កាច័ន មានពពារធំ ដូចគ្នានឹងបាច់ផ្កាម្ទេះ ។ បទថា **មា នាគំ ឃដ្ដេសិ** បានដល់ កុំប្រើចុងឈើ ចុងវល្លិ ឬរោយធូលីចូលទៅឲ្យប៉ះពាល់នាគ ។ បទថា **នមោ ករោហិ នាគស្ស** សេចក្ដីថា ចូរចៀសទៅខាងលើខ្យល់ ស្លៀកសំពត់

ស្អាត នមស្ការស្តេចនាគ ឈ្មោះថា ទ្រព្យដែលស្តេចនាគគ្រប់គ្រងលើស ៧ ជួរត្រកូល ក៏ប្រើប្រាស់មិនអស់ ស្តេចនាគនឹងឲ្យទ្រព្យដែលខ្លួនគ្រប់គ្រងដល់អ្នក ព្រោះដូច្នោះ អ្នកចូរនមស្ការដល់ស្តេចនាគ ។ បទថា **ឥតោ វា បន សុត្វា** សេចក្តីថា អស់នូវការសង្ស័យក្នុងកងទុក្ខអំពីសម្នាក់យើងនេះ ព្រោះដូច្នោះ ទើបឈ្មោះថា អស់សេចក្តីសង្ស័យក្នុងសាសនា យ៉ាងណា ក្នុងទីនេះ មិនដូច្នោះឡើយ តែក្នុងទីនេះអស់សេចក្តីសង្ស័យព្រោះទេវបុត្រ ព្រោះដូច្នោះ ទើបសេចក្តីនេះមានអត្ថដូច្នេះថា បទថា **ឥតោ វា បន** បានដល់ ព្រោះស្តាប់អំពីសម្នាក់របស់តថាគតក្តី ។

[ ២៩ ] បទថា **ចាតុម្មហាភូតិកស្ស** បានដល់ សម្រេចដោយមហាភូតទាំង ៤ ។ បទថា **កាយស្ស អធិវចនំ** ប្រែថា ជាឈ្មោះរបស់សរីរៈ ។ ដូចជាកាយខាងក្រៅ លោកហៅថា **វម្មិក** ព្រោះហេតុ ៤ យ៉ាង គឺដំបូករមែងខ្ជាក់ ១ អ្នកខ្ជាក់ ១ អ្នកខ្ជាក់សរីរៈដែលប្រជុំធាតុបួន ១ អ្នកខ្ជាក់ការសម្ពន្ធដោយស្នេហា ១ ពិតហើយ ដំបូកនោះរមែងខ្ជាក់សត្វតូច មានប្រការផ្សេងៗ ដូចជាពស់ ស្ការ កណ្តុរ ពស់ថ្លាន់ជាដើម ព្រោះដូច្នោះ កាយនោះឈ្មោះថា **វម្មិក** ។ កាយដែលកណ្តៀរខ្ជាក់ហើយ ហេតុនោះ ទើបឈ្មោះថា **វម្មិក** ។ កាយដែលកណ្តៀរពូនឡើងដោយធូលី ដែលកណ្តៀរលើកឡើងដោយមាត់ ប្រមាណត្រឹមចង្កេះខ្លះ មួយជួរបុរសខ្លះ ព្រោះដូច្នោះ ទើបឈ្មោះថា **វម្មិក** ។ កាយកាលភ្លៀងធ្លាក់ ៧ សប្តាហ៍ កណ្តៀរកពូន ព្រោះទាក់ទងដោយទឹកមាត់ ដែលខ្ជាក់ចេញ ក្នុងរដូវប្រាំង កណ្តៀរក៏ពាំយកធូលីអំពីទី

នោះ ពូនទីនោះឲ្យជាគំនរ ជ័រស្អិតក៏ចេញ ហើយជាប់គ្នាដោយជ័រស្អិតដែល ខ្ជាក់ ហេតុនោះ ទើបឈ្មោះថា **វម្មិក** យ៉ាងនោះឯង សូម្បីកាយនេះក៏ដូច្នោះ ឈ្មោះថា **វម្មិក** ព្រោះខ្ជាក់របស់មិនស្អាត របស់មានទោស និងមន្ទិល មាន ប្រការផ្សេងៗ ដោយន័យជាដើមថា អាចម៍ភ្នែកចេញអំពីភ្នែកជាដើម និង ឈ្មោះថា **វម្មិក** ព្រោះអរិយៈខ្ជាក់ចោលហើយ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះខីណាស្រពចោលអត្តភាពទៅ ព្រោះអស់នូវការជាប់ជំពាក់ក្នុងអត្តភាព នេះ ។ ឈ្មោះថា **វម្មិក** ព្រោះខ្ជាក់អស់ទាំងសរីរៈដែលប្រជុំធាតុ ៤ ដែល ព្រះអរិយៈខ្ជាក់សរីរៈទាំងអស់ ដែលគំនរឆ្អឹង ៣០០ កំណាត់លើកឡើងចង ដោយសរសៃ បូកលាបដោយសាច់ ពាសដោយស្បែកស្រស់ លាបពណ៌ បោកបញ្ឆោតសត្វទាំងឡាយ ។ ឈ្មោះថា **វម្មិក** ព្រោះចងដោយស្នេហា ដែលខ្ជាក់ចេញហើយ ហេតុកាយនេះ ចងដោយជ័រស្អិត គឺតណ្ហា ដែលព្រះ អរិយៈទាំងឡាយខ្ជាក់ហើយ ព្រោះតណ្ហាញុំាងឲ្យកើត តាមព្រះបាលីយ៉ាង នេះថា តណ្ហាញុំាងបុរសឲ្យកើត ចិត្តរបស់បុគ្គលនោះរមែងស្ទុះទៅ ។ មួយ៉ាង ទៀត សត្វតូចៗ មានប្រការផ្សេងៗ ខាងក្នុងដំបូក រមែងកើតបន្ទោបង់ ឧច្ចារៈ បស្សាវៈ ដេក ឈឺ រមែងស្លាប់នៅក្នុងដំបូកនោះឯង ដូច្នោះ ទើប ដំបូកនោះ ជាផ្ទះកើត ជាបង្គន់ ជារោងព្យាបាល និងជាស្មសានរបស់សត្វ តូចៗ ទាំងនោះ យ៉ាងណា កាយនេះ សូម្បីរបស់ក្សត្រមហាសាលជាដើម ក៏ដូច្នោះ ពួកសត្វដែលអាស្រ័យពណ៌សម្បុរ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង មិនបានគិតថា កាយនេះ ត្រូវគ្រប់គ្រងរក្សាហើយ ប្រដាប់តាក់តែង

ហើយ ជាកាយរបស់អ្នកមានអានុភាពធំ សរុបសេចក្តីថា ពួកជន្លើវដោយការរាប់ត្រកូល មានប្រមាណ ៨ ម៉ឺន ត្រកូល រមែងកើត រមែងបន្ទោបង់ឧច្ចារៈ បស្សាវៈ ដេកពពាក់ពពូន ព្រោះការឈឺថ្កាត់ ស្លាប់នៅក្នុងកាយនេះឯង ហេតុនោះ ទើបរាប់បានថា ជាដំបូក ព្រោះជាបន្ទប់ប្រសូត ជាបន្គន់ជាមន្ទីរពេទ្យ ជាទីចោលសាកសពរបស់សត្វល្អិតទាំងនោះ ព្រោះហេតុ នោះទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ពាក្យថា **វម្មិក** នេះ ជាឈ្មោះនៃកាយនេះ ដែលកើតអំពីមហាភូតរូបទាំង ៤ ។

បទថា **មាតាបេត្តិកសម្ភវស្ស** សេចក្តីថា ដែលកើតអំពីការប្រជុំនៃសុក្កាដែលកើតអំពីមាតាបិតា ឈ្មោះថា **មាតាបេត្តិក** ។ បទថា **ឱទន-កុម្មាសូបចយស្ស** សេចក្តីថា ធំចម្រើនឡើងដោយបាយ និងនំកុម្មាស ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មស្ស** ដូចតទៅនេះ កាយនេះ ឈ្មោះថា មានការមិនទៀងជាធម្មតា ព្រោះអត្ថថា មានហើយ ត្រឡប់ជាមិនមាន ឈ្មោះថា មានការបូកលាបជាធម្មតា ព្រោះពាសដោយស្បែក ដើម្បីប្រយោជន៍ដល់ការកម្ចាត់ក្លិនស្អុយ ឈ្មោះថា មានការគក់ប្រចាប់ជាធម្មតា ព្រោះមានការគក់ប្រចាប់រឿយៗ ដើម្បីប្រយោជន៍ដល់ការបន្ទោបង់ ការឈឺចាប់អវយវៈតូចធំ ម្យ៉ាងទៀត ឈ្មោះថា មានការទំនុកបម្រុងជាធម្មតា ដោយការបន្តក់ថ្នាំភ្នែក និងគក់ប្រចាប់ជាដើម ដើម្បីការបរិបូណ៌នៃសណ្ឋាននៃអវយវៈទាំងនោះ ដែលតាំងនៅមិនល្អ ដោយឲ្យដេកនៅលើភ្លៅ ឲ្យដេកតែក្នុងបន្ទប់ ក្នុងវេលាជាទារក អធិប្បាយថា សូម្បីផ្គត់ផ្គង់

ផុនផ្តើមយ៉ាងនេះ ក៏នៅតែមានការបែកធ្លាយទៅជាធម្មតា កាយនេះ មានសភាពយ៉ាងនេះ ។ លោកពោលកាយដែលតាំងឡើងដោយបទ គឺ **មាតាបេត្តិកសម្ភវឱទន កុម្មាសឧបចយ ឧច្ឆាទន** និង **បរិមទ្ទន** ក្នុងពាក្យនោះ ។ លោកពោលការរលត់ គឺ **អនិច្ច ឧច្ឆាទន ភេទន វិទ្ធំសន** ភាវៈដែលខ្ពស់ទាប សេចក្តីចម្រើន ការវិនាស ការកើត និងការរលត់នៃកាយដែលកើតអំពីមហាភូតទាំង ៤ គប្បីជ្រាបថា លោកពោលដោយបទទាំង ៧ យ៉ាងដោយប្រការដូច្នេះ ។

បទថា **ទិវា កម្មន្តេ** បានដល់ ការងារដែលគប្បីធ្វើក្នុងពេលថ្ងៃ ។ **ធូម** សព្ទ ក្នុងបទថា **ធូមាយនា** នេះ ប្រព្រឹត្តទៅក្នុងអត្ថទាំងនេះ គឺសេចក្តីក្រោធ តណ្ហា វិតក្ក កាមគុណ ៥ ធម្មទេសនា ផ្សែងតាមប្រក្រតី ។ ពិតហើយ **ធូម** សព្ទ ប្រព្រឹត្តទៅក្នុងសេចក្តីក្រោធ ដូចក្នុងប្រយោគជាដើមថា **កោធោ ធូមោ ភស្មនិម្មោសវជ្ជំ** សេចក្តីក្រោធ ដូចជាផ្សែង ពាក្យកុហក ដូចជាផេះ ។ ប្រព្រឹត្តទៅក្នុងតណ្ហា ដូចក្នុងប្រយោគជាដើមថា **ឥច្ឆាធូមាយិតា សត្តា** សត្វទាំងឡាយមានតណ្ហាដូចជាផ្សែង ។ ប្រព្រឹត្តទៅក្នុងវិតក្ក ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភគវតោ អវិទូរេ ធូមាយន្តោ និសិន្នោ ហោតិ** សម័យនោះ ភិក្ខុមួយរូបអង្គុយត្រិះរិះ ដូចជាផ្សែងក្នុងទីមិនឆ្ងាយអំពីព្រះមានព្រះភាគ ។ ប្រព្រឹត្តទៅក្នុងកាមគុណ ៥ ដូចក្នុងប្រយោគជាដើមថា

**បង្កោ ច កាមា បលិបោ ច កាមា   ភយញ្ច មេតំ តិមូលំ បវុត្តំ**
**រជោ ច ធូមោ ច មយា បកាសិតា   ហិត្វា តុវំ បព្ពជ ព្រហ្មទត្តាតិ ។**

កាមទាំងឡាយដូចភក់ផង កាមទាំងឡាយដូចគ្រឿងស្អិតផង នេះជាភ័យមានឫសគល់ ៣ យ៉ាង ដែលព្រះសម្ពុទ្ធពោលទុកហើយ កាមទាំងឡាយដូចធូលីផង ដូចផ្សែងផង ដែលអាត្មាប្រកាសហើយ បពិត្រព្រះរាជាព្រហ្មទត្ត សូមព្រះអង្គលះបង់ ( កាមទាំងនោះ ) ហើយបួសចុះ ។

ប្រព្រឹត្តទៅក្នុងធម្មទេសនា ដូចក្នុងប្រយោគជាដើមថា **ន ធូមំ កត្តា ហោតិ** មិនបំពក់ក្នក់[1] ។ ប្រព្រឹត្តទៅក្នុងផ្សែងតាមប្រក្រតី ដូចក្នុងប្រយោគជាដើមថា **ធជោ រថស្ស បញ្ញាណំ ធូមោ បញ្ញាណមគ្គិនោ** ទង់ជាគ្រឿងប្រាកដរបស់រថ ផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ។ តែក្នុងទីនេះ **ធូម** សព្ទនេះ លោកបំណងយកវិតក្ក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថាហុយផ្សែងក្នុងពេលយប់ ។ បទថា **តថាគតស្សេតំ អធិវចនំ** សេចក្ដីថា ពិតហើយ ព្រះតថាគត ឈ្មោះថា ព្រាហ្មណ៍ ព្រោះទ្រង់បន្សាត់ធម៌ទាំង ៧ បានហើយ ។ ដូចលោកពោលថា ភិក្ខុ ឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់ធម៌ទាំង ៧ បានហើយ ធម៌ទាំង ៧ តើដូចម្ដេច គឺរាគៈ ទោសៈ មោហៈ មានៈ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភិក្ខុ ឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់ធម៌ទាំង ៧ នេះបានហើយ ។ បទថា **សុមេធោ** ប្រែថា ជាអ្នក

---

១- ក្នុងមហាគោបាលសូត្រ ពាក្យថា មិនបំពក់ក្នក់ គឺភិក្ខុក្នុងសាសនានេះ មិនសម្ដែងធម៌ដល់ជនទាំងឡាយដទៃ ។

មានបញ្ញាល្អ ។ ក្នុងបទថា **សេក្ខស្ស** នេះ ឈ្មោះថា សេក្ខៈ ព្រោះនៅសិក្សានៅឡើយ ដូចលោកពោលថា ម្នាលភិក្ខុ ភិក្ខុនៅសិក្សានៅឡើយ ព្រោះហេតុដូច្នោះ ទើបលោកហៅថា សេក្ខៈ សួរថា សិក្សាអ្វីខ្លះ សិក្សាអធិសីលខ្លះ សិក្សាអធិចិត្តខ្លះ សិក្សាអធិប្បញ្ញាខ្លះ ។ បទថា **បញ្ញាយ ឯតំ អធិវចនំ** ពាក្យនេះជាឈ្មោះរបស់បញ្ញាដែលជាលោកិយ និងលោកុត្តរ មិនមែនជាឈ្មោះនៃអាវុធ និងសស្ត្រាឡើយ ។ បទថា **វីរិយារម្ភស្ស** បានដល់ សេចក្តីព្យាយាមតាមកាយ និងតាមចិត្ត ។ សេចក្តីព្យាយាមនោះ រមែងជាគតិនៃបញ្ញានោះឯង សេចក្តីព្យាយាមដែលជាគតិនៃលោកិយប្បញ្ញា ចាត់ជាលោកិយ គតិនៃលោកុត្តរប្បញ្ញា ចាត់ជាលោកុត្តរ ។ ក្នុងសេចក្តីនេះ មានការបង្អុលបង្ហាញដូច្នេះថា

បានឮថា ព្រាហ្មណ៍អ្នកជនបទម្នាក់ ចេញពីស្រុកអំពីព្រលឹម មួយអន្ទើដោយពួកមាណព ពេលថ្ងៃបង្រៀនមន្តក្នុងព្រៃ ពេលល្ងាចក៏ត្រឡប់ចូលស្រុក ក្នុងចន្លោះផ្លូវ មានដំបូក ១ ដំបូកនោះ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះជាភ្លើង ទើបព្រាហ្មណ៍និយាយនឹងសុមេធមាណពដែលជាសិស្សថា នែបា ដំបូកនេះ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះជាភ្លើង ខ្ញុំនឹងឃើញការខុសប្រប្រតីរបស់ដំបូកនោះ អ្នកចូរទម្លាយវាជា ៤ ចំណែកចោលទៅ ។ សិស្សនោះក៏ទទួលពាក្យ ចាប់ចប ប្រើជើងទាំង ២ ជាន់លើផែនដីហើយបានធ្វើយ៉ាងនោះ ក្នុងអាចារ្យ និងសិស្សនោះ ព្រះមានព្រះភាគ ប្រៀបដូចព្រាហ្មណ៍ដែលជាអាចារ្យ សេក្ខភិក្ខុ ប្រៀបដូចមាណពដែលជាសិស្ស កាយ

ប្រៀបដូចដំបូក វេលាដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកចូរចែកកាយដែលកើតអំពីមហាភូតរូបទាំង ៤ ជាចំណែកៗ កាន់យកជាអារម្មណ៍ ក៏ប្រៀបដូចវេលាដែលព្រាហ្មណ៍ជាអាចារ្យពោលថា នែបា ដំបូកនេះ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះជាភ្លើង ខ្ញុំនឹងឃើញការខុសប្រក្រតីនៃដំបូកនោះ អ្នកចូរទម្លាយវា ចែកជា ៤ ចំណែក ហើយចោលទៅ ។ គប្បីជ្រាបកំណត់កាយសម្រាប់សេក្ខភិក្ខុ ដោយកំណត់ធាតុ ៤ ជាអារម្មណ៍យ៉ាងនេះ គឺការដែលកាយជារបស់រឹង មានអាការ ២០ ចាត់ជាបឋវីធាតុ ការដែលកាយជ្រាបសើម ១២ អាការ ចាត់ជាអាបោធាតុ ការដែលកាយក្តៅ ៤ អាការ ចាត់ជាតេជោធាតុ ការដែលកាយកម្រើក ៦ អាការ ចាត់ជាវាយោធាតុ ប្រៀបដូចសុមេធមាណពដែលជាសិស្សទទួលពាក្យហើយ ចាប់ចបធ្វើយ៉ាងនោះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់សម្តែងអវិជ្ជា ឈ្មោះថា សន្ទះទ្វារកង់ ក្នុងពាក្យថា **លង្គីតិ ខោ ភិក្ខុ** ឆ្លើយថា ដូចបិទទ្វារព្រះនគរ ដាក់គន្លឹះ មហាជនក៏ដាច់ការទៅ ពួកជនដែលនៅខាងក្នុងព្រះនគរ ក៏នៅខាងក្នុងនោះឯង ពួកជនដែលនៅខាងក្រៅព្រះនគរ ក៏នៅខាងក្រៅ យ៉ាងណា សន្ទះទ្វារកង់ គឺអវិជ្ជា ធ្លាក់ទៅក្នុងមាត់ គឺញាណរបស់បុគ្គលណា ការទៅ គឺញាណដែលឲ្យដល់នូវព្រះនិព្វានរបស់បុគ្គលនោះ ក៏ដាច់ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងអវិជ្ជាឲ្យដូចជាសន្ទះទ្វារកង់ ក្នុងពាក្យថា **បជហ អវិជ្ជំ** នេះ លោកពោលការលះអវិជ្ជា ដោយអំណាចការរៀន និងការសាកសួរកម្មដ្ឋាន ។ ក្នុងបទថា **ឧទ្ធុមាយិកាតិ ខោ ភិក្ខុ** នេះ ដែលឈ្មោះថា ហើង

ប៉ោងឡើងមិនធំប្រមាណប៉ុនខ្នងក្រចក នៅក្នុងចន្លោះស្លឹកឈើចាស់ៗ ក្នុងចន្លោះគុម្ពឈើ ឬចន្លោះវល្លិ ហ៊ីងនោះត្រូវចុងឈើ ចុងវល្លិ ឬលម្អងធូលីប៉ះពាល់ ក៏រីកចេញ មានបរិមណ្ឌលធំ ទំហំប៉ុនចំណិតផ្លែល្ពៅ មានជើង ៤ កម្រើកនៅក្នុងអាកាស ដាច់ការទៅ គឺដើរមិនបាន ធ្លាក់នៅក្នុងអំណាចរបស់សត្រូវ ជាចំណីរបស់ក្អែក និងមៀមជាដើម យ៉ាងណា ការក្រោធនេះ ក៏ដូច្នោះដូចគ្នា កាលកើតឡើងដំបូង ក៏គ្រាន់តែជាការល្អក់កករនៃចិត្តប៉ុណ្ណោះ បើមិនសង្កត់ក្នុងខណៈនោះ ក៏រីកចេញទៅដល់មុខមាត់ ចិញ្ចើម បើមិនសង្កត់ក្នុងវេលានោះ ក៏ឲ្យដល់នូវចង្កាញ័រ បើមិនត្រូវសង្កត់ក្នុងវេលានោះ ក៏ឲ្យដល់នូវការបន្ទីវាចាគ្រោតគ្រាត បើមិនសង្កត់ក្នុងវេលានោះ ក៏ឲ្យដល់នូវការមើលមិនឃើញទិស បើមិនសង្កត់ក្នុងវេលានោះ ក៏ឲ្យដល់នូវការឱជងទៅមក បើមិនសង្កត់ក្នុងវេលានោះ ក៏ឲ្យដល់នូវការចាប់ដៃ ជុំជី ដំបង និងសស្ត្រា បើមិនត្រូវសង្កត់ក្នុងវេលានោះ ឲ្យដល់នូវការប្រហារដោយដំបង និងសស្ត្រា បើមិនសង្កត់ក្នុងវេលានោះ ឲ្យដល់នូវការសម្លាប់អ្នកដទៃខ្លះ សម្លាប់ខ្លួនឯងខ្លះ ។ សមដូចពាក្យដែលលោកពោលថា ក្នុងកាលណា បុគ្គលអ្នកក្រោធសម្លាប់បុគ្គលដទៃ ហើយសម្លាប់ខ្លួន ក្នុងកាលនោះ ក្រោធក៏ដល់នូវសភាពដ៏ចម្រើនក្រៃលែង ដល់នូវសភាពដ៏ទូលំទូលាយដ៏ក្រៃលែង ។ ក្នុងសេចក្តីនោះ កាលជើងទាំង ៤ របស់ហ៊ីងផុតនៅក្នុងអាកាស ក៏ដាច់ការទៅ គឺដើរមិនបាន ហ៊ីងក៏ធ្លាក់នៅក្នុងអំណាចរបស់សត្រូវ ជាចំណីរបស់សត្វ មានក្អែកជាដើម យ៉ាងណា បុគ្គលដែលធ្លាក់នៅក្នុងអំណាចនៃសេចក្តីក្រោធ ក៏ដូច្នោះដូច

គ្នា មិនអាចកំណត់កម្មដ្ឋានឲ្យរីកចេញទៅបាន ធ្លាក់នៅក្នុងអំណាចរបស់សត្រូវ ជាអ្នកដែលត្រូវអន្ទាក់មារ ធ្វើបានតាមការប្រាថ្នា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា សត្វហ៊ឹងនេះ ជាឈ្មោះរបស់សេចក្ដីក្រោធ និងសេចក្ដីចង្អៀតចង្អល់ចិត្ត ។ ក្នុងសេចក្ដីនោះ ការក្រោធខ្លាំង ឈ្មោះថា ចង្អៀតចង្អល់ដោយអំណាចការក្រោធ លោកពោលការលះដោយការពិចារណា ក្នុងបទថា **បជហ កោធុបាយាសំ ។**

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ទ្វិធាបថោ** ដូចតទៅនេះ បុរសអ្នកមានភោគទ្រព្យ ដើរផ្លូវឆ្ងាយដែលជាកន្ដារ ដល់ផ្លូវបែកជា ២ មិនអាចសម្រេចថា គួរទៅផ្លូវនេះ ឬមិនគួរទៅផ្លូវនេះ ឈប់នៅក្នុងទីនោះឯង កាលបើដូច្នោះ ចោរប្រាកដខ្លួនឡើង មកធ្វើបុគ្គលនោះឲ្យដល់នូវសេចក្ដីលំបាក យ៉ាងណាភិក្ខុដែលអង្គុយកំណត់កម្មដ្ឋានខាងដើម ក៏ដូច្នោះឯង កាលកើតសេចក្ដីសង្ស័យក្នុងព្រះពុទ្ធជាដើម ក៏មិនអាចចម្រើនកម្មដ្ឋានបាន កាលបើដូច្នោះ អន្ទាក់មារមានកិលេសមារជាដើម រមែងធ្វើភិក្ខុនោះឲ្យដល់នូវសេចក្ដីលំបាក ទើបវិចិកិច្ឆាស្មើដោយផ្លូវបែកជា ២ ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា ផ្លូវបែកជាពីរនេះ ជាឈ្មោះរបស់វិចិកិច្ឆា ។ ក្នុងបទថា **បជហ វិចិកិច្ឆំ** នេះ លោកពោលការលះវិចិកិច្ឆាដោយការរៀន និងការសាកសួរកម្មដ្ឋាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បង្គវាំ** ដូចតទៅនេះ កាលជាងជ្រលក់ដាក់ទឹកចូលក្នុងថ្នាំងតម្រងក្បុងមួយថ្នាំងក្ដី ពីរថ្នាំងក្ដី ១០ ថ្នាំងក្ដី ២០ ថ្នាំងក្ដី ១០០ ថ្នាំងក្ដី ក៏ហូរចេញ សូម្បីទឹកមួយទូក

ដៃក៏មិនតាំងនៅ យ៉ាងណា កុសលធម៌ខាងក្នុងនៃបុគ្គលដែលប្រកបដោយ នីវរណៈ រមែងមិនតាំងនៅដូច្នោះដូចគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា សំពត់តម្រងក្បួងនេះ ជាឈ្មោះរបស់នីវរណៈធម៌ ៥ ។ ក្នុងបទថា **បជហ បញ្ច នីវរណេ** នេះ ត្រាស់ការលះនីវរណៈដោយវិក្ខម្ភនប្បហាន និងតទង្គប្បហាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **កុម្មោ** ដូចតទៅនេះ អណ្តើកមានអវយវៈ ៥ គឺជើង ៤ ក្បាល ១ យ៉ាងណា សង្ខតធម៌ទាំងអស់កាលរួបរួម ក៏មានត្រឹម ៥ ប៉ុណ្ណោះដូច្នោះដូចគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា អណ្តើកនេះ ជាឈ្មោះរបស់ឧបាទានក្ខន្ធ ៥ ។ ក្នុងបទថា **បជហ បញ្ចុ–បាទានក្ខន្ធេ** នេះ ត្រាស់ការលះតម្រេក ដោយអំណាចការពេញចិត្តក្នុងខន្ធ ៥ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អសិសូនា** ដូច្នេះ យកសាច់ដាក់លើជ្រញ់ យកកាំបិតចិញ្ច្រាំ យ៉ាងណា សត្វទាំងនេះកាលត្រូវកាមកិលេសប៉ះខ្ទប់ ដើម្បីប្រយោជន៍ដល់ការធ្វើទុកលើវត្ថុកាម ត្រូវកិលេសកាមកាប់ចិញ្ច្រាំក៏ដូច្នោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ពាក្យថា ជ្រញ់ចិញ្ច្រាំសាច់នេះ ជាឈ្មោះនៃកាមគុណទាំង ៥ ។ ក្នុងបទថា **បជហ បញ្ច កាមគុណេ** នេះ ត្រាស់ការលះតម្រេកដោយអំណាចការពេញចិត្តក្នុងកាមគុណ ៥ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **មំសបេសីតិ ខោ ភិក្ខុ** ដូចតទៅ ដែលឈ្មោះថា ដុំសាច់នេះ ជនជាច្រើនប្រាថ្នាហើយ ទាំងពួកមនុស្ស មានក្សត្រជាដើម ទាំងសត្វតិរច្ឆាន មានក្អែកជាដើម តែងប្រាថ្នាវា

សត្វទាំងនេះប្រកបដោយអវិជ្ជា អាស្រ័យតម្រេក ដោយអំណាចការត្រេកអរ ក៏ប្រាថ្នាវដ្ដៈ ដុំសាច់រមែងជាប់នៅក្នុងទីដែលទុក យ៉ាងណា សត្វទាំងនេះត្រូវតម្រេក ដោយអំណាចការត្រេកអរចង ក៏ជាប់នៅក្នុងវដ្ដៈ សូម្បីជួបនូវសេចក្ដីទុក្ខ ក៏មិនទៀយណាយ យ៉ាងនោះ តម្រេកដោយអំណាចការត្រេកអររមែងដូចជាដុំសាច់ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ត្រង់ពាក្យថា ដុំសាច់នេះ ជាឈ្មោះរបស់នន្ទិរាគ ( សេចក្ដីត្រេកត្រអាល ) ។ ក្នុងបទថា **បជហ នន្ទិរាគំ** នេះ ទ្រង់ត្រាស់ការលះតម្រេកដោយអំណាចសេចក្ដីត្រេកអរ ដោយមគ្គទី ៤ ។

ក្នុងពាក្យថា ម្នាលភិក្ខុ ពាក្យថា **នាគ** នេះ ជាឈ្មោះនៃព្រះខីណាស្រព នេះ ព្រះខីណាស្រព លោកហៅថា **នាគ** ដោយអត្ថណា អត្ថនោះលោកប្រកាសហើយក្នុងអនង្គណសូត្រ ។ ក្នុងបទថា **នមោ ករោហិ នាគស្ស** នេះ មានអត្ថដូច្នេះ គឺអ្នកចូរធ្វើការនមស្ការព្រះពុទ្ធនាគដ៏ជាខីណាសវៈថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងហើយ រមែងសម្ដែងធម៌ដើម្បីការត្រាស់ដឹង ព្រះមានព្រះភាគអង្គនោះទ្រង់អប់រំហើយ ទ្រង់សម្ដែងធម៌ដើម្បីអប់រំ ព្រះមានព្រះភាគអង្គនោះទ្រង់ស្ងប់ហើយ ទ្រង់សម្ដែងធម៌ដើម្បីស្ងប់ ព្រះមានព្រះភាគអង្គនោះទ្រង់ឆ្លងហើយ សម្ដែងធម៌ដើម្បីឆ្លង ព្រះមានព្រះភាគអង្គនោះរម្ងត់ឥតមានសេសសល់ហើយ ទ្រង់សម្ដែងធម៌ ដើម្បីរម្ងត់ឥតមានសេសសល់ ។ ព្រះសូត្រនេះ បានកម្មដ្ឋានរបស់ព្រះថេរៈ ដោយប្រការដូច្នេះ ។

ឯព្រះថេរៈធ្វើព្រះសូត្រនេះឯងឲ្យជាកម្មដ្ឋាន ចម្រើនវិបស្សនា សម្រេចអរហត្ត ។ បទថា **អយមេតស្ស អត្ថោ** សេចក្តីថា នេះជាអត្ថនៃប្រស្នានោះ ។ ព្រះមានព្រះភាគ ទ្រង់ហាក់ដូចជាកាន់យកកំពូលមណីក្នុងគំនររតនៈ ទ្រង់បញ្ចប់ទេសនាតាមលំដាប់អនុសន្ធិ ដោយប្រការដូច្នេះឯង ។៚

**វម្មិកសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## រថវិនីតសូត្រទី ៤

[ ៣០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប អ្នកនៅក្នុងជាតិភូមិ នៅចាំវស្សាក្នុងជាតិភូមិហើយ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បណ្តាជាតិភូមិកភិក្ខុទាំងឡាយ ជាសព្រហ្មចារីដែលនៅក្នុងជាតិភូមិ ភិក្ខុណាហ្ន៎ ដែលមានគេសរសើរយ៉ាងនេះថា ជាអ្នកមិនមានសេចក្តីប្រាថ្នាដោយខ្លួនឯងផង សម្តែងអំពីការមិនមានសេចក្តីប្រាថ្នាដល់ពួកភិក្ខុផង ជាអ្នកសន្តោសដោយខ្លួនឯងផង សម្តែងអំពីការសន្តោសដល់ពួកភិក្ខុផង ជាអ្នកស្ងប់ស្ងាត់ដោយខ្លួនឯងផង សម្តែងអំពីការស្ងប់ស្ងាត់ដល់ពួកភិក្ខុផង ជាអ្នកមិនច្រឡូកច្រឡំដោយខ្លួនឯងផង សម្តែងអំពីការមិនច្រឡូកច្រឡំដល់ពួកភិក្ខុផង ជាអ្នកប្រារព្ធសេចក្តីព្យាយាមដោយខ្លួនឯងផង សម្តែងអំពីការប្រារព្ធព្យាយាមដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយសីលចំពោះខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយសីលដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយសមាធិចំពោះខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយសមាធិដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយបញ្ញាចំពោះខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយបញ្ញាដល់ពួកភិក្ខុ

ផង ជាអ្នកបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ចំពោះខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ដល់ពួកភិក្ខុផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញាណទស្សនៈ ដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិ-ញាណទស្សនៈដល់ពួកភិក្ខុផង ជាអ្នកឲ្យឱវាទ បំភ្លឺឲ្យដឹងច្បាស់ ពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយ ដល់ពួកសព្រហ្មចារីផង ។ ភិក្ខុទាំង-ឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បណ្តាជាតិភូមិកភិក្ខុទាំងឡាយ ជាសព្រហ្មចារីដែលនៅក្នុងជាតិភូមិ មានតែបុណ្ណត្ថេរមានអាយុ ជាមន្តាណីបុត្ត ( កូននៃព្រាហ្មណីឈ្មោះមន្តាណី ) ទេ ទើបគេតែងសរសើរគុណយ៉ាងនេះថា ជាអ្នកមិនប្រាថ្នា ដោយខ្លួនឯងផង សម្តែងអំពីការមិនមានប្រាថ្នាដល់ពួកភិក្ខុផង ជាអ្នកសន្តោសដោយខ្លួនឯងផង ។បេ។ ជាអ្នកស្ងប់ស្ងាត់ ដោយខ្លួនឯងផង ... ជាអ្នកមិនច្រឡូកច្រឡំដោយខ្លួនឯងផង ... ជាអ្នកមានសេចក្តីព្យាយាមដោយខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយសីលចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយសមាធិចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយបញ្ញាចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយវិមុត្តិចំពោះខ្លួនឯងផង ... ជាអ្នកបរិបូណ៌ដោយវិមុត្តិញាណទស្សនៈចំពោះខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ដោយវិមុត្តិញាណទស្សនៈដល់ពួកភិក្ខុផង ជាអ្នកឲ្យឱវាទ បំភ្លឺឲ្យដឹងច្បាស់ ពន្យល់ បបួល ធ្វើឲ្យក្លាហាន ធ្វើឲ្យរីករាយដល់ពួកសព្រហ្មចារីផង ។

[ ៣១ ] សម័យនោះឯង ព្រះសារីបុត្តមានអាយុ អង្គុយក្បែរព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្រមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា

បុណ្ណមន្តាណីបុត្តមានអាយុហៅពេញជាមានលាភ ទាំងអត្តភាពជាមនុស្ស ក៏បុណ្ណមន្តាណីបុត្តបានហើយដោយប្រពៃ ( ព្រោះ )ពួកសព្រហ្មចារីកិក្ខុដែលជាអ្នកប្រាជ្ញពិចារណារឿយៗ ហើយតែងពោលសរសើរក្នុងទីចំពោះព្រះភក្រ្តនៃព្រះសាស្តា ព្រះសាស្តាក៏ទ្រង់អនុមោទនាចំពោះបុណ្ណមន្តាណីបុត្តនោះ ធ្វើដូចម្តេចហ្ន៎ យើងនឹងបានទៅកាន់ទីប្រជុំជាមួយនឹងព្រះបុណ្ណមន្តាណីបុត្តមានអាយុម្តងអេះ ធ្វើដូចម្តេចហ្ន៎ នឹងបាននិយាយចរចាបន្តិចបន្តួចផងអេះ ។

[ ៣២ ] គ្រានោះឯង ព្រះភគវន្តមុនីទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមគួរដល់អធ្យាស្រ័យហើយ ទ្រង់ស្តេចទៅកាន់ចារិកឰដ៏ក្រុងសាវត្ថី លុះស្តេចទៅកាន់ចារិកតាមហូរហែ ក៏បានទៅដល់ក្រុងសាវត្ថីនោះ ។ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ ។ ព្រះបុណ្ណមន្តាណីបុត្តមានអាយុ បានឮដំណឹងដូច្នេះថា ព្រះមានព្រះភាគ យាងមកដល់ក្រុងសាវត្ថីហើយ ទ្រង់គង់ក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះឯង ព្រះបុណ្ណមន្តាណីបុត្តមានអាយុ រៀបចំសេនាសនៈហើយប្រដាប់បាត្រចីវរ ទៅកាន់ចារិកក្នុងក្រុងសាវត្ថីនោះដែរ លុះត្រាច់ទៅកាន់ចារិកតាមហូរហែ ក៏បានចូលទៅគាល់ព្រះមានព្រះភាគដែលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះបុណ្ណមន្តាណីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ ណែនាំ ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ។ គ្រានោះ

បុណ្ណមន្តាណីបុត្តមានអាយុ កាលបើព្រះមានព្រះភាគទ្រង់ពន្យល់ ណែនាំ ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចូលទៅឯអន្ធវ័ន ( ព្រៃជាំ ) ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។

[ ៣៣ ] គ្រានោះឯង មានភិក្ខុ ១ រូប ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យដូចនេះនឹងព្រះសារីបុត្តមានអាយុថា អាវុសោសារីបុត្ត អ្នកសម្តែងសេចក្តីសរសើររឿយៗ នូវភិក្ខុបុណ្ណមន្តាណីបុត្ត ឯភិក្ខុបុណ្ណមន្តាណីបុត្តនោះ ដែលព្រះមានព្រះភាគទ្រង់ពន្យល់ណែនាំឲ្យក្លាហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចហើយ ចេញទៅកាន់អន្ធវ័ននោះ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ លំដាប់នោះឯង ព្រះសារីបុត្តមានអាយុមានសភាពរួសរាន់កាន់និសីទនៈ ដើរតាមក្រោយៗ នៃភិក្ខុបុណ្ណមន្តាណីបុត្តមានអាយុ រមិលមើលនូវសីសៈនៃបុណ្ណមន្តាណីបុត្ត ។ គ្រានោះឯង បុណ្ណមន្តាណីបុត្តមានអាយុដើរចូលទៅកាន់អន្ធវ័នហើយ អង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបម្លប់ឈើមួយ ចំណែកខាងព្រះសារីបុត្តមានអាយុ ក៏ចូលទៅកាន់អន្ធវ័ន ហើយអង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបម្លប់ឈើមួយដែរ ។

[ ៣៤ ] គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីទីពួនក្នុង

សាយណ្ហសម័យ ហើយចូលទៅរកបុណ្ណមន្តាណីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល មួយអន្លើដោយបុណ្ណមន្តាណីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តមានអាយុអង្គុយក្នុងទីសមគួរហើយ បានពោលពាក្យដូច្នេះនឹងបុណ្ណមន្តាណីបុត្តមានអាយុថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគរបស់យើងដែរឬ ។ បុណ្ណមន្តាណីបុត្តមានអាយុតបថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ ។ ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃសីលឬ ។ ម្នាលអាវុសោ ការប្រព្រឹត្តនេះ មិនមែនត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃចិត្តឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃទិដ្ឋិឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃកង្ខាវិតរណៈឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃមគ្គាមគ្គញាណទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ចុះលោកមានអាយុ ប្រព្រឹត្ត

ព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃបដិបទាញាណ-ទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ ។ ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ។ ព្រះសារីបុត្តមានអាយុមានថេរវាចាថា កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃសីលឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃចិត្តឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃទិដ្ឋិឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃកង្ខាវិតរណៈឬ ... ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃមគ្គាមគ្គញ្ញាណទស្សនៈឬ ... ម្នាលអាវុសោ ដើម្បីបរិសុទ្ធិនៃបដិបទាញាណ-ទស្សនៈឬ ... កាលបើខ្ញុំសួរថា ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ លោកនិយាយថា ម្នាលអាវុសោ មិនមែនតែត្រឹមប៉ុណ្ណោះទេ ម្នាលអាវុសោ ( បើយ៉ាងនេះ ) ចុះលោកមានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគដើម្បីអ្វី ។ បុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ ព្រហ្ម-

ចរិយធម៌ដែលខ្ញុំប្រព្រឹត្តក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វានទេតើ ។ ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះចិត្តវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ទិដ្ឋិវិសុទ្ធិ ជាអនុបាទា-បរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះកង្ខាវិ-តរណវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះបដិបទាញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ញាណទស្សនវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ម្នាលអាវុសោ ចុះអនុបាទាបរិនិព្វានក្រៅអំពីធម៌ទាំងនេះឬ ។ ម្នាលអាវុសោ នេះមិនមែនទេ ។ ព្រះសារីបុត្តសួរថា កាលខ្ញុំសួរថា ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា អាវុសោ នេះមិនមែនទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះចិត្តវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ ម្នាលអាវុសោ ទិដ្ឋិវិសុទ្ធិ ជាអនុបាទា-បរិនិព្វានឬ ។បេ។ ម្នាលអាវុសោ ចុះកង្ខាវិតរណវិសុទ្ធិឬ ... ម្នាលអាវុសោ ចុះមគ្គាមគ្គញាណទស្សនវិសុទ្ធិឬ ... ម្នាលអាវុសោ ចុះបដិបទាញាណទស្សន-វិសុទ្ធិឬ ... កាលខ្ញុំសួរថា ម្នាលអាវុសោ ញាណទស្សនវិសុទ្ធិ ជាអនុបាទា-បរិនិព្វានឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ កាលខ្ញុំសួរថា

ម្នាលអាវុសោ ចុះអនុបាទាបរិនិព្វានក្រៅអំពីធម៌ទាំងនេះឬ លោកឆ្លើយថា ម្នាលអាវុសោ នេះមិនមែនទេ ម្នាលអាវុសោ ( កាលបើយ៉ាងនេះ ) ចុះសេចក្តីនៃភាសិតនេះ តើលោកយល់យ៉ាងណា ។

[ ៣៥ ] បុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវសីលវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវចិត្តវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវទិដ្ឋិវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវកង្ខាវិតរណវិសុទ្ធិ ថាជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទាន ថាជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវមគ្គាមគ្គញាណទស្សនវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះមានព្រះភាគបញ្ញត្តនូវបដិបទាញាណទស្សនវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើព្រះមានព្រះភាគបញ្ញត្តនូវញាណទស្សនវិសុទ្ធិថា ជាអនុបាទាបរិនិព្វានហើយ ឈ្មោះថា បញ្ញត្តនូវសឧបាទានថា ជាអនុបាទាបរិនិព្វានទៅវិញ ។ ម្នាលអាវុសោ បើអនុបា-

ទាបរិនិព្វាន ក្រៅអំពីធម៌ទាំងនេះហើយ បុថុជ្ជនក៏គង់បរិនិព្វានបាន ម្នាលអាវុសោ ព្រោះបុថុជ្ជន ក្រៅអំពីធម៌ទាំងនេះឯង ។ ម្នាលអាវុសោ បើដូច្នោះ ខ្ញុំនឹងធ្វើសេចក្តីឧបមាដល់លោក បុរសជាអ្នកប្រាជ្ញពួកខ្លះ ក្នុងលោកនេះ គង់ដឹងច្បាស់នូវសេចក្តីនៃភាសិត ដោយសេចក្តីឧបមាបាន ។

[ ៣៦ ] ម្នាលអាវុសោ ដូចជាព្រះបាទបសេនទិកោសល ទ្រង់នៅគ្រប់គ្រងក្រុងសាវត្ថី មានកិច្ចនីមួយដែលត្រូវធ្វើជាប្រញាប់ប្រញាល់ កើតឡើងក្នុងក្រុងសាកេត ជនទាំងឡាយដែលនៅត្រង់ចន្លោះក្រុងសាវត្ថី និងក្រុងសាកេត គប្បីរៀបចំនូវរថព្រះទីនាំងទាំង ៧ ថ្វាយព្រះបាទបសេនទិកោសល នោះរួចហើយ ម្នាលអាវុសោ ទើបព្រះបាទបសេនទិកោសល ទ្រង់ស្តេចចេញអំពីក្រុងសាវត្ថី ឡើងព្រះទីនាំងទី ១ ទៀបទ្វារព្រះរាជវាំងខាងក្នុង ទ្រង់ស្តេចដោយរថព្រះទីនាំងទី ១ ក៏បានដល់ទៅរថព្រះទីនាំងទី ២ ហើយលះបង់រថព្រះទីនាំងទី ១ ឡើងគង់រថព្រះទីនាំងទី ២ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ២ ក៏បានដល់រថព្រះទីនាំងទី ៣ ទ្រង់លះបង់រថព្រះទីនាំងទី ២ រួចឡើងគង់រថព្រះទីនាំងទី ៣ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៣ ក៏បានដល់រថព្រះទីនាំងទី ៤ ទ្រង់លះបង់រថព្រះទីនាំងទី ៣ ក៏ឡើងគង់រថព្រះទីនាំងទី ៤ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៤ ក៏បានដល់រថព្រះទីនាំងទី ៥ ទ្រង់លះបង់រថព្រះទីនាំងទី ៤ រួចឡើងគង់រថព្រះទីនាំងទី ៥ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៥ ក៏បានដល់រថព្រះទីនាំងទី ៦ ទ្រង់លះបង់រថព្រះទីនាំងទី ៥ រួចឡើងគង់រថព្រះទីនាំងទី ៦ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៦ ក៏បានដល់រថព្រះទីនាំងទី

៧ ទ្រង់លះបង់រថព្រះទីនាំងទី ៦ រួចឡើងគង់រថព្រះទីនាំងទី ៧ ទ្រង់ស្តេចដោយរថព្រះទីនាំងទី ៧ ក៏បានដល់ទៅក្រុងសាកេត ទ្រង់ប្រថាប់នៅត្រង់ទ្វារខាងក្នុងព្រះរាជវាំង ពួកមិត្រអាមាត្យជាញាតិសាលោហិត នាំគ្នាក្រាបបង្គំទូលសួរព្រះអង្គ ក្នុងកាលដែលស្តេចដល់ទ្វារខាងក្នុងព្រះរាជវាំងនោះ យ៉ាងនេះថា បពិត្រមហារាជ ព្រះអង្គស្តេចចេញពីក្រុងសាវត្ថី ដោយរថព្រះទីនាំងតែមួយនេះ ដល់មកទ្វារខាងក្នុងព្រះរាជវាំងនៃក្រុងសាកេតតែម្តងឬ ម្នាលអាវុសោ ( បើគេសួរយ៉ាងនេះ ) ព្រះបាទបសេនទិកោសលទ្រង់ដោះស្រាយដូចម្តេច ទើបឈ្មោះថាដោះស្រាយដោយប្រពៃ ។ ម្នាលអាវុសោ ព្រះបាទបសេនទិកោសល កាលបើដោះស្រាយយ៉ាងនេះ ឈ្មោះថាដោះស្រាយដោយប្រពៃថា យើងនៅអាស្រ័យឯក្រុងសាវត្ថី ( ឯណោះទេ ) តែមានកិច្ចនីមួយយ៉ាងរួសរាន់កើតឡើងក្នុងក្រុងសាកេតនេះ ក៏បណ្តាជនក្នុងចន្លោះក្រុងសាវត្ថីនិងក្រុងសាកេតបានរៀបចំរថ ៧ ឲ្យយើង ទើបយើងចេញមកពីក្រុងសាវត្ថីបានឡើងជិះរថទី ១ ត្រង់ទ្វារខាងក្នុងព្រះរាជវាំង មកដោយរថទី ១ ក៏បានដល់រថទី ២ ក៏លះបង់រថទី ១ ហើយឡើងជិះរថទី ២ មកដោយរថទី ២ ក៏បានដល់រថទី ៣ លះបង់រថទី ២ ហើយឡើងជិះរថទី ៣ មកដោយរថទី ៣ ក៏បានដល់រថទី ៤ លះបង់រថទី ៣ ហើយឡើងជិះរថទី ៤ មកដោយរថទី ៤ ក៏បានដល់រថទី ៥ លះបង់រថទី ៤ ហើយឡើងជិះរថទី ៥ មកដោយរថទី ៥ ក៏បានដល់រថទី ៦ លះបង់រថទី ៥ ឡើងជិះរថទី ៦ មកដោយរថទី ៦ ក៏បានដល់រថទី ៧ លះបង់រថទី ៦ ឡើងជិះរថទី ៧ មកដោយរថទី

៧ ទើបបានដល់មកក្រុងសាកេត ត្រង់ទ្វារខាងក្នុងព្រះរាជវាំងនេះ ម្នាលអាវុសោ ព្រះបាទបសេនទិកោសល កាលបើដោះស្រាយយ៉ាងនេះ ទើបឈ្មោះថាដោះស្រាយដោយប្រពៃ មានឧបមាដូចម្តេចមិញ ម្នាលអាវុសោ ឯសីលវិសុទ្ធិ មានប្រយោជន៍ត្រឹមតែចិត្តវិសុទ្ធិ ចិត្តវិសុទ្ធិ មានប្រយោជន៍ត្រឹមតែទិដ្ឋិវិសុទ្ធិ ទិដ្ឋិវិសុទ្ធិមានប្រយោជន៍ត្រឹមតែកង្ខាវិតរណវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មានប្រយោជន៍ត្រឹមតែមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ មានប្រយោជន៍ត្រឹមតែបដិបទាញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សវិសុទ្ធិ មានប្រយោជន៍ត្រឹមតែញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិមានប្រយោជន៍ត្រឹមតែអនុបាទាបរិនិព្វាន ម្នាលអាវុសោ ព្រហ្មចរិយធម៌ដែលខ្ញុំប្រព្រឹត្តក្នុងសំណាក់ព្រះមានព្រះភាគ ( នេះ ) ដើម្បីអនុបាទាបរិនិព្វាន តែម្យ៉ាងប៉ុណ្ណោះ សេចក្តីនេះ ក៏មានឧបមេយ្យដូច្នោះឯង ។

[ ៣៧ ] កាលបើបុណ្ណមន្តាណីបុត្តមានអាយុ ពោលយ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុបានសួរបុណ្ណមន្តាណីបុត្តមានអាយុ យ៉ាងនេះថា លោកមានអាយុឈ្មោះអ្វី ពួកសព្រហ្មចារីស្គាល់ឈ្មោះលោកមានអាយុថាដូចម្តេច ។ ព្រះបុណ្ណមន្តាណីបុត្តតបថា ម្នាលអាវុសោ ខ្ញុំឈ្មោះបុណ្ណៈ តែពួកសព្រហ្មចារីស្គាល់ឈ្មោះខ្ញុំថា មន្តាណីបុត្ត ។ ព្រះសារីបុត្តមានថេរវាចាតបវិញថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ត្រង់ការណ៍ដែលសាវកជាអ្នកចេះដឹង យល់នូវពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាដោយប្រពៃ ដូចជាព្រះបុណ្ណមន្តាណីបុត្តមានអាយុ ពិចារណារឿយៗ ( នូវកថាវត្ថុទាំង

១០ ) ហើយដោះស្រាយប្រស្នា ដ៏ជ្រាលជ្រៅៗ យ៉ាងនោះ ឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារី ទាំងជាតិជាមនុស្សក៏ឈ្មោះថា ពួកសព្រហ្មចារីបានល្អហើយ ត្រង់ដែលពួកសព្រហ្មចារីបុគ្គល បានឃើញបានចូលទៅអង្គុយជិតនូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ទោះបីពួកសព្រហ្មចារី ថែរក្សាដោយធ្វើរង្វេលសំពត់លើក្បាល ហើយឲ្យព្រះបុណ្ណមន្តាណីបុត្តមានអាយុ អង្គុយលើនោះ គប្បីបានឃើញ បានចូលទៅអង្គុយជិត នូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារីទាំងនោះផង ជាតិជាមនុស្សក៏ឈ្មោះថា ពួកសព្រហ្មចារីទាំងនោះ បានល្អហើយផង ឈ្មោះថាជាលាភរបស់យើងផង ជាតិជាមនុស្ស ក៏ឈ្មោះថាយើងបានដោយល្អផង ត្រង់ដែលពួកយើងបានឃើញ បានចូលមកអង្គុយជិតនូវព្រះបុណ្ណមន្តាណីបុត្តមានអាយុ ។

[ ៣៨ ] កាលបើព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះបុណ្ណមន្តាណីបុត្តមានអាយុ បានសួរព្រះសារីបុត្តមានអាយុយ៉ាងនេះថា ចុះលោកមានអាយុឈ្មោះអ្វី ពួកសព្រហ្មចារីស្គាល់ឈ្មោះលោកមានអាយុថាដូចម្តេច ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំឈ្មោះឧបតិស្សៈ តែពួកសព្រហ្មចារីស្គាល់ឈ្មោះខ្ញុំថា សារីបុត្ត ។ ព្រះបុណ្ណមន្តាណីបុត្តមានថេរវាចាថា ឱពុទ្ធោអើយ យើងបានប្រឹក្សាជាមួយនឹងសាវក ដែលទុកស្មើនឹងព្រះសាស្តាផងតើ តែឥតដឹងថាលោកមានអាយុ ឈ្មោះសារីបុត្តសោះ ប្រសិនបើយើងដឹងថាលោកមានអាយុឈ្មោះសារីបុត្តពិតហើយ ពាក្យឆ្លើយឆ្លងមានប្រមាណប៉ុណ្ណោះ ប្រហែលជាយើងឆ្លើយមិនច្បាស់លាស់ទេ ម្នាលអាវុសោ អស្ចារ្យណាស់

ម្នាលអាវុសោ ចម្លែកណាស់ ត្រង់ការណ៍ដែលសាវកជាអ្នកចេះដឹង យល់នូវពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាដោយប្រពៃ ដូចជាព្រះសារីបុត្តមានអាយុបានពិចារណារឿយៗ ហើយសាកសួរប្រស្នាដ៏ជ្រាលជ្រៅៗ យ៉ាងនោះឈ្មោះថាជាលាភរបស់ពួកសព្រហ្មចារី ជាតិជាមនុស្សក៏ឈ្មោះថា ពួកសព្រហ្មចារីបានល្អហើយ ត្រង់ដែលពួកសព្រហ្មចារីបានឃើញ បានចូលទៅអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ទោះបីពួកសព្រហ្មចារី ថែរក្សាដោយធ្វើរង្វេលសំពត់លើក្បាល ហើយឲ្យព្រះសារីបុត្តមានអាយុ អង្គុយលើនោះ គប្បីបានឃើញបានចូលទៅអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ឈ្មោះថា ជាលាភរបស់ពួកសព្រហ្មចារីទាំងនោះផង ជាតិជាមនុស្សក៏ឈ្មោះថា ពួកសព្រហ្មចារីទាំងនោះបានល្អហើយផង ឈ្មោះថាជាលាភរបស់យើងផង ជាតិជាមនុស្សក៏ឈ្មោះថាយើងបានល្អហើយផង ត្រង់ដែលបានឃើញ បានចូលមកអង្គុយជិតនូវព្រះសារីបុត្តមានអាយុ ។ ព្រះមហានាគទាំងពីរអង្គនោះ បានអនុមោទនាត្រេកអរនឹងភាសិតនៃគ្នានឹងគ្នា ដូចបានរៀបរាប់មកនេះឯង ។

## រថវិនីតសូត្រទី ៤ ចប់

# អដ្ឋកថា

## រថវិនីតសូត្រទី ៤

[ ៣០ ] រថវិនីតសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម គប្បីជ្រាបវិនិច្ឆ័យក្នុងរថវិនីតសូត្រនេះយ៉ាងនេះ បទថា **រាជគហេ** បានដល់នគរមានឈ្មោះយ៉ាងនោះ ។ ពិតហើយ នគរនោះ លោកហៅថា រាជគហៈ ព្រោះព្រះបាទមន្ធាតុរាជ និងមហាគោវិន្ទសាស្ដាជាដើម គ្រប់គ្រងរក្សា តែអាចារ្យពួកដទៃពណ៌នាច្រើនប្រការក្នុងពាក្យនេះ ។ លោកពណ៌នាដូចម្ដេច លោកពណ៌នាថា ពាក្យនេះជាឈ្មោះរបស់នគរនោះ ក្រុងរាជគ្រឹះនោះ ជានគរក្នុងកាលនៃព្រះពុទ្ធផង ក្នុងកាលនៃស្ដេចចក្រពត្តិផង ក្នុងវេលាក្រៅអំពីនោះ ជានគរដែលគេបោះបង់ មានតែអមនុស្សប៉ុណ្ណោះហួងហែង ក្លាយជាព្រៃដែលជាលំនៅរបស់អមនុស្សពួកនោះ ។ បទថា **វេឡុវនេ** ក្នុងបទថា **វេឡុវនេ កលន្ទកនិវាបេ** ជាឈ្មោះរបស់ឧទ្យាននោះ ។ បានឮថា ឧទ្យាននោះមានដើមឫស្សីជុះជុំវិញ មានកំពែងកម្ពស់ ១៨ ហត្ថ ប្រកបដោយខ្លោងទ្វារ និងប៉ម មានពណ៌ខៀវស្រស់ គួរជាទីរីករាយ ទើបលោកហៅថា **វេឡុវន** ។ម្យ៉ាងទៀត មនុស្សទាំងឡាយបានឲ្យចំណីដល់កង្ហែនក្នុងវេឡុវននោះ ដោយហេតុនោះ ទើបលោកហៅថា **កលន្ទកនិវាប** ជាទីឲ្យចំណីដល់កង្ហែន ។ បានឮថា អំពីកាលមុន ព្រះរាជាមួយអង្គយាងមកដើម្បីលេងកីឡាក្នុងព្រះរាជឧទ្យាននោះ តែស្រវឹងដោយទឹកចណ្ឌ ក៏ផ្ទំលក់ក្នុងវេលាថ្ងៃ ។ ជនដែលនៅជិតខាងព្រះរាជាដឹងថា ព្រះរាជាផ្ទំលក់ហើយ ក៏បែកគ្នា ទៅរកផ្កា

ផ្លៃឈើជាដើម ក៏បែកគ្នាទៅ ។ គ្រានោះ ពស់វែកមួយធុំក្លិនស្រា ក៏លូន ចេញមកអំពីព្រង់ឈើមួយដើម បែរមុខមករកព្រះរាជា ។ រុក្ខទេវតាឃើញ ពស់វែកនោះហើយ ក៏ជំណែងខ្លួនជាកង្អែន បំណងនឹងជួយជីវិតព្រះរាជា មក ធ្វើសំឡេងត្រង់ក្បែរព្រះកាណ៌ ។ ព្រះរាជាទ្រង់ភ្ញាក់ពីផ្ទំ ។ ពស់វែកក៏លូន ត្រឡប់ទៅ ។ ព្រះរាជាទតឃើញកង្អែននោះ ក៏ទ្រង់ជ្រាបថា កង្អែននេះជួយ ជីវិតអញ ក៏ទ្រង់ដាក់ចំណីទុកក្នុងព្រះរាជឧទ្យាននោះ ដើម្បីកង្អែនទាំងឡាយ នឹងឲ្យប្រកាសប្រទានអភ័យដល់កង្អែនទាំងឡាយ ព្រោះដូច្នោះ តាំងអំពីនោះ មក ទើបព្រះរាជឱទ្យាននោះ មានឈ្មោះថា **កលន្ទកនិវាប** ជាទីប្រទាន ចំណីដល់កង្អែន ។ ព្រោះថា បទថា **កលន្ទក** ជាឈ្មោះរបស់កង្អែន ទាំងឡាយ ។

បទថា **ជាតិភូមិកា** បានដល់ អ្នកនៅក្នុងជាតិភូមិ ។ ក្នុងបទថា ជាតិ ភូមិនោះ ។ បទថា **ជាតិភូមិ** ប្រែថា ទីកើត ។ ទីកើតនោះ មិនមែនជាទី កើតរបស់ព្រះបាទកោសលមហារាជ មិនមែនទីកើតរបស់ចង្កីព្រាហ្មណ៍ មិន មែនទីកើតរបស់សក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត មិនមែនជាទី កើតរបស់ព្រះអសីតិមហាសាវក មិនមែនទីកើតរបស់សត្វដទៃជាដើមឡើយ ដែលហៅថា **ជាតិភូមិ** នោះ ។ តែក្នុងថ្ងៃដែលព្រះសព្វញ្ញូពោធិសត្វអង្គ ណាកើតហើយ លោកធាតុមួយម៉ឺន ដេរដាសដោយទង់ និងផ្កា ដូចៗ គ្នា ក្រអូបឈ្ងុយឈ្ងប់ដោយក្លិនផ្កា និងលម្អិត រុងរឿងដូចនន្ទវ័ន មានផ្ការីកស្គុស ស្គាយទូទៅ ដូចតំណក់ទឹកលើស្លឹកឈូក បាដិហារ្យជាច្រើន ដូចជាមនុស្ស

ភ្នែកខ្វាក់ឃើញរូបជាដើម ប្រព្រឹត្តទៅហើយ ទីកើតនៃព្រះសព្វញ្ញុព្រះពោធិ-សត្វអង្គនោះ គឺក្រុងកបិលពស្តុសក្កជនបទនោះឯង ហៅថា **ជាតិភូមិ**។ បទថា **វស្សំ វុដ្ឋា** បានដល់ នៅចាំវស្សា ៣ ខែ បវារណាហើយ ។ បទថា **ភគវា ឯតទវោច** សេចក្តីថា ព្រះមានព្រះភាគ ត្រាស់ព្រះពុទ្ធវចនៈថា **កោ នុ ខោ ភិក្ខវេ** ដូច្នេះជាដើមនោះ ទ្រង់ធ្វើបដិសណ្ឋារៈទទួលអាគន្តុកៈ ដោយព្រះតម្រាស់ជាដើមថា **កច្ចិ ភិក្ខវេ ខមនីយំ** បានឮថា ភិក្ខុទាំងនោះត្រូវព្រះមានព្រះភាគត្រាស់សួរដោយបដិសណ្ឋារៈថា ម្នាលភិក្ខុទាំងឡាយ ល្មមអត់ធន់បានឬទេ ល្មមប្រព្រឹត្តទៅបានឬទេ ពួកអ្នកមកអំពីឆ្ងាយ មិនលំបាកទេឬ មិនលំបាកដោយបិណ្ឌបាតទេឬ ពួកអ្នកមកអំពីណា ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ មកអំពីជាតិភូមិ គឺកបិលពស្តុសក្កជនបទ ។ លំដាប់នោះ ព្រះមានព្រះភាគមិនត្រាស់សួរដល់ការមិនមានរោគ របស់ព្រះបាទសុទ្ធោទនមហារាជ របស់ព្រះបាទសុក្កោទនៈ របស់ព្រះបាទសក្កោទនៈ របស់ព្រះបាទធោតោទនៈ របស់ព្រះបាទអមិតោទនៈ របស់ព្រះនាងអមិតា-ទេវី របស់ព្រះនាងមហាបជាបតី របស់វង្សស្តេចសក្យៈទាំងអស់ឡើយ ដោយពិតនោះ ទ្រង់ត្រាស់សួរភិក្ខុដែលបានកថាវត្ថុ ១០ ដោយខ្លួនឯង និងអ្នកដទៃដែលដឹកនាំក្នុងបដិបទានោះ ដែលជាអ្នកបរិបូណ៌ដោយបដិបទា ទើបត្រាស់ព្រះពុទ្ធវចនៈនេះថា **កោ នុ ខោ ភិក្ខវេ** ជាដើម ។

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់សួរការមិនមានរោគរបស់ព្រះបាទសុទ្ធោទនៈជាដើម ត្រាស់សួរចំពោះភិក្ខុបែបនោះប៉ុណ្ណោះ ។ ព្រោះ

ជាទីស្រឡាញ់ ពិតហើយ ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលជាអ្នកបដិបត្តិ រមែងជាទីស្រឡាញ់ ជាទីពេញព្រះហឫទ័យនៃព្រះពុទ្ធទាំងឡាយ ព្រោះហេតុអ្វី ព្រោះទ្រង់ជាអ្នកធ្ងន់ក្នុងធម៌ ។ ពិតហើយ ព្រះតថាគតទាំង-ឡាយ ជាអ្នកធ្ងន់ក្នុងធម៌ ។ ភាវៈដែលព្រះតថាគតទាំងឡាយនោះ ជាអ្នកធ្ងន់ក្នុងធម៌នោះ គប្បីជ្រាបដោយអធ្យាស្រ័យដែលកើតនាគល់នៃដើមអជបាលនិគ្រោធថា បុគ្គលមិនមានសេចក្តីគោរពកោតក្រែង រមែងនៅបានទាំងលំបាកណាស់ ។ ពិតហើយ ព្រោះភាពជាអ្នកធ្ងន់ក្នុងធម៌ ព្រះមានព្រះភាគ ទ្រង់ធ្វើការទទួលក្នុងថ្ងៃចេញបួសរបស់ព្រះមហាកស្សបត្ថេរ ទ្រង់បានយាងទៅអស់ចម្ងាយផ្លូវប្រមាណ ៣ គាវុត ។ ទ្រង់ធ្វើដំណើរជាង ៣០០ យោជន៍ សម្តែងធម៌ត្រង់ប្រាំងស្ទឹងគង្គា ស្ដាប់នាព្រះបាទកប្បិន មួយអន្លើនឹងបរិស័ទទុកក្នុងអរហត្ត ។ ក្នុងវេលាបច្ឆាភត្ត គ្រាមួយ ទ្រង់ធ្វើដំណើរ ៤៥ យោជន៍ ត្រាស់សម្តែងធម៌រហូត ៣ យាម ត្រង់លំនៅរបស់ស្មូនឆ្នាំង ទ្រង់ស្ដាប់នាបុក្-សាតិកុលបុត្រ ទុកក្នុងអនាគាមិផល ។ ទ្រង់ទៅអស់ចម្ងាយផ្លូវ ២០០០ យោជន៍ ទ្រង់អនុគ្រោះសាមណេរដែលនៅព្រៃ ។ ទ្រង់យាងទៅអស់ផ្លូវ ៦០ យោជន៍ សម្តែងធម៌ប្រោសខទិរវនិយត្ថេរ ទ្រង់ជ្រាបថា ព្រះអនុរុទ្ធត្ថេរគង់នៅត្រង់បាចីនវង្សទាយវ័ន ត្រិះរិះដល់មហាបុរិសវិតក្ក ហើយហោះទៅក្នុងទីនោះ ហើយទ្រង់ចុះខាងមុខរបស់ព្រះថេរៈ ប្រទានសាធុការ ។ ឲ្យក្រាលសេនាសនៈ ត្រង់ព្រះគន្ធកុដិតែមួយ សម្រាប់ព្រះកុដិកណ្ណសោណត្ថេរ ក្នុងវេលាជិតភ្លឺ អារាធនាឲ្យសម្តែងធម៌ ក្នុងវេលាចប់សរភញ្ញ បានប្រទាន

សាធុការ ។ ទ្រង់ធ្វើដំណើរ ៣ គាវុត ត្រាស់អានិសង្សសាមគ្គីរស ក្នុងគោសិង្គសាលវ័ន ដែលជាលំនៅរបស់កុលបុត្រ ៣ អង្គ ។ ចំណែកព្រះមានព្រះភាគទ្រង់ព្រះនាមថា កស្សប កើតសេចក្ដីស្និទ្ធស្នាលនឹងព្រះអរិយសាវ័កដែលតាំងនៅក្នុងអនាគាមិផល ទ្រង់យាងទៅឯលំនៅរបស់ស្មូនឆ្នាំងឈ្មោះឃដិការទទួលអាមិសដោយព្រះហស្ដរបស់ព្រះអង្គ ហើយសោយ ។ ព្រះមានព្រះភាគនៃយើងទាំងឡាយ កាលចូលវស្សា ភិក្ខុសង្ឃហែហម ទ្រង់ចេញចារិកអំពីវត្តជេតពន ។ ព្រះបាទកោសលមហារាជ និងអនាថបិណ្ឌិកសេដ្ឋីជាដើម មិនអាចធ្វើឲ្យទ្រង់វិលមកវិញបាន ។ អនាថបិណ្ឌិកសេដ្ឋីត្រឡប់មកផ្ទះហើយ ក៏អង្គុយសញ្ចប់សញ្ចឹង ។ ទាសីឈ្មោះបុណ្ណាពោលនឹងអនាថបិណ្ឌិកសេដ្ឋីថា លោកម្ចាស់មានទុក្ខព្រួយឬ ។ អនាថបិណ្ឌិសេដ្ឋីឆ្លើយថា អើ អញមិនអាចធ្វើឲ្យព្រះសាស្ដាយាងត្រឡប់បាន កាលបើយ៉ាងនោះអញក៏គិតថា អញនឹងមិនបានស្ដាប់ធម៌ ថ្វាយទានតាមបំណងអស់កាល ៣ ខែនេះ ។ នាងបុណ្ណាទាសីពោលថា លោកម្ចាស់ ខ្ញុំនឹងនាំព្រះសាស្ដាត្រឡប់មក ។ សេដ្ឋីពោលថា បើឯងអាចនាំព្រះសាស្ដាត្រឡប់មកបាន ឯងនឹងបានទៅជាអ្នកជា ។ នាងទៅក្រាបទៀបព្រះយុគលបាទរបស់ព្រះទសពលទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គមេត្តាយាងត្រឡប់ចុះ ព្រះមានព្រះភាគត្រាស់ថា បុណ្ណា នាងជាអ្នកអាស្រ័យគេចិញ្ចឹមជីវិត នឹងធ្វើអ្វីដល់តថាគតបាន ។ នាងក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំម្ចាស់មិនមានទេយ្យធម៌ទេ សូម្បីព្រះអង្គក៏ទ្រង់ជ្រាប តែបើព្រះអង្គយាងត្រឡប់ ជាហេតុ

ឲ្យខ្ញុំម្ចាស់តាំងនៅក្នុងសរណៈ ៣ និងសីល ៥ ។ ព្រះមានព្រះភាគ ទ្រង់ឲ្យសាធុការថា សាធុ បុណ្ណា ហើយទ្រង់យាងត្រឡប់ចូលកាន់វត្តជេតពននោះឯង ។ រឿងនេះប្រាកដឡើងហើយ ។ សេដ្ឋីស្តាប់ហើយ គិតថា បានឮថាព្រះមានព្រះភាគយាងត្រឡប់ ព្រោះនាងបុណ្ណា ហើយឲ្យនាងបុណ្ណាជាអ្នកជាហើយតាំងទុកក្នុងឋានៈជាកូនស្រី ។ នាងសូមបួស ហើយក៏បួស ផ្តើមចម្រើនវិបស្សនា ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបថា នាងផ្តើមចម្រើនវិបស្សនាហើយ ទ្រង់បញ្ចេញឱភាស ត្រាស់គាថានេះថា

**បុណ្ណេ បូរស្សុ ធម្មេហិ ចន្ទោ បណ្ណរសេរិវ**
**បរិបុណ្ណាយ បញ្ញាយ តមោក្ខន្ធំ បទាលយ ។**

ម្នាលនាងបុណ្ណា នាងពេញដោយពោធិបក្ខិយធម៌ទាំងឡាយ ដូចជាព្រះចន្ទក្នុងថ្ងៃ ១៥ កើត នាងចូរទម្លាយនូវគំនរងងឹត គឺមោហៈ ដោយបញ្ញាដ៏បរិបូណ៌[១] ។

កាលចប់គាថា នាងក៏សម្រេចអរហត្ត បានជាព្រះអរិយសាវិកា ដែលជាអ្នកមានឈ្មោះបោះសំឡេង ។ ព្រះតថាគតទាំងឡាយ ទ្រង់ជាអ្នកធ្ងន់ក្នុងធម៌ ដោយប្រការដូច្នេះ ។

កាលព្រះនន្ទុត្តរសម្តែងធម៌នៅក្នុងរោងធាន់ ព្រះមានព្រះភាគ មិននាំអ្វីទៅ ប្រថាប់ឈរស្តាប់ព្រះធម្មកថាអស់ ៣ យាម កាលចប់ទេសនា បានប្រទានសាធុការ ។ ព្រះថេរៈមកថ្វាយបង្គំ ទូលសួរថា បពិត្រព្រះអង្គដ៏

---

១- បិដកខ្មែរលេខ ៥៧ ទំព័រ ១៤៥ ។

ចម្រើន ព្រះអង្គមកក្នុងវេលាណា ព្រះមានព្រះភាគត្រាស់ថា កាលអ្នកទើប តែផ្តើមសួញ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គ ទ្រង់ធ្វើកិច្ចដែលធ្វើបានលំបាក ទ្រង់ជាព្រះពុទ្ធសុខុមាលជាតិ ។ ព្រះមានព្រះ ភាគត្រាស់ថា អានន្ទ បើអ្នកអាចសម្តែងបានមួយកប្ប តថាគតក៏គប្បីឈរ ស្តាប់អស់មួយកប្ប ។ ព្រះតថាគតទាំងឡាយធ្ងន់ក្នុងធម៌យ៉ាងនេះ អ្នកបដិបត្តិ ទាំងឡាយ រមែងជាទីស្រឡាញ់របស់ព្រះតថាគតទាំងនោះ ព្រោះជាអ្នកធ្ងន់ ក្នុងធម៌ ព្រោះដូច្នោះ ទើបត្រាស់សួរអ្នកបដិបត្តិទាំងឡាយ ។

ដែលឈ្មោះថា អ្នកបដិបត្តិ មាន ៤ ប្រភេទ គឺបដិបត្តិដើម្បីប្រយោជន៍ ខ្លួន និងបដិបត្តិមិនដើម្បីប្រយោជន៍អ្នកដទៃ ១ អ្នកបដិបត្តិដើម្បីប្រយោជន៍ អ្នកដទៃ មិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន ១ អ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន ផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ អ្នកមិនបដិបត្តិដើម្បីប្រយោជន៍ខ្លួនផង មិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃផង ១ ។ បណ្តាអ្នកបដិបត្តិទាំងនោះ បុគ្គល ណាបានកថាវត្ថុ ១០ ឯង មិនពោល មិនទូន្មានអ្នកដទៃក្នុងកថាវត្ថុ ១០ នោះ ដូចជាព្រះពាកុលៈ បុគ្គលនោះឈ្មោះថា បដិបត្តិដើម្បីប្រយោជន៍ខ្លួន មិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។ ព្រះមានព្រះភាគ មិនសួរភិក្ខុដែល មានសភាពយ៉ាងនេះ ។ ព្រោះហេតុអ្វី ព្រោះភិក្ខុនោះមិនតាំងនៅក្នុងតំណែង នៃសេចក្តីចម្រើនក្នុងសាសនារបស់តថាគត ។ ឯបុគ្គលមិនបានកថាវត្ថុ ១០ ទូន្មានភិក្ខុដទៃដោយកថាវត្ថុ ១០ នោះ ដើម្បីត្រេកអរក្នុងវត្តដែលភិក្ខុនោះធ្វើ ហើយ ដូចព្រះឧបនន្ទសក្យបុត្រ បុគ្គលនោះឈ្មោះថា បដិបត្តិដើម្បីប្រយោជន៍

អ្នកដទៃ មិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន ។ ព្រះមានព្រះភាគមិនត្រាស់សួរភិក្ខុដែលមានសភាពយ៉ាងនោះ ព្រោះហេតុអ្វី ព្រោះភិក្ខុទាំងនោះ លះតណ្ហាមិនបាន ដូចកំប្រោងធំ ។ បុគ្គលណាមិនបានកថាវត្ថុ ១០ ដោយខ្លួនឯង មិនដឹកនាំ មិនទូន្មានអ្នកដទៃ ដោយកថាវត្ថុ ១០ នោះ ដូចព្រះលោឡុទាយី បុគ្គលនេះឈ្មោះថា មិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងមិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។ ទ្រង់មិនត្រាស់សួរភិក្ខុបែបនោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកិលេសទាំងឡាយខាងក្នុងរបស់លោកមានច្រើន ដូចជាត្រូវកាត់ចេញដោយពូថៅ ។ ឯភិក្ខុណា ខ្លួនឯងបានកថាវត្ថុ ១០ ផង ទូន្មានភិក្ខុដទៃដោយកថាវត្ថុ ១០ ផង ភិក្ខុនោះឈ្មោះថា បដិបត្តិដើម្បីប្រយោជន៍ខ្លួនផង ប្រយោជន៍អ្នកដទៃផង ដូចព្រះអសីតិមហាថេរៈ មានព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះមហាកស្សបជាដើម ។ ទ្រង់ត្រាស់សួរភិក្ខុបែបនោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភិក្ខុនោះ តាំងនៅក្នុងចំណែកនៃការបម្រើក្នុងសាសនារបស់តថាគត ។ ព្រះមានព្រះភាគ កាលត្រាស់សួរចំពោះភិក្ខុបែបនោះក្នុងទីនេះ ទើបត្រាស់ថា **កោ នុ ខោ ភិក្ខវេ** ជាដើម ។

## អធិប្បាយ កថាវត្ថុ ១០

ភិក្ខុទាំងនោះ កាលព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះហើយ ព្រះមានព្រះភាគត្រាស់សួរភិក្ខុអ្នកបានកថាវត្ថុ ១០ អ្នកបដិបត្តិដើម្បីប្រយោជន៍ទាំង ២ ចំណែក ក្នុងជាតិភូមិរបស់ព្រះអង្គ ។ មានការគិត ឬប្រឹក្សាគ្នានឹងគ្នាថា ក្នុង

ភិក្ខុទាំងនោះ ភិក្ខុបណាដែលមានសភាពដូច្នោះ ព្រោះហេតុអ្វី ព្រោះមន្តានី-បុត្តភិក្ខុមានឈ្មោះបោះសំឡេងក្នុងជនបទនោះ ដូចព្រះចន្ទ និងព្រះអាទិត្យប្រាកដច្បាស់ក្នុងកណ្តាលអាកាស ដូច្នោះ ។ ព្រោះដូច្នោះ ភិក្ខុទាំងនោះប្រៀបដូចហ្វូងក្ងោកបានស្តាប់សំឡេងផ្គរ ក៏ប្រមូលប្រជុំគ្នា និងដូចភិក្ខុដែលផ្តើមធ្វើគណៈស្វាធ្យាយ កាលនឹងក្រាបទូលដល់ព្រះបុណ្ណត្ថេរដែលជាអាចារ្យរបស់ខ្លួន ដល់ព្រះមានព្រះភាគ សូម្បីមានមាត់ ក៏មិនគ្រប់គ្រាន់ល្មមក្នុងការពោលសរសើរគុណរបស់ព្រះថេរៈ ទើបបានពោលជាសំឡេងតែមួយថា **បុណ្ណោ នាម ភន្តេ អាយស្មា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បុណ្ណោ** ជាឈ្មោះរបស់ព្រះថេរៈនោះ តែព្រោះលោកជាបុត្ររបស់មន្តានី-ព្រាហ្មណី ដូច្នោះ ទើបហៅថា មន្តានីបុត្រ ។ បទថា **សម្ភាវិតោ** បានដល់លើកតម្កើងដោយពោលសរសើរគុណ ។ បទថា **អប្បិច្ឆោ** បានដល់ ប្រាសចាកការប្រាថ្នា អស់នូវការចង់បាន អស់តណ្ហា ។ ក្នុងពាក្យនេះ ហាក់ដូចជាសល់ព្យញ្ជនៈ ឯអត្ថមិនមានសល់ឡើយ ។ ព្រះបុណ្ណមន្តានីបុត្រនោះ មិនមានការប្រាថ្នានៅសេសសល់ សូម្បីតិចតួច ព្រោះលោកជាព្រះខីណាស្រពលះតណ្ហាដោយប្រការទាំងពួង ។ម្យ៉ាងទៀត ក្នុងបទថា **អប្បិច្ឆោ** នេះគប្បីជ្រាបការផ្សេងគ្នាដូច្នេះថា ភាពជាអ្នកប្រាថ្នាមិនមានព្រំដែន ភាពជាអ្នកប្រាថ្នាលាមក ភាពជាអ្នកប្រាថ្នាច្រើន ភាពជាអ្នកប្រាថ្នាតិច ។ ក្នុង ៤ ប្រភេទនោះ បុគ្គលមិនឆ្អែតក្នុងលាភរបស់ខ្លួន ប្រាថ្នាលាភរបស់អ្នកដទៃ ឈ្មោះថាភាពជាអ្នកប្រាថ្នាមិនមានព្រំដែន ។ បុគ្គលដែលប្រកបដោយការប្រាថ្នាមិន

មានព្រំដែន រមែងសម្លឹងឃើញទំដែលឆ្អិនហើយក្នុងភាជនៈតែមួយ ដែលដាក់ចូលក្នុងបាត្ររបស់ខ្លួនថា ដូចជាមិនទាន់ឆ្អិន និងជារបស់តិចតួច របស់តែមួយនោះឯង ដែលដាក់ចូលក្នុងបាត្រ របស់ភិក្ខុដទៃ រមែងមើលឃើញថាហាក់ដូចជារបស់ឆ្អិនល្អ និងជារបស់ច្រើន ។ ម្យ៉ាងទៀត ការអួតនូវគុណដែលមិនមាន និងការមិនស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ជាអ្នកមានការប្រាថ្នាលាមក ។ សេចក្ដីនោះ មកហើយក្នុងព្រះអភិធម្ម ដោយន័យជាដើមថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា សូមជនទាំងឡាយដឹងនូវអាត្មាអញថា ជាអ្នកមានសទ្ធា ។ បុគ្គលដែលប្រកបដោយភាពជាអ្នកប្រាថ្នាលាមកនោះ រមែងតាំងនៅក្នុងឋានៈជាអ្នកបោកបញ្ឆោត ។ ឯការពោលសរសើរគុណដែលមានក្ដី និងការមិនស្គាល់ប្រមាណក្នុងការទទួលក្ដី ឈ្មោះថា ជាអ្នកប្រាថ្នាច្រើន ។ ភាពជាអ្នកប្រាថ្នាច្រើននោះ ក៏មកហើយដោយន័យជាដើមថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសទ្ធា រមែងប្រាថ្នាថា សូមមហាជនដឹងថា អញមានសទ្ធា ជាអ្នកមានសីល រមែងប្រាថ្នាថា សូមមហាជនដឹងនូវអញថា ជាអ្នកមានសីល ។ បុគ្គលដែលប្រកបដោយការប្រាថ្នាច្រើននោះរមែងជាទីស្រឡាញ់របស់មនុស្សអាក្រក់ ។ សូម្បីមាតាដែលជាអ្នកបង្កើត ក៏មិនអាចនឹងផ្គាប់ចិត្តបុគ្គលនោះបាន ដោយហេតុនោះ ទើបលោកពោលពាក្យនេះថា

អតិត្តោ សមុទ្ទោ ច　　　មហិច្ឆោ ចាបិ បុគ្គលោ
សកដេន បច្ចយំ ទេតុ　　　តយោ បេតេ អតប្បិយា ។

គំនរភ្លើង ១ សមុទ្រ ១ បុគ្គលប្រាថ្នាច្រើន ១ ទាំង ៣ នេះ បុគ្គលសូម្បីឲ្យរបស់រហូតពេញរទេះ ក៏មិនធ្វើឲ្យឆ្អែតបាន ។

ឯការបិទបាំងគុណដែលមាន និងភាពជាអ្នកស្គាល់ប្រមាណ ក្នុងការទទួល ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ។ បុគ្គលប្រកបដោយភាពជាអ្នកប្រាថ្នាតិចនោះ ព្រោះបំណងនឹងបិទបាំងគុណដែលមាននៅក្នុងខ្លួន សូម្បីសម្បូរដោយសទ្ធា ក៏មិនប្រាថ្នាឲ្យអ្នកដទៃដឹងថា អញមានសទ្ធា ជាអ្នកមានសីលជាអ្នកស្ងាត់ ជាពហូសូត ជាអ្នកប្រារព្ធព្យាយាម បរិបូណ៌ដោយសមាធិ មានបញ្ញា ជាព្រះខីណាស្រព ក៏មិនប្រាថ្នាឲ្យអ្នកដទៃដឹងថា អញជាព្រះខីណាស្រព ដូចព្រះមជ្ឈន្តិកត្ថេរ ដូច្នោះ ។

បានឮថា ព្រះថេរៈជាព្រះខីណាស្រព ។ ឯបាត្រ និងចីវររបស់លោកមានតម្លៃត្រឹមមួយបាទប៉ុណ្ណោះ ។ លោកបានជាប្រធានសង្ឃ ក្នុងថ្ងៃឆ្លងវិហារនៃព្រះបាទធម្មាសោករាជ ។ កាលនោះ មនុស្សទាំងឡាយឃើញលោកមានចីវរសៅហ្មងពេក ទើបពោលថា សូមលោកម្ចាស់រង់ចាំខាងក្រៅបន្តិចសិន ។ ព្រះថេរៈគិតថា កាលព្រះខីណាស្រពដូចអាត្មាអញ មិនសង្គ្រោះព្រះរាជា អ្នកដទៃណានឹងសង្គ្រោះបាន ទើបមុជទៅក្នុងផែនដី ហើយផុសឡើង ទទួលយកអាហារដែលគេរៀបចំទុកសម្រាប់ព្រះថេរៈ ដែលជាប្រធានសង្ឃ ។ អម្បាលព្រះខីណាស្រពដែលមានសភាពយ៉ាងនេះ គង់មិនប្រាថ្នាថា សូមមហាជនដឹងនូវអាត្មាអញថា ជាព្រះខីណាស្រព ។ ឯភិក្ខុអ្នកប្រាថ្នាតិច តែងញុំាងលាភ ដែលមិនទាន់កើត ឲ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយ

ឲ្យតាំងនៅ ធ្វើចិត្តរបស់ពួកទាយកឲ្យត្រេកអរ ដោយប្រការដូច្នេះ ។ ពិត ហើយ ភិក្ខុដែលមានការប្រាថ្នាតិចនោះ រមែងទទួលយកតែបន្តិចបន្តួច ព្រោះ ខ្លួន ជាអ្នកប្រាថ្នាតិច ដោយប្រការណាមួយ ពួកមនុស្សដែលជ្រះថ្លាក្នុងវត្ត បដិបត្តិរបស់លោក រមែងឲ្យច្រើន ដោយប្រការនោះៗ ។ មា៉ងទៀត ភិក្ខុ អ្នកប្រាថ្នាតិច មាន ៤ ពួក គឺប្រាថ្នាតិចក្នុងបច្ច័យ ១ ប្រាថ្នាតិចក្នុងធុតង្គ ១ ប្រាថ្នាតិចក្នុងបរិយត្តិ ១ ប្រាថ្នាតិចក្នុងអធិគម ១ ។ ក្នុង ៤ ពួកនោះ ភិក្ខុប្រាថ្នាតិចក្នុងបច្ច័យ ៤ ឈ្មោះថា ប្រាថ្នាតិចក្នុងបច្ច័យ ។ ភិក្ខុប្រាថ្នាតិច ក្នុងបច្ច័យនោះ រមែងដឹងសមត្ថភាពរបស់ទាយក រមែងដឹងសមត្ថភាពរបស់ ទេយ្យធម៌ រមែងដឹងកម្លាំងរបស់ខ្លួន ។ ឧបមាថា ទេយ្យធម៌មានច្រើន តែ ទាយកប្រគេនតិច ក៏ទទួលយកតែបន្តិចបន្តួច តាមសមត្ថភាពរបស់ទាយក ទេយ្យធម៌មានតិច ទាយកប្រគេនច្រើន ក៏ទទួលយកតែតិចតួច តាមសមត្ថ-ភាពរបស់ទេយ្យធម៌ ទេយ្យធម៌មានច្រើនផង ទាយកត្រូវការប្រគេនច្រើនផង ក៏ដឹងកម្លាំងរបស់ខ្លួន ទទួលយកតែល្មមប្រមាណ ។ ភិក្ខុដែលមានការប្រាថ្នា តិច មិនត្រូវការឲ្យអ្នកដទៃដឹងនូវភាពដែលខ្លួនជាអ្នកសមាទានធុតង្គ ឈ្មោះ ថា ជាអ្នកប្រាថ្នាតិចក្នុងធុតង្គ ។ ដើម្បីធ្វើសេចក្តីនេះឲ្យជាក់ច្បាស់ មានរឿង ទាំងនេះជាគំរូ

បានឮមកថា ព្រះមហាសុមត្ថេរ ជាអ្នកសមាទានសោសានិកង្គធុតង្គ នៅក្នុងព្រៃខ្មោចមក ៦០ ឆ្នាំ តែភិក្ខុដទៃត្រឹមតែមួយរូបក៏មិនដឹង ដោយហេតុ នោះឯង ទើបលោកពោលថា

សុសានេ សដ្ឋិវស្សានិ អព្ភោកិណ្ណោ វសាមហំ
ទុតិយោ មំ ន ជានេយ្យ អហោ សោសានិកុត្តមោ។

ខ្ញុំនៅដោយទំនើងនោះឯង ក្នុងព្រៃស្មសាន មក ៦០ ឆ្នាំ សព្រហ្មចារី ក៏មិនដឹងខ្ញុំ ឱ កំពូលនៃអ្នករក្សាសោសានិកង្គធុតង្គ ។

ព្រះថេរៈ ២ នាក់បងប្អូន នៅត្រង់ចេតិយបពិត ។ ព្រះថេរៈជាប្អូនទទួល កំណាត់អំពៅ ដែលឧបដ្ឋាកបញ្ជូនមកឲ្យ បានទៅកាន់សម្នាក់របស់ព្រះថេរៈ ជាបងពោលថា សូមលោកម្ចាស់បងឆាន់ចុះ ។ គាប់ជួនជាវេលា ដែលព្រះ ថេរៈឆាន់ខ្ពុរមាត់ហើយ ។ ព្រះថេរៈជាបងពោលថា ខ្ញុំគ្រប់គ្រាន់ហើយ ។ ព្រះ ថេរៈជាប្អូនសួរថា លោកម្ចាស់បងសមាទានឯកាសនិកង្គធុតង្គឬ ព្រះថេរៈជា បងពោលថា អាវុសោ នាំកំណាត់អំពៅមក ។ សូម្បីបុគ្គលកាន់ឯកាស-និកង្គធុតង្គមក ដល់ទៅ ៥០ ឆ្នាំ ក៏បិទធុតង្គ ឆាន់ហើយខ្ពុរមាត់ អធិដ្ឋាន ធុតង្គជាថ្មីហើយទៅ ។ ឯភិក្ខុប្រាថ្នាតិចរូបណា មិនបំណងនឹងឲ្យគេដឹងនូវ ភាពដែលខ្លួនជាពហុស្សូត ដូចព្រះសាកេតកតិស្សត្ថេរ ភិក្ខុនេះ ឈ្មោះថា ជាអ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។ បានឮថា ព្រះថេរៈមិនធ្វើឱកាស ក្នុងឧទ្ទេស និងបរិបុច្ឆាថា មិនមានពេល ត្រូវជាស់តឿនថា លោកម្ចាស់គង់នឹងមានតែ ពេលស្លាប់ លះបង់ពួកគណៈហើយ ទៅវិហារជិតសមុទ្រ ដែលមានខ្សាច់ ដូចផ្កាកណិការ ជាអ្នកឧបការៈពួកភិក្ខុលំដាប់ព្រះថេរៈ នវក និងមជ្ឈិម អស់ មួយវស្សា ញុំាងប្រជុំជនឲ្យត្រេកអរដោយធម្មកថា ក្នុងថ្ងៃមហាបវារណា និង ថ្ងៃឧបោសថ ហើយទៅ ។ ឯភិក្ខុប្រាថ្នាតិចរូបណា ជាព្រះអរិយបុគ្គលមួយ

អង្គ ក្នុងបណ្តាព្រះអរិយបុគ្គលដែលជាសោតាបន្នជាដើម តែងមិនប្រាថ្នាឲ្យដឹងនូវភាពជាសោតាបន្នជាដើម ភិក្ខុដែលប្រាថ្នាតិចរូបនេះ ឈ្មោះថា ប្រាថ្នាតិចក្នុងអធិគម ដូចកុលបុត្រ ៣ នាក់ និងស្មូនឆ្នាំង ឈ្មោះឃដិការ ដូច្នោះ ។ ឯព្រះបុណ្ណៈលះនូវការប្រាថ្នាហួសព្រំដែន ការប្រាថ្នាលាមក និងការប្រាថ្នាច្រើន បានឈ្មោះថា ជាអ្នកប្រាថ្នាតិច ព្រោះជាអ្នកប្រកបដោយការប្រាថ្នាតិចដ៏បរិសុទ្ធ ពោល គឺការមិនលោភ ដែលជាបដិបក្ខចំពោះការប្រាថ្នា ដោយប្រការទាំងពួង ។ ព្រះបុណ្ណៈសម្តែងទោសក្នុងធម៌ទាំងនោះថា អាវុសោ ធម៌ទាំងនេះ គឺការប្រាថ្នាហួសព្រំដែន ការប្រាថ្នាលាមក ការប្រាថ្នាច្រើន ដែលភិក្ខុគួរលះ ដូច្នេះហើយ ទើបពោលអប្បិច្ឆកថាដល់ភិក្ខុទាំងឡាយថា ភិក្ខុគួរសមាទាន ប្រព្រឹត្តភាពជាអ្នកប្រាថ្នាតិចបែបនេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុដែលប្រាថ្នាតិចដោយខ្លួនឯង និងទូន្មានរឿងប្រាថ្នាតិច ដល់ភិក្ខុទាំងឡាយ ។

ឥឡូវនេះ ខ្ញុំនឹងសម្តែងអត្ថដែលវិសេស ក្នុងបទថា **អត្តនា ច សន្តុដ្ឋោ** ជាដើម ។ តែគប្បីជ្រាបការប្រកបដោយន័យដូចពោលមកហើយ ។ បទថា **សន្តុដ្ឋោ** បានដល់ ជាអ្នកប្រកបដោយការសន្តោសក្នុងបច្ច័យតាមមានតាមបាន ។ ឯការសន្តោសនេះ មាន ១២ យ៉ាង គឺអ្វីខ្លះ លំដាប់ដំបូង សន្តោសក្នុងចីវរ មាន ៣ យ៉ាង គឺ **យថាលាភសន្តោស យថាពលសន្តោស យថា-សារុប្បសន្តោស ។** ក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។ ពណ៌នាប្រភេទបច្ច័យ គឺចីវរនោះ ដូច្នេះ ភិក្ខុក្នុងសាសនានេះ បានចីវរល្អក្តី មិនល្អក្តី ក៏ញុំាងអត្តភាព

ប្រព្រឹត្តទៅ ដោយចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃ ទោះបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។ម្យ៉ាងទៀត ភិក្ខុណាទុព្វលភាពដោយប្រក្រតី ឬត្រូវជំងឺតម្កាត់ និងជរាគ្របសង្កត់ គ្រង ចីវរធ្ងន់ក៏លំបាក ភិក្ខុនោះប្តូរចីវរនឹងភិក្ខុដែលពេញចិត្តស្មើគ្នា ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ជាអ្នកសន្តោសដូចគ្នា នេះឈ្មោះថា **យថាពលសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត ជាអ្នកបាន បច្ច័យដ៏ប្រណីត លោកបានចីវរមានតម្លៃច្រើនមួយផ្ទាំង មានចីវរព្រៃជាដើម ឬបានចីវរច្រើន គិតថា ចីវរនេះសមគួរដល់ព្រះថេរៈដែលបួសយូរ មួយផ្ទាំង នេះសមគួរដល់ភិក្ខុដែលជាពហុស្សុត មួយផ្ទាំងនេះសមគួរដល់ភិក្ខុដែលមាន ជំងឺ មួយផ្ទាំងនេះសមគួរដល់ភិក្ខុដែលមានលាភតិច ប្រគេនហើយ ជ្រើស យកចីវរចាស់ៗ ក្នុងបណ្តាចីវរទាំងនោះ ឬចម្រៀកសំពត់អំពីគំនរសំរាមជា ដើមធ្វើសង្ឃាដី ដោយសំពត់ទាំងនោះ សូម្បីគ្រងក៏ជាអ្នកសន្តោសនោះឯង នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានបិណ្ឌបាត មិនថាអន់ ឬប្រណីត លោកញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះប៉ុណ្ណោះ មិនប្រាថ្នា បិណ្ឌបាតដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ តែភិក្ខុណា បានបិណ្ឌបាតដែលស្លែងដល់ ប្រក្រតីរបស់ខ្លួន ឬស្លែងដល់រោគ កាលបើលោកឆាន់ហើយ មិនមានផាសុក ភិក្ខុនោះប្រគេនបិណ្ឌបាតនោះ ដល់ភិក្ខុដែលរាប់អានគ្នា ឆាន់ភោជនដែល

សប្បាយអំពីដៃរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត បានបិណ្ឌបាតប្រណីតដ៏ច្រើន លោកប្រគេនបិណ្ឌបាតនោះដល់ពួកភិក្ខុដែលបួសយូរ ដែលជាពហុស្សូត ជាអ្នកមានលាភតិច និងភិក្ខុឈឺ ដូចក្នុងចីវរដែរ សូម្បីឆាន់បិណ្ឌបាតដែលសល់របស់ភិក្ខុទាំងនោះ ឬត្រាច់បិណ្ឌបាត ហើយឆាន់អាហារលាយគ្នា ក៏នៅតែឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានសេនាសនៈពេញចិត្តក្ដី ឬមិនគួរពេញចិត្តក្ដី លោកមិនកើតសោមនស្ស មិនកើតបដិឃៈ ដោយសេនាសនៈនោះ ត្រេកអរដោយសេនាសនៈតាមដែលបាន ដោយហោចកម្រាលដែលធ្វើដោយស្មៅ នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត ភិក្ខុណាបានសេនាសនៈដែលស្លែងដល់ប្រក្រតីរបស់ខ្លួន ឬស្លែងដល់រោគ កាលនៅក៏មិនមានផាសុក ភិក្ខុនោះប្រគេនសេនាសនៈនោះដល់ភិក្ខុដែលរាប់អានគ្នា នៅក្នុងសេនាសនៈដែលជាសប្បាយ ដែលជាចំណែករបស់លោក ក៏នៅឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានសេនាសនៈច្រើន មានទីសម្ងំ មណ្ឌប និងផ្ទះកំពូលជាដើម លោកប្រគេនសេនាសនៈទាំងនោះ ដល់ភិក្ខុដែលបួសយូរ ដែលជាពហុស្សូត ដែលមានលាភតិច និងភិក្ខុឈឺ ដូចចីវរជាដើមដែរ សូម្បីនៅក្នុងទីណាមួយ ក៏

ឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងសេនាសនៈ របស់ភិក្ខុនោះ ។ សូម្បីភិក្ខុណាពិចារណាថា សេនាសនៈដ៏ឧត្តម ជាទីតាំង នៃសេចក្ដីប្រមាទ កាលអង្គុយក្នុងទីនោះ រមែងងងុយដេក កាលលក់ហើយ ភ្ញាក់ឡើង វិតក្កដ៏លាមកក៏ប្រាកដ ហើយមិនទទួលសេនាសនៈដូច្នោះ សូម្បី មកដល់ហើយ លោកបដិសេធហើយ នៅកណ្ដាលវាលក្ដី គល់ឈើជាដើម ក្ដី ក៏ឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុង សេនាសនៈ ។

ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានភេសជ្ជៈ មិនថា អន់ ឬប្រណីត ត្រេកអរដោយភេសជ្ជៈដែលបាន មិនប្រាថ្នាភេសជ្ជៈដទៃ សូម្បីបាន ក៏មិន ទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងគិលានប្បច្ច័យរបស់លោក ។ ម្យ៉ាងទៀត ភិក្ខុណាត្រូវការប្រេង តែបានទឹកអំពៅ លោកប្រគេនទឹកអំពៅ នោះដល់ភិក្ខុដែលត្រូវអធ្យាស្រ័យគ្នា កាន់យកប្រេងអំពីដៃរបស់ភិក្ខុនោះ ឬ ស្វែងរកទៀតក្ដី ធ្វើភេសជ្ជៈដោយបច្ច័យទាំងនោះ ក៏ឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងគិលានប្បច្ច័យរបស់លោក ។ ភិក្ខុមួយ រូបទៀត មានបុណ្យច្រើន បានភេសជ្ជៈប្រណីត មានប្រេង ទឹកឃ្មុំ ទឹក អំពៅជាដើមជាច្រើន លោកប្រគេនភេសជ្ជៈនោះ ដល់ភិក្ខុដែលបួសយូរ ភិក្ខុ ជាពហូសូត ភិក្ខុមានលាភតិច និងភិក្ខុឈឺជាដើម ដូចក្នុងចីវរប្បច្ច័យដែរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភេសជ្ជៈណាមួយ ដែលបានមកអំពីគិលាន-ប្បច្ច័យទាំងនោះ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ ម្យ៉ាងទៀត ភិក្ខុណាដែល

ភិក្ខុទាំងឡាយដាក់សម៉ត្រាំក្នុងភាជនៈមួយ ដាក់មធុរស ៤ យ៉ាង ទុកក្នុងភាជនៈមួយ ហើយពោលថា និមន្តកាន់យកវត្ថុដែលត្រូវការចុះ បើរោគរបស់លោករម្ងាប់ដោយរបស់ណាមួយ ក្នុងរបស់ទាំងនោះ កាលបើដូច្នោះ លោកក៏ហាមថា ដែលឈ្មោះថា សម៉ត្រាំ ព្រះសម្ពុទ្ធជាដើមទ្រង់សរសើរហើយ ធ្វើកេសជ្ជៈដោយសម៉ត្រាំប៉ុណ្ណោះ ឈ្មោះថា ជាអ្នកសន្តោសយ៉ាងក្រៃលែង នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងគិលានប្បច្ច័យ ។ យថាសារុប្បសន្តោស ជាកំពូលរបស់សន្តោសទីមួយៗ ៣ ក្នុងបច្ច័យទីមួយៗ ទាំងនេះ ព្រះបុណ្ណៈបានជាអ្នកសន្តោស ដោយការសន្តោសទាំង ៣ យ៉ាងនេះក្នុងបច្ច័យទីមួយៗ ។

## សំសគ្គ ៥ យ៉ាង

បទថា **សន្តុដ្ឋិកថញ្ច** បានដល់ ទូន្មានរឿងសន្តោសនេះដល់ភិក្ខុទាំងឡាយ ។ បទថា **បវិវិត្តោ** បានដល់ ជាអ្នកប្រកបដោយវិវេក ៣ នេះ គឺ កាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។ ក្នុងវិវេក ៣ នោះ ភិក្ខុដើរមួយអង្គឯង ឈរមួយអង្គឯង អង្គុយមួយអង្គឯង ដេកមួយអង្គឯង បិណ្ឌបាតមួយអង្គឯង ត្រឡប់វិញមួយអង្គឯង ចង្ក្រមមួយអង្គឯង ត្រាច់ចរមួយអង្គឯង នៅសម្ងំមួយអង្គឯង នេះឈ្មោះថា កាយវិវេក ។ ឯសមាបត្តិ ៨ ឈ្មោះថា ចិត្តវិវេក ។ និព្វាន ឈ្មោះថា ឧបធិវិវេក ។ សមដូចលោកពោលថា កាយវិវេកសម្រាប់អ្នកមានកាយគេចចេញ ( ចាកពួក ) អ្នកត្រេកអរចំពោះនេក្ខម្មៈ ចិត្តវិវេកសម្រាប់អ្នកមានចិត្តបរិសុទ្ធ អ្នកដល់សេចក្តីផូរផង់ដ៏

ក្រៃលែង ឯឧបធិវិវេក សម្រាប់បុគ្គលមិនមានឧបធិ អ្នកដល់នូវវិសង្ខារ គឺព្រះនិព្វាន ។ បទថា **បវិវេកដំ** បានដល់ ទូន្មានរឿងវិវេកនេះ ដល់ភិក្ខុទាំងឡាយ ។ បទថា **អសំសដ្ឋោ** បានដល់ ការប្រឡូកប្រឡំ ៥ យ៉ាង ។ ការប្រឡូកប្រឡំ ៥ យ៉ាង គឺសវនសំសគ្គៈ ១ ទស្សនសំសគ្គៈ ១ សមុល្លាបសំសគ្គៈ ១ សម្ភោគសំសគ្គៈ ១ កាយសំសគ្គៈ ១ ។

ក្នុងសំសគ្គៈ ៥ យ៉ាងនោះ ភិក្ខុក្នុងធម្មវិន័យនេះ បានឮថា ស្ត្រី ឬស្រីក្រមុំក្នុងស្រុកក្តី តំបន់ក្តីនោះស្អាត គួរសរសើរ ស្រស់បស់ មានពណ៌សម្បុរល្អក្រៃលែង ស្តាប់រឿងនោះហើយ រសាប់រសល់ មិនអាចបន្តព្រហ្មចរិយៈតទៅបាន សឹកដោយមិនបានពោលលាសិក្ខាឡើយ កាលលោកស្តាប់អ្នកដទៃនិយាយដល់រូបសម្បត្តិជាដើម ឬសំឡេងសើច ខ្លួនក៏កើតរាគៈដោយសោតវិញ្ញាណវិថី ឈ្មោះថា សវនសំសគ្គៈ ។ ឯសំសគ្គៈនោះ គប្បីជ្រាបដោយអំណាចព្រះអនិដ្ឋិគន្ធបច្ចេកពោធិសត្វ និងព្រះតិស្សកំលោះ ដែលនៅក្នុងបញ្ចគ្គឡគុហា ។ បានឮថា ភិក្ខុកំលោះហោះទៅបានឮសំឡេងកូនក្រមុំជាងមាស អ្នកដែនគិរិគាម ទៅកាន់ស្រះជាមួយស្ត្រី ៥ នាក់ ងូតទឹកលម្អខ្លួន ដោយផ្កាឈូក ច្រៀងដោយសំឡេងដ៏ពីរោះ ត្រូវកាមរាគៈចាក់ដោតវិនាសចាកឈាន ដល់នូវសេចក្តីវិនាស ។

ភិក្ខុក្នុងធម្មវិន័យនេះ មិនបានឮសំឡេងឡើយ តែខ្លួនឯងឃើញមនុស្សស្រី ឬស្រីក្រមុំដែលស្អាតគួរសរសើរ ស្រស់បស់ មានពណ៌សម្បុរល្អក្រៃលែង លោកឃើញហើយ រសាប់រសល់ មិនអាចបន្តព្រហ្មចរិយៈទៅបាន

សឹកមិនបានពោលលាសិក្ខា កាលលោកសម្លឹងមើលរូប ដែលជាសត្រូវយ៉ាងនេះ កើតរាគៈដោយចក្ខុវិញ្ញាណ ឈ្មោះថា ទស្សនសំសគ្គៈ ។ ទស្សនសំសគ្គៈនោះ គប្បីជ្រាបដូច្នេះថា

បានឮថា ភិក្ខុកំលោះមួយរូបទៅកាន់ទូរវិហារ ក្បែរបឹងកាលទីយៈ ដើម្បីរៀនឧទ្ទេស អាចារ្យឃើញអន្តរាយរបស់លោក ក៏មិនឲ្យឱកាស លោកក៏ព្យាយាមតាមជាប់ទៅ ។ អាចារ្យពោលថា បើអ្នកមិនត្រាច់ទៅក្នុងស្រុក ខ្ញុំនឹងបង្រៀនឧទ្ទេស ។ លោកទទួលពាក្យហើយ កាលរៀនឧទ្ទេសចប់ ក៏ថ្វាយបង្គំលាអាចារ្យទៅ គិតថា អាចារ្យមិនឲ្យអញត្រាច់ទៅក្នុងស្រុកនេះ ព្រោះហេតុអ្វីហ្ន៎ ដណ្តប់ចីវរចូលស្រុក ។ កុលធីតាម្នាក់ស្លៀកសំពត់ពណ៌លឿងឈរត្រង់ផ្ទះ ឃើញភិក្ខុក៏កើតរាគៈ យកបោយនាំយាគូមកដាក់ក្នុងបាត្រ ហើយត្រឡប់ទៅដេកលើគ្រែ កាលនោះ ទើបមាតាបិតាសួរថា តើកូនកើតអ្វី កុលធីតានោះឆ្លើយថា បើខ្ញុំបានភិក្ខុកំលោះដែលទៅត្រង់ទ្វារ ទើបមានជីវិតនៅបាន បើមិនបានខ្ញុំនឹងស្លាប់ ។ មាតាបិតាប្រញាប់ទៅជួបភិក្ខុកំលោះ ត្រង់ទ្វារស្រុក ថ្វាយបង្គំហើយ ប្រាប់ថា សូមលោកម្ចាស់ត្រឡប់មកទទួលភិក្ខា ។ ភិក្ខុកំលោះប្រាប់ថា គ្រប់គ្រាន់ហើយញោម អាត្មានឹងទៅ មាតាបិតាអង្វរថា រឿងនោះវាយ៉ាងនេះ ក្នុងផ្ទះរបស់ខ្ញុំព្រះករុណា មានទ្រព្យប៉ុណ្ណេះ ខ្ញុំមានកូនក្រមុំម្នាក់ប៉ុណ្ណោះ សូមលោកម្ចាស់មកជាកូនប្រុសច្បងរបស់ខ្ញុំចុះ អាចនៅបានយ៉ាងសប្បាយ ភិក្ខុកំលោះឆ្លើយថា អាត្មាមិនត្រូវការបលិពោធយ៉ាងនេះ មិនជាប់ជំពាក់ ហើយទៅ ។ មាតាបិតាទៅប្រាប់កូនស្រីថា នែកូន ពុក និង

ម៉ែមិនអាចនាំភិក្ខុកំលោះមកបានឡើយ ជ្រើសរើសស្វាមីដទៃដែលកូនត្រូវការចុះ ចូរកូនក្រោកឡើង មកបរិភោគបាយទឹកចុះ ។ កុលធីតានោះ ក៏មិនប្រាថ្នានាងអត់បាយ ៧ ថ្ងៃ ស្លាប់ទៅ ។ មាតាបិតាធ្វើឈាបនកិច្ចនាងហើយ ប្រគេនសំពត់ពណ៌លឿងមួយផ្ទាំងនោះ ដល់ភិក្ខុសង្ឃក្នុងទូរវិហារ ។ ភិក្ខុទាំងឡាយក៏ហែកជាចម្រៀកតូចធំចែកគ្នា ។ ភិក្ខុចាស់មួយរូបទទួលចំណែករបស់ខ្លួនទៅមកកាន់កល្យាណវិហារ ។ ភិក្ខុកំលោះនោះ គិតនឹងទៅថ្វាយបង្គំព្រះចេតិយក៏ទៅត្រង់កល្យាណវិហារនោះ អង្គុយក្នុងទីសម្រាកពេលថ្ងៃ ភិក្ខុចាស់ទាញសំពត់នោះមកហើយ ប្រាប់ភិក្ខុកំលោះថា លោកម្ចាស់ សូមប្រើសំពត់មួយផ្ទាំងនេះរបស់ខ្ញុំ ជាសំពត់តម្រងទឹកចុះ ។ ភិក្ខុកំលោះសួរថា លោកម្ចាស់បានមកអំពីណា ភិក្ខុចាស់និយាយរឿងទាំងអស់នោះ ។ ភិក្ខុកំលោះស្តាប់រឿងនោះហើយ គិតថា អញមិនបាននៅរួមជាមួយស្រីនេះ ត្រូវភ្លើងរាគៈដុតរោល ក៏អនិច្ចធម្មក្នុងទីនោះឯង ។

ឯរាគៈដែលកើតដោយការសន្ទនា ប្រាស្រ័យគ្នានឹងគ្នា ឈ្មោះសមុល្លាបសំសគ្គៈ ។ រាគៈដែលកើតដោយភិក្ខុ ទទួលរបស់ភិក្ខុនី ឬភិក្ខុនីទទួលរបស់ភិក្ខុ ហើយបរិភោគ ឈ្មោះសម្ភោគសំសគ្គៈ ។ សម្ភោគសំសគ្គៈនោះគប្បីជ្រាបដូច្នេះ

បានឮថា កាលធ្វើមរិចិវត្តិយវិហារ មានភិក្ខុមួយសែនរូប ភិក្ខុនី ៩ ម៉ឺនរូប ។ សាមណេរមួយរូប ទទួលយាគូក្តៅដាក់ត្រង់ជាយចីវរម្តង ដាក់លើផែនដីម្តង ។ សាមណេរីមួយរូបឃើញ ប្រគេនស្លាកបាត្រ ដោយពោល

ថា ដាក់បាត្រទុកក្នុងទីនេះហើយសឹមទៅ ។ ខាងក្រោយមក កាលភ័យកើតឡើង ទាំងពីរអង្គក៏ទៅកាន់ចេតិយសមុទ្ទវិហារ ទាំង ២ រូបនោះ ភិក្ខុនីទៅមុន ។ ភិក្ខុនីនោះបានឮថា ភិក្ខុអ្នកសីហឡមួយរូបមក ក៏ទៅកាន់សម្នាក់ព្រះថេរៈ ធ្វើបដិសណ្ឋារៈ ហើយអង្គុយ សួរថា បពិត្រលោកម្ចាស់ ក្នុងកាលចូលមរិចិ-វដ្ដិយវិហារ លោកម្ចាស់មានវស្សាប៉ុន្មាន ព្រះថេរៈឆ្លើយថា កាលនោះ ខ្ញុំជាសាមណេរអាយុ ៧ ឆ្នាំ ចុះអ្នកនាងម្ចាស់វិញវស្សាប៉ុន្មាន ភិក្ខុនីឆ្លើយថា កាលនោះ ខ្ញុំជាសាមណេរីអាយុ ៧ ឆ្នាំដូចគ្នា ខ្ញុំបានឲ្យស្ងោកបាត្រដល់សាមណេរមួយរូប ដែលទទួលយាគូក្ដៅទៅដើម្បីទ្របាត្រ ។ ព្រះថេរៈប្រាប់ថា សាមណេរនោះ គឺខ្ញុំនេះឯង នាំស្ងោកបាត្រចេញមកបង្ហាញ ។ ដោយសំសគ្គៈនេះឯង ទាំង ២ អង្គ លោកមិនអាចបន្តព្រហ្មចរិយទៅទៀត សឹកក្នុងវេលាអាយុ ៦០ ឆ្នាំ ។

រាគៈដែលកើតឡើងដោយការចាប់ដៃជាដើម ឈ្មោះថា កាយសំសគ្គៈ ក្នុងសេចក្ដីនោះ មានរឿងនេះជាគំរូ

បានឮថា ត្រង់មហាចេតិយង្គណៈ ពួកភិក្ខុកំលោះធ្វើការស្វាធ្យាយ ពួកភិក្ខុនីក្រមុំស្ដាប់ធម៌នៅខាងក្រោយពួកភិក្ខុកំលោះទាំងនោះ ។ ក្នុងភិក្ខុកំលោះទាំងនោះ ភិក្ខុកំលោះមួយរូប លាដៃចេញទៅ ត្រូវកាយភិក្ខុនីក្រមុំមួយរូប ។ ភិក្ខុនីក្រមុំចាប់ដៃមកផ្ទឹបទុកត្រង់ទ្រូងរបស់ខ្លួន ។ ដោយសំសគ្គៈនោះ ទាំង ២ អង្គក៏សឹកជាគ្រហស្ថ ។

ក្នុងសំសគ្គៈទាំង ៥ យ៉ាងនេះ ការស្ដាប់ ការឃើញ ការចរចា ការរួម

ការពាល់ត្រូវកាយរបស់ភិក្ខុ និងភិក្ខុទាំងឡាយ រមែងមានជានិច្ចនោះឯង វៀរ កាយសំសគ្គៈ គឺការប៉ះពាល់ជាមួយភិក្ខុនីទាំងឡាយ រមែងមានម្តងម្កាល ។ សំសគ្គៈទាំងអស់ជាមួយឧបាសក ឧបាសិកាទាំងឡាយ ក៏មានម្តងម្កាលដូចគ្នា ។ គប្បីរក្សាចិត្តចាកការកើតកិលេស ក្នុងសំសគ្គៈទាំងនោះ ។ ភិក្ខុមួយអង្គជាគាហគាហកៈ មួយអង្គជាគាហមុត្តកៈ មួយអង្គជាមុត្តគាហកៈ មួយអង្គជាមុត្តមុត្តកៈ ។ ក្នុងភិក្ខុទាំងនោះ ពួកមនុស្សចូលទៅរកភិក្ខុ ដោយការយកអាមិសបញ្ឆោតចាប់ទុកក្តី ភិក្ខុចូលទៅរកមនុស្ស ដោយការយកផ្កា ផ្លែឈើជាដើមបញ្ឆោតចាប់ទុកក្តី នេះឈ្មោះថា **គាហគាហក** គឺចាប់ទៅចាប់មក ។ ចំណែកមនុស្សចូលទៅរកភិក្ខុ ដោយន័យដែលពោលហើយ ភិក្ខុចូលទៅរកដោយភាពជាទក្ខិណេយ្យបុគ្គល នេះឈ្មោះថា **គាហមុត្តក** គឺផុតចាកអ្នកចាប់ ។ មនុស្សទាំងឡាយប្រគេនបច្ច័យ ៤ ដោយភាពជាទក្ខិ-ណេយ្យបុគ្គល ឯភិក្ខុចូលទៅរកដោយយកផ្កា ផ្លែឈើជាដើមបញ្ឆោតចាប់ទុក នេះឈ្មោះថា **មុត្តគាហ** គឺមួយលែង មួយចាប់ ។ មនុស្សទាំងឡាយប្រគេនបច្ច័យ ៤ ដោយភាពជាទក្ខិណេយ្យបុគ្គលក្តី ភិក្ខុបរិភោគដោយភាពជាទក្ខិណេយ្យបុគ្គល ដូចព្រះចុល្លបិណ្ឌបាតិយតិស្សត្ថេរក្តី នេះឈ្មោះថា **មុត្តមុត្តក** លែងទាំងអស់គ្នា ។ បានឮថា ឧបាសិកាម្នាក់ ឧបដ្ឋាកព្រះថេរៈមកអស់ ១២ ឆ្នាំ ។ ថ្ងៃមួយ ភ្លើងឆេះផ្ទះត្រង់ភូមិនោះ ។ ភិក្ខុប្រចាំត្រកូលរបស់ជនដទៃក៏មកសួរថា ឧបាសិកា ភ្លើងអាចធ្វើវត្ថុណាមួយឲ្យមិនខូចខាតមានខ្លះឬ មនុស្សទាំងឡាយ ពោលថា ព្រះថេរៈប្រចាំត្រកូលមាតារបស់ខ្ញុំ

មកតែក្នុងវេលាឆាន់ប៉ុណ្ណោះ ។ ថ្ងៃស្អែកឡើង ព្រះថេរៈកំណត់កាលនៃភិក្ខាចារហើយ ក៏មក ។ ឧបាសិកា និមន្តឲ្យគង់ត្រង់ម្លប់ជម្រក រៀបចំភិក្ខាប្រគេន ។ កាលព្រះថេរៈឆាន់ស្រេចក៏ហើយទៅ មនុស្សទាំងឡាយក៏ពោលថា ព្រះថេរៈប្រចាំត្រកូលរបស់មាតាខ្ញុំ មកតែក្នុងវេលាឆាន់ប៉ុណ្ណោះ ។ ឧបាសិកាពោលថា ភិក្ខុប្រចាំត្រកូលរបស់ពួកអ្នក ក៏សមគួរដល់ពួកអ្នកប៉ុណ្ណោះ ព្រះថេរៈរបស់ខ្ញុំ ក៏សមគួរដល់ខ្ញុំប៉ុណ្ណោះ ។ ព្រះមន្តានីបុត្រមិនច្រឡូកច្រឡំដោយបរិស័ទ ៤ ដោយសំសគ្គៈ ៥ យ៉ាងនេះ ទើបជាគាហមុត្តកៈផង មុត្តមុត្តកៈផង លោកមិនច្រឡូកច្រឡំឯង យ៉ាងណា ក៏បានទូន្មានក្នុងការមិនច្រឡូកច្រឡំនោះ ដល់ភិក្ខុទាំងឡាយ ដូច្នោះ ។

បទថា **អារទ្ធវីរិយោ** បានដល់ ផ្គងសេចក្តីព្យាយាម អធិប្បាយថា មានសេចក្តីព្យាយាមតាមកាយ និងផ្លូវចិត្តបរិបូណ៌ ។ ពិតហើយ ភិក្ខុណាដែលកិលេសកើតឡើងក្នុងខណៈដើរ រមែងមិនព្រមឈរ កិលេសកើតឡើងក្នុងខណៈឈរ ក៏មិនព្រមអង្គុយ កិលេសកើតឡើងក្នុងខណៈអង្គុយក៏មិនព្រមដេក រមែងត្រាច់ទៅ ដូចវាយមន្តបញ្ឈពស់វែក ចាប់ទុក និងដូចជាន់កសត្រូវ ភិក្ខុនេះឈ្មោះថា ជាអ្នកប្រារព្ធសេចក្តីព្យាយាម ។ ព្រះថេរៈក៏ដូច្នោះ ទូន្មានអំពីការប្រារព្ធព្យាយាមដល់ភិក្ខុទាំងឡាយ យ៉ាងនោះដូចគ្នា ។ ចតុប្បារិសុទ្ធិសីល ឈ្មោះថា សីល ក្នុងបទថា **សីលសម្បន្នោ** ជាដើម ។ សមាបត្តិ ៨ ជាបាទនៃវិបស្សនា ឈ្មោះថា សមាធិ ។ ញាណដែលជាលោកិយ និងលោកុត្តរ ឈ្មោះថា បញ្ញា ។ វិមុត្តិដែលជាអរិយផល ឈ្មោះ

ថា វិមុត្តិ ។ បច្ចវេក្ខណញ្ញាណ ១៩ ឈ្មោះថា ញាណទស្សនៈ ។ ព្រះថេរៈបរិបូណ៌ដោយសីលជាដើម ទូន្មានអំពីសីលជាដើមដល់ភិក្ខុទាំងឡាយ ។ ព្រះមន្តានីបុត្រនេះ ឈ្មោះថា **ឱវាទក** ព្រោះឱវាទដោយកថាវត្ថុ ១០ ភិក្ខុមួយរូបរមែងទូន្មានខ្លួនបានតែម្យ៉ាង មិនអាចលើកភាពដែលល្អិតឲ្យអ្នកដទៃដឹងបាន យ៉ាងណា ព្រះថេរៈមិនមែនដូច្នោះឡើយ ។ តែព្រះថេរៈ ឈ្មោះថា **វិញ្ញាបក** ព្រោះធ្វើអ្នកដទៃឲ្យដឹងកថាវត្ថុ ១០ នោះផង ។ ភិក្ខុមួយរូបអាចធ្វើអ្នកដទៃឲ្យដឹង មិនអាចនឹងសម្តែងហេតុបាន ។ ព្រះថេរៈ ឈ្មោះថា **សន្ទស្សក** ព្រោះសម្តែងហេតុបានផង ។ ភិក្ខុមួយរូបសម្តែងហេតុដែលមានតែមិនអាចឲ្យអ្នកដទៃស្តាប់បាន ។ ព្រះថេរៈ ឈ្មោះថា **សមាទបក** ព្រោះអាចឲ្យអ្នកដទៃស្តាប់បាន ។ ព្រះថេរៈឈ្មោះថា **សមុត្តេជក** ព្រោះកាលដឹកនាំអ្នកដទៃយ៉ាងនោះហើយ ធ្វើភិក្ខុទាំងឡាយឲ្យអាចហ៊ាន ដោយធ្វើឲ្យកើតឧស្សាហ៍ក្នុងកថាវត្ថុទាំងនោះ ។ ឈ្មោះថា **សម្បហំសក** ព្រោះសរសើរភិក្ខុដែលកើតឧស្សាហ៍ ហើយធ្វើឲ្យត្រេកអរ ។ បទថា **សុលទ្ធលាភា** បានដល់រមែងឈ្មោះថា បានគុណ មានអត្តភាពជាមនុស្ស និងបព្វជ្ជាជាដើមរបស់ភិក្ខុពួកដទៃ អធិប្បាយថា គុណធម៌ទាំងនេះ ជាលាភយ៉ាងល្អរបស់ព្រះបុណ្ណៈជាអ្នកដែលមានឈ្មោះបោះសំឡេង ខ្វរខ្វាយទៅយ៉ាងនេះ ចំពោះព្រះភក្ត្រនៃព្រះសាស្តា ។ ម្យ៉ាងទៀត ការពោលសរសើរដោយបុគ្គលដែលមិនមែនជាបណ្ឌិត មិនជាលាភយ៉ាងនោះ ឯការសរសើរដោយបណ្ឌិត ទើបជាលាភ ម្យ៉ាងទៀត ការសរសើរដោយគ្រហស្ថ ក៏មិនជាលាភយ៉ាងនោះ ។ គ្រហស្ថ

គិតថា អញនឹងសរសើរ កំពុងពោលថា លោកម្ចាស់របស់យើង ជាបុគ្គលមានវាចាល្អិតល្អន់ មានវាចាគួរគប់រក ជាសម្លាញ់ មានវាចាពីរោះ សង្គ្រោះបុគ្គលដែលមកវិហារដោយបបរ បាយ និងទឹកអំពៅជាដើម ដូចគ្នានឹងពោលតិះដៀលនោះឯង ។ គ្រហស្ថគិតថា អញនឹងតិះដៀល ពោលថា ព្រះថេរៈនេះ ហាក់ដូចជាមនុស្សប្រាញ្ញាអន់ ហាក់ដូចជាមនុស្សមិនមានកម្លាំង ហាក់ដូចជាមនុស្សមានមុខស្រពាប់ស្រពោន មិនមានការស្និទ្ធស្នាលជាមួយព្រះ-ថេរៈ ស្មើគ្នានឹងការសរសើរនោះឯង ។ សូម្បីសព្រហ្មចារីពោលសរសើរខាងក្រោយខ្នងព្រះសាស្តា ក៏មិនជាលាភយ៉ាងនោះ ឯអ្នកសរសើរចំពោះព្រះភក្ត្រព្រះសាស្តា ជាលាភយ៉ាងក្រៃលែង ព្រះមានព្រះភាគ ទ្រង់អាស្រ័យអំណាចប្រយោជន៍ដូចពោលមក ដូច្នេះ ទើបត្រាស់ថា **សុលទ្ធលាភោ** ដូច្នេះ ។

[ ៣១ ] បទថា **អនុមស្ស អនុមស្ស** បានដល់ កំណត់ចំពោះកថាវត្ថុ ១០ ។ បទថា **តញ្ច សត្ថា អព្ភនុមោទតិ** សេចក្តីថា ព្រះសាស្តាទ្រង់អនុមោទនាគុណរបស់ភិក្ខុនោះៗ គឺគុណនោះយ៉ាងនេះថា ភិក្ខុនោះជាអ្នកប្រាថ្នាតិច និងជាអ្នកសន្តោស ។ លោកសំដៅយកលាភ ៥ យ៉ាងនេះ គឺការដែលអ្នកប្រាជ្ញសរសើរ ជាលាភ ១ ការដែលសព្រហ្មចារីសរសើរ ជាលាភ ១ ការដែលសព្រហ្មចារីសរសើរចំពោះព្រះភក្ត្រព្រះសាស្តា ជាលាភ ១ ការកំណត់ចំពោះកថាវត្ថុ ១០ ជាលាភ ១ ការដែលព្រះសាស្តា ទ្រង់អនុមោទនាយ៉ាងក្រៃលែង ជាលាភ ១ ។ ទើបព្រះថេរៈត្រិះរិះថា **សុលទ្ធ-**

**លាភា** ដូច្នេះ ដោយប្រការយ៉ាងនេះ ។ បទថា **កទាចិ** គឺក្នុងកាលខ្លះ ។ បទថា **ករហចិ** ជាវេវចនៈនៃបទថា **កទាចិ** នោះឯង ។ បទថា **អប្បេវ នាម សិយា កោចិទេវ កថាសល្លាបោ** បានដល់ ហេតុអ្វីហ្ន៎ ការចរចាអ្វីតអាងខ្លះ គប្បីមាន ។ បានឮថា ព្រះថេរៈមិនធ្លាប់ឃើញព្រះបុណ្ណៈអំពីមុនឡើយ មិនធ្លាប់ស្តាប់ធម្មកថារបស់លោក ដូច្នោះ ទើបលោកប្រាថ្នានឹងឃើញព្រះបុណ្ណៈផង ការពោលធម៌របស់លោកផង ទើបពោលយ៉ាងនេះ ។

[ ៣២ ] បទថា **យថាភិរន្តំ** បានដល់ ប្រថាប់នៅតាមព្រះអធ្យាស្រ័យ ។ ពិតហើយ ព្រះសម្ពុទ្ធទាំងឡាយ កាលនៅប្រថាប់ក្នុងទីមួយកន្លែង ឈ្មោះថាមិនមានការត្រេកអរ ព្រោះអាស្រ័យការវិបត្តិនៃម្ហូប និងទឹកជាដើម សេនាសនៈដែលមិនផាសុក ឬការមិនមានសទ្ធាជាដើមរបស់ពពួកជន មិនមានការត្រេកអរថា អញនឹងនៅជាផាសុកក្នុងទីនេះហើយ នៅយូរៗ ព្រោះវត្ថុទាំងនោះ មានដេរដាស ។ តែកាលព្រះតថាគតប្រថាប់នៅក្នុងទីណា សត្វទាំងឡាយតាំងនៅក្នុងសរណៈ សមាទានសីល ឬបព្វជ្ជា ឬសត្វទាំងនោះ មានឧបនិស្ស័យនៃសោតាបត្តិមគ្គជាដើម ។ ព្រះពុទ្ធទាំងឡាយរមែងប្រថាប់នៅក្នុងទីនោះ តាមអធ្យាស្រ័យ ដែលទ្រង់ស្គាបនាសត្វទាំងនោះទុកក្នុងសម្បត្តិទាំងនោះ ព្រោះមិនមានសត្វទាំងនោះ ទើបទ្រង់ចៀសចេញទៅ ។ ដោយហេតុនោះ ទើបលោកពោលថា **យថាភរន្តំ វិហរិត្វា** ។ បទថា **ចារិកញ្ចរមានោ** សេចក្តីថា ទ្រង់ពុទ្ធដំណើរផ្លូវឆ្ងាយ ។ ឈ្មោះថា ចារិករបស់ព្រះមានព្រះភាគនេះ មាន ២ យ៉ាង គឺចារិកប្រញាប់ ១ ចារិកមិនប្រញាប់ ១ ។

បណ្ដាចារិកទាំង ២ នោះ ការដែលទ្រង់ឃើញបុគ្គល ដែលគួរត្រាស់ដឹងក្នុងទីឆ្ងាយ ហើយទ្រង់ប្រញាប់យាងទៅ ដើម្បីប្រោសឲ្យត្រាស់ដឹង ឈ្មោះថាចារិកដោយប្រញាប់ ។ ការចារិកប្រញាប់នោះ គប្បីឃើញដូចទ្រង់ចេញទៅទទួលព្រះមហាកស្សបជាដើម ។ ពិតហើយ ព្រះមានព្រះភាគ កាលយាងទៅទទួលព្រះមហាកស្សប ទ្រង់យាងទៅអស់ចម្ងាយផ្លូវ ៣ គាវុត ដោយមួយសន្ទុះប៉ុណ្ណោះ ទ្រង់យាងទៅ ៣០ យោជន៍ ដើម្បីប្រោសអាឡវកយក្ខ និងប្រោសអង្គុលិមាលក៏ដូចគ្នា តែប្រោសបុក្កុសាតិ ៤៥ យោជន៍ ប្រោសព្រះបាទមហាកប្បិន ២០០០ យោជន៍ ប្រោសខទិរវនិយត្ថេរ ៧០០ យោជន៍ ប្រោសវនវាសីតិស្សសាមណេរ សទ្ធិវិហារិករបស់ព្រះធម្មសេនាបតី ២០០០ យោជន៍ និង ៣ គាវុត ។ បានឮថា ថ្ងៃមួយ ព្រះថេរៈទូលថា ខ្ញុំព្រះអង្គនឹងទៅក្នុងសម្នាក់តិស្សសាមណេរ ។ ព្រះមានព្រះភាគត្រាស់ថា តថាគតក៏នឹងទៅ ហើយត្រាស់ប្រាប់ព្រះអានន្ទថា អានន្ទ អ្នកចូរប្រាប់ភិក្ខុដែលបានអភិញ្ញា ៦ ពីរម៉ឺនរូបថា ព្រះមានព្រះភាគទ្រង់នឹងទៅកាន់សម្នាក់របស់វនវាសីតិស្សសាមណេរ ។ ស្អែកឡើង ព្រះមានព្រះភាគ មានព្រះខីណាស្រព ២ ម៉ឺនហែហម ហោះទៅតាមអាកាស ទ្រង់ចុះក្បែរទ្វារគោចរគាមរបស់តិស្សសាមណេរនោះ ត្រង់ខាងចុងផ្លូវ ២ ពាន់យោជន៍ ទ្រង់ដណ្ដប់ចីវរ ។ ពួកមនុស្សដែលទៅធ្វើការឃើញ ក៏ពោលថា លោកដ៏ចម្រើន ព្រះសាស្ដាយាងមក សូមពួកលោកមកជួយគ្នាធ្វើការ មានក្រាលអាសនៈ ថ្វាយយាគូ ធ្វើទានវត្ត ហើយសួរភិក្ខុកំលោះទាំងឡាយថា លោកម្ចាស់ ព្រះមានព្រះភាគ

ទ្រង់យាងទៅណា ។ ភិក្ខុទាំងនោះក៏ពោលថា ឧបាសកទាំងឡាយ ព្រះមានព្រះភាគ ទ្រង់មិនទៅក្នុងទីដទៃទេ ទ្រង់មកដើម្បីសួរសុខទុក្ខតិស្សសាមណេរក្នុងទីនេះឯង ។ បុគ្គលទាំងនោះ កើតសោមនស្សថា បានឮថា ព្រះសាស្ដាយាងមកសួរសុខទុក្ខ ព្រះថេរៈប្រចាំត្រកូលរបស់ពួកយើង ព្រះថេរៈរបស់ពួកយើង មិនមែនថោកថយឡើយ ។ លំដាប់នោះ កាលព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចស្រេច សាមណេរចូលស្រុកបិណ្ឌបាត សួរថា មានភិក្ខុសង្ឃក្រុមធំឬ ។ គ្រានោះ ឧបាសកទាំងនោះ ប្រាប់ដល់សាមណេរថា បពិត្រលោកម្ចាស់ ព្រះសាស្ដាយាងមកហើយ ។ សាមណេរនោះ ចូលគាល់ព្រះមានព្រះភាគ អើពើដោយអាហារបិណ្ឌបាត ។ ព្រះសាស្ដាយកព្រះហស្ដចាប់បាត្ររបស់សាមណេរ ហើយត្រាស់ថា ល្មមហើយសាមណេរ តថាគតសម្រេចភត្តកិច្ចហើយ បន្ទាប់អំពីនោះ សាមណេរក៏ថ្វាយបង្គំព្រះឧបជ្ឈាយ៍អង្គុយលើអាសនៈដែលសមគួរដល់ខ្លួន ហើយធ្វើភត្តកិច្ច ។ កាលសាមណេរសម្រេចភត្តកិច្ចហើយ ព្រះសាស្ដាត្រាស់មង្គលហើយ យាងចេញប្រថាប់ឈរក្បែរទ្វារស្រុក ត្រាស់សួរថា តិស្សៈ ផ្លូវទៅលំនៅរបស់អ្នក មួយណា សាមណេរក្រាបទូលថា ផ្លូវនេះ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា តិស្សៈ អ្នកចូរដើរទៅខាងមុខ ។ បានឮថា ព្រះមានព្រះភាគ តែងប្រាប់ផ្លូវដល់លោក ព្រមទាំងទេវលោក តែទ្រង់ធ្វើសាមណេរនោះឲ្យជាមគ្គុទ្ទេសក៍ដោយព្រះពុទ្ធបំណងថា នឹងបានឃើញសាមណេរ អស់ចម្ងាយផ្លូវ ៣ គាវុត សាមណេរទៅកាន់លំនៅរបស់ខ្លួន បានធ្វើវត្តដល់ព្រះមានព្រះភាគ ។ កាល

នោះ ព្រះមានព្រះភាគត្រាស់សួរសាមណេរនោះថា តិស្សៈ ទីចង្ក្រមត្រង់ណា ហើយទ្រង់ទៅទីចង្ក្រមនោះ ប្រថាប់គង់លើថ្មសម្រាប់គង់របស់សាមណេរ ហើយត្រាស់សួរថា តិស្សៈ អ្នកនៅជាសុខក្នុងទីនេះឬ ។ សាមណេរទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនៅក្នុងទីនេះ បានឮសំឡេងរាជសីហ៍ ខ្លា ដំរី ម្រឹគ និងក្ងោកជាដើម ក៏កើតអារញ្ញសញ្ញាថា អាត្មាអញនឹងនៅជាសុខ ដោយសញ្ញានោះ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ប្រាប់សាមណេរនោះថា តិស្សៈ អ្នកចូរឲ្យភិក្ខុសង្ឃប្រជុំគ្នា តថាគតនឹងឲ្យតំណែងពុទ្ធទាយាទដល់អ្នក ទ្រង់ឲ្យភិក្ខុសង្ឃប្រជុំគ្នាកន្លះយោជន៍ ឲ្យសាមណេរឧបសម្បទា ហើយទ្រង់បានយាងទៅលំនៅរបស់ព្រះអង្គនោះឯង ហេតុនោះ ទើបចារិកនេះ ឈ្មោះថា ចារិកប្រញាប់ ។

ឯការដែលព្រះមានព្រះភាគទ្រង់អនុគ្រោះលោក ដោយការយាងបិណ្ឌបាតជាដើម ដោយផ្លូវមួយយោជន៍ និងកន្លះយោជន៍ រាល់ៗថ្ងៃ តាមលំដាប់តាមនិគម ឈ្មោះថា ចារិកមិនប្រញាប់ ។ ព្រះមានព្រះភាគទ្រង់ចារិកយ៉ាងនេះ រមែងចារិកទៅក្នុងមណ្ឌល ៣ មណ្ឌលណាមួយ យ៉ាងនេះ គឺមហាមណ្ឌល មជ្ឈិមមណ្ឌល អន្តិមមណ្ឌល ។ ក្នុងមណ្ឌល ៣ នោះ ទី ៩០០ យោជន៍ ឈ្មោះថា មហាមណ្ឌល ទី ៦០០ យោជន៍ ឈ្មោះថា មជ្ឈិមមណ្ឌល ទី ៣០០ យោជន៍ ឈ្មោះថា អន្តិមមណ្ឌល ។ កាលណាព្រះពុទ្ធបំណងយាងចារិកទៅក្នុងមហាមណ្ឌល ទ្រង់បវារណាក្នុងថ្ងៃមហាបវារណាហើយ ក្នុងថ្ងៃបាដិបទ មានភិក្ខុក្រុមធំជាបរិវារ យាងចេញទៅ បានកើត

កោលាហលដូចគ្នា អស់ទីចម្ងាយ ១០០ យោជន៍ដោយជុំវិញ ។ ពួកដែល មកមុនៗ បាននិមន្តឲ្យត្រឡប់ ។ មណ្ឌល ២ ក្រៅអំពីនេះ សក្ការៈរមែង សង្គ្រោះចូលក្នុងមហាមណ្ឌល ។ បើក្នុងទីនោះ ព្រះមានព្រះភាគនៅប្រថាប់ ១ ថ្ងៃ ២ ថ្ងៃ ក្នុងគាមនិគមនោះៗ ទ្រង់អនុគ្រោះមហាជន ដោយការទទួល អាមិសទាន និងទ្រង់ចម្រើនកុសលដែលអាស្រ័យវិវដ្ដៈ ដោយប្រទានធម៌ ដល់មហាជននោះ ៩ ខែ ទើបទ្រង់យាងចារិក ។ បើខាងក្នុងវស្សា ភិក្ខុទាំង-ឡាយមានសមថវិបស្សនានៅទន់ខ្សោយ ទ្រង់ក៏មិនបវារណា ក្នុងថ្ងៃមហា បវារណា តែទ្រង់ផ្លាស់បវារណា ទៅបវារណាក្នុងថ្ងៃបវារណា ពាក់កណ្ដាល ខែកត្តិក ដើមខែមិគសិរ មានភិក្ខុក្រុមធំជាបរិវារ ទ្រង់ចេញទៅអស់មជ្ឈិម មណ្ឌល ។ កាលទ្រង់មានព្រះពុទ្ធបំណងចារិកទៅក្នុងមជ្ឈិមមណ្ឌលដោយ ហេតុដទៃ ក៏នៅប្រថាប់អស់ ៤ ខែហើយ ទើបទ្រង់ចេញទៅ ។ មណ្ឌល ទាំង ២ ក្រៅអំពីនេះ លាភសក្ការៈ រមែងសង្គ្រោះចូលក្នុងមជ្ឈិមមណ្ឌល ដោយន័យដែលពោលហើយនោះឯង ។ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះ លោកដោយន័យខាងដើម ៨ ខែ ទើបសម្រេចចារិក ។ កាលព្រះមានព្រះ ភាគនៅប្រចាំ ៤ ខែហើយ ពួកវេនេយ្យសត្វមានឥន្ទ្រិយមិនទាន់ចាស់ក្លា ទ្រង់ ក៏រង់ចាំឥន្ទ្រិយរបស់វេនេយ្យសត្វទាំងនោះចាស់ក្លា នៅប្រថាប់ក្នុងទីនោះឯង ១ ខែខ្លះ ២ ខែខ្លះ ៣ ខែខ្លះ ហើយទ្រង់មានមហាភិក្ខុសង្ឃជាបរិវារយាង ចេញទៅក្នុងមណ្ឌល ២ ក្រៅពីនេះ លាភសក្ការៈរមែងសង្គ្រោះចូលក្នុងអន្តិម-មណ្ឌល ដោយន័យដែលពោលហើយនោះឯង ។ ព្រះមានព្រះភាគ កាល

ទ្រង់អនុគ្រោះលោកដោយន័យខាងដើម ៧ ខែខ្លះ ៦ ខែខ្លះ ៥ ខែខ្លះ ៤ ខែខ្លះ ទើបសម្រេចចារិក ដូច្នោះ កាលទ្រង់ចារិកទៅក្នុងមណ្ឌល ៣ មណ្ឌលណាមួយ ទើបមិនមែនចារិកទៅ ព្រោះហេតុនៃបច្ច័យ មានចីវរជាដើម ។ ដោយពិតនោះ ទ្រង់ចារិកទៅដើម្បីអនុគ្រោះ ដោយបំណងយ៉ាងនេះថា ជនពួកណាជាទុគ្គតជន ជាពាល ជាបុគ្គលចាស់ជរា ជាអ្នកមានព្យាធិ កាលណាជនទាំងនោះមកឃើញតថាគត កាលតថាគតចារិកទៅ មហាជនក៏នឹងបានឃើញតថាគតក្នុងទីនោះ បុគ្គលពួកខ្លះនឹងធ្វើចិត្តឲ្យជ្រះថ្លា ពួកខ្លះនឹងបូជាដោយផ្កាជាដើម ពួកខ្លះនឹងថ្វាយភិក្ខាត្រឹមមួយវែក ពួកខ្លះនឹងលះបង់នូវទិដ្ឋិខុស ជាសម្មាទិដ្ឋិ សេចក្ដីនោះក៏នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់បុគ្គលទាំងនោះ អស់កាលយូរ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទាំងឡាយ ទ្រង់រមែងចារិកដោយហេតុ ៤ យ៉ាង គឺដើម្បីប្រយោជន៍ដល់សេចក្ដីសុខរបស់សរីរៈ ដោយការសម្រួលស្មុង ១ ដើម្បីប្រយោជន៍ គឺរង់ចាំការកើតអត្ថុប្បត្តិហេតុ គឺហេតុដែលឲ្យកើតការត្រាស់ធម្មទេសនា ១ ដើម្បីប្រយោជន៍ដល់ការបញ្ញត្តសិក្ខាបទសម្រាប់ភិក្ខុទាំង-ឡាយ ១ ដើម្បីប្រយោជន៍ប្រោសសត្វដែលគួរត្រាស់ដឹង និងបុគ្គលមានឥន្ទ្រិយចាស់ក្លាហើយក្នុងទីនោះៗ ឲ្យត្រាស់ដឹង ១ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំង-ឡាយ ទ្រង់រមែងចារិកដោយហេតុ ៤ ប្រការដទៃទៀត គឺសត្វទាំងឡាយនឹងដល់នូវព្រះពុទ្ធជាសរណៈខ្លះ ដល់នូវព្រះធម៌ជាសរណៈខ្លះ ដល់នូវព្រះសង្ឃជាសរណៈខ្លះ នឹងធ្វើបរិស័ទ ៤ ឲ្យឆ្អែតដោយការស្ដាប់ធម៌ ក្នុងកាលដ៏ធំខ្លះ ។

ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់រមែងចារិកដោយហេតុ ៥ ប្រការដទៃទៀត គឺពួកសត្វនឹងវៀរចាកបាណាតិបាត ចាកអទិន្នាទាន ចាកកាមេសុមិច្ឆាចារ ចាកមុសាវាទ ចាកសុរាមេរយមជ្ជប្បមាទដ្ឋានខ្លះ ។ ព្រះពុទ្ធមានព្រះភាគទាំងឡាយ រមែងចារិកទៅដោយហេតុ ៨ ប្រការដទៃ គឺសត្វនឹងបានបឋមជ្ឈានខ្លះ ទុតិយជ្ឈានខ្លះ ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិខ្លះ ។ ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់រមែងចារិកទៅដោយហេតុ ៨ ប្រការដទៃទៀត គឺសត្វនឹងសម្រេចសោតាបត្តិមគ្គខ្លះ សោតាបត្តិផលខ្លះ ។បេ។ នឹងធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលខ្លះ ។ នេះឈ្មោះថា **អតុរិត ចារិក** មិនចារិកប្រញាប់ប្រញាល់ លោកបំណងយកក្នុងទីនេះ ។ ចារិកនោះ មាន ២ យ៉ាង គឺនិពទ្ធចារិក ១ អនិពទ្ធចារិក ១ ។ ចារិក ២ យ៉ាងនេះ ការដែលព្រះមានព្រះភាគ ទៅប្រោសសត្វដែលគួរត្រាស់ដឹងតែម្នាក់ប៉ុណ្ណោះ ឈ្មោះថា **និពទ្ធចារិក** ។ ការដែលព្រះមានព្រះភាគ ទ្រង់ចារិកទៅតាមលំដាប់គាមនិគម នគរ ឈ្មោះថា **អនិពទ្ធចារិក** ។ អនិពទ្ធចារិកនេះ លោកបំណងយកក្នុងទីនេះ ។

បទថា **សេនាសនំ សំសាមេត្វា** ប្រែថា ទុកដាក់សេនាសនៈ ។ ព្រះថេរៈកាលទុកដាក់សេនាសនៈនោះ ក៏យកបាត្រតូច បាត្រធំ ស្តោកបាត្រតូចធំ ចីវរព្រៃ និងចីវរសម្បកឈើជាដើម ធ្វើជាបង្វេច ទុកដាក់សប្បិ និងប្រេងជាដើមក្នុងថ្នាំង រក្សាទុកក្នុងបន្ទប់ បិទទ្វារ ឲ្យប្រកបសោ កត់ចំណាំ ទុកដាក់ដោយអាបុច្ឆា ពោលលាភិក្ខុម្ចាស់កន្លែងតាមព្រះបាលីថា បើភិក្ខុក្តី សាមណេរ

ក្ដី អារាមិកជនក្ដី ឧបាសកក្ដី មិនមានទេ ត្រូវរៀបចំគ្រែលើថ្មតូច ៤ ជុំ ហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំង ធ្វើសេនាសនៈឲ្យគរលើគ្នា រួច រៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី ហើយបិទទ្វារ និងបង្អួច ហើយដើរ ចេញទៅចុះ ។

បទថា **យេន សាវត្ថី តេន ចារិកំ បក្កាមិ** សេចក្ដីថា ព្រះបុណ្ណមន្តា-នីបុត្របំណងនឹងគាល់ព្រះសាស្ដា ទើបចៀសទៅកាន់ទិសដែលក្រុងសាវត្ថី តាំងនៅ ។ កាលចារិកទៅ លោកក៏ឲ្យក្រាបទូលដល់ព្រះបាទសុទ្ធោទនមហា-រាជ ឲ្យទ្រង់ទទួលសប្បិ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ហើយចេញទៅ កាលចៀសចេញទៅ ក៏នាំត្រឹមតែបាត្រ ចីវរ ចៀសចេញទៅ ដោយទំនើង ម្នាក់ឯង ដូចដំរីចុះប្រេង លះបង់ហ្វូងចៀសចេញទៅ ដូចរាជសីហ៍ មិនមាន កិច្ចដោយសម្លាញ់ ។ សួរថា ព្រោះហេតុអ្វី លោកមកក្រុងរាជគ្រឹះ មួយអន្លើ ដោយអន្តេវាសិករបស់លោក ៥០០ អង្គ ឥឡូវនេះ ចៀសចេញទៅតែម្នាក់ ឯង ឆ្លើយថា ក្រុងរាជគ្រឹះឆ្ងាយអំពីក្រុងលបិលកស្ថុ ៦០ យោជន៍ ឆ្ងាយ អំពីក្រុងសាវត្ថី ៥០ យោជន៍ ព្រះសាស្ដាយាងមកអំពីក្រុងរាជគ្រឹះ ៤៥ យោជន៍ ប្រថាប់នៅក្នុងក្រុងសាវត្ថី លោកបានឮមកថា ឥឡូវនេះព្រះសាស្ដា ជិតមកដល់ហើយ អញនឹងចៀសចេញទៅនោះឯង ដូច្នោះ ទើបសេចក្ដីនេះ មិនជាហេតុ ។ ពិតហើយ កាលទៅកាន់សម្នាក់ព្រះពុទ្ធទាំងឡាយ គប្បីទៅ អស់ចម្ងាយផ្លូវមួយពាន់យោជន៍ តែក្នុងគ្រានោះ លោកមិនអាចបានកាយ-វិវេក ដូច្នោះ ព្រោះត្រូវទៅជាមួយមនុស្សច្រើន កាលពោលថា ខ្ញុំនឹងទៅ

ម្នាក់ឯង ក៏ពោលខុសថា ខ្ញុំនឹងនៅទីនេះម្នាក់ឯង កាលពោលថា ខ្ញុំនឹងនៅម្នាក់ឯង ក៏បែរជាពោលថា ខ្ញុំនឹងទៅម្នាក់ឯង ព្រោះដូច្នោះ លោកមិនអាចគង់ចូលសមាបត្តិក្នុងខណៈដែលខ្លួនប្រាថ្នា ឬបានកាយវិវេកក្នុងសេនាសនៈដែលជាផាសុក កាលនៅដោយទំនើងម្នាក់ឯង ក៏នឹងបានវត្តនោះដោយងាយ ដូច្នោះ ទើបលោកមិនទៅក្នុងគ្រានោះ ចៀសចេញទៅនាគ្រានេះ ។

ក្នុងពាក្យថា **ចារិកំ ចរមានោ** នេះ ឈ្មោះថា ចារិក រមែងបានដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ដើម្បីសង្គ្រោះមហាជនក៏ពិត តែទោះជាដូច្នោះក៏គួរដល់ពួកសាវកទាំងឡាយផងដែរ សព្ទពង្រីកស៊ីសេចក្ដីដល់ព្រះពុទ្ធទាំង-ឡាយ ដូចផ្ចិតស្ទីកត្នោតដែលគេធ្វើដោយកន្ទេលផែងជាដើម ។ បទថា **យេន ភគវា** សេចក្ដីថា ព្រះបុណ្ណមន្តានីបុត្រ កាលត្រាច់បិណ្ឌបាតទៅក្នុងស្រុកមួយ មិនឆ្ងាយអំពីក្រុងសាវត្ថី ធ្វើភត្តកិច្ចហើយ ចូលទៅកាន់វត្តជេតពន ទៅកាន់លំនៅរបស់ព្រះសារីបុត្រ ឬរបស់ព្រះមហាមោគ្គល្លាន លាងជើងហើយលាបប្រេង ឆាន់ទឹក ឬទឹកបាន សម្រាកបន្តិច មិនកើតចិត្តគិតថានឹងគាល់ព្រះសាស្ដា ហើយដើរបែរមុខទៅកាន់បរិវេណព្រះគន្ធកុដិ ។ ព្រោះថា ព្រះថេរៈបំណងនឹងគាល់ព្រះសាស្ដា តែមិនមានកិច្ចជាមួយកិក្ខុដទៃ ព្រោះដូច្នោះ ទើបលោកមិនកើតចិត្តគិតយ៉ាងនេះថា អញនឹងនាំព្រះរាហុល ឬព្រះអានន្ទឲ្យធ្វើឱកាសគាល់ព្រះសាស្ដា ។ ពិតហើយ ព្រះថេរៈជាអ្នកស្និទ្ធស្នាលក្នុងព្រះពុទ្ធសាសនាខ្លួនឯងនោះឯង ដូចអ្នកចម្បាំងធំ ដែលមានជ័យជម្នះក្នុងសង្គ្រាមរបស់ព្រះរាជា ។ បើអ្នកចម្បាំងនោះបំណងនឹងគាល់ព្រះរាជា គឺមិន

មានកិច្ចដែលនឹងជួបអ្នកដទៃ ចង់គាល់ព្រះរាជា រមែងចូលគាល់បានតែម្តង ព្រោះជាអ្នកស្និទ្ធស្នាល យ៉ាងណា សូម្បីព្រះថេរៈក៏ដូច្នោះ ជាអ្នកស្និទ្ធស្នាល ក្នុងព្រះពុទ្ធសាសនា លោកមិនមានកិច្ចដែលត្រូវជួបភិក្ខុដទៃ ហើយគាល់ព្រះសាស្តា ព្រោះដូច្នោះ លោកលាងជើងហើយ ក៏ជូតជើង ចូលគាល់ព្រះមានព្រះភាគ ។ សូម្បីព្រះមានព្រះភាគ ក៏ទ្រង់សម្លឹងឃើញថា ក្នុងវេលាព្រឹកមន្តានីបុត្រនឹងមក ព្រោះដូច្នោះ ទើបទ្រង់ចូលទៅកាន់ព្រះគន្ធកុដិ មិនដាក់គន្លឹះ រម្ងាប់សេចក្តីក្រវល់ក្រវាយ តើនឡើងប្រថាប់គង់ ។ ព្រះថេរៈបើកសន្ទះទ្វារចូលទៅកាន់ព្រះគន្ធកុដិ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរក្នុងចំណែកម្ខាង ។ បទថា **ធម្មិយា កថាយ** សេចក្តីថា ព្រះមានព្រះភាគ កាលត្រាស់ធម្មីកថា ត្រាស់អានិសង្សសាមគ្គីរសដល់កុលបុត្រ ៣ អង្គ ក្នុងចូឡគោសិង្គសាលសូត្រ ត្រាស់អានិសង្សថ្វាយទីសម្រាកក្នុងសេក្ខសូត្រ ត្រាស់កថាដែលទាក់ទងដោយបុព្វេនិវាសានុស្សតិញ្ញាណ ដែលធ្វើឲ្យបានសតិ ក្នុងឃដិការសូត្រ ត្រាស់ធម្មទេស ៤ ក្នុងរដ្ឋបាលសូត្រ ត្រាស់រឿងអានិសង្សនៃការថ្វាយទឹកផឹក ក្នុងសេលសូត្រ កាលត្រាស់ធម្មកថា ត្រាស់អានិសង្ស ក្នុងភាពជាបុគ្គលម្នាក់ឯង ដល់ព្រះភគុត្ថេរ ក្នុងសន្និលេសិយសូត្រ ។ តែក្នុងរថវិនីតសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់ព្រះបុណ្ណៈ ទ្រង់សម្តែងកថាឈ្មោះ អនន្តន័យ ដែលជាទីអាស្រ័យរបស់កថាវត្ថុ ១០ ថា ម្នាលបុណ្ណៈ នេះឈ្មោះថា អប្បិច្ឆកថា សន្តោសកថាដូចគ្នា ប្រៀបដូចប្រថាប់ឈរត្រង់ទីបំផុតដែន លាព្រះហស្តទៅក្នុងមហាសមុទ្រ

ដល់សាវ័កដែលសម្រេចបដិសម្ភិទា ។ បទថា **យេន អន្ធវនំ** សេចក្តីថា បានឮថា គ្រានោះ ក្នុងបច្ឆាភត្ត វត្តជេតពនមានសភាពអ៊ូអរដោយមនុស្សជាច្រើន មានក្សត្រ ព្រាហ្មណ៍ ជាដើមដើរទៅមកកាន់វត្តជេតពន ដូចព្រះពន្លានៃស្តេចចក្រពត្តិ ភិក្ខុមិនអាចដើម្បីបាននូវការស្ងាត់ ឯអន្ធវនស្ងាត់ ដូចផ្ទះសម្រាប់ធ្វើសេចក្តីព្យាយាម ព្រោះដូច្នោះ ទើបព្រះបុណ្ណមន្តានីបុត្រ ចូលទៅកាន់អន្ធវន ។ ព្រោះហេតុអ្វី ទើបលោកមិនឃើញពួកព្រះមហាថេរៈ បានឮថា ព្រោះលោកគិតយ៉ាងនេះថា អញមកក្នុងវេលាល្ងាច នឹងឃើញព្រះមហាថេរៈ ហើយនឹងគាល់ព្រះទសពល ប្រណិប័តន៍ព្រះមហាថេរៈយ៉ាងនេះក៏នឹងមានម្តង សម្រាប់ព្រះសាស្តានឹងមានពីរដង បន្ទាប់អំពីនោះ អញនឹងថ្វាយបង្គំព្រះសាស្តា ហើយក៏នឹងត្រឡប់ទៅកាន់លំនៅរបស់អញ ។

[ ៣៣ ] បទថា **អភិណ្ហំ កិត្តយមានោ អហោសិ** បានដល់ សរសើររឿយៗ ។ បានឮថា ព្រះថេរៈគិតថា បានឮថា បុត្ររបស់នាងមន្តានីឈ្មោះបុណ្ណៈ មិនប្រឡូកប្រឡំដោយបរិស័ទ ៤ លោកនឹងមកគាល់ព្រះទសពល លោកមិនទាន់ជួបអញ ហើយទៅឬហ្ន៎ ហើយសរសើរព្រះបុណ្ណៈកណ្តាលជំនុំសង្ឃរាល់ៗ ថ្ងៃ តាំងអំពីនោះមក ដើម្បីជាស់តឿនស្មារតីដល់ពួកព្រះថេរៈ នវកភិក្ខុ និងមជ្ឈិមភិក្ខុ ។ បានឮថា លោកមានការគិតយ៉ាងនេះថា ធម្មតាភិក្ខុចាស់ៗ មិននៅខាងក្នុងវិហារគ្រប់កាល កាលខ្ញុំពោលគុណរបស់លោក បុគ្គលណាឃើញភិក្ខុនោះ បុគ្គលនោះក៏នឹងមកប្រាប់ ។ គ្រានោះ សទ្ធិវិហារិករបស់ព្រះថេរៈនោះ បានឃើញព្រះបុណ្ណមន្តានីបុត្រ កំពុងកាន់

បាត្រ ចីវរ ចូលទៅកាន់ព្រះគន្ធកុដិ ។ សួរថា លោកម្ចាស់បានស្គាល់ព្រះបុណ្ណមន្តានីបុត្រនោះដូចម្ដេច ឆ្លើយថា ភិក្ខុរូបនោះ បានដឹងទូទៅដល់ព្រះធម្មកថារបស់ព្រះមានព្រះភាគដែលត្រាស់ប្រារព្ធឈ្មោះបុណ្ណៈៗ ថា ព្រះថេរៈដែលព្រះឧបជ្ឈាយ៍របស់អញសរសើររឿយៗ គឺភិក្ខុអង្គនេះឯង ដូច្នោះ ទើបភិក្ខុរូបនោះមកប្រាប់ដល់ព្រះថេរៈ ។ បទថា **និសីទនំ អាទាយ** បានដល់សំពត់ស្មាច់ដែលមានជាយ លោកហៅថា និសីទនៈ ។ ព្រះថេរៈកាន់យកកំណាត់ស្បែកទៅ ។ បទថា **បិដ្ឋិតោ បិដ្ឋិតោ** ប្រែថា ខាងក្រោយៗ ។ បទថា **សីសានុលោកិ** សេចក្ដីថា ភិក្ខុណាដើរទៅ ឃើញខ្នងក្នុងទីទួល ឃើញក្បាលក្នុងទីទំនាប ភិក្ខុនេះហៅថា មើលឃើញក្បាល គឺភិក្ខុដូច្នោះជាប់តាមទៅ ។ ព្រះថេរៈដើរទៅជិត ព្រោះមានសំឡេងជើងដែលឈានទៅក៏មិនលំបាក ព្រោះសំឡេងជើង តែលោកដឹងថា នេះមិនមែនជាកាលដែលនឹងសម្ដែងការរាក់ទាក់គ្នា ទើបមិនទៅជិត ធម្មតាអន្លង់ជាព្រៃធំ បុគ្គលរមែងមើលមិនឃើញបុគ្គលដែលអង្គុយ ក្នុងទីមួយកន្លែង ត្រូវធ្វើសំឡេងដែលមិនជាផាសុក ( សំឡេងបន្លឺក ) ថា អាវុសោបុណ្ណៈៗ ព្រោះដូច្នោះទើបព្រះថេរៈនៅមិនឆ្ងាយពេក ដើម្បីដឹងទីដែលលោកគង់ ដើរទៅល្មមតែមើលឃើញក្បាល ។ បទថា **ទិវាវិហារំ និសីទិ** បានដល់ អង្គុយដើម្បីប្រយោជន៍ដល់ការសម្រាកពេលថ្ងៃ ។ ទាំង ២ អង្គនោះ ព្រះបុណ្ណៈក្ដី ព្រះសារីបុត្រក្ដី ជាជាតិនៃឧទិច្ចព្រាហ្មណ៍ ព្រះបុណ្ណត្ថេរក្ដី ព្រះសារីបុត្តត្ថេរក្ដី ក៏មានពណ៌ដូចមាស ព្រះបុណ្ណត្ថេរក្ដី ព្រះសារីបុត្តត្ថេរក្ដី ក៏ដល់ព្រមដោយ

សមាបត្តិ សម្បយុត្តដោយអរហត្តផល ព្រះបុណ្ណត្ថេរ ដល់ព្រមដោយអភិនីហារមួយសែនកប្ប ព្រះសារីបុត្តត្ថេរ ក៏ដល់ព្រមដោយអភិនីហារមួយអសង្ខេយ្យ និងមួយសែនកប្ប ព្រះបុណ្ណត្ថេរក្តី ព្រះសារីបុត្តត្ថេរក្តី ក៏ជាព្រះខីណាស្រពសម្រេចបដិសម្ភិទា ។ ដូច្នោះ ទើបដូចជារាជសីហ៍ ២ ចូលទៅកាន់គុហាមាសជាមួយគ្នា ដូចខ្លាធំ ២ ចូលទៅកាន់ទីរលាស់ស្នូង រលាស់ដើងជាមួយគ្នា ដូចស្តេចដំរីឆទ្ទន្ត ២ ចូលកាន់សាលវ័នដែលមានផ្ការីកល្អហើយជាមួយគ្នា ដូចស្តេចគ្រុឌ ២ ចូលកាន់សិម្ពិលីវ័នជាមួយគ្នា ដូចស្តេចវេស្សវ័ណ ២ អង្គប្រថាប់លើយាននរពាហនៈជាមួយគ្នា ដូចសក្កទេវរាជ ២ អង្គប្រថាប់រួមលើបណ្ឌុកម្ពលតែមួយ ដូចស្តេចហារិតមហាព្រហ្ម ២ អង្គប្រថាប់នៅក្នុងវិមានតែមួយ ព្រះមហាថេរៈជាជាតិព្រាហ្មណ៍ទាំង ២ រូប មានពណ៌សម្បុរដូចមាសទាំង ២ រូប បានសមាបត្តិទាំង ២ រូប ដល់ព្រមដោយអភិនីហារទាំង ២ រូប ជាព្រះខីណាស្រព បានទូវបដិសម្ភិទាទាំង ២ រូប ចូលទៅកាន់ដងព្រៃជាមួយគ្នា ធ្វើដងព្រៃនោះឲ្យរុងរឿង ។

[ ៣៤ ] បទថា **ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ** សេចក្តីថា ព្រះសារីបុត្រដឹងថា ព្រះបុណ្ណមន្តានីបុត្រនោះ នៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគ ក៏សួរដើម្បីផ្តើមរឿងឡើងដូច្នេះថា អាវុសោ លោកប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសម្នាក់ព្រះមានព្រះភាគរបស់ពួកខ្ញុំឬ ។ ពិតហើយកាលកថាដំបូងមិនទាន់ផ្តើមឡើង កថាក្រោយក៏កើតមិនបាន ព្រោះដូច្នោះទើបព្រះថេរៈសួរយ៉ាងនេះ ។ ព្រះថេរៈក៏ពោលស្រេបតាមថា អើ យ៉ាងនោះ

ឯងអាវុសោ គ្រានោះ ព្រះសារីបុត្រ ប្រាថ្នានឹងស្ដាប់ចម្លើយរបស់ព្រះបុណ្ណ-មន្តានីបុត្រ ទើបសួរវិសុទ្ធិ ៧ តាមលំដាប់ថា អាវុសោ លោកប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគដើម្បីសីលវិសុទ្ធិឬ ។ សេចក្ដីពិស្ដាររបស់វិសុទ្ធិ ៧ នោះ បានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ព្រោះហេតុដែលការនៅប្រព្រឹត្តព្រហ្មចរិយៈ នៃបុគ្គលដែលតាំងនៅក្នុងចតុប្បារិសុទ្ធិសីលជាដើម មិនទាន់ដល់ទីបំផុត ដូច្នោះ ទើបព្រះបុណ្ណៈបដិសេធទាំងអស់ថា មិនមែនយ៉ាងនេះទេ អាវុសោ ។ បទថា **កិមត្ថំ ចរហាវុសោ** សេចក្ដីថា ព្រះសារីបុត្រសួរថា បើលោកមិននៅប្រព្រឹត្តព្រហ្មចរិយៈដើម្បីប្រយោជន៍ដល់សីលវិសុទ្ធិជាដើម កាលបើដូច្នោះ លោកនៅប្រព្រឹត្តព្រហ្មចរិយៈដើម្បីអ្វី ។ និព្វានដែលមិនមានបច្ច័យតាក់តែង ឈ្មោះថា អនុបាទាបរិនិព្វាន ក្នុងបទថា **អនុបាទាបរិនិព្វានត្ថំ ខោ អាវុសោ** នេះ ។ ឧបាទានមាន ២ ចំណែក គឺ គហណុបាទាន ១ បច្ចយុបាទាន ១ ។ ឧបាទាន ៤ យ៉ាង មានកាមុបាទានជាដើម ឈ្មោះថា **គហណុបាទាន** ។ បច្ច័យដែលពោលហើយយ៉ាងនេះថា សង្ខារកើតមានព្រោះអវិជ្ជាជាបច្ច័យ ឈ្មោះថា **បច្ចយុបាទាន** ។ បណ្ដាឧបា-ទានទាំងនោះ អាចារ្យទាំងឡាយដែលកាន់យកគហណុបាទាន ហៅអរហត្តផលដែលមិនប្រកាន់ធម៌ណាមួយ ដោយឧបាទាន ៤ ណាមួយ ប្រព្រឹត្តទៅថា អនុបាទាបរិនិព្វាន ក្នុងបទថា **អនុបាទាបរិនិព្វានំ** ។ ពិតហើយ អរហត្តផលនោះ ប្រកបដោយឧបាទានមិនប្រកាន់ធម៌ណាមួយឡើយ លោកពោលថា បរិ-និព្វាន ព្រោះកើតក្នុងទីបំផុតនៃកិលេសបរិនិព្វាន ។ ឯអាចារ្យដែលកាន់យក

បច្ចយុបាទាន ហៅនិព្វានដែលមិនមានបច្ច័យ ដែលមិនកើតឡើងដោយបច្ច័យ ដែលបច្ច័យមិនតាក់តែង បានដល់ អមតធាតុនោះឯងថា អនុបាទាបរិនិព្វាន ក្នុងពាក្យថា អនុបាទាបរិនិព្វាន ។ នេះជាទីបំផុត នេះជាខាងចុង នេះជាទីបញ្ចប់ ព្រោះថា ការនៅចប់ព្រហ្មចរិយៈរបស់បុគ្គលដែលកាន់យកអប្បច្ចយបរិនិព្វាន រមែងឈ្មោះថាដល់នូវទីបំផុត ព្រោះដូច្នោះ ទើបព្រះថេរៈពោលថា អនុបា-ទាបរិនិព្វាន ។

លំដាប់នោះ ព្រះសារីបុត្រ ជាអ្នកប្រកបរឿយៗ នូវអនុបាទាបរិនិព្វាននោះ ផ្តើមសួរទៀតថា ម្នាលអាវុសោ សីលវិសុទ្ធិ ជាអនុបាទាបរិនិព្វានឬ ឯព្រះថេរៈបដិសេធពាក្យទាំងអស់នោះ ក្នុងបរិវដ្ត គឺជុំវិញទាំងឡាយនោះដូចគ្នា កាលសម្តែងទោសក្នុងទីបំផុត ទើបពោលពាក្យជាដើមថា **សីល-វិសុទ្ធិ ខោ អាវុសោ** ។

[ ៣៥ ] បណ្តាបទទាំងនោះ បទថា **បញ្ញាបេយ្យ** ប្រែថា បើគប្បីបញ្ញត្តសោត ។ បទថា **សឧបាទានំ យេវ សមានំ អនុបាទាបរិនិព្វានំ បញ្ញាបេយ្យ** សេចក្តីថា គប្បីបញ្ញត្តព្រោះសគ្គហណធម៌ថា និគ្គហណធម៌ គប្បីបញ្ញត្តចំពោះសប្បច្ចយធម៌ថា អប្បច្ចយធម៌ គប្បីបញ្ញត្តចំពោះសង្ខតធម៌ថា អសង្ខតធម៌ ។ គប្បីកាន់យកអត្ថក្នុងញាណទស្សនវិសុទ្ធិយ៉ាងនេះថា គប្បីបញ្ញត្តចំពោះសប្បច្ចយធម៌ថា អប្បច្ចយធម៌ គប្បីបញ្ញត្តចំពោះសង្ខតធម៌ថា អសង្ខតធម៌ ។ គប្បីឃើញលោកិយពាលបុថុជ្ជនដែលដើរទៅតាមវដ្តៈ ក្នុងបទថា **បុថុជ្ជនោ ហិ អាវុសោ** នេះ ។ ពិតហើយ បុថុជ្ជននោះ វៀរធម៌ទាំង

នេះដោយប្រការទាំងពួង ព្រោះសូម្បីត្រឹមតែចតុប្បារិសុទ្ធិសីល ក៏មិនមាន ។ បទថា **តេនហិ** សេចក្តីថា បណ្ឌិតពួកខ្លះ រមែងដឹងទូទៅដល់អត្ថបានដោយឧបមា ដោយហេតុណា ហេតុនោះ ទើបខ្ញុំឧបមាដល់លោក ។ បទថា **សត្ត-រថវិនីតានិ** បានដល់ រថ ៧ ដែលទឹមដោយសេះអាជានេយ្យដែលបង្ហឹកល្អហើយ ។ បទថា **យាវទេវ ចិត្តវិសុទ្ធត្ថា** សេចក្តីថា លោកដ៏មានអាយុដែលឈ្មោះថាសីលវិសុទ្ធិនេះ រមែងមានត្រឹមតែដើម្បីប្រយោជន៍នៃចិត្តវិសុទ្ធិ ។ បទថា **ចិត្តវិសុទ្ធត្ថា** នេះ ជាបញ្ចមីវិភត្តិ ។ ក្នុងសេចក្តីនេះ មានអត្ថដូច្នេះ ប្រយោជន៍ ពោល គឺចិត្តវិសុទ្ធិមានដរាបណា ឈ្មោះថា សីលវិសុទ្ធិនេះគប្បីប្រាថ្នាដរាបនោះ ចិត្តវិសុទ្ធិនេះ ជាប្រយោជន៍ដល់សីលវិសុទ្ធិ នេះជាទីបំផុត នេះជាខាងចុង ពិតហើយ បុគ្គលតាំងនៅក្នុងចិត្តវិសុទ្ធិ រមែងឈ្មោះថា ធ្វើកិច្ចនៃសីលវិសុទ្ធិ ក្នុងបទទាំងពួង ក៏ន័យនេះ ។

ក្នុងសេចក្តីនេះ មានការប្រៀបធៀប ដោយការឧបមាដូចតទៅនេះ ព្រះយោគាវចរដែលខ្លាចចំពោះជរា និងមរណៈ គប្បីឃើញដូចព្រះបាទបសេន-ទិកោសល សក្កាយនគរ គប្បីឃើញដូចសាវត្ថីនគរ នគរ គឺព្រះនិព្វាន គប្បីឃើញដូចនគរសាកេត វេលាដែលព្រះយោគីកើត គឺការត្រាស់ដឹងអរិយសច្ច ៤ ដែលមិនទាន់ដឹង គប្បីឃើញដូចវេលាព្រះរាជាដែលនាំនូវសេចក្តីចម្រើនកិច្ចដែលប្រញាប់ប្រញាល់ ដែលគប្បីទៅដល់ក្រុងសាកេត វិសុទ្ធិ ៧ គប្បីឃើញដូចរថ ៧ គ្រឿង វេលាដែលតាំងនៅក្នុងសីលវិសុទ្ធិ គប្បីឃើញដូចវេលាឡើងកាន់រថទី ១ វេលាដែលតាំងនៅក្នុងចិត្តវិសុទ្ធិជាដើម ដោយសីល-

វិសុទ្ធិជាដើម គប្បីឃើញដូចវេលាចេញអំពីរថទី ១ ឡើងកាន់រថទី ២ ជាដើម ។ វេលាដែលព្រះយោគាវចរធ្វើកិលេសទាំងពួងឲ្យអស់ទៅ ដោយញាណទស្សនវិសុទ្ធិ ហើយឡើងទៅលើប្រាសាទ គឺធម៌ដ៏ប្រសើរ បុគ្គលមានកុសល ៥០ ប្រព្រឹត្តទៅខាងមុខជាបរិវារ ចូលផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ហើយអង្គុយក្នុងទីដេក គឺនិរោធ គប្បីឃើញដូចពេលសោយភោជនមានរសល្អរបស់ព្រះរាជា ដែលយាងចុះអំពីខាងក្នុងទ្វារក្រុងសាកេត ដោយរថទី ៧ ហើយចោមរោមទៅដោយពពួកញាតិមិត្តខាងលើប្រាសាទ ។

ព្រះធម្មសេនាបតីសារីបុត្រ សួរដល់វិសុទ្ធិ ៧ ជាមួយព្រះបុណ្ណៈដែលជាអ្នកបានកថាវត្ថុ ១០ ប្រការ ដោយប្រការដូច្នេះ ។ ព្រះបុណ្ណៈក៏វិសជ្ជនាកថាវត្ថុ ១០ ប្រការ ។

ព្រះធម្មសេនាបតីកាលសួរយ៉ាងនេះ ដឹង ឬមិនដឹង ទើបសួរ ឬថាលោកជាអ្នកឈ្លាសក្នុងលទ្ធិ ទើបសួរក្នុងវិស័យ ឬមិនឈ្លាសក្នុងលទ្ធិ ទើបសួរក្នុងអវិស័យ ឯព្រះបុណ្ណត្ថេរ ដឹង ឬមិនដឹង ទើបវិសជ្ជនា ឬលោកជាអ្នកឈ្លាសក្នុងលទ្ធិ ទើបវិសជ្ជនាក្នុងវិស័យ ឬមិនឈ្លាសក្នុងលទ្ធិ ទើបវិសជ្ជនាក្នុងអវិស័យ ។

ព្រះធម្មសេនាបតីសារីបុត្រ ដឹង ជាអ្នកឈ្លាសក្នុងលទ្ធិ ទើបសួរក្នុងវិស័យ ព្រោះដូច្នោះ ព្រះបុណ្ណៈកាលពោល ទើបពោលនឹងព្រះធម្មសេនាបតីប៉ុណ្ណោះ ព្រះបុណ្ណៈ ដឹង ជាអ្នកឈ្លាសក្នុងលទ្ធិ ទើបឆ្លើយក្នុងវិស័យ ព្រោះ

ដូច្នោះ ព្រះធម្មសេនាបតីសារីបុត្រកាលពោល គប្បីពោលនឹងព្រះបុណ្ណៈប៉ុណ្ណោះ ។ សេចក្តីដែលលោកសង្ខេបក្នុងវិសុទ្ធិទាំងឡាយ លោកក៏ឲ្យពិស្តារហើយ ក្នុងកថាវត្ថុទាំងឡាយ សេចក្តីដែលលោកសង្ខេបក្នុងកថាវត្ថុទាំងឡាយ លោកក៏ឲ្យពិស្តារហើយក្នុងវិសុទ្ធិទាំងឡាយ សេចក្តីនោះគប្បីជ្រាបដោយន័យនេះ ។ ពិតហើយ ក្នុងវិសុទ្ធិទាំងឡាយ សីលវិសុទ្ធិតែម្យ៉ាងក៏មកជាកថាវត្ថុ ៤ គឺអប្បិច្ឆកថា សន្តុដ្ឋិកថា អសំសគ្គកថា សីលកថា ។ ចិត្តវិសុទ្ធិតែម្យ៉ាងមកដោយកថាវត្ថុ ៣ គឺវិវេកកថា វីរិយារម្ភកថា សមាធិកថា ។ ដំបូង ពាក្យដែលលោកសង្ខេបក្នុងវិសុទ្ធិទាំងឡាយ លោកក៏ឲ្យពិស្តារហើយ ក្នុងកថាវត្ថុទាំងឡាយ ដោយប្រការដូច្នេះ ។ បណ្តាកថាវត្ថុទាំងឡាយ បញ្ញាកថាតែម្យ៉ាង មកជាវិសុទ្ធិ ៥ គឺទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ ។ សេចក្តីដែលលោកសង្ខេបក្នុងកថាវត្ថុ លោកឲ្យពិស្តារហើយ ក្នុងវិសុទ្ធិទាំងឡាយ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ព្រះសារីបុត្រ កាលសួរវិសុទ្ធិ ៧ មិនសួរដទៃ សួរកថាវត្ថុ ១០ ប៉ុណ្ណោះ ។ ឯព្រះបុណ្ណត្ថេរកាលវិសជ្ជនាវិសុទ្ធិ ៧ ក៏មិនវិសជ្ជនាដទៃ វិសជ្ជនាចំពោះកថាវត្ថុ ១០ ប៉ុណ្ណោះ ។ សូម្បីលោកទាំង ២ នោះដឹង ហើយជាអ្នកឈ្លាសក្នុងលទ្ធិ គប្បីជ្រាបថា សួរ និងវិសជ្ជនាបញ្ហាក្នុងវិស័យប៉ុណ្ណោះ ។

[ ៣៧ ] បទថា **កោ នាមោ អាយស្មា** សេចក្តីថា ព្រះថេរៈមិនស្គាល់ឈ្មោះរបស់លោកក៏មិនមែន តែទោះស្គាល់ក៏ដោយ ដោយបំណងនឹងបាននូវ

ការត្រេកអរ ។ ព្រះថេរៈកាលអនុមោទនា ទើបពោលពាក្យនេះថា **កដញ្ញូ បន អាយស្មន្តំ** ។ បទថា **មន្តានីបុត្តោ** បានដល់ ជាកូនរបស់ព្រាហ្មណី ឈ្មោះមន្តានី ។ បទថា **តំ** ក្នុងបទថា **យថាតំ** នេះ ត្រឹមជានិបាត ។ សេចក្តីសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះថា លោកព្យាករហើយ ដូចព្រះសាវកដែលស្តាប់ព្យាករ ។ បទថា **អនុមាស្ស អនុមាស្ស** គឺមិនទាន់កំណត់កថាវត្ថុ ១០ សំពត់ជូតក្បាល គឺធ្នូត ហៅថា **ចេល** ក្នុងបទថា **ចេលណ្ឌុ-កេន** នេះ បើសព្រហ្មចារីទាំងឡាយឲ្យលោកគង់ក្នុងទីនោះ បរិហារសំពត់ជូតក្បាលនៅលើក្បាល ក៏គប្បីបានឃើញ សូម្បីការឃើញដែលបានឃើញហើយយ៉ាងនេះ ក៏ជាលាភរបស់សព្រហ្មចារីនោះឯង ព្រោះហេតុនោះ ទើបលោកសម្តែងឧបាយនៃការឃើញរឿយៗ ដោយការកំណត់ដែលមិនមែនឋានៈ ។ ព្រះថេរៈ កាលមិនបរិហារយ៉ាងនេះ ដើម្បីនឹងសួរបញ្ហា ឬដើម្បីស្តាប់ធម៌ ស្វែងរកថា ព្រះថេរៈឈរក្នុងទីណា អង្គុយទីណា គប្បីប្រព្រឹត្ត ។ កាលបរិហារយ៉ាងនេះ ឱនក្បាលចុះក្នុងខណៈដែលត្រូវការឲ្យព្រះថេរៈអង្គុយលើអាសនៈដែលសមគួរយ៉ាងធំ ទើបអាចសួរបញ្ហា ឬស្តាប់ធម៌បាន ។ ទើបលោកសម្តែងឧបាយនៃការឃើញរឿយៗ ដោយការកំណត់វត្ថុដែលមិនមែនឋានៈ ដោយប្រការដូច្នេះ ។

[ ៣៨ ] បទថា **សារីបុត្តោតិ ច បន មំ** សេចក្ដីថា ឯសព្រហ្មចារីទាំងឡាយស្គាល់ខ្ញុំយ៉ាងនេះថា ជាកូនរបស់នាងសារីព្រាហ្មណី ។ បទថា **សត្ថុកប្បេន** បានដល់ ដូចព្រះសាស្ដា ។ ព្រះបុណ្ណៈលើកព្រះសារីបុត្តត្ថេរហាក់ដូចជាតាំងទុកលើចន្ទមណ្ឌលដោយបទមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ពិតហើយ ព្រះថេរៈជាព្រះធម្មកថិកដោយចំណែកមួយ ប្រាកដហើយក្នុងទីនេះ កាលហៅអមាត្យថាជាអ្នកធំ គប្បីហៅដូចព្រះរាជា ហៅគោថា ទំហំប៉ុនដំរី ហៅបឹងថា ទំហំប៉ុនមហាសមុទ្រ ហៅពន្លឺថា ភ្លឺស្មើនឹងពន្លឺរបស់ព្រះចន្ទ ព្រះអាទិត្យ ។ បន្ទាប់អំពីនោះ ក៏មិនមានការហៅសព្រហ្មចារីទាំងនោះថាធំ ។ កាលហៅព្រះសាវកថាធំ ក៏គប្បីហៅថា ប្រៀបស្មើដូចព្រះពុទ្ធ ។ បន្ទាប់អំពីនោះ ក៏មិនមានព្រះថេរៈនោះជាធំ ។ ព្រះបុណ្ណៈលើកព្រះថេរៈទៅទល់គ្នានឹងចន្ទមណ្ឌលដោយបទមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ក្នុងបទថា **ឯត្តកំបិ នោ នប្បដិភាសេយ្យ** នេះ មានអធិប្បាយយ៉ាងនេះថា មិនមានបដិភាណសម្រាប់ព្រះថេរៈ ដែលជាអ្នកមិនប្រមាទ ដែលសម្រេចបដិសម្ភិទា ការឧបមានេះយ៉ាងណា លោកនាំមកហើយ មិនគួរនាំឧបមានោះមក គួរពោលតែអត្ថប៉ុណ្ណោះ តែនាំការឧបមាមកបាន សម្រាប់បុគ្គលមិនដឹងដោយឧបមាទាំងឡាយ តែក្នុងអដ្ឋកថា លោកបដិសេធសេចក្ដី

នេះ ពោលថា ដែលឈ្មោះថា ឧបមានាំមកបានក្នុងសម្នាក់នៃព្រះពុទ្ធទាំង-ឡាយ លោកកោតក្រែងព្រះថេរៈ ទើបពោលយ៉ាងនេះ ។ បទថា **អនុមស្ស អនុមស្ស បុច្ឆិតា** បានដល់ កំណត់ច្បាស់លាស់ សួរកថាវត្ថុ ១០ ។ សួរថា ការសួរជារបស់ធ្ងន់ ឬការឆ្លើយជារបស់ធ្ងន់ ឆ្លើយថា ការរៀនសូត្រហើយបុច្ឆាមិនជាការៈឡើយ ឯការវិសជ្ជនាជាការៈទាំងបុច្ឆាទាំងវិសជ្ជនា មានហេតុ ឬមានការណ៍ ក៏ជាការៈទាំងអស់ ។ បទថា **សម្មោទិសុ** បានដល់ មានចិត្តត្រេកអរស្មើគ្នា ។

ទេសនាចប់តាមលំដាប់អនុសន្ធិ ដោយប្រការដូច្នេះ ។៚

**រថវិនីតសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## និវាបសូត្រទី ៥

[ ៣៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ នេវាបិកជន ( ជនអ្នកដាំដំណាំ ) មិនមែនដាំដំណាំជាចំណីដើម្បីពួកម្រឹគ ដោយគិតថា ពួកម្រឹគចូរទំពាស៊ីនូវដំណាំដែលអាត្មាអញដាំហើយនេះ ជាសត្វមានអាយុវែង មានសម្បុរល្អ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានយូរអង្វែងចុះ ដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេវាបិកជន ដាំនូវដំណាំដើម្បីពួកម្រឹគ ដោយគិតយ៉ាងនេះវិញទេថា ពួកម្រឹគនឹងចូលមកលុកលុយដំណាំដែលអាត្មាអញដាំហើយនេះ ក៏មុខជានឹងភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះចូលមកលុកលុយ ភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយហើយ នឹងដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ នឹងដល់នូវសេចក្តីប្រមាទ លុះមានសេចក្តីប្រមាទហើយ ជាសត្វគួរអាត្មាអញនឹងធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំនេះ ។

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ បណ្តាសត្វម្រឹគទាំងនោះ ពួកសត្វម្រឹគទី ១ ចូលទៅលុកលុយដំណាំ ដែលនេវាបិកជនដាំឯណោះហើយ ក៏ភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះចូលទៅលុកលុយ ភ្លេចខ្លួនក្នុង

ដំណាំនោះហើយស៊ី ក៏ដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជន នឹងធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ ទាំងនោះ នឹងមិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទេ ។

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ បណ្តាម្រឹគទាំងនោះ ពួកម្រឹគទី ២ គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ចូលទៅលុកលុយដំណាំដែលនេវាបិកជនដាំឯណោះហើយ ក៏ភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះ ចូលទៅលុកលុយភ្លេចខ្លួនក្នុងដំណាំនោះ ហើយស៊ីនូវភោជនទាំងឡាយ ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជននឹងធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ នោះនឹងមិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទេ បើដូច្នោះគួរតែយើងទាំងឡាយ វៀរកុំស៊ីដំណាំទាំងអស់ និងវៀរចាកការស៊ីដោយសេចក្តីភិតភ័យ ហើយគួរចូលទៅរកព្រៃជ្រៅ នៅតាមសប្បាយវិញ លុះពួកម្រឹគទាំងនោះគិតដូច្នោះហើយ ក៏នាំគ្នាវៀរចាកនិវាបភោជន ( ដំណាំជានុយ ) ទាំងអស់ វៀរចាកការស៊ីដោយសេចក្តីភិតភ័យ ក៏ចូលទៅកាន់ព្រៃជ្រៅហើយនៅ ។ លុះដល់ខែជាទីបំផុតនៃគិម្ហរដូវ មានស្មៅនិងទឹកអស់ហើយ កាយរបស់ពួកម្រឹគទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះម្រឹគទាំងនោះ មានកាយដល់នូវភាពស្គាំងស្គមហើយ កម្លាំងកាយនិងសេចក្តីព្យាយាមក៏សាបសូន្យទៅ កាលបើកម្លាំងកាយ និងសេចក្តីព្យាយាម

សាបសូន្យហើយ ពួកម្រឹគក៏នាំគ្នាត្រឡប់មករកដំណាំ ដែលនេវាបិកជនដាំនោះវិញ ទើបពួកម្រឹគទាំងនោះ ចូលទៅលុកលុយក្នុងដំណាំនោះ ហើយភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះចូលទៅលុកលុយក្នុងដំណាំនោះ ហើយភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ ក៏ដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជននឹងធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ នោះ នឹងមិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនឡើយ ។

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ បណ្តាម្រឹគទាំងនោះ ពួកម្រឹគទី ៣ គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ( ចូលទៅលុកលុយ ) នូវដំណាំដែលនេវាបិកជនដាំឯណោះ ។បេ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ នោះមិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ ឯពួកម្រឹគទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ( ចូលទៅលុកលុយ ) នូវដំណាំដែលនេវាបិកជនដាំឯណោះ ។បេ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ១ នោះក៏មិនរួចអំពីឥទ្ធានុភាព របស់នេវាបិកជនទៅហើយ បើដូច្នោះ គួរតែយើងទាំងឡាយ វៀរចាកនិវាបភោជនទាំងអស់ វៀរចាកការបរិភោគ ដោយសេចក្តីភិតភ័យ ហើយចូលទៅកាន់ព្រៃជ្រៅ នៅតាមសប្បាយ ពួកម្រឹគនោះគិតដូច្នោះហើយ ក៏វៀរចាកនិវាបភោជនទាំងអស់ វៀរចាកការបរិភោគដោយសេចក្តីភិតភ័យ ហើយចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ លុះដល់ខែជា

ទីបំផុតនៃគិម្ហរដូវដែលមានស្មៅ និងទឹកអស់ហើយ កាយរបស់ពួកម្រឹគទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះពួកម្រឹគទាំងនោះ មានកាយដល់នូវភាពស្គាំងស្គមហើយ កម្លាំងកាយ និងកម្លាំងព្យាយាមក៏សាបសូន្យទៅ កាលបើកម្លាំងកាយ និងសេចក្តីព្យាយាមសាបសូន្យហើយ ពួកម្រឹគទាំងនោះ ក៏ត្រឡប់មករកដំណាំដែលនេវាបិកជនដាំនោះវិញ ពួកម្រឹគទាំងនោះ ក៏ចូលទៅលុកលុយក្នុងដំណាំនោះភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះម្រឹគទាំងនោះចូលទៅលុកលុយក្នុងដំណាំនោះភ្លេចខ្លួន ស៊ីនូវភោជនទាំងឡាយ ក៏ដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាសត្វគួរនេវាបិកជនធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ នោះក៏មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅអាស្រ័យដំណាំ ដែលនេវាបិកជនដាំឯណោះ ហើយសម្រេចទីនៅ ( ព្ធដ៏ខាងក្រៅ ) លុះសម្រេចទីនៅក្នុងទីនោះហើយ ពួកយើងនឹងកុំចូលទៅលុកលុយដំណាំ ដែលនេវាបិកជនគេដាំឯណោះ ភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះមិនចូលទៅលុកលុយ មិនភ្លេចខ្លួនគ្រាន់តែស៊ីនូវភោជនទាំងឡាយ នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាសត្វដែលនេវាបិកជនធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះ ។ ពួកម្រឹគទី ៣ នោះ ក៏ចូលទៅអាស្រ័យដំណាំដែលនេវាបិកជនដាំឯណោះ ហើយ សម្រេចទីនៅ ( ព្ធដ៏ខាងក្រៅ ) លុះសម្រេចទីនៅក្នុងទីនោះហើយ

ក៏មិនចូលទៅលុកលុយដំណាំដែលនេវាបិកជនដាំឯណោះ មិនភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះពួកម្រឹគទាំងនោះ មិនចូលទៅលុកលុយភ្លេចខ្លួន ក្នុងដំណាំនោះ គ្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាសត្វគួរនេវាបិកជនធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ នេវាបិកជន និងបរិសទ្យរបស់នេវាបិកជនមានសេចក្តីត្រិះរិះដូច្នេះថា អើក៏ពួកម្រឹគទី ៣ ទាំងនេះជាសត្វមានកលមាយា ដូចជាមានឫទ្ធិ ពួកម្រឹគទី ៣ នេះ ជាសត្វផ្សេងគ្នា ( អំពីពួកម្រឹគទី ១ ទី ២ ) មកស៊ីដំណាំដែលអញដាំហើយនេះឯង យើងទាំងឡាយមិនដឹងដំណើរមក និងដំណើរទៅរបស់វាទាំងនោះ បើដូច្នោះមានតែយើងទាំងឡាយធ្វើរបងព័ទ្ធដំណាំដែលយើងទាំងឡាយដាំហើយនេះ ព្រមទាំងប្រទេសជុំវិញ ដោយកំណាត់ឈើ និងបង្កាត់ទាំងឡាយធំៗ គង់យើងទាំងឡាយនឹងឃើញនូវទីអាស្រ័យរបស់ពួកម្រឹគទី ៣ នឹងចាប់ម្រឹគទាំងនោះ ត្រង់កន្លែងដែលវានៅឲ្យបាន ។ ជនទាំងឡាយនោះ នាំគ្នាធ្វើរបងព័ទ្ធដំណាំ ដែលខ្លួនដាំហើយឯណោះ ព្រមទាំងប្រទេសជុំវិញ ដោយកំណាត់ឈើ និងបង្កាត់ទាំងឡាយធំៗ ។ ម្នាលភិក្ខុទាំង-ឡាយ នេវាបិកជនក្តី បរិស័ទរបស់នេវាបិកជនក្តី បានឃើញទីនៅរបស់ពួកម្រឹគទី ៣ នោះហើយ ក៏ចាប់ពួកម្រឹគទាំងនោះ ត្រង់កន្លែងដែលវានៅ ។ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ៣ នោះ មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនឡើយ ។

[ ៤៣ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកម្រឹគទាំងនោះ ម្រឹគទី ៤ គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះ មិនរួចអំពីឥទ្ធានុភាព របស់នេវាបិកជនទៅហើយ ឯពួកម្រឹគទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះមិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះ គួរតែយើងទាំងឡាយ ។បេ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ នោះ មិនរួចអំពីឥទ្ធានុភាព របស់នេវាបិកជនទៅហើយ ឯពួកម្រឹគទី ៣ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ ឯពួកម្រឹគទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកម្រឹគទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកម្រឹគទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះ គួរតែយើងទាំងឡាយ ។បេ។ កាលបើយ៉ាងនេះ ពួកម្រឹគទី ២ ទាំងនោះ មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយគប្បីចូលទៅ អាស្រ័យដំណាំដែលនេវាបិ-កជនដាំឯណោះ ហើយសម្រេចទីនៅ លុះសម្រេចទីនៅក្នុងទីនោះហើយ ពួកយើងនឹងកុំចូលទៅលុកលុយដំណាំ ដែលនេវាបិកជនដាំឯណោះ កុំភ្លេចខ្លួនស៊ីនូវភោជនទាំងឡាយ លុះមិនចូលមកលុកលុយ មិនភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ នឹងជាសត្វគួរនេវាបិកជន

ធ្វើតាមសេចក្ដីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះឡើយ ទើបពួកម្រឹគទី ៣ នោះ ចូលទៅអាស្រ័យដំណាំដែលនេវាបិកជនគេដាំឯណោះ ហើយសម្រេចទីនៅ លុះសម្រេចទីនៅក្នុងទីនោះហើយ ក៏មិនចូលទៅលុកលុយដំណាំដែលនេវាបិកជនដាំឯណោះ មិនភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជនទាំងឡាយ ពួកម្រឹគទី ៣ នោះ មិនចូលទៅលុកលុយក្នុងដំណាំនោះ មិនភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្ដីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្ដីប្រមាទ លុះមិនប្រមាទហើយ ជាសត្វគួរនេវាបិកជនធ្វើតាមសេចក្ដីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះឡើយ ។ ក្នុងសម័យនោះ នេវា-បិកជន និងបរិសទ្យរបស់នេវាបិកជន មានសេចក្ដីត្រិះរិះដូច្នេះថា អើក៏ពួកម្រឹគទី ៣ នេះ មានកលមាយាសិក្សាហើយ ដូចជាសត្វមានឫទ្ធិ ពួកម្រឹគទី ៣ នេះ ជាសត្វផ្សេង ក្រៅអំពីម្រឹគទី ១ និងម្រឹគទី ២ ។បេ។ លុះនេវាបិកជន និងពួកបរិសទ្យរបស់នេវាបិកជន បានឃើញទីនៅនៃពួកម្រឹគទី ៣ ហើយ ក៏ចូលទៅចាប់ម្រឹគទាំងនោះ ត្រង់ទីដែលវានៅ កាលបើយ៉ាងនេះ ពួកម្រឹគទី ៣ នោះ មិនរួចអំពីឥទ្ធានុភាពរបស់នេវាបិកជនទៅហើយ បើដូច្នោះ ទីត្រង់ណាដែលមិនមែនជាវិស័យ របស់នេវាបិកជន និងនេវាបិកបរិសទ្យ គួរយើងទាំងឡាយសម្រេចនូវទីនៅត្រង់កន្លែងនោះ លុះសម្រេចទីនៅត្រង់ទីនោះហើយ កុំចូលទៅលុកលុយដំណាំដែលនេវាបិកជនដាំឯណោះ កុំភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជនទាំងឡាយ នឹងមិនដល់នូវសេចក្ដីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់នូវសេចក្ដីប្រមាទ លុះមិនប្រមាទហើយ នឹងជាសត្វគួរនេវាបិកជន

ធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះ ។ ទើបពួកម្រឹគទាំងនោះ សម្រេចទីនៅត្រង់ទី ដែលមិនមែនជាវិស័យរបស់នេវាបិកជន និងនេវាបិក-បរិសទ្យនោះ លុះសម្រេចនូវទីអាស្រ័យក្នុងទីនោះហើយ ក៏មិនចូលទៅលុក លុយដំណាំ ដែលនេវាបិកជនដាំឯណោះ មិនភ្លេចខ្លួន គ្រាន់តែស៊ីនូវភោជន ទាំងឡាយ លុះម្រឹគទាំងនោះមិនចូលទៅលុកលុយ មិនភ្លេចខ្លួនក្នុងដំណាំនោះ ហើយ គ្រាន់តែស៊ីនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិន ស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាសត្វគួរ នេវាបិកជនធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះ ។ ម្នាលភិក្ខុ ទាំងឡាយ ក្នុងសម័យនោះ នេវាបិកជន និងនេវាបិកបរិសទ្យមានសេចក្តី ត្រិះរិះដូច្នេះថា អើ ក៏ពួកម្រឹគទី ៤ នេះ មានកលមាយាសិក្សាហើយ ដូចជា សត្វមានឫទ្ធិ ពួកម្រឹគទី ៤ នេះ ជាសត្វផ្សេងអំពីពួកម្រឹគទី ១ ទី ២ ទី ៣ នោះ តែងស៊ីនូវដំណាំដែលយើងទាំងឡាយដាំហើយនេះ ឯយើងទាំងឡាយ មិនដឹងនូវដំណើរមក និងដំណើរទៅរបស់ពួកវា បើដូច្នោះ មានតែយើងទាំង-ឡាយធ្វើរបងព័ទ្ធដំណាំដែលយើងដាំហើយនេះ ព្រមទាំងប្រទេសជុំវិញ ដោយ កំណាត់ឈើ និងបង្កាត់ទាំងឡាយធំៗ ដោយគិតថា ធ្វើដូចម្តេច ពួកយើង នឹងឃើញនូវទីនៅរបស់ពួកម្រឹគទី ៤ ពួកម្រឹគទាំងនោះ គប្បីចូលទៅកាន់ទី គួរចាប់បានហ្ន៎ ( លុះគិតដូច្នេះហើយ ) ជនទាំងឡាយនោះ ក៏ធ្វើរបងព័ទ្ធ ដំណាំដែលខ្លួនដាំឯណោះ ព្រមទាំងប្រទេសជុំវិញ ដោយកំណាត់ឈើ និង បង្កាត់ទាំងឡាយធំៗ ។ ម្នាលភិក្ខុទាំងឡាយ នេវាបិកជនក្តី នេវាបិកបរិសទ្យ

ក្តី មិនបានឃើញទីអាស្រ័យរបស់ពួកម្រឹគទី ៤ ទេ ក៏នាំគ្នាទៅរកចាប់ម្រឹគទាំងនោះ ត្រង់កន្លែងដែលវានៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ នេវាបិកជន និងនេវាបិកបរិសទ្យ មានសេចក្តីត្រិះរិះដូច្នេះថា ប្រសិនបើយើងទាំងឡាយ សម្លាប់នូវពួកម្រឹគទី ៤ ហើយ អ្នកទាំងឡាយដទៃមុខជានឹងសម្លាប់នូវម្រឹគដែលយើងសម្លាប់នោះដែរ កាលបើយ៉ាងនេះ ពួកម្រឹគមុខជានឹងបោះបង់ចោលនូវជំណាំ ដែលយើងទាំងឡាយដាំហើយនេះ ដោយប្រការទាំងពួង បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើព្រងើយកន្តើយនឹងពួកម្រឹគទី ៤ ។ ម្នាលភិក្ខុទាំងឡាយ នេវាបិកជនក្តី នេវាបិកបរិសទ្យក្តី ក៏ធ្វើព្រងើយកន្តើយនឹងពួកម្រឹគទី ៤ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកម្រឹគទី ៤ នោះ រួចអំពីឥទ្ធានុភាពរបស់នេវាបិកជនបាន ។

[ ៤៤ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះឯង តថាគតធ្វើដើម្បីបញ្ជាក់សេចក្តីឲ្យច្បាស់លាស់ ។ សេចក្តីក្នុងរឿងឧបមានុ៎ះ ដូចតទៅនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ជំណាំនុ៎ះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា នេវាបិកជន ( អ្នកដាំជំណាំ ) នុ៎ះ ជាឈ្មោះនៃមារដែលមានចិត្តអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ពួកនេវាបិកបរិស័ទនុ៎ះ ជាឈ្មោះរបស់បរិស័ទនៃមារ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ពួកម្រឹគនុ៎ះ ជាឈ្មោះនៃសមណៈ និងព្រាហ្មណ៍ទាំងឡាយ ។

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកទី ១ លុកលុយជំណាំ ដែលមារដាំហើយឯណោះ និងលោកា-

មិសៈ ( អាមិសៈក្នុងលោក ) ទាំងឡាយឯណោះ ក្មេចខ្ចួនបរិភោគភោជនទាំងឡាយ កាលពួកសមណព្រាហ្មណ៍ទាំងនោះ លុកលុយក្នុងដំណាំ និងអាមិសៈក្នុងលោកនោះហើយ ក្មេចខ្ចួនបរិភោគភោជនទាំងឡាយ ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ សមណៈ និងព្រាហ្មណ៍ពួកទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ១ នោះ មានសេចក្តីឧបមាយ៉ាងណា តថាគតពោលនូវសមណព្រាហ្មណ៍ទាំងឡាយទី ១ នេះថា មានឧបមេយ្យដូច្នោះដែរ ។

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកទី ២ គិតព្រមគ្នាយ៉ាងនេះថា សមណៈ និងព្រាហ្មណ៍ពួកទី ១ ណា លុកលុយដំណាំដែលមារដាំហើយឯណោះ និងលោកាមិសៈឯណោះ ក្មេចខ្ចួនបរិភោគភោជនទាំងឡាយ កាលសមណព្រាហ្មណ៍ទាំងនោះលុកលុយក្នុងដំណាំ និងលោកាមិសៈនោះ ក្មេចខ្ចួនបរិភោគភោជនទាំងឡាយ ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង កាលបើយ៉ាងនេះ សមណៈ និងព្រាហ្មណ៍ពួកទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយវៀរចាកនិវាបភោជន និងលោកាមិសៈចេញ ដោយប្រការទាំងពួង វៀរ

ចាកការបរិភោគ ព្រោះសេចក្តីខ្លាចចេញ ហើយចូលទៅរកព្រៃជ្រៅនៅតាមសប្បាយ លុះសមណព្រាហ្មណ៍ទាំងនោះគិតដូច្នេះហើយ ក៏វៀរចាកនិវាបភោជន និងលោកាមិសៈដោយប្រការទាំងពួង ពួកសមណព្រាហ្មណ៍ទាំងនោះបានវៀរចាកនិវាបភោជន និងលោកាមិសៈដោយប្រការទាំងពួង ទាំងវៀរចាកបរិភោគព្រោះសេចក្តីខ្លាច ហើយចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ ពួកសមណព្រាហ្មណ៍ទាំងនោះ មានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានកម្ទេច ( ចំនៀរស្បែក ) ជាអាហារខ្លះ មានបន្លែ ឬសារាយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើ និងផ្លែឈើក្នុងព្រៃជាអាហារខ្លះ មានផ្លែឈើដែលជ្រុះឯងជាភោជនខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងដងព្រៃជ្រៅនោះ លុះដល់ខែជាទីបំផុតនៃគិម្ហរដូវ មានស្មៅ និងទឹកអស់ហើយ កាយរបស់សមណព្រាហ្មណ៍ទាំងនោះក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះមានកាយដល់នូវភាពស្គាំងស្គមហើយ កម្លាំង និងសេចក្តីព្យាយាមក៏សាបសូន្យទៅ កាលបើកម្លាំង និងសេចក្តីព្យាយាមសាបសូន្យហើយ ចេតោវិមុត្តិក៏សាបសូន្យទៅដែរ កាលបើចេតោវិមុត្តិសាបសូន្យហើយ ពួកសមណព្រាហ្មណ៍ទាំងនោះត្រឡប់មកកាន់ដំណាំ ដែលមារដាំហើយនោះវិញផង មកកាន់លោកាមិសៈទាំងឡាយនោះផង ពួកសមណព្រាហ្មណ៍ទាំងនោះ បានលុកលុយក្នុងដំណាំ និងលោកាមិសៈនោះហើយ ភ្លេចខ្លួនបរិភោគភោជនទាំងឡាយ កាលសមណព្រាហ្មណ៍ទាំង

នោះ លុកលុយភ្លេចខ្លួនក្នុងដំណាំ និងលោកាមិសៈនោះ បរិភោគភោជនហើយ ដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ សមណ-ព្រាហ្មណ៍ពួកទី ២ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ២ នោះ មានសេចក្តីឧបមាដូចម្តេចមិញ តថាគតពោលនូវសមណព្រាហ្មណ៍ទាំងឡាយទី ២ នេះ ថាមានឧបមេយ្យដូច្នោះដែរ ។

[ ៤៧ ] ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ទី ៣ គិតគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាព របស់មារទៅហើយ ទាំងពួកសមណព្រាហ្មណ៍ទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយ គប្បីវៀរចាកនិវាបភោជន និងលោកាមិសៈចេញ ដោយប្រការទាំងពួង ទាំងវៀរចាកការបរិភោគ ព្រោះសេចក្តីខ្លាច ហើយចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ លុះសមណ-ព្រាហ្មណ៍ទី ២ ទាំងនោះ គិតដូច្នេះហើយ ក៏វៀរចាកនិវាបភោជន និងលោកាមិសៈចេញ ដោយសព្វគ្រប់ វៀរចាកការបរិភោគ ព្រោះសេចក្តីខ្លាច ហើយចូលទៅកាន់ព្រៃជ្រៅនៅតាមសប្បាយ ពួកសមណព្រាហ្មណ៍ទាំងនោះ

មានបន្លែស្រស់ជាអាហារខ្លះ ។បេ។ មានផ្លែឈើដែលជ្រុះឯង ជាភោជនខ្លះ ក្នុងដងព្រៃនោះ លុះដល់ខែជាខាងចុងនៃគិម្ហរដូវ មានស្មៅ និងទឹកអស់ហើយ កាយរបស់សមណព្រាហ្មណ៍ទាំងនោះ ក៏ដល់នូវភាពស្គាំងស្គមក្រៃពេក លុះសមណព្រាហ្មណ៍ទាំងនោះ មានកាយដល់នូវភាពស្គាំងស្គមក្រៃពេកហើយ កម្លាំង និងសេចក្តីព្យាយាមក៏សាបសូន្យទៅ កាលបើកម្លាំង និងសេចក្តីព្យាយាមសាបសូន្យហើយ ចេតោវិមុត្តិក៏សាបសូន្យដែរ កាលបើចេតោវិមុត្តិសាបសូន្យហើយ ពួកសមណព្រាហ្មណ៍ទី ២ នោះ ក៏ត្រឡប់មកកាន់ជំណាំដែលមារដាំហើយនោះផង ត្រឡប់មកកាន់លោកាមិសៈទាំងឡាយនោះផង ពួកសមណព្រាហ្មណ៍ទាំងនោះ លុកលុយក្នុងជំណាំ និងលោកាមិសៈនោះ ភ្លេចខ្លួនបរិភោគភោជនទាំងឡាយ កាលពួកសមណព្រាហ្មណ៍ទាំងនោះ លុកលុយក្នុងជំណាំនោះ ភ្លេចខ្លួនបរិភោគភោជនទាំងឡាយ ហើយដល់នូវសេចក្តីស្រវឹង លុះស្រវឹងហើយ ក៏ដល់នូវសេចក្តីប្រមាទ លុះប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាបាន ព្រោះជំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ២ នោះ មិនរួចអំពីឥទ្ធានុភាពរបស់មារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយ នៅអាស្រ័យនឹងជំណាំ ដែលមារដាំហើយឯណោះផង អាស្រ័យនឹងលោកាមិសៈឯណោះផង ហើយគប្បីសម្រេចទីនៅអាស្រ័យ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ យើងកុំលុកលុយភ្លេចខ្លួននឹងជំណាំដែលមារដាំហើយនោះផង នឹងលោកាមិសៈឯណោះផង គ្រាន់តែបរិភោគភោជនទាំងឡាយ

កាលបើយើងមិនលុកលុយមិនក្ជេចខ្លួន គ្រាន់តែបរិភោគភោជន ក៏នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏នឹងមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ នឹងជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង លុះពួកសមណព្រាហ្មណ៍ទី ៣ នោះ គិតដូច្នេះហើយ ក៏ចូលទៅអាស្រ័យដំណាំ ដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ ហើយសម្រេចទីនៅអាស្រ័យ ។ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ ក៏មិនបានលុកលុយ មិនបានក្ជេចខ្លួននឹងដំណាំ ដែលមារដាំហើយឯណោះ នឹងលោកាមិសៈទាំងឡាយឯណោះ មិនក្ជេចខ្លួន គ្រាន់តែបរិភោគភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ។ មួយវិញទៀត ពួកសមណព្រាហ្មណ៍ទី ៣ មានសេចក្តីយល់យ៉ាងនេះថា លោកទៀងដូច្នេះខ្លះ លោកមិនទៀងដូច្នេះខ្លះ លោកមានទីបំផុតដូច្នេះខ្លះ លោកមិនមានទីបំផុតដូច្នេះខ្លះ ជីវិតនោះ គឺសរីរៈនោះដូច្នេះខ្លះ ជីវិតក៏ដទៃ សរីរៈក៏ដទៃដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ កើតទៀតដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះខ្លះ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតក៏មាន មិនមែនជាមិនកើតទៀតក៏មានដូច្នេះខ្លះ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកសមណ-

ព្រាហ្មណ៍ទី ៣ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ៣ នោះ មានឧបមាដូចម្តេចមិញ តថាគតពោលនូវសមណ-ព្រាហ្មណ៍ទី ៣ នេះថា មានឧបមេយ្យដូច្នោះដែរ ។

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ទី ៤ គិតគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធា-នុភាពនៃមារទៅហើយ ពួកសមណព្រាហ្មណ៍ទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយ ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ២ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទៅហើយ ពួកសមណព្រាហ្មណ៍ទី ៣ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះហើយ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទៅហើយ ពួកសមណព្រាហ្មណ៍ទី ២ ណា គិតព្រមគ្នាយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ទី ១ ណា ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ១ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយ ។បេ។ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ២ នោះ មិនរួចអំពីឥទ្ធានុភាពនៃមារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយចូលទៅអាស្រ័យដំណាំ ដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ

ហើយគប្បីសម្រេចទីនៅអាស្រ័យ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ យើងកុំលុកលុយ កុំភ្លេចខ្លួននឹងដំណាំ ដែលមារដាំហើយឯណោះផង និងលោកាមិសៈទាំងឡាយឯណោះផង ។បេ។ កាលបើយើងមិនលុកលុយ មិនភ្លេចខ្លួន គ្រាន់តែបរិភោគភោជនទាំងឡាយ នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ នឹងជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង លុះសមណព្រាហ្មណ៍ទាំងនោះ គិតដូច្នេះហើយ ក៏ចូលទៅអាស្រ័យដំណាំដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ ហើយសម្រេចទីនៅអាស្រ័យ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ មិនលុកលុយ មិនភ្លេចខ្លួននឹងដំណាំដែលមារដាំហើយឯណោះផង និងលោកាមិសៈទាំងឡាយឯណោះផង គ្រាន់តែបរិភោគភោជនទាំងឡាយ កាលសមណព្រាហ្មណ៍ទី ៣ ទាំងនោះ មិនបានលុកលុយ មិនបានភ្លេចខ្លួនក្នុងដំណាំនោះហើយ គ្រាន់តែបរិភោគភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ។ តែសមណព្រាហ្មណ៍ទី ៣ ទាំងនោះ មានសេចក្តីយល់ឃើញយ៉ាងនេះថា លោកទៀងដូច្នេះខ្លះ ។បេ។ សត្វទៅខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតក៏មាន មិនមែនមិនកើតទៀតក៏មានដូច្នេះខ្លះ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ៣ នោះ មិនរួចអំពីឥទ្ធានុភាព

របស់មារទៅហើយ បើដូច្នោះ មានតែយើងទាំងឡាយសម្រេចទីនៅអាស្រ័យត្រង់ទីដែលមិនមែនជាដំណើរនៃមារ និងបរិស័ទរបស់មារ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ យើងកុំលុកលុយដំណាំដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ មិនភ្លេចខ្លួន គ្រាន់តែបរិភោគនូវភោជនទាំងឡាយ កាលបើយើងមិនលុកលុយ មិនភ្លេចខ្លួន គ្រាន់តែបរិភោគនូវភោជនទាំងឡាយ នឹងមិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ នឹងមិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ នឹងជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ទើបពួកសមណព្រាហ្មណ៍ទាំងនោះ សម្រេចទីនៅអាស្រ័យត្រង់ទីដែលមិនមែនជាដំណើរនៃមារ និងបរិស័ទរបស់មារ លុះសម្រេចទីនៅអាស្រ័យក្នុងទីនោះហើយ ក៏មិនបានលុកលុយដំណាំដែលមារដាំហើយឯណោះ និងលោកាមិសៈទាំងឡាយឯណោះ មិនភ្លេចខ្លួន គ្រាន់តែបរិភោគនូវភោជនទាំងឡាយ កាលពួកសមណព្រាហ្មណ៍ទាំងនោះ មិនលុកលុយ មិនភ្លេចខ្លួនក្នុងដំណាំ និងលោកាមិសៈនោះហើយ គ្រាន់តែបរិភោគនូវភោជនទាំងឡាយ ក៏មិនដល់នូវសេចក្តីស្រវឹង លុះមិនស្រវឹងហើយ ក៏មិនដល់នូវសេចក្តីប្រមាទ លុះមិនប្រមាទហើយ ជាអ្នកគួរមារធ្វើតាមសេចក្តីប្រាថ្នាមិនបាន ព្រោះដំណាំឯណោះផង ព្រោះលោកាមិសៈឯណោះផង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ពួកសមណព្រាហ្មណ៍ទី ៤ នោះ ទើបរួចអំពីឥទ្ធានុភាពនៃមារបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកម្រឹគទី ៤ នោះ មានសេចក្តីឧបមាដូចម្តេចមិញ តថាគត

ពោលនូវពួកសមណព្រាហ្មណ៍ទី ៤ នេះ ថាមានឧបមេយ្យដូច្នោះដែរ ។

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ ចុះទីដែលមិនមែនជាដំណើររបស់មារ និងបរិស័ទនៃមារដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ និងបីតិ សុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុធ្វើនូវមារឲ្យខ្វាក់ បំបែកភ្នែកមិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារ មានចិត្តលាមករកមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុនោះព្រោះចូលទៅរម្ងាប់នូវវិតក្កវិចារៈរួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ក៏ញ៉ាំងចិត្តជាសមាធិឲ្យចម្រើនឡើង គ្មានវិតក្កវិចារៈទេ មានតែបីតិ និងសុខកើតអំពីសមាធិ ។បេ។ ហើយក៏បានចូលកាន់តតិយជ្ឈាន ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុបានធ្វើមារឲ្យខ្វាក់ បំបែកភ្នែកមិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមករកមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា ព្រោះដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុបានធ្វើនូវមារឲ្យខ្វាក់ បំបែកភ្នែកមិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមក

រកមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ក៏ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។បេ។ ភិក្ខុ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចមិនមានដូច្នេះ ។បេ។ ភិក្ខុ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់សញ្ញាវេទយិតនិរោធ (រលត់សញ្ញា និងវេទនា) ទើបអាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់ទៅ ព្រោះឃើញ (នូវអរិយសច្ច) ដោយមគ្គប្បញ្ញា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ភិក្ខុបានធ្វើមារឲ្យខ្វាក់ បំបែកភ្នែក មិនឲ្យឃើញស្នាមជើង ដល់នូវវិស័យដែលមារមានចិត្តលាមករកមិនឃើញ ជាអ្នកឆ្លងនូវតណ្ហាដែលចំពាក់នៅក្នុងលោក ។ លុះព្រះមានព្រះភាគសម្តែងនិវាបសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្តត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## និវាបសូត្រទី ៥ ចប់

# អដ្ឋកថា

# និវាបសូត្រ

[ ៣៩ ] និវាបសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិវាបសូត្រនោះដូចតទៅនេះ បុគ្គលណា រមែងដាំពូជ គឺស្មៅទុកក្នុងព្រៃ ដើម្បីចាប់ម្រឹគ ដោយតាំងចិត្តថា អញនឹងចាប់ពួកម្រឹគដែលមកស៊ីស្មៅនេះបានស្រួល បុគ្គលនោះ ឈ្មោះថា **នេវាបិក។** បទថា **និវាបំ** បានដល់ ពូជដែលគប្បីដាំ ។ បទថា **និវុត្តំ** បានដល់ ដាំ ។ បទថា **មិគជាតា** បានដល់ ប្រជុំពួកម្រឹគ ។ បទថា **អនុបខជ្ជ** ប្រែថា មិនចូលទៅបៀតបៀន ។ បទថា **មុច្ឆិតា** បានដល់ ងប់ជ្រប់ដោយអំណាចតណ្ហា អធិប្បាយថា ឈមចុះទៅក្នុងហទយៈដោយតណ្ហាហើយ ឲ្យដល់នូវការសុបសៅ ។ បទថា **មទំ អាបជ្ជិស្សន្តិ** បានដល់ នឹងដល់នូវការស្រវឹងដោយអំណាចនៃមានះ ។ បទថា **បមាទំ** បានដល់ ភាវៈ គឺភាពជាអ្នកភ្លេចស្មារតី ។ បទថា **យថា-កាមករណីយា ភវិស្សន្តិ** សេចក្ដីថា អញប្រាថ្នាដោយប្រការណា នឹងត្រូវធ្វើដោយប្រការនោះ ។ បទថា **ឥមស្មឹ និវាបេ** បានដល់ ក្នុងទីដែលជាទីដាំនេះ ។ បានឮថា ដែលឈ្មោះថា ស្មៅដាំនេះ មានការដុះលូតលាស់ល្អក្នុងរដូវប្រាំងក៏មាន ។ រដូវប្រាំងរមែងមានដោយប្រការណាមួយ ស្មៅនោះរមែងដុះក្រាស់ដូចគ្នានឹងស្រងែ និងដូចដុំពពក ដោយប្រការនោះៗ ។ ពួកព្រានភ្ជួរក្នុងទីសម្បូរដោយទឹកមួយកន្លែង ហើយដាំដោយស្មៅនោះ រាំងរបងប្រកបដោយទ្វាររក្សា ។ កាលណាក្នុងរដូវប្រាំងរាំងស្ងួត ស្មៅគ្រប់ប្រភេទ

រមែងមានពណ៌ស ទឹកត្រឹមតែសើមអណ្ដាត ក៏លំបាកនឹងរក ក្នុងវេលានោះ ម្រឹគទាំងឡាយ នាំគ្នាស៊ីស្មៅដែលមានពណ៌ស និងស៊ីកឈើចាស់ៗ ត្រាច់ទៅដោយភ័យខ្លាច ប៉ះភ្និនស្មៅដែលដាំ មិនពិចារណាដល់ការសម្លាប់ និងការចាប់ជាដើម ទ្ធូងរបងចូលទៅ ។ ពិតហើយ ស្មៅដែលដាំ រមែងជាទីស្រឡាញ់ ជាទីពេញចិត្តក្រៃលែងនៃពួកម្រឹគទាំងនោះ ។ ម្ចាស់ស្មៅបានឃើញពួកម្រឹគទាំងនោះ ធ្វើហាក់ដូចជាមិនឃើញអស់ ២-៣ ថ្ងៃ បើកទ្វារខាងក្នុងទីដែលដាំស្មៅនោះ សូម្បីអណ្ដូងទឹកក៏មានក្នុងទីនោះៗ ពួកម្រឹគចូលទៅតាមទ្វារដែលបើក ស៊ី និងផឹកប៉ុណ្ណោះ ក៏ចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង ក៏មិនមានអ្នកណាធ្វើអ្វី ព្រោះដូច្នោះ ទើបបក់ស៊ីកត្រចៀក ស៊ីផឹកហើយមិនប្រញាប់ទៅ ។ ថ្ងៃស្អែកឡើងមិនមានអ្នកណាធ្វើអ្វី ស៊ីផឹកតាមពេញចិត្ត ចូលទៅដេកសម្ងំត្រង់គុម្ពឈើ ។ ពួកព្រានដឹងថា ម្រឹគភ្លេចខ្លួន ក៏បិទទ្វារ វាយតាំងអំពីជាយព្រៃទៅ ។ ម្រឹគទាំងនោះ ត្រូវម្ចាស់ស្មៅធ្វើបានតាមចិត្ត ក្នុងព្រៃស្មៅនោះ ដោយប្រការដូច្នេះ ។

[ ៤០ ] បទថា **តត្រ ភិក្ខវេ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ក្នុងពួកម្រឹគទាំងនោះ ។ បទថា **បឋមា មិគជាតា** បានដល់ ដែលឈ្មោះថា ពួកម្រឹគទី ១ និងទី ២ រមែងមិនមាន ។ ព្រះមានព្រះភាគទ្រង់កំណត់តាមលំដាប់ពួកម្រឹគដែលមកដល់ សម្ដែងប្រារព្ធឈ្មោះថា ម្រឹគទី ១-២-៣-៤ ។ បទថា **ឥទ្ធានុភាវា** បានដល់ ព្រោះត្រូវធ្វើតាមបំណង ។ ពិតហើយ ភាពជាអ្នកជំនាញនោះឯង លោកបំណងយកថា ឫទ្ធិ និងថា អំណាចក្នុងទីនេះ ។

[ ៤១-៤៣ ] បទថា **ភយភោគា** បានដល់ អំពីការបរិភោគដោយសេចក្តីភ័យខ្លាច ។ បទថា **ពលវីរិយំ** បានដល់ វាយោធាតុដែលបក់ទៅមក អធិប្បាយថា វាយោធាតុនោះអស់ទៅ ។ បទថា **ឧបនិស្សាយ អាសយំ កប្បេយ្យាម** សេចក្តីថា កាលពួកម្រឹគដេកស៊ីខាងក្នុងក្តី មកអំពីខាងក្រៅទំពាស៊ីក្តី រមែងមានតែការខ្លាចប៉ុណ្ណោះ ម្រឹគទាំងនោះគិតថា ពួកយើងអាស្រ័យសួនស្មៅនោះ ទើបនៅអាស្រ័យក្នុងទីមួយកន្លែង ។ បទថា **ឧប-និស្សាយ អាសយំ កប្បយឹសុ** សេចក្តីថា ដែលឈ្មោះថា ពួកព្រាន រមែងមិនមានការភ្លេចភ្លាំងគ្រប់កាលឡើយ ពួកម្រឹគដែលអាស្រ័យសួនស្មៅ ដោយតាំងចិត្តថា ពួកយើងនឹងដេកក្នុងគុម្ពឈើ និងត្រង់ជើងរបងក្នុងទីនោះៗ កាលព្រានទាំងនោះចៀសទៅលុបមុខ ឬទៅបរិភោគអាហារ ទើបចូលទៅកាន់និវាបស្ថាន លុះស៊ីផឹកស្រេចហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន ហើយអាស្រ័យនៅក្នុងទីស្អុក មានគុម្ពឈើ និងជើងរបងជាដើម ។ បទថា **ភុញ្ជឹសុ** បានដល់ ដឹងពេលដែលពួកព្រានភ្លេចខ្លួនដោយន័យដូចពោលហើយ ពពាក់ពពូនទៅស៊ី ។ បទថា **កេដុភិនោ** បានដល់ កេរាដិកសាស្ត្រ ( តម្រាកលមាយាដែលសិក្សាមក ) ។ បទថា **ឥទ្ធិមន្តា** ប្រែថា ដូចបុគ្គលមានឫទ្ធិ ។ បទថា **បរជនា** បានដល់ យក្ខ យក្ខទាំងនេះមិនមែនម្រឹគ ។ បទថា **អាគតឹ វា គតឹ វា** បានដល់ ពួកយើងមិនដឹងនូវការគិតរបស់ពួកព្រានទាំងនោះដូច្នេះថា ពួកម្រឹគទាំងនេះ រមែងមកត្រង់ផ្លូវឈ្មោះនេះ ទៅក្នុងទីឈ្មោះនោះ ។ បទថា **ទណ្ឌវាគុរាហិ** បានដល់ បង្កាត់ គឺកំណាត់ឈើ និងដំបង ។ បទថា

**សមន្តា សប្បទេសំមនុបរិវារេសុំ** សេចក្តីថា អ្នកដាំមានមាយាច្រើន គិតថា ម្រឹគនេះនឹងមិនទៅឆ្ងាយ នឹងដេកក្នុងទីជិតនេះឯង ទើបព័ទ្ធដីរបស់ខ្លួន គឺឱកាសដែលធំជុំវិញចម្ការបន្លែ ។ បទថា **អទ្ទសាសុំ** សេចក្តីថា ព័ទ្ធយ៉ាងនេះហើយ ក៏វាយបន្ទាត់ដោយជុំវិញហើយឃ្លាំមើល ។ បទថា **យត្ថ តេ** បានដល់ ពួកព្រានទាំងនោះបានទៅចាប់ក្នុងទីណា បានឃើញទីនោះ ។ បទថា **យន្នូន មយំ យត្ថ អគតិ** សេចក្តីថា បានឮថា ព្រានទាំងនោះគិតយ៉ាងនេះថា ពួកម្រឹគដែលដេកស៊ីនៅខាងក្នុងក្តី មកពីខាងក្រៅស៊ីក្តី នៅក្នុងទីជិតស៊ីក្តី រមែងមានការភ័យខ្លាចទាំងអស់ ពិតហើយ ម្រឹគទាំងនោះត្រូវព័ទ្ធចាប់ដោយសំណាញ់ ព្រោះដូច្នោះ ទើបម្រឹគទាំងនោះ គិតដូច្នេះថា ហេតុអ្វីអញត្រូវដេកក្នុងទីដែលពួកអ្នកធ្វើចម្ការ មិនទៅហ្ន៎ ។ បទថា **អញ្ញេ ឃដ្ដេស្សន្តិ** បានដល់ បៀតបៀនម្រឹគដទៃៗ ដែលនៅឆ្ងាយអំពីទីនោះៗ ។ បទថា **តេ ឃដ្ដិតា អញ្ញេ** បានដល់ ម្រឹគដែលត្រូវបៀតបៀនទាំងនោះ ក៏នឹងត្រូវបៀតបៀនម្រឹគដទៃៗ ដែលនៅឆ្ងាយជាងនោះ ។ បទថា **ឯវំ ឥមំ និវាបំ និវុត្តំ សព្វសោ មិគជាតា រញ្ចិស្សន្តិ** បានដល់ ប្រជុំពួកម្រឹគទាំងអស់ និងលះបង់នូវចម្ការបន្លែ ដែលពួកយើងដាំ ។ បទថា **អជ្ឈុបេក្ខេយ្យាម** បានដល់ គប្បីខ្វល់ខ្វាយចាប់ម្រឹគទាំងនោះ ។ កាលម្រឹគទាំងឡាយ នាំគ្នាមកដោយអាការយ៉ាងណាក៏ដោយ ពួកយើងនឹងបានកូនម្រឹគខ្លះ ម្រឹគចាស់ខ្លះ ម្រឹគកម្លាំងតិចខ្លះ ម្រឹគបែកហ្វូងខ្លះ កាលមិនមក រមែងមិនបានវត្ថុណាមួយឡើយ ។ បទថា **អជ្ឈុបេក្ខឹសុ ខោ ភិក្ខវេ** បានដល់ គិតយ៉ាងនេះហើយ ទើបបានខ្វល់ខ្វាយ ។

[ ៤៥ ] ក្នុងបទថា **អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកា-មិសានិ** នេះ ។ បទថា **និវាប** ក្តី បទថា **លោកាមិស** នេះក្តី ជាឈ្មោះនៃកាមគុណ ៥ ដែលជានុយនៃវដ្តៈ ។ មារមិនបានដើរព្រោះពូជកាមគុណដូចពូជធម្មតានោះឡើយ តែផ្សាយអំណាចគ្របដណ្តប់បុគ្គលដែលត្រេកអរក្នុងកាមគុណ ដូច្នោះ ទើបកាមគុណ ឈ្មោះថា ជានុយបញ្ឆោតរបស់មារ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អមុំ និវាបំ និវុត្តំ មារស្ស** ដូច្នេះ ។ បទថា **ន បរិមុច្ចឹសុ មារស្ស ឥទ្ធានុភាវា** បានដល់ ជាអ្នកធ្លាក់នៅក្នុងអំណាចរបស់មារ ត្រូវមារធ្វើបានតាមពេញចិត្ត ។ នេះជាការប្រៀបធៀបដោយបព្វជ្ជា ព្រមទាំងបុត្រ និងភរិយា ។

[ ៤៦-៤៨ ] ឈ្មោះថា **ចេតោវិមុត្តិ** ក្នុងបទថា **ចេតោវិមុត្តិ បរិហាយិ** នោះ បានដល់ អាស្រ័យទីកើតឡើងថា ពួកយើងនឹងនៅក្នុងព្រៃ អធិប្បាយថា អធ្យាស្រ័យនោះវិនាសហើយ ។ បទថា **តថូបមេ អហំ ភិក្ខវេ ឥមេ ទុតិយេ** នេះ ជាការប្រៀបធៀបដោយបព្វជ្ជា ប្រកបដោយធម៌របស់ព្រាហ្មណ៍ពិតហើយ ព្រាហ្មណ៍ទាំងឡាយប្រព្រឹត្តកោមាព្រហ្មចរិយៈ ៤៨ ឆ្នាំ គិតថា នឹងបន្តបវេណី ព្រោះខ្លាចវង្សៈដាច់ ស្វែងរកទ្រព្យ បានភរិយា គ្រប់គ្រងផ្ទះ កាលកើតបានបុត្រមួយ គិតថា អញមានកូនហើយ វង្សៈមិនដាច់ បន្តបវេណីហើយ ទើបចេញបួសទៀត ឬមានភរិយាដូចដើម ។ បទថា **ឃរំ ហិ តេ ភិក្ខវេ តតិយាបិ សមណព្រាហ្មណា ន បរិមុច្ចឹសុ** សេចក្តីថា សមណ-ព្រាហ្មណ៍ទាំងនោះ មិនផុតចាកឫទ្ធិ និងអំណាចរបស់មារដូចមុន បានជាអ្នក

ត្រូវមារធ្វើតាមការពេញចិត្ត ។

សួរថា សមណព្រាហ្មណ៍ទាំងនោះធ្វើអ្វី ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ ទៅកាន់ស្រុកនិគម និងរាជធានី ឲ្យសាងអាស្រម នៅក្នុងអារាម និងសួននោះៗ ឲ្យក្មេងក្នុងត្រកូលទាំងឡាយសិក្សាសិប្បៈ មានប្រការផ្សេងៗ ដូចជា វិជ្ជាដំរី វិជ្ជាសេះ និងវិជ្ជារថជាដើម ។ ដូច្នោះ សមណព្រាហ្មណ៍ទាំងនោះ ត្រូវសំណាញ់ គឺទិដ្ឋិរបស់មារ ដែលជាអ្នកមានបាបបូរិត ត្រូវមារធ្វើបានតាមពេញចិត្ត ដូចហ្វូងម្រឹគទី ៣ ដែលត្រូវព័ទ្ធចាប់ដោយសំណាញ់ ។

បទថា **តថូបមេ អហំ ឥមេ ចតុត្ថេ** នេះ ជាគ្រឿងនាំមកប្រៀបធៀបសាសនានេះ ។

[ ៤៩ ] បទថា **អន្ធមកាសិ មារំ** សេចក្តីថា មិនទម្លាយភ្នែករបស់មារ តែចិត្តរបស់ភិក្ខុអ្នកចូលឈាន ដែលជាបាទរបស់វិបស្សនា រមែងអាស្រ័យអារម្មណ៍នេះប្រព្រឹត្តទៅ ដូច្នោះ ទើបមារមិនអាចមើលឃើញ ដោយហេតុនោះ ទើបលោកពោលថា **អន្ធមកាសិ មារំ** ដូច្នេះ ។ បទថា **អបទំ វធិត្វា មារចក្ខុំ** សេចក្តីថា ដោយបរិយាយនេះឯង ទើបលោកសម្ងាប់ដោយប្រការដែលធ្វើចក្ខុរបស់មារ មិនឲ្យឃើញស្នាមជើង មិនមានទីពឹង ប្រាសចាកអារម្មណ៍ ។ បទថា **អទស្សនំ គតោ បាបិមតោ** បានដល់ ដោយបរិយាយនោះឯង ទើបមារមានចិត្តបាបមើលមិនឃើញ ។ ពិតហើយ មារនោះមិនអាចមើលឃើញសរីរៈ គឺញាណរបស់ភិក្ខុអ្នកចូលឈាន ដែលជាបាទរបស់វិបស្សនានោះ ដោយមំសចក្ខុរបស់ខ្លួនបាន ។ បទថា **បញ្ញាយ ចស្ស ទិស្វា**

**អាសវា បរិក្ខីណា ហោន្តិ** សេចក្តីថា ព្រោះឃើញអរិយសច្ច ៤ ដោយមគ្គប្បញ្ញា ទើបអាសវៈ ៤ អស់ទៅ ។ បទថា **តិណ្ណា លោកេ វិសត្តិកំ** បានដល់ ដល់នូវការរាប់យ៉ាងនេះថា **វិសត្តិកា** ព្រោះជាប់ជំពាក់នឹងផ្សាយទៅក្នុងលោក ។ ម្យ៉ាងទៀត បទថា **វិសត្តិកា** សេចក្តីថា ដែលឈ្មោះថា **វិសត្តិកា** ព្រោះអត្ថដូចម្តេច ឈ្មោះថា **វិសត្តិកា** ព្រោះអត្ថថា សោត់ទៅផ្សាយទៅ ពង្រីកបរិបូណ៌ចេញទៅ វិសាល ប្រាសចាកសមត្ថភាព នាំវត្ថុដែលជាពិសមក មានវាទៈជាពិស មានឫសជាពិស មានផ្លែជាពិស មានគ្រឿងបរិភោគជាពិស ឬថា តណ្ហានោះ ផ្សព្វផ្សាយទៅ ក្នុងរូប សំឡេង ក្លិន រស និងផ្សព្វ ព្រោះដូច្នោះ ទើបឈ្មោះថា **វិសត្តិកា** ។ បុគ្គលឆ្លង ឆ្លងចេញ ឆ្លងឡើងនូវតណ្ហា ដែលរាប់ថា **វិសត្តិកា** ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា **តិណ្ណា លោកេ វិសត្តិកំ** ដូច្នេះ ៕

**និវាបសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ចាសភាសិសូត្រទី ៦

[ ៥០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លំដាប់នោះឯង ពួកភិក្ខុច្រើនរូបចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះអានន្ទយ៉ាងនេះថា ម្នាលអានន្ទមានអាយុ យើងទាំងឡាយខានស្តាប់ធម្មីកថា ចំពោះព្រះភក្ត្រព្រះមានព្រះភាគមកយូរហើយ ម្នាលអាវុសោអានន្ទ សូមឲ្យយើងទាំងឡាយ បានស្តាប់ធម្មីកថាចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគផង ។ ព្រះអានន្ទឆ្លើយតបថា លោកមានអាយុទាំង-ឡាយ បើដូច្នោះ ចូរលោកទាំងឡាយ ចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ទើបលោកទាំងឡាយនឹងបានស្តាប់ធម្មីកថា ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ។ ភិក្ខុទាំងនោះ ក៏ទទួលពាក្យព្រះអានន្ទមានអាយុថា ករុណាអាវុសោ ។ គ្រានោះ ព្រះមានព្រះភាគ ស្តេចទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកពីបិណ្ឌបាត ធ្វើភត្តកិច្ចស្រេចហើយ ក្នុងវេលាក្រោយភត្ត ទើបត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅកាន់ប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ដើម្បីឈប់សម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះ

អង្គ ។ គ្រានោះឯង ព្រះមានព្រះភាគ ព្រមទាំងព្រះអានន្ទមានអាយុចូលទៅកាន់ប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។ លុះព្រះមានព្រះភាគ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅកាន់បន្ទប់ទឹកក្នុងទិសខាងកើតដើម្បីស្រោចស្រពកាយ ។ ព្រះអានន្ទមានអាយុក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ព្រមទាំងព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់បន្ទប់ទឹកក្នុងទិសខាងកើត ដើម្បីស្រោចស្រពកាយទាំងឡាយ លុះទ្រង់ស្រោចស្រពកាយ ក្នុងបន្ទប់ទឹកទិសខាងកើតរួចហើយ ទើបស្តេចឡើងមកទ្រង់ចីវរតែមួយ ទ្រង់បិតសំដិលព្រះកាយឲ្យស្ងួត ។ គ្រានោះ ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អាស្រមរបស់រម្មកព្រាហ្មណ៍នេះ មិនឆ្ងាយប៉ុន្មានទេ បពិត្រព្រះអង្គដ៏ចម្រើន អាស្រមរបស់រម្មកព្រាហ្មណ៍គួរជាទីត្រេកអរ បពិត្រព្រះអង្គដ៏ចម្រើន អាស្រមរបស់រម្មកព្រាហ្មណ៍គួរជាទីជ្រះថ្លា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អាស្រ័យសេចក្តីអនុគ្រោះ ចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ ទើបព្រះមានព្រះភាគ ស្តេចចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ។ គាប់ចួនសម័យនោះឯង ពួកភិក្ខុច្រើនរូបកំពុងអង្គុយប្រជុំគ្នាដោយធម្មីកថា ក្នុងអាស្រមរបស់រម្មកព្រាហ្មណ៍ ។ ទើបព្រះមានព្រះភាគ ទ្រង់បិតនៅក្បែរខ្លោងទ្វារខាងក្រៅ រង់ចាំឲ្យចប់ពាក្យ

និយាយ ។

[ ៥១ ] គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបថា ចប់ពាក្យនិយាយហើយ ក៏គ្រហែមរួចទ្រង់គោះសន្ទះទ្វារ ។ ពួកភិក្ខុទាំងនោះ ក៏បើកទ្វារថ្វាយព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ហើយគង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ បានត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំនិយាយពាក្យដូចម្តេចខ្លះ ចុះពាក្យជាចន្លោះដូចម្តេច ដែលអ្នកទាំងឡាយនិយាយគ្នាមិនទាន់ស្រេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យប្រកបដោយធម៌ ប្រារព្ធចំពោះព្រះមានព្រះភាគដែលយើងទាំងឡាយនិយាយមិនទាន់ស្រេច ស្រាប់តែព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយល្អហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំដោយធម្មីកថានុ៎ះឯងសមគួរដល់អ្នកទាំងឡាយ ជាកុលបុត្រដែលចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធាហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នាហើយ ត្រូវធ្វើកិច្ច ២ យ៉ាង គឺពាក្យប្រកបដោយធម៌ ១ ភាពជាអ្នកស្ងប់ស្ងៀមនៅដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ២ ប្រការ គឺការស្វែងរកមិនប្រសើរ ១ ការស្វែងរកប្រសើរ ១ ។

[ ៥២ ] ការស្វែងរកមិនប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយបុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ស្វែងរករបស់មានជាតិ

ជាធម្មតាថែមទៀត ខ្លួនឯងមានជរាជាធម្មតា ស្វែងរករបស់មានជរាជាធម្មតាថែមទៀត ខ្លួនឯងមានព្យាធិជាធម្មតា ស្វែងរករបស់មានព្យាធិជាធម្មតាថែមទៀត ខ្លួនឯងមានមរណៈជាធម្មតា ស្វែងរករបស់មានមរណៈជាធម្មតាថែមទៀត ខ្លួនឯងមានសេចក្តីសោកជាធម្មតា ស្វែងរករបស់មានសេចក្តីសោកជាធម្មតាថែមទៀត ខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ស្វែងរករបស់មានសេចក្តីសៅហ្មងជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីដែលមានជាតិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថា បុត្រភរិយាមានជាតិជាធម្មតា ទាសីទាសៈមានជាតិជាធម្មតា ពពែចៀមមានជាតិជាធម្មតា មាន់ជ្រូកមានជាតិជាធម្មតា ដំរីគោសេះលាឈ្មោល និងញីមានជាតិជាធម្មតា មាសប្រាក់មានជាតិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជាតិធម៌ទាំងនោះឯង ជាឧបធិ ( កិលេស ) បុគ្គលនេះមានចិត្តងោកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ ( កិលេស ) ទាំងនុ៎ះ ឈ្មោះថា ខ្លួនឯងមានជាតិជាធម្មតា ស្វែងរករបស់មានជាតិជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីដែលមានជរាជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាបុត្រភរិយាមានជរាជាធម្មតា ទាសីទាសៈមានជរាជាធម្មតា ពពែចៀមមានជរាជាធម្មតា មាន់ជ្រូកមានជរាជាធម្មតា ដំរីគោសេះ និងលាមានជរាជាធម្មតា មាសប្រាក់មានជរាជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជរាធម៌ទាំងនោះឯង ជាឧបធិ ( កិលេស ) បុគ្គលនេះមានចិត្តងោកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ ( កិលេស ) ទាំងនុ៎ះ ឈ្មោះថាខ្លួនឯងមានជរាជាធម្មតា ស្វែងររបស់មានជរាជាធម្មតាថែម

ទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីដែលមានព្យាធិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថា បុត្រភរិយាមានព្យាធិជាធម្មតា ទាសីទាសៈមានព្យាធិជាធម្មតា ពពែចៀមមានព្យាធិជាធម្មតា មាន់ជ្រូកមានព្យាធិជាធម្មតា ដំរីគោសេះលាឈ្មោល និងញីមានព្យាធិជាធម្មតា មាសប្រាក់មានព្យាធិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ព្យាធិធម៌ទាំងនោះឯង ជាឧបធិ ( កិលេស ) បុគ្គលនេះមានចិត្តជោកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ ( កិលេស ) ទាំងនុ៎ះ ឈ្មោះថាខ្លួនឯងមានព្យាធិជាធម្មតា ស្វែងរករបស់មានព្យាធិជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថា អ្វីដែលមានមរណៈជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរថាបុត្រភរិយាមានមរណៈជាធម្មតា ទាសីទាសៈមានមរណៈជាធម្មតា ពពែចៀមមានមរណៈជាធម្មតា មាន់ជ្រូកមានមរណៈជាធម្មតា ដំរីគោសេះលាឈ្មោល និងញីមានមរណៈជាធម្មតា មាសប្រាក់មានការខូចខាតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឯមរណធម៌ទាំងនោះឯង ហៅថា ឧបធិ ( កិលេស ) បុគ្គលនេះមានចិត្តជោកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ ( កិលេស ) ទាំងនុ៎ះ ឈ្មោះថាខ្លួនឯងមានមរណៈជាធម្មតា ស្វែងរករបស់មានមរណៈជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីមានសោកជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរថាបុត្រភរិយាមានសោកជាធម្មតា ទាសីទាសៈមានសោកជាធម្មតា ពពែ ចៀមមានសោកជាធម្មតា មាន់ជ្រូកមានសោកជាធម្មតា ដំរីគោសេះលាឈ្មោល និងញីមានសោកជាធម្មតា មាសប្រាក់មានសេចក្តីស្ហួតជាធម្មតា ។

ម្នាលភិក្ខុទាំងឡាយ ឯសោកធម៌ទាំងនោះឯង ហៅថា ឧបធិ ( កិលេស ) បុគ្គលនេះ មានចិត្តជោកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ ( កិលេស ) ទាំងនុ៎ះ ឈ្មោះថា ខ្លួនឯងមានសេចក្តីសោកជាធម្មតា ស្វែងរករបស់មានសេចក្តីសោកជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាអ្វីមានសេចក្តីសៅហ្មងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថាបុត្រភរិយាមានសេចក្តីសៅហ្មងជាធម្មតា ទាសីទាសៈមានសេចក្តីសៅហ្មងជាធម្មតា ពពែចៀមមានសេចក្តីសៅហ្មងជាធម្មតា មាន់ជ្រូកមានសេចក្តីសៅហ្មងជាធម្មតា ដំរីគោសេះលាឈ្មោល និងញីមានសេចក្តីសៅហ្មងជាធម្មតា មាសប្រាក់មានសេចក្តីសៅហ្មងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឯសង្កិលេសធម៌ទាំងនុ៎ះឯង ហៅថា ឧបធិ ( កិលេស ) បុគ្គលនេះ មានចិត្តជោកជ្រប់លង់ស៊ប់ទៅក្នុងឧបធិ ( កិលេស ) ទាំងនុ៎ះ ឈ្មោះថា ខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ស្វែងរករបស់មានសេចក្តីសៅហ្មងជាធម្មតាថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកមិនប្រសើរ ។

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ ឯការស្វែងរកដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានជាតិ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា ដឹងច្បាស់នូវទោសក្នុងជរាធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានជរា ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា

ដឹងច្បាស់នូវទោសក្នុងព្យាធិធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានព្យាធិ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានមរណៈជាធម្មតា ដឹងច្បាស់នូវទោសក្នុងមរណធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានមរណៈ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសោកជាធម្មតា ដឹងច្បាស់នូវទោសក្នុងសោកធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានសេចក្តីសោក ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ដឹងច្បាស់នូវទោសក្នុងសង្កិលេសធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានសង្កិលេសធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកដ៏ប្រសើរ ។

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុនអំពីកាលជាទីត្រាស់ដឹង ដែលតថាគតនៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ ខ្លួនឯងមានជាតិជាធម្មតា ស្វែងរកនូវជាតិធម៌ថែមទៀត ខ្លួនឯងមានជរាជាធម្មតា ស្វែងរកនូវជរាធម៌ថែមទៀត ខ្លួនឯងមានព្យាធិជាធម្មតា ស្វែងរកនូវព្យាធិធម៌ថែមទៀត ខ្លួនឯងមានមរណៈជាធម្មតា ស្វែងរកនូវមរណធម៌ថែមទៀត ខ្លួនឯងមានសោកជាធម្មតា ស្វែងរកនូវសោកធម៌ថែមទៀត ខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ស្វែងរកនូវសេចក្តីសៅហ្មងថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា ខ្លួនឯងមានជាតិជាធម្មតា ហេតុដូចម្តេចបានជាអាត្មាអញស្វែងរកធម៌មានជាតិជាធម្មតាថែមទៀត ខ្លួនឯងមានជរាជាធម្មតា ... មាន

ព្យាធិជាធម្មតា ... មានមរណៈជាធម្មតា ... មានសោកជាធម្មតា ... ខ្លួនឯង មានសេចក្តីសៅហ្មងជាធម្មតា ស្វែងរកធម៌មានសេចក្តីសៅហ្មងជាធម្មតាថែម ទៀត បើដូច្នោះ គួរតែអាត្មាអញដែលខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវ ទោសក្នុងជាតិធម៌ ហើយគប្បីស្វែងរកព្រះនិព្វានដែលមិនមានជាតិធម៌ ឥត មានគុណជាតិដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា ដឹង ច្បាស់នូវទោសក្នុងជរាធម៌ ហើយគប្បីស្វែងរកព្រះនិព្វានដែលឥតមានជរាធម៌ មិនមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា ដឹងច្បាស់នូវទោសក្នុងព្យាធិធម៌ ហើយគប្បីស្វែងរកព្រះនិព្វាន ដែលមិនមាន ព្យាធិធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានមរណៈ ជាធម្មតា ដឹងច្បាស់នូវទោសក្នុងមរណធម៌ ហើយគប្បីស្វែងរកព្រះនិព្វាន ដែលមិនមានមរណធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានសោកជាធម្មតា ដឹងច្បាស់នូវទោសក្នុងសោកធម៌ហើយគប្បីស្វែង រកព្រះនិព្វាន ដែលមិនមានសោកធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេម ចាកយោគៈ ខ្លួនឯងមានសេចក្តីសៅហ្មងជាធម្មតា ដឹងច្បាស់នូវទោស ក្នុង សង្កិលេសធម៌ ហើយគប្បីស្វែងរកព្រះនិព្វានដែលឥតមានសង្កិលេសធម៌ ឥត មានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈវិញ ។

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ លុះសម័យតមក តថាគតនោះឯងនៅ ក្មេង មានសក់ខ្មៅស្និទ្ធល្អ កំពុងប្រកបដោយបឋមវ័យដ៏ចម្រើន កាលដែល មាតាបិតាមិនចង់ ( ឲ្យចេញបួស ) មានព្រះភក្ត្រទទឹកជោកដោយទឹកព្រះ

នេត្រ កំពុងទ្រង់ព្រះកន្សែង ( តថាគត ) ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកគេហដ្ឋានទៅកាន់ផ្នួស លុះតថាគត នោះបួសយ៉ាងនេះហើយ ក៏ស្វែងរកកិកុសល ( សេចក្តីពិតថាអ្វីជាកុសល ) កាលស្វែងរកនូវសន្តិវរបទ គឺព្រះនិព្វាន ដែលជាគុណជាតដ៏ប្រសើរ ក៏បាន ចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ បាននិយាយ នឹងអាឡារតាបសកាលាមគោត្រ យ៉ាងនេះថា ម្នាលអាវុសោកាលាមៈ ខ្ញុំ ចង់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ តថាគតនិយាយយ៉ាងនេះហើយ អាឡារតាបសកាលាមគោត្រ ក៏បាននិយាយ នឹងតថាគតយ៉ាងនេះថា អ្នកមានអាយុ ចូរនៅចុះ នេះធម៌ ប្រាកដដូចជាអ្នក ត្រូវការនោះ ជាធម៌សម្រាប់វិញ្ញូជន ធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យដោយ ប្រាជ្ញារបស់ខ្លួនពុំយូរឡើយ ក៏នឹងបានសម្រេច ។ ម្នាលភិក្ខុទាំងឡាយ តថាគត នោះឯងក៏បានរៀនធម៌នោះចប់មួយរំពេច មិនយូរឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯងពោលនូវញាណវាទផង ដឹងច្បាស់នូវថេរវាទ ( ពាក្យខ្ជាប់ ខ្ជួន ) ផង ប្តេជ្ញាថាតថាគតបានឃើញដូច្នេះផង ដោយគ្រាន់តែអាឡារតាបស បង្អើបមាត់ និងដោយគ្រាន់តែអាឡារតាបសពោលពាក្យចប់ប៉ុណ្ណោះ មិន មែនតែតថាគតប៉ុណ្ណោះទេ សូម្បីជនឯទៀត ( ក៏គេនិយាយយ៉ាងនេះដែរ ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាឡារតាបស កាលាមគោត្រ មិនប្រកាសថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួនឯង ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ តាមពិតអាឡារ-

តាបសកាលាមគោត្រ គ្រាន់តែជាអ្នកយល់ឃើញនូវធម៌នេះ ( ប៉ុណ្ណោះ ) ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតបានចូលទៅរកអាឡារតាបសកាលាមគោត្រ លុះចូលទៅដល់ហើយ បានសួរអាឡារតាបសកាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ អ្នកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ថ្លៃថ្លាខ្លួនឯង ហើយបានសម្រេចប្រកាសទុក ដោយហេតុដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតសួរយ៉ាងនេះហើយ អាឡារ-តាបសកាលាមគោត្រ ក៏ប្រកាសប្រាប់នូវអាកិញ្ចញ្ញាយតនសមាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាឡារតាបសកាលាមគោត្រ មិនមានសទ្ធាទេ អាត្មាអញទើបមានសទ្ធា អាឡារតាបសកាលាមគោត្រ មិនមានព្យាយាមទេ អាត្មាអញទើបមានព្យាយាម អាឡារ-តាបស កាលាមគោត្រ មិនមានសតិទេ អាត្មាអញទើបមានសតិ អាឡារ-តាបស កាលាមគោត្រ មិនមានសមាធិទេ អាត្មាអញទើបមានសមាធិ អាឡារតាបស កាលាមគោត្រ មិនមានបញ្ញាទេ អាត្មាអញទើបមានបញ្ញា បើដូច្នោះ គួរតែអាត្មាអញប្រឹងប្រែង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលអាឡារតាបសកាលាមគោត្រ ប្រកាសទុកថា អាត្មាអញបានសម្រេចហើយ ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌ដោយប្រាជ្ញាដ៏ថ្លៃថ្លាខ្លួនឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះក៏បានសម្រេចព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ មួយរំពេចពុំយូរឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតចូលទៅរកអាឡារ-តាបស កាលាមគោត្រ ( ទៀត ) លុះចូលទៅដល់ហើយ ទើបសួរអាឡារ-

តាបសកាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ អ្នកបានសម្រេចហើយ ព្រោះបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួន ហើយប្រកាសទុកដោយហេតុតែប៉ុណ្ណេះឬ ។ អាឡារតាបស កាលាមគោត្រតបថា ម្នាលអាវុសោ ខ្ញុំបានសម្រេចព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ហើយប្រកាសទុក ដោយហេតុតែប៉ុណ្ណេះឯង ។ តថាគតសួរទៀតថា ម្នាលអាវុសោកាលាមៈ ខ្ញុំឯងបានសម្រេចព្រោះបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួន ដោយហេតុប៉ុណ្ណេះដែរ ។ អាឡារតាបសកាលាមគោត្រតបថា ម្នាលអាវុសោ យើងពេញជាមានលាភហើយ ម្នាលអាវុសោ អត្តភាពជាមនុស្ស យើងពេញជាបានល្អហើយ ត្រង់ដែលយើងបានឃើញសព្រហ្មចារីបុគ្គល ប្រាកដដូចជាអ្នកមានអាយុ ព្រោះថាខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន ទាំងបានសម្រេចនូវធម៌ណាហើយប្រកាសទុក អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួន ទាំងបានសម្រេចនូវធម៌នោះ ហើយនៅដោយឥរិយាបថ ៤ ដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួន ទាំងបានសម្រេចនូវធម៌ណាហើយនៅដោយឥរិយាបថ ៤ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួនឯង ទាំងបានសម្រេចនូវធម៌នោះ ហើយប្រកាសទុកដែរ ព្រោះខ្ញុំចេះធម៌ណា អ្នកក៏ចេះធម៌នោះ អ្នកចេះធម៌ណា ខ្ញុំក៏ចេះធម៌នោះ ខ្ញុំប្រាកដយ៉ាងណា អ្នកក៏ប្រាកដយ៉ាងនោះ អ្នកប្រាកដយ៉ាងណា ខ្ញុំក៏ប្រាកដយ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ អ្នកចូរមក យើងទាំងពីរនាក់នឹងនៅគ្រប់គ្រង

គណៈនេះ ។ ម្នាលភិក្ខុទាំងឡាយ អាឡារតាបសកាលាមគោត្រ ជាអាចារ្យរបស់តថាគត តាំងតថាគតជាកូនសិស្សស្មើៗ នឹងខ្លួន ទាំងបូជាតថាគតដោយការបូជាដ៏លើសលុប ដោយហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌ ( គឺសមាបត្តិទាំង ៧ ) នេះ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយចាកកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរម្ងត់នូវរាគាទិក្កិលេស មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីដឹងដោយក្រៃលែង មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងត់ទុក្ខទេ ប្រព្រឹត្តទៅបានតែត្រឹមកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតនោះឯង មិនឱបក្រសោបធម៌នោះឡើយ នឿយណាយហើយដោះចេញអំពីធម៌នោះ ។

[ ៥៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតនោះជាអ្នកស្វែងរកកុសលកំពុងស្វែងរកនូវសន្តិវរបទ ក៏បានចូលទៅរកឧទ្ទកតាបសរាមបុត្រ លុះចូលទៅដល់ហើយ បាននិយាយនឹងឧទ្ទករាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ ខ្ញុំចង់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតនិយាយយ៉ាងនេះហើយ ឧទ្ទករាមបុត្របាននិយាយនឹងតថាគតយ៉ាងនេះថា អ្នកមានអាយុចូរនៅចុះ នេះធម៌ប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌សម្រាប់វិញ្ញូបុរស ធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួនហើយ បានសម្រេចមិនយូរឡើយ ។ ម្នាលភិក្ខុទាំងឡាយ

តថាគតនោះឯង បានរៀននូវធម៌នោះចប់ភ្លាមមិនយូរឡើយ ម្នាលភិក្ខុទាំង-ឡាយ តថាគតនោះឯងពោលនូវញាណវាទផង ដឹងច្បាស់នូវថេរវាទផង ប្តេជ្ញាថា តថាគតបានឃើញដូច្នេះផង ដោយគ្រាន់តែឧទ្ទករាមបុត្របង្អើបបបូរមាត់ និងដោយគ្រាន់តែឧទ្ទករាមបុត្រ ពោលពាក្យចប់ប៉ុណ្ណោះ មិនមែនតែតថាគតប៉ុណ្ណោះទេ ទាំងពួកជនឯទៀត ( ក៏និយាយយ៉ាងនេះដែរ ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឧទ្ទករាមបុត្រមិនប្រកាសថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ នូវធម៌នេះដោយប្រាជ្ញាដ៏ថ្លៃថ្លាខ្លួនឯង ដោយគ្រាន់តែសទ្ធាប៉ុណ្ណោះ តាមពិត ឧទ្ទករាមបុត្រគ្រាន់តែបានដឹងបានឃើញធម៌នេះប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតក៏បានចូលទៅរកឧទ្ទករាមបុត្រ លុះចូលទៅដល់ហើយ បានសួរឧទ្ទករាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ អ្នកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន បានសម្រេចហើយប្រកាសទុក ដោយហេតុដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតសួរយ៉ាងនេះហើយ ឧទ្ទករាមបុត្រ ក៏ប្រកាសនូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឧទ្ទករាមបុត្រមិនមានសទ្ធាទេ អាត្មាអញទើបមានសទ្ធា ឧទ្ទករាមបុត្រ មិនមានព្យាយាមទេ ។បេ។ សតិ ... សមាធិ ... បញ្ញាទេ អាត្មាអញទើបមានបញ្ញា បើដូច្នោះ គួរតែអាត្មាអញប្រឹងប្រែងដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដែលឧទ្ទករាមបុត្រប្រកាសទុកថា អាត្មាអញបានសម្រេចហើយ ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន

ឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ក៏បានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះភ្លាម ពុំយូរឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតចូលទៅរកឧទ្ទករាមបុត្រ ( ទៀត ) លុះចូលទៅដល់ហើយ បានសួរឧទ្ទករាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ អ្នកបានសម្រេច ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយប្រាជ្ញារបស់ខ្លួន ហើយប្រកាសទុកដោយហេតុតែប៉ុណ្ណេះទេឬ ។ ឧទ្ទករាមបុត្រតបថា ម្នាលអាវុសោ ខ្ញុំបានសម្រេច ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញារបស់ខ្លួនឯង ហើយប្រកាសទុក ដោយហេតុតែប៉ុណ្ណេះទេ ។ តថាគតក៏និយាយថា ម្នាលអាវុសោរាមៈ ខ្ញុំឯងបានសម្រេចព្រោះធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ថ្លៃថ្លាខ្លួនឯង ចំពោះធម៌នេះ ដោយហេតុប៉ុណ្ណេះដែរ ។ ឧទ្ទករាមបុត្រតបថា ម្នាលអាវុសោ យើងពេញជាមានលាភហើយ អត្តភាពជាមនុស្ស យើងពេញជាបានល្អហើយ ត្រង់ដែលយើងបានឃើញសព្រហ្មចារីបុគ្គល ប្រាកដដូចអ្នកមានអាយុ ព្រោះថា រាមៈបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ថ្លៃថ្លាចំពោះខ្លួន បានសម្រេចធម៌ណា ហើយប្រកាសទុក អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន បានសម្រេចធម៌នោះ ហើយនៅដោយឥរិយាបថទាំង ៤ ដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន ហើយបានសម្រេចធម៌ណា រាមៈក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ថ្លៃថ្លារបស់ខ្លួន បានសម្រេចធម៌នោះ ហើយប្រកាសទុកដែរ រាមៈបានដឹងធម៌ណា អ្នកក៏បានដឹងធម៌នោះ អ្នកចេះធម៌ណា រាមៈក៏ចេះធម៌នោះដែរ មួយទៀត រាមៈប្រាកដយ៉ាងណា អ្នកក៏ប្រាកដយ៉ាងនោះ អ្នកប្រាកដ

យ៉ាងណា រាមៈក៏ប្រាកដយ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ ចូរអ្នកមក ចូរអ្នកនៅគ្រប់គ្រងគណៈនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ឧទ្ទករាមបុត្រជាសព្រហ្មចារីរបស់តថាគត តាំងតថាគតក្នុងទីជាអាចារ្យ ទាំងបូជាតថាគតដោយការបូជាដ៏លើសលុបដោយហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌គឺសមាបត្តិទាំង ៨ នេះ មិនប្រព្រឹត្តទៅដើម្បីនឿយណាយចាកកិលេសវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរម្ងត់នូវរាគាទិក្កិលេស មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងដោយក្រៃលែង មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងត់ទុក្ខទេ ប្រព្រឹត្តទៅបានត្រឹមតែចូលទៅកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯងក៏មិនឱបក្រសោបធម៌នោះឡើយ នឿយណាយហើយដោះចេញអំពីធម៌នោះ ។

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯង ជាអ្នកស្វែងរកកឹកុសល កំពុងស្វែងសន្តិវរបទ ក៏បានត្រាច់ទៅកាន់ចារិក ក្នុងដែនមគធៈតាមលំដាប់លំដោយ សំដៅទៅរកឧរុវេលាសេនានិគម ។ ក្នុងទីនោះ តថាគតបានឃើញផ្ទៃផែនដី គួរឲ្យត្រេកអរ ដងព្រៃគួរឲ្យកើតជ្រះថ្លាផង ស្ទឹងមានទឹកថ្លាស្អាតហូរ ( មិនដាច់ ) មានកំពង់រាបស្មើល្អ គួរជាទីត្រេកអរផង ទាំងគោចរគ្រាម ( ស្រុកសម្រាប់បិណ្ឌបាត ) ក៏មាននៅជិតផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ភូមិភាគនេះគួរឲ្យត្រេកអរផង ដងព្រៃគួរ

ឲ្យកើតជ្រះថ្លាផង ស្ទឹងមានទឹកថ្លាស្អាតហូរមិនដាច់ មានកំពង់រាបស្មើល្អ គួរជាទីត្រេកអរផង គោចរគ្រាមក៏មាននៅជិតផង ទីនេះល្មមកុលបុត្រអ្នកត្រូវការដោយសេចក្តីព្យាយាម តាំងសេចក្តីព្យាយាមបានហើយតើ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតនោះឯង បានអង្គុយក្នុងទីនោះ ដោយគិតថា ទីនេះល្មមនឹងតាំងសេចក្តីព្យាយាមបាន ។

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនោះឯងមានជាតិជាធម្មតាដោយខ្លួនឯង ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកនូវព្រះនិព្វានដែលមិនមានជាតិ មិនមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ ក៏បានដល់នូវព្រះនិព្វានដែលមិនមានជាតិ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ មានជរាជាធម្មតាដោយខ្លួនឯង ... មានព្យាធិជាធម្មតាដោយខ្លួនឯង ... មានមរណៈជាធម្មតាដោយខ្លួនឯង ... មានសោកជាធម្មតាដោយខ្លួនឯង ... មានសេចក្តីសៅហ្មងជាធម្មតាដោយខ្លួនឯង ឃើញទោសក្នុងសង្កិលេសធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានសង្កិលេសធម៌ ឥតមានគុណជាតដទៃស្មើ ជាទីក្សេមចាកយោគៈ បានដល់នូវព្រះនិព្វានដែលមិនមានសេចក្តីសៅហ្មង ជាទីក្សេមចាកយោគៈដ៏ប្រសើរបំផុត ទាំងញាណជាគ្រឿងឃើញគឺសព្វញ្ញុតញ្ញាណក៏កើតឡើងដល់តថាគតថា វិមុត្តិរបស់តថាគតមិនរំកើប ( ដោយរាគាទិក្កិ-លេស ) នេះជាតិជាទីបំផុត ( របស់តថាគត ) ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះ

ថា ចតុរារិយសច្ចធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ជ្រាល ជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់ ជាធម៌ឧត្តម ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ឯពួកសត្វនេះ សុទ្ធតែកំពុងរីករាយក្នុងអាល័យ គឺតណ្ហា ១០៨ កំពុងត្រេកត្រអាលក្នុងអាល័យ កំពុងស្រើបស្រាលក្នុងអាល័យ ( ទៅរកកាមទាំងឡាយនៅឡើយ ) ក៏បដិច្ច-សមុប្បាទធម៌ ដែលជាបច្ច័យនៃធម៌មានសង្ខារជាដើមនេះ ជាហេតុដែលសត្វនៅរីករាយក្នុងអាល័យ នៅត្រេកត្រអាលក្នុងអាល័យ នៅស្រើបស្រាលក្នុងអាល័យ ឃើញបានដោយកម្រ មួយទៀត ធម៌ណារម្ងាប់នូវសង្ខារទាំងពួងជាគ្រឿងលះបង់នូវឧបធិ គឺខន្ធ និងកិលេសទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរលត់ទុក្ខ គឺព្រះនិព្វាន ធម៌នេះជាហេតុដែលសត្វឃើញបានដោយកម្រដែរ បើទុកជាតថាគតសម្តែងធម៌ទៅ ក៏ពួកសត្វដទៃមិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះសេចក្តីលំបាក សេចក្តីនឿយព្រួយ មុខជានឹងមានដល់តថាគតមិនខាន ។ មួយទៀត គាថាទាំងឡាយ ដែលមិនជាអស្ចារ្យណាស់ណានេះ តថាគតមិនដែលបានឮមកក្នុងកាលមុនឡើយ ក៏ភ្លឺស្វាងដល់តថាគតថា

ឥឡូវនេះ តថាគតមិនគួរសម្តែងធម៌ ដែលតថាគតបាន
ត្រាស់ដឹងដោយលំបាក ( នោះទេ ) ព្រោះពួកសត្វដែល
មានរាគៈ ទោសៈគ្របសង្កត់ មិនងាយនឹងត្រាស់ដឹងធម៌

នេះបានឡើយ ពួកសត្វដែលកំពុងត្រេកអរដោយរាគៈ ដែល
គំនរងងឹត គឺអវិជ្ជាគ្របសង្កត់ហើយ មុខជានឹងមិនឃើញ
ធម៌ដែលនាំសត្វឲ្យដល់ព្រះនិព្វាន ជាធម៌ល្អិតឆ្មារ ជ្រាល
ជ្រៅ សត្វឃើញបានដោយកម្រនោះទេ ។

ម្នាលភិក្ខុទាំងឡាយ កាលតថាគតពិចារណាឃើញដោយន័យដូច្នេះហើយ ចិត្តក៏ឱនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសម្តែងធម៌ឡើយ ។

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្មបានដឹងនូវបរិវិតក្កក្នុងចិត្តរបស់តថាគតដោយចិត្ត ( របស់ខ្លួន ) ហើយទើបរំពឹងដូច្នេះថា ឱ សត្វលោកនឹងវិនាសហើយតើហ្ន៎ ឱ សត្វលោកនឹងវិនាសហើយតើហ្ន៎ ព្រោះព្រះហឫទ័យរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសម្តែងធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្មក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ដូចជាបុរសដែលមានកម្លាំង លាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះមករកតថាគត ពោលនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ សូមព្រះសុគតទ្រង់សម្តែងធម៌ ព្រោះពួកសត្វដែលមានធូលី គឺរាគាទិក្កិលេសដ៏ស្រាលស្តើងក្នុងភ្នែក គឺបញ្ញាគង់មាន ព្រោះហេតុតែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យមិនខាន ពួកសត្វដែលយល់ធម៌ ក៏គង់មានដែរ ។

ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃ តទៅទៀតថា

ពីមុនរៀងមក ធម៌ដែលពួកជនអ្នកប្រកបដោយមន្ទិលបាន
គិតហើយ ជាធម៌មិនបរិសុទ្ធ ក៏កើតប្រាកដហើយក្នុងដែន
មគធៈ សូមព្រះអង្គបើកទ្វារនៃព្រះនិព្វានទុំះ ពួកសត្វប្រុង
ចាំស្តាប់ធម៌ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិល ទ្រង់ត្រាស់
ដឹងតាម ( លំអានព្រះពុទ្ធអំពីបុរាណ ) ដូចជាបុរសឈរ
លើកំពូលភ្នំថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជន ដោយជុំ
វិញខ្លួន យ៉ាងណាមិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ
មានបញ្ញាចក្ខុជុំវិញ ព្រះអង្គជាអ្នកមានសេចក្តីសោកសៅ
ទៅប្រាសហើយ ស្តេចឡើងកាន់ប្រាសាទ គឺធម៌ដែលមាន
ឧបមាយ៉ាងនោះ ពិចារណាមើលនូវប្រជុំជន អ្នកប្រឡូំ
ដោយសេចក្តីសោក ដែលជាតិជរាកំពុងគ្របសង្កត់ បពិត្រ
ព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះនូវសង្គ្រាម ហើយជា
នាយកនៃពួកសត្វ អ្នកមិនចំពាក់បំណុល គឺកាម សូម
ព្រះអង្គក្រោកឡើង សូមស្តេចទៅក្នុងលោក សូមព្រះ
មានព្រះភាគទ្រង់សម្តែងធម៌ ដ្បិតពួកសត្វអ្នកបម្រុងនឹង
ត្រាស់ដឹងធម៌ ក៏គង់មានដែរ ។

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះ តថាគតដឹងច្បាស់នូវសេចក្តី

អារាធនារបស់សហម្បតិព្រហ្មផង អាស្រ័យសេចក្ដីករុណាចំពោះពួកសត្វផង ទើបប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគត កំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក ( ខ្លះ ) មានធូលីច្រើនក្នុងភ្នែក ( ខ្លះ ) មានឥន្ទ្រិយក្លៀវក្លា ( ខ្លះ ) មានឥន្ទ្រិយទន់ ( ខ្លះ ) មានអាការល្អ ( ខ្លះ ) មានអាការអាក្រក់ ( ខ្លះ ) ជាសត្វដែលតថាគតគួរឲ្យត្រាស់ដឹងបានដោយងាយ ( ខ្លះ ) ឲ្យត្រាស់ដឹងបានដោយកម្រ ( ខ្លះ ) ជាអ្នកឃើញនូវទោស និងភ័យក្នុងលោកខាងមុខខ្លះ ។ ដូចជាផ្កាជលជាតិពួកខ្លះ គឺព្រលឹតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ក្នុងគុម្ពព្រលឹតក្ដី ក្នុងគុម្ពឈូកក្រហមក្ដី ក្នុងគុម្ពឈូកសក្ដី ដុះក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតឡើងតាមទឹក លិចនៅក្នុងទឹក ដែលទឹកកំពុងចិញ្ចឹមនៅឡើយ មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលឹតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ដុះក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតឡើងតាមទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលឹតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ដុះក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះខ្ពស់ឡើងផុតទឹក មិនជាប់ដោយទឹក មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលតថាគតប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក ( ខ្លះ ) មានធូលីច្រើនក្នុងភ្នែក ( ខ្លះ ) មានឥន្ទ្រិយក្លៀវក្លា ( ខ្លះ ) មានឥន្ទ្រិយទន់ ( ខ្លះ ) មានអាការល្អ ( ខ្លះ ) មានអាការអាក្រក់ ( ខ្លះ ) ជាសត្វដែលតថាគតគួរឲ្យត្រាស់ដឹងបានដោយ

ងាយ ( ខ្លះ ) ឲ្យត្រាស់ដឹងបានដោយកម្រ ( ខ្លះ ) ជាអ្នកឃើញនូវទោស និងភ័យក្នុងលោកខាងមុខខ្លះ មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ តថាគតបានពោលតបនឹងសហម្បតិព្រហ្ម ដោយគាថាថា

ទ្វារនៃព្រះនិព្វានទាំងនោះ តថាគតបានបើកហើយ ពួក
សត្វណា មានសោតប្រសាទ ពួកសត្វទាំងនោះ ចូរបញ្ចេញ
សទ្ធាចុះ ម្នាលព្រហ្ម តថាគតមានសេចក្តីសម្គាល់ក្នុងការ
នាំឲ្យលំបាកកាយ និងវាចា បានជាមិនសម្តែងធម៌ដ៏ឧត្តម
ដែលតថាគតស្ទាត់ហើយ ក្នុងពួកមនុស្សទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ សហម្បតិព្រហ្មគិតថា ខ្ញុំអញជាបុគ្គល ដែលព្រះមានព្រះភាគ ទ្រង់ទទួលព្រមនឹងសម្តែងធម៌ហើយ ( លុះគិតដូច្នេះ ហើយ ) ក៏ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណបាត់អំពីទីនោះទៅ ។

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះ ថា អាត្មាអញគួរសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះ ឆាប់រហ័សបានហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះ យ៉ាងនេះទៀតថា អាឡារតាបសកាលាមគោត្រនេះជាបណ្ឌិត ជាអ្នកឈ្លាសវៃ មានប្រាជ្ញា មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកស្រោបមកយូរហើយ បើ ដូច្នោះ គួរតថាគតសម្តែងធម៌ប្រោសអាឡារតាបសកាលាមគោត្រ ជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រា នោះ មានទេវតាអង្គមួយ ចូលមករកតថាគត ហើយនិយាយយ៉ាងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន អាឡារតាបសកាលាមគោត្រ ធ្វើកាលកិរិយា ៧ ថ្ងៃហើយ ។ ចំណែកខាងញាណទស្សនៈរបស់តថាគតក៏កើតឡើងថា អាឡារ-តាបសកាលាមគោត្រធ្វើកាលកិរិយា ៧ ថ្ងៃហើយមែន ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាឡារតាបសកាលាម-គោត្រនេះ ជាបុគ្គលមានសេចក្តីវិនាសធំ ព្រោះថា បើគាត់បានស្តាប់ធម៌នេះ សមជាត្រាស់ដឹងមួយរំពេចបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងសម្តែងធម៌ដល់អ្នកណាជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបានអេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា ឧទ្ទកតាបសរាមបុត្រនេះឯង ជាបណ្ឌិត ជាអ្នកឈ្លាសវៃ មានប្រាជ្ញា មានធូលីតិចក្នុងភ្នែកស្រាប់យូរមកហើយ បើដូច្នោះគួរតថាគតសម្តែងធម៌ប្រោសឧទ្ទកតាបសរាមបុត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មានទេវតាអង្គមួយ ចូលមករកតថាគតហើយនិយាយយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយា អំពីពេលពាក់កណ្តាលអធ្រាត្រហើយ ។ ឯញាណទស្សនៈរបស់តថាគត ក៏កើតឡើងថា ឧទ្ទកតា-បសរាមបុត្រ ធ្វើកាលកិរិយាអំពីពេលពាក់កណ្តាលអធ្រាត្រទៅហើយមែន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឧទ្ទកតាបស-រាមបុត្រនេះ ជាបុគ្គលមានសេចក្តីវិនាសធំ ព្រោះថាបើគាត់បានស្តាប់ធម៌នេះ សមជាត្រាស់ដឹងមួយរំពេចបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមាន

សេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញគួរសម្តែងធម៌ ប្រោសអ្នកណាជាមុនហ្ន៎ អ្នកណា នឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបានហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា បញ្ចវគ្គិយភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់តថាគត ព្រោះបានបម្រើតថាគតដែលកំពុងបញ្ជូនចិត្តទៅកាន់ព្យាយាម បើដូច្នោះ គួរតថាគតសម្តែងធម៌ប្រោសបញ្ចវគ្គិយភិក្ខុ ជាមុនចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយ នៅឯណាហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកបញ្ចវគ្គិយភិក្ខុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធ ស្អាតកន្លងលើសចក្ខុរបស់មនុស្សសាមញ្ញ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតសម្រេចឥរិយាបថក្នុងឧរុវេលាប្រទេស តាមសមគួរដល់អធ្យាស្រ័យ ហើយចៀសចេញទៅកាន់ចារិកក្នុងក្រុងពារាណសី ។

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ មានអាជីវកម្នាក់ឈ្មោះឧបកៈ បានឃើញតថាគតកំពុងដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះគយាប្រទេស និងចន្លោះនៃពោធិ-ព្រឹក្ស លុះឃើញហើយក៏និយាយនឹងតថាគតយ៉ាងនេះថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវិវណ្ណក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌នោះរបស់គ្រូណា ។ ម្នាលភិក្ខុទាំងឡាយ កាលបើឧបកាជីវកសួរយ៉ាងនេះហើយ តថាគតក៏ឆ្លើយតបដោយពាក្យជាគាថាទៅរកឧបកាជីវកថា

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹង

នូវចតុត្ថភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះ ព្រោះអស់ទៅនៃតណ្ហាហើយ ដឹងច្បាស់ចតុត្ថភូមិកធម៌ដោយខ្លួនឯង ចាំបាច់ចំពោះគ្រូណា តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលស្មើនឹងតថាគតទេក្នុងលោកនេះ ព្រមទាំងទេវលោក ក៏មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះថាតថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ឥឡូវតថាគត ទៅកាន់ក្រុងនៃពួកជនអ្នកកាសីដើម្បីនឹងសម្តែងធម្មចក្ក ( ដោយបំណងថា ) តថាគតនឹងវាយស្គរជ័យនៃអមតនិព្វាន ចំពោះសត្វលោកដែលងងឹត គឺអវិជ្ជាកំពុងគ្របសង្កត់ ។

ឧបកាជីវកតបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួន យ៉ាងណា អ្នកគួរ ( ដើម្បីបាននូវឈ្មោះ ) ថា អនន្តជិនៈ ( យ៉ាងនោះឯង ) ។ តថាគតក៏ពោលគាថាដូច្នេះទៀតថា

ជនទាំងឡាយណា បានដល់នូវធម៌ សម្រាប់ធ្វើអាសវៈឲ្យអស់ទៅ ជនទាំងឡាយនោះ ឈ្មោះថា ជិនៈ ( អ្នកឈ្នះកិលេស ) ប្រាកដដូចជាតថាគតដែរ តថាគតបាន

ឈ្មោះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុ
នោះ ទើបតថាគតបានឈ្មោះថា ជិនៈ ។

ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតពោលយ៉ាងនេះហើយ ឧបកាជីវក នោះ ក៏និយាយថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹងពិតមែនហើយ ( ថាហើយ ) ក៏ងក់ក្បាល កាន់យកផ្លូវខុសគ្នា គឺដើរបែកគ្នាចៀសចេញទៅ ។

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតត្រាច់ទៅកាន់ទីចារិកតាមលំដាប់ ចូលទៅរកបញ្ចវគ្គិយភិក្ខុឯឥសិបតនមិគទាយវ័នទៀបក្រុងពារាណសី។ ម្នាលភិក្ខុទាំងឡាយ ពួកបញ្ចវគ្គិយភិក្ខុបានឃើញតថាគតដើរមកអំពីចម្ងាយ លុះឃើញហើយក៏ប្រេដ្ឋាគ្នាថា នេះហើយសមណគោតម ជាអ្នកល្មោភច្រើន ឃ្លាតចាកព្យាយាម វិលត្រឡប់មកដើម្បីភាពជាអ្នកល្មោភច្រើន កំពុងតែដើរមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលបាត្រ និងចីវររបស់លោកទេ ប៉ុន្តែពួកយើងគួរក្រាលអាសនៈបម្រុងទុក បើលោកនឹងចង់គង់ក៏គង់ចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតចូលទៅដោយប្រការយ៉ាងណា ។ ពួកបញ្ចវគ្គិយភិក្ខុក៏មិនអាចនឹងឋិតនៅក្នុងពាក្យប្រេដ្ឋារបស់ខ្លួន ដោយប្រការយ៉ាងនោះៗ បានឡើយ ខ្លះក៏ក្រោកទទួលតថាគតហើយទទួលបាត្រចីវរ ខ្លះក្រាលអាសនៈ ខ្លះតម្កល់ទឹកសម្រាប់លាងជើង ប៉ុន្តែ ហៅតថាគតចំឈ្មោះខ្លះ ដោយពាក្យថា អាវុសោខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានពោលពាក្យនេះ នឹងពួកបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំហៅតថាគតចំឈ្មោះ ទាំងកុំហៅអាវុសោ

ទ្បើយ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ តថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយកាលបើបានប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតបានពោលយ៉ាងនេះហើយ ពួកបញ្ចវគ្គិយភិក្ខុបាននិយាយនឹងតថាគតយ៉ាងនេះថា ម្នាលអាវុសោគោតម សូម្បីដោយសេចក្តីព្យាយាមនោះ ដោយសេចក្តីប្រតិបត្តិនោះ ដោយទុក្ករកិរិយា ( ដែលបានធ្វើរួចមកហើយ ) នោះ ម្តេចគង់លោកមិនបានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈដ៏អាចធ្វើខ្លួនឲ្យជាអរិយៈ ក្រៃលែងជាងមនុស្សធម៌ ចំណាង់បើឥឡូវនេះ លោកប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើនហើយ នឹងត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ លុះពួកបញ្ចវគ្គិយភិក្ខុនិយាយយ៉ាងនេះហើយ ទើបតថាគតពោលនឹងពួកបញ្ចវគ្គិយភិក្ខុយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់មកដើម្បីល្មោភ

ច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានឋានៈជាអរហន្តសម្មាសម្ពុទ្ធ ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្រសាទចុះ តថាគត នឹងប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគតត្រាស់ដឹងហើយ តថាគតនឹង សម្តែងធម៌ ក៏កុលបុត្រទាំងឡាយចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ដោយ ប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបាន ប្រតិបត្តិ គួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងធ្វើ ឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទី បំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាល ភិក្ខុទាំងឡាយ ពួកបញ្ចវគ្គិយភិក្ខុនៅតែនិយាយនឹងតថាគតជាគម្រប់ពីរដង ទៀតយ៉ាងនេះថា ម្នាលអាវុសោគោតម សូម្បីដោយសេចក្តីព្យាយាមនោះ ដោយបដិបទានោះ ដោយទុក្ករកិរិយានោះ ម្តេចគង់លោកមិនបានត្រាស់ដឹង នូវគុណវិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាង មនុស្សធម៌ ចំណង់បើឥឡូវនេះ លោកប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាត ចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើនហើយ នឹងបានត្រាស់ ដឹងគុណវិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាង មនុស្សធម៌ ដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានពោលនឹងពួក បញ្ចវគ្គិយភិក្ខុ ជាគម្រប់ពីរដងទៀតយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគត មិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ ។បេ។ នឹងសម្រេចសម្រាន្តនៅដោយ ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកបញ្ចវគ្គិយភិក្ខុបាននិយាយនឹង

តថាគតជាគម្រប់បីដងទៀតយ៉ាងនេះថា ម្នាលអាវុសោគោតម សូម្បីដោយព្យាយាមនោះ ដោយបដិបទានោះ ដោយទុក្ករកិរិយានោះ ម្ដេចលោកមិនបានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ ចំណង់បើឥឡូវនេះ លោកប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើនហើយ នឹងបានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដូចម្ដេចបាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកបញ្ចវគ្គិយភិក្ខុនិយាយយ៉ាងនេះហើយ តថាគតបានពោលនឹងពួកបញ្ចវគ្គិយភិក្ខុយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្លាប់ឮពាក្យនេះដែលតថាគតនិយាយយ៉ាងនេះ ក្នុងកាលមុនអំពីកាលឥឡូវនេះដែរឬទេ ។ ពួកបញ្ចវគ្គិយភិក្ខុតបថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនធ្លាប់ឮពាក្យនុ៎ះទេ ។ តថាគតក៏និយាយថែមទៀតថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនជាអ្នកល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់មកដើម្បីល្មោភច្រើនទេ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្ដែងធម៌ ក៏កុលបុត្រទាំងឡាយចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ

ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនអាចឲ្យពួកបញ្ចវគ្គិយភិក្ខុ យល់ច្បាស់បាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតទូន្មានភិក្ខុ ២ រូប ភិក្ខុ ៣ រូបត្រាច់ទៅបិណ្ឌបាត ឯភិក្ខុ ៣ រូបដែលត្រាច់ទៅបិណ្ឌបាត នាំយកចង្ហាន់បិណ្ឌបាតណាមក យើងទាំង ៦ នាក់ ចិញ្ចឹមជីវិតដោយសារចង្ហាន់បិណ្ឌបាតនោះ ។ តថាគតទូន្មានភិក្ខុ ៣ រូប ឯភិក្ខុ ២ រូបក៏ត្រាច់ទៅបិណ្ឌបាត ភិក្ខុ ២ រូបដែលត្រាច់ទៅបិណ្ឌបាត នាំយកចង្ហាន់បិណ្ឌបាតណាមក យើងទាំង ៦ នាក់ ក៏ចិញ្ចឹមជីវិតដោយសារចង្ហាន់បិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ពួកបញ្ចវគ្គិយភិក្ខុកាលដែលតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកព្រះនិព្វានដែលមិនមានជាតិធម៌ ជាគុណជាតដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ហើយក៏បានដល់នូវព្រះនិព្វាន ដែលមិនមានជាតិធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានជរាជាធម្មតា បានដឹងច្បាស់នូវទោសក្នុងជរាធម៌ ហើយស្វែងរកព្រះនិព្វាន ដែលមិនមានជរាធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ហើយក៏បានដល់នូវព្រះនិព្វានដែលមិនមានជរាធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ខ្លួនឯងមានព្យាធិជាធម្មតា ។បេ។ ខ្លួនឯងមានមរណៈជាធម្មតា ... ខ្លួនឯងមានសោកជាធម្មតា ... ខ្លួនឯងមានសេចក្ដីសៅហ្មងជាធម្មតា បានដឹងច្បាស់នូវទោសក្នុងសង្កិលេសធម៌ហើយស្វែងរកនូវព្រះនិព្វាន ដែលមិនមានសង្កិលេស

ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ហើយក៏បានដល់នូវព្រះនិព្វានដែលមិនមានសង្កិលេសធម៌ ជាធម៌ដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ។ ទាំងញាណទស្សនៈក៏កើតឡើងដល់បញ្ចវគ្គិយភិក្ខុទាំងឡាយនោះថា វិមុត្តិរបស់យើងមិនបានរំកើប ( ដោយកិលេស ) ទេ នេះជាជាតិជាទីបំផុត ឥឡូវភពថ្មីទៀត ក៏មិនមានឡើយ ។

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការ តើដូចម្តេច គឺរូបទាំងឡាយដែលគប្បីដឹងបានដោយចក្ខុជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួររីករាយ ១ សំឡេងដែលគប្បីដឹងបានដោយសោតៈ ។បេ។ ក្លិនដែលគប្បីដឹងបានដោយឃានៈ ... រសដែលគប្បីដឹងបានដោយជិវ្ហា ... ផ្សព្វទាំងឡាយដែលគប្បីដឹងបានដោយកាយ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯងកាមគុណមាន ៥ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តងោកជ្រប់លង់ស៊ប់ ជាអ្នកមិនឃើញទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ( បច្ចវេក្ខណញ្ញាណ ) តែងបរិភោគកាមគុណទាំង ៥ នេះ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ជាអ្នកត្រូវមារមានចិត្តបាប នឹងធ្វើទៅតាមសេចក្តីប្រាថ្នាបាន ។

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ ដូចជាម្រឹគនៅក្នុងព្រៃដែលជាប់ ( អន្ទាក់ )

ហើយ គប្បីដេកសន្ធឹតគំនរអន្ទាក់ ម្រឹគនោះបណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាសត្វដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ជាសត្វដែលព្រាន នឹងធ្វើទៅតាមសេចក្តីប្រាថ្នាបាន កាលបើព្រានដើរមកដល់ ម្រឹគនោះនឹងស្ទុះ ចេញទៅតាមបំណងពុំបានឡើយ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តង៉ោកជ្រប់ លង់ស៊ប់ ជាអ្នកមិនឃើញទោស មិនមានប្រាជ្ញាជា គ្រឿងរលាស់ខ្លួនចេញ បរិភោគនូវកាមគុណទាំង ៥ នេះឯង ពួកសមណ-ព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកដល់នូវសេចក្តីមិន ចម្រើន ដល់នូវសេចក្តីវិនាស ជាអ្នកត្រូវមារមានចិត្តបាបនឹងធ្វើទៅតាមសេចក្តី ប្រាថ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នក មានចិត្តមិនង៉ោក មិនជ្រប់ មិនលង់ស៊ប់ ជាអ្នកឃើញទោស មានប្រាជ្ញាជា គ្រឿងរលាស់ខ្លួនចេញ តែនៅបរិភោគកាមគុណទាំង ៥ នេះ សមណព្រាហ្មណ៍ ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស ជាអ្នកមិនត្រូវមារមានចិត្តបាប ធ្វើទៅតាមសេចក្តី ប្រាថ្នាបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាម្រឹគដែលនៅក្នុងព្រៃ មិន ជាប់ ( អន្ទាក់ ) តែដេកសន្ធឹតលើគំនរអន្ទាក់ ម្រឹគនោះ បណ្ឌិតគប្បីជ្រាប យ៉ាងនេះថា ជាសត្វមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស ជាសត្វមិនត្រូវព្រានធ្វើទៅតាមសេចក្តីប្រាថ្នាបាន ទុកជាព្រានដើរមកដល់ ម្រឹគនោះនឹងស្ទុះទៅតាមសេចក្តីប្រាថ្នាខ្លួនបាន សេចក្តីនេះមានឧបមាយ៉ាងណា

មិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តមិនងោក មិនជ្រប់ មិនលង់ស៊ប់ ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ តែនៅបរិភោគកាមគុណទាំង ៥ នេះ នៅឡើយ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស ជាអ្នកមិនត្រូវមារមានចិត្តបាបធ្វើទៅតាមសេចក្តីប្រាថ្នាបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ម្រឹគដែលនៅក្នុងព្រៃត្រាច់រន្ធាត់ទៅក្នុងព្រៃតូចព្រៃធំ តែងដើរទៅឥតរង្កៀស ឈរក៏ឥតរង្កៀស អង្គុយក៏ឥតរង្កៀស សម្រេចការដេកក៏ឥតរង្កៀស ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រឹគនោះមិនបានប្រទះភ្នែកព្រាន សេចក្តីនេះមានឧបមាយ៉ាងណាមិញ ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កវិចារៈ មានបីតិសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា បានធ្វើមារឲ្យខ្វាក់ បំបិទភ្នែកមារមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែលមារមានចិត្តបាបមើលមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កវិចារៈរួចហើយ ក៏ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ក្នុងសន្តាន មានភាវៈនៃចិត្តដ៏ប្រសើរ ឥតមានវិតក្ក និងវិចារៈឡើយ មានតែបីតិនិងសុខដែលកើតអំពីសមាធិ ... ចូលកាន់តតិយជ្ឈាន ... ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថាបានធ្វើមារឲ្យខ្វាក់ បំបិទភ្នែកមារមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែលមារមានចិត្តបាបមើលមិនឃើញ ។ ម្នាល

ភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះកន្លងនូវពួករូបសញ្ញា ព្រោះវិនាសទៅនៃពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ បំបិទភ្នែកមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែលមារមានចិត្តបាប មើលមិនឃើញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវអាកាសានញ្ចាយ-តនជ្ឈាន ដោយប្រការទាំងពួងហើយ ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ បរិកម្មថា វត្ថុតិចតួចមិនមាន ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញា-នាសញ្ញាយតនជ្ឈាន ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញា-វេទយិតនិរោធ ។ អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះឃើញច្បាស់ ( នូវអរិយសច្ចធម៌ ) ដោយវិបស្សនាបញ្ញា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនេះតថាគតហៅថា បានធ្វើមារឲ្យខ្វាក់ បំបិទភ្នែកមារមិនឲ្យឃើញស្នាមជើង ទៅកាន់ទីដែលមារមានចិត្តបាបមើលមិនឃើញ ។ ភិក្ខុនោះឆ្លងនូវតណ្ហាដែលមានអារម្មណ៍ផ្សាយទៅក្នុងលោកនេះបានហើយ ជាអ្នកដើរទៅឥតរង្កៀស ឈរក៏ឥតរង្កៀស អង្គុយក៏ឥតរង្កៀស សម្រេចនូវការដេកក៏ឥត

វង្វៀស ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ( ព្រោះថា ) ភិក្ខុនោះ មិនបានមកកាន់វង្វង់ចក្ខុរបស់មារមានចិត្តបាបទៀតឡើយ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## បាសរាសិសូត្រទី ៦ ចប់

# អដ្ឋកថា

## បាសរាសិសូត្រ

[ ៥០ ] បាសរាសិសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបាសរាសិសូត្រនេះ បទថា **សាធុ មយំ អាវុសោ** បានដល់ ពោលសំណូមពរ ។ បានឮថា ភិក្ខុអ្នកជនបទប្រមាណ ៥០០ នោះ គិតគាល់ព្រះទសពល ទើបទៅដល់ក្រុងសាវត្ថី ។ ភិក្ខុទាំងនោះបាន គាល់ព្រះសាស្ដាហើយ មិនទាន់បានស្ដាប់ធម្មីកថា ។ ដោយការគោរពក្នុង ព្រះសាស្ដា ទើបភិក្ខុទាំងនោះ មិនអាចក្រាបទូលថា សូមព្រះអង្គមេត្តា សម្ដែងធម្មីកថាដល់ពួកខ្ញុំព្រះអង្គចុះ ។ ព្រោះព្រះពុទ្ធទាំងឡាយជាគ្រូ លំបាក ក្នុងការចូលជួប ដូចស្ដេចរាជសីហ៍ ត្រាច់ទៅតាមទំនើង ដូចដំរីចុះប្រេង ដូចអាសិរពិសដែលបើកពពារ ដូចគំនរភ្លើងធំ ។ សមដូចលោកពោលថា

ព្រះពុទ្ធទាំងឡាយ ចូលដល់បានលំបាក ដូចពស់ដែលមានពិសដ៏ពន្លឹក ដូចកេសរសីហរាជ និងដូចស្ដេចដំរី ដូច្នោះ ។

ភិក្ខុទាំងនោះ មិនអាចអារាធនាព្រះសាស្ដា ដែលចូលជួបបានលំបាក យ៉ាងនេះដោយខ្លួនឯង ទើបសំណូមពរព្រះអានន្ទថា **សាធុ មយំ អាវុសោ** ដូច្នេះ ។ បទថា **អប្បេវ នាម** បានដល់ ធ្វើម្ដេចហ្ន៎ ពួកយើងគប្បីបាន ។

ព្រោះហេតុអ្វី ទើបព្រះថេរៈពោលនឹងភិក្ខុទាំងនោះថា ពួកអ្នកគប្បីចូល ទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ។ ព្រោះមានកិរិយាប្រាកដ ។ ព្រោះ កិរិយារបស់ព្រះទសពល រមែងប្រាកដដល់ព្រះថេរៈ ។ ព្រះថេរៈជ្រាបថា

ថ្ងៃនេះ ព្រះសាស្តានៅប្រថាប់ត្រង់វត្តជេតពន ទ្រង់សម្រាកពេលថ្ងៃ ក្នុងបុព្វារាម ថ្ងៃនេះ ទ្រង់ចូលទៅបិណ្ឌបាតមួយព្រះអង្គឯង ថ្ងៃនេះ ចោមរោមទៅដោយភិក្ខុសង្ឃ វេលានេះ ទ្រង់ចារិកទៅក្នុងជនបទ ។

សួរថា ចេតោបរិយញ្ញាណ រមែងមានដើម្បីឲ្យលោកដឹងយ៉ាងនេះបានដូចម្តេច ឆ្លើយថា មិនមាន ។ លោកដឹងដោយកាន់យកន័យតាមកិរិយាដែលធ្វើ ដោយដឹងតាមការគិតគ្នេរ ។ ពិតហើយ ថ្ងៃនោះ ព្រះមានព្រះភាគនៅប្រថាប់ក្នុងវត្តជេតពន ទ្រង់មានបំណងនឹងសម្រាកពេលថ្ងៃក្នុងបុព្វារាមក្នុងវេលាណា ក្នុងវេលានោះ ទ្រង់សម្តែងអាការ គឺការរៀបចំសេនាសនៈនិងគ្រឿងបរិក្ខារ ។ ព្រះថេរៈទុកដាក់អំបោស និងសក្ការៈដែលគេបូជាជាដើមសូម្បីក្នុងវេលាដែលនៅប្រថាប់ក្នុងបុព្វារាម ហើយយាងមកវត្តជេតពនសម្រាកពេលថ្ងៃ ក៏ន័យនេះដូចគ្នា ។ ក្នុងកាលណា ទ្រង់មានបំណងត្រាច់ទៅបិណ្ឌ-បាតមួយព្រះអង្គឯង គ្រានោះ ទ្រង់បដិបត្តិសរីរកិច្ចអំពីព្រលឹម ចូលព្រះ-គន្ធកុដិ បិទទ្វារ ចូលផលសមាបត្តិ ព្រះថេរៈជ្រាបដោយសញ្ញានេះថា ថ្ងៃនេះ ព្រះមានព្រះភាគ ប្រថាប់គង់ប្រមើលមើលសត្វដែលគួរត្រាស់ដឹង ហើយទើបឲ្យសញ្ញាដល់ភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ថ្ងៃនេះ ព្រះមានព្រះភាគបំណងនឹងទៅមួយព្រះអង្គឯង ពួកលោកចូរត្រៀមភិក្ខាចារ ។ កាលណាព្រះអង្គមានបំណង មានភិក្ខុបរិវារយាងទៅ គ្រានោះ ទ្រង់បង្ហើបទ្វារព្រះគន្ធកុដិ គង់ចូលផលសមាបត្តិ ។ ព្រះថេរៈជ្រាបដោយសញ្ញានោះទើបឲ្យសញ្ញាដល់ភិក្ខុទាំងឡាយ ដើម្បីទទួលបាត្រ ចីវរ ។ ក្នុងកាលណា

ទ្រង់មានបំណងយាងចារិកទៅក្នុងជនបទ គ្រានោះ ទ្រង់សោយលើសមួយ ម៉ាត់ ពីរម៉ាត់ ហើយទ្រង់ចង្រ្កមទៅមកៗ គ្រប់កាល ។ ព្រះថេរៈជ្រាបដោយ សញ្ញានោះ ទើបឲ្យសញ្ញាដល់ភិក្ខុទាំងឡាយថា អ្នកមានអាយុទាំងឡាយ ព្រះមានព្រះភាគ មានបំណងនឹងចារិកទៅក្នុងជនបទ ពួកលោកចូរធ្វើកិច្ច ដែលគួរធ្វើរបស់លោកចុះ ។ ព្រះមានព្រះភាគ ក្នុងបឋមពោធិកាល នៅ ប្រថាប់មិនប្រចាំអស់ ២០ វស្សា ក្រោយមក ប្រថាប់ជាប្រចាំក្នុងក្រុងសាវត្ថី ២៥ វស្សា មួយថ្ងៃៗ ទ្រង់ប្រើប្រាស់ទីកន្លែង ២ ។ ពេលយប់នៅប្រថាប់ ក្នុងវត្តជេតពន ស្អែកឡើង ហែហមដោយភិក្ខុសង្ឃ យាងចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីតាមទ្វារទិសខាងត្បូង ស្តេចចេញតាមទ្វារទិសខាងកើត ទ្រង់ សម្រាកពេលថ្ងៃក្នុងបុព្វារាម ។ ពេលយប់ នៅប្រថាប់ក្នុងបុព្វារាម ស្អែក ឡើង ត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថីតាមទ្វារទិសខាងកើត ហើយចេញតាម ទ្វារទិសខាងត្បូង ទ្រង់សម្រាកពេលថ្ងៃក្នុងវត្តជេតពន ។ ព្រោះហេតុអ្វី ព្រោះ ទ្រង់អនុគ្រោះដល់ត្រកូល ២ ។ ពិតហើយ ធម្មតាបុគ្គលណាមួយតាំងនៅ ក្នុងភាពជាមនុស្ស ដូចអនាថបិណ្ឌិកសេដ្ឋី និងស្រីដទៃដែលតាំងនៅក្នុងភាព ជាមាតុគ្រាម ដូចនាងវិសាខាមហាឧបាសិកា ដែលបរិច្ចាគទ្រព្យឧទ្ទិសចំពោះ ព្រះតថាគតរមែងមិនមាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ប្រើឋានៈ ទាំង ២ នេះ ក្នុងថ្ងៃតែមួយ ព្រោះអនុគ្រោះដល់ត្រកូលនោះ ។ ក្នុងថ្ងៃនោះ ទ្រង់គង់នៅក្នុងវត្តជេតពន ។ ព្រោះដូច្នោះ ទើបព្រះថេរៈគិតថា ថ្ងៃនេះ ព្រះ មានព្រះភាគ ទ្រង់ត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី ក្នុងវេលាល្ងាច ទ្រង់យាង

ទៅកាន់ខ្លោងទ្វារទិសខាងកើត ដើម្បីទ្រង់លាបស្រឡាបព្រះកាយ កាលបើដូច្នេះ ទើបខ្ញុំទូលអារាធនាព្រះមានព្រះភាគ ដែលប្រថាប់ឈរស្រឡាបព្រះកាយ ហើយទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ កាលបើដូច្នេះ ទើបភិក្ខុទាំងនេះ បានស្តាប់ធម្មកថាចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដូច្នេះហើយ ទើបបានពោលនឹងភិក្ខុទាំងនោះយ៉ាងនេះ ។

បទថា **មិគារមាតុបាសាទោ** បានដល់ ប្រាសាទរបស់នាងវិសាខាឧបាសិកា ។ ពិតហើយ នាងវិសាខានោះ លោកហៅថា មិគារមាតា ព្រោះមិគារសេដ្ឋីស្ថាបនាក្នុងឋានៈជាម្តាយ ។ បទថា **បដិសល្លាណា វុដ្ឋិតោ** បានពួថា ក្នុងប្រាសាទនោះ មានបន្ទប់ដែលទ្រទ្រង់សិរីសម្រាប់ព្រះមានព្រះភាគត្រង់កណ្តាលជាបន្ទប់ដែលទ្រទ្រង់សិរីសម្រាប់ព្រះមហាសាវកទាំង ២ ។ ព្រះថេរៈបើកទ្វារ បោសខាងក្នុងបន្ទប់ នាំយកកម្រងមាលាដែលស្វិតស្រពោនចេញ រៀបចំគ្រែ និងតាំង ហើយបានឲ្យសញ្ញាដល់ព្រះសាស្តា ។ ព្រះសាស្តាស្តេចចូលកាន់បន្ទប់ដ៏មានសិរី មានសតិសម្បជញ្ញៈ ទ្រង់ផ្ទំសីហសយនា ដោយព្រះបង្អៀងខាងស្តាំ ទ្រង់រម្ងាប់សេចក្តីក្រវល់ក្រវាយ ក្រោកឡើងប្រថាប់គង់ចូលផលសមាបត្តិ ចេញអំពីផលសមាបត្តិក្នុងវេលាល្ងាច ។ លោកសំដៅយកពាក្យនោះ ទើបពោលថា **បដិសល្លាណា វុដ្ឋិតោ** ។ បទថា **បរិសិញ្ចិតុំ** សេចក្តីថា បុគ្គលណាដុសខាត់ខ្លួន ដោយលម្អិតដីជាដើម ឬដុសខាត់ខ្លួនដោយថ្មសម្រាប់ខាត់ជាដើម ទើបងូត បុគ្គលនោះ លោកហៅថា រមែងងូត ។ បុគ្គលណាមិនធ្វើយ៉ាងនោះ ងូតតាមប្រក្រតីនោះឯង បុគ្គល

នោះលោកហៅថា រមែងស្រោច ។ ដែលឈ្មោះថា ទឹកដែលលាយដោយធូលី ដែលគប្បីនាំទៅ ដូច្នោះ មិនជាប់ក្នុងសរីរៈរបស់ព្រះតថាគត តែដើម្បីកាន់យកតាមវជ្ជកាល ព្រះមានព្រះភាគ ទ្រង់រមែងស្រង់ទឹកតែម្យ៉ាង ។ ដោយហេតុនោះ ទើបលោកពោលថា **គត្តានិ បរិសិញ្ចិតុំ** ទ្រង់ស្រោចស្រពព្រះកាយ ។ បទថា **បុព្វកោដ្ឋកោ** ប្រែថា ខ្លោងទ្វារទិសខាងកើត ។ បានឮថា ក្នុងក្រុងសាវត្ថី គ្រាខ្លះ វិហារក៏ធំ គ្រាខ្លះក៏តូច ។ កាលព្រះមានព្រះភាគទ្រង់ព្រះនាមថា វិបស្សី មានទំហំ ១ យោជន៍ ។ កាលព្រះសិខីសម្ពុទ្ធ ទំហំ ៣ គាវុត កាលព្រះវេស្សភូ ទំហំកន្លះយោជន៍ កាលព្រះកកុសន្ធសម្ពុទ្ធ ទំហំ ១ គាវុត កាលព្រះកោនាគមនសម្ពុទ្ធ ទំហំ កន្លះគាវុត កាលព្រះកស្សបសម្ពុទ្ធ ទំហំ ២០ ឧសភៈ កាលព្រះមានព្រះភាគនៃយើងទាំងឡាយ មានទំហំ ៨ ករីស ។ សូម្បីនគរនោះ គ្រាខ្លះ នៅទិសខាងកើតនៃវិហារនោះ គ្រាខ្លះ ក៏នៅទិសខាងត្បូង ជួនកាលខាងលិច ជួនកាលខាងជើង ។ ក្នុងព្រះគន្ធកុដិជេតវនវិហារ ទីប្រតិស្ឋានជើងគ្រែ និងទីសំណាងដែលមានជើង ៤ នៅត្រង់កន្លែងតែមួយ ។ ពិតហើយ ដែលឈ្មោះថា អចលចេតិយដ្ឋាន មាន ៤ កន្លែង គឺទីតាំងមហាពោធិបល្ល័ង្ក ១ ទីប្រកាសធម្មចក្រក្នុងព្រៃឥសិបតនៈ ១ ទីដែលប្រតិស្ឋានជណ្ដើរ កាលទ្រង់ចុះអំពីទេវលោក នាសង្កស្សនគរ ១ ទីព្រះទែនសម្រាប់បរិនិព្វាន ១ ។ ខ្លោងទ្វារខាងមុខនេះ ជាខ្លោងទ្វារទិសខាងកើត ក្នុងកាលព្រះវិហារទំហំ ២០ ឧសភៈរបស់ព្រះកស្សបទសពល ។ សូម្បីឥឡូវនេះ វិហារនោះ ក៏នៅប្រាកដខ្លោង

ទ្វារខាងមុខនោះឯង ។ កាលព្រះកស្សបទសពល ស៊ីងអចិរវតី ហូរព័ទ្ធនគរ ដល់ខាងទ្វារខាងមុខ ត្រូវទឹកប្រោះ ធ្វើឲ្យកើតស្រះទឹកធំ មានកំពង់ទឹករាប ជ្រៅ ជម្រេលតាមលំដាប់ ។ ក្នុងទីនោះមានកំពង់ទឹកគួរីកកាយ មានខ្សាច់ពណ៌ប្រាក់ដេរដាស បែកគ្នាជាចំណែកៗ យ៉ាងនេះ គឺកំពង់ទឹកសម្រាប់ព្រះរាជា ១ សម្រាប់អ្នកនគរ ១ សម្រាប់ភិក្ខុសង្ឃ ១ សម្រាប់ព្រះពុទ្ធទាំង-ឡាយ ១ ដូច្នោះ ទើបព្រះមានព្រះភាគ និងព្រះអានន្ទយាងចូលទៅកាន់ខាងទ្វារទិសខាងមុខដែលតាំងនៅនេះ ដើម្បីស្រេពស្រង់ព្រះអង្គ ។ គ្រានោះព្រះអានន្ទ បង្អោនសំពត់ស្រង់ទឹកចូលទៅថ្វាយ ។ ព្រះមានព្រះភាគ ទ្រង់ដោះសំពត់ក្រហម ២ ជាន់ ទ្រង់ស្លៀកសំពត់ងូតទឹក ។ ព្រះថេរៈទទួលមហាចីវរ និងសំពត់ ២ ជាន់ ដាក់ក្នុងដៃរបស់ខ្លួន ។ ព្រះមានព្រះភាគទ្រង់ចុះស្រង់ទឹក ។ ក្នុងពេលដែលទ្រង់ចុះស្រង់ទឹក ហ្វូងត្រី និងអណ្តើកក្នុងទឹកនោះ ក៏មានពណ៌ដូចមាសទាំងអស់ ។ កាលនោះ ហាក់ដូចជាវេលាយកនាឡិយន្តស្រោចដោយទឹកមាស និងដូចវេលាផែបន្ទះមាស ។ កាលព្រះមានព្រះភាគ ទ្រង់សម្តែងទំនៀមក្នុងការស្រង់ទឹក ទ្រង់ស្រង់ទឹក យាងឡើងហើយព្រះថេរៈក៏បង្អោនសំពត់ពណ៌ក្រហម ២ ជាន់ថ្វាយ ។ ព្រះមានព្រះភាគទ្រង់ស្លៀកសំពត់នោះ ចងវត្ថពន្ធចង្កេះ ដូចផ្លេកបន្ទោរ ទ្រង់ចាប់មហាចីវរត្រង់ជាយទាំង ២ រួមជាយបង្អោនចូលមក ធ្វើឲ្យដូចជាត្របកឈូក ហើយប្រថាប់ឈរ ។ ដោយហេតុនោះ ទើបលោកពោលថា ព្រះមានព្រះភាគទ្រង់ស្រង់ព្រះកាយត្រង់ខាងទ្វារខាងមុខ ទ្រង់ឡើងប្រថាប់ឈរ មានចីវរមួយ

ផ្ទាំង ៗ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលប្រថាប់ឈរយ៉ាងនេះ រុងរឿង ដូចស្រះដែលពេញទៅដោយផ្កាឈូក និងឧប្បលកំពុងរីក ដូចដើមបារិច្ឆត្តកៈ មានផ្ការីកស្គុសស្គាយ និងដូចលម្ហមេឃ ដែលដេរដាសទៅដោយផ្កាយ និង ថ្ងៃបណ្តើរកូន ហាក់ដូចជាអន្ទងយកព្រលឹង លក្ខណៈដ៏ប្រសើរ ៣២ របស់ ព្រះអង្គដែលល្អល្អះ ធៀលធ្វាត់ដោយព្រះរស្មី ប្រមាណមួយព្យាម រុងរឿង យ៉ាងក្រៃលែង ដូចព្រះចន្ទ ៣២ ព្រះអាទិត្យ ៣២ ដែលក្រងសំយុងចុះ ដូចស្តេចចក្រពត្តិ ៣២ អង្គ ស្តេចទេវតា ៣២ អង្គ និងមហាព្រហ្ម ៣២ អង្គ ដែលស្ថិតនៅតាមលំដាប់ ៗ នេះឈ្មោះថា វណ្ណភូមិ គប្បីជ្រាបកម្លាំង របស់ធម្មកថិក ក្នុងឋានៈបែបនេះថា ព្រះធម្មកថិកដែលអាចនាំអត្ថមកឧបមា និងហេតុមកពោលសរសើរព្រះសរីរៈ និងព្រះគុណរបស់ព្រះពុទ្ធទាំងឡាយ ក្នុងឋានៈបែបនេះ ដោយចុណ្ណិយបទ ឬគាថាទាំងឡាយឲ្យបរិបូណ៌ ៗ

បទថា **គត្តានិ បុព្វាបយមានោ** សេចក្តីថា រង់ចាំភាពជាប្រក្រតី ធ្វើ ឲ្យព្រះកាយអស់ទឹក អធិប្បាយថា ធ្វើឲ្យស្ងួត ៗ ពិតហើយ កាលព្រះមាន ព្រះភាគ មានព្រះវរកាយសើមដោយទឹក ដណ្តប់ចីវរ ក៏កើតជាផ្កា ៗ គ្រឿង បរិក្ខារក៏ខូច ៗ តែទឹកដែលលាយដោយធូលី រមែងមិនជាប់ក្នុងព្រះសរីរៈ របស់ព្រះពុទ្ធទាំងឡាយ ទឹកក៏រមៀលធ្លាក់ចុះទៅ ដូចដំណក់ទឹកដែលដាក់ លើស្លឹកឈូក ៗ កាលបើដូច្នោះ ព្រោះការគោរពក្នុងសិក្ខា ទើបព្រះមាន ព្រះភាគ ទ្រង់ចាប់មហាចីវរទាំងពីរជ្រុង ដោយទ្រង់ព្រះតម្រិះថា នេះឈ្មោះ ថា ទំនៀមនៃបព្វជិត ប្រថាប់ឈរបិទព្រះកាយខាងមុខ ៗ ខណៈនោះ ព្រះ

ថេរៈគិតថា ព្រះមានព្រះភាគទ្រង់ដណ្តប់មហាចីវរ និងត្រឡប់ព្រះកាយបាន ដោយលំបាក ផ្តើមតាំងពីការឡើងកាន់មិគារមាតុប្រាសាទជាដើម ឈ្មោះថា ការប្តូរពុទ្ធបំណង រមែងជាភារៈ ដូចលាដៃចាប់រាជសីហ៍ ដែលត្រាច់តែឯង ដូចចាប់ប្រមោយដំរីដែលចុះប្រេង ដូចចាប់កអាសិរពិស ដែលកំពុងព្រួសពិស ទើបពណ៌នាគុណអាស្រមរបស់រម្មកព្រាហ្មណ៍ ទូលអារាធនាព្រះមានព្រះភាគ ដើម្បីយាងទៅក្នុងទីនោះ ព្រះថេរៈបានធ្វើយ៉ាងនោះ ព្រោះហេតុនោះ ទើបលោកពោលថា **អថខោ អាយស្មា អានន្ទោ ។បេ។ អនុកម្បំ ឧបាទាយ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អនុកម្បំ ឧបាទាយ** បានដល់ អាស្រ័យសេចក្តីអនុគ្រោះ ភិក្ខុ ៥០០ អង្គ ដែលទៅកាន់អាស្រមនោះ ដោយតាំងចិត្តនឹងស្តាប់ធម្មីកថា ចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ អធិប្បាយថា ធ្វើសេចក្តីករុណាពួកភិក្ខុទាំងឡាយ ។ បទថា **ធម្មិយា កថាយ** សេចក្តីថា អង្គុយប្រជុំគ្នាសរសើរព្រះបារមី ១០ ប្រការណាមួយ និងមហាភិនិស្ក្រមណ៍ ។ បទថា **អាគមយមានោ** បានដល់ មើលសន្សឹមៗ អធិប្បាយថា មិនប្រញាប់ប្រញាល់ យាងចូលទៅដោយប្រកាន់ព្រះអង្គថា អញជាព្រះពុទ្ធ ប្រថាប់ឈររហូតដល់គេនិយាយគ្នាចប់ ។

[ ៥១ ] បទថា **អគ្គឡំ អាកោដ្ដេសិ** បានដល់ គោះទ្វារ ។ បទថា **វិវរិំសុ** សេចក្តីថា រំពេចនោះឯង ភិក្ខុទាំងឡាយក៏មកបើកទ្វារ ព្រោះអង្គុយផ្ទៀងត្រចៀករង់ចាំស្តាប់ស្រាប់ហើយ ។ បទថា **បញ្ញត្តេ អាសនេ** សេចក្តីថា បានឮថា ក្នុងជំនាន់ពុទ្ធកាល ភិក្ខុនៅមួយអង្គឯងក្នុងទីណាមួយ ក៏រៀបចំ

ពុទ្ធាសនៈទុកក្នុងទីនោះឯង ។

ព្រោះហេតុអ្វី បានឮថា ព្រះមានព្រះភាគ ទ្រង់ដាក់ព្រះហឫទ័យដល់ភិក្ខុដែលរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះអង្គហើយ នៅក្នុងទីផាសុកថា ភិក្ខុរូបនោះ ទទួលកម្មដ្ឋានក្នុងសម្នាក់របស់តថាគតទៅហើយ អាចធ្វើគុណវិសេសឲ្យកើតឡើងឬទេហ្ន៎ ។ លំដាប់នោះ ទ្រង់ឃើញភិក្ខុនោះ លះបង់កម្មដ្ឋានកំពុងត្រិះរិះក្នុងអកុសលវិតក្ក បន្ទាប់អំពីនោះ ក៏ទ្រង់ព្រះតម្រិះថា ហេតុអ្វីហ្ន៎ទើបអកុសលវិតក្កទាំងឡាយគ្របសង្កត់កុលបុត្រនេះ ដែលរៀនកម្មដ្ឋានក្នុងសម្នាក់របស់សាស្តាដូចតថាគត ឲ្យលិចចុះក្នុងវដ្តទុក្ខ ដែលជាប់តាម ដឹងមិនបាន ទើបទ្រង់បង្ហាញខ្លួនក្នុងទីនោះឯង ដើម្បីអនុគ្រោះកុលបុត្រនោះ ទ្រង់ឲ្យឱវាទកុលបុត្រនោះហើយ ទ្រង់ហោះទៅទីប្រថាប់របស់ព្រះអង្គវិញ ។ គ្រានោះ ភិក្ខុទាំងឡាយបានទទួលឱវាទយ៉ាងនោះ ទើបគិតថា ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់អញ ទើបទ្រង់មកសម្តែងខ្លួនប្រថាប់ឈរក្នុងទីជិតៗ ពួកយើងក្នុងឋានៈនោះ ឈ្មោះថា ការស្វែងរកអាសនៈជាភារៈ ដោយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមប្រថាប់គង់ក្នុងទីនេះ សូមប្រថាប់គង់ក្នុងទីនេះ ទើបរៀបចំអាសនៈ ។ ភិក្ខុណាមានតាំង ភិក្ខុនោះក៏រៀបតាំង ភិក្ខុណាមិនមាន ភិក្ខុនោះក៏រៀបគ្រែ ឬបន្ទះក្តារ ឈើ ថ្ម ឬពំនូកខ្សាច់ ។ កាលមិនមាន ក៏ប្រមូលស្លឹកឈើចាស់ៗ មកតម្រៀបជាគំនរទុកក្នុងទីនោះ តែក្នុងរឿងនេះ មានអាសនៈដែលរៀបចំទុកតាមប្រក្រតីទាំងអស់ ។ លោកសំដៅយកសេនាសនៈនោះ ទើបពោលថា **បញ្ញត្តេ អាសនេ និសីទិ** ដូច្នេះ ។

បទថា **កាយនុត្ត** សេចក្តីថា អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ។ បាលីថា **កាយនេត្ថ** ដូច្នេះក៏មាន ។ បាលីនោះក៏មានអត្ថថា ពួកអ្នកអង្គុយប្រជុំគ្នាក្នុងទីនេះ ដោយរឿងអ្វីហ្ន៎ ។ បាលីថា **កាយនោត្ថ** ដូច្នេះក៏មាន បាលីនោះក៏មានអត្ថដូចពាក្យខាងដើម ។ បទថា **អន្តរា កថា** បានដល់ រឿងដទៃណាមួយ រវាងការដាក់ចិត្តក្នុងការរៀន ការសាកសួរកម្មដ្ឋានជាដើម ។ បទថា **វិប្បកតា** បានដល់ មិនទាន់ចប់ គឺមិនទាន់ដល់ទីបំផុត ព្រោះការមកនៃតថាគតជាបច្ច័យ ។ បទថា **អថ ភគវា អនុប្បត្តោ** សេចក្តីថា កាលនោះ គឺកាលនោះ ព្រះមានព្រះភាគយាងមក ។ បទថា **ធម្មី វា កថា** បានដល់ ឬធម្មីកថាដែលអាស្រ័យកថាវត្ថុ ១០ ។ ក្នុងបទថា **អរិយោ វា តុណ្ហីភាវោ** នេះ ទុតិយជ្ឈានក្តី មូលកម្មដ្ឋានក្តី គប្បីជ្រាបថា អរិយតុណ្ហីភាព ព្រោះដូច្នោះ ភិក្ខុអង្គុយចូលឈាននោះក្តី អង្គុយកំណត់មូលកម្មដ្ឋានជាអារម្មណ៍ក្តី គប្បីជ្រាបថា អង្គុយដោយអរិយតុណ្ហីភាព ។ បទថា **ទ្វេមា ភិក្ខវេ បរិយេសនា** មានអនុសន្ធិតែមួយ ។ ភិក្ខុទាំងនោះបានធ្វើឲ្យជាភារៈរបស់ព្រះថេរៈ ដោយតាំងចិត្តស្តាប់ធម្មីកថាចំពោះព្រះភក្ត្រ ។ ព្រះថេរៈបានត្រឡប់ទៅកាន់អាស្រមរបស់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះអង្គុយនៅក្នុងទីនោះ មិនមែនសន្ទនាដោយរឿងតិរច្ឆានកថា គឺអង្គុយសន្ទនាដោយរឿងធម៌ គ្រានោះ ព្រះមានព្រះភាគផ្តើមទេសនានេះ ដើម្បីសម្តែងថា ការស្វែងរកនៃពួកអ្នកនេះ ឈ្មោះថា **អរិយបរិយេសនា** ។

[ ៥២-៥៣ ] បណ្តាបទទាំងនោះ ក្នុងបទថា **កតមា ច ភិក្ខវេ អនរិយា**

**បរិយេសនា** នេះ សេចក្ដីថា បុរសអ្នកឈ្លាសក្នុងផ្លូវ កាលសម្ដែងឧបាយ ក៏គួររៀវមុន ទើបពោលថា ចូរលះផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្ដាំ យ៉ាង ណា ព្រះមានព្រះភាគក៏យ៉ាងនោះ ព្រោះទ្រង់ជាអ្នកឈ្លាសក្នុងទេសនា ទើប ទ្រង់ប្រាប់ការស្វែងរកដែលមិនមែនអរិយៈ ដែលគប្បីលះបង់ចេញមុន លុះ ក្រោយមក ទើបទ្រង់ចែកលំដាប់ឧទ្ទេសថា តថាគតនឹងប្រាប់ការស្វែងរកក្រៅ អំពីនេះ ដូច្នេះហើយ ទើបត្រាស់យ៉ាងនេះ ។ បទថា **ជាតិធម្មោ** ប្រែថា មានការកើតជាធម្មតា ។ បទថា **ជរាធម្មោ** ប្រែថា មានការចាស់ជាធម្មតា ។ បទថា **ព្យាធិធម្មោ** ប្រែថា មានជំងឺតម្កាត់ជាធម្មតា ។ បទថា **មរណធម្មោ** ប្រែថា មានការស្លាប់ជាធម្មតា ។ បទថា **សោកធម្មោ** ប្រែថា មានសោក ជាធម្មតា ។ បទថា **សង្កិលេសធម្មោ** ប្រែថា មានការសៅហ្មងជាសភាវៈ ។ បទថា **បុត្តភរិយំ** បានដល់ កូន និងប្រពន្ធ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ ក្នុងបទថា **ជាតរូបរជតំ** នេះ **ជាតរូបំ** បានដល់ មាស **រជតំ** បានដល់ មាសកលោហៈជាដើមណាមួយដែលគេសន្មតសម្រាប់ចាយវាយ ។ ដោយ បទថា **ជាតិធម្មា ហេតេ ភិក្ខវេ ឧបធយោ** ទ្រង់សម្ដែងថា កាមគុណទាំង ៥ នោះ ឈ្មោះថា **ឧបធិ** ឧបធិទាំងអស់នោះ មានការកើតជាធម្មតា ។ មាស និងប្រាក់ លោកមិនកាន់យកក្នុងព្យាធិធម្មវារៈជាដើមឡើយ ព្រោះមាស និង ប្រាក់នោះ មិនមានព្យាធិ មានរោគត្រង់ក្បាលជាដើម មិនមានមរណៈ ពោល គឺចុតិ ដូចសត្វទាំងឡាយ មិនកើតសេចក្ដីសោក តែរមែងសៅហ្មងដោយ សង្កិលេស មានជរាជាដើម ព្រោះដូច្នោះ ទើបលោកកាន់យកក្នុងសង្កិលេ-

សិកធម្មវារៈផង កាន់យកក្នុងជាតិធម្មវារៈផង ព្រោះមានឧតុជាសមុដ្ឋាន កាន់យកក្នុងជរាធម្មវារៈផង ព្រោះប្រែះចាប់ ទើបគ្រាំគ្រា ។ បទថា **អយម្បិ ភិក្ខវេ អរិយា បរិយេសនា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះគប្បីជ្រាបថា ការស្វែងរករបស់ព្រះអរិយៈ ព្រោះមិនមានទោសក្នុងខ្លួនឯងផង ព្រោះព្រះអរិយៈគប្បីស្វែងរកផង ។

[ ៥៤ ] សួរថា ព្រោះហេតុអ្វី ទើបផ្តើមពាក្យថា **អហម្បិ សុទំ ភិក្ខវេ** ឆ្លើយថា ដើម្បីសម្តែងការយាងចេញមហាភិនេស្រ្កម៍តាំងអំពីដើម ។ បានឮថា ព្រះអង្គមានព្រះតម្រិះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សូម្បីតថាគតក៏ស្វែងរកវត្ថុដែលមិនប្រសើរមកអំពីកាលមុនដែរ តថាគតលះការស្វែងរកដែលមិនប្រសើរនោះ ហើយស្វែងរករបស់ដែលប្រសើរ ទើបសម្រេចសព្វញ្ញុតញ្ញាណ សូម្បីបញ្ចវគ្គិយក៏ស្វែងរកវត្ថុដែលមិនប្រសើរ ពួកលោកក៏លះបង់វត្ថុដែលមិនប្រសើរ ស្វែងរកវត្ថុដែលប្រសើរ សម្រេចខីណាសវភូមិ សូម្បីពួកអ្នកក៏ដើរតាមគន្លងរបស់តថាគត និងរបស់បញ្ចវគ្គិយភិក្ខុ ការស្វែងរកដែលប្រសើរ ទើបចាត់ជាការស្វែងរករបស់ពួកអ្នក ព្រោះដូច្នោះ ទើបទ្រង់សម្តែងការចេញមហាភិនេស្រ្កម៍របស់ព្រះអង្គ តាំងអំពីដើមមក ។

[ ៥៥ ] បណ្តាបទទាំងនោះ បទថា **ទហរោវ សមានោ** ប្រែថា នៅកំលោះ ។ បទថា **សុសុកាឡកេសោ** បានដល់ មានសក់ខ្មៅស្រិល អធិប្បាយថា មានសក់ពណ៌ដូចផ្កាអញ្ជ័ន ។ បទថា **ភទ្រេន** ប្រែថា ស្អាតល្អ ។ បទថា **បឋមេន វយសា** បានដល់ តាំងនៅដោយបឋមវ័យ ក្នុង

បណ្តាវ័យទាំង ៣ ។ បទថា **អកាមកានំ** បានដល់ កាលមិនប្រាថ្នា ។ បទថា **អកាមកានំ** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃ **អនាទរ** ។ ឈ្មោះថា **អស្សុមុខា** ព្រោះមានមុខជោកដោយទឹកភ្នែកនៃមាតា និងបិតាដែលមានមុខជោកដោយទឹកភ្នែកនោះ អធិប្បាយថា ជាអ្នកមានមុខជោកដោយទឹកភ្នែក ។ បទថា **រុទន្តានំ** បានដល់ ទ្រហោយំ ។ បទថា **កឹកុសលំគវេសី** បានដល់ ស្វែងរកកុសលណាមួយ ។ បទថា **អនុត្តរំ សន្តិវរបទំ** សេចក្តីថា ស្វែងរកបទដ៏ប្រសើរ ពោល គឺការស្ងប់ដ៏ឧត្តម បានដល់ ព្រះនិព្វាន ។ បទថា **អាឡារោ** ក្នុងបទថា **យេន អាឡារោ** នេះ ជាឈ្មោះរបស់តាបសនោះ ។ បានឮថា តាបសនោះមានខ្នងវែង ដោយហេតុនោះ ទើបតាបសនោះ មានឈ្មោះថា អាឡារ ។ បទថា **កាឡាមោ** ជាគោត្រ ។ បទថា **វិហារ-តាយស្មា** ប្រែថា សូមអ្នកមានអាយុនៅសិន ។ បទថា **យត្ថ វិញ្ញូបុរិសោ** បានដល់ បុរសដែលជាបណ្ឌិតក្នុងធម៌ណា ។ បទថា **សកំ អាចរិយកំ** បានដល់ លទ្ធិអាចារ្យរបស់ខ្លួន ។ បទថា **ឧបសម្បជ្ជ វិហរេយ្យ** បានដល់ គប្បីចូលដល់ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា បុគ្គលនោះ បានធ្វើឱកាសហើយ ។ បទថា **តំ ធម្មំ** បានដល់ បែបផែនលទ្ធិនៃបុគ្គលទាំងនោះ ។ បទថា **បរិយាបុណឹ** បានដល់ លុះបានស្តាប់ រៀនយក ។ បទថា **ឱដ្ឋបហតមត្តេន** សេចក្តីថា ដោយហេតុត្រឹមតែបង្ហើបមាត់ដើម្បីទទួលពាក្យដែលបុគ្គលនោះពោល អធិប្បាយថា ត្រឹមតែចរចាប្រាស្រ័យទៅវិញទៅមក ។ បទថា **លបិតលាបនមត្តេន** បានដល់ ដោយហេតុត្រឹមតែកាន់យកពាក្យសម្តី

ដែលបុគ្គលនោះពោលចប់ ។ បទថា **ញាណវាទំ** បានដល់ ពាក្យថា ខ្ញុំដឹងដឹងច្បាស់ ។ បទថា **ថេរវាទំ** បានដល់ ពាក្យរឹងមាំ ។ ពាក្យនេះ សំដៅយក ពាក្យថា ខ្ញុំជាអ្នកមាំទាំក្នុងសេចក្តីនេះ ។ បទថា **អហាញ្ចេវ អញ្ញេ ច** សេចក្តីថា មិនមែនតែតថាគតពោលត្រឹមតែម្នាក់ឯងប៉ុណ្ណោះទេ សូម្បីអ្នកដទៃជាច្រើន ក៏ពោលយ៉ាងនេះ ។ បទថា **កេវលំ សទ្ធាមត្តកេន** សេចក្តីថា ដោយហេតុត្រឹមតែសទ្ធាដែលបរិសុទ្ធប៉ុណ្ណោះ មិនមែនធ្វើឲ្យជាក់ច្បាស់ដោយបញ្ញា ។ បានឮថា ព្រះពោធិសត្វរៀនធម៌ដោយវាចាប៉ុណ្ណោះ បានដឹងថាឥសីកាឡាមមិនមែនបានត្រឹមតែបរិយត្តិ ដោយវាចាត្រឹមតែម្យ៉ាង ក្នុងធម៌នេះប៉ុណ្ណោះឡើយ លោកគង់បានសមាបត្តិ ៧ យ៉ាងពិតប្រាកដ ដោយហេតុនោះទើបលោកមានការគិតយ៉ាងនេះ ។ បទថា **អាកិញ្ចញ្ញាយតនំ បវេទេសិ** សេចក្តីថា បានឲ្យតថាគតដឹងសមាបត្តិ ៧ ដែលមានអាកិញ្ចញ្ញាយតន-សមាបត្តិជាទីបំផុត ។ បទថា **សទ្ធា** បានដល់ សទ្ធាដើម្បីឲ្យកើតសមាបត្តិទាំង ៧ នេះ ។ សូម្បីក្នុងសេចក្តីព្យាយាមជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **បទហេយ្យំ** បានដល់ គប្បីធ្វើសេចក្តីព្យាយាម ។ បទថា **ន ចិរស្សេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ** សេចក្តីថា បានឮថា ព្រះពោធិសត្វទ្រង់បំពេញសេចក្តីព្យាយាមធ្វើសមាបត្តិ ៧ ឲ្យកើតឡើងត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ ដូចទាញវាំងននមាស ៧ ជាន់ ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។

បទថា **លាភា នោ អាវុសោ** សេចក្តីថា បានឮថា កាឡាមតាបសនេះ

ជាបុគ្គលមិនប្រណែន ព្រោះដូច្នោះ លោកគិតថា បុគ្គលនេះ ទើបតែមក ហេតុអ្វីធ្វើធម៌នេះឲ្យកើតឡើងបាន ដូច្នេះហើយ ក៏មិនប្រណែន ត្រឡប់ជាជ្រះថ្លា ដើម្បីប្រកាសសេចក្ដីជ្រះថ្លា ទើបពោលយ៉ាងនេះ ។ បទថា **ឧភោ វសន្តា ឥមំ គណំ បរិហាម** សេចក្ដីថា លោកពោលថា គណៈនេះ ជាមហាគណៈ យើងទាំងពីរនាក់ជួយគ្នាគ្រប់គ្រងចុះ ហើយបានឲ្យសញ្ញាដល់គណៈ ។ លោកពោលថា ខ្ញុំក៏បានសមាបត្តិ ៧ មហាបុរសក៏បានសមាបត្តិ ៧ ដូចគ្នា មនុស្សចំនួនប៉ុណ្ណេះ រៀនបរិកម្មក្នុងសម្នាក់របស់មហាបុរស ចំនួនប៉ុណ្ណេះ រៀនក្នុងសម្នាក់នៃខ្ញុំ ដូច្នេះហើយ បានបែងចែកឲ្យពាក់កណ្ដាល ។ បទថា **ឧឡារាយ** ប្រែថា ឧត្ដម ។ បទថា **បូជាយ** បានដល់ បានឮថា ស្រីផង ប្រុសផង ដែលជាឧបដ្ឋាករបស់កាឡាមតាបស កាន់គ្រឿងក្រអូប និងផ្កាជាដើមមក ។ កាឡាមប្រាប់ថា អ្នកទាំងឡាយចូរទៅបូជាមហាបុរសចុះ ។ ជនទាំងនោះ បូជាមហាបុរសហើយ បូជាកាឡាមតាបសដោយសក្ការៈដ៏សេស ។ មនុស្សទាំងឡាយ នាំគ្រែតាំងជាដើម ដែលមានតម្លៃច្រើនមកឲ្យដល់ព្រះមហាបុរស បើមានសល់ ទើបខ្លួនឯងទទួល ។ ក្នុងទីដែលទៅជាមួយគ្នា កាឡាមតាបស ប្រាប់ឲ្យរៀបចំសេនាសនៈយ៉ាងល្អដល់ព្រះពោធិសត្វ ខ្លួនឯងទទួលចំណែកដ៏សេស ។ ក្នុងបទថា **នាយំ ធម្មោ និព្វិទាយ** ជាដើម សេចក្ដីថា ធម៌ គឺសមាបត្តិ ៧ នេះ មិនប្រព្រឹត្តទៅដើម្បីនឿយណាយក្នុងវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរម្ងត់រាគៈជាដើម មិនប្រព្រឹត្តទៅដើម្បីវិវេក មិនប្រព្រឹត្តទៅដើម្បីដឹងក្រៃលែង

នូវធម៌ដែលគួរដឹងក្រៃលែង មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹងសច្ចៈ ៤ មិនប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា **យាវទេវ អាកិញ្ចញ្ញាយតនូបបត្តិយា** សេចក្តីថា ប្រព្រឹត្តទៅដើម្បីកើតក្នុងអាកិញ្ចញ្ញាយតនភព ដែលមានអាយុប្រមាណ ៦ ម៉ឺនកប្ប មិនលើសអំពីនោះឡើយ ធម៌នេះជាធម៌វិលមកទៀត ទាំងឲ្យដល់ឋានៈណា ឋានៈនោះក៏មិនផុតអំពីជាតិ ជរា មរណៈបានឡើយ ត្រូវចោមរោមដោយអន្ទាក់របស់មច្ចុនោះឯង ឯបុរសដែលជាអ្នកស្រេកឃ្លាន បានភោជនដែលគួរពេញចិត្ត បរិភោគឆ្អែតស្កប់ស្កល់ហើយ ចោលដោយអំណាចទឹកប្រមាត់ខ្លះ ស្លេស្មខ្លះ ដោយក្អួតខ្លះ មិនកើតការដឹងថា អញនឹងបរិភោគបាយមួយដុំទៀត យ៉ាងណា តាំងពីនោះមក ព្រះមហាសត្វក៏ដូច្នោះដែរ សូម្បីធ្វើសមាបត្តិ ៧ ឲ្យកើតដោយឧស្សាហ៍យ៉ាងច្រើន ឃើញទោស ដោយការវិលមកទៀតជាដើមនេះ ក្នុងសមាបត្តិទាំងនោះ មិនបានកើតចិត្តគិតថា អញនឹងពិចារណា ឬនឹងចូល នឹងស្ថិតនៅ នឹងចេញ ឬនឹងពិចារណាធម៌នេះទៀត ។ បទថា **អនលង្ករិត្វា** បានដល់ មិនពេញចិត្តរឿយៗ ថា នឹងល្មមអ្វីដោយវត្ថុនេះ នឹងពេញចិត្តអ្វីដោយវត្ថុនេះ ។ បទថា **និព្វិជ្ជ** ប្រែថា នឿយណាយ ។ បទថា **អបក្កមឹ** ប្រែថា ដោះចេញហើយ ។

[ ៥៦ ] បទថា **ន ខោ ភគោ ឥមំ ធម្មំ** សេចក្តីថា ព្រះពោធិសត្វរៀនធម៌ក្នុងទីនេះ ដឹងទូទៅថា ធម៌ គឺសមាបត្តិ ៨ នេះ ជាធម៌ដែលឧទ្ទកតាបសរាមបុត្រ តាំងទុកត្រឹមតែរៀនដោយវាចាប៉ុណ្ណោះ ដោយពិតនោះ

ឧទ្ទកតាបសរាមបុត្រនេះ ជាអ្នកបានសមាបត្តិ ៨ ដោយហេតុនោះ ទើបព្រះពោធិសត្វគិតយ៉ាងនេះថា **ន ខោ ភាគោ ។បេ។ ជានំ បស្សំ វិហាសិ ។** ពាក្យដ៏សេសក្នុងសេចក្ដីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងវារៈខាងដើមនោះឯង ។

[ ៥៧ ] ខេត្តធំ អធិប្បាយថា គំនរខ្សាច់ធំ ឈ្មោះថា ឧរុវេលា ក្នុងបទថា **យេន ឧរុវេលា សេនានិគមោ** នេះ ។ ម្យ៉ាងទៀត ខ្សាច់ លោកហៅថា **ឧរុ** ខេត្តដែន លោកហៅថា **វេលា** ។ គប្បីជ្រាបក្នុងពាក្យនេះយ៉ាងនេះថា ខ្សាច់ដែលគេនាំមក ព្រោះកន្លងព្រំដែន ឈ្មោះថា **ឧរុវេលា** ។

បានឮមកថា ក្នុងអតីតកាល កាលដែលព្រះសម្ពុទ្ធមិនទាន់កើតឡើង កុលបុត្រប្រមាណ ១ ម៉ឺននាក់ បួសជាតាបស នៅក្នុងប្រទេសនោះ ថ្ងៃមួយប្រជុំគ្នា ដាក់កតិកាថា ដែលឈ្មោះថា កាយកម្ម និងវចីកម្មប្រាកដដល់ជនទាំងឡាយដទៃ ឯមនោកម្មមិនប្រាកដ ព្រោះដូច្នោះ បុគ្គលណា មានកាមវិតក្ក ព្យាបាទវិតក្ក ឬវិហិង្សាវិតក្ក អ្នកដទៃដែលត្រូវដាស់តឿនបុគ្គលនោះមិនមាន បុគ្គលនោះត្រូវដាស់តឿនខ្លួនដោយខ្លួនឯង ចូរយកភាជនៈដាក់ខ្សាច់ឲ្យពេញមកដាក់ក្នុងទីនេះ នេះជាការដាក់ទោសដល់បុគ្គលនោះ ។ តាំងអំពីនោះមក បុគ្គលណា ត្រិះរិះដល់វិតក្កយ៉ាងនោះ បុគ្គលនោះ ក៏ត្រូវយកភាជនៈដាក់ខ្សាច់មកចាក់ក្នុងទីនេះ គំនរខ្សាច់ធំកើតឡើងដោយលំដាប់ក្នុងទីនោះ ដោយប្រការដូច្នេះ ។ តមក មនុស្សដែលកើតមកឯក្រោយ ទើបព័ទ្ធគំនរខ្សាច់ធំនោះ ធ្វើជាចេតិយដ្ឋាន លោកសំដៅយកគំនរខ្សាច់ធំនោះ ទើប

ពោលថា **ឧរុវេលាតិ ។បេ។ អត្តោ ឧជ្ជញ្ញោ ។**

បទថា **សេនានិគមោ** ប្រែថា និគមរបស់សេនា ។ បានឮថា ពួកជនក្នុងបឋមកប្ប មានការបោះជំរំកងទ័ពនៅក្នុងទីនោះ ព្រោះដូច្នោះ ទើបទីនោះហៅថា សេនានិគមក៏មាន ។ បាឋៈថា **សេនានិគាមោ** ក៏មាន ។ អធិប្បាយថា បិតារបស់នាងសុជាតា ឈ្មោះថា **សេនានិ** ស្រុកនេះ ជាស្រុករបស់លោកសេនានិនោះ ។ បទថា **តទវសរិ** ប្រែថា សង្រ្គោះចូលក្នុងទីនោះ ។ បទថា **រមណីយំ ភូមិភាគំ** បានដល់ ភូមិភាគដែលជាទីត្រេកអរ ដែលលម្អដោយផ្កាក្នុងទឹក និងផ្កាលើគោក មានប្រការផ្សេងៗ ដែលរីកស្គុសស្គាយ ។ បទថា **ចាសាទិកំ វនសណ្ឌំ** សេចក្តីថា បានឃើញដងព្រៃដែលឲ្យកើតសេចក្តីជ្រះថ្លា ដូចគ្នានឹងកន្ទុយក្ងោក ។ បទថា **នទិញ្ច សន្ទន្តឹ** សេចក្តីថា បានឃើញស្ទឹងនេរញ្ជរា មានទឹកថ្លាពណ៌ខៀវត្រជាក់ ដូចគ្នានឹងគំនរកែវមណីកំពុងហូរសន្សឹមៗ ។ បទថា **សេតកំ** បានដល់ ស្អាត ប្រាសចាកភក់ ។ បទថា **សុបតិត្ថំ** បានដល់ ប្រកបដោយកំពង់ដែលល្អ ជម្រាលទៅតាមលំដាប់ ។ បទថា **រមណីយំ** បានដល់ មានទិដ្ឋភាពគួររីករាយ មានខ្សាច់ដែលក្រាលទុកដូចបន្ទះប្រាក់ មានត្រី និងអណ្តើកច្រើន ។ បទថា **សមន្តា ច គោចរគាមំ** សេចក្តីថា បានឃើញគោចរគាមដែលរកកិក្ខាបានងាយសម្រាប់បព្វជិតដែលមកដល់ហើយ បរិបូណ៌ទៅដោយគមនាគមន៍ក្នុងទីមិនឆ្ងាយដោយជុំវិញប្រទេសនោះ ។ បទថា **អលំ វត** ប្រែថា អាចហ្ន៎ ។ បទថា **តត្ថេវ និសីទិ** លោកបំណងយកការប្រថាប់គង់ត្រង់ពោធិបល្ល័ង្ក ពិតហើយ

បទថា **តត្ថេវ** ក្នុងព្រះសូត្រមុន លោកបំណាងយកទីដែលទ្រង់បំពេញទុក្ករកិរិយា ឯក្នុងព្រះសូត្រនេះ លោកបំណាងយកពោធិបល្ល័ង្ក ដោយហេតុនោះ ទើបលោកពោលថា **តត្ថេវ និសីទឹ** ដូច្នេះ ។ បទថា **អលមិទំ បធានាយ** សេចក្ដីថា ប្រថាប់គង់ ទ្រង់ព្រះតម្រិះយ៉ាងនេះថា ទីនេះអាចធ្វើសេចក្ដីព្យាយាមបាន ។

[ ៥៨ ] បទថា **អជ្ឈគមឹ** បានដល់ សម្រេច គឺបានចំពោះហើយ ។ បទថា **ញាណញ្ច បន មេ ទស្សនំ** សេចក្ដីថា ព្រះសព្វញ្ញុតញ្ញាណដែលអាចឃើញធម៌ទាំងពួង កើតឡើងដល់តថាគត ។ បទថា **អកុប្បា មេ វិមុត្តិ** សេចក្ដីថា វិមុត្តិដែលប្រកបដោយអរហត្តផលរបស់តថាគត ឈ្មោះថា **អកុប្ប** ព្រោះមិនកម្រើក និងព្រោះមានអកុប្បធម៌ជាអារម្មណ៍ វិមុត្តិនោះមិនកម្រើកដោយរាគៈជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **អកុប្ប** ព្រោះមិនកម្រើកជាអកុប្បធម៌ មាននិព្វានជាអារម្មណ៍ ព្រោះហេតុនោះ ទើបឈ្មោះថា **អកុប្ប** ព្រោះមានអកុប្បធម៌ជាអារម្មណ៍ ។ បទថា **អាយមន្តិមា ជាតិ** ប្រែថា នេះជាជាតិចុងក្រោយ ។ បទថា **នត្ថិ ទានិ បុនព្ភវោ** លោកសម្ដែងថា សូម្បីបច្ចវេក្ខណញ្ញាណក៏កើតឡើងដល់តថាគតយ៉ាងនេះថា ឥឡូវនេះ តថាគតមិនមានបដិសន្ធិទៀតឡើយ ។

[ ៥៩ ] បទថា **អធិគតោ** ប្រែថា ចាក់ធ្លុះហើយ ។ បទថា **ធម្មោ** បានដល់ ធម៌ គឺសច្ចៈ ៤ ។ បទថា **គម្ភីរោ** នេះ ជាពាក្យបដិសេធការរាក់ ។ បទថា **ទុទ្ទសោ** បានដល់ ឃើញបានលំបាក គប្បីឃើញបានដោយលំបាក

មិនអាចឃើញបានដោយងាយ ព្រោះជាធម៌មានជម្រៅ ឈ្មោះថា ដឹងតាមបាន លំបាក ដឹងបានដោយលំបាក មិនអាចដឹងបានដោយងាយ ព្រោះជាធម៌ដែល ឃើញបានដោយក្រ ។ បទថា **សន្តោ** បានដល់ រម្ងត់ ។ បទថា **បណីតោ** បានដល់ មិនក្តៅក្រហាយ ។ ពាក្យទាំង ២ នេះ លោកពោលសំដៅយក លោកុត្តរធម៌ប៉ុណ្ណោះ ។ បទថា **អតក្កាវចរោ** បានដល់ ជាធម៌ដែលមិន គប្បីត្រិះរិះ ឈមចុះដោយវិតក្ក គឺពិចារណាដោយញាណប៉ុណ្ណោះ ។ បទថា **និបុណោ** ប្រែថា ល្អិត ។ បទថា **បណ្ឌិតវេទនីយោ** បានដល់ ដែលពួក បណ្ឌិតអ្នកបដិបត្តិប្រពៃគប្បីដឹង ។ បទថា **អាលយរាមា** សេចក្តីថា សត្វ ទាំងឡាយរមែងជាប់ជំពាក់ក្នុងកាមគុណ ៥ ព្រោះហេតុនោះ កាមគុណ ៥ នោះ ហៅថា អាល័យ ។ សត្វទាំងឡាយរមែងជាប់ជំពាក់ដោយតណ្ហា វិចរិត ១០៨ ព្រោះដូច្នោះ ទើបហៅថា អាល័យ ។ សត្វទាំងឡាយឈ្មោះ ថា **អាលយរាមា** ព្រោះត្រេកអរដោយកាមគុណដែលជាទីអាល័យនោះ ។ ឈ្មោះថា **អាលយរតា** ព្រោះ ត្រេកអរក្នុងកាមគុណដែលជាទីអាល័យ ។ ឈ្មោះថា **អាលយសមុទិតា** ព្រោះត្រេកអរក្នុងកាមគុណ ដែលជាទី អាល័យ ។ ឧបមាដូចព្រះរាជាយាងចូលទៅកាន់ព្រះរាជឧទ្យានដែលបរិបូណ៌ ដោយដើមឈើ ដែលពេញទៅដោយផ្កា និងផ្លែជាដើម ដែលគាត់តែងទុក យ៉ាងល្អ ទ្រង់ត្រេកអរដោយសម្បត្តិនោះៗ ។ ទ្រង់រមែងត្រេកអររីករាយ មិនទៀយណាយ សូម្បីល្ងាចហើយ ក៏មិនប្រាថ្នានឹងចេញទៅ យ៉ាងណា សត្វ ទាំងឡាយ រមែងត្រេកអរដោយអាល័យ គឺកាម និងអាល័យ គឺតណ្ហាទាំង

នេះក៏ដូច្នោះ រមែងត្រេកអរ មិនធុញទ្រាន់ក្នុងវដ្តៈ ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអាល័យ ២ យ៉ាង ដល់សត្វទាំងនោះឲ្យដូចឧទ្យានភូមិ ទើបត្រាស់ពាក្យថា **អាលយរាមា** ដូច្នេះជាដើម ។ បទថា **យទិទំ** ជានិបាត ។ សំដៅយក ឋានៈនៃអាល័យនោះ គប្បីឃើញអត្ថយ៉ាងនេះថា **យំ ឥទំ** សំដៅយកបដិច្ចសមុប្បាទ គប្បីឃើញអត្ថយ៉ាងនេះថា **យោ អយំ** ដូច្នេះ ។ បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បាទោ** សេចក្តីថា បច្ច័យនៃធម៌ទាំងនេះ ឈ្មោះថា **ឥទប្បច្ចយា** ។ **ឥទប្បច្ចយា** នោះឯង ឈ្មោះថា **ឥទប្បច្ចយតា** ឥទប្បច្ចយតានោះផង បដិច្ចសមុប្បាទផង ព្រោះដូច្នោះ ទើបឈ្មោះថា **ឥទប្បច្ចយតាបដិច្ចសមុប្បាទ** ។ បទថា **ឥទប្បច្ចយតាបដិច្ច-សមុប្បាទោ** នេះជាឈ្មោះរបស់បច្ច័យ មានសង្ខារជាដើម ។ បទថា **សព្វ-សង្ខារសមថោ** ជាដើម គ្រប់បទជាវេវចនៈនៃព្រះនិព្វានទាំងអស់ ។ ព្រោះហេតុដែលការក្តៅក្រហាយនៃសង្ខារទាំងពួង អាស្រ័យព្រះនិព្វានទោះរមែងស្ងប់រម្ងាប់ ដូច្នោះ ទើបនិព្វាននោះ លោកហៅថា **សព្វសង្ខារសមថោ** គឺជាទីស្ងប់សង្ខារទាំងពួង ។ ម្យ៉ាងទៀត ព្រោះឧបធិទាំងអស់ អាស្រ័យព្រះនិព្វាននោះ រមែងលះបង់តណ្ហាទាំងពួង រមែងអស់ទៅនៃរាគៈ គឺកិលេសទាំងពួង រមែងស្ងប់ទៅ ទុក្ខទាំងពួងរមែងរលត់ទៅ ដូច្នោះ ទើបនិព្វាននោះលោកហៅថា **សព្វូបធិបដិនិស្សគ្គោ** លះបង់ឧបធិទាំងពួង **តណ្ហក្ខយោ** ជាទីអស់តណ្ហា **វិរាគោ** ជាទីអស់កិលេស **និរោធោ** ការរលត់ ។ តណ្ហាលោកហៅថា **វាន** ព្រោះដោតក្រងភព និងភព ឬកម្ម និងផល ។ ឈ្មោះ

ថា **ឆិញ្ញាន** ព្រោះចេញចាកតណ្ហា គឺវានះនោះ ។ បទថា **សោមមស្ស កិលមថោ** សេចក្តីថា ឈ្មោះថាការសម្តែងធម៌ដល់បុគ្គលមិនដឹង ជាសេចក្តីលំបាកដល់តថាគត ការលំបាកឯណាគប្បីមានដល់តថាគត ការលំបាកនោះគប្បីជាការបៀតបៀនដល់តថាគត ។ លោកអធិប្បាយថា គប្បីជាការលំបាកកាយ និងការបៀតបៀនកាយ ដូច្នេះ ។ តែទាំង ២ យ៉ាងនោះ មិនមានក្នុងចិត្តនៃព្រះពុទ្ធទាំងឡាយ ។ បទថា **អបិស្សុ** ជានិបាត ចុះក្នុងអត្ថថា កពូន ។ ព្រះថេរៈរមែងសម្តែងថា មិនមានពាក្យនោះប៉ុណ្ណោះ សូម្បីគាថាទាំងនោះក៏ប្រាកដហើយ ។ បទថា **មំ** ប្រែថា ដល់ខ្ញុំ ។ បទថា **អនច្ឆរិយា** ជា **អនុ–អច្ឆរិយា** ជាការអស្ចារ្យតិចតួច ។ បទថា **បដិភំសុ** បានដល់ ជាផ្លូវធ្វើដំណើររបស់ញាណ ពោល គឺបដិភាណ គឺដល់នូវភាពជាប្រការដែលគប្បីបរិវិតក្ក ។

បទថា **កិច្ឆេន** បានដល់ មិនមែនជាទុក្ខាបដិបទា ។ ពិតហើយ មគ្គ ៤ រមែងជាសុខាបដិបទាសម្រាប់ព្រះពុទ្ធទាំងឡាយនោះឯង ។ ពាក្យនេះលោកពោលសំដៅយកអាគមនីយបដិបទានៃព្រះអង្គ ដែលនៅមានរាគៈ នៅមានទោសៈ និងនៅមានមោហៈនោះឯង ក្នុងកាលទ្រង់បំពេញបារមី ទ្រង់កាត់ក្បាលដែលស្អិតស្អាងហើយ នាំយកឈាមក្នុងបំពង់កចេញ ខ្វេះភ្នែកដែលបន្តក់ថ្នាំល្អហើយ ឲ្យទានវត្ថុដទៃយ៉ាងនេះ គឺបុត្រដែលជាប្រទីបនៃវង្សត្រកូល ភរិយាដែលមានចរិយាគួរពេញចិត្តដល់យាចកដែលមកហើយ សូម្បីត្រូវគាត់ត្រូវទម្លាយក្នុងអត្តភាពទាំងឡាយ ដូចជាខន្តិវាទីតាបសជាដើម ។ **ហ** អក្ខរៈ

ក្នុងបទថា **ហលំ** នេះ ត្រឹមតែជានិបាត សេចក្តីថា កុំឡើយ ។ បទថា **បកាសិតុំ** ប្រែថា ដើម្បីសម្តែង គឺមិនចែក មិនសម្តែងធម៌ ដែលតថាគត សម្រេចហើយ ដោយលំបាកយ៉ាងនេះឡើយ អធិប្បាយថា ធម៌ដែលតថាគត សម្តែងហើយ នឹងមានប្រយោជន៍អ្វី ។ បទថា **រាគទោសបរេតេហិ** បាន ដល់ បុគ្គលដែលរាគៈ និងទោសៈពាល់ត្រូវហើយ ឬដែលរាគៈ និងទោសៈ គ្របសង្កត់ហើយ ។ បទថា **បដិសោតគាមឹ** បានដល់ សច្ចធម៌ ៤ ដែល ទៅហើយយ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា អសុភំ** ដែលបញ្ច្រាសក្រសែ នៃធម៌ មានការទៀងជាដើម ។ បទថា **រាគរត្តា** បានដល់ ត្រេកអរហើយ ដោយកាមរាគៈ ភវរាគៈ និងទិដ្ឋិរាគៈ ។ បទថា **ន ទក្ខន្តិ** សេចក្តីថា រមែង មិនឃើញដោយសភាវៈនេះថា មិនទៀង ជាទុក្ខ ជាអនត្តា និងស្អាត ដូច្នេះ ។ បុគ្គលណាអាចដើម្បីធ្វើបុគ្គលដែលមិនឃើញទាំងនោះ ឲ្យកាន់យកយ៉ាងនេះ បាន ។ បទថា **តមោក្ខន្ធេន អាវុតា** សេចក្តីថា បុគ្គលដែលគំនរអវិជ្ជា ជន់លិចហើយ ។ បទថា **អប្បោស្សុក្កតាយ** បានដល់ ដើម្បីមិនមានការ ខ្វល់ខ្វាយ អធិប្បាយថា មិនបំណងដើម្បីនឹងទេសនា ។

សួរថា ព្រោះហេតុអ្វី ទើបចិត្តព្រះអង្គបង្អោនទៅយ៉ាងនេះថា តថាគត រួចផុតហើយ នឹងធ្វើឲ្យអ្នកដទៃរួចផុត តថាគតឆ្លងហើយ នឹងធ្វើឲ្យអ្នកដទៃ ឆ្លងមិនមែនឬ ព្រះអង្គតាំងសេចក្តីប្រាថ្នាថា

តែថា ប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ដោយគេទ ដែល គេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួច

ស្រឡះចាកកិលេស ញុំាងលោក ព្រមទាំងទេវលោក ឲ្យរួចរដោះ ( ចាកសង្សារ ) ។

ដូច្នេះហើយ បំពេញបារមីទាំងឡាយ ក៏សម្រេចសព្វញ្ញុតញ្ញាណ ។ ឆ្លើយថា សេចក្ដីនេះជាសេចក្ដីពិត ចិត្តរបស់ព្រះអង្គបង្អោនទៅយ៉ាងនេះ ដោយអានុភាពនៃបច្ចវេក្ខណញ្ញាណ ព្រះអង្គសម្រេចសព្វញ្ញុតញ្ញាណ ពិចារណាដល់សត្វដែលស្អិតដោយកិលេស និងសភាពដែលធម៌ ជាសភាវៈជ្រាលជ្រៅ ទើបប្រាកដថា សត្វនៅប្រកាន់ដោយកិលេស និងធម៌ជាសភាពជ្រាលជ្រៅ ដោយប្រការទាំងពួង កាលបើដូច្នោះ ទ្រង់ក៏ព្រះតម្រិះថា សត្វទាំងនេះដល់ព្រមទៅដោយកិលេស សៅហ្មងពន់ពេក តម្រេកព្រោះរាគៈ ក្រោធព្រោះទោសៈ វង្វេងព្រោះមោហៈ ដូចឃ្លោកពេញដោយទឹកបាយ ដូចពាងពេញដោយតក្កៈ ដូចសំពត់ចាស់សើមដោយខ្លាញ់ និងដូចដៃប្រឡាក់ថ្នាំបន្តក់ភ្នែក សត្វទាំងឡាយនោះនឹងត្រាស់ដឹងធម៌បានដូចម្ដេចហ្ន៎ ទើបទ្រង់បង្អោនចិត្តទៅយ៉ាងនោះ ដោយអានុភាពនៃការពិចារណាដល់ការប្រកាន់ដោយកិលេស ធម៌នេះ គប្បីជ្រាបថា ជ្រាលជ្រៅដូចទឹកទ្រផែនដី ឃើញបានលំបាក ដូចគ្រាប់ស្ពៃដែលយកភ្នំមកបាំង ដឹងតាមបានលំបាក ដូចចុងរោមទ្រាយដែលច្រៀកជា ៧ ចម្រៀក ឈ្មោះថា ទានដែលអញព្យាយាមដើម្បីត្រាស់ដឹង ធម៌នេះ មិនឲ្យហើយមិនមាន ឈ្មោះថា សីលដែលអញមិនបានរក្សាហើយមិនមាន ។ ឈ្មោះថា បារមីណាមួយ ដែលអញមិនបានបំពេញមិនមាន កាលអញកម្ចាត់កម្លាំងរបស់មារ ដែលគ្មានឧស្សាហ៍ ផែនដីក៏មិន

ញាប់ញ័រ កាលរឭកដល់បុព្វេនិវាសញ្ញាណ ក្នុងបឋមយាមក៏មិនញាប់ញ័រ កាលជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាមក៏មិនញាប់ញ័រ តែកាលចាក់ធ្លុះបដិច្ចសមុប្បាទក្នុងបច្ឆិមយាម ទើបលោកជាតុមួយម៉ឺនញាប់ញ័រ ដូច្នោះ បុគ្គលដែលមានញាណចាស់ក្លា អម្បាលដូចអាត្មាអញ គង់ចាក់ធ្លុះធម៌នេះបានដោយលំបាកដល់ម៉្លោះ ចំណាន់បើលោកិយមហាជន នឹងចាក់ធ្លុះធម៌នោះបានដូចម្ដេច គប្បីជ្រាបថា ទ្រង់បង្អោនចិត្តទៅយ៉ាងនេះ ដោយអានុភាពនៃការពិចារណានូវគម្ភីរភាពនៃព្រះធម៌ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កាលសហម្បតីព្រហ្មទូលអារាធនា ព្រះអង្គក៏ទ្រង់បង្អោនចិត្តទៅយ៉ាងនេះ ព្រោះទ្រង់មានព្រះបំណងនឹងសម្ដែងធម៌ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា កាលតថាគតបង្អោនចិត្តទៅដើម្បីភាពជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មហាព្រហ្មក៏នឹងអារាធនាតថាគតសម្ដែងធម៌ ។ ព្រោះថា សត្វទាំងនេះគោរពព្រហ្ម សត្វទាំងនោះនឹងសម្គាល់ថា ព្រះសាស្ដាមិនបំណងនឹងសម្ដែងធម៌ តែមហាព្រហ្មអារាធនាឲ្យតថាគតសម្ដែងធម៌ អ្នកដ៏ចម្រើនទាំងឡាយ ធម៌នេះ ស្ងប់ប្រណីតហ្ន៎ នឹងតាំងចិត្តស្ដាប់ ដោយល្អអាស្រ័យហេតុនេះ គប្បីជ្រាបថា ទ្រង់បង្អោនចិត្តទៅដើម្បីភាពជាអ្នកខ្វល់ខ្វាយតិច មិនបានបង្អោនទៅដើម្បីសម្ដែងធម៌ ។

បទថា **សហម្បតិស្ស** សេចក្តីថា បានឮថា សហម្បតីព្រហ្មនោះ កាលសាសនាព្រះមានព្រះភាគព្រះនាមថាកស្សប ជាព្រះថេរៈឈ្មោះថា សហកៈធ្វើបឋមជ្ឈានឲ្យកើតហើយ ទៅកើតជាព្រហ្មអាយុមួយកប្ប ក្នុងភូមិនៃបឋម-

ដ្ឋាន ។ ជនទាំងឡាយ រមែងសំដៅមហាព្រហ្មនោះថា សហម្បតីព្រហ្មក្នុងពាក្យនោះ ។ លោកសំដៅយកសហម្បតីព្រហ្មនោះ ទើបពោលថា **ព្រហ្មុនោ សហម្បតិស្ស** ។

[ ៦០ ] បទថា **ឧស្សុតិ វត ភោ** សេចក្តីថា បានឮថា សហម្បតីព្រហ្មនោះបន្លឺសំឡេងនេះចេញមក ព្រហ្មក្នុង ១ ម៉ឺនលោកធាតុបានឮហើយប្រជុំគ្នាទាំងអស់ ។ បទថា **យត្រ ហិ នាម** ប្រែថា ក្នុងលោកណា ។ បទថា **បុរតោ ធាតុរហោសិ** ប្រាកដព្រមជាមួយព្រហ្ម ១០០០ នោះ ។ បទថា **អប្បរជក្ខជាតិកា** បានដល់ ធូលី គឺរាគៈ ទោសៈ និងមោហៈក្នុងភ្នែកដែលសម្រេចដោយបញ្ញា មានប្រមាណតិចរបស់សត្វទាំងនោះ មានសភាពយ៉ាងនេះ ព្រោះដូច្នោះ ទើបសត្វទាំងនោះឈ្មោះថា **អប្បរជក្ខជាតិកា** មានធូលី គឺកិលេសក្នុងភ្នែកតិច ។ បទថា **អស្សវនតា** ប្រែថា ព្រោះមិនបានស្តាប់ ។ ដោយបទថា **ភវិស្សន្តិ** លោកសម្តែងថា សត្វទាំងឡាយអ្នកធ្វើបុណ្យដោយបុញ្ញកិរិយាវត្ថុ ១០ ក្នុងព្រះពុទ្ធអង្គមុនៗ ទន្ទឹងការសម្តែងធម៌ប្រៀបដូចផ្កាឈូកដែលចាស់ ត្រូវពន្លឺព្រះអាទិត្យ គួរនឹងឈមចុះក្នុងអរិយភូមិ កាលចប់គាថា ៤ បទ មិនមែនតែម្នាក់ មិនមែនពីរនាក់ តែជាច្រើនសែនដែលត្រាស់ដឹងធម៌ ។

បទថា **ធាតុរហោសិ** ប្រែថា ប្រាកដ ។ បទថា **សមលេហិ ចិន្តិតោ** បានដល់ ដែលពួកសាស្តាទាំង ៦ ដែលជាអ្នកគិតដោយមន្ទិល ។ ពិតហើយសាស្តាទាំងនោះកើតឡើងមុន នាំគ្នាសម្តែងធម៌ គឺមិច្ឆាទិដ្ឋិ ដែលមានមន្ទិល

ដូចស្រះបទ្មា និងដូចស្រោចដោយថ្នាំពិសពេញជម្ពូទ្វីប ។ បទថា **អបា-បុរេតំ** បានដល់ បើកទ្វារអមតៈនោះ ។ បទថា **អមតស្ស ទ្វារំ** បានដល់ អរិយមគ្គដែលជាទ្វារអមតនិព្វាន ។ បទថា **សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ** សេចក្តីថា ទូលអារាធនាថា បពិត្រព្រះមានព្រះភាគ ជាបឋម សូមសត្វទាំងនេះបានស្តាប់នូវធម៌ គឺអរិយសច្ច ៤ ដែលព្រះសម្មាសម្ពុទ្ធ ជាអ្នកមិនមានមន្ទិល ព្រោះមិនមានមន្ទិល គឺរាគៈជាដើមត្រាស់ដឹងហើយ ។ បទថា **សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ** សេចក្តីថា ប្រៀបដូចបុគ្គលដែលឈរលើភ្នំថ្មសុទ្ធ មិនចាំបាច់អើតក ដើម្បីនឹងមើលបុគ្គលដែលឈរនៅលើកំពូលភ្នំ ដែលជាថ្មសុទ្ធ ។ បទថា **តថូបមំ** ឧបមាយ៉ាងនោះ ឬឧបមាដោយភ្នំថ្ម ។

សេចក្តីសង្ខេបមានដូច្នេះ បុរសមានចក្ខុ ឈរនៅលើកំពូលភ្នំថ្ម គប្បីឃើញពពួកជនបានដោយជុំវិញ យ៉ាងណា បពិត្រសុមេធ ជាអ្នកមានបញ្ញាល្អ ទ្រង់មានសមន្តចក្ខុ ដោយសព្វញ្ញុតញ្ញាណ សូមព្រះអង្គឡើងកាន់ប្រាសាទធម៌ គឺបញ្ញា មិនសោយសោក ដោយព្រះអង្គឯង សូមត្រិះរិះពិចារណា ប្រមើលមើលពពួកជន ដែលក្តៅដោយសេចក្តីសោក និងត្រូវជាតិជរាគ្របសង្កត់ ក៏ដូច្នោះ ។ ក្នុងសេចក្តីនេះមានអធិប្បាយថា ឧបមាដូចជនទាំងឡាយ ធ្វើស្រែច្រើនជុំវិញជើងភ្នំ សង់ខ្ទមទុកត្រង់ភ្លឺស្រែ ក្នុងទីនោះពេលយប់ដុតភ្លើង ការងងឹតដែលប្រកបដោយអង្គ ៤ គប្បីមាន កាលបើដូច្នោះ បុរសដែលមានចក្ខុឈរលើកំពូលភ្នំនោះ សម្លឹងមើលផែនដី ស្រែចម្ការក៏មិនប្រាកដ ព្រំភ្លឺស្រែក៏មិនប្រាកដ ខ្ទមក៏មិនប្រាកដ អ្នកដេកនៅក្នុងទី

នោះក៏មិនប្រាកដ ប្រាកដត្រឹមតែពន្លឺភ្លើង ត្រង់ខ្ទមប៉ុណ្ណោះ យ៉ាងណា កាល ព្រះតថាគត ឡើងជម្ពូប្រាសាទ សម្លឹងមើលពួកសត្វ ពួកសត្វដែលមិនបាន ធ្វើកម្មល្អ សូម្បីអង្គុយនៅក្បែរព្រះជានុខាងស្តាំ ក្នុងវិហារតែមួយ ក៏មិន ប្រាកដដល់ពុទ្ធចក្ខុ ដូចព្រួញដែលគេបាញ់ក្នុងវេលាយប់ ឯវេនេយ្យបុគ្គល ធ្វើកម្មល្អ សូម្បីនៅក្នុងទីឆ្ងាយ ក៏ប្រាកដដល់ព្រះអង្គ ប្រៀបដូចភ្លើង និង ប្រៀបដូចភ្នំហិមពាន្ត ដូច្នោះ ។ សមដូចគាថាពន្ធដែលលោកពោលថា

**ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**
**អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។**

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួក អសប្បុរស ( ទុកជាស្ថិតនៅ ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញ ដែលបុគ្គលបាញ់ក្នុងវេលាយប់ ដូច្នោះ ។

បទថា **ឧដ្ឋេហិ** ព្រហ្មទូលអារាធនាព្រះមានព្រះភាគ ឲ្យទ្រង់ចារិក សម្តែងធម៌ ។ ក្នុងបទថា **វីរ** ជាដើម ព្រះមានព្រះភាគ ទ្រង់ឈ្មោះថា **វីរ** ព្រោះទ្រង់មានសេចក្តីព្យាយាម ។ ឈ្មោះថា **វិជិតសង្គាម** ព្រោះទ្រង់ ឈ្នះទេវបុត្តមារ មច្ចុមារ និងកិលេសមារ ដូចជាមេកងរទេះ ព្រោះជា អ្នកអាចក្នុងការនាំពួកវេនេយ្យសត្វ ឲ្យឆ្លងជាតិកន្តារជាដើម គប្បីជ្រាបថា បុគ្គលមិនមានបំណុល ព្រោះមិនមានបំណុល គឺ កាមច្ឆន្ទៈ ។

[ ៦១ ] បទថា **អជ្ឈេសនំ** ប្រែថា ទូលអារាធនា ។ បទថា **ពុទ្ធ-ចក្ខុនា** បានដល់ ដឹងឥន្ទ្រិយរបស់សត្វដែលទន់ខ្សោយ និងចាស់ក្លា និងដឹងអធ្យា-

ស្រ័យ និងកិលេស ។ ពាក្យថា **ពុទ្ធចក្ខុ** ជាឈ្មោះនៃញាណទាំង ២ នេះ **សមន្តចក្ខុ** ជាឈ្មោះនៃសព្វញ្ញុតញ្ញាណ **ធម្មចក្ខុ** ជាឈ្មោះនៃមគ្គញ្ញាណ ៣ ។ ក្នុងបទថា **អប្បរជក្ខេ** ជាដើម ធូលី គឺ កិលេស មានរាគៈជាដើម ក្នុងបញ្ញាចក្ខុនៃសត្វពួកណាមានតិច ដោយន័យដែលពោលហើយនោះឯង សត្វទាំងនោះ ឈ្មោះថា **អប្បរជក្ខ** សត្វពួកណាមានធូលី គឺកិលេសនោះច្រើន សត្វទាំងនោះ ឈ្មោះថា **មហារជក្ខ** សត្វពួកណាមានឥន្ទ្រិយ គឺ សទ្ធាជាដើមចាស់ក្លា សត្វទាំងនោះ ឈ្មោះថា **តិក្ខិន្ទ្រិយ** ។ សត្វពួកណា មានឥន្ទ្រិយទាំងនោះទន់ខ្សោយ សត្វទាំងនោះ ឈ្មោះថា **មុទិន្ទ្រិយ** សត្វពួកណាមានអាការ គឺសទ្ធាជាដើមទាំងនោះល្អ សត្វទាំងនោះឈ្មោះថា **ស្វាការ** សត្វពួកណាកំណត់ដឹងហេតុដែលត្រាស់ អាចដឹងបានងាយ សត្វទាំងនោះឈ្មោះថា **សុវិញ្ញាបយ** សត្វពួកណាឃើញបរលោក និងទោសថាជាភ័យ សត្វទាំងនោះ ឈ្មោះថា **បរលោកវជ្ជភយទស្សាវិនោ** ។

ក្នុងទីនោះ មានបាលីដូចតទៅនេះ បុគ្គលមានសទ្ធា ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកតិច បុគ្គលដែលមិនមានសទ្ធា ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកច្រើន បុគ្គលប្រារព្ធសេចក្តីព្យាយាម ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកតិច បើជាអ្នកខ្ជិលច្រអូស ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកច្រើន បុគ្គលមានសតិតាំងមាំ ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកតិច បុគ្គលមិនមានស្មារតី ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកច្រើន បុគ្គលមានចិត្តតាំងមាំ ឈ្មោះថា ជា

អ្នកមានធូលី គឺកិលេសក្នុងភ្នែកតិច បុគ្គលមានចិត្តមិនតាំងមាំ ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកច្រើន បុគ្គលមានបញ្ញា ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកតិច បុគ្គលមានបញ្ញាថោកថយ ឈ្មោះថា ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកច្រើន បុគ្គលមានសទ្ធាយ៉ាងនោះ ឈ្មោះថា មានឥន្ទ្រិយចាស់ក្លា ។បេ។ បុគ្គលមានបញ្ញា ឈ្មោះថា ជាអ្នកឃើញបរលោក និងទោសថាជាភ័យ បុគ្គលដែលមានបញ្ញាថោកថយ ឈ្មោះថា មិនឃើញបរលោក និងទោសថាជាភ័យ ។ បទថា **លោកោ** បានដល់ ខន្ធលោក អាយតនលោក ធាតុលោក សម្បត្តិភវលោក សម្បត្តិសម្ភវលោក វិបត្តិភវលោក វិបត្តិសម្ភវលោក ។ លោក ១ គឺសត្វទាំងពួង តាំងនៅបានដោយអាហារ លោក ២ គឺនាម និងរូប លោក ៣ គឺវេទនា ៣ លោក ៤ គឺអាហារ ៤ លោក ៥ គឺឧបាទានក្ខន្ធ ៥ លោក ៦ គឺអាយតនៈខាងក្នុង ៦ លោក ៧ គឺវិញ្ញាណដ្ឋិតិ ៧ លោក ៨ គឺលោកធម៌ ៨ លោក ៩ គឺសត្តាវាស ៩ លោក ១០ គឺអាយតនៈ ១០ លោក ១២ គឺអាយតនៈ ១២ លោក ១៨ គឺធាតុ ១៨ ។ បទថា **វជ្ជំ** សេចក្តីថា កិលេសទាំងពួងចាត់ជាទោស ទុច្ចរិតទាំងពួងចាត់ជាទោស អភិសង្ខារទាំងពួងចាត់ជាទោស កម្មដែលជាហេតុនាំសត្វទៅកាន់ភពទាំងពួងចាត់ជាទោស ការសម្គាល់ក្នុងលោកនេះ និងក្នុងទោសនេះថាជាភ័យដ៏ខ្លាំងក្លាប្រាកដហើយ ដូចពេជ្ឈឃាតងាដាវ ព្រះតថាគតរមែងដឹង ដឹងទូទៅ ដឹងដោយជុំវិញនូវឥន្ទ្រិយទាំង ៥ នេះ ដោយអាការទាំង ៥០ នេះ ឈ្មោះថា **ឥន្ទ្រិយបរោបរិយត្តិញ្ញាណ** របស់

ព្រះតថាគត ។

បទថា **ឧប្បលិនិយំ** ប្រែថា ក្នុងគុម្ពឧប្បល ។ សូម្បីក្នុងពាក្យក្រៅអំពីនេះ ក៏ន័យដូចគ្នា ។ បទថា **អន្តោ និមុគ្គបោសីនិ** បានដល់ ផ្កាឈូកដែលនៅក្រោមទឹក ដែលធម្មជាតិចិញ្ចឹម ។ បទថា **ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ** បានដល់ ផុសឡើង តាំងនៅ ។ ក្នុងផ្កាឈូកទាំងនេះ ផ្កាណាផុសឡើងអំពីទឹករង់ចាំ លុះទទួលសម្ផស្សនៃពន្លឺព្រះអាទិត្យ ក៏នឹងរីកក្នុងថ្ងៃនេះ ផ្កាណាតាំងនៅស្មើទឹក ផ្កានោះ នឹងរីកក្នុងថ្ងៃស្អែកនេះ ផ្កាណាលិចនៅក្នុងទឹក ត្រូវទឹកជាធម្មជាតិរក្សា ផ្កានោះ នឹងរីកក្នុងថ្ងៃទី ៣ ។ ឯផ្កាឈូកដទៃដែលនៅក្នុងស្រះជាដើម សូម្បីទឹកនៅមានក៏មិនរីក នឹងក្លាយជាភិក្ខារបស់ត្រី និងអណ្តើកតែម្យ៉ាង ផ្កាឈូកទាំងនោះ លោកសម្តែងទុក មិនឡើងកាន់បាលី ក៏គប្បីសម្តែង ។ ផ្កា ៤ យ៉ាងនោះ ប្រៀបដូចបុគ្គល ៤ ពួក គឺឧគ្ឃដិតញ្ញូ វិបចិតញ្ញូ នេយ្យ បទបរម ក៏ដូច្នោះដូចគ្នា ។ បុគ្គលទាំង ៤ នោះ បុគ្គលណាត្រាស់ដឹងធម៌ព្រមគ្នានឹងការលើកមាតិកាធម៌ បុគ្គលនេះ ហៅថា ឧគ្ឃដិតញ្ញូ ។ បុគ្គលណាត្រាស់ដឹងធម៌ កាលលោកចែកអត្ថនៃភាសិតសង្ខេបបានដោយពិស្តារ បុគ្គលនេះ ហៅថា វិបច្ចិតញ្ញូ ។ បុគ្គលណាដាក់ចិត្តដោយឧបាយ ដោយឧទ្ទេសផង ដោយបរិបុច្ឆាផង សេពគប់ចូលជិតកល្យាណមិត្តទើបត្រាស់ដឹងធម៌ បុគ្គលនេះ ហៅថា នេយ្យ ។ បុគ្គលណា ស្តាប់ច្រើនក្តី ពោលច្រើនក្តី ទ្រទ្រង់ចាំច្រើនក្តី បង្រៀនច្រើនក្តី នៅតែមិនត្រាស់ដឹងធម៌ក្នុងជាតិនោះ បុគ្គលនោះ ហៅថា បទបរម ។ បណ្តាបុគ្គលទាំងនោះ ព្រះមាន

ព្រះភាគ ទ្រង់ប្រមើលមើលលោកធាតុ ១ ម៉ឺន ដែលដូចជាព្រៃឈូកជាដើម ក៏ទ្រង់បានឃើញថា ឧគ្ឃដិតញ្ញូ ប្រៀបដូចផ្កាឈូកក្នុងថ្ងៃនេះ វិបចិតញ្ញូ ប្រៀបដូចផ្កាឈូកក្នុងថ្ងៃស្អែក នេយ្យ ប្រៀបដូចផ្កាឈូកក្នុងថ្ងៃទី ៣ បទបរម ប្រៀបដូចផ្កាដែលជាចំណីរបស់ត្រី និងអណ្ដើក ។ ព្រះមានព្រះភាគ កាលទ្រង់ឃើញ ទ្រង់ក៏ឃើញដោយអាការគ្រប់យ៉ាង យ៉ាងនេះថា សត្វមានប្រមាណប៉ុណ្ណេះមានធូលី គឺកិលេសក្នុងភ្នែកតិច ប៉ុណ្ណេះមានធូលី គឺកិលេសក្នុងភ្នែកច្រើន បណ្ដាសត្វទាំងនោះ សត្វទាំងនេះជាឧគ្ឃដិតញ្ញូ ដូច្នេះជាដើម ។ ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ រមែងឲ្យសម្រេចប្រយោជន៍ក្នុងអត្តភាពនេះប៉ុណ្ណោះ ដោយបុគ្គល ៣ ប្រភេទ ក្នុងចំនួនបុគ្គលទាំងនោះ បទបរមមានវាសនាដើម្បីប្រយោជន៍ក្នុងអនាគតកាល ។ កាលនោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រះធម្មទេសនានាំប្រយោជន៍មកឲ្យដល់បុគ្គល ៤ ប្រភេទ ទើបទ្រង់ធ្វើឲ្យកើតនូវពុទ្ធបំណងដើម្បីសម្ដែងធម៌ ទើបទ្រង់ចែកពួកសត្វក្នុងភពទាំង ៣ ជា ២ ចំណែកទៀត គឺភព្វបុគ្គល និងអភព្វបុគ្គល ។ លោកសំដៅយកសត្វពួកណា ទើបពោលពាក្យនេះថា ពួកសត្វដែលប្រកបដោយការឃាត់កម្ម ឃាត់វិបាក ឃាត់កិលេស មិនមានសទ្ធា កាត់មិនដាច់ មិនមានបញ្ញា មិនគួរឈមចុះកាន់ការប្រពៃក្នុងកុសលធម៌ពិតប្រាកដ សត្វទាំងនេះ ចាត់ជាអភព្វ ។ ពួកសត្វដែលជាភព្វនោះដូចម្ដេច គឺពួកសត្វដែលមិនប្រកបដោយកម្មាវរណៈ វិបាកាវរណៈ និងកិលេសាវរណៈ ។បេ។ សត្វទាំងនេះ ឈ្មោះថា ជាភព្វ ។ ក្នុងសត្វ ២ ប្រភេទនោះ ព្រះមានព្រះភាគ

ទ្រង់លះអភព្វបុគ្គលទាំងអស់ ទ្រង់កំណត់កាន់យកដោយព្រះញាណចំពោះភព្វបុគ្គលប៉ុណ្ណោះ ទ្រង់ចែកចេញជា ៦ ចំណែក គឺបុគ្គលដែលមានរាគចរិត ទោសចរិត មោហចរិត វិតក្កចរិត សទ្ធាចរិត និងពុទ្ធិចរិត ។ កាលចែកយ៉ាងនេះ ហើយទ្រង់ព្រះតម្រិះដើម្បីសម្តែងធម៌ប្រោស ។

បទថា **បច្ចភាសឹ** ប្រែថា ត្រាស់ចំពោះ ។ បទថា **អបារុតា** ប្រែថា បើក ។ បទថា **អមតស្ស ទ្វារា** បានដល់ អរិយមគ្គ ។ ពិតហើយ អរិយមគ្គនោះ ជាទ្វារនៃព្រះនិព្វាន ពោល គឺអមតៈ ព្រះមានព្រះភាគទ្រង់សម្តែងថា អរិយមគ្គនោះ តថាគតបើកហើយ ។ បទថា **បមុញ្ចន្តុ សទ្ធំ** បានដល់ ចូរសត្វបញ្ចេញ ចូរសត្វបញ្ជូននូវសទ្ធារបស់ខ្លួន ក្នុងបទ ២ ខាងក្រោយមានសេចក្តីដូច្នេះថា សូម្បីតថាគតយល់ថា លំបាកកាយ និងវាចា ទើបមិនពោលធម៌ដ៏ឧត្តមប្រណីតនេះ ដែលស្ទាត់ជំនាញហើយ ដែលប្រព្រឹត្តទៅដោយល្អរបស់ខ្លួន តែដល់ឥឡូវនេះ ចូរជនទាំងពួងបង្អោននូវភាជនៈ គឺសទ្ធាចូលមក តថាគតនឹងធ្វើតម្រិះរបស់សត្វទាំងនោះឲ្យពេញ ។

[ ៦២ ] បទថា **តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ** សេចក្តីថា តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា តថាគតគប្បីសម្តែងធម៌ដល់នរណាមុនហ្ន៎ វិតក្កដែលសម្បយុត្តដោយធម្មទេសនានេះកើតឡើងហើយ ។ សួរថា វិតក្កនេះកើតឡើងក្នុងកាលណា ឆ្លើយថា កាលព្រះពុទ្ធបានត្រាស់ក្នុងសប្តាហ៍ទី ៨ ក្នុងសេចក្តីនោះ នឹងពោលតាមលំដាប់ដូច្នេះ

បានឮមកថា ក្នុងថ្ងៃមហាភិនេស្រ្កម៍ ព្រះពោធិសត្វទតឃើញអាការ

ផ្សេងៗ របស់ស្រីស្នំ ក្នុងអាគារដែលបើក ក៏សង្វេគ ទើបត្រាស់ហៅឆន្ន-មាត្យមកប្រាប់ថា ចូរនាំសេះកណ្ឋកៈមកចុះ មានឆន្នមាត្យជាសម្លាញ់ ទ្រង់ឡើងផែលលើខ្នងសេះ ចេញចាកព្រះនគរ ទ្រង់សម្តែងចេតិយដ្ឋាន ដែលឲ្យសេះកណ្ឋកៈត្រឡប់ ទ្រង់លះរាជសម្បត្តិ ទ្រង់ផ្នួសក្បែរមាត់ស្ទឹងអនោមានទី ទ្រង់ចារិកទៅតាមលំដាប់ ត្រាច់ស្វែងរកអាហារក្នុងក្រុងរាជគ្រឹះ ប្រថាប់គង់ត្រង់ភ្នំបណ្ឌវៈ ត្រូវព្រះបាទពិម្ពិសារត្រាស់សួរដល់នាម និងគោត្រ ក៏សូមឲ្យទ្រង់ទទួលរាជសម្បត្តិ តែក៏ទូលថា កុំឡើយ មហាបពិត្រ អាត្មាភាពមិនត្រូវការរាជសម្បត្តិទេ អាត្មាភាពលះរាជសម្បត្តិ មកប្រកបសេចក្តីព្យាយាមដើម្បីជាប្រយោជន៍ដល់សត្វលោក ចេញបួសដោយបំណងត្រាស់ជាព្រះពុទ្ធកាត់វដ្តៈក្នុងលោក ទ្រង់ទទួលបដិញ្ញារបស់ព្រះបាទពិម្ពិសារដែលសូមថា បើយ៉ាងនោះ បើព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ សូមយាងមកនគរទូលបង្គំមុន ដូច្នេះហើយ ទ្រង់ចូលទៅរកអាឡារតាបសកាលាមគោត្រ និងឧទ្ទក-តាបសរាមបុត្រ កាលមិនជួបសារៈនៃធម្មទេសនារបស់តាបសទាំង ២ នោះទើបចៀសចេញទៅបំពេញទុក្ករកិរិយាអស់ ៦ ឆ្នាំ ត្រង់ឧរុវេលា កាលមិនអាចចាក់ធ្លុះអមតធម៌ ធ្វើព្រះកាយឲ្យឆ្អែតដោយការសោយអាហារដែលគ្រោតគ្រាត ។ គ្រានោះ ធីតារបស់កុដុម្ពិកៈម្នាក់ ឈ្មោះសុជាតា ក្នុងឧរុវេលគាមបានបន់ត្រង់ដើមនិគ្រោធមួយថា បើខ្ញុំរៀបការជាមួយមនុស្ស មានជាតិស្មើគ្នា បានកូនប្រុសមុន នឹងធ្វើពលីកម្ម ។ នាងសម្រេចសេចក្តីប្រាថ្នានោះហើយ ។ ថ្ងៃវិសាខបុណ្ណមី នាងត្រៀមមធុបាយាសយ៉ាងល្អ ក្នុងវេលារាត្រី

ទៀបក្តី ដោយប្រាថ្នានឹងធ្វើពលីកម្មអំពីព្រលឹម ។ កាលកំពុងចម្អិនមធុបាយាស នោះ ពពុះបាយាសប៉ោងផុសឡើងធំៗ វិលទៅស្តាំ ។ ចំណែកដែលត្រូវសម្ផស្សឯណាមួយ ក៏មិនខ្ទាតចេញទៅខាងក្រៅ ។ មហាព្រហ្មបាំងឆត្រ ។ ស្តេចចតុលោកបាលកាន់ដាវរក្សា ។ សក្កទេវរាជប្រមូលឈើងាប់មកដុតភ្លើង ។ ទេវតាក្នុងទ្វីបទាំង ៤ ប្រមូលឱជៈមកដាក់ចូលក្នុងមធុបាយាសនោះ ។ ព្រះពោធិសត្វផងចាំវេលាកិច្ចាចារ យាងទៅអំពីព្រលឹម ប្រថាប់គង់នាគល់ឈើ ។ អ្នកបម្រើមកដើម្បីសម្អាតគល់ជ្រៃនោះ ប្រាប់នាងសុជាតាថា ទេវតាមកអង្គុយត្រង់គល់ឈើហើយ ។ នាងសុជាតាប្រដាប់គ្រឿងអលង្ការទាំងពួងហើយដួសមធុបាយាសដាក់ក្នុងថាសមាស មានតម្លៃមួយសែន គ្របដោយថាសមាសមួយទៀត ហើយលើកឡើងដើរទៅ ឃើញព្រះមហាបុរស ក៏ដាក់លើដៃ ព្រមទាំងថាសនោះឯង ថ្វាយបង្គំហើយ ពោលថា មនោរថរបស់ខ្ញុំសម្រេចហើយយ៉ាងណា សូមមនោរថរបស់លោកសម្រេចយ៉ាងនោះហោង ហើយក៏ត្រឡប់ទៅ ។

ព្រះពោធិសត្វ យាងទៅកាន់ប្រាំងស្ទឹងនេរញ្ជរា ហើយដាក់ថាសមាសត្រង់ឆ្នេរស្ទឹង ចុះស្រង់ទឹក ស្តេចឡើងមកហើយ ទ្រង់ពូតមធុបាយាសចំនួន ៤៩ ពំនូត សោយមធុបាយាសហើយ ទ្រង់អធិដ្ឋានថា ប្រសិនបើអាត្មាអញត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះ ចូរថាសអណ្តែតប្រាសខ្សែទឹក ដូច្នេះហើយ ទ្រង់បោះថាសទៅ ។ ថាសក៏អណ្តែតប្រាសខ្សែទឹក ហើយឈប់បន្តិច ចូលទៅកាន់ភពរបស់កាឡនាគរាជ ក៏ជ្រៀតចូលទៅខាងក្រោមថាសរបស់ព្រះពុទ្ធ ៣

ព្រះអង្គ ។ ព្រះមហាសត្វប្រថាប់សម្រាកនៅពេលថ្ងៃ ក្នុងដងព្រៃ លុះដល់វេលាល្ងាច ទ្រង់ទទួលស្បូវ ៨ ក្តាប់ ដែលសោត្ថិយព្រាហ្មណ៍ប្រគេន រួចទ្រង់ឡើងកាន់ពោធិមណ្ឌលដ្ឋាន ប្រថាប់ឈរត្រង់ទិសទក្សិណ ។ ប្រទេសនោះបានញាប់ញ័រ ដូចដំណក់ទឹកក្នុងស្លឹកឈូក ។ ព្រះមហាសត្វទ្រង់ត្រិះរិះថា ត្រង់នេះមិនអាចទ្រទ្រង់គុណរបស់អាត្មាអញបានឡើយ ក៏យាងទៅកាន់ទិសខាងលិច ។ ទីនោះក៏កម្រើកដូចគ្នា ។ ទើបយាងទៅកាន់ទិសខាងជើង ។ ទីនោះក៏កម្រើកដូចគ្នា ។ ទើបយាងទៅត្រង់ទិសខាងកើត ក្នុងទីនោះ មិនញាប់ញ័រឡើយ ដូចសសរគោលដែលបោះល្អហើយ ។ ព្រះមហាសត្វ ទ្រង់ត្រិះរិះថា ទីនេះជាទីដែលជកនូវបញ្ជរកិលេសរបស់ព្រះពុទ្ធគ្រប់អង្គ ទ្រង់ចាប់ចុងស្បូវទាំងនោះ រលាស់ចុងស្បូវទាំងនោះ ក៏បានដូចជាជាងចិត្រកម្មគូរដោយចុងជក់ ។ ព្រះពោធិសត្វទ្រង់ចូលទៅជិតគល់ពោធិ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ថា ទ្រង់មិនទម្លាយនូវភ្នែននេះ ហើយប្រថាប់គង់ពត់ព្រះភ្នែន ។

វេលានោះឯង មារនិម្មិតដៃ ១ ពាន់ ឡើងជិះដំរី ឈ្មោះ គិរិមេខលៈ កម្ពស់ ១៥០ យោជន៍ នាំពលមារ ៩ យោជន៍ សម្លឹងមើលពាក់កណ្តាលភ្នែក ចូលទៅជិត ប្រៀបដូចភ្នំ ។ ព្រះមហាសត្វទ្រង់លាព្រះហស្តត្រាស់ថា អាត្មាអញកំពុងបំពេញបារមី ១០ មិនមានសមណព្រាហ្មណ៍ ទេវតា មារ ឬព្រហ្មជាសាក្សីឡើយ តែក្នុងអត្តភាពដែលជាព្រះវេស្សន្តរ មហាប្រឹថពីជាសាក្សីរបស់អាត្មាអញ ក្នុងទី ៧ កន្លែង សូម្បីឥឡូវនេះ មហាប្រឹថពីក៏មិន

មានចិត្ត ឧបមាដោយកំណាត់ឈើ ក៏ជាបន្ទាល់សាក្សី ។ រំពេចនោះឯង មហាប្រឹថពីក៏បន្លឺសំឡេង ១ រយដង ១ ពាន់ដង ដូចជួងដែលត្រូវវាយដោយដុំដែក ហើយប្រមូលពលមារទៅគរទុក ត្រង់កណ្តាប់ចក្រវាល ។ កាលព្រះអាទិត្យមិនទាន់លិចនៅឡើយ ទ្រង់ក៏កម្ចាត់ពលមារបាន ទ្រង់ជម្រះបុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ឈមចុះកាន់ញាណក្នុងបដិច្ចសមុប្បាទ នាបច្ឆិមយាម ទ្រង់ពិចារណាវដ្ដៈ និងវិវដ្ដៈ ក្នុងវេលាអរុណរះ ក៏បានត្រាស់ជាព្រះពុទ្ធ ទ្រង់ព្រះតម្រិះថាអាត្មាអញធ្វើសេចក្ដីព្យាយាមដើម្បីបល្ល័ង្កនេះ មកអស់ច្រើនសែនកោដិកប្បដូច្នេះហើយ ប្រថាប់គង់ពត់ព្រះភ្លែនក្នុងឥរិយាបថមួយ អស់មួយសប្តាហ៍ ។

បន្ទាប់មក ទេវតាពួកខ្លះ កើតសន្ទិះសង្ស័យថា នៅមានធម៌ដែលធ្វើភាពជាព្រះពុទ្ធទៀតឬហ្ន៎ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាបត្តិក្នុងថ្ងៃទី ៨ ទ្រង់ជ្រាបសេចក្ដីសង្ស័យរបស់ពួកទេវតា ទើបទ្រង់ហោះទៅលើអាកាស សម្ដែងយមកប្បាដិហារ្យ ដើម្បីកម្ចាត់សេចក្ដីសង្ស័យកាលទ្រង់កម្ចាត់សេចក្ដីសង្ស័យរបស់ទេវតាទាំងនោះហើយ ប្រថាប់ឈរត្រង់ទិសឦសាន ឆ្ងាយអំពីបល្ល័ង្កបន្តិច ទ្រង់សម្លឹងស្ពានទីសម្រេចផលនៃព្រះបារមីដែលទ្រង់បំពេញមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ចំពោះបល្ល័ង្កនិងពោធិព្រឹក្សដោយមិនប៉ប្រិចព្រះនេត្រអស់មួយសប្តាហ៍ ។ ទីនោះឈ្មោះថាអនិមិសចេតិយ ។ បន្ទាប់មក ទ្រង់យាងចង្ក្រមក្នុងផ្ទះកែវ ដែលតអំពីទិសខាងកើត និងទិសខាងលិច ក្នុងចន្លោះបល្ល័ង្ក និងទីប្រថាប់ឈរ កន្ទង់ទៅ

អស់មួយសប្តាហ៍ ។ ទីនោះឈ្មោះថា រតនចង្កមចេតិយ ។ បន្ទាប់អំពីនោះ ពួកទេវតាក្នុងចំណែកទិសខាងលិចនិម្មិតផ្ទះ ជាវិការនៃកែវ ។ ទ្រង់ប្រថាប់គង់ពត់ព្រះភ្នែនក្នុងផ្ទះនោះ ទ្រង់ពិចារណាអភិធម្មបិដក ដោយចំពោះយ៉ាងក្រៃលែង ក្នុងសមន្តប្បដ្ឋានអនន្តន័យ ក្នុងអភិធម្មនោះ អស់មួយសប្តាហ៍ ។ ទីនោះឈ្មោះថា រតនឃរចេតិយ ។ ក្នុងទីក្បែរពោធិមណ្ឌលដ្ឋាននោះឯង កន្លងទៅ ៤ សប្តាហ៍ ដោយអាការយ៉ាងនេះ ក្នុងសប្តាហ៍ទី ៥ ទ្រង់ចេញអំពីគល់ពោធិព្រឹក្ស ទៅកាន់អជបាលនិគ្រោធ ។ ទ្រង់ពិចារណាធម៌ក្នុងទីនោះប្រថាប់គង់សោយវិមុត្តិសុខ ។ កាលទ្រង់ពិចារណាធម៌ ទ្រង់ក៏ពិចារណាត្រឹមតែន័យព្រះអភិធម្មក្នុងធម៌នោះ គឺគម្ពីរដំបូង ឈ្មោះធម្មសង្គណិប្បករណៈ បន្ទាប់អំពីនោះ ឈ្មោះវិភង្គប្បករណៈ ធាតុកថាបករណៈ បុគ្គលប្បញ្ញត្តិ-ប្បករណៈ កថាវត្ថុប្បករណៈ យមកប្បករណៈ បន្ទាប់អំពីនោះ ក៏ពិចារណាមហាបដ្ឋានប្បករណៈ ។

កាលចិត្តរបស់ព្រះអង្គ ឈមចុះក្នុងបដ្ឋានដ៏ល្អិតសុខុម ក្នុងព្រះអភិធម្មនោះ បីតិក៏កើតឡើង ។ កាលបីតិកើតឡើង ព្រះលោហិតក៏ថ្លា កាលព្រះលោហិតថ្លា ព្រះឆវីក៏ផូរផង់ កាលព្រះឆវីផូរផង់ ព្រះរស្មីទំហំប៉ុនផ្ទះកំពូលក៏ផ្សាយឡើងអំពីព្រះវរកាយចំណែកខាងមុខ ភ្លឺទៅរហូតអនន្តចក្រវាល ក្នុងទិសខាងកើត ដូចដីរឆទន្តស្ទុះទៅក្នុងអាកាស ។ ព្រះរស្មីផុសឡើងអំពីព្រះកាយចំណែកខាងព្រះបិដ្ឋិផ្សាយទៅកាន់ទិសខាងលិច ផុសឡើងអំពីព្រះអង្សាស្តាំផ្សាយទៅទិសខាងត្បូង ផុតឡើងពីព្រះអង្សាឆ្វេង ផ្សាយទៅរហូតអនន្ត-

ចក្រវាលទិសខាងជើង ។ ព្រះរស្មីមានពណ៌ដូចពន្លកនៃកែវប្រពាល ក៏ចេញអំពីផ្ទៃព្រះបាត ទម្លុះមហាប្រឹថពី ញែកទឹកជា ២ ចំណែក ទម្លាយទាំងគំនរខ្យល់ទៅ រហូតអជដាកាស កម្រងព្រះរស្មីពណ៌ខៀវ ដូចកម្រងកែវមណីវិលចៀលច្នាត់ ផុសឡើងអំពីព្រះសីសៈ ទម្លុះទេវលោក ៦ ជាន់ រំលងព្រហ្មលោក ៩ ជាន់ ទៅរហូតដល់អជដាកាស ថ្ងៃនោះ ពួកសត្វមិនមានប្រមាណ ក្នុងចក្រវាឡជាអនន្ត ក៏នាំគ្នាមានពណ៌ដូចមាសទាំងអស់ ។ ថ្ងៃនោះ ព្រះរស្មីទាំងនោះដែលផ្សាយចេញអំពីព្រះសរីរៈ ក៏ប្រព្រឹត្តទៅរហូតអនន្តលោកធាតុ រហូតដល់សព្វថ្ងៃនេះ ។

ព្រះមានព្រះភាគ ប្រថាប់គង់ក្នុងអជបាលនិគ្រោធ អស់មួយសប្តាហ៍ដោយប្រការយ៉ាងនេះហើយ បន្ទាប់អំពីនោះ ក៏ប្រថាប់គង់ក្នុងមុច្ចលិន្ទអស់មួយសប្តាហ៍ទៀត ។ គ្រាន់តែព្រះមានព្រះភាគប្រថាប់គង់ប៉ុណ្ណោះ មហាមេឃពុំដូកាលក៏ធ្លាក់ចុះមក ធ្វើឲ្យឱកាសសកលចក្រវាលជោកជាំទូទៅ ។ បានឮថា មហាមេឃដូច្នោះ ធ្លាក់ក្នុងកាលទាំង ២ ប៉ុណ្ណោះ គឺក្នុងកាលនៃស្តេចចក្រពត្តិ ឬព្រះពុទ្ធកើតឡើង មហាមេឃនោះកើតក្នុងពុទ្ធកាលនេះ ។ កាលមហាមេឃនោះកើតឡើងហើយ ស្តេចនាគឈ្មោះមុច្ចលិន្ទ ក៏ត្រិះរិះថា ភ្លៀងនេះកើតឡើង កាលព្រះសាស្តាយាងចូលមកកាន់ទីកន្លែងរបស់អញ ព្រះអង្គគួរតែបានអាគារសម្រាប់បាំងភ្លៀង ។ ស្តេចនាគនោះ ត្រិះរិះថា អញអាចនិម្មិតប្រាសាទជារតនៈ ៧ ប្រការ តែធ្វើយ៉ាងនោះ ក៏មិនមានផលច្រើនណ្ហើយចុះ អញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ដោយការថ្វាយដល់ព្រះទសពល

ហើយទើបពង្រីកអត្តភាពឲ្យធំ យករង្វេលព័ទ្ធជុំវិញព្រះសាស្តា ៧ ជាន់ យកពពារបាំងខាងលើ ។ ឱកាសខាងក្នុងរង្វេល មានទំហំប៉ុនលោហប្រាសាទ ។ ស្តេចនាគមានអធ្យាស្រ័យបង្អោនទៅថា ព្រះសាស្តានឹងប្រថាប់នៅតាមឥរិយាបថដែលទ្រង់ត្រូវការ ។ ព្រោះដូច្នោះ ទើបព័ទ្ធឱកាសដ៏ធំយ៉ាងនេះ រៀបចំបល្ល័ង្កត្រង់កណ្តាល មានពិតានសំពត់ មានកម្រងគ្រឿងក្រអូប កម្រងផ្កាវិកស្គុសស្គាយ វិចិត្រដោយផ្កាយមាសនៅខាងលើ ។ រៀបប្រទីប ប្រេងក្រអូប មានពន្លឺទាំង ៤ ទិស តាំងជន្ទាប់ខ្លឹមចន្ទន៍ក្នុងទិសទាំង ៤ ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ក្នុងមុច្ចលិន្ទនោះអស់មួយសប្តាហ៍ ដោយអាការយ៉ាងនោះ បន្ទាប់អំពីនោះ ប្រថាប់គង់ក្នុងរាជាយតនព្រឹក្ស គឺដើមកែសអស់មួយសប្តាហ៍ទៀត ។ ក្នុងសប្តាហ៍ទី ៨ បន្ទាប់ពីរាជាយតនព្រឹក្ស ទ្រង់ទំពាឈើស្ទន់ និងឱសថសម៉ ដែលទេវរាជនាំមកថ្វាយ ទ្រង់ខ្ពុរព្រះឱស្ឋហើយ កាលស្តេចចតុលោកបាលបង្អោនបាត្រថ្ម មានតម្លៃពិសេសថ្វាយ ក៏សោយបិណ្ឌបាតរបស់តបុស្សៈ និងភល្លិកពាណិជបងប្អូន ទ្រង់ត្រឡប់មកប្រថាប់គង់ក្នុងអជបាលនិគ្រោធទៀត ទ្រង់កើតបរិវិតក្កនេះ ដែលព្រះពុទ្ធគ្រប់អង្គទ្រង់ក៏ធ្លាប់បរិវិតក្កមកហើយ ។

បណ្តាបទទាំងនោះ បទថា **បណ្ឌិតោ** បានដល់ បុគ្គលប្រកបដោយភាពជាអ្នកឈ្លាស ។ បទថា **ព្យត្តោ** បានដល់ ប្រកបដោយភាពឈ្លាសវៃ ។ បទថា **មេធាវី** បានដល់ អ្នកប្រកបដោយបញ្ញាសមគួរដល់ឋានៈ ។ បទថា **អប្បរជក្ខជាតិកោ** គឺសត្វបរិសុទ្ធ អស់កិលេស ព្រោះសង្កត់បានដោយ

សមាបត្តិ ។ បទថា **អាជានិស្សតិ** គឺកំណាត់ជីង ចាក់ថ្នុះ ។ បទថា **ញាណាញ្ច បន មេ** បានដល់ ព្រះសព្វញ្ញុតញ្ញាណកើតឡើងដល់តថាគត ។ បានឮថា ព្រះមានព្រះភាគ ទ្រង់មិនជាក់ព្រះទ័យ តាមពាក្យដែលទេវតាទូល ប៉ុណ្ណោះទេ ទ្រង់ពិចារណាមើលដោយព្រះអង្គឯង ដោយព្រះសព្វញ្ញុតញ្ញាណ ទ្រង់ក៏ជ្រាបថា អាឡារតាបសកាលាមគោត្រមរណកាពបាន ៧ ថ្ងៃ រាប់អំពីថ្ងៃនេះ កើតក្នុងអាកិញ្ចញ្ញាយតនកពហើយ ។ ព្រះមានព្រះភាគទ្រង់សំដៅដល់អត្ថនោះ ទើបត្រាស់ថា **ញាណាញ្ច បន មេ ឧស្សនំ ឧទចាទិ** ដូច្នេះ ។ បទថា **មហាជានិយោ** គឺឈ្មោះថា **មហាជានិយ** ព្រោះមានការវិនាសធំ ព្រោះជាអ្នកវិនាសចាកមគ្គផល ដែលគប្បីសម្រេចរវាង ៧ ថ្ងៃ ។ អាឡារ-តាបសកាលាមគោត្រនោះ ក៏មិនមានសោតបសាទដែលអាចស្តាប់ធម៌ ដែលព្រះអង្គយាងទៅសម្តែងប្រោស ព្រោះលោកកើតក្នុងអខណៈ សូម្បីបទដែលទាញមកឋានៈនៃព្រះធម្មទេសនានេះ ក៏មិនមាន ដោយហេតុនោះ ទើបទ្រង់សម្តែងថា **មហាជានិយោ ជាតោ** កើតការវិនាសធំ ដូច្នេះ ។ បទថា **អភិទោសកាលកតោ** គឺធ្វើកាលកិរិយាហើយ អំពីកណ្តាលយប់ ។ បទថា **ញាណាញ្ច បន មេ** បានដល់ ព្រះសព្វញ្ញុតញ្ញាណដែលកើតឡើងដល់តថាគត ។ បានឮថា ព្រះមានព្រះភាគ ទ្រង់មិនជាក់ព្រះហឫទ័យតាមពាក្យរបស់ទេវតា ទ្រង់រំពឹងមើលដោយសព្វញ្ញុតញ្ញាណ ក៏ទ្រង់ឃើញថា ឧទ្ទក-តាបសរាមបុត្រធ្វើកាលកិរិយាតាំងពីកណ្តាលយប់ម្សិលមិញនេះ កើតក្នុងនេវ-សញ្ញានាសញ្ញាយតនភព ។ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ ពាក្យ

ដ៏សេសក៏ដូចន័យដំបូងនោះឯង ។ បទថា **ពហុការា** ប្រែថា មានឧបការៈច្រើន ។ បទថា **បធានបហិតត្តំ ឧបដ្ឋហឹសុ** សេចក្តីថា ពួកបញ្ចវគ្គិយភិក្ខុបម្រើតថាគត កាលតាំងសេចក្តីព្យាយាម ដោយការបោសបរិវេណ ដោយការកាន់បាត្រ ចីវរជាប់តាមទៅ និងការឲ្យទឹកខ្ពុរមាត់ ឈើស្ទន់ជាដើម ។

បុគ្គលណា ឈ្មោះបញ្ចវគ្គិយនោះ ។ គឺព្រាហ្មណ៍ ៨ នាក់ ដែលទាយព្រះសុបិន និងទាយព្រះលក្ខណៈ ក្នុងកាលដែលពោធិសត្វប្រសូត តាមគាថាពន្ធថា

**រាមោ ធជោ លក្ខណោ ជោតិមន្តី**
**យញ្ញោ សុភោជោ សុយាមោ សុទត្តោ**
**ឯតេ តទា អដ្ឋ អហេសុ ព្រាហ្មណា**
**ឆឡង្គវា មន្ត វិយាករឹសុ ។**

គ្រានោះ មានព្រាហ្មណ៍ ៨ នាក់ គឺរាមៈ ធជៈ លក្ខណៈ ជោតិមន្តីយញ្ញៈ សុភោជៈ សុយាមៈ សុទត្តៈ ប្រើឆឡង្គវមន្តព្យាករ ។

បណ្តាព្រាហ្មណ៍ ៨ នាក់នោះ ព្រាហ្មណ៍ ៣ នាក់ ព្យាករជា ២ គតិថា បុគ្គលប្រកបដោយលក្ខណៈដូច្នេះ បើនៅគ្រប់គ្រងផ្ទះ ក៏នឹងបានជាស្តេចចក្រពត្តិ បេញបួស ក៏នឹងបានត្រាស់ជាព្រះពុទ្ធ ។ ព្រាហ្មណ៍ ៥ នាក់ព្យាករគតិតែមួយថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ មិនមែនគ្រប់គ្រងផ្ទះឡើយ នឹងត្រាស់ជាព្រះពុទ្ធតែម្យ៉ាង ។ បណ្តាព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍ ៣ ដំបូង កាន់តាមបទមន្ត ។ ឯព្រាហ្មណ៍ ៥ នាក់នេះ ឈានកន្លងបទមន្ត ។

ទើបពួកព្រាហ្មណ៍ទាំងនោះ លះបង់វង្វាន់ពេញភាជនៈដែលខ្លួនបានមក ដល់ពួកញាតិ អស់សេចក្តីសង្ស័យថា មហាបុរសនេះ នឹងមិននៅគ្រប់គ្រងផ្ទះ នឹងបានត្រាស់ជាព្រះពុទ្ធដោយចំណែកមួយ ទើបបួសជាសមណៈ ឧទ្ទិសដល់ព្រះពោធិសត្វ ។ អាចារ្យពួកខ្លះពោលថា អ្នកដែលបួស ជាកូនរបស់ព្រាហ្មណ៍ទាំងនេះដូច្នេះក៏មាន ។ ពាក្យនោះអដ្ឋកថាជំទាស់ហើយ ។ បានឮថា ព្រាហ្មណ៍ ៥ នាក់នោះ វេលានៅជាកំលោះ ចេះមន្តច្រើន ព្រោះដូច្នោះ ទើបព្រាហ្មណ៍ទាំងនោះនៅក្នុងឋានៈជាអាចារ្យ ។ ក្រោយមក ព្រាហ្មណ៍ទាំងនោះគិតគ្នាថា ពួកយើងមិនអាចកាត់បុគ្គលដែលជាបុត្រកិរិយាបួសបាន ទើបបួសក្នុងវេលាដែលជាកំលោះនោះឯង ប្រើប្រាស់សេនាសនៈដែលគួររីករាយ នាំគ្នាត្រាច់ទៅ ។ លុះចំណេរតមក សួរគ្នាថា អាវុសោ ព្រះមហាបុរសចេញបួសហើយឬ ។ មនុស្សទាំងឡាយពោលថា ពួកលោកនឹងជួបព្រះមហាបុរសបានក្នុងទីណា ទ្រង់សោយសម្បត្តិដូចទេវតា នៅក្នុងកណ្តាលស្រីរបាំ ៣ ពួក លើប្រាសាទ ក្នុងរដូវទាំង ៣ ព្រាហ្មណ៍ទាំង ៥ នាក់ គិតថា ញាណរបស់ព្រះមហាបុរសមិនទាន់ចាស់ក្លា ហើយនាំគ្នាខ្វល់ខ្វាយតិច ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ថា បញ្ចវគ្គិយមានឧបការៈដល់តថាគតច្រើន ព្រះអង្គទ្រង់សម្តែងធម៌ដល់ពួកបុគ្គលមានឧបការៈប៉ុណ្ណោះ ទ្រង់មិនសម្តែងធម៌ដល់ពួកបុគ្គលដែលមិនមានឧបការៈឬ ឆ្លើយថា មិនមែនទ្រង់មិនសម្តែងទេ សេចក្តីពិត ព្រះអង្គទ្រង់ប្រមើលមើលអាឡារតាបសកាលាមគោត្រ និងឧទ្ទកតាបសរាមបុត្រដោយការសន្សំបារមី ។ តែ

បើវៀរអញ្ញាកោណ្ឌញ្ញៈចេញ ក៏មិនមានអ្នកអាចធ្វើឲ្យជាក់ច្បាស់ នូវធម៌បាន មុនក្នុងពុទ្ធក្ខេត្ត ។ ព្រោះហេតុអ្វី ព្រោះព្រះអញ្ញាកោណ្ឌញ្ញៈ មានឧបនិស្ស័យ ៣ យ៉ាង ។ បានឮថា ក្នុងជាតិមុន មានបងប្អូន ២ នាក់ ក្នុងវេលាបំពេញបុណ្យ បុរសជាបងគិតនឹងថ្វាយទានស្រូវដ៏ប្រសើរ ៩ ដងក្នុងមួយរដូវ បុរសនោះក៏ថ្វាយទាននូវគ្រាប់បាយដ៏ប្រសើរ ក្នុងវេលាព្រោះ ក្នុងវេលាស្រូវមានដង្ហើម ក៏ប្រឹក្សានឹងប្អូនថា ប្អូនអើយ ពេលស្រូវផើម បងនឹងហែកស្រូវថ្វាយទាន ។ បុរសជាប្អូនប្រាប់ថា បងធ្វើសន្ទូងឲ្យវិនាសឬ ។ បុរសជាបងដឹងថា ប្អូនមិនយល់ព្រម ក៏ចែកស្រែគ្នា ហែកដង្ហើមស្រូវអំពីស្រែចំណែករបស់ខ្លួន ប្របាច់យកទឹកដោះ ចម្អិនជាមួយសប្បិ និងទឹកអំពៅថ្វាយទាន ។ ក្នុងវេលាដែលជាអំបុក ក៏ឲ្យធ្វើអំបុកដ៏ប្រសើរថ្វាយទាន ក្នុងវេលាប្រូត ក៏ឲ្យធ្វើស្រូវដែលប្រូតដ៏ប្រសើរថ្វាយទាន ក្នុងវេលាធ្វើចំណង ក៏ឲ្យធ្វើស្រូវចំណងដ៏ប្រសើរឲ្យទាន វេលាធ្វើជាកណ្តាប់ ក៏ធ្វើស្រូវកណ្តាប់ដ៏ប្រសើរឲ្យទាន ក្នុងវេលាជញ្ជូនចូលលាន ក៏ឲ្យទានដ៏ប្រសើរ ក្នុងវេលាបោកបែនក៏ឲ្យទានដ៏ប្រសើរ ក្នុងវេលាជញ្ជូនដាក់ជង្រុកក៏ឲ្យទានដ៏ប្រសើរ គឺឲ្យទាន ៩ ដង ក្នុងវេលាមួយរដូវ ដូចពោលមកនេះ ។ ឯបុរសជាប្អូនអស់រដូវស្រែហើយ ទើបថ្វាយទាន ។ ទាំង ២ នាក់នោះ បុរសជាបង គឺព្រះអញ្ញាកោណ្ឌញ្ញៈ បុរសជាប្អូន គឺសុភទ្ទបរិព្វាជក ។ វៀរព្រះថេរៈចេញ ក៏មិនមានបុគ្គលដទៃ ដែលអាចធ្វើឲ្យជាក់ច្បាស់នូវធម៌បានមុន ព្រោះលោកថ្វាយអគ្គទាន ៩ ដង ក្នុងមួយរដូវ ។ បទថា **ពហុការា ខោ មេ បញ្ចវគ្គិយា**

នេះ ត្រឹមតែត្រាស់ដោយការរឭកដល់ឧបការៈប៉ុណ្ណោះ ។

បទថា **ឥសិបតនេ មិគទាយេ** សេចក្ដីថា បានឮថា ក្នុងប្រទេសនោះ កាលមុនពុទ្ធុប្បាទកាល ព្រះបច្ចេកពុទ្ធទាំងឡាយ អាស្រ័យនៅដោយនិរោធសមាបត្តិអស់មួយសប្ដាហ៍ ត្រង់ភ្នំគន្ធមាទន៍ ចេញអំពីនិរោធសមាបត្តិហើយ ទំពាឈើស្ទន់ ឈ្មោះនាគលតា ( ម្ទូរព្រៃ ) ខ្ពុរមាត់ត្រង់អនោតត្តស្រះ កាន់បាត្រ ចីវរ ហោះទៅហើយ ចុះស្លៀកដណ្ដប់ចីវរក្នុងទីនោះ ហើយត្រាច់ទៅបិណ្ឌបាតក្នុងព្រះនគរ ឆាន់ស្រេចហើយ ដល់ពេល ក៏ហោះអំពីទីនោះទៅ ។ ឥសីទាំងឡាយចុះ និងចូលទៅក្នុងទីនោះ ហេតុនោះ ទើបទីនោះ ឈ្មោះថា **ឥសិបតន** ( ព្រៃធ្លាក់ឥសី ) ឯដែលហៅថា **មិគទាយ** ព្រោះឲ្យអភ័យដល់ម្រឹគទាំងឡាយ ដោយហេតុនោះ ទើបលោកហៅថា **ឥសិបតនេ មិគទាយេ** ។

[ ៦៣ ] បទថា **អន្តរា ច គយំ អន្តរា ច ពោធឹ** បានដល់ ក្នុងទីចន្លោះ ៣ គាវុត ក្នុងឱកាសរបស់តំបន់គយា និងពោធិព្រឹក្ស ។ តាំងអំពីពោធិមណ្ឌលដ្ឋាន ដល់តំបន់គយា ៣ គាវុត ក្រុងពារាណសី ១៨ យោជន៍ ។ ឧបកាជីវក បានឃើញព្រះមានព្រះភាគ ចន្លោះពោធិមណ្ឌលដ្ឋាន និងតំបន់គយា តែព្រោះប្រកបដោយ **អន្តរា** សព្ទ ទើបលោកធ្វើជាទុតិយាវិភត្តិ ។ តែក្នុងទីនេះ អ្នកអក្ខរសាស្ត្រប្រកប **អន្តរា** សព្ទ តែម្យ៉ាងប៉ុណ្ណោះថា **អន្តរា គាមញ្ច នទិញ្ច យាតិ** នៅចន្លោះស្រុក និងស្ទឹង **អន្តរា** សព្ទនោះ ក៏ប្រកបដោយបទទី ២ កាលមិនប្រកប ក៏មិនដល់ទុតិយាវិភត្តិ តែក្នុងទីនេះ លោក

ប្រកបហើយ ទើបបានពោលយ៉ាងនេះ ។

បទថា **អទ្ធានមគ្គប្បដិបន្នំ** សេចក្តីថា ដើរផ្លូវដែលរាប់ថា ឆ្ងាយ អធិប្បាយថា ដើរផ្លូវវែង ។ ពិតហើយ សម័យដែលដើរផ្លូវឆ្ងាយ សូម្បី កន្លះយោជន៍ ក៏ឈ្មោះថា ផ្លូវឆ្ងាយ ព្រោះព្រះបាលីក្នុងវិភង្គពោលថា គប្បី ធាន់ហើយ ដោយគិតនឹងដើរផ្លូវកន្លះយោជន៍ជាដើម តាំងអំពីពោធិមណ្ឌល ដល់តំបន់គយា ផ្លូវ ៣ គាវុត ។ បទថា **សព្វាភិភូ** បានដល់ គ្របសង្កត់ ផ្លូវ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ តាំងនៅ ។ បទថា **សព្វវិទូ** សេចក្តីថា បានដឹង បានដល់ត្រាស់ដឹងទូទៅ ដល់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ។ បទថា **សព្វេសុ ធម្មេសុ អនូបលិត្តោ** បានដល់ មិនជាប់ ព្រោះអស់កិលេសក្នុងធម៌ដែលទៅក្នុងភូមិទាំង ៣ ។ បទថា **សព្វញ្ជហោ** បានដល់ លះធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ តាំងនៅ ។ បទថា **តណ្ហក្ខយេ វិមុត្តោ** បានដល់ ផុតចាកអារម្មណ៍ក្នុងព្រះនិព្វាន ជាទីអស់ តណ្ហា ។ បទថា **សយំ អភិញ្ញាយ** បានដល់ ដឹងធម៌ដែលប្រព្រឹត្តទៅក្នុង ភូមិ ៤ ទាំងអស់ ដោយខ្លួនឯង ។ បទថា **កមុទ្ទិសេយ្យំ** សេចក្តីថា តថាគត គប្បីលើកបុគ្គលដទៃណាថា បុគ្គលនេះជាអាចារ្យរបស់តថាគត ។ បទថា **ន មេ អាចរិយោ អត្ថិ** សេចក្តីថា តថាគតមិនមានអាចារ្យក្នុង លោកុត្តរធម៌ ។ បទថា **នត្ថិ មេ បដិបុគ្គលោ** សេចក្តីថា មិនមានបុគ្គល ដែលអាចប្រៀបធៀបនឹងតថាគត ។ បទថា **សម្មាសម្ពុទ្ធោ** បានដល់ ត្រាស់ ដឹងឯងនូវសច្ចៈ ៤ ដោយប្រពៃ ដោយហេតុ ដោយន័យ ។ បទថា **សីតិ-**

**ភូតោស្មិ** ឈ្មោះថា ជាអ្នកត្រជាក់ ព្រោះរម្ងាប់ភ្លើង គឺកិលេស មិនមានសេសសល់ ឈ្មោះថា រលត់ ព្រោះកិលេសទាំងឡាយរលត់ទៅ ។ បទថា **កាសិនំ បុរំ** បានដល់ នគរក្នុងដែនកាសី ។ បទថា **អាហញ្ញឹ អមតទុន្ទុភឹ** សេចក្ដីថា ដើរផ្លូវបំណាងនឹងទូងអមតភេរី ដើម្បីឲ្យសត្វបានធម្មចក្ខុ ។ បទថា **អរហាសិ អនន្តជិនោ** បានដល់ ព្រះអង្គគួរបានជាអនន្តជិនៈឬ ។ បទថា **ហុវេយ្យាវុសោ** សេចក្ដីថា ឧបកាជីវកពោលថា អាវុសោ គប្បីមានឈ្មោះយ៉ាងនោះឬ ។ បទថា **បក្កាមិ** បានដល់ បានទៅកាន់ជនបទ ឈ្មោះវង្កហារ ។

## រឿង ឧបកាជីវក

ក្នុងជនបទនោះ ឧបកាជីវក នៅអាស្រ័យភូមិព្រានម្រឹគ ។ ប្រធាននៃព្រានទំនុកបម្រុងគាត់ ។ ក្នុងជនបទនោះ មានអ្នកប្រមង់កាច ឲ្យឧបកាជីវកនៅដោយកាជនៈមួយប៉ុណ្ណោះ ។ ព្រានម្រឹគទៅបាញ់សត្វក្នុងទីឆ្ងាយ ទើបប្រាប់កូនស្រីឈ្មោះនាវា[1] ថា កុំប្រមាទក្នុងព្រះអរហន្តរបស់ពួកយើង ហើយទៅជាមួយកូនប្រុសៗ ដែលជាបង ។ ធីតារបស់ព្រាននោះ មានរូបឆោមគួរសរសើរ បរិបូណ៌ដោយទ្រង់ទ្រាយដ៏ល្អ ។ ថ្ងៃស្អែកឡើង ឧបកៈមកផ្ទះជួបស្រីនោះ ចូលមកធ្វើការប្រតិបត្តិគ្រប់យ៉ាង កើតសេចក្ដីស្រឡាញ់ដ៏ពេញកម្លាំង មិនអាចបរិភោគ កាន់យកភោជនាហារទៅលំនៅ ដាក់អាហារក្នុងចំណែកម្ខាង គិតថា បើអញបាននាងនាវា ទើបមានជីវិត បើមិនបាន ក៏នឹងស្លាប់បង់ ហើយដេកអត់អាហារ ។ ថ្ងៃទី ៧ នាយព្រានត្រឡប់មក សួររឿង

---

១- ក្នុងទីខ្លះថា ចាវា ។

ឧបកៈនឹងធីតា ។ ធីតាប្រាប់ថា គាត់មកតែមួយថ្ងៃប៉ុណ្ណោះ ហើយមិនឃើញមកទៀត ។ នៅសម្លៀកបំពាក់ដែលមកអំពីព្រៃនោះឯង នាយព្រានប្រាប់ធីតាថា ពុកនឹងចូលទៅសួរគាត់មើល ហើយទៅភ្លាម ចាប់ជើងសួរថា នែលោកម្ចាស់ មិនសប្បាយរឿងអ្វី ។ ឧបកៈដកដង្ហើមប្រមៀលទៅមក ។ នាយព្រានពោលថា លោកម្ចាស់ប្រាប់មកចុះ ខ្ញុំអាចធ្វើបាន ក៏នឹងធ្វើគ្រប់យ៉ាង ។ ទើបឧបកៈប្រាប់ថា បើខ្ញុំបាននាងនាវា ទើបមានជីវិតនៅ បើមិនបានក៏នឹងស្លាប់ក្នុងទីនេះឯង ប្រសើរជាង ។ នាយព្រានសួរថា លោកម្ចាស់ចេះសិប្បៈណាមួយដែរឬ ឧបកៈឆ្លើយថា ខ្ញុំមិនចេះឡើយ ។ នាយព្រានពោលថា បើមិនចេះសិប្បៈណាមួយ នឹងនៅគ្រប់គ្រងផ្ទះបានឬ ។ ទើបឧបកៈពោលថា ខ្ញុំមិនចេះសិប្បៈក៏ពិត តែខ្ញុំអាចជាអ្នករែកសាច់របស់អ្នកលក់ដូរបាន ។ នាយព្រានគិតថា ឧបកៈពេញចិត្តកិច្ចការនេះរបស់អញ ទើបឲ្យសំពត់ស្លៀកមួយផ្ទាំង នាំទៅផ្ទះ ប្រគល់កូនស្រីឲ្យ ។ អាស្រ័យការនៅរួមនៃជនទាំង ២ រូប ក៏បានកូនប្រុសម្នាក់ ។ ទើបពីរនាក់ប្តីប្រពន្ធតាំងឈ្មោះកូននោះថា សុភទ្ទ ។ ពេលកូនយំ នាងពោលថា ឱ អាកូនអ្នករែកសាច់ កូនព្រានម្រឹគ កុំយំ ដូច្នេះជាដើម ដើម្បីចំអកឧបកៈ ដោយចម្រៀងបំពេរកូន ឧបកៈពោលថា នែហាងមានរូបស្អាត ហាងយល់ថា អញមិនមានទីពឹងឬ អញមានសម្លាញ់ម្នាក់ ឈ្មោះអនន្តជិនៈ អញនឹងទៅកាន់សម្នាក់របស់លោក ។ នាងនាវាដឹងថា ប្តីឈឺចិត្តដោយអាការយ៉ាងនេះ ទើបពោលរឿយៗ ។ ថ្ងៃមួយ ឧបកៈនោះមិនលា ក៏បែរមុខទៅកាន់មជ្ឈិមប្រទេស ។

សម័យនោះ ព្រះមានព្រះភាគ ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ នាក្រុងសាវត្ថី ទ្រង់ប្រាប់ភិក្ខុទាំងឡាយជាមុនថា ម្នាលភិក្ខុទាំងឡាយ បើអ្នកណាមកសួររកអនន្តជិនៈ ពួកអ្នកចូរបង្អួលប្រាប់ដល់បុគ្គលនោះ ។ សូម្បីជីវកក៏សួររឿយៗ មកថា អនន្តជិនៈនៅទីណា មកដល់ក្រុងសាវត្ថីតាមលំដាប់ឈរត្រង់កណ្តាលវិហារ សួរថា អនន្តជិនៈនៅឯណា ។ ភិក្ខុទាំងឡាយក៏នាំទៅកាន់សម្នាក់ព្រះមានព្រះភាគ ។ ឧបកៈនោះ ឃើញព្រះមានព្រះភាគ ទូលសួរថា បពិត្រព្រះមានព្រះភាគ ព្រះអង្គចាំខ្ញុំបានឬទេ ។ ព្រះមានព្រះភាគត្រាស់ថា អើ ឧបកៈ តថាគតចាំបាន អ្នកនៅឯណា ។ ឧបកៈទូលថា វង្កហារជនបទ ។ ព្រះមានព្រះភាគត្រាស់ថា ឧបកៈ អ្នកចាស់ហើយ អ្នកបួសបានឬ ។ ឧបកៈទូលថា បួសបានព្រះអង្គ ។ ព្រះមានព្រះភាគឲ្យបួសប្រទានកម្មដ្ឋានដល់ឧបកៈ ។ ឧបកៈនោះធ្វើកិច្ចក្នុងកម្មដ្ឋាន តាំងនៅក្នុងអនាគាមិផល ធ្វើកាលកិរិយាហើយ កើតក្នុងសុទ្ធាវាសជាន់អវិហា ហើយសម្រេចអរហត្តក្នុងខណៈដែលកើតនោះឯង ។ ពិតហើយ ជន ៧ នាក់គ្រាន់តែកើតក្នុងសុទ្ធាវាសជាន់អវិហាប៉ុណ្ណោះ ក៏សម្រេចព្រះអរហត្ត ។ ក្នុងចំនួន ៧ នាក់ ក៏មានឧបកៈម្នាក់ដែរ ។ សមដូចពាក្យលោកពោលដូច្នេះថា

> ភិក្ខុ ៧ រូប រួចផុតហើយ អស់រាគៈ ទោសៈហើយ ឆ្លង
> កិលេសដែលបន្សាត់ទៅក្នុងលោក ចូលដល់សុទ្ធាវាស-
> ព្រហ្ម ជាន់អវិហា គឺបុគ្គល ៣ នាក់ បានដល់ ឧបកៈ
> បឡគណ្ឌៈ បុក្កុសាតិ និងបុគ្គល ៤ នាក់ទៀត គឺភទ្ទិយៈ

ខណ្ឌទេវៈ ពាហុទត្តិ និងបិង្គិយៈ ទាំង ៧ នាក់នោះ
លះបង់នូវរាងកាយមនុស្សហើយ ចូលដល់កាយជាទិព្វ ។

បទថា **សណ្ឋបេសុំ** បានដល់ ធ្វើកតិកា ។ បទថា **ពាហុល្លិកោ** បានដល់ បដិបត្តិដើម្បីប្រយោជន៍ដល់ការប្រាថ្នាច្រើនក្នុងចីវរជាដើម ។ បទថា **បធានវិព្ភន្តោ** បានដល់ វិនាសចាកសេចក្តីព្យាយាម ។ បទថា **អាវត្តោ ពាហុល្លាយ** បានដល់ វិលមកដើម្បីត្រូវការចីវរច្រើនៗ ជាដើម ។ បទថា **អបិច ខោ អាសនំ បឋេតព្វំ** សេចក្តីថា បញ្ចវគ្គិយពោលថា គប្បីក្រាលត្រឹមតែអាសនៈទុកសម្រាប់លោក ដែលកើតក្នុងត្រកូលខ្ពស់ ។ បទថា **នាសក្ខឹសុ** សេចក្តីថា បញ្ចវគ្គិយត្រូវអានុភាពអំណាចរបស់ព្រះសម្ពុទ្ធគ្របសង្កត់ ទើបតាំងនៅក្នុងកតិការបស់ខ្លួនមិនបាន ។ បទថា **នាមេន ច អាវុសោ វាទេន ច សមុទាចរន្តិ** សេចក្តីថា ហៅថា គោតម ហៅថា អាវុសោ អធិប្បាយថា ពោលពាក្យបែបនេះថា អាវុសោគោតម កាលដែលលោកបំពេញព្យាយាមក្នុងឧរុវេលា ពួកខ្ញុំជួយកាន់បាត្រ ចីវរ ត្រាច់ទៅ ឲ្យទឹកខ្ពុរព្រះឱស្ឋ និងឈើស្ទន់ បោសបរិវេណដែលជាទីលំនៅ ក្រោយមក អ្នកណាធ្វើវត្តបដិបត្តិដល់លោក ក្នុងកាលដែលពួកយើងចៀសចេញទៅ លោកមិនគិតខ្វះទេឬ ។ បទថា **ឥរិយាយ** បានដល់ ដោយការប្រព្រឹត្តទៅដែលធ្វើបានលំបាក ។ បទថា **បដិបទាយ** បានដល់ ដោយបដិបត្តិដែលធ្វើបានលំបាក ។ បទថា **ទុក្ករការិកាយ** បានដល់ ដោយអាការដែលធ្វើបានលំបាក មានសោយអាហារដោយសណ្តែកបាយមួយទូកដៃ ឬកន្លះទូកដៃ

ជាដើម ។ បទថា **អភិជានាថ មេ នោ** បានដល់ ពួកអ្នកធ្លាប់ដឹងដល់ពាក្យដែលតថាគតពោលនេះឬ ។ បទថា **ឯវរូបំ ភាសិតមេតំ** សេចក្តីថា បន្ទីវាចាបែបនេះ អធិប្បាយថា អ្នកមានអាយុ តថាគតមកពេលយប់ ឬពេលថ្ងៃ ដើម្បីសង្គ្រោះអនុគ្រោះអ្នក កុំត្រិះរិះឡើយក្នុងការបំពេញព្យាយាម ក្នុងឱវុវេលា ឱកាស ឬនិមិត្តប្រាកដដល់តថាគត ព្រោះដូច្នោះ ទើបបានពោលពាក្យខ្លះបែបនេះ ។ បញ្ចវគ្គិយណាបានសតិ ដោយព្រះតម្រាស់មួយបទប៉ុណ្ណោះ កើតសេចក្តីគោរពជឿថា ណ្ហើយចុះ បុគ្គលនេះ ជាព្រះពុទ្ធដោយពិត ហើយពោលថា **នោ ហេតំ ភន្តេ** ពាក្យនោះមិនធ្លាប់បានឮទេព្រះអង្គ ។ បទថា **អសក្ខិ ខោ អហំ ភិក្ខវេ បញ្ចវគ្គិយេ ភិក្ខូ សញ្ញាបេតុំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតអាចធ្វើឲ្យបញ្ចវគ្គិយភិក្ខុដឹងថា តថាគតជាព្រះពុទ្ធ ជាព្រះអរហន្ត ។ កាលនោះ ព្រះមានព្រះភាគយាងមកក្នុងថ្ងៃឧបោសថទ្រង់ធ្វើឲ្យបញ្ចវគ្គិយភិក្ខុបានដឹងតាមដែលព្រះអង្គជាព្រះពុទ្ធ ត្រាស់ធម្មចក្កប្បវត្តនសូត្រ ធ្វើព្រះកោណ្ឌញ្ញៈឲ្យជាកាយសក្ខិ ។ ក្នុងវេលាចប់ព្រះសូត្រព្រះថេរៈតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រហ្ម ១៨ កោដិ ។ ព្រះអាទិត្យនៅមិនទាន់អស្តង្គតនៅឡើយ ធម្មទេសនាក៏ចប់ហើយ ។ ព្រះមានព្រះភាគ ទ្រង់ចូលវស្សាក្នុងព្រៃឥសិបតនមិគទាយវ័ននោះឯង ។ បទថា **ទ្វេបិ សុទំ ភិក្ខវេ ភិក្ខូ ឱវទាមិ** ជាដើម ត្រាស់ដើម្បីសម្តែងការមិនយាងចូលស្រុកដើម្បីបិណ្ឌបាត តាំងអំពីថ្ងៃបាដិបទ គឺថ្ងៃ ១ រោច ។ ដើម្បីទ្រង់ជម្រះមន្ទិលក្នុងព្រះកម្មដ្ឋានរបស់ភិក្ខុទាំងឡាយនោះ ទើបព្រះមានព្រះភាគ បាននៅ

ប្រថាប់ខាងក្នុងព្រះវិហារប៉ុណ្ណោះ ។ ភិក្ខុទាំងនោះបានទៅកាន់សម្នាក់នៃព្រះមានព្រះភាគ ហើយទូលសួរដល់មន្ទិលរបស់កម្មដ្ឋាន ដែលកើតឡើងរឿយៗ ។ ចំណែកព្រះមានព្រះភាគ ទ្រង់ទៅកាន់ទីដែលភិក្ខុទាំងនោះគង់នៅ ទ្រង់បន្ទោបង់មន្ទិល ។ លំដាប់នោះ បណ្ដាបញ្ចវគ្គិយភិក្ខុនោះ ព្រះមានព្រះភាគ ទ្រង់នាំភត្តចេញទៅយ៉ាងនេះ ហើយឲ្យឱវាទព្រះវប្បត្ថេរ បានជាព្រះសោតាបន្នក្នុងថ្ងៃបាដិបទ ។ ក្នុងថ្ងៃ ២ រោច ព្រះភទ្ទិយៈ ក្នុងថ្ងៃ ៣ រោច ព្រះមហានាមក្នុងថ្ងៃ ៤ រោច ព្រះអស្សជិ ។ ក្នុងថ្ងៃ ៥ រោចនៃបក្ខ ព្រះមានព្រះភាគឲ្យបញ្ចវគ្គិយភិក្ខុទាំងនោះប្រជុំគ្នា ត្រាស់អនត្តលក្ខណសូត្រ ។ វេលាចប់ព្រះសូត្រ ភិក្ខុទាំងអស់តាំងនៅក្នុងអរហត្តផល ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អថខោ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ ។បេ។ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមំសុ** ដូច្នេះ ។ បទថា **ឥត្ថិនានិ បុព្វេវ** សេចក្ដីថា ព្រះមានព្រះភាគ បានត្រាស់សួរមគ្គណាក្នុងគ្រាមុន កាលទ្រង់សម្ដែងអនុសន្ធិដូចគ្នា ដូច្នេះថា សូម្បីពួកអ្នកក៏ឡើងកាន់ផ្លូវរបស់តថាគតនិងរបស់បញ្ចវគ្គិយ ការស្វែងរករបស់ពួកអ្នក ឈ្មោះថា **អរិយបរិយេសនា** ដូច្នេះ ទើបទ្រង់នាំកថាមគ្គ មានប្រមាណប៉ុណ្ណេះមក ។

[ ៦៥ ] ឥឡូវនេះ ព្រោះហេតុដែលស្វែងរកកាមគុណ ៥ ជា **អនរិយបរិយេសនា** របស់គ្រហស្ថទាំងឡាយ ជា **អនរិយបរិយេសនា** របស់បព្វជិត ដែលមិនពិចារណាបរិភោគបច្ច័យ ៤ ដោយអំណាចកាមគុណ ៥ ដូច្នោះ ដើម្បីទ្រង់សម្ដែងសេចក្ដីនោះ ទើបត្រាស់ថា **បញ្ចិមេ ភិក្ខវេ**

**កាមគុណា** ជាដើម ។ ក្នុងកាមគុណទាំង ៥ នោះ កាមគុណ ៤ មានរូបដែលគប្បីដឹងដោយភ្នែកជាដើម រមែងបានក្នុងបច្ច័យ ៤ មានបាត្រ និងចីវរដែលបានមកថ្មីជាដើម ។ ឯរសក្នុងកាមគុណនោះ គឺរសក្នុងការបរិភោគកាមគុណទាំង ៥ រមែងបានក្នុងបិណ្ឌបាត និងភេសជ្ជៈដែលពេញចិត្ត ។ កាមគុណ ៤ រមែងបានក្នុងសេនាសនបរិក្ខារដូចក្នុងចីវរដែរ ។ ឯរសក្នុងសេនាសនបរិក្ខារនោះ គឺរសក្នុងការបរិភោគនោះឯង ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមពាក្យថា **យេ ហិ កេចិ ភិក្ខវេ** ដូច្នេះ ព្រោះថាព្រះមានព្រះភាគ កាលទ្រង់សម្ដែងកាមគុណ ៥ យ៉ាងនេះហើយ ឥឡូវនេះដើម្បីបដិសេធពួកដែលពោលយ៉ាងនេះថា ឈ្មោះថា **អនរិយបរិយេសនា** តាំងអំពីបួស នឹងជា **អរិយបរិយេសនា** របស់បព្វជិតបានទីណា ទើបទ្រង់ផ្ដើមទេសនានេះ ដើម្បីសម្ដែងថា ការបរិភោគដោយមិនពិចារណាក្នុងបច្ច័យ ៤ ជាអនរិយបរិយេសនារបស់បព្វជិត ។ បណ្ដាបទទាំងនោះ បទថា **គធិតា** បានដល់ តម្រេកដោយការត្រេកត្រអាលព្រោះតណ្ហា ។ បទថា **មុច្ឆិតា** បានដល់ ងប់ជ្រប់ដោយអំណាចតណ្ហា ។ បទថា **អជ្ឈាបន្នា** បានដល់ ត្រូវតណ្ហាគ្របសង្កត់ហើយ ។ បទថា **អនាទីនវទស្សាវិនោ** បានដល់ មិនឃើញទោស ។ បច្ចវេក្ខណញ្ញាណ លោកហៅថា និស្សរណៈ ក្នុងបទថា **អនិស្សរណប្បញ្ញា** វៀរបច្ចវេក្ខណញ្ញាណនោះ ។

[ ៦៦ ] ឥឡូវនេះ កាលទ្រង់សម្ដែងឧបមាដែលនឹងសាធកៈអត្ថនោះ

ទើបត្រាស់ថា **សេយ្យថាបិ ភិក្ខវេ** ជាដើម ។ គប្បីជ្រាបការប្រៀបក្នុងពាក្យនោះដូច្នេះ ។ សេចក្តីថា សមណព្រាហ្មណ៍ ដូចម្រឹគក្នុងព្រៃ បច្ច័យ ៤ ដូចអន្ទាក់ដែលព្រានដាក់ក្នុងព្រៃ ក្នុងកាលដែលសមណព្រាហ្មណ៍ទាំងនោះ មិនពិចារណា បរិភោគបច្ច័យ ៤ ដូចវេលាដែលព្រាននោះដាក់អន្ទាក់ហើយដេក វេលាដែលសមណព្រាហ្មណ៍ទាំងឡាយ ត្រូវមារធ្វើតាមការពេញចិត្ត ធ្លាក់ទៅកាន់អំណាចមារ ដូចវេលាដែលកាលព្រានមក ម្រឹគទៅមិនបានតាមការពេញចិត្ត ម្យ៉ាងទៀត ការពិចារណាក្នុងបច្ច័យ ៤ ហើយបរិភោគរបស់សមណព្រាហ្មណ៍ គប្បីឃើញដូចវេលាដែលម្រឹគមិនទាន់ជាប់អន្ទាក់ ដេកសង្កត់លើអន្ទាក់ ការមិនធ្លាក់ទៅក្នុងអំណាចនៃមាររបស់សមណព្រាហ្មណ៍ គប្បីជ្រាបដូចកាលព្រានមក ម្រឹគក៏ទៅបានតាមការពេញចិត្ត ។ បទថា **វិសដ្ឋោ** បានដល់ រួចផុតអំពីការភ័យខ្លាច រួចផុតអំពីសេចក្តីសង្ស័យ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង មានអត្ថងាយយល់ទាំងអស់ហើយ ។ល។

## ចាសរាសិសូត្រ ចប់

## សូត្រទី ៦ ចប់

# សុត្តន្តបិដក

## ចូឡហត្ថិបទោបមសូត្រទី ៧

[ ៦៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ មានព្រាហ្មណ៍ម្នាក់ ឈ្មោះជាណុស្សោណិ ទឹមរថដោយសេះស សុទ្ធ បរចេញអំពីក្រុងសាវត្ថី ទាំងកំពុងថ្ងៃត្រង់ ។ ជាណុស្សោណិព្រាហ្មណ៍ បានឃើញបិលោតិកបរិព្វាជក ( បរិព្វាជកអ្នកស្លៀកសំពត់ចាស់ ) កំពុង ដើរមកអំពីចម្ងាយ លុះឃើញជាក់ហើយ ទើបសួរបិលោតិកបរិព្វាជកដូច្នេះ ថា លោកវច្ឆាយនៈដ៏ចម្រើនមកអំពីទីណា ទាំងកំពុងថ្ងៃត្រង់នេះ ។ បិលោ-តិកបរិព្វាជកឆ្លើយថា ម្នាលអ្នកដ៏ចម្រើន អាត្មាមកអំពីសំណាក់ព្រះសមណ-គោតមនេះទេតើ ។ លោកដ៏ចម្រើនដឹងថា ព្រះសមណគោតមមានប្រាជ្ញា និងសេចក្តីវាងវៃ ល្មមឲ្យហៅថា ជាបណ្ឌិតបានឬទេ ។ ម្នាលអ្នកដ៏ចម្រើន អាត្មាឯណា នឹងដឹងនូវបញ្ញា និងសេចក្តីវាងវៃរបស់ព្រះសមណគោតមបាន បើបុគ្គលណាដឹងនូវបញ្ញា និងសេចក្តីវាងវៃ របស់ព្រះសមណគោតមបាន ហើយ បុគ្គលនោះឯងនឹងប្រាកដដូចជាព្រះសមណគោតមនោះដែរ ។ ម្តេចក៏ វច្ឆាយនៈដ៏ចម្រើនពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏ ខ្ពង់ខ្ពស់ដល់ម៉្លេះ ។ ម្នាលអ្នកដ៏ចម្រើន អាត្មាខានសរសើរព្រះសមណគោតម ដូចម្តេចបាន ( ដ្បិត ) ព្រះសមណគោតមដ៏ចម្រើននោះ ប្រសើរជាងអ្នក ដែលប្រសើរ គឺប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ។ លោកវច្ឆាយនៈ

ដ៏ចម្រើន ឃើញនូវអានិសង្ស នៃប្រយោជន៍ដូចម្ដេច បានជាជ្រះថ្លាក្នុងព្រះសមណគោតមយ៉ាងនេះ ។

[ ៦៨ ] បិលោតិកបរិព្វាជកឆ្លើយថា ម្នាលអ្នកដ៏ចម្រើន អាត្មាខានជ្រះថ្លាយ៉ាងនេះក្នុងព្រះសមណគោតម ដូចម្ដេចបាន ម្នាលអ្នកដ៏ចម្រើន ដូចជាព្រានដំរីដ៏ឈ្លាស ចូលទៅកាន់ព្រៃដំរី ព្រានដំរីនោះ បានឃើញស្នាមជើងដំរីដ៏ធំ ក្នុងព្រៃដំរី ខាងបណ្ដោយក៏វែង ខាងទទឹងក៏ធំ ។ ព្រានដំរីនោះ ចូលចិត្តដូច្នេះថា ឱហ្ន៎ ដំរីធំមែន សេចក្ដីនេះយ៉ាងណា ឯអាត្មាអញបានឃើញស្នាមព្រះបាទ គឺញាណទាំង ៤ ប្រការ របស់ព្រះសមណគោតមក្នុងវេលាណាហើយ អាត្មាក៏ចូលចិត្តថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធពិត ព្រះធម៌ព្រះមានព្រះភាគត្រាស់សម្ដែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគលោកប្រតិបត្តិប្រពៃហើយ ក៏យ៉ាងនោះដែរ ។ ស្នាមព្រះបាទ គឺញាណទាំង ៤ ប្រការ តើដូចម្ដេចខ្លះ ។ ម្នាលអ្នកដ៏ចម្រើន អាត្មាបានឃើញខត្តិយ-បណ្ឌិតពួកខ្លះ ក្នុងលោកនេះ មានបញ្ញាល្អិត ញាំញីនូវវាទះរបស់បុគ្គលដទៃបាន ប្រាកដដូចជាខ្មាន់ធ្នូបាញ់នូវសរសៃសក់ ខត្តិយបណ្ឌិតទាំងនោះហាក់ដូចជាត្រាច់ទៅទម្លាយនូវទិដ្ឋិរបស់បុគ្គលដទៃ ដោយប្រាជ្ញា ( របស់ខ្លួន ) ខត្តិយ-បណ្ឌិតទាំងនោះឮដំណឹងដូច្នេះថា ព្រះសមណគោតមដ៏ចម្រើន ទ្រង់ពុទ្ធដំណើរមកដល់ស្រុកឬនិគមឯណោះ ។ ខត្តិយបណ្ឌិតទាំងនោះចងប្រស្នាដោយគិតថា ពួកយើងនឹងចូលទៅគាល់ព្រះសមណគោតម ហើយក្រាបបង្គំទូលសួរប្រស្នានេះ បើយើងក្រាបបង្គំទូលប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករ

យ៉ាងនេះ ពួកយើងនឹងលើកទោស ព្រះសមណគោតមនោះយ៉ាងនេះ បើយើងបានក្រាបបង្គំទូលសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមនោះ យ៉ាងនេះវិញ ។ ខត្តិយបណ្ឌិតទាំងនោះឮដំណឹងដូច្នេះថា ព្រះសមណគោតមដ៏ចម្រើន ទ្រង់ពុទ្ធដំណើរមកដល់ស្រុក ឬនិគមឯណោះ ។ ទើបខត្តិយបណ្ឌិតទាំងនោះ ចូលទៅគាល់ព្រះសមណគោតម ។ ព្រះសមណគោតម ទ្រង់ញុំាងខត្តិយបណ្ឌិតទាំងនោះឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ពួកខត្តិយបណ្ឌិតនោះ ដែលព្រះសមណគោតមទ្រង់ឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏មិនអាចទូលសួរប្រស្នានឹងព្រះសមណគោតមបានឡើយ នឹងលើកទោសព្រះសមណគោតមដូចម្តេចបាន តាមពិតនឹងសម្រេចទៅជាសាវ័ករបស់ព្រះសមណគោតមវិញ ។ ម្នាលអ្នកដ៏ចម្រើន ក្នុងកាលដែលខ្ញុំបានឃើញនូវស្នាមព្រះបាទទី ១ នេះ របស់ព្រះសមណគោតមហើយ ខ្ញុំក៏ចូលចិត្តថាព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធពិត ព្រះធម៌ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ ម្នាលអ្នកដ៏ចម្រើន មួយទៀត ខ្ញុំបានឃើញព្រាហ្មណបណ្ឌិតពួកខ្លះ ក្នុងលោកនេះ ។បេ។ គហបតិបណ្ឌិត ។បេ។ សមណបណ្ឌិតដែលមានបញ្ញាល្អិត ញុំាញីនូវវាទៈនៃបុគ្គលដទៃបាន ប្រាកដដូចជាខ្មាន់ធ្នូបាញ់នូវសរសែសក់ សមណបណ្ឌិតទាំងអម្បាលនោះហាក់ដូចជាត្រាច់ទៅទម្លាយនូវទិដ្ឋិ ( បុគ្គលដទៃ ) ដោយបញ្ញា សមណបណ្ឌិតទាំងអម្បាលនោះបានឮ

ដំណឹងដូច្នេះថា ព្រះសមណគោតមដ៏ចម្រើន ទ្រង់ពុទ្ធដំណើរមកដល់ស្រុក ឬនិគមឯណោះ ។ សមណបណ្ឌិតទាំងអម្បាលនោះ ចងប្រស្នាដោយគិតថា ពួកយើងនឹងចូលទៅគាល់ព្រះសមណគោតម ហើយទូលសួរប្រស្នានេះ បើយើងសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមនោះយ៉ាងនេះ បើយើងទូលសួរប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតមយ៉ាងនេះ ។ សមណបណ្ឌិតទាំងអម្បាលនោះ បានឮដំណឹងដូច្នេះថា ព្រះសមណគោតមដ៏ចម្រើន ទ្រង់ពុទ្ធដំណើរមកដល់ស្រុក ឬនិគមឯណោះ សមណបណ្ឌិតទាំងនោះ ក៏ចូលទៅគាល់ព្រះសមណគោតម ។ ព្រះសមណគោតមទ្រង់ញុំាងសមណបណ្ឌិតទាំងនោះ ឲ្យយល់ឃើញ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ពួកសមណបណ្ឌិតនោះ ដែលព្រះសមណគោតមទ្រង់ឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏មិនអាចនឹងទូលសួរប្រស្នានឹងព្រះសមណគោតមបានឡើយ នឹងលើកទោសព្រះសមណគោតមដូចម្តេចបាន ទើបនាំគ្នាសូមឱកាសចំពោះព្រះសមណគោតម ដើម្បីនឹងចេញអំពីផ្ទះចូលទៅកាន់ផ្នួសវិញដោយពិត ។ ព្រះសមណគោតមទ្រង់បំបួសសមណបណ្ឌិតទាំងនោះ សមណបណ្ឌិតទាំងនោះ លុះបួសក្នុងសំណាក់ព្រះសមណគោតមនោះហើយ ក៏ចេញចាកពួកគណៈ មិនមានសេចក្តីធ្វេសប្រហែស មានសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅក្នុងកម្មដ្ឋាន កុលបុត្រទាំងឡាយដែលចេញ

ចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បានត្រាស់ដឹងនូវអនុត្តរធម៌នោះ មានព្រហ្មចរិយជាទីបំផុត ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ ។ សមណបណ្ឌិតទាំងនោះ និយាយសរសើរយ៉ាងនេះថា ឱហ្ន៎ ពួកយើងមិនបានវិនាសចាកប្រយោជន៍តិចតួចឡើយ ឱហ្ន៎ ពួកយើងមិនបានវិនាសចាកប្រយោជន៍តិចតួចឡើយ ដ្បិតក្នុងកាលមុន ពួកយើងមិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រាហ្មណ៍ ប្តេជ្ញាខ្លួនថាជាព្រាហ្មណ៍ មិនមែនជាព្រះអរហន្ត ប្តេជ្ញាខ្លួនថាជាព្រះអរហន្ត ឥឡូវនេះ ពួកយើងបានជាសមណៈហើយ ឥឡូវនេះ ពួកយើងបានជាព្រាហ្មណ៍ហើយ ឥឡូវនេះ ពួកយើងបានជាអរហន្តហើយ ។ ម្នាលអ្នកដ៏ចម្រើន ក្នុងកាលដែលអាត្មាបានឃើញនូវស្នាមព្រះបាទជាគម្រប់ ៤ នេះ របស់ព្រះសមណគោតមហើយ អាត្មាក៏ចូលចិត្តថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ ម្នាលអ្នកដ៏ចម្រើន ក្នុងកាលដែលអាត្មាបានឃើញនូវស្នាមព្រះបាទទាំង ៤ ប្រការនេះ របស់ព្រះសមណគោតមហើយ អាត្មាក៏ចូលចិត្តថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។

[ ៦៩ ] កាលបិលោតិកបរិព្វាជក ពោលយ៉ាងនេះហើយ ជាណុស្សោ-

ណិព្រាហ្មណ៍ក៏ចុះអំពីរថដែលទឹមដោយសេះសសុទ្ធ ធ្វើសំពត់ឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅត្រង់ទីដែលព្រះមានព្រះភាគគង់នៅ បន្លឺឧទានវាចា អស់វារៈ ៣ ដងថា សូមនមស្ការចំពោះព្រះមានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការចំពោះព្រះមានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការចំពោះព្រះមានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ធ្វើម្ដេច យើងគប្បីទៅចួបព្រះសមណគោតមបានម្ដងហ្ន៎ ធ្វើម្ដេច យើងគប្បីបាននិយាយឆ្លើយឆ្លងតិចតួចហ្ន៎ ។ លំដាប់នោះ ជាណុ-ស្សោណិព្រាហ្មណ៍ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល មួយអន្លើដោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ តាមពាក្យដែលខ្លួននិយាយឆ្លើយឆ្លង ជាមួយនឹងបិលោតិកបរិញ្វជកនោះដរាបដល់ចប់សព្វគ្រប់ ។ កាលជាណុស្សោណិព្រាហ្មណ៍ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ នឹងជាណុ-ស្សោណិព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ ធម៌ដែលឧបមាដូចស្នាមជើងដំរី មិនទាន់បរិបូណ៌ ដោយពិស្ដារត្រឹមតែប៉ុណ្ណេះទេ ម្នាលព្រាហ្មណ៍ ឯធម៌ដែលមានឧបមាដូចស្នាមជើងដំរី បរិបូណ៌ដោយពិស្ដារយ៉ាងណាមិញ អ្នកចូរស្ដាប់នូវសេចក្ដីឧបមានោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្ដែង ។ ជាណុស្សោណិព្រាហ្មណ៍ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់

ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ ។

[ ៧០ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ ដូចជាព្រានដំរីចូលទៅកាន់ព្រៃដំរី ព្រានដំរីនោះបានឃើញស្នាមជើងដំរីដ៏ធំក្នុងព្រៃដំរីវែងដោយបណ្តោយផង ធំដោយទទឹងផង ព្រានដំរីដែលឈ្លាសក៏មិនទាន់ចូលចិត្តថា ឱហ្ន៎ ដំរីធំមែន ដូច្នេះនៅឡើយ ។ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ក្នុងព្រៃ ដំរីរមែងមានមេដំរីទាំងឡាយមានខ្លួនខ្លី តែមានស្នាមជើងធំ ស្នាមជើងនេះជាស្នាមជើងមេដំរីទាំងនោះ ។ ព្រានដំរីនោះ ក៏ទៅតាមស្នាមជើងនោះ លុះទៅតាមស្នាមជើងនោះហើយ ក៏ឃើញស្នាមជើងដំរីធំក្នុងព្រៃដំរី វែងដោយបណ្តោយផង ធំដោយទទឹងផង មានទីត្រដុសដ៏ខ្ពស់ផង ព្រានដំរីដែលឈ្លាសមិនទាន់ចូលចិត្តថា ឱហ្ន៎ ដំរីធំណាស់ ដូច្នេះនៅឡើយ ។ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ក្នុងព្រៃ ដំរីរមែងមានមេដំរីទាំងឡាយឈ្មោះឧច្ចាកឡារិកា មានស្នាមជើងធំ ស្នាមជើងនេះជាស្នាមជើងនៃមេដំរីទាំងនោះ ។ ព្រានដំរីនោះក៏ដើរទៅតាមស្នាមជើងនោះ លុះដើរទៅតាមស្នាមជើងនោះហើយ ក៏ឃើញស្នាមជើងដំរីដ៏ធំក្នុងព្រៃដំរី វែងដោយបណ្តោយផង ធំដោយទទឹងផង មានទីត្រដុសដ៏ខ្ពស់ផង ទាំងទីដែលចាក់ដោយភ្លុកដ៏ខ្ពស់ផង ព្រានដំរីដែលឈ្លាសមិនទាន់ចូលចិត្តថា ឱហ្ន៎ ដំរីធំមែន ដូច្នេះនៅឡើយ ។ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ ព្រោះថា ក្នុងព្រៃ ដំរីរមែងមានមេដំរីឈ្មោះឧច្ចាករេណុកា មានស្នាមជើងដ៏ធំ ស្នាមជើងនេះ ជាស្នាមជើងនៃមេដំរីទាំងនោះ ។ ព្រានដំរីនោះ ដើរទៅតាមស្នាមជើងនោះ លុះ

ដើរទៅតាមស្នាមជើងនោះហើយ ក៏ឃើញស្នាមជើងដំរីដ៏ធំក្នុងព្រៃដំរី វែង ដោយបណ្ដោយផង ធំដោយទទឹងផង មានទីត្រដុសដ៏ខ្ពស់ផង ទាំងស្នាមចាក់ ដោយភ្លុកទាំងឡាយដ៏ខ្ពស់ផង ទាំងមែកឈើដែលដំរីនោះកាច់ហើយក៏ខ្ពស់ផង ហើយឃើញទាំងដំរីនោះនៅក្បែរគល់ឈើក្ដី នៅក្នុងទីវាលក្ដី កំពុងដើរក្ដី កំពុងឈរក្ដី កំពុងទ្រោមចុះក្ដី កំពុងដេកក្ដី ។ ទើបព្រានដំរីនោះចូលចិត្តថា ដំរីនេះជាដំរីធំមែន មានឧបមាដូចម្ដេចមិញ ។ ម្នាលព្រាហ្មណ៍ ឧបមេយ្យដូច ជាព្រះតថាគតកើតឡើងក្នុងលោកនេះ មាននាមប្រាកដថា ជាបុគ្គលឆ្ងាយ ចាកកិលេស ត្រាស់ដឹងដោយប្រពៃចំពោះខ្លួន បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អទៅកាន់សុន្ទរស្ថាន គឺ ព្រះនិព្វាន ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ជាសាស្ដាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ត្រាស់ ដឹងនូវអរិយសច្ចធម៌ លែងវិលត្រឡប់មកកាន់កពថ្មីទៀត ព្រះតថាគតនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាចំពោះខ្លួនឯង នូវលោកនេះ ព្រមទាំងទេវ-លោក មារលោក និងព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះតថាគត នោះសម្ដែងធម៌ មានលម្អបទដើម លម្អបទកណ្ដាល និងបទចុង បរិបូណ៌ ដោយអត្ថ និងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ពេញ លេញ គហបតីក្ដី កូនរបស់គហបតីក្ដី ឬបុគ្គលកើតក្នុងត្រកូលណាមួយ ជា ខាងក្រោយក្ដី បានស្ដាប់នូវធម៌នោះ លុះបុគ្គលនោះ ស្ដាប់នូវធម៌នោះហើយ

រមែងបានចំពោះនូវសទ្ធាក្នុងព្រះតថាគត បុគ្គលនោះ ប្រកបដោយការបាន ចំពោះនូវសទ្ធានោះហើយ រមែងពិចារណាឃើញច្បាស់ថា ការនៅគ្រប់គ្រង ផ្ទះជាទីចង្អៀតចង្អល់ ( ពេកណាស់ ) ជាផ្លូវហូរមកនៃធូលី គឺ កិលេស បព្វជ្ជាជាឱកាសទំនេរច្រើន ( ព្រោះជាឱកាសដើម្បីធ្វើកុសលតាមសប្បាយ ) បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ ដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ដូចជាស័ង្ខដែលគេខាត់ ហើយនោះបានទេ បើដូច្នោះ មានតែអាត្មាអញកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្ដប់សំពត់ជ្រលក់ដោយទឹកអម្ចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះសម័យខាងក្រោយមក បុគ្គលនោះ ក៏លះបង់នូវគំនរភោគៈតិចក្ដី លះបង់នូវគំនរភោគៈច្រើនក្ដី លះបង់នូវញាតិវង្សតិចក្ដី លះបង់នូវញាតិវង្ស ច្រើនក្ដី ហើយកោរសក់ និងពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់នូវសំពត់ ជ្រលក់ដោយទឹកអម្ចត់ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។

[ ៧១ ] លុះបុគ្គលនោះ បានបួសយ៉ាងនេះហើយ ក៏បរិបូណ៌ដោយ សិក្ខាព្រមទាំងអាជីវៈនៃភិក្ខុទាំងឡាយ ជាអ្នកលះបង់បាណាតិបាត វៀរស្រឡះ ចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្ដីខ្មាសបាប មានសេចក្ដីអាណិត មានសេចក្ដីអនុគ្រោះសព្វសត្វ ដោយប្រយោជន៍ ។ លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន កាន់យក តែវត្ថុដែលគេឲ្យ ប្រាថ្នាតែវត្ថុដែលគេឲ្យ មានអត្តភាពដ៏ស្អាត មិនមែនជា ចោរ ។ លះបង់នូវអព្រហ្មចរិយ គឺធម៌មិនប្រសើរ ហើយប្រព្រឹត្តតែធម៌ដ៏

ប្រសើរ ចៀសវាង វៀរស្រឡះចាកមេថុន ជាធម៌របស់អ្នកស្រុក ។ លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ពោលតែពាក្យពិត តនូវពាក្យពិតដោយពាក្យពិត ជាអ្នកមានសម្តីទៀងទាត់ មានពាក្យដែលគួរជឿ មិនបានពោលបំភ្លាត់សត្វលោក ។ លះបង់បិសុណវាចា វៀរស្រឡះចាកបិសុណវាចា គឺថា ឮពាក្យអំពីសម្នាក់ជននេះហើយ មិននាំទៅប្រាប់ជនឯណោះ ដើម្បីបំបែកនូវជនទាំងឡាយនេះ ឬឮពាក្យក្នុងសម្នាក់ជនឯណោះហើយ មិននាំមកប្រាប់ដល់ពួកជននេះ ដើម្បីបំបែកនូវជនទាំងឡាយឯណោះដូច្នេះ ជាអ្នកផ្សះផ្សានូវជនទាំងឡាយដែលបែកគ្នាហើយ ឬឲ្យកម្លាំងថែមដល់ជនទាំងឡាយដែលជានឹងគ្នាហើយ មានសេចក្តីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នា រីករាយតែក្នុងសេចក្តីព្រមព្រៀងគ្នា និយាយតែវាចាដែលជាគ្រឿងធ្វើឲ្យព្រមព្រៀងគ្នា ។ លះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចា វាចាណាដែលមិនមានទោស នាំមកនូវសេចក្តីសុខដល់ត្រចៀក ជាពាក្យគួរស្រឡាញ់ ជាពាក្យគួរតម្កល់ទុកក្នុងហឫទ័យ ជាសម្តីរបស់អ្នកក្រុង ដែលជាទីត្រេកអរដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកនិយាយតែវាចាមានសភាពដូច្នោះ ។ លះបង់សម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកពោលនូវពាក្យតាមកាលគួរ ជាអ្នកពោលនូវពាក្យពិត ជាអ្នកពោលនូវអត្ថ ( ពោលពាក្យអាស្រ័យប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ) ជាអ្នកពោលនូវធម៌ ( ពោលពាក្យអាស្រ័យលោកុត្តរធម៌ ) ជាអ្នកពោលនូវវិន័យ ( ពោលពាក្យអាស្រ័យសំវរវិន័យ និងបហានវិន័យ ) ពោលនូវពាក្យ

គួរតម្កល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយសេចក្តីអាងតាមកាល ជាពាក្យមានកំណត់ ។ ភិក្ខុនោះវៀរស្រឡះចាកកិរិយាផ្តិលផ្តាច់នូវពីជគាម និងភូតគាម ។ ជាអ្នកបរិភោគនូវភត្តតែ ១ ពេល វៀរស្រឡះចាកការបរិភោគក្នុងរាត្រី វៀរស្រឡះចាកការបរិភោគក្នុងកាលខុស ។ វៀរស្រឡះចាកកិរិយារាំច្រៀងប្រគំ និងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។ វៀរស្រឡះចាកកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែង ស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។ វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ ។ វៀរស្រឡះចាកកិរិយាទទួលកាន់យកនូវមាស និងប្រាក់ ។ វៀរស្រឡះចាកកិរិយាទទួលកាន់យកនូវស្រូវស្រស់ ។ វៀរស្រឡះចាកកិរិយាទទួលកាន់យកនូវសាច់ឆៅ ។ វៀរស្រឡះចាកកិរិយាទទួលស្ត្រី និងកុមារី ។ វៀរស្រឡះចាកកិរិយាទទួលនូវខ្ញុំស្រី និងខ្ញុំប្រុស ។ វៀរស្រឡះចាកកិរិយាទទួលនូវពពែ និងចៀម ។ វៀរស្រឡះចាកកិរិយាទទួលនូវមាន់ និងជ្រូក ។ វៀរស្រឡះចាកកិរិយាទទួលនូវដំរី គោសេះឈ្មោល និងញី ។ វៀរស្រឡះចាកកិរិយាទទួលនូវស្រែនិងចម្ការ ។ វៀរស្រឡះចាកកិរិយាប្រកបនូវទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្តាំដល់គ្រហស្ថ និងទៅដោយគេបញ្ជូនពីផ្ទះមួយទៅផ្ទះមួយ ។ វៀរស្រឡះចាកកិរិយាលក់ទិញផ្លាស់ប្តូរ ( របស់ផ្សេងៗ ) ។ វៀរស្រឡះចាកអំពើកោងដោយជញ្ជីង បន្លំដោយកាជន៍មាស និង អំពើកោងដោយរង្វាស់រង្វាល់ ។ វៀរស្រឡះចាកកិរិយាប្រកបនូវអំពើកោង ដោយមួលបង្កាច់ បំភាន់ដោយឧបាយ និងបន្លំដោយ

របស់បួម ។ វៀរស្រឡះចាកកិរិយាកាត់អវយវៈមានដៃ និងជើងជាដើម សម្លាប់ ចាប់ចង ធ្វើឲ្យវង្វេងផ្លូវ ប្លន់អ្នកស្រុក និងកំហែងយកទ្រព្យគេ ។ ភិក្ខុនោះជាអ្នកសន្តោសដោយចីវរ ដែលជាគ្រឿងរក្សានូវកាយដោយបិណ្ឌបាត ដែលជាគ្រឿងរក្សានូវផ្ទៃ និងចៀសចេញទៅក្នុងទិសណាៗ តែងកាន់យក ( នូវគ្រឿងបរិក្ខារ ) តែប៉ុណ្ណោះ ចៀសចេញទៅ ( ក្នុងទិសនោះៗ ) ។ ដូចជាសត្វស្លាបហើរទៅក្នុងទីណាៗ ក៏មានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅ ដូចម្តេចមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរដែលជាគ្រឿងរក្សានូវកាយ ដោយបិណ្ឌបាតដែលជាគ្រឿងរក្សានូវផ្ទៃ និងចៀសចេញទៅក្នុងទិសណាៗ តែងកាន់យក ( នូវគ្រឿងបរិក្ខារ ) ប៉ុណ្ណោះ ចៀសចេញទៅ ដូច្នោះដែរ ។ ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះហើយ សោយនូវសេចក្តីសុខដែលមិនមានទោសក្នុងសន្តានចិត្តខ្លួនបាន ។ ភិក្ខុនោះ ឃើញរូបដោយចក្ខុហើយ មិនកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈឡើយ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវឥន្ទ្រិយ គឺចក្ខុណា ភិក្ខុនោះក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺចក្ខុនោះ រក្សានូវឥន្ទ្រិយ គឺចក្ខុ ដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយ គឺចក្ខុ ។ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវសម្ផស្សដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត មិនបានកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈឡើយ អកុសលធម៌ដ៏លាមកទាំង-ឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គលដែលមិនបានសង្រួម

នូវឥន្ទ្រិយ គឺចិត្តណា ភិក្ខុនោះក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនោះ រក្សានូវឥន្ទ្រិយ គឺចិត្ត ដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយ គឺចិត្ត ។ ភិក្ខុនោះ ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះហើយ ទើបសោយចំពោះនូវសុខដែល មិនប្រឡំដោយកិលេសក្នុងសន្តានចិត្ត ។ កាលភិក្ខុនោះឈានទៅមុខ និង ឈានថយក្រោយ ក៏មានសេចក្តីដឹងខ្លួន កាលក្រឡេកមើលទៅមុខ និង ក្រឡេកមើលទៅទិសផ្សេងៗ ក៏មានសេចក្តីដឹងខ្លួន កាលអង្គុញដៃជើង និង លាដៃជើង ក៏មានសេចក្តីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ក៏ មានសេចក្តីដឹងខ្លួន កាលបរិភោគ ផឹក ទំពាស៊ី ជញ្ជក់ជញ្ជាប់ ក៏មានសេចក្តី ដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈក៏មានសេចក្តីដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ នៅស្ងៀម ក៏មានសេចក្តីដឹងខ្លួន ។

[ ៧២ ] ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយ ឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិសម្បជញ្ញៈដ៏ប្រសើរនេះផង តែងសេពនូវទីសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ រូងភ្នំ ព្រៃ ស្មសាន ព្រៃឆ្ងាយ ទីវាល ទីគំនរចំបើង ។ ភិក្ខុនោះត្រឡប់មកអំពីបិណ្ឌបាត វិញ ក្នុងវេលាក្រោយកត្ត ក៏អង្គុយពែនភ្នែនតម្រង់កាយឲ្យត្រង់ តាំងស្មារតី ឲ្យមានមុខឆ្ពោះ ( ទៅរកកម្មដ្ឋាន ) ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា ។ លះបង់នូវព្យាបាទ និងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះសព្វសត្វដោយ ប្រយោជន៍ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ និងសេចក្តីប្រទូស្ត ។ លះបង់នូវ

ថីនមិទ្ធៈ គឺសេចក្តីងងុយ និងងោកងក់ មានចិត្តប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ មានសតិ និងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ ។ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយចិត្ត និងសេចក្តីក្តៅក្រហាយ មានចិត្តមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ព្ធដ៏ខាងក្នុង ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់នូវវិចិកិច្ឆា គឺសេចក្តីងឿងឆ្ងល់ ឆ្លងផុតចាកវិចិកិច្ឆា អស់សេចក្តីសង្ស័យក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[ ៧៣ ] ភិក្ខុនោះលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើបញ្ញាឲ្យមានកម្លាំងថយ ហើយស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈានប្រកបដោយវិតក្កនិងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីវិវេកជាអារម្មណ៍ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលព្រាហ្មណ៍ នេះតថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាស្នាមចាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ មិនតែប៉ុណ្ណោះឡើយ ព្រះអរិយសាវកតែងចូលចិត្តថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគលោកប្រតិបត្តិប្រពៃហើយ ។ ម្នាលព្រាហ្មណ៍ ប្រការមួយទៀត លុះភិក្ខុរម្ងាប់វិតក្ក និងវិចារៈរួចហើយ ក៏បានចូលទុតិយជ្ឈានជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ញុំាងចិត្តជាសមាធិឲ្យបម្រើនឡើង មិនមានវិតក្ក និងវិចារៈ មានតែ

បីតិ និងសុខដែលកើតអំពីសមាធិប៉ុណ្ណោះ ។បេ។ ក៏បានចូលតតិយជ្ឈាន ... ចូលចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលព្រាហ្មណ៍ នេះតថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាស្នាមចាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ មិនប៉ុន្តែប៉ុណ្ណោះឡើយ ព្រះអរិយសាវកតែងចូលចិត្តថា ព្រះមានព្រះភាគជាសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។

[ ៧៤ ] កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះក៏រឭកនូវបុព្វេនិវាសជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ ភិក្ខុនោះរឭកបាននូវបុព្វេនិវាសានុស្សតិជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ នេះឯងតថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាស្នាមចាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ មិនតែប៉ុណ្ណោះឡើយ ព្រះអរិយសាវកតែងចូលចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។

[ ៧៥ ] កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាស

ចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ ទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅដើម្បីចុតូបបា-តញ្ញាណនៃសត្វទាំងឡាយ ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួន ។ ម្នាលព្រាហ្មណ៍ នេះឯងតថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាស្នាមចាក់ដោយភ្លុក របស់ព្រះតថាគតដូច្នេះខ្លះ ។ មិនតែប៉ុណ្ណោះឡើយ ព្រះអរិយសាវកតែងចូលចិត្តថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។

[ ៧៦ ] កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេសប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ។ ភិក្ខុនោះក៏ដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងតាមពិតថា នេះជាសេចក្តីរម្លត់ទុក្ខ ដឹងតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរម្លត់ទុក្ខ ។ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងតាមពិតថា នេះជាសេចក្តីរម្លត់នៃអាសវៈ ដឹងតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរម្លត់នៃអាសវៈ ។ ម្នាលព្រាហ្មណ៍ នេះឯងតថាគតហៅថា ស្នាមជើងរបស់

ព្រះតថាគតដូច្នេះខ្លះ ថាជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាស្នាមចាក់ដោយភ្លុក របស់ព្រះតថាគតដូច្នេះខ្លះ ។ ព្រះអរិយសាវកលោកមិនត្រឹមតែចូលចិត្តដោយហេតុមានប្រមាណប៉ុណ្ណោះទេ ។ ម្យ៉ាងទៀត ព្រះអរិយសាវកតែងចូលចិត្តថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកអាសវៈ ( គ្រឿងត្រាំ គឺកាម ) ផង ចិត្តក៏ផុតស្រឡះចាកភវាសវៈ ( គ្រឿងត្រាំ គឺភព ) ផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈ ( គ្រឿងត្រាំ គឺអវិជ្ជា ) ផង កាលបើចិត្តផុតស្រឡះហើយ សេចក្តីដឹង ក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ភិក្ខុនោះក៏ដឹងច្បាស់ថា កំណើតអស់ហើយ មគ្គព្រហ្មចារ្យអាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញក៏បានធ្វើស្រេចហើយ ករណីយកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលព្រាហ្មណ៍ នេះឯងតថាគតហៅថា ស្នាមជើងរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាទីត្រដុសរបស់ព្រះតថាគតដូច្នេះខ្លះ ថាជាស្នាមចាក់ដោយភ្លុករបស់ព្រះតថាគតដូច្នេះខ្លះ ។ ម្នាលព្រាហ្មណ៍ ព្រះអរិយសាវកតែងចូលចិត្តដោយហេតុមានប្រមាណប៉ុណ្ណោះថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងប្រពៃហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ ម្នាលព្រាហ្មណ៍ ធម៌ដែលមានឧបមាដូចស្នាមជើងដំរី ពេញបរិបូណ៌ដោយពិស្តារ

ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[ ៧៧ ] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ជាណុស្សោណិព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ គួរទាដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេទ្រោលប្រទីបក្នុងទីងងឹតដោយគិតថា បុរសអ្នកមានចក្ខុ តែងឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះទៅ ។

## ចូឡហត្ថិបទោបមសូត្រទី ៧ ចប់

# អដ្ឋកថា

# ចូឡហត្ថិបទោបមសូត្រ

[ ៦៧ ] ចូឡហត្ថិបទោបមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងចូឡហត្ថិបទោបមសូត្រនោះដូច្នេះ បទថា **សព្វសេតេន វឡវាភិរថេន** សេចក្ដីថា រថដែលទឹមដោយលា ៤ ពួក ពណ៌សទាំងអស់ ដែលលោកពោលយ៉ាងនេះថា បានឮថា សេះស មានគ្រឿងប្រដាប់សដែលទឹមហើយ រថសមានគ្រឿងប្រដាប់ស មានបរិវារស ស្នើស ខ្សែតីស ធត្រស ឈ្នួតស សំពត់ស ស្បែកជើងស ផ្លិតវាលវីជនីស ។ ធម្មតារថនេះ មាន ២ យ៉ាង គឺរថចម្បាំង និងរថប្រដាប់ ។ បណ្ដារថទាំង ២ នោះ រថចម្បាំងមាន ៤ ជ្រុង មិនធំពេក អាចដាក់មនុស្សបាន ២ ឬ ៣ នាក់ រថប្រដាប់ធំផង បណ្ដោយវែងផង ទូលាយផង ។ ក្នុងរថប្រដាប់មានមនុស្ស ៨ ឬ ១០ នាក់ គឺអ្នកកាន់ធត្រ កាន់ផ្លិតវាលវីជនី កាន់ផ្លិតស្លឹកត្នោត អាចឈរ អង្គុយ ឬដេកបានតាមសម្រួល រថនេះ ឈ្មោះថា រថប្រដាប់តែម្យ៉ាង រថទាំងអស់នោះ ដល់ព្រមដោយកង់ បង្អួច និងទូករថ ដំរំលេចដោយប្រាក់ ។ លាតាមប្រក្រតីមានពណ៌ស សូម្បីគ្រឿងប្រដាប់លាទាំងនោះ ក៏ធ្វើដោយប្រាក់ សូម្បីខ្សែក៏ជ្រលក់ដោយទឹកប្រាក់ ផ្កាដោយប្រាក់ សូម្បីខ្សែតីក៏រំលេចដោយប្រាក់ សូម្បីព្រាហ្មណ៍ក៏ស្លៀកស ដណ្ដប់ស លាបស្រឡាបគ្រឿងពណ៌ស ប្រដាប់មាល័យស ពាក់ចិញ្ចៀនក្នុងម្រាមទាំង ១០ ពាក់កុណ្ឌលទាំងសងខាង រួមសេចក្ដីដូចពោលមកនេះជាដើម សូម្បី

គ្រឿងប្រដាប់របស់រថនោះ ក៏ជាប្រាក់ទាំងអស់ ។ សូម្បីព្រាហ្មណ៍ដែលជាបរិវាររបស់ព្រាហ្មណ៍នោះ ក៏ប្រដាប់សំពត់ គ្រឿងលាប គ្រឿងក្រអូប និងកម្រងផ្កា មានពណ៌សដូចគ្នាដូច្នោះ ដោយហេតុនោះ ទើបលោកពោលថា **សព្វសេតេន វឡវាភិរថេន** ។

បទថា **សាវត្ថិយា នេយ្យាតិ** សេចក្ដីថា បានឮថា ៦ ខែ ព្រាហ្មណ៍នោះប្រទក្សិណព្រះនគរម្ដង ។ ហើយឲ្យឃោសនាជាមុនថា ព្រាហ្មណ៍ធ្វើប្រទក្សិណព្រះនគរក្នុងថ្ងៃទីប៉ុណ្ណេះ បន្ទាប់អំពីថ្ងៃនេះ ។ មនុស្សទាំងឡាយឮរឿងនោះហើយ ពួកដែលមិនទាន់ចេញអំពីព្រះនគរ ក៏មិនចេញទៅ ពួកដែលទៅហើយក៏ត្រឡប់មក ដោយបំណងនឹងមើលសិរីសម្បត្តិរបស់អ្នកមានបុណ្យ ។ ថ្ងៃណា ព្រាហ្មណ៍ធ្វើប្រទក្សិណព្រះនគរ ថ្ងៃនោះ មនុស្សម្នា ក៏បោសថ្នាល់ក្នុងព្រះនគរ កៀរខ្សាច់ រោយផ្កា លាជ រៀបក្អមទឹក ដែលមានទឹកពេញ លើកដើមចេក និងទង់ ធ្វើព្រះនគរទាំងមូលឲ្យក្រអូបឈ្ងុយឈ្ងប់ទៅដោយក្លិនធូបអំពីព្រលឹម ។ ព្រឹកឡើង ព្រាហ្មណ៍ក៏ងូតទឹក បរិភោគអាហារស្រាល អាហារធ្ងន់ តែងខ្លួនដោយសំពត់សជាដើម ដោយន័យដែលពោលហើយនោះឯង ចុះអំពីប្រាសាទ ហើយឡើងរថ ។ កាលនោះ ព្រាហ្មណ៍ទាំងនោះ ប្រដាប់ដោយសំពត់ គ្រឿងលាបស្រឡាប និងកម្រងផ្កា ពណ៌សទាំងអស់ កាន់ឆត្រស ហែហមជាណុស្សោណិព្រាហ្មណ៍នោះ ។ បន្ទាប់អំពីនោះ ក៏បែកផ្លែឈើតូចធំដល់ពួកក្មេងៗ ស្រករក្រោយនោះឯង ដើម្បីឲ្យមហាជនប្រជុំគ្នា បន្ទាប់អំពីនោះ ក៏បាចមាសក និងកហាបណៈ មហាជនប្រជុំ

គ្នាបន្ទឹសំឡេងហ៊ោ អឺងកង និងលើកសំពត់ជូតក្បាល គ្រវីទៅមកទូទៅ ។ លំដាប់នោះ កាលមង្គលិកព្រាហ្មណ៍ និងសោវត្ថិកព្រាហ្មណ៍ជាដើម ធ្វើការមង្គល និងសួស្តីមង្គល ធ្វើប្រទក្សិណព្រះនគរដោយសម្បត្តិដ៏ធំ ។ មនុស្សមានបុណ្យទាំងឡាយ ក៏ឡើងទៅប្រាសាទមួយជាន់ជាដើម បើកបង្អួច និងទ្វារ ដូចកាជនៈសសម្លឹងមើល ។ ឯព្រាហ្មណ៍បែរមុខទៅកាន់ខ្លោងទ្វារទិសខាងត្បូង ហាក់បីដូចគ្របសង្កត់ព្រះនគរដោយសម្បត្តិ គឺយស និងសិរីរបស់ខ្លួន ។ ដោយហេតុនោះ ទើបពោលថា **សាវត្ថិយា និយ្យាតិ ។**

បទថា **ទិវាទិវស្ស** ប្រែថា ថ្ងៃនៃថ្ងៃ អធិប្បាយថា វេលាថ្ងៃ ។ បទថា **បិលោតិកំ បរិព្វាជកំ** បានដល់ បរិព្វាជកបានឈ្មោះដោយហៅជាភេទស្រីយ៉ាងនេះថា **បិលោតិកា ។** បានឮថា បរិព្វាជកនោះជាកំលោះ នៅក្នុងបឋមវ័យ មានពណ៌ដូចមាស ជាពុទ្ធុបដ្ឋាក ធ្វើឧបដ្ឋាកព្រះតថាគត និងព្រះមហាថេរៈតាំងអំពីព្រលឹម កាន់យកឈើ ៣ កំណាត់ និងគ្រឿងបរិក្ខារ មានកុណ្ឌីទឹកជាដើម ចេញអំពីវត្តជេតពន ដើរសំដៅទៅកាន់ព្រះនគរ ។ ជាណុស្សោណិព្រាហ្មណ៍នោះ ឃើញបិលោតិកបរិព្វាជកនោះ ដើរមកអំពីចម្ងាយ ។ បទថា **ឯតទវោច** សេចក្តីថា ជាណុស្សោណិព្រាហ្មណ៍ចាំបានថា បិលោតិកបរិព្វាជកធ្លាប់មកសម្នាក់ដោយលំដាប់ ទើបពោលពាក្យប្រារព្ធគោត្រត្រកូលថា លោកវច្ឆាយនៈដ៏ចម្រើន មកអំពីទីណា ទាំងកំពុងថ្ងៃត្រង់នេះ ។ ក្នុងបទថា **បណ្ឌិតោ មញ្ញតិ** នេះ មានអត្ថដូច្នេះថា **វច្ឆាយ** នៅសម្គាល់ព្រះគោតមថាជាបណ្ឌិត ឬមិនមែនហ្ន៎ ។ បទថា **កោ ចាហំ ភោ** សេចក្តី

ថា ខ្ញុំនឹងដឹងការមានបញ្ញា និងការឈ្លាសរបស់ព្រះគោតមបានអំពីណា ។ ដោយបទថា **កោ ច សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានិស្សាមិ** នេះ បរិព្វាជកសម្ដែងថា ខ្លួនមិនដឹងគ្រប់ប្រការយ៉ាងនេះថា ខ្ញុំនឹងដឹងការមានបញ្ញា និងបដិភាណរបស់ព្រះគោតមបានអំពីណា នឹងដឹងដោយហេតុអ្វី ។ បទថា **សោបិ នូនស្ស តាទិសោ ច** នេះ បរិព្វាជកសម្ដែងថា បុគ្គលណាគប្បីដឹងការមានបញ្ញា និងការឈ្លាសរបស់ព្រះគោតម បុគ្គលនោះត្រូវបំពេញបារមី ១០ សម្រេចសព្វញ្ញុតញ្ញាណជាព្រះពុទ្ធ ដូច្នោះ បុគ្គលត្រូវវាស់ភ្នំសិនេរុ ភ្នំហិមពាន្ត ផែនដី ឬអាកាស គួរនឹងបានឬ ដោយប្រើខ្សែប្រមាណប៉ុណ្ណោះ បុគ្គលនឹងដឹងព្រះបញ្ញារបស់ព្រះសមណគោតម ក៏គួរបានសព្វញ្ញុតញ្ញាណ ដូចព្រះញាណរបស់ព្រះអង្គនោះឯង ។ លោកធ្វើការពោលត្រួតក្នុងទីនេះ ដោយការអើពើ ។ បទថា **ឧឡារាយ** ប្រែថា ឧត្តម ប្រសើរ ។ បទថា **កោ ចាហំ ភោ** សេចក្ដីថា ខ្ញុំគប្បីសរសើរព្រះសមណគោតមបានដូចម្ដេច ។ បទថា **កោ ច សមណំ គោតមំ បសំសិស្សាមិ** សេចក្ដីថា ខ្ញុំនឹងសរសើរដោយហេតុណា ។ បទថា **បសដ្ឋប្បសដ្ឋោ** សេចក្ដីថា បុគ្គលប្រសើរដោយគុណរបស់ខ្លួនលើសបុគ្គលដទៃ ដោយគុណទាំងពួងដែលសត្វលោកសរសើរហើយ ។

ព្រះអង្គមិនមានកិច្ច គឺសរសើរដោយគុណដទៃ ប្រៀបដូចផ្កាចម្ប៉ា ផ្កាឧប្បល ផ្កាបទុម ឬចន្ទន៍ក្រហម រមែងស្រស់ថ្លា និងមានក្លិនក្រអូប ដោយសិរីនៃពណ៌ និងក្លិនរបស់វា វាមិនមានកិច្ចដែលនឹងសរសើរដោយពណ៌ និង

ក្ខិនដែលចរមក ប្រៀបដូចកែវមណី ឬព្រះចន្ទ រមែងឱភាស ដោយពន្លឺរបស់ខ្លួនប៉ុណ្ណោះ មិនមានកិច្ចដោយពន្លឺដទៃឡើយ យ៉ាងណា ព្រះសមណ-គោតមក៏ដូច្នោះ ជាបុគ្គលដែលបណ្ឌិតសរសើរ លើកតម្កើងដោយគុណរបស់ខ្លួន ដែលលោកទាំងពួងសរសើរហើយ គឺឲ្យដល់នូវការប្រសើរបំផុតនៃលោកទាំងពួង ព្រះអង្គមិនមានកិច្ច គឺការសរសើរ ដោយការសរសើរដទៃឡើយម្យ៉ាងទៀត ជាបុគ្គលប្រសើរលើសបុគ្គលប្រសើរទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **បសដ្ឋប្បសដ្ឋ** គឺបុគ្គលប្រសើរបំផុតជាងបុគ្គលប្រសើរបំផុតទាំងឡាយ ។ បុគ្គលដទៃៗ ណា ឈ្មោះថា ជាបុគ្គលប្រសើរបំផុត ។ ព្រះបាទបសេនទិកោសល ជាបុគ្គលប្រសើរជាងអ្នកកាសី និងអ្នកកោសលទាំងឡាយ ព្រះបាទពិម្ពិសារជាបុគ្គលប្រសើរជាងអ្នកអង្គៈ និងអ្នកមគធៈ ព្រះបាទលិច្ឆវីក្រុងវេសាលី ប្រសើរជាងអ្នកដែនវជ្ជី ស្តេចមល្លៈក្រុងបាវា មល្លក្សត្រក្រុងកុសិនារា ព្រះរាជានោះៗអង្គដទៃ ប្រសើរជាងអ្នកជនបទនោះៗ ព្រាហ្មណ៍ មានចង្កីព្រាហ្មណ៍ជាដើម ប្រសើរជាងពួកព្រាហ្មណ៍ទាំង-ឡាយ ឧបាសក មានអនាថបិណ្ឌិកសេដ្ឋីជាដើម ប្រសើរជាងពួកឧបាសកឧបាសិកា មាននាងវិសាខាជាដើម ប្រសើរជាងឧបាសិកាច្រើនរយ បរិព្វាជកមានសកុលុទាយីជាដើម ប្រសើរជាងបរិព្វាជកច្រើនរយ ។ មហាសាវិកាមានឧប្បលវណ្ណាថេរីជាដើម ប្រសើរជាងភិក្ខុនីច្រើនរយ ព្រះមហាសាវកមានព្រះសារីបុត្តត្ថេរជាដើម ប្រសើរជាងភិក្ខុច្រើនរយ ទេវតាទាំងឡាយ មានសក្កទេវរាជជាដើម ប្រសើរជាងទេវតាទាំងឡាយ ព្រហ្មទាំងឡាយ មានមហា

ព្រហ្មជាដើម ប្រសើរជាងព្រហ្មច្រើនពាន់ បណ្ដាបុគ្គលទាំងនោះ រមែងលើក កម្ពស់ លើកតម្កើង សរសើរព្រះទសពលគ្រប់គ្នា ព្រោះហេតុនោះ ទើប ព្រះមានព្រះភាគ ហៅថា **បសដ្ឋប្បសដ្ឋ** ប្រសើរជាងបុគ្គលប្រសើរ ។ បទ ថា **អត្ថវសំ** ប្រែថា អានិសង្សប្រយោជន៍ ។

[ ៦៨ ] គ្រានោះ បរិព្វាជក កាលប្រាប់ហេតុនៃការជ្រះថ្លារបស់ខ្លួនដល់ ជាណុស្សោណិព្រាហ្មណ៍នោះ ទើបពោលថា **សេយ្យថាបិ ភោ កុសលោ នាគវនិកោ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **នាគវនិកោ** បានដល់ បុរសដែលរៀនសិល្បៈក្នុងដែននាគវន ។ បុរសអ្នករៀនសិល្បៈអំពីអ្នកដទៃ ហៅថា **នាគវនិក** ។ បទថា **ចត្តារិ បទានិ** បានដល់ ស្នាមព្រះបាទ គឺ ញាណ ៤ អធិប្បាយថា ទីដែលញាណជាន់ ។ បទថា **បណ្ឌិតេ** ក្នុងបទ ថា **ខត្តិយបណ្ឌិតេ** ជាដើម បានដល់ បុគ្គលប្រកបដោយភាពជាបណ្ឌិត ។ បទថា **និបុណេ** ប្រែថា ជាអ្នកល្អិត គឺជាអ្នកដឹងអត្ថដ៏ល្អិត បានដល់ បុគ្គល អាចចាក់ធ្លុះនូវអត្ថដ៏ល្អិតដទៃៗ ។ បទថា **កតបរប្បវាទេ** បានដល់ ដឹងនូវ បរប្បវាទ និងធ្វើការញាំញីបរប្បវាទ ។ បទថា **វាលវេធិរូបេ** ប្រែថា ដូច នាយខ្មាន់ធ្នូអ្នកបាញ់រោមទ្រាយ ។ បទថា **តេ ភិន្ទន្តា មញ្ញេ ចរន្តិ** សេចក្តី ថា ត្រាច់ទៅ ប្រៀបបីដូចទម្លាយនូវទិដ្ឋិរបស់អ្នកដទៃដ៏ល្អិត ដោយបញ្ញា របស់ខ្លួន ដូចនាយខ្មាន់ធ្នូដែលបាញ់រោមទ្រាយ ។ បទថា **បញ្ហំ អភិសង្ខរោន្តិ** បានដល់ តាំងបញ្ហា ២ បទខ្លះ ៣ បទខ្លះ ៤ បទខ្លះ ។ បទថា **វាទំ អារោ-បេស្សាម** បានដល់ លើកទោសឡើង ។ បទថា **ន ចេវ សមណំ គោតមំ**

**បញ្ហំ បុច្ឆន្តិ** សេចក្តីថា ហេតុអ្វី ទើបមិនសួរ ។

បានឮថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ទើបទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់បរិស័ទ បន្ទាប់អំពីនោះ ក៏ទ្រង់ដឹងថា ខត្តិយបណ្ឌិតទាំងនោះ មកចងបញ្ហាដែលកំបាំង ឈ្មោះថា ឱវដ្ដិកសារ-បញ្ហាដ៏ស្មុគស្មាញ ព្រះអង្គមិនត្រូវបានខត្តិយបណ្ឌិតសួរឡើយ ការត្រាស់សួរបញ្ហាទាំងនេះថា ក្នុងការសួរបញ្ហាមានទោស មានប្រមាណប៉ុណ្ណេះ ក្នុងការឆ្លើយបញ្ហាមានទោសប្រមាណប៉ុណ្ណោះ ក្នុងអត្ថ បទ អក្ខរៈ មានទោសប៉ុណ្ណេះ គប្បីត្រាស់សួរយ៉ាងនេះ កាលទ្រង់ឆ្លើយ គប្បីឆ្លើយយ៉ាងនោះ ព្រោះដូច្នោះ ទើបទ្រង់ដាក់ក្នុងចន្លោះធម្មកថា ហើយទ្រង់កម្ចាត់បញ្ហាដែលខត្តិយបណ្ឌិតនាំមកចងជាឱវដ្ដិកប្បញ្ហាចេញ ដោយប្រការដូច្នេះ ។ ពួកខត្តិយ-បណ្ឌិតរមែងត្រេកអរថា ជាការប្រពៃសម្រាប់អញហ្ន៎ ដែលពួកអញមិនត្រូវសួរប្រស្នានេះ បើគប្បីសួរសោត ព្រះសមណគោតម គប្បីបោះបង់ពួកយើងឲ្យអស់ទីពឹង ។ម្យ៉ាងទៀត ធម្មតាព្រះពុទ្ធទាំងឡាយ កាលសម្តែងធម៌ រមែងផ្សាយមេត្តាទៅកាន់បរិស័ទ មហាជនរមែងមានចិត្តជ្រះថ្លា ក្នុងព្រះទសពលដោយការផ្សាយមេត្តា ។ ព្រះពុទ្ធទាំងឡាយ មានព្រះរូបឆោមល្អក្រៃលែងគួរសរសើរ មានព្រះសូរសៀងពីរោះ មានព្រះជិវ្ហាទន់ មានជួរនៃព្រះទន្តស្មើល្អ ត្រាស់ធម៌ ហាក់ដូចជាស្រោចនូវហឫទ័យដោយទឹកអម្រឹត ។ ក្នុងទីនោះ មនុស្សទាំងនោះមានចិត្តជ្រះថ្លាព្រោះទ្រង់ផ្សាយមេត្តា ក៏មានការគិតយ៉ាងនេះថា ពួកយើងមិនអាចធ្វើខ្លួនឲ្យជាសត្រូវនឹងព្រះមានព្រះភាគ ដែលត្រាស់ព្រះ

វាចាមិនជាទី ២ វាចាមិនជាមោឃៈ វាចាដែលនាំសត្វចេញចាកទុក្ខបែបនេះឡើយ ។ ទើបមិនទូលសួរ ព្រោះខ្ញុំនជ្រះថ្លាហើយ ។ បទថា **អញ្ញាទត្ថុំ** ប្រែថា ដោយចំណែកមួយ ។ បទថា **សាវកា សម្បជ្ជន្តិ** បានដល់ ជាសាវកដោយការដល់សរណៈ ។ បទថា **តទនុត្តរំ** កាត់បទជា **តំ អនុត្តរំ** ។ បទថា **ព្រហ្មចរិយបរិយោសានំ** បានដល់ អរហត្តផលដែលជាទីបំផុតនៃមគ្គ-ព្រហ្មចរិយៈ ។ ពិតហើយ សមណព្រាហ្មណ៍ទាំងនោះ រមែងបួសដើម្បីអរហត្តផលនោះ ។ បទថា **មជំ វត ភោ អនស្សាម** សេចក្តីថា បើខ្ញុំមិនចូលទៅគាល់សោត ខ្ញុំគប្បីវិនាស ។ ព្រោះត្រឹមតែមិនបានចូលជិតបន្តិចបន្តួចប៉ុណ្ណោះ តែពួកយើងមិនបានវិនាសឡើយ ព្រោះហេតុត្រឹមតែចូលគាល់ ។ បទទី ២ ក៏ជាវេវចនៈនៃបទដើមនោះឯង ក្នុងបទថា **អស្សមណាវ សមានា** ជាដើម សេចក្តីថា ឈ្មោះថា មិនជាសមណៈ ព្រោះមិនស្ងប់នូវបាប ឈ្មោះថា មិនជាព្រាហ្មណ៍ ព្រោះមិនបន្សាត់នូវបាប និងមិនបានជាព្រះអរហន្តព្រោះមិនកម្ចាត់នូវសត្រូវ គឺកិលេស ។

[ ៦៩ ] បទថា **ឧទានំ ឧទានេសិ** បានដល់ នាំឡើងនូវវត្ថុដែលគួរនាំឡើង ឧបមាដូចប្រេងណាមិនអាចនឹងវាល់បាន ហូរទៅ ប្រេងនោះ លោកហៅថា **អវសេក** សើមទៅឯង ហើយទឹកណាមិនអាចជាប់ក្នុងស្រះ បានជ្រះទៅឯង ទឹកនោះ ហៅថា ឱឃៈ គឺជំនន់ យ៉ាងណា វាចាដែលកើតអំពីបីតិឯណា រមែងមិនអាចទាញហទយៈបាន ក៏ចេញទៅខាងក្រៅ មិនទៅខាងក្នុងពាក្យនោះ ហៅថា **ឧទាន** ដូច្នោះ ។ អធិប្បាយថា បន្ទឺពាក្យដែលកើតអំពី

បីតិដែលមានសភាពដូច្នេះ ។ បទថា **ហត្ថិបទោបមោ** មានវិគ្គហៈថា ស្នាម ជើងដំរី ជាឧបមានៃធម៌នោះ ហេតុនោះ ធម៌នោះឈ្មោះថា **ហត្ថិបទោបមា** ។ លោកសម្តែងថា ធម៌នោះ រមែងមិនបរិបូណ៌ទូលំទូលាយយ៉ាងនេះ ។

[ ៧០ ] បទថា **នាគវនិកោ** បានដល់ ហ្មដំរី អ្នកសិក្សាវិជ្ជាដំរីហើយ ។ សួរថា កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបក្នុងទីនេះមិនពោលថាអ្នកឈ្លាស ឆ្លើយថា ព្រោះនឹងសម្តែងចែកឲ្យដឹងថា បុគ្គលណាឈ្លាសទុកខាងមុខ ។ ពិតហើយ បុគ្គលដែលចូលទៅ បើជាអ្នកឈ្លាស បុគ្គលនោះនឹងមិនសម្រេច ចិត្តជាមុន ព្រោះដូច្នោះ ទើបក្នុងទីនេះ លោកមិនពោលថា អ្នកឈ្លាស តែពោលទុកខាងមុខ ។

បទថា **វាមនិកា** បានដល់ មេដំរីពោះធំខ្លី មិនវែងដោយចំណែក បណ្តោយ ។ បទថា **ឧច្ចា ច និសេវិតំ** ទីដែលដំរីត្រដុសត្រង់ដើមជ្រៃ ជាដើម ដែលកម្ពស់ ៧ ឬ ៨ ហត្ថ ។ បទថា **ឧច្ចាកឡារិកា** បានដល់ មេដំរីមានជើងខ្ពស់ដូចឈើប្រត់ និងដែលឈ្មោះថា **កឡារិកា** ព្រោះមាន ភ្លុកខ្មៅលាយក្រហម ។ បានឮថា ដំរីនោះមានភ្លុកមួយងឡើង មួយងចុះ ទាំង ២ ឆ្ងាយគ្នា មិនជិតគ្នា ។ បទថា **ឧច្ចា ច ទន្តេហិ អារញ្ជិតានិ** សេចក្តីថា ទីដែលចាក់ដោយភ្លុក ដូចគ្នានឹងយកពូថៅកាប់ត្រង់ដើមជ្រៃជាដើម កម្ពស់ ៧ ឬ ៨ ហត្ថ ។ បទថា **ឧច្ចាករេណុកា នាម** បានដល់ មេដំរីមាន ជើងវែងដូចឈើប្រត់ និងដែលឈ្មោះថា **ករេណុកា** ព្រោះមានភ្លុកកន្ទប ។ បានឮថា មេដំរីទាំងនោះ មានភ្លុកកន្ទុប ព្រោះដូច្នោះ ទើបលោកហៅថា

**ករេណុកា** ។ បទថា **សោ និដ្ឋំ គច្ឆតិ** សេចក្ដីថា ហ្មទាំងនោះមិនទាន់ដាក់ចិត្តថា អញមកតាមស្នាមជើងដំរីណា ដំរីនោះ គឺដំរីមួយនេះឯង មិនមែនដទៃឡើយ អញឃើញស្នាមជើងដំបូងណា មិនទាន់ដាក់ចិត្តថា នឹងជាស្នាមជើងរបស់ដំរីក្លៀប អញទៅឃើញស្នាមជើងណាក្នុងទីទាប ក៏មិនសម្រេចចិត្តថា ជាស្នាមជើងរបស់ដំរីកឡារិកា ឬរបស់ដំរីករេណុកា កាលឃើញដំរីធំប៉ុណ្ណោះ ទើបដាក់ចិត្តថា ស្នាមជើងទាំងអស់នោះ ជាស្នាមជើងដំរីធំមួយនេះឯង ។ ក្នុងបទថា **ឯវមេវ ខោ** នេះ ប្រៀបធៀបឧបមាដូច្នេះ ។

គប្បីជ្រាបព្រះធម្មទេសនាតាំងអំពីខាងដើម រហូតដល់លះនីវរណៈថា ដូចជាព្រៃដំរី ។ ព្រះយោគាវចរដូចហ្មដំរីដ៏ឈ្លាស ព្រះសម្មាសម្ពុទ្ធដូចស្ដេចដំរី ឈាន និងអភិញ្ញា ដូចស្នាមជើងដំរីធំ ការដែលព្រះយោគាវចរមិនសម្រេចចិត្តថា ធម្មតាឈាន និងអភិញ្ញាទាំងនេះ រមែងមានដល់បរិព្វាជកក្រៅសាសនា ដូចប្រការដែលហ្មដំរីឃើញស្នាមជើងក្នុងទីនោះៗ ក៏មិនសម្រេចចិត្តថា ជាស្នាមជើងរបស់មេដំរីវាមនិកា របស់មេដំរីកឡារិកា ឬរបស់មេដំរីករេណុកា ការដែលព្រះអរិយសាវកសម្រេចព្រះអរហត្តហើយ សម្រេចចិត្ត ក៏ដូចគ្នានឹងហ្មឃើញដំរីធំ ហើយក៏សម្រេចចិត្តថា ស្នាមជើងដែលអញឃើញ ក្នុងទីនោះៗ គឺស្នាមជើងរបស់ដំរីនេះប៉ុណ្ណោះ មិនមែនដំរីដទៃឡើយ ឯការប្រៀបសេចក្ដីឧបមានេះ រហូតចប់ក៏គួរ ។ សូម្បីក្នុងទីនេះក៏គួរដូចគ្នា ។ តែត្រូវទាញយកបទបាលីមកតាមលំដាប់ ធ្វើក្នុងទីនេះតែម្យ៉ាង ។

សព្វថា **៩៨** ក្នុងពាក្យនោះជានិបាត ប្រើក្នុងអត្ថថា បញ្ជាក់ ទេសៈ ទី

អាស្រ័យ និងបទបូរណៈ ។ ឯ សព្ទនោះ ក្នុងទីខ្លះ លោកអាងដល់លោក ដូចក្នុងប្រយោគជាដើមថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** ព្រះតថាគត ទ្រង់រមែងកើតឡើងក្នុងលោកនេះ ដូច្នេះ ។ ក្នុងទីខ្លះ លោកពោលអាងដល់ សាសនា ដូចក្នុងប្រយោគជាដើមថា **ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ** សមណៈទី ១ មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។ ក្នុងទីខ្លះ លោកពោលអាងដល់ឱកាស ដូចក្នុងប្រយោគជាដើមថា

**ឥធេវ តិដ្ឋមានស្ស ទេវភូតស្ស មេ សតោ**
**បុនរាយុ ច មេ លទ្ធោ ឯវំ ជានាហិ មារិសា ។**

ហៃសម្លាញ់រមទុក្ខ កាលខ្ញុំកើតជាទេវតា តាំងនៅក្នុងឱកាសនេះឯង ហើយខ្ញុំបានអាយុបន្ថែមទៀត សូមអ្នកជ្រាប ដូច្នេះ ។

ក្នុងទីខ្លះ លោកពោលអាងដល់ត្រឹមតែធ្វើបទឲ្យពេញប៉ុណ្ណោះ ដូចក្នុង ប្រយោគជាដើមថា **ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ** ម្នាលភិក្ខុ ទាំងឡាយ តថាគតបរិភោគស្រេចហើយ ហាមភត្តហើយ ដូច្នេះ ។ តែក្នុង ទីនេះ គប្បីជ្រាបថា លោកពោលសំដៅយកលោក ។ លោកអធិប្បាយថា ម្នាលព្រាហ្មណ៍ តថាគតកើតឡើងក្នុងលោកនេះ ជាព្រះអរហន្ត ។បេ។ ជា អ្នកក្រាក់ហើយ ជាអ្នកចែកនូវធម៌ ។ ក្នុងសព្ទទាំងនោះ សព្ទថា **តថាគត** លោកពោលពិស្តារហើយ ក្នុងមូលបរិយាយសូត្រ សព្ទថា **អរហន្ត** ជាដើម លោកពោលពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។ ក្នុងបទថា **លោកេ ឧប្បជ្ជតិ**

នេះ ។ បទថា **លោក** មាន ៣ គឺ ឱកាសលោក សត្វលោក សង្ខារលោក ។ តែក្នុងទីនេះ លោកបំណងយកសត្វលោក ។

ព្រះពុទ្ធទាំងឡាយ កាលកើតក្នុងសត្វលោក រមែងមិនកើតក្នុងទេវលោក មិនកើតក្នុងព្រហ្មលោក កើតតែក្នុងមនុស្សលោកប៉ុណ្ណោះ សូម្បីក្នុងមនុស្សលោក ក៏មិនកើតក្នុងចក្រវាលដទៃ កើតតែក្នុងចក្រវាលនេះប៉ុណ្ណោះ ។ សូម្បីក្នុងចក្រវាលនេះក៏មិនចេះតែកើត តែងកើតក្នុងមជ្ឈិមប្រទេស ដែលមានបណ្តាយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ លោកកំណត់យ៉ាងនេះ គឺទិសខាងកើត មាននិគមឈ្មោះកជង្គលៈ បន្ទាប់អំពីនោះ ជាមហាសាល ហួសអំពីនោះទៅ ជាបច្ចន្តជនបទ ចាប់អំពីមហាសាលចូលមក ជាមជ្ឈិមជនបទ ទិសអគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ហួសអំពីនោះទៅ ជាបច្ចន្តជនបទ រាប់ពីស្ទឹងនោះចូលមក ជាមជ្ឈិមជនបទ ក្នុងទិសទក្សិណ មាននិគមឈ្មោះថា សេតកណ្ណិកៈ ហួសអំពីនោះទៅ ជាបច្ចន្តជនបទ អំពីសេតកណ្ណិកនិគមចូលមក ជាមជ្ឈិមជនបទ ទិសខាងលិច មានស្រុកព្រាហ្មណ៍ឈ្មោះថូនៈ ហួសអំពីថូនគ្រាមនោះទៅ ជាបច្ចន្តជនបទ ពីថូនគ្រាមនោះចូលមកជាមជ្ឈិមជនបទ ក្នុងទិសឧត្តរ មានភ្នំឈ្មោះឧសីរធជៈ ហួសពីភ្នំនោះទៅជាបច្ចន្តជនបទ អំពីភ្នំនោះចូលមកជាមជ្ឈិមជនបទ ។ មិនមែនតែព្រះតថាគតតែម្យ៉ាងប៉ុណ្ណោះទេ ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវក ព្រះអសីតិមហាថេរៈ ពុទ្ធមាតា ពុទ្ធបិតា ស្តេចចក្រពត្តិ ព្រាហ្មណមហាសាល និងគហបតីមហាសាលដទៃ រមែងកើតក្នុងមជ្ឈិមប្រទេសនេះទាំងអស់ ។ ក្នុង

មជ្ឈិមប្រទេសនោះ ព្រះតថាគត រាប់តាំងអំពីសោយមធុបាយាសដែលនាងសុជាតាថ្វាយរហូតដល់អរហត្តមគ្គ ឈ្មោះថា កំពុងកើត ក្នុងអរហត្តផល ឈ្មោះថា កើតហើយ រាប់តាំងអំពីមហាភិនេស្រ្កម៍ រហូតដល់អរហត្តមគ្គក្តី តាំងអំពីតុសិតរហូតដល់អរហត្តមគ្គក្តី តាំងអំពីបាទមូលនៃព្រះពុទ្ធព្រះនាមថា ទីបង្ករ រហូតដល់អរហត្តមគ្គក្តី ឈ្មោះថា កំពុងកើត ក្នុងអរហត្តផលឈ្មោះថា កើតហើយ ក្នុងទីនេះ លោកសំដៅយកការៈដែលព្រះតថាគត កើតមុនជាងបុគ្គលទាំងពួង ទើបពោលថា **ឧប្បជ្ជតិ** ។ ពិតហើយ ក្នុងទីនេះ បានសេចក្តីថា **តថាគតោ លោកេ ឧប្បន្នោ ហោតិ** ព្រះតថាគត រមែងកើតឡើងក្នុងលោក ។

បទថា **សោ ឥមំ លោកំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងលោកនេះថា គួរពោលក្នុងឥឡូវនេះ ។ បទថា **សទេវកំ** ប្រែថា ព្រមដោយទេវៈ ឈ្មោះថា **សទេវក** ព្រមដោយមារ ឈ្មោះថា **សមារក** ព្រមដោយព្រហ្ម ឈ្មោះថា **សព្រហ្មក** ព្រមដោយសមណៈ និងព្រាហ្មណ៍ ឈ្មោះថា **សស្សមណព្រាហ្មណី** ឈ្មោះថា **បជា** ព្រោះកើតទូទៅព្រមដោយទេវតា និងមនុស្ស ឈ្មោះថា **សទេវមនុស្ស**។ ក្នុងពាក្យទាំងនោះ គប្បីជ្រាបថា កាមាវចរទេវតា ៥ ជាន់ ឈ្មោះថា **សទេវក**។ ឯកាមាវចរទេវតាជាន់ទី ៦ ឈ្មោះថា **សមារក** ។ ព្រហ្មកាយិជាដើម ឈ្មោះថា **សព្រហ្មក** ។ សមណៈ និងព្រាហ្មណ៍ដែលជាសត្រូវរបស់ព្រះសាសនា នឹងជាអ្នកស្ងប់បាប ជាអ្នកបន្សាត់បាប ឈ្មោះថា **សស្សមណព្រាហ្មណី** សត្វលោកឈ្មោះថា **បជា**។ សម្មតិទេព

និងមនុស្សដ៏សេស ឈ្មោះថា **សទេវមនុស្សំ ។** សត្វលោក និងឱកាសលោក គប្បីជ្រាបថា លោកកាន់យកដោយបទ ៣ សត្វលោកតែម្យ៉ាង គប្បីជ្រាបថា លោកកាន់យកដោយអំណាចបជា ដោយបទទាំង ២ ក្នុងពាក្យនេះដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត អរូបាវចរលោក លោកកាន់យកដោយសព្ទថា **សទេវក** ឆកាមាវចរលោក លោកកាន់យកដោយសព្ទថា **សមារក** រូបីព្រហ្មលោក លោកកាន់យកដោយសព្ទថា **សព្រហ្មក** មនុស្សលោក ឬសត្វលោកដ៏សេស និងសម្មតិទេព លោកកាន់យកដោយអំណាចបរិស័ទ ៤ ដោយសព្ទថា **សស្សមណព្រាហ្មណា** ជាដើម ។

ម្យ៉ាងទៀត ក្នុងទីនេះ លោកពោលភាពដែលព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកទាំងមូល ដោយកំណត់យ៉ាងខ្ពស់ ដោយពាក្យថា **សទេវក ។** លំដាប់នោះ កាលទ្រង់កម្ចាត់សេចក្តីសង្ស័យនៃពួកជនដែលមានការគិតយ៉ាងនេះថា វសវត្តីមារជាអ្នកមានអានុភាពច្រើន ជាធំក្នុងកាមាវចរទេព ព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយឬ ដូច្នេះ ទើបត្រាស់ថា **សមារកំ ។** ម្យ៉ាងទៀត កាលទ្រង់កម្ចាត់សេចក្តីសង្ស័យរបស់ពពួកជន ដែលមានការគិតថា ព្រហ្មមានអានុភាពច្រើន ប្រើម្រាមដៃមួយ ផ្សាយរស្មីទៅក្នុងចក្រវាលមួយពាន់ ប្រើម្រាមដៃ ២ ។បេ។ ប្រើម្រាមដៃ ១០ ផ្សាយរស្មីទៅក្នុងចក្រវាលមួយម៉ឺន ហើយសោយសុខដែលកើតអំពីឈានសមាបត្តិដ៏កំពូល ព្រហ្មនោះទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយឬ ដូច្នេះ ទើបត្រាស់ថា **សព្រហ្មកំ ។** បន្ទាប់អំពី

នោះ កាលទ្រង់កម្ចាត់សេចក្ដីសង្ស័យរបស់ពួកជន ដែលមានការគិតថា សមណព្រាហ្មណ៍ជាច្រើន ជាសត្រូវចំពោះព្រះសាសនាទាំងនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយឬ ដូច្នេះ ទើបត្រាស់ថា **សស្សមណព្រាហ្មណី បជំ** ។ កាលទ្រង់ប្រកាសភាពដែលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវមារ និងសមណព្រាហ្មណ៍ទាំងនោះដ៏ឧត្តមយ៉ាងនេះហើយ លំដាប់នោះ កាលទ្រង់ប្រកាសភាពដែលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសត្វលោកដ៏សេស ដោយកំណត់យ៉ាងខ្ពស់ សំដៅដល់សម្មតិទេព និងមនុស្សដ៏សេស ទើបត្រាស់ថា **សទេវមនុស្សំ** ។ ក្នុងពាក្យនេះ មានលំដាប់ជាក់ច្បាស់ដូច្នេះ ។ បុរាណាចារ្យពោលថា បទថា **សទេវកំ** បានដល់លោកដ៏សេស និងពួកទេវតា ។ បទថា **សមារកំ** បានដល់ លោកដ៏សេស និងមារ ។ បទថា **សព្រហ្មកំ** បានដល់ លោកដ៏សេស និងពួកព្រហ្ម ។ លោកដាក់សត្វដែលចូលដល់ត្រៃភពទាំងអស់ចូលក្នុងបទទាំង ៣ ដោយអាការ ៣ ដោយប្រការដូច្នេះ កាលកំណត់កាន់យកដោយបទដើមទាំង ២ ទៀត ទើបពោលថា **សស្សមណព្រាហ្មណី បជំ សទេវមនុស្សំ** ដូច្នេះ ជាការកំណត់កាន់យកធាតុ ៣ ប៉ុណ្ណោះ ដោយអាការនោះៗ ដោយបទទាំង ៥ ដោយប្រការដូច្នេះ ។

ក្នុងបទថា **សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ** បទថា **សយំ** ប្រែថា ឯង ។ បទថា **អភិញ្ញា** ប្រែថា ដឹង អធិប្បាយថា ដឹងដោយញាណដ៏ក្រៃលែង ។ បទថា **សច្ឆិកត្វា** បានដល់ ធ្វើឲ្យជាក់ច្បាស់ ។ គឺលោកពោលបដិសេធការគិតដៅស្មានជាដើម ដោយពាក្យនេះ ។ បទថា **បវេទេតិ**

បានដល់ ធ្វើឲ្យរាក់ ឲ្យដឹង ឲ្យជាក់ច្បាស់ ប្រកាស ។ បទថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់អាស្រ័យសេចក្ដីករុណាក្នុងសត្វទាំងឡាយ ទ្រង់សម្ដែងធម៌ មានសុខដែលកើតអំពីវិវេកដ៏កំពូល កាលទ្រង់សម្ដែងធម៌នោះមិនថា តិច ឬច្រើន ក៏ទ្រង់សម្ដែងប្រការ មានលម្អខាងដើមជាដើម ។ អធិប្បាយថា ទ្រង់សម្ដែងលម្អសេចក្ដីចម្រើន មិនមានទោសខាងដើម ទ្រង់សម្ដែងលម្អសេចក្ដីចម្រើន មិនមានទោសត្រង់កណ្ដាល និងខាងចុង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សោ ធម្មំ ទេសេតិ** ជាដើមនោះដូចតទៅនេះ ទេសនាក៏មានខាងដើម កណ្ដាល ខាងចុង សាសនាក៏មានដូចគ្នា ។ ជាដំបូង គាថា ៤ បាទ បាទដំបូង ឈ្មោះថា ខាងដើមនៃទេសនា ២ បាទបន្ទាប់អំពីនោះ ឈ្មោះថា កណ្ដាល បាទទី ៤ ឈ្មោះថា ខាងចុង ។ ព្រះសូត្រដែលមានអនុសន្ធិ ១ ពាក្យនិទានជាខាងដើម ពាក្យថា **ឥទមវោច** ជាខាងចុង ត្រង់ចន្លោះពាក្យទាំង ២ ឈ្មោះថា កណ្ដាល ។ ព្រះសូត្រដែលមានអនុសន្ធិច្រើន អនុសន្ធិដំបូងជាខាងដើម អនុសន្ធិខាងចុងជាខាងចុង ត្រង់កណ្ដាលអនុសន្ធិ ១ ក្ដី អនុសន្ធិ ២ ក្ដី អនុសន្ធិច្រើនក្ដី ជាកណ្ដាល ។ ឯសាសនា សីល សមាធិ វិបស្សនា ឈ្មោះថា ជាខាងដើម ។ សមដូចពាក្យដែលលោកពោលថា ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ គឺសីលដ៏បរិសុទ្ធ ១ ទិដ្ឋិត្រង់ ១ ។ អរិយមគ្គដែលលោកពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមប្បដិបទា មិនប៉ះពាល់នូវធម៌អមខាងទាំងពីរនោះ តថាគត

បានត្រាស់ដឹងហើយ ដូច្នេះ ឈ្មោះថា ជាបទកណ្តាល ។ ផល និងនិព្វាន លោកហៅថា ខាងចុង ។ ពិតហើយ ផល ឈ្មោះថា ខាងចុង ដូចក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មានអរហត្តផលនោះ ជាប្រយោជន៍ មានអរហត្តផលនោះ ជាខ្លឹម មានអរហត្តផលនោះ ជាទីបំផុត ដូច្នេះ ។ និព្វាន លោកហៅថា ខាងចុង ដូចក្នុងប្រយោគថា ម្នាលអាវុសោវិសាខៈ ព្រោះព្រហ្មចរិយធម៌ ឈមទៅកាន់ព្រះនិព្វាន មានព្រះនិព្វាន ជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វាន ជាទីបំផុត ។ ក្នុងទីនេះ លោកបំណងយកខាងដើម កណ្តាល និងខាងចុងនៃទេសនា ។ ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ទ្រង់សម្តែងសីលជាខាងដើម សម្តែងមគ្គជាកណ្តាល សម្តែងនិព្វានជាខាងចុង ។ ដោយហេតុនោះ ទើបលោកពោលថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាណកល្យាណំ** ដូច្នេះ ។ ព្រោះដូច្នោះ ធម្មកថិកដទៃ កាលពោលធម៌ គប្បីពោលដូច្នេះថា

គប្បីសម្តែងសីលជាខាងដើម សម្តែងមគ្គត្រង់កណ្តាល សម្តែងនិព្វានជាខាងចុង នេះជាជំហរ គឺគោលរបស់ធម្មកថិក ។

បទថា **សាត្ថ សព្យញ្ជនំ** សេចក្តីថា ទេសនារបស់ធម្មកថិកណា ពណ៌នាអំពីរឿងបបរ បាយ ស្រី ប្រុសជាដើម ធម្មកថិកនោះ ឈ្មោះថា មិនសម្តែងធម៌ជាសាត្ថៈមានប្រយោជន៍ ឯព្រះមានព្រះភាគ ទ្រង់ទេសនា ដូច្នេះ ទ្រង់សម្តែងទេសនាអាស្រ័យសតិប្បដ្ឋាន ៤ ជាដើម ព្រោះដូច្នោះ ទើបលោក

ពោលថា ទ្រង់សម្តែងធម៌ជាសាត្ថៈមានប្រយោជន៍ ។ មា្យ៉ាងទៀត ទេសនារបស់ភិក្ខុណា ប្រកបព្យញ្ជនៈ ១ ជាដើម ឬមានព្យញ្ជនៈខ្វាក់ទាំងអស់ ឬមានព្យញ្ជនៈបើកទាំងអស់ សង្កត់ទាំងអស់ ទេសនារបស់ភិក្ខុនោះ ឈ្មោះថា **អព្យញ្ជនៈ** ព្រោះមិនបរិបូណ៌ដោយព្យញ្ជនៈ ដូចភាសារបស់ជនជាតិមិលក្ខៈ អម្បូរទមិឡ អម្បូរមនុស្សព្រៃ និងមនុស្សល្ងីល្ងើជាដើម ។ ឯព្រះមានព្រះភាគ ទ្រង់លះទេសនាដែលមានសភាពដូច្នោះ ទ្រង់មិនធ្វើឲ្យខូចព្យញ្ជនៈ ១០ ដែលពោលយ៉ាងនេះថា សិថិល ១ ធនិត ១ ទីឃៈ ១ រស្សៈ ១ លហុ ១ គរុ ១ និគ្គហិត ១ សម្ពន្ធ ១ វវត្ថិតៈ ១ វិមុត្ត ១ ដែលជាគោលនៃការពង្រីកតួព្យញ្ជនៈ ១០ ប្រភេទ ។

ទ្រង់សម្តែងធម៌ មានព្យញ្ជនៈបរិបូណ៌ ព្រោះដូច្នោះ ទើបហៅថា ទ្រង់សម្តែងធម៌ជាសព្យញ្ជនៈ គឺដល់ព្រមដោយព្យញ្ជនៈ ។ បទថា **កេវលំ** ក្នុងបទថា **កេវលបរិបុណ្ណំ** នេះ ប្រែថា មិនមានសេសសល់ ។ បទថា **បរិ-បុណ្ណំ** ប្រែថា មិនខ្វះមិនលើស ។ លោកអធិប្បាយដូច្នេះថា ទ្រង់សម្តែងធម៌បរិបូណ៌មិនមានចន្លោះនោះឯង ទេសនាត្រឹមតែមួយ ដែលមិនបរិបូណ៌មិនមាន ។ បទថា **បរិសុទ្ធំ** ប្រែថា ប្រាសចាកការសៅហ្មង ។ ពិតហើយ ធម្មកថិកណាអាស្រ័យធម៌ទេសនានេះ សម្តែងធម៌ដោយបំណងនឹងបានលាភ ឬសក្ការៈ ទេសនារបស់ធម្មកថិកនោះមិនបរិសុទ្ធ ។ ឯព្រះមានព្រះភាគ ទ្រង់មិនប្រាថ្នាលោកាមិស ហើយសម្តែងធម៌ ទ្រង់មានព្រះហឫទ័យទន់ភ្លន់ដោយមេត្តាភាវនា ដោយការផ្សាយប្រយោជន៍ ទ្រង់សម្តែងដោយចិត្ត ដែល

តាំងនៅក្នុងសភាវៈ ដែលលើកឲ្យខ្ពស់ឡើង ព្រោះដូច្នោះ ទើបលោកហៅថា ទ្រង់សម្តែងធម៌បរិសុទ្ធ ។ សកលសាសនាដែលសង្គ្រោះសិក្ខា ៣ លោកហៅថា ព្រហ្មចរិយៈ ក្នុងបទនេះថា **ព្រហ្មចរិយំ បកាសេតិ** ដូច្នេះ ព្រោះដូច្នោះ ទើបលោកហៅថា ទ្រង់ប្រកាសព្រហ្មចរិយៈ ។ ក្នុងបទថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិសុទ្ធំ** នេះ គប្បីឃើញអត្ថយ៉ាងនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងយ៉ាងនេះ ឈ្មោះថា ទ្រង់ប្រកាសព្រហ្មចរិយៈ គឺសកលសាសនា ដែលសង្គ្រោះដោយសិក្ខា ៣ លោកអធិប្បាយថា ការប្រព្រឹត្តដ៏ប្រសើរ ឬការប្រព្រឹត្តរបស់ព្រះអរិយៈទាំងឡាយ មានព្រះសម្ពុទ្ធជាដើម ដែលជាអ្នកប្រសើរ ព្រោះអត្ថថា ប្រសើរបំផុត ឈ្មោះថា ព្រហ្មចរិយៈ ។ បទថា **តំ ធម្មំ** បានដល់ ធម៌ដែលដល់ព្រមដោយប្រការដូចពោលហើយនោះ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ចង្អុលយកគហបតីមុនថា **សុណាតិ គហបតិ** ឆ្លើយថា ព្រោះគហបតីកម្ចាត់មានះចេញបាន មានចំនួនច្រើន ។ ពិតហើយ ដោយច្រើន បុគ្គលដែលបួសអំពីខត្តិយត្រកូល រមែងអាស្រ័យជាតិធ្វើនូវមានះ ដែលបួសអំពីត្រកូលព្រាហ្មណ៍ អាស្រ័យមន្តធ្វើនូវមានះ ដែលបួសអំពីត្រកូលដែលមានជាតិថោកទាប ក៏តាំងនៅមិនបាន ព្រោះខ្លួនមានជាតិផ្សេងពីគេ ។ ឯក្មេងៗត្រកូលគហបតី មានញើសហូរ ខ្នងឡើងផ្កាអំបិល ភ្ជួរដី កម្ចាត់មានះ និងការរឹងត្អឹងបាន ក្មេងទាំងនោះ បួសហើយ ក៏មិនមានមានះ ឬការរឹងត្អឹង រៀនព្រះពុទ្ធវចនៈតាមកម្លាំង ធ្វើកិច្ចក្នុងវិបស្សនា រមែងតាំងនៅក្នុងអរហត្ត

បាន បុគ្គលដែលឈ្មោះថា ចេញបួសអំពីត្រកូលក្រៅអំពីនេះ មានមិនច្រើន ពួកគហបតីប៉ុណ្ណោះ មានច្រើន ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ចង្អុលបង្ហាញគហបតីមុន ព្រោះកម្ចាត់មានះបាន មានចំនួនច្រើន ។ បទថា **អញ្ញតរស្មឹ វា** បានដល់ ឬក្នុងត្រកូលក្រៅអំពីនេះណាមួយ ។ បទថា **បច្ឆាជាតោ** ប្រែថា កើតឯក្រោយ ។ បទថា **តថាគតេ សទ្ធំ បដិលភតិ** សេចក្តីថា ស្តាប់ធម៌ដែលបរិសុទ្ធហើយ ត្រឡប់បាននូវសទ្ធាក្នុងព្រះតថាគតដែលជាម្ចាស់នៃធម៌ថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងឯងដោយប្រពៃហ្ន៎ ។ បទថា **ឥតិបដិសញ្ចិក្ខតិ** បានដល់ ពិចារណាឃើញយ៉ាងនេះ ។ បទថា **សម្ពាធោ ឃរាវាសោ** សេចក្តីថា ឃរាវាស សូម្បីពីរនាក់ប្តីប្រពន្ធ ដែលនៅផ្ទះឆ្ងាយពីគ្នា ៦០ ហត្ថ ឬក្នុងទី ១០០ យោជន៍ ដូច្នោះ ឃរាវាសក៏ឈ្មោះថា ចង្អៀត ព្រោះអត្ថថា ពីរនាក់ប្តីប្រពន្ធនោះ មានការកង្វល់ មានការជាប់ចំពាក់ក្នុងគ្នានិងគ្នា ។ បទថា **រជាបថោ** លោកពោលក្នុងមហាអដ្ឋកថាថា បានដល់ ស្ថានទីតាំងឡើងនៃធូលី គឺរាគៈជាដើម ។ សូម្បីនឹងពោលថា ផ្លូវមកក៏គួរ ។ បព្វជ្ជាប្រៀបដូចទីវាល ព្រោះអត្ថថា មិនជាប់ជំពាក់ ដូច្នោះ ទើបឈ្មោះថា **អព្ភោកាស** ។ ពិតហើយ បុគ្គលដែលបួសហើយ សូម្បីនៅក្នុងផ្ទះកំពូល ប្រាសាទកែវ និងទេវវិមានជាដើម ដែលមានបង្អួចបិទ ដែលគេបិទបាំង ក៏មិនជាប់មិនជំពាក់ ។ ដោយហេតុនោះ ទើបត្រាស់ថា បព្វជ្ជាទូលំទូលាយយ៉ាងក្រៃលែង ។ ម្យ៉ាងទៀត ឃរាវាសឈ្មោះថា ចង្អៀត ព្រោះមិនមានឱកាសធ្វើបុណ្យ ឈ្មោះថា **រជាបថ** ព្រោះ

ជាទីប្រជុំនៃធូលី គឺកិលេស ដូចទីគំនរសំរាម ដែលគេមិនរក្សា បព្វជ្ជា ឈ្មោះថា **អព្ភោកាស** ព្រោះមានឱកាសធ្វើបុណ្យបានតាមសប្បាយ ។

ក្នុងបទថា **នយិទំ សុករំ ។បេ។ បព្វជ្ជេយ្យំ** នេះ នឹងពោលដោយសង្ខេប ដូច្នេះ ព្រហ្មចរិយៈ គឺសិក្ខា ៣ នេះ ឈ្មោះថា បរិបូណ៌ដោយចំណែកមួយ ព្រោះមិនធ្វើឲ្យដាច់សូម្បីត្រឹមតែមួយថ្ងៃ គប្បីឲ្យដល់ចរិមកចិត្ត និងឈ្មោះថា បរិសុទ្ធដោយចំណែកមួយ ព្រោះមិនអាប់អួរដោយមន្ទិល គឺកិលេស សូម្បីតែមួយថ្ងៃឲ្យដល់ចរិមកចិត្ត ។ បទថា **សង្ខលិខិតំ** បានដល់គប្បីប្រព្រឹត្តដូចគ្នានឹងការដុសខាត់ស័ង្ខ គឺប្រៀបធៀបដូចស័ង្ខដែលគេខាត់ហើយ ។ អ្នកនៅគ្រប់គ្រងផ្ទះ គឺជាអ្នកនៅកណ្តាលផ្ទះ ប្រព្រឹត្តព្រហ្មចរិយៈដែលបរិសុទ្ធបរិបូណ៌ដោយចំណែកមួយដូចស័ង្ខនេះ ធ្វើមិនបានងាយឡើយ ។ បើដូច្នោះ អញគប្បីកោរសក់ និងពុកមាត់ពុកចង្កា គ្រង គឺដណ្តប់សំពត់ដែលឈ្មោះកាសាយៈ ព្រោះជ្រលក់ដោយទឹកម្ចត់ ដែលសមគួរសម្រាប់អ្នកប្រព្រឹត្តព្រហ្មចរិយៈ បួស ជាអ្នកមិនមានផ្ទះ ។ ព្រោះហេតុដែលការងារ មានភ្ជួរស្រែ និងលក់ដូរជាដើម ជាប្រយោជន៍ដល់ផ្ទះ ហៅថា **អគារិយ** អគារិយកិច្ចនោះ មិនមានក្នុងបព្វជ្ជា ដូច្នោះ បព្វជ្ជា គប្បីជ្រាបថា **អនគារិយ** ក្នុងពាក្យនេះ ។ មិនមានកិច្ចនៃអ្នកគ្រប់គ្រងផ្ទះនោះ ។ បទថា **បព្វជេយ្យំ** ប្រែថា គប្បីបដិបត្តិ ។ បទថា **អប្បំ វា** សេចក្តីថា ភោគៈតិចជាងមួយពាន់ចុះមក ឈ្មោះថា តិច ខ្ពស់ជាងមួយពាន់ឡើងទៅ ឈ្មោះថា ច្រើន ។ ខ្សែស្រឡាយ គឺញាតិ ឈ្មោះថា សាលោហិត ព្រោះអត្ថថា ជាប់ទាក់ទងគ្នា

សាលោហិតនោះ តិចជាង ២០ ចុះមក ឈ្មោះថា តិច ច្រើនជាង ២០ ឡើងទៅ ឈ្មោះថា ច្រើន ។

[ ៧១ ] បទថា **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** សេចក្ដីថា ភិក្ខុ ឈ្មោះថា **សមាបន្ន** ព្រោះសិក្សាក្នុងសិក្ខា ពោល គឺអធិសីល និងសាជីវៈ ពោល គឺសិក្ខាបទដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តហើយសម្រាប់ភិក្ខុទាំងឡាយ ដែលនៅរួមគ្នា មានជីវិតដូចគ្នា មានការប្រព្រឹត្តស្មើគ្នា ដូច្នោះ ទើបភិក្ខុនោះឈ្មោះថា **សិក្ខាសាជីវសមាបន្ន** សម្រាប់ភិក្ខុទាំងឡាយ សេចក្ដីថា ធ្វើសិក្ខាឲ្យបរិបូណ៌ និងមិនកន្លងសាជីវៈ ចូលដល់សិក្ខា និងសាជីវៈទាំង ២ នោះ ។ កថាពោលដោយបាណាតិបាតជាដើម ក្នុងបទថា **បាណាតិបាតំ បហាយ** ជាដើម លោកពោលពិស្ដារហើយខាងដើម ។ បទថា **បហាយ** បានដល់ លះនូវការទ្រុស្តសីល ពោល គឺចេតនាសម្លាប់សត្វនេះ ។ បទថា **បដិវិរតោ ហោតិ** សេចក្ដីថា វៀរចាកការទ្រុស្តសីលនោះ តាំងអំពីពេលដែលលះបានហើយ ។ បទថា **និហិតទណ្ឌោ និហិតសត្ថោ** សេចក្ដីថា ឈ្មោះថា ដាក់ចុះនូវដំបង កាំបិត ព្រោះមិនកាន់យកទៅដើម្បីសម្លាប់បុគ្គលណាមួយឡើយ ។ ក្នុងទីនេះ គ្រឿងឧបករណ៍ដ៏សេសទាំងអស់ វៀរដំបងចេញ គប្បីជ្រាបថា ឈ្មោះថា សស្ត្រា ព្រោះជាគ្រឿងបៀតបៀនសត្វទាំងឡាយ ។ ភិក្ខុទាំងឡាយ កាន់ឈើច្រត់ ឬកាំបិតកាត់ឈើស្ទន់ ឬកាំបិតតូចមិនមែនដើម្បីសម្លាប់បុគ្គលណាម្នាក់ ដូច្នោះ ទើបឈ្មោះថា ដាក់ចុះនូវដំបង និងសស្ត្រា ។ បទថា **លជ្ជី** បានដល់ បុគ្គលប្រកបដោយសេចក្ដី

ខ្លាស មានការវៀរស្កៀសក្នុងបាបជាលក្ខណៈ ។ បទថា **ទយាបន្នោ** បានដល់ការអាណិតអាសូរ គឺភាពជាអ្នកមានចិត្តមេត្តា ។ បទថា **សព្វបាណភូត-ហិតានុកម្បិ** បានដល់ ជាអ្នកអនុគ្រោះនូវប្រយោជន៍ដល់សព្វសត្វទាំងពួង អធិប្បាយថា ឈ្មោះថា ជាអ្នកមានចិត្តអនុគ្រោះដល់សព្វសត្វ ព្រោះជាអ្នកមានករុណានោះ ។ បទថា **វិហរតិ** បានដល់ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ គឺចិញ្ចឹមអត្តភាព ។ បុគ្គលឈ្មោះថា **ទិន្នាទាយី** ព្រោះកាន់យករបស់ដែលគេឲ្យហើយប៉ុណ្ណោះ ។ ឈ្មោះថា **ទិន្នបាដិកង្ខី** ព្រោះសង្ឃឹមចំពោះតែវត្ថុដែលគេឲ្យដោយចិត្តប៉ុណ្ណោះ ។ បុគ្គលណា រមែងលួច បុគ្គលនោះឈ្មោះថា ថោរ ដោយការលួច ។ ឈ្មោះថា **អថេនេន** ព្រោះមិនលួច ។ ឈ្មោះថា **សុចិភូតេន** ព្រោះជាអ្នកមិនលួចនោះឯង ។ បទថា **អត្តនា** ប្រែថា ព្រមទាំងអត្តភាព លោកអធិប្បាយថា កាលបើដូច្នេះ បុគ្គលនោះរមែងធ្វើអត្តភាពឲ្យស្អាតបាន ។ បទថា **អព្រហ្មចរិយំ** ប្រែថា ប្រព្រឹត្តមិនប្រសើរ ។ ឈ្មោះថា **ព្រហ្មចារី** ព្រោះប្រព្រឹត្តអាចារដ៏ប្រសើរ គឺប្រសើរបំផុត ។ បទថា **អារាចារី** បានដល់ ប្រព្រឹត្តឆ្ងាយចាកអព្រហ្មចរិយៈ ។ បទថា **មេថុនា** បានដល់ អសទ្ធម្ម ដែលរាប់ថា មេថុន ព្រោះសេព ដោយបានវោហារថា **មេថុនក** ព្រោះហាក់ដូចជាត្រូវរាគៈចោមរោម ។ បទថា **គាមធម្មា** ប្រែថា ធម៌អ្នកស្រុក ។ ឈ្មោះថា **សច្ចវាទី** ព្រោះនិយាយពាក្យពិត ។ ឈ្មោះថា **សច្ចសន្ធោ** ព្រោះ យកសច្ចៈ និងសច្ចៈតភ្ជាប់គ្នា អធិប្បាយថា មិនពោលកុហក ។ សេចក្តីពិត បុរសបុគ្គលណា ក្នុងកាល

ខ្លះពោលកុហក ក្នុងកាលខ្លះពោលពិត មិនយកសច្ចៈ និងសច្ចៈភ្ជាប់តគ្នា ព្រោះសច្ចៈ និងមុសាវាទ មិននៅខាងក្នុង ព្រោះហេតុនោះ បុរសនោះមិនឈ្មោះថា យកសច្ចៈ និងសច្ចៈតភ្ជាប់គ្នាឡើយ តែបុគ្គលនេះមិនមែនដូច្នោះឡើយ ។ បុគ្គលមិនពោលមុសាវាទ ព្រោះហេតុនៃជីវិត តែយកសច្ចៈតភ្ជាប់សច្ចៈ ពោលពិតគ្រប់រឿង ហេតុនោះ បុគ្គលនោះ ឈ្មោះថា **សច្ចសន្ធ**។ បទថា **ថេតោ** ប្រែថា មុឺងម៉ាត់ អធិប្បាយថា ទៀងទាត់ ។ ពិតហើយ បុគ្គលណាម្នាក់ ជាអ្នកមានវាចាមិនស្ថិតស្ថេរ ដូចជ្រលក់ដោយរមៀត ដូចបោះបង្គោលចូលត្រង់ពំនូកអង្កាម និងដូចត្រឡាចដែលគេដាក់លើខ្នងសេះ ដូច្នោះ ។ បុគ្គលម្នាក់ទៀត មានវាចាមាំទាំ ដូចគំនូសលើថ្ម និងដូចសសរខឿន សូម្បីបុគ្គលយកដាវកាត់ក្បាល ក៏មិនពោលវាចាឲ្យជា ២ ឡើយ បុគ្គលនេះឈ្មោះថា **ថេត** គឺជាអ្នកមានវាចាទៀងទាត់ ។ បទថា **បច្ចយិកោ** ប្រែថា បុគ្គលដែលគួរជឿបាន អធិប្បាយថា គួរជឿ ។ សេចក្ដីពិត បុគ្គលពួកខ្លះជាអ្នកមិនគួរជឿ កាលគេសួរថា ពាក្យនេះអ្នកណាពោល បុគ្គលនោះពោលឬ រមែងត្រូវគេឆ្លើយថា កុំជឿពាក្យរបស់បុគ្គលនោះ ។ បុគ្គលម្នាក់ជាអ្នកគួរជឿបាន កាលគេសួរថា ពាក្យនេះអ្នកណាពោល បុគ្គលនោះពោលឬ រមែងត្រូវឆ្លើយថា បើបុគ្គលនោះនិយាយសោត ពាក្យនេះប៉ុណ្ណោះជាប្រមាណ ឥឡូវនេះ មិនមានពាក្យដែលត្រូវបញ្ជាក់ ពាក្យនេះ ត្រឹមត្រូវយ៉ាងនោះឯង បុគ្គលនេះ លោកហៅថា **បច្ចយិកោ** ។

បទថា **អវិសំវាទកោ លោកស្ស** សេចក្ដីថា រមែងមិនពោលពាក្យជា

ពិសជាមួយសត្វលោក ព្រោះមានប្រក្រតីពោលតែពាក្យសច្ចៈនោះ ។ បទថា **ឥមេសំ ភេទាយ** សេចក្តីថា ដើម្បីទម្លាយពួកជន ដែលបានឮក្នុងសម្នាក់នៃបុគ្គលដែលពោលថា បានស្តាប់មកអំពីខាងនេះ ។ បទថា **ភិន្នានំ វា សន្ធាតា** សេចក្តីថា កាលបុគ្គល ២ ពួក ជាមិត្តនឹងគ្នា ឬជាអ្នកទាក់ទងគ្នា មានរួមឧបជ្ឈាយ៍ជាមួយគ្នាជាដើម បែកគ្នាដោយកិច្ចណាមួយហើយ បុគ្គលដែលគួរជឿបាន ចូលទៅរកបុគ្គលមួយចំណែកទៀត ហើយពោលធ្វើនូវការស្និទ្ធស្នាលជាដើមថា ការយ៉ាងនេះ មិនសមគួរដល់ពួកលោក ដែលកើតក្នុងត្រកូលដូច្នេះ ដែលជាពហូសូតយ៉ាងនេះ ដូច្នេះ ។ បទថា **អនុប្បទាតា** បានដល់ បុគ្គលអនុគ្រោះបុគ្គលដែលផ្គត់ផ្គង់ហើយ អធិប្បាយថា បុគ្គលដែលគួរជឿបាន ឃើញជនទាំងពីរជាអ្នកសាមគ្គីគ្នាហើយ និយាយធ្វើឲ្យមាំថា ការយ៉ាងនេះ ជាការសមគួរដល់ពួកលោក ដែលកើតក្នុងត្រកូលបែបនោះ ប្រកបដោយគុណបែបនេះ ដូច្នេះជាដើម ។ ឈ្មោះថា **សមគ្គារាមោ** ព្រោះមានបុគ្គលសាមគ្គីជាទីមកត្រេកអរ អធិប្បាយថា សាមគ្គីបុគ្គលនោះ មិនមានក្នុងទីណា រមែងមិនប្រាថ្នានៅក្នុងទីនោះ ។ បាលីថា **សមគ្គរាមោ** ដូច្នេះក៏មាន ។ ឯសេចក្តីក៏ដូចគ្នា ។ បទថា **សមគ្គរតោ** បានដល់ បុគ្គលត្រេកអរក្នុងបុគ្គលដែលព្រមព្រៀងគ្នា អធិប្បាយថា រមែងមិនប្រាថ្នាលះបុគ្គលដែលសាមគ្គីគ្នាទាំងនោះ ទៅក្នុងទីដទៃ ។ ឈ្មោះថា បុគ្គលសរសើរក្នុងបុគ្គលដែលសាមគ្គីគ្នា ព្រោះបុគ្គលដែលគួរជឿបាននោះ ឃើញក្តី បានឮក្តី នូវបុគ្គលដែលសាមគ្គីគ្នា រមែងត្រេកអរ ។ បទថា **សមគ្គករណី វាចំ**

**ភាសិតា** សេចក្ដីថា បុគ្គលដែលគួរជឿបាននោះ រមែងពោលវាចាដែលធ្វើបុគ្គលឲ្យសាមគ្គីគ្នា ដែលជាវាចាសម្ដែងគុណនៃសាមគ្គីធម៌តែម្យ៉ាង មិនពោលវាចាផ្ទុយគ្នាអំពីនេះឡើយ ។ ទោសលោកហៅថា **ឯល** ក្នុងបទថា **នេលា** ដូច្នេះ វាចា ឈ្មោះថា មិនមានទោស ព្រោះទោសនៃវាចានោះមិនមាន អធិប្បាយថា វាចាមិនមានទោស ។ បទថា **នេលា** នោះ ដូចគ្នានឹង **នេល** សព្ទ ដែលព្រះមានព្រះភាគត្រាស់ក្នុងគាថានេះថា **នេលង្គោ សេត-បច្ឆាទោ** ដូច្នេះជាដើម ។ បទថា **កណ្ណសុខា** បានដល់ វាចាពីរោះត្រចៀក គឺមិនកើតនូវការចាក់ដោតត្រចៀក ដូចត្រូវម្ជុលចាក់ ព្រោះជាវាចាពីរោះដោយព្យញ្ជនៈ ។ ឈ្មោះថា **បេមនីយា** ព្រោះវាចានោះ មិនធ្វើឲ្យកើតការក្រោធ ធ្វើការស្រឡាញ់ឲ្យកើតពេញសរីរៈ ព្រោះជាវាចាពីរោះដោយអត្ថ ។ ឈ្មោះថា **ហទយង្គមា** ព្រោះវាចានោះ រមែងដល់ចិត្ត គឺមិនទង្គិច ចូលទៅដល់ចិត្តដោយស្រួល ។ ឈ្មោះថា **បោរី** ព្រោះវាចានោះ មាននៅក្នុងក្រុង ព្រោះជាវាចាដែលបរិបូណ៌ដោយគុណ ។ ឈ្មោះថា **បោរី** ព្រោះវាចានោះ ជាវាចាទន់ភ្លន់ ឧបមាដូចស្ត្រីដែលចម្រើនក្នុងបុរី ដូច្នេះក៏មាន ។ ឈ្មោះថា **បោរី** ព្រោះវាចានោះ ជាវាចាអ្នកបុរី ដូច្នេះក៏មាន អធិប្បាយថា ជាពាក្យរបស់អ្នកក្រុង ។ ព្រោះថា អ្នកក្រុង រមែងជាអ្នកមានពាក្យសមគួរ គឺហៅបុគ្គលស្រករឪពុក ថាឪពុក ស្រករម៉ែ ថាម៉ែ ស្រករបង ថាបង ។ ឈ្មោះថា **ពហុជនកន្តា** ព្រោះពាក្យបែបនោះ ជាវាចាដែលមនុស្សជាច្រើនចូលចិត្ត ។ ឈ្មោះថា **ពហុជនមនាបា** ព្រោះវាចានោះ ជាទីពេញចិត្ត គឺ

ការចម្រើនចិត្តដល់ជនជាច្រើន ព្រោះជាវាចាដែលមនុស្សទាំងឡាយប្រាថ្នា នោះឯង ។ បុគ្គលឈ្មោះថា **កាលវាទី** ព្រោះពោលដោយកាល អធិប្បាយថា បុគ្គលនោះរមែងកំណត់កាលដែលគួរពោល ហើយពោល ។ ឈ្មោះថា **ភូតវាទី** ព្រោះរមែងពោលពាក្យដែលពិត គឺពាក្យពិត បានដល់ ពាក្យពិតតែម្យ៉ាង ។ ឈ្មោះថា **អត្ថវាទី** ព្រោះបុគ្គលនោះ ពោលធ្វើឲ្យជាពាក្យអាស្រ័យអត្ថ ដែលជាប្រយោជន៍ក្នុងភពនេះ និងភពខាងមុខតែម្យ៉ាង ។ ឈ្មោះថា **ធម្មវាទី** ព្រោះបុគ្គលនោះ រមែងពោលធ្វើឲ្យជាពាក្យអាស្រ័យលោកុត្តរធម៌ ៩ ។ ឈ្មោះថា **វិនយវាទី**ព្រោះពោលធ្វើឲ្យជាពាក្យអាស្រ័យសំវរវិន័យ និងបហានវិន័យ ។ ឱកាសទីតាំង លោកហៅថា គោលនៃវាចា នោះមាន ហេតុនោះ វាចានោះ ឈ្មោះថា **និធានវតី** អធិប្បាយថា បុគ្គលដែលគួរជឿបាននោះ រមែងជាអ្នកតាក់តែងពោលវាចាដែលសមគួរ គប្បីរក្សាទុកក្នុងហឫទ័យ ។ បទថា **កាលេន** សេចក្តីថា បុគ្គលដែលគួរជឿបាននោះ កាលពោលពាក្យបែបនេះ ក៏រមែងមិនពោលដោយការដែលមិនសមគួរ ដោយប្រកាន់ថា នឹងពោលមានពាក្យជាគោលដូច្នេះ តែពិចារណាកាលដែលសមគួរហើយ ទើបពោល ។ បទថា **សាបទេសំ** សេចក្តីថា មានឧបមា មានហេតុ ។ បទថា **បរិយន្តវតី** សេចក្តីថា ទីបំផុតនៃវាចានោះប្រាកដដោយប្រការណា បុគ្គលដែលគួរជឿបាននោះ ពោលសម្តែងទីបំផុត ដោយប្រការដូច្នេះ ។ បទថា **អត្ថសញ្ហិតំ** សេចក្តីថា ឈ្មោះថា ដល់ព្រមដោយប្រយោជន៍ ព្រោះវាចានោះ ដែលបុគ្គលអ្នកចែកដោយន័យជាច្រើន មិនអាច

នឹងឲ្យកាន់យកទីបំផុតបាន ម្យ៉ាងទៀត សេចក្តីថា បុគ្គលដែលគួរជឿនោះ រមែងពោលវាចាដែលឈ្មោះថា ប្រកបដោយប្រយោជន៍ ព្រោះវាចានោះ ជាវាចាប្រកបដោយប្រយោជន៍ ដែលបុគ្គលនោះពោល លោកពោលអធិប្បាយថា បុគ្គលដែលគួរជឿនោះ មិនលើកពាក្យណាមួយ ហើយទៅពោលផ្តេសផ្តាសជាពាក្យមួយទៀតឡើយ ។

បទថា **វីជគាមភូតគាមសារម្ភា** សេចក្តីថា វៀរចាកការធ្វើពីជគាម ៥ យ៉ាង គឺពូជកើតអំពីឫស ពូជកើតអំពីដើម ពូជកើតអំពីថ្នាំង ពូជកើតអំពីត្រួយ ពូជកើតអំពីគ្រាប់ និងភូតគាម មានរបស់ពណ៌ខៀវ មានស្មៅ និងដើមឈើជាដើមប្រភេទណាមួយ គឺបំផ្លាញដោយកាត់ និងដុតជាដើម ។ បទថា **ឯកភត្តិកោ** សេចក្តីថា ភត្ត ២ យ៉ាង គឺភត្តដែលគប្បីបរិភោគក្នុងវេលាព្រឹក និងភត្តដែលគប្បីបរិភោគក្នុងវេលាល្ងាច ទាំង ២ យ៉ាងនោះ ភត្តដែលគប្បីបរិភោគក្នុងវេលាព្រឹក កំណត់ខាងក្នុងត្រឹមថ្ងៃត្រង់ ភត្តដែលគប្បីបរិភោគក្នុងវេលាល្ងាច កំណត់តាំងអំពីថ្ងៃត្រង់ រហូតដល់អរុណរះ ព្រោះដូច្នោះ សូម្បីបរិភោគក្នុងវេលាថ្ងៃត្រង់ ១០ ដង ក៏ឈ្មោះថា ជាអ្នកមានភត្តម្តង លោកពោលសំដៅយកភាពជាអ្នកមានភត្តម្តងនោះ ពោលថា **ឯកភត្តិកោ** ដូច្នេះ ។ ឈ្មោះថា **រត្តូបរតោ** ព្រោះវៀរចាកការបរិភោគក្នុងវេលារាត្រីនោះ ។ ការបរិភោគក្នុងវេលាហួសពីថ្ងៃត្រង់ទៅហើយ ទល់គ្នានឹងព្រះអាទិត្យលិច ឈ្មោះថា បរិភោគក្នុងវេលាវិកាល ។

ព្រោះវៀរចាកវិកាលភោជននោះ ទើបឈ្មោះថា វៀរចាកការបរិភោគ

អាហារក្នុងវេលាវិកាល ។ ឈ្មោះថា **វិសូកទស្សនំ** ព្រោះជាការមើលដែលជាសត្រូវ ព្រោះមិនអនុលោមតាមព្រះសាសនា ។ ឈ្មោះថា **នច្ចគីតវាទិ-តវិសូលទស្សនា** ព្រោះការរាំ ច្រៀង ប្រគំ ដោយអំណាចការរាំឯង និងឲ្យអ្នកដទៃរាំជាដើម និងការមើលដែលជាសត្រូវ ដែលការរាំជាដើមប្រព្រឹត្តទៅដោយហោច មានក្មោករាំជាដើម ។ ការប្រកបឯងក្តី ការឲ្យអ្នកដទៃប្រកបក្តីនូវការរាំជាដើម ឬការមើលការរាំជាដើម ដែលអ្នកដទៃប្រកប រមែងមិនគួរដល់ភិក្ខុ និងភិក្ខុនីទាំងអស់ ។ បទថា **មាលា** ក្នុងបទថា **មាលា** ជាដើមបានដល់ ផ្កាប្រភេទណាមួយ ។ បទថា **គន្ធំ** បានដល់ គ្រឿងក្រអូបបែបណាមួយ ។ បទថា **វិលេបនំ** បានដល់ គ្រឿងលាបស្បែក ។ បុគ្គលប្រដាប់ក្នុងគ្រឿងប្រដាប់យ៉ាងនោះ ឈ្មោះថា ទ្រទ្រង់ ។ បុគ្គលដែលធ្វើទីដែលខ្វះខាតឲ្យពេញ ឈ្មោះថា ប្រដាប់ ។ បុគ្គលត្រេកអរដោយគ្រឿងក្រអូប និងគ្រឿងធ្វើស្បែកឲ្យផូរផង់ ឈ្មោះថា តាក់តែង ។ ហេតុ លោកហៅថា ឋាន: ។ អធិប្បាយថា ព្រោះដូច្នោះ មហាជនធ្វើការទ្រទ្រង់នូវផ្កាកម្រងជាដើមនោះដោយចេតនាជាគ្រឿងទ្រុស្តសីលណា ជាអ្នកវៀរចាកចេតនាជាគ្រឿងទ្រុស្តសីលនោះ ។ ទីដេកដែលលើសប្រមាណ លោកហៅថា **ឧច្ចាសយន** ។ កម្រាលដែលមិនសមគួរ ឈ្មោះថា **មហាសយន** ។ អធិប្បាយថា វៀរចាកទីដេកខ្ពស់ និងទីដេកធំនោះ ។ បទថា **ជាតរូបំ** បានដល់ មាស ។ បទថា **រជតំ** សេចក្តីថា វត្ថុណាដល់នូវការបញ្ញត្តថា ជាកហាបណ: លោហ-មាសក មាសកជ័រ មាសកឈើ វៀរចាកការទទួលវត្ថុទាំង ២ នោះ

អធិប្បាយថា មិនទទួលឯង មិនឲ្យអ្នកដទៃទទួលវត្ថុទាំង ២ នោះ មិនត្រេកអរវត្ថុទាំង ២ ដែលអ្នកដទៃទុកដាក់ ។

បទថា **អាមកធញ្ញប្បដិគ្គហណា** បានដល់ ចាកការទទួលធញ្ញជាតិឆៅ ៧ យ៉ាង គឺស្រូវសាលី ស្រូវខ្សាយ ស្រូវជំណើប ស្រងែ ថ្ពៅ ស្កួយ និងស្មៅគែលលក ។ មិនមែនហាមការទទួលធញ្ញជាតិទាំងនោះតែម្យ៉ាងទេ ទោះការប៉ះពាល់ ក៏មិនគួរដល់ភិក្ខុទាំងឡាយ ។ បទថា **អាមកមំសប្បដិគ្គហណា** នេះ សេចក្ដីថា ការទទួលសាច់ និងត្រីឆៅ រមែងមិនគួរដល់ភិក្ខុទាំងឡាយ សូម្បីតែប៉ះក៏មិនគួរ ក្រៅអំពីអ្វីដែលទ្រង់អនុញ្ញាតដោយចំពោះ ។ បទថា **ឥត្ថី** ក្នុងបទថា **ឥត្ថី កុមារិកប្បដិគ្គហណា** នេះ បានដល់ ស្រីដែលកំពុងនៅជាមួយប្រុស ក្រៅអំពីនោះ ចាត់ជាស្រីក្រមុំ ។ ការទទួលក្ដី ការប៉ះពាល់ក្ដី នូវស្រីទាំងនោះ ។ ក្នុងបទថា **ទាសី ទាសប្បដិគ្គហណា** នេះ សេចក្ដីថា មិនគួរទទួលជនទាំងនោះមកធ្វើជាទាសីទាសាឡើយ តែបើគេពោលថា ខ្ញុំប្រគេនកប្បិយការកៈ ខ្ញុំប្រគេនញោមវត្ត ក៏គួរទទួលបាន ។ ក្នុងពពែ និងចៀមជាដើម មានស្រែ និងចម្ការជាទីបំផុត គប្បីពិចារណាន័យដែលសមគួរ និងមិនសមគួរតាមវិន័យផងចុះ ។ ក្នុងបណ្ដាស្រែ និងចម្ការនោះ ឈ្មោះថា ស្រែ គឺទីសម្រាប់ដាំបុព្វណ្ណជាតិ ដែលឈ្មោះថា ចម្ការ គឺទីសម្រាប់ដាំអបរណ្ណជាតិ ។ម្យ៉ាងទៀត ទីដែលបុព្វណ្ណជាតិ និងអបរណ្ណ-ជាតិទាំង ២ ដុះឡើងនោះ ឈ្មោះថា ស្រែ ភូមិភាគដែលមិនបានធ្វើដើម្បីប្រយោជន៍នោះ ឈ្មោះថា ចម្ការ ។ ក្នុងទីនេះ លោកសង្គ្រោះបឹង និង

ត្រពាំងជាដើមដោយមានស្រែ និងចម្ការជាគោល ។ ការបញ្ជូនដំណឹង គឺការកាន់សំបុត្រ ឬដំណឹងរបស់គ្រហស្ថ ទៅក្នុងទីនោះៗ ហៅថា **ទូតេយ្យ** ។ ការទៅដោយកិច្ចបន្តិចបន្តួចនៃបុគ្គល ដែលគេបញ្ជូនទៅអំពីផ្ទះនេះ ទៅកាន់ផ្ទះនោះ លោកហៅថា ការទទួលបម្រើ ការធ្វើទាំង ២ យ៉ាង ឈ្មោះថា **អនុយោគ** ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងសេចក្តីនេះថា ការប្រកបរឿយៗនូវការបញ្ជូនដំណឹង និងការទទួលបម្រើ ។ បទថា **កយវិក្កយា** បានដល់ការលក់ និងការដូរ ។ បទថា **កូដំ** ក្នុងបទថា **តុលាកូដំ** ជាដើម បានដល់ ការគៃបំបាត់ ។ ជាបឋម ក្នុងការគៃបន្លំទាំងនោះ ការគៃបន្លំដោយជញ្ជីង មាន ៤ យ៉ាង គឺគៃបន្លំដោយរូប គៃបន្លំដោយអវយវៈ គៃបន្លំដោយទទួល គៃបន្លំដោយបិទបាំងក្នុងការគៃបន្លំ ៤ យ៉ាងនោះ ឈ្មោះថា ការគៃបន្លំដោយរូប គឺការធ្វើក្អែកជញ្ជីង ២ ដែលឲ្យរូបប៉ុនគ្នា កាលទទួល ក៏ទទួលដោយជញ្ជីងធំ កាលឲ្យ ក៏ឲ្យដោយជញ្ជីងតូច ។ ឈ្មោះថា គៃបន្លំដោយអវយវៈ គឺកាលទទួល ក៏យកដៃសង្កត់ជញ្ជីងខាងក្រោយ កាលឲ្យក៏យកដៃសង្កត់ជញ្ជីងខាងមុខ ។ ឈ្មោះថា ការគៃបន្លំដោយទទួល គឺកាលទទួល ក៏ចាប់ខ្សែត្រង់ដើម កាលឲ្យ ក៏ចាប់ខ្សែខាងចុង ។ ឈ្មោះថា គៃបន្លំដោយបិទបាំង គឺកាលធ្វើជញ្ជីងបន្លំហើយ ដាក់កម្ទេចដែកខាងក្នុង កាលទទួល ក៏ធ្វើជញ្ជីងនោះទុកខាងក្រោយ កាលឲ្យ ក៏ធ្វើជញ្ជីងទុកខាងចុង ។

ថាសមាស ហៅថា សរីទ្ធ ។ ការគៃបន្លំដោយថាសមាសនោះ ឈ្មោះថា គៃបន្លំដោយសរីទ្ធ ។ សេចក្តីនេះដូចម្តេច គឺធ្វើថាសមាសមួយ ហើយ

ធ្វើថាសលោហៈដទៃ ២ ឬ ៣ ឲ្យមានពណ៌ដូចមាស បន្ទាប់អំពីនោះ ទៅកាន់ជនបទ ចូលទៅរកត្រកូលដែលស្តុកស្តម្ភណាមួយ ពោលថា សូមអ្នកទិញភាជនៈមាស កាលគេសួរតម្លៃ ជាអ្នកបំណងនឹងឲ្យវត្ថុដែលមានតម្លៃច្រើនជាង ។ បន្ទាប់អំពីនោះ កាលមនុស្សទាំងនោះពោលថា ប្រាប់ចុះ ខ្ញុំនឹងដឹងថា ថាសទាំងនេះ ជាមាសបានដូចម្តេច ទើបប្រាប់ថា អ្នកចូរសាកល្បងមើលចុះ ហើយយកថាសមាសកូតត្រង់ថ្ម ហើយប្រគល់ថាសទាំងអស់ឲ្យទៅ ។

ឈ្មោះថា ការកែបន្លំដោយគ្រឿងសម្រាប់វាល់ មាន ៣ យ៉ាង គឺ ហទយភេទ ១ សិខាភេទ ១ រជ្ជុភេទ ១ ក្នុងរង្វាល់ ៣ យ៉ាងនោះ ហទយភេទ ប្រើក្នុងវេលាវាល់សប្បិ និងប្រេងជាដើម គឺកាលនឹងទិញសប្បិ និងប្រេងជាដើមទាំងនោះ ក៏ប្រាប់ថា ចូរចាក់សន្សឹមៗ ហើយឲ្យសប្បិ និងប្រេងជាច្រើន ហូរចូលទៅខាងក្នុងភាជនៈ ដោយគ្រឿងវាល់ មានប្រហោងនៅខាងក្នុងហើយទទួលយក កាលនឹងលក់ ក៏បិទប្រហោង ធ្វើឲ្យឆាប់ពេញឲ្យទៅ ។ សិខាភេទ ប្រើក្នុងវេលាវាល់ល្ង និងអង្ករជាដើម គឺកាលទិញវាល់ល្ង និងអង្ករជាដើមនោះ ក៏វាល់សន្សឹមៗ ដាក់ឲ្យកំពុងកាន់យក កាលវាល់លក់ ក៏ប្រញាប់ឲ្យពេញ ហើយកៀសលក់ទៅ ។ រជ្ជុភេទ ប្រើក្នុងវេលាវាស់ស្រែ និងចម្ការ ។ គឺកាលមិនបានសំណូក ក៏វាស់ស្រែដែលមិនធំឲ្យធំបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អក្កោដន** ជាដើម ។ បទថា **ឧក្កោដនំ**

សំដៅយកការគែបន្ទំ ដើម្បីធ្វើបុគ្គលដែលជាម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់នៃទ្រព្យ ។ បទថា **វញ្ចនំ** បានដល់ ការបន្លំអ្នកដទៃដោយឧបាយនោះៗ ។ ក្នុងសេចក្ដីនោះ មានរឿងមួយជាឧទាហរណ៍ដូចតទៅនេះ

បានឮថា នាយព្រានម្នាក់ ចាប់ម្រឹគមេ និងកូនម្រឹគមក ។ អ្នកលេងម្នាក់ពោលនឹងព្រានថា អ្នកដ៏ចម្រើន មេម្រឹគតម្លៃប៉ុន្មាន កូនម្រឹគតម្លៃប៉ុន្មាន ។ នាយព្រានឆ្លើយថា មេម្រឹគថ្លៃ ២ កហាបណៈ កូនម្រឹគថ្លៃ ១ កហាបណៈ ទើបអ្នកលេងឲ្យ ១ កហាបណៈ ហើយនាំកូនម្រឹគទៅបានបន្តិច ក៏ត្រឡប់មកវិញ ពោលថា ខ្ញុំមិនត្រូវការកូនម្រឹគនេះទេ លោកចូរឲ្យមេម្រឹគដល់ខ្ញុំ ។ ព្រានពោលថា បើដូច្នោះ អ្នកចូរឲ្យ ២ កហាបណៈ ។ អ្នកលេងនោះពោលថា លោកដ៏ចម្រើន ខ្ញុំឲ្យ ១ កហាបណៈដល់លោកមុនហើយ មិនមែនឬ ព្រានពោលថា អើ ឲ្យហើយ ទើបអ្នកលេងពោលថា លោកចូរយកកូនម្រឹគនេះទៅ កាលបើដូច្នោះ កហាបណៈ ១ មុននោះ និងកូនម្រឹគដែលមានតម្លៃ ១ កហាបណៈ ទើបជា ២ កហាបណៈ ។ នាយព្រានកំណត់ថា អ្នកលេងពោលមានហេតុ មានផល ទើបទទួលយកកូនម្រឹគហើយឲ្យមេម្រឹគទៅ ។ បទថា **និកតិ** បានដល់ បោកបញ្ឆោតដោយរបស់ក្លែងក្លាយ ដោយធ្វើវត្ថុដែលមិនមែនសង្វារ ថាជាសង្វារ ដែលមិនមែនកែវមណី ថាជាកែវមណី ដែលមិនមែនមាស ថាជាមាស ដោយការបន្លំ ឬដោយការបញ្ឆោត ។ បទថា **សាវិយោគោ** ប្រែថា ការបន្លំដោយការគែ ។ បទថា **សាវិយោគោ** នេះ ជាឈ្មោះនៃការគែបន្លំជាដើមទាំងនោះឯង ។ ព្រោះ

ដូច្នោះ គប្បីឃើញសេចក្តីក្នុងបទថា **សាវិយោគោ** នេះថា បន្ទប់ដោយការកែបន្ទំ បន្ទប់ដោយការបោកបញ្ឆោត ។ អាចារ្យពួកខ្លះពោលថា ការបង្ហាញវត្ថុមួយហើយ ប្តូរវត្ថុមួយទៀត ឈ្មោះថា **សាវិយោគ** ប្រែថា បន្ទប់ ។ តែពាក្យនោះ លោកក៏សង្គ្រោះចូលដោយការបោកបញ្ឆោតដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឆេទន** ជាដើមដូចតទៅនេះ បទថា **ឆេទនំ** បានដល់ ការកាត់ដៃជាដើម ។ បទថា **វធោ** បានដល់ ការធ្វើឲ្យស្លាប់ ។ បទថា **ពន្ធោ** បានដល់ ការចងដោយចំណង គឺខ្សែជាដើម ។ បទថា **វិបរាមោសោ** បានដល់ ការបិទបាំងមាន ២ យ៉ាង គឺបិទបាំងដោយសន្សើម និងបិទបាំងដោយគុម្ពឈើ ។ ក្នុង ២ យ៉ាងនោះ បិទបាំងដោយសន្សើម ក្នុងវេលាសន្សើមធ្លាក់ ហើយនិយាយកុហកជនដែលដើរទៅ នេះហៅថា **ហិមវិបរាមោស ។** បិទបាំងដោយគុម្ពឈើជាដើម ហើយនិយាយកុហក នេះហៅថា **គុម្ពវិបរា-មោស ។** ការប្លន់អ្នកស្រុក និងអ្នកនិគមជាដើម លោកហៅថា **អាលោចោ** ប្រែថា ការប្លន់ ។ បទថា **សហសាការោ** បានដល់ ការធ្វើដោយចាប់រួសរាន់ គឺចូលទៅកាន់ទូកហើយ ភ្ជង់ដើមទ្រូងមនុស្សទាំងឡាយ ដោយអាវុធ ហើយកាន់យកទ្រព្យតាមប្រាថ្នាទៅ ជាអ្នកវៀរចាកការកាត់ សម្លាប់ ចាប់ចង ធ្វើឲ្យវង្វេងផ្លូវ ប្លន់ ដោយប្រការដូច្នេះ ។

បទថា **សោ សន្តុដ្ឋោ ហោតិ** សេចក្តីថា ភិក្ខុនេះប្រកបដោយ **ឥតរីតរបច្ចយសន្តោស** ១២ យ៉ាង ក្នុងបច្ច័យ ៤ ដូចពោលហើយខាងដើម ។ ម្យ៉ាងទៀត បរិក្ខារ ៨ នោះ គឺត្រៃចីវរ បាត្រ កាំបិតតូចសម្រាប់កាត់ឈើស្ទន់

ម្ជុលមួយដើម វត្ថពន្ធចង្កេះ សំពត់តម្រងទឹក រមែងគួរដល់ភិក្ខុដែលប្រកប ដោយសន្តោស ក្នុងបច្ច័យតាមមានតាមបាន ១២ យ៉ាងនេះ សមដូចដែល បុរាណាចារ្យពោលថា

បរិក្ខារទាំងនេះ គឺត្រៃចីវរ បាត្រ កាំបិតតូច ម្ជុល វត្ថពន្ធចង្កេះ សំពត់ តម្រងទឹកជាគម្រប់ ៨ រមែងគួរដល់ភិក្ខុ ដែលប្រកបសេចក្តីព្យាយាម ។

បរិក្ខារទាំងអស់នោះ ជាគ្រឿងបរិហារកាយក៏បាន បរិហារផ្ទៃក៏បាន សេចក្តីនេះដូចម្តេច ជាបឋម ត្រៃចីវររមែងបរិហារ គឺចិញ្ចឹមកាយ ក្នុងវេលា ដែលស្លៀក និងដណ្តប់ ព្រោះដូច្នោះ ទើបឈ្មោះថា ជាគ្រឿងបរិហារកាយ រមែងបរិហារ គឺចិញ្ចឹមផ្ទៃក្នុងគ្រាដែលធ្វើតម្រងទឹក ដោយជ្រុងចីវរ ហើយ ផឹក និងក្នុងគ្រាដែលវេចផ្លែឈើតូចធំ ដែលគួរទំពាឆាន់បានដោយជាយចីវរ នោះ ព្រោះដូច្នោះ ទើបឈ្មោះថា ជាគ្រឿងបរិហារផ្ទៃ ។ បាត្រក៏ជាគ្រឿង បរិហារកាយ ក្នុងគ្រាដែលដងទឹកដោយបាត្រនោះងូត និងក្នុងគ្រាដែលដងទឹក ដោយបាត្រនោះ ប្រោះព្រំកុដិ ។ ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាទទួលអាហារ ដោយបាត្រនោះឆាន់ ។ កាំបិតតូចជាគ្រឿងបរិហារកាយ ក្នុងគ្រាដែលកាត់ ឈើស្ទន់ ក្នុងគ្រាដែលធ្វើជើងគ្រែ និងដងក្រោះ ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រា ដែលកាប់អំពៅ និងបកដូងជាដើម ។ ម្ជុលរមែងជាគ្រឿងបរិហារកាយ ក្នុង គ្រាដែលដេរចីវរ ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាដែលចុចនំ ឬផ្លែឈើឆាន់ ។ វត្ថពន្ធចង្កេះ ជាគ្រឿងបរិហារកាយ ក្នុងគ្រាដែលចងចង្កេះត្រាច់ទៅ ជាគ្រឿង បរិហារផ្ទៃក្នុងគ្រាចងអំពៅជាដើមកាន់យកទៅ ។ តម្រងទឹក រមែងជាគ្រឿង

បរិហារកាយក្នុងគ្រាដែលត្រងទឹកដោយសំពត់នោះសម្រាប់ងូត និងធ្វើការប្រោះព្រំសេនាសនៈ ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាដែលត្រងទឹកផឹក និងក្នុងគ្រាដែលខ្ចប់ល្ង អង្ករ និងអំបុកជាដើម ដោយសំពត់នោះ ហើយឆាន់ ។ នេះជាប្រមាណបរិក្ខាររបស់ភិក្ខុដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ។

ឯភិក្ខុដែលមានបរិក្ខារ ៩ ចូលទៅកាន់ទីដេក មានកម្រាលសម្រាប់សេនាសនៈនោះ ឬមានកូនសោក៏គួរ ។ ឯភិក្ខុមានបរិក្ខារ ១០ គឺមានសំពត់និសីទនៈ ឬប្រមក្ខណ្ឌក៏គួរ ។ ភិក្ខុមានបរិក្ខារ ១១ ទោះមានឈើច្រត់មនុស្សចាស់ ឬត្រឡោកប្រេងក៏គួរ ។ ភិក្ខុមានបរិក្ខារ ១២ ទោះមានឆត្រ ឬស្បែកជើងក៏គួរ ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ឈ្មោះថា ជាអ្នកសន្តោស ក្រៅអំពីនោះ បុគ្គលណាម្នាក់ ក៏មិនគួរពោលថាមិនសន្តោស ជាអ្នកប្រាថ្នាច្រើន ជាអ្នកប្រកបដោយមហិច្ឆតា ភិក្ខុទាំងអស់នោះ ជាអ្នកប្រាថ្នាតិច សន្តោស ចិញ្ចឹមងាយ និងមានការប្រព្រឹត្តស្រាលនោះឯង ។ ព្រះមានព្រះភាគ ទ្រង់មិនបានសម្តែងព្រះសូត្រនេះ ដោយអំណាចនៃភិក្ខុទាំងនោះ ទ្រង់សម្តែងដោយអំណាចនៃភិក្ខុដែលមានបរិក្ខារ ៨ ពិតហើយ ភិក្ខុដែលមានបរិក្ខារ ៨ នោះ ខ្ចប់កាំបិតតូច និងម្ជុលដាក់ក្នុងតម្រងទឹក តម្រងទឹកដាក់ក្នុងបាត្រ ហើយពាក់ស្ពាយបាត្រត្រង់ចង្កេះស្មាដណ្តប់ត្រៃចីវរ ចងវត្តពន្ធចង្កេះ ហើយចៀសចេញទៅ សប្បាយតាមបំណង ។ លោកមិនត្រូវការត្រឡប់មកយកអ្វីទៀតឡើយ ។

ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការប្រព្រឹត្តស្រាលរបស់ភិក្ខុ

នេះ ទើបត្រាស់ថា **សន្តុដ្ឋោ ហោតិ កាយបរិហារិយេន ចីវរេន** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **កាយបរិហារិយេន** គឺត្រឹមតែជាគ្រឿងរក្សាកាយ ។ បទថា **កុច្ឆិបរិហារិយេន** បានដល់ ត្រឹមតែជាគ្រឿងរក្សាផ្ទៃ ។ បទថា **សមាទាយេវ បក្កមតិ** សេចក្តីថា លោកកាន់យកត្រឹមតែគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះជាប់តាមខ្លួនទៅ រមែងមិនជាប់ជំពាក់ថា វិហារ បរិវេណ ឧបដ្ឋាករបស់អញ ភិក្ខុអ្នកមានបរិក្ខារ ៨ នោះ ប្រើប្រាស់សេនាសនៈ ដែលខ្លួនប្រាថ្នាហើយ គឺដងព្រៃ គល់ឈើ ជាយព្រៃ នៅតែម្នាក់ឯង អង្គុយម្នាក់ឯង មិនមានសម្លាញ់ ក្នុងឥរិយាបថទាំងពួង ដូចព្រួញដែលផុតអំពីបន្ទោះធ្នូ និងដូចដំរីចុះប្រេង ចៀសទៅអំពីហ្វូង ដូច្នោះ រមែងដល់នូវភាពជាបុគ្គលដូចកុយរមាស ដែលលោកពណ៌នាយ៉ាងនេះថា

**ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ សន្តុស្សមានោ ឥតរីតរេន**
**បរិស្សយានំ សហិតា អឆម្ភី ឯកោ ចរេ ខគ្គវិសាណកប្បោ។**

បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរដោយបរិក្ខារតាមមានតាមបាន ជាអ្នកអត់ធន់ ចំពោះអន្តរាយទាំងឡាយ ទាំងជាអ្នកមិនតក់ស្លុត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ឥឡូវនេះ កាលទ្រង់សាធកៈសេចក្តីនោះដោយឧបមា ទើបត្រាស់ថា **សេយ្យថាបិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បក្ខី សកុណោ** បានដល់ សត្វមានស្លាប ។ បទថា **ឌេតិ** ប្រែថា ហើរ សេចក្តីសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះថា ធម្មតាបក្សីទាំងឡាយ ដឹងថា ដើមឈើក្នុងទីឯណោះមាន

ផ្លែទុំ ទើបនាំគ្នាមកអំពីទិសផ្សេងៗ ចឹកស៊ីផ្លែនៃដើមឈើនោះ ដោយក្រចក ស្លាប និងចំពុះជាដើម ។ បក្សីទាំងនោះ មិនមានការគិតថា នេះសម្រាប់ថ្ងៃនេះ នេះសម្រាប់ស្អែកនេះ តែកាលផ្លែឈើអស់ វាក៏មិនហួងហែងរក្សាដើមឈើ មិនយកស្លាប ក្រចក ឬចំពុះ ទុកដាក់ត្រង់ដើមឈើនោះ ដោយពិតនោះ មិនមានការអាល័យក្នុងដើមនោះ សត្វណាប្រាថ្នាទៅកាន់ទិសណា សត្វនោះមានការៈ គឺយកតែស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅកាន់ទិសនោះយ៉ាងណា ភិក្ខុនេះក៏ដូច្នោះដូចគ្នា មិនមានការគិត ប្រាសចាកសេចក្ដីអាល័យ ចៀសចេញទៅ ប្រាថ្នាតែនឹងចៀសចេញទៅតែម្យ៉ាង ។ បទថា **អរិយេន** ប្រែថា មិនមានទោស ។ បទថា **អជ្ឈត្តំ** ប្រែថា ក្នុងអត្តភាពរបស់ខ្លួន ។ បទថា **អនវជ្ជសុខំ** ប្រែថា សុខដែលមិនមានទោស ។ បទថា **សោ ចក្ខុនា រូបំ ទិស្វា** សេចក្ដីថា ភិក្ខុនោះ គឺជាអ្នកប្រកបដោយសីលក្ខន្ធដែលជាអរិយៈនេះ ឃើញរូបដោយចក្ខុវិញ្ញាណ ។ ពាក្យដែលគប្បីពោលក្នុងបទដ៏សេសទាំងឡាយ ពោលហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **អព្យាសេកសុខំ** បានដល់សុខដែលមិនលាយឡំដោយកិលេស ។ លោកពោលថា សុខដែលមិនទាក់ទងដោយកិលេសក៏មាន ពិតហើយ សុខក្នុងឥន្ទ្រិយសំវរៈ ឈ្មោះថា មិនជាប់ជំពាក់ ព្រោះប្រព្រឹត្តទៅដោយអំណាចត្រឹមតែរូបដែលឃើញហើយ ក្នុងអារម្មណ៍ មានរូបដែលឃើញហើយជាដើម ។ បទថា **សោ អភិក្កន្តេ បដិក្កន្តេ** សេចក្ដីថា ភិក្ខុនោះ គឺជាអ្នកប្រកបដោយការសង្រួមឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ជាបុគ្គលមានប្រក្រតីធ្វើនូវការដឹងខ្លួន ដោយសតិ និង

សម្បជញ្ញៈ ក្នុងឋានៈទាំង ៧ មានការឈានទៅមុខ និងការឈានថយក្រោយជាដើម ។ ពាក្យដែលគប្បីពោលក្នុងសេចក្តីនោះ បានពោលហើយ ក្នុងសតិប្បដ្ឋានសូត្រនោះឯង ។

[ ៧២ ] ដោយបទថា **សោ ឥមិនា ច** ជាដើម លោកសម្តែងដូចម្តេច ។ លោកសម្តែងដល់បច្ច័យសម្បត្តិនៃការនៅព្រៃ ។ ពិតហើយ ការនៅព្រៃរបស់បុគ្គលដែលមិនមានបច្ច័យទាំងនេះ រមែងមិនសម្រេច និងត្រូវតិះដៀលថា ដូចគ្នានឹងសត្វតិរច្ឆាន ឬព្រានព្រៃ ។ ពួកទេវតាដែលអាស្រ័យនៅក្នុងព្រៃ នាំគ្នាប្រកាសកងរំពងដោយសំឡេងដែលគួរខ្លាចថា ភិក្ខុអាក្រក់បែបនេះ នៅព្រៃធ្វើអ្វី យកដៃវាយក្បាល ធ្វើអាការឲ្យគេចទៅ ។ ការមិនមានកិត្តិយស ក៏ផ្សាយទៅថា ភិក្ខុនោះចូលទៅព្រៃ ធ្វើកម្មអាក្រក់ ដូច្នេះ ។ តែការនៅព្រៃរបស់ភិក្ខុដែលមានបច្ច័យទាំង ៤ នោះ រមែងសម្រេច ។ ពិតហើយ កាលលោកពិចារណាដល់សីលរបស់ខ្លួន មិនឃើញការពព្រុសពពាលណាមួយ ក៏ធ្វើបីតិឲ្យកើតឡើង ពិចារណាឃើញវត្ថុនោះ ដោយការអស់ទៅ រមែងឈានចុះកាន់អរិយភូមិ ។ ពួកទេវតាដែលអាស្រ័យនៅក្នុងព្រៃត្រេកអរ ក៏សរសើរ ។ កិត្តិយសរបស់ភិក្ខុនោះ ក៏ផ្សាយចេញទៅ ដូចតំណក់ប្រេងល្ង ដែលស្រក់ចូលទៅក្នុងទឹកដូច្នេះ ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិវិត្តំ** ប្រែថា ស្ងាត់ អធិប្បាយថា មិនមានសំឡេង គឺគ្មានសំឡេង ។ លោកសំដៅយកពាក្យនេះឯង ទើបពោលក្នុងវិភង្គថា បទថា **វិវិត្តំ** សេចក្តីថា បើសេនាសនៈមានក្នុងទីជិតសោត ហើយ

សេនាសនៈនោះ មិនប្រឡំដោយគ្រហស្ថ និងបព្វជិត ព្រោះដូច្នោះ សេនាសនៈនោះ ឈ្មោះថា **វិវិត្ត** ។ ឈ្មោះថា សេនាសនៈ ព្រោះជាទីដេក និងជាទីអង្គុយ ពាក្យនោះ ជាឈ្មោះរបស់គ្រែ និងតាំងជាដើម ដោយហេតុនោះ ទើបលោកពោលថា បទថា **សេនាសន** បានដល់ សេនាសនៈ គឺទីដេក ទីអង្គុយ តាំង ពូក ខ្នើយ វិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រនិល គុហា ប៉ម សាលា ទីសម្រាក គុម្ពឈើ គល់ឈើ មណ្ឌប ដែលជាទីភិក្ខុត្រូវអាស្រ័យទាំងអស់នោះ ចាត់ជាសេនាសនៈ ។ ម្យ៉ាងទៀត វិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រនិល គុហា នេះឈ្មោះថា **វិហារសេនាសន** សេនាសនៈ គឺទីសម្រាប់នៅ ។ គ្រែ តាំង ពូក ខ្នើយ នេះឈ្មោះថា **មញ្ចបីឋសេនាសន** កន្ទេលស្លឹកចាក ប្រមក្ខណ្ឌ កម្រាលធ្វើដោយស្មៅ កម្រាលធ្វើដោយស្លឹកឈើ នេះឈ្មោះថា **សន្ថតសេនាសន** ។ ទីដែលភិក្ខុអាស្រ័យ ឈ្មោះថា **ឱកាសសេនាសន** ។ សេនាសនៈទាំង ៤ ដូចពោលមកនេះ ចាត់ជាសេនាសនៈ ។ សេនាសនៈទាំងអស់នោះ លោកសង្គ្រោះសេចក្តីដោយសព្ទថា **សេនាសន** ដូចគ្នា ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈ ដែលសមគួរដល់ភិក្ខុដែលចារិកទៅក្នុងទិសទាំង ៤ ដូចគ្នានឹងសត្វបក្សីនេះ ទើបត្រាស់បទថា **អរញ្ញំ រុក្ខមូលំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អរញ្ញំ** បានដល់ ទីទាំងអស់ ខាងក្រៅសសរខឿនចេញទៅនោះ ឈ្មោះថា ព្រៃ ។ ពាក្យនេះមកដោយរឿងភិក្ខុនី ២ រូប ។ សេនាសនៈ ៥០០ ជួរធ្នូយ៉ាងឆ្ងាយ

ឈ្មោះថា សេនាសនៈព្រៃ សេនាសនៈព្រៃនេះ សមគួរដល់ភិក្ខុនេះ ។ លក្ខណៈនៃសេនាសនៈនោះ ពោលហើយក្នុងធុតង្គនិទ្ទេស ក្នុងវិសុទ្ធិមគ្គ ។ បទថា **រុក្ខមូលំ** បានដល់ គល់ឈើដែលស្ងាត់ មានម្លប់ត្រជាក់ណាមួយ ។ បទថា **បព្វតំ** ប្រែថា ភ្នំថ្ម ។ ពិតហើយ កាលភិក្ខុប្រើទឹកត្រង់ក្រហែងថ្ម ត្រង់ភ្នំថ្មនោះ អង្គុយក្នុងម្លប់នៃដើមឈើដ៏ត្រជាក់ ត្រូវខ្យល់ត្រជាក់ ដែលផាត់មកក្នុងទិសផ្សេងៗ ដែលប្រាកដ ចិត្តក៏មានអារម្មណ៍តែមួយ ។ ទឹកលោកហៅថា **កំ** ក្នុងបទថា **កន្ទរំ** ។ ទីដែលទឹកដក់ ទីដែលទឹកប្រោះ បានដល់ ប្រទេសនៃភ្នំ ដែលអាចារ្យពួកខ្លះហៅថា **នទីតុម្ពំ** ក៏មាន **នទីកុញ្ជំ** ក៏មាន ។ ពិតហើយ ក្នុងប្រទេសនៃភ្នំនោះ មានខ្សាច់ដូចកម្រាលប្រាក់ មានទឹកដូចដុំកែវមណី រមែងហូរឆ្លងព្រៃជ្រៅ ដូចពិតានកែវមណីលើកំពូល ភិក្ខុចុះកាន់ជ្រោះបែបនោះ ផឹកទឹក ស្រឡាបខ្លួនឲ្យត្រជាក់ លើកខ្សាច់ឡើងក្រាលសំពត់បង្សុកូលចីវរ អង្គុយធ្វើសមណធម៌ ចិត្តក៏ជាឯកគ្គតា ។ បទថា **គិរិគុហំ** បានដល់ មានទីទូលាយ ដូចគ្នានឹងឧម្មង្គរវាងភ្នំ ២ ឬភ្នំតែ ១ ។ លក្ខណៈនៃព្រៃស្មសាន ពោលហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **វនបត្ថំ** បានដល់ ទីដែលកន្លងឧបចារដ្ឋានរបស់មនុស្ស ដែលមនុស្សមិនសាបមិនព្រោះ ។ ដោយហេតុនោះ ទើបលោកពោលថា **វនបត្ថំ** ជាឈ្មោះរបស់សេនាសនៈ ដែលនៅឆ្ងាយ ។ បទថា **អព្ភោកាសំ** បានដល់ ទីមិនប្រក់បាំង ។ តែភិក្ខុបំណង ក៏ដោតក្លោះក្នុងទីនោះបាន ។ បទថា **បលាលបុញ្ជំ** បានដល់ គំនរចំបើង ពិតហើយ ពួកភិក្ខុទាញចំបើងអំពីគំនរធំធ្វើលំនៅ ដូចយកភ្នំ និងទី

សម្រាក ដាក់ចំបើងក្បែរគុម្ពឈើជាដើម ហើយអង្គុយធ្វើសមណធម៌ខាងក្រោម លោកសំដៅយកគំនរចំបើងនោះ ទើបពោលពាក្យនេះ ។ បទថា **បច្ឆាភត្តំ** គឺខាងក្រោយភត្ត ។ បទថា **បិណ្ឌបាតប្បដិក្កន្តោ** ប្រែថា ត្រឡប់អំពីបិណ្ឌបាត ។ បទថា **បល្លង្កំ** បានដល់ អង្គុយពត់ភ្នែនដោយជុំវិញ ។ បទថា **អាភុញ្ជិត្វា** ប្រែថា ជាប់គ្នា ។ បទថា **ឧជុំ កាយំ បណិធាយ** បានដល់ តាំងកាយខាងលើឲ្យត្រង់ យកចុងឆ្អឹងខ្នង និងចុងឆ្អឹងខ្នង ១៨ កំណាត់ឲ្យត្រួតលើគ្នា ។ ពិតហើយ ភិក្ខុអង្គុយយ៉ាងនេះ ស្បែក សាច់ សរសៃមិនចុករោយស្រពន់ កាលបើដូច្នោះ វេទនាទាំងឡាយដែលគប្បីកើតគ្រប់ខណៈ ព្រោះការជំទាស់គ្នានៃស្បែក សាច់ សរសៃទាំងនោះជាបច្ច័យ ក៏មិនកើតដល់ភិក្ខុនោះ កាលវេទនាទាំងនោះមិនកើតឡើង ចិត្តក៏មានអារម្មណ៍តែមួយ ។ កម្មដ្ឋានក៏មិនធ្លាក់ទៅ ក៏ចូលដល់នូវការចម្រើនដុះដាល ។ បទថា **បរិមុខំ សតិំ ឧបដ្ឋបេត្វា** សេចក្តីថា តាំងសតិ តម្រង់ចំពោះកម្មដ្ឋាន ឬធ្វើទុកខាងមុខ ដោយហេតុនោះ ទើបលោកពោលក្នុងវិភង្គថា សតិនេះរមែងតាំងមាំ តាំងមាំដោយល្អត្រង់ចុងច្រមុះ ឬលើបបូរមាត់ ដោយហេតុនោះទើបលោកពោលថា សតិតាំងទុកចំពោះមុខ ។ម្យ៉ាងទៀត សព្ទថា **បរិ** មានអត្ថថា កាន់យកដោយជុំវិញ សព្ទថា **មុខំ** មានអត្ថថា នាំចេញ សព្ទថា **សតិ** មានអត្ថថា ប្រាកដ ដោយហេតុនោះ ទើបលោកពោលថា **បរិមុខំ សតឹ** គប្បីឃើញអត្ថក្នុងពាក្យនេះ ដោយន័យដូចពោលមកហើយ ក្នុងបដិ-សម្ភិទាមគ្គ ដោយប្រការដូច្នេះ ។ ក្នុងពាក្យនោះ មានសេចក្តីសង្ខេបដូច្នេះ

ថា **បរិគ្គហិតនិយ្យានំ សតឹ កត្វា** ធ្វើសតិជាគ្រឿងនាំចេញចាកទុក្ខ ដែលកំណត់ទុក្ខជាអារម្មណ៍ ។

ឧបាទានក្ខន្ធ ៥ ឈ្មោះថា **លោក** ក្នុងបទថា **អភិជ្ឈំ លោកេ** នេះ ព្រោះអត្ថថា វិនាស ព្រោះដូច្នោះ ពាក្យនេះមានអត្ថដូច្នេះ លះរាគៈក្នុងឧបាទានក្ខន្ធ ៥ សង្កត់កាមឆន្ទៈ ។ បទថា **វិគតាភិជ្ឈេន** សេចក្តីថា ឈ្មោះថា ប្រាសចាកអភិជ្ឈា ព្រោះលះដោយវិក្ខម្ភនប្បហាន មិនមែនដូចចក្ខុវិញ្ញាណ ។ បទថា **អភិជ្ឈាយ ចិត្តំ បរិសោធេតិ** សេចក្តីថា រមែងជោះចិត្តចាកអភិជ្ឈា គឺធ្វើដោយប្រការដែលអភិជ្ឈានោះលែង និងកាលលែងហើយ ក៏មិនចាប់ចិត្តនោះទៀត ។ សូម្បីក្នុងបទថា **ព្យាបាទបទោសម្បហាយ** ដូច្នេះជាដើម ក៏ន័យនេះដូចគ្នា ។ ឈ្មោះថា **ព្យាបាទ** ព្រោះជាគ្រឿងបៀតបៀន គឺចិត្តលះប្រក្រតីដើម ដូចនំកុម្មាសផ្អូមជាដើម ។ ឈ្មោះថា **បទោស** ព្រោះប្រទូស្តដោយការឲ្យដល់នូវវិការ ឬប្រទូស្តអ្នកដទៃឲ្យវិនាស ។ ពាក្យទាំង ២ នេះ ជាឈ្មោះនៃសេចក្តីក្រោធដូចគ្នា ។ ថីនៈ ជាជំងឺផ្លូវចិត្ត មិទ្ធៈជាជំងឺចេតសិក ។ ថីនៈផង មិទ្ធៈផង ឈ្មោះថា **ថីនមិទ្ធ** ។ បទថា **អាលោកសញ្ញី** បានដល់ ប្រកបដោយបញ្ញាដ៏បរិសុទ្ធ ប្រាសចាកនីវរណៈ ព្រោះអំណាចចាំនូវពន្លឺដែលខ្លួនឃើញក្នុងពេលយប់ និងពេលថ្ងៃបាន ។ បទថា **សតោ សម្បជានោ** បានដល់ ប្រកបដោយសតិ និងញាណ ។ ទាំង ២ នោះ លោកពោលទុក ព្រោះជាធម៌ឧបការៈដល់អាលោកសញ្ញា ។ ឧទ្ធច្ចៈផង កុក្កុច្ចៈផង ឈ្មោះថា **ឧទ្ធច្ចកុក្កុច្ចៈ** ។ បទថា **តិណ្ណវិចិកិច្ឆោ** ប្រែថា

ខ្ទង់ផុតសេចក្តីសង្ស័យបានហើយ ។ ឈ្មោះថា **អកថំកថី** បុគ្គលមិនមានសេចក្តីសង្ស័យ ជាហេតុពោលថា យ៉ាងណា ព្រោះមិនប្រព្រឹត្តទៅយ៉ាងនេះថា នេះជាអ្វី ។ បទថា **កុសលេសុ ធម្មេសុ** បានដល់ ធម៌មិនមានទោស ។ អធិប្បាយថា មិនសន្ទិះ មិនសង្ស័យយ៉ាងនេះថា ធម៌ទាំងនេះជាកុសល ឬធម៌ទាំងនេះ ចាត់ជាកុសលបានដូចម្តេចហ្ន៎ ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូច្នេះ ។ តែកាលពោលដោយញែកតាមអត្ថ និងលក្ខណៈនៃពាក្យជាដើមក្នុងនីវរណៈទាំងនេះ ពាក្យដែលគួរពោលទាំងអស់ បានពោលហើយក្នុងវិសុទ្ធិមគ្គ ។

[ ៧៣-៧៤ ] បទថា **បញ្ញាយ ទុព្វលីករណេ** សេចក្តីថា នីវរណៈទាំង ៥ នេះ កាលកើត រមែងមិនឲ្យកើតបញ្ញា ទោះជាលោកិយ និងលោកុត្តរ ដែលមិនទាន់កើត សូម្បីកើតហើយ ក៏កាត់សមាបត្តិ ៨ អភិញ្ញា ៥ ឲ្យដាច់ធ្លាក់ទៅ ព្រោះដូច្នោះ ទើបលោកពោលថា **បញ្ញាយ ទុព្វលីករណេ** គឺធ្វើបញ្ញាឲ្យខ្សោយកម្លាំង ។ បទថា **តថាគតបទំ ឥតិបិ** សេចក្តីថា ផ្លូវ គឺញាណ ស្នាមជើង គឺញាណរបស់តថាគតនេះ លោកហៅថា ទីដែលញាណជាន់ហើយ ។ បទថា **តថាគតនិសេវិតំ** បានដល់ ស្ថានដែលគ្នីងជំនីរ គឺញាណ របស់តថាគតកោសហើយ ។ បទថា **តថាគតារញ្ជិតំ** បានដល់ ស្ថានដែលព្រះចង្កូមកែវ គឺញាណរបស់តថាគតប៉ះខ្ទប់ហើយ ។ បទថា **យថាភូតំ បជានាតិ** បានដល់ រមែងដឹងតាមសភាវៈ គឺសេចក្តីពិត ។

បទថា **ន ត្វេវ តាវ អរិយសាវកោ និដ្ឋំ គតោ ហោតិ** សេចក្តីថា ញាណ និងអភិញ្ញាទាំងនេះ រមែងមានទូទៅ សូម្បីបុគ្គលខាងក្រៅព្រះ-សាសនា ព្រោះដូច្នោះ ទើបអរិយសាវកមិនសម្រេចមុន ដែលឈ្មោះថា មិនទាន់សម្រេចមុន ក៏ព្រោះមិនទាន់សម្រេច សូម្បីក្នុងខណៈនៃមគ្គចិត្ត ។

[ ៧៥ ] បទថា **អបិច ខោ និដ្ឋំ គច្ឆតិ** សេចក្តីថា ម្យ៉ាងទៀត ក្នុងខណៈនៃមគ្គចិត្ត រមែងដល់នូវការសម្រេចក្នុងរតនៈ ៣ ដោយអាការនេះ ថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធហ្ន៎ ដូចជាហ្នដំរីឃើញដំរីធំ ដូច្នោះ ។ បទថា **និដ្ឋំ គតោ ហោតិ** សេចក្តីថា រមែងដល់នូវការសម្រេចក្នុងខណៈនៃ មគ្គចិត្តយ៉ាងនេះ រមែងដល់នូវការសម្រេចក្នុងរតនៈ ៣ ដោយអាការទាំង ពួង ព្រោះមានកិច្ចទាំងអស់ស្រេចហើយ ក្នុងខណៈនៃអរហត្តផលចិត្ត ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានសេចក្តីងាយយល់ទាំងអស់ហើយ ៕

**ចូឡហត្ថិបទោបមសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## មហាហត្ថិបទោបមសូត្រទី ៨

[ ៧៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្រមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយមានអាយុ ។ ភិក្ខុទាំងអម្បាលនោះ បានទទួលស្តាប់ថេរវាចានៃព្រះសារីបុត្រមានអាយុថា បពិត្រលោកមានអាយុ ។ ព្រះសារីបុត្រមានអាយុមានថេរវាចាដូច្នេះថា នៃអ្នកទាំងឡាយមានអាយុ ស្នាមជើងទាំងឡាយណាមួយ របស់ពួកសត្វដែលនៅលើផ្ទៃផែនដី ស្នាមជើងទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីប្រាកដជាវិសេសជាងស្នាមជើងនៃសត្វទាំងអម្បាលនោះ ព្រោះស្នាមជើងដំរីនោះជាស្នាមជើងធំ ដូចម្តេចមិញ ម្នាលអ្នកទាំងឡាយមានអាយុ កុសលធម៌ទាំងឡាយណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្គ្រោះចូលក្នុងអរិយសច្ចទាំង ៤ ដូច្នោះឯង អរិយសច្ចទាំង ៤ តើដូចម្តេចខ្លះ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធ-អរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

[ ៧៩ ] ម្នាលអ្នកទាំងឡាយមានអាយុ ទុក្ខអរិយសច្ច តើដូចម្តេចខ្លះ ជាតិ គឺសេចក្តីកើតជាទុក្ខ ១ ជរា គឺសេចក្តីគ្រាំគ្រាជាទុក្ខ ១ មរណៈ គឺសេចក្តីស្លាប់ជាទុក្ខ ១ សោក គឺសេចក្តីរឹងស្ងួតជាទុក្ខ ១ បរិទេវៈ គឺសេចក្តីខ្សឹកខ្សួលជាទុក្ខ ១ ទុក្ខ គឺសេចក្តីលំបាកកាយជាទុក្ខ ១ ទោមនស្ស គឺសេចក្តី

អាក់អន់ចិត្តជាទុក្ខ ១ ឧបាយាសៈ គឺសេចក្តីតានតឹងចិត្តជាទុក្ខ ១ បុគ្គលប្រាថ្នានូវរបស់ណា មិនបានរបស់នោះនាំមកនូវទុក្ខ ១ ដោយសេចក្តីបង្រួញ ឧបាទានក្ខន្ធទាំង ៥ ចាត់ជាទុក្ខ ១ ។ ម្នាលអ្នកទាំងឡាយមានអាយុ ឧបាទានក្ខន្ធទាំងឡាយ ៥ តើដូចម្តេចខ្លះ គឺរូបចាត់ជាឧបាទានក្ខន្ធ ១ វេទនាចាត់ជាឧបាទានក្ខន្ធ ១ សញ្ញាចាត់ជាឧបាទានក្ខន្ធ ១ សង្ខារចាត់ជាឧបាទានក្ខន្ធ ១ វិញ្ញាណចាត់ជាឧបាទានក្ខន្ធ ១ ។ ម្នាលអ្នកទាំងឡាយមានអាយុ រូបចាត់ជាឧបាទានក្ខន្ធ ដូចម្តេចខ្លះ គឺពួកមហាភូតរូប ៤ និងឧបាទាយរូប គឺរូបដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ។ ម្នាលអ្នកទាំងឡាយមានអាយុ មហាភូតរូបទាំង ៤ ដូចម្តេចខ្លះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។

[ ៨០ ] ម្នាលអ្នកទាំងឡាយមានអាយុ បឋវីធាតុ តើដូចម្តេច ។ គឺបឋវីធាតុខាងក្នុងក៏មាន បឋវីធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ បឋវីធាតុខាងក្នុង តើដូចម្តេច ។ ធាតុណាជាខាងក្នុងអាស្រ័យនូវខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ដែលវិញ្ញាណចូលទៅកាន់យក គឺសក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ឬក៏ធាតុដទៃណាមួយ ជាខាងក្នុងអាស្រ័យនឹងខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា បឋវីធាតុខាង

ក្នុង ។ បឋវីធាតុខាងក្នុងណាក្តី បឋវីធាតុខាងក្រៅណាក្តី ធាតុទាំងពីរនុ៎ះ ឈ្មោះថា បឋវីធាតុតែម្យ៉ាង ។ ភិក្ខុគួរឃើញបឋវីធាតុនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា ធាតុនោះឯង មិនមែនជារបស់អញ នេះមិនមែនជាអាត្មាអញ នេះមិនមែនខ្លួនរបស់អញ ។ លុះឃើញបឋវីធាតុនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះហើយ តែងនឿយណាយក្នុងបឋវីធាតុ ធ្វើចិត្តឲ្យធុញទ្រាន់ក្នុងបឋវីធាតុ ។ ម្នាលអ្នកទាំងឡាយមានអាយុ អាបោធាតុខាងក្រៅដោរជន់ក្នុងសម័យណា បឋវីធាតុខាងក្រៅក៏រលាយទៅក្នុងសម័យនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ អម្បាលបឋវីធាតុខាងក្រៅនោះ ជារបស់ធំដល់ម្ល៉ោះ ម្តេចគង់មានសភាពមិនទៀង ជាធម្មតា គង់មានសភាពអស់ទៅជាធម្មតា គង់មានសភាពសូន្យទៅ ជាធម្មតា គង់មានសភាពប្រែប្រួល ជាធម្មតា ។ ចំណង់បើកាយដែលតាំងនៅបន្តិចបន្តួចនេះ ភិក្ខុនឹងប្រកាន់ដោយតណ្ហាថាអញ ថារបស់អញ ថាអញមាន ដូចម្តេចបាន ( កាលបើគិតដូច្នេះហើយ ) សេចក្តីប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ក្នុងបឋវីធាតុជាខាងក្នុងនុ៎ះ របស់ភិក្ខុនោះ មិនមានឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ បើជនទាំងឡាយដទៃដេរ ប្រទេច ខ្ញាំងខ្ញប់ បៀតបៀនភិក្ខុនោះ ។ ភិក្ខុនោះតែងដឹងយ៉ាងនេះថា ទុក្ខវេទនាកើតអំពីសោតសម្ផស្សនេះ កើតឡើងដល់អាត្មាអញហើយតើ ក៏វេទនានោះ អាស្រ័យហេតុ ឬមិនមែនមិនអាស្រ័យហេតុទេ អាស្រ័យហេតុអ្វី គឺអាស្រ័យផស្សៈ ។ ភិក្ខុនោះឯង ឃើញថាផស្សៈមិនទៀង ឃើញថា វេទនាក៏មិនទៀង ឃើញថា សញ្ញាក៏មិនទៀង

ឃើញថា សង្ខារទាំងឡាយក៏មិនទៀង ឃើញថា វិញ្ញាណក៏មិនទៀង ចិត្ត របស់ភិក្ខុនោះ ក៏ស្ទុះស្ទាជ្រះថ្លា ឋិតនៅព្រម ស៊ប់ស្ងួននៅក្នុងអារម្មណ៍ គឺ ធាតុនោះឯង ។ ម្នាលអ្នកទាំងឡាយមានអាយុ បើជនទាំងឡាយដទៃ បៀត បៀនភិក្ខុនោះ ដោយសម្ផស្សដៃក្តី ដោយសម្ផស្សដុំដីក្តី ដោយសម្ផស្សដំបងក្តី ដោយសម្ផស្សគ្រឿងសស្ត្រាក្តី ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ។ ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា កាយនេះឯង ជាធម្មជាតិ សម្រាប់រងសម្ផស្សដៃខ្លះ សម្រាប់រងសម្ផស្សដុំដីខ្លះ សម្រាប់រងសម្ផស្សដំបងខ្លះ សម្រាប់រងសម្ផស្សគ្រឿងសស្ត្រាខ្លះ ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះ ទុកក្នុងឱវាទដែលមានឧបមាដូចរណារ ថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើចោរទាំងឡាយ ជាអ្នកធ្វើអំពើថោកទាប គប្បីអារអវយវៈតូចធំទាំងឡាយ ដោយរណារដែលមានដងទាំងពីរខាង ភិក្ខុណាមួយ មានចិត្ត ( មិនអត់ធន់ ) ប្រទូសរ៉ាយព្រោះជំងឺ ដែលពួកចោរអារនោះ ភិក្ខុនោះ ឈ្មោះថាមិនធ្វើតាមពាក្យប្រដៅរបស់តថាគត ដោយហេតុដែលមិនអត់ធន់នោះ ។ ភិក្ខុនោះគិតថា សេចក្តីព្យាយាមដែលអាត្មាអញប្រារព្ធហើយ មិនធូរថយឡើយ សតិដែលអាត្មាអញតាំងខ្ជាប់ហើយ មិនភ្លាំងភ្លាត់ឡើយ កាយដែលស្ងប់ស្ងាត់ហើយ មិនរសាប់រសល់ឡើយ ចិត្តដែលតម្កល់នឹងហើយ ជាចិត្តមានអារម្មណ៍តែមួយ ឥឡូវនេះ ទោះសម្ផស្សដៃត្រូវក្តី សម្ផស្សដុំដីត្រូវក្តី សម្ផស្សដំបងត្រូវក្តី សម្ផស្សគ្រឿងសស្ត្រាត្រូវក្តី ត្រង់កាយនេះ ( ក៏ត្រូវ ) ចុះ អញនៅតែធ្វើតាមពុទ្ធសាសនានេះ ។

ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះ រឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏មិនទាន់តាំងនៅនឹងបាន ។ ភិក្ខុនោះក៏តក់ស្លុត ដល់នូវសេចក្តីសង្វេគដោយហេតុនោះថា ឱហ្ន៎ យើងជាមនុស្សឥតលាភ ឱហ្ន៎ យើងជាមនុស្សមិនមានលាភ ឱហ្ន៎ អត្តភាពជាមនុស្ស យើងបានដោយកម្រ ឱហ្ន៎ អត្តភាពជាមនុស្ស យើងមិនមែនបានដោយងាយទេ ត្រង់ដែលអាត្មាអញរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏មិនទាន់តាំងនៅនឹងបាន ។ ម្នាលអ្នកទាំងឡាយមានអាយុ ដូចស្រីជាកូនប្រសា ឃើញឪពុកក្មេកហើយ ក៏តក់ស្លុតដល់នូវសេចក្តីព្រួយបារម្ភ ដូចម្តេចមិញ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះ រឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏មិនតាំងនៅនឹងបាន ដូច្នោះឯង ។ ភិក្ខុនោះក៏តក់ស្លុត ដល់នូវសេចក្តីសង្វេគដោយហេតុនោះថា ឱហ្ន៎ អាត្មាអញជាមនុស្សឥតលាភ ឱហ្ន៎ អាត្មាអញជាមនុស្សថ្នែងលាភ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញបានដោយកម្រ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញមិនបានដោយងាយទេ ត្រង់ដែលអាត្មាអញរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏មិនទាន់តាំងនៅមាំ ។ ម្នាលអ្នកទាំងឡាយមានអាយុ បើភិក្ខុនោះ រឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌

យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏តាំងនៅមាំបាន ។ ភិក្ខុនោះមានចិត្តត្រេកអរដោយហេតុនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ពាក្យប្រដៅរបស់ព្រះមានព្រះភាគ ឈ្មោះថា ភិក្ខុនោះធ្វើរឿយៗ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[ ៨១ ] ម្នាលអ្នកទាំងឡាយមានអាយុ អាបោធាតុ តើដូចម្តេច ។ អាបោធាតុខាងក្នុងក៏មាន អាបោធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ អាបោធាតុខាងក្នុង ដូចម្តេចខ្លះ ។ ធាតុណាដែលជាខាងក្នុងដែលអាស្រ័យនូវខ្លួន ជាទឹក ឬមានសភាពប្រហែលនឹងទឹក ដែលវិញ្ញាណចូលទៅកាន់យក គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ឬក៏ធាតុដទៃណានីមួយជាខាងក្នុង អាស្រ័យនូវខ្លួន ជាទឹក ឬមានសភាពប្រហែលនឹងទឹក ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា អាបោធាតុខាងក្នុង ។ ក៏អាបោធាតុខាងក្នុងណាក្តី អាបោធាតុខាងក្រៅណាក្តី ធាតុទាំងពីរនេះ ឈ្មោះថា អាបោធាតុ តែមួយយ៉ាង ។ ភិក្ខុគួរឃើញអាបោធាតុនោះដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះឯងមិនមែនជារបស់អញ នេះក៏មិនមែនជាអញ ខ្លួននោះមិនមែនជារបស់អញ ។ លុះភិក្ខុនោះ ឃើញអាបោ-ធាតុទាំងពីរនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះហើយ តែងនឿយណាយក្នុងអាបោធាតុ ធ្វើចិត្តឲ្យធុញក្នុងអាបោធាតុ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលអាបោធាតុខាងក្រៅ ដោរជន់ឡើងហើយ អាបោធាតុនោះ

ក៏លិចស្រុកខ្លះ លិចនិគមខ្លះ លិចនគរខ្លះ លិចជនបទខ្លះ លិចជនបទ និង ប្រទេសខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលទឹកក្នុងមហាសមុទ្រ មានជម្រៅ ១០០ យោជន៍ រឹងទៅក៏មាន ទឹកមានជម្រៅ ២០០ យោជន៍ រឹងទៅក៏មាន ទឹកមានជម្រៅ ៣០០ យោជន៍ រឹងទៅក៏មាន ទឹកមានជម្រៅ ៤០០ យោជន៍ រឹងទៅក៏មាន ទឹកមានជម្រៅ ៥០០ យោជន៍ រឹងទៅក៏មាន ទឹកមានជម្រៅ ៦០០ យោជន៍ រឹងទៅក៏មាន ទឹកមានជម្រៅ ៧០០ យោជន៍ រឹងទៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលទឹកមានជម្រៅ ៧ ដើមត្នោត ជក់នៅក្នុងមហាសមុទ្រខ្លះ ទឹកមានជម្រៅ ៦ ដើមត្នោតជក់នៅខ្លះ ទឹកមានជម្រៅ ៥ ដើមត្នោតជក់នៅខ្លះ ទឹកមានជម្រៅ ៤ ដើមត្នោតជក់នៅខ្លះ ទឹកមានជម្រៅ ៣ ដើមត្នោតជក់នៅខ្លះ ទឹកមានជម្រៅ ២ ដើមត្នោតជក់នៅខ្លះ ទឹកមានជម្រៅ ១ ដើមត្នោតជក់នៅខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលទឹកមានជម្រៅ ៧ ជំហរបុរសជក់នៅក្នុងមហាសមុទ្រខ្លះ ទឹកមានជម្រៅ ៦ ជំហរបុរសជក់នៅខ្លះ ទឹកមានជម្រៅ ៥ ជំហរបុរសជក់នៅខ្លះ ទឹកមានជម្រៅ ៤ ជំហរបុរសជក់នៅខ្លះ ទឹកមានជម្រៅ ៣ ជំហរបុរសជក់នៅខ្លះ ទឹកមានជម្រៅ ២ ជំហរបុរសជក់នៅខ្លះ ទឹកមានជម្រៅ ១ ជំហរបុរសជក់នៅខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលទឹកមានជម្រៅពាក់កណ្តាលជំហរបុរសជក់នៅក្នុងមហាសមុទ្រខ្លះ ទឹកមានប្រមាណត្រឹមចង្កេះជក់នៅខ្លះ ទឹកមានប្រមាណត្រឹមជង្គង់ជក់នៅខ្លះ ទឹកមានប្រមាណត្រឹមក្អែកគោជក់នៅខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលទឹកគ្រាន់តែសើម

ថ្នាំងម្រាមដៃ ( ដក់នៅ ) ក្នុងមហាសមុទ្រមិនមានឡើយ ក៏មានដែរ ។ ម្នាលអ្នកទាំងឡាយមានអាយុ សូម្បីអាបោធាតុខាងក្រៅនោះជារបស់ធំដល់ម៉្លោះ គង់មានសភាពមិនទៀងជាធម្មតា គង់មានសភាពអស់ទៅជាធម្មតា គង់មានសភាពសូន្យទៅជាធម្មតា គង់មានសភាពប្រែប្រួលទៅជាធម្មតា ។ ចំណាន់បើកាយដែលតាំងនៅបន្តិចបន្តួចនេះ ភិក្ខុនឹងប្រកាន់ដោយតណ្ហាថាអញ ថារបស់អញ ថាអញមានដូចម្តេចបាន ( កាលបើគិតដូច្នេះហើយ ) សេចក្តីប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ក្នុងអាបោធាតុជាខាងក្នុងនុ៎ះរបស់ភិក្ខុនោះមិនមានឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ទើបឧបេក្ខាដែលអាស្រ័យកុសលតាំងនៅនឹងបាន ។ ភិក្ខុនោះមានចិត្តត្រេកអរដោយហេតុនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ភិក្ខុនោះ ឈ្មោះថា ធ្វើតាមពាក្យប្រដៅរបស់ព្រះមានព្រះភាគរឿយៗ ហើយដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[ ៨២ ] ម្នាលអ្នកទាំងឡាយមានអាយុ តេជោធាតុដូចម្តេចខ្លះ ។ តេជោធាតុខាងក្នុងក៏មាន តេជោធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ តេជោធាតុខាងក្នុងតើដូចម្តេច ។ ធាតុណាជាខាងក្នុង ដែលអាស្រ័យនូវនឹងខ្លួន ជាភ្លើង ឬមានសភាពប្រហែលនឹងភ្លើង ដែលវិញ្ញាណចូលទៅកាន់យក គឺតេជោធាតុ ដែលញុំាងកាយឲ្យក្តៅសព្វ ១ តេជោធាតុដែលធ្វើកាយឲ្យគ្រាំគ្រា ១ តេជោធាតុដែលដុតកាយឲ្យក្រហល់ក្រហាយ ១

តេជោធាតុសម្រាប់ដុតភោជនដែលបុគ្គលស៊ី ផឹក ទំពាស៊ី ជញ្ជក់ជញ្ជាប់ ឲ្យទ្រុឌទ្រោមទៅដោយប្រពៃ ១ មួយទៀត ធាតុដទៃណានីមួយ ជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាភ្លើង ឬមានសភាពប្រហែលនឹងភ្លើង ដែលវិញ្ញាណ ចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា តេជោធាតុខាង ក្នុង ។ តេជោធាតុខាងក្នុងណាក្តី តេជោធាតុខាងក្រៅណាក្តី ធាតុទាំងពីរនេះ ឈ្មោះថា តេជោធាតុតែមួយយ៉ាង ។ ភិក្ខុគួរឃើញតេជោធាតុនោះ ដោយ បញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះឯង មិនជារបស់អញ នុ៎ះក៏មិនមែន ជាអញ នុ៎ះមិនមែនខ្លួនរបស់អញ ។ លុះភិក្ខុនោះឃើញតេជោធាតុនុ៎ះ ដោយ បញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះហើយ តែងនឿយណាយក្នុងតេជោធាតុ ធ្វើ ចិត្តឲ្យធុញទ្រាន់ក្នុងតេជោធាតុ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាល តេជោធាតុខាងក្រៅកម្រើកឡើង តេជោធាតុនោះ ឆេះស្រុកខ្លះ ឆេះនគរខ្លះ ឆេះនិគមខ្លះ ឆេះជនបទខ្លះ ឆេះជនបទ និងប្រទេសខ្លះ ។ តេជោធាតុនោះឆេះ ស្មៅស្រស់ខ្លះ ឆេះផ្លូវធំខ្លះ ថ្មភ្នំខ្លះ ទឹកខ្លះ ផ្ទៃផែនដីជារមណីយដ្ឋាន ( ដែល គ្មានស្មៅ ) ខ្លះ ឥតមានគ្រឿងឆេះតទៅទៀត ក៏រលត់បាត់ទៅ ។ ម្នាលអ្នក ទាំងឡាយមានអាយុ ចួនកាលជនទាំងឡាយ ស្វែងរកភ្លើងដោយស្លាបមាន់ ខ្លះ ដោយការកួតសរសៃស្បែកខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ សូម្បី តេជោធាតុខាងក្រៅនោះធំដល់ម៉្លោះ គង់មានសភាពមិនទៀងជាធម្មតា គង់ មានសភាពអស់ទៅជាធម្មតា គង់មានសភាពសូន្យទៅជាធម្មតា គង់មាន សភាពប្រែប្រួលទៅជាធម្មតា ។ ចំណង់បើកាយដែលតាំងនៅបន្តិចបន្តួចនេះ

ភិក្ខុនឹងប្រកាន់ដោយតណ្ហាថាអញ ថារបស់អញ ថាអញមាន ដូចម្តេចបាន ( កាលបើគិតដូច្នោះហើយ ) សេចក្តីប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ក្នុងតេជោធាតុជាខាងក្នុងនោះរបស់ភិក្ខុនោះ មិនមានឡើយ ។ ម្នាលអ្នកទាំង-ឡាយមានអាយុ កាលបើភិក្ខុនោះរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏តាំងនៅនឹងបាន ។ ភិក្ខុនោះមានចិត្តត្រេកអរ ដោយហេតុនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ភិក្ខុនោះឈ្មោះថា ធ្វើតាមពាក្យប្រដៅរបស់ព្រះមានព្រះភាគច្រើនៗ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

[ ៨៣ ] ម្នាលអ្នកទាំងឡាយមានអាយុ វាយោធាតុ តើដូចម្តេច ។ វាយោធាតុខាងក្នុងក៏មាន វាយោធាតុខាងក្រៅក៏មាន ។ ម្នាលអ្នកទាំងឡាយមានអាយុ វាយោធាតុខាងក្នុង តើដូចម្តេច ។ ធាតុណាជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាខ្យល់ ឬមានសភាពប្រហែលនឹងខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក គឺខ្យល់បក់ឡើងលើ ១ ខ្យល់បក់ចុះក្រោម ១ ខ្យល់បក់នៅក្នុងផ្ទៃ គឺបក់ខាងក្រៅពោះវៀន ១ ខ្យល់បក់ក្នុងពោះវៀន ១ ខ្យល់បក់សព្វសរីរាង្គកាយ ១ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ១ មួយទៀត វាយោធាតុដទៃណានីមួយ ជាខាងក្នុង អាស្រ័យនូវខ្លួន ជាខ្យល់ មានសភាពប្រហែលនឹងខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា វាយោធាតុខាងក្នុង ។ វាយោធាតុខាងក្នុងណាក្តី វាយោ-ធាតុខាងក្រៅណាក្តី ធាតុទាំងពីរនោះ ឈ្មោះថា វាយោធាតុតែមួយយ៉ាង ។

ភិក្ខុគួរឃើញវាយោធាតុនោះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះក៏មិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះភិក្ខុនោះឃើញវាយោធាតុនុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះហើយ ក៏នឿយណាយក្នុងវាយោធាតុ ធ្វើចិត្តឲ្យធុញទ្រាន់ក្នុងវាយោធាតុ ។ នែអ្នកទាំងឡាយមានអាយុ ចួនកាលវាយោធាតុខាងក្រៅកម្រើកឡើង វាយោធាតុនោះបក់លម្អិតស្រុកខ្លះ បក់លម្អិតនិគមខ្លះ បក់លម្អិតនគរខ្លះ បក់លម្អិតជនបទខ្លះ បក់លម្អិតជនបទ និងប្រទេសខ្លះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចួនកាលដល់ខែជាខាងចុងនៃគិម្ហរដូវ ជនទាំងឡាយតែងស្វែងរកខ្យល់ដោយផ្លិតស្លឹកត្នោតខ្លះ ដោយផ្លិតសម្រាប់បក់ភ្លើងខ្លះ សូម្បីតែស្បូវក្នុងសំយាបផ្ទះក៏មិនកម្រើកក៏មានដែរ ។ ម្នាលអ្នកទាំងឡាយមានអាយុ សូម្បីវាយោធាតុខាងក្រៅនោះ ធំដល់ម៉្លោះ គង់មានសភាពមិនទៀងជាធម្មតា គង់មានសភាពអស់ទៅជាធម្មតា គង់មានសភាពសូន្យទៅជាធម្មតា គង់មានសភាពប្រែប្រួលទៅជាធម្មតា ។ ចំណាន់បើកាយដែលតាំងនៅបន្តិចបន្តួចនេះ ភិក្ខុនឹងប្រកាន់ដោយតណ្ហា ថាអញ ថារបស់អញ ថាអញមាន ដូចម្ដេចបាន ( កាលបើគិតដូច្នេះហើយ ) សេចក្ដីប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ក្នុងវាយោធាតុជាខាងក្នុងនោះ របស់ភិក្ខុនោះ មិនមានឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ បើជនទាំងឡាយដទៃជេរប្រទេច ខ្ទាំងខ្ទប់ បៀតបៀនភិក្ខុនោះ ។ ភិក្ខុនោះតែងដឹងយ៉ាងនេះថា ទុក្ខវេទនាកើតអំពីសម្ផស្សនេះ កើតឡើងហើយដល់អាត្មាអញ គឺក៏វេទនានោះឯងអាស្រ័យហេតុ ឬមិនអាស្រ័យ

ហេតុទេ អាស្រ័យហេតុអ្វី គឺអាស្រ័យផស្សៈ ។ ភិក្ខុនោះឯងឃើញថា ផស្សៈមិនទៀង ឃើញថា វេទនាមិនទៀង ឃើញថា សញ្ញាមិនទៀង ឃើញថា សង្ខារទាំងឡាយមិនទៀង ឃើញថា វិញ្ញាណមិនទៀង ចិត្តរបស់ភិក្ខុនោះ ក៏ស៊ុះស្មុគ្រជះថ្លា ឋិតនៅព្រម ស៊ប់សួននៅក្នុងអារម្មណ៍ គឺធាតុនោះឯង ។ ម្នាលអ្នកទាំងឡាយមានអាយុ បើជនទាំងឡាយដទៃបៀតបៀនភិក្ខុនោះ ដោយសម្ផស្សដៃក្តី សម្ផស្សដុំដីក្តី សម្ផស្សដំបងក្តី សម្ផស្សគ្រឿងសស្ត្រាក្តី ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ ភិក្ខុនោះតែងដឹងច្បាស់យ៉ាងនេះថា កាយនេះឯងជាសភាពសម្រាប់រងសម្ផស្សដៃខ្លះ សម្ផស្សដុំដីខ្លះ សម្ផស្សដំបងខ្លះ សម្ផស្សសស្ត្រាខ្លះ ។ ព្រោះហេតុនោះបានជាព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះ ក្នុងឱវាទដែលប្រៀបដូចរណារថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកចោរ ជាអ្នកធ្វើអំពើថោកទាប គប្បីអារអវយវៈតូចធំទាំងឡាយ ( របស់ភិក្ខុនោះ ) ដោយរណារដែលមានដងទាំងពីរខាង ភិក្ខុណាធ្វើចិត្តប្រទូស្ត ( មិនអត់ធន់ ) ក្នុងជំនឺដែលពួកចោរអារនោះ ភិក្ខុនោះ ឈ្មោះថា មិនធ្វើតាមពាក្យប្រដៅរបស់តថាគត ដោយហេតុដែលមិនអត់ធន់នោះ ។ ភិក្ខុនោះគិតថា សេចក្តីព្យាយាមដែលអាត្មាអញប្រារព្ធហើយនឹងមិនធូរថយឡើយ សតិដែលអាត្មាអញតាំងខ្ជាប់ហើយ នឹងមិនភ្លាំងភ្លាត់ឡើយ កាយដែលស្ងប់ស្ងាត់ហើយ នឹងមិនរសាប់រសល់ឡើយ ចិត្តដែលតម្កល់នឹងហើយ នឹងមានអារម្មណ៍មូលតែមួយ ឥឡូវនេះ ទោះសម្ផស្សដៃត្រូវក្តី សម្ផស្សដុំដីត្រូវក្តី សម្ផស្សដំបងត្រូវក្តី សម្ផស្សគ្រឿងសស្ត្រាត្រូវក្តី ត្រង់

កាយនេះ ( ក៏ត្រូវទៅចុះ ) ឯអាត្មាអញក៏នៅតែធ្វើតាមពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធនេះមិនលែង ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល មិនទាន់តាំងនៅនឹងបាន ភិក្ខុនោះតែងតក់ស្លុត ដល់នូវសេចក្តីសង្វេគដោយហេតុនោះថា ឱហ្ន៎ អាត្មាអញជាមនុស្សឥតលាភ ឱហ្ន៎ អាត្មាអញជាមនុស្សមិនមានលាភ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញបានដោយកម្រ ឱហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញមិនមែនបានដោយងាយទេ ត្រង់ដែលអាត្មាអញរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល មិនទាន់តាំងនៅនឹងបាន ។ ម្នាលអ្នកទាំងឡាយមានអាយុ ដូចស្រីជាកូនប្រសា ឃើញឪពុកក្មេកហើយ ក៏ព្រួយបារម្ភ ដល់នូវសេចក្តីសង្វេគដូចម្តេចមិញ ម្នាលអ្នកទាំងឡាយមានអាយុ កាលភិក្ខុនោះរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏មិនបានតាំងនៅនឹងដូច្នោះឯង ។ ភិក្ខុនោះតែងតក់ស្លុត ដល់នូវសេចក្តីសង្វេគ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញជាមនុស្សឥតលាភ ឱហ្ន៎ អាត្មាអញជាមនុស្សមិនមានលាភ អត្តភាពជាមនុស្ស អាត្មាអញបានដោយកម្រ អត្តភាពជាមនុស្ស អាត្មាអញមិនមែនបានដោយងាយទេ ត្រង់ដែលអាត្មាអញរឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល មិនទាន់

តាំងនៅនឹងបាន ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើភិក្ខុនោះ រឭកនូវព្រះពុទ្ធយ៉ាងនេះ រឭកនូវព្រះធម៌យ៉ាងនេះ រឭកនូវព្រះសង្ឃយ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល រមែងតាំងនៅនឹងបាន ។ ភិក្ខុនោះមានចិត្តត្រេកអរដោយហេតុនោះ ។ ម្នាលអ្នកទាំងឡាយមានអាយុ ភិក្ខុនោះ ឈ្មោះថា ធ្វើតាមពាក្យប្រដៅរបស់ព្រះមានព្រះភាគច្រើនៗ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[ ៨៤ ] ម្នាលអ្នកទាំងឡាយមានអាយុ អាកាស គឺទីវាលដែលអាស្រ័យគ្រឿងឈើខ្លះ អាស្រ័យវល្លិសម្រាប់ចងខ្លះ អាស្រ័យដីសម្រាប់លាបខ្លះ អាស្រ័យស្បូវប្រក់ខ្លះ ផ្គុំជាមួយគ្នាហើយ ក៏រាប់ហៅថាផ្ទះបាន យ៉ាងណាមិញ ម្នាលអ្នកទាំងឡាយមានអាយុ អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថារូបបាន ដូច្នោះឯង ។ ម្នាលអ្នកទាំងឡាយមានអាយុ បើចក្ខុខាងក្នុងមិនសាបសូន្យទេ តែរូបទាំងឡាយខាងក្រៅ មិនបានមកកាន់គន្លងចក្ខុផង ការពិចារណាអារម្មណ៍ដែលកើតអំពីចក្ខុ និងរូបនោះមិនមានផង ចំណែកនៃវិញ្ញាណដែលកើតអំពីចក្ខុ និងរូបនោះក៏មិនទាន់កើតប្រាកដនៅឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ បើចក្ខុខាងក្នុងមិនសាបសូន្យទេ ហើយរូបទាំងឡាយខាងក្រៅ មកកាន់គន្លងចក្ខុ តែការពិចារណាអារម្មណ៍ដែលកើតអំពីចក្ខុ និងរូបនោះមិនមាន ចំណែកនៃវិញ្ញាណដែលកើតអំពីចក្ខុ និងរូបនោះ ក៏មិនទាន់កើតប្រាកដនៅឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលណាបើចក្ខុខាង

ក្នុងមិនសាបសូន្យផង រូបទាំងឡាយខាងក្រៅមកកាន់គន្លងចក្ខុផង ការពិចា-
រណាអារម្មណ៍ដែលកើតអំពីចក្ខុ និងរូបនោះ ក៏កើតមានផង ។ ចំណែកនៃ
វិញ្ញាណដែលកើតអំពីចក្ខុ និងរូបនោះ ទើបកើតប្រាកដឡើងបាន ដោយ
ប្រការដូច្នេះ ។ រូបណាដែលកើតជាមួយនឹងចក្ខុវិញ្ញាណ រូបនោះសង្គ្រោះ
ចូលក្នុងរូបូបាទានក្ខន្ធ ។ វេទនាណាដែលកើតជាមួយនឹងចក្ខុវិញ្ញាណ វេទនា
នោះសង្គ្រោះចូលក្នុងវេទនូបាទានក្ខន្ធ ។ សញ្ញាណាដែលកើតជាមួយនឹងចក្ខុ-
វិញ្ញាណ សញ្ញានោះ សង្គ្រោះចូលក្នុងសញ្ញូបាទានក្ខន្ធ ។ សង្ខារទាំងឡាយ
ណាដែលកើតជាមួយនឹងចក្ខុវិញ្ញាណ សង្ខារទាំងឡាយនោះសង្គ្រោះចូលក្នុង
សង្ខារូបាទានក្ខន្ធ ។ វិញ្ញាណណាដែលកើតជាមួយនឹងចក្ខុវិញ្ញាណនោះ សង្គ្រោះ
ចូលក្នុងវិញ្ញាណូបាទានក្ខន្ធ ។ ភិក្ខុនោះ តែងដឹងច្បាស់យ៉ាងនេះថា ការ
សង្គ្រោះ គឺប្រមូលប្រជុំនូវឧបាទានក្ខន្ធទាំង ៥ នេះ យ៉ាងនេះឯង ។ មួយ
វិញទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលណាឃើញបដិច្ច-
សមុប្បាទ ( គឺសេចក្តីកើតឡើង ព្រោះអាស្រ័យហេតុ ) បុគ្គលនោះ ឈ្មោះ
ថា ឃើញធម៌ បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញបដិច្ច-
សមុប្បាទ ( គឺសេចក្តីកើតឡើង ព្រោះអាស្រ័យហេតុ ) ។ ឧបាទានក្ខន្ធ
ទាំង៥ ណា ដែលមាននៅ ឧបាទានក្ខន្ធទាំង៥ នេះឯង កើតឡើងព្រម ព្រោះ
អាស្រ័យហេតុ សេចក្តីពេញចិត្ត សេចក្តីអាល័យ សេចក្តីត្រេកអរ និង
សេចក្តីជ្រប់ចុះក្នុងឧបាទានក្ខន្ធទាំង ៥ នេះណា សេចក្តីពេញចិត្តជាដើមនោះ
ឈ្មោះថា ទុក្ខសមុទយៈ ( ហេតុជាទីកើតឡើងនៃទុក្ខ ) ការកម្ចាត់បង់នូវ

តម្រេកដោយអំណាចនៃតណ្ហា និងការលះបង់នូវតម្រេក ដោយអំណាចនៃតណ្ហាណា ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ការកម្ចាត់បង់នូវតម្រេកជាដើមនោះ ឈ្មោះថា ទុក្ខនិរោធ ។ ម្នាលអ្នកទាំងឡាយមានអាយុ ពាក្យប្រដៅរបស់ព្រះមានព្រះភាគ ឈ្មោះថា ភិក្ខុនោះធ្វើរឿយៗ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ ម្នាលអ្នកទាំងឡាយមានអាយុ បើសោតប្បសាទខាងក្នុងមិនសាបសូន្យ ... ឃានប្បសាទមិនសាបសូន្យ ... ជិវ្ហាបសាទមិនសាបសូន្យ ... កាយប្បសាទមិនសាបសូន្យ ... ម្នាលអ្នកទាំងឡាយមានអាយុ បើមនោខាងក្នុងមិនសាបសូន្យទេ តែធម្មារម្មណ៍ទាំងឡាយខាងក្រៅ មិនបានមកកាន់គន្លងកវង្គផង ការពិចារណាអារម្មណ៍ដែលកើតអំពីមនោ និងធម្មារម្មណ៍នោះ ក៏មិនទាន់មានផង ចំណែកវិញ្ញាណដែលកើតអំពីមនោ និងធម្មារម្មណ៍នោះ ក៏មិនទាន់កើតប្រាកដនៅឡើយ ។ ម្នាលអ្នកទាំងឡាយមានអាយុ បើមនោខាងក្នុងមិនសាបសូន្យផង ធម្មារម្មណ៍ទាំងឡាយខាងក្រៅក៏បានមកកាន់គន្លងកវង្គផង តែការពិចារណាអារម្មណ៍ ដែលកើតអំពីមនោ និងធម្មារម្មណ៍នោះមិនមាន ចំណែកវិញ្ញាណដែលកើតអំពីមនោ និងធម្មារម្មណ៍នោះ ក៏នៅមិនទាន់ប្រាកដ ។ ម្នាលអ្នកទាំងឡាយមានអាយុ កាលបើមនោខាងក្នុងមិនសាបសូន្យផង ធម្មារម្មណ៍ទាំងឡាយខាងក្រៅបានមកកាន់គន្លងកវង្គផង ការពិចារណាអារម្មណ៍ដែលកើតអំពីមនោ និងធម្មារម្មណ៍នោះ ក៏មានផង ។ ចំណែកនៃវិញ្ញាណដែលកើតអំពីមនោ និងធម្មារម្មណ៍នោះ ទើបកើតប្រាកដឡើងបានយ៉ាងនេះឯង ។ រូបណាដែលកើតជាមួយនឹងមនោវិញ្ញាណ រូបនោះ

សង្គ្រោះចូលក្នុងរូបូបាទានក្ខន្ធ ។ វេទនាណា ដែលកើតជាមួយនឹងមនោ-
វិញ្ញាណ វេទនានោះ សង្គ្រោះចូលក្នុងវេទនូបាទានក្ខន្ធ ។ សញ្ញាណា ដែល
កើតជាមួយនឹងមនោវិញ្ញាណ សញ្ញានោះសង្គ្រោះចូលក្នុងសញ្ញូបាទានក្ខន្ធ ។
សង្ខារទាំងឡាយណា ដែលកើតជាមួយនឹងមនោវិញ្ញាណ សង្ខារទាំងឡាយ
នោះសង្គ្រោះចូលក្នុងសង្ខារូបាទានក្ខន្ធ ។ វិញ្ញាណណាដែលកើតជាមួយនឹង
ភវង្គ វិញ្ញាណនោះ សង្គ្រោះចូលក្នុងវិញ្ញាណូបាទាក្ខន្ធ ។ ភិក្ខុនោះ តែងដឹង
ច្បាស់យ៉ាងនេះថា ការសង្គ្រោះ គឺប្រជុំប្រមូលនូវឧបាទានក្ខន្ធទាំង ៥ នេះ
យ៉ាងនេះឯង ។ មួយទៀត ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា បុគ្គលណា
ឃើញបដិច្ចសមុប្បាទ បុគ្គលនោះឈ្មោះថាឃើញធម៌ បុគ្គលណាឃើញធម៌
បុគ្គលនោះឈ្មោះថា ឃើញបដិច្ចសមុប្បាទ ។ ឧបាទានក្ខន្ធទាំង ៥ ណា
ដែលមាននៅឧបាទានក្ខន្ធទាំង ៥ នេះឯង កើតឡើងព្រម ព្រោះអាស្រ័យ
ហេតុ សេចក្តីពេញចិត្ត សេចក្តីអាល័យ សេចក្តីត្រេកអរ និងសេចក្តីជ្រប់
ចុះណា ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ សេចក្តីពេញចិត្តជាដើមនោះ ឈ្មោះថា
ទុក្ខសមុទ័យ ការកម្ចាត់បង់នូវតម្រេកដោយអំណាចតណ្ហា និងការលះបង់
តម្រេកដោយអំណាចតណ្ហា ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ការកម្ចាត់បង់នូវ
តម្រេកជាដើមនោះ ឈ្មោះថា ទុក្ខនិរោធ ។ ម្នាលអ្នកទាំងឡាយមានអាយុ

ពាក្យប្រដៅរបស់ព្រះមានព្រះភាគ ឈ្មោះថា ភិក្ខុនោះ ធ្វើរឿយៗ ហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ លុះព្រះសារីបុត្រមានអាយុ សម្តែង នូវមហាហត្ថិបទោបមសូត្រនេះចប់ហើយ ភិក្ខុទាំងអម្បាលនោះ ក៏មានចិត្ត ត្រេកអររីករាយហើយ ចំពោះភាសិតរបស់ព្រះសារីបុត្រមានអាយុ ដោយ ប្រការដូច្នេះ ។

## មហាហត្ថិបទោបមសូត្រទី ៨ ចប់

# អដ្ឋកថា
## មហាហត្ថិបទោបមសូត្រ

[ ៧៨-៨០ ] មហាហត្ថិបទោបមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម គប្បីជ្រាបវិនិច្ឆ័យក្នុងមហាហត្ថិបទោបមសូត្រតទៅនេះ បទថា **ជង្គលានំ** ប្រែថា សញ្ចារទៅលើផែនដី ។ បទថា **ចាណានំ** បានដល់ សត្វមានជើង និងសត្វមិនមានជើង ។ បទថា **បទជាតានិ** ប្រែថា ស្នាមជើងទាំងឡាយ ។ បទថា **សមោធានំ គច្ឆន្តិ** បានដល់ ដល់នូវការសង្គ្រោះចូល គឺដាក់ចុះ ។ បទថា **អគ្គមក្ខាយតិ** ប្រែថា លោកពោលថា ប្រសើរ ។ បទថា **យទិទំ មហន្តត្តេន** សេចក្ដីថា លោកពោលថា លើស ព្រោះភាពជាស្នាមជើងធំ អធិប្បាយថា មិនមែនធំដោយគុណ ។ បទថា **យេ កេចិ កុសលា ធម្មា** បានដល់ កុសលធម៌ មិនថាលោកិយ ឬលោកុត្តរណាមួយឡើយ សង្គហៈ ក្នុងបទថា **សង្គហំ គច្ឆន្តិ** នេះ មាន ៤ យ៉ាង គឺសជាតិ-សង្គហៈ ១ សញ្ជាតិសង្គហៈ ១ កិរិយាសង្គហៈ ១ គណនសង្គហៈ ១ ។ បណ្ដាសង្គហៈ ៤ យ៉ាងនោះ ការសង្គ្រោះតាមជាតិរបស់ខ្លួនយ៉ាងនេះថា សូមក្សត្រទាំងឡាយមក សូមព្រាហ្មណ៍ទាំងឡាយមក ដូច្នេះ ឈ្មោះថា សជាតិ-សង្គហៈ ។ ការសង្គ្រោះតាមទឹកដីនៃជនជាតិនីមួយយ៉ាងនេះថា អ្នកដែនកោសលទាំងអស់ អ្នកមគធៈទាំងអស់ ឈ្មោះថា សញ្ជាតិសង្គហៈ ។ ការសង្គ្រោះដោយកិរិយា ដូចពាក្យថា ពលរថទាំងអស់ ពលធ្នូទាំងអស់ ឈ្មោះថា កិរិយាសង្គហៈ ។ ការសង្គ្រោះយ៉ាងនេះថា ចក្ខាយតនៈ សង្គ្រោះចូល

ក្នុងខន្ធណា ចក្ខាយតនៈ សង្គ្រោះចូលក្នុងរូបក្ខន្ធ ចក្ខាយតនៈដល់នូវការសង្គ្រោះចូលក្នុងរូបក្ខន្ធណា កាលត្រូវពោលដោយសេចក្តីនោះ ចក្ខាយតនៈលោកសង្គ្រោះជាមួយរូបក្ខន្ធ ឈ្មោះថា គណនសង្គហៈ ។ ក្នុងទីនេះ លោកបំណងយកគណនសង្គហៈនេះឯង ។

សួរថា ក្នុងការឆ្លើយបញ្ហាថា បណ្តាអរិយសច្ច ៤ មួយណាជាកុសល មួយណាជាអកុសល មួយណាជាអព្យាក្រឹត ដូច្នេះ ព្រះមហាថេរៈ ចែកកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ថា ជាសច្ចៈពាក់កណ្តាលប៉ុណ្ណោះ ព្រោះមកក្នុងព្រះបាលីថា សមុទយសច្ច ជាអកុសល មគ្គសច្ច ជាកុសល និរោធសច្ច ជាអព្យាក្រឹត ទុក្ខសច្ច ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន មិនមែនឬ កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបព្រះថេរៈពោលថា កុសលធម៌ទាំងនេះ សង្គ្រោះចូលក្នុងអរិយសច្ច ៤ ហ្ន៎ ឆ្លើយថា ព្រោះកុសលធម៌ទាំងនោះ សង្គ្រោះនៅក្នុងសច្ចៈទាំងឡាយ ។ ពិតហើយ សិក្ខាបទ ១៥០ ដែលសម្រេចប្រយោជន៍ រមែងជាអធិសីលសិក្ខា ម្យ៉ាងទៀត ភិក្ខុសិក្សាអធិសីលសិក្ខានោះ ព្រះមានព្រះភាគទ្រង់សម្តែងថា ឈ្មោះថា សិក្សាសិក្ខា ៣ ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ សម្រេចប្រយោជន៍នេះ រមែងសូធ្យរាល់កន្លះខែម្តង ពួកកុលបុត្រដែលប្រាថ្នាប្រយោជន៍កំពុងសិក្សា ម្នាលភិក្ខុទាំងឡាយ សិក្ខាទាំង ៣ នេះ គឺអធិសីល-សិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ព្រោះសិក្ខាបទ ១៥០ នោះ សង្គ្រោះចូលក្នុងសិក្ខាទាំងឡាយ ប្រៀបដូចស្នាមជើងនៃសត្វទាំងឡាយ មានចចក

ទន្សាយ និងម្រឹគជាដើម រមែងចុះក្នុងចំណែកមួយក្តី ចុះក្នុងចំណែក ២-៣-៤ ក្តី ឈ្មោះថា ក្នុងចំណែកនៃស្នាមជើងដំរីមួយ តែងចូលក្នុងស្នាមជើងដំរីទាំងអស់ មិនផុតចាកស្នាមជើងដំរីឡើយ ព្រោះចូលក្នុងស្នាមជើងដំរីនោះប៉ុណ្ណោះ យ៉ាងណា ធម៌ទាំងឡាយដែលរាប់ចូលក្នុងសច្ចៈ ១-២-៣-៤ ក្តី ក៏ដូច្នោះដូចគ្នា រមែងសង្គ្រោះចូលក្នុងសច្ចៈ ៤ ទាំងអស់ ព្រោះធម៌ទាំង-ឡាយ សង្គ្រោះចូលក្នុងសច្ចៈទាំងឡាយ ព្រោះហេតុនោះ ទើបលោកពោលដល់កុសលធម៌ ដែលសង្គ្រោះចូលក្នុងសច្ចៈពាក់កណ្តាលថា ធម៌ទាំងអស់នោះ សង្គ្រោះចូលក្នុងអរិយសច្ច ៤ ។

ពាក្យដែលគួរពោលក្នុងបទឧទ្ទេសថា **ទុក្ខំ អរិយសច្ចំ** ជាដើម និងក្នុងបទនិទ្ទេសថា **ជាតិបិ ទុក្ខា** ជាដើមទាំងអស់ បានពោលហើយ ក្នុងវិសុទ្ធិមគ្គ ។ តែក្នុងទីនេះ គប្បីជ្រាបចំពោះលំដាប់ទេសនាតែម្យ៉ាង ។ ឧបមាដូចជាងផែងដ៏ឈ្លាស បានឫស្សីដែលល្អមកមួយដើម កាត់ជា ៤ កំណាត់ ក្នុង ៤ កំណាត់នោះ វៀរ ៣ កំណាត់ កាន់យកតែ ១ កំណាត់ ទើបពុះជា ៥ ចម្រៀក ក្នុង ៥ ចម្រៀកនោះ វៀរ ៤ ចម្រៀក កាន់យកតែ ១ ចម្រៀក ហើយច្រៀកជា ៥ បន្ទះ ក្នុង ៥ បន្ទះនោះ វៀរ ៤ បន្ទះ កាន់យកតែ ១ បន្ទះ ហើយពុះជា ២ គឺខាងពោះ និងខាងខ្នង វៀរចំណែកខាងខ្នង កាន់យកតែចំណែកពោះ ធ្វើឲ្យជាគ្រឿងតម្បាញច្រើនប្រភេទ មានប្រអប់ផ្ទិតវីជនី និងផ្ទិតស្លឹកត្នោតជាដើម ជាងផែងនោះ មិនត្រូវបុគ្គលណាពោលថា មិនមែនជាការងារ ចំណែកខ្នង ៤ បន្ទះ ៤ ចម្រៀក និង ៣ កំណាត់ទៀត

ជាងមិនអាចប្រើការក្នុងគ្រាតែមួយបាន តែប្រើការផារតាមលំដាប់ យ៉ាងណា ឯព្រះមហាថេរៈនេះ ក៏ដូច្នោះដូចគ្នា ផ្តើមតាំងសុត្តន្តធំនេះហើយ តាំងមាតិកា ដោយអរិយសច្ច ៤ ដូចជាងផែងបានឫស្សីដែលល្អហើយ កាប់ជា ៤ កំណាត់ ដូច្នោះ ។ ព្រះថេរៈវៀរអរិយសច្ច ៣ ហើយ កាន់យកទុក្ខសច្ចតែមួយ ចំណែក ចែកធ្វើឲ្យជាខន្ធ ៥ ដូចជាងផែងវៀរ ៣ កំណាត់ កាន់យក ១ កំណាត់ ហើយធ្វើ ១ កំណាត់នោះ ឲ្យជា ៥ ចម្រៀកទៀត ។ បន្ទាប់អំពីនោះ ព្រះថេរៈវៀរអរូបក្ខន្ធ ៤ ហើយចែករូបក្ខន្ធ និងធ្វើមហាភូតរូប ៤ ឲ្យជា ៥ ចំណែក គឺមហាភូតរូប ៤ និងឧបាទាយរូប ១ ប្រៀបដូចជាងផែងនោះ វៀរ ៤ ចម្រៀក កាន់យក ១ ចម្រៀក ហើយពុះជា ៥ បន្ទះ ដូច្នោះ បន្ទាប់អំពីនោះ កាលព្រះថេរៈវៀរឧបាទាយរូប និងធាតុ ៣ ហើយ ចែកបឋវីធាតុតែម្យ៉ាងជា ២ ចំណែក គឺអជ្ឈត្តិករូប គឺរូបខាងក្នុង ពាហិររូប គឺរូបខាងក្រៅ ប្រៀបដូចជាងនោះវៀរ ៤ ចម្រៀក កាន់យក ១ ចម្រៀក ហើយពុះជា ២ គឺខាងពោះ ១ ខាងខ្នង ១ កាលវៀរបឋវីធាតុខាងក្រៅ ហើយសម្តែងចែកបឋវីធាតុខាងក្នុងដោយអាការ ២០ ទើបព្រះថេរៈពោលពាក្យជាដើមថា **កតមា ចាវុសោ អជ្ឈត្តិកា បឋវីធាតុ** ប្រៀបដូចជាងផែងវៀរចំណែកខ្នង កាន់យកចំណែកពោះ ទើបធ្វើឲ្យកើតជាគ្រឿងផែងប្រភេទផ្សេងៗ ដូច្នោះ ។ ម្យ៉ាងទៀត ប្រៀបដូចជាងផែង ប្រើចំណែកខាងខ្នង ៤ បន្ទះទៀត ៤ ចម្រៀកទៀត និង ៣ កំណាត់ទៀត ដោយលំដាប់ តែមិនអាចធ្វើក្នុងគ្រាតែមួយជាមួយគ្នាបាន ដោយប្រការដូច្នេះ យ៉ាងណា

សូម្បីព្រះថេរៈក៏ដូច្នោះ ចែកបឋវីធាតុខាងក្រៅ និងធាតុ ៤ ទៀត ឧបាទាយរូប អរូបក្ខន្ធ ៤ អរិយសច្ច ៣ ហើយសម្តែងតាមលំដាប់ តែមិនអាចសម្តែងតែម្តងបាន ។

ម្យ៉ាងទៀត គប្បីបរិយាយលំដាប់នេះ ដោយឧបមាអំពីរាជបុត្រ ឲ្យជាក់ច្បាស់ដូចតទៅនេះ បានឮថា មហារាជមួយអង្គ មានព្រះរាជឱរសច្រើនជាងមួយពាន់អង្គ ។ ព្រះអង្គទ្រង់ទុកគ្រឿងប្រដាប់ របស់ព្រះឱរសទាំងនោះក្នុងហិបធំ ៤ ទ្រង់ប្រគល់ទុកនឹងជេដ្ឋឱរស ដោយត្រាស់ប្រាប់ថា នែកូន គ្រឿងប្រដាប់នេះ ជារបស់ពួកប្អូននៃបា កាលមានមហោស្រព បាចូរឲ្យគ្រឿងប្រដាប់នេះ ព្រោះដូច្នោះ កាលប្អូនៗ សុំសឹមឲ្យ ឱរសច្បងនោះទទួលថា ករុណាថ្ងៃវិសេស ទើបរក្សាទុកក្នុងបន្ទប់សម្រាប់រក្សារាជសម្បត្តិ ។ ក្នុងថ្ងៃមហោស្រព ពួកព្រះរាជឱរសនាំគ្នាទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះបិតា សូមព្រះអង្គព្រះរាជទានគ្រឿងប្រដាប់ដល់ពួកទូលព្រះបង្គំចុះ ពួកទូលព្រះបង្គំនឹងលេងនក្ខត្តឫក្ស ។ ព្រះរាជាត្រាស់ថា នែកូន បិតាបានប្រគល់គ្រឿងប្រដាប់ទុកក្នុងដៃបងប្រុសរបស់បាហើយ ពួកបា ចូរនាំគ្រឿងប្រដាប់នោះទៅស្អិតស្អាងចុះ ។ ព្រះរាជឱរសទាំងនោះទទួលព្រះតម្រាស់រួច នាំគ្នាទៅរកព្រះជេដ្ឋឱរសនោះ ហើយទូលសូមគ្រឿងប្រដាប់អំពីជេដ្ឋឱរសនោះ ។ ជេដ្ឋឱរសបានចូលទៅក្នុងបន្ទប់ នាំយកហិបធំ ៤ ចេញមក វៀរហិប ៣ បើកហិប ១ នាំហិបតូច ៥ ចេញអំពីហិបធំនោះ ទុកហិបតូច ៤ បើកតែហិប ១ នាំប្រអប់ ៥ ចេញអំពីហិបតូច វៀរប្រអប់ ៤ បើកប្រអប់ ១ ដាក់សំពត់

ទុកម្ខាង បន្ទាប់អំពីនោះ ទើបនាំគ្រឿងប្រដាប់ដៃ គ្រឿងប្រដាប់ជើងផ្សេងៗ ប្រគល់ឲ្យ ។ ជេដ្ឋឱរស មិនបានចែកឲ្យអំពីប្រអប់ ៤ ហិបតូច ៤ ហិបធំ ៤ មុនក៏ពិត សូម្បីដូច្នោះ ក៏ឲ្យតាមលំដាប់ ព្រោះដូច្នោះ ទើបមិនអាចប្រគល់ឲ្យតែម្តងជាមួយគ្នាបាន ។

ក្នុងឧបមានោះ គប្បីឃើញព្រះមានព្រះភាគ ដូចជាមហារាជ ។ សមដូចពាក្យដែលលោកពោលថា ម្នាលសេលៈ តថាគតជាស្តេចធម្មរាជ ជាបុគ្គលប្រសើរ ... ដូច្នេះ ។ គប្បីឃើញព្រះសារីបុត្រដូចជេដ្ឋឱរស ។ សមដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាជនតែងនិយាយសរសើរភិក្ខុណាថា ( ភិក្ខុនេះ ) ជាបុត្រ ជាឱរសរបស់ព្រះមានព្រះភាគ កើតពីព្រះឱស្ឋរបស់ព្រះមានព្រះភាគ កើតអំពីធម៌ ធម៌និម្មិតឲ្យមក មានធម៌ជាមត៌ក មិនមែនមានអាមិសជាមត៌កឡើយ ដែលមហាជនតែងនិយាយសរសើរនូវភិក្ខុនោះ គឺសារីបុត្រហ្នឹងឯងថា ( សារីបុត្រនេះ ) ជាបុត្រ ជាឱរស របស់ព្រះមានព្រះមានព្រះភាគ កើតពីព្រះឱស្ឋរបស់ព្រះមានព្រះភាគ កើតពីធម៌ ធម៌និម្មិតឲ្យមក មានធម៌ជាមត៌ក មិនមែនមានអាមិសជាមត៌កឡើយ ។ គប្បីឃើញភិក្ខុសង្ឃដូចរាជឱរស ច្រើនជាង ១០០០ អង្គ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

ភិក្ខុច្រើនជាងពាន់ ចូលទៅគាល់ព្រះសុគតកំពុងសម្តែងធម៌ ដែលជាប់ទាក់ទងដោយព្រះនិព្វាន ជាធម៌ប្រាសចាកធូលី គឺកិលេស ឥតមានភ័យអំពីទីណាមួយឡើយ ។

វេលាដែលព្រះមានព្រះភាគ ទ្រង់ប្រកាសសច្ចៈ ៤ ទុកក្នុងដៃនៃព្រះធម្មសេនាបតី ប្រៀបដូចវេលាដែលព្រះរាជាទ្រង់ទុកគ្រឿងប្រដាប់ របស់ព្រះរាជឱរសទាំងនោះ ក្នុងហិបធំ ៤ ហើយទុកក្នុងដៃរបស់ជេដ្ឋឱរស ដូច្នោះ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រសមគួរប្រាប់ បញ្ញត្ត តែងតាំង បើកផ្សាយ ចែក ធ្វើឲ្យរាក់នូវអរិយសច្ច ៤ ដោយពិស្តារ ។ វេលាដែលភិក្ខុសង្ឃ មកក្នុងសម័យកៀកចូលវស្សា ហើយអារាធនាឲ្យសម្តែងធម៌ ប្រៀបដូចវេលាដែលព្រះរាជឱរសទាំងនោះចូលទៅគាល់ព្រះរាជា ទូលសូមគ្រឿងប្រដាប់ក្នុងថ្ងៃមហោស្រព ដូច្នោះ ។ បានឮថា ក្នុងថ្ងៃកៀកចូលវស្សា ព្រះមានព្រះភាគទ្រង់សម្តែងព្រះសូត្រនេះ ។ វេលាដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជូនភិក្ខុទាំងឡាយ ទៅកាន់សម្នាក់របស់ព្រះធម្មសេនាបតី ដោយព្រះតម្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរសេព ចូរគប់រកសារីបុត្រ និងមោគ្គល្លានចុះ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ និងមោគ្គល្លានជាបណ្ឌិត អនុគ្រោះសព្រហ្មចារី ប្រៀបដូចពេលដែលព្រះរាជាត្រាស់ថា នែកូន បិតាបានប្រគល់គ្រឿងប្រដាប់ទុកក្នុងដៃបងប្រុសពួកបាហើយ ចូរនាំមកប្រដាប់ចុះ ។ វេលាដែលភិក្ខុទាំងឡាយ ស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា ហើយចូលទៅរកព្រះធម្មសេនាបតី ហើយអារាធនាឲ្យសម្តែងធម៌ ប្រៀបដូចវេលាដែលពួកព្រះរាជឱរសស្តាប់ព្រះតម្រាស់របស់ព្រះរាជា ហើយទៅកាន់សម្នាក់របស់ជេដ្ឋឱរស ហើយសូមគ្រឿងប្រដាប់ ដូច្នោះ ។ វេលាដែលព្រះធម្មសេនាបតី ផ្តើមព្រះសុត្តន្តនេះ

ហើយ ដាក់មាតិកាដោយអរិយសច្ច ៤ ប្រៀបដូចវេលាដែលព្រះជេដ្ឋឱរស បើកបន្ទប់ ហើយនាំហិប ៤ ដាក់ទុក ដូច្នោះ ។ ការវៀរអរិយសច្ច ៣ ហើយចែកទុក្ខអរិយសច្ច សម្តែងបញ្ចក្ខន្ធ ប្រៀបដូចការវៀរហិប ៣ ហើយ បើកហិប ១ នាំហិបតូច ៥ ចេញអំពីហិប ១ នោះ ដូច្នោះ ។ ការដែល ព្រះថេរៈវៀរអរូបក្ខន្ធ ៤ ហើយសម្តែងចែករូបក្ខន្ធ ១ ជា ៥ ចំណែក ដោយមហាភូតរូប ៤ និងឧបាទាយរូប ១ ប្រៀបដូចវៀរហិបតូច ៤ បើក តែហិបតូច ១ ហើយនាំយកប្រអប់ ៥ ចេញអំពីហិបតូច ១ នោះ ដូច្នោះ ។ ការដែលព្រះថេរៈវៀរមហាភូតរូប ៣ និងឧបាទាយរូប ហើយចែកបឋវីធាតុ តែម្យ៉ាង វៀរបឋវីធាតុខាងក្រៅចេញ ដូចបិទទុកដើម្បីសម្តែងបឋវីធាតុខាង ក្នុង ដែលមានអាការ ២០ ដោយសភាវៈផ្សេងៗ ទើបពោលពាក្យថា **កតមា ចាវុសោ អជ្ឈត្តិកា បឋវីធាតុ** ដូច្នេះជាដើម ។ ប្រៀបដូចវៀរហិប ៤ បើកតែ ១ វៀរហិបដែលបិទទុកក្នុងចំណែកម្ខាងហើយ ឲ្យគ្រឿងប្រដាប់ដៃ និងគ្រឿងប្រដាប់ជើងជាដើម គប្បីជ្រាបថា សូម្បីព្រះថេរៈចែកមហាភូតរូប ៣ ឧបាទាយរូប អរូបក្ខន្ធ ៤ អរិយសច្ច ៣ ហើយសម្តែងតាមលំដាប់ ក្នុង កាលជាខាងក្រោយ ដូចរាជឱរសនោះ នាំប្រអប់ ៤ ហិបតូច ៤ និងហិប ទាំង ៣ នោះហើយ ប្រទានគ្រឿងប្រដាប់តាមលំដាប់ ក្នុងកាលជាក្រោយ ។ ពាក្យនោះ លោកពោលថា **កតមា ចាវុសោ អជ្ឈត្តិកា បឋវីធាតុ** ជា ដើម គប្បីជ្រាបវិនិច្ឆ័យពាក្យនោះ សូម្បីបទទាំង ២ ថា **អជ្ឈត្តំ បច្ចត្តំ** នេះ ជាឈ្មោះរបស់ធម្មជាតិដែលមានក្នុងខ្លួន ។ បទថា **កក្ខលំ** ប្រែថា រឹង ។

បទថា **ខរិគតំ** ប្រែថា គ្រោតគ្រាត ។ បទថា **ឧបាទិន្នំ** បានដល់ មិនមែនមានកម្មជាសមុដ្ឋានប៉ុណ្ណោះ ។ តែកាលពោលដោយមិនប្លែកគ្នា ពាក្យថា **ឧបាទិន្នំ** នេះ ជាឈ្មោះនៃរូបដែលតាំងនៅក្នុងសរីរៈ ។ ពិតហើយ រូបតាំងនៅក្នុងសរីរៈ មិនថាជាឧបាទិន្នរូប ឬអនុបាទិន្នរូប ឈ្មោះថា ជាឧបាទិន្នរូបទាំងអស់នោះឯង ដោយការប្រកាន់ ពាល់ ត្រូវ ស្ទាបអង្អែលបាន គឺសក់ រោម ។បេ។ អាហារថ្មី អាហារចាស់ ។ ពាក្យនេះ លោកកំណត់ចែកទុកដោយជាបឋវីធាតុជាខាងក្នុង សម្រាប់កុលបុត្រដែលបំពេញធាតុកម្មដ្ឋាន ។ តែក្នុងទីនេះ ពាក្យដែលបុគ្គលប្រាថ្នា នឹងផ្ដើមមនសិការ ចម្រើនវិបស្សនា ទាញយកព្រះអរហត្ត គួរធ្វើទាំងអស់ បានពោលពិស្ដារហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ តែពាក្យថា **មត្ថលុង្គំ** គឺខួរក្នុងក្បាល មិនបានឡើងកាន់បាលីក្នុងទីនេះ ។ តែខួរក្នុងក្បាលនោះ នាំមកកំណត់ដោយពណ៌ និងសណ្ឋានជាដើម ដោយន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គ ទើបមនសិការថា សូម្បីធាតុនេះ ក៏មិនមានចេតនា ជាអព្យាក្រឹត ទទេ ជារបស់រឹង ចាត់ជាបឋវីធាតុដូចគ្នា ។ បទថា **យំ វា បនញ្ញម្បិ** នេះ លោកពោលដើម្បីកំណត់កាន់យកបឋវីធាតុ ដែលនៅក្នុងចំណែក ៣ ក្រៅអំពីនេះ ។ បទថា **យា ចេវ ខោ បន អជ្ឈត្តិកា បឋវីធាតុ** សេចក្ដីថា បឋវីធាតុមានប្រការតាមដែលពោលហើយនេះ ចាត់ជាបឋវីធាតុខាងក្នុង ។ បទថា **យា ច ពាហិរា** សេចក្ដីថា បឋវីធាតុមកហើយក្នុងវិភង្គ ដោយន័យថា ដែក លោហៈ សំណប៉ាហាំង សំណកក់ជាដើម ឈ្មោះថា បឋវីធាតុខាងក្រៅ ។

ដោយលំដាប់ពាក្យ មានប្រមាណប៉ុណ្ណេះ ព្រះថេរៈសម្តែងបឋវីធាតុដែលជាខាងក្នុងដោយអាការ ២០ ដោយសភាវៈផ្សេងៗ យ៉ាងពិស្តារ សម្តែងធាតុខាងក្រៅដោយសង្ខេប ។ ព្រោះហេតុអ្វី ព្រោះក្នុងទីណាសត្វទាំងឡាយមានសេចក្តីអាល័យ ប្រាថ្នា ចោមរោម ប្រកាន់មាំ ប្រកាន់ស្អិត ខ្ជាំងក្លា ក្នុងទីនោះ ព្រះពុទ្ធទាំងឡាយក្តី ពុទ្ធសាវកក្តី នឹងពោលរៀងយ៉ាងពិស្តារ ដើម្បីដកនូវអាល័យជាដើមនៃសត្វទាំងនោះ ។ ម្យ៉ាងទៀត ក្នុងទីណា សេចក្តីអាល័យជាដើមរបស់សត្វមិនមានកម្លាំង ក្នុងទីនោះ លោកពោលដោយសង្ខេប ព្រោះមិនមានកិច្ចដែលនឹងត្រូវធ្វើ ដូចអ្នកស្រែ កាលភ្ជួរ ក៏បញ្ឈប់គោទុកត្រង់ទីដែលភ្ជួរ ព្រោះជាប់ដោយឫសឈើ និងជន្លត់ឈើដ៏ក្រាស់ កាយដីឡើង កាត់ឫសឈើ និងគល់ឈើ លើកឡើង ត្រូវធ្វើសេចក្តីព្យាយាមច្រើន ក្នុងទីណាមិនមានឫសឈើ និងជន្លត់ ក៏មិនចាំបាច់ព្យាយាមច្រើន ក្នុងទីនោះ គ្រាន់តែវាយខ្នងគោ ភ្ជួរទៅ យ៉ាងណា ពាក្យឧបមេយ្យនេះ ក៏គប្បីជ្រាប ដូច្នោះ ។

បទថា **បឋវីធាតុរេវេសា** សេចក្តីថា ធាតុទាំង ២ យ៉ាងនេះ មានលក្ខណៈតែមួយ ដោយអត្ថថា រឹង និងគ្រោតគ្រាត នេះក៏ចាត់ជាបឋវីធាតុ លោកសម្តែងប្រកបទុកខាងក្នុង និងខាងក្រៅ ព្រោះហេតុដែលបឋវីធាតុខាងក្រៅ ប្រាកដថា មិនមានចេតនា បឋវីធាតុខាងក្នុង មិនប្រាកដដូច្នោះឡើយ ព្រោះដូច្នោះ ព្រះយោគាវចរកំណត់ថា បឋវីធាតុខាងក្នុងនោះ ដូចគ្នានឹងបឋវី-ធាតុខាងក្រៅ មិនមានចេតនាដូចគ្នា ទើបកំណត់បានស្រួល សេចក្តីនេះ

ប្រៀបដូចអ្វី ប្រៀបដូចគោដែលមិនបានហ្វឹក ទឹមជាមួយគោដែលហ្វឹកហើយ រមែងរើបម្រះ ២ ថ្ងៃ ៣ ថ្ងៃប៉ុណ្ណោះ កាលបើដូច្នេះ មិនយូរប៉ុន្មាន ក៏បង្វឹកបាន យ៉ាងណា ព្រះយោគាវចរកំណត់ថា សូម្បីបឋវីធាតុខាងក្នុង ក៏ដូចគ្នានឹងបឋវីធាតុខាងក្រៅ បឋវីធាតុក៏ប្រាកដ មិនមានចេតនាបាន ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ កាលបើដូច្នេះ មិនយូរប៉ុន្មាន បឋវីធាតុខាងក្នុងនោះ ក៏ប្រាកដថា មិនមានចេតនាដូច្នោះ ។ បទថា **តំ ណេតំ មម** សេចក្តីថា ធាតុទាំង ២ ដែលបណ្ឌិតគប្បីឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនរបស់អញ ។ បទថា **តថាភូតំ** ប្រែថា តាមសភាវៈពិត ។ អធិប្បាយថា ពិតហើយ ធាតុទាំង ២ នោះមានភាវៈមិនទៀងជាដើម ព្រោះដូច្នោះ គប្បីឃើញយ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា** ។ បទថា **ហោតិ ខោ សោ អាវុសោ** សេចក្តីថា ព្រោះហេតុអ្វីទើបលោកប្រារព្ធទុក ព្រោះកាលសម្តែងសេចក្តីវិនាសនៃបឋវីធាតុខាងក្រៅដោយអំណាចអាបោធាតុខាងក្រៅ ហើយសម្តែងការវិនាសនៃបឋវីធាតុដែលតាំងនៅក្នុងរាងកាយ ដែលជាឧបាទិន្នរូបពិសេសជាងនោះ ។ បទថា **បកុប្បតិ** សេចក្តីថា កម្រើកញាប់ញ័រដោយអំណាចការវិនាសដោយទឹក ។ បទថា **អន្តរហិតា តស្មឹ សមយេ ពាហិរា បឋវីធាតុ ហោតិ** សេចក្តីថា សម័យនោះ បឋវីធាតុរលាយដោយទឹកក្រុត ក្នុងសែនកោដិចក្រវាលហូរតាមទឹកទៅតាំងអំពីភ្នំទាំងអស់ជាដើម ក៏អន្តរធានទៅ រលាយជាទឹកតែម្យ៉ាង ។ បទថា **តាវ មហល្លិកាយ** ប្រែថា ធំដល់ម៉្លោះ ។ ដែលឈ្មោះថា ធំ ព្រោះមាន

កម្រាស់យ៉ាងនេះ គឺ

**ទ្វេ ច សតសហស្សានិ ចត្តារិ នហុតានិ ច**
**ឯត្តកំ ពហលត្តេន សង្ខាតាយំ វសុន្ធរា ។**

ផែនដីធំនេះ ពោលដោយចំណែកកម្រាស់ មានប្រមាណ ២ សែន ៤ ម៉ឺនយោជន៍ ។ តែបើពោលដោយចំណែកទទឹង មានប្រមាណ ១ សែនកោដិចក្រវាល ដោយប្រការដូច្នេះ ។

បទថា **អនិច្ចតា** ប្រែថា មានហើយ ទៅជាមិនមាន ។ បទថា **ខយធម្មតា** ប្រែថា មានការអស់ទៅជាសភាវៈ ។ បទថា **វយធម្មតា** ប្រែថា មានការសូន្យទៅជាសភាវៈ ។ បទថា **វិបរិណាមធម្មតា** ប្រែថា មានការលះប្រក្រតីជាសភាវៈ ។ លោកពោលដល់អនិច្ចលក្ខណៈតែម្យ៉ាងក្នុងគ្រប់បទដោយប្រការដូច្នេះ ។ លក្ខណៈទាំង ៣ រមែងមកតាមប្រក្រតីថា របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា ។ បទថា **មត្តដ្ឋកស្ស** ប្រែថា តាំងនៅមួយជួរខណៈបន្តិចបន្តួច ។ ក្នុងបទនោះ គប្បីជ្រាបថា កាយនេះ តាំងនៅមួយជួរខណៈបន្តិចបន្តួច ដោយអាការ ២ គឺ តាំងនៅបន្តិចបន្តួច និងមានកិច្ចបន្តិចបន្តួច ។ ពិតហើយ កាយនេះ លោកពោលថា ក្នុងខណៈចិត្តដែលជាអតីតប្រព្រឹត្តទៅហើយ មិនមែនកំពុងរស់នៅ មិនមែននឹងរស់នៅ ក្នុងខណៈចិត្តដែលជាអនាគត នឹងប្រព្រឹត្តទៅ មិនមែនកំពុងរស់នៅ មិនមែនរស់នៅហើយ ខណៈចិត្តដែលជាបច្ចុប្បន្នកំពុងរស់នៅ មិនមែនរស់នៅហើយ មិនមែននឹងរស់នៅ ដើម្បីសម្ដែងថា កាយនេះឯង

តាំងនៅបន្តិចបន្តួច ទើបលោកពោលពាក្យនេះថា

**ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា**

**ឯកចិត្តសមាយុត្តា លហុសោ វត្តតេ ខណោ ។**

ជីវិតក្តី អត្តភាពក្តី សុខក្តី ទុក្ខក្តី សុទ្ធតែប្រកបដោយចិត្ត ១ ដួងខណៈរមែងប្រព្រឹត្តទៅឆាប់រហ័ស ។

គប្បីជ្រាបថា កាយនេះ តាំងនៅមួយជួរវេលាកាលតិចតួច ព្រោះតាំងនៅមួយជួរវេលាកាលតិចតួចយ៉ាងនេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា កាយនោះមានកិច្ចតិចតួច ព្រោះទាក់ទងដោយខ្យល់អស្សាសបស្សាសៈជាដើម ។ ពិតហើយ សត្វទាំងឡាយមានជីវិត ទាក់ទងដោយខ្យល់អស្សាសៈ ទាក់ទងដោយខ្យល់បស្សាសៈ ទាក់ទងដោយខ្យល់អស្សាសៈផង បស្សាសៈផង ទាក់ទងដោយមហាភូតរូប ទាក់ទងដោយកពឡិង្ការាហារ ទាក់ទងដោយវិញ្ញាណសេចក្តីនេះ បានពោលហើយ ក្នុងវិសុទ្ធិមគ្គ ។

បទថា **តណ្ហុបាទិន្នស្ស** ប្រែថា ត្រូវតណ្ហាប្រកាន់មាំ បរបោសអង្អែល ។ បទថា **អហន្តិ វា មមន្តិ វា អស្មីតិ វា អថខ្វស្ស នោ តេវេត្ថ ហោតិ** សេចក្តីថា គ្រានោះឯង ភិក្ខុនោះលើកឡើងកាន់ត្រៃលក្ខណ៍ ពិចារណាយ៉ាងនេះ រមែងមិនមានគាហៈ គឺតណ្ហា មានះ និងទិដ្ឋិ ៣ យ៉ាង ក្នុងបឋវីធាតុខាងក្នុងនេះថា នេះជាអញជាដើម អធិប្បាយថា មិនមានឡើយ ។ បឋវីធាតុខាងក្រៅ រមែងអន្តរធានទៅ ដោយអំណាចតេជោធាតុ វាយោធាតុ ។ ដូចអន្តរធានទៅដោយអំណាចអាបោធាតុ ដូច្នោះ ។ តែក្នុងទីនេះ មកតែម្យ៉ាង

ប៉ុណ្ណោះ ។ ក្រៅអំពីនេះ គប្បីជ្រាបដោយអត្ថដូចគ្នា ។ ក្នុងបទថា **តញ្ចេ អាវុសោ** នេះ ព្រះថេរៈកាលផ្តើមធ្វើការកំណត់អារម្មណ៍ក្នុងសោតទ្វាររបស់ភិក្ខុអ្នកបំពេញធាតុកម្មដ្ឋាននោះ ទើបសម្តែងកម្លាំង ។ បទថា **អក្កោសន្តិ** បានដល់ ជេរដោយអក្កោសវត្ថុ ១០ ។ បទថា **បរិភាសន្តិ** បានដល់ សម្លុតដោយវាចាថា លោកធ្វើយ៉ាងនេះ ខ្ញុំនឹងដាក់ទោសលោក យ៉ាងនេះ ។ បទថា **រោសេន្តិ** ប្រែថា រមែងបៀតបៀន ។ បទថា **វិហេសេន្តិ** ប្រែថា រមែងធ្វើឲ្យលំបាក ។ លោកពោលចំពោះការបៀតបៀនដោយវាចាទាំងអស់ ។ បទថា **សោ ឯវំ** សេចក្តីថា ភិក្ខុអ្នកបំពេញធាតុកម្មដ្ឋាន នោះរមែងដឹងយ៉ាងនេះ ។ បទថា **ឧប្បន្នា ខោ មេ អយំ** សេចក្តីថា កើតឡើងព្រោះធាតុ ៤ ដែលកើតប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងកើតឡើងព្រោះការកម្រើកញាប់ញ័រ ។ បទថា **សោតសម្ផស្សជា** សេចក្តីថា វេទនាដែលស្ទុះ ទៅតាមសោតទ្វារ កើតអំពីសោតសម្ផស្ស ដោយអំណាចឧបនិស្ស័យ ។ ដោយបទថា **ផស្សោ អនិច្ចោ** លោកសម្តែងថា សោតសម្ផស្ស ឈ្មោះថា មិនទៀង ព្រោះអត្ថថា មានហើយ ទៅជាមិនមាន ។ សូម្បីវេទនាជាដើម គប្បីយល់ថា សម្បយុត្ត ដោយសោតសម្ផស្សតែម្យ៉ាង ។ បទថា **ធាត្វារម្មណមេវ** បានដល់ អារម្មណ៍ ពោល គឺធាតុនោះឯង ។ បទថា **បក្ខន្ទតិ** បានដល់ ឈមចុះ ។ បទថា **បសីទតិ** បានដល់ ផូរផង់ក្នុងអារម្មណ៍ ។ ម្យ៉ាងទៀត ពាក្យនោះជាសត្តមីវិភត្តិតែម្យ៉ាង ។ កាលពោលដោយអំណាចព្យញ្ជនសន្ធិ លោកពោលថា **ធាត្វារម្មណមេវ** ក្នុងពាក្យនេះ មានអត្ថ ដូច្នេះថា **ធាត្វារម្មណេយេវ** ក្នុង

អារម្មណ៍ គឺធាតុ ។ កាលពោលដោយអំណាចធាតុ បទថា **វិមុច្ចតិ** នេះ រមែងបានដល់អធិមោក្ខ មិនត្រេកអរ មិនប្រទូស្ត ។ សេចក្តីពិត ភិក្ខុអ្នកបំពេញធាតុកម្មដ្ឋាននេះ កាលអារម្មណ៍មកប្រាកដក្នុងសោតទ្វារ រមែងកំណត់ថា ជាមូល ជាអារម្មណ៍ដែលគួរកំណត់ដឹង ជាអារម្មណ៍ដែលចរមក ជាអារម្មណ៍ដែលកើតឡើងមួយផ្លូវខណៈ ។ រឿងពិស្តារនៃអារម្មណ៍នោះ បានពោលហើយក្នុងសម្បជញ្ញបព្វៈ ក្នុងសតិប្បដ្ឋានសូត្រ ។ តែវេទនានោះពោលនៅក្នុងសតិប្បដ្ឋានសូត្រនោះ ដោយអំណាចចក្ខុទ្វារ ។ ក្នុងទីនេះ គប្បីជ្រាបដោយអំណាចសោតទ្វារ ។

ពិតហើយ ភិក្ខុបំពេញធាតុកម្មដ្ឋាន ធ្វើការកំណត់យ៉ាងនេះហើយ ចម្រើនវិបស្សនាយ៉ាងខ្ជាំងក្លា កាលអារម្មណ៍មកប្រាកដក្នុងចក្ខុទ្វារជាដើម រមែងកើតអាវជ្ជនចិត្ត វោដ្ឋព្វនចិត្ត ដោយអយោនិសោមនសិការដល់វោដ្ឋព្វនចិត្ត បានអាសេវនចិត្តម្តង ឬពីរដង ចិត្តក៏ធ្លាក់ចុះកាន់ភវង្គដូចមុន ក៏មិនកើតដោយអំណាចរាគៈជាដើម ភិក្ខុនេះឈ្មោះថា ដល់នូវទីបំផុតនៃពលវវិបស្សនា ។ ភិក្ខុមួយរូបកើតជវនចិត្តម្តង ដោយអំណាចរាគៈជាដើម តែក្នុងទីបំផុតជវនចិត្តលោកនឹកដោយអំណាចរាគៈជាដើមថា ជវនចិត្តកើតដល់អញ ឈ្មោះថាកំណត់អារម្មណ៍បានហើយ មិនកើតដូច្នោះម្តងទៀត ។ ភិក្ខុមួយរូបទៀតនឹកដល់ម្តង ក៏កើតជវនចិត្តដោយអំណាចរាគៈជាដើម ជាគ្រាទី ២ ទៀត កាលចប់គ្រាទី ២ នឹកថា ជវនចិត្តកើតដល់អញហើយយ៉ាងនេះ ឈ្មោះថា កំណត់អារម្មណ៍ដូចគ្នា ។ ក្នុងគ្រាទី ៣ ក៏មិនកើតយ៉ាងនោះ ។ បណ្តាភិក្ខុ ៣ រូប

នោះ រូបទី ១ ចាស់ក្លា រូបទី ៣ ទន់ខ្សោយ ។ តែពោលដោយអំណាចរូបទី ២ គប្បីជ្រាបអត្ថនេះ ក្នុងព្រះសូត្រនេះ មានសត្វប្រចៀច ជាគ្រឿងប្រៀបធៀបដោយការៈជាឥន្ទ្រិយនោះឯង ។ ព្រះថេរៈកាលសម្តែងកម្លាំងរបស់ភិក្ខុដែលបំពេញធាតុកម្មដ្ឋាន ដោយអំណាចការកំណត់ក្នុងសោតទ្វារយ៉ាងនេះហើយ ឥឡូវនេះ កាលសម្តែងក្នុងកាយទ្វារ ទើបពោលពាក្យថា **តញ្ចេ អាវុសោ** ជាដើម ។ ពិតហើយ ភិក្ខុដែលដល់នូវអនិដ្ឋារម្មណ៍ រមែងលំបាកក្នុងទ្វារទាំង ២ គឺសោតទ្វារ និងកាយទ្វារ ព្រោះដូច្នោះ ព្រះមហាថេរៈគិតថា ក្នុងអនាគតកាល កុលបុត្រដែលត្រូវសិក្សា បំពេញព្យាយាម ដល់នូវការសង្រួមក្នុងទ្វារទាំង ២ នេះ នឹងធ្វើទីបំផុតនៃជាតិ ជរា មរណៈ បានឆាប់រួសរាន់នោះឯង ប្រៀបដូចបុរសម្ចាស់ស្រែ កាន់ចបដើរពិនិត្យមើលស្រែ មិនបន្ថែមដុំដីក្នុងទីណាមួយ យកចបកាប់ដីចំពោះក្នុងទីដែលមិនរាបស្មើ បន្ថែមដីក្នុងទីដែលមានស្នៅ ដូច្នោះ កាលនឹងសម្តែងការសង្រួមក្នុងទ្វារទាំង ២ នេះឯង ឲ្យមាំទាំ ទើបផ្តើមទេសនានេះ ។

បណ្តាបទទាំងនោះ បទថា **សមុទាចរន្តិ** បានដល់ ព្យាយាម ។ បទថា **បាណិសម្ផស្សេន** បានដល់ ប្រហារដោយបាតដៃ ។ ក្នុងពាក្យក្រៅអំពីនេះក៏មានន័យដូចគ្នា ។ បទថា **យថាភូតោ** ប្រែថា មានសភាវៈយ៉ាងនោះ ។ បទថា **យថាភូតស្មឹ** ប្រែថា តាមសភាវៈ ។ បទថា **កមន្តិ** ប្រែថា ប្រព្រឹត្តទៅ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯវំ ពុទ្ធំ អនុស្សរតោ** ជាដើម ភិក្ខុអ្នកបំពេញធាតុកម្មដ្ឋាន កាលនឹកដល់ដោយន័យជាដើមថា **ឥតិបិ សោ ភគវា**

ឈ្មោះថា រឭកដល់ព្រះពុទ្ធ គឺកាលរឭកថា ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយដូចគ្នា ក៏ឈ្មោះថា រឭកដូចគ្នា ។ កាលរឭកដោយន័យជាដើមថា **ស្វាក្ខាតោ ភគវតា ធម្មោ** ឈ្មោះថា រឭកដល់ព្រះធម៌ សូម្បីរឭកដល់កកចូបមោវាទសូត្រ ក៏ឈ្មោះថា រឭកដល់ដូចគ្នា ។ សូម្បីរឭកដល់ដោយន័យជាដើមថា **សុបដិបន្នោ** ឈ្មោះថា រឭកដល់ព្រះសង្ឃ ទោះរឭកដល់គុណរបស់ភិក្ខុដែលអត់អន់ ដោយការអារដោយរណារ ក៏ឈ្មោះថា រឭកដល់ដូចគ្នា ។ ក្នុងបទថា **ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ** នេះ លោកបំណងយកវិបស្សនូបេក្ខា ។ ក្នុងបទថា **ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ** នេះ លោកបំណងយកឆឡង្គុបេក្ខាដែលមានអង្គ ៦ ។ ឆឡង្គុបេក្ខានេះប្រព្រឹត្តទៅដោយអំណាចការមិនត្រេកអរជាដើម ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍របស់ព្រះខីណាស្រពក៏ពិត សូម្បីយ៉ាងនោះ ភិក្ខុនេះ តាំងវិបស្សនារបស់ខ្លួន ដោយការសម្រេចនៃភាវនាតាមកម្លាំងព្យាយាម ក្នុងឋានរបស់ឆឡង្គុបេក្ខារបស់ព្រះខីណាស្រព ព្រោះដូច្នោះ ទើបវិបស្សនានោះឯង ឈ្មោះថា ឆឡង្គុបេក្ខា ។

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាបោធាតុនិទ្ទេសដូច្នេះ បទថា **អាបោគតំ** បានដល់ វត្ថុដែលឧបាទិន្នរូបជ្រួតជ្រាប នៅក្នុងអាបោធាតុទាំងអស់មានលក្ខណៈជាទឹកសើមជ្រួតជ្រាប ។ ពាក្យដែលគប្បីពោលក្នុងបទថា **បិត្តំ សេម្ហំ** ជាដើមទាំងអស់ ព្រមទាំងន័យរបស់ភាវនា បានពោលហើយ ក្នុងវិសុទ្ធិមគ្គ ។ បទថា **បកុប្បតិ** បានដល់ ហូរទៅ ដោយភាពជាឱឃៈ ឬហូរ

អំពីសមុទ្រទៅ ។ ទឹកនេះ មានការកម្រើកជាប្រក្រតីដូច្នេះ ។ កាលលោកវិនាសទៅដោយអាបោធាតុ សែននៃកោដិចក្រវាល ក៏ពេញទៅដោយទឹកនោះឯង ។ បទថា **ឱគ្គច្ឆន្តិ** សេចក្តីថា ហូរទៅខាងក្រោម ដល់នូវការវិនាសទៅ ដូចទឹកដែលលើកឡើងដាក់លើចង្ក្រាន ដូច្នោះ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតេជោធាតុនិទ្ទេសដូច្នេះ បទថា **តេជោគតំ** បានដល់ វត្ថុដែលជាឧបាទិន្នរូបទាំងអស់ ដែលនៅក្នុងតេជោធាតុទាំងអស់ មានលក្ខណៈក្តៅ ។ ម្យ៉ាងទៀត ឈ្មោះថា **តេជោគតំ** ព្រោះនៅក្នុងសភាវៈដែលក្តៅ គឺតេជោធាតុ ។ ក្នុងអាបោធាតុខាងដើមក្តី ក្នុងវាយោធាតុខាងក្រោយក្តី ក៏មានន័យនេះដូចគ្នា ។ បទថា **យេន ច** បានដល់ ដោយតេជោធាតុឯណា កាលតេជោធាតុនោះកម្រើក កាយក៏កើតកម្តៅ ដោយសភាវៈដែលគ្រាំគ្រាទៅអស់មួយថ្ងៃជាដើម ។ បទថា **យេន ច ជីរិយតិ** បានដល់ កាយនេះ រមែងទ្រុឌទ្រោមដោយតេជោធាតុណា បុគ្គលក៏មានឥន្ទ្រិយទន់ខ្សោយ អស់កម្លាំង ស្បែកជ្រីវជ្រួញ សក់ស្កូវជាដើម ដោយតេជោធាតុនោះ ។ បទថា **យេន ច បរិឌយ្ហតិ** សេចក្តីថា កាយនេះរមែងក្តៅដោយតេជោធាតុណា ដែលកម្រើកហើយ បុគ្គលនោះស្រែករើរវាយថា ក្តៅ ក្តៅ រមែងបំណងនូវការលាបដោយសប្បិ ចន្ទន៍ទេស និងចន្ទន៍ក្រហមផ្សំដោយសប្បិ ១០០ ដង និងខ្យល់ដែលកើតអំពីការបក់ដោយផ្លិតស្លឹកត្នោត ។ បទថា **យេន ច អសិតំ បីតំ ខាយិតំ សាយិតំ សម្មាបរិណាមំ**

**គច្ឆតិ** សេចក្តីថា បាយជាដើមដែលបរិភោគក្តី ទឹកជាដើម ដែលផឹកហើយក្តី ម្សៅ និងរបស់ទំពាជាដើម ដែលទំពាហើយក្តី ស្វាយទុំ ទឹកឃ្មុំ និងទឹកអំពៅជាដើម ដែលលិទ្ធក្តី រមែងឆ្អិនដោយប្រពៃ គឺរមែងផ្លាស់ប្តូរទៅជារសជាដើមនោះឯង ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូច្នេះ ។ តែពាក្យដែលគប្បីពោលដោយពិស្តារទាំងអស់ ព្រមដោយការវិនិច្ឆ័យ បានពោលហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **ហរិតន្តំ** បានដល់ របស់ខៀវស្រស់នោះឯង អធិប្បាយថា តេជោធាតុអាស្រ័យស្មៅស្រស់ជាដើមក៏រលត់ ។ បទថា **បន្ថន្តំ** បានដល់ ផ្លូវធំនោះឯង ។ បទថា **សេលន្តំ** បានដល់ ភ្នំ ។ បទថា **ឧទកន្តំ** បានដល់ ទឹក ។ បទថា **រមណីយំ វា ភូមិភាគំ** បានដល់ ភូមិភាគប្រាសចាកស្មៅ និងគុម្ពឈើជាដើម ជាទីទទេ បានដល់ ភូមិភាគដែលស្រឡះ ។ បទថា **អនាហារា** បានដល់ មិនមានអាហារ គឺមិនមានពូជ ។ លោកពោលគុណវិបត្តិ នៃតេជោធាតុតាមប្រក្រតី ដូច្នេះ ។ ក្នុងកាលវេលាដែលលោកវិនាសដោយតេជោធាតុ លោកធាតុក៏ឆេះមួយសែនកោដិចក្រវាលសូម្បីត្រឹមតែផេះក៏មិនទៅ សេសសល់ ។ បទថា **ន្ហារុទទ្ទុលេន** បានដល់ ដោយចំរៀករបស់ស្បែក ។ បទថា **អគ្គឹ គវេសន្តិ** សេចក្តីថា មនុស្សទាំងឡាយកាន់យករបស់តិចតួចបែបនេះហើយ ស្វែងរកភ្លើង ភ្លើងបានកម្តៅត្រឹមតែបន្តិចបន្តួច ក៏ឆេះរោមឡើង ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យមុននោះឯង ។

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវាយោធាតុនិទ្ទេសនេះ បទថា **ឧទ្ធង្គមាវាតា**

បានដល់ ខ្យល់ដែលបក់ឡើងខាងលើ ដែលប្រព្រឹត្តទៅដោយអាការ មានកើនិងផ្អើកជាដើម ។ បទថា **អធោគមា វាតា** បានដល់ ខ្យល់ដែលបក់ចុះខាងក្រោម មានការបន្ទោបង់ឧច្ចារបស្សាវៈជាដើម ។ បទថា **កុច្ឆិសយា វាតា** បានដល់ ខ្យល់ដែលបក់ចេញក្រៅពោះវៀនធំជាដើម ។ បទថា **កោដ្ឋាសយា វាតា** បានដល់ ខ្យល់ខាងក្នុងពោះវៀនធំ ។ បទថា **អង្គមង្គានុសារិនោ** បានដល់ ខ្យល់ដែលកើតអំពីការបត់អន្ទញ លាតសណ្តូកជាដើម ដែលផ្សាយទៅតាមអវយវៈតូចធំ ក្នុងរាងកាយទាំងមូល តាមសរសៃ ។ បទថា **អស្សាសោ** បានដល់ ខ្យល់ដង្ហើមចូល ។ បទថា **បស្សាសោ** បានដល់ ខ្យល់ដង្ហើមចេញ ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបប្រមាណប៉ុណ្ណោះ ។ តែកាលពោលដោយពិស្តារ ពាក្យដែលគប្បីពោលទាំងអស់នោះ មួយអន្លើដោយការនាន័យ បានពោលហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **គាមម្បិ វហតិ** បានដល់ បក់បោកស្រុកទាំងអស់ឲ្យល្អិតខ្ទេចខ្ទីទៅ ។ សូម្បីក្នុងនិគមជាដើម ក៏មានន័យដូចគ្នា ។ កាលលោករមែងវិនាសដោយខ្យល់នេះ លោកសម្តែងការផ្លាស់ប្តូរនៃវាយោធាតុ ដោយអំណាចការកម្ចាត់សែនកោដិចក្រវាល ។ បទថា **វិធូបនេន** បានដល់ បក់បោកភ្លើងទៅ ។ បទថា **ឱស្សវនេ** បានដល់ សំយាបផ្ទះ ទឹកដែលហូរចុះតាមសំយាបផ្ទះនោះ ព្រោះដូច្នោះ លោកហៅសំយាបផ្ទះនោះថា **ឱស្សវន** ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបដោយន័យមុននោះឯង ។

[ ៨៤ ] ក្នុងបទថា **សេយ្យថាបិ អាវុសោ** នេះ លោកសម្តែងដល់អ្វី ។

លោកសម្តែងដល់មហាភូតរូប ដែលពោលហើយអំពីខាងដើមថា មិនមែនសត្វ ។ បទថា **កដ្ឋំ** បានដល់ ទព្វសម្ភារៈ ។ បទថា **វល្លី** បានដល់ វល្លិសម្រាប់ចង ។ បទថា **តិណំ** បានដល់ ស្មៅសម្រាប់ប្រក់ ។ បទថា **មត្តិកំ** បានដល់ ដីសម្រាប់បូក ។ បទថា **អាកាសោ បរិវារិតោ** សេចក្តីថា ឱកាសទទេ ដែលនៅជុំវិញឈើជាដើមនោះ ទាំងខាងក្នុង និងខាងក្រៅ ។ បទថា **អគ្គារំ** ក្នុងបទថា **អគ្គារំត្វេវ សង្ខំ គច្ឆតិ** ត្រឹមតែជាបញ្ញត្តិ ។ តែកាលឈើជាដើមចែកចេញជាគំនរៗគំនរឈើលោកហៅថា **កដ្ឋរាសិ វល្លិរាសិ** ទាំងអស់ ។ បទថា **ឯវមេវ ខោ** សេចក្តីថា ឱកាសដែលនៅជុំវិញ ឆ្អឹងជាដើម ទាំងខាងក្នុង ខាងក្រៅ អាស្រ័យឆ្អឹងជាដើមនោះ ទើបរាប់ថា រូបទាំងនោះ ដូច្នោះដូចគ្នា ។

ផ្ទះដែលអាស្រ័យឈើជាដើម ឈ្មោះថា **គេហា** លោកហៅថា **ខត្តិយគេហា ព្រាហ្មណគេហា** យ៉ាងណា សូម្បីរូបក៏ដូច្នោះដូចគ្នា លោកហៅថា **ខត្តិយសរីរ ព្រាហ្មណសរីរ** ។ ពិតហើយ ក្នុងទីនេះ សភាវៈណាមួយ ដែលឈ្មោះថា **សត្វ** ឬ **ជីវ** មិនមាន ។ សួរថា ពាក្យថា **អជ្ឈត្តិកញ្ចេ អាវុសោ ចក្ខុ** នេះ លោកផ្តើមព្រោះហេតុអ្វី ឆ្លើយថា ឧបាទាយរូប អរូបក្ខន្ធ ៤ និងអរិយសច្ច ៣ លោកមិនបានពោលខាងដើម ឥឡូវនេះ កាលពោលឧបា-ទាយរូបទាំងនោះជាដើម ទើបលោកផ្តើមទេសនានេះ ។ បណ្តាបទទាំងនោះ បទថា **ចក្ខុ អបរិភិន្នំ** បានដល់ កាលចក្ខុបសាទរលត់ទៅក្តី ត្រូវអារម្មណ៍ខាងក្រៅមករារាំងក្តី ត្រូវប្រមាត់ស្លេស្ម និងឈាមរួបរឹតក្តី ចក្ខុបសាទមិន

អាចជាបច្ច័យដល់ចក្ខុវិញ្ញាណបាន ត្រឹមតែឈ្មោះថា បែកទៅប៉ុណ្ណោះ តែអាចជាបច្ច័យដល់ចក្ខុវិញ្ញាណ ឈ្មោះថា **អបរិភិន្ន** គឺមិនបែកទៅ ។ បទថា **ពាហិរា ច រូបា** បានដល់ រូបដែលមានសមុដ្ឋាន ៤ ខាងក្រៅ ។ បទថា **តជ្ជោ សមន្នាហារោ** បានដល់ អាស្រ័យចក្ខុនោះ និងរូប ពិចារណាដល់ភវង្គ ហើយកើតមនសិការ អធិប្បាយថា កិរិយាមនោធាតុចិត្តក្នុងចក្ខុទ្វារ អាចពិចារណាដល់ភវង្គ កិរិយាមនោធាតុចិត្តនោះ មិនមានដល់បុគ្គលដែលបញ្ជូនចិត្តទៅក្នុងទីដទៃ ព្រោះរូបារម្មណ៍មិនប្រាកដ ។ បទថា **តជ្ជស្ស** បានដល់ សមគួរដល់ចិត្ត ។ បទថា **វិញ្ញាណភាគស្ស** បានដល់ ចំណែកនៃវិញ្ញាណ ។ លោកសម្តែងសច្ចៈ ៤ ដោយអាការ ១២ ក្នុងបទថា **យថា-ភូតស្ស** ជាដើម ។ បណ្តាបទទាំងនោះ បទថា **យថាភូតស្ស** សេចក្តីថា កើតព្រមដោយចក្ខុវិញ្ញាណ គឺដល់ព្រមដោយចក្ខុវិញ្ញាណ ។ បទថា **រូបំ** សេចក្តីថា រូបដែលមានសមុដ្ឋាន ៣ រមែងបានក្នុងខណៈចក្ខុវិញ្ញាណ ព្រោះចក្ខុវិញ្ញាណ ជាតួធ្វើឲ្យរូបកើត សូម្បីរូបដែលមានសមុដ្ឋាន ៤ រមែងបានក្នុងចិត្តក្ខណៈបន្ទាប់អំពីនោះ ។ បទថា **សង្គហំ គច្ឆតិ** ប្រែថា ដល់នូវការរាប់ ។ ចេតសិកធម៌ មានវេទនាជាដើម ក៏សម្បយុត្តដោយចក្ខុវិញ្ញាណដូចគ្នា ។ វិញ្ញាណ គឺចក្ខុវិញ្ញាណនោះឯង ។ លោកពោលចេតនាថា សង្ខារក្នុងពាក្យនេះ ។ បទថា **សង្គហោ** ប្រែថា រួមគ្នា ។ បទថា **សន្និបាតោ** ប្រែថា មកព្រមគ្នា ។ បទថា **សមវាយោ** បានដល់ គំនរ ។ បទថា **យោ បដិច្ចសមុប្បាទំ បស្សតិ** បានដល់ បុគ្គលណាឃើញបច្ច័យទាំងឡាយ ។

បទថា **សោ ធម្មំ បស្សតិ** បានដល់ បុគ្គលនោះឈ្មោះថា ឃើញបដិច្ចសមុប្បន្នធម៌ ។ ពាក្យទាំងពួងមានឆន្ទៈជាដើម ជាវេវចនៈរបស់តណ្ហានោះឯង ។ ពិតហើយ តណ្ហា លោកហៅថា **ឆន្ទ** ព្រោះធ្វើនូវការពេញចិត្ត ហៅថា **អាលយ** ព្រោះធ្វើនូវការជាប់ជំពាក់ ហៅថា **អនុនយ** ព្រោះធ្វើការត្រេកអរ ហៅថា **អជ្ឈោសាន** ព្រោះលេប ។ បទថា **ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ** ជាឈ្មោះរបស់ព្រះនិព្វានទាំងអស់ ។ ក្នុងព្រះបាលី សច្ចៈមក ៣ ប៉ុណ្ណោះ គួរនាំមគ្គសច្ចមករួមផង ដោយប្រការដូច្នេះ ។ ក្នុងឋានៈទាំង ៣ នេះ ទិដ្ឋិ សង្កប្ប វាចា កម្មន្តៈ អាជីវៈ វាយាមៈ សតិ សមាធិ ភាវនា បដិវេធ នេះឈ្មោះថា មគ្គ ។ បទថា **ពហុកតំ ហោតិ** សេចក្តីថា ដោយអធិប្បាយមានប្រមាណប៉ុណ្ណោះ ក៏ឈ្មោះថា ធ្វើតាមពាក្យប្រៀនប្រដៅនៃព្រះមានព្រះភាគដ៏ច្រើន ។ សូម្បីក្នុងវារៈជាដើមថា **អជ្ឈត្តិកំ ចេ អាវុសោ សោតំ** ក៏មានន័យដូចគ្នា ។ ឯក្នុងមនោទ្វារ ភវង្គចិត្ត ឈ្មោះថា ចិត្តខាងក្នុង ភវង្គចិត្តនោះសូម្បីរលត់ទៅ មិនអាចជាបច្ច័យនៃអាវជ្ជនចិត្តបាន ភវង្គចិត្តដែលមានកម្លាំងទន់ខ្សោយ សូម្បីកំពុងប្រព្រឹត្តទៅ ក៏ឈ្មោះថា បែកធ្លាយហើយ ដែលអាចជាបច្ច័យរបស់អាវជ្ជនចិត្ត ឈ្មោះថា មិនបែកធ្លាយ ។ បទថា **ពាហិរា ច ធម្មា ។បេ។ នេវ តាវ តជ្ជស្ស** នេះ លោកពោលដោយសម័យភវង្គចិត្តប៉ុណ្ណោះ ។ ក្នុងវារៈទី ២ លោកពោលសំដៅយកភិក្ខុដែលបញ្ជូនចិត្តទៅក្នុងទីដទៃ ដោយពិចារណាឈានដែលស្ទាត់ជំនាញ ដាក់ចិត្តក្នុង

កម្មដ្ឋានដែលស្អាត់ជំនាញហើយ ឬទន្ទេញពុទ្ធវចនៈ ដែលជំនាញជាដើម ។ រូបសូម្បីមានសមុដ្ឋាន ៤ ក៏បានឈ្មោះថា រូប ក្នុងវារៈនេះ ។ ព្រោះមនោ-វិញ្ញាណរមែងឲ្យរូបកើតឡើង ។ ចេតសិកធម៌ មានវេទនាជាដើម ក៏សម្បយុត្តដោយមនោវិញ្ញាណ ។ វិញ្ញាណ គឺមនោវិញ្ញាណនោះឯង ។ តែក្នុងទីនេះ សង្ខារទាំងឡាយ លោកកាន់យកដោយផស្សចេតនាដូចគ្នា ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយនោះចុះ ។

ដូច្នោះ ព្រះមហាថេរៈ កាលពិចារណាចំពោះឯកទេសខាងដើម ទើបយកមកតាំងទុកក្នុងទីនេះ ហើយសម្តែងចែកទេសនាដែលមិនបរិបូណ៌ទាំងអស់ខាងដើម ដោយអំណាចទ្វារ សូត្រក៏ចប់តាមលំដាប់អនុសន្ធិដូច្នេះ ។៚

**មហាហត្ថិបទោបមសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## មហាសារោបមសូត្រទី ៩

[ ៨៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ កាលដែលទេវទត្តចៀសចេញទៅ មិនយូរប៉ុន្មាន ព្រះមានព្រះភាគទ្រង់ប្រារព្ធទេវទត្ត ត្រាស់ហៅភិក្ខុទាំង-ឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះក៏មានសេចក្តីពេញចិត្ត មានតម្រិះដ៏បរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុល-បុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះថា អាត្មាអញជាអ្នកបានលាភសក្ការៈ និងសេចក្តីសរសើរ ចំណែកភិក្ខុទាំងឡាយឯទៀតៗ នេះ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះយសសក្តិ ។ កុលបុត្រនោះតែងស្រវឹង វង្វេង ដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់

ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលង ខ្លឹម ស្រាយ សម្បក ក្រមរ ហើយកាត់យកតែមែក និងស្លឹកមក សម្គាល់ថា ខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ ក៏ និយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ហេតុដូច្នោះ បានជាបុរសដ៏ចម្រើននេះ ត្រូវការ ដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំ មានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយ សម្បក ក្រមរ ហើយ កាត់យកតែមែក និងស្លឹកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារ ណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើនោះ ការងារនោះ ក៏នឹងមិនសម្រេច ប្រយោជន៍ ដល់បុរសនោះឡើយ សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលភិក្ខុ ទាំងឡាយ ឧបមេយ្យដូចជាកុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ ចិត្ត គ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹត ហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះលុះបួសយ៉ាងនេះហើយ ក៏ញុាំងលាភសក្ការៈ និងសេចក្តីសរសើរ ឲ្យកើតឡើង ។ កុលបុត្រនោះ ក៏មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ រមែងលើក តម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ

ថា អាត្មាអញជាអ្នកមានលាភសក្ការៈ និងសេចក្តីសរសើរ ចំណែកភិក្ខុទាំង-ឡាយដទៃនេះ មិនមានកេរ្តិ៍ឈ្មោះ យសសក្តិទេ ។ កុលបុត្រនោះ រមែងស្រវឹង វង្វេង ដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគត ហៅថា បានកាន់យកតែមែក និងសន្ទឹករបស់ព្រហ្មចរិយៈ ហើយដល់នូវការបន្ទរបន្ថយសេចក្តីព្យាយាម ដោយហេតុនោះ ។

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះទៀត ចេញចាកផ្ទះដោយសទ្ធា ចូលទៅកាន់ផ្នួសដោយគិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ ក៏មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ មិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុល-បុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសីលសម្បទានោះ ។

កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្ទះបន្ទាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា អាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកភិក្ខុទាំងឡាយដទៃៗ នេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ កុលបុត្រនោះ រមែងស្រវឹង វង្វេង ដល់នូវសេចក្តីប្រមាទ ដោយសីលសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ហើយ ក៏រំលងខ្លឹម ស្រាយ សម្បក ហើយកេះយកតែក្រមរមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះមិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ហេតុដូច្នោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ហើយ ក៏រំលងខ្លឹម ស្រាយ សម្បក ហើយកេះយកតែក្រមរមក សម្គាល់ថាខ្លឹមហើយចៀសចេញទៅ ការងារណា ដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើនោះ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ (សេចក្តីនេះមានឧបមាយ៉ាងណា ) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាកុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះដោយសទ្ធា ចូលទៅកាន់ផ្នួសដោយគិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះ

ថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសីលសម្បទានោះ ។ កុលបុត្រនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា អាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកភិក្ខុទាំងឡាយដទៃៗនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ កុលបុត្រនោះ ក៏ស្រវឹង វង្វេងដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា បានកាន់យកតែក្រមររបស់ព្រហ្មចរិយៈ ហើយដល់នូវការបន្ធូរបន្ថយសេចក្តីព្យាយាម ដោយហេតុនោះ ។

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ កុលបុត្រពួកខ្លះក្នុងសាសនានេះ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តី

ចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដឡើងបាន ។ កុលបុត្រនោះលុះបួសយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនបានលើកតម្កើងខ្លួនឯង មិនបានបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះទេ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះឡើយ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសីល-សម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ កុលបុត្រនោះ លើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះថា អាត្មាអញជាអ្នកមានចិត្តខ្ជាប់ខ្ជួន មានចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ ចំណែកភិក្ខុទាំងឡាយដទៃៗ នេះ មិនមានចិត្តខ្ជាប់ខ្ជួន មានចិត្តវិលវង្វេងៗ ។ កុលបុត្រនោះតែងស្រវឹង វង្វេង ដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំង-

ឡាយ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម រំលងស្រាយ ហើយស្មោះយកតែសម្បកមកសម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក ស្លឹកទេតើ ព្រោះហេតុនោះបុរសដ៏ចម្រើននេះ អ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹមរំលងស្រាយ ហើយស្មោះយកតែសម្បកមក សម្គាល់ថា ខ្លឹម ហើយចៀសចេញទៅ ការងារសំខាន់ណា ដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើនោះការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ( សេចក្តីនេះឧបមា យ៉ាងណាមិញ ) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចកុលបុត្រពួកខ្លះក្នុងសាសនានេះ បានចេញចាកផ្ទះ បួលទៅកាន់ផ្នួសដោយសទ្ធា គិតថាអាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួលសេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កុលបុត្រនោះលុះបួសយ៉ាងនេះហើយក៏ញ៉ាំង លាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ

ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ កុលបុត្រនោះ តែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះថា អាត្មាអញជាអ្នកមានចិត្តខ្ជាប់ខ្ជួន មានចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ ចំណែកភិក្ខុទាំងឡាយដទៃៗ នេះ ជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តវិលវេរផ្សេងៗ ។ កុលបុត្រនោះ ក៏ស្រវឹង វង្វេង ដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានកាន់យកតែសម្បកនៃព្រហ្មចរិយៈ ហើយដល់នូវការបន្ធូរបន្ថយសេចក្តីព្យាយាម ដោយហេតុនោះ ។

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត កុលបុត្រពួកខ្លះ ក្នុងសាសនានេះ បានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ

មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញ៉ាំងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ មិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះ មានសេចក្តីពេញចិត្តដោយសមាធិសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិ-សម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះ បរិបូណ៌ដោយញាណទស្សនៈនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះថា អាត្មាអញ បានស្គាល់ បានឃើញ ( នូវរូបល្អិត )

ចំណែកភិក្ខុទាំងឡាយឯទៀតៗ នេះ មិនបានស្គាល់ មិនបានឃើញ ( នូវរូបល្អិត ) ទេ ។ កុលបុត្រនោះតែងស្រវឹង វង្វេង ដល់នូវសេចក្ដីប្រមាទ ព្រោះញាណទស្សនៈនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ព្រោះហេតុនោះបានជាបុរសដ៏ចម្រើននេះ អ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ហើយចាំងយកតែស្រាយមក សម្គាល់ថា ខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ( សេចក្ដីនេះឧបមាយ៉ាងណាមិញ ) ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចកុលបុត្រពួកខ្លះ ក្នុងសាសនានេះ បានចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្ដេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ

និងសេចក្ដីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះ មិនមានសេចក្ដីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្ដីសរសើរនោះឡើយ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបន្អាប់អ្នកដទៃ ព្រោះលាភ-សក្ការៈ និងសេចក្ដីសរសើរនោះ ។ កុលបុត្រនោះ មិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្ដីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្ដីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះ មានសេចក្ដីពេញចិត្តដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្ទុះបន្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្ដីប្រមាទ ព្រោះសីល-សម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុល-បុត្រនោះ មានសេចក្ដីពេញចិត្តដោយសមាធិសម្បទានោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្ទុះបន្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ កុលបុត្រនោះ មិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្ដីប្រមាទ ព្រោះសមាធិសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះ មានសេចក្ដីពេញចិត្ត មានតម្រិះបរិបូណ៌ដោយញាណទស្សនៈនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯង បន្ទុះបន្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះថា អាត្មាអញបានដឹងបានឃើញ ( រូបល្អិត ) ចំណែកភិក្ខុទាំងឡាយដទៃៗ នេះ មិនបានដឹង មិនបានឃើញ ( រូបល្អិត ) ទេ ។ កុលបុត្រនោះ តែងស្រវឹង វង្វេង ដល់នូវ

សេចក្ដីប្រមាទ ព្រោះញាណទស្សនៈនោះ លុះប្រមាទហើយ រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានកាន់យកតែស្រាយរបស់ព្រហ្មចរិយៈ ហើយដល់នូវការបន្ធូរបន្ថយសេចក្ដីព្យាយាមដោយហេតុនោះ ។

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត កុលបុត្រពួកខ្លះក្នុងសាសនានេះ បានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្ដេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសយ៉ាងនេះហើយ ក៏បានញុំាងលាភ-សក្ការៈ និងសេចក្ដីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្ដីសរសើរនោះ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្ដីសរសើរនោះឡើយ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្ដីប្រមាទ ព្រោះលាភសក្ការៈ និងសេចក្ដីសរសើរនោះ លុះមិនប្រមាទហើយ រមែងបាននូវសីលសម្បទា ។ កុលបុត្រនោះពេញចិត្តដោយសីល-សម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្ដីប្រមាទ ព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវសមាធិសម្បទា ។ កុលបុត្រនោះពេញចិត្ត

ដោយសមាធិសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសមាធិ-សម្បទានោះ លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះពេញចិត្តដោយញាណទស្សនៈនោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះញាណ-ទស្សនៈនោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះញាណទស្សនៈនោះ លុះមិនប្រមាទហើយ រមែងបាននូវសមយវិមោក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីសាបសូន្យចាកសមយវិមុត្តិនោះ ដោយហេតុណា ហេតុនុ៎ះឯងរមែងមាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏ចាំងយកតែខ្លឹមមក ដឹងថា ខ្លឹមពិតហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះ ស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកប្រាកដ ព្រោះហេតុនោះបានជាបុរសដ៏ចម្រើននេះ ត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏ចាំងយកតែខ្លឹមម្យ៉ាង ដឹងថាជាខ្លឹមពិត ហើយចៀសចេញទៅ ការងារណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះនឹងសម្រេចប្រយោជន៍ដល់បុរសនោះពិត ( សេចក្តីនេះមានឧបមាយ៉ាងណា ) ម្នាលភិក្ខុទាំងឡាយ

ឧបមេយ្យដូចជាកុលបុត្រពួកខ្លះ ក្នុងសាសនានេះ បានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ កុលបុត្រនោះលុះបួសយ៉ាងនេះហើយ បានញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមិនពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះហើយ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភ-សក្ការៈ និងសេចក្តីសរសើនោះ លុះមិនប្រមាទហើយ រមែងបាននូវសីល-សម្បទា ។ កុលបុត្រនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែថាមិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទព្រោះសីលសម្បទានោះ លុះមិនប្រមាទហើយរមែងបាននូវសមាធិសម្បទា ... ។ កុលបុត្រនោះ ពេញចិត្តដោយសមាធិ-សម្បទានោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ កុលបុត្រនោះមិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះសមាធិសម្បទានោះ

លុះមិនប្រមាទហើយ រមែងបាននូវញាណទស្សនៈ ។ កុលបុត្រនោះ ពេញចិត្តដោយញាណទស្សនៈនោះ តែថា មិនមានតម្រិះបរិបូណ៌ទេ ។ កុលបុត្រនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះ ។ កុលបុត្រនោះ មិនស្រវឹង មិនវង្វេង មិនដល់នូវសេចក្តីប្រមាទ ព្រោះញាណទស្សនៈនោះ លុះមិនប្រមាទហើយ រមែងបាននូវអសមយវិមោក្ខ ( ធម៌ដែលរួចចាកកិលេស ឥតមានកំណត់កាលវេលា បានដល់នូវលោកុត្តរធម៌ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសាបសូន្យចាកអសមយវិមុត្តិនោះ ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ។

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មិនមែនមានលាភសក្ការៈនិងសេចក្តីសរសើរជាអានិសង្ស មិនមែនមានសីលសម្បទាជាអានិសង្ស មិនមែនមានសមាធិសម្បទាជាអានិសង្ស មិនមែនមានញាណទស្សនៈជាអានិសង្សតែប៉ុណ្ណោះទេ ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិការរួចចាកកិលេសនៃចិត្ត គឺអរហត្តផល ជាធម្មជាតិមិនកម្រើកណា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះមានអរហត្តផលនុ៎ះជាប្រយោជន៍ មានអរហត្តផលនុ៎ះជាខ្លឹម មានអរហត្តផលនុ៎ះជាទីបំផុត ។ ព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត បានត្រេកអរហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

**មហាសារោបមសូត្រទី ៩ ចប់**

# អដ្ឋកថា

## មហាសារោបមសូត្រ

[ ៨៥ ] មហាសារោបមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម គប្បីជ្រាបវិនិច្ឆ័យ ក្នុងមហាសារោបមសូត្រនោះដូចតទៅនេះ បទថា **អចិរបក្កន្តេ** សេចក្ដីថា កាលទេវទត្តភិក្ខុបំបែកសង្ឃ ធ្វើលោហិតុប្បាទកម្ម គឺធ្វើព្រះលោហិតឲ្យពុះពង ចៀសចេញទៅមិនយូរប៉ុន្មាន នាំបក្ខពួកដែលបែកទៅដោយភេទដើមរបស់ខ្លួន ។ ក្នុងបទថា **ឥធ ភិក្ខវេ ឯកច្ចោ កុល-បុត្តោ** លោកមិនបានកំណត់ថា កុលបុត្រឈ្មោះនោះក៏ពិត សូម្បីយ៉ាងនោះ ពាក្យនេះគប្បីជ្រាបថា លោកពោលសំដៅចំពោះទេវទត្តភិក្ខុប៉ុណ្ណោះ ។ ពិតហើយ ទេវទត្ត ឈ្មោះថា ជាកុលបុត្រដោយជាតិ ព្រោះកើតក្នុងវង្សព្រះបាទឱក្កាករាជ តាមវង្សមហាសម្មតរាជ ដែលមិនលាយឡំវង្សដទៃ ។ បទថា **ឱតិណ្ណោ** បានដល់ ជាតិរបស់បុគ្គលណានៅខាងក្នុងបុគ្គលនោះ ឈ្មោះថា ត្រូវជាតិគ្របសង្កត់ហើយ សូម្បីក្នុងជរាជាដើមក៏មានន័យនេះដូចគ្នា ។ បច្ច័យ ៤ ឈ្មោះថា លាភ ក្នុងពាក្យថា លាភ និងសក្ការៈជាដើម ។ បទថា **សក្ការោ** បានដល់ បច្ច័យទាំង ៤ នោះ ដែលគេរៀបចំល្អហើយ ។ បទថា **សិលោកោ** បានដល់ ការពោលសរសើរ ។ បទថា **អភិនិព្វត្តេតិ** បានដល់ ឲ្យកើត ។ បទថា **អប្បញ្ញាតា** សេចក្ដីថា មិនប្រាកដក្នុងស្ថានទីដែលជនទាំង ២ ស្ថិតនៅ រមែងមិនបានត្រឹមតែអាហារ និងគ្រឿងស្លៀកដណ្ដប់ ។ បទថា **អប្បេសក្ខា** បានដល់ ពួកដែលមិនមានបរិវារ មិនបានមនុស្សហែហម

ទៅខាងមុខ ឬខាងក្រោយ ។ បទថា **សារេន សារករណីយំ** បានដល់វត្ថុណាមួយ មានក្តៅ កង់ ទឹម និងទន្ត័លជាដើម ដែលគប្បីធ្វើដោយឈើខ្លឹម ។ បទថា **សាខាបលាសំ អគ្គហេសិ ព្រហ្មចរិយស្ស** សេចក្តីថា បច្ច័យ ៤ ឈ្មោះថា មែក និងស្លឹកនៃសាសនព្រហ្មចរិយៈ ដែលមានមគ្គផលជាខ្លឹម បានកាន់យកអំពីមែក និងស្លឹកនោះ ។ បទថា **តេន ច វោសានំ អាបាទិ** សេចក្តីថា ដោយហេតុនោះឯង ទើបទេវទត្តនោះ ឈប់ដោយយល់ថា មកទល់នឹងពេលនេះ អញជួបសារៈហើយ ។

[ ៨៨ ] បទថា **ញាណទស្សនំ អារាធេតិ** សេចក្តីថា ទេវទត្តភិក្ខុបានអភិញ្ញា ៥ ឯទិព្វចក្ខុនៅខាងចុងនៃអភិញ្ញា ៥ ទិព្វចក្ខុនោះ លោកពោលថា ញាណទស្សនៈក្នុងព្រះសូត្រនេះ ។ បទថា **អជានំ អបស្សំ វិហរន្តិ** សេចក្តីថា ភិក្ខុទាំងឡាយមិនដឹងរូបតូចៗ ណាមួយ ដោយហោច សូម្បីបិសាចដែលត្រាច់ទៅក្នុងគំនរសំរាមក៏មិនឃើញ ។

[ ៨៩ ] បទថា **អសមយវិមោក្ខំ អារាធេតិ** សេចក្តីថា កុលបុត្ររមែងត្រេកអរ រមែងឲ្យដល់ព្រម រមែងបានលោកុត្តរធម៌ ៩ ដែលលោកពោលយ៉ាងនេះ អសមយវិមោក្ខតើដូចម្តេច អសមយវិមោក្ខ គឺអរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថា អសមយវិមោក្ខ ។ ពិតហើយ សមាបត្តិដែលជាលោកិយ រមែងផុតចាកធម៌ដែលជាសត្រូវក្នុងខណៈដែលដល់អប្បនានោះឯង ព្រោះដូច្នោះ ទើបលោកិយសមាបត្តិនោះ លោកពោលថាជាសមយវិមោក្ខយ៉ាងនេះថា សមយវិមោក្ខតើដូចម្តេច គឺរូបាវចរសមាបត្តិ

៤ អរូបាវចរសមាបត្តិ ៤ នេះ ហៅថា សមយវិមោក្ខ ឯលោកុត្តរធម៌ រមែងផុតបានគ្រប់កាល ពិតហើយ មគ្គចិត្ត និងផលចិត្ត ដែលផុតម្តង ក៏ឈ្មោះថា ផុតទៅរហូត និព្វានក៏ផុតហើយជាសមុច្ឆេទចាកកិលេសទាំងពួង ដោយចំណែកមួយ ព្រោះដូច្នោះ ទើបធម៌ទាំង ៩ នេះ លោកពោលថា **អសមយវិមោក្ខ** ។

[ ៩០ ] បទថា **អកុប្បា ចេតោវិមុត្តិ** បានដល់ វិមុត្តិសម្បយុត្តដោយអរហត្តផល ។ ប្រយោជន៍នៃព្រហ្មចរិយៈនោះមាន ព្រោះដូច្នោះ ទើបព្រហ្មចរិយៈនោះ ឈ្មោះថា **ឯតទត្ថ** គឺព្រហ្មចរិយៈនេះ មានអរហត្តផលនោះជាប្រយោជន៍ លោកអធិប្បាយថា ជាប្រយោជន៍នៃព្រហ្មចរិយៈនោះ ។ បទថា **ឯតំ សារំ** សេចក្តីថា អរហត្តមគ្គ និងអរហត្តផលនេះ ជាសារៈនៃព្រហ្មចរិយៈ ។ បទថា **ឯតំ បរិយោសានំ** សេចក្តីថា អរហត្តផលនេះជាទីបំផុតនៃព្រហ្មចរិយៈ នេះជាចុងក្រោយ មិនមានផលដែលគប្បីសម្រេចក្រៃលែងជាងនេះឡើយ ព្រោះដូច្នោះ ទើបលោកបញ្ចប់ទេសនាតាមអនុសន្ធិដូច្នេះឯង ៗ។

មហាសារោបមសូត្រ ចប់

សូត្រទី ៩ ចប់

# សុត្តន្តបិដក

## ចូឡសារោបមសូត្រទី ១០

[ ៩១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រាហ្មណ៍ឈ្មោះបិង្គលកោច្ឆៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ ហើយបញ្ចប់ពាក្យដែលគួរឲ្យកើតសេចក្តីរីករាយ គួរជាទីរឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ឈ្មោះបិង្គលកោច្ឆៈអង្គុយក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន សមណ-ព្រាហ្មណ៍ទាំងឡាយណា មានពួក មានគណៈ ជាអាចារ្យនៃគណៈ មានកេរ្តិ៍-ឈ្មោះយសសក្តិ ធ្វើលទ្ធិដូចជាកំពង់ ជនច្រើននាក់បានសន្មតថាជាមនុស្សត្រឹមត្រូវ គឺបូរណកស្សប ១ មក្ខលិគោសាល ១ អជិតកេសកម្ពល ១ បកុធកច្ចាយនៈ ១ សញ្ជយវេលដ្ឋបុត្ត ១ និគន្ថនាដបុត្ត ១ សមណព្រាហ្មណ៍ទាំងអស់នោះបានត្រាស់ដឹងដូចពាក្យប្តេជ្ញារបស់ខ្លួន ឬមិនបានត្រាស់ដឹងទាំងអស់គ្នាទេ ឬថាត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ កុំនិយាយឡើយ ពាក្យថា សមណព្រាហ្មណ៍ទាំងអស់នោះបានត្រាស់ដឹង ដូចពាក្យប្តេជ្ញារបស់ខ្លួន ឬមិនបានត្រាស់ដឹងទាំងអស់គ្នាទេ ឬថាត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ដូច្នេះនេះ ចូរលើកទុកសិនចុះ ម្នាលព្រាហ្មណ៍ តថាគតនឹងសម្តែងធម៌ដល់អ្នកវិញ ចូរអ្នកប្រុងស្តាប់ធម៌នោះ ចូរ

ធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ បិង្គលកោច្ឆព្រាហ្មណ៍ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះសមណៈដ៏ចម្រើន ។

[ ៩២ ] ព្រះមានព្រះភាគបានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលព្រាហ្មណ៍ ប្រៀបដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) រំលងខ្លឹម ស្រាយ សម្បក ក្រមរ ហើយកាត់យកតែមែក និងស្លឹកមកសម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងខ្លឹម ស្រាយ សម្បក ក្រមរ ហើយកាត់យកតែមែក និងស្លឹកមក សម្គាល់ថាខ្លឹមហើយចៀសចេញទៅ ការងារណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយ សម្បក ហើយកេះយកតែក្រមរមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះមិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ហេតុនោះបានជាបុរសដ៏ចម្រើន

នេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយ សម្បក ហើយកេះយកតែក្រមរមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ឬក៏ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយ ហើយស្ទុះយកតែសម្បកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយ ហើយស្ទុះយកតែសម្បកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណា ដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ពុំនោះសោត ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹម ឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយ និយាយយ៉ាងនេះថា ឱ

បុរសដ៏ចម្រើននេះ មិនស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកទេតើ ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ ពុំនោះសោត ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏ចាំងយកតែខ្លឹមមក ស្គាល់ថាខ្លឹមពិត ហើយចៀសចេញទៅ ។ បុរសមានចក្ខុបានឃើញបុរសនោះហើយនិយាយយ៉ាងនេះថា ឱ បុរសដ៏ចម្រើននេះ ស្គាល់ខ្លឹម ស្រាយ សម្បក ក្រមរ មែក និងស្លឹកមែន ហេតុនោះបានជាបុរសដ៏ចម្រើននេះ ជាអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏ចាំងយកតែខ្លឹមមក ស្គាល់ច្បាស់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះក៏នឹងសម្រេចប្រយោជន៍ដល់បុរសនោះ ។

[ ៩៣ ] ម្នាលព្រាហ្មណ៍ សេចក្តីដែលពោលមកហើយនេះ ក៏ដូចគ្នានឹងកុលបុត្រពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា ដោយគិតថា អាត្មាអញជាអ្នកមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់

ហើយ ឈ្មោះថា មានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ កុលបុត្រនោះ លុះបួសរួចយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ កុលបុត្រនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ កុលបុត្រនោះ រមែងលើកតម្កើងខ្លួនឯងបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះថា អាត្មាអញជាអ្នកមានលាភសក្ការៈ និងសេចក្តីសរសើរ ចំណែកភិក្ខុទាំងឡាយដទៃៗនេះ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះយសសក្តិទេ ។ ធម៌ទាំងឡាយដទៃណា ដែលជាធម៌ដ៏លើសលុប និងថ្លៃថ្លា ជាងលាភសក្ការៈ និងសេចក្តីសរសើរ កុលបុត្រនោះមិនបានញុំាងឆន្ទៈឲ្យកើតឡើង មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយសម្បក ក្រមរ ហើយកាត់យកតែមែក និងស្លឹកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

[ ៩៤ ] ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងសាសនានេះ ចេញចាកផ្ទះបួលកាន់ផ្នួសដោយសទ្ធា ដោយគិតថា អាត្មាអញមានជាតិ ជរា

មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថា ជាអ្នកមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ បុគ្គលនោះលុះបួសរួចយ៉ាងនេះហើយ រមែងញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ បុគ្គលនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងលាភសក្ការៈ និងសេចក្តីសរសើរ បុគ្គលនោះ រមែងញុំាងឆន្ទៈឲ្យកើតឡើង រមែងព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសីលសម្បទានោះ ។ បុគ្គលនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះថា អាត្មាអញជាអ្នកមានសីល មានធម៌ល្អ ចំណែកភិក្ខុទាំងឡាយដទៃៗនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមាន

ខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ស្រាយ សម្បក ហើយកេះយកតែក្រមរមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះ ក៏នឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

[ ៩៥ ] ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងសាសនានេះ ។បេ។ គប្បីធ្វើនូវទីបំផុតឲ្យប្រាកដបាន ។ បុគ្គលនោះ លុះបួសរួចយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើតឡើង ។ បុគ្គលនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃព្រោះលាភសក្ការៈ និងសេចក្តីសរសើរនោះឡើយ ។ ធម៌ទាំងឡាយដទៃណាជាធម៌ដ៏លើសលុប និងថ្លៃថ្លា ជាងលាភសក្ការៈនិងសេចក្តីសរសើរ បុគ្គលនោះរមែងញុំាងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្តីពេញចិត្តដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះរមែងញុំាងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិន

រួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសមាធិសម្បទា ។ បុគ្គលនោះមានសេចក្ដីពេញចិត្ត មានតម្រិះបរិបូណ៌ដោយសមាធិសម្បទានោះ ។ បុគ្គលនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃព្រោះសមាធិសម្បទានោះថា អាត្មាអញជាអ្នកមានចិត្តខ្ជាប់ខ្ជួន មានចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ ឯភិក្ខុទាំងឡាយដទៃៗ នេះ មិនមានចិត្តខ្ជាប់ខ្ជួន មានចិត្តវិលវេង្វេងៗ ។ ធម៌ទាំងឡាយដទៃណាជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងសមាធិសម្បទា បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹម ឋិតនៅ ( ចំពោះមុខ ) ក៏វិលងខ្លឹម ស្រាយហើយស្មោះយកតែសម្បកមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះ ត្រូវធ្វើដោយខ្លឹមឈើ ការងារនោះនឹងមិនសម្រេចប្រយោជន៍ ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

[ ៩៦ ] ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងសាសនានេះ ចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈគ្របសង្កត់ហើយ ។បេ។ នឹងធ្វើនូវទីបំផុតឲ្យប្រាកដបាន ។ បុគ្គលនោះ លុះបួសរួចយ៉ាងនេះហើយ ក៏ញុំាងលាភសក្ការៈ និងសេចក្ដីសរសើរឲ្យកើតឡើង ។ បុគ្គលនោះមិនមានសេចក្ដីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ

និងសេចក្ដីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះលាភសក្ការៈ និងសេចក្ដីសរសើរនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងលាភសក្ការៈនិងសេចក្ដីសរសើរ បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសីលសម្បទា ។ បុគ្គលនោះមានសេចក្ដីពេញចិត្តដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណាជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងសីលសម្បទា បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសមាធិសម្បទា ។ បុគ្គលនោះមានសេចក្ដីពេញចិត្ត ដោយសមាធិសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងសមាធិសម្បទា បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវញាណទស្សនៈ ។ បុគ្គលនោះ មានសេចក្ដីពេញចិត្ត មានតម្រិះបរិបូណ៌ដោយញាណទស្សនៈនោះ ។ បុគ្គលនោះរមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះ

ញាណទស្សនៈនោះថា អាត្មាអញជាអ្នកបានដឹង បានឃើញ ( រូបល្អិត ) ចំណែកភិក្ខុទាំងឡាយដទៃៗ នេះ ជាអ្នកមិនដឹង មិនឃើញ ( រូបល្អិត ) ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ បុគ្គលនោះមិនញុំាងឆន្ទៈឲ្យកើត មិនព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តរួញរា ប្រព្រឹត្តធូរថយផង ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹមឋិតនៅ ( ចំពោះមុខ ) ក៏រំលងខ្លឹម ហើយចាំងយកតែស្រាយមក សម្គាល់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវធ្វើដោយខ្លឹមឈើ ការងារនោះក៏នឹងមិនសម្រេចប្រយោជន៍ដល់បុរសនោះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

[ ៩៧ ] ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងសាសនានេះ ចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ឈ្មោះថាមានទុក្ខគ្របសង្កត់ហើយ មានទុក្ខរួបរឹតហើយ ធ្វើម្តេចហ្ន៎ នឹងធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ បុគ្គលនោះលុះបួសរួចយ៉ាងនេះហើយ តែងញុំាងលាភសក្ការៈ និងសេចក្តីសរសើរឲ្យកើត ។ បុគ្គលនោះមិនមានសេចក្តីពេញចិត្ត មិនមានតម្រិះបរិបូណ៌ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង

មិនបន្តុះបង្អាប់អ្នកដទៃ ដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លា ជាងលាភសក្ការៈ និងសេចក្តីសរសើរ បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើតឡើង ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសីលសម្បទា ។ បុគ្គលនោះ មានសេចក្តីពេញចិត្ត ដោយសីលសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសីលសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុបជាងសីលសម្បទានោះ បុគ្គលនោះ រមែងញ៉ាំងឆន្ទៈឲ្យកើតព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវសមាធិសម្បទា ។ បុគ្គលនោះ មានសេចក្តីពេញចិត្តដោយសមាធិសម្បទានោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះសមាធិសម្បទានោះ ។ ធម៌ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងសមាធិសម្បទា បុគ្គលនោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ បុគ្គលនោះរមែងបាននូវញាណទស្សនៈ ។ បុគ្គលនោះ មានសេចក្តីពេញចិត្តដោយញាណទស្សនៈនោះ តែមិនមានតម្រិះបរិបូណ៌ទេ ។ បុគ្គលនោះ មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះញាណទស្សនៈនោះ ។ ធម៌

ទាំងឡាយដទៃណា ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ បុគ្គល នោះរមែងញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ទាំងនោះ ផង ជាអ្នកមានការប្រព្រឹត្តមិនរួញរា ប្រព្រឹត្តមិនធូរថយផង ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយដូចម្តេច ដែលជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណ-ទស្សនៈ ។ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ដែលប្រកប ដោយវិតក្កវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ។ ម្នាល ព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កវិចារៈរួចហើយ ក៏បានដល់ នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តី ជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បានដល់នូវចតុត្ថជ្ឈាន ។ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏ លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយទៀត ភិក្ខុ ព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា ព្រោះអស់ទៅនៃបដិឃសញ្ញា ព្រោះមិនបាន ធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង បានដល់អាកាសានញ្ចា-យតនជ្ឈាន ដោយការពិចារណាថា អាកាសមិនមានទីបំផុតដូច្នេះ ។ ម្នាល ព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយវិញទៀត ភិក្ខុព្រោះប្រព្រឹត្តកន្លងនូវអាកាសានញ្ចា-

យតនជ្ឈានដោយប្រការទាំងពួង បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការពិចារណាថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។បេ។ ព្រោះប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈានដោយការពិចារណាថា អ្វីតិចតួចក៏មិនមានដូច្នេះ ។បេ។ ព្រោះប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ មួយវិញទៀត ភិក្ខុព្រោះប្រព្រឹត្តកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវសញ្ញាវេទយិតនិរោធ ។ អាសវៈទាំងឡាយរបស់ភិក្ខុនោះ រមែងអស់ទៅមិនមានសល់ ព្រោះបានឃើញច្បាស់ដោយបញ្ញា ។ ម្នាលព្រាហ្មណ៍ ធម៌នេះឯង ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយនេះឯង ជាធម៌ដ៏លើសលុប និងថ្លៃថ្លាជាងញាណទស្សនៈ ។ ម្នាលព្រាហ្មណ៍ ដូចបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើនោះ កាលបើឈើធំមានខ្លឹម ឋិតនៅ ( ចំពោះមុខ ) ក៏ចាំងយកតែខ្លឹមមក ដឹងច្បាស់ថាខ្លឹម ហើយចៀសចេញទៅ ការងារណាដែលបុរសនោះត្រូវការធ្វើដោយខ្លឹមឈើ ការងារនោះក៏នឹងសម្រេចប្រយោជន៍ដល់បុរសនោះ ។ ម្នាលព្រាហ្មណ៍ តថាគតពោលនូវបុគ្គលនេះថា ដូចជាបុរសនោះដែរ ។

[ ៩៨ ] ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះ មិនមែនមានត្រឹមតែលាភ-

សក្ការៈ និងសេចក្តីសរសើរជាអានិសង្សទេ មិនមែនមានត្រឹមតែសីល-សម្បទាជាអានិសង្សទេ មិនមែនមានត្រឹមតែសមាធិសម្បទាជាអានិសង្សទេ មិនមែនមានត្រឹមតែញាណទស្សនៈជាអានិសង្សទេ ដោយប្រការដូច្នេះឯង ម្នាលព្រាហ្មណ៍ ចេតោវិមុត្តិ ការរួចចាកកិលេសនៃចិត្ត គឺអរហត្តផល ជាធម៌មិនកម្រើកណា ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះ មានអរហត្តផលនុ៎ះជាប្រយោជន៍ មានអរហត្តផលនុ៎ះជាខ្លឹម មានអរហត្តផលនុ៎ះជាទីបំផុត ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ។ បិង្គលកោច្ឆ-ព្រាហ្មណ៍បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតរៀងទៅ ។

ចូឡសារោបមសូត្រទី ១០ ចប់

ឱបម្មវគ្គទី ៣ ចប់

## បញ្ជីរឿងនៃឱបម្មវគ្គនោះដូច្នេះ

រឿងមោលិយភិក្ខុ ដែលព្រះមានព្រះភាគ ទ្រង់គំរាមក្នុងកកចូបមសូត្រ ១ រឿងអរិដ្ឋភិក្ខុប្រកាន់មិច្ឆាទិដ្ឋិ ក្នុងអលគទ្ទូបមសូត្រ ១ រឿងកុមារកស្សបភិក្ខុនៅក្នុងអន្ធវ័ន ក្នុងវម្មិកសូត្រ ១ រឿងបុណ្ណភិក្ខុ ក្នុងរថវិនីតសូត្រ ១ រឿងបុគ្គលដាំដំណាំ ក្នុងនិវាបសូត្រ ១ រឿងសត្វម្រឹគដេកសង្កត់លើគំនរអន្ទាក់ ក្នុងបាសរាសិសូត្រ ១ រឿងប្រៀបមេដំរីឈ្មោះករេណុ ( មានធ្មេញក្បុំ ) ក្នុងចូឡហត្ថិបទោបមសូត្រ ១ រឿងស្នាមជើងដំរី ក្នុងមហាហត្ថិ-បទោបមសូត្រ ១ រឿងធម៌ដ៏ប្រសើរប្រៀបដូចខ្លឹមឈើ ក្នុងមហាសារោបម-សូត្រ ១ រឿងបិង្គលកោច្ឆព្រាហ្មណ៍ ក្នុងចូឡសារោបមសូត្រ ១ ។

# អដ្ឋកថា

## ចូឡសារោបមសូត្រទី ១០

[ ៩១ ] ចូឡសារោបមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម គប្បីជ្រាបវិនិច្ឆ័យក្នុងចូឡសារោបមសូត្រដូច្នេះ បទថា **បិង្គល-កោច្ឆោ** បានដល់ ព្រាហ្មណ៍ដែលមានធាតុលឿង ។ ពាក្យថា **កោច្ឆោ** នេះ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ព្រោះដូច្នោះ ទើបព្រាហ្មណ៍នោះ ហៅថា **បិង្គលកោច្ឆ** គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សង្ឃិនោ** ជាដើម សមណ-ព្រាហ្មណ៍ ឈ្មោះថា **សង្ឃិនោ** ព្រោះមានក្រុម ពោល គឺប្រជុំនៃអ្នកបួស ។ ឈ្មោះថា **គណិនោ** ព្រោះមានគណៈនោះឯង ។ ឈ្មោះថា **គណាចរិយា** ព្រោះជាអាចារ្យនៃគណៈ ដោយអំណាចអាចារសិក្ខាបទ ។ បទថា **ញាតា** បានដល់ បុគ្គលដែលគេស្គាល់ទូទៅ គឺដែលប្រាកដ បានដល់ ដែលគេលើកតម្កើង ដោយន័យជាដើមថា ជាអ្នកប្រាថ្នាតិច សន្ដោស មិនស្លៀកដណ្ដប់សូម្បីសំពត់ ព្រោះជាអ្នកប្រាថ្នាតិច ។ ឈ្មោះថា **យសស្សិនោ** ព្រោះជាបុគ្គលមានយស ។ បទថា **តិត្ថករា** ប្រែថា មេលទ្ធិ ។ បទថា **សាធុ-សម្មតា** បានដល់ ដែលចូលសមាបត្តិយ៉ាងនេះថា មនុស្សទាំងនេះ ជាបុគ្គលមានប្រយោជន៍ ជាមនុស្សល្អ ជាសប្បុរស ។ បទថា **ពហុជនស្ស** បានដល់ បុគ្គលមិនបានស្ដាប់ ជាបុថុជ្ជនអន្ធពាល ។

ឥឡូវនេះ កាលទ្រង់សម្ដែងបុគ្គលទាំងនោះ ទើបត្រាស់ថា **សេយ្យថីទំ បូរណោ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **បូរណោ** ជាឈ្មោះ

របស់មេលទ្ធិនោះ ដែលបញ្ញត្តខ្លួនថា ជាសាស្ដា ។ បទថា **កស្សបោ** ជាគោត្រ ។ បានឮថា មេលទ្ធិឈ្មោះបូរណៈនោះ ជាទាសៈគម្រប់ ១០០ របស់ត្រកូលមួយ ដែលមានទាសៈ ៩៩ នាក់ ។ ដោយហេតុនោះ ទើបមនុស្សទាំងឡាយដាក់ឈ្មោះឲ្យថា **បូរណោ** ព្រោះបូរណៈជាទាសៈមង្គល ទើបមិនមានបុគ្គលពោលថា គាត់ធ្វើកិច្ចដែលធ្វើបានលំបាក ឬមិនធ្វើកិច្ចដែលបុគ្គលណាគេមិនធ្វើ ។ បូរណៈគិតថា អញនៅក្នុងទីនេះធ្វើអ្វី ហើយក៏គេចទៅ ។ លំដាប់នោះ ពួកចោរបានដណ្ដើមយកសំពត់របស់គាត់ទៅ ។ គាត់មិនបិទបាំងដោយស្លឹកឈើ ឬស្មៅ ក៏ចូលទៅកាន់តំបន់មួយ ទាំងកាយអាក្រាតនោះឯង ។ ពួកមនុស្សឃើញគេហើយ គិតថា សមណៈនេះជាព្រះអរហន្ត ជាអ្នកប្រាថ្នាតិច បុគ្គលដែលស្មើនឹងសមណៈនេះមិនមាន ទើបកាន់យកបង្អែមនិងចម្អាបជាដើមចូលទៅរក ។ បូរណៈគិតថា រឿងនេះកើតឡើងព្រោះមិនស្លៀកសំពត់ តាំងអំពីនោះមក សូម្បីបានសំពត់ក៏មិនស្លៀក គេបានសមាទានការមិនស្លៀកសំពត់នោះឯងជាបព្វជ្ជា ។ បុគ្គលដទៃៗ ៥០០ នាក់ ក៏បួសក្នុងសម្នាក់របស់គេ លោកសំដៅយកមេលទ្ធិនោះ ទើបពោលថា បូរណកស្សប ។ បទថា **មក្ខលិ** ជាឈ្មោះនៃមេលទ្ធិនោះ ។ បទថា **គោសាលោ** ជាឈ្មោះទី ២ ព្រោះកើតក្នុងក្រោលគោ ។ បានឮថា គេកាន់ផ្ទាំងប្រេងកំពុងទៅលើផែនដី ដែលមានភក់ ចៅហ្វាយប្រាប់ថា ប្រយ័ត្នរអិល ។ គេរអិលដោយការធ្វេសប្រហែស ទើបរត់ទៅព្រោះខ្លាចម្ចាស់ ។ ចៅហ្វាយរត់ទៅចាប់សំពត់ទាន់ ។ គេបោលសំពត់ មិនមានសំពត់ជាប់ខ្លួនរត់ទៅ ។ ពាក្យ

ដ៏សេស ដូចគ្នានឹងមេលទ្ធិ ឈ្មោះបូរណៈនោះឯង ។ បទថា **អជិត** ជាឈ្មោះនៃមេលទ្ធិនោះ ។ គេឈ្មោះថា **កេសកម្ពល** ព្រោះស្លៀកសំពត់ដែលធ្វើអំពីសក់មនុស្ស ។ ហេតុនោះ ទើបរួមឈ្មោះទាំង ២ ចូលគ្នា ហៅថា **អជិតកេសកម្ពល** ។ ក្នុងពាក្យនោះ សំពត់កម្ពលដែលធ្វើដោយសក់មនុស្សឈ្មោះថា **កេសកម្ពល** ដែលឈ្មោះថា សំពត់អាក្រក់ជាងសំពត់កេស-កម្ពលនោះមិនមាន ។ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំពត់ទាំង-ឡាយណាមួយ ដែលគេត្បាញដោយតម្បាញ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុត ជាងសំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ ... ដូច្នេះ ។ បទថា **បកុធោ** ជាឈ្មោះនៃមេលទ្ធិនោះ ។ បទថា **កច្ចាយនោ** ជាគោត្រ ។ លោករួមឈ្មោះ និងគោត្រ ទើបហៅថា **បកុធ-កច្ចាយន** ។ មេលទ្ធិនោះ ជាអ្នកឃាត់ទឹកត្រជាក់ សូម្បីបន្ទោបង់ឧច្ចារៈ ក៏មិនប្រើទឹក ។ កាលបានទឹកក្តៅ ឬទឹកបាយ ទើបប្រើ ។ គាត់ដើរឆ្លងស្ទឹង ឬទឹកក្នុងផ្លូវ ក៏គិតថា សីលរបស់អញដាច់ហើយ ក៏ពូនខ្សាច់ធ្វើជាស្តូបអធិដ្ឋានសីល ទើបដើរតទៅទៀត បកុធកច្ចាយនៈនេះ ជាមេលទ្ធិដែលមិនមានសិរីបែបនេះ ។ បទថា **សញ្ជយោ** ជាឈ្មោះរបស់មេលទ្ធិនោះ ។ ឈ្មោះថា **វេលដ្ឋបុត្ត** ព្រោះជាកូនរបស់វេលដ្ឋៈ ។ មេលទ្ធិ ឈ្មោះថា **និគណ្ឋ** បានឈ្មោះដោយពោលយ៉ាងនេះថា ពួកយើងមិនមានកិលេសជា

គ្រឿងរួបរឹត មិនមានកិលេសជាគ្រឿងជាប់ជំពាក់ ពួកយើងវៀរចាកគ្រឿងរួបរឹត គឺកិលេស ។ ឈ្មោះថា **ឆាដបុត្ត** ព្រោះជាកូនរបស់អ្នករបាំ ។ បទថា **អត្តញ្ញឹសុ** សេចក្តីថា សមណព្រាហ្មណ៍ដឹង មិនដឹងក៏ដោយ ពួកបុគ្គលនោះក៏ប្តេជ្ញា ។ លោកពោលពាក្យអធិប្បាយថា បើប្តេជ្ញានោះនៃពួកបុគ្គលនោះ ជានិយ្យានិកសោត បុគ្គលទាំងអស់ក៏ដឹង បើមិនជានិយ្យានិកសោត ពួកបុគ្គលទាំងនោះក៏មិនដឹង ព្រោះដូច្នោះ ទើបសេចក្តីនៃបញ្ហានោះ មានដូច្នេះថា ប្តេជ្ញារបស់ពួកបុគ្គលនោះ ជានិយ្យានិក ឬជាអនិយ្យានិក ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បដិសេធថា ម្នាលព្រាហ្មណ៍ កុំនិយាយឡើយ ព្រោះមិនមានប្រយោជន៍ ដោយការពោលដល់ពាក្យប្តេជ្ញាដែលជាអនិយ្យានិកនៃមេលទ្ធិទាំងនោះ កាលនឹងប្រកាសបទដែលមានប្រយោជន៍ដោយឧបមា ដើម្បីទ្រង់សម្តែងចំពោះធម៌ ទើបត្រាស់ពាក្យថា ម្នាលព្រាហ្មណ៍ តថាគតនឹងសម្តែងធម៌ដល់អ្នកវិញ ដូច្នេះជាដើម ។

[ ៩៤ ] បណ្តាបទទាំងនោះ បទថា **សច្ឆិកិរិយាយ** ប្រែថា ដើម្បីធ្វើឲ្យជាក់ច្បាស់ ។ បទថា **ន ឆន្ទំ ជនេតិ** សេចក្តីថា មិនឲ្យកើតការពេញចិត្តប្រាថ្នានឹងធ្វើ ។ បទថា **ន វាយមតិ** បានដល់ មិនធ្វើសេចក្តីព្យាយាមប្រឹងប្រែង ។ បទថា **ឱលីនវុត្តិកោ ច ហោតិ** បានដល់ ជាអ្នកមានអធ្យាស្រ័យឡេះឡោះ ។ បទថា **សាថិលិកោ** បានដល់ ជាអ្នករួញរា គឺជាអ្នកកាន់ សាសនាធូរថយ មិនធ្វើឲ្យធ្ងន់ ។ បទថា **៩ធ ព្រាហ្មណា ភិក្ខុ**

**វិវិច្ចេវ កាមេហិ** សួរថា ធម៌មានបឋមជ្ឈានទាំងនេះជាដើម ក្រៃលែងជាងញាណទស្សនៈបានដូចម្ដេច ពិតហើយ ធម៌ទាំងឡាយ មានបឋមជ្ឈានជាដើម ជាបាទនៃវិបស្សនា ឈ្មោះថា ទាបជាង ព្រោះធ្វើឲ្យជាបាទនៃនិរោធ ទើបធម៌ទាំងនេះ ឈ្មោះថា ជាបាទនៃនិរោធ ព្រោះដូច្នោះ គប្បីជ្រាបថា ញាណទស្សនៈនោះក្រៃលែងជាង ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់សូត្រនេះតាមអនុសន្ធិដោយប្រការដូច្នេះ ។ ក្នុងកាលចប់ទេសនា ព្រាហ្មណ៍ក៏តាំងនៅក្នុងសរណៈ ដូច្នេះ ៕៚

**ចូឡសារោបមសូត្រ ចប់**

**សូត្រទី ១០ ចប់ វគ្គវណ្ណនាទី ៣ ចប់**

# ក្បាលទី ១៨

# សុត្តន្តបិដក បាលីប្រែ -២០

## សន្ទឹកបង្អួលប្រាប់មាតិកា

*មាតិកា* *លេខទំព័រ*


**ចូឡសីហនាទសូត្រទី១** ........ ...... ...... ...... ...... ...... ....... ២

**អដ្ឋកថា ចូឡសីហនាទសូត្រ** ........ ...... ...... ...... ...... ...... ....... ១៤

**មហាសីហនាទសូត្រទី២** ........ ...... ...... ...... ...... ...... ...... ៤៩

**អដ្ឋកថា មហាសីហនាទសូត្រ** ...... ...... ...... ...... ...... ...... ....... ៨៨

*កម្លាំងកាយរបស់ព្រះតថាគត* ...... ...... ...... ...... ...... ....... ១០១

*អត្ថរបស់ ចក្ក សព្ទ* ........ ...... ...... ...... ...... ...... ...... ១០៤

*អត្ថរបស់ ព្រហ្មចរិយ សព្ទ* ........ ...... ...... ...... ...... ...... ....... ១៣១

**មហាទុក្ខក្ខន្ធសូត្រទី៣** ........ ...... ...... ...... ...... ...... ....... ១៥៦

**អដ្ឋកថា មហាទុក្ខក្ខន្ធសូត្រ** ........ ...... ...... ...... ...... ...... ....... ១៧៥

*អត្ថរបស់ គុណ សព្ទ* ........ ...... ...... ...... ...... ...... ....... ១៧៨

**ចូឡទុក្ខក្ខន្ធសូត្រទី៤** ........ ...... ...... ...... ...... ...... ....... ១៨៩

**អដ្ឋកថា ចូឡទុក្ខក្ខន្ធសូត្រ** ........ ...... ...... ...... ...... ...... ....... ២០៤

**អនុមានសូត្រទី៥** ........ ...... ...... ...... ...... ...... ....... ២១៤

**អដ្ឋកថា អនុមានសូត្រ** ........ ...... ...... ...... ...... ...... ...... ២៣៧

**ចេតោខីលសូត្រទី៦** ........ ...... ...... ...... ...... ...... ....... ២៤២

**អដ្ឋកថា ចេតោខីលសូត្រ** ........ ...... ...... ...... ...... ...... ....... ២៥២

**វនបត្ថសូត្រទី៧** ........ ...... ...... ...... ...... ...... ...... ២៦០

**អដ្ឋកថា វនបត្ថបរិយាយសូត្រ** ...... ...... ...... ...... ...... ....... ២៧១

**មធុបិណ្ឌិកសូត្រទី ៨** ........ ...... ...... ...... ...... ...... ...... ២៧៣

**អដ្ឋកថា មធុបិណ្ឌិកសូត្រ** ........ ...... ...... ...... ...... ...... ....... ២៨៩

**ទ្វេធាវិតក្កសូត្រទី ៩** ........ ...... ...... ...... ...... ...... ....... ៣០១

**អដ្ឋកថា ទ្វេធាវិតក្កសូត្រ** ........ ...... ...... ...... ...... ...... ....... ៣១៣

**វិតក្កសណ្ឋានសូត្រទី ១០** ....... ...... ...... ...... ...... ...... ......... ៣២៩

**អដ្ឋកថា វិតក្កសណ្ឋានសូត្រ** ........ ...... ...... ...... ...... ...... ....... ៣៣៩

*អំពីមនសិការនិមិត្តដទៃៗ* ........ ...... ...... ...... ...... ...... ....... ៣៤១

*លះមោហៈដោយធម៌ ៥* ........ ...... ...... ...... ...... ...... ....... ៣៤៣

*រឿងតិស្សសាមណេរ* ........ ...... ...... ...... ...... ...... ....... ៣៤៨

*រឿងទន្សាយផ្អើលផ្លែព្នៅ* ........ ...... ...... ...... ...... ...... ....... ៣៥១


## សុត្តន្តបិដក ចាលីប្រែ -២១


**កកចូបមសូត្រ ទី ១** ...... ...... ...... ...... ...... ...... ......៣៥៦

**អដ្ឋកថា កកចូបមសូត្រ** ...... ...... ...... ...... ...... ...... ......៣៧៤

*កម្រាស់ផែនដី* ...... ...... ...... ...... ...... ...... ......៣៨៥

**អលគទ្ទូបមសូត្រទី ២** ...... ...... ...... ...... ...... ...... ... ៣៩០

**អដ្ឋកថា អលគទ្ទូបមសូត្រ** ...... ...... ...... ...... ...... ...... .....៤២២

*អធិប្បាយអន្តរាយិកធម៌ ៥* ...... ...... ...... ...... ...... ...... ... ៤២២

*បរិយត្តិ ៣* ...... ...... ...... ...... ...... ...... .... ៤៣១

**វម្មិកសូត្រទី ៣** ...... ...... ...... ...... ...... ...... .... ៤៥៦

**អដ្ឋកថា វម្មិកសូត្រ** ...... ...... ...... ...... ...... ...... .... ៤៦៣

*អត្ថរបស់ អគ្គិកូន សព្ទ* ...... ...... ...... ...... ...... ...... ... ៤៧០

*អត្ថរបស់ វណ្ណ សព្ទ* ...... ...... ...... ...... ...... ...... ... ៤៧០

*អត្ថរបស់ កេវល សព្ទ* ...... ...... ...... ...... ...... ...... ... ៤៧២
*អត្ថរបស់ កប្ប សព្ទ* ...... ...... ...... ...... ...... ...... ... ៤៧៣
*អត្ថរបស់ ធូម សព្ទ* ...... ...... ...... ...... ...... ...... .... ៤៨១
**រថវិនីតសូត្រទី៤** ...... ...... ...... ...... ...... ...... ... ៤៩០
**អដ្ឋកថា រថវិនីតសូត្រ** ...... ...... ...... ...... ...... ...... .. ៥០៣
*អធិប្បាយ កថាវត្ថុ ១០* ...... ...... ...... ...... ...... ...... .. ៥១០
*សំសគ្គៈ ៥ យ៉ាង* ...... ...... ...... ...... ...... ...... .... ៥២០
**និវាបសូត្រ ទី៥** ...... ...... ...... ...... ...... ...... ... ៥៥០
**អដ្ឋកថា និវាបសូត្រ** ...... ...... ...... ...... ...... ...... .... ៥៦៩
**ចាសរាសិសូត្រទី៦** ...... ...... ...... ...... ...... ...... .... ៥៧៦
**អដ្ឋកថា ចាសរាសិសូត្រ** ...... ...... ...... ...... ...... ...... .. ៦១០
*រឿងឧបកាជីវក* ...... ...... ...... ...... ...... ...... .... ៦៥៦
**ចូឡហត្ថិបទោបមសូត្រ ទី៧** ...... ...... ...... ...... ...... ...... .... ៦៦៤
**អដ្ឋកថាចូឡហត្ថិបទោបមសូត្រ** ...... ...... ...... ...... ...... ..... ៦៨២
**មហាហត្ថិបទោបមសូត្រ ទី៨** ...... ...... ...... ...... ...... ...... ..... ៧២៧
**អដ្ឋកថា មហាហត្ថិបទោបមសូត្រ** ... ...... ...... ...... ...... ...... .... ៧៤៥
**មហាសារោបមសូត្រ ទី៩** ...... ...... ...... ...... ...... ...... ..... ៧៦៩
**អដ្ឋកថា មហាសារោបមសូត្រ** ...... ...... ...... ...... ...... ...... .... ៧៨៤
**ចូឡសារោបមសូត្រ ទី១០** ...... ...... ...... ...... ...... ...... .... ៧៨៧
**អដ្ឋកថា ចូឡសារោបមសូត្រ** ...... ...... ...... ...... ...... ...... ..... ៨០២